ផ្នែកទីមួយបង្ហាញខ្លះៗ អំពីការវិវត្តន៍ប្រព័ន្ធពាណិជ្ជកម្មពហុភាគី ចាប់តាំងពីពេលអនុម័ត GATT ឆ្នាំ១៩៤៨ និងការបង្កើត WTO នៅថ្ងៃទី ១ មករា ឆ្នាំ១៩៩៥ ព្រមទាំងពិពណ៌នាអំពីសារៈសំខាន់របស់ WTO នៅក្នុងសេដ្ឋកិច្ចបច្ចុប្បន្នដែលកំពុងឈានទៅរកសកលភាវូបនីយកម្មយ៉ាងលឿន ។ ផ្នែកទីពីរ រៀបរាប់សង្ខេបពីគោលការណ៍ និងវិធានចែងនៅក្នុងលិខិតុបករណ៍ច្បាប់ដែលបច្ចុប្បន្នបង្កើតបានជាប្រព័ន្ធ WTO ។ ផ្នែកទីបី រៀបរាប់ពិពណ៌នាយ៉ាងខ្លីអំពីការសន្យាធ្វើសេរីភាវូបនីយកម្មពាណិជ្ជកម្ម របស់បណ្តាប្រទេសនានានៅក្នុងកិច្ចប្រជុំនៅ Uruguay និងនៅក្នុងការចរចាក្រោយៗមកទៀត ។ ផ្នែកទីបួន ផ្តោតទៅលើការងារធ្វើឡើងក្នុងអំឡុងពេលពីឆ្នាំ ១៩៩៥ ដល់ ១៩៩៨ រួមទាំងសេចក្តីសំរេចនានាធ្វើឡើងនៅក្នុងសន្និសីទថ្នាក់រដ្ឋមន្ត្រីរបស់ WTO ចំនួនពីរ ដើម្បីបន្ថែមប្រធានបទថ្មីៗទៅក្នុងកម្មវិធីការងាររបស់ WTO សំរាប់សិក្សាបន្ថែមទៀត ព្រមទាំងសំណើដែលកំពុងស្ថិតក្នុងការពិចារណា សំរាប់ការបង្កើតឡើងជាយថាភាពនូវកិច្ចប្រជុំចរចាយ៉ាងទូលំទូលាយមួយនៅលើប្រធានបទផ្សេងៗជាច្រើន ។ បន្ទាប់មក នៅក្នុងផ្នែកទីប្រាំ មានការពន្យល់អំពីផលប៉ះពាល់នៃប្រព័ន្ធ WTO ចំពោះពាណិជ្ជកិច្ច ។ ផ្នែកនេះបញ្ជាក់ថា រដ្ឋាភិបាលធ្វើការចរចាអំពីលិខិតុបករណ៍ច្បាប់ និងការកែលំអការបើកទីផ្សារទៅកាន់ទីផ្សារបរទេស ជាចំបង គឺដើម្បីផលប្រយោជន៍នៃឧស្សាហកម្ម សហគ្រាសអាជីវកម្ម និងសហគមន៍ពាណិជ្ជកម្មរបស់ខ្លួន ។ ការទទួលខុសត្រូវជាមូលដ្ឋាន ទៅលើការទាញយកនូវផលប្រយោជន៍អំពីកាលានុវត្តភាពពាណិជ្ជកម្មថ្មីៗ ដែលត្រូវបានបង្កើតឡើងជាលទ្ធផលខាងលើ បច្ចុប្បន្នបានធ្លាក់ទៅលើសហគមន៍អាជីវកម្ម និងពាណិជ្ជកម្មនានាហើយ ។ ដើម្បីជួយពួកគេក្នុងការប្រែក្លាយកាលានុវត្តភាពនោះឱ្យទៅជារបៀបរបបអាជីវកម្មនានា និងនៅក្នុងការខិតខំជាមួយសំដៅអភិវឌ្ឍន៍ពាណិជ្ជកម្ម ប្រព័ន្ធច្បាប់ផ្តល់ដល់ពួកគេនូវការធានាបើកទីផ្សារ ព្រមទាំងបង្កើតសិទ្ធិមួយចំនួន ជាគុណប្រយោជន៍ចំពោះពួកគេផងដែរ ។ ប៉ុន្តែសមត្ថភាពរបស់គេ ក្នុងការទាញយកនូវផលប្រយោជន៍អោយបានទាំងស្រុងអំពីប្រព័ន្ធខាងលើអាស្រ័យទៅលើចំណេះ និងការយល់ដឹងរបស់គេជាសំខាន់អំពីវិធាននៃប្រព័ន្ធនោះ។

បញ្ជីបង្ហាញនូវផលប្រយោជន៍ និងសិទ្ធិនានាផ្តល់ដោយលិខិតុបករណ៍ច្បាប់នានាចំពោះ ឧស្សាហកម្ម និងសហគមន៍ពាណិជ្ជកម្មមានចែងនៅក្នុងឧបសម្ព័ន្ធ I នៃទិដ្ឋភាពរួមនេះ ។ ការសង្ខេបវិភាគទៅលើបទប្បញ្ញត្តិនៃប្រព្រឹត្តកម្មពិសេស និងដោយឡែកសំរាប់ប្រទេសកំពុងអភិវឌ្ឍន៍ និងប្រទេសក្រីក្រ ដែលបានបញ្ចូលទៅក្នុងកិច្ចព្រមព្រៀងផ្សេងៗ មានចែងនៅក្នុងឧបសម្ព័ន្ធ II ។

ប្រព័ន្ធ WTO និងការខិតខំសេដ្ឋកិច្ចជាសកល

ការវិវត្តន៍ប្រព័ន្ធពាណិជ្ជកម្មពហុភាគី

ប្រព័ន្ធពាណិជ្ជកម្មពហុភាគី ជាទូទៅ ត្រូវបានកំណត់ថាជាកំរងវិធានអន្តរជាតិ ដែលទាមទារឱ្យបណ្តាប្រទេសត្រូវគោរពតាមក្នុងការទំនាក់ទំនងពាណិជ្ជកម្មរវាងគ្នាទៅវិញទៅមក ។ គោលដៅជាមូលដ្ឋាននៃវិធាននេះ គឺជំរុញបណ្តាប្រទេសឱ្យអនុវត្តនយោបាយពាណិជ្ជកម្មសេរី និងបើកចំហរ ។ វិធានការណ៍នោះមានលក្ខណៈវិវត្តន៍ពុំឈប់ឈរ ។ វិធានដែលមានស្រាប់កំពុង

ត្រូវបានពិនិត្យបញ្ជាក់ និងធ្វើឱ្យសុក្រឹត្យ ដើម្បីអោយស្របទៅតាមល័ក្ខខ័ណ្ឌប្រែប្រួលរបស់ពាណិជ្ជកម្មពិភពលោក ។ ទន្ទឹមនោះគេបានបញ្ចូលនូវវិធានសំរាប់គ្រប់ដណ្តប់លើប្រធានបទថ្មីៗសំរាប់ដោះស្រាយបញ្ហា និងកិច្ចការផ្សេងៗដែលកំពុងជួបប្រទះ។

ការបង្កើតកិច្ចព្រមព្រៀងទូទៅស្តីពីពន្ធគយ និងពាណិជ្ជកម្ម (GATT)

បន្ទាប់ពីសង្គ្រាមលោកលើកទីពីរភ្លាម បណ្តាប្រទេសជាច្រើនបានខិតខំអនុម័តជាបន្តបន្ទាប់នូវវិធាន សំរាប់គ្រប់គ្រងទំនាក់ទំនងពាណិជ្ជកម្មអន្តរជាតិ ។ ការខិតខំនេះនាំមកនូវការអនុម័តកិច្ចព្រមព្រៀងស្តីពីពន្ធគយ និងពាណិជ្ជកម្ម (ឬ GATT) នៅឆ្នាំ ១៩៤៨ ។ វិធានរបស់ GATT អនុវត្តចំពោះពាណិជ្ជកម្មលើទំនិញ ។ ក្នុងអំឡុងឆ្នាំបន្តបន្ទាប់មកទៀត គេបានធ្វើការកែសំរួលអត្ថបទ GATT ដើម្បីដាក់បញ្ចូលនូវបទប្បញ្ញត្តិថ្មីៗ ជាពិសេសសំរាប់ដោះស្រាយបញ្ហាពាណិជ្ជកម្មរបស់បណ្តាប្រទេសកំពុងអភិវឌ្ឍន៍ ។ ក្រៅពីនេះ នៅមានការអនុម័តផងដែរ នូវកិច្ចព្រមព្រៀងពាក់ព័ន្ធមួយចំនួនទៀត ដែលបានរៀបចំឡើងដោយផ្អែកនៅលើបទប្បញ្ញត្តិសំខាន់ៗរបស់ GATT ។

កិច្ចប្រជុំនៅយូរ៉ូហ្គាយស្តីពីការចរចាពាណិជ្ជកម្ម

វិធាន GATT និងកិច្ចព្រមព្រៀងពាក់ព័ន្ធនានាត្រូវបានកែលំអជាបន្តបន្ទាប់ និង បានសំរបទៅតាមលក្ខខណ្ឌប្រែប្រួលរបស់ពាណិជ្ជកម្មពិភពលោក នៅក្នុងកិច្ចប្រជុំនៅយូរ៉ូហ្គាយស្តីពីការចរចាពាណិជ្ជកម្ម ធ្វើឡើងពីឆ្នាំ ១៩៨៦ ដល់១៩៩៤ ។ អត្ថបទរបស់ GATT រួមនឹងសេចក្តីសំរេចធ្វើឡើងក្រោម GATT នាអំឡុងពេលកន្លងមក ព្រមទាំងកិច្ចយោគយល់គ្នាផ្សេងៗ ធ្វើឡើងនៅក្នុងកិច្ចប្រជុំនៅយូរូហ្គាយ ត្រូវបានស្គាល់ថាជា GATT ១៩៩៤។ មានការអនុម័តកិច្ចព្រមព្រៀងដោយឡែកៗ មួយចំនួននៅក្នុងវិស័យដូចជា កសិកម្ម វាយនភ័ណ្ឌ ការឧបត្ថម្ភធន ការប្រឆាំងនឹងការលក់បង្ខូចថ្លៃ ការការពារ និងបញ្ហាផ្សេងៗទៀត ហើយកិច្ចព្រមព្រៀងដែលបានរៀបរាប់មកនេះបូកផ្សំជាមួយ GATT ១៩៩៤ បង្កើតបានជាសមាសធាតុនៃកិច្ចព្រមព្រៀងពហុភាគីស្តីពីពាណិជ្ជកម្មលើទំនិញ ។ កិច្ចប្រជុំនៅយូរ៉ូហ្គាយ ក៏បាននាំមកនូវការអនុម័តវិធានអំពីពាណិជ្ជកម្មលើសេវាកម្ម និងទិដ្ឋភាពពាណិជ្ជកម្មពាក់ព័ន្ធនឹងច្បាប់ស្តីពីកម្មសិទ្ធិបញ្ញាដែរ ។

ប្រព័ន្ធ WTO

សមិទ្ធិផលមួយក្នុងចំណោមសមិទ្ធិផលផ្សេងទៀតគឺ ការបង្កើតនូវ WTO ។GATT ដែលដឹកនាំចរចាទាំងប៉ុន្មាននេះ ចុងក្រោយលែងជាអង្គការដាច់ដោយឡែកទៀតហើយ ព្រោះបន្ទាប់មកបានក្លាយទៅជាអង្គការ WTO តែមួយវិញ ។

ប្រព័ន្ធ WTO ដូចដែលបានកើតឡើងពីកិច្ចប្រជុំនៅយូរូហ្គាយបច្ចុប្បន្នរួមមានកិច្ចព្រមព្រៀងជាសារធាតុសំខាន់ៗដូចតទៅ ÷

- ☐ កិច្ចព្រមព្រៀងពហុភាគីស្តីពីពាណិជ្ជកម្មលើទំនិញ រួមទាំងកិច្ចព្រមព្រៀងទូទៅស្តីពីពន្ធគយ និងពាណិជ្ជកម្ម (GATT១៩៩៤) និងកិច្ចព្រមព្រៀងពាក់ព័ន្ធនានា ។
- ☐ កិច្ចព្រមព្រៀងទូទៅស្តីពីពាណិជ្ជកម្មលើសេវាកម្ម (GATS)។
- ☐ កិច្ចព្រមព្រៀងស្តីពីទិដ្ឋភាពពាណិជ្ជកម្មពាក់ព័ន្ធនឹងច្បាប់ស្តីពីកម្មសិទ្ធិខាងបញ្ញា (TRIPS) ។

វណ្ឌ ១ មានរាយនាមលិខិតុបករណ៍ច្បាប់នានា ដែលបច្ចុប្បន្នបង្កើតបានជាប្រព័ន្ធ WTO ។

WTO ទទួលខុសត្រូវលើការត្រួតពិនិត្យការអនុវត្តន៍កិច្ចព្រមព្រៀងទាំងនោះ ។ WTO ក៏ផ្តល់ផងដែរនូវវេទិការ សំរាប់ការចរចាររវាងបណ្តាប្រទេសនានា សំដៅធ្វើសេរីភាវូបនីយកម្មពាណិជ្ជកម្មលើទំនិញ និងសេវាកម្មជាបន្តទៀត ។ WTO ផ្តល់នូវយន្តការសំរាប់ដោះស្រាយវិវាទពាណិជ្ជកម្ម ក្នុងចំណោមប្រទេសជាសមាជិក ។ ប្រទេសជាសមាជិកណាមួយដែលយល់ថា ពាណិជ្ជកម្មរបស់ខ្លួនបានទទួលរងនូវផលប៉ះពាល់អវិជ្ជមាន ដោយសារតែការខុសឆ្គងរបស់សមាជិកមួយផ្សេងទៀតក្នុងការគោរពតាមវិធាននានា អាចលើកបញ្ហានេះជូនទៅ WTO ដើម្បីដោះស្រាយ ប្រសិនបើខ្លួនមិនអាចស្វែងរកនូវដំណោះស្រាយសមស្របតាមរយៈកិច្ចព្រមព្រៀងទ្វេភាគីនោះ ។

ខណ្ឌ ១

លិខិតុបករណ៍ច្បាប់សំខាន់ៗ ដែលបានចរចានៅក្នុងកិច្ចប្រជុំនៅអ៊ុយរូហ្គាយ (Uruguay Round)

ក. កិច្ចព្រមព្រៀងម៉ារ៉ាកេស្ស (Marrakesh) ដែលបង្កើតអង្គការពាណិជ្ជកម្មពិភពលោក

ខ. កិច្ចព្រមព្រៀងពហុភាគី

១. ពាណិជ្ជកម្មលើទំនិញ

□ កិច្ចព្រមព្រៀងទូទៅស្តីពីពន្ធគយ និងពាណិជ្ជកម្ម (GATT ១៩៩៤) កិច្ចព្រមព្រៀងដែលពាក់ព័ន្ធ

កិច្ចព្រមព្រៀងទូទៅស្តីពីការអនុវត្តន៍មាត្រា VII នៃ GATT ១៩៩៤ (ការវាយតម្លៃពន្ធគយ)

កិច្ចព្រមព្រៀងស្តីពីការត្រួតពិនិត្យមុនពេលដឹកជញ្ជូន (PSI)

កិច្ចព្រមព្រៀងទូទៅស្តីពីរបាំងបច្ចេកទេសចំពោះពាណិជ្ជកម្ម (TBT)

កិច្ចព្រមព្រៀងស្តីពីការអនុវត្តន៍វិធានការអនាម័យ និងភូតគាមអនាម័យ (SPS)

កិច្ចព្រមព្រៀងស្តីពីនីតិវិធីផ្តល់អាជ្ញាប័ណ្ណនាំចូល

កិច្ចព្រមព្រៀងស្តីពីវិធានការការពារ

កិច្ចព្រមព្រៀងស្តីពីឧបត្ថម្ភធន និងវិធានការប៉ះប៉ូវ (SCM)

កិច្ចព្រមព្រៀងទូទៅស្តីពីការអនុវត្តន៍មាត្រា VI នៃ GATT ១៩៩៤

(ការប្រឆាំងនឹងការលក់បង្ខូចថ្លៃទំនិញ) (Anti-Dumping ADP)

កិច្ចព្រមព្រៀងទូទៅស្តីពីវិធានការវិនិយោគពាក់ព័ន្ធនឹងពាណិជ្ជកម្ម (TRIMs)

កិច្ចព្រមព្រៀងទូទៅស្តីពីវាយនភ័ណ្ឌ និងសំលៀកបំពាក់ (ATC)

កិច្ចព្រមព្រៀងស្តីពីកសិកម្ម

កិច្ចព្រមព្រៀងស្តីពីវិធាននៃប្រភពដើមទំនិញ

□ កិច្ចយោគយល់គ្នា និងសេចក្តីសំរេច

កិច្ចយោគយល់គ្នាអំពីបទបញ្ញត្តិស្តីពីជញ្ជីងទូទាត់នៃ GATT ១៩៩៤

សេចក្តីសំរេចទាក់ទិននឹងករណីដែលរដ្ឋបាលគយមានមូលហេតុសង្ស័យទៅលើភាពពិត ឬត្រឹមត្រូវនៃតម្លៃដែលបានធ្វើប្រតិវេទន៍ (សេចក្តីសំរេចអំពីការកែប្រែខ្លឹមសារនៃភស្តុតាង)

កិច្ចយោគយល់គ្នាអំពីការបកស្រាយមាត្រា XVII នៃ GATT ១៩៩៤ (សហគ្រាសពាណិជ្ជកម្មរដ្ឋ)

កិច្ចយោគយល់គ្នាអំពីវិធាន និងនីតិវិធីដោះស្រាយវិវាទ

កិច្ចយោគយល់គ្នាអំពីការបកស្រាយមាត្រា២. ១(ខ)នៃ GATT ១៩៩៤ (ការចងភ្ជាប់នូវសម្បទានពន្ធគយ)

សេចក្តីសំរេចអំពីពាណិជ្ជកម្ម និងបរិស្ថាន

យន្តការពិនិត្យលើគោលនយោបាយពាណិជ្ជកម្ម

២. ពាណិជ្ជកម្មលើសេវាកម្ម

□ កិច្ចព្រមព្រៀងទូទៅស្តីពីពាណិជ្ជកម្មលើសេវាកម្ម (GATS)

៣. សិទ្ធិកម្មសិទ្ធិខាងបញ្ញា (IPRs)

□ កិច្ចព្រមព្រៀងស្តីពីទិដ្ឋភាពពាណិជ្ជកម្មពាក់ព័ន្ធនឹងច្បាប់ស្តីពីកម្មសិទ្ធិបញ្ញា

គ. កិច្ចព្រមព្រៀងពាណិជ្ជកម្មពហុភាគីតាមការស្ម័គ្រចិត្ត

កិច្ចព្រមព្រៀងស្តីពីពាណិជ្ជកម្មលើយន្តហោះស៊ីវិល

កិច្ចព្រមព្រៀងស្តីពីលទ្ធកម្មរដ្ឋាភិបាល

WTO និងសេដ្ឋកិច្ចសកល

ការសំរេចនៅលើបញ្ហាសំខាន់ៗទាំងអស់ ដែលស្ថិតនៅក្រោមសមត្ថកិច្ចរបស់គេ ត្រូវបានធ្វើឡើងនៅក្នុងសន្និសីទថ្នាក់រដ្ឋមន្ត្រីនៃបណ្តាប្រទេសជាសមាជិក ។ សន្និសីទត្រូវធ្វើឡើងយ៉ាងហោចក៏មួយដងដែរ ក្នុងរវាងពីរឆ្នាំ ។

ខ្លឹមសារនៃប្រព័ន្ធ WTO ដំបូង មាននៅក្នុង GATT ជួនកាលត្រូវបានចាត់ទុកថាជាក្លឹបរបស់អ្នកមានសម្បត្តិ ដោយសារគេគិតថា ប្រព័ន្ធនេះ មានបំណងជាបឋម គឺបំរើផលប្រយោជន៍របស់ប្រទេសជឿនលឿនតែប៉ុណ្ណោះ ។ នៅពេលបើកកិច្ចប្រជុំនៅយូរ៉ូហ្គាយស្តីពីការចរចាពាណិជ្ជកម្ម (១៩៨៦) មានប្រទេសកំពុងអភិវឌ្ឍន៍តែមួយចំនួនតូចប៉ុណ្ណោះ ដែលបានបង្ហាញនូវការចាប់អារម្មណ៍យ៉ាងសំខាន់ ទៅលើការងាររបស់GATT តាមរយៈការតែងតាំងអោយមានបេសកកម្មអចិន្ត្រៃយ៍នៅទីក្រុង ហ្សឺណែវ។ ប៉ុន្តែស្ថានការណ៍បានប្រែប្រួលយ៉ាងច្រើន បន្ទាប់ពីកិច្ចប្រជុំនោះមក ។ នៅពេលចប់កិច្ចប្រជុំហើយ GATT បានប្រែក្លាយទៅជា WTO មានប្រទេសជាច្រើនបានចូលរួម និងកំពុងបន្តការចូលរួមនៅក្នុងការចរចា និងពិភាក្សា ។ បច្ចុប្បន្នប្រទេសមួយចំនួនធំ បានបង្កើតបេសកកម្មអចិន្ត្រៃយ៍ របស់គេនៅទីក្រុង ហ្សឺណែវ ។ លើសពីនេះទៀត បន្ទាប់ពីរបបកុម្មុយនីស្តបានដួលរលំមក ប្រទេសអន្តរកាលមួយចំនួនក៏បានស្នើសុំចូលជាសមាជិកនៃអង្គការនេះដែរ ។ បច្ចុប្បន្ន មានប្រទេសចំនួន ១៣៤[’] ជាសមាជិករបស់ WTO ។ ក្រៅពីនេះ ប្រទេសកំពុងអភិវឌ្ឍន៍ និងប្រទេសដែលមានសេដ្ឋកិច្ចអន្តរកាលចំនួន ៣០ ទៀត កំពុងធ្វើការចរចាដើម្បីចូលជាសមាជិកអង្គការនេះ ។ ក្នុងនោះមានបណ្តាប្រទេសដូចជា ចិន សហភាពសូវៀត និងអ៊ុយក្រែន ដែលមានឥទ្ធិពលដ៏ច្រើនទៅលើពាណិជ្ជកម្មអន្តរជាតិ ។

អ្វីទៅដែលនាំទៅរកការប្រែប្រួលឥរិយាបទឆ្ពោះទៅរកសមាជិកភាពនៅក្នុង WTO និងហេតុអ្វី ទើបបណ្តាប្រទេសមួយចំនួនបង្ហាញនូវចំណាប់អារម្មណ៍កាន់តែខ្លាំងទៅលើប្រព័ន្ធផ្អែកលើវិធានដែលលេចចេញពីកិច្ចប្រជុំនៅយូរ៉ូហ្គាយដូច្នេះ ? មូលហេតុគឺមានច្រើន តែយើងអាចកត់សំគាល់ទៅលើមូលហេតុសំខាន់ចំនួនបី ។

មូលហេតុទីមួយ ទាក់ទិននៅនឹងល្បឿនសេដ្ឋកិច្ចពិភពលោកឈានទៅរកសកលភាវូបនីយកម្ម តាមរយៈពាណិជ្ជកម្មអន្តរជាតិ ព្រមទាំងលំហូរនៃវិនិយោគផ្ទាល់ពីបរទេស ។ ការប្រែប្រួលដ៏ខ្លាំង ដែលបច្ចុប្បន្នកើតមានឡើងនៅក្នុងវិស័យដឹកជញ្ជូននិងទូរគមនាគមន៍បានផ្តល់លទ្ធភាព សូម្បីតែចំពោះកម្មន្តសាលករតូចតាចនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ឱ្យអាចស្វែងរកទីផ្សារចំពោះផលិតផលរបស់ខ្លួន នៅក្នុងប្រទេសឆ្ងាយរាប់ពាន់ម៉ៃលបានដែរ ។ មធ្យោបាយសំរាប់ដឹកជញ្ជូនទំនិញពីប្រទេសមួយទៅប្រទេសមួយ ដូចដែលអ្នកសង្កេតការណ៍បានលើកឡើង បានធ្វើឱ្យពិភពលោកក្លាយទៅជា "ភូមិសកល" មួយ ។

មូលហេតុទីពីរគឺ ដំណើរការសកលភាវូបនីយកម្ម ដែលបានបង្កើនឯករាជ្យភាពរបស់បណ្តាប្រទេសនៅក្នុងពាណិជ្ជកម្មអន្តរជាតិត្រូវបានជំរុញល្បឿនជាបន្ថែមទៀត តាមរយៈការប្រែប្រួលនយោបាយសេដ្ឋកិច្ច និងពាណិជ្ជកម្ម ជាពិសេសគឺស្ទើរតែចំពោះគ្រប់ប្រទេសទាំងអស់ ។ ការដួលរលំនៃរបបកុម្មុយនីស្ត បាននាំទៅរកការអនុម័តនូវនយោបាយឆ្ពោះទៅរកទីផ្សារជាលំដាប់ស្ទើរតែចំពោះគ្រប់ប្រទេសទាំងអស់ដែលផលិតកម្ម និងពាណិជ្ជកម្មអន្តរជាតិ ធ្លាប់ស្ថិតក្រោមការគ្រប់គ្រងរបស់រដ្ឋ ។ ប្រទេសទាំងនោះ ដែលនាអតីតកាល ជាបឋម ធ្វើពាណិជ្ជកិច្ចតែរវាងគ្នាទៅវិញទៅមក ឥឡូវកំពុងធ្វើពាណិជ្ជកម្មទូទាំងពិភពលោក ។ ប្រទេសកំពុងអភិវឌ្ឍន៍ជាច្រើន បានបោះបង់ចោលនយោបាយជំនួសឱ្យការនាំចូល ហើយងាកទៅរកនយោបាយឆ្ពោះទៅរកការនាំចេញវិញ ដែលតាមរយៈនេះ គេប្រាថ្នាជំរុញកំណើនសេដ្ឋកិច្ចដោយការនាំចេញច្រើនឡើងៗនូវផលិតផលរបស់ខ្លួន ។

មូលហេតុទីបីគឺ នយោបាយពាណិជ្ជកម្មសេរី និងបើកចំហរនេះ ព្រមទាំងវិធានការដែលបណ្តាប្រទេសអនុវត្ត សំដៅលើកទឹកចិត្តវិនិយោគផ្ទាល់បរទេស បានជំរុញដល់ក្រុមហ៊ុនពហុជាតិ ឱ្យទទួលយកផ្នែក និងផលិតផលពាក់កណ្តាលសំរេចរបស់គេពីបណ្តាប្រទេសដែលអស់ចំណាយទាបជាង និងបង្កើតនូវសហគ្រាសផលិតកម្មនៅទីនោះ ។ ដូច្នេះកាន់តែច្រើនឡើងៗ ផលិតផលដែលបច្ចុប្បន្នមាននៅលើទីផ្សារ ទោះបីជាទំនិញប្រើប្រាស់ ដូចជាសម្លៀកបំពាក់ស្រាប់ៗ ឬទំនិញប្រើយូរអង្វែងក្តី ដូចជា ទូទឹកកក និងម៉ាស៊ីនត្រជាក់ ឬទំនិញមូលធនជាដើម គឺជាលទ្ធផលនៃដំណើរការផលិតកម្ម ដែលធ្វើឡើងនៅក្នុងប្រទេសលើសពីមួយ ។ ភស្តុតាងជាក់លាក់នៃសកលភាវូបនីយកម្មសេដ្ឋកិច្ចពិភពលោក ព្រមទាំងការពឹងផ្អែកកាន់តែច្រើនឡើងៗ នៃបណ្តាប្រទេសទៅលើពាណិជ្ជកម្មអន្តរជាតិ ត្រូវបានផ្តល់ឱ្យ នៅក្នុងការផ្សព្វផ្សាយពាណិជ្ជកម្មថ្មីៗនេះ របស់ក្រុមហ៊ុនពហុជាតិមួយ ជាអ្នកផលិតទំនិញប្រើប្រាស់អេឡិកត្រូនិក ដែលបានប្រកាសថា ផលិតផលខ្លួនកើតឡើងពីការបញ្ចូលផ្នែកផ្សេងៗមក ដែលផលិតនៅប្រទេសពីប្រាំទៅប្រាំមួយ ។

’ នៅថ្ងៃទី២១ ឧសភា ឆ្នាំ១៩៩៩ ក្រុមប្រឹក្សាជាន់ខ្ពស់បានអនុម័តបញ្ចូលប្រទេសកេនីយ៉ា ទៅក្នុង WTO ។ ប្រទេសនេះនឹងក្លាយទៅជាសមាជិកទី១៣៥ របស់ WTO ក្នុងរយៈពេល៣០ថ្ងៃ បន្ទាប់ពីបានជូនដំណឹងដល់លេខាធិការដ្ឋាន ថាខ្លួនបានបញ្ចប់ដំណើរការធ្វើសច្ចានុម័តជាតិរួច ។

ការពឹងផ្អែកកាន់តែច្រើនឡើងៗ ទៅលើពាណិជ្ជកម្មអន្តរជាតិ ទាំងចំពោះអ្នកនាំចេញ និងអ្នកនាំចូលទំនិញ និងផលិតផលសេវាកម្ម បានធ្វើឱ្យរដ្ឋាភិបាល និងសហគ្រាសអាជីវកម្មយល់ដឹងអំពីតួនាទីដ៏ចាំបាច់ ដែលប្រព័ន្ធពាណិជ្ជកម្មពហុភាគី ដើរតួនៅក្នុងការរក្សាផលប្រយោជន៍ពាណិជ្ជកម្មរបស់ខ្លួន ។ ប្រព័ន្ធដែលផ្អែកលើវិធាន បានធានាចំពោះពួកគេថា ច្រកចូលទៅកាន់ទីផ្សារដែលផលិតផល របស់គេទទួលបាននៅក្នុងទីផ្សារបរទេសនឹងពុំត្រូវកាត់ផ្តាច់ភ្លាមៗ ដោយសារវិធានការផ្សេងៗរបស់រដ្ឋាភិបាលដូចជា ការតំឡើងពន្ធនាំចូល ឬការហាមឃាត់ ឬការដាក់កំរិតលើការនាំចូលឡើយ ។ ការបើកទីផ្សារដែលអាចទស្សន៍ទាយជាមុន និងមានការធានា ដែលប្រព័ន្ធនោះបានផ្តល់ទៅឱ្យទីផ្សារបរទេស អនុញ្ញាតឱ្យសហគ្រាសអាជីវកម្មធ្វើផែនការ និងអភិវឌ្ឍន៍ផលិតកម្មសំរាប់ការនាំចេញ ដោយគ្មានការភ័យខ្លាចថា ទីផ្សារបរទេសអាចត្រូវបាត់បង់ដោយសារការដាក់កំហិតរបស់រដ្ឋាភិបាលទេ ។ បន្ថែមពីលើនេះ អ្វីដែលជាញឹកញាប់ពុំសូវមានការដឹងជាទូទៅ គឺប្រព័ន្ធនោះក៏ផ្តល់ផងដែរ នូវសិទ្ធិច្បាស់លាស់មួយចំនួនចំពោះសហគ្រាសអាជីវកម្ម ។ នៅពេលដែលគេអាចអនុវត្តសិទ្ធិភាគច្រើនរបស់គេជាមួយរដ្ឋាភិបាលគេបាន គេក៏អាចប្រើប្រាស់សិទ្ធិរបស់គេមួយចំនួនតូចតទល់នឹងរដ្ឋាភិបាលបរទេសដែរ ។

ដូច្នេះ ក្របខ័ណ្ឌនៃសិទ្ធិ និងកាតព្វកិច្ចដែលប្រព័ន្ធ WTO បានបង្កើតឡើង បានដើរតួនាទីដ៏សំខាន់មួយនៅក្នុងការអភិវឌ្ឍន៍ពាណិជ្ជកម្មនៅក្នុងសេដ្ឋកិច្ចពិភពលោកដ៏កាន់តែមានលក្ខណៈជាសកល ។ សមត្ថភាពរបស់រដ្ឋាភិបាល និងសហគ្រាសពាណិជ្ជកម្ម ក្នុងការទាញយកនូវផលប្រយោជន៍ពីប្រព័ន្ធនោះ គឺពឹងផ្អែកជាខ្លាំងទៅលើចំណេះ និងការយល់ដឹងអំពីវិធាននានានៃប្រព័ន្ធ អំពីផលប្រយោជន៍ផ្តល់ឱ្យដោយប្រព័ន្ធ ព្រមទាំងអំពីបញ្ហាប្រឈមបង្កឡើងដោយប្រព័ន្ធនោះ ។

លក្ខណៈពិសេសនៃកិច្ចព្រមព្រៀងរបស់ WTO

កិច្ចព្រមព្រៀងពហុភាគីស្តីពីពាណិជ្ជកម្មលើទំនិញ

គោលបំណង និងគោលការណ៍

គោលបំណងជាមូលដ្ឋាននៃកិច្ចព្រមព្រៀង GATT ដែលចែងអំពីវិធានពហុភាគីសំរាប់ការធ្វើពាណិជ្ជកម្មលើទំនិញ គឺការបង្កើតប្រព័ន្ធពាណិជ្ជកម្ម សេរី និងបើកចំហ ហើយតាមប្រព័ន្ធនេះ បណ្តាសហគ្រាសអាជីវកម្មរបស់ប្រទេសជាសមាជិក អាចធ្វើជំនួញជាមួយគ្នា ដោយផ្អែកលើលក្ខខណ្ឌនៃការប្រកួតប្រជែងដោយយុត្តិធម៌ ។ ទោះបីជាវិធានពិស្តារដែលកិច្ចព្រមព្រៀង GATT និងកិច្ចព្រមព្រៀងពាក់ព័ន្ធរបស់អង្គការនេះ (សូមអានវណ្ឌ ២) មានលក្ខណៈស្មុគស្មាញ ហើយពាក្យបច្ចេកទេសច្បាប់ធ្វើឱ្យមានការភន្តច្រឡំក្តី ក៏វិធានទាំងនោះតែងតែផ្អែកលើគោលការណ៍ និងវិធានសាមញ្ញមួយចំនួន ។ ជាពិសេស ក្របខណ្ឌទាំងមូលនៃកិច្ចព្រមព្រៀង GATT ត្រូវផ្អែកលើវិធានជាមូលដ្ឋានចំនួនបួន ។ *(សូមអានជំពូកទី ២)* ។

វិធានជាមូលដ្ឋានបួនយ៉ាង

ការការពារឧស្សាហកម្មក្នុងស្រុកតាមរយៈពន្ធគយ

ថ្វីត្បិតតែកិច្ចព្រមព្រៀង GATT មានបំណងធ្វើសេរីភាវូបនីយកម្មជាបន្តបន្ទាប់ក្តី ក៏កិច្ចព្រមព្រៀងនេះ ទទួលស្គាល់ថាប្រទេសជាសមាជិករបស់ខ្លួន អាចត្រូវការកិច្ចគាំពារផលិតកម្មក្នុងស្រុកតទល់នឹងការប្រកួតប្រជែងពីបរទេសដែរ ។ ទោះជាយ៉ាងណាក្តី កិច្ចព្រមព្រៀងនេះតម្រូវឱ្យប្រទេសទាំងឡាយ ផ្តល់កិច្ចគាំពារបែបនេះតាមរយៈពន្ធគយ ។ មានបទប្បញ្ញត្តិហាមឃាត់ការដាក់កំហិតលើបរិមាណ លើកលែងតែក្នុងស្ថានភាពពិសេសមួយចំនួន ។

ការចងភ្ជាប់ពន្ធគយ

ប្រទេសទាំងឡាយត្រូវបានជំរុញឱ្យកាត់បន្ថយ ហើយបើអាចធ្វើទៅបាន ត្រូវលុបបំបាត់កិច្ចគាំពារផលិតកម្មក្នុងស្រុក តាមរយៈការកាត់បន្ថយពន្ធគយ និងលុបបំបាត់របាំងពាណិជ្ជកម្មផ្សេងទៀត នៅក្នុងកិច្ចចរចាពាណិជ្ជកម្មពហុភាគី ។ ពន្ធគយដែលបានកាត់បន្ថយនោះ ត្រូវចងភ្ជាប់មិនអោយមានការបង្កើនណាមួយ តាមរយៈការចុះអត្រានោះចូលក្នុងតារាងពន្ធគយរបស់ប្រទេសនីមួយៗ ។ តារាងពន្ធគយទាំងនេះគឺជាផ្នែកទាំងមូលនៃប្រព័ន្ធច្បាប់នៃកិច្ចព្រមព្រៀង GATT ។

ប្រព្រឹត្តិកម្មនៃប្រជាជាតិដែលបានទទួលការអនុគ្រោះបំផុត (MFN)

វិធានដ៏សំខាន់នៃកិច្ចព្រមព្រៀង GATT នេះ មានចែងពីគោលការណ៍នៃការមិនរើសអើង ។ វិធាននេះចែងថា ពន្ធគយ និងបទប្បញ្ញត្តិផ្សេងទៀត គប្បីអនុវត្តន៍ចំពោះទំនិញនាំចេញ ឬ នាំចូល ក្នុងចំណោមប្រទេសជាសមាជិក ដោយគ្មានការរើសអើង។ ដូច្នេះវិធាននេះ មិនបើកលទ្ធភាពឱ្យប្រទេសមួយកំណត់យកពន្ធគយលើទំនិញនាំចូលពីប្រទេសមួយ តាមអត្រាមួយ ដែលខ្ពស់ជាងអត្រាដែលខ្លួនអនុវត្តន៍ចំពោះការនាំចូលពីប្រទេសសមាជិកផ្សេងទៀតឡើយ ។ ប៉ុន្តែមានអញ្ញត្រកម្មមួយចំនួនទៅលើវិធាននេះ។ ការធ្វើពាណិជ្ជកម្មរវាងភាគីនៃកិច្ចព្រមព្រៀងពាណិជ្ជកម្ម ដែលត្រូវគោរពតាមអត្រាអនុគ្រោះ ឬ អត្រារួចពន្ធគយ គឺជាអញ្ញត្រកម្មមួយ ។ អញ្ញត្រកម្មមួយទៀតមានចែងនៅក្នុងប្រព័ន្ធអនុគ្រោះទូទៅ ។ តាមប្រព័ន្ធនេះ ប្រទេសជឿនលឿន អនុវត្តអត្រាអនុគ្រោះ ឬ អត្រារួចពន្ធគយចំពោះការនាំចូលពីប្រទេសកំពុងអភិវឌ្ឍន៍ ប៉ុន្តែអនុវត្តអត្រា MFN ចំពោះការនាំចូលពីប្រទេសដទៃទៀត។

វិធានប្រព្រឹត្តិកម្មជាតិ

កាលណាវិធាន MFN ហាមមិនឱ្យប្រទេសទាំងឡាយមានការរើសអើងចំពោះទំនិញដែលមានប្រភពដើមមកពីប្រទេសផ្សេងទៀត វិធានប្រព្រឹត្តិកម្មជាតិ ហាមមិនឱ្យមានការរើសអើងនេះរវាងផលិតផលនាំចូល និងទំនិញផលិតក្នុងស្រុក រប់ទាំងក្នុងករណីមានការអនុវត្តន៍ពន្ធដារផ្ទៃក្នុង និងក្នុងការអនុវត្តន៍បទប្បញ្ញត្តិផ្ទៃក្នុងផងដែរ ។

ដូច្នេះ ក្រោយពីផលិតផលបានចូលទៅដល់ទីផ្សាររបស់ខ្លួន ដោយបានបង់ពន្ធគយរួចហើយ វិធាននេះមិនបើកលទ្ធភាពឱ្យប្រទេសនេះកំណត់ពន្ធផ្ទៃក្នុង (ឧទាហរណ៍ ពន្ធលើថ្លៃលក់ ឬ ពន្ធលើតម្លៃបន្ថែម) ដែលមានអត្រាខ្ពស់ជាងអត្រាដែលត្រូវបង់ចំពោះផលិតផលដែលមានប្រភពដើមរបស់ជាតិ ឬ ក្នុងប្រទេសឡើយ ។

វិធាននៃការអនុវត្តន៍ទូទៅ

វិធានមូលដ្ឋានទាំងបួនដែលបានពិរពណ៌នាខាងលើ ត្រូវបានបំពេញបន្ថែមដោយវិធាននៃការអនុវត្តន៍ទូទៅ សំរាប់គ្រប់គ្រងលើទំនិញដែលចូលទៅក្នុងទឹកដីមានពន្ធគយរបស់ប្រទេសនាំចូល ។ វិធានទាំងនេះរាប់បញ្ចូលទាំងវិធានទាំងឡាយដែលប្រទេសនោះត្រូវតែគោរព ÷

- ☐ ក្នុងការកំណត់តម្លៃដែលជាប់ពន្ធគយ លើទំនិញនាំចូល កាលណាពន្ធគយត្រូវបានប្រមូល ដោយផ្អែកលើមូលដ្ឋានតម្លៃបន្ថែម *(ad valorem)* (សូមអានជំពូកទី ៣) ។
- ☐ ការអនុវត្តន៍តាមភាតព្វកិច្ចនូវស្តង់ដារផលិតផល និងបទបញ្ជាអនាម័យ និងភូតគាមអនាម័យ *(sanitary and phytosanitary)* ចំពោះផលិតផលនាំចូល (សូមអានជំពូកទី ៥) ។
- ☐ ការចេញអាជ្ញាប័ណ្ណនាំចេញ (សូមអានជំពូកទី ៦) ។

វិធានពិស្តារដែលអនុវត្តន៍ចំពោះបញ្ហាទាំងនេះ និងបញ្ហាផ្សេងទៀត មានចែងនៅក្នុងកិច្ចព្រមព្រៀងពាក់ព័ន្ធ ។ ចំណុចសំខាន់ៗនៃវិធានទាំងនេះ ត្រូវបានពិរពណ៌នានៅក្នុងវណ្ឌ ២ ។

វិធានផ្សេងៗទៀត

ក្រៅពីវិធាននៃការអនុវត្តន៍ទូទៅដូចមានពិរពណ៌នាខាងលើ ប្រព័ន្ធពហុភាគីរបស់ GATT រួមមានវិធានដែលគ្រប់គ្រងលើ ÷

- ☐ ការផ្តល់ឧបត្ថម្ភធនដោយរដ្ឋាភិបាល
- ☐ វិធានការដែលជាធម្មតាអនុញ្ញាតិអោយរដ្ឋាភិបាលប្រកាន់យក ប្រសិនបើមានសំណើពីឧស្សាហកម្ម និង
- ☐ វិធានការវិនិយោគដែលអាចមានផលប៉ះពាល់ដល់ពាណិជ្ជកម្ម ។

វិធានដែលគ្រប់គ្រងការប្រើប្រាស់ឧបត្ថម្ភធន

រដ្ឋាភិបាលទាំងឡាយ ផ្តល់ឧបត្ថម្ភធនសំរាប់គោលនយោបាយផ្សេងៗ ។ ជាក់ស្តែងការផ្តល់ឧបត្ថម្ភធនបែបនេះ ធ្វើឱ្យប៉ះពាល់ដល់ល័ក្ខខ័ណ្ឌនៃការប្រកួតប្រជែងក្នុងពាណិជ្ជកម្មអន្តរជាតិ ។ វិធានរបស់ GATT ដែលក្រោយមកត្រូវបានពង្រីកថែម នៅក្នុងកិច្ចព្រមព្រៀងស្តីពីឧបត្ថម្ភធន និងវិធានការប៉ះប៉ូវ (Agreement on Subsidies and Countervailing Measures "SCM") មានគោលដៅជាសំខាន់ គឺហាមឃាត់ ឬ ដាក់កំរិតលើការប្រើប្រាស់វិធីឧបត្ថម្ភធនដែលមានផលប៉ះពាល់ដល់ពាណិជ្ជកម្ម។

ឧបត្ថម្ភធនសំរាប់វិស័យឧស្សាហកម្មដែលផ្តល់អោយដោយរដ្ឋាភិបាលតាមកិច្ចព្រមព្រៀងស្តីពីឧបត្ថម្ភធន និងវិធានការប៉ះប៉ូវនេះ មាន២យ៉ាង គឺឧបត្ថម្ភធនដែលហាមឃាត់ និងឧបត្ថម្ភធនដែលអនុញ្ញាត ។

ឧបត្ថម្ភធនដែលហាមឃាត់ រួមមានឧបត្ថម្ភធនសំរាប់ការនាំចេញ និងឧបត្ថម្ភធនដែលមានគោលបំណងជំរុញឱ្យមានការប្រើប្រាស់ទំនិញក្នុងស្រុក ច្រើនជាងទំនិញនាំចូល ។ មុនកិច្ចប្រជុំតុមូលនៅឡឺហ្គាយ វិធានហាមឃាត់ការប្រើឧបត្ថម្ភធន សំរាប់ការនាំចេញ គឺជាកាតព្វកិច្ចសំរាប់តែប្រទេសជឿនលឿនប៉ុណ្ណោះ ។ ជាគោលការណ៍ វិធាននេះក៏អនុវត្តន៍ចំពោះប្រទេសកំពុងអភិវឌ្ឍន៍ផងដែរនាពេលបច្ចុប្បន្ននេះ ។

ខណ្ឌ ២

សង្ខេបពីវិធាន GATT ដែលអនុវត្តន៍នៅតាមព្រំដែន *ការកំណត់តម្លៃជាប់ពន្ធគយ ។ (ចូរអានជំពូកទី ៣) កិច្ចព្រមព្រៀងស្តីពីការកំណត់តម្លៃពន្ធគយ ការពារផលប្រយោជន៍អ្នកនាំចូល តាមការចែងថា តម្លៃសំរាប់គោលបំណងពន្ធគយ គប្បីកំណត់ដោយផ្អែកតាមមូលដ្ឋានតម្លៃដែលបានបង់ ឬ តម្លៃត្រូវបង់ដោយអ្នកនាំចូល ចំពោះប្រតិបត្តិការដែលត្រូវជំរះពន្ធដោយអាជ្ញាធរគយ ។ ប៉ុន្តែអាជ្ញាធរគយអាចបដិសេធតម្លៃដែលបានធ្វើប្រតិវេទន៍ កាលណាខ្លួនមានភវនីយហេតុ អំពីការពិត ឬ ភាពត្រឹមត្រូវនៃតម្លៃដែលបានប្រកាស ។ ក្នុងគ្រប់ករណីបែបនេះ អាជ្ញាធរគយត្រូវតែផ្តល់ឱកាសឱ្យអ្នកនាំចូលបង្ហាញហេតុផលពីតម្លៃដែលគេបានប្រកាស ។ កាលណាអាជ្ញាធរគយមិនយល់ស្របនឹងការបង្ហាញហេតុផលនេះទេ កិច្ចព្រមព្រៀងបានចែងពីឋានានុក្រមនៃជំរើសចំនួនប្រាំ ដែលអាចយកមកអនុវត្តន៍ ។ ការអនុវត្តន៍ស្តង់ដាកាតព្វកិច្ច (ចូរអានជំពូកទី ៥) ។ ប្រទេសទាំងឡាយតែងតែតម្រូវឱ្យស្តង់ដារនៃផលិតផលនាំចូលស្របតាមស្តង់ដាជាកាតព្វកិច្ច ដែលគេបានអនុម័ត ដើម្បីការពារសុខភាព និងសុវត្ថិភាពពលរដ្ឋរបស់គេ ។ កិច្ចព្រមព្រៀងស្តីពីរបាំងបច្ចេកទេសលើពាណិជ្ជកម្មចែងថា មិនត្រូវបង្កើតស្តង់ដាបែបនេះ និងអនុវត្តន៍តាមរបៀបមួយដែលបង្កឱ្យមានរបាំងពាណិជ្ជកម្មដែលមិនចាំបាច់ឡើយ ។ ហួតមកដល់បច្ចុប្បន្ន កិច្ចព្រមព្រៀងនេះ តម្រូវឱ្យប្រទេសទាំងឡាយប្រើស្តង់ដាអន្តរជាតិ កាលបើមាន បើសិនជាគ្មានទេ ត្រូវប្រកាន់យកពត៌មាន និងភស្តុតាងវិទ្យាសាស្ត្រជាបង្អែកនៃស្តង់ដាកាតព្វកិច្ចរបស់ខ្លួន ។ ការអនុវត្តន៍បទបញ្ជាអនាម័យ និងភូតគាមអនាម័យ (ចូរអានជំពូកទី៥)។ ប្រទេសទាំងឡាយបានអនុវត្តបទបញ្ជាទាំងនេះ ដើម្បីការពារជីវរុក្ខជាតិ សត្វពាហនៈ និងអាយុជីវិតមនុស្សរបស់គេ ឱ្យរួចផុតពីការរីករាលដាលនៃរោគប៉េស្ត៍ និងជម្ងឺទាំងឡាយដែលចូលមកក្នុងប្រទេសរបស់គេ ដោយសារផ្លែឈើ បន្លែ សាច់ និងផលិតផលអាហារផ្សេងទៀតដែលខូចគុណភាព ។ កិច្ចព្រមព្រៀងស្តីពីការអនុវត្តន៍វិធានការអនាម័យ និងភូតគាមអនាម័យ បានហាមមិនឱ្យប្រទេសជាសមាជិកអនុវត្តន៍បទបញ្ជាបែបនេះ តាមរបៀបមួយ ដែលបង្កឱ្យមានរបាំងពាណិជ្ជកម្មដែលមិនចាំបាច់ឡើយ ហើយជំរុញឱ្យប្រទេសទាំងនេះ ប្រកាន់យកគោលការណ៍វិទ្យាសាស្ត្រជាបង្អែកនៃបទបញ្ជារបស់គេ និងជំរុញឱ្យគេអនុម័តស្តង់ដា និងគោលការណ៍ណែនាំអន្តរជាតិ កាលបើអាចធ្វើទៅបាន ។ នីតិវិធីចេញអាជ្ញាប័ណ្ណនាំចូល។ (ចូរអានជំពូកទី ៦) ។ កិច្ចព្រមព្រៀងស្តីពីនីតិវិធីចេញអាជ្ញាប័ណ្ណនាំចូល ចែងពីគោលការណ៍ណែនាំ សំរាប់ឱ្យអាជ្ញាធរចេញអាជ្ញាប័ណ្ណអនុវត្ត តាមក្នុងការចេញអាជ្ញាប័ណ្ណនាំចូល ដោយធ្វើយ៉ាងណាធានាកុំឱ្យនីតិវិធីទាំងនោះ មានអនុភាពរឹតបន្តឹងលើពាណិជ្ជកម្មបន្ថែមទៀត ។*

ប៉ុន្តែប្រទេសទាំងនេះ មានរយៈពេលអន្តរកាលចំនួនប្រាំបីឆ្នាំ (គឺរហូតដល់ថ្ងៃទី ១ ខែមករា ឆ្នាំ ២០០៣) ដើម្បីកែសំរួលការអនុវត្តន៍ឧបត្ថម្ភធនរបស់គេ ។ ប្រទេសកំពុងអភិវឌ្ឍន៍ដែលមានផលិតផលជាតិសរុប ក្នុងបុគ្គលម្នាក់តិចជាង ១០០០ ដុល្លារ ដែលបានរាយនាមក្នុងកិច្ចព្រមព្រៀង និងប្រទេសក្រីក្រ ត្រូវបានលើកលែងឱ្យរួចផុតពីវិធានហាមឃាត់ឧបត្ថម្ភធនលើការនាំចេញនេះ *(ចូរអានជំពូកទី ៨)* ។

ឧបត្ថម្ភធនដែលបានអនុញ្ញាតមាន ២ ប្រភេទ : ឧបត្ថម្ភធនដែលអាចប្តឹងបាន និងមិនអាចប្តឹងបាន ។ ចំពោះការនាំចូលផលិតផលដែលបានទទួលឧបត្ថម្ភធនដែលអាចប្តឹងបាន បង្កើតអោយមានផលប៉ះពាល់ប្រឆាំងនឹងពាណិជ្ជកម្មនោះ ប្រទេសនាំចូលដែលរងគ្រោះអាចធ្វើបណ្តឹងឱ្យមានវិធានការដោះស្រាយ ។ វិធានការដោះស្រាយនេះអាចមានទ្រង់ទ្រាយជាពន្ធប៉ះប៉ូវ (ចូរអានចំណុចខាងក្រោម) ។ ប៉ុន្តែប្រទេសនាំចូល មិនអាចដាក់ពន្ធប៉ះប៉ូវលើផលិតផលដែលបានទទួលអត្ថប្រយោជន៍ពីឧបត្ថម្ភធនមួយចំនួនជាក់លាក់ ហើយត្រូវបានចាត់ទុកថាជាឧបត្ថម្ភធន ដែលមិនអាចប្តឹងបាននោះឡើយ ។

វិធានការដែលរដ្ឋាភិបាលនៃប្រទេសនាំចូលអាចប្រើ បើមានសំណើពីឧស្សាហកម្មក្នុងស្រុក

វិធានទាំងនេះបានចែងទៀតថា រដ្ឋាភិបាលនៃប្រទេសនាំចូលអាចចាត់វិធានមួយចំនួន ដែលអាចមានអនុភាពហាមប្រាមដល់ការនាំចូលតែក្នុងករណីដែលឧស្សាហកម្មក្នុងស្រុកទទួលរងគ្រោះដោយកំណើននៃការនាំចូល ។ វិធានការទាំងនេះមាន ÷

- ☐ វិធានការការពារ *(ចូរអានជំពូកទី ៩)* ។
- ☐ ការកំណត់ពន្ធប្រឆាំងនឹងការលក់បង្ខូចថ្លៃ និងពន្ធប៉ះប៉ូវ *(ចូរអានជំពូកទី ៨ និង ១១)* ។

វិធានការការពារ

កិច្ចព្រមព្រៀងស្តីពីការការពារ បានអនុញ្ញាតឱ្យប្រទេសនាំចូល ដាក់កំរិតលើការនាំចូលផលិតផលសំរាប់រយៈពេលបណ្តោះអាសន្ន តាមការបង្កើនពន្ធគយ ឬការដាក់កំរិតលើបរិមាណ ។ វិធានការការពារនេះអាចយកមកប្រើបាន តែក្នុងពេលដែលរដ្ឋនោះអាចបង្ហាញភស្តុតាងតាមរយៈការស៊ើបអង្កេតត្រឹមត្រូវថា ការនាំចូលបានកើនយ៉ាងឆាប់រហ័ស (តាមលក្ខណៈដាច់ខាតនិងធៀបនឹងផលិតកម្មក្នុងស្រុក) ហើយបានបណ្តាល ឬ បង្ហាញថានឹងបណ្តាលឱ្យមានការខូចខាតធ្ងន់ធ្ងរដល់ឧស្សាហកម្មក្នុងស្រុក ។ វិធានការការពារនេះមិនអាចយកមកប្រើប្រាក់បាន ក្នុងករណីដែលមានតែក្រុមហ៊ុនមួយ ឬ ពីរ ដែលផលិតផលិតផលស្រដៀងគ្នានឹងផលិតផលនាំចូលជាក្រុមហ៊ុនរងគ្រោះនោះឡើយ ។ វិធានការនេះត្រូវបានអនុញ្ញាតឱ្យប្រើតែក្នុងករណីមួយគត់ គឺនៅពេលដែលរដ្ឋនោះបានបង្ហាញភស្តុតាងថា កំណើននៃការនាំចូលកំពុងបណ្តាលឱ្យមានការខូចខាតធ្ងន់ធ្ងរដល់ផលិតករទាំងឡាយតំណាងឱ្យសមាមាត្រភាគច្រើននៃផលិតកម្មសរុបក្នុងស្រុក នូវផលិតផលដែលស្រដៀងគ្នានឹងផលិតផលដែលបាននាំចូល ។ *(ចូរអានជំពូកទី៩)* ។

គោលបំណងចម្បងនៃការចែងពីការបង្កើនការការពារបណ្តោះអាសន្ន គឺដើម្បីទុកពេលឱ្យឧស្សាហកម្មរងគ្រោះ សំរបសំរួលទៅតាមកំណើននៃការប្រកួតប្រជែង ដែលនឹងត្រូវប្រឈមមុខបន្ទាប់ពីការលុបចោលការហាមឃាត់ ។ កិច្ចព្រមព្រៀងនេះចែងថា ការហាមឃាត់នេះត្រូវអនុវត្តតែក្នុងរយៈពេលបណ្តោះអាសន្ន ដោយចែងបញ្ជាក់ពីរយៈពេលអតិបរិមា ៨ ឆ្នាំ សំរាប់ការអនុវត្តន៍វិធានការការពារលើផលិតផលជាក់លាក់ ។

ថ្វីត្បិតតែរដ្ឋាភិបាលខ្លួនឯងជាអ្នកផ្តួចផ្តើមគំនិតក្នុងការចាប់ផ្តើមស៊ើបអង្កេតក៏ដោយ ក៏ជាក់ស្តែងនៅក្នុងប្រទេសភាគច្រើន ការស៊ើបអង្កេតអាចចាប់ផ្តើមបានតែក្នុងករណីដែលមានពាក្យបណ្តឹងពីឧស្សាហកម្មរងគ្រោះប៉ុណ្ណោះ ។

ពន្ធគយប្រឆាំងនឹងការលក់បង្ខូចថ្លៃ និងពន្ធប៉ះប៉ូវ

កិច្ចព្រមព្រៀងនេះក៏បើកចំហឱ្យរដ្ឋាភិបាលកំណត់ពន្ធគយជាសំណងលើផលិតផលនាំចូល កាលណាមានការចោទប្រកាន់ថា អ្នកផ្គត់ផ្គង់បរទេសកំពុងធ្វើពាណិជ្ជកម្មមិនស្មោះត្រង់ ។ វិធានទាំងនេះទាក់ទិននឹងការអនុវត្តន៍មិនស្មោះត្រង់ ដែលអាចធ្វើឱ្យមានការប៉ះពាល់ដល់ល័ក្ខខ័ណ្ឌនៃការប្រកួតប្រជែងជាអន្តរជាតិ ។

បញ្ហាទីមួយគឺការលក់ទំនិញបង្ខូចតម្លៃនៅក្នុងទីផ្សារបរទេស ។ កិច្ចព្រមព្រៀងស្ដីពីការអនុវត្តន៍ប្រឆាំងការលក់ទំនិញបង្ខូចតម្លៃ ចែងពីលក្ខណៈវិនិច្ឆ័យតឹងរឹងមួយចំនួន សំរាប់ការកំណត់ការលក់បង្ខូចថ្លៃ ។ កិច្ចព្រមព្រៀងនេះ ចែងថាផលិតផលមួយ អាចត្រូវបានចាត់ទុកថាបានលក់បង្ខូចថ្លៃកាលណាតម្លៃនាំចេញនៃផលិតផលនោះទាបជាងតម្លៃដែលប្រកាសលក់នៅក្នុងទីផ្សារក្នុងស្រុករបស់ប្រទេសនាំចេញ។

បញ្ហាទីពីរគឺ ការប្រកួតប្រជែងមិនយុត្តិធម៌ ដែលអាចកើតមានកាលណាក្រុមហ៊ុនបរទេស មានលទ្ធភាពកំណត់តម្លៃនាំចេញទាប ដោយសារគេបានទទួលឧបត្ថម្ភធនពីរដ្ឋាភិបាល ។

កិច្ចព្រមព្រៀងស្ដីពីការប្រឆាំងនឹងការលក់បង្ខូចថ្លៃ អនុញ្ញាតឱ្យប្រទេសនានាកំណត់ពន្ធគយប្រឆាំងនឹងការលក់បង្ខូចថ្លៃចំពោះផលិតផលដែលត្រូវបានលក់បង្ខូចថ្លៃ ។ ដូចគ្នានេះដែរ កិច្ចព្រមព្រៀងស្ដីពីឧបត្ថម្ភធន និងវិធានការប៉ះប៉ូវអនុញ្ញាតឱ្យប្រទេសនានាកំណត់ពន្ធគយ ប៉ះប៉ូវលើផលិតផលនាំចូលដែលបានទទួលអត្ថប្រយោជន៍ពីឧបត្ថម្ភធននោះ ។

ប៉ុន្តែ ការកំណត់ពន្ធគយនេះត្រូវគោរពតាមលក្ខខណ្ឌសំខាន់ៗ ចំនួនពីរ ។ ទីមួយ ពន្ធគយមិនអាចកំណត់ដោយផ្អែកតែលើមូលហេតុ ដែលផលិតផលនោះត្រូវបានលក់បង្ខូចថ្លៃ ឬ ទទួលអត្ថប្រយោជន៍ពីឧបត្ថម្ភធនបានឡើយ ។ ជាចាំបាច់ប្រទេសនាំចូលត្រូវបង្ហាញភស្តុតាង តាមការស៊ើបអង្កេតក្នុងស្រុកថា កំណើននៃការនាំចូលនោះ កំពុងតែបណ្ដាលឱ្យមានការខូចខាតធ្ងន់ធ្ងរដល់ឧស្សាហកម្មក្នុងស្រុក ។ ទីពីរ ដូចបានកត់សំគាល់ខាងដើមរួចមកហើយថា រដ្ឋាភិបាលអាចផ្ដើមគំនិតធ្វើការស៊ើបអង្កេត បើមានបណ្ដឹងធ្វើឡើងដោយ ឬ តាងនាមឧស្សាហកម្មក្នុងស្រុក ដែលអះអាងថាការនាំចូលតាមការលក់បង្ខូចថ្លៃ ឬ តាមឧបត្ថម្ភធននេះ កំពុងតែបណ្ដាលឱ្យមានការខូចខាតធ្ងន់ធ្ងរដល់ផលិតករ ដែលតំណាងយ៉ាងហោចណាស់ ២៥% នៃផលិតកម្មក្នុងស្រុកសរុប ។ គប្បីកត់សំគាល់ថា ស្តង់ដាសំរាប់កំណត់ការខូចខាតរបស់ឧស្សាហកម្មនៅក្នុងវិធានការការពារមានទម្ងន់ធ្ងន់ធ្ងរជាងវិធានការដែលត្រូវការ ដើម្បីកំណត់ការខូចខាត សំរាប់កំណត់ពន្ធគយប៉ះប៉ូវ ។ ចំពោះវិធានការការពារនេះ គេត្រូវតែបង្ហាញភស្តុតាងថា ការខូចខាតរបស់ឧស្សាហកម្មមានលក្ខណៈធ្ងន់ធ្ងរ រីឯវិធានការប្រឆាំងការលក់បង្ខូចថ្លៃ និងពន្ធប៉ះប៉ូវត្រូវបញ្ជាក់ថា ការខូចខាតដែលមានកំរិតទាបជាងនោះ អាចជាភស្តុតាងគ្រប់គ្រាន់ ។ ភាពខុសគ្នា គឺអាស្រ័យទៅតាមកត្តាជាក់ស្ដែងចំពោះវិធានការការពារបញ្ហាដែលកើតមានទៅលើឧស្សាហកម្មក្នុងស្រុករបស់ប្រទេសនាំចូល បណ្ដាលមកពីការប្រកួតប្រជែងស្មោះត្រង់ពីបរទេស ហើយក្នុងករណីវិធានការប្រឆាំងការលក់បង្ខូចថ្លៃ និងប៉ះប៉ូវ បញ្ហាកើតឡើងដោយសារការធ្វើពាណិជ្ជកម្មមិនស្មោះត្រង់របស់អ្នកផ្គត់ផ្គង់បរទេស ។ កិច្ចព្រមព្រៀងទាំងពីរនេះ ចែងអំពីកត្តាទាំងឡាយ (ដូចជាការធ្លាក់ចុះផលរបរ ឬ ប្រាក់ចំណេញ ឬ ការថយចុះកម្លាំងពលកម្ម) ដែលអាជ្ញាធរស៊ើបអង្កេតត្រូវលើកមកពិចារណា ក្នុងការកំណត់ថាតើឧស្សាហកម្មនេះ កំពុងទទួលរងការខូចខាតពីការនាំចូល ឬ ក៏អត់ ។ *(ចូរអានជំពូកទី ១១)* ។

វិធានការវិនិយោគពាក់ព័ន្ធនឹងពាណិជ្ជកម្ម (TRIMs)

ប្រទេសទាំងឡាយតែងតែដាក់លក្ខខណ្ឌលើវិនិយោគិនបរទេស ដើម្បីជំរុញការពង្រីកឧស្សាហូបនីយកម្ម ។ កាលណាលក្ខខណ្ឌទាំងនេះមានផលប៉ះពាល់លើពាណិជ្ជកម្មនោះលក្ខខណ្ឌទាំងនោះត្រូវបានគេហៅថា វិធានការវិនិយោគពាក់ព័ន្ធនឹងពាណិជ្ជកម្ម ។

កិច្ចព្រមព្រៀងស្ដីពីវិធានការវិនិយោគពាក់ព័ន្ធនឹងពាណិជ្ជកម្ម ដែលបានលើកមកចរចាក្នុងកិច្ចប្រជុំតុមូលឃ្នូរ៉ូហ្គាយ ហាមមិនឱ្យប្រទេសជាសមាជិកប្រើវិធានការ ៥ ប្រភេទ (ដូចជាលក្ខខណ្ឌតំរូវអោយប្រើប្រាស់វត្ថុធាតុដើមក្នុងស្រុក និងសមតុល្យពាណិជ្ជកម្ម) ដោយបានចាត់ទុកថា ផ្ទុយពីវិធាននៃកិច្ចព្រមព្រៀង GATT ដែលចែងពីប្រព្រឹត្តិកម្មជាតិ និងវិធានដែលហាមឃាត់ការដាក់កំហិតលើបរិមាណផលិតផលនាំចូល ។ *(ចូរអានជំពូកទី ១៣)* ។

កិច្ចព្រមព្រៀងទូទៅស្ដីពីពាណិជ្ជកម្មលើសេវាកម្ម (GATS)

វិធីបួនយ៉ាងនៃពាណិជ្ជកម្មអន្តរជាតិលើសេវាកម្ម

សេវាកម្មរាប់បញ្ចូលទាំងសកម្មភាពទាំងឡាយចាប់តាំងពីអាជីវកម្មធនាគារ ធានារ៉ាប់រង និងទូរគមនាគមន៍ រហូតដល់សេវាកម្ម

វិស័យកំសាន្ត វប្បធម៌ និងកីឡា ។ អង្គការពាណិជ្ជកម្មពិភពលោកបានកំណត់ថា មានសេវាកម្មដែលបំបែកទៅផ្នែកតូចៗ ជាង ១៥០ ប្រភេទ ។

ចរិតលក្ខណៈចម្បងមួយក្នុងការកំណត់ពីសេវាកម្ម គឺថាសេវាកម្មមានលក្ខណៈអរូបី និងមិនអាចមើលឃើញផ្ទុយទៅវិញ ទំនិញគឺជាវត្ថុដែលមានរូបរាង និងអាចមើលឃើញ ។ ភាពខុសគ្នាទាំងនេះក៏មានឥទ្ធិពលលើរបៀបនៃការកើតឡើងនៃប្រតិបត្តិការពាណិជ្ជកម្មអន្តរជាតិដែរ ។ ផ្ទុយទៅវិញ ពាណិជ្ជកម្មលើទំនិញអន្តរជាតិទាក់ទិននឹងចលនាទំនិញពីប្រទេសមួយទៅប្រទេសមួយទៀត មានការពាក់ព័ន្ធតែនឹងប្រតិបត្តិការសេវាកម្មតិចតួច ចំពោះចលនាឆ្លងកាត់ព្រំដែន ។ ចំពោះប្រតិបត្តិការសេវាកម្មភាគច្រើន ការនៅជិតគ្នារវាងអ្នកផ្តល់សេវាកម្ម និងអ្នកប្រើប្រាស់គឺជាការចាំបាច់ណាស់ ។ ការនៅជិតនេះ អាចទទួលបានតាមរយៈការបង្កើតទីតាំងក្រុមហ៊ុនពាណិជ្ជកម្ម នៅក្នុងប្រទេសនាំចូល (ដូចជាការបើកសាខា) ឬ តាមរយៈការបញ្ជូននូវរូបវន្តបុគ្គលសំរាប់រយៈពេលបណ្តោះអាសន្ន (ដូចជាការបញ្ជូនមេធាវី ឬ ស្ថាបត្យករទៅប្រទេសផ្សេង) ។ ក្នុងករណីដែលមានសេវាកម្មតិចតួចពេក អ្នកប្រើប្រាស់អាចនឹងត្រូវប្តូរទីតាំងទៅប្រទេសនាំចូលនេះ (ឧទាហរណ៍ វិស័យទេសចរណ៍ ដែលភ្ញៀវទេសចរធ្វើដំណើរទៅប្រទេសផ្សេង) ។ *(ចូរអានជំពូកទី១៧)* ។

ពាណិជ្ជកម្មលើសេវាកម្មកំពុងតែរីកចំរើន ហើយបច្ចុប្បន្ននេះគ្របដណ្តប់លើអត្រាចំនួន ២០% នៃអត្រាពាណិជ្ជកម្មអន្តរជាតិ។ កិច្ចព្រមព្រៀងទូទៅស្តីពីពាណិជ្ជកម្មលើសេវាកម្ម ដែលបានលើកមកចរចាក្នុងសន្និសីទតុមូលឃ្មួរ៉ូហ្គាយ បានបង្កើតក្របខណ្ឌដើម្បីដាក់ឱ្យពាណិជ្ជកម្មនេះស្ថិតនៅក្រោមច្បាប់អន្តរជាតិ ។ បទប្បញ្ញត្តិនៃកិច្ចព្រមព្រៀងនេះអនុវត្តន៍លើរាល់របៀបធ្វើពាណិជ្ជកម្មផ្នែកសេវាកម្មអន្តរជាតិ ដូចជា ÷

- ☐ ចលនាឆ្លងកាត់ព្រំដែននៃផលិតផលសេវាកម្ម
- ☐ ការបង្កើតទីតាំងពាណិជ្ជកម្មនៅក្នុងប្រទេសដែលត្រូវផ្តល់សេវាកម្ម
- ☐ ការបញ្ជូនរូបវន្តបុគ្គលជាបណ្តោះអាសន្ន ទៅកាន់ប្រទេសផ្សេង ដើម្បីផ្តល់សេវាកម្មនៅទីនោះ និង
- ☐ ចលនានៃអ្នកប្រើប្រាស់ទៅកាន់ប្រទេសនាំចូល ។

បទប្បញ្ញត្តិសំខាន់ៗនៃកិច្ចព្រមព្រៀងពាណិជ្ជកម្មលើសេវាកម្ម

កិច្ចព្រមព្រៀងនេះចែងអំពី ÷

- ☐ អត្ថបទតំរោងដែលកំណត់នូវគោលការណ៍ទូទៅ ដែលអនុវត្តន៍ចំពោះវិធានការដែលប៉ះពាល់ដល់ពាណិជ្ជកម្មលើសេវាកម្ម។
- ☐ ការសន្យាធ្វើសេរីភាវូបនីយកម្មជាក់លាក់ ដែលអនុវត្តន៍ចំពោះឧស្សាហកម្មខាងសេវាកម្ម និងឧស្សាហកម្មតូចៗ ដែលមានរាយនៅក្នុងបញ្ជីរបស់ប្រទេសនីមួយៗ ។

ប្រជាជាតិទទួលនូវភាពអនុគ្រោះបំផុត និងប្រព្រឹត្តកម្មជាតិ

គោលការណ៍មូលដ្ឋានទាំងពីរដែលអនុវត្តន៍ចំពោះពាណិជ្ជកម្មលើទំនិញ ឥឡូវនេះក៏អនុវត្តន៍ចំពោះពាណិជ្ជកម្មលើសេវាកម្មដែរ ។ ប៉ុន្តែគេបានកែសំរួលគោលការណ៍ទាំងនោះ ដើម្បីបញ្ចូលនូវចរិតលក្ខណៈពិសេសៗ នៃពាណិជ្ជកម្មលើសេវាកម្ម ។

ដូច្នេះកិច្ចព្រមព្រៀងនេះតម្រូវឱ្យប្រទេសជាសមាជិកអនុវត្តន៍ប្រព្រឹត្តកម្ម MFN ដោយគ្មានការរើសអើងចំពោះផលិតផលសេវាកម្ម និងអ្នកផ្តល់សេវាកម្មរបស់ប្រទេសផ្សេងៗ ។ ប៉ុន្តែប្រទេសនេះអាចរក្សាទុកក្នុងរយៈពេលបណ្តោះអាសន្ន ១០ ឆ្នាំ (ឧ. រហូតដល់ថ្ងៃទី ១ ខែមករា ឆ្នាំ ២០០៥) នូវវិធានការនានាដែលមិនស្របនឹងគោលការណ៍ MFN បាន ។

គោលការណ៍ប្រព្រឹត្តកម្មជាតិ បង្ហាញឱ្យឃើញថាប្រទេសទាំងឡាយ មិនត្រូវឱ្យតម្លៃផលិតផលសេវាកម្ម និងអ្នកផ្តល់សេវាកម្មបរទេសទាបជាងផលិតផលសេវាកម្ម និងអ្នកផ្តល់សេវាកម្មរបស់ខ្លួនទេ ។ ប៉ុន្តែវាខុសពីករណីពាណិជ្ជកម្មលើទំនិញ កិច្ចព្រមព្រៀងនេះបាន

កំណត់គោលការណ៍ នេះជាកាតព្វកិច្ចដែលត្រូវអនុវត្តន៍ទូទាំងប្រទេស ចំពោះវិស័យសេវាកម្មទាំងអស់ ប៉ុន្តែតម្រូវឱ្យប្រទេសបញ្ជាក់នូវវិស័យនានាក្នុងបញ្ជីសម្បទានរបស់គេ និងល័ក្ខខ័ណ្ឌទាំងឡាយដែលត្រូវបំពេញ ដើម្បីបានទទួលការឱ្យតម្លៃខ្ពស់ឡើង ។

តំរូវការស្តីពីតម្លាភាព

ដើម្បីធានាឱ្យអ្នកផ្តល់សេវាកម្មបរទេស បានយល់ដឹងគ្រប់គ្រាន់ពីបទបញ្ជាទាំងឡាយដែលអនុវត្តន៍ចំពោះពាណិជ្ជកម្មលើសេវាកម្ម ប្រទេសជាសមាជិកត្រូវតែបោះពុម្ពផ្សាយច្បាប់ និងបទបញ្ជាទាំងអស់ដែលពាក់ព័ន្ធ ។ ល័ក្ខខ័ណ្ឌនេះតម្រូវឱ្យប្រទេសនីមួយៗបង្កើតកន្លែងសំរាប់ការសាកសួរពត៌មាន ដែលតាមរយៈកន្លែងនេះ ប្រទេសជាសមាជិកផ្សេងទៀតអាចទទួលបានពត៌មានអំពីច្បាប់និងបទបញ្ជាទាំងឡាយក្នុងវិស័យសេវាកម្ម ។

លើសពីនេះទៀតល័ក្ខខ័ណ្ឌនេះតំរូវឱ្យប្រទេសជឿនលឿនបង្កើតកន្លែងទាក់ទង ដែលតាមរយៈកន្លែងនេះអ្នកផ្តល់សេវាកម្មនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍អាចទទួលបានពត៌មាន *និងអ្វីផ្សេងៗទៀត* ដែលប្រាប់ពីវត្តមានបច្ចេកវិទ្យាសេវាកម្ម និងទិដ្ឋភាពពាណិជ្ជកម្ម និងបច្ចេកទេសនៃការផ្គត់ផ្គង់សេវាកម្មនោះ អំពីច្បាប់ និងបទបញ្ជាទាំងឡាយក្នុងវិស័យសេវាកម្ម ។

កំណើននៃការចូលរួមរបស់ប្រទេសកំពុងអភិវឌ្ឍន៍

កិច្ចព្រមព្រៀងនេះទទួលស្គាល់ថា ក្នុងខណៈដែលឧស្សាហកម្មសេវាកម្មក្នុងប្រទេសកំពុងអភិវឌ្ឍន៍ មិនទាន់អភិវឌ្ឍន៍ពេញលេញនៅឡើយ ពួកគេនឹងត្រូវរក្សាទុកកិច្ចគាំពារដែលមានកំរិតខ្ពស់ ។ ដូច្នេះហើយ កិច្ចព្រមព្រៀងនេះចែងថា នៅពេលធ្វើការសន្យាពីសេរីភាវូបនីយកម្ម ប្រទេសទាំងនោះ គប្បីមានភាពអាចបត់បែនបាន ដើម្បីបើកចំហឱ្យមានការប្រកួតប្រជែងនាំចូលចំពោះវិស័យមួយចំនួនតូច ហើយបង្ខំឱ្យអ្នកផ្គត់ផ្គង់បរទេសដែលចង់ធ្វើវិនិយោគ ឬ បង្កើតសាខា ឬ បុត្រសម្ព័ន្ធ ត្រូវគោរពតាមល័ក្ខខ័ណ្ឌដែលចាំបាច់ក្នុងការធានាឱ្យមានការផ្ទេរបច្ចេកវិទ្យា ឬ ដើម្បីសំរេចដល់គោលបំណងអភិវឌ្ឍន៍ផ្សេងទៀត ។

ការសន្យាធ្វើសេរីភាវូបនីយកម្ម

ការសន្យាធ្វើសេរីភាវូបនីយកម្មដោយបណ្តាប្រទេសជាសមាជិកមួយចំនួននៅក្នុងសន្និសីទឃ្សូហ្គាយមានចែងនៅក្នុងបញ្ជីសម្បទានរបស់ប្រទេសនីមួយៗ ។ ដោយផ្អែកលើមូលដ្ឋានសេរីភាវូបនីយកម្មមួយវិស័យម្តង-មួយវិស័យម្តង និងសំរាប់របៀបទាំងបួនដែលធ្វើឱ្យមានពាណិជ្ជកម្មលើសេវាកម្ម ពួកគេបានបញ្ជាក់ពីល័ក្ខខ័ណ្ឌដែលប្រទេសបានឯកភាពគោរពតាម ដើម្បីបង្កើនលទ្ធភាពចូលទៅកាន់ទីផ្សារ និងពង្រីកប្រព្រឹត្តិកម្មជាតិ ដោយការលុបបំបាត់ ឬ កាត់បន្ថយប្រព្រឹត្តកម្មដែលរើសអើង ចំពោះអ្នកផ្គត់ផ្គង់បរទេសបើប្រៀបធៀបទៅនឹងអ្នកផ្គត់ផ្គង់ក្នុងស្រុក ។ ចាប់តាំងពីការបញ្ចប់សន្និសីទតុមូលឃ្សូហ្គាយមក គេបានរៀបចំអោយមានការចរចារពីសេរីភាវូបនីយកម្មជាច្រើននៅក្នុងវិស័យទូរគមនាគមន៍ និងសេវាកម្មហិរញ្ញវត្ថុ ។

កិច្ចព្រមព្រៀងនេះបានបន្ថែមកាតព្វកិច្ច *និងអ្វីៗផ្សេងទៀត* ទៅលើប្រទេសនានា មិនឱ្យដាក់កំហិតលើការផ្ទេរ និងការបង់ប្រាក់អន្តរជាតិ (លើកលែងតែក្នុងករណីដែលគេស្ថិតនៅក្នុងស្ថានភាពលំបាកផ្នែកជញ្ជីងទូទាត់) នៅក្នុងវិស័យដែលគេបានសន្យាធ្វើសេរីភាវូបនីយកម្មជាក់លាក់ ។

កិច្ចព្រមព្រៀងស្តីពីទិដ្ឋភាពពាណិជ្ជកម្មពាក់ព័ន្ធនឹងច្បាប់ស្តីពីកម្មសិទ្ធិបញ្ញា (TRIPS)

លក្ខណៈនៃកម្មសិទ្ធិបញ្ញា

កិច្ចព្រមព្រៀង TRIPS បង្កើតឡើងតាមកិច្ចព្រមព្រៀងពហុភាគីស្តីពីពាណិជ្ជកម្មលើទំនិញ និងកិច្ចព្រមព្រៀងស្តីពីពាណិជ្ជកម្មលើសេវាកម្ម ដែលជាមូលដ្ឋានគ្រឹះបីនៃប្រព័ន្ធច្បាប់អង្គការពាណិជ្ជកម្មពិភពលោក ។ កម្មសិទ្ធិបញ្ញា មានគោលបំណងស្តាបនានូវបញ្ញាស្មារតីរបស់មនុស្ស ។ សិទ្ធិរបស់អ្នកបង្កើតលើស្នាដៃបង្កើតថ្មី និងស្នាដៃសិល្បៈ ត្រូវបានហៅថាសិទ្ធិលើកម្មសិទ្ធិបញ្ញា។ សិទ្ធិទាំងនេះមាន សិទ្ធិអ្នកនិពន្ធ (ដែលការពារសិទ្ធិអ្នកនិពន្ធសៀវភៅ និងវត្ថុសិល្បៈផ្សេងទៀត) ប្រកាសនីយបត្រតក្កកម្ម (ដែលការពារសិទ្ធិរបស់អ្នកបង្កើត) និងគំនូរឧស្សាហកម្ម (ដែលការពារសិទ្ធិលើគំនូរគ្រឿងតុបតែង) ។ សិទ្ធិទាំងនេះ

កំគ្រប់ដណ្តប់លើម៉ាកពាណិជ្ជកម្ម និងផ្លាកសញ្ញាដទៃទៀត ដែលពាណិជ្ជករប្រើ ដើម្បីបញ្ជាក់ថាផលិតផលរបស់គេ ខុសគ្នាពីផលិតផលរបស់អ្នកដទៃ ហើយបានបង្កើតទំនុកចិត្ត និងកិត្តិស័ព្ទចំពោះអ្នកប្រើប្រាស់ម៉ាក ឬ នាមសញ្ញាទាំងនោះ ។

សារៈសំខាន់នៃការចរចានៃកិច្ចព្រមព្រៀង TRIPS

ការប្រើប្រាស់កម្មសិទ្ធិបញ្ញាដោយគ្មានការអនុញ្ញាត គឺជាការបំពានលើសិទ្ធិរបស់កម្មសិទ្ធិករ ។ ក្នុងរយៈពេលជាច្រើនឆ្នាំមុនពេលមានកិច្ចប្រជុំតុមូល Uruguay មានការកើនឡើងគួរឱ្យចាប់អារម្មណ៍នូវការផលិត និងការធ្វើជំនួញអន្តរជាតិនូវទំនិញក្លែងក្លាយ និងទំនិញលួចចម្លង ។ បញ្ហាទាំងនេះភាគច្រើនបណ្តាលមកពីការអនុវត្តន៍ច្បាប់ស្តីពីម៉ាកពាណិជ្ជកម្ម និងសិទ្ធិអ្នកនិពន្ធ មិនបានគ្រប់គ្រាន់នៅក្នុងប្រទេសជាច្រើន ។ លើសពីនេះទៀត បច្ចេកវិទ្យាខាងប្រកាសនីយប័ត្រតក្កកម្ម ត្រូវបានប្រើប្រាស់ដោយផលិតករនានាដោយគ្មានការអនុញ្ញាតិពីកម្មសិទ្ធិករ ។ ស្តង់ដានៃការការពារ និងរយៈពេលដែលផ្តល់ការការពារដល់សិទ្ធិ ក៏មានភាពខុសគ្នាឆ្ងាយពីប្រទេសមួយទៅប្រទេសមួយ *(ចូរអានជំពូកទី ២០)* ។

បទប្បញ្ញត្តិចម្បងនៃកិច្ចព្រមព្រៀង

កិច្ចព្រមព្រៀង TRIPS បំពេញបន្ថែមលើលើកិច្ចព្រមព្រៀងស្តីពីការការពារកម្មសិទ្ធិបញ្ញា ដែលបានរៀបចំឡើងដោយអង្គការកម្មសិទ្ធិបញ្ញាពិភពលោក (WIPO) ។ ជាពិសេសកិច្ចព្រមព្រៀងចែងពីស្តង់ដា និងរយៈពេលអប្បបរិមាដែលត្រូវផ្តល់ការការពារដល់សិទ្ធិនៃកម្មសិទ្ធិបញ្ញាផ្សេងៗ ។ ក្នុងការធ្វើដូច្នេះ កិច្ចព្រមព្រៀងនេះបានដាក់បញ្ចូលនូវស្តង់ដាទាំងឡាយដែលមានចែងក្នុងអនុសញ្ញាអង្គការ WIPO និងបន្ថែមស្តង់ដាខ្លះៗ ទៅលើប្រកាសនីយប័ត្រតក្កកម្ម ។ កិច្ចព្រមព្រៀងនេះបានតម្រូវថា ប្រទេសជាសមាជិក មិនត្រូវរើសអើងក្នុងចំណោមជនបរទេស និងរវាងជនបរទេស និងពលរដ្ឋរបស់ខ្លួនក្នុងលទ្ធកម្ម វិសាលភាព និងការគោរពសិទ្ធិលើកម្មសិទ្ធិបញ្ញា (ការពង្រីកប្រព្រឹត្តិកម្ម MFN និងប្រព្រឹត្តិកម្មជាតិ) ឡើយ ។ ចំណុចពិសេសនៃកិច្ចព្រមព្រៀង TRIPS គឺថាស្តង់ដានៃកិច្ចគំពារដែលមានចែងនៅក្នុងអនុសញ្ញា WIPO អាចយកមកអនុវត្តបានដោយស្របច្បាប់ ។

ការកំណត់ប្រភេទសមាជិកអង្គការ WTO

ប្រព័ន្ធអង្គការពាណិជ្ជកម្មពិភពលោកបានកំណត់ប្រទេសជាសមាជិក ជាបួនក្រុម គឺប្រទេសជឿនលឿន ប្រទេសកំពុងអភិវឌ្ឍន៍ ប្រទេសក្រីក្រ និងប្រទេសដែលមានសេដ្ឋកិច្ចអន្តរកាល ។ នៅក្នុងសន្និសីទថ្នាក់រដ្ឋមន្ត្រីនាទីក្រុងហ្សឺណែវ ឆ្នាំ ១៩៩៨ មានការបញ្ជាក់ជាលើកដំបូងអំពី "ប្រទេសដែលមានសេដ្ឋកិច្ចតូចៗមួយចំនួន" ក្នុងក្រុមនៃប្រទេសកំពុងអភិវឌ្ឍន៍[៦] ជារួម ។

ប្រទេសទាំងឡាយណាដែលបានចាត់ទុកជា "ជាប្រទេសក្រីក្រ" តាមប្រព័ន្ធអង្គការសហប្រជាជាតិ ក៏ត្រូវបានចាត់ទុកថាជា ប្រទេសក្រីក្រតាមប្រព័ន្ធអង្គការ WTO ដែរ ។ បច្ចុប្បន្ននេះមានប្រទេសចំនួន ៤៨ ស្ថិតនៅក្នុងក្រុមនេះ ។ ទោះជាយ៉ាងនេះក្តី គ្មាននិយមន័យច្បាស់លាស់ និងដែលបានឯកភាព ដើម្បីកំណត់ថាប្រទេសក្រៅពីនេះស្ថិតនៅក្នុងក្រុមណាឡើយ ។ ការកំណត់ថាប្រទេសមួយ "កំពុងអភិវឌ្ឍន៍" ឬមិនមែននោះ ត្រូវបានធ្វើឡើងស្របតាមគោលការណ៍នៃ "ការកំណត់ខ្លួនឯង"។ ប្រទេសទាំងឡាយដែលធ្លាប់មានសេដ្ឋកិច្ចផែនការក្នុងអតីតកាល (ដែលស្ថិតនៅក្នុងអឺរ៉ុបខាងកើត និងអឺរ៉ុបកណ្តាល និងអតីតសហភាពសូវៀត) ហើយដែលកំពុងចាប់ផ្តើមទទួលយកប្រព័ន្ធដែលផ្អែកលើសេដ្ឋកិច្ចផ្សារសេរី និងលទ្ធិប្រជាធិបតេយ្យ ត្រូវបានចាត់ទុកថាប្រទេសដែលមានសេដ្ឋកិច្ចអន្តរកាល ។ ប្រទេសជាសមាជិកក្រៅពីនេះត្រូវបានចាត់ទុកថាស្ថិតនៅក្នុងប្រទេសជឿនលឿន ។

វិធានពាណិជ្ជកម្មតែមួយ

លិខិតុបករណ៍ច្បាប់ពហុភាគីដែលបង្កើតប្រព័ន្ធអង្គការ WTO ត្រូវបានចាត់ទុកថាជាវិធានពាណិជ្ជកម្មតែមួយ ។ វិធាននេះតម្រូវឱ្យប្រទេសជាសមាជិកអង្គការ WTO ទាំងអស់ (ទោះបីជាប្រទេសជឿនលឿន ប្រទេសកំពុងអភិវឌ្ឍន៍ ប្រទេសក្រីក្រ

---

[៦] សេចក្តីប្រកាសថ្នាក់រដ្ឋមន្ត្រី ក្នុងសន្និសីទក្រុងហ្សឺណែវ ចែងក្នុងចំណោមបញ្ហាមួយចំនួនថា "យើងកំពុងមានការព្រួយបារម្ភយ៉ាងខ្លាំងចំពោះការកំណត់ព្រំដែនសេដ្ឋកិច្ចរបស់ប្រទេសក្រីក្រ និងប្រទេសសេដ្ឋកិច្ចតូចៗមួយចំនួន ហើយទទួលស្គាល់ពីសេចក្តីត្រូវការបន្ទាន់ ក្នុងការលើកឡើងពីបញ្ហានេះដែលបានបូកបន្ថែមដោយបញ្ហាបំណុលបរទេសរ៉ាំរ៉ៃ ដែលប្រទេសទាំងនោះកំពុងប្រឈម " ។

និងប្រទេសមានសេដ្ឋកិច្ចអន្តរកាលក្តី) អនុម័តច្បាប់ជាតិ និងបទបញ្ញាទាំងឡាយ ដើម្បីអនុវត្តនីតិវិធានដែលបានកំណត់ដោយកិច្ចព្រមព្រៀងស្តីពីពាណិជ្ជកម្មលើទំនិញ ដូចជាកិច្ចព្រមព្រៀង GATT ឆ្នាំ ១៩៩៤ និងកិច្ចព្រមព្រៀងពាក់ព័ន្ធរួមមានកិច្ចព្រមព្រៀង GATS និង TRIPS ជាដើម ។ ប៉ុន្តែកាតព្វកិច្ចគោរពតាមបទប្បញ្ញត្តិនៃកិច្ចព្រមព្រៀងពហុភាគីអនុវត្តន៍ចំពោះតែប្រទេសជាសមាជិករបស់អង្គការ WTO ដែលបានសំរេចចូលជាសមាជិកនៃកិច្ចព្រមព្រៀងទាំងនេះតែប៉ុណ្ណោះ។ (វណ្ឌ ១ រៀបរាប់ពីកិច្ចព្រមព្រៀងពហុភាគី និង plurilateral Agreement) ។

បទប្បញ្ញត្តិស្តីពីប្រព្រឹត្តិកម្មពិសេស និងដោយឡែកនៃប្រទេសកំពុងអភិវឌ្ឍន៍ និងប្រទេសក្រីក្រ

កិច្ចព្រមព្រៀងពហុភាគីបានទទួលស្គាល់ថា ប្រទេសកំពុងអភិវឌ្ឍន៍ រាប់បញ្ចូលទាំងប្រទេសក្រីក្រផង អាចមានការលំបាកក្នុងការទទួលយកកាតព្វកិច្ចទាំងអស់ ឬ ខ្លះៗ ដែលតម្រូវ និងចែងឱ្យមានការពង្រីកប្រព្រឹត្តិកម្មពិសេស និងដោយឡែកចំពោះប្រទេសទាំងនេះ ។ យើងអាចបែងចែកបទប្បញ្ញត្តិនេះ ឱ្យទៅជាបីប្រភេទធំៗដូចខាងក្រោមនេះ ÷

- ☐ បទប្បញ្ញត្តិដែលតម្រូវឱ្យប្រទេសទាំងឡាយ (ប្រទេសជឿនលឿន និងកំពុងអភិវឌ្ឍន៍) ចាត់វិធានការជួយសំរួលដល់ពាណិជ្ជកម្មរបស់ប្រទេសកំពុងអភិវឌ្ឍន៍ និងប្រទេសក្រីក្រ ។
- ☐ ត្រូវមានភាពអាចបត់បែនសំរាប់ប្រទេសកំពុងអភិវឌ្ឍន៍ និងប្រទេសក្រីក្រ ក្នុងការទទួលយកកាតព្វកិច្ចដែលបង្គាប់ដោយកិច្ចព្រមព្រៀងអង្គការ WTO ។
- ☐ បទប្បញ្ញត្តិស្តីពីជំនួយការបច្ចេកទេសសំរាប់អោយប្រទេសកំពុងអភិវឌ្ឍន៍ និងប្រទេសក្រីក្រ កសាងសមត្ថភាពក្នុងការអនុវត្តន៍កិច្ចព្រមព្រៀងទាំងនេះ ។

សេចក្តីវិភាគសង្ខេបពីបទប្បញ្ញត្តិទាំងនេះ មានភ្ជាប់មកជាមួយក្នុងឧបសម្ព័ន្ធទី ២ ។

នីតិវិធីដោះស្រាយវិវាទ

ប្រព័ន្ធអង្គការ WTO ចែងពីយន្តការដោះស្រាយវិវាទ នៅពេលដែលប្រទេសមួយបានរកឃើញថា ប្រទេសមួយទៀតកំពុងបំពានលើវិធាន និងកិច្ចប្រឹងប្រែងរកដំណោះស្រាយសមស្រប ក្នុងករណីការពិគ្រោះយោបល់ទ្វេភាគីទទួលបរាជ័យ ។ ជាទូទៅវិវាទដែលត្រូវបានដាក់ជូនអង្គការ WTO គឺកើតចេញពីពត៌មានដែលបានផ្តល់ដោយឧស្សាហកម្ម ឬ សាខារបស់គេជូនទៅរដ្ឋាភិបាលអំពីការលំបាកដែលគេប្រឈមក្នុងការរកទីផ្សារសំរាប់ផលិតផលរបស់គេនៅទីផ្សារខាងក្រៅ *(ចូរអានជំពូកទី ១)* ។

ទោះបីជាក្នុងដំណើរការនៃការដោះស្រាយវិវាទ - ការពិគ្រោះយោបល់ទ្វេភាគី ការពិនិត្យដោយស្ថាប័នដោះស្រាយវិវាទ និងក្រោយមកការពិនិត្យ ដោយស្ថាប័នឧទ្ធរណ៍ - តំណាងរដ្ឋាភិបាលជាអ្នកចូលរួម ពួកគេត្រូវតែពឹងផ្អែកខ្លាំងទៅលើវិវាទ និងការគាំទ្រដែលមាននិរន្តរភាពពីឧស្សាហកម្ម និងសមាគមន៍ទាំងឡាយដែលមានផលប្រយោជន៍ក្នុងកម្មវត្ថុនៃវិវាទនោះ ។ លទ្ធភាពរបស់រដ្ឋាភិបាលក្នុងការដោះស្រាយរឿងក្តីដោយមានប្រសិទ្ធិភាព ឬ ដើម្បីការពារផលប្រយោជន៍ដែលត្រូវបានប្តឹងប្រឆាំង និងខ្លួនពឹងផ្អែកយ៉ាងខ្លាំងទៅលើជំនួយ និងការគាំទ្រដែលក្រុមឧស្សាហកម្មពាក់ព័ន្ធបានផ្តល់ឱ្យ ។

យន្តការសំរាប់ពិនិត្យមើលគោលនយោបាយពាណិជ្ជកម្ម

ក្រៅពីការផ្តល់យន្តការដោះស្រាយវិវាទ អង្គការ WTO ដើរតួជាវេទិកាសំរាប់ពិនិត្យយ៉ាងទៀងទាត់លើគោលនយោបាយពាណិជ្ជកម្មរបស់ប្រទេសជាសមាជិក ។ គោលបំណងនៃការពិនិត្យនេះ មានមុខងារពីរយ៉ាង ។ ទីមួយ ការពិនិត្យនេះមានគោលបំណងចង់រកឱ្យឃើញថាតើប្រទេសនេះបានគោរពតាមវិធាន និងការសន្យាទាំងឡាយ ដែលចែងក្នុងកិច្ចព្រមព្រៀងពហុភាគីបានដល់កំរិតណា (និងកិច្ចព្រមព្រៀង plurilateral បើមាន) ។ តាមការពិនិត្យទៀងទាត់ទាំងនេះ អង្គការ WTO ដើរតួជាអ្នកឃ្លាំមើល ដើម្បីធានាឱ្យមានការអនុវត្តន៍វិធាន និងជួយការពារកុំឱ្យមានការប៉ះទង្គិចខាងពាណិជ្ជកម្ម ។ ប៉ុន្តែបទប្បញ្ញត្តិដែលចែងពីយន្តការពិនិត្យបញ្ជាក់ថាការ ពិនិត្យនេះគ្មានគោលបំណងធ្វើជាមូលដ្ឋាននៃការបង្ខំឱ្យអនុវត្តន៍កាតព្វកិច្ច ហើយក៏មិនអាចយកការ

និន្នាការសេរីភាវូបនីយកម្ម ដែលប្រទេសជាសមាជិកអនុវត្តន៍ ក្រោយពីមានការសន្យានៅក្នុងកិច្ចប្រជុំតុមូលឈ្នួរ៉ហ្គាយ

ពិនិត្យនេះជាយន្តការដោះស្រាយវិវាទដែរ ។ កម្មវត្ថុមួយនៃការត្រួតពិនិត្យនេះ គឺដើម្បីផ្តល់នៅតំលាភាព និងការយល់ដឹងអោយបានច្រើន ពីគោលនយោបាយពាណិជ្ជកម្ម និងការអនុវត្តន៍របស់បណ្តាប្រទេសជាសមាជិក *(ចូរអានជំពូកទី ១)* ។

ការកែលំអលទ្ធភាពបើកទីផ្សារ

ក្រៅពីការកំណត់ប្រព័ន្ធច្បាប់សំរាប់ការធ្វើពាណិជ្ជកម្មអន្តរជាតិ ប្រព័ន្ធពាណិជ្ជកម្មពហុភាគីចែងពីវេទិកាសំរាប់ការចរចារឱ្យមានសេរីភាវូបនីយកម្មពាណិជ្ជកម្ម ។ ជាលទ្ធផលនៃការចាចារតុមូលជាបន្តបន្ទាប់ ក្នុងរយៈពេល ៥០ ឆ្នាំកន្លងមកនេះ យើងទទួលបានការកាត់បន្ថយពន្ធគយ និងរបាំងពាណិជ្ជកម្មជាច្រើន ។ កិច្ចចរចារតុមូល Uruguay បានចាប់ផ្តើមនូវជំហានដ៏សំខាន់សំដៅឱ្យមានការកាត់បន្ថយរបាំងពាណិជ្ជកម្មទាំងនេះ ។

វិស័យឧស្សាហកម្ម

ការកាត់បន្ថយពន្ធគយ

ជាលទ្ធផលនៃការកាត់បន្ថយដែលបានធ្វើឡើងនៅក្នុងកិច្ចប្រជុំតុមូលលើកមុន អត្រាពន្ធគយមធ្យមរបស់ប្រទេសជឿនលឿនលើផលិតផលឧស្សាហកម្មបានថយចុះពីប្រហែល ៤០% ក្នុងឆ្នាំ ១៩៤៨ នៅពេលបង្កើតអង្គការ GATT មកត្រឹមអត្រាប្រហែល ៧% នៅពេលបញ្ចប់សន្និសីទតុមូលទីក្រុងតូក្យូ ។ នៅក្នុងសន្និសីទតុមូល Uruguay ប្រទេសទាំងនេះបានឯកភាពកាត់ពន្ធគយរបស់គេ ឱ្យបានប្រហែល ៤០% គឺកាត់អត្រាស្មើៗគ្នា ក្នុងរយៈពេលប្រាំឆ្នាំ ។ ប៉ុន្តែភាគរយនៃការកាត់បន្ថយពន្ធគយលើផលិតផលនាំចេញខ្លះ ដែលជាអត្ថប្រយោជន៍របស់ប្រទេសកំពុងអភិវឌ្ឍន៍ ដូចជាផ្នែកវាយនភណ្ឌ និងសំលៀកបំពាក់ ស្បែកសត្វ និងផលិតផលស្បែកសត្វ គឺមានអត្រាទាបជាងអត្រាមធ្យម ។ ប្រទេសកំពុងអភិវឌ្ឍន៍មួយចំនួន និងប្រទេសដែលមានសេដ្ឋកិច្ចអន្តរកាលក៏បានព្រមព្រៀងកាត់បន្ថយពន្ធគយរបស់គេស្មើរតែពីរភាគបីភាគរយនៃអត្រាដែលប្រទេសជឿនលឿនបានកាត់បន្ថយ ។ ជាលទ្ធផលគេរំពឹងថា កំរិតពន្ធគយដែលអនុវត្តចំពោះផលិតផលឧស្សាហកម្ម ធ្លាក់ចុះដូចខាងក្រោមនេះ (សូមអានមាត្រា ១៦):

- ☐ ពី ៦.៣% ទៅ ៣.៨% នៅក្នុងប្រទេសជឿនលឿន
- ☐ ពី ១៥.៣% ទៅ ១២.៣% នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍
- ☐ ពី ៨.៦% ទៅ ៦% នៅក្នុងប្រទេសដែលមានសេដ្ឋកិច្ចអន្តរកាល។

តាមវិធានទូទៅ ដំណើរការនៃការកាត់បន្ថយពន្ធនេះត្រូវបញ្ចប់នៅថ្ងៃទី ១ ខែមករា ឆ្នាំ ២០០០ នៅពេលដែលអត្រាចុងក្រោយដែលជាលទ្ធផលនៃការកាត់ភាគរយដែលបានឯកភាពគ្នា នៅក្នុងសន្និសីទតុមូល Uruguay ចូលជាធរមានពេញលេញ ។ ក្នុងករណីខ្លះមានការកំណត់ដំណាក់កាលយូរជាងនេះ សំរាប់បណ្តាប្រទេសជាសមាជិកទាំងឡាយ ។

កិច្ចព្រមព្រៀងវាយនភណ្ឌ និងសំលៀកបំពាក់

សមិទ្ធិផលដ៏សំខាន់មួយទៀតនៃសន្និសីទតុមូលឈ្នួរ៉ហ្គាយគឺសេចក្តីសំរេចលុបចោលល័ក្ខខ័ណ្ឌនៃការដាក់កំហិតលើបរិមាណ នាំចូលទំនិញវាយនភណ្ឌ និងសំលៀកបំពាក់ ។ ល័ក្ខខ័ណ្ឌទាំងនេះត្រូវបានកំណត់ដោយប្រទេសជឿនលឿនមួយចំនួន ជាពិសេសសំដៅលើការនាំចូលពីប្រទេសកំពុងអភិវឌ្ឍន៍ តាមកិច្ចព្រមព្រៀងទ្វេភាគីដែលបានចរចារក្រោមកិច្ចព្រមព្រៀងពហុសរសៃអំបោះ (Multi-Fibre Agreement "MFA") ដែលចែងពីអញ្ញាត្រកម្ម វិធាននៃកិច្ចព្រមព្រៀង GATT ដែលហាមឃាត់ការ ដាក់កំហិតលើបរិមាណប្រកបដោយការរើសអើង ។ កិច្ចព្រមព្រៀងស្តីវាយនភណ្ឌ និងសំលៀកបំពាក់ (Agreement on Textiles and Clothing "ATC") ដែលជំនួសកិច្ចព្រមព្រៀង MFA ចែងពីការលុបចោលការដាក់កំហិតលើបរិមាណទំនិញ វាយនភណ្ឌជា ៤ ដំណាក់កាលក្នុងរយៈពេល១០ឆ្នាំ ។ កម្មវិធីនៃការលុបចោលជាដំណាក់ៗនេះនឹងបញ្ចប់នៅថ្ងៃទី១ ខែមករា ឆ្នាំ២០០៥ ។

ចាប់ពីពេលនោះមក ពាណិជ្ជកម្មវាយនភណ្ឌនឹងត្រូវបញ្ចូលទៅក្នុងកិច្ចព្រមព្រៀង GATT ទាំងស្រុង និងគ្រប់គ្រងដោយវិធាននៃកិច្ចព្រមព្រៀងនេះ *(ចូរអានជំពូកទី ១៨)* ។

កិច្ចព្រមព្រៀងស្តីពីកសិកម្ម

កន្លងមក វិធាននៃកិច្ចព្រមព្រៀង GATT ស្តីពីវិស័យកសិកម្មមិនសូវមានអនុភាពខ្លាំងក្លាទេ ឬ បើមានការអនុវត្តន៍ ក៏អនុវត្តតិចតួចប៉ុណ្ណោះ ។ ប្រទេសជឿនលឿនខ្លះបានការពារនូវផលិតផលកសិកម្មក្នុងតំបន់ដែលមានសីតុណ្ហភាពជាក់លាក់ ជាពិសេសផលិតកម្មដែលមានចំណាយខ្ពស់ និងគ្មានប្រសិទ្ធិភាព (ឧ. ស្រូវសាឡី និងធញ្ញជាតិផ្សេងៗទៀត សាច់ និងផលិតផលទឹកដោះគោ) តាមការដាក់កំហិតលើបរិមាណ និង/ឬពន្ធអាករផ្សេងៗ បន្ថែមលើពន្ធគយដែលមានអត្រាខ្ពស់។ កិរិតនៃការការពារនេះ តែងតែធ្វើឱ្យមានកំណើនផលិតកម្មក្នុងស្រុក ដែលមិនអាចយកទៅលក់ក្នុងទីផ្សារអន្តរជាតិបាន (ដោយតម្លៃខ្ពស់ពេក) ប្រសិនបើគ្មានឧបត្ថម្ភធនសំរាប់ការនាំចេញទេ ។ ការលក់ទំនិញតាមរូបភាពឧបត្ថម្ភធននេះ បានគាបសង្កត់លើតម្លៃទំនិញអន្តរជាតិ ។ ការលក់បែបនេះក៏បានធ្វើឱ្យផលិតករដែលមានប្រសិទ្ធិភាពបាត់បង់ទីផ្សាររបស់គេមួយចំណែកផងដែរ។ *(ចូរអានជំពូកទី ១៥)* ។

កម្មវិធីកំណែទម្រង់ដែលបានអនុម័តតាមកិច្ចព្រមព្រៀងស្តីពីកសិកម្ម ដែលបានចរចារក្នុងសន្និសីទតុមូលឃ្លុយហ្គាយ មានគោលបំណងបង្កើតប្រព័ន្ធពាណិជ្ជកម្មទីផ្សារបើកចំហ និងស្មោះត្រង់ក្នុងវិស័យកសិកម្ម ។ ការចរចារដែលបានអនុវត្តន៍ស្របតាមវិធានទាំងនេះ បានបង្កើតឱ្យមានការរីកចំរើនខ្លះៗក្នុងសេរីភាវូបនីយកម្មនៃការធ្វើពាណិជ្ជកម្មផលិតផលទាំងនេះ ។

ប្រទេសជាសមាជិកទាំងអស់បានព្រមព្រៀងលុបចោលការដាក់កំហិតលើបរិមាណ និងវិធានការមិនមែនពន្ធគយ លើផលិតផលកសិកម្មដែលមានពន្ធគយ ។ ការកំណត់អត្រា "ពន្ធគយ"ថ្មី (កើតឡើងដោយសារការបន្ថែមវិធានការមិនមែនពន្ធគយ ទៅលើពន្ធគយដែលមានស្រាប់) ព្រមទាំងពន្ធគយដទៃទៀត ដែលកំពុងត្រូវបានកាត់បន្ថយក្នុងរយៈពេលប្រាំមួយឆ្នាំ (១០ឆ្នាំចំពោះប្រទេសកំពុងអភិវឌ្ឍន៍) ដោយចាប់ផ្តើមពីឆ្នាំ ១៩៩៥ ពីអត្រាមធ្យម ៣៦% សំរាប់ប្រទេសជឿនលឿន (២៤% សំរាប់ប្រទេសកំពុងអភិវឌ្ឍន៍) ។ ប្រទេសក្រីក្រមិនមានការកាត់បន្ថយពន្ធគយណាមួយឡើយ ។ លើសពីនេះទៀត ប្រទេសជាសមាជិកទាំងអស់ត្រូវគោរពតាមអត្រាពន្ធគយដែលអនុវត្តន៍ចំពោះផលិតផលកសិកម្មទាំងអស់ ។ ប៉ុន្តែក្នុងករណីភាគច្រើន ប្រទេសកំពុងអភិវឌ្ឍន៍ ត្រូវគោរពតាមអត្រាដែលខ្ពស់ជាងអត្រាដែលអនុវត្តន៍បច្ចុប្បន្ន ឬ អត្រាដែលកាត់បន្ថយរួចរបស់គេ ។ ប្រទេសជាសមាជិកដែលប្រើឧបត្ថម្ភធន បានព្រមព្រៀងគ្នាកាត់បន្ថយឧបត្ថម្ភធនទាំងក្នុងវិស័យផលិតកម្ម និងវិស័យនាំចេញ ឱ្យនៅត្រឹមកាគរយដែលបានឯកភាពគ្នា *(ចូរអានជំពូកទី១៥)* ។

ការប៉ាន់ប្រមាណប្រាក់ចំណូល និងផលចំណេញពីពាណិជ្ជកម្ម

សំរាប់សហគ្រាសពាណិជ្ជកម្មដែលបានសំរេចយកយុទ្ធសាស្ត្រទីផ្សារ ជាចាំបាច់ត្រូវដឹងថា គេនឹងទទួលបានផលចំណេញអ្វី - ក្នុងន័យ នៃប្រាក់ចំណូល និងពាណិជ្ជកម្ម - ពីសេរីភាវូបនីយកម្មពាណិជ្ជកម្មនេះ ។ ទាក់ទិននឹងវិធានការលុបចោលពន្ធគយ និងរបាំងពាណិជ្ជកម្មទំនិញ អង្គការពាណិជ្ជកម្មពិភពលោក និងអង្គការដទៃទៀត បានធ្វើការសិក្សាមួយចំនួន ក្នុងកំរិតម៉ាក្រូសេដ្ឋកិច្ច ដើម្បីវាយតម្លៃផលប៉ះពាល់នៃវិធានទាំងនេះ ទៅលើប្រាក់ចំណូល និងពាណិជ្ជកម្មទូទាំងពិភពលោក ។ តាមការនិយាយជាទូទៅ ការប៉ាន់ប្រមាណលើផលចំណេញពីសន្និសីទតុមូលឃ្លុយហ្គាយបានបង្ហាញថា កាលណាមានការអនុវត្តន៍វិធានការសេរីភាវូបនីយកម្មដែលរដ្ឋាភិបាលទាំងឡាយបានឯកភាពបានពេញលេញ នោះជំរុញឱ្យមានការកើនឡើងនូវប្រាក់ចំណូលទូទាំងពិភពលោកបាន ១% ភាគរយក្នុងមួយឆ្នាំ ឬ ពី ២០០ កោដិដុល្លារ ទៅ ៥០០ កោដិដុល្លារ សហរដ្ឋក្នុងមួយឆ្នាំ ។ ការប៉ាន់ប្រមាណពីកំណើនទំហំនៃពាណិជ្ជកម្មពិភពលោក មានភាពខុសគ្នាអាស្រ័យទៅតាមការសន្និដ្ឋាននៅក្នុងការសិក្សានានា ហើយមានអត្រាក្នុងចន្លោះពី ៦% ទៅ ២០% ក្នុងមួយឆ្នាំ ។ ប៉ុន្តែការសិក្សាទាំងនេះ បានបញ្ជាក់ថាប្រទេសទាំងឡាយ នៅក្នុងតំបន់ខុសគ្នាមិនបានទទួលកំណើនទាំងនេះស្មើគ្នាទេ ។ ប្រទេសជឿនលឿន និងប្រទេសកំពុងអភិវឌ្ឍន៍ខ្លះដែលមានដំណាក់កាលអភិវឌ្ឍន៍ខ្ពស់ ជាប្រទេសដែលបានទទួលអត្ថប្រយោជន៍ច្រើនជាងគេ ។ ប្រទេសទាំងឡាយក្នុងទ្វីបអាហ្វ្រិក និងប្រទេសក្រីក្រ ជាប្រទេសដែលបានទទួលអត្ថប្រយោជន៍តិច ឬ គ្មានបានទទួលអ្វីសោះ ។

ត្រូវមានការប្រុងប្រយ័ត្នក្នុងការបកស្រាយលទ្ធផលនៃការសិក្សាម៉ាក្រូសេដ្ឋកិច្ច

កាលណាការសិក្សាម៉ាក្រូសេដ្ឋកិច្ចផ្តល់ការណែនាំដែលអាចមានផលប្រយោជន៍ដល់សហគមន៍ពាណិជ្ជកម្ម នោះគេត្រូវប្រើប្រាស់លទ្ធផលនៃការសិក្សានេះ ដោយប្រុងប្រយ័ត្ន ជាពិសេសក្នុងការរៀបចំផែនការសំរាប់អនាគត និងក្នុងការធ្វើសេចក្តីសំរេចការងារប្រចាំថ្ងៃ ។ ឥឡូវនេះមានការចង្អុលបង្ហាញយ៉ាងច្បាស់ថាការប៉ាន់ប្រមាណទាំងនេះដែលបានធ្វើមុន ឬ ភ្លាមៗ បន្ទាប់ពីការបញ្ចប់សន្និសីទតុមូលឈ្នួយហ្គាយ នឹងត្រូវមានការកែសំរួលមួយផ្នែកធំពីលើចុះក្រោមដោយមានមូលហេតុចម្បងពីរ ។

មូលហេតុទី ១ ឥឡូវនេះយើងយល់ច្បាស់ថាក្នុងវិស័យខ្លះៗ ប្រទេសមួយចំនួនបានអនុវត្តការសន្យាខាងសេរីភាវូបនីយកម្មរបស់គេគ្រាន់តែឱ្យឃើញជារូបរាង មិនមែនស៊ីជំរៅដល់ខ្លឹមសារទេ ។ ឧទាហរណ៍ ការសិក្សាភាគច្រើនបានប៉ាន់ប្រមាណថា កំណើនទាំងមូលនៃពាណិជ្ជកម្ម នឹងកើតមកពីសេរីភាវូបនីយកម្មពាណិជ្ជកម្មវាយនភណ្ឌ ។ ការសិក្សានេះមិនបានព្យាករណ៍ថាប្រទេសទាំងឡាយដែលរក្សាទុកនូវការដាក់កំហិតលើបរិមាណ នឹងប្រើលទ្ធភាពដែលគេមានតាមវិធាននេះ ដើម្បីលុបចោលការដាក់កំហិតមួយចំនួនតូចក្នុងកំឡុងប្រាំពីរឆ្នាំដំបូង នៃរយៈពេលអន្តរកាល១០ឆ្នាំ ហើយផលវិបាកគឺល័ក្ខខ័ណ្ឌទាំងមូលនឹងត្រូវលុបចោលឱ្យអស់ នៅថ្ងៃទី ១ ខែមករា ឆ្នាំ ២០០៥ នៅពេលចប់រយៈពេលអន្តរកាល ។

មូលហេតុទី ២ ការសិក្សាបានសន្និដ្ឋានថា សេដ្ឋកិច្ចពិភពលោកនឹងរីកចំរើនតាមការិតធម្មតា ហើយការរីកចំរើននេះមិនមានការធ្លាក់ចុះទេ ។ សេចក្តីពឹងនេះត្រូវបានគេយកចិត្តទុកដាក់យ៉ាងខ្លាំង ។ វិបត្តិហិរញ្ញវត្ថុអាស៊ីដែលចាប់ផ្តើមនៅពាក់កណ្តាលឆ្នាំ ១៩៩៧ និងដំណើរការសេដ្ឋកិច្ចអន់ខ្សោយរបស់ជប៉ុនក្នុងឆ្នាំ ១៩៩៨ បាននាំឱ្យសេចក្តីត្រូវការមានការធ្លាក់ចុះជាទូទៅជាពិសេសក្នុងទីផ្សារអាស៊ី ព្រមទាំងការធ្លាក់ចុះតម្លៃប្រេងឥន្ធនៈ និងទំនិញផ្សេងទៀត ។

សេរីភាវូបនីយកម្មក៏អាចមានផលប៉ះពាល់ផ្សេងៗ ទៅលើសហគ្រាសនៅក្នុងប្រទេសទាំងឡាយផងដែរ ។ យើងលើកយកករណីវាយនភណ្ឌដែលប្រទេសនាំចូលបានអនុវត្តដោយផ្អែកលើមូលដ្ឋានរើសអើង ។ សហគ្រាសទាំងឡាយនៅក្នុងប្រទេស ក ដែលការនាំចេញរបស់ប្រទេសនេះ ត្រូវបានដាក់កំហិត អាចដឹងបានថា គេអាចនឹងទទួលផលប្រយោជន៍ពីការលុបចោលការដាក់កំហិតទាំងនោះនៅក្នុងទីផ្សារធំៗរបស់គេ ហើយអាចអនុម័តយុទ្ធសាស្ត្រផលិតកម្ម និងយុទ្ធសាស្ត្រនាំចេញ ដើម្បីទទួលអត្ថប្រយោជន៍ពីកាលានុវត្តន៍ភាពពាណិជ្ជកម្មដែលបានកែលំអទាំងនោះ ។ ផ្ទុយទៅវិញ នៅក្នុងប្រទេស ខ ដែលការនាំចេញរបស់ប្រទេសនេះមិនត្រូវបានដាក់កំហិត អាចត្រូវរៀបចំខ្លួនដើម្បីសំរបទៅនឹងកំណើននៃការប្រកួតប្រជែងដែលនឹងកើតឡើងបន្ទាប់ពីការលុបចោលល័ក្ខខ័ណ្ឌទាំងនោះនៅក្នុងប្រទេស ក ។

ដូចគ្នានេះដែរ សហគ្រាសរបស់ប្រទេសដែលបានទទួលអត្ថប្រយោជន៍ពីការអនុគ្រោះពន្ធគយនៅទីផ្សារធំៗរបស់គេ អាចយល់ថាលទ្ធភាពទទួលបានទីផ្សារនេះត្រូវបានកាត់ផ្តាច់ ដោយការកាត់បន្ថយ MFN ដែលជាលទ្ធផលនៃការសន្យាដែលធ្វើឡើងក្នុងសន្និសីទតុមូលឈ្នួយហ្គាយ ។ ការសិក្សាម៉ាក្រូសេដ្ឋកិច្ចបានចង្អុលបង្ហាញថាការកាត់បន្ថយទំហំនៃការអនុគ្រោះ មិនអាចបង្កឱ្យមានផលប៉ះពាល់អវិជ្ជមានទូទៅ លើពាណិជ្ជកម្មរបស់ប្រទេស ដែលទទួលការអនុគ្រោះទេ ។ ប៉ុន្តែសហគ្រាសនាំចេញនីមួយៗ អាចដឹងថាការខាតបង់ការអនុគ្រោះនេះ មានផលប៉ះពាល់អវិជ្ជមានដល់ពាណិជ្ជកម្មយ៉ាងពិតប្រាកដ ។ បញ្ហានេះអាចកើតមានឡើងប្រសិនបើការអនុគ្រោះនេះមានប្រយោជន៍ ជាក់ស្តែងក្នុងពាណិជ្ជកម្ម ដោយរាប់បញ្ចូលក្នុងកត្តាទាំងនេះ ដូចជាតម្លៃដែលអ្នកផ្គត់ផ្គង់បានទូទាត់យកក្នុងទីផ្សារនាំចេញ ។

ដូច្នេះជាកត្តាសំខាន់ សហគ្រាសអាជីវកម្មត្រូវសិក្សាម៉ាក្រូសេដ្ឋកិច្ចបន្ថែមទៀត ដោយពិនិត្យផលប៉ះពាល់នៃការកាត់បន្ថយពន្ធគយនិងការលុបចោលរបាំងពាណិជ្ជកម្មលើផលិតផលដែលគេនាំចេញទៅកាន់ទីផ្សារគោលដៅរបស់គេ ។ កង្វះខាតធនធានហិរញ្ញវត្ថុនិងបច្ចេកវិទ្យា អាចរារាំងសហគ្រាសទាំងឡាយ (ជាពិសេសធុនតូច និងមធ្យម) មិនឱ្យអនុវត្តការសិក្សាបែបនេះបានដោយខ្លួនឯង ដូច្នេះវិទ្យាស្ថានជាតិត្រូវមានគំនិតផ្តួចផ្តើមធ្វើការសិក្សាលើបញ្ហានេះ ។ អង្គការអន្តរជាតិ ដូចជាលេខាធិការដ្ឋានប្រទេសសហធន (Commonwealth) និងមជ្ឈមណ្ឌលបច្ចេកវិទ្យាពត៌មាន ក៏អាចជួយធ្វើការសិក្សាលើផលិតផល ដែលមានផលប្រយោជន៍សំរាប់ការនាំចេញរបស់ប្រទេសកំពុងអភិវឌ្ឍន៍ និងប្រទេសក្រីក្របានផងដែរ ។

ការអភិវឌ្ឍន៍ក្រោយពេលបង្កើតអង្គការពាណិជ្ជកម្មពិភពលោក

ដូចដែលបានគូសបញ្ជាក់ពីខាងលើរួចមកហើយថា WTO គឺជាវេទិកាសំរាប់ធ្វើការពិចារណាទៅលើបញ្ហាផ្សេងៗពាក់ព័ន្ធនឹងពាណិជ្ជកម្មអន្តរជាតិ ជាវេទិកាសំរាប់បន្តធ្វើការចរចាលើសេរីភាវូបនីយកម្មពាណិជ្ជកម្ម និងការអភិវឌ្ឍន៍បន្ថែមទៀតនូវវិធានសំរាប់ប្រធានបទថ្មីៗ ដែលប្រទេសជាសមាជិកចាត់ទុកថាមានផលប៉ះពាល់ទៅលើពាណិជ្ជកម្មអន្តរជាតិ ។ ការអភិវឌ្ឍន៍មួយចំនួនដែលកើតមានឡើងក្នុងអំឡុងឆ្នាំ ១៩៩៥-១៩៩៨ នឹងមានរៀបរាប់ជូនដូចខាងក្រោមនេះ ។

បញ្ហាពាណិជ្ជកម្មរបស់បណ្តាប្រទេសក្រីក្រ

ការកាត់បន្ថយបញ្ហាពាណិជ្ជកម្មរបស់បណ្តាប្រទេសក្រីក្រ គឺជាកត្តាសំខាន់មួយ ដែល WTO ចាប់អារម្មណ៍ក្នុងអំឡុងឆ្នាំ ១៩៩៥-១៩៩៨ ។ ដូចដែលគូសបញ្ជាក់ពីខាងលើរួចមកហើយថា ពាណិជ្ជកម្មរបស់បណ្តាប្រទេសក្រីក្រ ប្រហែលជាបានទទួលផលប្រយោជន៍តិចតួចប៉ុណ្ណោះ ពីការកាត់បន្ថយអត្រាពន្ធគយ និងការលប់ចោលរបាំងផ្សេងៗ ក្នុងពេលកិច្ចចរចាតុមូលឃ្លួរ៉ូហ្គាយ ។ កត្តានេះបូកផ្សំជាមួយការថយចុះជាប្រចាំនៃតំលៃទំនិញនាំចេញរបស់គេ និងការដាក់កំហិតផ្នែកផ្គត់ផ្គង់លើការផលិតផលិតផលសំរាប់នាំចេញ រីតតែធ្វើអោយពាណិជ្ជកម្មរបស់ពួកគេបានទទួលផលប្រយោជន៍ មានកំរិតបំផុតនៅក្នុងពាណិជ្ជកម្មអន្តរជាតិ ។ ដើម្បីរកដំណោះស្រាយសំរាប់បញ្ហាទាំងនេះ និងដោយអនុលោមទៅតាមសេចក្តីសំរេចនាសម័យប្រជុំជាន់ខ្ពស់ ដែលប្រារព្ធធ្វើឡើងក្នុងខែតុលា ឆ្នាំ១៩៩៧ ស្តីពីការផ្តួចផ្តើមគំនិតសមាហរណកម្មសំរាប់អភិវឌ្ឍន៍ពាណិជ្ជកម្មរបស់បណ្តាប្រទេសក្រីក្រ ប្រទេសជឿនលឿនភាគច្រើនបានធ្វើការកែលំអប្រព័ន្ធអនុគ្រោះទូទៅរបស់ខ្លួន ដើម្បីអនុញ្ញាតិអោយមានការនាំចូលដោយរួចពន្ធនូវផលិតផលនាំចេញដោយប្រទេសក្រីក្រ ។ ប្រទេសកំពុងអភិវឌ្ឍន៍មួយចំនួនបានចាត់វិធានការកែលំអការនាំចូលពីបណ្តាប្រទេសទាំងនេះ តាមមូលដ្ឋានអនុគ្រោះ ក្នុងខណៈពេលប្រទេសផ្សេងទៀត កំពុងពិចារណាទៅលើសមិទ្ធិលទ្ធភាពក្នុងការចាប់ផ្តើមអនុវត្តគំរោងនេះ ។

សម័យប្រជុំជាន់ខ្ពស់ ក៏អនុម័តផងដែរទៅលើកម្មវិធីសមាហរណកម្មនៃការផ្តល់ជំនួយ ពាក់ព័ន្ធពាណិជ្ជកម្មរបស់បណ្តាប្រទេសក្រីក្រ ។ តាមកម្មវិធីនេះ ទីភ្នាក់ងារចំនួន ៦ មាន ITC, WTO, UNCTAD, UNDP, IMF និងធនាគារពិភពលោក បានសំរបសំរួលគ្នាផ្តល់ជំនួយការពាក់ព័ន្ធពាណិជ្ជកម្ម ដោយឈរលើមូលដ្ឋាននៃការវាយតំលៃពីតំរូវការរបស់ប្រទេសក្រីក្រនីមួយៗ។ ជំនួយការនេះបច្ចុប្បន្នផ្តល់ទៅលើវិស័យមួយចំនួន រួមមាន ការអនុវត្តន៍តាមវិធាន និងកាតព្វកិច្ច WTO ក្នុងការកាត់បន្ថយការដាក់កំហិតផ្នែកផ្គត់ផ្គង់ ដូចជាហេរដ្ឋារចនាសម្ព័ន្ធ ការកសាងសមត្ថភាពស្ថាប័ន និងមនុស្ស និងតំរូវការរបស់ផ្នែកឯកជន ។ កម្មវិធីប្រមើលមើលពីការរៀបចំការចរចាតុមូលពាក់ព័ន្ធនឹងពាណិជ្ជកម្ម របស់ប្រទេសក្រីក្រនីមួយៗ ការចរចាទាំងនេះចូលរួមដោយដៃគូពាណិជ្ជកម្មទ្វេភាគី ទីភ្នាក់ងារពហុភាគី និងអង្គការក្នុងតំបន់ផ្សេងទៀត ដែលចាប់អារម្មណ៍ក្នុងការផ្តល់ហិរញ្ញប្បទាន ឬពង្រីកកម្មវិធីជំនួយការបច្ចេកទេសដែលបានរៀបចំរួចមកហើយ ។

ការចរចាស្តីពីសេរីភាវូបនីយកម្មពាណិជ្ជកម្មបន្ថែម

ប្រទេសជាសមាជិកមួយចំនួន ក្នុងអំឡុងពេលនេះ បានប្រកាន់យកនូវវិធានការសេរីភាវូបនីយកម្មពាណិជ្ជកម្មបន្ថែមទៀត ទាំងពាណិជ្ជកម្មលើទំនិញ និងលើសេវាកម្ម ។ តាមសេចក្តីប្រកាសថ្នាក់រដ្ឋមន្ត្រីស្តីពីផលិតផលបច្ចេកវិទ្យាពត៌មាន (ចុះថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ១៩៩៦ ដែលគេស្គាល់ថាជាកិច្ចព្រមព្រៀងបច្ចេកវិទ្យាពត៌មាន ឬ ITA) ធ្វើអោយបណ្តាប្រទេសដែលមានផលប្រយោជន៍ពាណិជ្ជកម្មក្នុងផលិតផលបច្ចេកវិទ្យាពត៌មាន ព្រមព្រៀងលប់ចោលពន្ធគយលើផលិតផលដូចជា កុំព្យូទ័រ បរិក្ខាទូរគមនាគមន៍ semiconductor បរិក្ខាផលិត semiconductor, software និងបរិក្ខាវិទ្យាសាស្ត្រផ្សេងៗ ។ ម្យ៉ាងទៀត បណ្តាប្រទេសដែលចាប់អារម្មណ៍លើការនាំចេញផលិតផលឱសថ បានដាក់បញ្ចូលផលិតផលបន្ថែមចំនួន ៤៥០ មុខទៀត ទៅក្នុងបញ្ជីផលិតផលដែលគេបានព្រមព្រៀងនៅក្នុង Uruguay Round ដើម្បីលប់បំបាត់អត្រាពន្ធគយ ។ ទោះបីមានការចរចាទៅលើសម្បទានបែបនេះ ក្នុងចំណោមប្រទេសមួយចំនួនតូចក៏ដោយ ក៏សម្បទានបែបនេះកំពុងត្រូវបានពង្រីកតាមមូលដ្ឋាន MFN *(សូមមេត្តាអានជំពូក១៦)* ។

ក្នុងផ្នែកសេវាកម្ម ការចរចាត្រូវបានធ្វើឡើងទៅលើវិស័យជាក់លាក់មួយចំនួន ហើយការវិវត្តន៍នៃការចរចាដែលសំរេចបាននៅ Uruguay Round ត្រូវចាត់ទុកថាមិនទទួលបាននូវលទ្ធផលគួរជាទីពេញចិត្តទេ ។ ការចរចានេះធ្វើអោយមានការអនុម័តទៅលើកញ្ចប់នៃការសន្យារួមមាន ការសន្យាធ្វើសេរីភាវូបនីយកម្ម (បន្ថែមទៅលើអ្វីដែលបានផ្លាស់ប្តូរយោបល់នៅក្នុងកិច្ចប្រជុំតុមូល) នៅក្នុងវិស័យសេវាកម្មចំនួន ២ មានសេវាកម្មហិរញ្ញវត្ថុ និងទូរគមនាគមន៍ ។ គិតទៅលើលក្ខណៈមានកំណត់ ការវិវត្តន៍ខ្លះក៏សំរេចបាន នៅក្នុងការចរចាស្តីពីចលនារបស់រូបវន្តបុគ្គល ។ ក្នុងផ្នែកសេវាកម្មមុខរបរវិជ្ជាជីវៈ ការចរចាបណ្តាលអោយមានកើតមាននូវការរៀបចំគោលការណ៍ស្តីពីលទបញ្ញាក្នុងស្រុកសំរាប់វិស័យគណនេយ្យកិច្ច ។ កិច្ចព្រមព្រៀងមួយចំនួនមានបទបញ្ញត្តិបន្ថែមសំរាប់ចាប់ផ្តើមការចរចារតុមូលជាថ្មី ។ ដូច្នេះ GATS ចែងថា រាល់ការចរចារទាំងឡាយលើសេរីភាវូបនីយកម្មពាណិជ្ជកម្មបន្ថែមក្នុងផ្នែកសេវាកម្មទាំងអស់ គួរតែចាប់ផ្តើមនៅថ្ងៃទី១ ខែមករា ឆ្នាំ២០០០ ។ បទបញ្ញត្តិនៃកិច្ចព្រមព្រៀងស្តីពីកសិកម្មក៏អំពាវនាវផងដែរអោយបណ្តាប្រទេសជាសមាជិកចាប់ផ្តើមធ្វើការចរចារមុនបំណាច់ឆ្នាំ១៩៩៩ នៅក្នុងផ្នែកកសិកម្ម ដោយរួមបញ្ចូលផងដែរនូវមតិយោបល់សំរាប់ធានានូវសេរីភាវូបនីយកម្មពាណិជ្ជកម្មបន្ថែមក្នុងផ្នែកនេះ ។ ការងាររៀបចំចាប់ផ្តើមការចរចារនៅក្នុងផ្នែកទាំងនេះ បច្ចុប្បន្នកំពុងដំណើរការនៅក្នុងគណៈកម្មាធិការពាក់ព័ន្ធរបស់ WTO ។

របៀបវារៈបន្ថែមសំរាប់ចាប់ផ្តើមការចរចារថ្មី

កិច្ចព្រមព្រៀងមួយចំនួនបានចែងបន្ថែម ពីការពិនិត្យមើលសារឡើងវិញលើបទបញ្ញត្តិទាំងអស់ ឬ មួយផ្នែកនៃកិច្ចព្រមព្រៀង។ ការពិនិត្យមើលឡើងវិញត្រូវបានធ្វើឡើងដោយផ្អែកទៅលើបទពិសោធន៍រួមជាមួយការអនុវត្តន៍ ដើម្បីកំណត់ថា តើការកែប្រែបទបញ្ញត្តិទាំងនេះ ជាការចាំបាច់ដែរឬទេ ។

សេចក្តីសំរេចទាំងឡាយនាសន្និសីទថ្នាក់រដ្ឋមន្ត្រី

ដូចដែលកត់សំគាល់ពីខាងលើរួចមកហើយថា ការទទួលខុសត្រូវចំបងក្នុងការចាត់វិធានការ និងធ្វើសេចក្តីសំរេច ដើម្បីធានាអោយមានការអនុវត្តន៍កម្មវត្ថុណាមួយ ដែល WTO បានបង្កើតឡើងគឺស្ថិតនៅលើសន្និសីទថ្នាក់រដ្ឋមន្ត្រី ដែលធ្វើឡើងនៅរាល់ ២ ឆ្នាំម្តង ។ WTO មានសន្និសីទថ្នាក់រដ្ឋមន្ត្រីចំនួន ២ ដងរួចមកហើយ ចាប់តាំងពីបានបង្កើតឡើងមក ដែលលើកទីមួយត្រូវបានធ្វើនៅប្រទេសសឹង្ហបុរី (Singapore) នៅខែ ធ្នូ ១៩៩៦ ហើយលើកទី ២ នៅ Geneva ក្នុងខែធ្នូ ឆ្នាំ១៩៩៨ ។ ដោយឡែកសន្និសីទលើកទី៣ ត្រូវបានធ្វើឡើងនៅទីក្រុង Seattle នាខែ វិច្ឆិកា-ធ្នូ ឆ្នាំ១៩៩៩ ។

ក្នុងសន្និសីទថ្នាក់រដ្ឋមន្ត្រីដែលបានធ្វើនៅប្រទេសសឹង្ហបុរី និង Geneva បន្ទាប់ពីបានពិនិត្យសើរើឡើងវិញលើការអភិវឌ្ឍន៍ពាណិជ្ជកម្មអន្តរជាតិ និងបញ្ហាទាំងឡាយដែលកើតមានឡើងនៅក្នុងការអនុវត្តន៍កិច្ចព្រមព្រៀងផ្សេងៗរបស់ WTO បណ្តារដ្ឋមន្ត្រីទាំងអស់បានសំរេចចិត្តរួមបញ្ចូលទៅក្នុងកម្មវិធីការងាររបស់ WTO ដើម្បីសិក្សា និងវិភាគទៅលើប្រធានបទថ្មីចំនួន ៦ ដោយសារតែប្រទេសជាច្រើនស្នើរសុំអោយសេចក្តីសន្និដ្ឋានរបស់ពួកគេមានឥទ្ធិពលទៅលើការអភិវឌ្ឍន៍ពាណិជ្ជកម្មអន្តរជាតិ។ សេចក្តីសន្និដ្ឋានទាំងនេះរួមមាន ÷

- ☐ ពាណិជ្ជកម្ម និងបរិស្ថាន
- ☐ ពាណិជ្ជកម្ម និងការវិនិយោគ
- ☐ ពាណិជ្ជកម្ម និងគោលនយោបាយប្រកួតប្រជែង
- ☐ ការសំរួលផ្នែកពាណិជ្ជកម្ម
- ☐ តំលាភាពនៅក្នុងលទ្ធកម្មសាធារណៈ និង
- ☐ ពាណិជ្ជកម្មទៅលើគ្រឿងអេឡិចត្រូនិក

ការសិក្សា និងការវិភាគបញ្ហាពាក់ព័ន្ធពាណិជ្ជកម្ម បញ្ហា និងដំណោះស្រាយទាំងឡាយ នៅក្នុងបរិវេណនៃប្រធានបទទាំងនេះ បានរ៉ាប់រងដោយក្រុមការងារ ឬ អង្គភាពដទៃជាច្រើនទៀតដែលបានបង្កើតឡើងដើម្បីដោះស្រាយបញ្ហាបែបនេះ ។ ជាកត្តាសំខាន់ត្រូវកត់សំគាល់ថា ក្នុងដំណាក់កាលនេះ មិនមានប្រទេសជាសមាជិកណាមួយធ្វើការសន្យាស្តីពីគោលបំណងដែលចង់បាន ឬ អ្វីផ្សេងទៀតដែលពាក់ព័ន្ធនៅក្នុងការចរចារបស់ WTO ស្តីពីការរៀបចំវិធានសំរាប់វិស័យទាំងនេះទេ (សូមអានជំពូក ២១-២៦) ។

ការចាប់ផ្តើមការចរចាជាថ្មី

សន្និសីទថ្នាក់រដ្ឋមន្ត្រីនៅទីក្រុង Geneva បានអនុញ្ញាតិអោយអគ្គក្រុមប្រឹក្សា (General Council) រៀបចំកម្មវិធីមួយ សំរាប់អោយ WTO ធ្វើការពិចារណាលើលទ្ធភាពនៃការចរចា និងបំពេញការងារនាពេលអនាគត ក្នុងនោះមាន ÷

- ☐ បញ្ហា និងរឿងរ៉ាវទាំងឡាយដែលបានកើតឡើងនៅក្នុងការអនុវត្តន៍កិច្ចព្រមព្រៀង WTO ។
- ☐ បទបញ្ញត្តិនៅក្នុងរបៀបវារៈបន្ថែមនៃកិច្ចព្រមព្រៀង ។
- ☐ ប្រធានបទថ្មីៗ ដែលបច្ចុប្បន្នការងារវិភាគលើប្រធានបទទាំងនេះកំពុងដំណើរការ ។
- ☐ ប្រធានបទដទៃទៀតមួយចំនួនដែលស្នើរដោយបណ្តាប្រទេសជាសមាជិក ដើម្បីដាក់បញ្ចូលនៅក្នុងរបៀបវារៈសំរាប់ការចរចា ។

អគ្គក្រុមប្រឹក្សានឹងពិនិត្យមើលថា តើការចរចាថ្មីៗណាខ្លះ ដែលត្រូវរីងបន្តឹងទៅលើផ្នែកកសិកម្ម និងសេវាកម្ម ហើយការចរចាណាមួយដែលរបៀបវារៈបន្ថែមរបស់ WTO អំពាវនាវអោយមាន ឬថាតើការចរចាទាំងនោះគួរគ្រប់ដណ្តប់ទៅប្រធានមួយចំនួនធំដូចដែលគេធ្វើក្នុងពេលចរចាតុមូលលើកមុនដែរទេ ។

អគ្គក្រុមប្រឹក្សាសង្ឃឹមថានឹងបំពេញការងាររបស់គេក្នុងការរៀបចំកម្មវិធីការងារបានល្អ មុនពេលសន្និសីទថ្នាក់រដ្ឋមន្ត្រី (ដែលគ្រោងធ្វើនៅទីក្រុង Seattle ពីថ្ងៃទី ៣០ វិច្ឆិកា ដល់ ៣ ខែ ធ្នូ ឆ្នាំ ១៩៩៩ ដូចបានបញ្ជាក់ ពីខាងដើម) ដើម្បីអោយសន្និសីទនេះអាចសំរេចបាននូវសេចក្តីសំរេចចិត្ត សមស្របស្តីពីការចាប់ផ្តើមចរចា ។

អត្ថប្រយោជន៍ចំពោះសហគមន៍ពាណិជ្ជកម្មនៃប្រព័ន្ធ WTO

តើប្រព័ន្ធ WTO មានការពាក់ព័ន្ធអ្វីទៅនឹងសេចក្តីសំរេច អោយឧស្សាហកម្ម និងសហគ្រាសពាណិជ្ជកម្មជាច្រើនដំណើរការនៅក្នុងសកម្មភាពពាណិជ្ជកម្មអន្តរជាតិរបស់ពួកគេ ? នៅពេលពិចារណាសំនួរនេះ យើងត្រូវចងចាំថា រដ្ឋាភិបាលបានចរចាបើកទីផ្សារកាន់តែច្រើន ដើម្បីផ្តល់លទ្ធភាព អោយសហគ្រាសពាណិជ្ជកម្មអាចផ្លាស់ប្តូរសម្បទានពាណិជ្ជកម្មទៅក្នុងកាលានុវត្តន៍ភាពពាណិជ្ជកម្ម ។ គោលដៅពីក្រោយប្រព័ន្ធមូលដ្ឋានច្បាប់ គឺធានាអោយទីផ្សារនៅបើកចំហ ហើយការបើកចំហនេះមិនមានការរាំងស្ទាមៗ ដោយការកំណត់លំកូឥណ្ឌតាមទំនើងចិត្ត ទៅលើការដាក់កំហិតលើការនាំចូលទេ ។

ទោះជាយ៉ាងណាក៏ដោយ សហគមន៍ពាណិជ្ជកម្មជាច្រើននៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍មួយចំនួន នៅតែមិនទាន់ដឹងអោយបានគ្រប់ជ្រុងជ្រោយពីអត្ថប្រយោជន៍នៃប្រព័ន្ធពាណិជ្ជកម្មរបស់ WTO ។ មូលហេតុចំបងនៃការមិនដឹងនេះ គឺបណ្តាលមកពីប្រព័ន្ធនេះមានភាពស្មុគស្មាញ ដែលរាំងសហគមន៍ទាំងនេះមិនអោយមានការចាប់អារម្មណ៍ និងយល់ច្បាស់ពីវិធានរបស់ប្រព័ន្ធនេះ ។ ឧទាហរណ៍ មិនមានការយល់ដឹងអោយទូលំទូលាយថា ប្រព័ន្ធច្បាប់មិនត្រឹមតែផ្តល់អត្ថប្រយោជន៍ជាច្រើនចំពោះឧស្សាហកម្មផលិត និងសហគ្រាសពាណិជ្ជកម្មប៉ុណ្ណោះទេ ប៉ុន្តែក៏បានបង្កើតសិទ្ធិនៅក្នុងភាពអនុគ្រោះរបស់ពួកគេផងដែរ ។

អត្ថប្រយោជន៍ជាច្រើនដែលបានផ្តល់ដល់សហគមន៍ពាណិជ្ជកម្ម

អត្ថប្រយោជន៍ដែលប្រព័ន្ធច្បាប់ ផ្តល់ដល់សហគ្រាសពាណិជ្ជកម្ម និងផលប្រយោជន៍ដែលពួកគេអាចទាញយកពីប្រព័ន្ធនេះបាន មាននៅក្នុងទស្សនៈវិស័យពីរខុសៗគ្នាគឺ ÷

- ☐ ពីទស្សនៈវិស័យរបស់សហគ្រាសដែលជាអ្នកនាំចេញទំនិញ និងសេវាកម្ម ។
- ☐ ពីទស្សនៈនៃសហគ្រាសដែលជាអ្នកនាំចូលវត្ថុធាតុដើម និងសេវាកម្មផ្សេងៗទៀតដែលត្រូវសំរាប់ផលិតកម្មនាំចេញ ។

អត្ថប្រយោជន៍សំរាប់អ្នកនាំចេញទំនិញ និងសេវាកម្ម

សុវត្ថិភាពនៃការបើកទីផ្សារ

នៅក្នុងពាណិជ្ជកម្មលើទំនិញ ពន្ធគយស្ទើរតែទាំងអស់របស់ប្រទេសជឿនលឿន និងសមាមាត្រដ៏ខ្ពស់មួយរវាងសេដ្ឋកិច្ចនៃប្រទេសកំពុងអភិវឌ្ឍន៍ និងសេដ្ឋកិច្ចរបស់ប្រទេសអន្តរកាល មានប្រសិទ្ធភាពចងភ្ជាប់មិនអោយមានការកើនឡើងក្នុង WTO ទេ ។ ប្រសិទ្ធិភាពចងភ្ជាប់នេះ ធានាមិនអោយមានការរារាំង បង្អាក់ដោយការបង្កើនអត្រាពន្ធគយណាមួយដោយតំហុក ឬការដាក់កំហិតផ្សេងៗទៀត ដោយប្រទេសនាំចូលណាមួយទៅលើការបើកទីផ្សារ បានច្រើនដោយសារការកាត់បន្ថយអត្រាពន្ធគយដែលបានព្រមព្រៀង និងបានដាក់បញ្ចូលទៅក្នុងតារាងសម្បទានរបស់ប្រទេសនីមួយៗឡើយ ។ នៅក្នុងពាណិជ្ជកម្មលើសេវាកម្មប្រទេសជាច្រើនបានធ្វើការសន្យាដែលមានប្រសិទ្ធិភាពចងភ្ជាប់ ថានឹងមិនដាក់កំរិតលើការបើកទីផ្សារចំពោះផលិតផលសេវាកម្ម និងអ្នកផ្គត់ផ្គង់សេវាកម្មបរទេស អោយលើសពីលក្ខខ័ណ្ឌ និងដែនកំណត់ដែលមានបញ្ជាក់នៅក្នុងឧបសម្ព័ន្ធជាតិរបស់ពួកគេទេ។

ការបើកទីផ្សារដែលមានការធានា ហើយដែលមានប្រសិទ្ធិភាពចងភ្ជាប់ បានផ្តល់លទ្ធភាពអោយឧស្សាហកម្មនាំចេញ ធ្វើការវិនិយោគ និងបង្កើតរោងចក្រផលិតកម្ម តាមល័ក្ខខ័ណ្ឌដែលមានភាពប្រាកដប្រជាច្រើន ។

ស្ថេរភាពនៃការបើកទីផ្សារ

ប្រព័ន្ធក៏បានចែងផងដែរ ពីស្ថេរភាពនៃការបើកទីផ្សារនាំចេញដោយតំរូវអោយប្រទេសទាំងអស់ អនុវត្តនូវបណ្តុំវិធានដូចគ្នា ដែលបង្កើតឡើងនូវកិច្ចព្រមព្រៀងផ្សេងៗ ។ ដូច្នេះប្រទេសជាច្រើន មានកាតព្វកិច្ចធានាថា វិធានសំរាប់កំណត់តំលៃដែលត្រូវបង់ពន្ធគយ សំរាប់ត្រួតពិនិត្យផលិតផល អោយស្របតាមស្តង់ដារចាំបាច់ ឬ វិធានសំរាប់ចេញអាជ្ញាប័ណ្ណនាំចូលទាំងឡាយរបស់គេ ត្រូវមានលក្ខណៈស្របទៅតាមបទបញ្ញត្តិនៃកិច្ចព្រមព្រៀងដែលពាក់ព័ន្ធ ។

អត្ថប្រយោជន៍សំរាប់អ្នកនាំចូលវត្ថុធាតុដើម និងវត្ថុធាតុផ្សេងៗទៀត

សហគ្រាសជាច្រើន ជារឿយៗត្រូវធ្វើការនាំចូលវត្ថុធាតុដើម ផលិតផលពាក់កណ្តាលសំរេច និងសេវាកម្មសំរាប់ផលិតកម្មនាំចេញ។ វិធានជាមូលដ្ឋាន ដែលតំរូវអោយមានការនាំចូលដោយគ្មានការដាក់កំហិត អាស្រ័យទៅតាមការបង់ពន្ធគយ និងកាតព្វកិច្ចធានាអោយបទបញ្ញាផ្សេងៗទៀត ដែលអនុវត្តនៅតាមព្រំដែនរបស់ប្រទេស មានលក្ខណៈស្របទៅតាមវិធានតែមួយដែលបានកំណត់ដោយកិច្ចព្រមព្រៀង ដើម្បីសំរួលដល់ការនាំចូល។ កិច្ចព្រមព្រៀងទាំងនេះ ផ្តល់ការធានារ៉ាប់រងមួយចំនួនដល់ឧស្សាហកម្មនាំចេញ ដើម្បីគេអាចទទួលបាននូវតំរូវការវត្ថុធាតុដើមរបស់គេដោយគ្មានយឺតយ៉ាវ និងតាមតំលៃដែលមានលក្ខណៈប្រកួតប្រជែង ។ ជាងនេះទៅទៀត អត្រាពន្ធគយដែលមានប្រសិទ្ធិភាពអាចយកមកប្រើប្រាស់ ដើម្បីធានាថា មិនអោយតំលៃនាំចូលរបស់អ្នកនាំចូល មានការកើនឡើងដោយសារការដាក់អត្រាពន្ធគយខ្ពស់ជាងឡើយ ។

សិទ្ធិទាំងឡាយដែលបានផ្តល់អោយចំពោះសហគមន៍ពាណិជ្ជកម្ម

បន្ថែមពីលើការផ្តល់ជូននូវអត្ថប្រយោជន៍ ប្រព័ន្ធច្បាប់បានបង្កើតសិទ្ធដ៏ជាក់លាក់មួយ ជាផលប្រយោជន៍របស់សហគ្រាសពាណិជ្ជកម្ម។ មានការបែងចែក សិទ្ធិទាំងនេះជា ២ ប្រភេទ ។ ប្រភេទទីមួយ គឺសិទ្ធិរបស់អ្នកផលិតក្នុងស្រុក និងអ្នកនាំចូលចំពោះមុខ

រដ្ឋាភិបាលផ្ទាល់របស់ពួកគេ ។ រីឯប្រភេទទី ២ គឺសិទ្ធិរបស់សហគ្រាសនាំចេញដើម្បីការពារផលប្រយោជន៍ពួកគេនៅពេលអាជ្ញាធរក្នុងបណ្តាប្រទេសនាំចូល ចាត់វិធានការណ៍បណ្តោះអាសន្នណាមួយ ដើម្បីរាំងការនាំចេញរបស់ពួកគេ ។

សិទ្ធិរបស់ផលិតករ និងអ្នកនាំចូលក្នុងស្រុក

កិច្ចព្រមព្រៀងមួយចំនួន ទាមទារអោយច្បាប់របស់ប្រទេសជាសមាជិក ចែងច្បាស់លាស់ពីសិទ្ធិរបស់ផលិតករ និងអ្នកនាំចូលនៅក្នុងស្រុក ។ រដ្ឋាភិបាលមានកាតព្វកិច្ចដាក់អោយអនុវត្តសិទ្ធិមួយចំនួននៃសិទ្ធិទាំងនេះតាមប្រព័ន្ធច្បាប់របស់ប្រទេសគេ ។ ពាក់ព័ន្ធនឹងសិទ្ធិផ្សេងទៀត គេបានស្នើសុំអោយរដ្ឋាភិបាលនីមួយៗ ខិតខំប្រឹងប្រែងអោយអស់ពីសមត្ថភាព ដើម្បីធានាអោយភាគីដែលពាក់ព័ន្ធទទួលបានផលប្រយោជន៍ពេញលេញពីសិទ្ធិទាំងនេះ ។

សិទ្ធិដែលអាចអនុវត្តបាន រួមមានសិទ្ធិដែលផ្តល់អោយ តាមកិច្ចព្រមព្រៀងស្តីពីការវាយតំលៃគយ ដែលកំណត់កាតព្វកិច្ចអោយរដ្ឋាភិបាលតាក់តែងច្បាប់ អោយអ្នកនាំចូលមានសិទ្ធិ ÷

- ☐ ផ្ទៀងផ្ទាត់តំលៃដែលបានធ្វើប្រតិវេទន៍ នៅពេលដែលគយសំដែងនូវការសង្ស័យអំពីការពិត ឬ ភាពត្រឹមត្រូវនៃតំលៃនោះ និង
- ☐ តំរូវអោយគយផ្តល់អោយអ្នកនាំចូលនូវមូលហេតុជាលាយល័ក្ខអក្សរនៃការបដិសេធតំលៃដែលបានធ្វើប្រតិវេទន៍ ដើម្បីអោយពួកគេអាចប្តឹងតវ៉ាទៅអាជ្ញាធរថ្នាក់ខ្ពស់ ជំទាស់ពីសេចក្តីសំរេចនោះ ។

សិទ្ធិតំរូវអោយរដ្ឋាភិបាលខិតខំប្រឹងប្រែងអោយអស់ពីសមត្ថភាព រួមមានទាំងការខិតខំប្រឹងប្រែងដែលគ្របដណ្តប់ដោយបទបញ្ញត្តិនៃកិច្ចព្រមព្រៀងស្តីពីការចេញអាជ្ញាប័ណ្ណនាំចូល ដែលទាមទារអោយមានការចេញអាជ្ញាប័ណ្ណនាំចូលក្នុងរយៈពេលមួយមានកំណត់បន្ទាប់ពីបានទទួលពាក្យស្នើសុំ ។ នៅក្នុងឧទាហរណ៍នេះ លើកលែងតែច្បាប់ជាតិមានចែងផ្សេងពីនេះ បើមិនដូច្នោះទេអ្នកនាំចូលមានសិទ្ធិនឹងទទួលបានអាជ្ញាប័ណ្ណ តាមពេលវេលាដែលមានចែងច្បាស់លាស់ ។

ការទាមទារសិទ្ធិទាំងនោះ ជារឿយៗយោងទៅតាមល័ក្ខខ័ណ្ឌដែលសហគ្រាស ឬ ឧស្សាហកម្មក្នុងស្រុកត្រូវបំពេញ ។ ឧទាហរណ៍ដូចដែលបានកំណត់ពីខាងដើមរួចមកហើយថា ឧស្សាហកម្មមានសិទ្ធិស្នើសុំអោយរដ្ឋាភិបាលរបស់គេចាត់វិធានការពារ ឬ ប្រមូលពន្ធប៉ះប៉ូវ ឬ ពន្ធប្រឆាំងនឹងការលក់បង្ខូចថ្លៃបាន ប្រសិនបើអង្គភាពដែលដាក់ពាក្យបណ្តឹងនោះ អាចបញ្ជាក់ប្រាប់អាជ្ញាធរស៊ើបអង្កេតថាសំណើររបស់គេមានការគាំទ្រពីផលិតករដែលមានសមាមាត្រផលិតកម្មភាគច្រើន ។

សិទ្ធិរបស់សហគ្រាសនាំចេញ

ឧទាហរណ៍ស្តីពីសិទ្ធិដែលកិច្ចព្រមព្រៀងបានកំណត់ ដើម្បីជាផលប្រយោជន៍របស់សហគ្រាសនាំចេញ គឺជាសិទ្ធិផ្តល់ភស្តុតាងក្នុងអំឡុងពេលស៊ើបអង្កេត នៅក្នុងប្រទេសនាំចូល ដើម្បីអនុវត្តពន្ធប៉ះប៉ូវ ឬ ពន្ធប្រឆាំងនឹងការលក់បង្ខូចថ្លៃ ។

នៅពេលដែលអាជ្ញាធរនៃប្រទេសនាំចូលទាំងឡាយ មិនគោរពសិទ្ធិរបស់ពួកគេ នោះសហគ្រាសនាំចេញមិនអាចស្នើសុំអោយអាជ្ញាធរនោះចេញសំណងដោយផ្ទាល់បានឡើយ ។ ពួកគេត្រូវតែយកបញ្ហានេះទៅពិភាក្សាជាមួយរដ្ឋាភិបាលរបស់គេ ហើយទុកអោយរដ្ឋាភិបាល ជាអ្នកដោះស្រាយបញ្ហានេះ ជាមួយរដ្ឋាភិបាលប្រទេសនាំចេញតាមមូលដ្ឋានកិច្ចព្រមព្រៀងទ្វេភាគី និងប្រសិនបើចាំបាច់ត្រូវលើកបញ្ហានោះមកដោះស្រាយតាមនីតិវិធី WTO ស្តីពីដំណោះស្រាយវិវាទ និងភាពខុសគ្នាផ្សេងៗ ។

តារាងពន្យល់អំពីសិទ្ធិ

ឧបសម្ព័ន្ធ១ ជាតារាងពន្យល់ពីអត្ថប្រយោជន៍ និងសិទ្ធិដែលឯកសារច្បាប់ផ្សេងៗ ផ្តល់អោយសហគមន៍ពាណិជ្ជកម្ម និងឧស្សាហកម្ម ។ សិទ្ធិ និងអត្ថប្រយោជន៍ទាំងនេះ មានរៀបរាប់ពិស្តារនៅក្នុងជំពូកបន្តបន្ទាប់ទៀតនៃមគ្គុទ្ទេសក៍ពាណិជ្ជកម្មនេះ ។

ការប្រើប្រាស់ដ៏មានប្រសិទ្ធិភាពនៃនីតិវិធីដោះស្រាយវិវាទរបស់ WTO

ចំណេះដឹងពីប្រព័ន្ធនិងផ្តល់លទ្ធភាពផងដែរ អោយសហគមន៍ពាណិជ្ជកម្ម និងអាជីវកម្ម ជួយដល់រដ្ឋាភិបាលរបស់គេ ទទួលបាននូវផលប្រយោជន៍ពេញលេញពីយន្តការរបស់ WTO សំរាប់ពិនិត្យមើលការអនុវត្តន៍កិច្ចព្រមព្រៀង ការដោះស្រាយវិវាទ និងភាពខុសគ្នា។ រដ្ឋាភិបាលនឹងមានលទ្ធភាពលើកយកបញ្ហាទាំងនេះមកពិភាក្សា និងដោះស្រាយនៅក្នុងគណៈកម្មាធិការសមស្របណាមួយ ប្រសិនបើសហគ្រាសនាំចេញបង្កើតអោយមានបញ្ហាទីផ្សារ ដែលបណ្តាលមកពីការបំពានវិធានរបស់ពួកគេ ។ ម្យ៉ាងវិញទៀត រដ្ឋាភិបាលអាចលើកយកបណ្តឹងទាមទារណាមួយមកដោះស្រាយ តាមនិតិវិធីដោះស្រាយវិវាទរបស់ WTO ប្រសិនបើឧស្សាហកម្មដែលទទួលរងនូវផលប៉ះពាល់នោះ លើកយកបណ្តឹងទាមទារនោះមកដោះស្រាយមុន និងផ្តល់នូវពត៌មានដែលត្រូវការជាបឋម ។

ឥទ្ធិពលចំពោះការចរចានាពេលអនាគត

ទោះជាយ៉ាងណាក៏ដោយ ការទទួលខុសត្រូវរបស់សហគ្រាសនាំចេញ និងសហគ្រាសផលិតមិនមែនចប់ នៅពេលដែលគេផ្តល់សេចក្តីជូនដំណឹងទៅរដ្ឋាភិបាលរបស់គេ អំពីបញ្ហានៃការអនុវត្តន៍ជាក់ស្តែងដែលពួកគេជួបប្រទះនោះឡើយ ។ ពួកគេ និងសមាគមជាតិរបស់គេ ត្រូវបន្តតាមដានយ៉ាងប្រុងប្រយ័ត្នលើការងាររបស់ WTO ។ ជាសំខាន់ត្រូវកត់សំគាល់ថា ការចរចាមិនអាចបញ្ចប់នៅពេលអនុម័តកិច្ចព្រមព្រៀងឡើយ ។ ជារឿយៗ ការចរចាបន្ថែមដែលអនុវត្តទៅលើផ្នែកពាណិជ្ជកម្ម ត្រូវបានធ្វើឡើងនៅក្នុងដំណាក់កាលនៃការអនុវត្តន៍ ជាពិសេសក្នុងកំឡុងពេលពិនិត្យមើលឡើងវិញជាទៀងទាត់ ដើម្បីកំណត់ថា កិច្ចព្រមព្រៀងនោះអាចយកមកអនុវត្តបានទេ និងដើម្បីកំណត់ថា ថាតើបទបញ្ញត្តិណាខ្លះដែលចាំបាច់ ត្រូវធ្វើការកែប្រែឡើងវិញនោះ ។ យោបល់ទិទៀនពីសហគមន៍ពាណិជ្ជកម្មទៅលើបញ្ហាជាក់ស្តែងដែលគេបានជួបប្រទះ (ដូចជាបទបញ្ហាបច្ចេកវិទ្យា ឬវិធានការណ៍អនាម័យ និងភូតគ្គាមអនាម័យ ដែលអនុវត្តទៅលើការនាំចូលដោយបណ្តាប្រទេសនាំចេញ) អាចជួយរដ្ឋាភិបាលបានយ៉ាងច្រើននៅក្នុងការធានាអោយមានការកែប្រែកិច្ចព្រមព្រៀងអោយបានសមស្រប ។

បន្ថែមពីលើនេះ បច្ចុប្បន្ន WTO កំពុងដំណើរការវិភាគលើប្រធានបទថ្មីចំនួន ៦ ដោយមានទស្សនៈស្វែងយល់ថា តើការបកស្រាយរបស់វិធាន WTO ទៅក្នុងប្រធានបទទាំងនេះ មានលក្ខណៈសមស្របដែរឬទេ ។ ទស្សនៈរបស់សហគមន៍ពាណិជ្ជកម្មលើលទ្ធភាពតំរូវការ ឬ អ្វីផ្សេងទៀតនៃវិធាននោះ និងថាតើគេត្រូវពិចារណាយ៉ាងណាទៅលើបញ្ហាព្រួយបារម្ភ និងផលប្រយោជន៍របស់គេ ប្រសិនបើវិធាននោះត្រូវបានអភិវឌ្ឍន៍ ជាកត្តាចាំបាច់សំរាប់រដ្ឋាភិបាលនៅក្នុងការសំរេចចិត្ត ទៅលើគំហិតជិតគោលនយោបាយដែលពួកគេត្រូវប្រើប្រាស់នៅក្នុងការចរចាដែលពាក់ព័ន្ធ ។

សហគមន៍ពាណិជ្ជកម្មត្រូវមានលទ្ធភាពធានាអោយផលប្រយោជន៍ និងការព្រួយបារម្ភរបស់ពួកគេ ត្រូវបានលើកឡើងយ៉ាងពេញលេញ ដោយរដ្ឋាភិបាលរបស់ពួកគេ ដោយការពិនិត្យឡើងវិញអោយបានជិតដល់លើកិច្ចព្រមព្រៀង និងការចរចារទៅលើការអនុម័តវិធានសំរាប់ប្រធានបទថ្មី ។ នៅក្នុងចំណោមការលំបាក ដែលសហគមន៍ និងក្រុមពាក់ព័ន្ធផ្សេងទៀត ត្រូវប្រឈមមុខទៅនឹងការអភិវឌ្ឍន៍នៅក្នុងការងាររបស់ WTO គឺរាល់ការប្រជុំរបស់ WTO បានធ្វើឡើងដោយសំងាត់មិនអោយសាធារណៈដឹង ជាងនេះទៅទៀត រាល់ឯកសារ និងរបាយការណ៍ស្តីពីការប្រជុំនេះ ត្រូវរក្សាទុកយ៉ាងតឹងរឹង ។ បណ្តាប្រទេសជាសមាជិកនាពេលថ្មីៗ នេះបានប្រកាន់យកវិធានការប្រកបដោយតម្លាភាព ដោយកំណត់ពីការចែកចាយឯកសារ អោយបានទូលាយគ្មានដាក់កំហិតក្រោយពេលប្រជុំ ៦ ខែ ។ របាយការណ៍របស់គណៈវិនិច្ឆ័យ និងរបស់អង្គភាពឧទ្ធរណ៍ នៅក្នុងការដោះស្រាយវិវាទត្រូវចែកចាយដោយគ្មានដាក់កំហិត នៅពេលចេញរបាយការណ៍នេះតែម្តង ។ បច្ចុប្បន្នឯកសារទាំងនេះមានជាសាធារណៈនៅលើ Web site របស់ WTO ។

មានការទទួលស្គាល់កាន់តែច្រើនឡើងៗ ថា អង្គការក្រៅរដ្ឋាភិបាល (NGOs) ដែលតំណាងអោយផលប្រយោជន៍ផ្សេងៗគ្នាដូចជាពាណិជ្ជកម្ម បរិស្ថាន និងការអភិវឌ្ឍន៍ អ្នកប្រើប្រាស់សហជីពពាណិជ្ជកម្ម និងកសិករ អាចដើរតួយ៉ាងសំខាន់នៅក្នុងការបង្កើនការយល់ដឹងជាសាធារណៈ ពីសកម្មភាព WTO ប្រសិនបើពួកគេទទួលបានពត៌មានជាប្រចាំ និងយ៉ាងទៀងទាត់ពីសកម្មភាពទាំងនេះ។ លេខាធិការដ្ឋាន WTO បានប្រឹងប្រែងកែលំអទំនាក់ទំនងរបស់គេជាមួយសង្គមស៊ីវិលដោយការរៀបចំអោយមានការប្រជុំពិភាក្សាជាទៀងទាត់លើបញ្ហាជាក់លាក់ណាមួយ ដូចជាពាណិជ្ជកម្ម ។ NGOs ត្រូវបានអនុញ្ញាតិអោយចូលរួមក្នុងកិច្ចប្រជុំពេញអង្គនៃ

សន្និសីទថ្នាក់រដ្ឋមន្ត្រី ហើយទទួលបានពត៌មាន ដែលសង្ខេបជូនយ៉ាងទៀងទាត់ ដោយលេខាធិការដ្ឋាន WTO អំពីសម័យប្រជុំការងារផងដែរ ។ ជាកត្តាសំខាន់ដែលត្រូវកត់សំគាល់នៅក្នុងបរិបទនេះថា បញ្ហាមួយក្នុងចំណោមបញ្ហាជាច្រើន ដែលនឹងត្រូវលើកឡើងនៅក្នុងឆ្នាំខាងមុខនេះ គឺធ្វើយ៉ាងណាអោយការងាររបស់ WTO ដំណើរការប្រកបដោយតំលាភាព ដោយការបើកចំហអោយសាធារណៈជន ទទួលបានពត៌មានច្រើនស្តីពីសកម្មភាពរបស់ WTO ។

ការទាញយកអត្ថប្រយោជន៍ពីវិធានការសេរីភាវូបនីយកម្ម

ក្រៅពីការជួយរដ្ឋាភិបាលរៀបចំកំហិតជិតគោលនយោបាយ ដែលគេត្រូវអនុម័តនៅក្នុងការពិភាក្សាស្តីពីការអនុវត្តនីវិធាននៃកិច្ច ព្រមព្រៀង និងនៅក្នុងការចរចារស្តីពីការបង្កើតវិធានសហគមន៍ពាណិជ្ជកម្មមានការទទួលខុសត្រូវជាបឋម ក្នុងការផ្លាស់ប្តូរការបន្ថយ ថ្លៃពន្ធ និងការសន្យាធ្វើសេរីភាវូបនីយកម្មទៅក្នុងកាលានុវត្តន៍ភាពពាណិជ្ជកម្មដោយការអនុម័តយុទ្ធសាស្ត្រអភិវឌ្ឍន៍ និងជំរុញការ នាំចេញដ៏សមស្របមួយ ។ ចំណេះលំអិតនៃសម្បទានដែលមានលើទំនិញ និងផលិតផលសេវាកម្មនៃផលប្រយោជន៍ជាសក្តានុពល និងពិតប្រាកដចំពោះសហគមន៍មានភាពចាំបាច់សំរាប់ជំរុញយុទ្ធសាស្ត្រនោះ ។

សេចក្តីសន្និដ្ឋាន

ត្រូវកត់សំគាល់ថា ការធ្វើពាណិជ្ជកម្មមិនអាចរីកធំធាត់បានដោយស្វ័យប្រវត្តិ ដោយសារតែការកាត់បន្ថយពន្ធ និងការដកចេញនូវរបាំងពាណិជ្ជកម្មនោះឡើយ ។ ពាណិជ្ជកម្មអាចរីកលូតលាស់បាន ប្រសិនបើសហគ្រាសពាណិជ្ជកម្ម អនុម័តនូវយុទ្ធសាស្ត្រអភិវឌ្ឍន៍ការនាំចេញសមស្រប ដើម្បីពិចារណាទៅលើផលប៉ះពាល់នៃវិធានការសេរីភាវូបនីយកម្មលើផលិតផលដែលគេនាំចេញ ។

ការអនុវត្តនីវិធានការសេរីភាវូបនីយកម្មបច្ចុប្បន្ន និងវិធានការដែលអាចព្រមព្រៀងក្នុងពេលអនាគត អាចបង្កើតនូវឱកាសលោនុវត្តន៍ភាព និងបញ្ហាប្រឈមសំរាប់សហគមន៍ពាណិជ្ជកម្ម ។ បញ្ហាប្រឈមកើតមកពីការប្រកួតប្រជែងដែលកើនឡើងទាំងទីផ្សារក្នុងស្រុក និងក្រៅស្រុក ក្រោយពេលដកចេញអត្រាពន្ធគយ និងរបាំងផ្សេងទៀត ។ ប្រព័ន្ធ WTO ធានាធ្វើយ៉ាងណាអោយការប្រកួតប្រជែងដែលកើនឡើងនោះ នៅមានភាពស្មោះត្រង់ និងស្មើភាព ។ ប្រព័ន្ធច្បាប់ក៏បានបង្កើតសិទ្ធិមួយចំនួន ដើម្បីជាផលប្រយោជន៍សហគមន៍ពាណិជ្ជកម្មផងដែរ ។ ដូចដែលបាននិយាយម្តងហើយម្តងទៀតដែរថា សហគមន៍មានលទ្ធភាពទទួលផលប្រយោជន៍ពីប្រព័ន្ធ និងសិទ្ធិទាំងនេះបាន អាស្រ័យទៅលើការយល់ដឹង និងចំណេះដឹងក្នុងការស្វែងយល់ពីវិធានលំអិតនៃប្រព័ន្ធនេះ។

ជំពូកជាបន្តបន្ទាប់ទៅនេះ នឹងរៀបរាប់លំអិតពីចំណុចដែលមាននិយាយនៅក្នុងទិដ្ឋភាពរួមនេះ ហើយនឹងពន្យល់ពីវិធាននៃកិច្ចព្រមព្រៀង ។

ឧបសម្ព័ន្ធ ១

បញ្ជីរៀបរាប់ត្រួសៗពីអត្ថប្រយោជន៍ដែលទទួលបានពីប្រព័ន្ធអង្គការពាណិជ្ជកម្មពិភពលោក

ប្រសិទ្ធិភាពចងភ្ជាប់ (Binding) នៃសម្បទាន និងការសន្យាអនុវត្តន៍ពន្ធគយ

ការពាក់ព័ន្ធផ្នែកពាណិជ្ជកម្ម សន្តិសុខនៃការបើកទីផ្សារបរទេស

សិទ្ធិរបស់អ្នកនាំចេញ: ពាណិជ្ជកម្មលើទំនិញ: សិទ្ធិក្នុងការរំពឹងថា ផលិតផលនាំចេញ ពុំស្ថិតនៅក្រោមការបង់ពន្ធគយខ្ពស់ជាងអត្រាពន្ធដែលមានប្រសិទ្ធិភាពចងភ្ជាប់ទេ ឬ ក៏តំលៃនៃប្រសិទ្ធិភាពចងភ្ជាប់នឹងត្រូវបានបន្ថយដោយការកំណត់បរិមាណ ឬ តាមការដាក់កំហិតផ្សេងៗទៀត។

ពាណិជ្ជកម្មលើសេវាកម្ម: សិទ្ធិក្នុងការរំពឹងថា ការបើកច្រកទីផ្សារបរទេសនៃផលិតផលសេវាកម្ម និងអ្នកផ្តល់សេវាកម្មបរទេស មិនត្រូវបានគេកំហិតជាងអ្វីដែលលក្ខខ័ណ្ឌបានចែងនៅក្នុងសន្យាអនុវត្តន៍ (Commitments) របស់ប្រទេសនោះឡើយ ។

សិទ្ធិរបស់អ្នកនាំចូល: ពាណិជ្ជកម្មលើទំនិញ : សិទ្ធរំពឹងថាវត្ថុធាតុដើម និងផលិតផលនាំចូលសំរាប់បំរើផលិតកម្មផ្សេងៗទៀត មិនត្រូវបង់ពន្ធគយខ្ពស់ជាងអត្រាដែលមានប្រសិទ្ធិភាពចងភ្ជាប់នោះទេ ។

ពាណិជ្ជកម្មលើសេវាកម្ម: សិទ្ធរំពឹងថា ឧស្សាហកម្មផ្តល់សេវាកម្មក្នុងស្រុក នឹងត្រូវអនុញ្ញាតអោយធ្វើវិនិយោគរួមគ្នា ឬ អនុញ្ញាតរួមសហការណ៍គ្នាតាមរបៀបផ្សេងៗទៀត ប្រសិនបើស្របទៅតាមល័ក្ខខ័ណនានា ដែលមានចែងនៅក្នុងឧបសម្ព័ន្ធនៃការសន្យាអនុវត្តន៍ (សូមពិនិត្យជំពូក ២) ។

ការវាយតំលៃគយលើបណ្តាទំនិញនានា (កិច្ចព្រមព្រៀងស្តីអំពីការវាយតំលៃគយ)

ការពាក់ព័ន្ធផ្នែកពាណិជ្ជកម្ម: ការធានាអះអាងថាតំលៃដែលបានធ្វើប្រតិវេទន៍ដោយអ្នកនាំចូល តាមវិធាននឹងអាចទទួលយកធ្វើជាមូលដ្ឋាន សំរាប់កំណត់តំលៃទំនិញនាំចូលក្នុងគោលដៅហូតពន្ធគយ ។

សិទ្ធរបស់អ្នកនាំចូល: អ្នកនាំចូលមានសិទ្ធិដូចខាងក្រោម ÷

- ☐ សិទ្ធិពិគ្រោះយោបល់នៅគ្រប់ដំណាក់កាលនៃការកំណត់តំលៃគយ ។
- ☐ សិទ្ធិបង្ហាញហេតុផលសមរម្យទៅលើតំលៃដែលបានធ្វើប្រតិវេទន៍ ក្នុងករណីដែលស្ថាប័នមានការសង្ស័យអំពីភាពត្រឹមត្រូវនៃតំលៃដែលបានធ្វើប្រតិវេទន៍ ប ្នៃឯកសារដែលបានជូន ។
- ☐ សិទ្ធិទាមទារអោយស្ថាប័នគយផ្តល់ជាលាយល័ក្ខអក្សរ នូវមូលហេតុនៃការបដិសេធន៍តំលៃដែលបានធ្វើប្រតិវេទន៍ ដើម្បីគេអាចធ្វើការតវ៉ាទៅអាជ្ញាធរថ្នាក់លើជំទាស់នឹងសេចក្តីសំរេចនោះ (អានជំពូក ៣) ។

ការប្រើប្រាស់សេវាកម្មត្រួតពិនិត្យមុនពេលដឹកជញ្ជូន (កិច្ចព្រមព្រៀងស្តីអំពីការត្រួតពិនិត្យមុនពេលដឹកជញ្ជូន)

ការពាក់ព័ន្ធផ្នែកពាណិជ្ជកម្ម: សេវាកម្មនេះបានជួយដល់រដ្ឋាភិបាលក្នុងការត្រួតពិនិត្យពេលអនុវត្តជាក់ស្តែង ដូចជាការវាយតំលៃលើស ឬ ការវាយតំលៃខ្វះ លើទំនិញនាំចូល ។ សេវាកម្មត្រួតពិនិត្យមុនពេលដឹកជញ្ជូន (PSI) ជួយកែលំអបរិយាកាសពាណិជ្ជកម្មអោយកាន់តែប្រសើរឡើង ។

សិទ្ធិរបស់អ្នកនាំចូល: តាមបទពិសោធន៍បានបង្ហាញអោយឃើញថា សេវាកម្ម PSI នេះ ជំរុញអោយការបំពេញបែបបទគយដំណើរបានលឿន និងជួយបន្ថយអំពើពុករលួយរបស់មន្ត្រីគយផងដែរ ។

សិទ្ធិរបស់អ្នកនាំចេញ : អ្នកនាំចេញទំនិញទៅប្រទេសកំពុងអភិវឌ្ឍន៍ ដែលកំពុងប្រើប្រាស់សេវាកម្ម PSI មានសិទ្ធិដូចខាងក្រោម ÷

- ☐ ទទួលបានពត៌មានអំពីនីតិវិធីនានា ដែលក្រុមហ៊ុន PSI ត្រូវផ្តល់ក្នុងការត្រួតពិនិត្យជារូបវន្ត និងផ្ទៀងផ្ទាត់តំលៃ ។
- ☐ អាចធ្វើការតវ៉ាទាក់ទងទៅនឹងថ្លៃកំណត់ដោយអ្នកត្រួតពិនិត្យ ហើយបណ្តឹងតវ៉ានោះ គួរត្រូវបានពិចារណាដោយភាពអនុគ្រោះដោយមន្ត្រីថ្នាក់ខ្ពស់ជាងនៅក្នុងក្រុមហ៊ុន PSI និង
- ☐ មានសិទ្ធិតវ៉ាទៅស្ថាប័នត្រួតពិនិត្យឯករាជ្យមួយ នៅពេលដែលគេពុំពេញចិត្តនឹងសេចក្តីសំរេចរបស់មន្ត្រីថ្នាក់ខ្ពស់ដូចបាននិយាយខាងលើ ។

អត្ថប្រយោជន៍ចំពោះអ្នកនាំចូល: អ្នកនាំចូលទទួលនូវអត្ថប្រយោជន៍ដូចខាងក្រោម ÷

- ☐ ការប្រើប្រាស់សេវាកម្ម PSI ជួយជំរុញការបំពេញបែបបទគយបានឆាប់រហ័ស ហើយជួយបន្ថយអំពើពុករលួយរបស់មន្ត្រីគយទៀតផង ។
- ☐ ការត្រួតពិនិត្យជាលក្ខណៈរូបវន្តធ្វើឡើងដោយក្រុមហ៊ុន PSI មុនពេលធ្វើការផ្ទៀងផ្ទាត់ថ្លៃ និងជួយធានាថាផលិតផលនាំចូលមានគុណភាព និងល័ក្ខខ័ណ្ឌផ្សេងៗស្របទៅតាមកិច្ចសន្យា។ (សូមអានជំពូក៤)

នីតិវិធីនៃការផ្តល់អាជ្ញាប័ណ្ណនាំចូល (កិច្ចព្រមព្រៀងស្តីអំពីនីតិវិធីផ្តល់អាជ្ញាប័ណ្ណនាំចូល)

ការពាក់ព័ន្ធផ្នែកពាណិជ្ជកម្ម: ធានាចំពោះអ្នកនាំចូល និងអ្នកផ្គត់ផ្គង់បរទេស នូវការចេញអាជ្ញាប័ណ្ណលើផលិតផលដែលតំរូវអោយមានអាជ្ញាប័ណ្ណនាំចូលអោយបានរួសរាន់ ។

សិទ្ធិរបស់អ្នកនាំចូល: អ្នកនាំចូល និងអ្នកផ្គត់ផ្គង់បរទេសមានសិទ្ធិដូចខាងក្រោមថា ÷

- ☐ នីតិវិធីដែលបានអនុម័តឡើង សំរាប់ការចេញអាជ្ញាប័ណ្ណ នៅកំរិតជាតិស្របទៅតាមគោលការណ៍ណែនាំដែលមានចែងក្នុងកិច្ចព្រមព្រៀង ។
- ☐ មិនទទួលបាននូវការផាកពិន័យដោយពុំសមហេតុផលលើកំហុសឆ្គងអក្ខរាវិរុទ្ធបន្តិចបន្តួចដែលមានក្នុងពាក្យសុំនោះឡើយ ។
- ☐ នឹងទទួលបានអាជ្ញាប័ណ្ណ ដែលចេញអោយតាមពេលវេលាដែលមានចែងក្នុងកិច្ចព្រមព្រៀង ។ (សូមអានជំពូក ៦) ។

វិធាននានាដែលអនុវត្តលើការនាំចេញ:

ការសងមកវិញនូវពន្ធប្រយោលទៅលើផលិតផលនាំចេញ

សិទ្ធិរបស់អ្នកនាំចេញ: អ្នកនាំចេញរំពឹងថាមានសិទ្ធិនឹង ÷

- ☐ លើកលែងដល់ការទូទាត់ ឬ កំត្រូវដកសងមកវិញនូវពន្ធគយលើផលិតផលនាំចេញ ។
- ☐ សងមកវិញនូវរាល់ពន្ធប្រយោលដែលបានបង់លើផលិតផលនាំចេញ ។

ពន្ធនាំចេញ: ក្រៅពីនេះ អ្នកនាំចេញមានសិទ្ធិក្នុងការរំពឹងអោយរដ្ឋាភិបាលគិតពន្ធលើចំណូល ឬ លើមុខសញ្ញាគិតពន្ធផ្សេងទៀត តាមអត្រាដូចគ្នា ដោយពុំធ្វើការបែងចែកគោលដៅនៃការនាំចេញឡើយ ។

(សូមអានជំពូក ៧) ។

សកម្មភាពប្រឆាំងនឹងការលក់បង្ខូចថ្លៃ និងសកម្មភាពប៉ះប៉ូវ

សិទ្ធិរបស់អ្នកនាំចេញ:

- ☐ សិទ្ធិរំពឹងថា អ្នកនាំចេញ ដែលសង្ស័យថាបានលក់បង្ខូចថ្លៃ ឬ នាំចេញផលិតផលដែលទទួលបានឧបត្ថម្ភធននឹងទទួលបានការជូនដំណឹងអោយដឹងភ្លាមៗ នៅពេលគេចាប់ផ្តើមធ្វើការស៊ើបអង្កេត ។
- ☐ ពួកគេមានសិទ្ធិផ្តល់ទល្លីករណ៍(ភស្តុតាង) ដើម្បីការពារផលប្រយោជន៍ នៅក្នុងពេលស៊ើបអង្កេត ។
- ☐ រំពឹងថា ត្រូវបញ្ចប់នីតិវិធីនៅពេលដែលការស៊ើបអង្កេតជំហានដំបូងបង្ហាញថា ទំហំនៃការលក់បង្ខូចថ្លៃ ឬ ការនាំចូលផលិតផលដែលទទួលបានឧបត្ថម្ភធននេះ មានរូបភាពតូចតាច ហើយការនាំចូលនោះក៏តិចតួចស្តួចស្តើង ។

សិទ្ធិរបស់ផលិតករក្នុងស្រុក: សិទ្ធិក្នុងការដាក់ពាក្យបណ្តឹងសុំអោយមានការគិតពន្ធលើការលក់បង្ខូចថ្លៃ ឬ ពន្ធប៉ះប៉ូវ នៅពេលដែលការលក់បង្ខូចថ្លៃ ឬ ការផ្តល់ឧបត្ថម្ភធនបង្កអោយមានការខូចខាតធ្ងន់ធ្ងរដល់ឧស្សាហកម្មក្នុងស្រុក ប្រសិនបើពាក្យបណ្តឹងនោះមានអះអាងដោយគិតគួរឃើញថាខូចខាតយ៉ាងហោចណាស់ ២៥% នៃផលិតកម្មឧស្សាហកម្ម ។

(សូមអានជំពូក១១) ។

ឧបសម្ព័ន្ធ ២

កិច្ចព្រមព្រៀង WTO: បទបញ្ញត្តិស្តីពីប្រព្រឹត្តកម្មពិសេស និងដោយឡែករបស់ប្រទេសកំពុងអភិវឌ្ឍន៍-អត្ថបទវិភាគសង្ខេប

ទូទៅ

កិច្ចព្រមព្រៀង WTO រួមមានបទបញ្ញត្តិចែងពីការពង្រីកបន្ថែមនូវប្រព្រឹត្តកម្មពិសេស និងដោយឡែកសំរាប់ប្រទេសកំពុងអភិវឌ្ឍន៍។ តាមបទបញ្ញត្តិទាំងនេះ ប្រទេសកំពុងអភិវឌ្ឍន៍នឹងទទួលបាននូវភាពអនុគ្រោះជាងប្រទេសជឿនលឿន ។

បទបញ្ញត្តិនោះអាចចែកចេញជាបីប្រភេទធំដោយឡែកពីគ្នា ÷

- ☐ បទបញ្ញត្តិដែលតំរូវអោយប្រទេសប្រកាន់យកវិធានការណ៍សំរាប់ជួយសំរួលដល់ការធ្វើពាណិជ្ជកម្ម នៃប្រទេសកំពុងអភិវឌ្ឍន៍ និងប្រទេសក្រីក្រ (LDCs) ។
- ☐ ភាពអាចបត់បែនបាន ឬ ផ្លាស់ប្តូរបានចំពោះប្រទេសកំពុងអភិវឌ្ឍន៍ និងប្រទេសក្រីក្រក្នុងការទទួលយកកាតព្វកិច្ចដែលកំហិតដោយកិច្ចព្រមព្រៀង WTO។
- ☐ បទបញ្ញត្តិចែងពីជំនួយបច្ចេកទេសសំរាប់ប្រទេសកំពុងអភិវឌ្ឍន៍ និងប្រទេសក្រីក្រសំរាប់កសាងសមត្ថភាពដើម្បីអនុវត្តកិច្ចព្រមព្រៀង ។

ការពន្យល់បកស្រាយអំពីចរិក និងខ្លឹមសារនៃបទបញ្ញត្តិសំខាន់ៗ នៅក្នុងប្រភេទនិមួយៗ នឹងមានរៀបរាប់ដូចខាងក្រោមនេះ។

បទបញ្ញត្តិដែលតំរូវអោយបណ្តាប្រទេសនានាចាត់វិធានការណ៍ S&D ដើម្បីសំរួលដល់ការធ្វើពាណិជ្ជកម្មរបស់ប្រទេសកំពុងអភិវឌ្ឍន៍

វិធានការណ៍ S&D ដែលស្ថិតនៅក្នុងប្រភេទនេះរួមមាន ÷

- ☐ វិធានការណ៍ឯកតោភាគីប្រកាន់យកដោយប្រទេសជឿនលឿន ក្នុងការអនុញ្ញាតអោយមានការនាំចូលតាមល័ក្ខខ័ណ្ឌអនុគ្រោះពីប្រទេសកំពុងអភិវឌ្ឍន៍ ។
- ☐ ការផ្តល់អទិភាពនៅក្នុងកិច្ចចរចាពាណិជ្ជកម្មសំដៅកាត់បន្ថយ និងលប់ចោលពន្ធគយ MFN ទៅលើផលិតផលដែលជាផលប្រយោជន៍ដល់ប្រទេសកំពុងអភិវឌ្ឍន៍ និងប្រទេសក្រីក្រ ។
- ☐ ការពង្រីកប្រព្រឹត្តិកម្ម S&D ដល់ប្រទេសកំពុងអភិវឌ្ឍន៍ និងប្រទេសក្រីក្រតាមទំរង់នៃការអនុវត្តន៍ដូចជា ÷
  - ការកំហិតគូតា
  - នីតិវិធីនៃការផ្តល់អាជ្ញាប័ណ្ណ

- វិធានការការពារ បំរុងទុកទុននូវការកើតមានជាយថាហេតុ ដូចជាសកម្មភាពការពារសុវត្ថិភាពការប្រឆាំងនឹងការលក់បង្ខូចថ្លៃ និងវិធានការប៉ះប៉ូវ ។

វិធានការលើឯកតោភាគីអនុម័តដោយប្រទេសជឿនលឿន ក្នុងការអនុញ្ញាតិអោយមានការនាំចូលក្រោមមូលដ្ឋានប្រព័ន្ធអនុគ្រោះ

ប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម GSP

មានការអនុញ្ញាតិអោយនាំចូលពីប្រទេសកំពុងអភិវឌ្ឍន៍ និងប្រទេសក្រីក្រ តាមប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម GSP ផ្អែកតាមការមិនយកពន្ធសោះ ឬ យកពន្ធតិចតួច ។GSP គ្របដណ្តប់ស្ទើរតែគ្រប់ផលិតផលឧស្សាហកម្មទាំងអស់ និងផលិតផលកសិកម្មមួយចំនួន។

មូលដ្ឋានច្បាប់ សំរាប់កិច្ចព្រមព្រៀងអនុគ្រោះនេះ ត្រូវបានកំណត់តាមការសំរេចផ្អែកលើការអនុគ្រោះច្រើន ឬ តាមលក្ខខ័ណ្ឌពិសេសមួយតាមលក្ខណៈមានទៅមានមក និងតាមរយៈ Fuller ការចូលរួមដ៏ពេញលេញរបស់ប្រទេសកំពុងអភិវឌ្ឍន៍ (អនុម័តក្នុងឆ្នាំ ១៩៧៩ និងគេទទួលស្គាល់ថាជាប្រយោគបន្ថែមទូទៅ General Enabling Clause) ។ ទោះជាយ៉ាងនេះក៏ដោយកិច្ចព្រមព្រៀង GSP ប្រព្រឹត្តទៅតាម ÷

- ☐ ការនាំចូលដែលមានកំរិតកំណត់ ដូចជាការកំណត់កូតា : ការនាំចូលនៅក្នុងចន្លោះកូតា នោះត្រូវបានគេអនុញ្ញាតិអោយដោយគិតតាមមូលដ្ឋានអនុគ្រោះពាណិជ្ជកម្ម តែបើការនាំចូលច្រើនជាងកូតាកំណត់នោះ ត្រូវគិតពន្ធនាំចូលតាម MFN។
- ☐ មិនអនុញ្ញាតិអោយនាំចូលនូវផលិតផលមួយចំនួនពីប្រទេសខ្លះ ដែលក្លាយទៅជាអ្នកប្រកួតប្រជែង (លក្ខណៈវិនិច្ឆ័យអំពីការប្រកួតប្រជែង)
- ☐ មិនអនុញ្ញាតិអោយនាំចូលចំពោះប្រទេសកំពុងអភិវឌ្ឍន៍ណា ដែលកំរិតអភិវឌ្ឍន៍របស់ខ្លួន កើនឡើងទៅដល់តំណាក់កាលកំណត់មួយ ឬ ក៏ជាប្រទេសដែលមិនគោរពសិទ្ធិមនុស្ស ។ ប្រទេសណាដែលប្រាក់ចំណូលក្នុងមនុស្សម្នាក់ មានកំរិតខ្ពស់ជាក់លាក់មួយ មានន័យថា ប្រទេសនោះ ឈានទៅដល់កំរិតអភិវឌ្ឍន៍ខ្ពស់ល្មមឈប់ទទួលបានការអនុគ្រោះផ្នែកពាណិជ្ជកម្មហើយ ។

ប្រព្រឹត្តកម្មដែលផ្តល់ការអនុគ្រោះពាណិជ្ជកម្មច្រើនដល់បណ្តាប្រទេសក្រីក្រ

ប្រយោគពិសេសបន្ថែមចែងថា ក្រោមគំរោង GSP ប្រព្រឹត្តិកម្មពិសេស លើសពីអ្វីដែលគេបានផ្តល់អោយទៅប្រទេសកំពុងអភិវឌ្ឍន៍ ត្រូវបានគេផ្តល់អោយទៅប្រទេស LDCs ។ ស្របតាមប្រការនេះបណ្តាប្រទេសជឿនលឿនបានឯកភាពគ្នា នៅឯកិច្ចប្រជុំថ្នាក់ខ្ពស់នាខែតុលា ឆ្នាំ១៩៩៧ ស្តីអំពីគំនិតផ្តួចផ្តើមរួមបញ្ចូលការអភិវឌ្ឍន៍ពាណិជ្ជកម្មរបស់ប្រទេស LDCs តាមរយៈការអនុញ្ញាតិអោយនាំចូលនូវផលិតផលទាំងអស់ ដែលផ្តល់ប្រយោជន៍ដល់ LDCs ផ្អែកតាមមូលដ្ឋានអនុគ្រោះដោយពុំយកពន្ធ ។ បន្ថែមទៀត ការកំរិតទៅលើការនាំចូលតាមរយៈកូតា ក្រោមប្រព័ន្ធ GSP (ដូចជាការកំណត់កូតា និងលក្ខណៈវិនិច្ឆ័យពីការប្រកួតប្រជែងរបស់ប្រទេស) មិនត្រូវបានគេអនុវត្តជាទូទៅ ចំពោះការនាំចូលពីប្រទេស LDCs ឡើយ ។

កិច្ចព្រមព្រៀងដែលចែងពីការបើកទីផ្សារប្រកបដោយតាមលក្ខខណ្ឌអនុគ្រោះ សំរាប់ប្រទេសកំពុងអភិវឌ្ឍន៍មួយចំនួន

កិច្ចព្រមព្រៀងនេះរួមមាន ÷

- ☐ សន្ធិសិទ្ធ LOME តាមទំរង់ដែលសហគមន៍អ៊ឺរ៉ុប អនុញ្ញាតិអោយមានការនាំចូលពីប្រទេស ACP ដោយផ្អែកលើមូលដ្ឋានអនុគ្រោះដោយពុំយកពន្ធ ។
- ☐ ការផ្តួចផ្តើមគំនិតសំរាប់តំបន់ ការ៉ាអ៊ីប (CBI) ដែលអនុញ្ញាតិអោយការនាំចូលពីបណ្តាប្រទេសការ៉ាអ៊ីបទៅសហរដ្ឋអាមេរិកដោយពុំយកពន្ធ ។

ដោយពុំមានមូលដ្ឋានគតិយុត្តតាមច្បាប់របស់ WTO ចំពោះកិច្ចព្រមព្រៀងពិសេសដូចរៀបរាប់ខាងលើ កិច្ចព្រមព្រៀងនេះត្រូវបានគេអនុញ្ញាតិ អោយអនុវត្តតាមរបៀបលើកលែងពិសេស Waivers ។ រយៈពេលនៃការលើកលែងពិសេស (Waivers)

ចំពោះសន្និសីទនៅ LOME គឺផុតកំណត់ នៅថ្ងៃទី ១ ខែមករា ឆ្នាំ២០០០ តែវាអាចពន្យាពេលបានប្រាំឆ្នាំទៀត (អាចបានរហូតដល់ថ្ងៃទី ១ ខែមករា ឆ្នាំ ២០០៥) ។

អាទិភាពក្នុងការកាត់បន្ថយ និងលប់ចោលពន្ធគយនៅក្នុងការចរចារពាណិជ្ជកម្ម

សកម្មភាពដែលប្រកាន់យកដោយប្រទេសជឿនលឿន

ពាណិជ្ជកម្មលើទំនិញ

ជំពូកទាំងឡាយនៃ GATT ស្តីអំពីពាណិជ្ជកម្ម និងអភិវឌ្ឍន៍ (ផ្នែកទី ៦) បានសុំឱ្យប្រទេសជឿនលឿន ផ្តល់អាទិភាពអោយបានច្រើនក្នុងការចរចាពាណិជ្ជកម្ម ដើម្បីបញ្ចុះ ឬ លប់ចោលពន្ធគយ MFN ប្រសិនជាអាចធ្វើបាន ចំពោះផលិតផលជាប្រយោជន៍ដល់ប្រទេសកំពុងអភិវឌ្ឍន៍ និងប្រទេសក្រីក្រ មិនតែប៉ុណ្ណោះ សុំឱ្យដកចេញនូវវិធានការណ៍ទាំងឡាយ ដែលបង្កផលប៉ះពាល់ដល់ការធ្វើពាណិជ្ជកម្មមុខទំនិញទាំងនោះផងដែរ ។

ការបន្ថយពន្ធគយ ជួយបង្កលក្ខណៈអនុគ្រោះដែលជាប្រយោជន៍ដល់ប្រទេសកំពុងអភិវឌ្ឍន៍ក្រោមកិច្ចព្រមព្រៀងផ្តល់ភាពអនុគ្រោះ ។ វិធានជាមូលដ្ឋានដំបូងរបស់ GATT ដែលបានអនុម័តនៅក្នុងកិច្ចចរចា បានទទួលស្គាល់ពីសេចក្តីត្រូវការចាំបាច់តាមមូលដ្ឋានករណីនីមួយៗ នូវលទ្ធភាពដកចេញពន្ធគយ MFN ពីផលិតផលដែលគេរកឃើញថា វាផ្តល់ផលប្រយោជន៍ជាសំខាន់ៗដល់ប្រទេសកំពុងអភិវឌ្ឍន៍ ហើយមានអត្ថន័យជ្រាលជ្រៅចំពោះល័ក្ខខ័ណ្ឌធ្វើពាណិជ្ជកម្ម ។

ពាណិជ្ជកម្មលើសេវាកម្ម

GATTS ចែងថា ប្រទេសជឿនលឿនត្រូវផ្តល់អាទិភាពច្រើនដល់ការចរចាពាណិជ្ជកម្ម ដើម្បីធ្វើសេរីភាវូបនីយកម្មលើសេវាកម្ម និងធ្វើសេរីភាវូបនីយកម្មដល់របៀបផ្គត់ផ្គង់សេវាកម្មទាំងឡាយ ដែលជាផលប្រយោជន៍ពិសេសរបស់ប្រទេសកំពុងអភិវឌ្ឍន៍ ។

សកម្មភាពប្រកាន់យកដោយប្រទេសកំពុងអភិវឌ្ឍន៍

ផ្នែកទី ៤ នៃ GATT ក៏បានលើកទឹកចិត្តផងដែរ អោយប្រទេសកំពុងអភិវឌ្ឍន៍ប្រកាន់យកវិធានការណ៍ស្រដៀងគ្នាទៅនឹងប្រទេសជឿនលឿន និងផ្តល់អតិភាពដល់ការដកចេញនូវពន្ធគយ និងរបាំងពាណិជ្ជកម្មផ្សេងទៀត ដែលមានទៅលើផលិតផលដែលជាប្រយោជន៍នៃប្រទេសកំពុងអភិវឌ្ឍន៍នានា ។

បន្ថែមទៀតប្រការចែងពិសេសទូទៅ (General Erabling Clouse) អនុញ្ញាតិឱ្យប្រទេសកំពុងអភិវឌ្ឍន៍ ពង្រីកប្រព្រឹត្តកម្មពិសេស និងអនុគ្រោះបំផុតទៅលើការនាំចូលពីប្រទេស LDCs ក្រោមកិច្ចព្រមព្រៀងអនុគ្រោះក្នុងតំបន់ ឬ សាកល ដែលត្រូវបានអនុម័តដោយពួកគេសំរាប់ពង្រឹងពាណិជ្ជកម្ម ក្នុងចំណោមប្រទេសក្នុងតំបន់ និងក្នុងសកលលោក។

ការដាក់កំហិតលើបរិមាណ និងការកំហិតផ្សេងទៀត

វគ្គចរចានៅ អ៊ុយរ៉ុយហ្គាយ បានដកចេញនូវការដាក់កំហិតលើបរិមាណនៅក្នុងផ្នែកកសិកម្ម និងឧស្សាហកម្ម ហើយក៏បានលប់ចោលនូវវិធានការណ៍ដាក់កំហិតផ្សេងទៀត ដូចជា ការរឹតកំណត់ការនាំចេញដោយស្ម័គ្រចិត្ត និងការដាក់ពន្ធប្រែប្រួលពុំកំណត់ច្បាស់លាស់។ ការដាក់កំហិតលើបរិមាណ ដែលត្រូវបានគេអនុញ្ញាតិ គឺចំពោះតែ ÷

- ☐ ការកំហិតដែលដាក់ចេញក្រោមបទបញ្ញត្តិនៃកិច្ចព្រមព្រៀងអំពីវាយនភ័ណ្ឌ និងសំលៀកបំពាក់ ។
- ☐ ការកំហិតដែលដាក់ចេញឱ្យប្រទេសដែលមានផលលំបាកផ្នែកតុល្យភាពនៃការទូទាត់ហើយស្របតាមមាត្រា១២ និង១៣ នៃ GATT ឆ្នាំ ១៩៩៤ និងស្របតាមការពន្យល់ណែនាំអំពីតុល្យភាពនៃការទូទាត់តាមបទបញ្ញត្តិរបស់ GAT ឆ្នាំ ១៩៩៤ (អនុម័តនៅវគ្គចរចាអ៊ុយរ៉ូយហ្គាយ)

- ☐ ការដាក់កំហិតដែលដាក់ចេញស្របតាមបទបញ្ញត្តិអញ្ញត្រកម្មផ្សេងទៀតនៃ GATT ឆ្នាំ ១៩៩៤ ជាពិសេសបទបញ្ញត្តិដែលចែងនៅក្នុងមាត្រាទី២០ ។

គួរកត់សំគាល់ថា កិច្ចព្រមព្រៀងស្តីអំពីវាយនភ័ណ្ឌ និងសំលៀកបំពាក់ចែងថា ប្រទេសដែលមានការដាក់កំហិត(ជាពិសេសប្រទេសជឿនលឿន) ត្រូវដកការដាក់កំហិតនោះចេញជា បួនដំណាក់កាលក្នុងពេលដប់ឆ្នាំ គឺត្រូវបញ្ចប់នៅថ្ងៃមួយ ខែមករា ឆ្នាំ២០០៥ ។ បន្ថែមទៀត ដើម្បីអោយផលិតផលវាយនភ័ណ្ឌអាចបើកច្រកទីផ្សារកាន់តែទូលាយចំពោះផ្នែកដែលមានកំហិតក្នុងរយៈពេលអន្តរកាល កិច្ចព្រមព្រៀងចែងថា កត្តាកំណើននៃបញ្ញតិកំណត់ត្រូវអនុវត្តឱ្យទូលាយជាងអត្រាកំពុងមានសព្វថ្ងៃនៃកំណើននៅក្នុងកូតាកំណត់ ចំពោះពាណិជ្ជកម្មទ្វេភាគី ។ វិធាននេះចែងសំរាប់ប្រព្រឹត្តកម្មពិសេស និងអនុគ្រោះច្រើន ទៅដល់អ្នកផ្គត់ផ្គង់តូចតាច និងប្រទេស LDCs ផ្អែកតាមមូលដ្ឋានកំរិតកូតា និងផ្អែកតាមអត្រា កំណើននៃការប្រែប្រួលការតំរូវនានា នៅក្នុងបញ្ហាផ្សេងៗទៀត ។

និតិវិធីសំរាប់ការផ្តល់អាជ្ញាប័ណ្ណនាំចូល

កិច្ចព្រមព្រៀងស្តីអំពីនិតិវិធីនៃការផ្តល់អាជ្ញាប័ណ្ណនាំចូល មានកំណត់គោលការណ៍ និងវិធាននានា ដើម្បីធានាថា និតិវិធីនៃការផ្តល់អាជ្ញាប័ណ្ណនាំចូលអនុម័តដោយប្រទេស (ចំពោះការគ្រប់គ្រងក្នុងគោលបំណងកំហិតកូតា និងគោលបំណងផ្សេងទៀត) ទាំងឡាយពុំបង្កើតជាឧបសគ្គដល់ការធ្វើពាណិជ្ជកម្មឡើយ ។ វិធាននេះចែងថា ត្រូវផ្តល់ការគិតគូរពិចារណា ជាពិសេសចំពោះការបែងចែកអាជ្ញាប័ណ្ណនាំចូលពីបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ជាពិសេសពីប្រទេស LDCs ។

វិធានការណ៍សំរាប់ការពារហេតុការណ៍កើតជាយថាហេតុ (សកម្មភាពការពារខ្លួន ការប្រឆាំងនឹងការលក់បង្ខូចថ្លៃ និងវិធានការណ៍ប៉ះប៉ូវ)

វិធានការណ៍សំរាប់ការពារហេតុការណ៍កើតជាយថាហេតុ រួមមានវិធានការណ៍ដាក់កំហិតលើការនាំចូលនានា ដែលគេអនុញ្ញាតិឱ្យបណ្តាប្រទេសផ្សេងៗ អាចប្រកាន់យកបានក្នុងស្ថានភាពចាំបាច់ ដែលមានផ្តល់លក្ខខ័ណ្ឌច្បាស់លាស់។ វិធានការណ៍ទាំងនោះមាន ÷

- ☐ សកម្មភាពការពារខ្លួនដើម្បីដាក់កំហិតលើការនាំចូល នៅពេលដែលការនាំចូលផលិតផលកើនឡើងបង្កផលប៉ះពាល់ធ្ងន់ធ្ងរដល់ផលិតករក្នុងស្រុកណាដែលផលិតផលិតផលស្រដៀងគ្នា ឬ ផលិតផលដែលប្រកួតប្រជែងគ្នា ។
- ☐ ការយកពន្ធសំរាប់ប្រឆាំងនឹងការលក់បង្ខូចថ្លៃ ចំពោះការនាំចូលដែលបង្កឱ្យខូចថ្លៃ និងពន្ធប៉ះប៉ូវចំពោះការនាំចូលដែលមានឧបត្ថម្ភធន ហើយដែលការនាំចូលនោះ នឹងបង្កផលប៉ះពាល់ធ្ងន់ធ្ងរដល់ឧស្សាហកម្មក្នុងស្រុក ។

វិធាននានា ចែងពីការពង្រីកប្រព្រឹត្តកម្ម សិក្សាស្រាវជ្រាវ និងការអភិវឌ្ឍន៍ក្នុងការអនុវត្តនីតិវិធានការទាំងនេះ ។ ដូចជា ÷

- ☐ កិច្ចព្រមព្រៀងស្តីអំពីការការពារខ្លួនចែងថា ការនាំចូលពីប្រទេសកំពុងអភិវឌ្ឍន៍ត្រូវលើកលែងពីវិធានការការពារខ្លួន ប្រសិនបើភាគរយនៃការនាំចូលផលិតផលនេះ ទៅប្រទេសដែលប្រកាន់យកវិធានការណ៍នោះ មានអត្រាតិចជាង ៣% ។ អញ្ញត្រកម្មនេះមិនត្រូវបានគេអនុវត្តទេ ប្រសិនជាបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ទាំងនោះមានភាគរយនៃការនាំចូលនីមួយៗ តិចជាង ៣% តែធៀបទៅនឹងការនាំចូលសរុបទៅវាច្រើនជាង៧% ។
- ☐ កិច្ចព្រមព្រៀងស្តីពីឧបត្ថម្ភធន និងវិធានការណ៍ប៉ះប៉ូវ តំរូវឱ្យអាជ្ញាធរមានសមត្ថកិច្ច ធ្វើការស៊ើបអង្កេតឱ្យបានច្បាស់លាស់នូវស្ថានភាព ដូចបានអធិប្បាយខាងក្រោម ÷
    - ក្នុងករណីដែលផលិតផលមួយមានប្រភពមកពីប្រទេសជឿនលឿន ហើយបរិមាណនៃការឧបត្ថម្ភធនមានកំរិតអប្បរមាបំផុត (ឧទាហរណ៍ តូចជាង១%) ឬ ទំហំនៃការនាំចូលដែលមានឧបត្ថម្ភធន ឬ ភាពបង្កផលប៉ះពាល់ទៅលើឧស្សាហកម្មក្នុងស្រុកមានកំរិតតិចតួចអាចអធ្យាស្រ័យបាន ។
    - ក្នុងករណីដែលផលិតផលមួយមានប្រភពមកពីប្រទេសកំពុងអភិវឌ្ឍន៍ហើយ ÷

- កំរិតនៃឧបត្ថម្ភធនទៅលើផលិតផលនោះមិនលើសពី ២% នៃតំលៃដែលបានគណនា ក្នុងមួយឯកត្តា
- ការនាំចូលដែលមានឧបត្ថម្ភធនតិចជាង ៤% នៃការនាំចូលសរុបនៃប្រទេសនាំចូល ។ ទោះបីជា យ៉ាងណាក៏ដោយ វិធានទាំងនេះ មិនត្រូវអនុវត្តក្នុងករណីដែលភាគរយនៃការនាំចូលរបស់បណ្តាប្រទេស កំពុងអភិវឌ្ឍន៍នីមួយៗ នោះ តិចជាង ៤% តែគិតទៅឃើញច្រើនជាង៩%នៃការនាំចូលសរុប ។

បទបញ្ញត្តិចែងពីភាពអាចបត់បែនបាននៃប្រទេសកំពុងអភិវឌ្ឍន៍ និងប្រទេសក្រីក្រ ក្នុងការទទួលយកភាតព្វកិច្ចរបស់អង្គការ WTO

បទបញ្ញត្តិទាំងនោះ អាចចែកចេញជាក្រុមដូចខាងក្រោម ÷

- ☐ ភាពអាចបត់បែនបានក្នុងការទទួលយកកាតព្វកិច្ចក្នុងពេលចរចាពាណិជ្ជកម្ម
- ☐ ភាពអាចបត់បែនបានសំរាប់ការរឹតបន្តឹងការការពារជាបណ្តោះអាសន្ន ដើម្បីលើកទឹកចិត្តដល់ការអភិវឌ្ឍន៍ឧស្សាហកម្មថ្មី និង សំរាប់ការទទួលយកវិធានការដាក់កំហិត (រឹតត្បិត) នៅពេលមានការលំបាកផ្នែកតុល្យភាពនៃការទូទាត់ ។
- ☐ រយៈពេលអន្តរកាលសំរាប់ការទទួលយកកាតព្វកិច្ចទាំងអស់ ឬខ្លះៗ ដែលកំណត់ដោយកិច្ចព្រមព្រៀង ។
- ☐ ការលើកលែងដល់ប្រទេសកំពុងអភិវឌ្ឍន៍ពីកាតព្វកិច្ចជាក់លាក់ណាមួយ ។

ភាពអាចបត់បែនបាន ក្នុងការទទួលយកកាតព្វកិច្ចនៅពេលចរចាពាណិជ្ជកម្ម

ពាណិជ្ជកម្មលើទំនិញ

ផ្អែកតាមវិធាននានានៃ GATT ការចរចាដើម្បីកាត់បន្ថយពន្ធគយ និងរបាំងពាណិជ្ជកម្មផ្សេងទៀត ចាំបាច់ត្រូវតែធ្វើ ដោយផ្អែកទៅតាមគោលការណ៍ដែលផ្តល់អត្ថប្រយោជន៍ទៅវិញទៅមក ។ ទោះវាយ៉ាងណាក៏ដោយផ្នែកទី៤ នៃ GATT ឆ្នាំ១៩៩៤ (ដែលមានបទបញ្ញត្តិស្តីអំពីការជំរុញការអភិវឌ្ឍន៍សេដ្ឋកិច្ច) ចែងថា ប្រទេសកំពុងអភិវឌ្ឍន៍មិនត្រូវទាមទារ ដើម្បីចូលរួមចំណែកនៅក្នុងកិច្ចចរចាពាណិជ្ជកម្ម (ក្នុងបែបបទកាត់បន្ថយ និងចងពន្ធគយ) ដែលពុំសមស្របតាមពាណិជ្ជកម្ម ការអភិវឌ្ឍន៍ និងសេចក្តីត្រូវការផ្នែកហិរញ្ញវត្ថុរបស់ខ្លួនឡើយ ។ បទបញ្ញត្តិនានានៅក្នុងផ្នែក ៤ ត្រូវបានបំពេញបន្ថែមដោយប្រការបន្ថែមទូទៅ (General Enaling clause) ដែលមានក្នុងចំណោមបទបញ្ញត្តិដ៏ទៃទៀត ថាសមត្ថភាពរបស់ប្រទេសនានាដែលចូលរួមវិភាគទាន និងផ្តល់សម្បទានតាមការចរចាត្រូវតែធ្វើឡើងតាមកំណើន និងដំណាក់កាលនៃការអភិវឌ្ឍន៍សេដ្ឋកិច្ចរបស់ខ្លួន ។

គំនិតនេះគឺច្រើនយោងទៅលើភាពមានទៅមានមកនៃការផ្តល់សម្បទាន ។ នៅក្នុងកិច្ចចរចា អ៊ុយរ៉ុយហ្គាយ ប្រទេសកំពុងអភិវឌ្ឍន៍នានាបានបញ្ចុះពន្ធគយទៅលើទំនិញទាំងក្នុងវិស័យឧស្សាហកម្ម និងកសិកម្មដែលអត្រាដែលបានបញ្ចុះនោះទាបជាងអត្រាដែលកំពុងអនុវត្តជាក់ស្តែងដោយប្រទេសជឿនលឿនទៅទៀត ។

វិធានដែលសុំឱ្យមានការចុះពន្ធគយលើច្រើនមុខទំនិញ ផ្អែកលើមូលដ្ឋានគិតជាភាគរយ មិនអនុវត្តទៅលើប្រទេស LDCs ទេ។ ក្នុងវិស័យឧស្សាហកម្ម បណ្តាប្រទេសជឿនលឿនបានបញ្ចុះពន្ធគយគ្រាន់តែជានិមិត្តសញ្ញាទៅលើមុខទំនិញមួយចំនួនតូចតែប៉ុណ្ណោះ ។ នៅក្នុងវិស័យកសិកម្ម ពុំមានការទាមទារឱ្យពួកគេបញ្ចុះពន្ធគយឡើយ ។

ជាងនេះទៀតប្រទេសកំពុងអភិវឌ្ឍន៍ និងប្រទេសក្រីក្រ អាចមានសិទ្ធិចងភ្ជាប់ពន្ធគយឱ្យខ្ពស់ជាងអត្រាដែលពួកគេកំពុងអនុវត្ត ឬខ្ពស់ជាងអត្រាដែលពួកគេបានបញ្ចុះ ។ ការចងអត្រាពន្ធបែបនេះគឺផ្តល់អាទិភាពឱ្យពួកគេក្នុងការតំឡើងពន្ធ (មិនឱ្យលើសអត្រាដែលមានប្រសិទ្ធិភាពចងរួច) ដោយពុំមានប៉ះពាល់ដល់កាតព្វកិច្ចនៃការអនុវត្តន៍ GATT ឡើយ ប្រសិនជាពួកគេយល់ថា ការតំឡើងពន្ធនេះជាការចាំបាច់ក្នុងការផ្តល់ការការពារដល់ផលិតកម្ម ឧស្សាហកម្ម និងកសិកម្មក្នុងស្រុក។

ពាណិជ្ជកម្មលើសេវាកម្ម

មាត្រាទី១៩ នៃកិច្ចព្រមព្រៀងGATS ផ្តល់ជូនដល់ប្រទេសកំពុងអភិវឌ្ឍន៍នូវលទ្ធភាពអាចបត់បែនបានក្នុងការបើកទូលាយវិស័យខ្លះ ឬ ធ្វើសេរីភាវូបនីយកម្មអាជីវកម្មមួយចំនួននៃការចរចាពាណិជ្ជកម្ម ដោយពួកគេមានសិទ្ធិទាំងស្រុងក្នុងជ្រើសយកវិធានការធ្វើសេរីភាវូបនីយកម្ម ដោយស្របទៅតាមស្ថានភាពអភិវឌ្ឍន៍របស់ខ្លួន ។ គេក៏ទទួលស្គាល់ផងដែរថា ការបើកទីផ្សារធ្វើឡើងដោយប្រទេសកំពុងអភិវឌ្ឍន៍ គឺផ្អែកទៅតាមល័ក្ខខ័ណ្ឌក្នុងគោលដៅពង្រឹងសមត្ថភាពអ្នកផ្តល់សេវាកម្មក្នុងស្រុក និងក្នុងគោលបំណងទទួលបាននូវការផ្ទេរបច្ចេកវិទ្យាក្នុងល័ក្ខខ័ណ្ឌពាណិជ្ជកម្ម ។ មាត្រា ១៩ក៏បានសុំឱ្យមានការពិចារណា ជាពិសេសដល់ប្រទេស LDCs ផងដែរ។

ភាពអាចបត់បែនបានក្នុងការបង្កើនកិច្ចការពារនិយម សំរាប់ការអភិវឌ្ឍន៍ឧស្សាហកម្មថ្មី និងសំរាប់ការប្រកាន់យកវិធានការណ៍ការពារ កំណត់នានានៅពេលមានបញ្ហាខាងតុល្យភាពនៃការទូទាត់

វិធានការណ៍ការពារសំរាប់ការអភិវឌ្ឍន៍ឧស្សាហកម្មថ្មី

មាត្រាទី XVIII:C នៃ GATT 1994 អនុញ្ញាតិឱ្យប្រទេសកំពុងអភិវឌ្ឍន៍ ប្រកាន់យកវិធានការដាក់កំហិតផ្នែកពាណិជ្ជកម្ម (ដូចជាការតំឡើងអត្រាពន្ធដែលបានចងភ្ជាប់ ឬ កំរិតកំណត់ដល់បរិមាណនៃការនាំចូល) ដើម្បីជំរុញដល់ការអភិវឌ្ឍន៍ឧស្សាហកម្មថ្មី ឬ ជំរុញដល់ការបង្កើនឧស្សាហកម្មថ្មីបន្ថែមទៀត ។ តែទោះជាយ៉ាងណាក៏ដោយវិធានការទាំងនោះដែលពុំស្របទៅតាមបទបញ្ញត្តិនានានៃ GATT អាចអនុវត្តបាន លុះត្រាតែមានការយល់ព្រមពីប្រទេសជាសមាជិក WTO ។ GATT បានផ្តល់ជានីតិវិធីសំរាប់ការពិគ្រោះយោបល់ជាមួយប្រទេសដែលអាចទទួលរងនូវផលប៉ះពាល់ពីវិធានការណ៍ដាក់កំហិតដែលគ្រោងនឹងប្រកាន់នោះ ។

វិធានការក្នុងករណីមានការលំបាកផ្នែកតុល្យភាពនៃការទូទាត់

បទបញ្ញត្តិដែលអនុញ្ញាតិឱ្យប្រទេសជាសមាជិកប្រកាន់យកវិធានការដាក់កំហិតលើការនាំចូល នៅពេលដែលជួបការលំបាកផ្នែកតុល្យភាពនៃការទូទាត់ មានចែងនៅក្នុងមាត្រា១២ និង១៨ នៃ GATT ។ មាត្រា១២ បានចែងពីឱកាស និងលក្ខខ័ណ្ឌដែលប្រទេសជឿនលឿន ប្រកាន់យកវិធានការណ៍ដាក់កំហិតលើការនាំចូល ។ មាត្រាទី១៨ អនុវត្តសំរាប់ប្រទេសកំពុងអភិវឌ្ឍន៍ ។ គេទទួលស្គាល់ថា ដោយសារកត្តាមួយចំនួន (ដូចជាករណីការនាំចេញមានការធ្លាក់ចុះពុំអាចបង្កើនប្រាក់ចំណូលបាន ហើយតំរូវការនាំចូលមានការកើនឡើង) ប្រទេសជួបការលំបាកនេះ ចាំបាច់ត្រូវដាក់កំហិតផ្នែកពាណិជ្ជកម្ម ដើម្បីការពារការធ្លាក់ចុះនៃធនបំរុងផ្នែកហិរញ្ញវត្ថុ ។ វាអនុញ្ញាតិឱ្យមានការបត់បែន និងបន្ថយការតឹងរ៉ឹងពេក ក្នុងការសុំឱ្យអនុវត្តបទបញ្ញត្តិដូចមានកំណត់នៅក្នុងមាត្រាទី១២ ។

តាមមាត្រាទី១២ ប្រទេសជឿនលឿនអាចប្រកាន់យកវិធានការណ៍ដាក់កំហិតផ្នែកពាណិជ្ជកម្មបាន នៅពេលដែលមានការធ្លាក់ចុះយ៉ាងធ្ងន់ធ្ងរនូវធនបំរុងផ្នែកហិរញ្ញវត្ថុ ឬ នៅពេលវាមានកំរិតទាបគួរឱ្យបារម្ភ ។ នៅក្នុងមាត្រាទី ១៨ ប្រទេសកំពុងអភិវឌ្ឍន៍អាចប្រកាន់យកសកម្មភាពកំរិតកំណត់ នៅពេលដែលខ្លួនគិតថា មានការធ្លាក់ចុះយ៉ាងធ្ងន់ធ្ងរនូវធនបំរុងផ្នែកហិរញ្ញវត្ថុ ទោះបីជាវាពុំទាន់ឈានដល់ភាពប្រកាសអាសន្នក៏ដោយ ។ មាត្រាទី១៨ ចែងបន្ថែមទៀតថា ប្រទេសកំពុងអភិវឌ្ឍន៍ អាចប្រកាន់យកសកម្មភាពខាងលើបាន ប្រសិនជាមានទស្សនៈយល់ថា ធនបំរុងផ្នែកហិរញ្ញវត្ថុវាពុំគ្រប់គ្រាន់សំរាប់ការទូទាត់ផ្នែករូបិយប័ណ្ណបរទេស ។ ផ្ទុយមកវិញមាត្រាទី១២ ចែងថា សកម្មភាពខាងលើអាចធ្វើបានលុះត្រាតែធនបំរុងផ្នែកហិរញ្ញវត្ថុវាមានកំរិតទាបខ្លាំង ។

រយៈពេលអន្តរកាលសំរាប់ការទទួលយកកាតព្វកិច្ចមកអនុវត្ត

កិច្ចព្រមព្រៀងពហុភាគីដែលបង្កើតជាធម្មនុញ្ញនៃប្រព័ន្ធ WTO មានប្រសិទ្ធិភាពចងភ្ជាប់កាតព្វកិច្ចចំពោះសមាជិកទាំងអស់។ តែទោះជាយ៉ាងណាក៏ដោយ កិច្ចព្រមព្រៀងខ្លះទទួលស្គាល់ថាប្រទេសកំពុងអភិវឌ្ឍន៍ និងប្រទេស LDCs មួយចំនួនពុំអាចមានលទ្ធភាពទទួលយកទៅអនុវត្តភ្លាមៗ នូវកាតព្វកិច្ចរបស់ WTO នោះបានឡើយ។ ហេតុដូច្នេះហើយទើបកិច្ចព្រមព្រៀងទាំងនោះផ្តល់រយៈពេលអន្តរកាលដែលប្រែប្រួលពី៥ ទៅ ១១ ឆ្នាំ ដើម្បីទុកលទ្ធភាពអោយប្រទេសទាំងនោះរៀបចំខ្លួនដើម្បីទទួលយកកាតព្វកិច្ចទៅអនុវត្ត។

ខាងក្រោមនេះគឺជាឧទាហរណ៍ខ្លះៗ នៃរយៈពេលអន្តរកាលដែលផ្តល់ឱ្យ ÷

- ☐ កិច្ចព្រមព្រៀងអំពីការវាយតំលៃពន្ធគយ : ប្រទេសកំពុងអភិវឌ្ឍន៍ និងប្រទេស LDCs អាចពន្យាពេលអនុវត្តកិច្ចព្រមព្រៀង ក្នុងរយៈពេល ៥ ឆ្នាំ ចាប់ផ្តើមពីថ្ងៃទី ០១ មករា ឆ្នាំ២០០០ ។

- ☐ កិច្ចព្រមព្រៀងស្តីអំពីទិដ្ឋភាពពាណិជ្ជកម្មទាក់ទងនឹងច្បាប់កម្មសិទ្ធបញ្ញា : រំពឹងថាប្រទេសកំពុងអភិវឌ្ឍន៍អាចអនុវត្តបទបញ្ញត្តិនៃ កិច្ចព្រមព្រៀងនេះនៅ ថ្ងៃ ០១ មករា ឆ្នាំ ២០០០ ហើយប្រទេស LDCs ចាប់ផ្តើមអនុវត្តបាននៅថ្ងៃ ០១ មករា ឆ្នាំ ២០០៦ ។

ការពន្យាពេលអនុវត្តកាតព្វកិច្ច មានបកស្រាយដូចខាងក្រោម ÷

- ☐ កិច្ចព្រមព្រៀងវាយតំលៃយកពន្ធគយ : ប្រទេសកំពុងអភិវឌ្ឍន៍ អាចស្នើសុំរយៈពេលអន្តរកាលលើស ឬ ច្រើនជាង ៥ ឆ្នាំ ហើយរយៈពេលបន្ថែម ៣ ឆ្នាំ សំរាប់អនុវត្តបទបញ្ញត្តិស្តីអំពីវិធីសាស្រ្តនៃការគណនាតំលៃ ។

- ☐ កិច្ចព្រមព្រៀងស្តីពីការអនុវត្តវិនិច្ឆ័យការណ៍អនាម័យ និងភូតគាមអនាម័យ ព្រមទាំងរបាំងបច្ចេកទេសផ្នែកពាណិជ្ជកម្ម: កិច្ចព្រមព្រៀងនេះ អនុញ្ញាតិឱ្យគណៈកម្មាធិការនីមួយៗផ្តល់ឱ្យប្រទេសកំពុងអភិវឌ្ឍន៍នូវការអញ្ញត្រកម្មក្នុងពេលកំណត់មួយ នូវកាតព្វកិច្ចមួយផ្នែក ឬទាំងស្រុង ដែលកិច្ចព្រមព្រៀងទាំងពីរនេះ កំណត់ឱ្យអនុវត្ត ។

អញ្ញត្រកម្មចំពោះប្រទេសកំពុងអភិវឌ្ឍន៍ ពីកាតព្វកិច្ចត្រូវអនុវត្តណាមួយ ឬ ពីភាពអាចបត់បែនបាន ស្របតាមកាតព្វកិច្ចត្រូវធ្វើ

កិច្ចព្រមព្រៀងស្តីពីឧបត្ថម្ភធន និងវិធានការប៉ះប៉ូវ

ការបកស្រាយនៃករណីអញ្ញត្រកម្ម របស់ប្រទេសកំពុងអភិវឌ្ឍន៍ ពីកាតព្វកិច្ចណាមួយ មានចែងក្នុងកិច្ចព្រមព្រៀងស្តីអំពីឧបត្ថម្ភធន និងវិធានការប៉ះប៉ូវ ។ វិធាននៃកិច្ចព្រមព្រៀងបានហាមឃាត់ប្រទេសជាសមាជិកពីការប្រើប្រាស់ការឧបត្ថម្ភធនដល់ការនាំចេញ តែពុំអនុវត្តចំពោះប្រទេសជាសមាជិកដែលជាប្រទេសកំពុងអភិវឌ្ឍន៍ និងប្រទេស LDCs ដែលមានប្រាក់ចំណូលក្នុងប្រជាជន ម្នាក់ស្មើនឹង ១០០០ USD ឬតិចជាងនេះក្នុងមួយឆ្នាំនោះឡើយ ។

កិច្ចព្រមព្រៀងស្តីពីកសិកម្ម

ឧទាហរណ៍ ស្តីពីការផ្តល់ភាពអាចបត់បែនបានបន្ថែមជូនប្រទេសកំពុងអភិវឌ្ឍន៍ស្របតាមកាតព្វកិច្ចផ្តល់ ឬ ចែងក្នុងកិច្ចព្រមព្រៀង ស្តីពីកសិកម្ម ។ កិច្ចព្រមព្រៀងហាមឃាត់ចំពោះប្រទេសដែលពុំទាន់បានបន្ថយការផ្តល់ឧបត្ថម្ភធនដល់ការនាំចេញកសិផល ឬ ផលិតផលកសិកម្ម ។ ដោយប្រទេសកំពុងអភិវឌ្ឍន៍ជាច្រើនពុំទាន់បានធ្វើការសន្យាបន្ថយការផ្តល់ឧបត្ថម្ភធននេះ ការហាមឃាត់ ត្រូវអនុវត្តចំពោះប្រទេសទាំងនោះ ។ ទោះជាយ៉ាងណាក៏ដោយ កិច្ចព្រមព្រៀងអនុញ្ញាតិឱ្យពួកគេផ្តល់ឧបត្ថម្ភធនតាមប្រភេទពីរយ៉ាង÷

- ☐ ការផ្តល់ឧបត្ថម្ភធនដែលនាំឱ្យមានការកាត់បន្ថយថ្លៃដើមនៃការនាំចេញ ស្វែងរកទីផ្សាររួម មានថ្លៃដើមសំរាប់ការប្រើប្រាស់ និងកែលំអរ និងដំណើរការផលិតផ្សេងទៀតដែលទាក់ទងនឹងការស្វែងរកទីផ្សារព្រមទាំងថ្លៃដើមដឹកជញ្ជូនអន្តរជាតិ និង

- ☐ ការគិតកំរៃដឹកជញ្ជូនផ្ទៃក្នុងអំពីការបញ្ជូនទំនិញនាំចេញតាមល័ក្ខខ័ណ្ឌអនុគ្រោះជាងការបញ្ជូនទំនិញក្នុងស្រុក ។

កិច្ចព្រមព្រៀងគំរូវបន្ថែមទៀតអោយប្រទេសទាំងនោះ ត្រូវបន្ថយការផ្តល់ឧបត្ថម្ភធនក្នុងស្រុក (ដូចជាការផ្តល់ឧបត្ថម្ភធនផ្សេងទៀត ក្រៅពីការផ្តល់ឧបត្ថម្ភធនដល់កសិផលនាំចេញ) តាមអត្រាដែលបានព្រមព្រៀងគ្នា។ ដើម្បីលើកទឹកចិត្តដល់ការអភិវឌ្ឍន៍កសិកម្ម និងជនបទ ប្រទេសកំពុងអភិវឌ្ឍន៍ត្រូវបានអនុញ្ញាតិឱ្យដកចេញពីការគណនាវាស់វែង អំពីការគាំពារជាទូទៅ (Aggregate Measurement of Support) ដែលការផ្តល់ឧបត្ថម្ភធននោះមានគោលបំណងដូចខាងក្រោម ÷

- ☐ គាំពារដល់វិនិយោគទុនដែលជាទូទៅអាចធ្វើបាន ចំពោះវិស័យកសិកម្មនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ។

- ☐ គាំពារដល់ធនធានបំរើឱ្យរោងចក្រ ឬ ឱ្យផលិតកម្មដែលជាទូទៅអាចធ្វើបាន ចំពោះផលិតករដែលមានចំណូលទាប ឬខ្វះធនធាន ។
- ☐ គាំពារដែលលើកទឹកចិត្តដល់កសិករដែលយល់ព្រមឈប់ប្រកបរបរដាំដំណាំគ្រឿងញៀន ។

ជំនួយបច្ចេកទេសដើម្បីកសាងសមត្ថភាពសំដៅអនុវត្តកិច្ចព្រមព្រៀងទាំងឡាយ

កិច្ចព្រមព្រៀង WTO មួយចំនួនមានបទប្បញ្ញត្តិតំរូវអោយប្រទេសជាសមាជិក (ប្រទេសជឿនលឿន ប្រទេសកំពុងអភិវឌ្ឍន៍ និងប្រទេសដែលស្ថិតក្នុងអន្តរកាល) លេខាធិការដ្ឋាន WTO និងអង្គការអន្តរជាតិនានាដែលមានសមត្ថកិច្ចលើវិស័យដែលខ្លួនកំពុងគ្រប់គ្រង ត្រូវធ្វើការផ្តល់ជាជំនួយបច្ចេកទេសដល់ប្រទេសកំពុងអភិវឌ្ឍន៍ និងប្រទេសក្រីក្រ ដើម្បីធ្វើការកែលំអរស្ថាប័ន និងប្រព័ន្ធច្បាប់ព្រមទាំងសមត្ថភាព ដើម្បីអាចមានលទ្ធភាពអនុវត្តកិច្ចព្រមព្រៀង ។

ផ្នែកទីមួយ

អង្គការពាណិជ្ជកម្មពិភពលោក
តួនាទី និងមុខងាររបស់អង្គការនេះ

ជំពូក ១

អង្គការពាណិជ្ជកម្មអន្តរជាតិ : វេទិកាសំរាប់ការចរចា ដោះស្រាយវិវាទ និងពិនិត្យមើលគោលនយោបាយពាណិជ្ជកម្ម

សេចក្តីសង្ខេបៈ

អង្គការ WTO គឺជាអង្គការកំពូលមួយទទួលខុសត្រូវក្នុងការត្រួតពិនិត្យមើលការអនុវត្តន៏កិច្ចព្រមព្រៀងដូចខាងក្រោម ÷

- ☐ *GATT និងកិច្ចព្រមព្រៀងពាក់ពន្ធ័ផ្សេងៗទៀត*
- ☐ *GATs*
- ☐ *កិច្ចព្រមព្រៀង TRIPS និង*
- ☐ *ឯកសារច្បាប់ដែលត្រូវអនុវត្តផ្សេងៗ ទៀតរបស់ WTO ។*

អង្គការ WTO ផ្តល់ជាវេទិកាសំរាប់កិច្ចចរចាបន្តទៀតក្នុងចំណោមប្រទេសជាសមាជិកសំដៅធ្វើសេរីភាវូបនីយកម្មបន្តនូវពាណិជ្ជកម្មលើទំនិញ និងសេវាកម្ម ព្រមទាំងសំរាប់ពិភាក្សាអំពីបញ្ហាទាក់ទងនឹងពាណិជ្ជកម្ម ដែលត្រូវសិតសំរាំងយកមករៀបចំជាវិធាន និងវិន័យទាំងឡាយរបស់អង្គការពាណិជ្ជកម្មពិភពលោក ។

ក្រៅពីនេះ អង្គការពាណិជ្ជកម្មពិភពលោកបានធ្វើការពិនិត្យមើលជាប្រចាំលើគោលនយោបាយពាណិជ្ជកម្ម របស់ប្រទេសជាសមាជិកនីមួយៗ ។ អង្គការនេះក៏ទទួលខុសត្រូវផងដែរ ក្នុងការសំរុះសំរួលវិវាទពាណិជ្ជកម្ម ក្នុងចំណោមប្រទេសជាសមាជិក ដោយផ្អែកលើមូលដ្ឋានច្បាប់នៃកិច្ចព្រមព្រៀងទាំងឡាយរបស់ខ្លួន ។

មកដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ ១៩៩៩ អង្គការពាណិជ្ជកម្មពិភពលោកមានសមាជិកចំនួន ១៣៤ ប្រទេស ហើយមានប្រទេសចំនួន ៣០ កំពុងធ្វើការចរចាដើម្បីសុំចូលជាសមាជិក [៣] ។

អង្គការពាណិជ្ជកម្មពិភពលោក : គោលបំណង មុខងារ និងរចនាសម្ព័ន្ធ

គោលបំណង និងអាណត្តិ

កិច្ចព្រមព្រៀង Marrakesh ស្តីពីការបង្កើត WTO
កិច្ចព្រមព្រៀង WTO
បុព្វកថា

អង្គការពាណិជ្ជកម្មពិភពលោក គឺជាអង្គការកំពូលមួយទទួលខុសត្រូវក្នុងការពិនិត្យមើលការអនុវត្តន៏កិច្ចព្រមព្រៀងពហុភាគី និងច្រើនភាគី ដែលបានលើកមកចរចានៅវគ្គចរចានៅឃ្សវ៉ូហ្គាយ និងខ្លះទៀតត្រូវលើកមកចរចានាពេលអនាគតខាងមុខ ។ គោលបំណងជាមូលដ្ឋានរបស់អង្គការពាណិជ្ជកម្មពិភពលោក គឺស្រដៀងគ្នាទៅនឹងGATT ដែលក្រោយមកGATT បានរួមបញ្ចូលតាមផ្លូវច្បាប់ទៅជា WTO ។ មានការពង្រីកកម្មវត្ថុទាំងឡាយរបស់ WTO ដើម្បីផ្តល់អំណាចអោយអង្គការនេះដោះស្រាយកិច្ចការពាណិជ្ជកម្មលើសេវាកម្ម ។ គោលបំណងសំខាន់បន្ថែមទៀត គឺដើម្បីជំរុញដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ច តាមរយៈការពង្រីកផ្នែកពាណិជ្ជកម្ម ហើយក៏មានការយកចិត្តទុកដាក់ជាសំខាន់ផងដែរដល់កិច្ចការពារបរិស្ថាន (សូមអានវណ្ណ ៣) ។

[៣] នាថ្ងៃទី ២១ ខែមិនា ១៩៩៩ អគ្គក្រុមប្រឹក្សាភិបាលបានទទួលយកពាក្យស្នើសុំចូលជាសមាជិករបស់ Estonia ហើយ Estonia នឹងក្លាយជាប្រទេសសមាជិកទី ១៣៥ ក្នុងរយៈពេល ៣០ ថ្ងៃ ក្រោយពេលគេបានជូនដំណឹងទៅលេខាធិការដ្ឋានស្តីពីការបញ្ចប់ដំណើរការផ្តល់សច្ចាប័នរបស់ជាតិគេ ។

មុខងារ

កិច្ចព្រមព្រៀងបង្កើតអង្គការ WTO បានចែងថា អង្គការនេះត្រូវមានមុខនាទីដូចតទៅ ÷

ខណ្ឌ ៣ :

គោលបំណងរបស់ WTO

នៅក្នុងបុព្វកថានៃកិច្ចព្រមព្រៀងបង្កើតអង្គការពាណិជ្ជកម្មពិភពលោក មានចែងពីគោលបំណងរបស់WTO ដូចជា ÷ លើកកំពស់ជីវភាពរស់នៅ និងចំណូលនានា ធានាអោយមានការងារធ្វើពេញលេញ ពង្រីកផលិតកម្ម និងពាណិជ្ជកម្ម អនុញ្ញាតអោយមានការប្រើប្រាស់ធនធានពិភពលោកប្រកបដោយប្រសិទ្ធភាព និងអស់សក្តានុពល ។ បុព្វកថាបានពង្រីកបន្ថែមគោលបំណងទៅលើវិស័យមួយចំនួនដូចខាងក្រោម ÷

- ☐ *ពាណិជ្ជកម្មលើសេវាកម្ម*
- ☐ *សេចក្តីត្រូវការសំរាប់ជំរុញនិរន្តភាពនៃការអភិវឌ្ឍន៍ និងការពារបរិស្ថាន តាមរបៀបមួយសមស្របទៅតាមកំរិតនៃការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិនីមួយៗ ។*
- ☐ *សេចក្តីត្រូវការចំពោះការខិតខំជាវិជ្ជមាន ដើម្បីធានាថា ប្រទេសកំពុងអភិវឌ្ឍន៍ និងប្រទេសក្រីក្រ មានការអភិវឌ្ឍន៍ និងមានកំណើនសេដ្ឋកិច្ចផងដែរ ក្នុងការចូលរួមក្នុងកិច្ចចរចាពាណិជ្ជកម្មអន្តរជាតិ ។*

កិច្ចព្រមព្រៀង WTO មាត្រា ៣:១

ទីមួយ ត្រូវជួយសំរួលដល់ការអនុវត្តន៍ ការគ្រប់គ្រង និងប្រតិបត្តិការនៃឯកសារគតិយុត្ត នាកិច្ចប្រជុំចរចាឃ្លូរ៉ូហ្គាយ និងរាល់កិច្ចព្រមព្រៀងទាំងឡាយដែលបានចរចា និងបានអនុម័តក្នុងកិច្ចចរចានាពេលអនាគត ។

កិច្ចព្រមព្រៀង WTO មាត្រា ៣:២

ទីពីរ ត្រូវផ្តល់ជាវេទិកាសំរាប់ការចរចាបន្តទៀតទៅក្នុងចំណោមប្រទេសជាសមាជិកនូវបញ្ហាផ្សេងៗ ដែលមានចែងក្នុងកិច្ចព្រមព្រៀង និងអំពីបញ្ហាថ្មីនានាដែលស្ថិតក្នុងអំណាចរបស់ខ្លួន ព្រមទាំងអំពីការធ្វើសេរីភាវូបនីយកម្មផ្នែកពាណិជ្ជកម្មបន្ថែមទៀត ។

កិច្ចព្រមព្រៀង WTO មាត្រា ៣:៣ និង ៣:៤

ទីបី ត្រូវទទួលខុសត្រូវលើការសំរបសំរួលរាល់ការខ្វែងគំនិតគ្នា និងវិវាទនៅក្នុងចំណោមប្រទេសជាសមាជិក ។

ទីបួន ត្រូវទទួលខុសត្រូវលើការត្រួតពិនិត្យជាប្រចាំលើគោលនយោបាយពាណិជ្ជកម្ម របស់បណ្តាប្រទេសជាសមាជិក ។

រចនាសម្ព័ន្ធ

កិច្ចព្រមព្រៀង WTO មាត្រា ៤:១

អង្គភាពកំពូលរបស់អង្គការពាណិជ្ជកម្មពិភពលោកដែលទទួលខុសត្រូវក្នុងការសំរេចចិត្តចុងក្រោយ គឺសន្និសីទថ្នាក់រដ្ឋមន្ត្រីដែលធ្វើការជួបជុំគ្នារៀងរាល់ ពីរឆ្នាំម្តង ។ ចាប់ពីពេលដែលអង្គការពាណិជ្ជកម្ម ពិភពលោកបង្កើតឡើង គេបានប្រារព្ធធ្វើសិន្និសីទថ្នាក់រដ្ឋមន្ត្រីចំនួនពីរលើក គឺលើកទីមួយ នៅប្រទេសសាំងហ្គាពួរ នាខែធ្នូឆ្នាំ១៩៩៦ និងលើកទី២ធ្វើនៅទីក្រុងហ្សឺណែវ នាខែឧសភាឆ្នាំ ១៩៩៨ រីឯសិន្និសីទលើកទី៣ និងគ្រោងធ្វើនៅទីក្រុងសេអាតថល(សហរដ្ឋអាមេរិក) ពីថ្ងៃទី ៣០ ខែ វិច្ឆិកា ដល់ថ្ងៃទី៣ ខែធ្នូ ឆ្នាំ១៩៩៩ ។

កិច្ចព្រមព្រៀង WTO មាត្រា ៤.២

ក្នុងចន្លោះពេលពីរឆ្នាំនៃកិច្ចប្រជុំ អគ្គក្រុមប្រឹក្សាដើរតួនាទីជាអង្គភាពសំខាន់ក្នុងការអនុវត្តន៍មុខងាររបស់ខ្លួន ។

កិច្ចព្រមព្រៀង WTO មាត្រា ៤.១៣

អគ្គក្រុមប្រឹក្សាជួបប្រជុំក្នុងនាមជាអង្គភាពសំរបសំរួលវិវាទនៅពេលបានទទួលបណ្តឹងតវ៉ាមកពិនិត្យ ពិចារណា និងប្រកាន់យកវិធានការណ៍ដោះស្រាយវិវាទ រវាងប្រទេសជាសមាជិក ។ អគ្គក្រុមប្រឹក្សាទទួលខុសត្រូវផងដែរក្នុងការពិនិត្យមើលគោលនយោបាយពាណិជ្ជកម្មរបស់ប្រទេសនីមួយៗ ផ្អែកតាមរបាយការណ៍ដែលរៀបចំដោយលេខាធិការដ្ឋាន WTO ។

អគ្គក្រុមប្រឹក្សាទទួលបានជំនួយក្នុងការបំពេញការងារពី ÷

កិច្ចព្រមព្រៀង WTO មាត្រា ៤៥

- ☐ ក្រុមប្រឹក្សាពាណិជ្ជកម្មលើទំនិញ ដែលឃ្លាំមើលការអនុវត្តន៍ និងកិច្ចដំណើរការនៃកិច្ចព្រមព្រៀងGATT ឆ្នាំ ១៩៩៤ និងកិច្ចព្រមព្រៀងពាក់ព័ន្ធនានា ។
- ☐ ក្រុមប្រឹក្សាពាណិជ្ជកម្មលើសេវាកម្ម ដែលឃ្លាំមើលការអនុវត្តន៍ និងកិច្ចដំណើរការនៃកិច្ចព្រមព្រៀង GATS និង
- ☐ ក្រុមប្រឹក្សា TRIPS ដែលឃ្លាំមើលកិច្ចដំណើរការនៃកិច្ចព្រមព្រៀង TRIPS ។

ឧបសម្ព័ន្ធ ១ នៃជំពូកនេះមានបង្ហាញជូនពីរចនាសម្ព័ន្ធសរុបរបស់ WTO

រចនាសម្ព័ន្ធនេះ ក៏បានបង្ហាញជូនផងដែរពីគណៈកម្មការផ្សេងៗដែលបានបង្កើតដោយកិច្ចព្រមព្រៀង WTO ព្រមទាំងគណៈកម្មការផ្សេងទៀត ដែលបានបង្កើតសំរាប់បំពេញការងារលំអិតនៅក្រោកដំណើរការផ្សេងៗ និងកិច្ចព្រមព្រៀងពាក់ព័ន្ធផ្សេងៗ ។

កិច្ចដំណើរការធ្វើសេចក្តីសំរេចចិត្ត

កិច្ចព្រមព្រៀង WTO មាត្រា ៩:១

កិច្ចព្រមព្រៀងចែងថា អង្គការពាណិជ្ជកម្មពិភពលោក ត្រូវបន្តការងារពី GATT ក្នុងការធ្វើសេចក្តីសំរេចតាមលក្ខណៈប្រជាមតិ (Consensus) ។គេចាត់ទុកថាមានកុងសង់ស៊ុស នៅពេលដែលគេអនុម័តសេចក្តីសំរេចចិត្ត ហើយគ្មានប្រទេសណាមួយមានយោបល់ជំទាស់ ។

នៅពេលដែលពុំមានកុងសង់ស៊ុស កិច្ចព្រមព្រៀងរបស់អង្គការពាណិជ្ជកម្មពិភពលោក បានផ្តល់សិទ្ធអោយសំរេចតាមការបោះឆ្នោតយកតាមមតិភាគច្រើន ដែលក្នុងនោះប្រទេសមួយមានសិទ្ធិបោះឆ្នោតមួយសំលេង [៤] ។

ទោះបីជាបទប្បញ្ញត្តិនេះ មានន័យដូច្នេះក៏ដោយ តែការសំរេចចិត្តអំពីបញ្ហាគោលនយោបាយសំខាន់ៗ (ដូចជាការចាប់ផ្តើមកិច្ចចរចាលើវិស័យដែលពីមុនមកពុំមានចែងក្នុងកិច្ចព្រមព្រៀងរបស់អង្គការពាណិជ្ជកម្មពិភពលោក) ត្រូវបានគេរំពឹងថា នឹងបន្តសំរេចតាមកុងសង់ស៊ុស ។ វិធានស្តីពីកុងសង់ស៊ុសការពារនូវភាពផ្តាច់ការ អត្តនោម័តតាមមតិភាគច្រើនដែលមានមតិគ្របដណ្តប់ប្រឆាំងទៅលើសេចក្តីសំរេចនោះ ។

ទោះជាយ៉ាងណាក៏ដោយនៅក្នុងករណីមួយចំនួនទៀតតំរូវអោយមានការបោះឆ្នោតជាពិសេស ដូចមានចែងក្នុងវណ្ឌ៤ខាងក្រោម÷

> **ខណ្ឌ ៤**
>
> *តំរូវការនៃការបោះឆ្នោតពិសេស*
>
> *កិច្ចព្រមព្រៀងចែងពីការបោះឆ្នោតផ្សេងៗ គ្នាលើសេចក្តីសំរេចចិត្ត ក្នុងករណីដូចខាងក្រោម ÷*
>
> - ☐ ការបកស្រាយបទបញ្ញត្តិនានានៃកិច្ចព្រមព្រៀងណាមួយតំរូវអោយមានឆ្នោតគាំទ្រភាគច្រើនបីភាគបួន (កិច្ចព្រមព្រៀងអង្គការពាណិជ្ជកម្មពិភពលោកមាត្រាទី ៩.២)
> - ☐ *ការធ្វើវិសោធនកម្ម ដែលជាទូទៅតំរូវអោយមានឆ្នោតគាំទ្រភាគច្រើនពីរភាគបី ។ ទោះជាយ៉ាងណាក៏ដោយ ការធ្វើវិសោធនកម្មទៅលើ ÷*
>   - *បទបញ្ញត្តិនានានៃកិច្ចព្រមព្រៀង WTO ស្តីអំពីវិសោធនកម្ម និងការធ្វើសេចក្តីសំរេចចិត្ត និង*
>   - *បទបញ្ញត្តិ MFN នៅក្នុង GATT ឆ្នាំ១៩៩៤ ។ GATS និងកិច្ចព្រមព្រៀង TRIPS នឹងចូលជាធរមានតែនៅពេលដែលមានការទទួលយល់ព្រមពីគ្រប់ប្រទេសជាសមាជិកទាំងអស់ (កិច្ចព្រមព្រៀងWTO មាត្រា ៩.២)*
> - ☐ *សំណើសុំបដិសេធជាបណ្តោះអាសន្នដោយប្រទេសជាសមាជិកណាមួយចំពោះភាតព្វកិច្ច WTO ដែលទាមទារអោយមានសំលេងឆ្នោតគាំទ្រភាគច្រើន បីភាគបួន (កិច្ចព្រមព្រៀង WTO មាត្រា ៩.២)*

[៤] ខុសពី IMF និងអង្គការផ្សេងទៀត WTO មិនមានប្រព័ន្ធ Weighted Voting ដែលតាមប្រព័ន្ធនេះ ប្រទេសខ្លះមានសិទ្ធិបោះឆ្នោតច្រើនជាងប្រទេសផ្សេងទៀត

លេខាធិការដ្ឋាន WTO

កិច្ចព្រមព្រៀង WTO មាត្រា ៦:១

អង្គការពាណិជ្ជកម្មពិភពលោក មានទីតាំងនៅទីក្រុងហ្សឺណែវ ប្រទេសស្វីស ។ អង្គការនេះដឹកនាំ ដោយអគ្គលេខាធិការមួយរូប និងមានអគ្គនាយករងចំនួនបីរូបជាជំនួយការ ។ អគ្គនាយករងទាំងបីរូប ត្រូវបានជ្រើសតាំងដោយអគ្គនាយក ដោយមានការពិភាក្សាជាមួយបណ្តាប្រទេសជាសមាជិក ។

កិច្ចព្រមព្រៀង WTO មាត្រា ៦:៤

លេខាធិការដ្ឋានអង្គការពាណិជ្ជកម្មពិភពលោកមានមន្ត្រីសញ្ជាតិផ្សេងៗធ្វើការចំនួន៥០០នាក់ ។ ក្នុងពេលអនុវត្តមុខងាររបស់ខ្លួន អគ្គនាយក និងមន្ត្រីធ្វើការទាំងឡាយពុំមានសិទ្ធសួរយោបល់ ឬ ទទួលយកការណែនាំពីរដ្ឋាភិបាល ឬ អាជ្ញាធរក្រៅពីអង្គការពាណិជ្ជកម្មពិភពលោកណាមួយឡើយ ដែលនេះគឺជាតំលៃនៃចរិកអន្តរជាតិរបស់លេខាធិការដ្ឋាន ។

សមាជិកភាព

កិច្ចព្រមព្រៀងអង្គការពាណិជ្ជកម្មពិភពលោកមាត្រា ៩

ច្បាប់ចុងក្រោយ. §៥. កិច្ចព្រមព្រៀង WTO មាត្រា ១២ សេចក្តីសំរេចស្តីអំពីការទទួលយក និងការសុំចូលក្នុងកិច្ចព្រមព្រៀងបង្កើត WTO

អង្គការពាណិជ្ជកម្មពិភពលោកមានសមាជិកចំនួន១៣៤ គិតត្រឹមថ្ងៃទី ៣១ខែឧសភា ឆ្នាំ ១៩៩៩ ។ បណ្តាប្រទេសដែលបច្ចុប្បន្នមិនមែនជាសមាជិក អាចក្លាយជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោកបានដោយការចរចាសុំចូល។ ក្នុងការចរចាសុំចូលនេះ បណ្តាប្រទេសទាំងនោះ ត្រូវយល់ព្រមទទួលយកនូវវិធានការធ្វើច្បាប់ជាតិរបស់គេ អោយស្របជាមួយបទបញ្ញត្តិនៃកិច្ចព្រមព្រៀងពហុភាគីនានា ។ បន្ថែមលើនេះពួកគេ ត្រូវធ្វើការសន្យាបញ្ចុះពន្ធ និងកែប្រែបទប្បញ្ញត្តិច្បាប់របស់ពួកគេ ដើម្បីផ្តល់នូវការបើកច្រកទីផ្សារសំរាប់ទំនិញ និងសេវាកម្ម ។ ការសន្យាទាំងនេះតែងតែត្រូវបានគេចាត់ទុកថាជាតំលៃនៃ "ការទិញសំបុត្រចូល" ដែលនឹងផ្តល់សិទ្ធិស្របច្បាប់ដល់ប្រទេសសុំចូល នូវផលប្រយោជន៍ផ្អែកលើមូលដ្ឋាន MFN ពីការកាត់បន្ថយពន្ធទាំងអស់ និងការសន្យាដទៃទៀតដែលអនុវត្តដោយប្រទេសជាសមាជិកកន្លងមក ។ បច្ចុប្បន្ននេះ មានប្រទេសចំនួន ៣០ កំពុងតែចរចាសុំចូល។ ឧបសម្ព័ន្ធខាងក្រោមមានរាយនាមពីសមាជិកអង្គការ WTO និងប្រទេស/តំបន់ដែលកំពុងសុំចូល ។

អង្គការពាណិជ្ជកម្មពិភពលោកគឺជាវេទិកាសំរាប់ការចរចា

ការចរចាជាបន្ត

កិច្ចព្រមព្រៀង WTO មាត្រា ៣:២

អង្គការពាណិជ្ជកម្មពិភពលោក ផ្តល់នូវវេទិការសំរាប់ការចរចាបន្តអំពី ÷

- ☐ ការធ្វើសេរីភាវូបនីយកម្មពាណិជ្ជកម្មបន្ថែមទៀតលើវិស័យទំនិញ និងសេវាកម្ម និង
- ☐ ការកែលំអវិធានជាធរមាន ឬ អនុម័តវិធានសំរាប់វិស័យថ្មីទៀត។

របៀបវារៈសំរាប់ការចរចា (Built-in agenda)

បទបញ្ញត្តិសំរាប់ចាប់ផ្តើម និងការប្រព្រឹត្តិទៅនៃការចរចា ដើម្បីពិនិត្យឡើងវិញនូវបទបញ្ញត្តិទាំងអស់ ឬ មួយចំនួននៃកិច្ចព្រមព្រៀងជាក់លាក់ តែងតែមាននៅក្នុងកិច្ចព្រមព្រៀងខ្លួនឯងផ្ទាល់តែម្តង ។ បទប្បញ្ញត្តិទាំងនោះ ត្រូវបានគេទទួលស្គាល់ថាជារបៀបវារៈសំរាប់ធ្វើការចរចា ។

GATS មាត្រា ១៩:១ កិច្ចព្រមព្រៀង WTO មាត្រា ២០

អនុលោមតាមរបៀបវារៈនៃការចរចាកិច្ចព្រមព្រៀងទូទៅស្តីពីពាណិជ្ជកម្មលើសេវាកម្ម (GATS) ការធ្វើសេរីភាវូបនីយកម្មក្នុងវិស័យទូរគមនាគមន៍ និងហិរញ្ញវត្ថុត្រូវបានធ្វើឡើង ហើយបានបញ្ចប់បន្ទាប់ពីការបញ្ចប់ការចរចានៅឃ្យូរ៉ូហ្គាយ។ កិច្ចព្រមព្រៀងទូទៅស្តីអំពីពាណិជ្ជកម្មលើសេវាកម្ម ចែងបន្ថែមទៀតថា ការចរចាក្នុងការធ្វើសេរីភាវូបនីយកម្មពាណិជ្ជកម្មគ្របវិស័យ សេវាកម្មទាំងអស់ គួរត្រូវធ្វើឡើងចាប់ថ្ងៃទី១ ខែមករា ឆ្នាំ២០០០ ។ ក្នុងវិស័យពាណិជ្ជកម្មលើទំនិញ កិច្ចព្រមព្រៀងស្តីអំពីកសិកម្ម ចែងថា ការចរចាដើម្បីសំរេចបាននូវកំរិតខ្ពស់ជាងនៃការធ្វើសេរីភាវូបនីយកម្ម និងការកែលំអកម្មវិធីកែទំរង់កសិកម្មដែលបានអនុម័ត នៅក្នុងបទប្បញ្ញត្តិនៃកិច្ចព្រមព្រៀងរបស់ខ្លួន គួរចាប់ផ្តើមមុនបំណាច់ឆ្នាំ១៩៩៩ ។

ការពិនិត្យកិច្ចព្រមព្រៀងឡើងវិញ

ក្រៅពីបទបញ្ញត្តិស្តីពីការចាប់ផ្តើមចរចាតាមកាលបរិច្ឆេទកំណត់ជាក់លាក់ កិច្ចព្រមព្រៀងមួយចំនួន មានចែងអំពីការពិនិត្យឡើងវិញនូវបទបញ្ញត្តិទាំងអស់ ឬ មួយចំនួន ដោយផ្អែកលើបទពិសោធន៍ដែលទទួលបានពីការអនុវត្តន៍កិច្ចព្រមព្រៀងនោះ ថាតើការកែប្រែ ឬ ការកែលំអបទបញ្ញត្តិទាំងនេះ គឺជាការចាំបាច់ឬទេ ។ វណ្ឌ ៥ មានរៀបរាប់ពីកិច្ចព្រមព្រៀង ដែលស្ថិតនៅក្រោមការពិនិត្យឡើងវិញ ហើយពេលកំណត់នៃការត្រួតពិនិត្យឡើងវិញនោះ គឺនៅពេលខាងមុខយ៉ាងខ្លីនេះ ។

ការបន្ថែមប្រធានបទថ្មីលើកម្មវិធីការងាររបស់ WTO

សេចក្តីសំរេចក្នុងការបន្ថែមប្រធានបទថ្មីលើកម្មវិធីការងាររបស់ WTO ដើម្បីពិនិត្យមើល ថាតើការចរចាដែលបានធ្វើឡើងដើម្បីអនុមតិវិធាននៅក្នុងវិស័យទាំងនេះ ត្រូវបានគេអនុវត្តនៅសន្និសីទថ្នាក់រដ្ឋមន្ត្រីរៀងរាល់ ២ ឆ្នាំម្តងដែរឬទេ ។ វណ្ឌ៦ មានរៀបរាប់អំពីប្រធានបទដែលបានបន្ថែមលើកម្មវិធីការងាររបស់អង្គការ WTO ជាលទ្ធផលនៃសេចក្តីសំរេចនាសន្និសីទថ្នាក់រដ្ឋមន្ត្រីដែលបានប្រារព្ធធ្វើឡើងនៅ ម៉ារ៉ាកេស ឆ្នាំ ១៩៩៥ នៅសិង្ហបុរី ឆ្នាំ១៩៩៦ និងនៅទីក្រុងស៊ីណែវ ក្នុងឆ្នាំ១៩៩៨ ។ ការសិក្សាស្រាវជ្រាវ និងការវិភាគបញ្ហាពាក់ព័ន្ធនឹងរឿងពាណិជ្ជកម្មដែលកើតឡើងក្នុងវិស័យនីមួយៗនៃវិស័យទាំងនេះ ត្រូវបានគេអនុវត្តផ្អែកលើមូលដ្ឋាននៃការផ្តល់ឯកសារពាក់ព័ន្ធ ដែលបានរៀបចំដោយលេខាធិការដ្ឋាន និងឯកសារដាក់ជូនដោយគណៈប្រតិភូ និងដោយមិនទាក់ទងជាមួយផ្នែកនៃការសន្យាណាមួយនៃប្រទេសជាសមាជិកក្នុងការចូលរួមចរចាស្តីអំពីការបង្កើតវិធានទាំងនេះ (ប្រធានបទនេះត្រូវបានពិនិត្យលំអិតជាងនេះនៅផ្នែកទី៦) ។

ខណ្ឌ ៥

លិខិតុបករណ៍ច្បាប់របស់ WTO : កម្មវិធីនៃការត្រួតពិនិត្យបន្តនាពេលបច្ចុប្បន្ន និងពេលអនាគត

បច្ចុប្បន្ន កំពុងមានការត្រួតពិនិត្យកិច្ចព្រមព្រៀងស្តីអំពីវិធាន និងនីតិវិធីដែលគ្រប់គ្រងលើការដោះស្រាយវិវាទ ។

កិច្ចព្រមព្រៀងស្តីអំពីទិដ្ឋភាពពាណិជ្ជកម្មទាក់ទងនឹងច្បាប់កម្មសិទ្ធិបញ្ញា(TRIPS), មាត្រា២៧:៣(ខ)ស្តីអំពីការមិនរាប់បញ្ចូលរុក្ខជាតិ សត្វជាជាងរបស់មានជីវិតក្នុងទ្រង់ទ្រាយតូច (Miro-organism) ពីការធ្វើប្រកាសនីយប័ត្រតក្កកម្ម : ការត្រួតពិនិត្យកំពុងតែធ្វើបន្ត ។

កិច្ចព្រមព្រៀងស្តីអំពីទិដ្ឋភាពពាណិជ្ជកម្មទាក់ទងនឹងច្បាប់កម្មសិទ្ធិបញ្ញា ការត្រួតពិនិត្យពីរឆ្នាំម្តង លើកទីមួយ ដែលមានចែងនៅក្នុងមាត្រា ៧១:១ គ្រោងនឹងផ្តើមធ្វើនៅថ្ងៃទី១ ខែមករា ឆ្នាំ២០០០ ។ កិច្ចព្រមព្រៀងស្តីអំពីទិដ្ឋភាពពាណិជ្ជកម្មទាក់ទងនឹងវិធានការវិនិយោគ: ការត្រួតពិនិត្យ ដែលបានចែងក្នុងមាត្រា៩ ស្តីអំពីកិច្ចប្រតិបត្តិការនៃកិច្ចព្រមព្រៀង និងពិចារណាតើប្រការចែងស្តីអំពី "នយោបាយវិនិយោគ និងការប្រកួតប្រជែង" គួរបញ្ចូលក្នុងកិច្ចព្រមព្រៀងដែលគ្រោងផ្តើមធ្វើនៅថ្ងៃទី ១ខែមករា ឆ្នាំ២០០០ ឬទេ ។

ខណ្ឌ ៦

ប្រធានបទថ្មីបន្ថែមទៅលើកម្មវិធីការងាររបស់អង្គការ WTO កើតមកពីលទ្ធផលនៃសេចក្តីសំរេចនៅសន្និសីទថ្នាក់រដ្ឋមន្ត្រីរបស់អង្គការ WTO

- ☐ *ពាណិជ្ជកម្ម និងបរិស្ថាន*
- ☐ *ពាណិជ្ជកម្ម និងវិនិយោគ*
- ☐ *ពាណិជ្ជកម្ម និងគោលនយោបាយប្រកួតប្រជែង*
- ☐ *ការសំរបសំរួលពាណិជ្ជកម្ម*

- ☐ *តំលាភាពនៅក្នុងលទ្ធកម្មសាធារណៈរដ្ឋាភិបាល*
- ☐ *ពាណិជ្ជកម្មអេឡិចត្រូនិក*

អង្គការ WTO បច្ចុប្បន្នកំពុងបន្តការងារវិភាគរបស់ខ្លួន ដើម្បីកំណត់ថាតើគួរអនុម័តវិធានថ្មីដើម្បីដោះស្រាយទិដ្ឋភាពពាក់ព័ន្ធនឹងការធ្វើពាណិជ្ជកម្មចំពោះវិស័យថ្មីទាំងនេះដែរឬទេ ។

លទ្ធភាពនៃការចាប់ផ្តើមវគ្គចរចាពាណិជ្ជកម្មថ្មី

វិធានរបស់អង្គការ WTO រំពឹងគិតបន្ថែមទៀតថានៅក្នុងពេលសន្និសីទរបស់ពួកគេ រដ្ឋមន្ត្រីអាចសំរេចចាប់ផ្តើមវគ្គចរចាថ្មីលើប្រធានបទដ៏ទូលំទូលាយទាំងនេះ ។

នៅសន្និសីទនាក្រុងហ្សឺណែវឆ្នាំ១៩៩៨ រដ្ឋមន្ត្រីបានអំពាវនាវអោយអគ្គក្រុមប្រឹក្សា (General council) រៀបចំកម្មវិធីមួយសំរាប់ការងារបន្ថែម និងសំរាប់ការចរចាដោយពិចារណាទៅលើ ÷

- ☐ បញ្ហាដែលបានកើតឡើងក្នុងពេលអនុវត្តកិច្ចព្រមព្រៀង
- ☐ បទបញ្ញត្តិនៃរបៀបវារៈសំរាប់ចាប់ផ្តើមចរចាលើប្រធានបទជាក់លាក់ណាមួយ (Built-in agenda)
- ☐ និងប្រធានបទថ្មីដែលបច្ចុប្បន្នស្ថិតក្រោមការស្រាវជ្រាវ និងវិភាគនៅអង្គការ WTO ។

កម្មវិធីត្រូវបានគេរំពឹងថា នឹងផ្តោតអារម្មណ៍យ៉ាងពិសេសទៅលើបញ្ហាពាណិជ្ជកម្ម របស់បណ្តាប្រទេសកំពុងអភិវឌ្ឍន៍ និងជាពិសេសលើបញ្ហាដែលប្រទេសក្រីក្របានជួបប្រទះ និងបណ្តាប្រទេសសេដ្ឋកិច្ចតូចៗដែលបណ្តាលមកពីការកើនឡើងនូវការទទួលផលតិចតួចបំផុតរបស់ពួកគេពីពាណិជ្ជកម្មពិភពលោក ។

ក្នុងការបង្កើតកម្មវិធីការងារមួយ នោះក្រុមប្រឹក្សាត្រូវបានគេរំពឹងថា នឹងពិនិត្យមើលពីបំណងប្រាថ្នានៃការចាប់ផ្តើមវគ្គចរចាថ្មីនៃការចរចាពាណិជ្ជកម្ម នៅដើមឆ្នាំ ២០០០ ដែលបច្ចុប្បន្ននេះត្រូវបាន គេគិតថាជា " វគ្គនៃការចរចាសហស្សវត្សរ៍ " ដែលនឹងគ្របដណ្តប់ទៅលើប្រធានបទដ៏ទូលំទូលាយមួយ ។ សេចក្តីសំរេចចំពោះ បញ្ហាទាំងនេះសង្ឃឹមថា នឹងសំរេចបាននៅសន្និសីទថ្នាក់រដ្ឋមន្ត្រីលើកទី ៣ ដែលត្រូវប្រារព្ធធ្វើឡើងនៅខែ វិច្ឆិកា ឆ្នាំ ១៩៩៩ ។

ប្រព័ន្ធអង្គការ WTO ក្នុងការដោះស្រាយវិវាទ

ការដែលមានវិធានព្រមព្រៀងមួយ ដើម្បីអោយប្រព័ន្ធពាណិជ្ជកម្មពហុភាគីមួយដំណើរការបានត្រឹមត្រូវនោះ ជាកត្តាមិនគ្រប់គ្រាន់ឡើយ ។ វិធានទាំងនោះត្រូវបំពេញទៅដោយវិធានដ៏ទៃទៀត ដើម្បីផ្តល់សិទ្ធិឱ្យបណ្តាប្រទេសមួយចំនួនកែប្រែ នៅពេលមានការរំលោភកើតឡើង និងសំរាប់ដោះស្រាយចំពោះភាពខុសគ្នា និងវិវាទរបស់ពួកគេ ។ ការបង្កើតយន្តការដោះស្រាយវិវាទពហុភាគីមួយដ៏ខ្លាំងដែលលុបចោលនូវភាពខ្សោយរបស់ GATT ដែលមានពីមុននោះ គឺជាសមិទ្ធិផលដ៏សំខាន់មួយនៃកិច្ចចរចានៅអ៊ុយរ៉ុយហ្គាយ។

អង្គភាពដោះស្រាយវិវាទ

កិច្ចព្រមព្រៀងអង្គការ WTO មាត្រា៣:៣ និង ៤៣ កិច្ចព្រមព្រៀងស្តីអំពីវិធាន និងនីតិវិធីគ្រប់គ្រងការដោះស្រាយវិវាទ (DSU)

កិច្ចព្រមព្រៀងអង្គការ WTO មានចែងពីប្រព័ន្ធវិធាន និងនីតិវិធីមួយសំរាប់អនុវត្តចំពោះ វិវាទដែលកើតឡើងនៅក្រោមលិខិតុបករណ៍ច្បាប់ណាមួយរបស់ខ្លួន ។ ការទទួលខុសត្រូវសំខាន់ សំរាប់គ្រប់គ្រងវិធាន និងនីតិវិធីទាំងនេះស្ថិតនៅលើអគ្គក្រុមប្រឹក្សាដែលបានកត់សំគាល់ពីដំបូងថា មានតួនាទីជាអង្គភាពដោះស្រាយវិវាទ (DSB) ។

សារៈសំខាន់នៃការពិគ្រោះយោបល់ និងការផ្សះផ្សា

DSU, មាត្រា៤ គោលការណ៍សំខាន់មួយ ក្នុងចំណោមគោលការណ៍សំខាន់ៗដទៃទៀត ដែលនីតិវិធីទាំងនេះបានកំណត់ គឺថា រដ្ឋាភិបាលនៃប្រទេសជាសមាជិកគួរដាក់វិវាទជូនអង្គភាពដោះស្រាយវិវាទ ដើម្បីដោះស្រាយ បន្ទាប់ពីបរាជ័យក្នុងការប្រឹងប្រែងដោះស្រាយតាមរយៈការពិគ្រោះយោបល់ ។ នីតិវិធីបានចែងផងដែរថា ដើម្បីសំរេចបានដំណោះស្រាយមួយដែលអាចទទួលយកបានទាំងសង្ខាង ភាគីទាំងពីរ
DSU, មាត្រា៥ អាចធ្វើសំណើរទៅអគ្គលេខាធិការអង្គការ WTO រឺបុគ្គលដទៃទៀត ដើម្បីប្រើប្រាស់សមត្ថភាព និងកេរ្តិ៍ឈ្មោះរបស់គាត់ផ្សះផ្សា និងសំរុះសំរួលរវាងភាគីជំលោះ ។

នៅពេលដែលការពិគ្រោះយោបល់ រឺការប្រឹងប្រែងពិគ្រោះយោបល់ មិនសំរេចបានលទ្ធផលតាមបំណង នៅក្នុងអំឡុងពេល ៦០ ថ្ងៃ ភាគីប្តឹងអាចធ្វើសំណើរទៅអង្គភាពដោះស្រាយវិវាទជាផ្លូវការ ដើម្បីចាប់ផ្តើមយន្តការដោះស្រាយវិវាទ ដោយបង្កើតគណៈ
DSU, មាត្រា ៥:៤ វិនិច្ឆ័យពិនិត្យមើលពាក្យបណ្តឹង តែលុះត្រាតែមានការព្រមព្រៀងលើការបង្កើតដូចគ្នានោះ ។ ដើម្បីបង្កើនការដោះស្រាយជំលោះ
DSU, មាត្រា ៦:១ ឱ្យបានលឿន និងធានាបង្កើតគណៈវិនិច្ឆ័យដោយមិនបង្អែបង្អង់ដោយប្រទេសដែលបានទទួលពាក្យបណ្តឹង នីតិវិធីតំរូវឱ្យអង្គភាពដោះស្រាយវិវាទបង្កើតគណៈវិនិច្ឆ័យ នៅពេលដែលមានការស្នើឡើងដោយប្រទេសប្តឹង លើកលែងតែមានមតិរួមប្រឆាំងនឹងការបង្កើតគណៈវិនិច្ឆ័យនោះ ។

គណៈវិនិច្ឆ័យ

DSU, មាត្រា ៨ ជាធម្មតាគណៈវិនិច្ឆ័យ មានសមាជិកចំនួន ៣ រូប លើកលែងតែភាគីជំលោះយល់ព្រមថា គួរមានប្រាំរូប ។ ឈ្មោះបុគ្គលដែល
DSU, មាត្រា ៨:៥ ត្រូវតែងតាំងនៅក្នុងគណៈវិនិច្ឆ័យ គឺស្នើរឡើងដោយលេខាធិការដ្ឋានអង្គការពាណិជ្ជកម្មពិភពលោក លើបញ្ជីឈ្មោះដែលរក្សាទុកដោយអង្គការនេះរួមមានជំនាញការមកពីខាងរដ្ឋាភិបាល និងខាងអង្គការក្រៅរដ្ឋាភិបាល ។ បុគ្គលនៅក្នុងបញ្ជីឈ្មោះគឺជាមន្ត្រីជាន់ខ្ពស់មានសមត្ថភាពរបស់ប្រទេសជាសមាជិកសមាជិកគណៈប្រតិភូប្រចាំអង្គការ WTO មន្ត្រីជាន់ខ្ពស់ ដែលធ្លាប់បង្រៀនច្បាប់ និងគោលនយោបាយពាណិជ្ជកម្មអន្តរជាតិ ។

DSU, មាត្រា ១២:៨ សមាជិកភាពរបស់គណៈវិនិច្ឆ័យ ជាធម្មតាត្រូវជ្រើសរើសដោយមានការពិគ្រោះយោបល់ ជាមួយភាគីជំលោះ ។ គណៈវិនិច្ឆ័យ
DSU, មាត្រា ១១ ជាទូទៅតំរូវឱ្យដាក់របាយការណ៍ដែលរួមមានអនុសាសន៍របស់ពួកគេ និងការវាយតំលៃអង្គហេតុនៃរឿងក្តីដោយមិនលំអៀង ស្របនឹងវិធានការដែលបានប្តឹងអំពីអ្វីដែលពាក់ព័ន្ធនឹងបទបញ្ញត្តិនៃលិខិតុបករណ៍ច្បាប់ ជូនអង្គភាពដោះស្រាយវិវាទនៅក្នុងអំឡុងពេល ៦ ទៅ ៩ ខែ ។[៥]

អង្គភាពឧទ្ធរណ៍

DSU, មាត្រា១៧
ការបង្កើតអង្គភាពឧទ្ធរណ៍ ដែលមានលក្ខណៈដូចជាតុលាការឧទ្ធរណ៍ គឺជាការបន្ថែមថ្មីពីលើប្រព័ន្ធដោះស្រាយវិវាទ ។ អង្គភាពនេះរួមមានបុគ្គលិកចំនួន ៧ នាក់ និងជាអាជ្ញាធរដែលគេទទួលស្គាល់ថាមានជំនាញច្បាប់ពាណិជ្ជកម្មអន្តរជាតិ និងប្រធានបទផ្សេងទៀត
DSU, មាត្រា១៧:២ ដែលគ្របដណ្តប់ដោយកិច្ចព្រមព្រៀងនេះ ។ អង្គភាពនេះមិនមែនជាសាខារបស់រដ្ឋាភិបាលណាមួយឡើយ។ ក្នុងចំណោម ៧ នាក់ មានតែ៣នាក់ទេ ត្រូវបានកោះអញ្ជើញឱ្យបំរើក្នុងរឿងក្តីណាមួយនោះ ។ បណ្តឹងឧទ្ធរណ៍អាចធ្វើឡើងដោយភាគីជំលោះ
DSU, មាត្រា១៧:៥ ណាមួយក៏បាន ។ របាយការណ៍របស់អង្គភាពឧទ្ធរណ៍ និងត្រូវកំណត់ទៅលើតែអង្គច្បាប់ក្នុងរបាយការណ៍របស់គណៈវិនិច្ឆ័យ និងការបកស្រាយអំពីច្បាប់ ដែលបង្កើតដោយខ្លួនឯងផ្ទាល់ ហើយត្រូវដាក់ជូនអង្គភាពដោះស្រាយវិវាទក្នុងអំឡុងពេលពី ៦០ទៅ៩០ថ្ងៃ។

ការពិចារណាចំពោះរបាយការណ៍ដោយអង្គភាពដោះស្រាយវិវាទ

DSU, មាត្រា ២០ របាយការណ៍របស់គណៈវិនិច្ឆ័យ ឬ របស់អង្គការឧទ្ធរណ៍ ដែលភាគីណាមួយបានធ្វើឧទ្ធរណ៍ប្រឆាំងនឹងរបាយការណ៍របស់ គណៈវិនិច្ឆ័យ ត្រូវដាក់ជូនអង្គភាពដោះស្រាយវិវាទ ដើម្បីអនុម័ត និងផ្តល់អនុសាសន៍សមស្រប ព្រមទាំងធ្វើការសំរេច ។ ដើម្បីធានាបាននូវការ

[៥] នីតិវិធីទទួលស្គាល់ថា ភាគីទាំងអស់ ដែលយល់ព្រមគ្នាទៅវិញទៅមក ឯកភាពដាក់វិវាទទៅសាលាជំនុំជំរះក្តី ។ ប៉ុន្តែក្នុងករណីនេះ ពួកគេត្រូវបញ្ជាក់ថា ក្នុងករណីបែបនេះប្រាកដថាគឺជាកាតព្វកិច្ចរបស់ភាគីទាំងអស់ ហើយត្រូវធ្វើរបាយការណ៍ជូនទៅអង្គភាពដោះស្រាយវិវាទ។

ដោះស្រាយវិវាទអោយបានឆាប់ គេត្រូវកំណត់ថារយៈពេល "ចាប់គិតពីកាលបរិច្ឆេទនៃការបង្កើតគណៈវិនិច្ឆ័យដោយអង្គភាពដោះស្រាយវិវាទ និងកាលបរិច្ឆេទ "ដែលអង្គភាពដោះស្រាយវិវាទពិចារណារបាយការណ៍របស់គណៈវិនិច្ឆ័យ និងរបាយការណ៍ឧទ្ធរណ៍" មិនត្រូវឱ្យលើសពីរយៈពេល ៩ខែ ពេលដែលរបាយការណ៍របស់គណៈវិនិច្ឆ័យមិនត្រូវបានគេឧទ្ធរណ៍ និង១២ ខែ ពេលដែលរបាយការណ៍ នោះមានគេឧទ្ធរណ៍ ។

ការអនុវត្តន៍របាយការណ៍

DSU, មាត្រា ២១

អនុលោមទៅតាមនីតិវិធី របាយការណ៍របស់គណៈវិនិច្ឆ័យ ត្រូវបានអនុវត្តដោយភាគីក្នុងរបៀបបីយ៉ាង ដូចរៀបរាប់ខាងក្រោម÷

☐ បញ្ហាដែលបានកើតឡើងក្នុងពេលអនុវត្តកិច្ចព្រមព្រៀង

DSU, មាត្រា ២១:១ ***ការប្រព្រឹត្តិស្របច្បាប់***

DSU, មាត្រា ២០ ទី១, នីតិវិធីបញ្ជាក់ថាភាគីដែលរំលោភកាតព្វកិច្ច ត្រូវអនុវត្តអោយស្របទៅនឹងអនុសាសន៍របស់គណៈវិនិច្ឆ័យ ឬ អង្គភាពឧទ្ធរណ៍យ៉ាងឆាប់រហ័ស។ ប្រសិនបើភាគីមិនមានលទ្ធភាពអនុវត្តជាបន្ទាន់ទេ អង្គភាពដោះស្រាយវិវាទអាចស្នើសុំផ្តល់រយៈពេល

DSU, មាត្រា ២១:៣ សមស្របមួយសំរាប់អោយភាគីនោះអនុវត្ត ។

DSU, មាត្រា ២២ ***បទបញ្ញត្តិស្តីពីសំណង***

ទី២, ក្នុងករណីដែលភាគីរំលោភមិនអនុវត្តនៅក្នុងអំឡុងពេលសមស្រប ភាគីដែលបានប្រើនីតិវិធីនៃការដោះស្រាយវិវាទអាចស្នើសុំសំណងទូទាត់ ។ ជាជំរើស ភាគីរំលោភកាតព្វកិច្ចអាចដាក់សំណើផ្តល់សំណងទូទាត់នោះ ដោយខ្លួនឯងបាន ។

ការអនុញ្ញាតិចំពោះសកម្មភាពវាយបក

ទី៣, ពេលភាគីរំលោភខកខានមិនបានអនុវត្ត និង ផ្តល់សំណងគ្រប់គ្រាន់ ភាគីរងគ្រោះ អាចស្នើរឱ្យអង្គភាពដោះស្រាយវិវាទ

DSU, មាត្រា២២:២-៩ អនុញ្ញាតិអោយខ្លួនធ្វើសកម្មភាពវាយបកដោយផ្អាកការផ្តល់សម្បទាន ឬ ផ្អាកកាតព្វកិច្ចក្រោមកិច្ចព្រមព្រៀងទូទៅស្តីអំពីពន្ធគយ និងពាណិជ្ជកម្ម (GATT) ឬនៅក្រោមកិច្ចព្រមព្រៀងមួយនៃកិច្ចព្រមព្រៀងពាក់ព័ន្ធទាំងឡាយរបស់ខ្លួន ហើយអង្គភាព (DSU,) ដោះស្រាយវិវាទអាចអនុញ្ញាតិអោយភាគីរងគ្រោះ តំឡើងពន្ធលើផលិតផលដែលខ្លួននាំចូលពីភាគីរំលោភ ហើយការធ្វើពាណិជ្ជកម្មលើផលិតផលទាំងនោះគួរតែប្រហាក់ប្រហែលស្មើនឹងអ្វីដែលទទួលរងនូវផលប៉ះពាល់ដោយវិធានការដែលបានប្តឹងតវ៉ាចំពោះ ។

DSU, មាត្រា ២២:៣ វិធានចែងថា អង្គភាពដោះស្រាយវិវាទអាចអនុញ្ញាតិអោយមានសកម្មភាពវាយបក ដែលកន្លងមកធ្វើទៅលើវិស័យដូចគ្នានៃ GATT គឺកិច្ចព្រមព្រៀងទូទៅស្តីអំពីពាណិជ្ជកម្មលើសេវាកម្ម (GATS) ដែលគណៈវិនិច្ឆ័យបានរកឃើញថាមានការរំលោភ ។ ប៉ុន្តែអង្គភាពដោះស្រាយវិវាទ ពិចារណាថា ធ្វើដូច្នេះវាមិនអាចទៅរួច ខ្លួនអាចអនុញ្ញាតិឱ្យមានការវាយបកលើវិស័យឯទៀត នៃកិច្ចព្រមព្រៀងដូចគ្នា ។ គ្រាន់តែក្នុងករណីខ្លះ និង ជាវិធីចុងក្រោយដែលអង្គភាពដោះស្រាយ វិវាទអាចអនុញ្ញាតិឱ្យធ្វើការវាយបកឆ្លងកាត់កិច្ចព្រមព្រៀងនានា មានន័យថា ការវាយពន្ធខ្ពស់ ចំពោះទំនិញសំរាប់ការរំលោភកាតព្វកិច្ច ដែលមានចែងក្នុង GATS រឺនៅក្រោមកិច្ចព្រមព្រៀង TRIPS ។

DSU, មាត្រា ២ ក៏ប៉ុន្តែ ការផ្តល់សំណងនិងការអនុញ្ញាតិអោយប្រើវិធានការវាយបក ដោយអង្គភាពដោះស្រាយវិវាទ គឺជាវិធានការបណ្តោះអាសន្ន។ ដំណោះស្រាយចុងក្រោយចំពោះប្រទេសរំលោភកាតព្វកិច្ច គឺត្រូវអនុវត្តអនុសាសន៍ ។ វិធានតំរូវឱ្យអង្គភាពដោះស្រាយវិវាទរក្សាទុករឿងក្តី ទាំងនោះនៅក្រោមការត្រួតពិនិត្យ ដើម្បីធានាដល់ការអនុវត្តន៍យ៉ាងពេញលេញរបស់ពួកគេ ។

តើជាក់ស្តែងយន្តការដោះស្រាយវិវាទប្រព្រឹត្តិទៅយ៉ាងដូចម្តេច

ឯកអគ្គរដ្ឋទូតមកពីប្រទេសមួយដែលដាក់រឿងក្តីជូនទៅអង្គភាពដោះស្រាយវិវាទ បានពន្យល់ក្នុងការឆ្លើយតបនឹងសំនួរអ្នកកាសែតថា តើរដ្ឋាភិបាលរបស់គាត់សំរេចដាក់បញ្ហានេះជូនអង្គភាព WTO ដូចម្តេច ?

ឧស្សាហកម្មគីមីបាននាំមកនូវបញ្ហាជាច្រើនដល់យើង ហើយសូមផ្តល់ពត៌មានអោយយើងបានដឹង ស្តីអំពីនីតិវិធីនៃការចេញអាជ្ញាបណ្ណ័នាំចូល របស់ប្រទេសនាំចូល ។ យើងបានស្នើឱ្យតំណាងពាណិជ្ជកម្មរបស់យើងពិនិត្យមើលអង្គហេតុ ហើយស្វែងរកពត៌មានពិស្តារអំពីបទបញ្ញត្តិទាំងនោះ។ ពេលយើងទទួលបានពត៌មានគ្រប់គ្រាន់ ដែលផ្តល់ឱ្យដោយឧស្សាហកម្មដែលត្រូវប៉ះពាល់នោះ និងរបាយការណ៍ទទួលបានពីតំណាងពាណិជ្ជកម្ម ដែលថាមានការរំលោភលើវិធានដោយការនាំចូល យើងបានសំរេចចិត្តប្រើនីតិវិធីដោះស្រាយវិវាទ ដោយស្នើឱ្យប្រទេសនាំចូលធ្វើការពិគ្រោះយោបល់ទ្វេភាគី។ ពេលយើងរកឃើញថា ការពិគ្រោះយោបល់ទ្វេភាគី មិនអាចដោះស្រាយបាន យើងបានសំរេចស្នើឱ្យអង្គភាពដោះស្រាយវិវាទតែងតាំងគណៈវិនិច្ឆ័យ ។

វិវាទភាគច្រើនដែលដាក់ជូន WTO គឺជាលទ្ធផលនៃពត៌មានដែលផ្តល់ដោយឧស្សាហកម្ម ឬ សមាគមជូនរដ្ឋាភិបាល របស់ពួកគេចំពោះការលំបាក ដែលពួកគេកំពុងជួបប្រទះក្នុងការរកទីផ្សារបរទេស ។ រដ្ឋាភិបាលប្រើនីតិវិធីដោះស្រាយវិវាទ ពេលដែលខ្លួនយល់ព្រមជាមួយការវាយតំលៃរបស់ឧស្សាហកម្ម ដែលប្រទេសត្រូវជួបការលំបាកពេលមានការរំលោភវិធានរបស់ WTO ។

ជំហានទីមួយ ដែលរដ្ឋាភិបាលត្រូវប្រកាន់យក ពេលខ្លួនសំរេចប្រើនីតិវិធីដោះស្រាយវិវាទ គឺត្រូវចូលរួមពិគ្រោះយោបល់ទ្វេភាគីជាមួយប្រទេសដែលចាត់ទុកថាបានរំលោភកាតព្វកិច្ចរបស់ខ្លួន ។ ក្នុងករណីដែលការប្រឹងប្រែងទ្វេភាគី ដើម្បីដោះស្រាយវិវាទអោយទទួលលទ្ធផលតាមការពេញចិត្តរបស់ភាគីទាំងសងខាង មិនអាចប្រព្រឹត្តទៅបាន នោះប្រទេសប្តឹងអាចស្នើ WTO ឱ្យតែងតាំងគណៈវិនិច្ឆ័យមួយ ដើម្បីពិនិត្យទាំងអង្គហេតុ និងអង្គច្បាប់នៃរឿងក្តីនោះ ។

ជាសំខាន់ត្រូវកត់សំគាល់ថា បញ្ហាមួយចំនួនធំដែលបណ្តារដ្ឋាភិបាលនានាលើកមកដោះស្រាយតាមនីតិវិធីដោះស្រាយវិវាទ ត្រូវបានដោះស្រាយរួចដោយការពិគ្រោះយោបល់ ។ ការពិគ្រោះយោបល់មិនអាចសំរេចបានតែលើរឿងក្តីមួយចំនួនតូចប៉ុណ្ណោះ គឺនៅពេលដែលប្រទេសដែលត្រូវគេប្តឹងមិនយល់ស្របនឹងទស្សនៈរបស់ប្រទេសប្តឹងថា គេបានរំលោភវិធាន ក្នុងករណីនេះហើយដែលគេត្រូវដាក់រឿងក្តីនោះទៅ WTO ដើម្បីអោយគណៈវិនិច្ឆ័យដោះស្រាយ ។

ទោះជាយ៉ាងណាក៏ដោយ អ្នកចូលរួមនៅក្នុងដំណើរការទាំងមូលនៃការដោះស្រាយវិវាទ-ការពិគ្រោះយោបល់ ការពិនិត្យមើលដោយគណៈវិនិច្ឆ័យ ហើយក្រោយមកដោយអង្គភាពឧទ្ធរណ៍-គឺជាតំណាងរដ្ឋាភិបាល ពួកគេមានជំនឿយ៉ាងខ្លាំងចំពោះការផ្តល់យោបល់ និងការគាំទ្រជាបន្តពីឧស្សាហកម្ម និងសមាគម ដែលមានផលប្រយោជន៍ក្នុងប្រធានបទនៃវិវាទនោះ ។ សមត្ថភាពរដ្ឋាភិបាលក្នុងការការពាររឿងក្តីរបស់ខ្លួន ឬ ការពារផលប្រយោជន៍ឧស្សាហកម្មក្នុងរឿងក្តី អាស្រ័យយ៉ាងខ្លាំងលើជំនួយ និងការគាំទ្រដែលផ្តល់ឱ្យដោយក្រុមឧស្សាហកម្មពាក់ព័ន្ធ ។

ទាក់ទងនឹងអង្គហេតុនៃរឿងក្តី តំណាងរដ្ឋាភិបាលត្រូវពឹងពាក់លើពត៌មានដែលផ្តល់អោយដោយឧស្សាហកម្ម ។ បន្ថែមលើនេះ តំណាងរដ្ឋាភិបាលនឹងចូលរួមក្នុងការងាររបស់គណៈវិនិច្ឆ័យ ឬ អង្គភាពឧទ្ធរណ៍តែងតែទទួលបាននូវយោបល់លើអង្គច្បាប់ ដែលមានផលប្រយោជន៍ផ្តល់អោយពីក្រោយដោយឧស្សាហកម្ម ។

សេចក្តីសង្ខេបនៃដំណោះស្រាយវិវាទនាពេលថ្មីៗ នេះចំនួនពីរ មានចែងនៅក្នុងវណ្ឌ ៧ បង្ហាញពីប្រភេទរឿងក្តីដែលដាក់ជូន WTO សំរាប់ដោះស្រាយ ។

ខណ្ឌ ៧

សេចក្តីសង្ខេបពីអង្គហេតុ និងអង្គច្បាប់ក្នុងរឿងក្តីទាំងពីរ ដែលបានដោះស្រាយតាមនីតិវិធីដោះស្រាយវិវាទ WTO

សហរដ្ឋអាមេរិក - វិធានការដែលប៉ះពាល់លើការនាំចូលអាវស្រីធ្វើពីខ្សែន ប្តឹងដោយប្រទេសឥណ្ឌា (WTDS 33)

វិធាន WTO

កិច្ចព្រមព្រៀងស្តីអំពីវាយនភ័ណ្ឌ និងសំលៀកបំពាក់ (ATC) តំរូវឱ្យបណ្តាប្រទេសដែលមានការដាក់កំហិតដោយរើសអើងលើការនាំចូលវាយនភ័ណ្ឌ និងសំលៀកបំពាក់ដកចេញការដាក់កំហិតទាំងនោះ ជាបណ្តើរៗ ក្នុងរយៈពេល ១០ឆ្នាំ ដោយបញ្ចប់នៅថ្ងៃ ទី ១ ខែ មករា ឆ្នាំ ២០០៥ ។ ទោះបីជាកិច្ចព្រមព្រៀងនេះមានគោលបំណងសំរបសំរួលដកចេញនូវការដាក់កំហិតទាំងនោះក៏ដោយ ក៏កិច្ចព្រមព្រៀងអនុញ្ញាតិឱ្យប្រទេសនាំចូលអនុវត្ត "វិធានការការពារបណ្តោះអាសន្ន " ដើម្បីដាក់កំហិតលើការនាំចូល នៅពេលដែលការនាំចូលផលិតផលវាយនភ័ណ្ឌ ប្រភេទជាក់លាក់មួយចំនួនធ្វើអោយប៉ះពាល់ ឬបណ្តាលអោយមានការ "ខូចខាតដ៏ធ្ងន់ធ្ងរ ឬគំរាមកំហែងពិត " ដល់ឧស្សាហកម្មក្នុងស្រុក ដែលផលិតផលិតផលដូចគ្នា។ មាត្រា ៦ នៃកិច្ចព្រមព្រៀងកំណត់នូវកត្តាសេដ្ឋកិច្ច (ឧទាហរណ៍ការប្រែប្រួលទិន្នផល ផលិតភាព ការប្រើប្រាស់សមត្ថភាពសារពើភ័ន្ឋ ចំណែកទីផ្សារ ការនាំចេញ ប្រាក់ឈ្នួល អាជីព តំលៃក្នុងស្រុក ប្រាក់ចំណូល និងការវិនិយោគ) ដែលត្រូវយកមកពិចារណា ដើម្បីកំណត់ថាតើការនាំចូលដែលកើនឡើងនេះ បង្កអោយមានការគ្រោះថ្នាក់ឬទេ ។ មាត្រានេះបានចែងបន្ថែមទៀតថា មិនគួរដាក់វិធានការការពារនេះទេ ប្រសិនបើការខូចខាតធ្ងន់ធ្ងរ ឬការគំរាមកំហែងជាក់ស្តែងបណ្តាលមកពី "កត្តាដទៃទៀត ដូចជាការប្រែប្រួលបច្ចេកវិទ្យា ឬ ការប្រែប្រួលចំណូលចិត្តរបស់អ្នកប្រើប្រាស់" ។

មូលហេតុនៃរឿងក្តី

សហរដ្ឋអាមេរិកបានដាក់វិធានការការពារបណ្តោះអាសន្ន ដែលដាក់កំហិតលើការនាំចូលអាវស្រីធ្វើពីខ្សែនពីប្រទេសឥណ្ឌានៅថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ១៩៩៥ ។ មុនពេលដាក់វិធានការនេះ សហរដ្ឋអាមេរិក និងឥណ្ឌា បានធ្វើការពិគ្រោះយោបល់លើបណ្តឹងតវ៉ា កន្លងមកថាការ នាំចូលអាវស្រីធ្វើពីខ្សែន បណ្តាលឱ្យមានការខូចខាតយ៉ាងធ្ងន់ធ្ងរ ចំពោះឧស្សាហកម្មក្នុងស្រុករបស់សហរដ្ឋអាមេរិក ។ ដោយពិគ្រោះយោបល់មិនបានលទ្ធផលពេញចិត្ត ឥណ្ឌា បានយករឿងក្តីនេះដាក់ទៅ WTO ដើម្បីដោះស្រាយ ។

លទ្ធផលរបស់គណៈវិនិច្ឆ័យ

បន្ទាប់ពីពិនិត្យអង្គហេតុហើយ គណៈវិនិច្ឆ័យបានរកឃើញថា ដើម្បីកំណត់ថា ការនាំចូលដែលកើនឡើងនោះ បណ្តាលឱ្យមានគ្រោះថ្នាក់ដល់ឧស្សាហកម្មរបស់ខ្លួន ឬ អត់ សហរដ្ឋអាមេរិកត្រូវពិនិត្យមើលបំរែបំរួលសេដ្ឋកិច្ចអោយបានគ្រប់ជ្រុងជ្រោយ ដូចដែលបានរាយនៅក្នុងមាត្រា ៦ នៃកិច្ចព្រមព្រៀងស្តីអំពីវាយនភ័ណ្ឌ ដែលតំរូវអោយបណ្តាប្រទេសធ្វើការពិចារណាក្នុងការកំណត់ទំនាក់ទំនងរវាងគ្រោះថ្នាក់ឧស្សាហកម្មក្នុងស្រុក និងការនាំចូលដែលកើនឡើងនោះ ។ សហរដ្ឋអាមេរិកមិនបានពិនិត្យ ដូចដែលតំរូវដោយមាត្រានោះ ថាតើការខូចខាតចំពោះឧស្សាហកម្ម មិនមែនមកពីការប្រែប្រួលចំណូលចិត្តរបស់អ្នកប្រើប្រាស់ ឬ ក៏ការប្រែប្រួលបច្ចេកវិទ្យាឡើយ ។ ដូច្នេះគណៈវិនិច្ឆ័យបានសន្និដ្ឋានថា ការដាក់វិធានការការពាររបស់សហរដ្ឋអាមេរិក គឺជាការរំលោភកាតព្វកិច្ចរបស់ខ្លួនតាមកិច្ចព្រមព្រៀងស្តីអំពីវាយនភ័ណ្ឌនិងសំលៀកបំពាក់ ។ សហរដ្ឋអាមេរិកបានអនុវត្តសេចក្តីសំរេចរបស់គណៈវិនិច្ឆ័យ ដោយដកចេញវិញនូវវិធានការការពារបណ្តោះអាសន្ននោះ។

ជប៉ុន - ការយកពន្ធលើភេសជ្ជៈស្រា ប្តឹងដោយសហគមន៍អឺរ៉ុប (WT/DS8), កាណាដា (WT/DS10), និងសហរដ្ឋអាមេរិក (WT/DS11)

វិធាន WTO

អនុលោមតាមគោលការណ៍ប្រព្រឹត្តិកម្មជាតិរបស់ GATT ១៩៩៤ ចែងថា មិនត្រូវយកពន្ធក្នុងស្រុក និងការយកតំលៃឯទៀតទេ ដើម្បីអោយឧស្សាហកម្មក្នុងស្រុកទទួលបាននូវកិច្ចការពារខ្ពស់ជាងអ្វីដែលកំណត់ដោយអត្រាពន្ធគយ ។ ការវាយពន្ធ និងយកតំលៃឯទៀតលើផលិតផលនាំចូល បន្ទាប់ពីផលិតផលនោះបានចូលមកដល់ទីផ្សារនាំចូល ដោយបានបង់ពន្ធរួចហើយ តាមអត្រាដែលខ្ពស់ជាងអត្រាដែលវាយលើផលិតក្នុងស្រុកដូចគ្នា គឺជាការរំលោភគោលការណ៍នេះ។ មាត្រា ៣. ២ នៃ GATT ១៩៩៤ ចែងថា ផលិតផលនាំចូលមិនគួរជាប់ពន្ធក្នុងស្រុក ឬតំលៃឯទៀតដែល "លើសអត្រាដែលអនុវត្តដោយផ្ទាល់ ឬមិនផ្ទាល់ចំពោះផលិតផលក្នុងស្រុកដូចគ្នា" ។

អង្គហេតុនៃរឿងក្តី

ជំលោះបានកើតឡើងពីច្បាប់ស្តីពីសារពើពន្ធលើស្រារបស់ជប៉ុន ដែលបានវាយពន្ធលើភេសជ្ជៈស្រានាំចូល ដូចជា វ៉ូតកា រ៉ាំមយើន (ស្រាស) និងវីស្គី កូញ៉ាក់ (ស្រាពណ៌ត្នោត) ដែលអាត្រាពន្ធនេះ ខ្ពស់ជាងអាត្រាពន្ធ ដែលដាក់លើផលិតផលស្រាស៊ូឈូ ដែលផលិតក្នុងស្រុក ។ សហរដ្ឋអាមេរិក កាណាដា និងសហគមន៍អ៊ឺរ៉ុប បានពិចារណាថា ច្បាប់នោះមានលក្ខណៈរំលោភនឹងបទបញ្ញត្តិរបស់ GATT មាត្រា ៣.២ ហើយបានធ្វើការពិគ្រោះយោបល់ទ្វេភាគីរៀងៗខ្លួនជាមួយជប៉ុន។ ការចរចាពិគ្រោះយោបល់មិនអាចដំណើរការទៅបាននាំឱ្យមានការបង្កើតគណៈវិនិច្ឆ័យ ។

លទ្ធផលរបស់គណៈវិនិច្ឆ័យ និងអង្គភាពឧទ្ធរណ៍

គណៈវិនិច្ឆ័យបានកំណត់ថា ស្រាស ដូចជាវ៉ូតកា និងពណ៌ត្នោត ដូចជាវីស្គី ដែលបាននាំចូល និងស្រាស៊ូឈូដែលផលិតក្នុងប្រទេសជប៉ុន ជា "ផលិតផលដូចគ្នា " ដោយពិចារណាទៅលើលក្ខណៈកាយវប្បកម្ម និងការប្រើប្រាស់ចុងបញ្ចប់ ។ គណៈវិនិច្ឆ័យ បានសំរេចផងដែរថា ភាពខ្លាំងនៃភេសជ្ជៈស្រា មិនបានច្រានចោលនូវការរកឃើញអំពីភាពដូចគ្នា ព្រោះភេសជ្ជៈស្រា គឺតែងតែធ្វើឱ្យស្រវឹងនៅក្នុងទំរង់រាវ ហើយ វ៉ូតកា និងស៊ូឈូត្រូវ បានចាត់បញ្ចូលក្នុងតារាងពន្ធគយរបស់ជប៉ុនក្នុងប្រភេទលេខកូដដូចគ្នា ។

ដោយស្រាស និងស្រាពណ៌ត្នោតនាំចូល និងស្រាស៊ូឈូ ផលិតក្នុងស្រុក ជាផលិតផលដូចគ្នា ការវាយពន្ធតាមមាត្រាមួយខ្ពស់ជាងការវាយពន្ធលើផលិតក្នុងស្រុក ក្រោមច្បាប់ស្តីពីសារពើពន្ធស្រា ជាការរំលោភលើកាតព្វកិច្ចជប៉ុនក្រោមឃ្លាទី១ នៃ GATT មាត្រា ៣.២ ។

គណៈវិនិច្ឆ័យ បានរកឃើញផងដែរថា ក្នុងលក្ខខណ្ឌនៃបទបញ្ញត្តិ មាត្រា ៣ ផលិតផលនាំចូល ពាក់ព័ន្ធ (វ៉ូតកា រ៉ាំមយើន កូញ៉ាក់ វីស្គី និង លីកឺរ) គឺមានលក្ខណៈ "ប្រកួតប្រជែងដោយផ្ទាល់ និងអាចជំនួសគ្នាបាន"សំរាប់ស្រាស៊ូឈូ ។ មកដល់ត្រឹមការរកឃើញនេះ គណៈវិនិច្ឆ័យ បានពឹងផ្អែកលើការសិក្សាស្រាវជ្រាវ ផ្តល់អោយដោយប្រទេសប្តឹងដែលបានបង្ហាញថា ភាពប្រែប្រួលនៃតំលៃ គឺមានកំរិតខ្ពស់រវាងស្រាស៊ូឈូ និងស្រាពណ៌ត្នោត ចំនួន ៥ ប្រភេទ និងស្រាសចំនួន ៣ប្រភេទ ។ គណៈវិនិច្ឆ័យបានរកឃើញផងដែរថា នៅក្រោមច្បាប់ស្តីពីសារពើពន្ធស្រារបស់ជប៉ុន ផលិតផលនាំចូលដែលប្រកួតប្រជែងដោយផ្ទាល់ និងមានលក្ខណៈអាចជំនួសគ្នាបាន (ស្រាស និងស្រាពណ៌ត្នោត) និងផលិតផលក្នុងស្រុក (ស្រាស៊ូឈូ) មិនបានត្រូវគេ "វាយពន្ធប្រហាក់ប្រហែលគ្នាទេ " ហើយការវាយពន្ធមានភាពលំអៀង លើផលិតផលក្នុងស្រុកដែលផ្តល់ការការពារបន្ថែមចំពោះផលិតផលទាំងនោះ ។

ដូច្នេះ គណៈវិនិច្ឆ័យសំរេចថា ប្រទេសជប៉ុន បានរំលោភផងដែរលើកាតព្វកិច្ចរបស់ខ្លួន នៅក្រោមឃ្លាទី២ នៃមាត្រា ៣.២ ដោយរក្សាប្រពន្ធ័បែបនេះ ។ ជប៉ុនធ្វើឧទ្ធរណ៍ ប្រឆាំងនឹងការសំរេចរបស់គណៈវិនិច្ឆ័យ ។ អង្គភាពឧទ្ធរណ៍បានព្រមចំពោះលទ្ធផលសំខាន់ៗ របស់គណៈវិនិច្ឆ័យ ដែលបានរៀបរាប់ខាងលើ ។ រដ្ឋាភិបាលជប៉ុនបានអនុវត្តលទ្ធផល និងសេចក្តីសំរេចរបស់អង្គភាពឧទ្ធរណ៍ ដោយធ្វើការកែប្រែច្បាប់ពាក់ព័ន្ធនោះ ។

យន្តការត្រួតពិនិត្យគោលនយោបាយពាណិជ្ជកម្ម (TPRM)

កិច្ចព្រមព្រៀង WTO
មាត្រា ៣

TPRM , A

ក្រៅពីការផ្តល់យន្តការសំរាប់ដោះស្រាយវិវាទ WTO ដើរតួជាវេទិកាសំរាប់ពិនិត្យមើលជាប្រចាំ លើគោលនយោបាយពាណិជ្ជកម្មរបស់ប្រទេសជាសមាជិក ។ ការត្រួតពិនិត្យនេះមានគោលបំណងពីរយ៉ាង ។ ទី១ សំដៅស្វែងរកឱ្យឃើញថា តើប្រទេសជាសមាជិកកំពុងអនុវត្តតាមវិន័យ និងយោបល់ដែលបានលើកឡើងក្រោមបណ្តាកិច្ចព្រមព្រៀងពហុភាគី បានយ៉ាងណា (និងប្រសិនបើអាចអនុវត្តគឺតាមក្រោមកិច្ចព្រមព្រៀងពហុភាគីដោយឡែកមួយចំនួនទៀត) ។ ដោយប្រកាន់ខ្ជាប់នូវការពិនិត្យមើលជាប្រចាំនោះ WTO ដើរតួជាអ្នកឃ្លាំមើល ដើម្បីធានាថាប្រទេសជាសមាជិកទាំងអស់ បានអនុវត្តវិធានរបស់ខ្លួនយ៉ាងខ្ជាប់ខ្ជួន ដែលរួមចំណែកការពារនូវការ

TPRM, B

ផ្នែកបាក់ផ្នែកពាណិជ្ជកម្ម ។ ក៏ប៉ុន្តែបទបញ្ញត្តិស្តីពីការបង្កើតយន្តការត្រួតពិនិត្យនេះ បានបញ្ជាក់ថា WTO មិនមានគោលបំណងប្រើប្រាស់យន្តការនេះជាមូលដ្ឋានសំរាប់បង្ខំឱ្យប្រតិបត្តិកាតព្វកិច្ច ហើយយន្តការនោះមិនត្រូវបានគេប្រើសំរាប់ដោះស្រាយវិវាទដែរ ។ គោលបំណងទី ២ នៃការត្រួតពិនិត្យនេះមានសារៈសំខាន់ដូចគ្នាដែរ គឺដើម្បីផ្តល់នូវតំលាភាព និងការយល់ដឹងអោយកាន់តែច្បាស់ពីគោលនយោបាយពាណិជ្ជកម្ម និងការអនុវត្តន៍ជាក់ស្តែងរបស់ប្រទេសជាសមាជិក ។

ការត្រួតពិនិត្យតាមពេលកំណត់

TPRM, C:ii

ការត្រួតពិនិត្យអនុវត្តឡើងអោយបានញឹកញាប់ ឬ យ៉ាងណានោះ គឺអាស្រ័យលើចំណែកនៃប្រទេសជាសមាជិក នៅក្នុងពាណិជ្ជកម្មពិភពលោក ។ ប្រទេសធំជាងគេចំនួន ៤ ត្រូវបានគេត្រួតពិនិត្យរៀងរាល់ ២ ឆ្នាំ ម្តង" នៅបច្ចុប្បន្ននេះ គឺសមាគមន៍អឺរ៉ុប (រាប់ជាប្រទេសតែមួយ) សហរដ្ឋអាមេរិក ជប៉ុន និងកាណាដា ។ ប្រទេសធំបន្ទាប់ចំនួន ១៦ ត្រូវបានគេត្រួតពិនិត្យរៀងរាល់ ៤ ឆ្នាំម្តង និងប្រទេសជាសមាជិកផ្សេងទៀតគឺ ៦ ឆ្នាំម្តង លើកលែងប្រទេសក្រីក្រ ដែលរយៈពេលត្រួតពិនិត្យមានយូរជាងនេះ។

TPRM, C:v

មូលដ្ឋានសំរាប់ត្រួតពិនិត្យត្រូវបានកំណត់ដោយ ÷

- ☐ របាយការណ៍ពេញលេញ រៀបចំដោយប្រទេសជាសមាជិកណាដែលគោលនយោបាយពាណិជ្ជកម្មរបស់គេ ស្ថិតនៅក្រោមការត្រួតពិនិត្យ និង
- ☐ របាយការណ៍រៀបចំដោយលេខាធិការដ្ឋាន ឈរលើការទទួលខុសត្រូវរបស់ខ្លួន ដោយពិចារណា ទៅលើពត៌មានផ្តល់ឱ្យដោយសមាជិក និងពត៌មានដទៃទៀត រួមទាំងពត៌មានដែលបានទទួលក្នុងពេលទស្សនៈកិច្ចចំពោះប្រទេសពាក់ពន្ធ័នោះផង ។

TPRM ,C:i

TPRM, C:vi

ការត្រួតពិនិត្យត្រូវធ្វើឡើងដោយអគ្គក្រុមប្រឹក្សា ដែលដើរតួជាអង្គភាពត្រួតពិនិត្យគោលនយោបាយពាណិជ្ជកម្ម សំរាប់គោលបំណងនៃការត្រួតពិនិត្យនេះ ។ របាយការណ៍របស់ប្រទេស និងរបាយការណ៍ រៀបចំដោយលេខាធិការដ្ឋានទាំងអស់ជាមួយនឹងកំណត់ហេតុចំពោះការពិភាក្សាត្រូវបោះពុម្ពផ្សាយយ៉ាងឆាប់បន្ទាប់ពីត្រួតពិនិត្យហើយ ។

ការពិគ្រោះយោបល់ពាក់ព័ន្ធនឹង WTO

យន្តការសំរាប់ពិគ្រោះយោបល់រវាងរដ្ឋាភិបាល ជាមួយវិស័យឯកជន

រដ្ឋាភិបាល មិនអាចធ្វើសកម្មភាពតែម្នាក់ឯងទេ ។ នៅក្នុងប្រទេសជឿនលឿនស្ទើរតែទាំងអស់ និងប្រទេសកំពុងអភិវឌ្ឍន៍ជាច្រើនគេបង្កើតយន្តការជាស្ថាប័នផ្លូវការ សំរាប់ធ្វើការពិគ្រោះយោបល់ជាមួយឧស្សាហកម្ម និងសមាគមរបស់ពួកគេ សភាពាណិជ្ជកម្មនិងសមាគមពាណិជ្ជកម្មដទៃទៀត ស្តីអំពីបញ្ហាពិភាក្សា នៅ WTO ។ ក្នុងការពិគ្រោះយោបល់ទាំងនេះ រដ្ឋាភិបាលស្វែងរកនូវទស្សនៈរបស់សហគមពាណិជ្ជកម្មស្តីអំពី ÷

- ☐ កំហិតជិតលើគោលនយោបាយ ដែលរដ្ឋាភិបាលគួរអនុម័ត លើបញ្ហាជាក់លាក់ក្នុងការចរចា
- ☐ ជំហរដែលរដ្ឋាភិបាល គួរប្រកាន់យកលើសំណើរដែលបានស្នើឡើងដើម្បីដាក់បញ្ចូលប្រធានបទថ្មីក្នុងរបៀបវារៈសំរាប់ការចរចា ។

យន្តការផ្តល់ផងដែរនូវកាលានុវត្តន៍ភាពសំរាប់អោយឧស្សាហកម្ម និងពាណិជ្ជកម្ម លើកឡើងនូវបញ្ហាណាដែលពួកគេអាចជួបប្រទះនៅក្នុងទីផ្សារនាំចេញរបស់ពួកគេ ដោយសារការអនុវត្តវិធានការរបស់រដ្ឋាភិបាលនៃប្រទេសនាំចូល ។ នៅក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍន៏ដែលគ្មានយន្តការសំរាប់ពិគ្រោះយោបល់ នោះជាការចាំបាច់គួរតែបង្កើតយន្តការនេះឡើង។

ក្នុងបណ្តាប្រទេសដែលមានយន្តការនេះ ហើយចាំបាច់គួរតែកែលំអយន្តការនេះឡើង ដើម្បីធានាថាផលប្រយោជន៏ពាណិជ្ជកម្មផ្សេងៗត្រូវបានលើកឡើងយ៉ាងគ្រប់គ្រាន់ និងអាចប្រាប់ទៅរដ្ឋាភិបាលរបស់ពួកគេឱ្យដឹងអំពីបញ្ហាដែលគេជួបប្រទះនៅបរទេស ។

ឥទ្ធិពលរបស់សមាគមឧស្សាហកម្ម

ក្រៅពីការចូលរួមក្នុងការពិគ្រោះយោបល់ ដែលរៀបចំដោយរដ្ឋាភិបាល សហគ្រាសឧស្សាហកម្ម និងពាណិជ្ជកម្មក្នុងប្រទេសជឿនលឿន ត្រូវធ្វើអោយរដ្ឋាភិបាលបានដឹងពីការព្រួយបារម្ភ និងទស្សនៈរបស់គេលើប្រធានបទនៃការចរចានៅ WTO តាមរយៈការរៀបចំការពិភាក្សាដោយមានការឧបត្ថម្ភរបស់សភាពាណិជ្ជកម្ម រឺ សហពន្ធ័ឧស្សាហកម្ម ។ ជាងនេះទៀត បណ្តាក្រុមដាក់សម្ពាធត្រូវប្រឹងប្រែងធ្វើយ៉ាងណាអោយរដ្ឋាភិបាលពិចារណាអោយបានគ្រប់គ្រាន់ទៅផលប្រយោជន៏តាមផ្នែករបស់គេ នៅពេលពិភាក្សាពីបញ្ហាជាក់លាក់ណាមួយនៅកំរិតអន្តរជាតិ ។ របាយការណ៏ស្តីអំពីការពិភាក្សានេះត្រូវបោះពុម្ពផ្សាយយ៉ាងទូលំទូលាយ ដើម្បីជះឥទ្ធិពលដល់សាធារណៈជនឱ្យគាំទ្រទស្សនៈរបស់ក្រុមគេ ។ គេប្រើប្រាស់របាយការណ៏នេះផងដែរ ដើម្បីបញ្ចុះបញ្ចូលសមាជិកអង្គនីតិបញ្ញត្តិជាតិ ដើម្បីធានាអោយរដ្ឋាភិបាលចុងក្រោយអនុម័តលើកំហិតជិតគោលនយោបាយលើការចរចានៅ WTO ដែលឆ្លុះបញ្ចាំងអោយបានគ្រប់គ្រាន់អំពីទស្សនៈ និងការបារម្ភរបស់ពួកគេ ។

ឧទាហរណ៏ ការងារជាមូលដ្ឋានលើប្រធានបទមួយចំនួន ក្នុងរបៀបវារៈសំរាប់ការចរចានៅ Uruguay Round បានអនុវត្តដោយសមាគមឧស្សាហកម្ម និងពាណិជ្ជកម្ម ។ ការសិក្សាស្រាវជ្រាវលំអិតដែលរៀបចំដោយសហពន្ធ័ឧស្សាហកម្មជាតិ និងអន្តរជាតិស្តីអំពីផលប៉ះពាល់លើពាណិជ្ជកម្ម ក្នុងទំនិញក្លែងបន្លំ គឺដើម្បីដាក់ឥទ្ធិពលអោយរដ្ឋាភិបាលរបស់ប្រទេសជឿនលឿន បញ្ចូលចំណុចទាំងនេះទៅក្នុងរបៀបវារៈ ដែលជាចុងក្រោយនាំឱ្យកើតមានកិច្ចព្រមព្រៀង TRIPS ។ ម្យ៉ាងវិញទៀត ដើមកំណើតនៃកិច្ចព្រមព្រៀង TRIMS កើតឡើងដោយសារការសិក្សាស្រាវជ្រាវរៀបចំឡើងដោយអង្គការឧស្សាហកម្ម និងវិទ្យាស្ថានស្រាវជ្រាវដទៃទៀត ស្តីអំពីផលប៉ះពាល់មិនល្អដល់ពាណិជ្ជកម្ម ក្នុងការតំរូវអោយប្រើប្រាស់វត្ថុធាតុដើមក្នុងស្រុក និងតំរូវការអនុវត្ត ការនាំចេញដែលដាក់ទៅលើវិនិយោគីនបរទេស ។ សំណើរមួយចំនួនស្តីពីការកែលំអរវិធាន នៅក្នុងកិច្ចព្រមព្រៀងស្តីអំពីការប្រឆាំងនឹងការលក់បង្ខូចថ្លៃ (Anti-Dumping) មានប្រភពចេញមកពីការព្រួយបារម្ភរបស់សមាគមឧស្សាហកម្ម តាមរយៈការជូនដំណឹងទៅរដ្ឋាភិបាលរបស់ពួកគេ ។

កិច្ចព្រមព្រៀងស្តីពីបច្ចេកវិទ្យាពត៏មាន (ITA) ដែលអនុមត័នៅសន្និសីទថ្នាក់រដ្ឋមន្ត្រីនៅប្រទេសសិង្ហបូរី នៅ ខែធ្នូ ឆ្នាំ ១៩៩៦ គឺជាលទ្ធផលនៃការដាក់សម្ពាធរបស់ឧស្សាហកម្មនាំចេញលើរដ្ឋាភិបាលរបស់គេ ។ តាមពិតប្រធានបទថ្មីភាគច្រើនក្នុងកម្មវិធីការងារ WTO ដូចជាការសំរួលពាណិជ្ជកម្ម និងពាណិជ្ជកម្មអេឡិត្រូនិកបានស្នើឡើងដោយរដ្ឋាភិបាលផ្អែកលើមូលដ្ឋាន នៃអនុសាសន៏ធ្វើឡើងដោយឧស្សាហកម្ម សមាគមជំនួញ និងក្រុមមានផលប្រយោជន៏ដទៃទៀត ដែលត្រូវការអោយមានការអភិវឌ្ឍវិធានថ្មីក្នុងវិស័យទាំងនេះ ។

ផលប្រយោជន៏ប្រកាន់យកដោយសមាគមឧស្សាហកម្មមិនបញ្ឈប់នូវការស្នើសុំអោយបញ្ចូលនូវបណ្តាប្រធានបទទាំងនេះ នៅក្នុងការចរចាទេ ។

ក្នុងករណីជាច្រើន សមាគមទាំងនោះតាមដានការចរចាយ៉ាងយកចិត្តទុកដាក់ និងធ្វើឱ្យរដ្ឋាភិបាល ដឹងអំពីទស្សនៈរបស់ពួកគេថាសំណើរសំរាប់វិធានថ្មីនោះ មិនផ្តល់ផលប្រយោជន៏ដល់ពួកគេ។ ឧទាហរណ៏នៅ Uruguay Round លទ្ធផលចុងក្រោយនៃការចរចាស្តីអំពីវាយនភណ្ឌត្រូវរងឥទ្ធិពលយ៉ាងសម្បើមពីសម្ពាធបញ្ចុះបញ្ចូលរបស់ក្រុមវាយនភណ្ឌទៅលើរដ្ឋាភិបាល នៃបណ្តាប្រទេសជឿនលឿនដែលនាំចូល ។ គេដឹងយ៉ាងច្បាស់ថា ការចរចានៅ Uruguay Round បានប្រព្រឹត្តិទៅដោយមានការផ្អាកចំនួន ២ ឆ្នាំ ពីព្រោះមានការដាក់សម្ពាធលើរដ្ឋាភិបាលនៃប្រទេសមួយចំនួន ដោយក្រុមបញ្ចុះបញ្ចូលផ្នែកកសិកម្ម ដែលបានពិចារណាថាពួកគេនឹងទទួលរងនូវផលប៉ះពាល់មិនល្អ ពីសំណើធ្វើសេរីភាវូនីយកម្ម ដែលស្ថិតក្រោមការពិភាក្សានោះ ។

ដូច្នេះ សមាគមឧស្សាហកម្ម និងពាណិជ្ជកម្ម ត្រូវបន្តតាមដានការងាររបស់ WTO ស្តីពីការអនុវត្តន៏វិធាននៃកិច្ចព្រមព្រៀងផ្សេងៗ និងការងារនៅកំរិតវិភាគដែលនឹងធ្វើចំពោះប្រធានបទថ្មី ។

ដើម្បីផ្តល់លទ្ធភាពអោយសមាគមឧស្សាហកម្ម និងពាណិជ្ជកម្ម និងអង្គការក្រៅរដ្ឋាភិបាលមានលទ្ធភាពទទួលបាននូវផលប្រយោជន៏យ៉ាងសកម្មក្នុងការងាររបស់ WTO បាន អគ្គលេខាធិការដ្ឋានបានចាត់វិធានការមួយចំនួន ដើម្បីធ្វើអោយការងាររបស់គេកាន់តែមានតំលាភាពឡើង ។ ឯកសារការងារដែលរៀបចំឡើងដោយអគ្គលេខាធិការដ្ឋាន និងរបាយការណ៏ស្តីពីសម័យប្រជុំ ដែលកន្លងមក

ចាត់ទុកជាឯកសារសំងាត់ ហើយមានតែរដ្ឋាភិបាលប៉ុណ្ណោះដែលអាចពិនិត្យបាន បច្ចុប្បន្នលែងជាឯកសារសំងាត់ទៀតហើយ ក្រោយរយៈពេល ៦ ខែ ដែលឯកសារនេះបានចេញផ្សាយ ។ ជាងនេះទៅទៀត ក្នុងប្រធានបទថ្មីមួយចំនួន ដូចជាពាណិជ្ជកម្ម និងបរិស្ថាន អគ្គលេខាធិការដ្ឋានបានរៀបចំអោយមានសម័យប្រជុំរាយការណ៍ត្រួសៗ អោយអង្គការក្រៅរដ្ឋាភិបាល និងអង្គការផ្នែកឯកជនផ្សេងទៀតបានដឹងស្តីពីការអភិវឌ្ឍន៍នៅក្នុងការពិភាក្សានៅ WTO ។ ក៏ប៉ុន្តែ ក្នុងប្រទេសកំពុងអភិវឌ្ឍន៍មួយចំនួន សភាពាណិជ្ជកម្ម និងសមាគមពាណិជ្ជកម្មកន្លងមក មិនបានបង្ហាញអោយឃើញពីការចាប់អារម្មណ៍អោយបានខ្លាំងក្លា នៅក្នុងការពិភាក្សាជាមួយអង្គការអន្តរជាតិ ដូចជា WTO នេះទេ ។

នេះមួយផ្នែក ដោយសារកត្តាថា រហូតមកដល់ប៉ុន្មានឆ្នាំមុននេះ ប្រទេសទាំងនោះមួយចំនួន អនុវត្តគោលនយោបាយផ្តល់ឧបត្ថម្ភធនលើការនាំចូល ។ បន្ទាប់មក គេបានផ្តោតអារម្មណ៍ជាសំខាន់ ទៅលើបញ្ហាគោលនយោបាយក្នុងស្រុក ។ ដោយមានការផ្លាស់ប្តូរគោលនយោបាយ ជំរុញកំណើននាំចេញ សមាគមទាំងនេះ បានយកចិត្តទុកដាក់កាន់តែខ្លាំងឡើងៗពីតំរូវការរបស់សមាជិកគេ ក្នុងការស្វែងយល់ពីប្រព័ន្ធច្បាប់របស់អង្គការ WTO និងតំរូវការរបស់ពួកគេផ្ទាល់ ក្នុងការចាប់អារម្មណ៍អោយបានខ្លាំង ទៅលើការងារបច្ចុប្បន្នរបស់ WTO ។ សមាជិកភាគច្រើនទាមទារជំនួយការ ដើម្បីកែលំអការយល់ដឹងរបស់គេពីខ្លឹមសារនៃប្រព័ន្ធ WTO និងវិធានតាមនីតិវិធី ។ អង្គការអន្តរជាតិអាចជួយដល់សមាគមទាំងនេះបាន ដោយរក្សាផលប្រយោជន៍របស់សមាជិករបស់គេតាមរយៈ ÷

- ☐ សិក្ខាសាលាទូទៅស្តីអំពីប្រព័ន្ធច្បាប់របស់អង្គការ WTO និង
- ☐ សិក្ខាសាលាស្តីពីវិធានក្នុងវិស័យជាក់លាក់ ដូចជាស្តង់ដារចាំបាច់ និងវិធានអនាម័យ និងភូតគាមអនាម័យ វិធានការវាយតំលៃពន្ធគយ ឧបត្ថម្ភធន វិធានការប៉ះប៉ូវ និងវិធានការប្រឆាំងនឹងការលក់បង្ខូចថ្លៃ និងកម្មសិទ្ធិបញ្ញា ។

ការប្រើប្រាស់ប្រកបដោយប្រសិទ្ធិភាពនៃពត៌មានគតិយុត្ត និងពាណិជ្ជកម្មដែលមាននៅក្នុង WTO

អត្ថប្រយោជន៍មួយក្នុងចំណោមអត្ថប្រយោជន៍ដែលមានការផ្សព្វផ្សាយតិចតួច ជូនទៅរូបវន្តបុគ្គលនៃប្រព័ន្ធ WTO បណ្តាលមកពីការកើនឡើងនូវពត៌មានយ៉ាងច្រើនរបស់អគ្គលេខាធិការដ្ឋាន WTO ស្តីពីលិខិតបទដ្ឋាន និងវិធានជាតិក្នុងវិស័យពាណិជ្ជកម្មអន្តរជាតិ ។ កិច្ចព្រមព្រៀងភាគច្រើនរបស់ WTO ទាមទារអោយប្រទេសជាសមាជិកទាំងឡាយជូនដំណឹងទៅអគ្គលេខាធិការដ្ឋាន WTO ស្តីពីច្បាប់វិធាន និងបទបញ្ជារបស់ជាតិក្នុងវិស័យដែលគ្របដណ្តប់ដោយបណ្តាច្បាប់ទាំងនោះ ។

ក្រៅពីនេះ ពត៌មានដ៏មានតំលៃស្តីពីផលិតផល មាននៅក្នុងរបាយការណ៍របស់ប្រទេស ដែលបានរៀបចំឡើងតាមយន្តការត្រួតពិនិត្យគោលនយោបាយពាណិជ្ជកម្ម ។ ពត៌មាននេះមានសារៈប្រយោជន៍សំរាប់សហគ្រាសនាំចេញ ឬ សំរាប់ពិចារណាលើការនាំចេញផលិតផលណាមួយ ។ តាមការសិក្សា របាយការណ៍ស្តីពីការពិភាក្សាជាមួយប្រទេសណាមួយអាចធ្វើអោយអ្នកនាំចេញទទួលបាននូវពត៌មានពីតារាងពន្ធគយ ស្តង់ដារចាំបាច់ និងលិខិតបទដ្ឋានផ្សេងៗទៀត ដែលអនុវត្តទៅលើផលិតផលជាក់លាក់ ឬ ក្រុមផលិតផលនៅក្នុងទីផ្សារគោលដៅរបស់គេ ។ ទោះបីជារបាយការណ៍ទាំងនេះមានបោះពុម្ពផ្សាយក៏ដោយ ក៏ពត៌មានទាំងនេះកំរមានលើកឡើងនៅក្នុងព្រឹត្តិបត្រ័ពាណិជ្ជកម្មជាតិរបស់បណ្តាប្រទេសកំពុងអភិវឌ្ឍន៍ណាស់ ។

Web site របស់អង្គការ WTO បច្ចុប្បន្នសំបូរទៅដោយពត៌មានដ៏មានតំលៃស្តីពីទិដ្ឋភាពគ្រប់ផ្នែកនៃប្រព័ន្ធ WTO ។

សង្ខេប

ដើម្បីប្រមូលសរុប លទ្ធភាពរបស់រូបវន្តបុគ្គល ក្នុងការទាញយកអត្ថប្រយោជន៍ពីប្រព័ន្ធស្ថាប័នដែលបានកែលំអ ដោយសារ Uruguay Round នោះ អាស្រ័យជាសំខាន់ទៅលើ ÷

- ☐ ចំណេះដឹងរបស់គេលើវិធានពាណិជ្ជកម្ម និងលើសិទ្ធិដែលគេមាន ក៏ដូចជាកាតព្វកិច្ចដែលគេកំណត់ដែរ ។
- ☐ ចំណេះដឹងរបស់គេពីកាលានុវត្តន៍ភាពពាណិជ្ជកម្មថ្មី កើតឡើងពីការសន្យាធ្វើសេរីភាវូបនីយកម្ម ដែលអនុវត្តឡើងដោយបណ្តាប្រទេសនានាក្នុងពេលចរចា ។

- ☐ ការផ្ដួចផ្ដើមគំនិតក្នុងការជូនដំណឹងទៅរដ្ឋាភិបាលពីបញ្ហារបស់គេ ក្នុងការលក់ផលិតផលទៅកាន់ទីផ្សារអន្តរជាតិ ដើម្បីអោយរដ្ឋាភិបាលរបស់គេអាចលើកបញ្ហានេះឡើងនៅក្នុងវេទិកាសមស្របណាមួយរបស់ WTO និងប្រសិនបើចាំបាច់ ត្រូវប្រើប្រាស់វិធានការដោះស្រាយវិវាទរបស់ WTO ។

ជំពូក ២ ដល់ជំពូក ២០ នៃមគ្គុទេសក៍នេះ នឹងពន្យល់ពីវិធានរបស់ប្រព័ន្ធ ដែលបានបង្កើតកន្លងមក ព្រមទាំងបញ្ហាប្រឈមដែលសហគ្រាសពាណិជ្ជកម្មត្រូវជួបប្រទះទាំងក្នុងទីផ្សារអន្តរជាតិ និងទីផ្សារក្នុងស្រុក ដោយសារតែលទ្ធផលនៃសេរីភាវូបនីយកម្មពាណិជ្ជកម្ម ។

ឧបសម្ព័ន្ធ ១

រចនាសម្ព័ន្ធ WTO

សមាជិក WTO ទាំងអស់អាចចូលរួមក្នុងក្រុមប្រឹក្សា គណៈកម្មការនានាទាំងអស់ ។ល។ លើកលែងតែអង្គភាពឧទ្ធរណ៍ គណៈវិនិច្ឆ័យ សំរាប់ការដោះស្រាយវិវាទ អង្គភាពត្រួតពិនិត្យវាយនភណ្ឌ និង គណៈកម្មាធិការពហុភាគីដោយឡែក។



ខែ វិច្ឆិកា ឆ្នាំ១៩៩៧ ប្រភព :WTO

ឧបសម្ព័ន្ធ ២

សមាជិកភាព WTO

(គិតត្រឹមថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ១៩៩៩ ជាមួយកាលបរិច្ឆេទរបស់សមាជិកភាព WTO)

រដ្ឋាភិបាល	ចូលជាធរមានជាសមាជិកភាព
Antigua and Barbuda	1/01/1995
Angola	1/12/1996
Argentina	1/01/1995
Australia	1/01/1995
Austria	1/01/1995
Bahrain	1/01/1995
Bangladesh	1/01/1995
Barbados	1/01/1995
Belgium	1/01/1995
Belize	1/01/1995
Benin	22/02/1996
Bolivia	13/09/1995
Botswana	31/05/1995
Brazil	1/01/1995
Brunei Darussalam	1/01/1995
Bulgaria	1/12/1996
Burkina Faso	3/06/1995
Burundi	23/07/1995
Cameroon	13/12/1995
Canada	1/01/1995
Central African Republic	31/05/1995
Chad	19/10/1996
Chile	1/01/1995
Colombia	30/04/1995
Congo	27/03/1997
Costa Rica	1/01/1995
Cote d'Ivoire	1/01/1995
Cuba	20/04/1995
Cyprus	30/07/1995
Czech Republic	1/01/1995
Democratic Republic of the Congo	1/01/1997
Denmark	1/01/1995
Djibouti	31/05/1995
Dominica	1/01/1995
Dominican Republic	9/03/1995
Ecuador	21/01/1996
Egypt	30/06/1995
El Salvador	7/05/1995
European Communities	1/01/1995
Fiji	14/01/1996
Finland	1/01/1995
France	1/01/1995
Gabon	1/01/1995
Gambia	23/10/1996
Germany	1/01/1995
Ghana	1/01/1995
Greece	1/01/1995
Grenada	22/02/1996
Guatemala	21/07/1995
Guinea Bissau	31/05/1995
Guinea	25/10/1995
Guyana	1/01/1995
Haiti	30/01/1996
Honduras	1/01/1995
Hong Kong, China	1/01/1995
Hungary	1/01/1995
Iceland	1/01/1995
India	1/01/1995
Indonesia	1/01/1995
Ireland	1/01/1995
Israel	21/04/1995
Italy	1/01/1995
Jamaica	9/03/1995
Japan	1/01/1995
Kenya	1/01/1995
Korea	1/01/1995
Kuwait	1/01/1995
Kyrgyzstan	20/12/1998
Latvia	10/02/1999
Lesotho	31/05/1995
Liechtenstein	1/09/1995
Luxembourg	1/01/1995
Macau	1/01/1995
Madagascar	17/11/1995
Malawi	31/05/1995
Malaysia	1/01/1995
Maldives	31/05/1995
Mali	31/05/1995
Malta	1/01/1995
Mauritania	31/05/1995
Mauritius	1/01/1995
Mexico	1/01/1995
Mongolia	29/01/1997
Morocco	1/01/1995
Mozambique	26/08/1995
Myanmar	1/01/1995
Namibia	1/01/1995
Netherlands- For theKingdom in Europe and for the Netherlands Antilles	1/01/1995

រដ្ឋាភិបាល	ចូលជាធរមានជាសមាជិកភាព
New Zealand	1/01/1995
Nicaragua	3/09/1995
Niger	13/12/1996
Nigeria	1/01/1995
Norway	1/01/1995
Pakistan	1/01/1995
Panama	6/09/1997
Papua New Guinea	9/06/1996
Paraguay	1/01/1995
Peru	1/01/1995
Philippines	1/01/1995
Poland	1/07/1995
Portugal	1/01/1995
Qatar	13/01/1996
Romania	1/01/1995
Rwanda	22/05/1996
Saint Kitts and Nevis	21/02/1996
Saint Lucia	1/01/1995
Saint Vincent & theGrenadines	1/01/1995
Senegal	1/01/1995
Sierra Leone	23/07/1995
Singapore	1/01/1995
Slovak Republic	1/01/1995

រដ្ឋាភិបាល	ចូលជាធរមានជាសមាជិកភាព
Slovenia	30/07/1995
Solomon Islands	26/07/1996
South Africa	1/01/1995
Spain	1/01/1995
Sri Lanka	1/01/1995
Suriname	1/01/1995
Swaziland	1/01/1995
Sweden	1/01/1995
Switzerland	1/07/1995
Tanzania, United Rep.of	1/01/1995
Thailand	1/1/01995
Togo	31/05/1995
Trinidad and Tobago	1/03/1995
Tunisia	29/03/1995
Turkey	26/03/1995
Uganda	1/01/1995
United Arab Emirates	10/04/1996
United Kingdom	1/01/1995
United States	1/01/1995
Uruguay	1/01/1995
Venezuela	1/01/1995
Zambia	1/01/1995
Zimbabwe	3/03/1995

រដ្ឋាភិបាលសង្កេតការណ៍

Albania
Algeria
Andorra
Armenia
Azerbaijan
Belarus
Bhutan
Cambodia
Cape Verde
ChinaCroatia
Estonia*
Ethiopia
Former Yugoslav Republic of Macedonia
Georgia
Holy See (Vatican) Jordan
Kazakhstan
Lao People's Democratic Republic
Lebanon
Lithuania
Moldova
Nepal
Oman
Russian Federation
Samoa
Saudi Arabia
Seychelles
Sudan
Taiwan Province (China)
Tonga
Ukraine
Uzbekistan
Vanuatu
Vietnam

កំណត់ចំណាំ

ប្រទេសសង្កេតការណ៍ទាំងអស់បានដាក់ពាក្យសុំចូលរួម WTO លើកលែងតែ ហូលីសី (វ៉ាទីកង់) និងឥឡូវនេះប្រទេសអេត្យូពី ការីដេ ប៊ូតាន និងប្រទេសយេម៉ែន ។ ការសុំចូលរបស់អេត្យូនីសំរាប់សមាជិកភាពបានយល់ព្រមដោយអគ្គក្រុមប្រឹក្សានៅ ខែ ឧសភា ឆ្នាំ ១៩៩៧ ។

អ្នកសង្កេតការណ៍អង្គការអន្តរជាតិនៅក្នុងអគ្គក្រុមប្រឹក្សា (អ្នកសង្កេតការណ៍នៅក្នុងក្រុមប្រឹក្សាដទៃទៀត និងក្នុងគណៈកម្មការខុសគ្នា)"

អង្គការសហប្រជាជាតិ
សន្និបាតអង្គការសហប្រជាជាតិស្ដីអំពីពាណិជ្ជកម្ម និងការអភិវឌ្ឍន៍ (UNCTAD)
អង្គការរូបិយវត្ថុអន្តរជាតិ (IMF)
អង្គការកសិកម្មនិង ម្ហូបអាហាររបស់អង្គការសហប្រជាជាតិ (FAO)
អង្គការកម្មសិទ្ធិបញ្ញាពិភពលោក (WIPO)
អង្គការសំរាប់កិច្ចសហប្រតិបត្តិការ និងការអភិវឌ្ឍន៍ (OECD)

ប្រភព : WTO

ផ្នែកទីពីរ

វិធានអន្តរជាតិស្តីពីការធ្វើពាណិជ្ជកម្ម ផ្នែកទំនិញ (GATT ១៩៩៤ និង កិច្ចព្រមព្រៀងដែលពាក់ព័ន្ធ)

បណ្ណាល័យ
ក.ជ.អ.ប

ឧបសម្ព័ន្ធ ២

វិធានសំខាន់ៗទាំង៤ របស់ GATT

សេចក្ដីសង្ខេប:

មូលដ្ឋានគ្រឹះនៃការបើកចំហរបស់ GATT និងប្រព័ន្ធពាណិជ្ជកម្មសេរីពហុភាគី រៀបចំឡើងដោយផ្អែកលើវិធានសាមញ្ញ និងជាមូលដ្ឋានចំនួន ៤ ។

វិធានទីមួយ ត្រូវបានគេទទួលស្គាល់ថា មានសារៈសំខាន់សំរាប់ប្រទេសជាសមាជិក ដើម្បីអនុវត្តតាមការបើកចំហ និងគោលនយោបាយពាណិជ្ជកម្មសេរី គឺការអនុញ្ញាតិឱ្យប្រទេសជាសមាជិកការពារផលិតកម្មក្នុងស្រុក ពីការប្រកួតប្រជែងបរទេសដែលចែងថា ការការពារនោះត្រូវបានពង្រីកតាមរយៈការដាក់ពន្ធគយ និងត្រូវរក្សាវានៅកំរិតទាបបំផុត ។ តាមវិធីនេះ គេអាចហាមឃាត់ប្រទេសទាំងឡាយពីការដាក់កំហិតលើបរិមាណ លើកលែងតែមានករណីពិសេសណាមួយ ។ វិធានប្រឆាំងនឹងការដាក់កំហិតលើបរិមាណត្រូវបានពង្រឹងឡើងនៅឯវគ្គចរចាយូរ៉ុយហ្គាយ ។

វិធានទី ២ ចែងពីការកាត់បន្ថយ និងលុបបំបាត់ចោលពន្ធគយ ព្រមទាំងរបាំងពាណិជ្ជកម្មផ្សេងទៀតតាមរយៈ ការចរចាពហុភាគី ។ ពន្ធគយដែលបានកាត់បន្ថយមានរាយនាមនៅក្នុងបញ្ជីផ្អែកលើមូលដ្ឋាន តារាងពន្ធនៃកម្មវិធីសម្បទានធ្វើដោយប្រទេសនីមួយៗ ។ អត្រាចែងក្នុងកម្មវិធីពន្ធគយ គឺជាអត្រាពន្ធដែលមានប្រសិទ្ធិភាពចងភ្ជាប់ ។ ប្រទេសនីមួយ ៗ ជាប់កាតព្វកិច្ចមួយគឺមិនតំឡើងពន្ធគយឱ្យខ្ពស់ជាងអត្រាដែលខ្លួនបានចងដោយមានប្រសិទ្ធិភាពក្នុងតារាងពន្ធគយទេ ។

វិធានទី ៣ គឺតំរូវឱ្យប្រទេសនីមួយៗ ធ្វើពាណិជ្ជកម្មដោយពុំមានការរើសអើង ឬ បែងចែកបក្សពួកក្នុងចំណោមដែលខ្លួននាំទំនិញចេញទៅ ។ វិធាននេះ ផ្ដោតជាសំខាន់ទៅលើគោលការណ៍ប្រជាជាតិ ដែលទទួលភាពអនុគ្រោះបំផុត(MFN) ។ ការលើកលែងដែលសំខាន់បំផុតនោះគឺការអនុញ្ញាតិឱ្យមានការអនុគ្រោះដោយឡែក សំរាប់កិច្ចរៀបចំតំបន់អនុគ្រោះផ្សេងៗ ។

វិធានទី ៤ គឺជាវិធានប្រព្រឹត្តកម្មជាតិ (National Treatment) ។ វិធាននេះមិនតំរូវឱ្យប្រទេសនីមួយៗ ដាក់ពន្ធនានាដូចជាអាករគយ នៅមាត់ច្រកព្រំដែន ពន្ធផ្ទៃក្នុងដូចពន្ធលើការលក់ ឬ ពន្ធលើតំលៃបន្ថែមចំពោះទំនិញនាំចូលក្នុងព្រំដែន តាមអត្រាមួយខ្ពស់ជាងអត្រាពន្ធដែលបានដាក់ទៅលើផលិតផលក្នុងស្រុកស្រដៀងគ្នានោះទេ ។

GATT 1994 បុព្វកថា

ប្រពន្ធ័ពាណិជ្ជកម្មពហុភាគីផ្នែកទំនិញដែលបង្កើតឡើងដោយ GATT មានបំណងផ្ដល់ឱ្យសហគ្រាសឧស្សាហកម្ម និងពាណិជ្ជកម្មនៃប្រទេសផ្សេងគ្នា នូវសន្តិសុខ បរិយាកាស ស្ថេរភាព និងភាពអាចទស្សន៍ទាយបាន ដែលពួកគេអាចធ្វើពាណិជ្ជកម្មជាមួយគ្នាតាមល័ក្ខខ័ណ្ឌប្រកួតប្រជែង ស្មើភាពនិងយុត្តិធម៌ ។ ប្រព័ន្ធពាណិជ្ជកម្មសេរីដែលបើកចំហនេះ ជួយជំរុញឱ្យមានការកើនឡើងនូវសកម្មភាពពាណិជ្ជកម្ម វិនិយោគទុន ផលិតកម្ម និងធានាការងារធ្វើ ព្រមទាំងជួយសំរួលដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ចរបស់ប្រទេសទាំងអស់ ។

វិធានទីមួយៈ ការការពារឧស្សាហកម្មក្នុងស្រុកអាចធ្វើបានតែតាមរយៈពន្ធគយតែមួយគត់

ប្រព័ន្ធច្បាប់ដែល GATT បានបង្កើតឡើងសំដៅសំរេចបាននូវគោលដៅខាងលើ មានភាពស្មុគស្មាញណាស់ តែវាផ្អែកទៅលើវិធានជាមូលដ្ឋាន និងសាមញ្ញាមួយចំនួន ។

នៅពេលដែល GATT តំណាងឱ្យពាណិជ្ជកម្មសេរី GATT ក៏ទទួលស្គាល់ផងដែរថា បណ្តាប្រទេសមួយចំនួនមានបំណងការពារឧស្សាហកម្មរបស់ខ្លួនពីការប្រកួតប្រជែងរបស់បរទេស ។ ប្រការនេះបានបង្ខំឱ្យពួកគេរក្សា ការការពារក្នុងកំរិតទាបសមស្របមួយតាមតារាងពន្ធគយ ។ គោលការណ៍ការពារតាមរយៈពន្ធគយ គឺបង្ខំឱ្យអនុវត្តតាមបទបញ្ញត្តិដែលហាមឃាត់ប្រទេសជាសមាជិកមិនអោយប្រើប្រាស់វិធានការណ៍ដាក់កំហិតលើបរិមាណនាំចូល ។ ទោះជាយ៉ាងនេះក្តី វិធាននេះក៏មានអញ្ញត្រកម្មពិសេសផងដែរ ។
GATT ១៩៩៤ អញ្ញត្រកម្មពិសេសគឺអនុញ្ញាតិឱ្យប្រទេស ដែលមានបញ្ហាផ្នែកតុល្យភាពនៃការទូទាត់ ដាក់កំហិតលើការនាំចូល ដើម្បីធានាសន្តិសុខ
មាត្រា១១ និង១២ សុវត្ថិភាពនៃស្ថានភាពហិរញ្ញវត្ថុរបស់ខ្លួន ។ កអញ្ញត្រកម្មនេះ បានផ្តល់នូវភាពបត់បែនដ៏សមម្យើមមួយ ចំពោះប្រទេសកំពុងអភិវឌ្ឍន៍ជាជាងប្រទេសជឿនលឿន ក្នុងការប្រើប្រាស់ការដាក់កំហិតលើបរិមាណនាំចូល នៅពេលដែលការដាក់កំហិតនេះ សំខាន់ធ្វើឡើងសំរាប់បង្កានូវការធ្លាក់ចុះដ៏គួរឱ្យព្រួយបារម្ភនូវធនបំរុងហិរញ្ញវត្ថុ ។

ករណីលើកលែងពីការអនុវត្តន៍វិធានប្រឆាំងនឹងការដាក់កំហិតលើបរិមាណ

វិស័យកសិកម្ម

កន្លងមកមានប្រទេសមួយចំនួន មិនបានគោរពតាមវិធានរបស់ GATT ស្តីពីការការពារដោយប្រើតែពន្ធគយឡើយ ។ ជាក់ស្តែងនៅក្នុងវិស័យកសិកម្ម មានប្រទេសជឿនលឿនមួយចំនួន បានរក្សាទុកនូវវិធានការណ៍ដាក់កំហិតលើបរិមាណនាំចូលលើសពីអញ្ញត្រកម្មដែលមានចែងនៅក្នុង GATT ។ ក្រៅពីការដាក់កំហិតលើបរិមាណ ប្រទេសខ្លះទៀតនៃសហគមន៍អ៊ឺរ៉ុប បានអនុវត្តការហូតអាករផ្សេងៗ តាមអត្រាប្រែប្រួលជំនួសឱ្យការហូតពន្ធ ដែលមានអត្រាថេរ ចំពោះផលិតផលកសិកម្មខ្លះ ដូចជាស្រូវសាលី និងគ្រាប់ធុញ្ញជាតិដ៏ទៃទៀត សាច់ និងផលិតផលហូបចុកប្រចាំថ្ងៃផ្សេងទៀត ។ គោលបំណងសំខាន់នៃការដាក់អាករតាមអត្រាប្រែប្រួលនោះ គឺដើម្បីជួយទ្រទ្រង់ចំណូលរបស់កសិករ និងដើម្បីរក្សាភាពប្រហាក់ប្រហែលគ្នានៃចំណូលរកបាន ដោយកសិករ និងចំណូលរកបានដោយកម្មករឧស្សាហកម្ម ។ អាករដែលអាចទូទាត់បាននោះត្រូវកំណត់ជាខួប និងជាទូទៅស្មើគ្នាទៅនឹងគំលាតថ្លៃផលិតផលកសិកម្មក្នុងស្រុក និងថ្លៃផលិតផលនាំចូល ។

ការគិតអាករតាមអត្រាប្រែប្រួលនោះ វាអាចជួយឱ្យផលិតកម្មក្នុងស្រុក ទប់ទល់បានពីការប្រកួតប្រជែងបរទេស ដោយសារហេតុថា អាករនោះវាបំពេញជំនួសថ្លៃប្រកួតប្រជែង ដែលអ្នកផ្គត់ផ្គង់បរទេសមានលទ្ធភាពប្រកួតប្រជែងខ្ពស់ជាង ។

ពាណិជ្ជកម្មផ្នែកវាយនភ័ណ្ឌ និងសំលៀកបំពាក់

ក្នុងវិស័យឧស្សាហកម្ម ប្រទេសជឿនលឿនភាគច្រើនពុំបានអនុវត្តវិធានតទល់នឹងការដាក់កំហិតលើបរិមាណ ចំពោះពាណិជ្ជកម្មវាយនភ័ណ្ឌ ដែលជាវិស័យមួយផ្តល់ផលប្រយោជន៍ដល់បណ្តាប្រទេសកំពុងអភិវឌ្ឍន៍នោះទេ ។ ប្រការនេះ គឺជាលក្ខណៈសំខាន់មួយដែលខុសគ្នារវាងការដាក់កំហិតលើបរិមាណដែលអនុវត្ត នៅក្នុងវិស័យកសិកម្ម និងការដាក់កំហិតលើបរិមាណនៅក្នុងវិស័យវាយនភ័ណ្ឌ ។ នៅមានអញ្ញត្រកម្មគួរឱ្យកត់សំគាល់ខ្លះ គឺការដាក់កំហិតលើបរិមាណដែលគេទៅអនុវត្តក្នុងវិស័យកសិកម្មស្ថិតនៅក្រៅក្របខ័ណ្ឌនៃវិធានរបស់ GATT ។ នៅក្នុងករណីវាយនភ័ណ្ឌ ការដាក់កំហិតលើបរិមាណ ត្រូវបានគេអនុញ្ញាតិតាមបទបញ្ញត្តិនៃកិច្ចព្រមព្រៀងស្តីពីការរៀបចំពហុវាយនភ័ណ្ឌ (MFA) ដែលបានចរចាក្រោមក្របខ័ណ្ឌ GATT ។ MFA អនុញ្ញាតិឱ្យបណ្តាប្រទេសនាំចូលវាយនភ័ណ្ឌ បន្ធូរបន្ថយកាតព្វកិច្ច និងដាក់កំហិតលើបរិមាណនាំចូលផលិតផលវាយនភ័ណ្ឌ ប្រសិនមានការគោរពលក្ខខ័ណ្ឌដែលបានដាក់នោះ ។

ប្រទេសកំពុងអភិវឌ្ឍន៍

GATT ១៩៩៤ ក្រៅពីមានអត្រាពន្ធគយខ្ពស់ ប្រទេសកំពុងអភិវឌ្ឍន៍មួយចំនួន បានអនុវត្តវិធានការណ៍ ដាក់កំហិតលើបរិមាណនាំចូល ទាំងក្នុងវិស័យ
មាត្រាទី XII កសិកម្ម និងឧស្សាហកម្ម ។ ទោះជាយ៉ាងណាក៏ដោយ ការប្រើប្រាស់វិធីដាក់កំហិតលើបរិមាណ ត្រូវបានបង្ហាញថាមានហេតុផលសមរម្យ
និងទី XVIII:B តាមផ្លូវច្បាប់ដោយផ្អែកលើអញ្ញត្រកម្មនៃវិធានរបស់ GATT ដែលអនុញ្ញាតិឱ្យប្រទេសដែលមានការលំបាកផ្នែកតុល្យភាពនៃការទូទាត់ដាក់កំហិតលើបរិមាណនៃការនាំចូលបាន[៥]។

ការពង្រឹងច្បាប់ដើម្បីប្រឆាំងទៅនឹងការដាក់កំហិតលើបរិមាណ

ការគិតពន្ធលើមុខទំនិញផ្នែកខាងកសិកម្ម

ប្រព័ន្ធច្បាប់នៃអង្គការ WTO បាននាំមកនូវការផ្លាស់ប្តូរយ៉ាងច្រើនក្នុងការដាក់កំហិតលើបរិមាណ ហើយនិងវិធានការមិនដាក់ពន្ធលើមុខទំនិញផ្សេងទៀត ដែលជះឥទ្ធិពលលើការនាំចូលផលិតផល ។ ឧទាហរណ៍ ផ្នែកកសិកម្ម យោងតាមបទបញ្ញត្តិដែលចែងនៅក្នុងកិច្ចព្រមព្រៀងផ្នែកកសិកម្ម ប្រទេសដែលជាសមាជិកនៃអង្គការ WTO បានលប់បំបាត់លែងឱ្យមានការដាក់កំហិតលើបរិមាណ ហើយនិងប្រព័ន្ធវាយតំលៃពន្ធខុសគ្នា ដោយដាក់ជំនួសមកវិញនូវប្រព័ន្ធគិតពន្ធលើមុខទំនិញដូចគ្នា ។ អត្រាថ្មីលើការគិតពន្ធលើទំនិញផ្សេងៗ ត្រូវបានកំណត់ដោយបញ្ជីពន្ធ ឧទាហរណ៍ ការគណនាលើចំនួនដែលគេបានដាក់កំហិត ហើយនឹងវិធានការចំពោះតម្លៃទំនិញនាំចូលរួច បូកជាមួយនឹងពន្ធទំនិញទូទៅ ។ បន្ទាប់ពីមានបញ្ជីពន្ធ ចាប់ពីពេលនេះតទៅបណ្តាប្រទេសដែលការពារផលិតផលកសិកម្មក្នុងស្រុក គ្រាន់តែធ្វើឡើងដោយតាមរយៈការហូតពន្ធលើមុខទំនិញ (សូមមើលជំពូក ១៥) ប៉ុណ្ណោះ។

ការលប់បំបាត់ការដាក់កំហិតលើបរិមាណវាយនភ័ណ្ឌ និងសំលៀកបំពាក់

នៅក្នុងវិស័យវាយនភ័ណ្ឌ និងសំលៀកបំពាក់ (ATC) តម្រូវអោយបណ្តាប្រទេសជាសមាជិក រក្សាការដាក់កំហិតបណ្តោះអាសន្នសិន តែត្រូវធ្វើការលប់បំបាត់វាចោលបន្តិចម្តងៗ ជាបួនដំណាក់កាល និងត្រូវបំបាត់ចោលជាស្ថាពរនៅ ថ្ងៃទី១ ខែមករា ឆ្នាំ២០០១ (សូមអានជំពូក ១៤) ។

ជំរុញអោយបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ទាំងឡាយដែលមានការលំបាកផ្នែកតុល្យភាពនៃការទូទាត់ ប្រើប្រាស់វិធានការផ្អែកតាមតម្លៃជាមូលដ្ឋាន

ការយល់ដឹងពីបទបញ្ញត្តិ BOPនៃកិច្ចព្រមព្រៀង GATT 1994

បន្ថែមពីលើនេះ ការយល់ដឹងបទបញ្ញត្តិនៃតុល្យភាពនៃការទូទាត់នៅក្នុងកិច្ចព្រមព្រៀង GATT ឆ្នាំ ១៩៩៤ បានជំរុញយ៉ាងខ្លាំងក្លាមិនអោយបណ្តាប្រទេសជាសមាជិកដាក់កំហិតលើបរិមាណ ដើម្បីការពារស្ថានភាពតុល្យភាពនៃការទូទាត់របស់គេ (BOP)។ កិច្ចព្រមព្រៀងនេះតំរូវឱ្យបណ្តាប្រទេសនានា ទោះជាប្រទេសកំពុងអភិវឌ្ឍន៍ ឬ ប្រទេសជឿនលឿនក្តី ប្តឹងអំពីការដាក់កំហិតលើបរិមាណ (ដូចជាការគិតឈ្នួលបន្ថែមលើការនាំចូល និងតំរូវការកក់តំលៃចំពោះផលិតផលនាំចូល) ដោយសារឥទ្ធិពលនៃការដាក់កំហិតលើតម្លៃផលិតផលនាំចូលនោះ មានតំលាភាព និងជាវិធានការសមស្រប ។ ការដាក់កំហិតលើបរិមាណអាចធ្វើឡើងវិញបានតែនៅពេលណាដែលស្ថានភាពនៃការសងប្រាក់ជំពាក់ មានភាពតឹងតែង និងនៅពេលដែលមានការឈ្វេងយល់ថាវិធានការដែលផ្អែកលើតម្លៃមិនអាចធ្វើអោយមានសភាពការធូរស្រាលបានជាងមុន ។

ដោយការពង្រឹងវិធានប្រឆាំងនឹងការប្រើប្រាស់ការដាក់កំហិតលើបរិមាណ ប្រព័ន្ធច្បាប់ WTO បានពង្រឹងបន្ថែមទៀតនូវវិធានជាមូលដ្ឋានរបស់ GATT ដែលការពារផលិតកម្មក្នុងស្រុកតាមរយៈការដាក់ពន្ធ ។

វិធានទី២ : ការបន្ថយពន្ធលើមុខទំនិញនិងអត្រាដែលមានប្រសិទ្ធិភាពចងភ្ជាប់មិនអោយកើនឡើងនាពេលអនាគត

ការកាត់បន្ថយអត្រាពន្ធគយ

GATT ឆ្នាំ១៩៩៤ បុព្វកថា មាត្រាទី ២៨

វិធានសំខាន់ទី ២ នៃកិច្ចព្រមព្រៀង GATT បានចែងអំពីវិធានការកាត់បន្ថយពន្ធផ្សេងៗ ទៀតដែលបណ្តាប្រទេសនានាបានរក្សាទុក

[៦] ប្រទេសដែលគេយល់ឃើញថា មានការលំបាកផ្នែកតុល្យភាពនៃការទូទាត់គឺប្រទេសដែលមានចំណូលពីក្រៅ លើពាណិជ្ជកម្មទំនិញ និងសេវាកម្ម ហើយជាប្រទេស ដែលមានការហូរចូលវិនិយោគទុន ប្រាក់កម្ចី ស្ថិតនៅទាបពុំគ្រប់គ្រាន់សំរាប់ការទូទាត់ បំណុលទាំងឡាយរបស់ខ្លួន ហើយនៅពេលដែលធនបំរុងហិរញ្ញវត្ថុ ពុំអាចទូទាត់បំណុលបាន។ វិធានរបស់ GATT អាចផ្តល់ភាពបត់បែនបានក្នុងការអនុវត្តន៍កាតព្វកិច្ចចំពោះប្រទេសដែលមានការលំបាកផ្នែកតុល្យភាពនៃការទូទាត់ដោយអនុញ្ញាតិឱ្យពួកគេអាចប្រើប្រាស់វិធានការណ៍ដាក់កំហិតលើបរិមាណនាំចូល ។

ដើម្បីការពារផលិតផលក្នុងស្រុករបស់គេ ឬ ក៏អាចលប់បំបាត់ចោលតាមរយៈកិច្ចចរចាររវាងបណ្តាប្រទេសជាសមាជិក ហើយពន្ធដែលបានកាត់បន្ថយនោះ ត្រូវមានប្រសិទ្ធិភាពចងភ្ជាប់ មិនអោយកើនឡើងនាពេលអនាគត ។

ពន្ធដែលមានប្រសិទ្ធិភាពចងភ្ជាប់មិនកើនឡើងទៀតបាន

កិច្ចព្រមព្រៀង GATT ឆ្នាំ ១៩៩៤ មាត្រា ២:១ (ខ) : ការយល់ដឹងពីការបកស្រាយមាត្រា ២ : ១(ខ)

គោលគំនិតស្តីពីពន្ធដែលមានប្រសិទ្ធិភាពចងភ្ជាប់ ទាមទារអោយមានការពន្យល់ខ្លះៗ ។ អត្រាពន្ធដែលបានព្រមព្រៀងគ្នានៅក្នុងកិច្ចចរចា និងការសន្យាអនុវត្តដោយបណ្តាប្រទេសទាំងឡាយបានត្រូវបញ្ចូលទៅក្នុងឯកសារស្តីពីសម្បទាន ។ ប្រទេសជាសមាជិកអង្គការ WTO នីមួយៗ មានឯកសារដោយឡែកៗរបស់ខ្លួន ដែលស្តីពីកាតព្វកិច្ចមិនដាក់ពន្ធទំនិញ ឬ ពន្ធផ្សេងៗទៀត ឬ ដាក់លើសពីសេចក្តីថ្លែងនៅក្នុងឯកសាររបស់ខ្លួន ។ ប្រទេសជាសមាជិកមានកាតព្វកិច្ចមិនចាត់វិធានការ ដូចជាការកំហិតលើបរិមាណ ដែលអាចធ្វើអោយមានការថយចុះនូវតម្លៃពន្ធសម្បទាន។ អត្រាពន្ធដែលមានរាយនាមក្នុងឯកសារឧបសម្ព័ន្ធ គឺជាអត្រាពន្ធដែលមានប្រសិទ្ធិភាពចងភ្ជាប់ (សូមមើលវណ្ណ ៨) ។

ខណ្ឌ ៨

អត្រាពន្ធដែលមានប្រសិទ្ធិភាពចងភ្ជាប់

មិនអនុញ្ញាតិអោយប្រទេសណាមួយ បង្កើនអត្រាពន្ធគយលើសពីអត្រាដែលមាន ប្រសិទ្ធិភាពចងភ្ជាប់ ដូចមានបង្ហាញនៅក្នុងបញ្ជីសម្បទានឡើយ ។ ឯកសារក្នុងចំណោមនោះ មានរៀបរាប់ពីអត្រាពន្ធគយ មុនពេលចរចាតាមផលិតផលមួយមុខៗ និងអត្រាពន្ធគយដែលប្រទេសនីមួយៗបានព្រមព្រៀង "ក្នុងពេលចរចា ដើម្បីចងភ្ជាប់អត្រាពន្ធគយនោះ" ។ ក្នុងការចរចាលើផ្នែកពាណិជ្ជកម្មប្រទេសនីមួយៗអាចព្រមព្រៀងដើម្បី ÷

- ☐ *ចងភ្ជាប់អត្រាដែលមានស្រាប់ជាវិជ្ជមាន (ឧទាហរណ៍ ១០ ភាគរយ) ឬ អត្រា ០ ភាគរយ ឬ*
- ☐ *កាត់បន្ថយអត្រាពន្ធគយ ឧទាហរណ៍ពី ១០ ភាគរយទៅ ៥ ភាគរយ និងដើម្បីចងភ្ជាប់អត្រាដែលបានកាត់បន្ថយនោះប្រទេសនីមួយៗ អាចមានលទ្ធភាពចងភ្ជាប់អត្រាពន្ធគយរបស់គេអោយមានប្រសិទ្ធិភាពបាន ដល់អត្រាមួយខ្ពស់បំផុត ហើយដែលខ្ពស់ជាងអត្រា ដែលបានព្រមព្រៀងកាត់បន្ថយនាពេលចរចា ។ ដូច្នេះប្រទេសដែលបានព្រមព្រៀងកាត់បន្ថយអត្រាពន្ធគយពី ១០ ភាគរយ ទៅ ៥ ភាគរយ អាចបង្ហាញអោយឃើញថា នៅពេលដែលគេអនុវត្តអត្រាពន្ធគយ ដែលបានកាត់បន្ថយនោះទៅលើការនាំចូល នោះអត្រាពន្ធគយដែលមានប្រសិទ្ធិភាពចងភ្ជាប់នោះ គឺ ៨ ភាគរយ ។ ក្នុងករណីនេះ ប្រទេសនោះមានសិទ្ធិតំឡើងអត្រាពន្ធគយរបស់គេ បានដោយសេរីទៅដល់ ៨ ភាគរយ ក្នុងពេលណាមួយ ដោយមិនមានប៉ះពាល់ដល់កាតព្វកិច្ចក្រោម GATT ឡើយ ។ Uruguay Round ធ្វើអោយមានការវិវត្តន៍យ៉ាងច្រើន នៅក្នុងការចងភ្ជាប់ប្រកបដោយប្រសិទ្ធិភាពលើអត្រាពន្ធគយរបស់ប្រទេសទាំងអស់ ។ ប្រទេសទាំងអស់ ទោះជាប្រទេសជឿនលឿន ប្រទេសកំពុងអភិវឌ្ឍន៍ និងប្រទេសដែលមានសេដ្ឋកិច្ចអន្តរកាលក្តី ត្រូវជាប់កាតព្វកិច្ចក្នុងការអនុវត្តន៍អត្រាពន្ធគយរបស់គេទៅលើវិស័យកសិកម្ម ។ ក្នុងវិស័យឧស្សាហកម្ម ការនាំចូលជាង ៩៨ ភាគរយទៅក្នុងប្រទេសជឿនលឿន និងប្រទេសដែលមានសេដ្ឋកិច្ចអន្តរកាលនឹងត្រូវជាប់អត្រាពន្ធគយដែលមានប្រសិទ្ធិភាពចងភ្ជាប់ ។ ក្នុងករណីនាំចូលទៅកាន់ប្រទេសកំពុងអភិវឌ្ឍន៍ សមាមាត្រនៃការនាំចូលតាមអត្រាពន្ធគយដែលមានប្រសិទ្ធិភាពចងភ្ជាប់នេះ មានប្រហែល ៧៣ ភាគរយ ។ ក៏ប៉ុន្តែប្រទេសកំពុងអភិវឌ្ឍន៍មួយចំនួនបានផ្តល់អត្រាពន្ធគយខ្ពស់ក្នុងករណីខ្លះ ។ ប្រសិទ្ធិភាពចងភ្ជាប់ខ្ពស់នេះ មានក្នុងទំរង់ជាការសន្យាថាមិនតំឡើងអត្រាពន្ធ ÷*
    - ☐ *លើសពីអត្រាខ្ពស់ដែលមានបង្ហាញជូនសំរាប់ផលិតផលនីមួយៗទេ*
    - ☐ *លើសពីអត្រាខ្ពស់ដែលអនុវត្តបានទៅលើវិស័យជាក់លាក់ណាមួយ*
    - ☐ *លើសពីអត្រាខ្ពស់ដែលអនុវត្តទៅលើផលិតផលទាំងអស់*

ប្រទេសនីមួយៗ ទទួលបាននូវលទ្ធភាពចងភ្ជាប់អត្រាពន្ធគយរបស់គេ ដើម្បីធានាដល់ការលើកលែងពីការចងភ្ជាប់ និងបង្កើនអត្រាពន្ធគយលើសពីអត្រាចងភ្ជាប់នេះ ។ គេធ្វើដូច្នេះបាន ដោយចូលរួមក្នុងការចរចាជាមួយបណ្តាប្រទេសដែលបានចរចាជាដំបូងលើសម្បទាន និងជាមួយប្រទេសផ្គត់ផ្គង់ចំបងនូវផលិតផលដែលពាក់ព័ន្ធ ហើយដែលបានទទួលផលចំណេញពីសម្បទាននោះ ។ ក្នុងការចរចាបែបនោះ ប្រទេសដែលស្នើសុំអោយមានការលើកលែង នឹងបានផ្តល់សម្បទានពន្ធគយជាសំណងទៅលើផលិតផលផ្សេងទៀត ដែលប្រទេសនោះបានចរចាដោយមានផលចំណេញពាណិជ្ជកម្ម ។

គោលការណ៍ដែលគ្រប់គ្រងលើការផ្លាស់ប្តូរសម្បទាននៅក្នុងកិច្ចចរចា

តើតាមគោលការណ៍អ្វី ដែលធ្វើអោយបណ្តាប្រទេសនានាព្រមព្រៀងនៅក្នុងកិច្ចចរចារពាណិជ្ជកម្ម ដើម្បីកាត់បន្ថយពន្ធ ដើម្បីចងពន្ធមិនអោយមានការឡើងតម្លៃពន្ធ និងលប់ចោលរបាំងពាណិជ្ជកម្មផ្សេងទៀតនោះ ? គោលការណ៍គ្រឹះដែលគ្រប់គ្រងការផ្លាស់ប្តូរសម្បទាន គឺគោលការណ៍បដិការ និងគោលការណ៍ផ្តល់អត្ថប្រយោជន៍ទៅវិញទៅមក ។ ប្រទេសដែលសំណូមពរអោយកែលំអការបើកទីផ្សារទៅក្នុងទីផ្សារនៃបណ្តាប្រទេសដ៏ទៃទៀត តាមរយៈការកាត់បន្ថយពន្ធ ឬ ក៏តាមរយៈការលប់បំបាត់របាំងពាណិជ្ជកម្មផ្សេងៗ ដូចជាការដាក់កំហិតលើបរិមាណជាដើម ត្រូវប្រុងប្រៀបខ្លួន ដើម្បីធ្វើការផ្តល់សម្បទាន លើតារាងពន្ធគយ និងលើវិស័យផ្សេងៗ ទៀតដែលបណ្តាប្រទេសទាំងឡាយគិតថាជាផលប្រយោជន៍សំរាប់គេ និងមានតម្លៃស្មើចំពោះសម្បទានដែលគេបានផ្តល់អោយដែរ ។

GATT ១៩៩៤ (ពាណិជ្ជកម្ម និង ការអភិវឌ្ឍន៍) មាត្រា៣៤ កិច្ចចរចានៅ ទីក្រុងតូក្យូស្តីពីប្រព្រឹត្តកម្ម ដោយឡែក និងដែលផ្តល់ភាពអនុគ្រោះច្រើនស្តីពីបដិការ និងការចូលរួមអោយបានពេញលេញរបស់បណ្តាប្រទេសកំពុងអភិវឌ្ឍន៍ មាត្រា ៥ ៦ និង ៧

ទោះជាយ៉ាងណាក៏ដោយ វិធានដែលមានបដិការពេញលេញ អនុវត្តទៅលើការចរចារវាងប្រទេសជឿនលឿន និងប្រទេសកំពុងអភិវឌ្ឍន៍ ។ ប្រទេសកំពុងអភិវឌ្ឍន៍ ត្រូវបានតំរូវអោយធ្វើសម្បទានក្នុងទំរង់ជាការកាត់បន្ថយអត្រាពន្ធគយតាមមូលដ្ឋានបដិការទៅវិញទៅមក ហើយដែលត្រូវពិចារណា ទៅលើកត្តាថា ដោយសារការអភិវឌ្ឍន៍ផ្នែកសេដ្ឋកិច្ច និងពាណិជ្ជកម្មនៅមានកំរិតទាប និងដោយសារមានតំរូវការហិរញ្ញវត្ថុ គេមិនអាចមានលទ្ធភាពធ្វើសម្បទានតាមលក្ខណៈដូចគ្នានឹងការធ្វើសម្បទានរបស់ប្រទេសជឿនលឿនបានទេ ។ ក៏ប៉ុន្តែ វិធានទទួលស្គាល់ថា ប្រទេសកំពុងអភិវឌ្ឍន៍ទាំងអស់មិនមានការអភិវឌ្ឍន៍ស្មើគ្នាទេ ប្រទេសខ្លះឈានដល់ដំណាក់កាលនៃរីកចំរើនខ្ពស់ ឯប្រទេសខ្លះទៀតស្ថិតនៅដំណាក់កាលនៃការអភិវឌ្ឍន៍ខុសៗគ្នា ។ ប្រទេសចំនួន ៤៨ នៃចំណោមប្រទេសទាំងនោះ គឺជាប្រទេសក្រីក្រ ។

ប្រទេសកំពុងអភិវឌ្ឍន៍ ដែលបានឈានដល់កំរិតអភិវឌ្ឍន៍ខ្ពស់ តម្រូវឱ្យចូលរួមចំណែក និងធ្វើសម្បទានក្នុងទំរង់នៃការកាត់បន្ថយអត្រាពន្ធ និងចងភ្ជាប់ពន្ធគយនៅកំរិតមួយទាបបើប្រៀបនឹងកំណើនសេដ្ឋកិច្ច ។ គោលគំនិតត្រូវបានចាត់ទុកថា " ជាការចាត់ថ្នាក់ " ដោយសារគោលគំនិត នោះបង្ហាញអោយឃើញថា នៅពេលដែលប្រទេសកំពុងអភិវឌ្ឍន៍ឈានឡើងទៅដល់ស្ថានភាពមួយខ្ពស់ជាងមុន ហើយអាចនឹងមានលទ្ធភាពធ្វើសម្បទានពន្ធគយ និងទទួលយកវិន័យក្នុងវិស័យផ្សេងទៀត តាមមូលដ្ឋានដូចគ្នានឹងប្រទេសជឿនលឿន ។

ការចូលរួមចំណែកយ៉ាងច្រើនពីបណ្តាប្រទេសកំពុងអភិវឌ្ឍន៍នៅកិច្ចប្រជុំ Uruguay Round

ដោយសារតែវិធាននៃបដិការពាក់ព័ន្ធ ប្រទេសកំពុងអភិវឌ្ឍន៍មួយចំនួនតូច បានធ្វើពន្ធសម្បទានពន្ធគយ នៅក្នុងកិច្ចប្រជុំទីក្រុងតូក្យូ និងនៅក្នុងវគ្គចរចាថ្មីៗនេះ ។ លើសពីនេះទៀតប្រទេសទាំងនោះបានធ្វើសម្បទានពន្ធតែទៅលើផលិតផលពីរបីមុខប៉ុណ្ណោះ។ ហេតុការណ៍ នេះបានផ្លាស់ប្តូរគួរអោយកត់សំគាល់នៅក្នុងកិច្ចប្រជុំឃ្លុំយហ្គាយ ហើយបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ស្ទើរតែទាំងអស់បានព្រមព្រៀង ធ្វើសម្បទានដោយកាត់បន្ថយពន្ធតាមមូលដ្ឋានភាគរយ ។ យ៉ាងណាមិញយោងទៅតាមគោលការណ៍គ្រឹះដែលមានទំនាក់ទំនងគ្នាទៅវិញទៅមក សម្បទានទាំងនេះបានធ្វើឡើងតាមភាគរយដែលទាបជាងភាគរយដែលអនុវត្តទៅលើបណ្តាប្រទេសជឿនលឿន។

នៅក្នុងវគ្គប្រជុំឃ្លុំយហ្គាយ មានកត្តាពីរ ដែលទទួលខុសត្រូវលើភាពស្មគ្រចិត្តរបស់បណ្តាប្រទេសកំពុងអភិវឌ្ឍន៍ក្នុងការធ្វើសម្បទាន និងទទួលយកតាមរយៈការចរចានូវកាតព្វកិច្ចខ្ពស់ជាងពេលមុន ។ ទីមួយ បណ្តាប្រទេសទាំងនេះមួយចំនួនធំ បានកំពុងតែបោះជំហ៊ានទៅមុខគួរឱ្យកត់សំគាល់ ក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចរបស់ពួកគេ ។ ទីពីរ ជាកត្តាដែលមានទំនាក់ទំនងជិតដិតនិងកត្តាទី ១ គឺការផ្លាស់ប្តូរជាច្រើនដែលបានកើតឡើងចំពោះគោលនយោបាយពាណិជ្ជកម្មរបស់បណ្តាប្រទេសកំពុងអភិវឌ្ឍន៍ស្ទើតែទាំងអស់។ កន្លងមក នៅពេលដែលពួកគេអនុវត្តន៍តាមគោលនយោបាយសំរាប់ជំនួសការនាំផលិតផលចូល គេបានស្ថាបនាជញ្ជាំងពន្ធដ៏ខ្ពស់ ហើយបានដាក់ផលិតផលក្នុងស្រុកអោយនៅដាច់ពីការប្រកួតប្រជែងរបស់បរទេស ធ្វើអោយមានការពិបាកសំរាប់ពួកគេ ក្នុងការធ្វើសម្បទានក្នុងទម្រង់នៃការកាត់បន្ថយពន្ធ ។

ឥឡូវនេះ បណ្តាប្រទេសទាំងនេះកំពុងតែអនុវត្តន៍គោលនយោបាយជំរុញកំណើននាំចេញ និងកាត់បន្ថយអត្រាពន្ធ លប់បំបាត់នីតិវិធីច្រើនហួសហេតុនៃការចេញអាជ្ញាប័ណ្ណ និងប្រព័ន្ធដ៏ទៃទៀតដែលគេបានរក្សាទុក ដើម្បីដាក់កំហិតលើការនាំចូលផលិតផល។

ការបើកទូលាយ និងគោលនយោបាយពាណិជ្ជកម្មសេរី ផ្តល់លទ្ធភាពឱ្យពួកគេមិនត្រឹមតែទទួលបានផលប្រយោជន៍ លើការកាត់បន្ថយអត្រាពន្ធជាឯកតោភាគី ដោយការចងភ្ជាប់អត្រាពន្ធ ទាំងនោះប៉ុណ្ណោះទេ ប៉ុន្តែបានកែលំអស្ថានភាពចរចានៅក្នុងការចរចាជាមួយដៃគូដែលជាប្រទេសជឿនលឿនផងដែរ ។

និធានទី៣: ការធ្វើពាណិជ្ជកម្មដែលយោងទៅតាមកិច្ចសន្យាស្តីពីការអនុគ្រោះបំផុតផ្នែកពាណិជ្ជកម្ម

GATT ១៩៤៤ មាត្រា ១

វិធានជាមូលដ្ឋានទីបីនៃកិច្ចព្រមព្រៀង GATT បានចែងពីការធ្វើពាណិជ្ជកម្មដោយមិនរើសអើង នៅក្នុងកិច្ចសន្យាស្តីពីការអនុគ្រោះបំផុតផ្នែកពាណិជ្ជកម្ម (MFN) ។ ក្នុងលក្ខណ្ឌធម្មតា គោលការណ៍គ្រឹះមានន័យថា ប្រសិនបើមានប្រទេសជាសមាជិកណាយល់ព្រមផ្តល់ផលប្រយោជន៍ពន្ធទៅប្រទេសជាសមាជិកដ៏ទៃទៀត ឬ ក៏ផលប្រយោជន៍ផ្សេងទៀតទៅផលិតផលណាមួយ ត្រូវតែប្រទេសជាសមាជិកនោះបន្តផ្តល់អោយបានដូចគ្នា ទៅបណ្តាប្រទេសសមាជិកដ៏ទៃទៀតចំពោះមុខទំនិញដូចគ្នាអោយបាន ឆាប់រហ័សដោយគ្មានល័ក្ខខ័ណ្ឌអ្វីឡើយ ។ ដូច្នេះប្រសិនបើប្រទេស ក បានព្រមព្រៀងគ្នា នៅក្នុងកិច្ចចរចាពាណិជ្ជកម្មជាមួយប្រទេស ខ ដើម្បីកាត់បន្ថយពន្ធគយលើការនាំចូលផលិតផលពី ១០% ទៅ ៥% នោះអត្រាកាត់បន្ថយ ត្រូវតែបន្តផ្តល់អោយបណ្តាប្រទេសជាសមាជិក WTO ដ៏ទៃទៀតទាំងអស់ដែរ ។ កាតព្វកិច្ចដែលមានចំពោះប្រព្រឹត្តកម្ម MFN អនុវត្តទៅលើទាំងការនាំចូល និងនាំចេញ។ ដូច្នេះប្រសិនបើប្រទេសមួយកំណត់ពន្ធគយលើការនាំចេញផលិតផលទៅកាន់គោលដៅណាមួយ នោះការកំណត់ពន្ធគយនោះទៅកាន់គោលដៅផ្សេងៗទៀត ត្រូវតែមានតាមអត្រាដូចគ្នា ។

GATT ១៩៤៤ មាត្រា ១:១

ម៉្យាងវិញទៀត កាតព្វកិច្ចសំរាប់ផ្តល់ប្រព្រឹត្តកម្ម MFN មិនមានកំណត់ចំពោះអត្រាពន្ធទេ ។ ជាងនេះទៅទៀតប្រព្រឹត្តកម្ម MFN ក៏ត្រូវអនុវត្តន៍ផងដែរចំពោះ ÷

- ☐ ថ្លៃឈ្នួលណាមួយពាក់ព័ន្ធនឹងការនាំចូល និងចេញ
- ☐ វិធីនៃការគិតពន្ធ និងថ្លៃឈ្នួលនោះ
- ☐ វិធាន និងបែបបទដែលពាក់ព័ន្ធនឹងការនាំចូល និងចេញ
- ☐ ពន្ធក្នុងប្រទេស និងថ្លៃឈ្នួលលើទំនិញនាំចូល និងច្បាប់ លិខិតបទដ្ឋាន និងតំរូវការផ្សេងៗដែលពាក់ព័ន្ធដល់ការលក់របស់ទំនិញនោះ

GATT ១៩៩៤ មាត្រា ១៣

- ☐ គ្រប់គ្រងចំពោះការដាក់កំហិតលើបរិមាណ (ឧទាហរណ៍ ដោយការកំរិតកូតានៅក្នុងចំណោមបណ្តាប្រទេសផ្គត់ផ្គង់ដោយគ្មានការរើសអើង) លើកលែងតែការដាក់កំហិតនោះ ត្រូវបានអនុញ្ញាត្តិតាមបទបញ្ញាត្តិអញ្ញត្រកម្មពិសេស ។

ដូច្នេះ តាមរយៈការព្រមព្រៀងផ្តល់ប្រព្រឹត្តកម្ម **MFN** ជាគោលការណ៍ត្រូវកំណត់យ៉ាងណាមិនអោយប្រទេសជាសមាជិកទាំងអស់មានការរើសអើង ក្នុងចំណោមបណ្តាប្រទេសទាំងនោះ នឹងមិនត្រូវផ្តល់ភាពអនុគ្រោះអោយប្រទេសមួយតិចជាងប្រទេសមួយទៀតទេ ចំពោះការធ្វើពាណិជ្ជកម្មអន្តរជាតិលើទំនិញ ។

អញ្ញត្រកម្មចំពោះវិធាន MFN

GATT ១៩៩៤ មាត្រា ២៤

ក៏ប៉ុន្តែវិធានរបស់ GATT ទទួលស្គាល់ថា អត្រាពន្ធទំនិញ និងរបាំងពាណិជ្ជកម្មផ្សេងទៀត អាចកាត់បន្ថយបានតាមរយៈការអនុគ្រោះជាមូលដ្ឋាន ដោយបណ្តាប្រទេសតាមកិច្ចព្រមព្រៀងក្នុងតំបន់ ។ ការយកពន្ធទាប ឬ ការលើកលែងពន្ធចំពោះពាណិជ្ជកម្មតាមកិច្ចព្រមព្រៀង ក្នុងតំបន់មិនអាចមានវិសាលភាពសំរាប់បណ្តាប្រទេសដទៃទៀតឡើយ ។ ដូច្នេះកិច្ចព្រមព្រៀងអនុគ្រោះក្នុងតំបន់បង្កើតបានជាអញ្ញត្រកម្មដ៏សំខាន់ចំពោះវិធាន MFN ។ ដើម្បីការពារផលប្រយោជន៍ពាណិជ្ជកម្មរបស់បណ្តាប្រទេសដែលមិនមែនសមាជិក កិច្ចព្រមព្រៀង GATT បានកំណត់លក្ខ័ណ្ឌយ៉ាងតឹងតែងសំរាប់រៀបចំកិច្ចព្រមព្រៀងបែបនោះ ។ ក្នុងចំណោមនោះល័ក្ខខ័ណ្ឌទាំងនេះចែងថា ÷

GATT ១៩៩៤ មាត្រា ២៤:៨

□ បណ្តាប្រទេសជាសមាជិកនៃកិច្ចព្រមព្រៀងតំបន់ ត្រូវលប់ចេញនូវអត្រាពន្ធគយ និងរបាំងពាណិជ្ជកម្មផ្សេងទៀត ដែលមានផលប៉ះពាល់យ៉ាងខ្លាំងដល់ពាណិជ្ជកម្មទាំងអស់ ដែលមានក្នុងកិច្ចព្រមព្រៀងនោះខ្លួនឯង ។

□ កិច្ចព្រមព្រៀងនេះ មិនគួរបង្កើតអោយមានរបាំងពាណិជ្ជកម្មថ្មីជាមួយប្រទេសដទៃទៀតឡើយ ។

GATT ១៩៩៤ មាត្រា ២៤:៨

កិច្ចព្រមព្រៀងនេះអាចមានក្នុងទំរង់ជាសហពន្ធគយ ឬ តំបន់ពាណិជ្ជកម្មដោយសេរី ។ ក្នុងឧទាហរណ៍ទាំងពីរនេះ ពាណិជ្ជកម្មរវាងបណ្តាប្រទេសជាសមាជិកធ្វើឡើងតាមការលើកលែងពន្ធ នៅពេលដែលការធ្វើពាណិជ្ជកម្មជាមួយបណ្តាប្រទេសផ្សេងទៀតបន្តធ្វើតាមអត្រាពន្ធ MFN ។ ក្នុងករណីនៃសហពន្ធគយ អត្រាពន្ធនៃបណ្តាប្រទេសជាសមាជិកត្រូវបានរៀបចំអោយស៊ីចង្វាក់គ្នាហើយរួមគ្នាចំពោះការនាំចូលផលិតផលពីបណ្តាប្រទេសផ្សេងទៀត ។ នៅក្នុងតំបន់ពាណិជ្ជកម្មសេរី បណ្តាប្រទេសជាសមាជិកបន្តប្រើប្រាស់ដោយគ្មានសុខុដុមភាវូបនីយកម្មនូវពន្ធទំនិញដែលមានកំនត់នៅក្នុងឯកសារឧបសម្ព័ន្ធរបស់ប្រទេសគេនីមួយៗ ។

បច្ចុប្បន្ន មានកិច្ចព្រមព្រៀមស្តីពីការអនុគ្រោះក្នុងតំបន់ជាធរមានលើសពី ១០០ ហើយ។ ដូចមានបង្ហាញនៅក្នុងខណ្ឌ ៩ ថាការយកចិត្តទុកដាក់ និងការជំរុញពាណិជ្ជកម្មនៅក្នុងតំបន់កើតមានឡើងដោយការពង្រឹង និងការសំអាងលើពន្ធទំនិញ និងការប្តូរសម្បទានគ្នាទៅវិញទៅមក នៅក្នុងតំបន់ដែលមានកិច្ចព្រមព្រៀងអនុគ្រោះ មានការរីកដុះដាលឡើងជាលំដាប់ក្នុងប៉ុន្មានឆ្នាំនេះ។ ជាលទ្ធផលពាណិជ្ជកម្មក្នុងតំបន់កំពុងតែរីកចំរើនឡើងទៅក្នុងពាណិជ្ជកម្មពិភពលោក ។

កិច្ចព្រមព្រៀងស្តីពីការអនុគ្រោះនេះ ផ្តល់ផលប្រយោជន៍ទៅបណ្តាសហគ្រាស ដែលស្វែងរកទីផ្សារសំរាប់ផលិតផលរបស់គេនៅក្នុងបណ្តាប្រទេសផ្សេងទៀតក្នុងតំបន់ ។ ក្នុងពេលជាមួយគ្នានោះ គេអាចធ្វើឧស្សាហកម្មនៅក្នុងបណ្តាប្រទេសនានា ដែលនៅក្រៅតំបន់ ហើយដែលត្រូវបង់ពន្ធគយតាម MFN ក្នុងស្ថានភាពមួយដែលមានគុណវិបត្តិផ្នែកប្រកួតប្រជែង ។ បញ្ហាប្រឈមមួយដែលសំខាន់សំរាប់បណ្តាប្រទេសជាសមាជិកនាពេលខាងមុខនេះ គឺត្រូវធ្វើយ៉ាងណាធានាអោយមានការបំពេញបន្ថែមរវាងកិច្ចខិតខំប្រឹងប្រែងដើម្បីអភិវឌ្ឍន៍ពាណិជ្ជកម្មតំបន់ និងប៉ុនប៉ងធ្វើសេរីភាវូបនីយកម្មបន្ថែមនៅកំរិតពហុភាគី ។

ខណ្ឌ ៩

ការរួមបញ្ចូលគ្នានៃពាណិជ្ជកម្មតំបន់ : ការអភិវឌ្ឍន៍នាពេលថ្មីៗនេះ

ក្នុងរយៈពេលពីរ បី ឆ្នាំកន្លងមកនេះ ចលនាពង្រីក និងពង្រឹងកិច្ចព្រមព្រៀង ពាណិជ្ជកម្មក្នុងតំបន់បានបន្តធ្វើឡើងនៅគ្រប់ឧបទ្វីបទាំងអស់ ។

ទ្វីបអាហ្វ្រិក

នៅអាហ្វ្រិក ភូមិភាគខាងត្បូងដើរកំពុងបោះជំហានឆ្ពោះទៅរកការធ្វើសមាហរណកម្មនៅក្នុងតំបន់ពាណិជ្ជកម្មសេរីតាមរយៈសហគមន៍អភិវឌ្ឍន៍អាហ្វ្រិកខាងត្បូង (SADC) ។ នៅក្នុងក្រុមបណ្តាប្រទេសជាសមាជិក នៃសហពន្ធគយ អាហ្វ្រិកខាងត្បូង (SACU) គេកំពុងតែធ្វើការចរចាអំពីទំនាក់ទំនងសហពន្ធគយរបស់គេ ។

នៅក្នុងផ្នែកផ្សេងទៀតនៃទ្វីបអាហ្វ្រិក កំពុងមានការកែកប្រែធ្វើសមាហរណកម្មតំបន់ផងដែរ។ ឧទាហរណ៍ នៅអាហ្វ្រិកខាងលិចតាមសេដ្ឋកិច្ចថ្មី និងសហព័ន្ធរូបិយវត្ថុ (WEAMU; ជាភាសាបារាំង UEMOA) មានគំរោងដាក់អោយដំណើរការនូវពន្ធទំនិញខាងក្រៅរួមមួយគណៈកម្មការចំរុះ និងសមាសភាពផ្សេងទៀតនៃប្រព័ន្ធសហគមន៍អឺរ៉ុប (រូបិយវត្ថុរួមគ្នានៅក្នុងចំណែក CFA franc ដែលមានស្រាប់) ។ បណ្តាសមាជិកនៃសាជីវកម្មអាហ្វ្រិកខាងកើត (ប្រទេស Kenya, Uganda និងសហរដ្ឋ សាធារណៈរដ្ឋ Tanzania) បានបន្តចលនាកែប្រែឆ្ពោះទៅរកការបង្កើតសហភាពរូបិយវត្ថុ និងសេដ្ឋកិច្ចជាយថាហេតុ ដោយមានរូបិយវត្ថុរួម ។

ទីផ្សាររួមសំរាប់អាហ្វ្រិកខាងកើត និងខាងត្បូង (COMESA) ដែលមានប្រទេសជាសមាជិកចំនួន ២០ នៅតែទីផ្សារដ៏ធំជាងគេក្នុងតំបន់ទ្វីបអាហ្វ្រិក ហើយមានគោលបំណងបង្កើតសហព័ន្ធគយ និងអត្រាពន្ធគយក្រៅប្រទេសរួមគ្នាទៀត។

បណ្តាប្រទេសជាសមាជិករបស់គេ មានប្រទេស Angola, Burundi, Comoros, Djibouti, Eritrea, Ethiopia, Kanya, Lesotho, Madagascar, Malawi, Mauritius, Mozambique, Namibia, Rwanda, Seychelles, Somalia, Sudan, Swaziland, United Republic of Tanzania, Uganda, Zaire, Zambia and Zimbabwe ។

ទ្វីបអាមេរិក

នៅក្នុងទ្វីបអាមេរិក ការបង្កើតកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីរបស់អាមេរិកខាងជើង (NAFTA) ដោយសហរដ្ឋអាមេរិក កាណាដា ហើយនិងម៉ិចស៊ិក្ខ គឺជាការជំរុញបង្កើតតំបន់ពាណិជ្ជកម្មសេរីសំរាប់បណ្តាប្រទេសទាំងអស់នៃអាមេរិកខាងជើង និងខាងត្បូង ។ ក្នុងខែ មេសា ១៩៩៨ មានប្រទេសចំនួន ៣៤ ក្នុងតំបន់បានចុះហត្ថលេខាលើកិច្ចព្រមព្រៀង ដើម្បីបង្កើតតំបន់ពាណិជ្ជកម្មសេរីរបស់អាមេរិក (FTAA) មុនឆ្នាំ ២០០៥ ។ មានកិច្ចព្រមព្រៀងមួយចំនួនបានកំណត់ឡើងនូវការប្រមូលផ្តុំតំបន់ និងអនុតំបន់ ហើយរំពឹងថាបានអនុវត្តយ៉ាងពេលពេញមកដល់ថ្ងៃនេះ ។

តំបន់ផ្តុំគ្នាមួយឈ្មោះ MERCOSUR (ជាទីផ្សាររួមភាគខាងត្បូង) គឺជាតំបន់ដែលប៉ុនប៉ងស្ថាបនាទីផ្សាររួមគ្នាមួយសំរាប់សមាជិករបស់គេ គឺ Argentina, Brazil, Paraguay និង Uruguay (Bolivia និង Chile គឺជាសមាជិកសមាគម) ។ ឥឡូវនេះសហព័ន្ធគយ MERCOSUR បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងជាមួយសហគមន៍ Andean (ដើម្បីចាប់ផ្តើមកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីឱ្យបានពេញលេញនៅឆ្នាំ ២០០០) និងជាមួយទីផ្សាររួម របស់អាមេរិកកណ្តាល (ដើម្បីជាកិច្ចចាប់ផ្តើមកម្មវិធីកាត់បន្ថយពន្ធទំនិញសំរាប់អនុវត្ត កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី)។ គេមានកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីជាមួយនឹងប្រទេស Bolivia nig Chile ។

សហគមន៍ Andean (រួមមាន Bolivia, Colombia, Ecuador, Peru និង Venezuela) បានព្រមព្រៀងបង្កើតទីផ្សាររួម នៅឆ្នាំ ២០០៥ និងបានចុះហត្ថលេខាលើគម្រោងកិច្ចព្រមព្រៀងជាមួយ Panama សំដៅរួមបញ្ចូលគ្នាក្នុងសហគមន៍នាពេលក្រោយ ។

ទ្វីបអាស៊ី

នៅក្នុងទ្វីបអាស៊ី បណ្តាប្រជាជាតិអាស៊ីភាគអគ្នេយ៍ (ឬ អាស៊ាន មាន Brunei Darussalam, Indonesia, សាធារណៈរដ្ឋប្រជាមានិតឡាវ, ម៉ាឡេស៊ី, ភូមា, ហ្វីលីពីន, សិង្ហបុរី, ថៃ, និងវៀតណាម) កំពុងខិតខំយ៉ាងខ្លាំងក្លាដើម្បីបង្កើតតំបន់ពាណិជ្ជកម្មសេរីដោយការកាត់បន្ថយពន្ធទំនិញ និងរបាំងពាណិជ្ជកម្មដទៃទៀត ។

បណ្តាប្រទេសហត្ថលេខីនៃកិច្ចព្រមព្រៀងនៃទីក្រុង បាងកក (មាន ប្រទេស បង់ក្លាដេស, Bhutan, ឥណ្ឌា Maldives នេប៉ាល់ ប៉ាគីស្ថាន, និងស្រីលង្កា) ក៏កំពុងតែប្រឹងប្រែងជំរុញពាណិជ្ជកម្មក្នុងតំបន់ដែរ ទោះបីជាស្ថានការនយោបាយដ៏លំបាករបស់គេ បានរាំងមិនអោយគេសំរេចបានក៏ដោយ ។

នៅអាស៊ីកណ្តាល រួមមាន Kazakhstan, Tyrgyzstan, Tajikistan, Turkmenistan និង Uzbekistan បានរួមដៃគ្នាជាមួយសាធារណៈរដ្ឋ អ៊ីស្លាម អ៊ីរ៉ង់, ប៉ាគីស្ថាន និងទួរគី ដើម្បីបង្កើនការផ្សារភ្ជាប់ពាណិជ្ជកម្មអោយបានជិតដិត។

បណ្តាប្រទេសជាសមាជិកនៃវេទិកាសហប្រតិបត្តិការសេដ្ឋកិច្ចអាស៊ីប៉ាស៊ីហ្វិច (APEC) កំពុងប្រឹងប្រែងរំលាយចោលអត្រាពន្ធគយ និងរបាំងពាណិជ្ជកម្មផ្សេងៗទៀត ។ សមាជិករបស់គេគឺ: Australia, Brunei Darussalam, Canada, Chile, Hong Kong, Indonesia, Japan, Malaysia, Mexico, New Zealand, Peru, Papua New Guinea, the Philippines, Republic of Korea, the Russian Federation, Singapore, Taiwan Province (China), Thailand, the United States និងវៀតណាម។

ទ្វីបអ៊ឺរ៉ុប

នៅក្នុងទ្វីបអ៊ឺរ៉ុប មានការធ្វើសមាហរណ៍សេដ្ឋកិច្ច ក្នុងចំណោមប្រទេសចំនួន ១៥ តាមរយៈការបង្កើតសហគមន៍អ៊ឺរ៉ុប។ មានការចរចាលើការអនុញ្ញាត្តិ ឲ្យប្រទេសមួយចំនួនទៀតចូលជាសមាជិក ដែលរួមមានប្រទេស Union of Cyprus, the Czech Republic, ហុងគ្រី, ប៉ូឡូញ, និងSlovenia ។ សហគមន៍អ៊ឺរ៉ុបបានរក្សាកិច្ចសហការគយជាមួយប្រទេសទួរគី ហើយកំពុងចរចារលើការបង្កើតកិច្ចព្រមព្រៀងថ្មី ស្ដីពីតំបន់ពាណិជ្ជកម្ម សេរីជាមួយ និងដៃគូរពាណិជ្ជកម្មរបស់ខ្លួននៅក្នុងតំបន់ Mediterranean ។ បច្ចុប្បន្ននេះ សមាជិកទាំងនោះរួមមាន: Austria, Belgium, Denmark, Finland, France, Germany, Iceland, Ireland, Italy, Luxembourg, Netherlands, Portugal Spain, Sweden, និង the United Kingdom ។

ដូច្នេះមានការបញ្ជាក់ច្បាស់លាស់ណាស់ ចំពោះចរន្តសេដ្ឋកិច្ច និងនយោបាយសំរាប់កិច្ចព្រមព្រៀងពាណិជ្ជកម្មតំបន់ដែលមានវិសាលភាពទៅលើពាណិជ្ជកម្មពិភពលោក ក្នុងសមាមាត្រមួយខ្ពស់ ហើយដែលកាន់តែមានលក្ខណៈតឹងតែងឡើងថែមទៀតនៅឆ្នាំខាងមុខ ។

ប្រភព: WTO, របាយការណ៍ប្រចាំឆ្នាំ ១៩៩៨Vol ១ ប្រធានបទពិសេស: សកលភាវូបនីយកម្ម និងពាណិជ្ជកម្ម

ក្រៅពីកិច្ចព្រមព្រៀងទាំងនេះ ប្រទេសជឿនលឿន បានណែនាំអោយប្រើប្រាស់កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីតាមវិធីតែមួយ ដែលតាមវិធីនេះ ការនាំចូលពីប្រទេសកំពុងអភិវឌ្ឍន៍ ទោះជាមានចំនួនកំណត់ ឬ មិនកំណត់ក្ដី អាចនាំចូលមកកាន់ទីផ្សាររបស់គេបាន ដោយមិនបាច់បង់ពន្ធ ។ កិច្ចព្រមព្រៀងទាំងអស់នេះ ជាកិច្ចព្រមព្រៀងមិនមានបដិការ ដោយសារប្រទេសកំពុងអភិវឌ្ឍន៍ដែលបានទទួលផលចំណេញពីការបើកទីផ្សារមានភាពអនុគ្រោះ មិនមានវិសាលភាពទៅលើប្រព្រឹត្តកម្មអនុគ្រោះណាមួយទៅលើការនាំចូលពីប្រទេសជឿនលឿន ។ ឧទាហរណ៍នៃកិច្ចព្រមព្រៀងអំពីប្រព័ន្ធអនុគ្រោះតាមវិធីតែមួយ ដូចជា ÷

GATT ១៩៩៤ សេចក្ដីសំរេចនៃកិច្ចប្រជុំតូក្យូលើប្រព័ន្ធអនុគ្រោះទៅវិញទៅមក និងការប្រព្រឹត្ត និងការចូលរួមអោយបានពេញលេញរបស់បណ្ដាប្រទេសកំពុងអភិវឌ្ឍន៍ ២ (ក)

- ☐ ប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម (GSP) ដែលបណ្ដាប្រទេសជឿនលឿន អនុញ្ញាត្តិអោយមានការនាំចូលផលិតផលពីគ្រប់បណ្ដាប្រទេសកំពុងអភិវឌ្ឍន៍នៃផលិតផលឧស្សាហ៍កម្មទាំងអស់ហើយ និងជំរើសផលិតផលកសិកម្មលើមូលដ្ឋាននៃប្រព័ន្ធអនុគ្រោះនិងការមិនយកពន្ធ ។
- ☐ កិច្ចព្រមព្រៀង Lomé ដែលតាមកិច្ចព្រមព្រៀងនេះ បណ្ដាប្រទេសជាសមាជិកសហគមន៍អ៊ឺរ៉ុប អនុញ្ញាត្តិអោយមានការនាំចូលផលិតផលពីបណ្ដាប្រទេសកំពុងអភិវឌ្ឍន៍ និងពីប្រទេសក្រីក្រមួយចំនួនក្នុងទ្វីបអាហ្វ្រិក, Caribbean, អាស៊ី និងប៉ាស៊ីហ្វិក (ឧទាហរណ៍ បណ្ដាប្រទេស ACP) ដោយមិនបង់ពន្ធ ។
- ☐ ការផ្ដួចផ្ដើមគំនិត Caribbean Basin តាមការផ្ដួចផ្ដើមគំនិតនោះ សហរដ្ឋអាមេរិកអនុញ្ញាត្តិអោយមានការនាំផលិតផលចូលពីបណ្ដាប្រទេស Caribbean ដោយមិនបង់ពន្ធ ។

ច្បាប់ជាមូលដ្ឋានដែលប្រើសំរាប់ពង្រីកប្រព្រឹត្តកម្មនៃប្រព័ន្ធអនុគ្រោះ ដោយប្រទេសជឿនលឿន លើការនាំចូលពីបណ្ដាប្រទេសកំពុងអភិវឌ្ឍន៍ក្រោម ប្រព័ន្ធអនុគ្រោះពន្ធពាណិជ្ជកម្ម (GSP) គឺមានចែងដោយសេចក្ដីសំរេចស្ដីពីប្រព្រឹត្តកម្មដោយឡែក និងប្រព័ន្ធអនុគ្រោះបដិការ និងការរួមចំណែកយ៉ាងពេញលេញនៃបណ្ដាប្រទេសកំពុងអភិវឌ្ឍន៍ ។ សេចក្ដីសំរេចនេះគឺដកស្រង់ចេញមកពីកិច្ចព្រមព្រៀង GATT ឆ្នាំ ១៩៧៩ ហើយត្រូវបានគេស្គាល់ជាទូទៅថាជាប្រយោគដែលផ្ដល់លទ្ធភាពទូទៅ ។ គ្មានមូលដ្ឋានច្បាប់ពិតប្រាកដណាមួយដែលស្ថិតនៅក្រោមបទបញ្ញត្តិនៃកិច្ចព្រមព្រៀង GATT ឆ្នាំ១៩៩៤ សំរាប់កិច្ចព្រមព្រៀងអនុគ្រោះ ដូចជាកិច្ចព្រមព្រៀង Lome និងកិច្ចព្រមព្រៀង Caribbean Basin ដែលអនុញ្ញាតិអោយមានភាពអនុគ្រោះ និងការបើកទីផ្សារដោយមិនបង់ពន្ធសំរាប់តែប្រទេសកំពុងអភិវឌ្ឍន៍មួយចំនួនប៉ុណ្ណោះ ។ កិច្ចព្រមព្រៀងបែបនេះ បច្ចុប្បន្នអនុញ្ញាតិអោយមានការបដិសេធលើការផ្ដល់ភាពអនុគ្រោះដោយបណ្ដាប្រទេសជឿនលឿនពីកាតព្វកិច្ចចំពោះប្រព្រឹត្តកម្ម MFN ។

យោងតាមទស្សនៈច្បាប់ កិច្ចព្រមព្រៀងប្រពន្ធ័អនុគ្រោះដែលមានការបែបនេះនឹងនាំមកនូវប្រព្រឹត្តកម្មរើសអើងលើការនាំចូលផលិតផលពីសំណាក់បណ្តាប្រទេសដែលមិនបានទទួលផលពីប្រព័ន្ធអនុគ្រោះនេះ។ ដូច្នេះវាដាក់សម្ពាធអោយបណ្តាប្រទេសជឿនលឿនដែលផ្តល់ប្រព័ន្ធអនុគ្រោះ ធ្វើការកែប្រែប្រព័ន្ធអនុគ្រោះរបស់គេនោះ អោយស្របទៅតាមវិធានរបស់ GATT។ កិច្ចព្រមព្រៀង Lomé (Lomé IV) នាពេលបច្ចុប្បន្ននេះ នឹងហួសពេលកំណត់ក្នុងខែ ២ ឆ្នាំ ២000 ។ មានការបង្ហាញអោយឃើញថា សហព័ន្ធអឺរ៉ុប (EU) ប្រហែលជាអាចមានលទ្ធភាពទទួលសិទ្ធលើកលែង ដើម្បីបន្តកិច្ចព្រមព្រៀងបន្ថែមតិច ឬ ច្រើនសំរាប់រយៈពេល ៥ ឆ្នាំទៅមុខទៀត រហូតដល់ឆ្នាំ ២០០៥ ។ ឥឡូវនេះកិច្ចចរចារកំពុងតែចាប់ផ្តើមរវាងសហព័ន្ធអឺរ៉ុបនិងបណ្តាប្រទេសអ្នកទទួលផល GATT ថាតើត្រូវកែប្រែកិច្ចព្រមព្រៀងនេះយ៉ាងណា ដើម្បីអោយស្របទៅតាមបទបញ្ញត្តិ GATT ១៩៩៤ និងប្រយោគដែលផ្តល់លទ្ធភាពទូទៅ ។

អញ្ញត្រកម្មពិសេស ដែលផ្តល់អោយសហរដ្ឋអាមេរិកក្នុងការអនុវត្តន៏ Carebbean Basin នឹងផុតកំណត់នៅចុងឆ្នាំ ២០០៥។

វិធានទី៤ : ប្រព្រឹត្តកម្មជាតិ

GATT ១៩៩៤
មាត្រា ៣

ដូចដែលបានកត់សំគាល់រួចមកហើយថា គោលការណ៍ MFN មិនតម្រូវអោយបណ្តាសមាជិកទាំងអស់ ធ្វើការរើសអើងក្នុងចំណោមបណ្តាប្រទេសនានាឡើយ ។ គោលការណ៍ប្រព្រឹត្តកម្មជាតិ ដែលបំពេញគោលការណ៍ MFN តម្រូវអោយផលិតផលនាំចូលដែលបានឆ្លងកាត់ព្រំដែន បន្ទាប់ពីបង់ពន្ធគយ និងបង់ថ្លៃផ្សេងៗរួចនោះ មិនគួរទទួលបាននូវប្រព្រឹត្តកម្ម ដែលមានភាពអនុគ្រោះតិចជាងភាពអនុគ្រោះដែលផ្តល់អោយផលិតផលដូចគ្នា ដែលផលិតនៅក្នុងស្រុកនោះឡើយ ។ ម៉្យាងទៀត មូលដ្ឋាននេះតម្រូវអោយបណ្តាប្រទេសជាសមាជិកប្រព្រឹត្តចំពោះប្រភេទផលិតផលនាំចូល តាមល័ក្ខខ័ណ្ឌដូចគ្នានឹងផលិតផលដែលបានផលិតក្នុងស្រុកដែរ ។ ដូច្នេះមិនមែនបើកចំហរអោយប្រទេសនីមួយៗ កំណត់ពន្ធក្នុងស្រុក (ដូចជាពន្ធលក់) ខ្ពស់ជាងពន្ធដែលអាចប្រៀបធៀបបានទៅនឹងផលិតផលក្នុងស្រុក ទៅលើផលិតផលនាំចូល បន្ទាប់ពីបាននាំចូលមកក្នុងប្រទេស ហើយថែមទាំងបានបង់ពន្ធគយនៅឯព្រំដែនរួចមកហើយដែរនោះទេ ។ ម៉្យាងទៀត បទបញ្ញាដែលមានផលប៉ះពាល់ដល់ការលក់ និងការទិញផលិតផលនៅទីផ្សារក្នុងស្រុក មិនអាចអនុវត្តបានច្រើនជាងផលិតផលនាំចូលទេ ។

ការពាក់ព័ន្ធផ្នែកពាណិជ្ជកម្ម

ប្រព័ន្ធវិធានថ្មី ដែលគ្របដណ្តប់ទៅលើផលិតផលកសិកម្មនិងវាយនភ័ណ្ឌ ដែលបានរៀបចំឡើងដោយ Uruguay Round នឹងធានាថា វិធានជាមូលដ្ឋាននៃ GATT ជាវិធានប្រឆាំងនឹងការដាក់កំហិតលើបរិមាណ ហើយតំរូវអោយមានការការពារផលិតផលក្នុងស្រុកតាមរយៈការយកពន្ធទំនិញ ដែលប្រទេសទាំងអស់ត្រូវអនុវត្តន៏តាម ។ សហគ្រាសនាំចេញចង់បានអត្រាពន្ធគយតាមរបៀបការដាក់កំហិតលើបរិមាណ ដោយមានមូលហេតុច្រើនយ៉ាង ។ អត្រាពន្ធគយត្រូវមានតំលាភាព និងហេតុការលើតម្លៃក៏អាចព្យាករណ៍បានដែរ ។ ការដាក់កំហិតលើបរិមាណទំនិញ ធ្វើអោយមានបញ្ហាដល់ការធ្វើពាណិជ្ជកម្ម ដោយអាជ្ញាធរគ្រប់គ្រងមានសិទ្ធិអំណាចក្នុងការកែតំរូវចំនួនកូតាបានគ្រប់ពេលវេលា ។ នៅចុងបញ្ចប់ នៅពេលដែលមានកិច្ចដំណើរការដាក់កំហិតកូតា តម្រូវអោយមានអាជ្ញាប័ណ្ណ សហគ្រាសអាចធ្វើការនាំចេញបានតែនៅពេលណា ដែលអ្នកទិញបរទេសអាចមានលទ្ធភាពទទួលបាននូវអាជ្ញាប័ណ្ណប៉ុណ្ណោះ។

កិច្ចប្រជុំ Uruguay Round បានទទួលលទ្ធផលជាទីគាប់ចិត្តអំពីការចងភ្ជាប់ពន្ធគយប្រកបដោយប្រសិទ្ធិភាពពីសំណាក់បណ្តាប្រទេសទាំងអស់ ។ ការអះអាងថា ដោយសារមានការចងភ្ជាប់អត្រាពន្ធគយ នោះអត្រាទាបនោះនឹងមិនត្រូវបានតំឡើងអោយខ្ពស់វិញដោយបណ្តាប្រទេសដែលនាំផលិតចេញនោះទេ គឺដើម្បីលើកទឹកចិត្តដល់បណ្តាសហគ្រាសអោយវិនិយោគ លើដំណាំឧស្សាហកម្ម ឧបករណ៏ផ្សេងៗ បណ្តាញចែកចាយព្រមទាំងវិធានការ ដើម្បីអភិវឌ្ឍន៏ពាណិជ្ជកម្ម ។ លើសពីនេះ ទៅទៀតការចងភ្ជាប់ពន្ធបានផ្តល់

អោយបណ្តាសហគ្រាសនូវការធានារ៉ាប់រងស្តីអំពីពន្ធគយ ដែលត្រូវបង់លើទំនិញវត្ថុធាតុដើម ហើយនិងមុខទំនិញផ្សេងៗទៀត ដែលគេត្រូវធ្វើការនាំចូលសំរាប់ប្រើប្រាស់ក្នុងការនាំផលិតផលចេញ ពន្ធនេះនិងមិនត្រូវបានតំឡើងដោយរដ្ឋាភិបាលផ្ទាល់របស់គេទេ ។

ចុងក្រោយ វិធាននៃប្រព្រឹត្តកម្មជាតិ ធានាចំពោះសហគ្រាសនាំចេញថា នៅពេលផលិតផលរបស់គេចូលទៅក្នុងទីផ្សារនាំចូលបន្ទាប់ពីបានបង់ពន្ធអោយគយ និងថ្លៃផ្សេងៗទៀតនៅព្រំដែនរួចហើយ ពួកគេនឹងមិនតម្រូវអោយបង់ពន្ធក្នុងប្រទេសដែលមានអត្រាខ្ពស់ជាងអត្រាពន្ធដែលបង់ទៅលើផលិតផលក្នុងស្រុកឡើយ ។ វិធានប្រព្រឹត្តកម្មជាតិ មិនត្រឹមតែអនុវត្តទៅលើអត្រាពន្ធក្នុងស្រុកប៉ុណ្ណោះទេ តែក៏សំរាប់ប្រើទៅលើវិធានដែល គ្រប់គ្រងស្តង់ដារចាំបាច់របស់ផលិតផលផងដែរ និងអនុវត្តទៅលើការលក់ និងការចែកចាយទំនិញទៀតផង ។ នៅពេលដែលរដ្ឋាភិបាលបានបង្កើនការកំណត់ពន្ធ ហើយអនុម័តការគ្រប់គ្រងផលិតផលដើម្បីការពារបរិដ្ឋាន សុខភាពព្រមទាំងសុវត្ថិភាពរបស់អ្នកប្រើប្រាស់ផងនោះ វិធានដែលអនុវត្តទៅលើពន្ធ និងបទបញ្ញាទាំងនោះត្រូវតែបានគេអនុវត្តន៍ ទៅលើផលិតផលក្នុងស្រុក និងផលិតផលនាំចូលដោយគ្មានរើសអើង ដែលជាប្រការមួយសំខាន់ណាស់សំរាប់សហគ្រាសនាំចេញ។

ជំពូក ៣

ការវាយតម្លៃទំនិញ ដើម្បីប្រមូលពន្ធគយ

សេចក្តីសង្ខេប

នៅពេលកំណត់ពន្ធគយដោយផ្អែកលើតំលៃ (ad valorem) រួចមក (ឧទាហរណ៍ ១០ភាគរយនៃតំលៃផលិតផលនាំចូល) តំលៃពន្ធពិតប្រាកដគឺយោងទៅតាមបច្ចេកទេសរបស់គយជាអ្នកធ្វើការកំណត់ ។ កិច្ចព្រមព្រៀងស្តីអំពីរបៀបវាយតំលៃពន្ធគយ តម្រូវអោយគយកំណត់តម្លៃពន្ធទៅតាមតំលៃនៃផលិតផលដែលបានចំណាយ ។ យោងតាមលទ្ធផលនៃសេចក្តីសំរេចនាកិច្ចប្រជុំ Uruguay Round គយអាចធ្វើការបដិសេធតម្លៃទំនិញ នាំចូលដែលអ្នកនាំចូលបានប្រកាសនៅលើឯកសាររបស់គេ នៅពេលដែលគយមានមូលហេតុសង្ស័យថាការប្រកាសនោះមិនពិត ឬ មិនត្រឹមត្រូវ ។ ក្នុងស្ថានការបែបនេះ ដើម្បីការពារផលប្រយោជន៍ដល់អ្នកនាំចូល គយត្រូវផ្តល់ឱកាសអោយអ្នកនាំចូលធ្វើការកែតំរូវតម្លៃទំនិញរបស់គេ ។ នៅពេលដែលគយមិនយល់ស្របជាមួយនឹងសេចក្តីពន្យល់របស់អ្នកនាំចូល ពេលនោះគយមានកាតព្វកិច្ចផ្តល់មូលហេតុជាលាយល័ក្ខអក្សរ អោយអ្នកនាំចូល អំពីមូលហេតុដែលគេមិនអាចទទួលយកបាននូវតំលៃដែលអ្នកនាំចូលបានធ្វើប្រតិវេទន៍នោះ ។

កិច្ចព្រមព្រៀងបានចែងពីវិធីកំណត់តំលៃចំនួន ៥ យ៉ាង សំរាប់ពេលដែលគយមិនអាចទទួលយកបាននូវតម្លៃទំនិញដែលអ្នកនាំចូលបានធ្វើប្រតិវេទន៍នោះ ។ ដើម្បីកំណត់តំលៃដោយផ្អែកលើមូលដ្ឋាននៃវិធីទាំងនេះ គយចាំបាច់ត្រូវធ្វើការពិគ្រោះយោបល់ជាមួយបណ្តាអ្នកនាំចូល ហើយទទួលធ្វើការពិចារណានូវទស្សនៈរបស់អ្នកនាំចូល ។

បណ្តាប្រទេសកំពុងអភិវឌ្ឍន៍មួយចំនួន បច្ចុប្បន្នកំពុងតែប្រើប្រាស់នូវប្រព័ន្ធវាយតំលៃ ដោយយោងទៅតាមនិយមន័យ ទីក្រុង Brussels ដែលរៀបចំឡើងដោយអង្គការគយអន្តរជាតិ (WTO) ។ បណ្តាប្រទេសទាំងនេះត្រូវធ្វើការកែលំអរបណ្តាប្រព័ន្ធនានារបស់គេ ដើម្បីអោយអនុលោមទៅតាមច្បាប់នៃកិច្ចព្រមព្រៀងស្តីអំពីការវាយតម្លៃពន្ធគយនៅក្នុងរយៈពេលអន្តរកាល ៥ឆ្នាំ (ឧទាហរណ៍ រហូតដល់ថ្ងៃទី ១ ខែ មករា ឆ្នាំ ២០០) ហើយបានព្រមព្រៀងថា សំរាប់ប្រទេសកំពុងអភិវឌ្ឍន៍ រយៈពេលផ្លាស់ប្តូរប្រព័ន្ធនេះនឹងត្រូវបានកំណត់ដោយកិច្ចព្រមព្រៀង ។

ប្រភេទនៃបណ្តាពន្ធគយ

បណ្តាពន្ធគយ ត្រូវបានកំណត់ដោយផ្អែកទៅលើតំលៃពិសេស ad Valorem (ឧទាហរណ៍ 20% នៃតម្លៃផលិតផលនាំចូល) ឬក៏តាមពន្ធជាក់លាក់មួយ (ឧទាហរណ៍ $2 ក្នុង ១ គីឡូក្រាម ឬ ក្នុង ១ លីត្រ) ។ ពន្ធបញ្ចូលគ្នា ឬ ពន្ធចំរុះរួមមានទាំងពន្ធ ad Valorem និងអត្រាជាក់លាក់ក៏ត្រូវបានកំណត់ផងដែរទៅលើមុខទំនិញមួយចំនួន (10% នៃតម្លៃ $2 ក្នុង ១ គីឡូក្រាម)។

មានអញ្ញត្រកម្មមួយចំនួនតូច ដែលធ្វើអោយបណ្តាប្រទេសមួយចំនួនដាក់កំណត់ពន្ធតាមតំលៃពិសេស ad Valorem ។ រដ្ឋាភិបាលនិយមដាក់ពន្ធប្រភេទនេះដោយ មានមូលហេតុជាទូទៅពីរយ៉ាង ។ ទីមួយ វាបង្ករលក្ខណៈងាយស្រួលចំពោះអាជ្ញាធរក្នុងការប៉ាន់ប្រមាណប្រាក់ចំណូលដែលប្រមូលពីពន្ធ ad Valorem ហើយពន្ធនេះត្រូវបានគេវាយតំលៃឃើញមានលើសពីប្រាក់ចំណូលដែលបានមកពីពន្ធជាក់លាក់ ដែលត្រូវបានគេកំណត់យោងទៅតាមបរិមាណ ឬ ទំងន់ ។ ទីពីរ ពន្ធដោយផ្អែកលើតំលៃ ad Valorem មានសមភាពជាងពន្ធជាក់លាក់ ពីព្រោះពន្ធបែបនេះមានទាបសំរាប់ផលិតផលដែលមានមានតំលៃថោក ហើយយកពន្ធកំរិតខ្ពស់លើផលិតផលដែលមានតំលៃថ្លៃ ។ ឧទាហរណ៍ពន្ធជាក់លាក់ $២ ក្នុង ១ លីត្រ និងធ្វើអោយមានការបង់ពន្ធ ៥% នៃស្រាដែល

មានតំលៃថ្លៃ ២០ ដុល្លាក្នុងមួយដប ។ ពន្ធ ad Valorem នៃ១០ ភាគរយអាចមានចំនួន ០.២០ ដុល្លា លើស្រាមួយដបដែលមានតំលៃថោក និង ២ ដុល្លា លើស្រាមួយដបដែលមានតំលៃថ្លៃ ២០ ដុល្លា ។ មូលហេតុទីបី នៅក្នុងកិច្ចចរចារអន្តរជាតិស្តីអំពីការកាត់បន្ថយពន្ធ រឹតតែធ្វើឱ្យមានភាពងាយស្រួលទៅទៀត ក្នុងការប្រៀបធៀបកំរិតអត្រាពន្ធគយ និងការចរចា ដើម្បីកាត់បន្ថយប្រសិនបើពន្ធនោះជាពន្ធដោយផ្អែកលើតំលៃ ។

តែទោះជាយ៉ាងណាក៏ដោយ ការកើតមានពន្ធ Ad Valorem គឺអាស្រ័យទៅតាមកំរិតស្តីពីវិធីដែលបានប្រើប្រាស់ដើម្បីកំណត់តំលៃពន្ធ ។ ដូច្នេះ បើគយធ្វើការកំណត់តំលៃពន្ធចំនួន $1,000 ហើយ Ad Volorem មាន ១០% នោះ តំលៃពន្ធគយស្មើនឹង $100 ។ ម៉្យាងទៀត ប្រសិនបើគេធ្វើការកំណត់តំលៃ $1,200 អ្នកនាំចូលត្រូវបង់ពន្ធនាំចូលចំនួន $120 សំរាប់ទំនិញដូចគ្នា ។ ផលប្រយោជន៍សំរាប់ពាណិជ្ជកម្ម ដែលកើតមកពីអត្រាពន្ធគយដែលមានប្រសិទ្ធិភាពចងភ្ជាប់ អាចមិនដំណើរការទៅបានប្រសិនបើគយប្រើប្រាស់តំលៃផ្សេងក្រៅពីតំលៃតាមវិក័យបត្រដើម្បីកំណត់ពន្ធគយ ។ ដូច្នេះ វិធានដែលអនុវត្តសំរាប់វាយតំលៃទំនិញ គឺជាកត្តាសំខាន់ក្នុងការធានាថាពន្ធគយដែលទទួលបានដោយអ្នកនាំចូល មិនខ្ពស់ជាងអត្រាពន្ធគយដែលអត្រាទាបបំផុត ដូចមានចែងនៅតារាងពន្ធគយរបស់ប្រទេសនាំចូលឡើយ ។

វិធាននៃកិច្ចព្រមព្រៀងស្តីអំពីការវាយតំលៃពន្ធគយ

កិច្ចព្រមព្រៀងស្តីអំពីការវាយតំលៃពន្ធគយ បុព្វកថា

វិធានលំអិតនៃ WTO ស្តីអំពីការវាយតំលៃពន្ធគយលើទំនិញ គឺស្ថិតនៅក្នុងកិច្ចព្រមព្រៀងនៃការវាយតម្លៃពន្ធគយ (ចំណងជើងពេញលេញគឺ: កិច្ចព្រមព្រៀងស្តីពីការអនុវត្តន៍មាត្រា៧ នៃ GATT ឆ្នាំ ១៩៩៤) ។ ប្រព័ន្ធវាយតំលៃក្នុងកិច្ចព្រមព្រៀងអាស្រ័យទៅលើលក្ខណៈវិនិច្ឆ័យ ដែលសាមញ្ញ និងសមភាព ដោយពិចារណាទៅលើការធ្វើពាណិជ្ជកម្ម ។ មានការតំរូវអោយប្រទេសជាសមាជិកទាំងឡាយ រៀបចំច្បាប់នៃប្រទេសរបស់គេអោយស៊ីសង្វាក់ទៅនឹងមូលដ្ឋាននៃវិធាន កិច្ចព្រមព្រៀងធ្វើយ៉ាងណាអោយមានភាពស្របគ្នា នៅក្នុងការអនុវត្តន៍វិធាននោះ ដើម្បីឱ្យអ្នកនាំចូលអាចដឹងមុនពីតំលៃបង់ពន្ធ ពិតប្រាកដលើការនាំចូលផលិតផល។

ស្តង់ដាជាចំបង: តំលៃទំនិញ

កិច្ចព្រមព្រៀងស្តីអំពីការវាយតំលៃពន្ធគយ មាត្រា ៨:១

កិច្ចព្រមព្រៀងស្តីអំពីការវាយតំលៃពន្ធគយ មាត្រា ៨:១

វិធានគ្រឹះនៃកិច្ចព្រមព្រៀងចែងថា តំលៃសំរាប់វាយតំលៃពន្ធគយត្រូវយោងទៅតាមតម្លៃពិតប្រាកដដែលបានបង់ជាក់ស្តែង ឬអាចបង់បាននៅពេលលក់ ដើម្បីនាំចេញទៅប្រទេសដែលធ្វើការនាំចូល (ឧទាហរណ៍ តម្លៃប្រកាសលើវិក័យបត្រ) ដែលបានកែតំរូវនៅពេលណាសមស្រប ដោយគិតបញ្ចូលនូវការទូទាត់ណាមួយដែលអ្នកទិញបានចំណាយ ដូចជាថ្លៃរវចខ្ចប់ និងដាក់ប្រអប់ ថ្លៃជួយពន្ធសួយសារអាករ និងថ្លៃអាជ្ញាប័ណ្ណ (សូមមើល វណ្ឌ ១០) ។ វិធានមិនមានគិតបញ្ចូលតំលៃជើងសារ និងការបញ្ចុះតំលៃពិសេសដែលត្រូវផ្តល់អោយទៅទីភ្នាក់ងារ និងសម្បទានិកផ្តាច់មុខណាមួយ នៅពេលពិចារណាពីពន្ធគយដែលត្រូវបង់នោះឡើយ ។

កិច្ចព្រមព្រៀងនៃវគ្គប្រជុំ នៅទីក្រុង តូក្យូ បានដាក់កំហិតដាច់ខាតទៅលើឆន្ទានុសិទ្ធិដែលគយមាន ក្នុងការបដិសេធនូវតំម្លៃទំនិញទៅលើករណី មួយចំនួនតូចដូចមានរៀបរាប់នៅក្នុងវណ្ឌ ១១ ។ នេះជាបញ្ហាចោទរបស់បណ្តាប្រទេសកំពុងអភិវឌ្ឍន៍មួយចំនួន ។ គេគិតថា វិធាននេះបានរាំង ការងារគ្រប់គ្រងរបស់គយខ្លាំងពេក ក្នុងការដោះស្រាយ ជាមួយពួកពាណិជ្ជករ ដែលបន្ទាបតំលៃទំនិញនាំចូល ដើម្បីបន្ថយតំលៃពន្ធ ។ នេះគឺជាមូលហេតុមួយដែលនាំមកនូវការស្នើរស្មាក់របស់បណ្តាប្រទេសកំពុងអភិវឌ្ឍន៍មួយចំនួនចំក្នុងការយល់ព្រមទៅនឹងកិច្ចព្រមព្រៀងមុនពេលកើតអង្គការ WTO ។

សេចក្តីសំរេចស្តីពីការផ្លាស់ប្តូរបន្ទុកភស្តុតាង មាត្រា ១

កន្លងមក សេចក្តីសំរេចអំពីករណីដែលខាងរដ្ឋបាលគួរមានមូលហេតុសង្ស័យអំពីតំលៃដែលបានធ្វើប្រតិវេទន៍ (ត្រូវបានគេដឹងផងដែរថាជាសេចក្តីសំរេច លើការប្តូរចំណុចសំខាន់នៃភស្តុតាង) បានកើតឡើងដោយសារលទ្ធផលនៃការផ្តួចផ្តើមគំនិតរបស់បណ្តាប្រទេសកំពុងអភិវឌ្ឍន៍ នាវគ្គប្រជុំនៅ Uruguay Round ដើម្បីធ្វើការកែតំរូវភាពខ្វះខាត ។ កិច្ចព្រមព្រៀងនៃវគ្គប្រជុំនាទីក្រុងតូក្យូ បានដាក់បន្ទុកនៃការរកភស្តុតាងទៅលើគយ ប្រសិនបើគេបដិសេធតំលៃទំនិញដែលបានធ្វើប្រតិវេទន៍អ្នកនាំចូល ។

កិច្ចប្រជុំបានសំរេចប្តូរបន្ទុកនៃការរកភស្តុតាងទៅលើរូបអ្នកនាំចូល នៅពេលដែលគយមានពាក្យមានតំលៃ និងមានពាក្យមានដទៃទៀត ដែលជាមូលហេតុធ្វើអោយគយសង្ស័យពីភាពត្រឹមត្រូវ និងភាពពិតប្រាកដរបស់ឯកសារដែលភ្ជាប់ជាមួយសេចក្តីប្រកាសរបស់អ្នកនាំចូល។

ធាតុ ១០

ការកំណត់តំលៃពន្ធគយ: ការកែតំរូវតំលៃទំនិញដែលអនុញ្ញាតិ

(កិច្ចព្រមព្រៀងលើការវាយតំលៃពន្ធគយ, មាត្រា ៨)

ដើម្បីឈានដល់ដំណោះស្រាយនៃតំលៃទំនិញ មាត្រា ៨ នៃកិច្ចព្រមព្រៀងលើការវាយតំលៃពន្ធគយបានចែងថា ការទូទាត់ដែលបានបង់សំរាប់សមាសភាពខាងក្រោមនេះ នឹងត្រូវបូកបន្ថែមពីលើតំលៃពិតប្រាកដដែលបានបង់រួចមកហើយ ឬ ដែលអាចទូទាត់បាន (ឧទាហរណ៍ តំលៃវិក័យប័ត្រ) ដោយអ្នកនាំចូលសំរាប់ទំនិញ នាំចូលរបស់គេ ÷

- ☐ *កំរៃជើងសារ និងឈ្នួលកណ្តាល លើកលែងកំរៃជើងសារពេលទិញ*
- ☐ *ចំណាយ និងថ្លៃឈ្នួលវេចខ្ចប់ និងដាក់កំប៉ុង*
- ☐ *ផ្គត់ផ្គង់ ឧទាហរណ៍បណ្តាទំនិញ (សំភារៈ សមាសធាតុ ឧបករណ៍, ។ល។...) ឬ សេវាកម្ម គំនូសបំព្រួញ ធ្វើគំរោង ។ល។....) ដែលបានមកទទេ ឬ ក៏បានបញ្ចុះតំលៃទាបដោយអ្នកទិញ ទិញយកមកប្រើប្រាស់ ដើម្បីផលិតទំនិញនាំចូល*
- ☐ *ពន្ធសួយសារអាករ និងថ្លៃអាជ្ញាប័ណ្ណ*
- ☐ *ប្រាក់ចំណូលដែលបានបន្តបន្ទាប់ពីការលក់ ដូចជាការលក់បន្ត ឬ ការប្រើប្រាស់ទំនិញនាំចូល*
- ☐ *តំលៃនៃការដឹកជញ្ជូន ធានារ៉ាប់រង និងថ្លៃឈ្នួលពាក់ព័ន្ធផ្សេងៗទៀត ទៅនឹងទីកន្លែងនាំចូលផលិតផល ប្រសិនបើប្រទេសនោះយកការវាយតំលៃលើតំលៃ CIF ជាមូលដ្ឋាន*

មាត្រានេះបានបញ្ជាក់បន្ថែមទៀតថា គ្មានមានការបូកបន្ថែម នៅលើតំលៃដែលបានបង់រួចមកហើយ និងចំពោះផ្នែកៗ ទាំងប៉ុន្មានដែលបានរៀបរាប់ខាងលើ ដើម្បីធ្វើឱ្យបានសំរេចនូវតំលៃទំនិញនោះទេ ។ ក្រៅពីនេះ មាត្រាបានចែងបន្ថែមទៀតថា គេនឹងចាត់ទុកការតំរូវអោយបង់ ឬ តំលៃដែលមិនគួរនឹងបូកបន្ថែមទៅនិងតំលៃពន្ធគយប្រសិនបើគេអាចប្រៀបធៀប តំលៃទាំងនេះទៅនឹងតំលៃពិតប្រាកដដែលបានបង់ ឬតំម្លៃដែលត្រូវបង់ ទាំងនេះគឺ ÷

- ☐ *ការដឹកជញ្ជូនក្រោយពេលនាំចូលទៅក្នុងកន្លែងគយនៃប្រទេសនាំចូល*
- ☐ *ថ្លៃសាងសង់, តែលំអ ផ្គុំសង់ ឬ ជំនួយបច្ចេកទេសដែលកើតឡើង ក្រោយពេលនាំចូល*
- ☐ *ពន្ធនៃប្រទេសនាំចូល*

ខណ្ឌ ១១

ឧទាហរណ៍សំរាប់គយដែលនាំឲបដិសេធលើតំលៃទំនិញដែលបានធ្វើប្រតិវេទន៍អ្នកនាំចូល

១- នៅពេលដែលគ្មានការលក់

២- នៅពេលដែលមានការហាមឃាត់សកម្មភាព ឬ ការប្រើប្រាស់ទំនិញដោយអ្នកទិញ ។ តំលៃទំនិញមិនបាច់អោយមានការទទួលស្គាល់ឡើយ ប្រសិនបើកិច្ចសន្យាលក់ តំរូវអោយមានការហាមឃាត់ខ្លះលើការប្រើប្រាស់ ឬសកម្មភាពទំនិញលើកលែងតែ ÷

- ការហាមត្រូវបានកំណត់ដោយច្បាប់ (ឧទាហរណ៍ តម្រូវអោយមានការខ្ចប់ទំនិញជាដើម)

- ការហាមឃាត់តំបន់លក់ទំនិញ (កិច្ចសន្យាលើការចែកចាយដែលដាក់កំរិតការលក់ទៅបណ្តាប្រទេសនៅអឺរ៉ុប)

- ការហាមឃាត់មិនប៉ះពាល់ដល់តំលៃនៃទំនិញ (ឧទាហរណ៍ ម៉ូតថ្មីនៃទំនិញចូលមិនត្រូវលក់មុនថ្ងៃកំណត់)

៣. នៅពេលដែលការលក់ ឬ តម្លៃមានការជួបប្រទះនឹងល័ក្ខខ័ណ្ឌដែលពុំអាចអោយធ្វើការកំណត់បាន (ឧទាហរណ៍ អ្នកលក់បង្កើតតំលៃពិសេសមួយនៃទំនិញនាំចូលនៅក្នុងល័ក្ខខ័ណ្ឌដែលអ្នកទិញបានទិញទំនិញផ្សេងទៀត ព្រមទាំងទាក់ទងនឹងបរិមាណផងដែរ)

៤. នៅពេលដែលផ្នែកនៃប្រាក់ចំណេញដែលបានកើតឡើងដោយសារការលក់ជូននានាក្រោយមកទៀត ។

៥. នៅពេលដែលអ្នកលក់ និងអ្នកទិញមានទំនាក់ទំនងជាមួយគ្នាហើយធ្វើឱ្យប៉ះពាល់ដល់តំលៃមិនល្អត្រឹមត្រូវគ្រប់គ្រាន់ដោយសារតែទំនាក់ទំនងនេះ ។

ដើម្បីធានាចំពោះករណីដែលគយបដិសេធតំលៃទំនិញ កិច្ចព្រមព្រៀងលើការវាយតំលៃពន្ធគយ ចែងថាច្បាប់របស់ជាតិត្រូវផ្តល់សិទ្ធជាក់លាក់ដល់អ្នកនាំចូល ។ ទី ១ នៅពេលដែលគយមានការសង្ស័យទៅលើតំលៃទំនិញដែលបានធ្វើប្រតិវេទន៍នោះ អ្នកនាំចូលត្រូវមានសិទ្ធពន្យល់ រួមបញ្ចូលទាំងការបង្ហាញឯកសារ ឬ ភស្តុតាងផ្សេងទៀត ដើម្បីបញ្ជាក់ពីតំលៃទំនិញពិតប្រាកដដែលពួកគេបានធ្វើប្រតិវេទន៍ ។ ទី ២ នៅពេលដែលគយមិនយល់ស្របទៅនឹងការពន្យល់របស់អ្នកនាំចូល នោះអ្នកនាំចូលត្រូវមានសិទ្ធស្នើអោយគយទាក់ទងមកគេវិញជាលាយល័ក្ខអក្សរអំពីមូលហេតុរបស់គយ ដែលសង្ស័យចំពោះតំលៃទំនិញដែលពួកអ្នកនាំចូលបានធ្វើប្រតិវេទន៍ ។ បទបញ្ញត្តិនេះមានបំណងការពារផលប្រយោជន៍របស់អ្នកនាំចូល ដោយផ្តល់សិទ្ធិអោយពួកគេធ្វើការតវ៉ាប្រឆាំងទៅរដ្ឋអំណាចថ្នាក់លើ តទល់នឹងសេចក្តីសំរេចរបស់គយ ប្រសិនបើចាំបាច់ អាចប្តឹងតវ៉ាទៅតុលាការ ឬ អង្គការឯករាជ្យនៅក្នុងរដ្ឋបាលគយ ។

កិច្ចព្រមព្រៀងស្តីអំពីការវាយតំលៃពន្ធគយ
មាត្រា ២(ក)

វិធានដែលចែងថា តំលៃទំនិញដែលបានធ្វើប្រតិវេទន៍ អ្នកនាំចូលត្រូវបានប្រើ មិនមែនសំរាប់តែវាយតំលៃទំនិញប៉ុណ្ណោះទេ ប៉ុន្តែក៏ត្រូវប្រើចំពោះទំនាក់ទំនងការងារពាណិជ្ជកម្មរវាងភាគីពាក់ព័ន្ធផងដែរ ។ នៅក្នុងការងារពាណិជ្ជកម្មក្រោយនេះ ដែលតែងតែកើតឡើងនៅក្នុងចំណោមសាជីវកម្ម និងការគាំទ្រ ការក្លាយជាសមាជិក តំលៃត្រូវបានគិតអោយបង់ទៅតាមការផ្លាស់ប្តូរតំលៃជាមូលដ្ឋានដែលមិនតែងតែបានត្រឹមត្រូវទៅតាមតំលៃទំនិញនាំចូលនោះទេ ។ មានករណីដែលកិច្ចព្រមព្រៀងតម្រូវអោយគយត្រូវពិគ្រោះយោបល់ជាមួយបណ្តាអ្នកនាំចូល ដើម្បីធ្វើការកំណត់ប្រភេទនៃទំនាក់ទំនង ជុំវិញកាលទេសៈនៃសកម្មភាពទំនិញ ហើយនឹងតើទំនាក់ទំនងនេះមានឥទ្ធិពលទៅលើតំលៃឬអត់ ។ បន្ទាប់ពីគយធ្វើការពិនិត្យរួចមក ឃើញថាទំនាក់ទំនងនោះគ្មានឥទ្ធិពលទៅលើការប្រកាសតំលៃនោះទេតំលៃនៃទំនិញនឹងត្រូវបានកំណត់យកទៅតាមបណ្តាតំលៃទាំង នោះជាមូលដ្ឋាន ។

កិច្ចព្រមព្រៀងស្តីអំពីការវាយតំលៃពន្ធគយ មាត្រា ២ (ខ)

បន្ទាប់មកទៀត ដើម្បីធានាដល់ការអនុវត្តន៍ជាក់ស្តែង មិនអោយមានការបដិសេធតំលៃទំនិញដោយគ្រាន់តែផ្អែកលើសាវតា ដែលភាគីមានការពាក់ព័ន្ធគ្នានោះទេ កិច្ចព្រមព្រៀងត្រូវផ្តល់សិទ្ធិអោយអ្នកនាំចូលទាមទារអោយទទួលស្គាល់តំលៃនៅពេលដែលគេអាចបញ្ជាក់ថាតំលៃមានភាពប្រហាក់ប្រហែលទៅនឹងតំលៃដែលគេបានសាកល្បងជាមូលដ្ឋាននៃ ÷

- ☐ តំលៃពន្ធគយដែលបានកំនត់នៅក្នុងការនាំចូលកន្លងមក ក្នុងពេលដូចគ្នា រវាងអ្នកទិញ និងអ្នកលក់ដែលគ្មានការពាក់ព័ន្ធគ្នាចំពោះទំនិញនោះ
- ☐ តម្លៃដែលបានកាត់បន្ថយ ឬ បានគណនាសំរាប់ទំនិញដូចគ្នា ឬ ប្រហាក់ប្រហែលគ្នា (សូមអានខាងក្រោម)

ស្តង់ដាប្រាំយ៉ាងទៀត

កិច្ចព្រមព្រៀងស្តីអំពីការវាយតំលៃពន្ធគយ ឧបសម្ព័ន្ធ ១ កំណត់សំគាល់ទូទៅ

តើគយអាចកំណត់តម្លៃតាមរបៀបណា នៅពេលគេបដិសេធតំលៃដែលអ្នកនាំចូលបានធ្វើប្រតិវេទន៍ ? ដើម្បីការពារផលប្រយោជន៍របស់អ្នកនាំចូល និងដើម្បីធានាបាននូវតំលៃដែលនៅក្នុងករណីរបៀបនេះបានត្រូវគេកំណត់ក្នុងភាពត្រឹមត្រូវ និងអព្យាក្រិតជាមូលដ្ឋាននោះ កិច្ចព្រមព្រៀងធ្វើការកំរិតនូវសិទ្ធអំណាចដែលមានចំពោះគយក្នុងការប្រើប្រាស់ស្តង់ដាទាំងប្រាំ ដែលបានដាក់ចេញមក។ កិច្ចព្រមព្រៀងបានជំរុញអោយមានការប្រើប្រាស់ស្តង់ដារទាំងនេះឱ្យបានត្រឹមត្រូវដូចដែលបានបង្ហាញនៅក្នុងអត្ថបទ ហើយអោយប្រើតែនៅពេលណាដែលគយយល់ឃើញថា ស្តង់ដាមួយមិនអាចប្រើការបាន ហើយត្រូវកំណត់តំលៃទៅតាមស្តង់ដារ ផ្សេងទៀតដែលល្អជាងនេះ ។ ស្តង់ដាប្រើប្រាស់ដែលបានលើកឡើងបន្តបន្ទាប់ទៅនេះ ត្រូវបានគេពិភាក្សានៅខាងក្រោម ÷

កិច្ចព្រមព្រៀងស្តីអំពីការវាយតំលៃពន្ធគយ មាត្រា ២

តំលៃចំពោះប្រភេទទំនិញដែលដូចគ្នា

នៅពេលដែលមិនអាចកំណត់តំលៃបានតាមមូលដ្ឋាននៃតំលៃទំនិញពាណិជ្ជកម្ម នោះគេអាចកំណត់វាបានដោយការប្រើប្រាស់តំលៃដែលបានកំណត់ពីមុនមកសំរាប់ប្រភេទទំនិញដូចគ្នា ។

កិច្ចព្រមព្រៀងស្តីអំពីការវាយតំលៃពន្ធគយ មាត្រា ៣

តំលៃនៃទំនិញប្រហាក់ប្រហែលគ្នា

បើសិនគ្មានលទ្ធភាព កំណត់តំលៃតាមមូលដ្ឋាននៃវិធីខាងលើទេ គេអាចកំណត់តំលៃជាមូលដ្ឋានដោយយកតាមតំលៃទំនិញស្រដៀងគ្នា ។ តាមវិធីទាំងនេះ ទំនិញជ្រើសរើសត្រូវតែជាទំនិញដែលមានទំនាក់ទំនងទៅនឹងទំនិញនាំចូលហើយត្រូវបានលក់សំរាប់ការនាំចេញទៅប្រទេសដែលធ្វើការនាំចូលនៅក្នុងរយៈពេលដូចគ្នា នឹងការនាំទំនិញចេញ ។

វណ្ឌ ១២ រៀបរាប់អំពីវិធានដែលត្រូវអនុវត្តតាម ដើម្បីកំណត់ថាតើទំនិញដែលត្រូវបានប្រើប្រាស់សំរាប់កំនត់ពន្ធគយមានលក្ខណៈដូចគ្នា ឬ ប្រហាក់ប្រហែលទៅនឹងទំនិញនាំចូល ។

ខណ្ឌ ១២

វិធានសំរាប់កំណត់ថាតើទំនិញដូចគ្នា ឬ ប្រហាក់ប្រហែលគ្នា

(កិច្ចព្រមព្រៀងស្តីអំពីការវាយតំលៃពន្ធគយ មាត្រា ១៥:២)

ចំពោះប្រភេទទំនិញដូចគ្នា ឬ ទំនិញប្រហាក់ប្រហែលគ្នាទៅនឹងបណ្តាទំនិញដែលត្រូវយកមកគិតតំលៃ ត្រូវបានកំណត់តាមចរិកលក្ខណៈនៃប្រភេទទំនិញដែលពិពណ៌នាខាងក្រោម ÷

ចាត់ទុកជាប្រភេទទំនិញដូចគ្នាប្រសិនបើវា

មានភាពដូចគ្នា គ្រប់យ៉ាងទាំងអស់រូបមាន ចរិកលក្ខណៈគុណភាព និង*កេរ្តិ៍ឈ្មោះ*

ចាត់ថាជាទំនិញប្រភេទស្រដៀងគ្នាប្រសិនបើប្រហាក់ប្រហែល

ទៅនឹងទំនិញដែលគេវាយតំលៃតាមសមាសធាតុ តាមសំភារៈ និងលក្ខណៈសម្បត្តិ

> អាចមានលទ្ធភាពបំពេញមុខងារដូចគ្នាហើយមានតំលៃពាណិជ្ជកម្ម ដែលអាចដោះដូរបាន ជាមួយនិងទំនិញដែលគេវាយតំលៃ
>
> ក្រៅពីនេះ ដើម្បីចាត់ទុកបានថា ជាទំនិញប្រភេទដូចគ្នា ឬ ប្រហាក់ប្រហែលគ្នា បណ្តាទំនិញទាំងនោះត្រូវតែបាន
>
> - ផលិតនៅក្នុងប្រទេសតែមួយ
> - ហើយផលិតដោយផលិតករតែមួយ
>
> ដូចបណ្តាទំនិញដែលគេយកមកវាយតំលៃ ។
>
> ក៏ប៉ុន្តែ នៅពេលដែលមិនមានការនាំចូលពាក់ព័ន្ធទៅនឹងភាពដូចគ្នា ឬ ប្រហាក់ប្រហែលគ្នា ទៅនឹងផលិតផលដែលផលិតដោយផលិតករដូចគ្នា នៅក្នុងប្រទេសផលិតទំនិញដែលត្រូវបានយកមកវាយតំលៃនោះការផលិត ដោយផលិតករខុសគ្នាអាចយកមកពិចារណាបាន ។

តំលៃដែលអាចកាត់បន្ថយបាន

វិធីពីរយ៉ាងបន្ទាប់ទៀត គឺជាវិធីដែលអាចកាត់បន្ថយបាន និងវិធីតំលៃដែលបានគណនា ។

កិច្ចព្រមព្រៀងស្តីអំពីការវាយតំលៃពន្ធគយ មាត្រា ៥

តំលៃដែលអាចកាត់បន្ថយបាន ត្រូវបានកំណត់តាមមូលដ្ឋាននៃតំលៃលក់និមួយៗនៅក្នុងទីផ្សារក្នុងស្រុកនៃទំនិញនាំចូលដែលយកមកវាយតំលៃ ឬ ដូចគ្នា ឬ ប្រហាក់ប្រហែល ក្រោយពេលកាត់ទុកជាផ្នែកនៃការចំណេញពន្ធគយ ការដឹកជញ្ជូន ថ្លៃធានារ៉ាប់រង និងចំណាយផ្សេងៗទៀត ដែលកើតមាននៅក្នុងប្រទេសដែលធ្វើការនាំចូល។

កិច្ចព្រមព្រៀងស្តីអំពីការវាយតំលៃពន្ធគយ មាត្រា ៦

ការគណនាតំលៃ

ការគណនាតំលៃត្រូវបានកំណត់ធ្វើឡើង ដោយការបូកថ្លៃចំណាយលើការផលិតទំនិញដែលគេយកទៅវាយតំលៃ ជាមួយនឹងប្រាក់ចំណេញនៃទំនិញនោះ ហើយនឹងប្រាក់ចំណាយជាទូទៅ ដែលផលបូកនេះស្មើនិងថ្លៃលក់នៃបណ្តាទំនិញក្នុងក្រុមជាមួយគ្នា ឬប្រភេទទំនិញដូចគ្នាដែលគេយកទៅវាយតំលៃងបានផលិតឡើងដោយផលិតករក្នុងប្រទេសចេញសំរាប់នាំចេញទៅប្រទេសដែលនាំចូល ។

កិច្ចព្រមព្រៀងស្តីអំពីការវាយតំលៃពន្ធគយ មាត្រា ៧

មេធ្យោបាយត្រឡប់ក្រោយ (Fall back method)

នៅពេលដែលតំលៃគយអាចកំណត់បានតាមវិធីទាំងបួនខាងលើ នោះគេអាចកំណត់បានដោយការប្រើវិធីមុនណាមួយតាមលក្ខណៈដែលអាចបត់បែនបានប្រសិនបើលក្ខណៈវិនិច្ឆ័យដែលបានប្រើប្រាស់នោះស្របទៅតាមមាត្រានៃកិច្ចព្រមព្រៀងជាទូទៅ ។ តំលៃដែលបានកំណត់នោះ មិនត្រូវអនុវត្តន៍តាមបណ្តាកត្តាដូចខាងក្រោមនេះទេ ÷

- ☐ តំលៃនៃបណ្តាទំនិញសំរាប់ធ្វើការនាំចេញទៅកាន់ទីផ្សារនៃប្រទេសទី ៣
- ☐ តំលៃគយជាអប្បបរិមា
- ☐ តំលៃអាជ្ញាកណ្តា ឬ តំលៃប្រឌិត (Firtitious)

កិច្ចព្រមព្រៀងស្តីអំពីការវាយតំលៃពន្ធគយ មាត្រា ៦ កំណត់សំគាល់មាត្រា ៦

វិធានទូទៅចែងថា កិច្ចព្រមព្រៀងប្រមើលមើលថា នៅពេលដែលតម្លៃទំនិញមិនអាចទទួលយកបាននោះ តំលៃទំនិញទាំងនេះនឹងត្រូវបានកំណត់ដោយការប្រើប្រាស់នូវបណ្តាស្តង់ដាខាងលើ ទៅតាមពត៌មានដែលមានជាមូលដ្ឋាននៅក្នុងប្រទេសដែលធ្វើការនាំចូលផលិតផល ។ ទោះបីជាគេបានទទួលស្គាល់របៀបគណនាតម្លៃនេះក៏ដោយ ប៉ុន្តែវាអាចមានសារៈសំខាន់ក្នុងការពិនិត្យលើប្រាក់ចំណាយដើម្បីផលិតទំនិញសំរាប់យកទៅវាយតំលៃ ហើយនឹងពត៌មានដែលបានមកពីប្រទេសដែលធ្វើការនាំចូល ។ កិច្ចព្រមព្រៀង

សំណូមពរអោយមានការធានាមិនអោយអ្នកនាំចូល ត្រូវទទួលបន្ទុកដែលចាំបាច់ ហើយស្តង់ដាគណនាតំលៃ មិនត្រូវបានប្រើប្រាស់នៅពេលដែលអ្នកលក់ និងអ្នកទិញមានទំនាក់ទំនងនឹងគ្នាប៉ុណ្ណោះទេ វាក៏ប្រើនៅពេលដែលផលិតករប្រុងប្រៀបនឹងផ្តល់អោយអាជ្ញាធរគយ ក្នុងប្រទេសនាំចូលនូវពត៌មានសំខាន់អំពីតំលៃ និងភាពងាយស្រួលសំរាប់គយធ្វើការត្រួតពិនិត្យផងដែរ ។

បណ្តាប្រទេសកំពុងអភិវឌ្ឍន៍ និងកិច្ចព្រមព្រៀង

កិច្ចព្រមព្រៀងស្តីអំពីការវាយតំលៃពន្ធគយ មាត្រា ២០:១

មុនថ្ងៃទី ១ ខែ មករា ឆ្នាំ ១៩៩៥ មានតែប្រទេសចំនួន ១១ ប៉ុណ្ណោះ ដែលអនុវត្តន៍កិច្ចព្រមព្រៀងស្តីពីការវាយតំលៃពន្ធគយ។ នៅពេលចរចាកិច្ចព្រមព្រៀងនេះ គេមានការទទួលស្គាល់ថា បណ្តាប្រទេសកំពុងអភិវឌ្ឍន៍ភាគច្រើន (ដែលយកប្រព័ន្ធការវាយតំលៃពន្ធគយតាមរបស់គេ តាមតំលៃនិយមន័យរបស់ទីក្រុង Belgium[7] ជានិយមន័យដែលខុសគ្នាស្រឡះ ពីការអនុវត្តន៍ដោយកិច្ចព្រមព្រៀង) ត្រូវការពេលវេលា ដើម្បីអនុម័តច្បាប់ជាតិ និងប្រព័ន្ធស្ថាប័ន ព្រមទាំងត្រូវការពេលវេលា ដើម្បីបណ្តុះបណ្តាលមន្ត្រីរដ្ឋការដែលជាអ្នកអនុវត្តន៍ ។ ដូច្នេះ កិច្ចព្រមព្រៀងបានពន្យាពេល ៥ ឆ្នាំទៀត សំរាប់បណ្តាប្រទេសកំពុងអភិវឌ្ឍន៍ ដែលគេគិតថាការផ្លាស់ប្តូរភ្លាមៗទៅនឹងប្រព័ន្ធថ្មីអាចនឹងមានការលំបាកសំរាប់ពួកគេ ។

បណ្តាប្រទេសកំពុងអភិវឌ្ឍន៍មួយចំនួនឥឡូវនេះបានក្លាយជាសមាជិកនៃកិច្ចព្រមព្រៀង។ ក៏ប៉ុន្តែ មានប្រទេសចំនួន ៥០ (រួមមានប្រទេសក្រីក្របំផុត) បានប្រើប្រាស់បទបញ្ញត្តិស្តីពីការពន្យាពេលនេះ។ រយៈពេលនេះនឹងហួសកំណត់សំរាប់បណ្តាប្រទេសទាំងអស់នោះនៅមុនឆ្នាំ ឬ ពាក់កណ្តាលឆ្នាំ ២០០០ ។ ដើម្បីសម្រួលអោយមានការអនុម័តប្រព័ន្ធនេះមុនពេលវេលាកំណត់ អគ្គលេខាធិការនៃអង្គការ WTO នឹង WCO បានបង្កើនជំនួយការបច្ចេកទេស ដើម្បីបណ្តុះបណ្តាលមន្ត្រីរដ្ឋការតាមវិធីនៃកិច្ចព្រមព្រៀង ។

អាចដាក់សំណូមពរទៅគណៈកម្មាធិការវាយតំលៃពន្ធ ដែលបានបង្កើតឡើងតាមកិច្ចព្រមព្រៀងនេះ អោយពន្យាពេលនៃរយៈពេល ៥ ឆ្នាំនេះតទៅទៀត ។ បណ្តាប្រទេសកំពុងអភិវឌ្ឍន៍ដែលជាអ្នកធ្វើសំណូមពរត្រូវតែបញ្ជាក់នូវភាពលំបាកដែលគេកំពុងជួបប្រទះក្នុងការប្រឈមមុខទៅនឹងការអនុម័តប្រព័ន្ធនេះ ។ គណៈកម្មាធិការជាអ្នកសំរេចលើការពន្យាពេលនោះ ។

ការពារគ័ន្ធផ្នែកពាណិជ្ជកម្ម

កិច្ចព្រមព្រៀង មានបំណងជាមូលដ្ឋាន គឺការពារផលប្រយោជន៍របស់ពាណិជ្ជករស្មោះត្រង់ ដោយតម្រូវអោយគយទទួលយកការកំណត់តំលៃពន្ធទៅតាម តំលៃទំនិញពិតប្រាកដដែលបានបង់រួចពីមុនមកដោយអ្នកនាំផលិតផលចូល ។ គោលបំណងនេះ អនុវត្តទៅលើការងារពាណិជ្ជកម្មទាំងពីរប្រភេទ គឺពាណិជ្ជកម្មដោយស្មើភាព(arms-length) និងកិច្ចការពាណិជ្ជកម្មនៃភាគីដែលមានទំនាក់ទំនងជាមួយគ្នា ។ កិច្ចព្រមព្រៀងទទួលស្គាល់ថាតំលៃដែលអ្នកនាំចូលបានទទួលខុសគ្នាសំរាប់ទំនិញដូចគ្នា អាចមានការប្រែប្រួល ។ កត្តាជាក់ស្តែង គឺថាតំលៃដែលទទួលបានដោយអ្នកនាំចូលណាមួយ ទាបជាងតំលៃដែលអ្នកនាំចូលផ្សេងទៀតបាននាំចូលផលិតផលនោះ មិនអាចយកមកប្រើប្រាស់ជាមូលដ្ឋានសំរាប់បដិសេធតំលៃទំនិញដែលធ្វើពាណិជ្ជកម្មនោះបានឡើយ ។

គយអាចបដិសេធតំលៃទំនិញតែនៅក្នុងស្ថានភាពដែលគេមានមូលហេតុសង្ស័យពីការពិត និងតំលៃពិតប្រាកដនៃទំនិញនាំចូលដែលបានធ្វើប្រតិវេទន៍តែប៉ុណ្ណោះ ។ សូម្បីតែនៅក្នុងករណីខ្លះ គយត្រូវតែផ្តល់ឱកាសអោយបណ្តាអ្នកនាំចូល ធ្វើការកែសំរួលតំលៃទំនិញរបស់គេ ហើយបើសិនជាការកែតំរូវនេះគយមិនអាចទទួលយកបាន នោះគយត្រូវផ្តល់មូលហេតុជាលាយលក្ខណ៍អក្សរអំពីការបដិសេធនោះ ហើយនឹងការកំណត់តំលៃពន្ធដោយការប្រើប្រាស់វិធីផ្សេងមួយទៀត ។ បន្ថែមពីលើនេះទៀត ត្រូវផ្តល់សិទ្ធិឱ្យអ្នកនាំចូលធ្វើការពិគ្រោះយោបល់អំពីកិច្ចការគ្រប់មុខទាំងអស់នៃការកំណត់តំលៃ ហើយកិច្ចព្រមព្រៀងធានាថា គយមានឆន្ទានុសិទ្ធិក្នុងការពិនិត្យពិច័យតំលៃដែលបានធ្វើប្រតិវេទន៍ ហើយដែលបានប្រើប្រាស់ជាកម្មវត្ថុនោះ ។

[៧] ប្រព័ន្ធដែលរៀបចំឡើងដោយក្រុមប្រឹក្សាសហប្រតិបត្តិការគយ បច្ចុប្បន្នជាអង្គការគយអន្តរជាតិ ។

បន្ថែមទៅលើសិទ្ធិដែលត្រូវពិភាក្សាជាមួយអ្នកនាំចូល នៅរាល់ដំណាក់កាលទាំងអស់ ដើម្បីកំណត់តំលៃពន្ធគយ កិច្ចព្រមព្រៀងតំរូវអោយច្បាប់ជាតិស្តីពីការវាយតំលៃទំនិញ ផ្តល់នូវសិទ្ធិដូចខាងក្រោមនេះជូនដល់អ្នកនាំចូល ÷

កិច្ចព្រមព្រៀងស្តីអំពីការវាយតំលៃពន្ធគយ
មាត្រា ១៣ ១០ និង១១

- ☐ សិទ្ធិក្នុងការដកយកវិញនូវទំនិញនាំចូលពីគយនៅពេលដែលមានការយឺតយ៉ាវក្នុងការកំណត់តំលៃពន្ធគយ ប្រសិនបើគេបានធានាគ្រប់គ្រាន់ ដោយការដាក់ប្រាតិភោគ ដាក់ប្រាក់កក់ដឹកល់ ដើម្បីគ្របដណ្តប់លើការទូទាត់ពន្ធគយចំពោះតំលៃទំនិញ ដែលអាចជឿទុកចិត្តបាន
- ☐ សិទ្ធិរឹងថា គ្រប់ពត៌មានសំងាត់ដែលគេបានផ្តល់ទៅអោយគយត្រូវថែរក្សាទុកជាការសំងាត់
- ☐ សិទ្ធិក្នុងការតវ៉ា ដោយគ្មានញញើតនឹងការផាកពិន័យ ដល់អង្គការឯករាជ្យនៅក្នុងរដ្ឋបាលគយ និងដល់អាជ្ញាធរច្បាប់ ដើម្បីប្រឆាំងតវ៉ាទៅនឹងការសំរេចរបស់គយ

ជំពូក ៨

ការត្រួតពិនិត្យមុនពេលដឹកជញ្ជូន

សេចក្ដីសង្ខេប

ចាប់តាំងពីពាក់កណ្ដាលសតវត្សទី ២០ មក អ្នកនាំចូលទាំងឡាយបានប្រើប្រាស់សេវាកម្មរបស់ក្រុមហ៊ុនត្រួតពិនិត្យឯកជនឯករាជ្យមួយ អោយធ្វើការផ្ទៀងផ្ទាត់គុណភាព និងបរិមាណផលិតផលដែលគេចង់នាំចូល ។ ក្នុងករណីភាគច្រើន ការត្រួតពិនិត្យទាំងនេះត្រូវធ្វើឡើងមុនពេលដឹកជញ្ជូន និងនៅក្នុងប្រទេសនាំចេញ ដើម្បីធានាចំពោះអ្នកនាំចូល ថាទំនិញទាំងនោះ មានលក្ខណៈស្របទៅតាមយថាប្រភេទបច្ចេកទេស និងស្តង់ដារគុណភាពដែលបានកំណត់នៅក្នុងកិច្ចសន្យា ហើយបរិមាណដែលត្រូវនាំចេញក៏ត្រឹមត្រូវដែរ។ មិនត្រឹមតែក្រុមហ៊ុនអាជីវកម្មឯកជនទេ ដែលប្រើប្រាស់សេវាកម្មរបស់បណ្តាក្រុមហ៊ុនត្រួតពិនិត្យនោះ សូម្បីតែសហគ្រាសរដ្ឋ និងនាយកដ្ឋានរដ្ឋាភិបាលក៏ប្រើប្រាស់សេវាកម្មនោះដែរ ។ ជាក់ស្តែង បទបញ្ជានៅក្នុងបណ្តាប្រទេសជាច្រើន ទាមទារអោយក្រុមហ៊ុនត្រួតពិនិត្យឯកជនដែលមានសមត្ថភាព និងឯករាជ្យធ្វើការត្រួតពិនិត្យ និងបញ្ជាក់លើគុណភាព និងបរិមាណទំនិញទាំងឡាយដែលផ្គត់ផ្គង់ដោយនាយកដ្ឋានរដ្ឋាភិបាល ។

ចាប់ពីពាក់កណ្តាលទសវត្សទី ៦០ រដ្ឋាភិបាលនៃបណ្តាប្រទេសកំពុងអភិវឌ្ឍន៍មួយចំនួន ក៏ប្រើប្រាស់សេវាកម្មត្រួតពិនិត្យមុនពេល (PSI) ដឹកជញ្ជូនរបស់ក្រុមហ៊ុនមួយចំនួនដែរ ព្រោះចង់អោយក្រុមហ៊ុននោះត្រួតពិនិត្យទំនិញដែលត្រូវនាំចូល និងផ្ទៀងផ្ទាត់តំលៃទំនិញមុនពេលដឹកជញ្ជូន និងនៅក្នុងប្រទេសនាំចេញ ។ គោលបំណងជាមូលដ្ឋានក្នុងការត្រួតពិនិត្យនេះ គឺដើម្បីគ្រប់គ្រងការគិតប្រាក់លើស ឬ ខ្វះក្នុងវិក័យប័ត្រនៃទំនិញដែលត្រូវនាំចូល និងភាពមិនយុត្តិធម៌ ឬ ការអនុវត្តន៍មិនសមស្របផ្សេងទៀត ។ បច្ចុប្បន្នមានប្រទេសជាង ៣០ នៅអាហ្វ្រិក អាស៊ី និងអាមេរិកឡាទីន ប្រើប្រាស់សេវាកម្មនេះ ÷

- ☐ *ដើម្បីធ្វើការត្រួតពិនិត្យជារូបវន្តទៅលើទំនិញដែលត្រូវនាំចូល ដើម្បីធានាអោយទំនិញទាំងនោះស្របទៅតាមលក្ខខណ្ឌនៃកិច្ចសន្យា។*
- ☐ *ដើម្បីផ្ទៀងផ្ទាត់តំលៃ និង*
- ☐ *ដើម្បីធានាអោយអ្នកនាំចេញបែងចែកទំនិញទាំងនោះតាមប្រភេទ នៃចំណាត់ថ្នាក់ពន្ធគយរបស់ប្រទេសនាំចូលអោយបានត្រឹមត្រូវ ។*

ការត្រួតពិនិត្យទំនិញជារូបវន្ត គឺជាផ្នែកមួយនៃនីតិវិធីដែលបានអនុម័តដោយបណ្តាក្រុមហ៊ុន PSI ដើម្បីធានាថាតំលៃដែលអ្នកនាំចេញបានកំណត់នៅក្នុងវិក័យប័ត្រនោះ គឺជាតំលៃទំនិញពិតប្រាកដ ហើយមិនមានការគិតថ្លៃលើស ឬ ខ្វះឡើយ ។ ការត្រួតពិនិត្យនេះ ធានាអោយអ្នកនាំចូលជឿជាក់ថា ទំនិញដែលគេបានបញ្ជាទិញនោះ មានលក្ខណៈស្របទៅតាមយថាប្រភេទដែលមានកំណត់ក្នុងកិច្ចសន្យា និងស្របតាមស្តង់ដារគុណភាព ដូច្នេះតាមរយៈទង្វើនេះអាចជួយកាត់បន្ថយលទ្ធភាពដែលអាចមានវិវាទបន្ទាប់ពីទំនិញបានមកដល់គោលដៅ ។ ការត្រួតពិនិត្យនេះ ក៏ជួយទប់ស្កាត់ការនាំចូលទំនិញណាដែលចាត់ទុកថា ជាទំនិញបង្កគ្រោះថ្នាក់ដល់សុខភាព និងរាំងមិនអោយមានការលក់ទំនិញទាំងនោះ (ឧទាហរណ៍ ផលិតផលឱសថ និងគីមីដែលហាមឃាត់ ផលិតផលស្បៀងក្រោមស្តង់ដារ) នៅក្នុងបណ្តាប្រទេសនាំចេញ ។

ការត្រួតពិនិត្យជារូបវន្ត និងការផ្ទៀងផ្ទាត់តំលៃទំនិញស្ទើរតែទាំងអស់នោះមុនពេលនាំចេញ នៅក្នុងបណ្តាប្រទេសភាគច្រើនដែលប្រើប្រាស់សេវាកម្ម PSI គឺជាកាតព្វកិច្ចរបស់អ្នកនាំចូលដែលត្រូវសុំការអនុញ្ញាត ។ នៅក្នុងប្រទេសណា ដែលប្រព័ន្ធនេះគឺជា

ប្រព័ន្ធស្ម័គ្រចិត្ត នោះអ្នកនាំចូលដែលប្រើប្រាស់សេវាកម្មPSI មានសិទ្ធិរៀបចំបែបបទគយ ដោយមិនមានការពិនិត្យពិច័យបន្ថែម ទៅលើតំលៃដែលបញ្ជាក់ដោយក្រុមហ៊ុនដែលពាក់ព័ន្ធនោះទេ ។

បណ្តាប្រទេសភាគច្រើន ដែលប្រើប្រាស់សេវាកម្ម PSI អាចលើកលែងមិនត្រួតពិនិត្យចំពោះទំនិញណាដែលមានតំលៃទាបជាងកំរិតកំណត់ ។

កម្មវត្ថុក្នុងការប្រើប្រាស់សេវាកម្ម PSI

កិច្ចសន្យាត្រួតពិនិត្យមុនពេលដឹកជញ្ជូនតាមច្បាប់ អាចចាត់ទុកថាមាន ២ ប្រភេទធំៗ ដោយអនុលោមទៅតាមគោលបំណងនៃការប្រើប្រាស់សេវាកម្មរបស់ក្រុមហ៊ុន PSI នេះ ។ ពាក្យដែលក្រុមហ៊ុន PSI បានប្រើប្រាស់មានកិច្ចសន្យារូបិយប័ណ្ណបរទេស និងកិច្ចសន្យាគយ ។ ពាក្យទីមួយ ជាធម្មតាត្រូវបានប្រើប្រាស់ដើម្បីកំណត់ពីកិច្ចសន្យា ដែលកម្មវត្ថុជាមូលដ្ឋាន (និងដែលរដ្ឋាភិបាលទាមទារអោយមាន) គឺការពាររាំងមិនអោយមានការហូរមូលធនចេញតាមរយៈការគិតប្រាក់លើសក្នុងវិក័យប័ត្រ ។ ពាក្យទី ពីរ ត្រូវបានប្រើប្រាស់សំរាប់ការអនុវត្តន៍កិច្ចសន្យា នៅពេលដែលរដ្ឋាភិបាលមានគោលបំណងរាំងមិនអោយប្រាក់ចំណូលពន្ធធ្លាក់ចុះដោយសារតែការវាយតំលៃទាបមិនត្រឹមត្រូវ ឬ ដោយសារពាណិជ្ជករចាត់ថ្នាក់ទំនិញដែលត្រូវធ្វើការនាំចូល ក្នុងជំពូកទំនិញដែលមានពន្ធគយទាប ។

រហូតមកដល់ប៉ុន្មានឆ្នាំមុននេះ រដ្ឋាភិបាលមានកម្មវត្ថុជាច្រើន រាំងមិនអោយមានការអោយថ្លៃហួសទៅលើការនាំចូល ។ ពាណិជ្ជករមានបំណងអោយថ្លៃហួសលើការនាំចូល នៅពេលដែលពាណិជ្ជកម្មនាំចូល និងការងារផ្លាស់ប្តូររូបិយប័ណ្ណបរទេស ស្ថិតនៅក្រោមការដាក់កំហិត ។ ជាលទ្ធផល នៅពេលដែលបណ្តាប្រទេសកំពុងអភិវឌ្ឍន៍បានចាត់វិធានការ ដើម្បីធ្វើសេរីភាវូបនីយកម្មរបបពាណិជ្ជកម្ម និងរូបិយប័ណ្ណបរទេសរបស់គេ ពាណិជ្ជករបច្ចុប្បន្ន មិនមានការលើកទឹកចិត្តណាមួយ ដើម្បីអោយថ្លៃហួសលើទំនិញនាំចូលរបស់គេឡើយ ។ ដូចដែលមានបង្ហាញនៅក្នុងវណ្ឌ ១៣ លទ្ធផលគឺថា កិច្ចសន្យា PSI ភាគច្រើន បច្ចុប្បន្នជាកិច្ចសន្យាគយគោលបំណងសំខាន់នៃកិច្ចសន្យានោះ គឺការចង់អោយបាននូវការវាយតំលៃទាបលើទំនិញនាំចូល ដើម្បីធានាអោយមានការប្រមូលប្រាក់ចំណូលពន្ធបានពេញលេញ និងត្រឹមត្រូវនិងដើម្បីគ្រប់គ្រងអំពើពុករលួយដែលពាក់ព័ន្ធនឹងគយ ។

ខណៈពេលដែលបច្ចុប្បន្នមានការប្រើប្រាស់សេវាកម្ម PSI យ៉ាងច្រើន ក្នុងការត្រួតពិនិត្យទំនិញមុនដឹកជញ្ជូននាំចេញ រដ្ឋាភិបាលមួយចំនួនតូចក៏ប្រើប្រាស់សេវាកម្មនេះ ដើម្បីគ្រប់គ្រងការហូរចេញនូវមូលធនតាមរយៈការអោយតំលៃទាបលើទំនិញនាំចេញ ។

បច្ចុប្បន្ន មានក្រុមហ៊ុន PSI ចំនួន ៥ ដែលផ្តល់សេវាកម្មត្រួតពិនិត្យមុនដឹកជញ្ជូន នៅទូទាំងពិភពលោក ឬ ទូទាំងតំបន់ ។ ក្រុមហ៊ុនដែលធំជាងគេបំផុត គឺក្រុមហ៊ុន Societe general de surveillance (SGS) ដែលស្ថិតនៅទីក្រុងហ្សឺណែវ ។ ក្រុមហ៊ុននេះមានសាខាជាង ១៣០ ដែលមានវត្តមាននៅបណ្តាប្រទេសជាង ១៤០ ហើយមានបុគ្គលិកជាង ៣០ ០០០ នាក់។ ឯក្រុមហ៊ុនបួនទៀត គឺក្រុមហ៊ុន BIVAC International នៅទីក្រុងប៉ារីស ក្រុមហ៊ុន COTECNA នៅទីក្រុងហ្សឺណែវ និងក្រុមហ៊ុន Inchape Testing Service International (ITSI) នៅទីក្រុងឡុងដ៍ និងក្រុមអធិការកិច្ច របស់សហរដ្ឋអាមេរិក ។ ក្រុមហ៊ុនទាំងនេះ ជាសមាជិកនៃគណៈកម្មាធិការត្រួតពិនិត្យមុនពេលដឹកជញ្ជូន របស់ភ្នាក់ងារត្រួតពិនិត្យសហព័ន្ធអន្តរជាតិ (IFIA) ។ មានទស្សនីយភាពបង្ហាញថា នាពេលអនាគត អាចមានមានក្រុមហ៊ុនផ្សេងៗទៀត ដែលផ្តល់សេវាកម្មដូចគ្នាច្រើន ឬ តិចចូលមកក្នុងទីផ្សារនេះដែរ ។

សាធារណៈនៃការចរចារលើកិច្ចព្រមព្រៀង PSI

ការឯកភាពលើការពង្រីកសេវាកម្ម PSI ដើម្បីផ្ទៀងផ្ទាត់តំលៃស្របច្បាប់ រវាងអ្នកនាំចូល និងអ្នកនាំចេញ នឹងត្រូវពិនិត្យមើលឡើងវិញដោយអាជីវកម្ម និងឧស្សាហកម្មដែលពាក់ព័ន្ធ ជាពិសេសនៅក្នុងបណ្តាជឿនលឿនមួយចំនួន ។ បណ្តាប្រទេសទាំង

នោះ មានការព្រួយបារម្ភជាពិសេសទៅលើកត្តាដែលថា អាចមានការស្នើសុំអោយពួកគេកែប្រែតំលៃបញ្ចុះមកវិញ នៅពេលដែលបណ្តាក្រុមហ៊ុន PSI រកឃើញពីការអោយថ្លៃលើសពីថ្លៃតាមកិច្ចសន្យា ។ គេតវ៉ាថា អ្នកនាំចេញ មិនមែនជានិច្ចជាកាលបានដឹងពីលក្ខណៈវិនិច្ឆ័យដែល PSI បានប្រើប្រាស់ ដើម្បីប្រៀបធៀបតំលៃនោះឡើយ ។ កង្វះខាតតំលាភាព មិនត្រឹមតែបង្កើតអោយមានភាពមិនច្បាស់លាស់ប៉ុណ្ណោះអំពីលទ្ធភាពនៃការទទួលយល់ព្រមលើតំលៃដែលបានចរចាជាមួយអ្នកទិញប៉ុណ្ណោះទេ ប៉ុន្តែក៏ធ្វើអោយអ្នកនាំចេញស្ថិតនៅក្នុងស្ថានភាពដែលបាត់បង់អត្ថប្រយោជន៍ ដោយសារមិនមាននីតិវិធីសំរាប់តវ៉ាទៅអង្គភាពឯករាជ្យណាផ្សេងប្រឆាំងនឹងសេចក្តីសំរេចរបស់បណ្តាក្រុមហ៊ុន PSI ។ ភាពយឺតយ៉ាវក្នុងការត្រួតពិនិត្យជារូបវន្ត និងការផ្ទៀងផ្ទាត់តំលៃ ក៏ធ្វើអោយមានការយឺតយ៉ាវក្នុងការដឹកជញ្ជូន ដែលជាការបន្ថែមចំណាយទៅលើអ្នកនាំចេញ ។

កិច្ចព្រមព្រៀងស្តីពីការត្រួតពិនិត្យមុនពេលដឹកជញ្ជូន ដែលបានចរចានៅក្នុងសម័យប្រជុំ Uruguay Round មានបំណងលប់ចោលតុល្យភាពរវាងការព្រួយបារម្ភដែលលើកឡើងដោយសហគ្រាសនាំចេញនៅក្នុងបណ្តាប្រទេសជឿនលឿន និងតំរូវការក្នុងការការពារផលប្រយោជន៍ជាសំខាន់របស់បណ្តាប្រទេសកំពុងអភិវឌ្ឍន៍ ដែលចាត់ទុកសេវាកម្ម PSI ជាសេវាកម្មមានប្រយោជន៍ ។ មានការស្រាយបំភ្លឺថា បទបញ្ញត្តិទាំងឡាយនៃកិច្ចព្រមព្រៀង អនុវត្តទៅលើសកម្មភាពមុនពេលដឹកជញ្ជូន ដែលធ្វើនៅក្នុងបណ្តាប្រទេសនាំចេញ តាមរដ្ឋាភិបាលបានចុះកិច្ចសន្យា ឬ បានប្រគល់អាណត្តិអោយប៉ុណ្ណោះ ។ ពាក្យថា " ត្រួតពិនិត្យមុនពេលដឹកជញ្ជូន " ត្រូវបានកំណត់ ថាជា "សកម្មភាពទាំងឡាយណាដែលទាក់ទងទៅនឹងការផ្ទៀងផ្ទាត់គុណភាព បរិមាណ តំលៃរួមមានទាំងអត្រានៃការផ្លាស់ប្តូររូបិយប័ណ្ណអន្តរជាតិ និងល័ក្ខខ័ណ្ឌហិរញ្ញវត្ថុ និង/ឬ ការចាត់ថ្នាក់ពន្ធគយលើទំនិញដែលត្រូវនាំចូលផងដែរ "។

ខណ្ឌ ១៣

ប្រទេស/តំបន់ដែលប្រើប្រាស់សេវាកម្ម

PSI ប្រទេស/តំបន់	*ប្រភេទនៃកិច្ចសន្យា PSI*
Argentina	*Customs*
Bangladesh	*Customs*
Benin	*Customs/Forex*
Bolivia	*Forex*
Burkina Faso	*Customs/Forex*
Burundi	*Customs*
Cameroon	*Customs/Forex*
Central African Republic	*Customs/Forex*
Columbia	*Customs*
Comoros	*Customs/Forex*
Cote d'Ivoire	*Customs*
Democratic Republic of Congo	*Customs*
Ecuador	*Customs*
Ghana	*Customs/Forex*
Guinea	*Customs/Forex*
Iran, Islamic Republic of	*Quantity/Quantity*
Kenya	*Customs*
Liberia	*Customs*
Madagascar	*Customs/Forex*

Malawi	*Customs*
Mauritania	*Customs/Forex*
Mexico	*Customs*
Mozambique	*Customs/Forex*
Niger	*Customs/Forex*
Nigeria	*Customs/Forex*
Paraguay	*Customs*
Peru	*Customs*
Philippines	*Customs*
Rwanda	*Customs/Forex*
Senegal	*Customs/Forex*
Sierra Leone	*Customs/FOrex*
Togo	*Customs*
Uganda	*Customs*
United Republic of Tanzania	*Customs/Forex*
Uzbekistan	*Forex*
Zanzibar	*Forex*

បទបញ្ញត្តិសំខាន់ៗនៃកិច្ចព្រមព្រៀង

បុព្វកថានៃកិច្ចព្រមព្រៀង PSI

កិច្ចព្រមព្រៀងបានទទួលស្គាល់ទៀតថា មានប្រទេសកំពុងអភិវឌ្ឍន៍មួយចំនួន កំពុងប្រើប្រាស់សេវាកម្ម PSI និងអនុញ្ញាតិអោយប្រើប្រាស់ " រហូតតរៀងទៅ និងកន្លងមក " ព្រោះសេវាកម្មនេះ មាន "លក្ខណៈចាំបាច់ ដើម្បីផ្ទៀងផ្ទាត់គុណភាព បរិមាណ ឬ តំលៃនៃទំនិញនាំចូល " ។ កិច្ចព្រមព្រៀងមានគោលបំណងជាសំខាន់ គឺកំណត់នូវគោលការណ៍ និងវិធានដែលបណ្តាប្រទេសប្រើប្រាស់សេវាកម្ម PSI និងប្រទេសនាំចូលទាំងឡាយត្រូវអនុវត្តតាម ដើម្បីធានាអោយសកម្មភាពរបស់គេមិនរារាំងដល់ការធ្វើពាណិជ្ជកម្ម។

កាតព្វកិច្ចរបស់បណ្តាប្រទេសដែលប្រើប្រាស់សេវាកម្ម PSI

កិច្ចព្រមព្រៀងនេះបានដាក់កាតព្វកិច្ចទៅលើបណ្តាប្រទេស ដែលប្រើប្រាស់សេវាកម្ម PSI អោយធានាកាត់បន្ថយ ឬ លប់បំបាត់នូវបញ្ហាជាក់ស្តែងដែលអ្នកនាំចេញត្រូវប្រឈម ដូចជាការយឺតយ៉ាវរបស់បណ្តាក្រុមហ៊ុន PSI ក្នុងការត្រួតពិនិត្យជារូបវន្ត និងការផ្ទៀងផ្ទាត់តំលៃ កង្វះខាតតំលាភាពនៅក្នុងនីតិវិធីដែលគេត្រូវអនុវត្តតាម និងប្រព្រឹត្តកម្មនៃពត៌មានសំងាត់ ។ ដើម្បីបញ្ចប់បញ្ហាទាំងនេះ កិច្ចព្រមព្រៀងនេះមានបទបញ្ញត្តិមួយចំនួនដែលគ្របដណ្តប់បញ្ហានេះ ក្នុងនោះមាន ÷

- ☐ ការពន្យា MFN និងកិច្ចប្រព្រឹត្តកម្មជាតិ
- ☐ ការការពារពត៌មានសំងាត់របស់អាជីវកម្ម
- ☐ ចៀសវាងភាពយឺតយ៉ាវមិនសមស្រប និង
- ☐ ការប្រើប្រាស់គោលការណ៍ណែនាំជាក់លាក់ក្នុងការផ្ទៀងផ្ទាត់តំលៃ

វណ្ឌ ១៤ រៀបរាប់ពីលក្ខណៈពិសេសនៃកាតព្វកិច្ចសំខាន់ៗ ដែលកិច្ចព្រមព្រៀងបានកំណត់ទៅលើបណ្តាប្រទេសដែលប្រើប្រាស់ PSI

ខណ្ឌ ១៤

កាតព្វកិច្ចចំបងរបស់បណ្តាប្រទេសដែលប្រើប្រាស់ PSI

មិនរើសអើង *: ត្រូវប្រើប្រាស់នីតិវិធី និងលក្ខណៈវិនិច្ឆ័យទៅលើអ្នកនាំចេញទាំងឡាយ តាមគោលការណ៍ស្មើភាព ។ អ្នកត្រួតពិនិត្យ ត្រូវអនុវត្តការត្រួតពិនិត្យតាមទំរង់តែមួយ (កិច្ចព្រមព្រៀងស្តីពីការត្រួតពិនិត្យមុនពេលដឹកជញ្ជូន មាត្រា ២.១) ។*

ប្រព្រឹត្តិកម្មជាតិ *: បណ្តាប្រទេសដែលប្រើប្រាស់PSI មិនត្រូវអនុវត្តសមបញ្ញាជាតិ តាមរបៀបដែលធ្វើអោយមានប្រព្រឹត្តកម្មប្រកបដោយភាពអនុគ្រោះតិច ចំពោះទំនិញដែលស្ថិតត្រួតពិនិត្យ ដោយប្រៀបធៀបជាមួយផលិតផលក្នុងស្រុក (កិច្ចព្រមព្រៀងស្តីពីការត្រួតពិនិត្យមុនពេលដឹកជញ្ជូន មាត្រា ២.២)*

ទីតាំងត្រួតពិនិត្យ *: ការត្រួតពិនិត្យជារូបវន្ត ត្រូវធ្វើឡើងនៅក្នុងប្រទេសនាំចេញ និងលើកលែងក្នុងករណីដែលមិនអាចធ្វើបាននោះ ទើបការត្រួតពិនិត្យនោះត្រូវធ្វើឡើងនៅក្នុងប្រទេសផលិត ។ (កិច្ចព្រមព្រៀងស្តីពីការត្រួតពិនិត្យមុនពេលដឹកជញ្ជូន មាត្រា ២.៣)។*

ស្តង់ដារ *: ការត្រួតពិនិត្យគុណភាព និងបរិមាណ ត្រូវធ្វើឡើងដោយអនុលោមទៅតាមស្តង់ដារដែលបានព្រមព្រៀងគ្នារវាងអ្នកទិញ និងអ្នកលក់ ឬ នៅក្នុងករណីដែលមិនមានចែងពីបញ្ហានេះ នោះគេត្រូវអនុវត្តទៅតាមស្តង់ដារអន្តរជាតិ។ (កិច្ចព្រមព្រៀងស្តីពីការត្រួតពិនិត្យមុនពេលដឹកជញ្ជូនមាត្រា ២.៤) ។*

តំលាភាព *: អ្នកនាំចេញត្រូវធានាអោយមានតំលាភាព លើរាល់ពត៌មាន ក្នុងចំណោមនោះ គឺពត៌មានស្តីពីច្បាប់ និងបទបញ្ញារបស់ប្រទេសដែលប្រើប្រាស់ពត៌មាននោះអំពីសកម្មភាព PSI និងនីតិវិធីព្រមទាំងលក្ខណៈវិនិច្ឆ័យដែលបានប្រើប្រាស់ដើម្បីធ្វើការត្រួតពិនិត្យ ។*

(កិច្ចព្រមព្រៀងស្តីពីការត្រួតពិនិត្យមុនពេលដឹកជញ្ជូន មាត្រា ២.៥ ដល់ ២.៨) *: ការការពារពត៌មានសំងាត់ ។ មិនត្រូវបញ្ចេញពត៌មានសំងាត់អោយភាគីទី ៣ បានដឹង (កិច្ចព្រមព្រៀងស្តីពីការត្រួតពិនិត្យមុនពេលដឹកជញ្ជូន មាត្រា ២.៥ ដល់ ២.១៣)។*

ការយឺតយ៉ាវ *: ត្រូវចៀសវាងការយឺតយ៉ាវដោយគ្មានមូលហេតុសមស្រប ។ (កិច្ចព្រមព្រៀងស្តីពីការត្រួតពិនិត្យមុនពេលដឹកជញ្ជូន មាត្រា ២.១៥ ដល់ ១៩)។*

ការផ្ទៀងផ្ទាត់តំលៃ *: សូមមេត្តាអាន វណ្ឌ ១៥ ។*

គោលការណ៍ណែនាំសំរាប់ផ្ទៀងផ្ទាត់តំលៃ

កិច្ចព្រមព្រៀងបានចែងថា ដើម្បីកំណត់ថា តើតំលៃនាំចេញ នោះឆ្លុះបញ្ចាំងពីតំលៃទំនិញត្រឹមត្រូវ ឬអត់ ក្រុមហ៊ុនPSI អាចធ្វើការប្រៀបធៀបតំលៃនេះជាមួយតំលៃទំនិញដូចគ្នា ឬ ប្រហាក់ប្រហែលគ្នាដែលត្រូវធ្វើការនាំចេញ ចេញពីប្រទេសនាំចេញដូចគ្នា ÷

- ទៅកាន់ប្រទេសនាំចូល ឬ
- ទៅកាន់ទីផ្សារផ្សេងទៀត

តែទោះជាយ៉ាងណាក៏ដោយ ក្នុងគោលបំណងប្រៀបធៀប គេត្រូវប្រើប្រាស់តំលៃដែលគិតសំរាប់នាំចេញ ទៅកាន់បណ្តាប្រទេសផ្សេងទៀតក្រៅពីប្រទេសនាំចូល ហើយកត្តាសេដ្ឋកិច្ច និងកត្តាផ្សេងទៀតដែលមានឥទ្ធិពលទៅលើតំលៃដែលគិតសំរាប់នាំចេញទៅប្រទេសខុសៗគ្នា ក៏ត្រូវយកមកពិចារណាផងដែរ។ ម្យ៉ាងទៀត វិធាននានាទទួលស្គាល់ថាក្រុមហ៊ុនជារឿយៗ គិតតំលៃខុសគ្នាសំរាប់ទីផ្សារទីខុសគ្នាដោយធ្វើការពិចារណាទៅលើតំរូវការ និងកំណើនជាសក្តានុពលព្រមទាំងកត្តាផ្សេងទៀតដូចជា ចំណូលក្នុងប្រជាជនម្នាក់ និងស្តង់ដារនៃជីវភាពរស់នៅ នៅក្នុងទីផ្សារទាំងនោះ ។ ពេលនោះក្រុមហ៊ុន នាំចេញអាចគិតតំលៃខ្ពស់ជាង ចំពោះការនាំចេញរបស់ប្រទេសនោះ ឧទាហរណ៍ អាវមួយដែលនាំចេញទៅអឺរ៉ុប មានតំលៃខ្ពស់ជាងតំលៃអាវនាំចេញទៅអាហ្វ្រិក ។ កិច្ចព្រមព្រៀងកំណត់ថា នៅពេលគេប្រើប្រាស់តំលៃរបស់ប្រទេសតតិយលោក ដើម្បីប្រៀបធៀបនោះកត្តាដែលទទួលខុសត្រូវលើការប្រែប្រួលតំលៃ គិតទៅលើអ្នកនាំចូលនៅក្នុងប្រទេសផ្សេងគ្នា ក៏ត្រូវលើកយកមកពិចារណាដែរ ហើយក្រុមហ៊ុន PSI មិនត្រូវ "កំណត់តាមទំនើងចិត្តនូវតំលៃទាបបំផុត ទៅលើការដឹកជញ្ជូននោះទេ " ។ ក្រៅពីនេះកិច្ចព្រមព្រៀងបានចែងទៀតថា ក្រុមហ៊ុន PSI ត្រូវរៀបចំឱ្យមានការឧបត្ថម្ភសមស្របសំរាប់ "កត្តាកែសំរួល ដែលអាចអនុវត្តបាន" មួយចំនួនទាក់ទងទៅនឹងតំលៃនាំចេញ ទំនិញដែលត្រូវត្រួតពិនិត្យជាមួយតំលៃទំនិញដូចគ្នា ឬ ប្រហាក់ប្រហែលគ្នាដែលប្រើប្រាស់សំរាប់ប្រៀបធៀបតំលៃ (សូមមេត្តាអានវណ្ណ ១៥ ដែលមានចែងលំអិត)។

ខណ្ឌ ១៥

កិច្ចព្រមព្រៀងស្តីពីការត្រួតពិនិត្យមុនពេលដឹកជញ្ជូន: បទបញ្ញត្តិស្តីពីការផ្ទៀងផ្ទាត់តំលៃ

(អត្ថបទមាត្រា ២.២០)

សមាជិកដែលជាអ្នកប្រើប្រាស់ត្រូវធានាថា ដើម្បីរារាំងការពារមិនឱ្យមានការអោយថ្លៃលើស ឬ ខ្វះក្នុងវិក័យប័ត្រ និងទប់ស្កាត់មិនឱ្យមានការក្លែងបន្លំ បណ្តាក្រុមហ៊ុនត្រួតពិនិត្យមុនពេលដឹកជញ្ជូនត្រូវធ្វើការផ្ទៀងផ្ទាត់តំលៃ ស្របទៅតាមគោលការណ៍ណែនាំដូចខាងក្រោម ៖

ក. ក្រុមហ៊ុនត្រួតពិនិត្យមុនពេលដឹកជញ្ជូនត្រូវបដិសេធ តំលៃកិច្ចសន្យាណាដែលបានព្រមព្រៀងរវាងអ្នកនាំចេញ និងអ្នកនាំចូល ប្រសិនបើគេអាចបង្ហាញពីលទ្ធផលនៃការរកឃើញតំលៃមិនត្រឹមត្រូវដោយផ្អែកទៅតាមដំណើរការផ្ទៀងផ្ទាត់តំលៃស្របទៅតាមលក្ខណៈវិនិច្ឆ័យដែលមានចែងនៅក្នុងអនុវាក្យខណ្ឌ (ខ)ដល់ (ង) ។

ខ. ក្រុមហ៊ុនត្រួតពិនិត្យមុនពេលដឹកជញ្ជូនត្រូវពឹងផ្អែក ការប្រៀបធៀបតំលៃរបស់គេសំរាប់ផ្ទៀងផ្ទាត់តំលៃនាំចេញជាមួយតំលៃនៃទំនិញដែលស្មើនាំចេញដូចគ្នា ឬ ប្រហាក់ប្រហែលគ្នាចេញពីប្រទេសនាំចេញតែមួយ ឬ ក្នុងពេលតែមួយតាមលក្ខខណ្ឌនៃការលក់ដែលអាចប្រៀបធៀបបាន និងមានភាពប្រកួតប្រជែងស្របទៅតាមការធ្វើពាណិជ្ជកម្មតាមទំនៀមទំលាប់ និងបណ្តាញនៃស្តង់ដារ បញ្ចុះតំលៃដែលអាចអនុវត្តបានណាមួយ។ ការប្រៀបធៀបធ្វើឡើងដោយផ្អែកលើកត្តាដូចតទៅ ៖

១. តំលៃដែលផ្តល់ការប្រៀបធៀបជាមូលដ្ឋានមានសុពលភាព ត្រូវបានយកមកប្រើប្រាស់ និងយកមកពិចារណានូវកត្តាសេដ្ឋកិច្ច ដែលពាក់ព័ន្ធទៅនឹងប្រទេសនាំចូល និងបណ្តាប្រទេសដែលបានប្រើប្រាស់ សំរាប់ប្រៀបធៀបតំលៃ ។

(២) ក្រុមហ៊ុនត្រួតពិនិត្យមុនពេលដឹកជញ្ជូន មិនត្រូវពឹងផ្អែកទៅលើតំលៃទំនិញដែលស្នើនាំចេញទៅកាន់បណ្តាប្រទេសនាំចូលផ្សេងៗ ដោយការកំណត់តាមទំនើងចិត្តនូវតំលៃដែលទាបបំផុតទៅលើការដឹកជញ្ជូននោះទេ។

(៣) ក្រុមហ៊ុនត្រួតពិនិត្យមុនពេលដឹកជញ្ជូន ត្រូវពិចារណាទៅលើសមាសធាតុជាក់លាក់ដែលមានរាយនាមនៅក្នុងអនុវាក្យខណ្ឌ (គ)

(៤) នៅដំណាក់កាលណាមួយនៃកិច្ចដំណើរការដែលមានរៀបរាប់ខាងលើ ក្រុមហ៊ុនត្រួតពិនិត្យមុនពេលដឹកជញ្ជូនត្រូវផ្តល់កាលានុវត្តន៍ភាពអោយអ្នកនាំចេញធ្វើការពន្យល់ពីតំលៃ

(គ) នៅពេលធ្វើការផ្ទៀងផ្ទាត់តំលៃ ក្រុមហ៊ុនត្រួតពិនិត្យមុនពេលដឹកជញ្ជូន ត្រូវផ្តល់ការអនុញ្ញាតិសមស្របតាមល័ក្ខខ័ណ្ឌនៃកិច្ចសន្យាលក់ និងកត្តាកែតំរូវដែលអាចអនុវត្តបានជាទូទៅ ទាក់ទងនឹងការងារនោះ កត្តាទាំងនេះ រួមមានតែមិនកំណត់ទៅលើកំរិតពាណិជ្ជកម្ម និងបរិមាណនៃការលក់ រយៈពេល និងល័ក្ខខ័ណ្ឌនៃការប្រគល់ ប្រយោគស្តីពីបង្កើនតំលៃ យថាប្រភេទនៃគុណភាព លក្ខណៈពិសេសនៃគំនូសបំព្រួញបច្ចេកទេស ការដឹកជញ្ជូនពិសេស ឬ យថាប្រភេទនៃការវេចខ្ចប់ ទំហំ នៃការបញ្ជាទិញ ការលក់ភ្លាមៗ ឥទ្ធិពលតាមរដូវ អាជ្ញាប័ណ្ណ ឬ តំលៃកម្មសិទ្ធិបញ្ញាផ្សេងទៀត ព្រមទាំងសេវាកម្មដែលបានផ្តល់ជូនជាផ្នែកមួយនៃកិច្ចសន្យា ប្រសិនបើមិនមានធ្វើក័យបត្រតាមទំនៀមទំលាប់ដោយឡែក ។ កត្តាទាំងនេះ ក៏ត្រូវគិតបញ្ចូលផងដែរ នូវសមាសធាតុសំខាន់ៗ មួយចំនួនពាក់ព័ន្ធទៅនឹងតំលៃរបស់អ្នកនាំចេញ ដូចជាទំនាក់ទំនងតាមកិច្ចសន្យារវាងអ្នកនាំចេញ និងនាំចូល ។

(ឃ) ការផ្ទៀងផ្ទាត់ថ្លៃឈ្នួលដឹកជញ្ជូន ពាក់ព័ន្ធមិនត្រឹមតែតំលៃដែលបានព្រមព្រៀងលើរបៀបដឹកជញ្ជូនក្នុងប្រទេសនាំចូល ដូចដែលបានបង្ហាញអោយឃើញនៅក្នុងកិច្ចសន្យានៃការលក់ប៉ុណ្ណោះទេ ។

(ង) ត្រូវប្រើប្រាស់កត្តាខាងក្រោមនេះ ដើម្បីផ្ទៀងផ្ទាត់តំលៃ ÷

(១) តំលៃលក់នៅក្នុងប្រទេសនាំចូលទំនិញ ដែលបានផលិតនៅក្នុងប្រទេសនោះ

(២) តំលៃទំនិញសំរាប់នាំចេញ ចេញពីប្រទេសមួយក្រៅពីប្រទេសនាំចេញ

(៣) ចំណាយផលិតកម្ម

(៤) តំលៃតាមទំនើងចិត្ត ឬ តំលៃដែលប្រឌិតឡើង ។

និទានផ្សេងៗ ស្តីពីការផ្ទៀងផ្ទាត់តំលៃនៅក្នុងកិច្ចព្រមព្រៀងស្តីពី PSI និងស្តីពីការវាយតំលៃទំនិញនៅក្នុងកិច្ចព្រមព្រៀងតំលៃពន្ធគយ

ភាពខុសគ្នាជាចំបងនៅក្នុងបទបញ្ញត្តិនៃកិច្ចព្រមព្រៀងទាំងពីរ

ចាប់តាំងពីរដ្ឋាភិបាលមានគោលបំណងជាចំបងក្នុងការប្រើប្រាស់សេវាកម្ម PSI ដើម្បីរារាំងមិនអោយមានការខាតបង់ប្រាក់ចំណូលពន្ធគយ ពីការអោយតំលៃទាបលើទំនិញមក មានបញ្ហាមួយចំនួនបានកើតឡើងថា តើគយត្រូវប្រើប្រាស់តំលៃដែលបានផ្តល់អោយដោយ PSI យ៉ាងដូចម្តេច ក្នុងការកំណត់តំលៃសំរាប់គោលបំណងពន្ធគយនោះ ។ បញ្ហានេះជាបញ្ហាសំខាន់ ដោយសារតាមនិយមន័យនៃតំលៃនៃទីក្រុង Brussel ប្រព័ន្ធបច្ចុប្បន្ននៅក្នុងបណ្តាប្រទេសដែលប្រើប្រាស់ PSI អាជ្ញាធរគយមានភាពបត់បែនដែលគួរអោយកត់សំគាល់ទៅលើការប្រើប្រាស់តំលៃដែលបានផ្តល់អនុសាសន៍ដោយបណ្តាក្រុមហ៊ុន PSI ក្នុងការកំណត់តំលៃគយ ។ តែទោះជាយ៉ាងណាក៏ដោយ បណ្តាប្រទេសនានាមានកាតព្វកិច្ចកែប្រែប្រព័ន្ធដែលបានកំណត់ដោយកិច្ចព្រមព្រៀងស្តីពីតំលៃពន្ធគយ នៅពេលដែលប្រទេសកំពុងអភិវឌ្ឍន៍បានពន្យាពេលយឺតយ៉ាវ ហើយហួសរយៈពេលអនុវត្តរបស់ខ្លួននាថ្ងៃទី ១ ខែ មករា ឆ្នាំ ២០០០ ។

វិន័យដែលមានលក្ខណៈតឹងតែងជាង នៅពេលដែលកិច្ចព្រមព្រៀងស្តីពីតំលៃពន្ធគយ បានដាក់កំហិតគួរអោយកត់សំគាល់ទៅលើសិទ្ធិរបស់គយ ក្នុងការប្រើប្រាស់តំលៃដែលបានផ្តល់អនុសាសន៍ដោយក្រុមហ៊ុន PSI ។ ជាងនេះទៅទៀត កិច្ចព្រមព្រៀងបានហាមឃាត់ប្រទេសមួយចំនួនមិនអោយប្រើប្រាស់តំលៃដែលគិតដោយអ្នកនាំចេញដូចគ្នាទៅលើទីផ្សារទីបីរបស់គេ ជាមូលដ្ឋានសំរាប់វាយតំលៃទេ ។ ផ្ទុយទៅវិញ ដូចដែលបានបញ្ជាក់ពីខាងលើរួចមកហើយកិច្ចព្រមព្រៀង PSI អនុញ្ញាតិអោយពួកគេប្រើប្រាស់តំលៃនោះ

ប៉ុន្តែបានកំណត់នូវគោលការណ៍ណែនាំមួយចំនួន ដែលគេត្រូវយកមកពិចារណា នៅក្នុងការផ្តល់អនុសាសន៍លើតំលៃ (សូមមេត្តាអានវណ្ឌ ១៥) ។ ដើម្បីពិចារណាទៅលើស្ថានភាពនេះ កិច្ចព្រមព្រៀងស្តីពីតំលៃពន្ធគយ បានបញ្ជាក់យ៉ាងច្បាស់ពីតួនាទីរបស់គយ ដោយលើកឡើងថា កាតព្វកិច្ចរបស់ប្រទេសដែលជាអ្នកប្រើប្រាស់ " ពាក់ព័ន្ធទៅនឹងសេវាកម្មរបស់ក្រុមហ៊ុនត្រួតពិនិត្យមុនពេលដឹកជញ្ជូន (ពាក់ព័ន្ធទៅនឹងការវាយតំលៃពន្ធគយ) គឺជាកាតព្វកិច្ចដែលគេត្រូវតែទទួលយក " តាមកិច្ចព្រមព្រៀងស្តីពីតំលៃពន្ធគយ។

ការពាក់ព័ន្ធជាក់ស្តែងនៃភាពខុសគ្នា

គោលបំណងនៃការស្រាយបំភ្លឺខាងលើ គឺដើម្បីធានាអោយរដ្ឋបាលគយនៅក្នុងប្រទេសនានា ដែលមានឧបាស្រ័យចំពោះសេវាកម្ម PSI ប្រើប្រាស់តំលៃ ដែលក្រុមហ៊ុន PSI បានផ្តល់អោយ គ្រាន់តែជាតំលៃសាកល្បង ឬ មតិយោបល់ នៅពេលផ្ទៀងផ្ទាត់រកការពិត ឬ រកភាពត្រឹមត្រូវនៃតំលៃដែលបានធ្វើប្រតិវេទន៍របស់អ្នកនាំចូលតែប៉ុណ្ណោះ ។ គយអាចប្រើប្រាស់តំលៃដែលបានផ្តល់អនុសាសន៍ជាតំលៃសាកល្បង ទោះបីជានៅពេលដែលតំលៃដែលបានផ្តល់អោយនោះ ទទួលបានតាមមូលដ្ឋាននៃតំលៃដែលគិតដោយអ្នកនាំចេញទៅលើទីផ្សារទីបី របស់គេក៏ដោយ ។

ក៏ប៉ុន្តែ គយមិនអាចកំណត់ដោយស្វ័យប្រវត្តនូវតំលៃជាប់ពន្ធសំរាប់បង់ពន្ធគយ ដោយផ្អែកលើតំលៃដែលផ្តល់អនុសាសន៍ដោយក្រុមហ៊ុន PSI ។ ដូច្នេះ ត្រូវធ្វើការត្រួតពិនិត្យរៀងរាល់ករណី ។ ប្រសិនបើផ្អែកលើការត្រួតពិនិត្យ និងការប្រៀបធៀបតំលៃដែលធ្វើប្រតិវេទន៍ដោយអ្នកនាំចូល និងដែលផ្តល់អនុសាសន៍ដោយក្រុមហ៊ុន PSI ហើយរកឃើញថា តំលៃដែលផ្តល់អនុសាសន៍ដោយ ក្រុមហ៊ុន PSI នេះផ្ទុះបញ្ជាំងពីតំលៃត្រឹមត្រូវ ហើយអ្នកនាំចូលមិនតវ៉ា ពេលនោះតំលៃត្រូវបានកំណត់ដោយផ្អែកលើមូលដ្ឋាននៃតំលៃនោះ។ ក្នុងរាល់ករណីទាំងអស់ ជាកត្តាចាំបាច់ត្រូវធានាថា ដើម្បីទទួលបាននូវតំលៃដែលបានផ្តល់អនុសាសន៍នោះ ក្រុមហ៊ុន PSI បានគោរពទៅតាមវិធានស្តីពីការកែសំរួលសមាសធាតុផ្សេងៗ (ឧទាហរណ៍ គណៈកម្មការទិញ និងគណៈកម្មការភ្នាក់ងារដាច់មុខ) ដែលបានកំណត់ដោយកិច្ចព្រមព្រៀងតំលៃពន្ធគយ ។

ជានិច្ចជាកាលមានអ្នកនាំចូលមួយចំនួន បានតវ៉ាទៅនឹងតំលៃដែលផ្តល់អនុសាសន៍ដោយ PSI ដែលគយអាចទទួលយកបាន និងអះអាងថា តំលៃដែលគេបានធ្វើប្រតិវេទន៍នោះ ពិតជាតំលៃទំនិញពិតប្រាកដ ។ អ្នកនាំចូលនោះ មានសិទ្ធិរំពឹងថា គយនឹងផ្តល់កាលានុវត្តន៍ ភាពអោយពួកគេរៀបចំឯកសារ និងភស្តុតាង ដើម្បីបញ្ជាក់ពីតំលៃដែលបានធ្វើប្រតិវេទន៍ ។ ប្រសិនបើ ក្រោយពីមានការត្រួតពិនិត្យភស្តុតាងហើយ គយនៅតែអះអាងថា តំលៃដែលបានធ្វើប្រតិវេទន៍ដោយអ្នកនាំចូលពាក់ព័ន្ធទៅនឹងការអោយតំលៃលើស ឬ ខ្វះពីវិក័យបត្រ វាមិនអាចស្ថិតនៅក្រោមបទបញ្ញត្តិនៃកិច្ចព្រមព្រៀងស្តីពីតំលៃពន្ធគយ ដោយផ្អែកលើមូលដ្ឋាននៃតំលៃដែលបានផ្តល់អនុសាសន៍ដោយ PSI[៤]។ នៅពេលតំលៃអាជីវកម្មដែលអ្នកនាំចូលបានធ្វើប្រតិវេទន៍នោះ មិនអាចទទួលយកបាន នោះគេត្រូវកំណត់តំលៃនេះដោយការប្រើប្រាស់វិធីដែលបានកំណត់នៅក្នុងកិច្ចព្រមព្រៀង ដើម្បីកំណត់តំលៃ ។ វិធីមួយចំនួន ក្នុងចំណោមនេះចែងពីការកំណត់តំលៃទំនិញនាំចូលលើមូលដ្ឋាននៃតំលៃដែលបានកំណត់ ក្នុងពេលធ្វើអាជីវកម្មជំនួញលើទំនិញដូចគ្នា ឬ ប្រហាក់ប្រហែលគ្នា ។ នៅពេលមិនអាចកំណត់តំលៃបានតាមវិធានទាំងនេះ នោះតំលៃនោះត្រូវកំណត់ដោយផ្អែកលើមូលដ្ឋាននៃតំលៃ ទំនិញនាំចូលនៅក្នុងទីផ្សារក្នុងស្រុករបស់ប្រទេសនាំចូល (តំលៃដែលអាចកាត់បន្ថយបាន) ឬ លើមូលដ្ឋាននៃចំណាយផលិតកម្ម (តំលៃដែលអាចគណនាបាន) ។

ភាតព្វកិច្ចរបស់បណ្តាប្រទេសនាំចេញ

កន្លងមក ការពិភាក្សាបានផ្តោតអារម្មណ៍ទៅលើកាតព្វកិច្ច ដែលកិច្ចព្រមព្រៀងស្តីពី PSI បានដាក់មកលើបណ្តាប្រទេសប្រើប្រាស់សេវាកម្ម PSI ដើម្បីធានាមិនអោយការអនុវត្តន៍ និងចំណាត់ការដែលបានប្រកាន់ឡើងដោយ PSI ក្លាយជារបាំងពាណិជ្ជកម្ម។ កិច្ចព្រមព្រៀងក៏បានដាក់កាតព្វកិច្ចមួយចំនួនផងដែរទៅលើបណ្តាប្រទេសដែលនាំចេញទៅកាន់បណ្តាប្រទេសដែលប្រើប្រាស់ PSI។

៤ តំលៃនេះអនុវត្តនៅពេលដែលក្រុមហ៊ុន PSI ទទួលបានតំលៃដោយការទទួលស្គាល់ស្របទៅនឹងវិធាននៃកិច្ចព្រមព្រៀង ស្តីពីតំលៃពន្ធគយ។

កាតព្វកិច្ចទាំងនេះ ត្រូវបានកំណត់នៅក្នុងកិច្ចព្រមព្រៀង ដូចជា "ប្រទេសនាំចេញដែរ" ។ កាតព្វកិច្ចចំបងដែលកិច្ចព្រមព្រៀងបានដាក់ទៅលើបណ្តាប្រទេសទាំងនេះ មានរៀបរាប់យ៉ាងសង្ខេបដូចខាងក្រោមនេះ ÷

កិច្ចព្រមព្រៀងស្តីពី PSI (មាត្រា ៣:១)

☐ មិនរើសអើង ។ ច្បាប់ និងបទបញ្ជាដែលបានអនុម័ត ដើម្បីគ្រប់គ្រងកិច្ចដំណើរការសេវាកម្ម PSI ត្រូវយកមកអនុវត្តដោយឈរលើមូលដ្ឋានមិនរើសអើង ។

កិច្ចព្រមព្រៀងស្តីពី PSI (មាត្រា ៣:៣)

☐ តំលាភាព ។ ត្រូវតែបោះពុម្ពផ្សាយ រាល់ច្បាប់ និងបទបញ្ជាទាំងឡាយ ។ កិច្ចព្រមព្រៀងស្តីពី PSI (មាត្រា ៣:២)

ដូចដែលបានបញ្ជាក់កត់សំគាល់ពីខាងលើរួចមកហើយថា កិច្ចព្រមព្រៀង គិតថា ប្រទេសកំពុងអភិវឌ្ឍន៍នឹងប្រើប្រាស់ការត្រួតពិនិត្យមុនពេលដឹកជញ្ជូន តែលើរយៈពេលខ្លីប៉ុណ្ណោះ ។ សំរាប់រយៈពេលយូរអង្វែង គឺត្រូវកាត់បន្ថយកម្មវត្ថុនៃបណ្តាប្រទេសទាំងនេះ ដែលពឹងផ្អែកទៅលើការប្រើប្រាស់សេវាកម្ម PSI ដើម្បីចាប់អោយបាននូវការអនុវត្តន៍មិនត្រឹមត្រូវរបស់គយ និងការក្លែងបន្លំ ដោយការអភិវឌ្ឍន៍បន្តិចម្តង ៗ នូវសមត្ថភាពបច្ចេកទេសរបស់រដ្ឋបាលគយរបស់គេ ដើម្បីដោះស្រាយបញ្ហាអនុវត្តនេះ ។ ដើម្បីជួយបណ្តាប្រទេសដែលប្រើប្រាស់ PSI កសាងសមត្ថភាព កិច្ចព្រមព្រៀងបានអំពាវនាវអោយបណ្តាប្រទេសនាំចេញ ផ្តល់ជំនួយការបច្ចេកទេសអោយបណ្តាប្រទេសដែលប្រើប្រាស់ PSI ដើម្បីកាត់បន្ថយបន្តិចម្តងៗ នូវពំនឹងផ្អែករបស់គេទៅលើសេវាកម្ម PSI ក្នុងការផ្ទៀងផ្ទាត់តំលៃ ។

ការពិនិត្យមើលឡើងវិញលើបទបញ្ញត្តិនៃកិច្ចព្រមព្រៀង

កិច្ចព្រមព្រៀងស្តីពី PSI (មាត្រា២:២១) មាត្រា ៤

កត្តាដែលអ្នកនាំចេញបានធ្វើការទិទៀនយ៉ាងខ្លាំងបំផុតទៅលើសកម្មភាព PSI គឺស្ថាប័នគ្មានយន្តការសំរាប់ពិចារណាទៅលើពាក្យបណ្តឹងចំពោះការធ្វើសេចក្តីតាមទំនើងចិត្ត ឬ សេចក្តីសំរេចខុស ។ ដើម្បីសំរួលដល់ការពិចារណាពាក្យបណ្តឹងនោះ កិច្ចព្រមព្រៀងបានរៀបចំ អោយមានយន្តការដោះស្រាយជាបីដំណាក់កាល ÷

ដំណាក់កាលទីមួយ កិច្ចព្រមព្រៀងបានស្នើអោយក្រុមហ៊ុន PSI តែងតាំងមន្ត្រីមួយចំនួន ដើម្បីទទួលពាក្យបណ្តឹងតវ៉ា ចំពោះសេចក្តីសំរេចរបស់ក្រុមហ៊ុន PSI នោះ ។

ដំណាក់កាលទីពីរ កិច្ចព្រមព្រៀងបានរៀបចំបង្កើតអោយមានអង្គភាពត្រួតពិនិត្យឡើងវិញឯករាជ្យមួយ (IE) ដើម្បីទទួលពាក្យបណ្តឹងពីអ្នកនាំចេញ និងអង្គភាព PSI ។ IE ត្រូវបានបង្កើតឡើងរួមគ្នាដោយ WTO សភាពាណិជ្ជកម្មអន្តរជាតិ (ICC ដែលតំណាងអោយផលប្រយោជន៍របស់អ្នកនាំចេញ) និងទីភ្នាក់ងារត្រួតពិនិត្យនៃសហពន្ធ័អន្តរជាតិ (IFIA ដែលតំណាងអោយផលប្រយោជន៍របស់ក្រុមហ៊ុន PSI)។ WTO ត្រូវទទួលខុសត្រូវលើការគ្រប់គ្រង IE ។

ដំណាក់កាលទីបី កិច្ចព្រមព្រៀងទទួលស្គាល់ពីសិទ្ធិរបស់រដ្ឋាភិបាលនៃបណ្តាប្រទេសប្រើប្រាស់សេវាកម្ម PSI និងសិទ្ធិរបស់រដ្ឋាភិបាលនៃបណ្តាប្រទេសនាំចេញ ក្នុងការប្រើប្រាស់នីតិវិធីនៃដំណោះស្រាយវិវាទរបស់ WTO ប្រសិនបើគេចាត់ទុកថា មិនមានការអនុវត្តតាមវិធាននានារបស់រដ្ឋាភិបាល ។

សហគ្រាសនាំចេញ ឬ ក្រុមហ៊ុន PSI អាចដាក់ពាក្យបណ្តឹងទៅ IE បាន ។ នៅពេលដាក់ពាក្យប្តឹងហើយ នោះគេរំពឹងថា IE នឹងធ្វើការតែងតាំងអ្នកជំនាញពាណិជ្ជកម្មមួយរូប ឬ គណៈវិនិច្ឆ័យដែលមានសមាជិកចំនួន ៣ រូប ដោយមានការយល់ព្រមពីភាគីទាំងឡាយនៃពាក្យបណ្តឹង ។ នៅពេលបង្កើតគណៈវិនិច្ឆ័យនេះរួចហើយ ICC ត្រូវតែងតាំងសមាជិកមួយរូប IFIA តែងតាំងមួយរូប និងសមាជិកទីបី គឺជាអ្នកជំនាញផ្នែកពាណិជ្ជកម្ម ដែលត្រូវធ្វើសកម្មភាពជាប្រធានត្រូវបានតែងតាំងដោយ IE ខ្លួនឯង ។ គណៈវិនិច្ឆ័យនេះ ត្រូវតំរូវអោយធ្វើសេចក្តីសំរេចដោយផ្អែកលើសំលេងភាគច្រើន នៅក្នុងរយៈពេល ៨ ថ្ងៃនៃថ្ងៃធ្វើការ រាប់ចាប់ពីថ្ងៃដែលបានដាក់ពាក្យប្តឹង ។ ត្រូវតំរូវអោយភាគីទាំងពីរនៃវិវាទ ដាក់ដឹកល់ប្រាក់សំរាប់រំលោះចំណាយដែលគណៈវិនិច្ឆ័យចំណាយ ។

ក៏ប៉ុន្តែកន្លងមកទាំងអ្នកនាំចេញ ឬ ក្រុមហ៊ុន PSI មិនមកបានយកនីតិវិធីទាំងនេះមកប្រើប្រាស់ទេ ។

ការពិនិត្យមើលឡើងវិញលើបទបញ្ញត្តិនៃកិច្ចព្រមព្រៀង

អនុសាសន៍ដែលបានអនុម័តដើម្បីស្រាយបំភ្លឺវិធាននៃកិច្ចព្រមព្រៀង

កិច្ចព្រមព្រៀងស្តីពី PSI មាត្រា ៦

កិច្ចព្រមព្រៀងកំណត់ថា ត្រូវធ្វើការពិនិត្យមើលបទបញ្ញត្តិនៃកិច្ចព្រមព្រៀងឡើងវិញ នៅចុងឆ្នាំទី ២ នៃកិច្ចដំណើរការ ។ ដើម្បីធ្វើការពិនិត្យមើលឡើងវិញនេះ អគ្គក្រុមប្រឹក្សាបានធ្វើការតែងតាំងក្រុមការងារទទួលបន្ទុកត្រួតពិនិត្យមុនពេលដឹកជញ្ជូន ។

ការងារដែលគាត់បានបំពេញ ឆ្លុះបញ្ចាំងអោយឃើញនៅក្នុងការអនុម័តលើអនុសាសន៍សំរាប់ធ្វើការស្រាយបំភ្លឺ និងកែលំអរបទបញ្ញត្តិក្នុងកិច្ចព្រមព្រៀង ។ អនុសាសន៍ទាំងនេះមានដូចខាងក្រោម ÷

☐ *ការទទួលខុសត្រូវក្នុងការកំណត់តំលៃជាប់ពន្ធគយគឺជាបន្ទុករបស់គយ* ។ ការផ្ទៀងផ្ទាត់តំលៃដោយក្រុមហ៊ុនPSI ក្នុងគោលបំណងពន្ធគយ ត្រូវបានដាក់កំហិត ដោយការផ្តល់យោបល់បច្ចេកទេស ដើម្បីសំរួលការកំណត់តំលៃគយ ដោយសមាជិកដែលជាអ្នកប្រើប្រាស់ ។ ទាក់ទងនឹងបញ្ហានេះ ការទទួលខុសត្រូវចុងក្រោយលើតំលៃពន្ធគយ និងការប្រមូលប្រាក់ចំណូល ជាបន្ទុករបស់សមាជិកប្រើប្រាស់ ។ សមាជិកជាអ្នកប្រើប្រាស់ ត្រូវតាមដានរាល់សកម្មភាពរបស់PSI ហើយទទួលបាននូវការលើកទឹកចិត្តអោយដាក់បញ្ចូលបទបញ្ញត្តិស្តីពីការតាមដានលើសកម្មភាពនេះក្នុងបទបញ្ជារដ្ឋបាល និងច្បាប់ជាតិ ។

☐ *លក្ខណៈវិនិច្ឆ័យនៃការផ្ទៀងផ្ទាត់តំលៃត្រូវបោះពុម្ពផ្សាយជាសាធារណៈ* ។ សមាជិកដែលជាអ្នកប្រើប្រាស់ ត្រូវបានតំរូវអោយ÷

- បោះពុម្ពផ្សព្វផ្សាយជាសាធារណៈនូវរាល់ឯកសារស្តីពីលក្ខណៈវិនិច្ឆ័យនៃការផ្ទៀងផ្ទាត់តំលៃ
- ជំរាបជូនអ្នកនាំចេញ និងអ្នកនាំចូលអំពីវិធីសាស្ត្រនៃការអោយតំលៃដែលអាចយកមកអនុវត្តបាន

លក្ខណៈវិនិច្ឆ័យនៃការផ្ទៀងផ្ទាត់តំលៃ ត្រូវគិតបញ្ចូលទាំងវិធីសាស្ត្រនៃការអោយតំលៃ ដូចមានចែងនៅក្នុងច្បាប់ ឬ បទបញ្ជារដ្ឋបាលរបស់សមាជិកជាអ្នកប្រើប្រាស់ ដែលបានយកមកប្រើប្រាស់ នៅពេលផ្តល់យោបល់បច្ចេកទេសលើការអោយតំលៃគយ ។ ទាក់ទងនឹងបញ្ហានេះ សមាជិកជាអ្នកប្រើប្រាស់ ត្រូវជំរុញលើកទឹកចិត្តអោយក្រុមហ៊ុន PSI ប្រើប្រាស់មធ្យោបាយអេឡិចត្រូនិក ក្នុងគោលបំណងផ្តល់ពត៌មានចាំបាច់ទៅអោយអ្នកនាំចេញ និងអ្នកនាំចូល ។

សមាជិកជាអ្នកប្រើប្រាស់ ត្រូវធានាថា សំណើសុំពត៌មាននោះ មិនមានលើសពីអ្វីដែលតំរូវដោយបទបញ្ញត្តិនៃកិច្ចព្រមព្រៀងស្តីពីការត្រួតពិនិត្យមុនពេលដឹកជញ្ជូនទេ ។ ផ្ទុយទៅវិញ សមាជិកនៃអ្នកនាំចេញ ត្រូវជូនដំណឹងដល់សមាជិកអ្នកប្រើប្រាស់ នៅពេលណាដែលគេបានដឹងថា សំណើសុំពត៌មានរបស់ក្រុមហ៊ុន PSI មានលើសពីអ្វីដែលមានចែងក្នុងមាត្រានោះ ។

☐ *តំបន់ត្រួតពិនិត្យ* ។ សមាជិកអ្នកប្រើប្រាស់ ត្រូវធានាអោយក្រុមហ៊ុន PSI រៀបចំបង្កើតការិយាល័យទាក់ទងនៅមូលដ្ឋានក្នុងបណ្តាប្រទេសដែលគេមិនធ្វើការត្រួតពិនិត្យជារូបវន្ត គឺជាការិយាល័យតំណាងនៅនឹងកន្លែង ។

☐ *ប្រើប្រាស់មធ្យោបាយប្រាស្រ័យទាក់ទងតាមអេឡិចត្រូនិក* ។ ការរៀបចំបង្កើត Web sites ដោយ IFIA និង PSI ជាមួយបណ្តាសេវាកម្ម អាចធ្វើអោយកិច្ចដំណើរការ PSI មានប្រសិទ្ធិភាពខ្ពស់ នៅក្នុងផ្នែកដូចជានីតិវិធី របៀបវីធី លក្ខណៈវិនិច្ឆ័យនៃការត្រួតពិនិត្យ ការឆ្លើយតបនឹងសំណួរផ្សេងៗ ការចែកចាយពត៌មានដែលអាចប្រើប្រាស់បាន ដែលសំខាន់ដោយអ្នកនាំចូល និងអ្នកនាំចេញ ។ ក្រៅពីនេះ ដើម្បីចែកចាយឯកសារជាលាយលក្ខអក្សរលើក្រដាស ត្រូវជំរុញលើកទឹកចិត្តអោយក្រុមហ៊ុន PSI ធ្វើការផ្សព្វផ្សាយរបាយការណ៍ចុងក្រោយស្តីពីលទ្ធផល (Clean Reports of Findings – CRFs) ទៅអោយអ្នកនាំចូល និងអ្នកនាំចេញតាមរយៈម៉ាស៊ីនអេឡិចត្រូនិក ។

---

[៥] ប្រភព : " របាយការណ៍របស់ក្រុមការងារស្តីពីការត្រួតពិនិត្យមុនពេលដឹកជញ្ជូន ដែលផ្ញើជូនទៅអគ្គក្រុមប្រឹក្សា " នាថ្ងៃទី ២ ខែ ធ្នូ ឆ្នាំ ១៩៩៧ (ឯកសារ WTO G/L ២១៤) ។

- ☐ *ចៀសវាងការយឺតយ៉ាវ* ។ សមាជិកអ្នកប្រើប្រាស់ ត្រូវធានាធ្វើយ៉ាងណាអោយក្រុមហ៊ុន PSI ចេញ CRF ទៅអោយអ្នកនាំចូល និងអ្នកនាំចេញ ក្រោយពេលដែលបានទទួលឯកសារចុងក្រោយ និងបន្ទាប់ពីបានបញ្ចប់ការត្រួតពិនិត្យហើយភ្លាម។ មិនមានករណីណាមួយដែលរយៈពេលនៃការចេញ CRF នោះមានលើសពី ៥ ថ្ងៃនៃថ្ងៃធ្វើការក្រោយពេលត្រួតពិនិត្យឡើយ។ ប្រសិនបើមិនបានចេញតាមពេលកំណត់ នោះសមាជិកអ្នកប្រើប្រាស់ ត្រូវធានាធ្វើយ៉ាងណាអោយក្រុមហ៊ុន PSI ចេញលិខិតពន្យល់លំអិតជាលាយល័ក្ខអក្សរ ដោយបញ្ជាក់ពីមូលហេតុដែលមិនបានចេញ CRF នោះ ។

- ☐ *ការការពារពត៌មានសំងាត់* ។ សមាជិកអ្នកប្រើប្រាស់ ត្រូវធានាធ្វើយ៉ាងណាអោយកិច្ចសន្យាជាមួយក្រុមហ៊ុន PSI ឬ ច្បាប់អនុវត្តជាតិ ឬ បទបញ្ជារដ្ឋបាល មានបញ្ជាក់ពីនីតិវិធីដែលក្រុមហ៊ុនត្រូវអនុវត្តតាម ដើម្បីកំណត់ថាពត៌មានដែលគេទទួលបានពីអ្នកនាំចេញ តាមកិច្ចព្រមព្រៀងជាពត៌មានសំងាត់ផ្នែកអាជីវកម្ម និងត្រូវធានាធ្វើយ៉ាងណាមិនអោយក្រុមហ៊ុន PSI ប្រើប្រាស់ពត៌មានដែលគេទទួលបាននោះ ដើម្បីគោលបំណងណាផ្សេងទៀត ក្រៅពីសកម្មភាព PSI សំរាប់សមាជិកអ្នកប្រើប្រាស់ឡើយ ។ រាល់ការបំពានទៅនឹងវិធាននៃការរក្សាការសំងាត់នេះ ដោយក្រុមហ៊ុន PSI គឺជាសកម្មភាពដែលអាចជាមូលដ្ឋានសំរាប់ធ្វើការប្តឹងតវ៉ាចំពោះក្រុមហ៊ុននេះបាន នៅក្នុងវេទិកាតុលាការ ឬ រដ្ឋបាលណាមួយរបស់សមាជិកអ្នកប្រើប្រាស់។

- ☐ *រចនាសម្ព័ន្ធថ្លៃឈ្នួល* ។ សមាជិកអ្នកប្រើប្រាស់ ត្រូវធានាធ្វើយ៉ាងណាអោយកិច្ចសន្យាជាមួយក្រុមហ៊ុន PSI ឬ ច្បាប់អនុវត្តជាតិ ឬ បទបញ្ជារដ្ឋបាល មានចែងពីរចនាសម្ព័ន្ធថ្លៃឈ្នួល ដែលមិនបង្កើតអោយមានការលើកទឹកចិត្តក្នុងការបង្កអោយការប៉ះពាល់ផលប្រយោជន៍ជាសក្តានុពល តាមវិធីណាមួយដែលមិនស្របទៅនឹងកម្មវត្ថុនៃកិច្ចព្រមព្រៀង ។ ជាបន្ថែមទៀត កិច្ចសន្យាជាមួយក្រុមហ៊ុន PSI ឬ ច្បាប់អនុវត្តជាតិ ឬ បទបញ្ជារដ្ឋបាល ត្រូវបញ្ជាក់ថា ក្រុមហ៊ុន PSI មិនត្រូវត្រួតពិនិត្យការងារណាដែលពាក់ព័ន្ធទៅនឹងផលិតផល ដែលក្នុងនោះក្រុមហ៊ុន PSI ឬ ក្រុមហ៊ុនពាក់ព័ន្ធរបស់គេ មានផលប្រយោជន៍ពាណិជ្ជកម្មឡើយ ។

- ☐ *ការពិនិត្យមើលពាក្យបណ្តឹងរបស់អ្នកនាំចេញ* ។ នៅពេលឆ្លើយតបទៅនឹងវិវាទលើការផ្ទៀងផ្ទាត់តំលៃ សមាជិកត្រូវធានាធ្វើយ៉ាងណាអោយក្រុមហ៊ុន ផ្តល់នូវការពន្យល់លំអិតជាលាយល័ក្ខអក្សរក្នុងរយៈពេល ១០ ថ្ងៃ បន្ទាប់ពីបានទទួលពាក្យបណ្តឹង ហើយក្នុងលិខិតពន្យល់នោះត្រូវបញ្ជាក់ពីមូលដ្ឋាននៃការអោយយោបល់លើតំលៃ ដោយយោងទៅលើសមាសធាតុនៃលក្ខណៈវិនិច្ឆ័យលើការផ្ទៀងផ្ទាត់តំលៃ ដែលអាចអនុវត្តបានជាក់លាក់ ។

- ☐ *ការប្រើប្រាស់កិច្ចសន្យាគំរូ* ។ សមាជិកត្រូវធានាធ្វើយ៉ាងណាអោយកិច្ចសន្យាមានលក្ខណៈស្របទៅតាមបទបញ្ញត្តិនៃកិច្ចព្រមព្រៀង PSI និងជំរុញអោយអោយមានការពិចារណាទៅលើគំរូកិច្ចសន្យា នៅពេលណាដែលអាចធ្វើទៅបាន ហើយដែលគំរូនោះបានរៀបចំឡើងដោយភាគីជាក្រុមការងារ (Working Party)។

- ☐ *ភាពដែលអាចជ្រើសរើសបាន និងការវាយតំលៃលើហានិភ័យ* ។ សមាជិកត្រូវពិនិត្យមើលការបញ្ចូលគោលការណ៍ស្តីពីការជ្រើសរើស និងការវាយតំលៃលើហានិភ័យនៅក្នុងកិច្ចសន្យារបស់គេ ។

- ☐ *ការធ្វើសវនកម្ម PSI* ។ សមាជិកដែលចង់អោយមានសវនកម្មលើកម្មវិធី PSI របស់គេ ត្រូវអនុវត្តតាមគោលការណ៍ដែលបានរៀបចំឡើងដោយភាគីការងារ ឬ ដើម្បីធានាថា នៅពេលដែលមានការប្រើប្រាស់លក្ខណៈវិនិច្ឆ័យណាមួយផ្សេងក៏ដោយ ក៏ត្រូវតែគោរពទៅតាមគោលការណ៍នៃកិច្ចព្រមព្រៀង PSI ដែរ ។

- ☐ *ជំនួយការបច្ចេកទេស* ។ បណ្តាប្រទេសជឿនលឿន ត្រូវធ្វើយ៉ាងណាអោយបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ ទទួលបាននូវជំនួយការបច្ចេកទេសចាំបាច់ សំរាប់កសាងសមត្ថភាពក្នុងស្រុក ដើម្បីសំរេចបាននូវសម័យអន្តរកាលពី PSI ។

ការតាមដាននាពេលអនាគត

នៅពេល PSI ជាចំណុចមួយក្នុងរបៀបវារៈ នោះការតាមដាននាពេលអនាគតនៃកិច្ចព្រមព្រៀង PSI ត្រូវអនុវត្តជាដំបូងនូវ និងត្រូវអនុវត្តឡើងដោយគណៈកម្មាធិការកំណត់តំលៃពន្ធគយ ។

ការពាក់ព័ន្ធផ្នែកអាជីវកម្ម

ជាសំខាន់ត្រូវកត់សំគាល់ថា កិច្ចព្រមព្រៀងបានចែងថា បណ្តាប្រទេសដែលប្រើប្រាស់សេវាកម្ម របស់ក្រុមហ៊ុន PSI ដើម្បីផ្ទៀងផ្ទាត់តំលៃ អាចធ្វើបានតែក្នុងរយៈពេលបណ្តោះអាសន្នតែប៉ុណ្ណោះ ។ កម្មវត្ថុក្នុងរយៈពេលយូរអង្វែង គឺការកាត់បន្ថយបន្តិចម្តងៗនូវពឹងផ្អែកទៅលើការប្រើប្រាស់សេវាកម្មទាំងនេះ ដោយការអភិវឌ្ឍន៍សមត្ថភាពមន្ត្រីគយរបស់គេ ដើម្បីចាប់អោយបាននូវករណីអោយតំលៃទាប និងការអនុវត្តន៍មិនត្រឹមត្រូវផ្សេងទៀត ។

ចំណាត់ថ្នាក់នៃវិធាននៃកិច្ចព្រមព្រៀង PSI ដូចដែលបានរៀបរាប់ខាងលើ គឺមានបំណងកាត់បន្ថយជាបន្ថែមទៀត ប្រសិនបើមិនអាចលប់បំបាត់បានពេញលេញ នូវការលំបាកដែលសហគ្រាសបានជួបប្រទះនៅក្នុងការនាំចេញទៅបណ្តាប្រទេសដែលប្រើប្រាស់សេវាកម្ម PSI ។ ក្រៅពីនេះ កិច្ចព្រមព្រៀងបានបង្កើតអោយមានយន្តការសំរាប់ពិចារណាទៅលើពាក្យបណ្តឹងផងដែរ ។ ទង្វើនេះផ្តល់លទ្ធភាពអោយអ្នកនាំចេញដាក់ពាក្យបណ្តឹងទៅមន្ត្រីជាន់ខ្ពស់ដែលបានតែងតាំងរបស់ក្រុមហ៊ុនត្រួតពិនិត្យ ប្រសិនបើគេមានជំនឿថា អ្នកត្រួតពិនិត្យផ្ទៀងផ្ទាត់បានកែប្រែតំលៃរបស់គេតាមទំនើងចិត្ត ហើយបើគេមិនពេញចិត្តនោះ គេអាចអាចដាក់ពាក្យបណ្តឹងរបស់គេទៅអោយអង្គភាពត្រួតពិនិត្យឯករាជ្យណាមួយ ដែលបានបង្កើតឡើងតាមកិច្ចព្រមព្រៀងនេះ ។

រដ្ឋាភិបាលនៃបណ្តាប្រទេសដែលប្រើប្រាស់សេវាកម្ម PSI អាចទទួលផលចំណេញពីចំណូលគយដែលកើនឡើង ដោយសារការរកឃើញនូវការអោយតំលៃទាប និងពីការធ្លាក់ចុះនៃកំណើនមូលធន តាមរយៈការអោយតំលៃលើស ។ ការប្រើប្រាស់សេវាកម្ម PSI ក៏នាំមកនូវផលប្រយោជន៍ដោយផ្ទាល់ផងដែរដល់សហគ្រាសអាជីវកម្ម ។ ទីមួយ វាជំរុញអោយមានការត្រួតពិនិត្យទំនិញអោយបានឆាប់ ។ ទីពីរ ការប្រើប្រាស់សេវាកម្ម PSI បន្ថយចុះនូវកិរិតអំពើពុករលួយពាក់ព័ន្ធនឹងគយ ដោយការកាត់បន្ថយតំរូវការនៃការទូទាត់ក្រៅផ្លូវការលើទំនិញនាំចូល ដែលត្រូវត្រួតពិនិត្យគយ ។ ទីបី នៅពេលធ្វើការផ្ទៀងផ្ទាត់តំលៃ ក្រុមហ៊ុន PSI ធ្វើការត្រួតពិនិត្យទំនិញដែលត្រូវនាំចូលជារូបវន្ត ដើម្បីធានាអោយគុណភាព និងបរិមាណនៃទំនិញទាំងនោះស្របទៅតាមល័ក្ខខ័ណ្ឌដែលមានចែងនៅក្នុងកិច្ចសន្យារវាងអ្នកនាំចូល និងអ្នកនាំចេញ ។ លើកលែងតែក្នុងករណីដែលតំលៃនៃការនាំចូលមានទាប ដែលមិនចាំបាច់ធ្វើការត្រួតពិនិត្យ ហើយអ្នកនាំចូលទទួលបាននូវការធានាអះអាងថា ទំនិញដែលគេត្រូវទទួលបាននោះ នឹងមានលក្ខណៈស្របទៅតាមល័ក្ខខ័ណ្ឌក្នុងកិច្ចសន្យារបស់គេ ។ តែទោះជាយ៉ាងណាក៏ដោយ នៅពេលក្រុមហ៊ុន PSI ចុះកិច្ចសន្យាជាមួយរដ្ឋាភិបាល អ្នកនាំចូលមិនមានសិទ្ធិឧបាស្រ័យចំពោះក្រុមហ៊ុនទាំងនេះទេ ប្រសិនបើគេ (អ្នកនាំចូល) រកឃើញពិតប្រាកដថា ទំនិញដែលនាំចូលនោះជាក់ស្តែងមិនស្របទៅតាមល័ក្ខខ័ណ្ឌក្នុងកិច្ចសន្យា ។

ជំពូក ៥

ស្តង់ដារផលិតផលចាំបាច់ និងស្ម័គ្រចិត្ត បទបញ្ញាអនាម័យ និងភូតគាមអនាម័យ

សេចក្តីសង្ខេប

ជារឿយៗ បណ្តាប្រទេសជាច្រើនទាមទារអោយផលិតផលនាំចូល មានលក្ខណៈស្របទៅតាមស្តង់ដារចាំបាច់ ដែលគេបានអនុម័ត ដើម្បីការពារសុខភាព និងសុវត្ថិភាពប្រជាជន ឬ ដើម្បីរក្សាបរិស្ថានរបស់គេ ។

កិច្ចព្រមព្រៀងស្តីពីរបាំងបច្ចេកទេសទៅលើពាណិជ្ជកម្ម (TBT) ចែងថា ប្រទេសនានាមិនគួរយកស្តង់ដារផលិតផលចាំបាច់បែបនោះ មកអនុវត្តទេ ដោយសារវាអាចក្លាយជាឧបសគ្គមិនចាំបាច់រាំងដល់ពាណិជ្ជកម្មអន្តរជាតិ ។ ជាងនេះទៅទៀត ស្តង់ដារដែលអាចយកមកអនុវត្តបាន គួរផ្អែកទៅលើព័ត៌មាន និងភស្តុតាងវិទ្យាសាស្ត្រ ។

តាមទស្សនៈនៃកិច្ចព្រមព្រៀងនេះ ស្តង់ដារផលិតផលចាំបាច់ មិនត្រូវបង្កើតនូវរបាំងពាណិជ្ជកម្មមិនចាំបាច់ទេ ប្រសិនបើស្តង់ដារនោះផ្អែកទៅលើស្តង់ដារដែលបានព្រមព្រៀងជាអន្តរជាតិ ។ ដោយសារមូលហេតុភូមិសាស្ត្រ អាកាសធាតុ និងមូលហេតុផ្សេងៗទៀត មិនអាចផ្តល់លទ្ធភាពអោយបណ្តាប្រទេសជាសមាជិកពឹងពាក់ទៅលើបទបញ្ញាចាំបាច់របស់គេស្តីពីបទបញ្ញាអន្តរជាតិបាន នោះគេត្រូវមានកាតព្វកិច្ចបោះពុម្ពផ្សាយបទបញ្ញាទាំងនេះក្នុងទំរង់ជាពង្រាង ដើម្បីផ្តល់កាលានុវត្តភាពអោយផលិតករនៅក្នុងបណ្តាប្រទេសផ្សេងទៀត ផ្តល់មតិណែនាំលើបទបញ្ញានោះបាន ។ កិច្ចព្រមព្រៀងក៏កំណត់កាតព្វកិច្ចអោយប្រទេសជាសមាជិកទទួលយកមតិណែនាំនោះមកពិចារណា នៅពេលរៀបចំសំរេចស្តង់ដារ ដើម្បីធានាអោយមានការពិចារណាអោយបានគ្រប់គ្រាន់ទៅលើលក្ខណៈសម្បត្តិនៃផលិតផលដែលត្រូវផលិតនៅក្នុង និង នាំចេញដោយបណ្តាប្រទេសផ្សេងទៀត ។

ស្តង់ដារផលិតផលស្ម័គ្រចិត្ត គឺជាស្តង់ដារដែលធ្វើឡើងដោយគ្មានការចាំបាច់ ឬ ដោយគ្មានការកំណត់ដោយច្បាប់ ហើយអាចបង្កើតអោយមានបញ្ហាផងដែរនៅក្នុងពាណិជ្ជកម្មអន្តរជាតិ ប្រសិនបើស្តង់ដារនេះមានលក្ខណៈខុសគ្នាពេកពីប្រទេសមួយទៅប្រទេសមួយ។ ក្រមសីលធម៌ដែលល្អក្នុងការរៀបចំ (Code of Good Practice for the Preparation) ការអនុម័ត និងការអនុវត្តន៍ស្តង់ដារ ដែលជាផ្នែកមួយនៃកិច្ចព្រមព្រៀងស្តីពី TBT បានជំរុញអោយប្រទេសនានាខិតខំប្រឹងប្រែងយ៉ាងអស់ពីសមត្ថភាព ក្នុងការទាមទារអោយអង្គភាពស្តង់ដារជាតិ ប្រើប្រាស់គោលការណ៍ និងវិធានដូចគ្នា ក្នុងការរៀបចំ និងអនុវត្តស្តង់ដារស្ម័គ្រចិត្ត ដូចមានចែងសំរាប់ស្តង់ដាចាំបាច់ ។

បណ្តាប្រទេសនានា ក៏ទាមទារអោយផលិតផលកសិកម្មនាំចេញ មានលក្ខណៈស្របតាមបទបញ្ញាអនាម័យ និងភូតគាមអនាម័យរបស់ជាតិគេដែរ ។ បទបញ្ញាទាំងនេះមានគោលបំណងជាសំខាន់ គឺការពារមនុស្សជាតិ សត្វ ឬ រុក្ខជាតិ ឬ សុខភាពពីសត្វល្អិតចង្រៃ និងជំងឺផ្សេងៗ ដែលអាចកើតមានតាមរយៈផលិតផលកសិកម្មដែលនាំចូល ។ វិធានដែលកិច្ចព្រមព្រៀងស្តីពីការអនុវត្តន៍វិធានការអនាម័យ និងភូតគាមអនាម័យ (SPS) បានកំណត់ គឺមានដូចគ្នានឹងវិធានដែលអាចអនុវត្តបានទៅលើស្តង់ដារផលិតផលចាំបាច់ដែរ ។ តែទោះជាយ៉ាងណាក៏ដោយ ក៏នៅមានភាពខុសគ្នាមួយចំនួន ។

កិច្ចព្រមព្រៀងស្តីពីTBT ទាមទារអោយមានការអនុវត្តន៍ស្តង់ដារផលិតផលចាំបាច់លើផលិតផលនាំចូល ដោយឈរលើមូលដ្ឋានមិនរើសអើង ។ ក៏ប៉ុន្តែ បទបញ្ញាអនាម័យ និងភូតគាមអនាម័យ ជាពិសេសបទបញ្ញាដែលមានបំណងបង្ការមិនអោយជំងឺសត្វ

ឬ ដំណាំក្នុងជាតិ ផ្សឹងសត្វចូលមកក្នុងប្រទេស អាចពាក់ព័ន្ធទៅនឹង " កំរិតនៃការមានជំងឺ ឬសត្វល្អិតចង្រៃណាមួយមានច្រើនលើសលប់ជាក់លាក់ "(Level of prevalence of specific disease or pest) និងអាចត្រូវបានអនុវត្តឡើងយ៉ាងលំបាកលើការនាំចូលពីបណ្តាប្រទេសដែលជំងឺ ឬ សត្វល្អិតចង្រៃនោះមានច្រើនលើសលប់ ។ កិច្ចព្រមព្រៀងស្តីពី SPS បានអនុញ្ញាតិបន្ថែមទៀតអោយបណ្តាប្រទេសនានាចាត់វិធានការក្នុងការដាក់កំហិតលើការនាំចូល ដោយផ្អែកលើមូលដ្ឋានអន្តរកាលមួយចំនួន ដូចជាវិធានការប្រុងប្រយត្ន័ជាមុន នៅពេលហានិភ័យអាចនឹងកើតមានឡើង ដោយការរីករាលដាលនៃជំងឺ ប៉ុន្តែ " ភស្តុតាងវិទ្យាសាស្ត្រ មិនមានគ្រប់គ្រាន់ "។

តួនាទីនៃស្តង់ដារ

ជារួម

ស្តង់ដារនានាជ្រាបចូលទៅក្នុងសកម្មភាពអាជីវកម្មទាំងអស់ និងសូម្បីតែនៅក្នុងជីវិតប្រចាំថ្ងៃរបស់មនុស្សទាំងឡាយនៅតាមផ្លូវផងដែរ ។ ស្តង់ដារដើរតួយ៉ាងសំខាន់នៅក្នុងកាមន្តសាលកម្ម និងឧស្សាហកម្មសេវាកម្ម និងនៅក្នុងការលក់ផលិតផលនៅទីផ្សារជាតិ និងអន្តរជាតិ ។

លក្ខណៈសម្បត្តិមួយនៃកាមន្តសាលកម្មទំនើប គឺថា សហគ្រាសកាមន្តសាលកម្មមួយចំនួន មិនបានផលិតបំណែក និងសមាសធាតុទាំងអស់ដែលគេត្រូវការនោះឡើយ ប៉ុន្តែគេទិញផលិតផលទាំងនេះពីឧស្សាហកម្មតូចៗ(បន្ទាប់បន្សំ) ដែលជារឿយៗ ឧស្សាហកម្មបែបនេះមានទីតាំងនៅឆ្ងាយពីប្រទេស ។ ស្តង់ដារភាវូបនីយកម្មនៃបំណែក និងសមាសធាតុផ្សេ បានធ្វើអោយសហគ្រាសមានជំរើសយ៉ាងច្រើន ដើម្បីជ្រើសរើសផលិតផលផ្គត់ផ្គង់ដែលមានតំលៃទាប ។ វាក៏ផ្តល់លទ្ធភាពអោយសហគ្រាសរក្សាបញ្ជីសារពើភ័ណ្ឌតាមកំរិតកំលៃប្រៀបធៀប និងផ្តល់អោយពួកគេនូវភាពដែលអាចបត់បែនបានក្នុងការប្រើប្រាស់សមាសធាតុផ្សេជំនួស នៅក្នុងខ្សែសង្វាក់ដំឡើងផលិតផល ។ ដូច្នេះស្តង់ដារជួយអោយឧស្សាហកម្មកាត់បន្ថយចំណាយ និងបង្កើនប្រសិទ្ធភាពផលិតកម្ម ។

ស្តង់ដារ គឺជាលក្ខណៈចាំបាច់សំរាប់ការស្វែងរកទីផ្សារផលិតផលអន្តរជាតិ ដោយសារស្តង់ដារបានផ្តល់អោយអ្នកទិញនូវពត៌មានដែលអាចយល់បាន និងដែលសមស្រប ។ អ្នកទិញបរទេស ដែលដឹងពីស្តង់ដារ សំរាប់ផលិតផលដែលត្រូវផលិត អាចមើលឃើញយ៉ាងច្បាស់ពីយថាប្រភេទ និងមានលទ្ធភាពវាយតំលៃគុណភាពផលិតផលនោះបាន ។ ដូច្នេះ ស្តង់ដារជួយកាត់បន្ថយវិវាទលើយថាប្រភេទ និងគុណភាពទំនិញ (និងសេវាកម្ម) ដែលបាននាំចេញ និងនាំចូល ។

រដ្ឋាភិបាលក៏ប្រើប្រាស់ស្តង់ដារផងដែរ ដើម្បីជំរុញគោលដៅសង្គមរបស់គេ ។ ទីភ្នាក់ងាររបស់រដ្ឋាភិបាលកំរិតជាតិ កំរិតមូលដ្ឋានបានកំណត់ស្តង់ដារគ្រប់គ្រងរាប់ពាន់ ដើម្បីការពារសុខភាព ធានាសុវត្ថិភាពប្រជាពលរដ្ឋ និងដើម្បីរក្សាបរិស្ថាន ។ បទបញ្ជាទាំងនេះគ្របដណ្តប់ទៅលើទាំងលក្ខណៈសម្បត្តិផលិតផល និងសំភារៈ ព្រមទាំងកិច្ចដំណើរការដែលបានប្រើប្រាស់សំរាប់ផលិត ផលិតផលនោះដែរ ។ ការអនុវត្តន៍តាមស្តង់ដារ ដែលបានកំណត់ដោយបទបញ្ជារដ្ឋាភិបាល គឺជាកាតព្វកិច្ច ។

ក្នុងការអនុវត្តន៍ជាក់ស្តែង ភាពខុសគ្នារវាងស្តង់ដារចាំបាច់ និងស្តង់ដារស្ម័គ្រចិត្ត អាចមានភាពស្រពិចស្រពិលមិនច្បាស់លាស់ ។ ចំពោះទស្សនៈរបស់អ្នកផ្គត់ផ្គង់ យថាប្រភេទនៃលទ្ធកម្មដែលបានកំណត់ដោយផលិតករធំៗ គឺជាស្តង់ដារចាំបាច់ក្នុងការធ្វើអាជីវកម្ម ដូចជាស្តង់ដារលទ្ធកម្មសាធារណៈរបស់រដ្ឋាភិបាលដែរ ។

ក្នុងការជំរុញពាណិជ្ជកម្ម

ទោះបីស្តង់ដារសំរួលដល់ការធ្វើពាណិជ្ជកម្មអន្តរជាតិ ដោយផ្តល់លទ្ធភាពអោយអ្នកទិញបរទេស វាយតំលៃលើយថាប្រភេទ និងគុណភាពផលិតផលដែលស្នើលក់ក៏ដោយ ក៏ស្តង់ដារនោះនឹងក្លាយជារបាំងពាណិជ្ជកម្ម ប្រសិនបើវាមានលក្ខណៈខុសគ្នាពីប្រទេសមួយទៅប្រទេសមួយ ។ ជារួម អ្នកទិញមានការស្ទាក់ស្ទើរក្នុងការទិញទំនិញណាដែលផលិតតាមស្តង់ដារខុសគ្នាពីស្តង់ដារនៅក្នុងប្រទេសរបស់គេ ។ ដូច្នេះ អ្នកផលិតដែលមានបំណងដំណើរការកាមន្តសាលកម្មនៅក្នុងប្រទេសផ្សេងទៀត ចាំបាច់ត្រូវតែកែតំរូវកិច្ចដំណើរការផលិតកម្មអោយស្របទៅនឹងយថាប្រភេទរបស់ប្រទេសនោះ ។ ទង្វើនេះបង្កើននូវចំណាយលើឧបករណ៍ និងរារាំងអ្នកផលិតពីការទាញយកអត្ថប្រយោជន៍លើកំរិតសេដ្ឋកិច្ច ។ ដូចគ្នានេះដែរ នៅពេលអាជ្ញាធរគ្រប់គ្រងទាមទារអោយធ្វើការសាកល្បង

ផលិតផលនៅក្នុងប្រទេសនាំចូល ដើម្បីបញ្ជាក់ពីការអនុវត្តន៍តាមបទបញ្ញាស្តីពីសុខភាព និងសុវត្ថិភាពរបស់ប្រទេសនោះ អ្នកផ្គត់ផ្គង់បរទេស អាចយល់ឃើញដោយខ្លួនឯងពីការបាត់បង់អត្ថប្រយោជន៍ ប្រសិនបើផលិតផលរបស់គេត្រូវស្ថិតនៅក្រោមការសាកល្បង ដែលមានលក្ខណៈតឹងតែង ឬ មានតំលៃខ្ពស់ជាងការសាកល្បង ឬ តំលៃដែលត្រូវសំរាប់ផលិតផលក្នុងស្រុក ។

ដំណោះស្រាយចំពោះបញ្ហាទាំងនេះ ស្ថិតនៅក្នុងស្តង់ដារសុខុដុមនីយកម្ម តាមកំរិតអន្តរជាតិ និងក្នុងការអភិវឌ្ឍន៍គោលការណ៍ណែនាំ ដើម្បីកំណត់អោយស្របគ្នាទៅនឹងស្តង់ដារ ។ ការងារនៅក្នុងបញ្ហាទាំងពីរនេះ ក្នុងវិស័យឧស្សាហកម្ម និងបច្ចេកវិទ្យាទាំងអស់ត្រូវបានអនុវត្តឡើងដោយអង្គការស្តង់ដារអន្តរជាតិ (ISO) ។

និធានអន្តរជាតិដែលគ្រប់គ្រងលើស្តង់ដារ

ក្រៅពីការប្រមូលពន្ធគយលើទំនិញនាំចូល ប្រទេសនានាបានតំរូវអោយទំនិញនោះមានលក្ខណៈស្របទៅតាមស្តង់ដារគុណភាព សុខភាព និងសុវត្ថិភាពចាំបាច់ ដែលអាចអនុវត្តបាន ដូចគ្នានឹងផលិតផលដែលផលិតក្នុងស្រុកដែរ ។ បន្ថែមពីលើនេះ ផលិតផលកសិកម្មដែលនាំចូល ត្រូវស្របទៅនឹងបទបញ្ញាអនាម័យ និងភូតគាមអនាម័យដែលបានអនុម័ត ដើម្បីរាំងមិនអោយមានការនាំចូលសត្វល្អិតចង្រៃ និងជំងឺមកក្នុងប្រទេសនាំចូល ដែលមិនមានជំងឺ ឬ ប្រភេទសត្វល្អិតចង្រៃនោះ ។

បទបញ្ញាបច្ចេកទេសដែលកំណត់ស្តង់ដារចាំបាច់ កាន់តែមានចំនួនច្រើនឡើងៗ នៅក្នុងបណ្តាប្រទេសភាគច្រើន ។ ទំនោរការនេះគឺដើម្បីឆ្លើយតបទៅនឹងសិទ្ធិអំណាចគ្រប់គ្រងរបស់រដ្ឋាភិបាល ចំពោះកំណើនតំរូវការសាធារណៈ ដើម្បីអោយផលិតផលកំពុងចរាចរលើទីផ្សារនោះ ស្របទៅតាមស្តង់ដារគុណភាព និងសុវត្ថិភាពជាអប្បបរិមា និងមិនមានផលប៉ះពាល់ទៅលើសុខភាពរបស់សាធារណៈជនដែលជាអ្នកប្រើប្រាស់ និងទៅលើបរិស្ថាន ។ ជារឿយ ៗ មានការពិចារណាដូចគ្នា ក្នុងការជំរុញអោយអាជ្ញាធរគ្រប់គ្រង រៀបចំ និង អនុវត្តអោយបានតឹងតែងនូវបទបញ្ញាអនាម័យ និង ភូតគាមអនាម័យ ។ វណ្ណ ១៦ រួមមានបញ្ជីពន្យល់ពីផលិតផលណាដែលប្រទេសនានាត្រូវអនុវត្តបទបញ្ញាសុខភាព និង សុវត្ថិភាពចាំបាច់ ហើយផលិតផលកសិកម្មណាដែលស្ថិតនៅក្រោមបទបញ្ញាអនាម័យ និង ភូតគាមអនាម័យក្នុងបណ្តាប្រទេសភាគច្រើន ។

វណ្ណ ១៦

បញ្ជីពន្យល់ពីផលិតផលនាំចូលដែលត្រូវស្ថិតនៅក្រោមបទបញ្ញាអនាម័យ និងភូតគាមអនាម័យ និង បច្ចេកទេស

ផលិតផលដែលស្ថិតនៅក្រោមបទបញ្ញាបច្ចេកទេស

- *ម៉ាស៊ីន និងបរិក្ខា*
  Boilers
  ឧបករណ៍សំរាប់ភ្លើង និងបរិក្ខាអគ្គីសនីសំរាប់ការសាងសង់
  លោហធាតុ និងបរិក្ខាឈើ
  បរិក្ខាពេទ្យ
  បរិក្ខាសំរាប់កែច្នៃស្បៀង
- *របស់ប្រើប្រាស់*
  ឧសថ និងគ្រឿងផ្សំឧសថ
  គ្រឿងសំអាង
  មេរោគសាប៊ូវិភាគ
  ប្រដាប់ប្រដារប្រើប្រាស់អគ្គិសនីក្នុងគេហដ្ឋាន
  វីដេអូ និងទូរទស្សន៍
  បរិក្ខារសំរាប់ថតកុន និងរូបថត
  រថយន្ត
  ល្បែងក្មេងលេង
  ផលិតផលស្បៀងមួយចំនួនទៀត
- *វត្ថុធាតុដើម និងផលិតផលកសិកម្ម*
  ជី
  ថ្នាំសំលាប់សត្វល្អិត
  សារធាតុគីមីប្រកបដោយគ្រោះថ្នាក់

ផលិតផលដែលស្ថិតនៅក្រោមវិធានការអនាម័យ និងភូតគាមអនាម័យ

ផ្លែឈើ និងបន្លែស្រស់
ទឹកផ្លែឈើ និងការផលិតស្បៀងផ្សេងទៀត
សាច់
និងផលិតផលធ្វើពីសាច់
ផលិតផលស្បៀងប្រចាំថ្ងៃ
ផលិតផលស្បៀងកែច្នៃ

ថ្វីបើប្រទេសជាច្រើនបានអនុម័តបទបញ្ជានេះ ដើម្បីសំរេចបាននូវកម្មវត្ថុគោលនយោបាយសមស្របក៏ដោយ ក៏ក្នុងការអនុវត្តន៍ជាក់ស្តែង គេប្រើប្រាស់បទបញ្ជាទាំងនោះ ដើម្បីផ្តល់នូវការការពារខុសៗគ្នាទៅលើផលិតផលក្នុងស្រុក ។

វិធានអន្តរជាតិស្តីពីការអនុវត្តន៍ស្តង់ដារចាំបាច់ (ដែលគេហៅផងដែរថា ជាបទបញ្ជាបច្ចេកទេស) ក៏មាននៅក្នុងកិច្ចព្រមព្រៀង TBT ដែរ ។ កិច្ចព្រមព្រៀងស្តីពីការអនុវត្តនីវិធានការអនាម័យ និងភូតគាមអនាម័យ (SPS) បានកំណត់នូវវិធានសំរាប់អនុវត្តវិធានការនេះ (SPS) ។ គោលបំណងជាមូលដ្ឋាននៃវិធាន និងគោលការណ៍លំអិតរបស់កិច្ចព្រមព្រៀងទាំងពីរនេះ គឺធានាធ្វើយ៉ាងណាកុំអោយបណ្តាប្រទេសនានារៀបចំ និងអនុវត្តបទបញ្ជាបច្ចេកទេស អនាម័យ និងភូតគាមអនាម័យ ដែលបង្កើតជាឧបសគ្គមិនចាំបាច់ដល់ការធ្វើពាណិជ្ជកម្ម ។

កិច្ចព្រមព្រៀងស្តីពីរបាំងបច្ចេកទេសទៅលើពាណិជ្ជកម្ម

និយមន័យ

បទបញ្ជាបច្ចេកទេស និងស្តង់ដារ

កិច្ចព្រមព្រៀងស្តីពី TBT ឧបសម្ព័ន្ធ ១

វិធានអន្តរជាតិដែលអាចអនុវត្តបានទៅលើស្តង់ដារផលិតផល និងដែលបានប្រើប្រាស់នៅក្នុងពាណិជ្ជកម្មទំនិញ និងនីតិវិធីដែលបានប្រើប្រាស់ដើម្បីវាយតំលៃនូវអនុលោមភាពតាមស្តង់ដារ គឺមាននៅក្នុងកិច្ចព្រមព្រៀងស្តីពី TBT ។ កិច្ចព្រមព្រៀងបានប្រើពាក្យ "បទបញ្ជាបច្ចេកទេស" ដើម្បីគ្របដណ្តប់ទៅលើស្តង់ដារអនុវត្តន៍ចាំបាច់ ។ គេប្រើពាក្យ "ស្តង់ដារ" ដើម្បីគ្របដណ្តប់លើស្តង់ដារដែលស្ម័គ្រចិត្តផងដែរ ។

ពាក្យទាំងពីរនេះគ្របដណ្តប់លើ ÷

☐ លក្ខណៈសម្បត្តិបច្ចេកទេស ដែលរួមមានទាំងលក្ខណៈសម្បត្តិពាក់ព័ន្ធទៅនឹងគុណភាព

☐ កិច្ចដំណើរការ និងវិធីផលិតកម្ម (PPM) ដែលមានប្រសិទ្ធិភាពទៅលើលក្ខណៈសម្បត្តិនៃផលិតផល ។

☐ វាក្យសព្ទបច្ចេកទេស និងនិមិត្តសញ្ញា និង

☐ តំរូវការវេចខ្ចប់ និង ការបិទផ្លាកលើផលិតផល

កិច្ចព្រមព្រៀងស្តីពី TBT ឧបសម្ព័ន្ធ ១

វិធាននៃកិច្ចព្រមព្រៀង បានអនុវត្តទៅលើដំណើរការ និង វិធីផលិតកម្ម តែក្នុងករណីដែលវិធីទាំងនេះមានប្រសិទ្ធភាពទៅលើគុណភាព ឬ លក្ខណៈសម្បត្តិផ្សេងៗទៀតនៃផលិតផល ។ បទបញ្ញត្តិនៃកិច្ចព្រមព្រៀងស្តីពី TBT មិនមាននិយាយពីកិច្ចដំណើរការ និងវិធីផលិតកម្មផ្សេងទៀតទេ (សូមមេត្តាអានវណ្ណ ១៧) ។

> ចណ្ឌ ១៧
>
> ***ភាពខុសគ្នារវាងស្តង់ដារផលិតផល និងស្តង់ដារ PPM***
>
> *ស្តង់ដារផលិតផល កំណត់ពីលក្ខណៈសម្បត្តិ ឬ ពីគុណភាព តំរូវការបច្ចេកទេស ឬ ការផលិតតាមការកំណត់ណាមួយសំរាប់ផលិតផលនោះ ។ ស្តង់ដារនោះ ត្រូវតែមានលក្ខណៈខុសគ្នាពីស្តង់ដារនៃរបៀប និងវិធីផលិតកម្ម (ជាទូទៅគេហៅថា PPM) ដែលបញ្ជាក់ពីធម្មនិយាមដែលផលិតផលនោះត្រូវផលិតតាមយ៉ាងដូចម្តេច ។ ស្តង់ដារ PPM អនុវត្តមុនពេល និងក្នុងកំឡុងពេលផលិត ដូច្នេះមុនពេលដាក់លក់ផលិតផលទាំងនោះនៅលើទីផ្សារ ។*
>
> *បទបញ្ញត្តិនៃកិច្ចព្រមព្រៀងស្តីពី TBT អនុវត្តជាបឋមទៅលើស្តង់ដារផលិតផល ។ បទបញ្ញត្តិទាំងនោះ មិនមានគ្របដណ្តប់ទៅលើ*

ស្តង់ដារPPM ទេ លើកលែងតែនៅពេលដែលរបៀប ឬ វិធីផលិតកម្មដែលបានប្រើប្រាស់នោះ មានប្រសិទ្ធភាពទៅលើគុណភាពផលិតផល ។

សន្និដ្ឋានថា ប្រទេស ក ហាមឃាត់មិនអោយមានការនាំចូលឱសថពីប្រទេស ខ ។ ការហាមឃាត់នេះធ្វើឡើងដោយសារថា ប្រទេស ខ មិនបានបំពេញទៅតាមតំរូវការរបស់ប្រទេស ក ក្នុងការផលិតអោយបានត្រឹមត្រូវ និងភាពគ្មានអនាម័យរបស់រោងចក្រ អាចធ្វើអោយប៉ះពាល់ដល់គុណភាពផលិតផល ។ ក្នុងករណីនេះ កិច្ចព្រមព្រៀងស្តីពី TBT ត្រូវគ្របដណ្តប់ទៅលើស្តង់ដារ PPM ហើយ ប្រទេស ក អាចធ្វើការកែតំរូវចំណាត់ការរបស់គេ ប្រសិនបើគេអាចបញ្ជាក់ថា តំរូវការផលិតកម្ម និងរបៀបផលិតកម្មនោះ មានផលប៉ះពាល់ទៅលើគុណភាពផលិតផល ។

ឧទាហរណ៍ឧបមាថា ប្រទេស ក ហាមឃាត់មិនអោយមានការនាំចូលដែកថែប ដោយសារថា ស្តង់ដារនៃការបំពុលនៅរោងចក្រផលិតដែកថែប នៅក្នុងប្រទេស ខ មានទាបជាងស្តង់ដារនៃការបំពុលនៅក្នុងប្រទេស ក ។ ក្នុងករណីនេះ មិនមានបង្កគ្រោះថ្នាក់ដល់បរិស្ថាន របស់ប្រទេសនាំចូលទេ ដូច្នេះកិច្ចព្រមព្រៀង អាចមិនមានគ្រប់គ្រងទៅលើស្តង់ដារនៃរបៀបផលិតរបស់ប្រទេស ក ជាហេតុធ្វើអោយការហាមឃាត់លើការនាំចូលរបស់ប្រទេស ក អាចធ្វើការកែតំរូវបាន ។

ការវាយតំលៃលើអនុលោមភាព

សារៈសំខាន់នៃស្តង់ដារ ក្នុងការសំរួលពាណិជ្ជកម្មអន្តរជាតិ ភាគច្រើនអាស្រ័យទៅលើកត្តាដែលថា តើអ្នកទិញមានទំនុកចិត្តយ៉ាងប៉ុណ្ណាទៅលើសេចក្តីប្រកាសរបស់ផលិតករថា ផលិតផលរបស់គេស្របទៅតាមស្តង់ដារណាមួយនោះ ។ ផលិតផលភាគច្រើនអាចឈានចូលទៅក្នុងពាណិជ្ជកម្មអន្តរជាតិបាន ដោយសារអ្នកទិញជឿជាក់ទៅលើសេចក្តីប្រកាសរបស់ផលិតករ ថាផលិតផលរបស់គេស្របទៅតាមស្តង់ដារ ។ ក៏ប៉ុន្តែ មានកាលៈទេសៈចំនួន ២ ដែលសេចក្តីប្រកាសរបស់ផលិតករតែមួយមុខនោះ មិនអាចធ្វើអោយអ្នកទិញជឿបាន ។ កាលៈទេសៈទីមួយ ក្នុងករណីជាក់លាក់ខ្លះ ផលិតករដែលទិញបំណែក សមាសធាតុ ឬ សំភារៈ អាចធ្វើការជ្រើសរើសភាគីទីបី អោយបញ្ជាក់ថាតើរបស់ដែលគេត្រូវទិញនោះស្របទៅតាមយថាប្រភេទនៃស្តង់ដារឬទេ ។ កាលៈទេសៈទីពីរ ទាក់ទងទៅនឹងផលិតផលដែលត្រូវគ្រប់គ្រង នោះអ្នកគ្រប់គ្រងជារឿយៗ ទាមទារអោយមានការធានាជាវិជ្ជមានពីស្ថាប័ន ឬ មន្ទីរពិសោធដែលមានការទទួលស្គាល់ថា ផលិតផល នោះស្របទៅតាមតំរូវការសុវត្ថិភាព សុខភាព ឬ បរិស្ថានដែលបទបញ្ញាបានកំណត់ មុនពេលដាក់លក់ផលិតផលដែលផលិតក្នុងស្រុក ឬ ដែលនាំចូលនោះ ។

កិច្ចព្រមព្រៀងស្តីពី TBT ឧបសម្ព័ន្ធ ១:៣

កិច្ចព្រមព្រៀងស្តីពី TBT កំណត់ពីនីតិវិធីនៃការវាយតំលៃអនុលោមភាពជា " នីតិវិធីដែលបានប្រើប្រាស់ដោយផ្ទាល់ ឬ ដោយប្រយោលដើម្បីកំណត់ពីតំរូវការពាក់ព័ន្ធនៅក្នុងបទបញ្ញាបច្ចេកទេស ឬ ស្តង់ដារដែលត្រូវបំពេញ " ។ ការវាយតំលៃលើអនុលោមភាពទៅតាមស្តង់ដារ ដោយការប្រើប្រាស់ភាគីទីបី ត្រូវធ្វើតាមទំរង់ដូចតទៅ ÷

- ☐ ការសាកល្បងលើផលិតផល
- ☐ វិញ្ញាបនបត្របញ្ជាក់ផលិតផល ក្រោយពេលត្រួតពិនិត្យ
- ☐ ការវាយតំលៃលើប្រព័ន្ធគ្រប់គ្រងគុណភាព និង
- ☐ នីតិវិធីដែលទទួលស្គាល់ជាផ្លូវការ

ការសាកល្បងផលិតផល

ទំរង់ទីមួយនៃការវាយតំលៃអនុលោមភាពលើផលិតផល គឺជាការសាកល្បងផលិតផល ជាទូទៅធ្វើឡើងដោយមន្ទីរពិសោធសាកល្បងដែលឯករាជ្យ ។ អង្គការស្តង់ដារអន្តរជាតិ (ISO)កំណត់ពីការសាកល្បង ក្នុងបរិបទនៃការវាយតំលៃលើអនុលោមភាពជា "កិច្ចប្រតិបត្តិការបច្ចេកទេស ដែលរួមមានការកំណត់ទៅលើលក្ខណៈសម្បត្តិមួយ ឬ ច្រើននៃផលិតផលណាមួយ ពីរបៀបផលិត

ឬ សេវាកម្ម ដោយអនុលោមទៅតាមនីតិវិធីជាក់លាក់ ”[១០]។ ដូច្នេះ សេវាកម្មលើការសាកល្បង រួមមានវិសាលភាពនៃសកម្មភាពបច្ចេកទេសដ៏ទូលំទូលាយមួយ ។ អាចធ្វើការសាកល្បងរកគុណភាពនៃសំភារៈបំណែក និងផលិតផលសំរេច ដូចជាភាពខ្លាំង និងរយៈពេលថេរ មាត្រដ្ឋានជាស្តង់ដារ លក្ខណៈសម្បត្តិផ្នែកអគ្គិសនី រួមមានទាំងការជ្រៀតជ្រែក (interference) ជាមួយហ៊ីកម្ម ផ្សេងៗទៀត គុណភាពនៃការពួសួរ សមាសភាពគីមី វត្តមាននៃគ្រឿងផ្សំផ្នែកគីមី និងលក្ខណៈពិសេសជាច្រើនទៀត ។

វិញ្ញាបនបត្រ័បញ្ជាក់ផលិតផលក្រោយពេលត្រួតពិនិត្យ

ទំរង់ទីពីរ នៃការវាយតំលៃលើអនុលោមភាព គឺវិញ្ញាបនបត្រ័បញ្ជាក់គុណភាព ។ ជាថ្មីម្តងទៀត ISO កំណត់វិញ្ញាបនបត្រ័ជា “នីតិវិធីដែលភាគីទីបី ត្រូវអនុវត្តតាម ក្នុងការធានារ៉ាប់រងជាលាយល័ក្ខអក្សរថា ផលិតផល របៀបផលិត ឬ សេវាកម្មនោះស្របទៅតាមតំរូវការជាក់លាក់ណាមួយហើយ ”[១១]។

វិញ្ញាបនបត្រ័មានលក្ខណៈខុសគ្នាពីការសាកល្បង ដោយសារលក្ខណៈពិសេស ២ យ៉ាង ÷

- ☐ ទីមួយ វិញ្ញាបនបត្រ័ ជានិច្ចជាកាលស្មុសស្មង់ ប្រៀបធៀបផលិតផល (ឬរបៀបផលិត ឬ សេវាកម្ម) ជាមួយស្តង់ដារជាក់លាក់ណាមួយ ឬច្រើន ទោះបីជាស្តង់ដារចាំបាច់ ឬ ដោយស្ម័គ្រចិត្តក៏ដោយ ។ ផ្ទុយមកវិញការសាកល្បង មិនចាំបាច់ប្រៀបធៀបជាមួយស្តង់ដារណាមួយឡើយ ។
- ☐ ទីពីរ វិញ្ញាបនបត្រ័ ធ្វើឡើងជាសេចក្តីថ្លែងការស្តីពីអនុលោមភាពជាផ្លូវការ - វិញ្ញាបនបត្រ័ ដែលអ្នកផលិតអាចយកមកប្រើប្រាស់ បង្ហាញពីការអនុវត្តន៍តាមបទបញ្ជា និងយថាប្រភេទនៃការទិញ និងដើម្បីបង្កើនលទ្ធភាពរកទីផ្សារបានរបស់ផលិតផលនោះ ។

អង្គភាពចេញវិញ្ញាបនបត្រ័ភាគច្រើនជា អង្គភាពឯកជន ជាមន្ទីរពិសោធសាកល្បង ដើម្បីរកប្រាក់ចំណេញ ។ ក្រៅពីនេះ ដើម្បីផ្តល់សេវាកម្មសាកល្បង មន្ទីរពិសោធទាំងនេះ បានចាត់វិធានការបន្ថែមក្នុងការបញ្ជាក់ពីផលិតផលដែលស្របទៅតាមស្តង់ដារណាមួយ និងផ្តល់អាជ្ញាប័ណ្ណដល់អ្នកផលិត ដើម្បីប្រើប្រាស់ជាសញ្ញាសំគាល់នៅលើផលិតផល ឬ នៅលើការវេចខ្ចប់របស់គេ ។ ក៏ប៉ុន្តែផ្លាកសញ្ញានេះ គឺជាទ្រព្យសម្បត្តិរបស់អ្នកបញ្ជាក់ និងត្រូវស្ថិតនៅក្រោមច្បាប់ស្តីពីផ្លាកសញ្ញារបស់ជាតិ ។

ប្រព័ន្ធគ្រប់គ្រងគុណភាព

ទំរង់ទីបី នៃការធានាលើអនុលោមភាព គឺប្រព័ន្ធគ្រប់គ្រងគុណភាពដែលបានវាយតំលៃដោយភាគីទីបីរបស់ផលិតករ ។ ខណៈពេលដែលការសាកល្បង និងការចេញវិញ្ញាបនបត្រ័មានបំណងវាយតំលៃលើគុណភាពផលិតផលដោយខ្លួនឯង ការវាយតំលៃនៃប្រព័ន្ធធានារ៉ាប់រងលើគុណភាព ដែលធ្វើឡើងដោយភាគីទីបី មានបំណងធានាចំពោះអ្នកទិញថា ផលិតករមានប្រព័ន្ធប្រកបដោយប្រសិទ្ធិភាព និងគួរអោយទុកចិត្តបាន និងមានសមត្ថភាពផលិតផលិតផលដែលមានគុណភាពស្មើរ មិនប្រែប្រួល ឬ មានការប្រែប្រួលតិចតួចបំផុត។ នេះជាឧបករណ៍គ្រប់គ្រងផលិតកម្មសំរាប់ត្រួតពិនិត្យ និងតាមដានភាពដែលអាចប្រែប្រួលបាននៅក្នុងរបៀបផលិត និងអាចដឹកនាំទៅរកភាពត្រឹមត្រូវឥតខ្ចោះ ។

ប្រព័ន្ធធានារ៉ាប់រងគុណភាពដែលល្បីបំផុត គឺប្រព័ន្ធស្តង់ដារ ISO ៩០០០ ។ ស្តង់ដារនេះរៀបចំឡើងដោយ ISO ហើយសង្កត់ធ្ងន់ថា ការរក្សាគុណភាពផលិតផលអោយស្ថិតស្ថេរ អាចធ្វើទៅបាន ប្រសិនបើមានការទទួលស្គាល់ថា ជាការទទួលខុសត្រូវលើការគ្រប់គ្រងដែលមានសារៈសំខាន់ ។ ប្រព័ន្ធនេះបានកំណត់បន្ថែមទៀតពីនីតិវិធីនៃការរៀបចំឯកសារ និងរបាយការណ៍ ដែលក្រុមហ៊ុនត្រូវរក្សាទុក ដើម្បីបង្ហាញ និងដើម្បីធានាដល់អតិថិជន និងអ្នកទិញរបស់គេថា ក្រុមហ៊ុនមានការចាប់អារម្មណ៍ពេញលេញទៅលើការរក្សា

---

[១០] ISO/IEC ការវាយតំលៃលើអនុលោមភាព ច្បាប់បោះពុម្ពផ្សាយលើកទី ៣ (ទីក្រុងហ្សឺណែវ ១៩៩៥)

[១១] ដូចគ្នា ។

ប្រព័ន្ធគុណភាព ។ ISO ៩០០០ ក៏ចែងពីគោលការណ៍ណែនាំសំរាប់ធ្វើការបណ្តុះបណ្តាលលទ្ធផលនៃការតាមដានស្ថិតិ និងបន្តការកែលំអ ។

អនុញ្ញាតិអោយមានការចុះបញ្ជី និងការចេញវិញ្ញាបនបត្ររបស់សហគ្រាសណាមួយលើ ISO ៩០០០ ក្រោយពេលធ្វើការវាយតំលៃដោយភាគីទីបី ដែលជាភាគីអព្យាក្រឹត្យថា ប្រព័ន្ធដែលដំណើរការនោះស្របទៅតាមតំរូវការទាំងអស់ហើយ ។ ត្រូវធ្វើសវនកម្មជាប្រចាំ និងបន្តបន្ទាប់មកទៀត ដើម្បីធានាអោយក្រុមហ៊ុនបន្តដំណើរការស្របទៅតាមប្រព័ន្ធនោះ ។

ក្រុមហ៊ុនទិញទាំងឡាយនៅលើពិភពលោក កំពុងសំដែងនូវចំណូលចិត្តច្រើនឡើង ៗ អោយអ្នកផ្គត់ផ្គង់ចុះបញ្ជីក្នុង ISO ៩០០០ ទៅលើវត្ថុធាតុដើម បំណែក និងសមាសធាតុផ្សេងៗរបស់គេ ។ បទបញ្ជានៅក្នុងបណ្តាប្រទេសជាច្រើន កំណត់ភាគព្វកិច្ចអោយទីភ្នាក់ងារទិញរបស់រដ្ឋាភិបាល ទទួលអោយបាននូវតំរូវការរបស់គេពីក្រុមហ៊ុនទាំងនោះ ។

នីតិវិធីដែលទទួលស្គាល់ជាផ្លូវការ

ឧស្សាហកម្មដែលផ្គត់ផ្គង់ ព្រមទាំងអតិថិជនរបស់គេ ហាក់ដូចជាមានទំនុកចិត្តនៅក្នុងប្រព័ន្ធធានាអនុលោមភាព ប្រសិនបើសមត្ថភាពរបស់មន្ទីរពិសោធសាកល្បង អ្នកបញ្ជាក់ផលិតផល ឬការចុះបញ្ជីការធានារ៉ាប់រងលើគុណភាព ត្រូវបានទទួលស្គាល់ដោយអង្គភាពបច្ចេកទេសឯករាជ្យមួយ ។ នីតិវិធី ដែលក្រុមហ៊ុនបច្ចេកទេសឯករាជ្យនោះអនុវត្តតាម ក្នុងការវាយតំលៃ និងទទួលស្គាល់ជាផ្លូវការពីសមត្ថភាពរបស់អង្គភាពវាយតំលៃអនុលោមភាពថ្នាក់ដំបូងដែលបានរៀបរាប់ពីខាងលើ ត្រូវបានហៅថា " ការទទួលស្គាល់ជាផ្លូវការ" ។ អ្នកទទួលស្គាល់ជាផ្លូវការ ជាទូទៅជាអង្គភាពជំនាញផ្នែកវិជ្ជាជីវៈ ឬ សមាគមឧស្សាហកម្មនៅក្នុងផ្នែកឯកជន ។ ក៏ប៉ុន្តែ ក្នុងបណ្តាប្រទេសមួយចំនួន សិទ្ធិក្នុងការទទួលស្គាល់ជាផ្លូវការ ត្រូវបានផ្តល់អោយតាមរយៈច្បាប់ទៅអោយអង្គភាពស្តង់ដារភាវូបនីយកម្មជាតិ ឬ ទៅអោយអង្គភាពដោយឡែក ដែលធ្វើសកម្មភាពរួមគ្នាជាមួយអង្គភាពនេះ ។

គោលការណ៍ទូទៅ និងវិធាននៃកិច្ចព្រមព្រៀងស្តីពី TBT

ការជំរុញលើកទឹកចិត្តអោយប្រើប្រាស់ស្តង់ដារ គោលការណ៍ណែនាំ និងអនុសាសន៍អន្តរជាតិ

កិច្ចព្រមព្រៀងនេះមានគោលបំណងសំខាន់ គឺធានាអោយមាន ÷

- បទបញ្ញាបច្ចេកទេស និងស្តង់ដា រួមមានទាំងតំរូវការវេចខ្ចប់ ការដាក់ផ្លាកសញ្ញា និងបិទស្លាក ។
- នីតិវិធីដែលបានប្រើប្រាស់ដើម្បីវាយតំលៃអនុលោមភាព ទៅតាមបទបញ្ជា តាមតំរូវការ និងស្តង់ដារ ។

កិច្ចព្រមព្រៀងស្តីពី TBT ឧបសម្ព័ន្ធ ២:

មិនគួរបង្កើតតំរូវការទាំងនេះទេ តែបើអនុវត្តដូច្នេះ ហាក់ដូចជាបង្កើតអោយមានរបាំងមិនចាំបាច់ដល់ផ្នែកពាណិជ្ជកម្ម ។ កិច្ចព្រមព្រៀងសន្និដ្ឋានថា គោលបំណងនេះអាចសំរេចបាន ប្រសិនបើបណ្តាប្រទេសទាំងអស់ប្រើប្រាស់ នៅពេលណាដែលសមស្រប និងអាចធ្វើទៅបាន នូវស្តង់ដារអន្តរជាតិ ក្នុងការរៀបចំបទបញ្ញាបច្ចេកទេសរបស់គេ ឬ ក្នុងការអភិវឌ្ឍន៍ស្តង់ដារអន្តរជាតិដោយស្ម័គ្រចិត្ត ។ ម៉្យាងទៀត កិច្ចព្រមព្រៀងនេះអំពាវនាវអោយបណ្តាប្រទេសជាសមាជិកប្រើប្រាស់គោលការណ៍ណែនាំ ឬ អនុសាសន៍ ដែលរៀបចំឡើងដោយអង្គការស្តង់ដារអន្តរជាតិ ជាមូលដ្ឋានសំរាប់ជានីតិវិធីនៃការវាយតំលៃអនុលោមភាព ។

ដើម្បីផ្តល់នូវការលើកទឹកចិត្តដល់បណ្តាប្រទេសដែលប្រើប្រាស់ស្តង់ដារអន្តរជាតិ កិច្ចព្រមព្រៀងបានកំណត់ថា នៅពេលគេប្រើប្រាស់ស្តង់ដារអន្តរជាតិ ឬ គោលការណ៍ណែនាំ ឬ ប្រព័ន្ធវាយតំលៃអនុលោមភាព ជាមូលដ្ឋានសំរាប់បទបញ្ញាបច្ចេកទេស នោះស្តង់ដារនោះមិនបានបង្កើតឧបសគ្គដែលមិនចាំបាច់ដល់ពាណិជ្ជកម្មទេ ។ កិច្ចព្រមព្រៀងបានជំរុញបន្ថែមទៀតអោយប្រទេសជាសមាជិកចូលរួមនៅក្នុងការងាររបស់អង្គការស្តង់ដារអន្តរជាតិ ដើម្បីអោយមានស្តង់ដារអន្តរជាតិសំរាប់ផលិតផលទាំងអស់ ដែលគេមានបំណងអនុម័តបទបញ្ញាបច្ចេកទេស ឬ រៀបចំអភិវឌ្ឍន៍ស្តង់ដារដោយស្ម័គ្រចិត្ត ។ កិច្ចព្រមព្រៀងក៏បានជំរុញអោយប្រទេសទាំងឡាយចូលរួមនៅក្នុងសកម្មភាពរបស់អង្គការនោះ ដើម្បីរៀបចំការណែនាំ និងអនុសាសន៍អន្តរជាតិ ដែលអាចយកមកប្រើប្រាស់នៅក្នុងការរៀបចំនីតិវិធីវាយតំលៃអនុលោមភាព ។

តែទោះជាយ៉ាងណាក៏ដោយ កិច្ចព្រមព្រៀងមិនមានបញ្ជាក់ ពីការប្រើប្រាស់ស្តង់ដាររបស់អង្គការអន្តរជាតិណា សំរាប់រៀបចំបទបញ្ញត្តិបច្ចេកទេសនោះទេ ។ អង្គការសំខាន់ៗដែលអភិវឌ្ឍន៍ស្តង់ដារអន្តរជាតិ សំរាប់ផលិតផលឧស្សាហកម្ម មានដូចតទៅ ÷

- ☐ អង្គការស្តង់ដារអន្តរជាតិ (ISO)
- ☐ គណៈកម្មការអន្តរជាតិ ផ្នែកអេឡិចត្រូនិក (IEC)
- ☐ សហភាពទូរគមនាគមន៍អន្តរជាតិ (ITU)
- ☐ គណៈកម្មការ Codex Alimentarius

កាលៈទេសៈដែលអនុញ្ញាតិអោយមានការប្រែប្រួលខុសពីស្តង់ដារ និងគោលការណ៍ណែនាំអន្តរជាតិ

កិច្ចព្រមព្រៀងស្តីពី TBT មាត្រា ២:៤

នៅពេលដែលស្តង់ដារ និងគោលការណ៍ណែនាំអន្តរជាតិ ត្រូវបានចាត់ទុកថា មិនមានប្រសិទ្ធិភាព ឬ មិនសមស្របក្នុងការសំរេចកម្មវត្ថុជាតិ (ឧបមាថា ដោយសារកត្តាភូមិសាស្ត្រ និងអាកាសធាតុជាសំខាន់ ឬ បញ្ហាបច្ចេកវិទ្យាគ្រឹះ) ឬ នៅពេលដែលគ្មានស្តង់ដារអន្តរជាតិនោះ បណ្តាប្រទេសនានាអាចរៀបចំបង្កើតស្តង់ដារជាតិផ្ទាល់របស់គេបានដោយសេរី ។ ម៉្យាងទៀត ប្រទេសមួយអាចអនុម័តប្រព័ន្ធវាយតំលៃអនុលោមភាព ដោយមិនផ្អែកទៅលើគោលការណ៍ណែនាំ ឬ អនុសាសន៍ដែលអាចទទួលយកបានជាអន្តរជាតិ

កិច្ចព្រមព្រៀងស្តីពី TBT មាត្រា ២:៩

ប្រសិនបើគេចាត់ទុកថា ខ្លឹមសារបច្ចេកទេសនៃគោលការណ៍ណែនាំទាំងនេះ មិនសមស្របសំរាប់សមិទ្ធិផលនៃកម្មវត្ថុណាមួយរបស់ប្រព័ន្ធជាតិដែលបានស្នើឡើង ។ ក៏ប៉ុន្តែក្នុងរាល់ករណី នៅពេលដែលមានការរំពឹងថាវិធានការដែលបានស្នើឡើងនោះ មានប្រសិទ្ធិភាពគួរអោយកត់សំគាល់ទៅលើពាណិជ្ជកម្ម នោះកិច្ចព្រមព្រៀងត្រូវកំណត់កាតព្វកិច្ចទៅលើបណ្តាប្រទេសក្នុងចំណោមនោះត្រូវ ÷

- ☐ ធ្វើការបោះពុម្ពផ្សាយក្នុងទំរង់ជាពង្រាងនូវបទបញ្ញត្តិបច្ចេកទេសស្តង់ដារ និងប្រព័ន្ធវាយតំលៃអនុលោមភាពដែលស្នើឡើង
- ☐ ផ្តល់កាលានុវត្តន៍ភាពសមស្រប ដល់ភាគីផ្សេងទៀតក្នុងការផ្តល់មតិទៅលើពង្រាងទាំងនេះ
- ☐ ពិចារណាទៅលើមតិណែនាំទាំងនេះ ដើម្បីរៀបចំសំរេចលើពង្រាងនេះ

បណ្ណាល័យ
គ.ជ.អ.ប

វិធានជាក់លាក់

បទបញ្ញត្តិ និងស្តង់ដារបច្ចេកទេស

ដើម្បីធានាអោយបទបញ្ញត្តិបច្ចេកទេស ដែលកំណត់ពីស្តង់ដារចាំបាច់ និងស្តង់ដារស្ម័គ្រចិត្ត មិនបង្កើតរបាំងពាណិជ្ជកម្មដែលមិនចាំបាច់ កិច្ចព្រមព្រៀងបានកំណត់គោលការណ៍ និងវិធានជាក់លាក់បន្ថែមទៀត។ គោលការណ៍ និងវិធានទាំងនេះបានអំពាវនាវឱ្យមន្ត្រីក្រសួងការគ្រប់គ្រងធានាថាយ៉ាងណាអោយបទបញ្ញត្តិ និងស្តង់ដារបច្ចេកទេស ÷

កិច្ចព្រមព្រៀងស្តីពី TBT មាត្រា ២:១

- ☐ ត្រូវបានយកមកអនុវត្ត ដោយមិនមានការរើសអើងក្នុងចំណោមទំនិញដែលបាននាំចូលតាមប្រភព (គោលការណ៍ MFN)

កិច្ចព្រមព្រៀងស្តីពី TBT មាត្រា ២:២

- ☐ មិនមានវិសាលភាពទៅលើប្រព្រឹត្តកម្មនៃទំនិញនាំចូលដែលផ្តល់ភាពអនុគ្រោះតិចជាង ទៅលើផលិតផលដែលផលិតក្នុងស្រុក (គោលការណ៍ប្រព្រឹត្តកម្មជាតិ)
- ☐ ផ្អែកទៅលើភស្តុតាងបច្ចេកទេស និងវិទ្យាសាស្ត្រនៅពេលដែលពាក់ព័ន្ធ ។
- ☐ មិនត្រូវបានរៀបចំឡើង ឬ អនុវត្តក្នុងលក្ខណៈដែលបង្កជា "ឧបសគ្គមិនចាំបាច់ដល់ពាណិជ្ជកម្មអន្តរជាតិ" ។

កិច្ចព្រមព្រៀងបានកំណត់នូវគោលការណ៍ណែនាំជាក់លាក់ សំរាប់អោយបណ្តាអាជ្ញាធរគ្រប់គ្រង រៀបចំបង្កើតបទបញ្ញត្តិបច្ចេកទេស និងធានាកុំឱ្យបទបញ្ញត្តិទាំងនេះបង្កើតនូវឧបសគ្គមិនចាំបាច់ដល់ពាណិជ្ជកម្ម (សូមមើលប្រអប់ទំព័រ ១៨) ។

ធណ្ឌ ១៨

គោលការណ៍ណែនាំសំរាប់កំណត់ថាតើបទបញ្ញាបច្ចេកទេសមាន បង្កើតជាឧបសគ្គមិនចាំបាច់ចំពោះពាណិជ្ជកម្មឬទេ

កិច្ចព្រមព្រៀងស្តីពី TBT ចែងថា បទបញ្ញាបច្ចេកទេសដែលកំណត់ពីស្តង់ដារផលិតផលព្រមទាំងតំរូវការនៃការវេចខ្ចប់ ការដាក់ផ្លាកសញ្ញា និងការដាក់ស្លាកសញ្ញាជាធម្មតា មិនត្រូវបានចាត់ទុកជាការបង្កឧបសគ្គមិនចាំបាច់ដល់ពាណិជ្ជកម្មទេ ប្រសិនបើ ÷

- ☐ *បទបញ្ញាទាំងនោះ ត្រូវបានអនុម័តដើម្បីសំរេចនូវកម្មវត្ថុស្របច្បាប់*
- ☐ *បទបញ្ញានោះរៀបចំឡើងដោយផ្អែកលើស្តង់ដារអន្តរជាតិ និង*
- ☐ *នៅពេលដែលស្តង់ដារអន្តរជាតិ ត្រូវបានចាត់ទុកថា មិនសមស្រប ឬ មិនមានជាធរមានពេលនោះបទបញ្ញាបច្ចេកទេស ត្រូវបានអនុវត្តឡើងដើម្បីឱ្យបទបញ្ញារ ÷*
  - *មិនមានការដាក់កំហិតខ្លាំងជាងអ្វី ដែលចាំបាច់ដើម្បីបំពេញកម្មវត្ថុស្របច្បាប់ខាងលើ និង*
  - *ពិចារណាទៅលើហានិភ័យនៃការមិនបានបំពេញកាតព្វកិច្ច(កម្មវត្ថុទាំងនេះ) ដែលអាចបង្កើតកម្មវត្ថុស្របច្បាប់ដែលប្រទេសអាចអនុម័តបទបញ្ញាបច្ចេកទេសឬមមាន ÷*
- ☐ *តំរូវការសន្តិសុខជាតិ*
- ☐ *មិនអោយមានការក្លែងបន្លំ*
- ☐ *ការការពារជីវិតមនុស្ស សត្វ និងរុក្ខជាតិ ឬ បរិស្ថាន*

អាស្រ័យដោយបទបញ្ញាតិទាំងនេះ ទោះជាបទបញ្ញាតិបច្ចេកទេសដែលមិនពឹងផ្អែកទៅលើស្តង់ដារអន្តរជាតិក្តី ក៏អាចចាត់ទុកជាឧបសគ្គមិនចាំបាច់ដល់ពាណិជ្ជកម្ម ហើយដែលពឹងផ្អែកជាដំបូងទៅលើកម្មវត្ថុណាដែលគេបានអនុម័ត ។ ប្រសិនបើកម្មវត្ថុណាមួយត្រូវបានអនុម័តដើម្បីសំរេចឱ្យបានកម្មវត្ថុណាមួយក្នុងចំណោមកម្មវត្ថុស្របច្បាប់ដែលមានចែងខាងលើ នោះសំណួរបន្ទាប់ដែលត្រូវចោទសួរថាតើ បទបញ្ញាមានការដាក់កំហិតផ្អែកពាណិជ្ជកម្មច្រើនជាងអ្វីដែលចាំបាច់សំរាប់សំរេចកម្មវត្ថុ និងប្រសិនបើមានការអនុម័តវិធានពាណិជ្ជកម្មដែលបានដាក់កំហិតតិចជាង និង ថាតើមានហានិភ័យនៃការមិនបំពេញនោះគេត្រូវពិចារណាទៅលើសមាសធាតុដូចជា ÷

- ☐ *បទបញ្ញាបច្ចេកទេស និងវិទ្យាសាស្ត្រដែលមាន*
- ☐ *បច្ចេកវិទ្យានៃរបៀបផលិត ដែលពាក់ព័ន្ធ ឬ*
- ☐ *ការបញ្ចប់តាមគោលបំណងនៃការប្រើប្រាស់ផលិតផល*

នីតិវិធីនៃការវាយតំលៃអនុលោមភាព

កិច្ចព្រមព្រៀងស្តីពី TBT មាត្រា ៥

កិច្ចព្រមព្រៀងចែងថាប្រព័ន្ធដែលបានអនុម័តសំរាប់វាយតំលៃពីអនុលោមភាពទៅតាមបទបញ្ញាបច្ចេកទេស មិនត្រូវបង្កើត ឬ អនុវត្តជារបាំងពាណិជ្ជកម្មទេ ។ ដើម្បីបញ្ចប់បញ្ហានេះ កិច្ចព្រមព្រៀងចែងថា ÷

- ☐ មិនត្រូវរៀបចំ អនុម័ត និងអនុវត្តនីតិវិធីនៃការវាយតំលៃអនុលោមភាព ទៅលើផលិតផលនាំចូល តាមល័ក្ខខ័ណ្ឌដែលផ្តល់ភាពអនុគ្រោះតិចជាងអ្វីដែលអនុវត្តទៅលើផលិតផលជាតិឡើយ ។
- ☐ ត្រូវផ្តល់អោយអ្នកផ្គត់ផ្គង់បរទេសតាមសំណើ នូវពត៌មានស្តីពីរយៈពេលរៀបចំឯកសារ និងឯកសារនានាដែលតំរូវដើម្បីវាយតំលៃអនុលោមភាពនៃផលិតផលដែលគេចង់នាំចេញ ។
- ☐ ថ្លៃឈ្នួលណាមួយដែលគិតពីអ្នកផ្គត់ផ្គង់បរទេស ត្រូវមានសមភាពទៅនឹងថ្លៃឈ្នួលដែលគិតលើផលិតផលជាតិដែរ ។

- ☐ សម្បទាននៃការអនុវត្តន៍ និងការជ្រើសរើសគំរូសំរាប់ធ្វើការសាកល្បង មិនត្រូវបង្កអោយមានការលំបាកដល់អ្នកផ្គត់ផ្គង់បរទេស ទេ ហើយ
- ☐ នីតិវិធីនៃការវាយតំលៃអនុលោមភាព ត្រូវចែងពីការពិនិត្យមើលពាក្យបណ្តឹងស្តីពីកិច្ចដំណើរការនីតិវិធីនោះ ។

កិច្ចព្រមព្រៀងស្តីពី TBT មាត្រា ៦

កិច្ចព្រមព្រៀងទទួលស្គាល់ នីតិវិធីនៃការវាយតំលៃអនុលោមភាពទៅវិញទៅមក

ការសាកល្បងផលិតផល និងការត្រួតពិនិត្យដោយអាជ្ញាធរគ្រប់គ្រង នៅក្នុងបណ្តាប្រទេសនាំចូល ដើម្បីអោយមានអនុលោមភាពទៅតាមបទបញ្ញា អាចបណ្តាលអោយមានបញ្ហាជាក់ស្តែងសំរាប់អ្នកផ្គត់ផ្គង់បរទេស ទោះបីជាអាជ្ញាធរគោរពតាមគោលការណ៍ និងវិធានដែលបានរៀបរាប់ខាងលើក៏ដោយ ។ អ្នកផ្គត់ផ្គង់បរទេស ត្រូវរ៉ាប់រងលើចំណាយក្នុងការបញ្ជូនវត្ថុតាងទៅអោយប្រទេសនាំចូល និងជារឿយៗ ត្រូវការជួលភ្នាក់ងារដែលមានជំនាញធ្វើការសាកល្បង និងត្រួតពិនិត្យវត្ថុតាងនោះ ។ ជាងនេះទៅទៀត នៅពេលដែលបទបញ្ញាបច្ចេកទេស តំរូវអោយអធិការកិច្ចស្របច្បាប់របស់ប្រទេសនាំចូលធ្វើការត្រួតពិនិត្យរោងចក្រផលិត និងដើម្បីទទួលបានពត៌មាន ឧទាហរណ៍ថា ការគោរពតាមស្តង់ដារនៃការផលិតទំនិញ នោះអ្នកផ្គត់ផ្គង់បរទេសត្រូវទទួលបន្ទុកក្នុងការចេញចំណាយលើការធ្វើដំណើររបស់អធិការកិច្ចទៀត ។

ដើម្បីកាត់បន្ថយគុណវិបត្តិបែបនោះចំពោះអ្នកផ្គត់ផ្គង់បរទេស កិច្ចព្រមព្រៀងជំរុញអោយប្រទេសជាសមាជិកទទួលយកនូវលទ្ធផលនៃការសាកល្បងលើការវាយតំលៃអនុលោមភាព ដែលធ្វើឡើងនៅក្នុងបណ្តាប្រទេសនាំចេញ នៅពេលដែលអាចធ្វើទៅបាន ។ កិច្ចព្រមព្រៀងបានសំណូមពរបន្ថែមទៀត អោយបណ្តាប្រទេសនានាបង្ហាញនូវភាពស្ម័គ្រចិត្តក្នុងការទទួលយកវិញ្ញាបនបត្រ ដែលចេញអោយដោយអាជ្ញាធរគ្រប់គ្រង នៅក្នុងប្រទេសនាំចេញនានា ទោះបីក្នុងករណីដែលនីតិវិធីមានភាពខុសគ្នាពីនីតិវិធីក្នុងប្រទេសរបស់គេក៏ដោយ លើកលែងតែគេពេញចិត្តថា នីតិវិធីនោះមានតំលៃស្មើនឹងនីតិវិធីនៃប្រទេសរបស់ខ្លួន ។ តែទោះជាយ៉ាងណាក៏ដោយ កិច្ចព្រមព្រៀងទទួលស្គាល់ថា វាផ្តល់លទ្ធភាពអោយប្រទេសនាំចូលទទួលយកនូវនីតិវិធីរបស់ប្រទេសនាំចេញ ថាមានតំលៃស្មើតែក្នុងករណី ដែលគេមានទំនុកចិត្តនៅក្នុងសមត្ថកិច្ចបច្ចេកទេសដែលគ្រប់គ្រាន់ និងថេរ របស់អាជ្ញាធរគ្រប់គ្រងនៃប្រទេសនាំចេញ និងក្នុងករណី នៃភាពជឿជាក់ទៅលទ្ធផលនៃការវាយតំលៃអនុលោមភាព " ។ ដើម្បីសំរួលអោយប្រទេសនាំចូលយកព្រមទទួលយកវិញ្ញាបនបត្រ វាយតំលៃអនុលោមភាព កិច្ចព្រមព្រៀងបានជំរុញអោយមានការចាត់ចែងបន្ថែមទៀតលើ " ការទទួលស្គាល់ទៅវិញទៅមក " លើនីតិវិធីវាយតំលៃអនុលោមភាពរបស់ប្រទេសជាសមាជិក ។

ក្រមអនុវត្តសមស្របសំរាប់ស្តង់ដារតាមបទនីយកម្មស្ម័គ្រចិត្ត (Code of Good Practice)

កិច្ចព្រមព្រៀងស្តីពី TBT មាត្រា ៤ ឧបសម្ព័ន្ធ ៣

ដូចដែលបានបញ្ជាក់ពីខាងលើរួចមកហើយថា ស្តង់ដារភាគច្រើនដែលឧស្សាហកម្មបានប្រើប្រាស់ គឺជាស្តង់ដារស្ម័គ្រចិត្ត ។ ស្តង់ដារនេះជារឿយៗ ត្រូវបានរៀបចំឡើងអង្គភាពកំណត់ស្តង់ដារធម្មជាតិ នៅក្នុងបណ្តាប្រទេសជាសមាជិកផ្សេងៗ ។ ស្តង់ដារស្ម័គ្រចិត្ត អាចបង្កើតបានជាបញ្ហានៅក្នុងពាណិជ្ជកម្មអន្តរជាតិ ប្រសិនបើស្តង់ដារនោះប្រែប្រួលខុសគ្នាពីប្រទេសមួយ ទៅប្រទេសមួយ ។ ដូច្នេះ កិច្ចព្រមព្រៀងបានរៀបចំអភិវឌ្ឍន៍ក្រមអនុវត្តសមស្របមួយសំរាប់រៀបចំអនុម័ត និង អនុវត្តស្តង់ដារសំរាប់អោយ អង្គភាពកំណត់ស្តង់ដារជាតិអនុវត្តតាម ក្នុងការរៀបចំអនុម័ត និងអនុវត្តស្តង់ដារ ។ ក្រមនោះ តំរូវអោយអង្គភាពកំណត់ស្តង់ដារជាតិ អនុវត្តតាមគោលការណ៍ និងវិធានដែលដូចគ្នាទៅនឹងវិធាននិងគោលការណ៍ដែលមាន កំណត់សំរាប់ស្តង់ដារចាំបាច់ ។ ដូច្នេះក្រមជំរុញអោយបណ្តាប្រទេសជាសមាជិក ÷

- ☐ ប្រើប្រាស់ស្តង់ដារអន្តរជាតិ ជាមូលដ្ឋានសំរាប់កំណត់ស្តង់ដារជាតិរបស់គេ
- ☐ នៅក្នុងគិតនៃធនធានរបស់ខ្លួន ត្រូវចូលរួមយ៉ាងពេញទំហឹង ក្នុងការរៀបចំស្តង់ដារអន្តរជាតិ សំរាប់ផលិតផលណាដែលគេស្នើ ដើម្បីអនុម័តស្តង់ដារជាតិ ។

ការបូបនីយកម្មស្ម័គ្រចិត្ត J

ជាងនេះទៅទៀត ដើម្បីស្គាល់អ្នកផលិតបរទេសដែលការងារស្តីពីស្តង់ដារភាវូបនីយកម្មរបស់គេ កំពុងត្រូវបានអនុវត្តឡើងដោយអង្គភាពជាតិ នៅក្នុងប្រទេសផ្សេងៗ នោះ កិច្ចព្រមព្រៀងទាមទារអោយអង្គភាពទាំងនោះធ្វើការបោះពុម្ពផ្សាយកម្មវិធីការងាររបស់គេ " យ៉ាងហោចណាស់មួយដងក្នុងរៀងរាល់ ៦ ខែ ដោយផ្តល់ពត៌មានស្តីពីស្តង់ដារដែលគេកំពុងរៀបចំ និងស្តង់ដារដែលគេបានអនុម័តហើយកាលពីរយៈពេលកន្លងមក ។ នៅពេលធ្វើការបោះពុម្ពផ្សាយ ក៏មានការទាមទារអោយអង្គភាពជាតិជូនដំណឹងបញ្ជាក់ទៅមជ្ឈមណ្ឌលពត៌មាន ISO/IEC អំពីឈ្មោះនៃឯកសារបោះពុម្ពផ្សាយ និងថាតើត្រូវរកឯកសារនោះបានយ៉ាងដូចម្តេច និងនៅទីណា ។

ក្រមតំរូវអោយអង្គភាពកំណត់ស្តង់ដារ ផ្តល់រយៈពេលយ៉ាងតិច ៦០ សំរាប់អោយភាគីដែលពាក់ព័ន្ធនៅក្រៅប្រទេសផ្តល់មតិលើពង្រាងស្តង់ដានោះ ។ ជាធម្មតា ត្រូវផ្តល់មតិកែលំអរតាមរយៈអង្គភាពកំណត់ស្តង់ដារជាតិ ។ ក្រមអំពាវនាវអោយអង្គភាពកំណត់ស្តង់ដារដែលជាអ្នករៀបចំបង្កើតស្តង់ដារនោះ ទទួលយកមតិកែលំអរទាំងនោះទៅពិចារណា នៅពេលសំរេចស្តង់ដារចុងក្រោយ។

កិច្ចព្រមព្រៀងស្តីពីការអនុវត្តន៍វិធានការអនាម័យ និងភូតគាមអនាម័យ

កន្លងមក ការពិភាក្សាបានផ្តោតអារម្មណ៍ទៅលើបទបញ្ញាបច្ចេកទេស ស្តង់ដារ និងប្រព័ន្ធដែលបានអនុម័តសំរាប់វាយតំលៃអនុលោមភាព ។ វិធានអន្តរជាតិនៅក្នុងវិស័យទាំងនេះ ដែលមាននៅក្នុងកិច្ចព្រមព្រៀងស្តីពី TBT អនុវត្តទៅលើទាំងផលិតផលកសិកម្ម និងឧស្សាហកម្ម ។ ផលិតផលកសិកម្មដែលបាននាំចូល ក្នុងករណីមួយចំនួនមិនត្រឹមតែត្រូវស្របតាមបទបញ្ញាបច្ចេកទេសប៉ុណ្ណោះទេ ប៉ុន្តែត្រូវស្របផងដែរទៅនឹងវិធានការអនាម័យ និងភូតគាមអនាម័យរបស់ប្រទេសនាំចូល ។

និយមន័យនៃបទបញ្ញាអនាម័យ និងភូតគាមអនាម័យ

តើវិធានការអនាម័យ និងភូតគាមអនាម័យជាអ្វី ? តើវិធានការនេះខុសគ្នាយ៉ាងណាពីបទបញ្ញាបច្ចេកទេស ? វិធានការទាំងនេះត្រូវបានអនុម័តដោយប្រទេសនានា ដើម្បីការពារ ÷

កិច្ចព្រមព្រៀងស្តីពី SPS ឧបសម្ព័ន្ធ ក

- ☐ ជីវិតមនុស្ស និងសត្វ ពីហានិភ័យលើស្បៀងអាហារ ដែលកើតមកពីការប្រើប្រាស់សារធាតុបន្ថែម សារធាតុកខ្វក់ សារធាតុពុល ឬ សេរីរាង្គដែលបង្កអោយមានជំងឺ (និងដើម្បីធានាសុវត្ថិភាពស្បៀងអាហារ) ។
- ☐ សុខភាពមនុស្សពីជំងឺដែលបណ្តាលមកពីរុក្ខជាតិ និងសត្វ និង
- ☐ មនុស្ស និងសត្វពីសត្វល្អិតចង្រៃ និងជំងឺ

គេប្រើប្រាស់ពាក្យថា "បទបញ្ញអនាម័យ" ដើម្បីគ្របដណ្តប់ទៅលើប្រភេទបទបញ្ញាដែលមានកម្មវត្ថុជាមូលដ្ឋាន ការពារសុវត្ថិភាពស្បៀង ឬ បង្ការមិនអោយជំងឺសត្វ ចូលមកក្នុងប្រទេសបាន ។ នៅពេលដែលបទបញ្ញាមានកម្មវត្ថុ ធានាមិនអោយប្រភេទរុក្ខជាតិផ្សេងៗ ដែលបាននាំចូល នាំជំងឺរុក្ខជាតិចូលមកក្នុងប្រទេសបាន នោះបទបញ្ញានោះត្រូវបានកំនត់ថាជា " បទបញ្ញាភូតគាមអនាម័យ" ។

ភាពខុសគ្នារវាងបទបញ្ញាបច្ចេកទេស និងវិធានការ SPS

ភាពខុសគ្នាជាមូលដ្ឋានរវាងបទបញ្ញាបច្ចេកទេស និងវិធានការអនាម័យ និងភូតគាមអនាម័យ មាននៅក្នុងកម្មវត្ថុនៃបទបញ្ញាដែលគេបានអនុម័ត ។ ក្នុងវិធានការ SPS គឺមានគោលបំណងច្បាស់លាស់ និងមានកំរិត ដើម្បីការពារជីវិតមនុស្ស សត្វ និងរុក្ខជាតិ ឬ សុខភាព ដោយការធានាសុវត្ថិភាពស្បៀង និងរារាំងមិនអោយជំងឺសត្វ និងរុក្ខជាតិចូលមកក្នុងប្រទេសបាន ។ ម្យ៉ាងទៀត បទបញ្ញាបច្ចេកទេស ត្រូវបានអនុវត្តទៅលើកម្មវត្ថុនៃគោលនយោបាយផ្សេងៗ ។ ដូចដែលបានបញ្ជាក់ពីខាងលើរួចមក ហើយថា បទបញ្ញាទាំងនេះ រួមមានតំរូវការសន្តិសុខជាតិ ការរារាំងមិនអោយមានការឆបោក និងការការពារបរិស្ថាន ។ បទបញ្ញាទាំងនេះ

អាចត្រូវបានអនុម័ត ដើម្បីការពារសុខភាព និងសុវត្ថិភាពមនុស្ស ឬ សត្វ ឬ រុក្ខជាតិសំរាប់គម្មវត្ថុផ្សេង ពីគម្មវត្ថុដែលមាននៅក្នុងវិធានការអនាម័យ និងសុខភាព (សូមមេត្តាអានការពន្យល់ក្នុងវណ្ឌ ១៩) ។

កំហិតជិតនៃកិច្ចព្រមព្រៀង SPS

វិធាននានាដែលគ្រប់គ្រងការប្រើប្រាស់វិធានការអនាម័យ និងភូតគាមអនាម័យ មាននៅក្នុងកិច្ចព្រមព្រៀងស្តីពីការអនុវត្តន៍វិធានការអនាម័យ និងភូតគាមអនាម័យ ។ ដូចជាកិច្ចព្រមព្រៀង TBT ដែរ កិច្ចព្រមព្រៀង SPS ទាមទារអោយប្រទេសនានា ÷

ខណ្ឌ ១៩

ភាពខុសគ្នារវាងបទបញ្ញាបច្ចេកទេស និងវិធានការអនាម័យ និងភូតគាមអនាម័យ : ឧទាហរណ៍មួយចំនួន

បទបញ្ញាដែលការពារសុខភាព និងជីវិតមនុស្ស សត្វ ឬ រុក្ខជាតិ និងពពួកសត្វរបស់ប្រទេស គឺជាបទបញ្ញាបច្ចេកទេស ឬ វិធានការអនាម័យ និងភូតគាមអនាម័យ អាស្រ័យទៅលើគម្មវត្ថុ ដែលវិធានការ ឬ បទបញ្ញានោះបានអនុម័តលើ។ ភាពខុសគ្នា គឺជាកត្តាសំខាន់ ដោយសារវិធាននៃកិច្ចព្រមព្រៀងស្តីពី TBT អាចអនុវត្តបាន ប្រសិនបើបទបញ្ញានោះត្រូវបានចាត់ទុកថា ជាបទបញ្ញាបច្ចេកទេស ហើយវិធានរបស់កិច្ចព្រមព្រៀង SPS អាចអនុវត្តបានប្រសិនបើបទបញ្ញាត្រូវបានចាត់ទុកថាជា វិធានការអនាម័យ និងភូតគាមអនាម័យ ។ ទោះបីបទបញ្ញត្តិនៃកិច្ចព្រមព្រៀងទាំងពីរមានលក្ខណៈប្រហាក់ប្រហែលគ្នាក្នុងវិស័យមួយចំនួនធំក៏ដោយ ក៏កិច្ចព្រមព្រៀងទាំងពីរនេះនៅមានភាពខុសគ្នាច្រើនទៀតដែរ ។

និយាយជារួម វិធានការអាចត្រូវបានចាត់ទុកថាជាវិធានការអនាម័យ និងភូតគាមអនាម័យ នៅពេលដែលគម្មវត្ថុនៃវិធានការមានបំណងការពារ ÷

- ☐ *ជីវិតមនុស្សពីហានិភ័យ ដែលកើតមកពីការប្រើសារធាតុបន្ថែម សារធាតុពុល និងជំងឺដែលមាននៅលើសត្វ និងរុក្ខជាតិ ។*
- ☐ *ជីវិតសត្វពីហានិភ័យ ដែលកើតមកពីការប្រើសារធាតុបន្ថែម សារធាតុពុល សត្វល្អិតចង្រៃ សរីរាង្គដែលបង្កជំងឺ និងជំងឺផ្សេងៗ ។*
- ☐ *ជីវិតរុក្ខជាតិពីហានិភ័យដែលបង្កមកពីសត្វល្អិតចង្រៃ ជំងឺ និងសរីរាង្គដែលបង្កជំងឺ និង*
- ☐ *ប្រទេសជាតិ ពីហានិភ័យដែលបង្កមកពីគ្រោះថ្នាក់នានា ដែលបណ្តាលមកពីការចូល ការបង្កើត ឬ ការរីករាលដាលនៃសត្វល្អិតចង្រៃ ។*

បទបញ្ញាដែលបានអនុម័តសំរាប់គោលបំណងផ្សេងៗ ដើម្បីការពារជីវិតមនុស្ស សត្វ និងរុក្ខជាតិ ត្រូវបានចាត់ទុកថាជាបទបញ្ញាបច្ចេកទេស ។

ឧទាហរណ៍ ដែលបង្ហាញជូនភ្ជាប់ទៅនឹងការពន្យល់លំអិត ថាតើគម្មវត្ថុនៃវិធានការកំណត់យ៉ាងណា ថាវិធានការនោះជាបទបញ្ញាបច្ចេកទេស (TR) ឬ ជាវិធានការអនាម័យ និងភូតគាមអនាម័យ (SPS) និងថាតើវិធានការ និងបទបញ្ញានេះត្រូវបានកំណត់យ៉ាងណា ដើម្បីអោយដឹងថា វាស្ថិតនៅក្រោមកិច្ចព្រមព្រៀងស្តីពី TBT ឬ កិច្ចព្រមព្រៀងស្តីពី SPS ។

កិច្ចព្រមព្រៀងគ្រប់គ្រង	*ការពិពណ៌នាអំពីវិធានការ*
បទបញ្ជាស្តីពីថ្នាំសំលាប់សត្វល្អិត	
SPS	*ប្រសិនបើវិធានការទាក់ទងទៅនឹងកាកសំណល់ក្នុងស្បៀង ឬ ក្នុងចំណីសត្វ ហើយកម្មវត្ថុនៃវិធានការនោះ គឺការការពារសុខភាពមនុស្ស ឬ សត្វ ។*
TBT	*ប្រសិនបើវិធានការទាក់ទងទៅនឹងគុណភាព ឬ ប្រសិទ្ធិភាពនៃផលិតផល ឬ ទៅនឹងហានិភ័យសុខភាពដល់អ្នកប្រើប្រាស់ ។*
ការរៀបចំបង្កើតតម្រូវការបិទស្លាកសញ្ញាលើម្ហូបអាហារ	
SPS	*ប្រសិនបើវិធានការទាក់ទងទៅនឹងសុវត្ថិភាពម្ហូបអាហារ ។*
TBT	*ប្រសិនបើបទបញ្ជាទាក់ទងទៅនឹងបញ្ហាដូចជា ទំហំនៃផ្ទៃខាងលើដែលបានប្រើប្រាស់សំរាប់ស្លាកសញ្ញា ការបង្ហាញពីពត៌មានពីខ្លឹមសារ ប្រភេទកំរិត ។ល។*
បទបញ្ជាស្តីពីកុងទេន័រសំរាប់ដឹកជញ្ជូនផ្លែជាតិ	
SPS	*ប្រសិនបើបទបញ្ជា មាននិយាយពីការចំហុយដោយផ្សែងអោយស្អុក ឬ ប្រព្រឹត្តកម្មផ្សេងៗទៀតនៃប្រអប់ ឬ កុងទេន័រនោះ ដូចជាការរំងាប់មេរោគ ដើម្បីបង្ការមិនអោយមានការឆ្លងជំងឺ ។*
TBT	*ប្រសិនបើបទបញ្ជាទាក់ទងទៅនឹងទំហំ ឬ រចនាសម្ព័ន្ធនៃប្រអប់ ឬកុងទេន័រ ។*

ប្រភព: ឯកសាររបស់ WTO ។

☐ ពឹងផ្អែកទៅលើវិធានការ SPS ស្តីពី ស្តង់ដារអន្តរជាតិ គោលការណ៍ណែនាំ ឬ អនុសាសន៍ដែលផ្តល់អោយដោយ ÷

- គណៈកម្មការ Codex Alimentarius
- International Office of Epizootics
- អង្គការអន្តរជាតិ និងតំបន់ដែលពាក់ព័ន្ធ ហើយដែលកំពុងដំណើរការនៅក្នុងក្របខណ្ឌនៃសន្ធិសញ្ញាស្តីពីការការពាររុក្ខជាតិអន្តរជាតិ ឬ
- អង្គការអន្តរជាតិណាផ្សេងទៀត ដែលគណៈកម្មាធិការ SPS នៃ WTOបានតែងតាំងឡើង ។

កិច្ចព្រមព្រៀងស្តីពី SPS មាត្រា ៣:៤

☐ ចូលរួមយ៉ាងពេញទំហឹងនៅក្នុងរាល់សកម្មភាពរបស់អង្គការអន្តរជាតិដែលបានរៀបរាប់ខាងលើ ដើម្បីជំរុញអោយមានសុខដុមនីយកម្មនៃវិធានការ SPS តាមមូលដ្ឋានអន្តរជាតិ ។

កិច្ចព្រមព្រៀងស្តីពី TBT ឧបសម្ព័ន្ធ ២:៤

☐ ដើម្បីផ្តល់កាលានុវត្តន៍ភាពដល់ភាគីពាក់ព័ន្ធទាំងអស់ នៅក្នុងប្រទេសផ្សេងៗ អោយផ្តល់មតិកែលំអលើពង្រាងស្តង់ដារ នៅពេលដែលពង្រាងនោះមិនផ្អែកតាមស្តង់ដារអន្តរជាតិ ឬ នៅពេលដែលស្តង់ដារនោះប្រែប្រួលពីស្តង់ដារអន្តរជាតិ ឬ នៅពេលដែលគ្មានស្តង់ដារអន្តរជាតិ ។

កិច្ចព្រមព្រៀងស្តីពី SPS ឧបសម្ព័ន្ធ ១:៥

☐ ទទួលយកវិធានការ SPS របស់ប្រទេសនាំចេញ ជាសមមូល្យ ប្រសិនបើវិធានការនោះសំរេចបាននូវកំរិតនៃការការពារ SPS ដូចគ្នា និងត្រូវរៀបចំចុះកិច្ចព្រមព្រៀង នៅពេលណាដែលអាចធ្វើទៅបាន លើការទទួលស្គាល់ទៅវិញទៅមក លើសមមូល្យនៃវិធានការអនាម័យ និងភូតគាមអនាម័យដែលបានកំណត់ណាមួយ ។

ភាពខុសគ្នាជាសំខាន់រវាងកិច្ចព្រមព្រៀង SPS និង TBT

វិធាននៃកិច្ចព្រមព្រៀង SPS ខុសគ្នាពីវិធាននៃកិច្ចព្រមព្រៀង TBT ក្នុងវិស័យជាសំខាន់ចំនួន ៤ ÷

វិស័យទីមួយ ពាក់ព័ន្ធទៅនឹងសារៈសំខាន់ដែលមានភ្ជាប់ទៅនឹងភស្តុតាងវិទ្យាសាស្ត្រ ក្នុងការរៀបចំបទបញ្ញា ។ ចំពោះវិធានការអនាម័យ និងភូតគាមអនាម័យវិញ ភាតព្វកិច្ចដែលត្រូវពឹងផ្អែកក្នុងការរៀបចំបទបញ្ញាលើភស្តុតាងវិទ្យាសាស្ត្រ គឺមានភាពច្បាស់លាស់។ កិច្ចព្រមព្រៀងបានកំណត់ថា វិធានការនោះ ត្រូវពឹងផ្អែកទៅលើគោលការណ៍វិទ្យាសាស្ត្រ និងមិនត្រូវរក្សាទុក ដោយគ្មានភស្តុតាងវិទ្យាសាស្ត្រគ្រប់គ្រាន់ទេ " ។ ម៉្យាងទៀត កិច្ចព្រមព្រៀង TBT ទទួលស្គាល់ថា ការប្រើប្រាស់ភស្តុតាងវិទ្យាសាស្ត្រ អាចអាស្រ័យទៅលើកម្មវត្ថុដែលបទបញ្ញាបច្ចេកទេសនោះបានអនុម័ត ។ បទបញ្ញាដែលបានអនុម័តក្នុងគោលបំណងការពារសុខភាព និងសុវត្ថិភាពអាចធ្វើឡើងដោយផ្អែកទៅលើភស្តុតាងវិទ្យាសាស្ត្រ ហើយផ្ទុយនេះមិនចាំបាច់ពាក់ព័ន្ធថាតើ កម្មវត្ថុនៃបទបញ្ញា ត្រូវបានការពារតទល់នឹងការបោកបញ្ឆោត ឬ ដែលបានអនុម័តសំរាប់មូលហេតុសន្តិសុខជាតិឬអត់ទេ ។

កិច្ចព្រមព្រៀងស្តីពី SPS
ឧបសម្ព័ន្ធ ២:២

វិស័យទីពីរ កិច្ចព្រមព្រៀង TBT ទាមទារអោយអនុវត្ត បទបញ្ញាបច្ចេកទេសដែលកំណត់ពីស្តង់ដារផលិតផលលើមូលដ្ឋាន MFN ចំពោះការនាំចូលពីគ្រប់ប្រភពទាំងអស់ ។ បទបញ្ញាអនាម័យ និងភូតគាមអនាម័យ ជាពិសេសបទបញ្ញាដែលមានបំណងបង្ការមិនអោយមានជំងឺរុក្ខជាតិ និងសត្វចូលមកក្នុងប្រទេសបាន អាចមានតំរូវការពឹងផ្អែកច្រើន ឬតិចទៅលើ " ការីតនៃការមានច្រើនលើសលប់នៃជំងឺ ឬ សត្វល្អិតចង្រៃណាមួយ " នៅក្នុងប្រទេស ឬ ក្នុងតំបន់នៃប្រទេស ។

តទល់ចំពោះសាវតានេះ កិច្ចព្រមព្រៀង SPS តំរូវអោយប្រទេសនានា ÷

កិច្ចព្រមព្រៀងស្តីពី SPS
ឧបសម្ព័ន្ធ ៦:១

- ☐ ដើម្បី "ធានាថា បទបញ្ញាអនាម័យ និងភូតគាមអនាម័យ ត្រូវបានអនុម័តទៅតាមលក្ខណៈសម្បត្តិនៃអនាម័យ និងភូតគាមអនាម័យនៃតំបន់នោះ "- ទោះបីជា នៅទូទាំងប្រទេសផ្នែកណាមួយរបស់ប្រទេស ឬ ទូទាំង ឬ ផ្នែកណាមួយនៃប្រទេសមួយចំនួន ដែលផលិតផលិតផល និងដែលជាទីដៅត្រូវដឹកទំនិញទៅ "។ លក្ខណៈសម្បត្តិបែបនោះត្រូវបានកំណត់ក្នុងចំណោមកត្តាផ្សេងៗ ដោយផ្អែកទៅលើមូលដ្ឋាននៃការីតដែលមានច្រើនលើសលប់នៃប្រភេទជំងឺ ឬ សត្វល្អិតចង្រៃ និង

កិច្ចព្រមព្រៀងស្តីពី SPS
ឧបសម្ព័ន្ធ ២:៣

- ☐ មិនត្រូវអនុវត្តបទបញ្ញានោះ ដោយបង្កើតអោយមានការរើសអើងមិនត្រឹមត្រូវ ឬ តាមទំនើងចិត្តក្នុងចំណោមប្រទេស ឬ តំបន់នានា ដែលមានល័ក្ខខ័ណ្ឌដូចគ្នា ឬ បង្កើតជាការដាក់កំហិតគួរអោយធុញទ្រាន់ទៅលើពាណិជ្ជកម្មអន្តរជាតិ ។

ក៏ប៉ុន្តែ គួរកត់សំគាល់ថា មានការអនុញ្ញាតិអោយមានភាពដែលអាចបត់បែនបានពីគោលការណ៍ MFN សំរាប់តែវិធានការ SPS ដែលមានបំណងរារាំងមិនអោយសត្វល្អិតចង្រៃ និងជំងឺដែលមានលើសត្វ និងរុក្ខជាតិចូលមកក្នុងប្រទេសបាន ។ វិធានការ SPS មានបំណងធានាសុវត្ថិភាពម្ហូបអាហារ (ឧទាហរណ៍ បទបញ្ញាស្តីពីការដាក់សារធាតុបន្ថែម សារធាតុកខ្វក់ ឬ ការីតនៃកាកសំណល់ដែលបានអនុញ្ញាតិ) ជាធម្មតាអាចអនុវត្តបានដោយផ្អែកលើមូលដ្ឋាន MFN ។

ម៉្យាងទៀត ទាំងក្នុងករណីដែលមានការប៉ះពាល់ធ្ងន់ធ្ងរទៅលើឧស្សាហកម្មនៅក្នុងស្រុក និងក្នុងករណីនៃការទទួលរងនូវផលប៉ះពាល់អាក្រក់ផ្សេងទៀត ប្រទេសនាំចូលអាចដាក់ពាក្យប្តឹងទៅអង្គភាពដោះស្រាយវិវាទ (DSB) ដើម្បីធានាអោយប្រទេសផ្តល់ឧបត្ថម្ភធនដក ឬ កែប្រែឧបត្ថម្ភធនណាដែលបង្កអោយមានផលប៉ះពាល់មិនល្អនោះ ។

រដ្ឋាភិបាលផ្តល់ឧបត្ថម្ភធន ដើម្បីសំរេចកម្មវត្ថុនៃគោលនយោបាយផ្សេងៗ ។ ដូច្នេះ អាចមានឧបត្ថម្ភធនសំរាប់ជំរុញការអភិវឌ្ឍន៍ឧស្សាហកម្មថ្មី សំរាប់លើកទឹកចិត្តដល់ការវិនិយោគទុន និងបង្កើតឧស្សាហកម្មនៅក្នុងបណ្តាលប្រទេសដែលមិនសូវមានការរីកចំរើន ជួយធ្វើការអភិវឌ្ឍន៍ឧស្សាហកម្មនាំចេញ កែលំអរហេដ្ឋារចនាសម្ព័ន្ធសំរាប់ផលិតកម្មកសិកម្ម និងដើម្បីកើតចំណូលរបស់កសិករ ។

វិធានរបស់ GATT ដែលគ្រប់គ្រងលើការប្រើប្រាស់ឧបត្ថម្ភធន មានលក្ខណៈស្មុគស្មាញ ហើយខុសគ្នារវាងឧបត្ថម្ភធនសំរាប់ផលិតផលឧស្សាហកម្ម និងផលិតផលកសិកម្ម ។ បទបញ្ញត្តិសំខាន់របស់ GATT ស្តីពីឧបត្ថម្ភធន មានចែងលំអិតនៅក្នុងកិច្ចព្រមព្រៀងស្តីពីឧបត្ថម្ភធន និងវិធានការប៉ះប៉ូវ (SCM) និងនៅក្នុងកិច្ចព្រមព្រៀងស្តីពីកសិកម្ម ។ កិច្ចព្រមព្រៀង SCM អនុវត្តទៅលើផលិតផលឧស្សាហកម្ម ដោយមានអញ្ញត្រកម្មមួយចំនួន ឯកិច្ចព្រមព្រៀងស្តីពីកសិកម្មទាក់ទងទៅនឹងផលិតផលកសិកម្ម។ វិធាននៃកិច្ចព្រមព្រៀង SCM មានពិពណ៌នានៅក្នុងជំពូកនេះ រីឯវិធានដែលអនុវត្តបានទៅលើផ្នែកកសិកម្ម មានពិភាក្សានៅក្នុងជំពូក ១៥ ។

និយមន័យនៃពាក្យឧបត្ថម្ភធន, គោលបំណងនៃកិច្ចព្រមព្រៀង SCM

កិច្ចព្រមព្រៀង SCM មាត្រា ១

តាមកិច្ចព្រមព្រៀង SCM ឧស្សាហកម្មចាត់ទុកថាបានទទួលឧបត្ថម្ភធន នៅពេលណាឧស្សាហកម្មនោះបានទទួលផលប្រយោជន៍ដោយសារ ÷

- ☐ ការផ្ទេរដោយផ្ទាល់ពីរដ្ឋាភិបាលនូវមូលនិធិ (ឧទាហរណ៍ ជំនួយ កម្ចី ឬ ការផ្តល់អោយដោយសមធម៌) ឬ ការធានារបស់រដ្ឋាភិបាលក្នុងការទូទាត់ប្រាក់កម្ចី ។
- ☐ ចំណូលរបស់រដ្ឋាភិបាល ដែលបានប្រមូលពីគ្រប់ទិសទី នាពេលអនាគត ។
- ☐ រដ្ឋាភិបាលផ្តល់នូវ ទំនិញ ឬ សេវាកម្ម ឬ ការទិញទំនិញ ។

ពាក្យថា ផលប្រយោជន៍ មានសារៈសំខាន់ ដើម្បីកំណត់ថា តើវិធានការណ៍តំណាងអោយឧបត្ថម្ភធនទេ ។ ទោះជាកិច្ចព្រមព្រៀងចែងពីគោលការណ៍ណែនាំមានកំណត់ទៅលើចំណុចនេះក្តី ក៏វិធានជាទូទៅ អាចនិយាយបានថា សកម្មភាពរដ្ឋាភិបាលមិនស្របទៅតាមតំលៃតបស្នងផ្នែកពាណិជ្ជកម្មដែលផ្តល់ផលប្រយោជន៍នោះដែរ ។ ដូច្នេះការផ្តល់ទ្រព្យទុនរបស់រដ្ឋាភិបាលតាមល័ក្ខខ័ណ្ឌជាវិនិយោគិនឯកជននោះមិនអាចទទួលយកបានទេ ហើយកម្ចីតាមល័ក្ខខ័ណ្ឌដែលផ្តល់ភាពអនុគ្រោះច្រើនជាងអ្វីដែលផ្តល់អោយដោយធនាគារពាណិជ្ជកម្ម ឬ ក៏រដ្ឋាភិបាលធ្វើការបែងចែកទំនិញ ឬ សេវាកម្មទាបជាងតំលៃដែលមាននៅក្នុងទីផ្សារ ហាក់ដូចជាការប្រគល់អោយនូវផលប្រយោជន៍ និងអាចចាត់ទុកជាឧបត្ថម្ភធនទេ ។

កិច្ចព្រមព្រៀងនេះ មិនមានគោលបំណងដាក់កំហិតដោយមិនត្រឹមត្រូវទៅលើសិទ្ធិរបស់រដ្ឋាភិបាល ក្នុងការផ្តល់ឧបត្ថម្ភធននោះទេ ប៉ុន្តែដើម្បីហាមឃាត់ និងមិនជំរុញអោយគេប្រើប្រាស់ឧបត្ថម្ភធនណាដែលមានផលប៉ះពាល់មិនល្អទៅលើពាណិជ្ជកម្មនៃប្រទេសដទៃទៀត។ ជាចុងក្រោយកិច្ចព្រមព្រៀងបានចាត់ថ្នាក់ឧបត្ថម្ភធន ទៅក្នុងប្រភេទនៃឧបត្ថម្ភធនដែលហាមឃាត់ និងអនុញ្ញាត ។

ឧបត្ថម្ភធនដែលហាមឃាត់

ឧបត្ថម្ភធនដែលហាមឃាត់រួមមាន ÷

កិច្ចព្រមព្រៀង SCM មាត្រា ៣

- ☐ ឧបត្ថម្ភធនសំរាប់ការនាំចេញ ដូចជាឧបត្ថម្ភធនដែលអាចកើតមានចំពោះការនាំចេញ។ (សូមអានវណ្ណ ២២ ស្តីពីបញ្ជីពន្យល់ពីឧបត្ថម្ភធនបែបនេះ)
- ☐ ឧបត្ថម្ភធន ដែលកើតមានទៅលើការប្រើប្រាស់ទំនិញក្នុងស្រុកលើទំនិញនាំចូល ។

កន្លងមក វិធានបានហាមឃាត់ការប្រើប្រាស់ឧបត្ថម្ភធន លើការនាំចេញចំពោះផលិតផលឧស្សាហកម្មសំរាប់តែប្រទេសជឿនលឿនប៉ុណ្ណោះ ។ តែបច្ចុប្បន្នកិច្ចព្រមព្រៀងនេះ មានវិសាលភាពអនុវត្តទៅលើបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ដែរ ។ បណ្តាប្រទេសទាំងនោះអាច (ដោយមានអញ្ញត្រកម្មខ្លះៗ) លប់បំបាត់បន្តិចម្តងៗនូវការប្រើប្រាស់ឧបត្ថម្ភធន ក្នុងរយៈពេលអន្តរកាល ៨ឆ្នាំ ដែលនឹងផុតកំណត់នៅថ្ងៃទី ១ ខែមករា ឆ្នាំ ២០០៣ ។ បណ្តាប្រទេសទាំងនោះអាចមានរយៈពេលអន្តរកាល ៥ ឆ្នាំទៀត ដើម្បីលប់បំបាត់ឧបត្ថម្ភធន ដែលកើតមានទៅលើការប្រើប្រាស់ផលិតផលក្នុងស្រុកលើផលិតផលនាំចូល ។ រយៈពេល នេះនឹងផុតកំណត់នាថ្ងៃទី១ ខែមករា ឆ្នាំ២០០០ ។ វណ្ឌ ២៣ នឹងរៀបរាប់ពីបទបញ្ញត្តិនៃកិច្ចព្រមព្រៀងដែលគ្របដណ្តប់ទៅលើប្រព្រឹត្តកម្មពិសេស និងដោយឡែកចំពោះបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ ទាក់ទងទៅនឹងការប្រើប្រាស់ឧបត្ថម្ភធនហាមឃាត់ និងអនុញ្ញាតិ ។

វណ្ឌ ២២

តារាងដែលធ្វើការពន្យល់ពីឧបត្ថម្ភធនហាមឃាត់ បញ្ជីរាយនាមពីឧបត្ថម្ភធនហាមឃាត់នៃកិច្ចព្រមព្រៀង SCM រួមមានដូចតទៅ ÷

- ☐ *ប្រាក់ឧបត្ថម្ភធនដោយផ្ទាល់ផ្អែកលើការនាំចេញ*
- ☐ *គំរោងទប់ស្កាត់ការហូរចូលនូវរូបិយវត្ថុដែលពាក់ព័ន្ធនឹងរង្វាន់លើការនាំចេញ*
- ☐ *ការចែកចាយវត្ថុធាតុដើមដែលបានទទួលឧបត្ថម្ភធន សំរាប់ប្រើប្រាស់នៅក្នុងផលិតកម្មទំនិញនាំចេញ*
- ☐ *ការលើកលែងពន្ធប្រយោល (ឧទាហរណ៍ ការលើកលែងពន្ធលើប្រាក់ចំណេញ ទាក់ទងនឹងការនាំចេញ)*
- ☐ *ការមិនយកពន្ធ ឬ ការលើកលែងពន្ធប្រយោល (ឧទាហរណ៍ ពន្ធលើតំលៃបន្ថែម(VAT) ក្នុងទំនិញនាំចេញ លើសពីអ្វីដែលបានបង់នៅពេលលក់ទៅអោយអ្នកប្រើប្រាស់ក្នុងស្រុក ។*
- ☐ *ការលើកលែង ឬ ការដកហូតមកវិញនូវសោហ៊ុយនាំចូល (ឧទាហរណ៍ តារាងពន្ធគយ ឬ ការយកពន្ធអាករផ្សេងៗទៀត) លើសពីអ្វីដែលបានកំណត់ទៅលើវត្ថុធាតុដើមដែលបានប្រើប្រាស់សំរាប់ផលិតទំនិញនាំចេញ*
- ☐ *គំរោងធានាការនាំចេញ តាមអត្រាបុព្វលាភ មិនគ្រប់គ្រាន់សំរាប់គ្របដណ្តប់លើចំណាយរយៈពេលយូររបស់គំរោង។*
- ☐ *ឥណទាននាំចេញតាមអត្រាដែលទាបជាង ចំណាយរបស់រដ្ឋាភិបាលក្នុងការខ្ចី នៅពេលដែលគេប្រើប្រាស់ដើម្បីបានអត្ថប្រយោជន៍ដ៏សំខាន់ក្នុងការនាំចេញតាមលក្ខខណ្ឌឥណទាន ។*

ឧបត្ថម្ភធនដែលអនុញ្ញាតិ

តាមវិធាននៃកិច្ចព្រមព្រៀង ជាគោលការណ៍ រដ្ឋាភិបាលបានទទួលការអនុញ្ញាតអោយផ្តល់ឧបត្ថម្ភធនដទៃទៀត ក្រៅពីឧបត្ថម្ភធនដែលមានចែងខាងលើ ដែលជាឧបត្ថម្ភធនហាមឃាត់ ។ ក៏ប៉ុន្តែ កិច្ចព្រមព្រៀងបានប្រមូលផ្តុំឧបត្ថម្ភធនជាពីរប្រភេទ: គឺឧបត្ថម្ភធនដែលអាចប្តឹងបាន និងឧបត្ថម្ភធនដែលមិនអាចប្តឹងបាន ។ ការបែងចែកនេះបានក្លាយទៅជាការអនុវត្តន៍ ទូទៅក្នុងការប្រៀបធៀបចំណាត់ថ្នាក់ឧបត្ថម្ភធននៃកិច្ចព្រមព្រៀងទៅនឹងភ្លើងស្តុប ។ ឧបត្ថម្ភធនហាមឃាត់ មានឈ្មោះថា ឧបត្ថម្ភធនភ្លើងក្រហម ហើយឧបត្ថម្ភធនដែលអាចប្តឹងបាន ហៅថាឧបត្ថម្ភធនភ្លើងលឿង ឧបត្ថម្ភធនដែលមិនអាចប្តឹងបាន ហៅថាឧបត្ថម្ភធនភ្លើងបៃតង ។

ឧបត្ថម្ភធនដែលអនុញ្ញាត និងជាឧបត្ថម្ភធនដែលអាចប្តឹងបាន (ឧបត្ថម្ភធនភ្លើងលឿង)

និយាយជារួម កិច្ចព្រមព្រៀងបានប្រើទស្សនៈនៃការបញ្ជាក់ពីប្រភេទឧបត្ថម្ភធន ដែលអាចប្តឹងបាន និងដែលមិនអាចប្តឹងបាន ។ ឧបត្ថម្ភធនមានភាពជាក់លាក់ ប្រសិនបើមានការកំណត់ទៅលើ ÷

កិច្ចព្រមព្រៀង SCM មាត្រា ២ និង៥

☐ សហគ្រាសមួយ ឬ សហគ្រាសមួយក្រុម ។

☐ ផ្នែកឧស្សាហកម្មមួយ ឬ ឧស្សាហកម្មមួយក្រុម ។

☐ តំបន់ភូមិសាស្ត្រដែលបានកំណត់ នៅក្នុងយុត្តាធិការនៃការផ្តល់អំណាច ។

ឧបត្ថម្ភធនជាក់លាក់ទាំងអស់ (ក្រៅពីឧបត្ថម្ភធនដែលមានបញ្ជាក់នៅក្នុងផ្នែកខាងក្រោម) គឺជាឧបត្ថម្ភធនដែលអាចប្តឹងបាន ប្រសិនបើឧបត្ថម្ភធននោះបណ្តាលអោយមានផលប៉ះពាល់មិនល្អទៅលើផលប្រយោជន៍របស់ប្រទេសជាសមាជិកផ្សេងទៀត ។ ផលប៉ះពាល់មិនល្អនោះកើតមានក្នុងទំរង់ជា ÷

☐ ការប៉ះពាល់ខ្លាំងទៅលើឧស្សាហកម្មក្នុងស្រុក ។

☐ បង្កអោយមានការខូចខាតដល់ឧស្សាហកម្មក្នុងស្រុកនៅក្នុងប្រទេសនាំចូល ។

☐ ធ្វើមោឃៈភាព ឬ ខូចខាតប្រយោជន៍ អត្រាពន្ធគយដែលមានប្រសិទ្ធិភាពចងភ្ជាប់ ។

ទណ្ឌ ២៣

ភាពអាចបត់បែនបានសំរាប់ប្រទេសកំពុងអភិវឌ្ឍន៍ក្នុងការប្រើប្រាស់ឧបត្ថម្ភធន កិច្ចព្រមព្រៀងSCM មាត្រា ២៧

កិច្ចព្រមព្រៀង SCM ទទួលស្គាល់ថា "ប្រាក់ ឧបត្ថម្ភធនអាចដើរតួយ៉ាងសំខាន់ក្នុងកម្មវិធីអភិវឌ្ឍន៍សេដ្ឋកិច្ចរបស់បណ្តាប្រទេសកំពុងអភិវឌ្ឍន៍ដែលជាសមាជិក ។ ព្រោះតែដូច្នេះហើយ ទើបកិច្ចព្រមព្រៀងនេះ ទទួលស្គាល់បន្ថែមទៀតថា ប្រទេសកំពុងអភិវឌ្ឍន៍ទាំងអស់នេះ ប្រហែលជាមិនអាចមានលទ្ធភាពគោរពបានភ្លាមនូវគោលការណ៍ដែលវិធាននេះបានកំណត់ទេ ។ ដើម្បីផ្តល់ភាពដែលអាចបត់បែនបានក្នុងការអនុវត្តនវិធាននេះ កិច្ចព្រមព្រៀងបានចែងពីប្រព្រឹត្តកម្មពិសេស និងដោយឡែកសំរាប់បណ្តាប្រទេសកំពុងអភិវឌ្ឍន៍ ។

ឧបត្ថម្ភធនសំរាប់ការនាំចេញ

ដូចបានកត់សំគាល់ពីខាងលើរួចមកហើយថា វិធានដែលហាមឃាត់ចំពោះឧបត្ថម្ភធនលើការនាំចេញ អាចអនុវត្តបានទៅលើប្រទេសកំពុងអភិវឌ្ឍន៍ ក្រោយរយៈពេលអន្តរកាល ប្រាំបីឆ្នាំ រហូតដល់ថ្ងៃទី ១ ខែមករា ឆ្នាំ ២០០៣ ។ ទោះជាយ៉ាងណាក៏ដោយ ប្រទេសទាំងនោះបានជំរុញអោយលុបចោលឧបត្ថម្ភធនទាំងនេះអោយបានច្រើនក្នុងរយៈពេល ៨ ឆ្នាំនេះ និងមិនអនុញ្ញាតអោយបង្កើនកំរិតនៃការផ្តល់ឧបត្ថម្ភធនចំពោះការនាំចេញរបស់ពួកគេទេ។ រយៈពេលអន្តរកាលនេះ នឹងត្រូវបន្តបាន ២ឆ្នាំទៀត បើសិនមានការស្នើសុំដោយប្រទេសកំពុងអភិវឌ្ឍន៍ ។

មានការស្នើសុំបន្ថែមទៀត អោយប្រទេសទាំងនោះលុបចោលក្នុងរយៈពេល ២ ឆ្នាំ នូវឧបត្ថម្ភធននៃការនាំចេញចំពោះផលិតផលណាមួយ ដែលឈានទៅដល់លក្ខណៈប្រកួតប្រជែង ។ ប្រទេសដែលបានចាត់ទុកថា ឈានទៅដល់កំរិតប្រកួតប្រជែងលើការនាំចេញផលិតផល បើសិនការនាំចេញនោះមានចំណែកលើទីផ្សារពិភពលោកចំនួន៣.២៥ ភាគរយ ក្នុងរយៈពីរឆ្នាំជាប់ៗគ្នា ។ ក្នុងករណីនេះ ផលិតផលត្រូវបានកំណត់ក្នុងផ្នែកមួយដែលនាំមុខដោយប្រព័ន្ធ Harmanized System Nomanclative ដែលរៀបចំឡើងដោយអង្គការគយពិភពលោក សំរាប់ចំណាត់ ថ្នាក់អត្រាពន្ធគយ និងស្ថិតិពាណិជ្ជកម្ម ។

ប្រទេសក្រីក្រ និងប្រទេសកំពុងអភិវឌ្ឍន៍ដែលមានប្រាក់ចំណូលទាប ដោយមាន GNP តិចជាង ១០០០ ដុល្លាអាមេរិក(*) ត្រូវបានលើកលែងពីការអនុវត្តនវិធានហាមឃាត់ការផ្តល់ឧបត្ថម្ភធនទាំងស្រុង ។ ទោះជាយ៉ាងណាក៏ដោយ

បើសិនរកឃើញថា ពួកគេបានអភិវឌ្ឍន៍ភាពប្រកួតប្រជែងលើការនាំចេញក្នុងផលិតផលណាមួយ នោះពួកគេមានកាតព្វកិច្ចលប់ចោលការផ្តល់ឧបត្ថម្ភធនលើការនាំចេញ ចំពោះផលិតផលនោះក្នុងរយៈពេល ៨ ឆ្នាំ (ប្រៀបធៀបនឹងរយៈពេលពីរឆ្នាំដែលផ្តល់អោយទៅប្រទេសកំពុងអភិវឌ្ឍន៍ដទៃទៀត) ។ ឧបត្ថម្ភធនលើការនាំចេញ ដែលផ្តល់អោយដោយសមាជិកនៃប្រទេសកំពុងអភិវឌ្ឍន៍ នៅតែជាឧបត្ថម្ភធនដែលអាចប្តឹងបាន ក៏ប៉ុន្តែទាំងតាមរយៈពន្ធលុបភាគី និងតាមរយៈពន្ធប៉ះប៉ូវ។

ឧបត្ថម្ភធនដើម្បីជំរុញការប្រើប្រាស់ទំនិញក្នុងស្រុក

វិធានដែលហាមឃាត់ការប្រើឧបត្ថម្ភធន ដើម្បីជំរុញការប្រើប្រាស់ផលិតផលក្នុងស្រុកលើសពីទំនិញនាំចូលនឹងត្រូវបានអនុវត្តទៅលើប្រទេសកំពុងអភិវឌ្ឍន៍ ក្រោយរយៈពេលអន្តរកាល ៨ ឆ្នាំ គិតរហូតដល់ថ្ងៃទី១ ខែមករា ឆ្នាំ២០០០ និងអនុវត្តចំពោះប្រទេសក្រីក្រ បន្ទាប់ពីពេល ៨ ឆ្នាំ (គិតដល់ថ្ងៃទី១ ខែមករា ឆ្នាំ២០០៣) ។

ឧបត្ថម្ភធនសំរាប់ជំរុញឯកជនភាវូបនីយកម្ម

ដើម្បីជំរុញឯកជនភាវូបនីយកម្ម កិច្ចព្រមព្រៀងចែងថា "ការលើកលែងដោយផ្ទាល់នូវសំណងឧបត្ថម្ភធនសំរាប់គ្របដណ្តប់លើចំណាយសង្គម ទោះតាមទំរង់ណាក៏ដោយ រួមមានការលះបង់ចំណូលរដ្ឋាភិបាល....." ដោយរដ្ឋាភិបាលនៃប្រទេសកំពុងអភិវឌ្ឍន៍ គួរត្រូវបានចាត់ទុកជាឧបត្ថម្ភធនដែលមិនអាចប្តឹងបានទៅវិញទៅមក ប្រសិនបើឧបត្ថម្ភធន នោះត្រូវបានផ្តល់អោយក្នុងរយៈពេលមានកំណត់ និងដោយអនុលោមទៅតាមកម្មវិធីឯកជនភាវូបនីយកម្ម ។ ឧបត្ថម្ភធនទាំងនេះ នៅតែស្ថិតនៅក្រោមវិធានការប៉ះប៉ូវដដែល ។

* *បណ្តាប្រទេសដែលមានប្រាក់ចំណូលទាប ដែលមាន GNP តិចជាង ១000 ដុល្លារអាមេរិករួមមាន: ប្រទេស Bolivia, Cameroon, Cote d'Ivoire, the Domnican Republic, Egypt, Ghana, Guatemala, Guyana, India, Indonesia, Kenya, Morocco, Nicaragua, Nigeria, Pakistan, the Philippines, Senegal, Sri Lanka និង Zimbabwe. ។ ក៏ប៉ុន្តែមានការស្នើសុំអោយប្រទេសទាំងនេះទទួលយកកាតព្វកិច្ច ហាមឃាត់ការប្រើប្រាស់ឧបត្ថម្ភធននៃការនាំចេញ នៅពេលដែល GNP របស់គេឡើងដល់ ១ 000 ដុល្លារអាមេរិក ។*

គោលការណ៍ដែលអាចប្តឹងបាន គឺការប៉ះពាល់ធ្ងន់ធ្ងរ ទៅលើផលប្រយោជន៍របស់បណ្តាប្រទេសផ្សេងៗទៀត ។ គេអាចប្តឹងបាន នៅពេលផលិតផលដែលទទួលបានឧបត្ថម្ភធន មានលក់ជំនួសការនាំចេញរបស់ភាគីដើមចោទ នៅទីផ្សារនៃប្រទេសដែលផ្តល់ឧបត្ថម្ភធន ឬ ក៏នៅប្រទេសទីបី ។ វណ្ឌ ២៤ នឹងរៀបរាប់ពិពណ៌នាអំពីលក្ខណៈវិនិច្ឆ័យមួយ ដែលកិច្ចព្រមព្រៀងបានចែងសំរាប់កំណត់ថាតើឧបត្ថម្ភធនដែលបានផ្តល់អោយដោយប្រទេសណាមួយនោះ បណ្តាលអោយមានការប៉ះពាល់ខ្លាំង ទៅលើផលប្រយោជន៍របស់បណ្តាប្រទេសជាសមាជិកផ្សេងទៀតឬទេ ។

ខណ្ឌ ២៤

លក្ខណៈវិនិច្ឆ័យសំរាប់កំណត់ពីការប៉ះពាល់ធ្ងន់ធ្ងរ ទៅលើផលប្រយោជន៍របស់ប្រទេសដទៃទៀត (SCM មាត្រា៦) កិច្ចព្រមព្រៀងបានបញ្ជាក់ច្បាស់ថា មានការប៉ះពាល់ធ្ងន់ធ្ងរទៅលើផលប្រយោជន៍របស់ប្រទេសផ្សេងទៀត នៅក្នុងករណីដូចតទៅ ÷

- ☐ *ប្រាក់ឧបត្ថម្ភធន ad valorem និងសរុប លើផលិតផលមានលើសពី ៥%*
- ☐ *ឧបត្ថម្ភធនគ្របដណ្តប់លើការខាតបង់នៃកិច្ចដំណើរការដែលមានជាប្រចាំលើឧស្សាហកម្ម*
- ☐ *ឧបត្ថម្ភធនផ្សេងៗទៀត ក្រៅពីវិធានការមួយដង ដែលគ្របដណ្តប់លើការបាត់បង់ក្នុងកិច្ចដំណើរការរបស់សហគ្រាសឬ*

ការលើកលែងបំណុលដោយផ្ទាល់ពីរដ្ឋាភិបាលក្នុងរាល់ករណីទាំងអស់ ដើម្បីកំណត់ថាមានការកើតឡើងនូវការប៉ះពាល់ធ្ងន់ធ្ងរ ភាគីដើមចោទត្រូវបង្ហាញថា ផលប៉ះពាល់នៃឧបត្ថម្ភធននោះគឺ ÷

- ☐ *ការផ្លាស់ប្តូរទីកន្លែង ឬ ការបង្អាក់ការនាំចូលពីបណ្តាលប្រទេសនានាជាសមាជិកចូលមកក្នុងប្រទេសដែលផ្តល់ឧបត្ថម្ភធន*
- ☐ *ផ្លាស់ប្តូរទីកន្លែងនាំចេញទៅកាន់ទីផ្សារនៃប្រទេសទីពា*
- ☐ *ដែលសំខាន់ធ្វើការទប់ស្កាត់ ឬ ទប់ស្កាត់តំលៃនៅក្នុងទីផ្សារដែលផ្តល់ឧបត្ថម្ភធន*
- ☐ *ការកើនឡើងនូវចំណែកទីផ្សារពិភពលោករបស់ប្រទេសដែលផ្តល់ឧបត្ថម្ភធន លើសពីមធ្យមភាគនៃចំណែកកាលពី ៣ ឆ្នាំ មុនទៅលើផលិតផល ឬ របស់ប្រើប្រាស់ដែលបានទទួលផលប្រយោជន៍ពីឧបត្ថម្ភធន ។*

ការខូចខាតធ្ងន់ធ្ងរ គឺជាកត្តាផ្សេងទៀតសំរាប់ធ្វើការប្តឹងផ្តល់ ។ ដោយឡែក វាគឺជាមូលដ្ឋានគ្រឹះ សំរាប់កំណត់ពន្ធប៉ះប៉ូវលើការនាំចូលដែលមានឧបត្ថម្ភធន ហើយដែលបង្កអោយមានការខូចខាតដល់ឧស្សាហកម្មក្នុងស្រុក ។

ឧបត្ថម្ភធន ដែលបង្កអោយមានមោឃៈភាព និងការខូចខាតដល់ផលប្រយោជន៍ដែលប្រព័ន្ធ GATT ផ្តល់អោយ អាចក្លាយទៅឧបត្ថម្ភដែលអាចប្តឹងបានដែរ ។ ការបង្ករអោយមានមោឃភាព និងការធ្វើអោយខូចខាតផលប្រយោជន៍អាចចាត់ទុកថា កើតមានឡើង នៅពេលដែលប្រទេសនាំចេញរកឃើញថា តំលៃសម្បទានក្នុងទំរង់ជាអត្រាពន្ធគយដែលមានប្រសិទ្ធិភាពចងភ្ជាប់ ដែលគេទទួលបានក្នុងពេលចរចារពាណិជ្ជកម្មតាមរយៈការផ្តល់សម្បទានទៅវិញទៅមក ត្រូវបានកាត់បន្ថយគួរអោយកត់សំគាល់ ដោយសារឧស្សាហកម្មក្នុងស្រុកបានបាត់បង់ចំណែកទីផ្សារ ទៅលើឧស្សាហកម្មក្នុងប្រទេសនាំចូល ដែលបានទទួលផលប្រយោជន៍មកពីឧបត្ថម្ភធន។

ឧបត្ថម្ភធនដែលអនុញ្ញាត ហើយមិនអាចប្តឹងបាន (ឧបត្ថម្ភធនភ្លើងបៃតង)

កិច្ចព្រមព្រៀង SCM មាត្រា ៤, ៧, ៩

ដោយមានអញ្ញត្រកម្មមួយចំនួន រាល់ឧបត្ថម្ភធនដែលអនុញ្ញាត គឺជាឧបត្ថម្ភធនជាក់លាក់អាចប្តឹងបាន ។ ឯឧបត្ថម្ភធនដែលមិនជាក់លាក់គឺមិនអាចប្តឹងបានឡើយ ។ កម្មវិធីឧបត្ថម្ភធន ដែលចែងពីឧបត្ថម្ភធនលើមូលដ្ឋាននៃលក្ខណៈវិនិច្ឆ័យសេដ្ឋកិច្ច គឺជាលក្ខណៈទូលំទូលាយ និងមិនផ្តល់ភាពអនុគ្រោះដល់សហគ្រាសណាមួយជាងសហគ្រាសផ្សេងទៀតបានឡើយ ។ ឧបត្ថម្ភធនបែបនេះជាឧបត្ថម្ភធនមិនអាចប្តឹងបាន ។ ដូច្នេះឧបត្ថម្ភធន ដែលផ្តល់អោយដោយរដ្ឋាភិបាលទៅអោយសហគ្រាស ធុនតូច និងធុនមធ្យមបានបញ្ជាក់អោយឃើញតាមមូលដ្ឋាននៃទំហំ ឬ ចំនួនបុគ្គលិកដែលជាធម្មតា គឺជាឧបត្ថម្ភធនដែលមិនអាចប្តឹងបាន ។

ក្រៅពីនេះ ឧបត្ថម្ភធនជាក់លាក់ គឺជាឧបត្ថម្ភធន មិនអាចប្តឹងបាន ប្រសិនបើល័ក្ខខ័ណ្ឌមួយចំនួនគ្របដណ្តប់ទៅលើការផ្តល់ឧបត្ថម្ភធនរបស់គេនោះស្របទៅតាមវិធាននៃកិច្ចព្រមព្រៀង ។ ឧបត្ថម្ភធនរួមមានឧបត្ថម្ភធនសំរាប់ ÷

- ☐ សកម្មភាពស្រាវជ្រាវដឹកនាំដោយក្រុមហ៊ុន ដែលចែងពីល័ក្ខខ័ណ្ឌមួយចំនួនដែលត្រូវបំពេញ
- ☐ អនុវត្តតាមសម្បទាផលិតផលជាធរមាន ចំពោះតំរូវការបរិយាកាសថ្មី ដែលចែងថា ឧបត្ថម្ភធន គឺជាវិធានការដែលមិនអាចកើតមានឡើងជាថ្មី,, (one-time non-recurring measure) និងត្រូវបានកំណត់ ២០% នៃតំលៃលើការអនុវត្តន៏តាម ។
- ☐ ជួយអភិវឌ្ឍន៏ឧស្សាហកម្មក្នុងតំបន់ ដែលមិនបានទទួលអត្ថប្រយោជន៍ ប្រសិនបើបានបំពេញតាមលក្ខខ័ណ្ឌជាក់លាក់ ប្រទេសនាំចូលមិនអាចកំណត់ពន្ធប៉ះប៉ូវលើផលិតផលដែលបានទទួលផលប្រយោជន៍ពីឧបត្ថម្ភធនដែលមិនអាចប្តឹងបាននេះឡើយ។

សំណួរដែលមានចំពោះឧស្សាហកម្មដែលទទួលរងនូវផលប៉ះពាល់ និងចំពោះរដ្ឋាភិបាលរបស់ពួកគេ

តើមានសំណាងអ្វីខ្លះសំរាប់ឧស្សាហកម្ម និងសំរាប់រដ្ឋាភិបាលនៃប្រទេសដែលគិតថា ផលប្រយោជន៍របស់គេកំពុងទទួលរងនូវការខូចខាតដោយសារការនាំចូលដែលមានឧបត្ថម្ភធន ?

កិច្ចព្រមព្រៀងចែងពីសំណងដែលមាន ពីរ ប្រភេទ ។ ទីមួយ ប្រទេសដែលចាត់ទុកថាបានប្រើប្រាស់ឧបត្ថម្ភធនហាមឃាត់ ឬប្រទេសដែលទទួលរងនូវផលប៉ះពាល់មិនល្អ ដោយសារឧបត្ថម្ភធន ដែលអនុញ្ញាតិ អាចលើកបញ្ហានេះជូនទៅអង្គភាពដោះស្រាយវិវាទ (DSB) របស់ WTO ដើម្បីធ្វើការកែប្រែ ។ នៅពេលដែលផលប៉ះពាល់កើតឡើងក្នុងទំរង់នៃការខូចខាតធ្ងន់ធ្ងរ ចំពោះឧស្សាហកម្មក្នុងស្រុករបស់គេ ក្រៅពីការប្រើប្រាស់នីតិវិធីដោះស្រាយវិវាទ ប្រទេសនាំចូលអាចកំណត់ពន្ធប៉ះប៉ូវ ទៅលើផលិតផលនាំចូលដែលមានឧបត្ថម្ភធន (សូមមើលវណ្ឌ ២៥) ។ ក៏ប៉ុន្តែ ពន្ធបែបនេះ អាចអនុវត្តបានក្រោយពីមានការស៊ើបអង្កេតនៅកំរិតជាតិ និងតាមបណ្តឹងរបស់ឧស្សាហកម្មដែលទទួលរងនូវផលប៉ះពាល់ ដែលបញ្ជាក់ថា ការនាំចូលដោយមានឧបត្ថម្ភធននោះបង្កការខូចខាតដល់ឧស្សាហកម្មក្នុងស្រុក ។ ពន្ធប៉ះប៉ូវមិនអាចដាក់បានទៅលើផលិតផលដែលបានទទួលផលប្រយោជន៍ពីឧបត្ថម្ភធនដែលមិនអាចប្តឹងបានឡើយ ។

> ខណ្ឌ ២៥
>
> ***សំណងសំរាប់ប្រទេសនាំចូលតាមកិច្ចព្រមព្រៀង SCM***
>
> *មាត្រា ៤ ៧ និង ៨)*
>
> *សំណាងមានពីរប្រភេទ សំរាប់ប្រទេសនាំចូលដែលគិតថា ការប្រើប្រាស់ឧបត្ថម្ភធន ដោយប្រទេសជាសមាជិកផ្សេងទៀតកំពុងបង្កផលប៉ះពាល់មិនល្អដល់ផលប្រយោជន៍របស់គេ ។ គេអាចដាក់ពន្ធប៉ះប៉ូវបាន ក្រោយពេលស៊ើបអង្កេតដោយអនុលោមទៅតាមបណ្តឹងរបស់ឧស្សាហកម្មណា ដែលទទួលរងនូវផលប៉ះពាល់មិនល្អនេះ និងបើគេអាចបញ្ជាក់ថាការនាំចូលដោយមានឧបត្ថម្ភធននោះ បង្កការខូចខាតធ្ងន់ធ្ងរដល់ឧស្សាហកម្មរបស់គេ ។ គេអាចធ្វើការកែសំរួលបញ្ហាទាំងនេះបាន ចំពោះមុខអង្គភាពដោះស្រាយវិវាទ ។*
>
> ***ឧបត្ថម្ភធនហាមឃាត់:*** *ប្រទេសណាមួយក៏ដោយដែលជឿជាក់ថាប្រទេសដទៃទៀតកំពុងប្រើប្រាស់ឧបត្ថម្ភធនហាមឃាត់ ហើយប្រសិនបើការពិភាក្សាទ្វេភាគីមិនអាចធ្វើអោយប្រទេសផ្តល់ឧបត្ថម្ភធនលប់ចោលការឧបត្ថម្ភធននោះបានទេ ពេលនោះប្រទេសដែលអាចទទួលរងនូវផលប៉ះពាល់អាចដាក់ពាក្យប្តឹងទៅ DSB ។*
>
> ***ឧបត្ថម្ភធនដែលអាចប្តឹងបាន:*** *បើប្រទេសណារកឃើញថា ប្រទេសណាមួយផ្សេងទៀតបានផ្តល់ឧបត្ថម្ភធនដែលអាចប្តឹងបាន ហើយឧបត្ថម្ភធននេះបង្កផលប៉ះពាល់មិនល្អដល់ផលប្រយោជន៍របស់គេ នោះគេអាចពាក្យប្តឹងទៅ DSB ដើម្បីដោះស្រាយ ប្រសិនបើការពិភាក្សាទ្វេភាគីមិនអាចសំរេចបាននូវដំណោះស្រាយសមស្របទៅវិញទៅមក។*
>
> ***ឧបត្ថម្ភធនដែលមិនអាចប្តឹងបាន:*** *ពន្ធប៉ះប៉ូវមិនអាចដាក់ទៅលើផលិតផលដែលបានទទួលអត្ថប្រយោជន៍ពីឧបត្ថម្ភធនដែលមិនអាចប្តឹងបាននេះឡើយ ។ ទោះជាយ៉ាងណាក៏ដោយ នៅពេលដែលប្រទេសណាមួយ "មានហេតុផលច្បាស់លាស់ក្នុងការជឿជាក់" ថាកម្មវិធីឧបត្ថម្ភធន មាន "ផលប៉ះពាល់ធ្ងន់ធ្ងរ" ទៅលើឧស្សាហកម្មក្នុងស្រុករបស់គេ និងបង្កការខូចខាតយ៉ាងធ្ងន់ធ្ងរដែលការខូចខាតនេះពិបាកនឹងជួសជុលឡើងវិញ នោះគេអាចស្នើសុំអោយមានកិច្ចពិភាក្សាជាមួយប្រទេសដែលផ្តល់ឧបត្ថម្ភធន ។ បើសិនជាការចរចាបរាជ័យ នេះគេអាចស្នើសុំទៅគណៈកម្មាធិការឧបត្ថម្ភធន និងវិធានការប៉ះប៉ូវ ដែលបានបង្កើតឡើងតាមកិច្ចព្រមព្រៀង ធ្វើការកំណត់ថាតើផលប៉ះពាល់បែបនោះមានមែនឬអត់។*

នៅក្នុងករណីទាំងបីដែលបានលើកឡើងខាងលើនេះ បើសិនជាប្រទេសផ្តល់ឧបត្ថម្ភធន ខកខានមិនបានចាត់វិធានការសមស្រប ដើម្បីអនុវត្តតាមអនុសាសន៍ដែលបានធ្វើនោះទេ DSB / គណៈកម្មាធិការឧបត្ថម្ភធន និងវិធានការប៉ះប៉ូវអាចផ្តល់សិទ្ធិអំណាចទៅអោយប្រទេសដែលទទួលរងនូវផលប៉ះពាល់ ចាត់វិធានការតបត ដែលអាចបង្កផលប៉ះពាល់ដល់ពាណិជ្ជកម្មនៃប្រទេសដែលផ្តល់ឧបត្ថម្ភធននោះ ។

កិច្ចព្រមព្រៀង SCM កំណត់នូវវិធាន និងនីតិវិធីលំអិតដល់អាជ្ញាធរស៊ើបអង្កេតសំរាប់អនុវត្តតាម ក្នុងការស៊ើបអង្កេត និងធ្វើការគណនានូវចំនួននៃពន្ធប៉ះប៉ូវដែលអាចដាក់បានទៅលើផលិតផល ។ ដោយសារវិធានដែលអាចអនុវត្តបានទៅលើការដាក់ពន្ធប៉ះប៉ូវ និងទៅលើការប្រើប្រាស់វិធានការប្រឆាំងនឹងការលក់បង្ខូចថ្លៃ មានលក្ខណៈប្រហាក់ប្រហែលគ្នា និងដោយសារនៅក្នុងបណ្តា

ប្រទេសភាគច្រើន ការស៊ើបអង្កេតសំរាប់កំណត់ពន្ធទាំងពីរប្រភេទ ត្រូវបានធ្វើឡើងដោយអាជ្ញាធរស៊ើបអង្កេតតែមួយ ដូច្នេះ វិធានទាំងនេះនឹងមានពន្យល់រួមគ្នានៅក្នុងជំពូក ១១ ។

ការពាក់ព័ន្ធផ្នែកពាណិជ្ជកម្ម

វិធានប្រឆាំងនឹងការប្រើប្រាស់ឧបត្ថម្ភធនលើការនាំចេញផលិតផលឧស្សាហកម្ម ដែលកន្លងមកមានអនុវត្តសំរាប់តែប្រទេសជឿនលឿន បច្ចុប្បន្ននេះក៏មានអនុវត្តផងដែរ ចំពោះបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ ។ (លើកលែងតែប្រទេសក្រីក្រ និងប្រទេសដែលកំពុងអភិវឌ្ឍន៍ ដែល GNP មានតិចជាង ១០០០ ដុល្លា) ។ ប្រទេសទាំងនេះមានរយៈពេលអន្តរកាលចំនួន ៨ ឆ្នាំ (គិតដល់ ថ្ងៃទី១ ខែមករា ឆ្នាំ២០០៣) ដែលក្នុងរយៈពេលនោះ គេត្រូវលប់បំបាត់ចោលនូវប្រព័ន្ធឧបត្ថម្ភធនជាធរមានរបស់គេ ។ ក្នុងរយៈពេលនោះ គេមិនអាចបង្កើនកំរិតឧបត្ថម្ភធនរបស់គេ ឬ ផ្តល់ឧបត្ថម្ភធនទៅលើផលិតផលណាដែលមិនធ្លាប់ផ្តល់ពីមុនមកទេ ។ សហគ្រាសបច្ចុប្បន្នដែលបានទទួលផលប្រយោជន៍ពីឧបត្ថម្ភធននាំចេញ ត្រូវត្រៀមខ្លួនលប់ចោលឧបត្ថម្ភធន ដែលផ្តល់អោយដោយរដ្ឋាភិបាលមុនពេលចប់រយៈពេលអន្តរកាល ប្រសិនបើមិនបានមុន ។

គួរកត់សំគាល់ផងដែរថា នៅពេលដែលកិច្ចព្រមព្រៀង SCM អនុញ្ញាតអោយប្រទេសកំពុងអភិវឌ្ឍន៍ ប្រើប្រាស់ឧបត្ថម្ភធននាំចេញក្នុងរយៈពេលអន្តរកាល ហើយឧបត្ថម្ភធនទាំងនេះអាចត្រូវបានប៉ះប៉ូវដោយប្រទេសនាំចូលក្នុងរយៈពេលអន្តរកាល ប្រសិនបើឧបត្ថម្ភធននោះបង្កផលប៉ះពាល់ដល់ឧស្សាហកម្មក្នុងស្រុករបស់គេ ។ ការប៉ះប៉ូវនេះអាចអនុវត្តផងដែរទៅលើបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ដែលបានលើកលែងពីវិធានហាមឃាត់ស្តីពីការប្រើប្រាស់ឧបត្ថម្ភធននាំចេញ ។ ការរក្សាទុកឧបត្ថម្ភធននាំចេញលើផលិតផល ដែលត្រូវបានចាត់ទុកថា ជាការនាំចូលប្រកបដោយវេទយិតភាពដោយប្រទេសនាំចូល (ឧទាហរណ៍ វាយនភ័ណ្ឌ ស្បែកសត្វ និងផលិតផលស្បែកសត្វ ។ល។) ត្រូវបានអនុញ្ញាតិយ៉ាងតឹងតែងបំផុតតាមកិច្ចព្រមព្រៀង ដោយសារវាជាបញ្ហាប្រកបដោយគ្រោះថ្នាក់ ។ ដូច្នេះជាកត្តាសំខាន់សំរាប់ រដ្ឋាភិបាលក្នុងការទទួលយកគោលនយោបាយរូបិយវត្ថុបរទេស និងពាណិជ្ជកម្ម ដែលត្រូវលប់ចោលភាពលំអៀងចំពោះការនាំចេញរបស់ប្រទេសពួកគេ និងកាត់បន្ថយតំរូវការឧបត្ថម្ភធននាំចេញ ។ ជាការចាំបាច់ផងដែរសំរាប់ពួកគេ ក្នុងការត្រួតពិនិត្យ ដោយពិភាក្សា និងសហការជាមួយសហគ្រាសនាំចេញ និងសមាគមន៍របស់គេ ថាតើគេត្រូវការឧបត្ថម្ភធនដែលអនុញ្ញាតិក្នុងទ្រង់ទ្រាយបែបណា សំរាប់អ្វី និងឧបត្ថម្ភធន ដែលមិនអាចប្តឹងបានបែបណា ដោយប្រទេសនាំចូល។ ក្នុងបរិបទនេះ ជាសំខាន់ត្រូវកត់សំគាល់ថា ឧបត្ថម្ភធនមិនមានបញ្ហាក់ច្បាស់លាស់សំរាប់ឧស្សាហកម្មណាទេ ប៉ុន្តែអាចអនុវត្តបានជាទូទៅ ដោយមិនអាចប៉ះប៉ូវបានដោយប្រទេសនាំចូល ។ នៅក្នុងអត្ថន័យនេះ វាមានលក្ខណៈសំខាន់ដែលកំណត់ថា ប្រាក់ជំនួយគឺមានលក្ខណៈពិសេសសំរាប់សហគ្រាសជាក់លាក់ណាមួយ ក៏ប៉ុន្តែវាមានលក្ខណៈជាការប្រើប្រាស់ទូទៅដែលមិនមានសំណាងពីបណ្តាប្រទេសនាំចូលនេះ ។

ជំពូក៩

វិធានការការពារខ្លួន ដើម្បីដាក់កំហិតលើការនាំចូលក្នុងស្ថានការមានអាសន្ន

សេចក្តីសង្ខេប

កិច្ចព្រមព្រៀងស្តីពីវិធានការការពារ អនុញ្ញាតិឱ្យប្រទេសនាំចូល ដាក់កំហិតលើការនាំចូលក្នុងរយៈពេលជាបណ្តោះអាសន្ន ប្រសិនបើអាជ្ញាធរមានសមត្ថកិច្ចអង្កេតឃើញថា បរិមាណនៃការនាំចូលកើនឡើង (កើនពិតប្រាកដ ឬ កើនឡើង បើធៀបទៅផលិតកម្មក្នុងស្រុក) ហើយអាចធ្វើឱ្យមានគ្រោះថ្នាក់យ៉ាងធ្ងន់ធ្ងរ ចំពោះឧស្សាហកម្មក្នុងស្រុកដែលផលិតផលិតផលដូចគ្នា ឬ ដែលមានការប្រកួតប្រជែងផ្ទាល់ ។ កិច្ចព្រមព្រៀងបានបន្ថែមទៀតថា វិធានការការពារខ្លួន អាចធ្វើឡើងក្នុងទំរង់នៃការបង្កើនអត្រាពន្ធលើអត្រាដែលមានប្រសិទ្ធិភាពចងភ្ជាប់ ឬ ជាដាក់កំហិតលើបរិមាណ ដែលការងារនេះជាធម្មតាអាចត្រូវគេអនុវត្តន៍លើមូលដ្ឋាន MFN ចំពោះការនាំចូលពីគ្រប់ប្រភពទាំងអស់ ។

ការស៊ើបអង្កេតដើម្បីដាក់វិធានការដូច្នេះ អាចផ្តួចផ្តើមឡើងដោយរដ្ឋាភិបាលខ្លួនឯង ឬ នៅពេលមានការប្តឹងតវ៉ាពីឧស្សាហកម្មដែលទទួលរងនូវផលប៉ះពាល់ ។ ក៏ប៉ុន្តែជាក់ស្តែង ការស៊ើបអង្កេតជាទូទៅ អាចផ្តួចផ្តើមឡើងនៅពេលមានការប្តឹងតវ៉ាពីឧស្សាហកម្មដែលទទួលរងនូវផលប៉ះពាល់។

កិច្ចព្រមព្រៀង បានកំណត់នូវលក្ខណៈវិនិច្ឆ័យសំរាប់អោយអាជ្ញាធរស៊ើបអង្កេតយកមកពិចារណាក្នុងការសំរេចចិត្ត ថាតើ ការនាំចូលដែលកើនឡើងនោះ បង្កអោយមានការខូចខាតយ៉ាងធ្ងន់ធ្ងរដល់ឧស្សាហកម្មក្នុងស្រុកឬទេ ។ កិច្ចព្រមព្រៀងក៏កំណត់នូវតំរូវការតាមនីតិវិធីជាមូលដ្ឋាន សំរាប់អនុវត្តការស៊ើបអង្កេតផងដែរ ។ គោលបំណងមួយនៃតំរូវការតាមនីតិវិធី គឺដើម្បីផ្តល់ឱ្យអ្នកផ្គត់ផ្គង់បរទេស និងរដ្ឋាភិបាលដែលផលប្រយោជន៍របស់គេអាចទទួលរងនូវផលប៉ះពាល់មិនល្អ ដោយវិធានការការពារខ្លួនដែលបានស្នើឡើងនេះ នូវកាលានុវត្តន៍ភាពគ្រប់គ្រាន់ ដើម្បីផ្តល់នូវភស្តុតាង និងដើម្បីការពារអត្ថប្រយោជន៍របស់ពួកគេ ។

គោលដៅជាបឋម នៃការផ្តល់វិធានការការពារជាបណ្តោះអាសន្ននេះ គឺដើម្បីផ្តល់ពេលវេលាអោយឧស្សាហកម្មដែលទទួលរងនូវផលប៉ះពាល់មិនល្អ ត្រៀមខ្លួនដើម្បីប្រឈមមុខនឹងការប្រកួតប្រជែងដែលកើនឡើង ក្រោយពេលលប់ចោលការដាក់កំហិតលើការនាំចូល ។ កិច្ចព្រមព្រៀងធានាអោយការដាក់កំហិតរបៀបនេះ អនុវត្តបានតែក្នុងគ្រាបណ្តោះអាសន្ន ដែលមានជាអតិបរមា ៨ ឆ្នាំ ដើម្បីអនុវត្តន៍វិធានការនៅលើផលិតផលជាក់លាក់ណាមួយ ។ ប្រទេសកំពុងអភិវឌ្ឍន៍ អាចដាក់វិធានការទាំងនេះបានសំរាប់រយៈពេល ១០ ឆ្នាំ ។

ត្រូវផ្តល់ពេលវេលាអោយឧស្សាហកម្ម កែតំរូវបន្តិចម្តងៗ ឈានទៅរកការប្រកួតប្រជែងដែលកើនឡើង បណ្តាលមកពីការកាត់បន្ថយអត្រាពន្ធគយ និងការលុបចោលរបាំងពាណិជ្ជកម្មផ្សេងៗទៀត ។ ក្នុងការអនុវត្តន៍ GATT ទាមទារអោយមានការឯកភាពគ្នាក្នុងការកាត់ចោលនូវអត្រាពន្ធគយ ក្នុងពេលចរចារពាណិជ្ជកម្មពហុភាគី ក្នុងរយៈពេលមួយតែប៉ុណ្ណោះ។ ដូច្នេះនៅក្នុងកិច្ចប្រជុំនៅឃ្យូរ៉ូហ្គាយ គេបានព្រមព្រៀងគ្នា កាត់បន្ថយអត្រាពន្ធគយ លើផលិតផលឧស្សាហកម្ម ក្នុងរយៈពេលបណ្តាក់ ៥ ឆ្នាំ ជា ៥ ដងស្មើៗគ្នា ។ ដូចគ្នានេះដែរ ការកាត់បន្ថយអត្រាពន្ធគយទៅលើផលិតផលកសិកម្ម ព្រមទាំងឧបត្ថម្ភធនក្នុងស្រុក និងនាំចេញអាចធ្វើឡើងក្នុងដំណាក់កាលជាដំណាក់ៗ ៦ ឆ្នាំ ។ ប្រទេសកំពុងអភិវឌ្ឍន៍បានទទួល រយៈពេលវែងជាង ដើម្បីអនុវត្តការកាត់បន្ថយនេះ ។

វិធានរបស់ GATT ទទួលស្គាល់ថា ទោះជាការអនុវត្តន៍កាត់បន្ថយតារាងពន្ធមានជាដំណាក់ៗក៏ដោយ ក៏ក្នុងរយៈពេលខ្លីមានវិស័យឧស្សាហកម្ម ឬ កសិកម្មមួយចំនួនអាចប្រឈមមុខជាមួយនឹងបញ្ហាកែតំរូវទៅតាមការប្រកួតប្រជែងនាំចូលដែលកើនឡើង។ បញ្ហាទាំងនេះអាចកើតចេញអំពីភាពបរាជ័យរបស់គេ ក្នុងការធ្វើសនិទានកម្មរចនាសម្ព័ន្ធ ផលិតកម្មឱ្យបានត្រឹមត្រូវ ឬ ដើម្បីអនុវត្តន៍នូវនិមិត្តកម្មបច្ចេកទេសចាំបាច់ ដើម្បីបង្កើនផលិតភាព ។ ដើម្បីផ្តល់ពេលវេលាដល់ឧស្សាហកម្ម ដែលទទួលរងនូវផលប៉ះពាល់មិនល្អ

GATT 1994
មាត្រា XIX:1 (ក)

កែតំរូវអោយស្របទៅតាមការប្រកួតប្រជែង មាត្រា១៩ នៃ GATT បានចែងថា ជាលទ្ធផលនៃការកាត់បន្ថយតារាងពន្ធ ប្រទេសដែលរកឃើញថា ផលិតផលដែលកំពុងត្រូវបានគេនាំចូលមក "ក្នុងរូបភាពជាការបង្កើនបរិមាណ និងក្រោមល័ក្ខខ័ណ្ឌ ដូចជា ធ្វើឱ្យខូចខាត ឬ គំរាមកំហែងធ្ងន់ធ្ងរដល់ផលិតករក្នុងស្រុក" នោះប្រទេស ក្នុងស្រុកអាចដាក់វិធានការពារខ្លួនដើម្បីដាក់កំហិតលើការនាំចូលនោះ ក្នុងរយៈពេលជាបណ្តោះអាសន្នសិន ។

ភាពវៀសវាងវិធានការ GATT តាមរយៈ VERs

ដោយសារ GATT មានតំរូវការជាច្រើនចែងថា វិធានការការពារខ្លួនគួរអនុវត្តឡើង ដោយឈរលើគោលការណ៍មិនរើសអើង កន្លងមកប្រទេសនានាបានរៀបចំដោយស្ម័គ្រចិត្តនូវការដាក់កំហិតលើការនាំចេញ VER ឬ ការរៀបចំទីផ្សារដោយមានរបៀបរៀបរយ (OMAS) ។ តាមកិច្ចព្រមព្រៀងទាំងនេះ ប្រទេសនាំចូលបានបានដាក់កំហិតលើការនាំចូលរបស់គេ ទៅតាមចំនួនដែលបានព្រមព្រៀងមួយ ចំពោះប្រទេសនាំចេញដែលចង់បង្កើនការនាំចេញរបស់គេ ។ ទោះបីជាកិច្ចព្រមព្រៀងទាំងនេះ គេអោយឈ្មោះហៅថា "ជាកិច្ចព្រមព្រៀងដោយស្ម័គ្រចិត្ត" ក៏ដោយ ក៏តាមពិតពួកគេមិនដែលអនុវត្តន៍បែបដូចនេះទេ ។ ពីព្រោះការដាក់កំហិត អនុវត្តតែលើការនាំចូលពីប្រទេសមួយចំនួនប៉ុណ្ណោះ ដូច្នេះការកំហិតបែបនេះ មិនស្របទៅនឹងវិធានដែលចែងថា ការដាក់កំហិតលើការនាំចូលត្រូវអនុវត្តឡើងដោយឈរលើគោលការណ៍មិនរើសអើងនោះឡើយ ។

ការប្រើប្រាស់វិធានការដែលមិនច្បាស់លាស់ (គេហៅដូច្នេះ ដោយសារតែវាមិនស្របទៅនឹងវិធានរបស់ GATT) ដោយប្រទេសជឿនលឿនមួយចំនួនជាអាទិ៍ USA សមាជិកសហគមអឺរ៉ុប បានកើនឡើងក្នុងកំឡុងពេលបីទស្សវត្សចុងក្រោយនេះ ។ រដ្ឋាភិបាលនៃប្រទេសទាំងនោះ ពេលខ្លះបានជំរុញលើកទឹកចិត្ត និងពេលខ្លះគាំទ្រនូវគំនិតផ្តួចផ្តើមនានាដែលស្នើឡើង ដោយឧស្សាហកម្មរបស់ពួកគេ ដើម្បីរៀបចំដោយស្ម័គ្រចិត្តនូវកិច្ចព្រមព្រៀងដាក់កំហិតលើការនាំចេញ ជាមួយប្រទេសដៃគូរនៅក្នុងប្រទេសនាំចេញនានា។ តាមការប៉ាន់ស្មានបានអោយដឹងថានៅឆ្នាំ ១៩៩៥ ពេលដែល WTO បានកើតជារូបរាងឡើង មានកិច្ចព្រមព្រៀងទ្វេភាគី និងពហុភាគីជាង ២០០ ។ កិច្ចព្រមព្រៀងទាំងនេះ គ្របដណ្តប់លើផលិតផលនានា រាប់ទាំងទំនិញកសិកម្ម (ដូចជា សាច់គោ) ទំនិញពាណិជ្ជកម្មសាមញ្ញ (ដូចជា ផលិតផលធ្វើអំពីជ័រកៅស៊ូ ទំនិញសំរាប់ទេសចរណ៍, ឆ្នាំងដី និងគ្រឿងចានព៌ណសខៀវ និងស្បែកសត្វ...) រហូតដល់ផលិតផលជឿនលឿនដូចជា ទូរទស្សន៍ ម៉ាស៊ីនទេសចរណ៍ និងរថយន្តដឹកជញ្ជូន ។

កិច្ចព្រមព្រៀងស្តីពីវិធានការការការពារខ្លួន (Safeguards)

ការសន្យាលុបចោល VER

គោលបំណងដ៏សំខាន់នៃការចចារនៅយូរ៉ូហ្គាយ ក្នុងវិស័យនេះ គឺដើម្បីធានាថា វិធាននៃការដាក់កំហិត ដូចជា VER និងវិធានការដែលរើសអើងដទៃទៀតដែលស្រដៀងគ្នា ត្រូវលើកយកមកពិចារណាកែប្រែអោយស្របទៅតាមវិធាន និងគោលការណ៍របស់ GATT ។ កិច្ចព្រមព្រៀងស្តីពីវិធានការការពារខ្លួន (ដែលបានចចារគ្នាក្នុងវគ្គប្រជុំ) បានស្នើអោយប្រទេសជាច្រើនលប់ចោលនូវវិធានការមិនច្បាស់លាស់ (grey areas) ដែលគេអាចរក្សាទុកបានក្នុងរយៈពេល៤ឆ្នាំ (ឧទាហរណ៍ មុនថ្ងៃទី១ មករា ១៩៩៩)[១២] ។ ក្រៅពីនេះ ប្រទេសនានាបានសន្យាថា "មិនស្វែងរក ឬ ចាត់វិធានការ ឬ ថែរក្សាការដាក់កំហិតលើការ

---

[១២] ទោះបីជាយ៉ាងណាក៏ដោយ សមាជិករបស់ប្រទេសនីមួយៗអាចរក្សាទុកនូវវិធានការនេះ ក្នុងរយៈពេលមួយឆ្នាំបន្ថែម ។

នាំចេញដោយស្ម័គ្រចិត្ត ការរៀបចំទីផ្សារឱ្យមានរបៀបរៀបរយ ឬ វិធានការស្រដៀងគ្នាដទៃទៀត ចំពោះផ្នែកនៃការនាំចេញ ឬ នាំចូលណាទេ ។ កិច្ចព្រមព្រៀង ក៏ទាមទារឱ្យមានការលើកទឹកចិត្ត ឬ គាំទ្រការអនុវត្តន៍ ឬ ការថែរក្សា" នៃការរៀបចំអន្តរឧស្សាហកម្មដែលស្របទៅតាមវិធានការនានារបស់រដ្ឋាភិបាលដែលបានរៀបរាប់ពីខាងលើដែរ ។

ស្តង់ដារនៃការខូចខាតដ៏ធ្ងន់ធ្ងរ

កិច្ចព្រមព្រៀង បានចែងបន្ថែមទៀតថា វិធានការការពារខ្លួន អាចធ្វើឡើងតែក្នុងករណីដែលបានកំណត់ ដោយអាជ្ញាធរស៊ើបអង្កេតថា ÷

កិច្ចព្រមព្រៀងស្តីពីវិធានការការពារ មាត្រា២

- ☐ ផលិតផលបាននឹងកំពុងនាំចូលក្នុងបរិមាណមួយដែលកើនឡើង (ពិតប្រាកដ ឬ ធៀបនឹងផលិតផលក្នុងស្រុក)
- ☐ នៅក្នុងល័ក្ខខ័ណ្ឌដែលបង្កអោយខូចខាត ឬ គំរាមកំហែងយ៉ាងធ្ងន់ធ្ងរចំពោះផលិតករដែលផលិត ផលិតផលប្រហាក់ប្រហែលគ្នា ឬ ផលិតផលដែលមានការប្រកួតប្រជែងដោយផ្ទាល់ ។

កិច្ចព្រមព្រៀងស្តីពីវិធានការការពារ មាត្រា៤

ពាក្យថា "ការខូចខាតធ្ងន់ធ្ងរ" ត្រូវបានកំណត់ថាជា "ការខូចខាតធ្ងន់ធ្ងរគួរអោយកត់សំគាល់ ចំពោះឧស្សាហកម្មក្នុងស្រុក"។ ការនាំចូលធ្វើឱ្យមានការខូចខាតឧស្សាហកម្មក្នុងស្រុក ត្រូវបានកំណត់នៅពេលដែលមានការប៉ះពាល់ដល់ "ផលិតករទាំងមូលដែលមានផលិតផលដូចគ្នា ឬ ផលិតផលប្រកួតប្រជែងដោយផ្ទាល់" ឬ ឧស្សាហកម្មក្នុងស្រុកទាំងឡាយណាដែលទិន្នផលសម្ភូហភាពនៃផលិតកម្ម ឬ ផលិតផលប្រកួតប្រជែងដោយផ្ទាល់ បង្កើតជាសមាមាត្រដ៏ច្រើនលើសលុបនៃផលិតផលក្នុងស្រុកសរុបទាំងអស់នេះ។ ម៉្យាងទៀត គេមិនអាចចាត់វិធានការការពារខ្លួន ដើម្បីដាក់កំហិតលើការនាំចូល នៅពេលដែលផលិតករមួយចំនួនតូច យល់ឃើញថា គេមានបញ្ហាលំបាកក្នុងការប្រកួតប្រជែងលើការនាំចូលនេះឡើយ ។

វិធានគ្រប់គ្រងការស៊ើបអង្កេត

កិច្ចព្រមព្រៀងតំរូវអោយប្រទេសជាសមាជិកតែងតាំងអាជ្ញាធររបស់ខ្លួន ទទួលខុសត្រូវលើការស៊ើបអង្កេត និងត្រូវធ្វើការបោះពុម្ពផ្សាយនីតិវិធីដែលត្រូវអនុវត្តតាម ដើម្បីអោយសាធារណៈជនបានដឹង ។

រដ្ឋាភិបាលខ្លួនឯង ឬ ឧស្សាហកម្មណាដែលមានទិន្នផលរួមបង្កើតបានជាសមាមាត្រដ៏ធំមួយនៃផលិតកម្មក្នុងស្រុកលើផលិតផលនាំចូល អាចផ្តួចផ្តើមគំនិតស្នើរសុំស៊ើបអង្កេត ។ ក៏ប៉ុន្តែ ជាក់ស្តែងការស៊ើបអង្កេត ជាទូទៅអាចកើតមានឡើងដោយមានការស្នើសុំពីផលិតករ ឬ ដោយសមាគមន៏តាងនាមអោយផលិតករ ។ ការស្នើសុំនោះជាក់ស្តែង តែងតែតវ៉ាថា ការនាំចូលដែលកាន់តែកើនឡើងនោះ កំពុងធ្វើឱ្យផលិតករ ទទួលរងនូវការខូចខាតយ៉ាងធ្ងន់ធ្ងរ នាំឱ្យមានការបាត់បង់ប្រាក់ចំណេញ កាត់បន្ថយផលិតកម្ម និងការប្រើប្រាស់មិនបានពេញលេញនូវសមត្ថភាព និង/ឬទាមទារអោយមានការកាត់បន្ថយកំលាំងពលកម្ម។

កិច្ចព្រមព្រៀងស្តីពីវិធានការការពារ មាត្រា ៣

អាជ្ញាធរស៊ើបអង្កេតត្រូវផ្តល់សេចក្តីជូនដំណឹងជាសាធារណៈ អំពីការស៊ើបអង្កេត និងរៀបចំធ្វើសវនាការសាធារណៈ ឬ ចាត់វិធានការសមស្របផ្សេងៗទៀត ដើម្បីអោយ "អ្នកនាំចូល អ្នកនាំចេញ និងភាគីពាក់ព័ន្ធដទៃទៀតអាចបង្ហាញភស្តុតាង និងបញ្ចេញទស្សនៈរបស់ពួកគេបាន"។ អាជ្ញាធរត្រូវពិនិត្យទស្សនៈ និងមតិប្រឆាំងនឹងចំណាត់ការការពារដែលស្នើឡើង ហើយពិនិត្យមើលថាតើការអនុវត្តន៏វិធានការទាំងនេះ អាចផ្តល់ផលប្រយោជន៏ជូនសាធារណៈជនយ៉ាងដូម្តេច ។

កិច្ចព្រមព្រៀងស្តីពីវិធានការការពារ មាត្រា ៤:២

អាជ្ញាធរស៊ើបអង្កេតអាចអនុញ្ញាត្តិ អោយមានវិធានការការពារខ្លួនបានបន្ទាប់ពីបានវាយតំលៃលើកត្តាពាក់ព័ន្ធ ចំពោះកម្មវត្ថុ និងប្រភេទបរិមាណទាំងអស់ដែលបង្កផលវិបាករវាងការនាំចូលដែលកើនឡើងទៅនឹងផលិតផលដែលពាក់ព័ន្ធ និងគ្រោះថ្នាក់គំរាមកំហែងដ៏ធ្ងន់ធ្ងរចំពោះឧស្សាហកម្ម ។ មិនអនុញ្ញាតិអោយមានវិធានការការពារខ្លួនទេ ប្រសិនបើបញ្ហាឧស្សាហកម្មដែលកំពុងប្រឈមមុខនោះ កើតចេញអំពីកត្តាដទៃទៀតក្រៅពីការនាំចូលដែលកើនឡើងនោះ "ឧទាហរណ៍ ការធ្លាក់ចុះនូវតំរូវការទូទៅលើផលិតផលនានា"។ ដើម្បីផ្តល់នូវតម្លាភាព អាជ្ញាធរស៊ើបអង្កេតចាំបាច់ត្រូវតែបោះពុម្ភ ផ្សាយនូវរបាយការណ៍ និងសេចក្តីសន្និដ្ឋាននានារបស់គេ ។

ការអនុវត្តន៍វិធានការការពារខ្លួន

កិច្ចព្រមព្រៀងស្តីពីវិធានការការពារ បុព្វកថា

កិច្ចព្រមព្រៀងបានសង្កត់ធ្ងន់ថា ដើម្បីប្រកាន់យកវិធានការការពារ រដ្ឋាភិបាលមានបំណងជំរុញ "ការកែប្រែរចនាសម្ព័ន្ធ" និង ដើម្បី "កែលំអអ្វីផ្សេងក្រៅពីជំរុញការប្រកួតប្រជែងក្នុងទីផ្សារអន្តរជាតិ" ។ កិច្ចព្រមព្រៀងក៏បានចែងដែរថា វិធានការការពារខ្លួនទាំងនេះ អាចយកមកអនុវត្តបាន តែក្នុងរយៈពេលបណ្តោះអាសន្នតែប៉ុណ្ណោះ ដើម្បីឱ្យឧស្សាហកម្មដែលទទួលរងការប៉ះពាល់ អាចចាត់វិធានការកែតំរូវខ្លួនឯង អោយស្របទៅតាមការប្រកួតប្រជែងដែលមានច្រើនឡើងៗ នៅពេលលុបចោលនូវវិធានទាំងនោះ។ ត្រូវធ្វើការកែប្រែ ក្នុងទំរង់ជាការអនុវត្តន៍បច្ចេកវិទ្យាដែលបានកែលំអ ឬ សនិទានកម្មនៃការរៀបចំរចនាសម្ព័ន្ធផលិតកម្ម ។

កិច្ចព្រមព្រៀងស្តីពីវិធានការការពារ មាត្រា ៥

លើសពីនេះទៀត វិធានការការពារខ្លួន អាចអនុវត្តន៍បានក្នុង "ករណីចាំបាច់ ដើម្បីការពារ ឬ ចេញសំណងចំពោះការខូចខាតដ៏ធ្ងន់ធ្ងរ និងដើម្បីសំរួលអោយមានការកែតំរូវផ្សេងៗ " ដោយឈរលើ "មូលដ្ឋានមិនរើសអើង ចំពោះការនាំចូលពីគ្រប់ប្រភពទាំងអស់" ។ ប្រភេទនៃវិធានការការពារខ្លួន ដែលគេប្រកាន់យក - គឺការបង្កើនអត្រាពន្ធគយដែលមានប្រសិទ្ធិភាពចងភ្ជាប់ ឬការដាក់កំហិតទៅលើបរិមាណនៃការនាំចូល - ហើយអាជ្ញាធរស៊ើបអង្កេតជាអ្នកសំរេចរាល់ល័ក្ខខ័ណ្ឌទាំងនេះ ។ នៅពេលដែលគេប្រើប្រាស់វិធានការដាក់កំហិតលើបរិមាណ នោះគេត្រូវធ្វើការបែងចែកកូតា ក្នុងចំណោមប្រទេសផ្គត់ផ្គង់សំខាន់ៗ ។ នៅក្នុងករណីនេះ ការបែងចែកចំណែកនីមួយៗ ធ្វើឡើងដោយមានការពិភាក្សាគ្នាជាមួយប្រទេសផ្គត់ផ្គង់ ដោយផ្អែកលើមូលដ្ឋាននៃចំណែករបស់គេក្នុងការនាំចូលកន្លងមក។ ក្នុងការបែងចែកចំណែកតាមរបៀបនេះ គេត្រូវពិចារណាអោយបានគ្រប់គ្រាន់ផងដែរពីការផ្តល់ផលប្រយោជន៍អោយអ្នកផ្គត់ផ្គង់ថ្មី ។

ក្នុងស្ថានការណ៍លើកលែងមួយចំនួន កិច្ចព្រមព្រៀងបានអនុញ្ញាតិអោយប្រទេសជាសមាជិកនានា អនុវត្តខុសពីវិធានស្តីពីការមិនរើសអើង និងអនុវត្តការដាក់កំហិតលើកូតាលើប្រទេសមួយចំនួន នៅពេលដែលការនាំចេញពីប្រទេសនោះ "បានកើនលើសពីភាគរយ មិនសមាមាត្រទៅនឹងកំណើននៃការនាំចូលសរុបនៃផលិតផលនោះកន្លងមក "។ ដើម្បីធានាអោយមានការអនុវត្តន៍ចំណាត់ការនោះ តែក្នុងករណីលើកលែងមែន កិច្ចព្រមព្រៀងបានកំណត់ថា ចំណាត់ការនេះអាចប្រកាន់យកបាន បន្ទាប់ពីមានការពិគ្រោះយោបល់ និងបន្ទាប់ពីបានអនុម័តដោយគណៈកម្មាធិការស្តីពីវិធានការការពារ ។ គណៈកម្មាធិការនេះ ត្រូវបានបង្កើតឡើងក្រោមកិច្ចព្រមព្រៀង។

សំណងលើការខាតបង់ចំពោះពាណិជ្ជកម្ម

កិច្ចព្រមព្រៀងស្តីពីវិធានការការពារ មាត្រា៨

គេរំពឹងថា ប្រទេសជាសមាជិកដែលស្នើសុំអនុវត្តន៍វិធានការការពារ នឹងផ្តល់នូវសំណងលើការខូចខាតផ្នែកពាណិជ្ជកម្មរបស់ប្រទេសទាំងឡាយដែលផលប្រយោជន៍របស់គេទទួលរងនូវផលប៉ះពាល់មិនល្អ ដោយសារតែចំណាត់ការនោះ។[១៣] ប្រសិនបើ កិច្ចព្រមព្រៀងស្តីអំពីសំណងការខូចខាតពាណិជ្ជកម្មគ្រប់គ្រាន់មិនអាចសំរេចបាន ដោយប្រទេសដែលស្នើសុំអនុវត្តន៍វិធានការការពារខ្លួនទេនោះ ប្រទេសជាសមាជិកដែលការនាំចេញរបស់គេទទួលរងនូវផលប៉ះពាល់ និងប្រទេសនាំចេញ អាចចាត់វិធានការសងសឹកបាន[១៤]។ ក៏ប៉ុន្តែសិទ្ធិចាត់វិធានការសងសឹក មិនអាចអនុវត្តន៍បាន ក្នុងរយៈពេលបីឆ្នាំដំបូង ពេលដែលវិធានការចូលជាធរមានទេ គឺនៅពេលដែលវិធានការការពារខ្លួននោះត្រូវគេធ្វើឡើងឱ្យស្របគ្នាទៅនឹងបទបញ្ញត្តិនៃកិច្ចព្រមព្រៀង ហើយជាលទ្ធផលការនាំចូលបានកើនឡើងពិតប្រាកដ "មិនទាក់ទងចំពោះផលិតផលក្នុងស្រុកក៏ដោយ"។

ប្រព្រឹត្តកម្មពិសេស និងដោយឡែករបស់ប្រទេសកំពុងអភិវឌ្ឍន៍

កិច្ចព្រមព្រៀងស្តីពីវិធានការការពារ មាត្រា ៩

កិច្ចព្រមព្រៀងចែងពីប្រព្រឹត្តកម្មពិសេស និងដោយឡែកចំពោះប្រទេសកំពុងអភិវឌ្ឍន៍ ក្នុងការអនុវត្តន៍វិធានការការពារខ្លួន ។ ការនាំចូលពីប្រទេសកំពុងអភិវឌ្ឍន៍ ត្រូវបានលើកលែងពីវិធានការការពារខ្លួន ប្រសិនណាបើចំណែកនៃការនាំចូលផលិតផលដែល

[១៣] សំណងជាទូទៅគឺជា សម្បទាន ក្នុងទំរង់នៃការកាត់បន្ថយអត្រាពន្ធគយពីប្រទេសដែលមានបំណងចាត់វិធានការការពារខ្លួន ទៅលើប្រទេសដែលពាណិជ្ជកម្មរបស់គេ ត្រូវទទួលរងនូវការដាក់កំហិតលើផលិតផលផ្សេងៗដែលនាំចេញទៅកាន់ប្រទេសរបស់គេ ។

[១៤] សកម្មភាពសងសឹកនេះ ជាទូទៅជាការបញ្ឈប់ការធ្វើសម្បទាន ឬកាតព្វកិច្ចដ៏ទៃទៀតដែលប្រទេសនោះអនុវត្តន៍នូវវិធានការការពារ ។

ពាក់ព័ន្ធចូលទៅក្នុងប្រទេសនោះមានទំហំតិចជាង 3% ។ ការលើកលែងនេះ មិនអាចអនុវត្តបានទេ ប្រសិនបើការនាំចូលនីមួយៗ របស់ប្រទេសកំពុងអភិវឌ្ឍន៍ មានតិចជាង 3% សរុបចំនួនច្រើនជាង 9% នៃការនាំចូលទាំងអស់ ។

រយៈពេលនៃវិធានការការពារខ្លួន

កិច្ចព្រមព្រៀងស្តីពី វិធានការការពារ មាត្រា ៧

បទបញ្ញត្តិដទៃទៀត នៃកិច្ចព្រមព្រៀង មានចង្អុលបង្ហាញពីការធានា ចំពោះការអនុវត្តនីវិធានការការពារខ្លួន ក្នុងកំឡុងពេល បណ្តោះអាសន្ន។ កិច្ចព្រមព្រៀងចែងថា ÷

- ☐ វិធានការការពារខ្លួន បានចូលជាធរមាន នាថ្ងៃទី ០១ មករា ឆ្នាំ ១៩៩៥ គឺនៅពេលដែលកិច្ចព្រមព្រៀងចូលជាធរមាន ហើយវិធានការនេះនឹងត្រូវបញ្ចប់បន្ទាប់ពី ៨ ឆ្នាំក្រោយ ឬ មុនថ្ងៃទី ០១ មករា ឆ្នាំ ២០០០ ឬ យូរជាងនេះ ។
- ☐ រយៈពេលអតិបរិមាដំបូងសំរាប់អនុវត្តវិធានការការពារខ្លួន គឺមានរយៈពេល ៤ ឆ្នាំ ។ រយៈពេលដំបូងនេះអាចពន្យាបាន រហូតដល់ ៨ ឆ្នាំ (ប្រទេសកំពុងអភិវឌ្ឍន៍ខ្លះមានរយៈពេលរហូតដល់១០ឆ្នាំ) ។

ដើម្បីជួយអោយឧស្សាហកម្មដែលទទួលរងនូវផលប៉ះពាល់ អាចរៀបចំខ្លួនចំពោះការប្រកួតប្រជែងដែលកើនឡើងនោះ និង អនុវត្តតាមការផ្លាស់ប្តូរនៃវិធានការការពារ កិច្ចព្រមព្រៀងទាមទារអោយមានរយៈពេលច្រើនជាង ១ ឆ្នាំ ដើម្បីអោយវិធាន នោះមានភាពរីវត្តនីកាន់តែសេរី ។ មានការពិនិត្យវិធានការឡើងវិញក្នុងពាក់កណ្តាលអាណត្តិនៃ រយៈពេល ៣ឆ្នាំ ដើម្បីពិនិត្យ អោយឃើញច្បាស់ថា ត្រូវដកចេញនូវវិធានការទាំងនោះ ឬ បន្ថែមល្បឿនអោយមានភាពសេរីបន្ថែមទៀត ។

ក្រៅពីនេះ កិច្ចព្រមព្រៀងបានរាំងប្រទេសនានា ពីការគេចវេសកំណត់ពេលវេលា ចំពោះវិធានការការពារ ដោយការហាមឃាត់ ការដាក់កំហិតឡើងវិញ ដើម្បីការពារផលិតផលដូចគ្នា ។ ក្នុងករណីមួយដែលវិធានការនេះ មិនអាចត្រូវគេដាក់អោយអនុវត្ត សារជាថ្មី ក្នុងរយៈកាលតិចជាង ២ ឆ្នាំ ។ លើសពីនេះទៅ ទៀតវិធានការការពារខ្លួនជាបណ្តោះអាសន្ន ដែលគេធ្វើឡើងសំរាប់រយៈពេល ៦ ខែ ឬ តិចជាង អាចយកមកអនុវត្តជាថ្មីបាន បន្ទាប់ពីរយៈពេល ១ ឆ្នាំ ដរាបណាគេមិនបានចាត់វិធានការនោះឡើង លើ ផលិតផលដូចគ្នាច្រើនជាង២ដងក្នុងរយៈពេល៥ឆ្នាំ ។ មួយវិញទៀត ប្រទេសកំពុងអភិវឌ្ឍន៍មានកាតព្វកិច្ចតិចជាងប្រទេសជឿនលឿន ឬ ប្រទេសកំពុងអភិវឌ្ឍន៍អាចចាត់វិធានការសារជាថ្មី ទៅលើផលិតផលដូចគ្នាបន្ទាប់ពីកំលុងពេលស្មើគ្នា (ប៉ុន្តែមិនអាចតិចជាងរយៈពេល ២ឆ្នាំឡើយ) ។

ការពាក់ព័ន្ធផ្នែកពាណិជ្ជកម្ម

វិធានថ្មី និងដែលបានកែលំអស្តីពីវិធានការការពារបានពង្រឹងវិធានរបស់ GATT ដែលចែងពីការធានាបើកទីផ្សារ ។ មានការហាមឃាត់មិនអោយប្រទេសនាំចូល ស្នើសុំសហគ្រាសនៃប្រទេសនាំចេញ ដាក់កំហិតលើការនាំចេញរបស់ពួកគេតាម កិច្ចព្រមព្រៀងណាមួយ ដែលប្រហាក់ប្រហែលគ្នា ឬ តាម VER ។ ជាសំខាន់ត្រូវកត់សំគាល់ថា រដ្ឋាភិបាលនានា មិនគួរលើក ទឹកចិត្តអោយឧស្សាហកម្មរបស់ខ្លួន ចុះកិច្ចព្រមព្រៀងបែបនេះជាមួយឧស្សាហកម្មនៃប្រទេសដទៃទៀតឡើយ កិច្ចព្រមព្រៀងបាន រាំងឧស្សាហកម្មពីការចុះកិច្ចសន្យាប្រហាក់ប្រហែលគ្នា ទោះបីស្ថិតនៅលើមូលដ្ឋានមិនជាផ្លូវការក៏ដោយ ។

ដូចដែលបានបញ្ជាក់ពីខាងលើរួចមកហើយ អត្រាពន្ធភាគច្រើនរបស់ប្រទេសជឿនលឿន និងសមាមាត្រដ៏ខ្ពស់នៃអត្រាពន្ធរបស់ ប្រទេសកំពុងអភិវឌ្ឍន៍មានប្រសិទ្ធិភាពចងភ្ជាប់មិនអោយកើនឡើងថែមទៀត ដូច្នេះជាការដាក់កំហិតមិនអោយប្រទេសនានា មានសិទ្ធិក្នុងការដំឡើងពន្ធគយ ។ យោងតាមវិធាននៃកិច្ចព្រមព្រៀងស្តីពីវិធានការការពារខ្លួន ប្រទេសនាំចូលនានា អាចមាន លទ្ធភាពចាត់វិធានដាក់កំហិតលើការនាំចូលបាន ក្រោយពីការស៊ើបអង្កេតបង្ហាញអោយឃើញថាការនាំចូលទាំងនេះ បង្កការ ខូចខាតធ្ងន់ធ្ងរចំពោះឧស្សាហកម្មក្នុងស្រុករបស់គេ ។ វិធាននេះព្យាយាមការពារអត្ថប្រយោជន៍នៃសហគ្រាសនាំចេញបន្ថែមទៀត ដោយការផ្តល់អោយសហគ្រាសទាំងនោះនូវសិទ្ធិ ដើម្បីការពារអត្ថប្រយោជន៍របស់ពួកគេក្នុងពេលស៊ើបអង្កេត ហើយប្រសិនបើចាំបាច់

ត្រូវផ្ដល់ភស្តុតាងបញ្ជាក់ថា ការដាក់កំហិតនោះមិនមែនជាផលប្រយោជន៍របស់សាធារណៈជនដែលជាអ្នកប្រើប្រាស់ក្នុងប្រទេសនាំចូលឡើយ ។

លើសពីនេះទៀត ជាកត្តាសំខាន់ត្រូវកត់សំគាល់ថា វិធានទូទៅស្ដីពីវិធានការពារខ្លួនមិនអាចអនុវត្តន៍បាន លើផលិតផលវាយនភ័ណ្ឌឡើយ។ កិច្ចព្រមព្រៀងស្ដីពីវាយនភ័ណ្ឌ និងសំលៀកបំពាក់ ដែលបានចរចារនៅក្នុងវគ្គប្រជុំយូរ៉ូហ្គាយ បានចែងថា បច្ចុប្បន្ននេះ ការដាក់កំហិតដែលមានភាពរើសអើងត្រូវអនុវត្ត ចំពោះផលិតផលវាយនភ័ណ្ឌ ដោយប្រទេសនាំចូលមួយចំនួន តែគេនឹងលុបបំបាត់ចោលការដាក់កំហិតនេះបន្តិចម្តងៗជា៤ ដំណាក់កាលក្នុងកំលុងពេល ១០ ឆ្នាំនេះ ។ នៅក្នុងដំនាក់កាលលប់ចោល កិច្ចព្រមព្រៀងអនុញ្ញាតិអោយប្រទេសនានា ចាត់វិធានការការពារខ្លួន ដើម្បីដាក់កំហិតលើការនាំចូលតាមមូលដ្ឋានរើសអើង ពីប្រទេសនាំចេញនានា ឬ ពីប្រទេសណា " ដែលការនាំចូលរបស់គេមានការកើនឡើងយ៉ាងរហ័ស និងគួរអោយកត់សំគាល់ " ពីប្រទេសទាំងនេះ ឬ " បង្កការខូចខាតធ្ងន់ធ្ងរដល់ឧស្សាហកម្មក្នុងស្រុក ។

ពាណិជ្ជកម្មវាយនភ័ណ្ឌ ត្រូវបានគ្រប់គ្រងដោយវិធាននៃកិច្ចព្រមព្រៀងស្ដីពីវិធានការការពារ ដោយឈរលើគោលការណ៍មិនរើសអើង បន្ទាប់ពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០០៥ ។ មកដល់កាលបរិច្ឆេទនោះ កិច្ចព្រមព្រៀងស្ដីពីវាយនភ័ណ្ឌ និងសំលៀកបំពាក់ ដែលគេបានអនុវត្តអស់រយៈពេល ១០ឆ្នាំ មកហើយនោះនឹងលែងមានប្រសិទ្ធិភាពតទៅទៀតហើយ។

ជាប្រការសំខាន់ ត្រូវក្រលេកមើលទៅវិធានទាំងនោះមិនត្រឹមតែពីទស្សនៈរបស់សហគ្រាសនាំចេញប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងពីទស្សនៈវិស័យនៃសហគ្រាសនានានាដែលយល់ឃើញថាការកើនឡើងយ៉ាងរហ័សភ្លាមៗក្នុងការនាំចូល និងធ្វើអោយពួកគេជួបប្រទះនឹងការលំបាកលំបិនក្នុងការប្រកួតប្រជែងជាមួយអ្នកផ្គត់ផ្គង់បរទេសនៅទីផ្សារក្នុងស្រុករបស់ពួកគេ ។ សហគ្រាស ទាំងនោះមានសិទ្ធិប្ដឹងតវ៉ាទៅរដ្ឋាភិបាលរបស់ពួកគេ អោយចាត់វិធានការការពារខ្លួន ដើម្បីដាក់កំហិតលើការនាំចូល ។ ក្រុមហ៊ុនមួយ ឬសហគ្រាសមួយចំនួនតូចមិនអាចធ្វើបណ្ដឹងតវ៉ានេះបានទេ ប៉ុន្តែផលិតករណាដែលផលិតកម្មរបស់គេមានចំណែកសមាមាត្រភាគច្រើននៃផលិតកម្មក្នុងស្រុកសរុប ទើបអាចធ្វើបណ្ដឹងតវ៉ានោះបាន ។ ជាក់ស្ដែង បណ្ដឹងតវ៉ា ឬការអនុវត្តនីវិធានការពារខ្លួនជារឿយៗ គឺតែងតែធ្វើឡើងដោយសមាគមន៍ ជួសមុខឱ្យផលិតករទាំងអស់ ។ គេអាចដាក់បណ្ដឹងតវ៉ាបាន នៅពេលដែលគេមានលទ្ធភាពបញ្ជាក់ពីទំនាក់ទំនងនៃការបង្កអោយមានគ្រោះថ្នាក់រវាងការនាំចូលដែលកើនឡើង និងការខូចខាតធ្ងន់ធ្ងរជាក់លាក់ចំពោះឧស្សាហកម្ម ។ សមត្ថភាពរបស់ឧស្សាហកម្មដែលទទួលរងនូវផលប៉ះពាល់ ក្នុងការស្រូបទាញយកឧត្តមភាពពីបទបញ្ញត្តិទាំងនោះអាស្រ័យទៅលើកត្តាថាតើ ពួកគេមានលទ្ធភាពយ៉ាងណាក្នុងការការពាររឿងក្ដីរបស់ខ្លួន ដោយពិចារណាទៅលើល័ក្ខខ័ណ្ឌតឹងរឹងនៃកិច្ចព្រមព្រៀង ដើម្បីដាក់វិធានការការពារខ្លួននោះ ។

ជំពូក១០

វិធានការការពារខ្លួន ក្នុងគោលបំណងអភិវឌ្ឍន៍សេដ្ឋកិច្ច : ភាពដែលអាចបត់បែនបានជាពិសេសសំរាប់ប្រទេសកំពុងអភិវឌ្ឍន៍

សេចក្តីសង្ខេប

វិធាន GATT បានចែងពីភាពដែលអាចបត់បែនបានជាពិសេស សំរាប់ប្រទេសកំពុងអភិវឌ្ឍន៍ ដើម្បីចាត់វិធានការការពារខ្លួនចំពោះការដាក់កំហិតលើការនាំចូលក្នុងរយៈពេលបណ្តោះអាសន្ន ដើម្បីជំរុញការអភិវឌ្ឍន៍ថ្មី ឬ ជំរុញឧស្សាហកម្មផុនតូច។ ក៏ប៉ុន្តែ វិធាន GATT បានកំណត់នូវលក្ខខ័ណ្ឌយ៉ាងតឹងរឹង សំរាប់ការបង្កើតវិធានទាំងនោះ។ មួយវិញទៀត វិធានការការពារខ្លួនអាចត្រូវគេដាក់ឱ្យអនុវត្តន៍លុះត្រាតែមានការអនុម័តពី WTO ។

GATT ១៩៩៤
មាត្រា ១៨: ផ្នែកគ
កិច្ចប្រជុំ Tokyo
(Tokyo Round) :
សេចក្តីប្រកាស : វិធានការការពារខ្លួនក្នុងគោលបំណងអភិវឌ្ឍន៍

វិធាន GATT ទទួលស្គាល់ថា ដោយអនុលោមទៅតាមកម្មវិធី និងការអភិវឌ្ឍន៍គោលនយោបាយសេដ្ឋកិច្ចរបស់ខ្លួន រដ្ឋាភិបាលនៃប្រទេសកំពុងអភិវឌ្ឍន៍ អាចស្វែងរកនូវភាពចាំបាច់ទាំងឡាយ ដើម្បីផ្តល់ជាជំនួយដល់ឧស្សាហកម្មថ្មី ឬ ផុនតូច ឬ សំរាប់ការអភិវឌ្ឍន៍ឧស្សាហកម្មដែលមានស្រាប់បន្ថែមទៀត ហើយដែលការផ្តល់ជំនួយទាំងនោះអាចធ្វើក្នុងទំរង់ជាវិធានការការពារខ្លួន ដើម្បីដាក់កំហិតលើការនាំចូលក្នុងរយៈពេលបណ្តោះអាសន្ន ។ ប្រសិនបើការដាក់ការកំហិតនេះ បង្កអោយមានផលប៉ះពាល់មិនល្អដល់អត្ថប្រយោជន៍នៃប្រទេសនាំចេញនោះ ជាវិធានអាចកំណត់លក្ខខ័ណ្ឌតឹងរ៉ឹងជាង ដើម្បីអនុម័ត ។

លក្ខខ័ណ្ឌនៃការប្រើប្រាស់បទបញ្ញត្តិស្តីពីវិធានការការពារខ្លួន

រដ្ឋាភិបាលណាដែលចង់ការពារខ្លួនតាមរយៈការដាក់កំហិតលើការនាំចូល ត្រូវជូនដំណឹងទៅអគ្គលេខាធិការដ្ឋានរបស់ WTO អំពី÷

- ☐ ការអភិវឌ្ឍន៍ឧស្សាហកម្មជាក់លាក់ណាមួយ ឬ ច្រើនដែលមានស្រាប់ ឬ បង្កើតថ្មី ឬ ចាស់ ហើយដែលចាំបាច់ត្រូវការវិធានការការពារខ្លួន ។
- ☐ ប្រភេទនៃវិធានការដាក់កំហិតដែលស្នើឡើង (ដូចជា ការតំឡើងអត្រាពន្ធដែលមានប្រសិទ្ធិភាពចងភ្ជាប់ មិនអាចតំឡើងបាន ការដាក់កំហិតលើបរិមាណនៃការនាំចូល ឬ ដាក់ឱ្យអនុវត្តន៍នូវប្រព័ន្ធចេញអាជ្ញាប័ណ្ណនានា ។
- ☐ ភាពលំបាកពិសេសៗ ដែលចោទជាបញ្ហាដល់ការនាំចូលសំរាប់ការអភិវឌ្ឍន៍ឧស្សាហកម្មទាំងនោះ ។
- ☐ វិធានដ៏ទៃទៀត ក្រៅពីការដាក់កំហិតលើការនាំចូល ហើយដែលមិនអាចយកមកអនុវត្តបាន ។

ត្រូវធ្វើសេចក្តីជូនដំណឹង មុនពេលអនុវត្តវិធានការ ។ ក្នុងករណីលើកលែង ប្រសិនបើមានការយឺតយ៉ាវក្នុងការអនុវត្តនិវិធានការ ដោយសារវាអាចចោទជាភាពលំបាកដល់ឧស្សាហកម្មពាក់ព័ន្ធនានា នោះការជូនដំណឹងអាចធ្វើឡើងភ្លាមៗ បន្ទាប់ពីដាក់វិធានការអនុវត្ត។

ការដាក់ឱ្យអនុវត្តន៏វិធានការការពារខ្លួន ឬ ការបន្តអនុវត្ត នៅពេលដែលសេចក្តីជូនដំណឹងត្រូវបានធ្វើឡើង បន្ទាប់ពីវិធានការបានត្រូវគេដាក់ឱ្យអនុវត្តន៍[៧៥] ជាធម្មតា និងប្រសិនបើប្រទេសជាសមាជិករបស់ WTO យល់ព្រម បន្ទាប់ពីបានពិនិត្យមើលហេតុផលនានាហើយ ។

ការពាក់ព័ន្ធផ្នែកពាណិជ្ជកម្ម

ក្នុងការអនុវត្តន៍ជាក់ស្តែង ប្រទេសកំពុងអភិវឌ្ឍន៍អាចប្រើប្រាស់ភាពដែលអាចបត់បែនបាន ជាពិសេសមួយចំនួន ។ មូលហេតុសំខាន់មួយក្នុងចំណោមមូលហេតុនានា គឺថាតារាងពន្ធគយនៃប្រទេសកំពុងអភិវឌ្ឍន៍ មិនមានប្រសិទ្ធិភាពចងភ្ជាប់ប្រឆាំងនឹងការតំឡើងបានឡើយ រហូតដល់មានសេចក្តីសន្និដ្ឋាននាវគ្គប្រជុំនៅឃ្យូរ៉ុយហ្គាយ ។ ហេតុផលដ៏សំខាន់នេះផ្តល់លទ្ធភាពអោយប្រទេសកំពុងអភិវឌ្ឍន៍ការពារឧស្សាហកម្មដ៏ក្មេងខ្ចីរបស់គេបាន និងនៅពេលចាំបាច់គេអាចតំឡើងអត្រាពន្ធបានទៀត ។

នៅក្នុងវគ្គប្រជុំឃ្យូរ៉ុយហ្គាយ ដូចដែលបានបញ្ជាក់ពីខាងលើ សមាមាត្រមួយភាគធំនៃតារាងពន្ធគយរបស់ប្រទេសកំពុងអភិវឌ្ឍន៍មានប្រសិទ្ធិភាពចងភ្ជាប់មិនអាចតំឡើងបានទៀតទេ ។ សហគ្រាសក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ជឿជាក់ថា គេត្រូវការការពារខ្លួនឱ្យបានច្រើន ដើម្បីអភិវឌ្ឍន៍ឧស្សាហកម្មក្មេងខ្ចីរបស់គេ ឬ ដើម្បីអភិវឌ្ឍន៍បន្ថែមទៀតនូវឧស្សាហកម្មដែលមានស្រាប់ ដូច្នេះគេត្រូវស្នើសុំអោយរដ្ឋាភិបាលរបស់គេអនុវត្តបទបញ្ញត្តិស្តីពី " វិធានការការពារខ្លួន ក្នុងគោលបំណងអភិវឌ្ឍន៍"។ មួយវិញទៀត រដ្ឋាភិបាលនានាត្រូវស្នើសុំការអនុម័តពី WTO ជាមុនសិន មុននឹងអនុវត្តន៏វិធានការទាំងនោះ (ដូចជា ការដំឡើងអត្រាពន្ធគយ ឬ ការដាក់កំហិតលើបរិមាណទំនិញជាដើម) ។

ដោយការអនុម័តវិធានការទាំងនោះ គឺជាសជិប្បញ្ញត្តិនៃវិធានជាមូលដ្ឋាននានា WTO នឹងផ្តល់ការអនុម័តបានលុះត្រាតែប្រទេសជាសមាជិកទាំងអស់យល់ព្រមពេញចិត្ត ដោយយកមកពិចារណានូវកត្តាដែលមានផ្សេងៗ ដូចជា ធនធានធម្មជាតិ និងផលិតកម្មដែលមានស្រាប់ ព្រមទាំងនិន្នាការប្រើប្រាស់ ព្រោះការការពារកំរិតខ្ពស់អាចជួយអោយឧស្សាហកម្មមានលក្ខណៈប្រកួតប្រជែងជាអន្តរជាតិ ក្នុងកំឡុងពេលសមស្របណាមួយ ។ ជាងនេះទៅទៀត ក្នុងការអនុម័តបែបនេះ WTO អាចដាក់លក្ខខ័ណ្ឌតឹងរឹង ដើម្បីធានាថាការដាក់កំហិតលើបរិមាណអាចធ្វើបានតែក្នុងរយៈកាលបណ្តោះអាសន្នតែប៉ុណ្ណោះ ហើយធានាអោយមានការលប់បំបាត់ចោលបន្តិចម្តងៗនូវវិធានការនានា ក្នុងរយៈពេលនោះដែរ ។

[៧៥] ប្រសិនបើ អត្រាពន្ធទៅលើផលិតផលមួយមានប្រសិទ្ធិភាពចងភ្ជាប់មិនអាចតំឡើងទៀតបាន នោះការអនុវត្តន៏វិធានការដាក់កំហិតអាចធ្វើបានដរាបណាមានយល់ព្រមជាមុនពី WTO ។ ទោះបីយ៉ាងណាក៏ដោយ នៅពេលដែលអត្រាពន្ធមិនមានប្រសិទ្ធិភាពចងភ្ជាប់ នោះមានជំរើស ២ ដែលបើកចំហរចំពោះប្រទេសកំពុងអភិវឌ្ឍន៍ដែលមានបំណងផ្តល់ការការពារ ។ គេអាចបង្កើនអត្រាពន្ធគយ ។ នៅពេលដែលអត្រាពន្ធកើនឡើង នោះពុំមានការចងភ្ជាប់ដែលអាចធ្វើទៅបានតាមវិធានរបស់ GATT ទេ ហើយគេអាចចាត់វិធានការដែលមិនប៉ះពាល់ដល់បទបញ្ញត្តិ GATT មាត្រា XVIII:C ។ ទោះបីយ៉ាងណាក៏ដោយ នៅពេលដែលគេធ្វើសំណើរដើម្បីផ្តល់ការការពារខ្ពស់ ដោយធ្វើការដាក់កំហិតដែលវិធាន GATT ពុំអនុញ្ញាត្តិ (ដូចជាការ អនុវត្តន៍ការដាក់កំហិតលើបរិមាណ ឬ អនុវត្តប្រាក់ឧបត្ថម្ភធនលើការនាំចេញជាដើម) គេត្រូវធ្វើការជូនដំណឹងដល់ WTO និងធ្វើការពិគ្រោះយោបល់ជាមួយប្រទេសជាសមាជិកដ៏ទៃទៀត ដើម្បីទទួលបានការយល់ព្រមលើវិធានការដែលបានស្នើសុំនោះ ។ ទោះបីមាត្រានេះចែងដូច្នេះក៏ដោយ តែប្រទេសកំពុងអភិវឌ្ឍន៍ដែលពាក់ព័ន្ធ អាចអនុវត្តន៏វិធានការនេះ ទោះបីពុំមានការយល់ព្រមក៏ដោយ ។ នេះគឺជាហេតុផលដែលមាត្រានេះផ្តល់សិទ្ធិដល់បណ្តាសមាជិកដ៏ទៃទៀត អោយចាត់វិធានការសងសឹក ប្រសិនគេពិចារណាឃើញថា វិធានការនេះប៉ះពាល់ធ្ងន់ធ្ងរដល់អត្ថប្រយោជន៍ពាណិជ្ជកម្មរបស់ពួកគេ ។

ជំពូក ១១

ការឆ្លើយតបទៅនឹងការធ្វើពាណិជ្ជកម្មមិនត្រឹមត្រូវ : វិធានស្តីពីការប្រើប្រាស់ពន្ធប៉ះប៉ូវ និងវិធានការប្រឆាំងនឹងការលក់បង្ខូចថ្លៃ

សេចក្តីសង្ខេប

វិធានរបស់ GATT អនុវត្តទៅលើការធ្វើពាណិជ្ជកម្មមិនត្រឹមត្រូវ ២ ប្រភេទ ដែលបង្កផលប៉ះពាល់ដល់លក្ខខ័ណ្ឌនៃការប្រកួតប្រជែង ។ ទី១ ការប្រកួតប្រជែងអាចមានលក្ខណៈមិនយុត្តិធម៌ ប្រសិនបើទំនិញនាំចេញនោះទទួលបានផលចំណេញពីឧបត្ថម្ភធន។ ទី២ លក្ខខ័ណ្ឌនៃការប្រកួតប្រជែងអាចមានលក្ខណៈខុសពីភាពដើម ប្រសិនបើមានការលក់ផលិតផលនាំចេញនោះ ក្នុងលក្ខណៈបង្ខូចថ្លៃនៅលើទីផ្សារបរទេស ។

និយាយជារួម គេកំណត់ថា ទំនិញនាំចូលណាដែលមានតំលៃថោកជាងតំលៃលក់ក្នុងស្រុក គឺជាទំនិញលក់បង្ខូចថ្លៃ ។ ប៉ុន្តែកិច្ចព្រមព្រៀងស្តីអំពីការប្រឆាំងនឹងការលក់បង្ខូចថ្លៃ មានពីលក្ខណៈវិនិច្ឆ័យតឹងរឹងជាង សំរាប់កំណត់ថា តើនៅពេលណាដែលផលិតផលទាំងនោះ ត្រូវចាត់ទុកថាជាទំនិញលក់បង្ខូចថ្លៃ ។ ជាទូទៅផលិតផលមួយចាត់ទុកថាលក់បង្ខូចថ្លៃ ប្រសិនបើថ្លៃនាំចេញទាបជាងថ្លៃផលិតផលដូចគ្នានៅក្នុងប្រទេសអ្នកនាំចេញ ។

កិច្ចព្រមព្រៀងស្តីអំពីការអនុវត្តន៍ប្រឆាំងនឹងការលក់បង្ខូចថ្លៃ និងកិច្ចព្រមព្រៀងស្តីពីឧបត្ថម្ភធន និងវិធានកំណត់ពន្ធប៉ះប៉ូវ អនុញ្ញាតិឱ្យប្រទេសនានាដាក់ពន្ធសងវិញទៅលើការនាំចូលផលិតផល ដែលទទួលបានផលចំណេញ ពីការធ្វើពាណិជ្ជកម្មពុំត្រឹមត្រូវ ។ ប៉ុន្តែប្រទេសនាំចូលអាចកំណត់ពន្ធប៉ះប៉ូវលើទំនិញដែលមានឧបត្ថម្ភធន និងពន្ធប្រឆាំងនឹងការលក់បង្ខូចថ្លៃលើទំនិញលក់បង្ខូចថ្លៃ ប្រសិនបើការស៊ើបអង្កេតបានបញ្ជាក់ថា ការនាំចូលបែបនេះ បង្កអោយមានការខូចខាតធ្ងន់ធ្ងរចំពោះឧស្សាហកម្មក្នុងស្រុក ។ ការស៊ើបអង្កេតដើម្បីកំណត់ពន្ធបែបនេះគួរផ្តួចផ្តើមឡើង តាមការប្តឹងទាមទារដែលធ្វើឡើងដោយផលិតករ ឬ តាងនាមអោយផលិតករដែលចោទប្រកាន់ថា ការនាំចូលនេះ បង្កអោយមានគ្រោះថ្នាក់ដល់ឧស្សាហកម្មរបស់គេ ។

កិច្ចព្រមព្រៀងទាំង ២ បានចែងនូវលក្ខណៈវិនិច្ឆ័យស្រដៀងគ្នា សំរាប់កំណត់គ្រោះថ្នាក់នេះ ។ នីតិវិធីក្នុងការស៊ើបអង្កេតសំរាប់កំណត់ពន្ធប្រឆាំងនឹងការលក់បង្ខូចថ្លៃ និងពន្ធប៉ះប៉ូវមានលក្ខណៈប្រហាក់ប្រហែលគ្នា ។

ដូចដែលបានកត់សំគាល់ក្នុងជំពូក ៩ រួចមកហើយថា វិធានបានអនុញ្ញាតិអោយប្រទេសនានាចាត់វិធានការការពារ ដោយដាក់កំហិតលើការនាំចូលក្នុងរយៈពេលបណ្តោះអាសន្ន នៅពេលដែលការនាំចូលកើនឡើងយ៉ាងខ្លាំង និងឆាប់រហ័ស ហើយអាចបង្កផលវិបាកធ្ងន់ធ្ងរដល់ឧស្សាហកម្មក្នុងស្រុកនៃប្រទេសនាំចូល ។ ការនាំចូលដែលកើនឡើង ហើយគ្របដណ្តប់ដោយវិធានទាំងនេះ ពុំបានសំដៅចំពោះការធ្វើពាណិជ្ជកម្មពុំត្រឹមត្រូវដោយអ្នកផ្គត់ផ្គង់បរទេសទេ ។

ទោះយ៉ាងណាក៏ដោយ ក៏ច្បាប់ GATT ទទួលស្គាល់ថា កំណើននៃការនាំចូល អាចបណ្តាលមកពីការធ្វើពាណិជ្ជកម្មពុំត្រឹមត្រូវដោយអ្នកផ្គត់ផ្គង់បរទេស ។ អាស្រ័យហេតុនេះច្បាប់បានចែងពីមូលដ្ឋានសំរាប់អោយរដ្ឋាភិបាល កំណត់ពន្ធប៉ះប៉ូវលើទំនិញនាំចូលដែលទទួលផលតំរៃពីការធ្វើពាណិជ្ជកម្មពុំត្រឹមត្រូវបែបនេះ ។ វិធាន GATT អនុវត្តន៍ទៅលើការធ្វើពាណិជ្ជកម្មពុំត្រឹមត្រូវ ២ ប្រភេទ ដែលធ្វើអោយប៉ះពាល់ដល់លក្ខខ័ណ្ឌប្រកួតប្រជែង ។ ទី១ ការប្រកួតប្រជែងមានលក្ខណៈមិនត្រឹមត្រូវ ប្រសិនបើ

ទំនិញនាំចេញបានទទួលផលប្រយោជន៍ពីឧបត្ថម្ភធនជាក់លាក់ណាមួយ ។ ទី២ ល័ក្ខខ័ណ្ឌប្រកួតប្រជែង អាចទទួលរងនូវផលមិនល្អ ប្រសិនបើផលិតករលក់បង្ខូចថ្លៃទំនិញនៅទីផ្សារបរទេស ។

បទបញ្ញាតិគ្រឹះនៃកិច្ចព្រមព្រៀងGATT 1994 ស្តីអំពីការប្រើប្រាស់ឧបត្ថម្ភធន បានត្រូវបកស្រាយដោយកិច្ចព្រមព្រៀង ស្តីអំពី SCM ។ ដូចបានកត់សំគាល់ពីមុនមកហើយថា បទបញ្ញត្តិនេះមានគោលបំណងសំខាន់ គឺហាមឃាត់ ឬ ទប់ស្កាត់ការប្រើប្រាស់ឧបត្ថម្ភធន ដែលបង្កនូវឥទ្ធិពលអាក្រក់ចំពោះផលប្រយោជន៍របស់ប្រទេសជាសមាជិកដ៏ទៃទៀត ។ ប៉ុន្តែនៅពេលដែលការប្រើប្រាស់ឧបត្ថម្ភធនដែលបានអនុញ្ញាតិ បង្កអោយមានគ្រោះថ្នាក់ចំពោះឧស្សាហកម្មក្នុងស្រុក ក្នុងប្រទេសនាំចូល បទបញ្ញាតិបានអនុញ្ញាតិអោយប្រទេសនាំចូលចាត់វិធានការណ៍ ដែលអាចជាទំរង់នៃការដាក់ពន្ធប៉ះប៉ូវ លើទំនិញដែលទទួលបានឧបត្ថម្ភធននោះ ។ ដូចជាកិច្ចព្រមព្រៀងស្តីអំពីការអនុវត្តន៍ប្រឆាំងនឹងការលក់បង្ខូចថ្លៃ (មានឈ្មោះពេញថា : កិច្ចព្រមព្រៀងស្តីអំពីការអនុវត្តន៍មាត្រា៦ នៃកិច្ចព្រមព្រៀងទូទៅ ស្តីអំពីអត្រាពន្ធគយ និងរបាំងពាណិជ្ជកម្មឆ្នាំ ១៩៩៤) ដែលបកស្រាយនូវបទបញ្ញាតិគ្រឹះរបស់ GATT អំពីការលក់បង្ខូចថ្លៃ និងបានអនុញ្ញាតិអោយប្រទេសជាសមាជិកដាក់ពន្ធប្រឆាំងនឹងការលក់បង្ខូចថ្លៃ លើទំនិញដែលលក់បង្ខូចថ្លៃនោះ ។

ជាទូទៅផលិតផលមួយចាត់ទុកថា លក់បង្ខូចថ្លៃប្រសិនបើថ្លៃនាំចេញទាបជាងថ្លៃនៃផលិតផលដូចគ្នាក្នុងប្រទេសនាំចេញ ។ និយាយអោយច្បាស់ជាងនេះ គឺថា បើសហគ្រាសផលិត អាចកំណត់ថ្លៃខ្ពស់លើការលក់នៅទីផ្សារក្នុងស្រុក ប្រសិនបើកំរិតការពារខ្ពស់នោះ និងប្រសិនបើពុំមានការប្រកួតប្រជែងពីបរទេស ឬ ការប្រកួតប្រជែងពីបរទេសនៅខ្សោយ ។

វិធាននៃកិច្ចព្រមព្រៀងSCM និង AOP មិនបានដាក់កំហុសលើការលក់បង្ខូចថ្លៃ ឬ ឧបត្ថម្ភធនទេ ។ កិច្ចព្រមព្រៀងទាំងនេះទទួលស្គាល់ថា ថ្លៃផលិតផលនាំចូលទាប បណ្តាលពីការលក់បង្ខូចថ្លៃ ឬ មានឧបត្ថម្ភធន អាចផ្តល់ផលចំណេញដល់អ្នកប្រើប្រាស់នៅក្នុងប្រទេសនាំចូល ។ ដូច្នេះកិច្ចព្រមព្រៀងទាំងពីរនេះ កំណត់នូវគោលការណ៍សំខាន់ៗ : ការដាក់ពន្ធសងវិញលើទំនិញដែលមានឧបត្ថម្ភធន និងការដាក់ពន្ធប្រឆាំងនឹងការលក់បង្ខូចថ្លៃ លើទំនិញលក់បង្ខូចថ្លៃ តែមិនអាចដាក់បាន នៅពេលដែលផលិតផលបានទទួលអត្ថប្រយោជន៍ពីឧបត្ថម្ភធន ឬ នៅពេលលក់បង្ខូចថ្លៃទេ ។ គេអាចដាក់បាន បន្ទាប់ពីមានការស៊ើបអង្កេតមួយ ដែលជាធម្មតាចាប់ផ្តើមដោយមានសំណើពីឧស្សាហកម្មក្នុងស្រុកថា ការលក់បង្ខូចថ្លៃ និងឧបត្ថម្ភធនបង្កអោយមានគ្រោះថ្នាក់ដល់ឧស្សាហកម្មនោះ ។

គេអនុវត្តន៍គោលការណ៍ស្រដៀងគ្នានេះ នៅពេលដែលរដ្ឋាភិបាលចាត់វិធានការណ៍ការពារ ដើម្បីដាក់កំហិតលើការនាំចូល ដើម្បីជួយឧស្សាហកម្មក្នុងស្រុកដែលកំពុងរងគ្រោះដោយកំណើននៃការនាំចូលខ្លាំង ។ ប៉ុន្តែស្តង់ដារនៃការទទួលរងនូវផលប៉ះពាល់ចំពោះឧស្សាហកម្មក្នុងស្រុកមានកំរិតខ្ពស់ជាងកំរិតតំរូវការសំរាប់ការដាក់ពន្ធប៉ះប៉ូវ ឬ ពន្ធប្រឆាំងនឹងការលក់បង្ខូចថ្លៃ ។ ក្នុងករណីដែលមានវិធានការណ៍ការពារ ផលប៉ះពាល់ដែលមានចំពោះឧស្សាហកម្ម ត្រូវតែមានលក្ខណៈធ្ងន់ធ្ងរ ហើយក្នុងករណីនៃការដាក់ពន្ធប៉ះប៉ូវ និងការលក់បង្ខូចថ្លៃ ស្តង់ដារនៃការបញ្ជាក់ពីកំរិតគ្រោះថ្នាក់ដែលមានទាបជាងនេះ អាចចាត់ទុកគ្រប់គ្រាន់ហើយ ។ ស្តង់ដារខុសគ្នានេះបង្ហាញថា ក្នុងឧទាហរណ៍ទី១ បញ្ហានៃឧស្សាហកម្ម មិនអាចកើតឡើងពីការប្រកួតប្រជែងមិនយុត្តិធម៌ឡើយ ហើយឧទាហរណ៍ទី២ កើតឡើងដោយសារការធ្វើពាណិជ្ជកម្មអន្តរជាតិពុំយុត្តិធម៌ ។

ជំពូកនេះនឹងពិភាក្សាលើប្រធានបទដូចខាងក្រោម ÷

☐ ទស្សនៈនៃការលក់បង្ខូចថ្លៃដូចបានចែងក្នុងច្បាប់ GATT

☐ បទបញ្ញាតិ និងនិតិវិធីដែលត្រូវអនុវត្តន៍ក្នុងការកំណត់ពន្ធប៉ះប៉ូវ និងពន្ធប្រឆាំងនឹងការលក់បង្ខូចថ្លៃ ។

វិធានដែលស្តីពីកិច្ចព្រមព្រៀងSCM និង ADP បានកំណត់ពន្ធសំរាប់ជាសំណងទាំងនេះប្រហាក់ប្រហែលគ្នា ។ ម្យ៉ាងទៀតក្នុងកំរិតថ្នាក់ជាតិ អាជ្ញាធរទទួលបន្ទុកពាក្យបណ្តឹងស៊ើបអង្កេត ដើម្បីកំណត់ពន្ធប៉ះប៉ូវ និងពន្ធប្រឆាំងនឹងការលក់បង្ខូចថ្លៃ មានលក្ខណៈដូចគ្នាក្នុងករណីភាគច្រើន ។

ទស្សនៈនៃការលក់បង្ខូចថ្លៃដូចបានចែងក្នុងច្បាប់ GATT

កិច្ចព្រមព្រៀងស្តីពីការប្រឆាំងនឹងការលក់បង្ខូចថ្លៃ មាត្រា ទី២:១

ក្នុងលក្ខណៈទូទៅ គេកំណត់ថា ការនាំចូលណាដែលមានតំលៃទាបទាំងអស់ គឺជាការលក់បង្ខូចថ្លៃ ។ ប៉ុន្តែកិច្ចព្រមព្រៀងស្តីពីប្រឆាំងនឹងការលក់បង្ខូចថ្លៃ ចែងនូវលក្ខណៈវិនិច្ឆ័យយ៉ាងតឹងរឹងសំរាប់កំណត់ថា ពេលណាទើបផលិតផលនាំចូលមួយត្រូវបានចាត់ទុកថា ជាផលិតផលលក់បង្ខូចថ្លៃ ។ ជាពិសេសគេចែងថា "ផលិតផលមួយចាត់ទុកថាលក់បង្ខូចថ្លៃ ប្រសិនបើ ថ្លៃនាំចេញទាបជាងថ្លៃនៃផលិតផលដូចគ្នា ដែលលក់សំរាប់ការប្រើប្រាស់ក្នុងប្រទេសនាំចេញ ។ ម្យ៉ាងទៀត លើមូលដ្ឋានប្រៀបធៀបថ្លៃនាំចេញនិងថ្លៃប្រើប្រាស់ក្នុងស្រុក ក្នុងប្រទេសនាំចេញ បើរកឃើញថាតំលៃនាំចេញទាបជាងតំលៃដែលលក់ក្នុងស្រុកនោះ ផលិតផលនោះត្រូវចាត់ទុកថាបានលក់បង្ខូចថ្លៃ ។

កិច្ចព្រមព្រៀងស្តីពីការប្រឆាំងនឹងការលក់បង្ខូចថ្លៃ មាត្រា ទី២.២

ប៉ុន្តែកិច្ចព្រមព្រៀងចែងថា និយមន័យស្តីពីការកំណត់ការលក់បង្ខូចថ្លៃតាមមូលដ្ឋានខាងលើ អាចមិនសមស្របក្នុងករណី ÷

- ☐ ការលក់ក្នុងទីផ្សារក្នុងស្រុកនៃប្រទេសនាំចេញ មិនស្ថិតក្នុងលក្ខណៈពាណិជ្ជកម្មធម្មតា (ឧទាហរណ៍ : ការលក់ក្រោមតំលៃផលិតកម្ម)
- ☐ ទំហំនៃការលក់ក្នុងស្រុកទាប

ក្នុងករណីនេះកិច្ចព្រមព្រៀងអនុញ្ញាតិអោយកំណត់ការលក់បង្ខូចថ្លៃដោយប្រៀបធៀបថ្លៃនាំចេញជាមួយ ÷

- ☐ ថ្លៃប្រៀបធៀបចំពោះផលិតផលដូចគ្នា នៅពេលនាំចេញទៅកាន់ប្រទេសទីពា
- ☐ តំលៃស្ថាបនា កំណត់លើមូលដ្ឋាននៃតំលៃផលិតកម្មរបស់ទំនិញនាំចូល បន្ថែមតំលៃលក់ ចំណាយរដ្ឋបាល និងផលចំណេញ។

ប៉ុន្តែដើម្បីធានាអោយដល់កំរិតអតិបរិមាថា ការលក់បង្ខូចថ្លៃត្រូវបានកំណត់លើមូលដ្ឋានប្រៀបធៀបរវាងថ្លៃនាំចេញ ជាមួយ ថ្លៃប្រើប្រាស់ក្នុងស្រុក ក្នុងប្រទេសនាំចេញ កិច្ចព្រមព្រៀងចែងនូវអ្វីដែលហៅថា ការសាកល្បងតំណាង ៥% ។ អង្គភាពស៊ើបអង្កេតត្រូវប្រើប្រាស់ថ្លៃប្រៀបធៀបដែលកំណត់ចំពោះទីផ្សារប្រទេសទីពា ឬប្រើប្រាស់តំលៃស្ថាបនា ដែលគណនាលើមូលដ្ឋាននៃតំលៃផលិតកម្ម ប្រសិនបើតំលៃលក់ក្នុងទីផ្សារក្នុងស្រុកនៃប្រទេសនាំចេញ បង្កើតឡើងនូវបរិមាណ តិចជាង ៥% នៃការលក់ផលិតផលទៅប្រទេសនាំចូល ។

បទបញ្ញាតិ និងនិតិវិធីសំរាប់កំណត់ពន្ធប៉ះប៉ូវ និងពន្ធប្រឆាំងនឹងការលក់បង្ខូចថ្លៃ

លក្ខណៈវិនិច្ឆ័យសំខាន់ៗសំរាប់ដាក់ពន្ធ

គ្រោះថ្នាក់ចំពោះឧស្សាហកម្មក្នុងស្រុក

កិច្ចព្រមព្រៀងស្តីពីពន្ធប្រឆាំងនឹងការលក់បង្ខូចថ្លៃ មាត្រាទីពា

កិច្ចព្រមព្រៀងស្តីពីវិធាននៃការដាក់ពន្ធប៉ះប៉ូវចំពោះឧបត្ថម្ភធន មាត្រា១៥

បទបញ្ញាតិត្រូវដែលកិច្ចព្រមព្រៀងស្តីអំពី ADP និង SCM ចែង គឺពន្ធប្រឆាំងនឹងការលក់បង្ខូចថ្លៃ និងពន្ធប៉ះប៉ូវ គួរកំណត់នៅពេលណាដែលការស៊ើបអង្កេតបានបង្ហាញអោយឃើញថា ÷

- ☐ មានការកើនឡើងយ៉ាងខ្លាំងនូវការលក់បង្ខូចថ្លៃ និងឧបត្ថម្ភធនទាំងក្នុងល័ក្ខខ័ណ្ឌដាច់ខាត ឬ ប្រៀបធៀបទាក់ទងនឹងផលិតកម្ម ឬ ការប្រើប្រាស់ ។
- ☐ ថ្លៃនៃការនាំចូលលក់ថោកជាងផលិតផលក្នុងស្រុក ដែលដូចគ្នា ហើយបានធ្វើអោយប៉ះពាល់ថ្លៃនៃផលិតផលដូចគ្នា ឬ បានទប់ស្កាត់ថ្លៃមិនអោយកើនឡើង ។
- ☐ ជាលទ្ធផលធ្វើអោយមានផលប៉ះពាល់ ឬ ជាការគំរាមកំហែងចំពោះឧស្សាហកម្មក្នុងស្រុកនៃប្រទេសនាំចូល ។

ទំនាក់ទំនងរវាងការលក់បង្ខូចថ្លៃ ការនាំចូលដែលមានឧបត្ថម្ភធន និងផលប៉ះពាល់ចំពោះឧស្សាហកម្មក្នុងស្រុក

កិច្ចព្រមព្រៀងទាំងពីរចែងថា ត្រូវពិចារណាទៅលើកត្តាសេដ្ឋកិច្ចពាក់ព័ន្ធក្នុងស្ថានភាពឧស្សាហកម្ម (សូមអានវណ្ណ ២៦) ដើម្បីកំណត់ថា តើទំនិញលក់បង្ខូចថ្លៃ បង្កគ្រោះថ្នាក់ដល់ឧស្សាហកម្មក្នុងស្រុកឬទេ ។

ខណ្ឌ ២៦

កត្តាដែលត្រូវយកមកពិចារណាក្នុងការកំណត់ផលប៉ះពាល់ដល់ឧស្សាហកម្មក្នុងស្រុក

កិច្ចព្រមព្រៀងអំពីការអនុវត្តន៍ប្រឆាំងនឹងការលក់បង្ខូចថ្លៃ មាត្រា៣ កិច្ចព្រមព្រៀងស្តីអំពីឧបត្ថម្ភធន និងវិធានការប៉ះប៉ូវ មាត្រា ១៥)

កិច្ចព្រមព្រៀង SCM និងADP ចែងថា ការកំណត់ថាតើឧបត្ថម្ភធន ឬ ការលក់បង្ខូចថ្លៃបង្កគ្រោះថ្នាក់ដល់ឧស្សាហកម្មក្នុងស្រុកឬយ៉ាងណានោះ គេគួរតែធ្វើឡើងដោយផ្អែកលើ "កត្តាសេដ្ឋកិច្ចពាក់ព័ន្ធទាំងអស់ក្នុងស្ថានភាពឧស្សាហកម្ម" ។ កត្តាសេដ្ឋកិច្ចបែបនោះរួមមាន ÷

- ☐ *ការធ្លាក់ចុះជាក់ស្តែង ឬ ជាសក្តានុពលនូវផលិតកម្ម ការលក់ផ្សារហ៊ុន ផលចំណេញ ផលិតភាព ប្រាក់ចំណូលពីការវិនិយោគ ឬ សមត្ថភាពនៃការប្រើប្រាស់*
- ☐ *ប្រសិទ្ធិភាពលើថ្លៃក្នុងស្រុក*
- ☐ *ផលប៉ះពាល់ជាក់ស្តែង ឬ ជាសក្តានុពលនៃចរន្តសាច់ប្រាក់ សារពើភ័ណ្ឌ ការងារ ប្រាក់បំណាច់ កំណើន លទ្ធភាពប្រមូលដើមទុន ឬ វិនិយោគ ។*

ក្នុងករណីស៊ើបអង្កេតការប្រឆាំងនឹងការលក់បញ្ចុះថ្លៃ គេត្រូវពិចារណាលើកត្តាមួយ គឺទំហំនៃការលក់បង្ខូចថ្លៃ ។ ម៉្យាងទៀត ការស៊ើបអង្កេត ដើម្បីកំណត់ពន្ធប៉ះប៉ូវលើការនាំចូលផលិតផលកសិកម្ម នោះគេត្រូវពិចារណាលើកត្តាបន្ថែមមួយទៀត ថាតើមានបង្កើនបន្ទុកលើកម្មវិធីការពាររបស់រដ្ឋាភិបាលឬទេ ។

កិច្ចព្រមព្រៀងទាំងពីរចែងច្បាស់ថា ការាងកត្តាសេដ្ឋកិច្ចខាងលើ គឺជាការពន្យល់បង្ហាញ ដែលមិនគិតប្រយោជន៍ទេ ហើយកត្តាមួយចំនួនណានោះនឹងផ្តល់នូវគំរុយសំរាប់ការសំរេចចិត្ត ។

កិច្ចព្រមព្រៀងចែងបន្តទៀតថា អាជ្ញាធរស៊ើបអង្កេតត្រូវត្រួតពិនិត្យផងដែរថា តើកត្តាណាខ្លះក្រៅពីឧបត្ថម្ភធន ឬការលក់បង្ខូចថ្លៃ ដែលបង្កគ្រោះថ្នាក់ដល់ឧស្សាហកម្មក្នុងស្រុក ។ មិនត្រូវដាក់ពន្ធប៉ះប៉ូវ ឬពន្ធប្រឆាំងនឹងការលក់បង្ខូចថ្លៃទេ ប្រសិនបើកត្តាសំខាន់ៗ ដែលបង្កការលំបាកដល់ឧស្សាហកម្មនោះ គឺជាកត្តាផ្សេងក្រៅពីឧបត្ថម្ភធន ឬការលក់បង្ខូចថ្លៃ។ កត្តាបែបនោះរួមមាន÷

- ☐ *តំរូវការធ្លាក់ចុះ ឬផ្លាស់ប្តូររបៀបប្រើប្រាស់*
- ☐ *ការធ្វើពាណិជ្ជកម្មដែលមានលក្ខណៈដាក់កំហិត និងការប្រកួតប្រជែងរវាងជនបរទេស និងផលិតករក្នុងស្រុក*
- ☐ *ការអភិវឌ្ឍន៍បច្ចេកវិទ្យា និងសកម្មភាពនាំចេញ*
- ☐ *ផលិតភាពឧស្សាហកម្មក្នុងស្រុក*

ម៉្យាងទៀត ដើម្បីដាក់ពន្ធប្រឆាំងនឹងការលក់បង្ខូចថ្លៃ ឬពន្ធប៉ះប៉ូវ គេត្រូវបញ្ជាក់អោយច្បាស់អំពីទំនាក់ទំនងដែលបង្កអោយមានផលប៉ះពាល់ រវាងការលក់បង្ខូចថ្លៃ ឬឧបត្ថម្ភធន និងគ្រោះថ្នាក់ចំពោះឧស្សាហកម្ម ។

នៅពេលណាដែលបញ្ហាប្រឈមរបស់ឧស្សាហកម្មក្នុងស្រុក កើតឡើងដោយកត្តាជាច្រើនដូចជា តំរូវការថយចុះ ការប្រែប្រួលការប្រើប្រាស់ ហើយមិនអាចចាត់ទុកថា ជាការលក់បង្ខូចថ្លៃ ឬ ការនាំចូលដែលមានឧបត្ថម្ភធនផ្ទាល់ នោះការកំណត់ពន្ធប្រឆាំងនឹងការ

លក់បង្ខូចថ្លៃ ឬ ពន្ធប៉ះប៉ូវមិនអាចអនុវត្តទៅបានទេ ។ ម្យ៉ាងទៀតពន្ធប្រភេទនេះ មិនអាចដាក់បាន នៅពេលណាដែលការនាំចូលដែលកើនឡើងនោះ ជះឥទ្ធិពលអាក្រក់ទៅលើតែផលិតករមួយចំនួនតូចប៉ុណ្ណោះ ។ គេអាចដាក់ពន្ធទាំងនេះបានភ្លាម តែក្នុងករណីដែលគេពិនិត្យឃើញថា ការនាំចូលបង្កបញ្ហាចំពោះផលិតករណា ដែលផលិតកម្មសរុបរបស់គាត់មានសមាមាត្រផលិតកម្ម ឧស្សាហកម្មក្នុងស្រុកភាគច្រើន ។

ភាពគ្រួតគ្នានៃការនាំចូល

កិច្ចព្រមព្រៀងស្ដីពីការប្រឆាំងនឹងការលក់បង្ខូចថ្លៃ មាត្រាទី៣.៣ និងវិធានការឧបត្ថម្ភធន និងការដាក់ពន្ធប៉ះប៉ូវ មាត្រា១៥.៣

ជាធម្មតានៅពេលដែលការនាំចូលពីប្រទេសមួយចំនួន ស្ថិតនៅក្រោមការស៊ើបអង្កេត នោះគេត្រូវការវាយតំលៃដោយឡែកៗពីគ្នារវាងប្រទេសនីមួយៗថា តើការនាំចូលប្រភេទនេះ បង្កគ្រោះថ្នាក់ចំពោះឧស្សាហកម្មក្នុងស្រុកយ៉ាងណា ។ ប៉ុន្តែក្នុងស្ថានភាពជាក់ស្ដែង កិច្ចព្រមព្រៀងអនុញ្ញាតិ អោយអាជ្ញាធរស៊ើបអង្កេត វាយតំលៃផលប៉ះពាល់រួមនៃការនាំចូលក្រោមការស៊ើបអង្កេត ដើម្បីកំណត់ពីគ្រោះថ្នាក់ ។ ការកើនឡើងនៃការនាំចូលប្រភេទនេះ ត្រូវបានអនុញ្ញាតិប្រសិនបើ ÷

☐ កំរិតនៃការបង្ខូចថ្លៃ ឬបរិមាណនៃឧបត្ថម្ភធនរបស់ប្រទេសនីមួយៗលើសកំរិតអប្បបរិមា (de minimis)

☐ បរិមាណនៃការនាំចូលពីប្រទេសនីមួយ ៗ មិនមានច្រើនគួរអោយកត់សំគាល់

☐ ការវាយតំលៃដែលកើនឡើងសមស្របចំពោះលក្ខខណ្ឌប្រកួតប្រជែងត្រឹមត្រូវ រវាងផលិតផលនាំចូល និងលក្ខខណ្ឌប្រកួតប្រជែងរវាងផលិតផលនាំចូល និងផលិតផលក្នុងស្រុកដូចគ្នា ។

គោលជំហររបស់អ្នកប្ដឹងទាមទារ

ជាកត្តាសំខាន់គួរអោយកត់សំគាល់ថា កិច្ចព្រមព្រៀងទាំង ២ ចែងថា លើកលែងតែមានករណីពិសេស[១៦] បើមិនដូច្នោះទេការស៊ើបអង្កេតប្រឆាំងនឹងការលក់បង្ខូចថ្លៃ និងវិធានការដាក់ពន្ធប៉ះប៉ូវ អាចផ្ដួចផ្ដើមឡើងបានតែតាមបណ្ដឹងរបស់ឧស្សាហកម្មក្នុងស្រុក ឬតាងនាមអោយឧស្សាហកម្មក្នុងស្រុកប៉ុណ្ណោះ ។

កិច្ចព្រមព្រៀងស្ដីពីការប្រឆាំងនឹងការលក់បង្ខូចថ្លៃ មាត្រាទី៥:៤ និងវិធានឧបត្ថម្ភធន និងការដាក់ពន្ធប៉ះប៉ូវ មាត្រា១១.៤

ជាងនេះទៅទៀត ត្រូវធានាថា ការដាក់ពន្ធអាចធ្វើឡើងបានតែ នៅពេលផលិតករជាច្រើនទទួលរងនូវផលប៉ះពាល់នោះ ហើយកិច្ចព្រមព្រៀងនេះបានកំណត់នូវលក្ខណៈវិនិច្ឆ័យបន្ថែម ២ ÷

☐ ទី១ ផលិតករដែលគាំពារការអនុវត្តន៍នោះ ត្រូវមានសមាមាត្រផលិតកម្មលើសពី៥០% នៃផលិតកម្មរបស់ផលិតករដែលបង្ហាញទស្សនៈទាំងយល់ស្រប ឬ ប្រឆាំងនឹងការបណ្ដឹងទាមទារនោះ [១៧] ។

☐ ទី២ ផលិតករដែលគាំពារការអនុវត្តន៍នេះ ត្រូវមានសមាមាត្រផលិតកម្មយ៉ាងតិច២៥% នៃផលិតកម្មឧស្សាហកម្មសរុប ។

មុនធ្វើការស៊ើបអង្កេត អាជ្ញាធរស៊ើបអង្កេតមានកាតព្វកិច្ចកំណត់អោយច្បាស់ថា តើអ្នកប្ដឹងទាមទារមានគោលជំហរបែបនេះទេ។

វិធានស្ដីពីនីតិវិធី

ពត៌មានដែលត្រូវផ្ដល់ក្នុងពាក្យសុំ

កិច្ចព្រមព្រៀងស្ដីពីការប្រឆាំងនឹងការលក់បង្ខូចថ្លៃ មាត្រាទី៥.៥.

កិច្ចព្រមព្រៀងបានចែងបន្ថែមទៀតនូវប្រភេទពត៌មាន (សូមអានវណ្ឌ ២៧) ដែលឧស្សាហកម្មប្ដឹងទាមទារត្រូវផ្ដល់ក្នុងពាក្យសុំរបស់គេ ដើម្បីបង្ហាញថា ការលក់បង្ខូចថ្លៃ និងឧបត្ថម្ភធនបង្កគ្រោះថ្នាក់ដល់ឧស្សាហកម្មរបស់គេពិតមែន ។

---

[១៦] រដ្ឋាភិបាលនៃប្រទេសនាំចូលអាចផ្ដួចផ្ដើមគំនិតចាត់វិធានការដាក់ពន្ធប្រឆាំងនឹងការលក់បង្ខូចថ្លៃ និងពន្ធប៉ះប៉ូវបានតែក្នុងករណីលើកលែងប៉ុណ្ណោះ ។

[១៧] ផលិតករមួយចំនួន អាចមិនចង់សំដែងនូវមតិគាំទ្រ ឬ ប្រឆាំងនឹងបណ្ដឹងទាមទារនោះឡើយ ។ ចំណែករបស់ផលិតករនោះនឹងត្រូវបានលើកលែងនៅពេលគេគិតជាភាគរយនៃផលិតកម្មសរុប ។

អាជ្ញាធរស៊ើបអង្កេត មានសិទ្ធិបដិសេធពាក្យសុំណា ដែលមិនបានបង្ហាញភស្តុតាងឬមិនបានបំពេញតាមលក្ខណៈវិនិច្ឆ័យខាងលើ។ ការដាក់ពាក្យសុំបែបនេះជារឿយៗបង្កើតឡើងនូវភាពមិនច្បាស់លាស់ចំពោះពាណិជ្ជកម្ម ដូច្នេះកិច្ចព្រមព្រៀងតំរូវអោយអាជ្ញាធរស៊ើបអង្កេតជៀសវាងបោះពុម្ពផ្សាយពាក្យសុំទាំងនោះ ។ ប៉ុន្តែបន្ទាប់ពីមានសេចក្តីសំរេចបង្កើត ការស៊ើបអង្កេត អាជ្ញាធរមានកាតព្វកិច្ចផ្តល់ពត៌មានជាសាធារណៈ ស្តីអំពីការបង្កើតការស៊ើបអង្កេត ក្នុងចំណោមនោះ មានឈ្មោះប្រទេសនាំចេញ ឬប្រទេសនានា មូលដ្ឋានដែលសង្ស័យថាមានការលក់បង្ខូចថ្លៃ ឬ ឧបត្ថម្ភធន និងសេចក្តីសង្ខេបនៃការចោទប្រកាន់សំរាប់ធ្វើពាក្យប្តឹងទាមទារនោះ ។

សេចក្តីជូនដំណឹងចំពោះរដ្ឋាភិបាល

១២.១.៦.១.៣ និង
វិធានឧបត្ថម្ភធន និង
ការដាក់ពន្ធប្រឆាំង
តបវិញមាត្រា១១.៥
២២.២,១២.១.៣ ១៣

ម្យ៉ាងវិញទៀត អាជ្ញាធរស៊ើបអង្កេតតំរូវអោយផ្ញើលិខិតជូនដំណឹងទៅរដ្ឋាភិបាលនៃបណ្តាប្រទេសជាសមាជិកនាំចេញ ពីការទទួលឯកសារបណ្តឹងសមស្រប មុននឹងចាប់ផ្តើមស៊ើបអង្កេតលើការប្រឆាំងនឹងការលក់បង្ខូចថ្លៃ និងវិធានការណ៍ប៉ះប៉ូវ ។ នៅពេលចាប់ផ្តើមធ្វើការស៊ើបអង្កេត អាជ្ញាធរត្រូវផ្សព្វផ្សាយអត្ថបទពាក្យសុំជាលាយល័ក្ខអក្សរទាំងមូលទៅរដ្ឋាភិបាលនៃប្រទេសនាំចេញ ។ លើសពីនេះទៀតកិច្ចព្រមព្រៀង SCM បានកំណត់កាតព្វកិច្ចអោយប្រទេសដែលធ្វើការស៊ើបអង្កេត ពិគ្រោះយោបល់ជាមួយរដ្ឋាភិបាលនៃប្រទេសនាំចេញ បន្ទាប់ពីបានទទួលបណ្តឹងទាមទារ និងមុនពេលចាប់ផ្តើមស៊ើបអង្កេត ។ ការពិគ្រោះយោបល់បែបនេះ ផ្តល់កាលានុវត្តន៍ភាពអោយរដ្ឋាភិបាលប្រទេសស៊ើបអង្កេត ធ្វើការបញ្ជាក់អោយច្បាស់ថា តើប្រទេសអ្នកនាំចេញ ត្រៀមខ្លួនកែតំរូវការផ្តល់ឧបត្ថម្ភធនរបស់គេ ដើម្បីឈានទៅរកដំណោះស្រាយដែលអាចទទួលយកបានទៅវិញទៅមកឬទេ និងដោយពិនិត្យពិចារណានូវពត៌មានដែលមាននៅលើពាក្យសុំស្តីអំពីផលប៉ះពាល់ធ្ងន់ធ្ងរនៃឧបត្ថម្ភធនទៅលើឧស្សាហកម្ម ។

វណ្ឌ ២៧

ពត៌មានដែលត្រូវផ្តល់ជូននៅក្នុងពាក្យស្នើសុំដាក់ពន្ធប្រឆាំងនឹងការលក់បង្ខូចថ្លៃ ឬពន្ធប៉ះប៉ូវពាក្យស្នើសុំដាក់ពន្ធប្រឆាំងនឹងការលក់បង្ខូចថ្លៃ និងពន្ធប៉ះប៉ូវ ត្រូវមានពត៌មានដូចខាងក្រោម :

☐ *បរិមាណនៃផលិតកម្មក្នុងស្រុករបស់ផលិតករដែលធ្វើពាក្យស្នើសុំ*

☐ *ការពិពណ៌នាអំពីផលិតផលដែលលក់បង្ខូចថ្លៃ ឬបានទទួលឧបត្ថម្ភធន*

☐ *ឈ្មោះរបស់ប្រទេសនាំចេញ អ្នកនាំចេញដែលស្គាល់គ្នាទៅវិញទៅមក ឬផលិតករបរទេស និងតារាងអ្នកនាំចូលផលិតផលនោះ*

☐ *ពត៌មានអំពីការលក់បង្ខូចថ្លៃ/ឧបត្ថម្ភធន ÷*

- *ក្នុងពាក្យស្នើសុំចាត់សកម្មភាពប្រឆាំងនឹងការលក់បង្ខូចថ្លៃ ពត៌មានដែលត្រូវដាក់បញ្ចូល រួមមានថ្លៃលក់របស់ផលិតផលនោះ នៅក្នុងទីផ្សារក្នុងស្រុកនៃប្រទេសអ្នកនាំចេញ និងពត៌មានស្តីអំពីថ្លៃនាំចេញ*
- *ក្នុងពាក្យស្នើសុំដាក់ពន្ធប៉ះប៉ូវ ពត៌មានដែលត្រូវដាក់បញ្ចូល រួមមានភស្តុតាងជាក់ស្តែង បរិមាណ និងលក្ខណៈនៃឧបត្ថម្ភធន*
- *ពត៌មានទាក់ទងនឹងគ្រោះថ្នាក់ និងឧបព្ធហេតុ*
- *ពត៌មានអំពីបរិមាណនៃការលក់បង្ខូចថ្លៃ ឬ ការនាំចូលដែលមានឧបត្ថម្ភធន*
- *ពត៌មានអំពីផលប៉ះពាល់ធ្ងន់ធ្ងរ នៃការនាំចូលនោះ*
  * *ទៅលើថ្លៃក្នុងស្រុក*
  * *ទៅលើឧស្សាហកម្មក្នុងស្រុក*

សិទ្ធិក្នុងការផ្តល់ភស្តុតាង

កិច្ចព្រមព្រៀងស្តីពីការប្រឆាំងនឹងការលក់បង្ខូចថ្លៃ មាត្រាទី៦.១. និងឧបត្ថម្ភធន និងវិធានការដាក់ពន្ធប៉ះប៉ូវ មាត្រា១២.១

វិធាននៃកិច្ចព្រមព្រៀងទាំង ២ មានបំណងបញ្ជាក់ថែមទៀតថា នៅពេលចាប់ផ្តើមស៊ើបអង្កេត អ្នកនាំចេញ និងអ្នកនាំចូលផលិតផលដែលអះអាងថាលក់បង្ខូចថ្លៃ ឬ មានឧបត្ថម្ភធន រដ្ឋាភិបាលនៃប្រទេសនាំចេញ និងភាគីពាក់ព័ន្ធដទៃទៀត (ឧទាហរណ៍: ពាណិជ្ជកម្ម ឬសមាគមន៍អ្នកនាំចេញ ឬ ផលិតករ) មានឱកាសគ្រប់គ្រាន់ក្នុងការដាក់ជូននូវភស្តុតាង ផ្ទាល់មាត់ ឬលាយល័ក្ខអក្សរ ដើម្បីបដិសេធចំពោះបណ្តឹងទាមទារ ដែលធ្វើឡើងដោយអ្នកប្តឹងទាមទារ និងដើម្បីការពារផលប្រយោជន៍របស់គេ ។ នៅចុងបញ្ចប់ កិច្ចព្រមព្រៀងបានចែងយ៉ាងច្បាស់ថា ៖

- ☐ ត្រូវផ្សព្វផ្សាយអត្ថបទនៃពាក្យសុំទាំងមូល អោយអ្នកនាំចេញដែលសង្ស័យថា មានលក់ផលិតផលបង្ខូចថ្លៃ ឬ ទទួលផលប្រយោជន៍ពីឧបត្ថម្ភធន និងរដ្ឋាភិបាលនៃប្រទេសនាំចេញដែលពាក់ព័ន្ធទាំងអស់បានដឹង ។
- ☐ ភស្តុតាងដែលបង្ហាញដោយភាគីមួយត្រូវផ្សព្វផ្សាយភ្លាមទៅដល់ភាគីដទៃទៀតដែលចូលរួមក្នុងការស៊ើបអង្កេត
- ☐ ភាគីនានាមានសិទ្ធិពិនិត្យមើលពត៌មានទាំងអស់ (លើកលែងតែពត៌មានសំងាត់) ដែលអាជ្ញាធរស៊ើបអង្កេត ប្រើប្រាស់ក្នុងកំឡុងពេលស៊ើបអង្កេត ដើម្បីជួយពួកគេក្នុងការរៀបចំសេចក្តីថ្លែងការ ។

កិច្ចព្រមព្រៀងស្តីពីពន្ធប្រឆាំងនឹងការលក់បង្ខូចថ្លៃ មាត្រាទី៦.១២.

ម្យ៉ាងទៀតកិច្ចព្រមព្រៀងទាំង២ចែងថា ក្នុងការស៊ើបអង្កេតប្រឆាំងនឹងការលក់បង្ខូចថ្លៃ និងការដាក់ពន្ធប៉ះប៉ូវ អ្នកប្រើប្រាស់ផលិតផលឧស្សាហកម្ម និងអង្គការប្រើប្រាស់ផលិតផលដែលស្ថិតនៅក្រោមការស៊ើបអង្កេត ត្រូវមានឱកាស ដើម្បីសំដែងពីទស្សនៈរបស់គេ ថាតើរឿងក្តីនេះសមស្របទៅតាមលក្ខណៈវិនិច្ឆ័យសំរាប់ដាក់ពន្ធបែបនេះឬទេ (ឧទាហរណ៍ ការលក់បង្ខូចថ្លៃ ឬ ឧបត្ថម្ភធន គ្រោះថ្នាក់ និងឧប្បត្តិហេតុ) ។

គេអាចប្រើប្រាស់បទបញ្ញត្តិនេះ ដើម្បីការពារផលប្រយោជន៍ចាំបាច់របស់អ្នកប្រើប្រាស់ និងអតិថិជន នៅពេលដែលអាជ្ញាធរពិនិត្យឃើញថា ការដាក់ពន្ធបែបនេះ អាចឈានទៅរកការបង្កើនតំលៃមិនត្រឹមត្រូវ ។

ការផ្តល់ពត៌មានដោយអ្នកនាំចេញ និងវិធានផ្តល់ពត៌មានដ៏ល្អបំផុត

កិច្ចព្រមព្រៀងស្តីអំពីឧបត្ថម្ភធន និងវិធានការដាក់ពន្ធប៉ះប៉ូវ មាត្រា១២.១០

នៅពេលផ្តល់សិទ្ធិអោយសហគ្រាសនាំចេញការពារផលប្រយោជន៍របស់គេ ក្នុងកំឡុងពេលស៊ើបអង្កេត កិច្ចព្រមព្រៀងបង្ខំអោយពួកគេសហការជាមួយអាជ្ញាធរស៊ើបអង្កេត និងផ្តល់ពត៌មានមួយចំនួនជូនអាជ្ញាធរ អំពីតំលៃផលិតកម្ម និងបញ្ហាផ្សេងៗទៀត។ ក្នុងការអនុវត្តន៍ជាក់ស្តែង អាជ្ញាធរស៊ើបអង្កេតទាមទារអោយផ្តល់ពត៌មានតាមរបៀបជាតារាងសំនួរ ចំលើយ និងក្នុងអំឡុងពេលមិនតិចជាង ៣០ថ្ងៃ ។ នៅពេលដែលសហគ្រាសមិនអាចឆ្លើយតបក្នុងរយៈពេលនេះបាន កិច្ចព្រមព្រៀងស្នើសុំអោយអាជ្ញាធរស៊ើបអង្កេត ពិនិត្យពិចារណា ដើម្បីបន្តពេលវេលាប្រកបដោយសមានចិត្តបន្ថែមទៀត និងជួយដល់សហគ្រាស ប្រសិនមានការស្នើសុំផ្តល់ពត៌មានតាមទំរង់ដែលគេបានទាមទារ ។ ប៉ុន្តែ នៅពេលសហគ្រាសបដិសេធមិនសហការ ឬ មិនផ្តល់ពត៌មានដែលគេចង់បានក្នុងរយៈពេលសមស្រប អាជ្ញាធរស៊ើបអង្កេតអាចធ្វើការសំរេច ដោយផ្អែកលើពត៌មានដែលមាន និងដែលបានផ្តល់អោយដោយឧស្សាហកម្មដែលប្តឹងទាមទារនោះ ។

ការស៊ើបអង្កេតនៅនឹងកន្លែង

កិច្ចព្រមព្រៀងស្តីពីការប្រឆាំងនឹងការលក់បង្ខូចថ្លៃ.មាត្រាទី៦.៧ ឧបសម្ព័ន្ធ ១

និងវិធានឧបត្ថម្ភធន និងការដាក់ពន្ធប៉ះប៉ូវ មាត្រា ១២.៦ និង AnnexVI

អាជ្ញាធរស៊ើបអង្កេតជារឿយៗ និងចាំបាច់ត្រូវធ្វើការស៊ើបអង្កេតនៅនឹងកន្លែង ដើម្បីផ្ទៀងផ្ទាត់ពត៌មានដែលផ្តល់អោយដោយ អ្នកនាំចេញ ឬក្រុមហ៊ុនផលិតក្នុងការឆ្លើយតបទៅនឹងតារាងសំនួរ ឬ ដើម្បីប្រមូលពត៌មានបន្ថែម ។ កិច្ចព្រមព្រៀងចែងថា ការស៊ើបអង្កេតបែបនេះអាចធ្វើទៅបានដរាបណាមានការយល់ព្រមពីអ្នកនាំចេញ រឺ ផលិតករដែលពាក់ព័ន្ធ និងប្រសិនបើរដ្ឋាភិបាលនៃប្រទេសនាំចេញមិនបដិសេធចំពោះការស៊ើបអង្កេតនោះ ។ ត្រូវផ្តល់សេចក្តីជូនដំណឹងអំពីគោលបំណងនៃដំណើរទស្សនៈកិច្ចនេះជាមុន។ សេចក្តីជូនដំណឹងបង្ហាញគួរតែប្រភេទពត៌មាន ដែលគេត្រូវការដើម្បីអោយអ្នកនាំចេញ រឺ ផលិតករអាចរៀបចំខ្លួន ក្នុងការផ្តល់ពត៌មានទាំងនេះ។

ការបដិសេធពុំអនុញ្ញាតិអោយធ្វើការស៊ើបអង្កេតនៅនឹងកន្លែង អាចតំរូវអោយអាជ្ញាធរធ្វើការស៊ើបអង្កេតដោយផ្អែកតែលើពត៌មានដែលមានប៉ុណ្ណោះ ។

វិធានស្តីពីវិធីសាស្ត្រ

អាជ្ញាធរស៊ើបអង្កេតត្រូវប្រើប្រាស់វិធីសាស្ត្រ ដើម្បីគណនាឧបត្ថម្ភធន ក្នុងមួយឯកត្តាដែលទទួលបានដោយផលិតផលមួយ ឬ កំរិតនៃការលក់បង្ខូចថ្លៃ ដែលអាចជះឥទ្ធិពលយ៉ាងខ្លាំងដល់កំរិតនៃការបង់ពន្ធប៉ះប៉ូវ ឬពន្ធប្រឆាំងនិងការលក់បង្ខូចថ្លៃ ដែលបង្កការខូចខាត។ ដូច្នេះកិច្ចព្រមព្រៀងទាំង ២ បានចែងនូវវិធានមួយចំនួនសំរាប់អោយអាជ្ញាធរស៊ើបអង្កេត អនុវត្តតាមក្នុងការគណនា។

កិច្ចព្រមព្រៀង SCM

កិច្ចព្រមព្រៀងស្តីពីឧបត្ថម្ភធន និងវិធានការដាក់ពន្ធប៉ះប៉ូវ មាត្រា ១៤

កិច្ចព្រមព្រៀង SCM ចែងថា ច្បាប់ជាតិ ឬ បទបញ្ញត្តិអនុវត្តរបស់បណ្តាប្រទេសជាសមាជិក គួរបញ្ជាក់អោយច្បាស់ពីវិធីសាស្ត្រដែលអាជ្ញាធរស៊ើបអង្កេតប្រើប្រាស់ក្នុងការកំណត់ឧបត្ថម្ភធនក្នុងមួយឯកត្តា ។ ម្យ៉ាងទៀត ដើម្បីធានានូវតម្លាភាព កិច្ចព្រមព្រៀងបានកំណត់កាតព្វកិច្ចអោយអាជ្ញាធរស៊ើបអង្កេត ពន្យល់ពីសេចក្តីសំរេចក្នុងការគណនាឧបត្ថម្ភធនក្នុងមួយឯកត្តាត្រឹមកំរិតណាដោយប្រើប្រាស់វិធីសាស្ត្រជាក់លាក់ក្នុងច្បាប់នោះ ។

កិច្ចព្រមព្រៀងស្តីពី ADP

ការប្រៀបធៀបថ្លៃ : គោលការណ៍ទូទៅ

កិច្ចព្រមព្រៀងស្តីពីការប្រឆាំងនឹងការលក់បង្ខូចថ្លៃ.មាត្រាទី២.៤

ដូចបានកត់សំគាល់ពីមុនរួចមកហើយថា ផលិតផលមួយអាចចាត់ទុកថា បានលក់បង្ខូចថ្លៃ នៅពេលថ្លៃនាំចេញរបស់ផលិតករបរទេសទាបជាងថ្លៃនៃការប្រើប្រាស់ក្នុងស្រុក របស់ប្រទេសអ្នកនាំចេញ ។ ទំហំនៃការលក់បង្ខូចថ្លៃ ត្រូវបានកំណត់ដោយការប្រៀបធៀបថ្លៃទាំងពីរនេះ ។

កិច្ចព្រមព្រៀងADP កំណត់ពីគោលការណ៍ណែនាំដើម្បីធានានូវការប្រៀបធៀបយ៉ាងត្រឹមត្រូវ រវាងថ្លៃប្រើប្រាស់ក្នុងស្រុក និងថ្លៃនាំចេញ ។ ជាពិសេស កិច្ចព្រមព្រៀងចែងថា ការប្រៀបធៀបបែបនេះ គួរធ្វើក្នុងកំរិតពាណិជ្ជកម្មដូចគ្នា ជាធម្មតាតាមតំលៃនៅរោងចក្រ ហើយពាក់ព័ន្ធទៅនឹងថ្លៃលក់នៅក្បែរៗនោះ ក្នុងពេលដូចគ្នា ។ ត្រូវផ្តល់តាវកាលិកត្រឹមត្រូវ សំរាប់ " ភាពខុសគ្នាក្នុងល័ក្ខខ័ណ្ឌនៃការលក់ ការកំណត់ពន្ធ កំរិតពាណិជ្ជកម្ម បរិមាណ លក្ខណៈជារូបវន្ត" និងកត្តាផ្សេងៗទៀត ដែលប៉ះពាល់ដល់ការប្រៀបធៀបតំលៃ ។

ក្នុងការប្រៀបធៀបថ្លៃ សំណួរចោទឡើងជារឿយៗ ថាតើត្រូវប្រើប្រាស់ចំណុចគោលណា ដើម្បីកំណត់ថ្លៃសំរាប់ការប្រើប្រាស់ក្នុងស្រុក នៅពេលដែលផលិតករលក់ផលិតផលនៅទីផ្សារក្នុងស្រុក តាមតំលៃមួយទាបជាងតំលៃផលិតកម្មជាមធ្យម រឺតំលៃខាតបង់ ។ ផលិតករដែលបានលក់ផលិតផលតាមតំលៃខាតមួយនៅទីផ្សារក្នុងស្រុក អស់រយៈយូរមកហើយ អាចមានលទ្ធភាពលក់បង្ខូចថ្លៃនៅទីផ្សារអន្តរជាតិ ដោយការលក់យកផលចំណេញពីផលិតផលដ៏ទៃទៀតប៉ុណ្ណោះ (ការផ្តល់ឧបត្ថម្ភធនចំពោះផលិតផលផ្សេងទៀត)។ កន្លងមកប្រទេសមួយចំនួនបានលប់ចោលការលក់ក្នុងស្រុកបែបនេះចេញពីការកំណត់ថ្លៃប្រើប្រាស់ក្នុងស្រុក ។ ដើម្បីធានានូវការអនុវត្តន៍ដូចគ្នា ដែលអនុម័តដោយអាជ្ញាធរស៊ើបអង្កេត កិច្ចព្រមព្រៀងបានចែងថា ការលក់នៅទីផ្សារក្នុងស្រុក ក្រោមតំលៃផលិតកម្មដែលបានកំណត់ (រួមមានតំលៃរដ្ឋបាល និងតំលៃលក់) មិនអាចយកមករាប់បញ្ចូលបាននៅពេលដែល ÷

កិច្ចព្រមព្រៀងស្តីពីការប្រឆាំងនឹងការលក់បង្ខូចថ្លៃ. មាត្រាទី ២.១.១ ក្នុងសេចក្តីពន្យល់ខាងក្រោម៣.៤.៥

- ☐ ការលក់នេះធ្វើឡើងលើរយៈពេលវែង (ជាធម្មតា ១ឆ្នាំ)
- ☐ ថ្លៃលក់ជាមធ្យមនៅទីផ្សារក្នុងស្រុក ទាបជាងថ្លៃជាមធ្យមក្នុងមួយឯកត្តា
- ☐ បរិមាណនៃការលក់ទាបជាងតំលៃមួយឯកត្តា មានច្រើនជាង ២០% នៃបរិមាណសរុប
- ☐ ចំណាយពុំបានស្រង់មកវិញក្នុងរយៈពេលមួយសមស្រប ។

ការកំណត់តំលៃមធ្យម

កិច្ចព្រមព្រៀងស្តីពីការប្រឆាំងនឹងការលក់បង្ខូចថ្លៃ. មាត្រាទី២. ៤.២

ដើម្បីឈានដល់ការកំណត់រឹកនៃការលក់បង្ខូចថ្លៃ ដោយប្រៀបធៀបថ្លៃក្នុងស្រុករបស់អ្នកនាំចេញ អាជ្ញាធរស៊ើបអង្កេតជារឿយៗ បានប្រើប្រាស់ប្រព័ន្ធកំណត់តំលៃជាមធ្យម ជាពិសេសនៅពេលការធ្វើអាជីវកម្មធុនតូចមានចំនួនច្រើន ។ ក្នុងករណីនេះ ដើម្បីធានាអោយមានការប្រៀបធៀបតំលៃតាមមូលដ្ឋានដូចគ្នា កិច្ចព្រមព្រៀងតំរូវអោយមានការប្រៀបធៀបដោយផ្អែកលើ ÷

- ☐ ថ្លៃប្រើប្រាស់ក្នុងស្រុកជាមធ្យម ជាមួយនឹងថ្លៃមធ្យមនៃការនាំចេញទាំងអស់
- ☐ ឬទៅលើថ្លៃទីផ្សារក្នុងស្រុក និងថ្លៃនាំចេញលើមូលដ្ឋានអាជីវកម្មដូចគ្នា

កិច្ចព្រមព្រៀងអនុញ្ញាតអោយមានអញ្ញត្រកម្ម ចំពោះវិធានទូទៅនេះ នៅពេលដែលថ្លៃនាំចេញមានលក្ខណៈខុសគ្នាច្រើន ក្នុងចំណោមអ្នកទិញក្នុងតំបន់ ឬ រយៈពេល ។ ក្នុងឧទាហរណ៍បែបនេះ ថ្លៃប្រើប្រាស់មធ្យមក្នុងស្រុក អាចត្រូវបានប្រៀបធៀបជាមួយថ្លៃនាំចេញនីមួយៗ ។

ការប្តូររូបិយប័ណ្ណ

កិច្ចព្រមព្រៀងស្តីពីការប្រឆាំងនឹងការលក់បង្ខូចថ្លៃ មាត្រាទី២.៤.១

ការប្រៀបធៀបថ្លៃប្រើប្រាស់ក្នុងស្រុក ជាមួយនឹងថ្លៃនាំចេញ ជាធម្មតាពាក់ព័ន្ធនឹងការផ្លាស់ប្តូររូបិយប័ណ្ណរបស់ប្រទេសនាំចេញ ។ ដោយសារអតិផរណា អត្រាដែលប្រើប្រាស់សំរាប់ប្តូររូបិយប័ណ្ណ អាចជះឥទ្ធិពលយ៉ាងច្រើនដល់ទំហំនៃការលក់បង្ខូចថ្លៃជាច្រើន។ ដើម្បីរក្សាភាពស្ថិតស្ថេរក្នុងវិធីសាស្ត្រដែលអាជ្ញាធរស៊ើបអង្កេតបានប្រើប្រាស់កិច្ចព្រមព្រៀង ADB ចែងថា អត្រាប្តូរប្រាក់ទូទៅនៅកាលបរិច្ឆេទនៃថ្ងៃលក់ មានសុពលភាពក្នុងការប្រើប្រាស់សំរាប់ប្តូររូបិយប័ណ្ណ ។ ប៉ុន្តែប្រសិនបើ ការធ្វើអាជីវកម្មផ្អែកលើអត្រាប្តូរប្រាក់ដែលមានចែងក្នុងកិច្ចសន្យានោះត្រូវយកអត្រាតាមកិច្ចសន្យានោះមកប្រើប្រាស់ ។

តំលៃស្ថាបនា (Constructed Value)

កិច្ចព្រមព្រៀងស្តីពីការប្រឆាំងនឹងការលក់បង្ខូចថ្លៃ មាត្រាទី ២.២. ២.៣

ដូចមានកត់សំគាល់ពីខាងលើរួចមកហើយថា កិច្ចព្រមព្រៀង ADP ទទួលស្គាល់ថា នៅពេលដែលទំហំនៃការលក់ក្នុង ស្រុកមានទាប នោះថ្លៃប្រើប្រាស់ក្នុងប្រទេសនាំចេញ មិនអាចផ្តល់មូលដ្ឋានសមស្របសំរាប់ការប្រៀបធៀបតំលៃទេ ។ ក្នុងករណីនេះកិច្ចព្រមព្រៀងអនុញ្ញាតិអោយអាជ្ញាធរស៊ើបអង្កេតប្រើប្រាស់តំលៃស្ថាបនា ជំនួសអោយការប្រើប្រាស់ថ្លៃប្រើប្រាស់ក្នុងស្រុកសំរាប់ធ្វើការប្រៀបធៀបថ្លៃ ។ ត្រូវគណនាតំលៃស្ថាបនា ដោយឈរលើមូលដ្ឋាននៃតំលៃផលិតកម្ម ឧស្សាហកម្មនាំចេញ ។ វណ្ណ ២៨ នឹងពិពណ៌នានីតិវិធីដែលកិច្ចព្រមព្រៀងអំពី ADP ចែងសំរាប់គណនាតំលៃស្ថាបនា ។

ខណ្ឌ ២៨

កិច្ចព្រមព្រៀង ស្តីពីការប្រឆាំងនឹងការលក់បង្ខូចថ្លៃ មាត្រាទី ២.២. ២.៣

ដើម្បីប្រៀបធៀបថ្លៃ អាជ្ញាធរស៊ើបអង្កេតសំរេចជំនួសថ្លៃប្រើប្រាស់ក្នុងប្រទេសនាំចេញដោយតំលៃស្ថាបនា ដែលគណនាតាមតំលៃផលិតកម្មរបស់ឧស្សាហកម្មនាំចេញ ហើយកិច្ចព្រមព្រៀង ADP បានចែងពីគោលការណ៍សំរាប់គណនាតំលៃបែបនេះ ។ ជាពិសេសកិច្ចព្រមព្រៀងចែងថា " ជាធម្មតា ត្រូវគណនាចំណាយដោយផ្អែកលើបញ្ជីការណ៍ដែលអ្នកនាំចេញ ឬ ផលិតកររក្សាទុក ក្រោមការស៊ើបអង្កេត ប្រសិនបើបញ្ជីការណ៍នោះ ស្របទៅតាម គោលការណ៍គណនេយ្យទូទៅរបស់ប្រទេសអ្នកនាំចេញ ។ កិច្ចព្រមព្រៀងចែងបន្តទៀតថា បរិមាណសំរាប់ចំណាយរដ្ឋបាល លក់ និងសំរាប់តំលៃទូទៅ និងផលចំណេញត្រូវផ្អែកលើទិន្នន័យជាក់ស្តែង ទាក់ទងនឹងផលិតកម្ម និងការលក់ក្នុងចន្លោះពេល ពាណិជ្ជកម្មធម្មតាទៅលើផលិតផលដូចគ្នា ធ្វើឡើងដោយអ្នកនាំចេញ ឬ អ្នកផលិតដែលស្ថិតក្រោមការស៊ើបអង្កេត ។ ប៉ុន្តែនៅពេលពុំអាចកំណត់បរិមាណតាមមូលដ្ឋានខាងលើបានកិច្ចព្រមព្រៀងចែងថា គេអាចកំណត់តាមមូលដ្ឋានខាងក្រោម÷

> ☐ *មិនមានព័ត៌មានពិតប្រាកដពីអ្នកលក់ ឬ អ្នកផលិតដទៃទៀត នៃផលិតផលប្រភេទទូទៅដូចគ្នា ។*
>
> ☐ *តំលៃ និងផលចំណេញមធ្យម របស់អ្នកនាំចេញដទៃទៀត ទៅលើផលិតផលដូចគ្នា ។*
>
> ☐ *វិធីសាស្ត្រសមស្របដទៃខ្លះទៀត អោយតែបរិមាណនោះមិនលើសពីបរិមាណរបស់អ្នកនាំចេញ ឬ អ្នកផលិត ផលិតផលក្នុងប្រភេទដូចគ្នា ។*

ច្បាប់ De minimis

ជាញឹកញាប់ក្នុងអំឡុងពេលស៊ើបអង្កេតដំបូង អាជ្ញាធរយល់ស្របថា អ្នកប្តឹងទាមទារមិនអាចមានលទ្ធភាពកំណត់នូវគ្រោះថ្នាក់បាន នៅពេលដែលទំហំនៃការលក់បង្ខូចថ្លៃតិច ឬ ការជ្រៀតចូលនៃទំនិញនាំចូលមិនមានច្រើនគួរអោយកត់សំគាល់ ។ កិច្ចព្រមព្រៀង ADP ចែងថា ត្រូវធ្វើការបដិសេធពាក្យសុំ និងបញ្ឈប់ការស៊ើបអង្កេតភ្លាមប្រសិនបើ ÷

កិច្ចព្រមព្រៀងស្តីពីការប្រឆាំងនឹងការលក់បង្ខូចថ្លៃ,មាត្រាទី៥.៨

☐ ទំហំនៃការលក់បង្ខូចថ្លៃ de minims បានន័យថា មានតិចជាង ២% ជាការបញ្ជាក់ពីជាភាគរយនៃថ្លៃនាំចេញ

☐ ទំហំនៃការនាំចូលពីប្រទេសណាមួយនោះ មានបរិមាណតិចជាង ៣% នៃការនាំចូលផលិតផលដូចគ្នាចូលទៅក្នុងប្រទេសអ្នកនាំចូលនោះ ។ ប៉ុន្តែវិធាននេះ មិនអាចអនុវត្តន៍បាន នៅពេលប្រទេសមានភាគហ៊ុនតិចជាង ៣% ជារួមមានច្រើនជាង ៧% នៃផលិតផលកំពុងធ្វើការស៊ើបអង្កេត ។

☐ គ្រោះថ្នាក់មានតិចតួច

កិច្ចព្រមព្រៀងស្តីពីឧបត្ថម្ភធន និងវិធានការដាក់ពន្ធប៉ះប៉ូវ មាត្រាទី១១.៩

ដូចគ្នានេះដែរ កិច្ចព្រមព្រៀងSCM តំរូវអោយអាជ្ញាធរបញ្ឈប់ការស៊ើបអង្កេតក្នុងស្ថានភាពដូចខាងក្រោម ÷

☐ ក្នុងករណីផលិតផលមានប្រភពមកពីប្រទេសជឿនលឿនដែល ÷

- ទំហំឧបត្ថម្ភធនមានតិច de minims បានន័យថា តិចជាង ១% ឬ
- ទំហំនៃការនាំចូលដែលទទួលបានឧបត្ថម្ភធន ឬ បង្កគ្រោះថ្នាក់មានតិចតួច ។

កិច្ចព្រមព្រៀងស្តីពីឧបត្ថម្ភធន និងវិធានការដាក់ពន្ធប៉ះប៉ូវ មាត្រា ២៧.១០

☐ ក្នុងករណីមានប្រភពមកពីប្រទេសដែលកំពុងអភិវឌ្ឍន៍ ÷

- កំរិតនៃការឧបត្ថម្ភធនដែលផ្តល់អោយមិនលើសពី ២% នៃតំលៃដែលគណនាលើមូលដ្ឋានជាឯកត្តា
- ការនាំចូលដែលទទួលបានឧបត្ថម្ភធន មានបរិមាណតិចជាង ៣% នៃការនាំចូលរបស់ប្រទេសនាំចូល ។ ប៉ុន្តែ វិធាននេះពុំអាចអនុវត្តបាន នៅពេលប្រទេសកំពុងអភិវឌ្ឍន៍ដែលមានភាគហ៊ុនរបស់ខ្លួន តិចជាង ៤% នៃចំនួនរួមដែលមានច្រើនជាង៩% នៃការនាំចូលសរុបទេ ។

វិធានស្តីពីការបន្ថយពន្ធ

កិច្ចព្រមព្រៀងស្តីពីការប្រឆាំងនឹងការលក់បង្ខូច ថ្លៃ មាត្រាទី៩.១ កិច្ចព្រមព្រៀងស្តីពីឧបត្ថម្ភធន និងវិធានការដាក់ពន្ធប៉ះប៉ូវ មាត្រា ១៩.២

ក្នុងបរិបទនេះ ជាសំខាន់ត្រូវកត់សំគាល់ផងដែរថា កិច្ចព្រមព្រៀងទាំងពីរគឺ កិច្ចព្រមព្រៀងADP និង SCM បានសង្កត់ធ្ងន់ថា ក្រោយពេលបញ្ចប់ការស៊ើបអង្កេតហើយ រដ្ឋាភិបាលគួរពិនិត្យពិចារណាដោយយកចិត្តទុកដាក់ថា តើគួរដាក់ពន្ធបន្ថែមឬទេ ប្រសិនបើគេបានបំពេញតាមតំរូវការនៃការកំណត់ពន្ធទាំងអស់ហើយ ។

កិច្ចព្រមព្រៀងនេះបានជំរុញអោយមានការប្រើប្រាស់វិធានស្តីពីការបន្ថយពន្ធ ។ តាមកំហិតជិតនេះ បន្ទាប់ពីមានការអះអាង ថាការនាំចូលដើម្បីលក់បង្ខូចថ្លៃ រឺ ដែលបានទទួលឧត្ថម្ភធន បានបង្កអោយមានគ្រោះថ្នាក់ដល់ឧស្សាហកម្មក្នុងស្រុក ហើយអាជ្ញាធររដ្ឋាភិបាលត្រូវធ្វើសេចក្តីសំរេចថា ពន្ធគួរកំណត់ស្មើតំលៃនៃការលក់បង្ខូចថ្លៃ រឺ ស្មើចំនួនឧបត្ថម្ភធន ឬ តិចជាង ប្រសិនបើវិធានស្តីពីការ

បន្ថយពន្ធ មានលក្ខណៈសមស្របក្នុងការលប់បំបាត់គ្រោះថ្នាក់ដល់ឧស្សាហកម្មក្នុងស្រុក ពេលនោះ គេគួរអនុវត្តវិធានស្តីពីការបន្ថយពន្ធ ។ ប្រទេសមួយចំនួនបានអនុវត្តគោលការណ៍នេះ បន្ទាប់ពីបញ្ចប់ការស៊ើបអង្កេត ហើយព្យាយាមកំណត់កំរិតគ្រោះថ្នាក់ និងដាក់ពន្ធទៅលើកំរិតគ្រោះថ្នាក់នោះ ប្រសិនបើគ្រោះថ្នាក់មានកំរិតទាបជាងទំហំការលក់បង្ខូចថ្លៃ ឬ ទំហំនៃឧបត្ថម្ភធន ។

វិធានការណ៍បណ្តោះអាសន្ន

កិច្ចព្រមព្រៀងស្តីពីការប្រឆាំងនឹងការលក់បង្ខូច ថ្លៃ.មាត្រាទី៧ កិច្ចព្រមព្រៀងស្តីពីឧបត្ថម្ភធន និងវិធានការដាក់ពន្ធប៉ះប៉ូវ មាត្រា ១៧

កិច្ចព្រមព្រៀងទាំងពីរផ្តល់វិធានការណ៍បណ្តោះអាសន្ន នៅក្នុងទំរង់ជាការដកលស់សាច់ប្រាក់ ឬ សញ្ញាប័ណ្ណ ដែលប្រកាន់យកនៅពេលដែលអាជ្ញាធរស៊ើបអង្កេតវិនិច្ឆ័យថា វិធានការណ៍នេះ ជាវិធានការណ៍ចាំបាច់ក្នុងការទប់ស្កាត់គ្រោះថ្នាក់ ដែលកើត មានឡើងក្នុងអំឡុងពេលស៊ើបអង្កេត ។ ប៉ុន្តែកិច្ចព្រមព្រៀងបានចែងថា វិធានការណ៍បណ្តោះអាសន្ននេះ គួរប្រកាន់ឡើង បន្ទាប់ពីអាជ្ញាធរស៊ើបអង្កេតបានកំណត់អំពីការលក់បង្ខូចថ្លៃ រឺ ឧបត្ថម្ភធន និងផលប៉ះពាល់ពីគ្រោះថ្នាក់ចំពោះឧស្សាហកម្មក្នុងស្រុករួច ។ ប្រសិនបើមានសេចក្តីសំរេចស្ថាពរក្នុងការកំណត់ពន្ធ ហើយពន្ធនោះខ្ពស់ជាងប្រាក់កក់ ឬ ក៏សញ្ញាប័ណ្ណនោះ ចំនួនទឹកប្រាក់ដែលខុសគ្នានេះ មិនអាចយកពីអ្នកនាំចូលទេ ។ តែទោះជាយ៉ាងណាក៏ដោយ ក៏អ្នកនាំចូលមានសិទ្ធិទាមទារ សំណងដ៏ទៃទៀត នៅពេលដែលពន្ធស្ថាពរនោះ មានទាបជាងប្រាក់កក់ ។

ការកំណត់តំលៃស្ម័គ្រចិត្ត (Price Undertakings)

កិច្ចព្រមព្រៀងស្តីពីការប្រឆាំងនឹងការលក់បង្ខូចថ្លៃ. មាត្រាទី៨

កិច្ចព្រមព្រៀងស្តីពីឧបត្ថម្ភធន និងវិធានការកំណត់ពន្ធប៉ះប៉ូវ មាត្រា ទី១៨

អ្នកនាំចូលអាចចៀសវាងពីការបង់ពន្ធប្រឆាំងនឹងការលក់បង្ខូចថ្លៃ ឬ ពន្ធប៉ះប៉ូវ ដោយការបង្កើនថ្លៃនាំចូលរបស់គេ ។ ប៉ុន្តែដើម្បីទប់ស្កាត់អ្នកនាំចូលពីការបង្កើនតំលៃនេះ នៅពេលដែលការនាំចូលរបស់គេបង្កគ្រោះថ្នាក់ដល់ឧស្សាហកម្មក្នុងស្រុករបស់ប្រទេសនាំចូល កិច្ចព្រមព្រៀងបានអនុញ្ញាតិអោយមានការបង្កើនថ្លៃនេះ បន្ទាប់ពីអាជ្ញាធរស៊ើបអង្កេតកំណត់នូវគ្រោះថ្នាក់ដល់ឧស្សាហកម្មក្នុងស្រុក និងការលក់បង្ខូចថ្លៃ ឬ ឧបត្ថម្ភធនរួចៈ ។ កិច្ចព្រមព្រៀងបានចែងបន្ថែមថា ការសំរេចទទួល យកការបង្កើនថ្លៃគួរតែប្រគល់អោយទៅអ្នកនាំចេញ ហើយចែងទៀតថា គ្មានអ្នកនាំចេញណាត្រូវបានបង្ខំអោយទទួលការបង្កើន ថ្លៃនេះទេ ។ អាជ្ញាធររបស់ប្រទេសនាំចូលមានលទ្ធភាព ពិនិត្យពិចារណាទទួលយកការបង្កើនថ្លៃដែលមានលក្ខណៈផ្ទុយនឹងការប្រតិបត្តិ ។ ទាំងនេះគឺជាបញ្ហា នៅពេលដែលចំនួនពិតប្រាកដនៃអ្នកនាំចេញច្រើនហួសកំណត់ ។

ការផ្សព្វផ្សាយមុនធ្វើការកំណត់ចុងក្រោយ

កិច្ចព្រមព្រៀងស្តីពីការប្រឆាំង និងការលក់បង្ខូច ថ្លៃ.មាត្រាទី៦.៩.

កិច្ចព្រមព្រៀងទាំងពីរបានចែងថា ត្រូវបញ្ចប់ការស៊ើបអង្កេតក្នុងរយៈពេល ១ ឆ្នាំ ហើយមិនមានករណីណាមួយ ដែលការស៊ើបអង្កេតអាចធ្វើលើសពី ១៨ ខែឡើយ បន្ទាប់ពីបានចាប់ផ្តើម ។ មុនពេលធ្វើការកំណត់ចុងក្រោយ កិច្ចព្រមព្រៀងតំរូវអោយអាជ្ញាធរស៊ើបអង្កេត បង្ហាញជូនភាគីពាក់ព័ន្ធ (ឧទាហរណ៍ : អ្នកនាំចេញ ឬ ផលិតករដែលស្ថិតនៅក្រោមការស៊ើបអង្កេត រដ្ឋាភិបាល និងអ្នកនាំចូល) នូវអង្គហេតុចាំបាច់ដែលជាមូលដ្ឋាននៃការធ្វើសេចក្តីសំរេចដើម្បីកំណត់ពន្ធ ។

ការកំណត់អំពីទំហំនៃឧបត្ថម្ភធន និងការលក់បង្ខូចថ្លៃ

កិច្ចព្រមព្រៀងស្តីពីការប្រឆាំងនឹងការលក់បង្ខូច ថ្លៃ.មាត្រាទី៦.១០.៩.២.

និងវិធានឧបត្ថម្ភធននិងការដាក់ពន្ធប្រឆាំងតបវិញមាត្រា១៩.៣

កិច្ចព្រមព្រៀងបានចែងថា ប្រសិនបើអាចធ្វើបាន គេត្រូវកំណត់បរិមាណនៃពន្ធប៉ះប៉ូវ និង ពន្ធប្រឆាំងនឹងការលក់បង្ខូចថ្លៃ ដោយឡែកៗពីគ្នា ចំពោះអ្នកនាំចូល ឬ ផលិតករនីមួយៗ ។ ដូចនេះចំនួនពន្ធដែលអាចទូទាត់បាន អាច ប្រែប្រួលយោងទៅតាមកត្តាឧបត្ថម្ភធន រឺ ទំហំនៃការលក់បង្ខូចថ្លៃ ដែលបានកំណត់ចំពោះអ្នកនាំចូលម្នាក់ៗ ។ ប៉ុន្តែអាជ្ញាធរស៊ើបអង្កេតអាចកំណត់ពន្ធ ដោយផ្អែកលើគំរូស្ថិតិជាផ្លូវការ (ឬ បរិមាណនៃការនាំចូលច្រើនបំផុតពីប្រទេសដែលមានបញ្ហានោះ) នៅពេលដែលចំនួនអ្នកនាំចេញ ឬ ផលិតករមានចំនួនច្រើនពេក សំរាប់គណនាឧបត្ថម្ភធនរបស់ប្រទេសនីមួយៗ ឬ ទំហំនៃការ លក់បង្ខូចថ្លៃមិនអាចអនុវត្តបាន ។ ក្នុងការជ្រើសរើសនេះ ត្រូវជំរុញអោយអាជ្ញាធរស៊ើបអង្កេត ពិគ្រោះយោបល់ជាមួយអ្នកនាំចេញ ឬ ផលិតករដែលពាក់ព័ន្ធ ដើម្បីធ្វើការជ្រើសរើសដោយមានការព្រមព្រៀងសមស្រប ។ លើសពីនេះទៀតអ្នកនាំចេញ ឬ ផលិតករខ្លះ ដែលមិនបានរាប់បញ្ចូលក្នុងគំរូនេះ មានសិទ្ធិស្នើសុំអោយកំណត់ទំហំនៃការលក់បង្ខូចថ្លៃដាច់ដោយឡែកពីគ្នា ។

បទបញ្ញត្តិស្តីពីការផុតកំណត់ (Sunset Clause)

កិច្ចព្រមព្រៀងស្តីពីការប្រឆាំងនឹងការលក់បង្ខូចថ្លៃ.មាត្រាទី១១

និងឧបត្ថម្ភធន និងវិធានការកំណត់ពន្ធប៉ះប៉ូវ មាត្រា២១

កិច្ចព្រមព្រៀងតំរូវ អោយមានការត្រួតពិនិត្យជាអចិន្ត្រៃយ៍នូវវិធានការបន្តប្រឆាំងទៅនឹងការលក់បង្ខូចថ្លៃ និងវិធានការកំណត់ពន្ធប៉ះប៉ូវ (ពន្ធនិងការបង្កើនថ្លៃ)។ ការត្រួតពិនិត្យនេះគួរតែអនុវត្តន៍ដោយអាជ្ញាធរ ក្រោមការផ្តួចផ្តើមគំនិតរបស់គេផ្ទាល់ ឬ តាមសំណើរបស់ភាគីពាក់ព័ន្ធ ។ ប្រសិនបើលទ្ធផលនៃការពិនិត្យនេះ បង្ហាញអោយឃើញថា វិធានការនានានេះ មិនមានសុពលភាពទៀតទេ នោះគេត្រូវតែបញ្ឈប់វិធានការទាំងនោះ ។ ម្យ៉ាងទៀតកិច្ចព្រមព្រៀងមានបទបញ្ញត្តិស្តីពីការផុតកំណត់ (Sunset Clause) ដែលតាមបទបញ្ញត្តិនេះ វិធានការប្រឆាំងនឹងការលក់បង្ខូចថ្លៃ និងវិធានកំណត់ពន្ធប៉ះប៉ូវ នឹងត្រូវផុតកំណត់ដោយស្វ័យប្រវត្តិក្នុងរយៈពេល ០៥ ឆ្នាំ លើកលែងតែការត្រួតពិនិត្យនោះបានកំណត់ថា ប្រសិនបើគ្មានវិធានការប្រឆាំងនឹងការលក់បង្ខូចថ្លៃនេះទេ នោះការលក់បង្ខូចថ្លៃ និងផលប៉ះពាល់នឹងបន្តកើតមានជាថ្មី ។ ការពិនិត្យជាថ្មីត្រូវធ្វើឡើង អោយបានមុនកាលបរិច្ឆេទផុតកំណត់ (Sunset date) ហើយជាធម្មតាត្រូវបញ្ចប់នៅក្នុងរយៈពេល ១ ឆ្នាំ ។

ការពាក់ព័ន្ធផ្នែកពាណិជ្ជកម្ម

ចំពោះពាណិជ្ជករ ចំណេះដឹងអំពីវិធានដ៏ស្មុគស្មាញ ស្តីអំពីការកំណត់ពន្ធប្រឆាំងនឹងការលក់បង្ខូចថ្លៃមានសារៈសំខាន់ចំពោះពួកគេដែលជាអ្នកនាំចេញ រឺផលិតករដែលផលប្រយោជន៍របស់ពួកគេអាចទទួលរងនូវផលប៉ះពាល់ធ្ងន់ធ្ងរ ដោយការអនុវត្តន៍ថ្លៃមិនបានត្រឹមត្រូវរបស់ផលិតករក្នុងស្រុកដ៏ទៃទៀត ។

ក្នុងប៉ុន្មានឆ្នាំថ្មី ៗ នេះ ចំនួនអ្នកប្តឹងទាមទាររកវិធានការប្រឆាំងនឹងការលក់បង្ខូចថ្លៃ កើនឡើងជាលំដាប់ ទាំងក្នុងប្រទេសជឿនលឿន និងប្រទេសកំពុងអភិវឌ្ឍន៍ (សូមអានវណ្ណ ២៩)។ សហគ្រាសក្នុងប្រទេសកំពុងអភិវឌ្ឍន៍ជាច្រើន ទទួលស្គាល់ថា នៅពេលដែលការនាំចេញផលិតផលឧស្សាហកម្មរបស់គេកើនឡើង កំណើននៃសម្ពាធពីឧស្សាហកម្មក្នុងប្រទេសនាំចូល លើការកំណត់ពន្ធដោយផ្អែកលើកត្តាថាទំនិញនោះ កំពុងត្រូវបានលក់បង្ខូចថ្លៃ និងមានឧបត្ថម្ភធនក៏កាន់តែកើនឡើងដែរ ។ អាចមានការដាក់ពន្ធបែបនេះទៅលើទំនិញនាំចូលខ្លះរួមមាន : ផលិតផលវាយនភ័ណ្ឌ ដែលមានសារៈសំខាន់បំផុតចំពោះពាណិជ្ជកម្មក្នុងប្រទេសកំពុងអភិវឌ្ឍន៍។

ជាការចាំបាច់ ក្នុងកាលៈទេសៈបែបនេះ សហគ្រាសនានាត្រូវដឹងពីវិធានដែលអាចអនុវត្តបាននៅក្នុងវិស័យនេះ ។ ឧទាហរណ៍ ការយល់ដឹងអំពីវិធាន អាចបង្កលក្ខណៈអោយសហគ្រាសនាំចេញ ចាត់វិធានការណ៍ជាមុន ដើម្បីចៀសវាងនូវសកម្មភាពនៃការលក់បង្ខូចថ្លៃនៅក្នុងទីផ្សារបរទេស ដែលជាទីកន្លែងមានការកើនឡើងនូវសម្ពាធពីក្រុមដ៏ទៃទៀត និងក្រុមផលិតករ ចំពោះសកម្មភាពបែបនេះ ។ នៅពេលដែលសកម្មភាពនេះអាចនៅបន្តធ្វើការទូទាត់នូវថ្លៃនាំចេញ ដែលតំលៃវាទាបជាង តំលៃទីផ្សារក្នុងស្រុក ដែលជាទីកន្លែងអាចប្រឈមមុខទៅនឹងការភ័យខ្លាច និងវាគួរតែចៀសវាងនូវការធ្វើសកម្មភាពលក់បង្ខូចថ្លៃ ។ នៅក្នុងទីផ្សារបែបនេះ គេអាចបញ្ចៀសពន្ធប្រឆាំងនឹងការលក់បង្ខូចថ្លៃបាន ប្រសិនបើអ្នកនាំចេញមិនអនុញ្ញាតិអោយភាពខុសប្លែកគ្នាពីតំលៃក្នុងស្រុក និងតំលៃនាំចេញ ដើម្បីបំពាក់នូវកំរិតដ៏សមហេតុសមផល ។ ដូចបានជំរាប រួចហើយ ប្រសិនបើទំហំមាន de minims ឬក៏តិចជាងនោះតំរូវអោយអាជ្ញាធរស៊ើបអង្កេត បដិសេធពាក្យស្នើសុំកំណត់ពន្ធ ។ អាជ្ញាធរស៊ើបអង្កេត ត្រូវពិចារណាអំពីចំណែកភាគហ៊ុនរបស់ប្រទេសនាំចេញនៅក្នុង ផលិតផលនាំចូលសរុប ។ នេះអាចជាផលប្រយោជន៍របស់សហគ្រាសនាំចេញ ដែលមិនអនុញ្ញាតិអោយការនាំចេញរបស់គេកើនឡើងនៅទីផ្សារ ដែលមានពាក្យប្តឹងទាមទារអោយចាត់វិធានការប្រឆាំងនឹងសកម្មភាពលក់បង្ខូចថ្លៃ និងប្រសិនបើមានលទ្ធភាព គេនឹងបង្វែរពាណិជ្ជកម្មរបស់គេទៅកាន់ទីផ្សារដ៏ទៃទៀត ។

នៅពេលចាប់ផ្តើមស៊ើបអង្កេត កិច្ចព្រមព្រៀងបានផ្តល់ (សមាគមន៍ពាណិជ្ជកម្ម និងពាណិជ្ជកម្ម) សិទ្ធិដល់សហគ្រាសនាំចេញក្នុងការការពារផលប្រយោជន៍របស់ពួកគេ ។ កិច្ចព្រមព្រៀង ADP កំណត់កាតព្វកិច្ចអោយពួកគេផ្តល់ពត៌មាន អំពីការចំណាយលើផលិតកម្ម និងបញ្ហាដ៏ទៃទៀត តាមសំណួរដែលអាជ្ញាធរស៊ើបអង្កេតបានផ្ញើមកអោយ ។ ជាកត្តាសំខាន់ អ្នកនាំចេញត្រូវសហការជាមួយគ្នា អាជ្ញាធរស៊ើបអង្កេត ព្រមទាំងផ្តល់ពត៌មានដែលគេត្រូវការ និងបណ្តាហេតុផល ទាំងឡាយដែលកំពុងស្ថិតក្នុងករណីលក់បង្ខូចថ្លៃ នៅពេលពន្ធដែលអាចទូទាត់បានត្រូវបានកំណត់ដោយឡែក សំរាប់សហគ្រាសនាំចេញ ដោយឈរលើមូលដ្ឋានទំហំរវាងតំលៃដែលត្រូវបានទូទាត់ដោយទីផ្សារក្នុងស្រុក និងតំលៃនាំចេញរបស់ពួកគេ ។

កិច្ចព្រមព្រៀងបានកំណត់កាតព្វកិច្ចអោយអាជ្ញាធរស៊ើបអង្កេត ជូនដំណឹងដល់រដ្ឋាភិបាលរបស់ប្រទេសនាំចេញអំពីសេចក្តីសំរេចរបស់គេ មុនពេលចាប់ផ្តើមស៊ើបអង្កេត ។ រដ្ឋាភិបាលមានសិទ្ធិផ្តល់ភស្តុតាង បញ្ជាក់តវ៉ានឹងពាក្យបណ្តឹង និងដើម្បីការពារផលប្រយោជន៍របស់អ្នកនាំចេញ។ ការចំណាយតាមផ្លូវច្បាប់ និងចំណាយដ៏ទៃទៀត ក្នុងការចូលរួមស៊ើបអង្កេតមានច្រើន និងជារឿយៗ មានច្រើនជាងធនធានរបស់សហគ្រាសមធ្យម និងធុនតូច ដូច្នេះចាំបាច់ដែលពួកគេត្រូវពឹងផ្អែកទៅលើរដ្ឋាភិបាលដើម្បីការពារផលប្រយោជន៍របស់ពួកគេ ។

ខណ្ឌ ២៩

ការស៊ើបអង្កេតលើការលក់បង្ខូចថ្លៃនៅក្នុងឆ្នាំ ១៩៩៧

ក្នុងអំឡុងពេលពី ថ្ងៃទី ១ ខែ មករា ដល់ថ្ងៃទី ៣១ ខែ ធ្នូ ១៩៩៧ ការស៊ើបអង្កេតប្រឆាំងនឹងការលក់បង្ខូចថ្លៃ មានចំនួន ២៤០ ករណីដែលផ្តួចផ្តើមឡើងដោយប្រទេសជាសមាជិក WTO ។ បណ្តាប្រទេសដែលជាសមាជិកសកម្មបំផុត រួមមានដូច ខាងក្រោម ÷

ប្រទេស	*ទិន្នន័យនៃការអង្កេតដែលបានផ្តួចផ្តើមឡើង*
អូស្ត្រាលី	*៤២*
សហគមន៍អឺរ៉ុប	*៣១*
អាហ្វ្រិកខាងត្បូង	*២៣*
សហរដ្ឋអាមេរិក	*១៦*
អាហ្សង់ទីន	*១៥*
សធារណរដ្ឋកូរ៉េ	*១៥*
កាណាដា	*១៤*
ឥណ្ឌា	*១៣*
ប្រេស៊ីល	*១៤*
ម៉ាឡេស៊ី	*៨*
ម៉ិចស៊ិក	*៦*

នៅក្នុងលក្ខខណ្ឌនៃការនាំចេញផលិតផលដែលបានអង្កេត ក្នុងរយៈពេលមួយឆ្នាំពេញ សហគមន៍អឺរ៉ុបមានតួលេខច្រើនជាងគេ គឺ (៥៩) ហើយបន្ទាប់មកទៀតចិន (៣១) តៃវ៉ាន់ (១៦) សាធារណៈរដ្ឋកូរ៉េ (១៦) អាមេរិក (១៥) និង ជប៉ុនមានចំនួន (១២)។

នៅចុងឆ្នាំ១៩៩៧ មានវិធានការណ៍ប្រឆាំងនឹងការលក់បង្ខូចតំលៃចំនួន ៨៨០ ករណី នៅក្នុងបណ្តាប្រទេសដែលជាសមាជិកផ្សេងៗទៀត ។ ក្នុងនោះសហរដ្ឋអាមេរិកមានចំនួន ៣៤% សហគមន៍អឺរ៉ុប ១៦% កាណាដា ១០% និង ម៉ិចសិចកូ ៩%។ បណ្តាប្រទេសផ្សេង ៗ ទៀតមានចំនួនតិចជាង ៥% នៃវិធានការណ៍សរុបដែលគេបានធ្វើកន្លងមក ។

សកម្មភាពនៃការដាក់ពន្ធប៉ះប៉ូវ

នៅក្នុងកំឡុងថ្ងៃទី ១ ខែ មករា រហូតដល់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៧ ការស៊ើបអង្កេតមានចំនួន ១៦ ករណី នៃការកំណត់ពន្ធប៉ះប៉ូវ ដែលបានផ្តួចផ្តើមគំនិតដោយបណ្តាប្រទេសជាសមាជិក ។

នៅចុងឆ្នាំ ១៩៩៧ សកម្មភាពកំណត់ពន្ធប៉ះប៉ូវចំនួន ៨៧ ករណីមានសុពលភាពនៅក្នុងបណ្តាប្រទេសជាសមាជិក ។

កិច្ចព្រមព្រៀងថែមទាំងស្វែងរកកិច្ចគាំពារផលប្រយោជន៍របស់សហគ្រាសណា ដែលយល់ឃើញថា ពួកគេកំពុងទទួលរងនូវផលប៉ះពាល់ ឬ ខូចប្រយោជន៍ ដោយសារការកំណត់តំលៃពុំយុត្តិធម៌របស់អ្នកផ្គត់ផ្គង់បរទេស ។ សហគ្រាសដែលទទួលរងនូវផលប៉ះពាល់មានសិទ្ធិធ្វើពាក្យបណ្តឹង ទៅអាជ្ញាធរស៊ើបអង្កេតរបស់គេពួកគេ ដើម្បីដាក់ពន្ធប្រឆាំងនឹងការលក់បង្ខូចថ្លៃ ប្រសិនបើការនាំចូលត្រូវបានគេលក់បង្ខូចថ្លៃ និងត្រូវដាក់ពន្ធប៉ះប៉ូវ ប្រសិនបើការនាំចូលទាំងនោះ ទទួលបានឧបត្ថម្ភធន ។ ប៉ុន្តែកិច្ចព្រមព្រៀងបានកំណត់នូវល័ក្ខខ័ណ្ឌតឹងរឹងចំពោះការយកសិទ្ធិនោះមកប្រើ ។ ជាពិសេសពាក្យសុំអនុវត្តកំណត់ពន្ធ អាចត្រូវបានគេធ្វើឡើងប្រសិនបើច្បាប់នោះមានសុពលភាព (standing) ឧទាហរណ៍ : ការគាំទ្រដល់ផលិតករដែលមានផលិតកម្ម យ៉ាងហោចណាស់ ២៥% នៃផលិតផលក្នុងស្រុកដែលបានអះអាង ត្រូវបានគេលក់បង្ខូចថ្លៃ ឬ មានឧបត្ថម្ភធន ។ ជាបន្ថែមទៀតពាក្យស្នើសុំកំណត់ពន្ធត្រូវផ្តល់ពត៌មាន បញ្ជាក់ពីមូលហេតុដែលបង្កអោយមានផលប៉ះពាល់រវាងការនាំចូលដែលកើនឡើង ហើយបានលក់បង្ខូចថ្លៃ និងមានឧបត្ថម្ភធន និងផលប៉ះពាល់បង្កគ្រោះថ្នាក់ដល់ផលិតករ ក្នុងរូបភាពនៃការខាតបង់ផលិតផល ការលក់ដូរក្នុងស្រុក ឬ ការបាត់បង់អាជីព ។

ដូចបានជំរាបពីដំបូង បណ្តឹងស្តីពីការនាំចូលដើម្បីលក់បង្ខូចថ្លៃ និងមានឧបត្ថម្ភធន មានការកើនឡើង នៅក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ភាគច្រើន ដែលអនុវត្តវិធានការសេរីភាវូបនីយកម្ម។ នៅពេលពាក្យបណ្តឹងទាំងនេះ កើតមានដោយសារអសមត្ថភាពរបស់ឧស្សាហកម្មក្នុងស្រុក ដែលមានទំលាប់យូរអង្វែងទៅនឹងកិច្ចគាំពារក្នុងកំរិតមួយខ្ពស់ និងដើម្បីកែតំរូវស្ថានភាពរបស់ខ្លួនអោយស្របទៅនឹងសកម្មភាពប្រកួតប្រជែង ក្រោយពេលលប់ចោលពន្ធគយ និងរបាំងផ្សេងៗទៀត ពេលនោះរាល់ពាក្យបណ្តឹងអំពីការអនុវត្តន៍ពាណិជ្ជកម្មពុំបានត្រឹមត្រូវ របស់អ្នកផ្គត់ផ្គង់បរទេស ប្រាកដជាកើតមានច្រើនយ៉ាងពិតប្រាកដ ។ ការយល់ដឹងច្បាស់អំពីកិច្ចព្រមព្រៀង អាចជួយអោយឧស្សាហកម្មផលិត ប្រើប្រាស់សិទ្ធិរបស់ពួកគេបានយ៉ាងត្រឹមត្រូវ ក្នុងការដាក់ពាក្យប្តឹងទៅអាជ្ញាធរ ដើម្បីដាក់ពន្ធប្រឆាំងនឹងការលក់បង្ខូចថ្លៃ និងដាក់ពន្ធប៉ះប៉ូវ នៅក្នុងករណីបែបនេះ ។ កិច្ចព្រមព្រៀងបានកំណត់ល័ក្ខខ័ណ្ឌតឹងរឹង ដើម្បីធានាអោយការដាក់ពន្ធបែបនេះអាចធ្វើបាន តែនៅពេលណាដែលការលក់បង្ខូចថ្លៃ និងឧបត្ថម្ភធនបង្កអោយមានផលប៉ះពាល់ដល់ឧស្សាហកម្មដែលពាក់ព័ន្ធប៉ុណ្ណោះ ។

ជំពូក ១២

វិធានស្តីពីប្រភពដើមទំនិញ

សេចក្តីសង្ខេប

រដ្ឋាភិបាលបានប្រើប្រាស់ វិធានស្តីពីប្រភពដើមនៃទំនិញដើម្បីកំណត់ប្រទេស ដែលតាមវិធាននេះ ទំនិញនាំចូល ទទួលបានប្រព្រឹត្តកម្មដូចគ្នានឹងទំនិញដែលផលិតនៅទីនោះដែរ ។ ការផ្លាស់ប្តូរនេះកើតមានឡើងនៅក្នុងវិស័យទូរគមនាគមន៍ និងដឹកជញ្ជូន ដែលបច្ចុប្បន្នផ្តល់លទ្ធភាពអោយក្រុមហ៊ុនកាមន្តសាលកម្ម ទទួលបាននូវវត្ថុធាតុដើមសំរាប់ផលិត ផលិតផលសំរេចនៅបរទេស ដែលមានបុគ្គលជំនាញច្រើន ហើយមានចំណាយទាប ។ និន្នាការនេះ សំដៅទៅលើប្រភពផ្តល់វត្ថុធាតុដើមពីប្រទេសផ្សេងៗ ដែលបានទទួលការសំរួលបន្ថែមដោយវិធានការលប់បំបាត់ពន្ធគយ និងរបាំងពាណិជ្ជកម្ម ។

ជាក់ស្តែងផលិតផលដែលមាននៅក្នុងទីផ្សារសព្វថ្ងៃនេះ កំពុងត្រូវបានផលិតនៅក្នុងប្រទេសជាច្រើន ។ ការផលិតមិនថាតែផលិតផលជាសំភារៈប្រើប្រាស់ ដូចជា ក្រណាត់ គ្រឿងសំអាង ឬ ម៉ាស៊ីនទំនើបៗ ដែលបានប្រើប្រាស់ដើម្បីផលិតទំនិញប្រើប្រាស់នោះទេ។ ឧទាហរណ៍ ក្នុងករណីផលិតផលវាយនភ័ណ្ឌ ដូចជាអាវ ឬ ខោ ដែលត្រូវការប្រើក្រណាត់អំបោះកប្បាស ឬ សំយោគ ដើម្បីផលិតខោអាវទាំងនោះ បានផលិតឡើងនៅក្នុងប្រទេសមួយ វាយនភ័ណ្ឌកម្បាញ ការសំរួត និងក្រណាត់បោះពុម្ពត្រូវផលិតនៅប្រទេសមួយទៀត ហើយត្រូវយកមកកាត់ និងដេរនៅក្នុងប្រទេសមួយផ្សេងទៀត ។

គោលបំណងនៃការអនុវត្តន៍វិធាន ដើម្បីកំណត់ប្រទេសផលិតទំនិញ

ហេតុអ្វីបានជា រដ្ឋាភិបាលយល់ថា ការកំណត់ពីប្រភពដើមនៃទំនិញនាំចូល ជាកត្តាចាំបាច់? ការកំណត់នេះ ជាការចាំបាច់ក្នុងស្ថានភាពបី យ៉ាង ។

ស្ថានភាពទីមួយ ការនាំចូលតាមកិច្ចព្រមព្រៀងដែលផ្តល់ភាពអនុគ្រោះ ប្រទេសនាំចូលត្រូវធានាផ្តល់ អត្រាដែលទាបជាង ឬអត្រាដែលផ្តល់ភាពអនុគ្រោះទៅលើទំនិញណាដែលមានប្រភពមកពីបណ្តាប្រទេសដែលបានទទួលភាពអនុគ្រោះនេះ ។ ដូច្នេះ គេត្រូវការភស្តុតាង ដើម្បីបង្ហាញថា ទំនិញនាំចេញនោះ បើមិនបានផលិតទាំងស្រុងទេ យ៉ាងហោចណាស់ក៏បានកែឆ្នៃភាគច្រើននៅក្នុងបណ្តាប្រទេសដែលទទួលបានភាពអនុគ្រោះដែរ ។

ស្ថានភាពទីពីរ សំរាប់ការនាំចូលតាមអត្រាពន្ធគយ MFN ការកំណត់ប្រភពផលិត ជាធម្មតាមិនចាំបាច់ទេ ដោយសារមានការអនុវត្តន៍ពន្ធគយ ដោយឈរលើគោលការណ៍មិនរើសអើង ទៅលើការនាំចូលពីគ្រប់ប្រភពទាំងអស់ ។ តែទោះជាយ៉ាងណាក៏ដោយ នៅពេលដែលវិធានការអាចអនុវត្តបាននៅព្រំដែន ពិចារណាទៅលើប្រទេសប្រភពទំនិញ នោះការកំណត់ប្រភពទំនិញនឹងក្លាយជាកត្តាចាំបាច់ ។ វិធានការទាំងនេះ រួមមានដូចតទៅ ÷

- ☐ ការប្រមូលពន្ធគយលើការលក់បង្ខូចថ្លៃ និងពន្ធប៉ះប៉ូវ

- ☐ ការគ្រប់គ្រងការដាក់កំហិតលើកូតាជាក់លាក់របស់ប្រទេស (ឧទាហរណ៍ការដាក់កំហិតលើកូតាតាមបទបញ្ញត្តិនៃកិច្ចព្រមព្រៀងស្តីពីវាយនភ័ណ្ឌ និងសំលៀកបំពាក់ ឬ តាមវិធានការការពាររបស់ប្រទេស) ។

- ☐ ការគ្រប់គ្រងកូតាពន្ធគយ និង
- ☐ ការដាក់ផ្លាកសញ្ញា ឬ ស្លាកសញ្ញានៃប្រទេសប្រភពដើមនៃទំនិញ ដើម្បីបង្ហាញពីប្រទេសប្រភពដើមនៃទំនិញ

ស្ថានភាពទីបី ការកំណត់ប្រភពដើមនៃទំនិញ ក៏មានការចាំបាច់ផងដែរ នៅក្នុងការប្រមូលផ្តុំស្ថិតិពាណិជ្ជកម្ម ។

គោលការណ៍សំខាន់ ដែលវិធានជាតិបច្ចុប្បន្នអនុវត្តតាម

ប្រព័ន្ធជាតិ ដែលប្រើប្រាស់នាពេលបច្ចុប្បន្ន ដើម្បីកំណត់ប្រភពដើមនៃទំនិញ មានភាពខុសគ្នាគួរអោយកត់សំគាល់ ។ ជាងនេះទៅទៀត នៅក្នុងបណ្តាប្រទេសនានា វិធាននេះអាចមានភាពខុសគ្នា ទៅតាមគោលបំណងនៃការប្រើប្រាស់ (ឧទាហរណ៍ ការគ្រប់គ្រងការដាក់កំហិតលើបរិមាណ ការប្រមូលពន្ធអនុគ្រោះពិសេស ការបិទស្លាកសញ្ញាសំគាល់ប្រភពដើមនៃទំនិញ) ។ ក៏ប៉ុន្តែ ទោះបីមានការប្រែប្រួលយ៉ាងសំខាន់នៅក្នុងប្រព័ន្ធដែលបានអនុម័តរួចក៏ដោយ ក៏និយាយជារួម ប្រព័ន្ធនេះផ្អែកទៅលើគោលការណ៍ ចំនួន២ ។

គោលការណ៍ទីមួយ គឺគោលការណ៍នៃតំលៃបន្ថែមក្នុងការផលិត ឬ កែច្នៃបន្ថែម ។ តាមប្រព័ន្ធដែលផ្អែកលើគោលការណ៍នេះ ផលិតផលមួយអាចចាត់ទុកថាបានផលិតនៅក្នុងប្រទេស ដែលភាគរយជាក់លាក់ (ឧទាហរណ៍ ៤០ ៥០ ៦០ ភាគរយ) នៃតំលៃផលិតផលត្រូវបានដាក់ចូលបន្ថែម ។

គោលការណ៍ទីពីរ គឺជាការកំណត់ប្រភពដើមនៃទំនិញដោយផ្អែកលើការផ្លាស់ប្តូរចំណាត់ថ្នាក់អត្រាពន្ធគយ ។ បណ្តាប្រទេសដែលជាសមាជិក WTO ត្រូវបានជំរុញអោយប្រើប្រាស់ប្រព័ន្ធតារាងពន្ធគយស្របគ្នា ដែលបានរៀបចំឡើងដោយអង្គការគយអន្តរជាតិ (WCO អតីតក្រុមប្រឹក្សាសហប្រតិបត្តិការគយ) ដើម្បីប្រមូលស្ថិតិពាណិជ្ជកម្ម និងដើម្បីកំណត់ពន្ធគយ ។ ប្រព័ន្ធតារាងនេះមាន ៩៧ ជំពូក ហើយនៅក្នុងជំពូកនីមួយៗ មានការរៀបចំចាត់ថ្នាក់ផលិតផលទៅតាមកំរិតនៃការកែច្នៃ ដោយចាប់ផ្តើមពីវត្ថុធាតុដើម រហូតផលិតផលពាក់កណ្តាលកែច្នៃ និងនៅចុងចប់គឺផលិតផលសំរេច ។ តាមការប្រើប្រព័ន្ធចំណាត់ថ្នាក់នេះ ចំណាត់ថ្នាក់នៃតារាងពន្ធគយ ប្រែប្រួលទៅតាមប្រភពដើមនៃទំនិញនៅក្នុងប្រទេស ដែលធ្វើការកែច្នៃ ។

បញ្ហាដែលកើតមកពីភាពខុសគ្នានៅក្នុងវិធានកំណត់ប្រភពដើមនៃទំនិញ

GATT មិនមានវិធានច្បាស់លាស់សំរាប់កំណត់ប្រភពដើមនៃទំនិញទេ ។ ការដែលមិនមានវិធានច្បាស់លាស់នេះ ធ្វើអោយប្រទេសមានភាពអាចបត់បែនបាន ក្នុងការអនុម័តវិធានផ្ទាល់របស់គេ និងប្រើប្រាស់វិធាននោះខុសៗគ្នា ដោយអនុលោមទៅតាមគោលបំណងដែលគេប្រើប្រាស់ (សូមមេត្តាអានអត្ថបទខាងលើ) ។ ជាងនេះទៅទៀត ភាពដែលអាចបត់បែនបាននេះ បានផ្តល់លទ្ធភាពអោយប្រទេសអនុម័តវិធានស្តីពីប្រភពដើមនៃទំនិញក្នុងគោលបំណងការពារ ឧទាហរណ៍បដិសេធមិនអោយទទួលបានកូតា ដោយមូលហេតុថា ផលិតផលនាំចូលមិនត្រូវបានចាត់ទុកថាមានប្រភពមកពីប្រទេសដែលទទួលបានកូតានោះ ។

ដើម្បីស្វែងរកដំណោះស្រាយចំពោះបញ្ហានេះ និងចំពោះបញ្ហាខាងលើដែលកើតមកពីការមិនមានវិធានច្បាស់លាស់ ទើបកិច្ចប្រជុំយូរ៉ូហ្គាយបានធ្វើការចរចាទៅលើកិច្ចព្រមព្រៀងស្តីពីវិធានប្រភពដើមនៃទំនិញ ។

កិច្ចព្រមព្រៀងស្តីពីវិធានប្រភពដើមនៃទំនិញ

វិសាលភាព និងកម្មវត្ថុ

បទបញ្ញត្តិនៃកិច្ចព្រមព្រៀងអនុវត្តទៅលើ " ច្បាប់ បទបញ្ជា និងការអនុវត្តន៍ជាទូទៅនៃការកំណត់ផ្នែករដ្ឋបាល ដែលបានអនុវត្តដោយសមាជិកណាមួយ ដើម្បីកំណត់ប្រទេសប្រភពដើមនៃទំនិញ " ដែលនាំចូលតាមល័ក្ខខ័ណ MFN ។ កិច្ចព្រមព្រៀងបាន

កិច្ចព្រមព្រៀងស្តីពីវិធានប្រភពដើមនៃទំនិញ មាត្រា ១:១

បញ្ជាក់ជាពិសេសថា បទបញ្ញត្តិជាខ្លឹមសារនៃកិច្ចព្រមព្រៀង មិនអនុវត្តទៅលើការនាំចូល ដែលធ្វើឡើងតាមកិច្ចព្រមព្រៀងផ្តល់ភាពអនុគ្រោះពិសេសទេ ។

កម្មវត្ថុជាមូលដ្ឋាននៃកិច្ចព្រមព្រៀង គឺតំរូវអោយប្រទេសនានា អនុម័តវិធានស្របគ្នាតែមួយសំរាប់កំណត់ប្រភពទំនិញនាំចូលតាមមូលដ្ឋាន MFN។ ដោយសារកិច្ចព្រមព្រៀងរំពឹងថា ការងារបច្ចេកទេសក្នុងការរៀបចំវិធានទាំងនេះ ទាមទាររយៈពេលយូរ ទើប កិច្ចព្រមព្រៀងកំណត់នូវបទបញ្ញត្តិពីរយ៉ាង ។

បទបញ្ញត្តិទីមួយ កំណត់ពីវិន័យដែលប្រទេសនានាត្រូវអនុវត្តតាមក្នុងរយៈពេលអន្តរកាល ដូចជា រហូតដល់ពេលវិធានសុខដុមកាវូបនីយកម្មថ្មី ចូលជាធរមាន ។ ការងារបច្ចេកទេសទីពីរ ស្តីពីសុខដុមកាវូបនីយកម្មនៃវិធាននេះ ដែលបច្ចុប្បន្នគណៈកម្មាធិការបច្ចេកទេសរបស់ WCO កំពុងបំពេញតាមគោលការណ៍ណែនាំរបស់គណៈកម្មាធិការស្តីពីវិធានប្រភពដើមនៃទំនិញរបស់ WTO ដែលបានបង្កើតឡើងតាមកិច្ចព្រមព្រៀង ។ បទបញ្ញត្តិទីពីរ អាចអនុវត្តបានក្រោយរយៈពេលអន្តរកាល ។ បទបញ្ញត្តិនេះ ចែងពីគោលការណ៍ និងគោលការណ៍ណែនាំសំរាប់ការងារបច្ចេកទេស លើសុខដុមកាវូបនីកម្មនៃវិធានប្រភពដើមនៃទំនិញ ។

វិធានដែលអាចអនុវត្តបាននៅក្នុងរយៈពេលអន្តរកាល

កិច្ចព្រមព្រៀងស្តីពីវិធានប្រភពដើមនៃទំនិញ មាត្រា ២

ក្នុងរយៈពេលអន្តរកាល មានការអនុញ្ញាតិអោយប្រទេសអនុវត្តស្តង់ដារខុសៗគ្នា ដោយអនុលោមទៅតាមគោលបំណង ឬ កម្មវត្ថុដែលវិធានត្រូវអនុវត្តទៅលើ ។ ក៏ប៉ុន្តែ ក្រោយរយៈពេលអន្តរកាល ស្តង់ដារសុខដុមកាវូនីយកម្ម ដែលបានលប់បំបាត់ចោលលើមូលដ្ឋានទំនិញ តាមទំនិញ ត្រូវបានយកមកអនុវត្តដូចគ្នាតែមួយ ដោយមិនគិតពីគោលបំណងដែលស្តង់ដារនោះអនុវត្តទៅលើឡើយ។ ម្យ៉ាងទៀត មិនមានការលើកចំហអោយប្រទេសអនុវត្តស្តង់ដារតែមួយប្រភេទ ដើម្បីកំណត់ប្រភពដើមនៃទំនិញ ក្នុងគោលបំណងដាក់កំហិតលើការគ្រប់គ្រងបរិមាណ និងមួយប្រភេទទៀត ដើម្បីបង្ហាញពីប្រភពដើមនៃទំនិញតាមរយៈការបិទស្លាកសញ្ញា ។

កិច្ចព្រមព្រៀងបានកំណត់បន្ថែមទៀត ពីគោលការណ៍ (ឧទាហរណ៍ តំលាភាព មិនរើសអើង និងបទបញ្ញត្តិសំរាប់ត្រួតពិនិត្យមើលឡើងវិញលើសេចក្តីសំរេចផ្នែករដ្ឋបាល) ដែលប្រទេសនានារំពឹងថា នឹងត្រូវអនុវត្តតាមក្នុងរយៈពេលអន្តរកាល ។ គោលការណ៍ទាំងនេះ មានកំណត់នៅក្នុងវណ្ណ ៣០ ។

វិធានដែលអាចអនុវត្តបានក្រោយរយៈពេលអន្តរកាល

កិច្ចព្រមព្រៀងស្តីពីវិធានប្រភពដើមនៃទំនិញ មាត្រា ៣ (ខ)

ក្រោយរយៈពេលអន្តរកាល វិធានបានចែងថា ប្រភេទប្រភពដើមនៃទំនិញ ជានិច្ចជាកាល គឺ ˝ ជាប្រទេសដែលធ្វើការកែច្នៃចុងក្រោយលើទំនិញចុងក្រោយ ˝ ។ ក្នុងគោលបំណងនេះ តំរូវអោយគណៈកម្មការធិការបច្ចេកទេស WCO ធ្វើការពន្យល់អោយបានលំអិតពីផលិតផលពិសេស ឬ ការផ្លាស់ប្តូរវិស័យផលិតផលនៅក្នុងអនុចំណងជើង ឬ ចំណងជើងតារាងពន្ធគយ ដែលត្រូវកើតមានឡើងតាមរយៈកាមន្តសាលកម្ម ឬ កែច្នៃសំរាប់ប្រទេស ដើម្បីអះអាងពីប្រភពដើមនៃទំនិញ ។ តែទោះជាយ៉ាងណាក៏ដោយ សំរាប់ផលិតផលដែលមានការ ˝ប្រើប្រាស់ផ្តាច់មុខ˝ នូវការផ្លាស់ប្តូរក្នុងអនុចំណងជើងតារាងពន្ធគយ ˝ មិនអនុញ្ញាតិអោយមានការបញ្ជាក់ពីការកែប្រែជាសំខាន់ ˝ គណៈកម្មាធិការ ត្រូវបានផ្តល់យោបល់អោយកំនត់លក្ខណៈវិនិច្ឆ័យបន្ថែម ។ លក្ខណៈវិនិច្ឆ័យនោះ អាចដាក់បញ្ចូលនូវតំរូវការបន្ថែម ទាក់ទងទៅនឹង ˝ ភាគរយនៃ ad valorem និង/ឬ កាមន្តសាលកម្ម ឬ កិច្ចដំណើរការកែច្នៃ˝ ។

ការអនុវត្តន៍បច្ចុប្បន្នការងារបច្ចេកទេសស្តីពីសុខដុមកាវូបនីយកម្ម

ការងារបច្ចេកទេសស្តីពីសុខដុមកាវូបនីយកម្ម នៃវិធានប្រភពដើមនៃទំនិញ បានបញ្ចប់មុនឆ្នាំ ១៩៩៨ ។ លក្ខណៈស្មុគស្មាញនៃការងារនេះ និងភាពខុសគ្នាដែលកើតមានឡើងលើលក្ខណៈវិនិច្ឆ័យជាក់លាក់ ក្នុងចំណោមបណ្តាប្រទេស សំរាប់កំណត់ប្រភពដើមនៃទំនិញចំពោះក្រុមទំនិញជាក់លាក់ បានរាំងគណៈកម្មាធិការបច្ចេកទេស WCO មិនអោយបញ្ចប់ការងាររបស់គេបាន មុនកាលបរិច្ឆេទដែលបានកំណត់ ។ លទ្ធផលនៃការងាររបស់គេ ក្រោយពីបានបំពេញរួច និងក្រោយពេលបានអនុម័តដោយគណៈកម្មាធិការស្តីពីវិធានប្រភពដើមនៃទំនិញរបស់ WTO នឹងត្រូវអនុម័តទៀតដោយសន្និសីទថ្នាក់រដ្ឋមន្ត្រី WTO ។ ពេលនោះគេនឹង

ដាក់បញ្ចូលវិធាននោះទៅក្នុងកិច្ចព្រមព្រៀងស្តីពីវិធានប្រភពដើមនៃទំនិញជាឧបសម្ព័ន្ធ ។ រាល់ប្រទេសជាសមាជិក នឹងត្រូវបានតំរូវអោយអនុវត្តលក្ខណៈវិនិច្ឆ័យបែបសុខដុមភាវូបនីយកម្ម ដែលមានបញ្ជាក់នៅក្នុងឧបសម្ព័ន្ធស្តីពីចាប់ពីកាលបរិច្ឆេទ ដែលបានឯកភាពអោយចូលជាធរមាន ។

គួរកត់សំគាល់ថា ក្រៅពីកាតព្វកិច្ចក្នុងការអនុវត្តន៍ លក្ខណៈវិនិច្ឆ័យបែបសុខដុមភាវូបនីយកម្ម បណ្តាប្រទេសជាសមាជិក ត្រូវគោរពគោលការណ៍ពាក់ព័ន្ធទៅនឹងតំលាភាព ការមិនរើសអើង ការវាយតំលៃផ្នែករដ្ឋបាល និងការពិនិត្យមើលឡើងវិញផ្នែកតុលាការ ដូចមានរាយនាមក្នុងវណ្ណ ៣០ (d) ដល់ (k) ។

វណ្ណ ៣០

វិន័យក្នុងសម័យអន្តរកាល

កិច្ចព្រមព្រៀងស្តីពីវិធានប្រភពដើមនៃទំនិញ មាត្រា ២

ក្នុងសម័យអន្តរកាល (រហូតដល់វិធានសុខដុមភាវូបនីយកម្ម ចូលជាធរមាន) សមាជិកទាំងអស់ត្រូវធានា ÷

(ក) អោយមានការកំណត់យ៉ាងច្បាស់លាស់ទៅលើវិធាននៃប្រភពដើមនៃទំនិញ រួមមានទាំងឧបាយប្រភេទសំរាប់ធ្វើការសាកល្បង ការកែច្នៃប្រកបដោយខ្លឹមសារផងដែរ ។

(ខ) មិនត្រូវប្រើប្រាស់ វិធាននៃប្រភពដើមនៃទំនិញ ជាលិខិតុបករណ៍នៃគោលនយោបាយពាណិជ្ជកម្មទេ

(គ) វិធាននៃប្រភពដើមនៃទំនិញមិនបង្កើតអោយមានឥទ្ធិពលបែបជាការដាក់កំហិតការបំលាស់ប្តូរ ឬ បង្អាក់ដល់ផ្នែកពាណិជ្ជកម្មអន្តរជាតិ និងមិនតំរូវអោយមានការបំពេញលក្ខខ័ណ្ឌ ដែលមិនពាក់ព័ន្ធទៅនឹងការផលិត ឬ ការកែច្នៃផលិតផល ដែលកំពុងមានបញ្ហានោះឡើយ ។

(ឃ) វិធាននៃប្រភពដើមនៃទំនិញ ដែលអនុវត្តទៅលើការនាំចូល និងនាំចេញ មិនមានលក្ខណៈតឹងតែងជាងវិធានដែលបានអនុវត្ត ដើម្បីកំណត់ថាតើទំនិញនោះជាទំនិញក្នុងស្រុក និងមិនមានរើសអើងរវាងប្រទេសជាសមាជិក (គោលការណ៍ MFN និងGSP)។

(ង) វិធាននៃប្រភពដើមនៃទំនិញ ត្រូវបានគ្រប់គ្រងតាមរបៀបដែលស្របគ្នា ក្នុងទំរង់តែមួយមិនលំអៀង និងតាមលក្ខណៈសមស្រប ។

(ច) វិធាននៃប្រភពដើមនៃទំនិញ ត្រូវផ្អែកទៅលើស្តង់ដារជាវិជ្ជមាន ។ ស្តង់ដារអវិជ្ជមាន អាចអនុញ្ញាតិបានតែក្នុងករណីជាផ្នែកមួយនៃចំណាត់ថ្នាក់ស្តង់ដារវិជ្ជមាន ឬ ក្នុងករណីនីមួយៗ ដែលការកំណត់បែបវិជ្ជមាន ឬ ការកំណត់ប្រភពនោះមិនមានភាពចាំបាច់ ។

(ឆ) វិធាននៃប្រភពដើមនៃទំនិញ ត្រូវបោះពុម្ពផ្សាយជាបន្ទាន់

(ជ) តាមសំណើ ការវាយតំលៃលើប្រភពដើមនៃទំនិញ ត្រូវបានចេញផ្សាយ អោយបានឆាប់តាមលទ្ធភាពដែលអាចធ្វើទៅបាន ប៉ុន្តែមិនអោយយឺតជាង ១៥០ ថ្ងៃក្រោយពេលដាក់សំណើស្នើសុំនោះទេ ។ ការវាយតំលៃត្រូវបោះពុម្ពផ្សាយជាសាធារណៈ តែមិនត្រូវផ្សព្វផ្សាយពត៌មានសំងាត់ទេ លើកលែងតែតំរូវក្នុងបរិបទនៃដំណើរការក្តីនៅតុលាការ ។ ការវាយតំលៃលើប្រភពដើមនៃទំនិញ នៅមានសុពលភាពក្នុងរយៈពេល ៣ ឆ្នាំ ប្រសិនបើអង្គហេតុ និងលក្ខខ័ណ្ឌនៅតែអាចប្រៀបធៀបបាន លើកលែងតែមានការត្រួតពិនិត្យឡើងវិញលើសេចក្តីសំរេចផ្ទុយពីការវាយតំលៃនេះ ដូចមានចែងនៅក្នុង (ញ) ។

(ឈ) មិនមានវិធាននៃប្រភពដើមនៃទំនិញ ឬ ការកែប្រែណាមួយនៅទីនេះ អាចអនុវត្តបានដោយមានប្រតិសកម្មទេ ។

(ញ) ចំណាយការផ្នែករដ្ឋបាលណាមួយ ពាក់ព័ន្ធទៅនឹងការកំណត់ប្រភពដើមនៃទំនិញ អាចត្រួតពិនិត្យមើលបានជាបន្ទាន់ដោយតុលាការ ឬ សាលាជំនុំជំរះក្តីផ្នែករដ្ឋបាល ឬ ដោយនីតិវិធីនៃអាជ្ញាធរឯករាជ្យដែលជាអ្នកចេញការកំណត់នេះ ហើយលទ្ធផលនៃសេចក្តីសំរេចអាចធ្វើការកែប្រែបាន ឬ អាចមានខ្លឹមសារផ្ទុយពីការកំណត់នោះឡើយ ។

(ដ) ពត៌មានសំងាត់ មិនអាចផ្សព្វផ្សាយបាន ដោយគ្មានការអនុញ្ញាតិណាមួយពីបុគ្គលដែលផ្តល់ពត៌មាននោះទេ លើកលែងតែមានការតំរូវនៅក្នុងបរិបទនៃដំណើរការក្តីរបស់តុលាការ ។

វិធាននៃប្រភពដើមនៃទំនិញដែលមានភាពអនុគ្រោះ

ថ្វីបើ WCO កំពុងអភិវឌ្ឍន៍វិធាននៃប្រភពទំនិញស្របគ្នា មិនអាចអនុវត្តបានទៅលើការនាំចូលដែលបានទទួលតាមកិច្ចព្រមព្រៀងអនុគ្រោះពិសេសក្នុងតំបន់ ឬ តាម GSP ក៏ដោយ ក៏កិច្ចព្រមព្រៀងបានចែងថា បណ្ដាប្រទេសនានាត្រូវពិចារណាទៅលើគោលការណ៍ទូទៅ ដែលមានរាយនាមនៅក្នុងវគ្គ ៣០ នៅក្នុងការអនុវត្តន៍ និងគ្រប់គ្រងវិធាននៃប្រភពដើមនៃទំនិញនោះ។

ការពាក់ព័ន្ធផ្នែកពាណិជ្ជកម្ម

ការអនុម័ត លក្ខណៈវិនិច្ឆ័យបែបសុខដុមកាវូបនីយកម្ម ដើម្បីកំណត់ប្រភពដើមនៃទំនិញ រំពឹងថា នឹងអាចដោះស្រាយបញ្ហាជាច្រើនដែលអ្នកនាំចេញសព្វថ្ងៃនេះជួបប្រទះ ជាពិសេសបញ្ហាដែលពាក់ព័ន្ធទៅនឹងរាយនភ័ណ្ឌ ក្នុងការប្រើប្រាស់កូតា ដែលបានបែងចែកជាពិសេសទៅអោយប្រទេសរបស់គេ ។ សុខដុមកាវូបនីយកម្ម ក៏លប់បំបាត់ផងដែរនូវភាពខុសគ្នាក្នុងវិធានជាតិ សំរាប់កំណត់ប្រភពទំនិញ ។ សុខុដុមកាវូបនីយកម្ម នឹងកាត់បន្ថយបន្ទុករដ្ឋបាលទៅលើសហគ្រាសនាំចេញ ដែលបច្ចុប្បន្នត្រូវធានាអោយសហគ្រាសទាំងនោះបំពេញទៅតាមតំរូវការផ្សេងៗ ដែលកំណត់ដោយប្រទេសខុសៗគ្នា ទៅលើផលិតផល ដែលស្ថិតនៅក្រោមវិធានការដាក់កំហិត និងវិធានការកំណត់បរិមាណផ្សេងៗ ។

ជំពូក ១៣
វិធានការវិនិយោគដែលពាក់ព័ន្ធនឹងពាណិជ្ជកម្ម

សេចក្តីសង្ខេប

ជារឿយៗ រដ្ឋាភិបាលតែងដាក់លក្ខខណ្ឌទៅលើវិនិយោគិនបរទេស ដើម្បីជំរុញការវិនិយោគទុន ដោយអនុលោមទៅតាមអាទិភាពជាតិមួយចំនួន ។ លក្ខខណ្ឌដែលមានឥទ្ធិពលទៅលើពាណិជ្ជកម្ម ត្រូវបានគេទទួលស្គាល់ថាជា វិធានការវិនិយោគទុនដែលពាក់ព័ន្ធនឹងពាណិជ្ជកម្ម ឬ TRIMs ។

កិច្ចព្រមព្រៀងស្តីពី TRIMs ដែលបានចរចានៅក្នុងយូរ៉ូហ្គាយ បានតំរូវអោយបណ្តាប្រទេសនានាបំបាត់ចោល TRIMs ដែលកន្លងមកបានបញ្ជាក់ថា មិនមានលក្ខណៈស្របទៅនឹងវិធាន GATT ។ រយៈពេលលប់បំបាត់ TRIMs សំរាប់ប្រទេសជឿនលឿនមានរយៈពេល ២ ឆ្នាំ ដោយគិតចាប់ពីថ្ងៃទី ១ ខែ មករា ១៩៩៥ ។ ប្រទេសកំពុងអភិវឌ្ឍន៍មានរយៈពេលអន្តរកាលចំនួន ៥ ឆ្នាំ ឯប្រទេសក្រីក្រមាន ៧ ឆ្នាំ ។

នៅពេលកិច្ចចរចានៅយូរ៉ូហ្គាយ បានចាប់ផ្តើមឡើង សហរដ្ឋអាមេរិកបានស្នើ អោយមានការដាក់វិន័យចំពោះវិធានការ វិនិយោគណាដែលធ្វើអោយមានផលប៉ះពាល់ដល់ពាណិជ្ជកម្ម ។ មានសំណើរទៀតដែរថា ការចរចាគួរគ្របដណ្តប់ទៅលើបញ្ហាគោលនយោបាយដែលមានផលប៉ះពាល់ទៅលើចរន្តនៃការវិនិយោគផ្ទាល់ពីបរទេស ។ ជាពិសេស មានសំណូមពរអោយមានការពិនិត្យមើលជាចាំបាច់ទៅលើភាពដែលអាចសិក្សាបាននៃការវិនិយោគផ្ទាល់ពីបរទេស គោលការណ៍ GATT នៃប្រព្រឹត្តកម្មជាតិ (ដែលអាចផ្តល់អោយក្រុមហ៊ុនបរទេសនូវសិទ្ធិដូចគ្នានឹងក្រុមហ៊ុនជាតិចំពោះការវិនិយោគ ការរៀបចំបង្កើត និងកិច្ចប្រតិបត្តិក្នុងស្រុក) និងប្រព្រឹត្តកម្ម MFN (ដែលអាចរារាំងប្រទេសពីការរើសអើងក្នុងចំណោមប្រភពវិនិយោគទុន) ។

នៅខណៈពេលដែលសំណើនោះទទួលបាននូវការគាំទ្រមួយចំនួន ពីបណ្តាប្រទេសជឿនលឿនផ្សេងទៀត គេក៏មិនបានពិនិត្យមើលការផ្តល់ផលអនុគ្រោះអោយបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ដែរ ។ ក្រៅពីអះអាងថា អាណត្តិនៃ GATT មិនអនុញ្ញាតិអោយមានការចរចាលើបញ្ហាវិនិយោគ ប្រទេសទាំងនេះបានប្រកាន់ថា ប្រសិនបើមានការចរចាបែបនោះកើតឡើង នោះការចរចាគួរដាក់បញ្ចូលទាំងបញ្ហាដែលបានដាក់ទៅលើពាណិជ្ជកម្ម ដោយក្រុមហ៊ុនសាជីវកម្មអន្តរជាតិ ដើម្បីដោះស្រាយផ្ទេរការកំណត់ថ្លៃ វិធីរាជីវកម្មដែលមានកំហិត និងការអនុវត្តន៍ផ្សេងៗទៀត ។ ការស្ទាក់ស្ទើររបស់បណ្តាប្រទេសកំពុងអភិវឌ្ឍន៍ ក្នុងការអនុញ្ញាតិអោយមានការពិភាក្សានៅក្នុង GATT អំពីបញ្ហាវិនិយោគទុន ដែលបង្ហាញជាលទ្ធផលពិតប្រាកដនៅក្នុងការចរចាដែលធ្វើឡើងតាមគំនិតដែលបានកំណត់យ៉ាងចង្អៀតពីវិធានការវិនិយោគដែលពាក់ព័ន្ធនឹងពាណិជ្ជកម្ម ។

តើមានដូចម្តេច? TRIMs ?

វិធានការដែលបានអនុម័តដោយរដ្ឋាភិបាល ដើម្បីទាក់ទាញ និងគ្រប់គ្រងការវិនិយោគទុនបរទេស រួមមានទាំងការលើកទឹកចិត្តផ្នែកសារពើពន្ធ ការបង្វិលពន្ធ និងការបែងចែកដីធ្លី ព្រមទាំងសេវាកម្មផ្សេងៗ ទៀតតាមលក្ខខណ្ឌអនុគ្រោះជាពិសេស ។ ក្រៅពីនេះរដ្ឋាភិបាលបានកំណត់លក្ខខណ្ឌបន្ថែម ដើម្បីជំរុញលើកទឹកចិត្ត ឬ បង្ខិតបង្ខំអោយប្រើប្រាស់ការវិនិយោគ ដោយអនុលោមទៅតាមអាទិភាពជាតិមួយចំនួន ។ តំរូវការអោយវិនិយោគិនប្រើប្រាស់វត្ថុធាតុដើមក្នុងស្រុក មួយចំនួនក្នុងការផលិត គឺជាឧទាហរណ៍

នៃល័ក្ខខ័ណ្ឌបែបនោះ ។ តំរូវការនាំចេញ ក៏ជាឧទាហរណ៍មួយទៀត ដែលបង្ខំអោយវិនិយោគិនធ្វើការនាំចេញទិន្នផលរបស់គេមួយចំនួន ។ ល័ក្ខខ័ណ្ឌដែលអាចមានផលប៉ះពាល់ទៅលើពាណិជ្ជកម្ម ត្រូវបានគេហៅថា វិធានការវិនិយោគដែលពាក់ព័ន្ធនឹងពាណិជ្ជកម្ម ឬ TRIMs ។ បញ្ជីពន្យល់លំអិត មានបង្ហាញជូននៅក្នុងវណ្ណ ៣១ ។

វណ្ណ ៣១

បញ្ជីពន្យល់លំអិតអំពី TRIMs

តំរូវការប្រើប្រាស់វត្ថុធាតុដើមក្នុងស្រុក (LCRs) *: ការប្រើប្រាស់វត្ថុធាតុដើមក្នុងស្រុកមួយចំនួនសំរាប់ផលិតកម្ម ។*

តំរូវការតុល្យភាពពាណិជ្ជកម្ម *: កំណត់អោយការនាំចូលត្រូវសមមូល្យទៅនឹងសមាមាត្រនៃការនាំចេញជាក់លាក់ ។*

តំរូវការតុល្យភាពរូបិយប័ណ្ណបរទេស *: ចែងថា រូបិយប័ណ្ណបរទេស ដែលមានសំរាប់ការនាំចូល គឺជាសមាមាត្រនៃតំលៃរូបិយប័ណ្ណបរទេសណាមួយ ដែលបានមកដោយការនាំចេញរបស់ក្រុមហ៊ុន និងមកពីប្រភពផ្សេងៗទៀត ។*

ការដាក់កំហិតលើរូបិយប័ណ្ណបរទេស *: មានការដាក់កំហិតក្នុងការទទួលបាននូវរូបិយប័ណ្ណបរទេស និងធ្វើអោយមានការដាក់កំហិតលើការនាំចូល ។*

តំរូវការលក់ក្នុងស្រុក *: តំរូវអោយក្រុមហ៊ុនលក់ទិន្នផលផលិតក្នុងស្រុករបស់គេនូវចំនួនសមាមាត្រណាមួយ ដែលចំនួននោះបង្កើតជាការដាក់កំហិតលើការនាំចេញ ។*

តំរូវការកម្មន្តសាលកម្ម *: តំរូវអោយមានការផលិតផលិតផលក្នុងស្រុកមួយចំនួន ។*

តំរូវការអនុវត្តន៍លើការនាំចេញ *: ចែងថា ត្រូវធ្វើការនាំចេញនូវសមាមាត្រផលិតផលមួយចំនួន។*

តំរូវការលើការដាក់ទាណត្ថិផលិតផល *: កំណត់កាតព្វកិច្ចអោយវិនិយោគិនផ្គត់ផ្គង់ទីផ្សារមួយចំនួន នូវផលិតផលដែលបានកំណត់ និងផលិតផលដែលបានផលិតពីរោងចក្រ ឬ ពីកិច្ចដំណើរការដែលបានកំណត់ ។*

ដែនកំណត់នៃកាមន្តសាលកម្ម *: រារាំងក្រុមហ៊ុនមួយចំនួនមិនអោយផលិតទំនិញ ឬ ខ្សែផលិតផលជាក់លាក់ណាមួយនៅក្នុងសាមីប្រទេស ។*

តំរូវការផ្ទេរបច្ចេកវិទ្យា *: តំរូវអោយមានការផ្ទេរបច្ចេកវិទ្យាជាក់លាក់ស្ថិតិលក្ខខ័ណ្ឌក្រៅពាណិជ្ជកម្ម និង/ឬ កំរិតជាក់លាក់និងប្រភេទនៃការស្រាវជ្រាវ និងការអភិវឌ្ឍន៍ (R&D) ដែលនឹងត្រូវអនុវត្តក្នុងស្រុក ។*

តំរូវការសុំអាជ្ញាប័ណ្ណ *: កំណត់កាតព្វកិច្ចអោយវិនិយោគិន សុំអាជ្ញាប័ណ្ណបច្ចេកវិទ្យាដែលប្រហាក់ប្រហែលគ្នា ឬ ដែលមិនពាក់ព័ន្ធទៅនឹងបច្ចេកវិទ្យាដែលប្រើប្រាស់នៅក្នុងប្រទេសរបស់គេ ទៅអោយក្រុមហ៊ុននៃប្រទេសទទួល ។*

ការដាក់កំហិតលើការផ្ទេរចេញ *: ដាក់កំហិតលើសិទ្ធិរបស់វិនិយោគិន ក្នុងការបញ្ជូនចេញនូវប្រាក់ចំណូលដែលបានមកពីការវិនិយោគទុន ។*

តំរូវការស្មើភាពក្នុងស្រុក *: បញ្ជាក់អោយច្បាស់ថា វិនិយោគិនជាតិ ត្រូវកាន់កាប់ភាគហ៊ុននៃទេព្យសកម្មក្នុងចំនួនជាភាគរយជាក់លាក់ណាមួយ ។*

វិធានការនៃការវិនិយោគពាក់ព័ន្ធនឹងពាណិជ្ជកម្ម ត្រូវបានប្រើប្រាស់ជាសំខាន់ដោយបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ ដើម្បីជំរុញការអភិវឌ្ឍន៍។ ឧទាហរណ៍ កំណើនឧស្សាហកម្មបន្ទាប់បន្សំក្នុងស្រុកកើតមានឡើងតាមរយៈការវាយពន្ធនៃតំរូវការប្រើប្រាស់វត្ថុធាតុ ដើមក្នុងស្រុក និងពង្រីកការនាំចេញតាមតំរូវការ ។ ក្នុងករណីជាច្រើនគេបានរៀបចំ TRIMS សំរាប់ដោះស្រាយការដាក់កំហិតលើអាជីវកម្មរបស់ក្រុមហ៊ុនសាជីវកម្មអន្តរកាល និងឥរិយាបទប្រឆាំងភាពប្រកួតប្រជែង ។

គាការអង្កេតនាពេលថ្មីៗ បានបង្ហាញអោយឃើញពីការផ្តោតអារម្មណ៍ទៅលើឧស្សាហកម្មជាក់លាក់ដូចជា ឧស្សាហកម្មផលិត យានយន្ត ឧស្សាហកម្មគីមី និងផលិតផលគីមី កុំព្យូទ័រ និងពត៌មានវិទ្យា។ តំរូវការវិនិយោគទុនប្រើប្រាស់វត្ថុធាតុដើមក្នុងស្រុកមានច្រើនលើសលប់ជាងតំរូវការវិនិយោគ សំរាប់នាំចេញនៅក្នុងឧស្សាហកម្មយានយន្ត តែមានតិចជាងក្នុងឧស្សាហកម្មផលិតកុំព្យូទ័រ/ពត៌មានវិទ្យា ។

ទាំងតំរូវការក្នុងការវិនិយោគសំរាប់នាំចេញ និងការវិនិយោគដែលប្រើប្រាស់វត្ថុធាតុដើមក្នុងស្រុកមានច្រើនលើសលប់នៅក្នុងឧស្សាហកម្ម និងផលិតប្រេងឥន្ធនៈគីមី ។

កិច្ចព្រមព្រៀងស្តីពីវិធានការវិនិយោគពាក់ព័ន្ធនឹងពាណិជ្ជកម្ម

កិច្ចព្រមព្រៀងស្តីពី វិធានការវិនិយោគពាក់ព័ន្ធនឹងពាណិជ្ជកម្ម (TRIMS) មាត្រា២

កិច្ចព្រមព្រៀង TRIMS ដែលបានចរចានៅយូរ៉ូហ្គាយ បានហាមឃាត់ប្រទេសមួយចំនួនពីការប្រើប្រាស់ TRIMS ចំនួន៥ ពីបញ្ជីក្នុងវគ្គ ៣១ ។ TRIMS ទាំង៥នោះ ត្រូវបានចាត់ទុកថាមិនស្របទៅវិធាន GATT ស្តីពីប្រព្រឹត្តិកម្មជាតិ និងមិនស្របទៅនឹងវិធានប្រឆាំងនឹងការដាក់កំហិតលើបរិមាណ ។

TRIMS បានហាមឃាត់ដោយផ្អែកទៅលើមូលដ្ឋានថា បានផ្តល់ប្រព្រឹត្តិកម្មជាតិ ដែលមានភាពអនុគ្រោះច្រើនចំពោះផលិតផលក្នុងស្រុក បើប្រៀបធៀបនឹងផលិតផលនាំចូល ។

ដូច្នេះធ្វើអោយប៉ះពាល់ដល់គោលការណ៍ប្រព្រឹត្តិកម្មជាតិ រួមមានទាំងគោលការណ៍ដែលតំរូវអោយ ÷

- ☐ ទិញ ឬ ប្រើប្រាស់ដោយសហគ្រាសណាមួយ នូវផលិតផលដែលមានប្រភពផលិតក្នុងស្រុក ឬមានប្រភពមកពីក្នុងស្រុកណាមួយ (តំរូវការវិនិយោគប្រើប្រាស់វត្ថុធាតុដើមក្នុងស្រុក) ឬ
- ☐ ការទិញ ឬ ការប្រើប្រាស់ផលិតផលដែលបាននាំចូល របស់សហគ្រាសណាមួយត្រូវបានកំណត់ត្រឹមចំនួនដែលពាក់ព័ន្ធទៅនឹងបរិមាណ ឬ តំលៃនៃផលិតផលក្នុងស្រុក សំរាប់នាំចេញ (តំរូវការសមតុល្យពាណិជ្ជកម្ម)។

កិច្ចព្រមព្រៀង TRIMS មាត្រា ២ ឧបសម្ព័ន្ធ

TRIMS បានចាត់ទុកថា មិនស្របទៅនឹងបទបញ្ញត្តិនៃមាត្រា១១ នៃ GATT តទល់នឹងការដាក់កំហិតលើបរិមាណនាំចូល និងនាំចេញរួមទាំង ÷

- ☐ ការដាក់កំហិតលើការនាំចូលត្រឹមចំនួនដែលពាក់ព័ន្ធទៅនឹងបរិមាណ ឬតំលៃផលិតផលដែលត្រូវនាំចេញ (ដូចជាតំរូវការសមតុល្យពាណិជ្ជកម្ម ដែលបង្កើតបានជាការដាក់កំហិតលើការនាំចូល)។
- ☐ ការដាក់កំហិតលើការទទួលបាននូវរូបិយប័ណ្ណបរទេសត្រឹមចំនួនរូបិយប័ណ្ណបរទេស ដែលបានដាក់ចូលទៅក្នុងសហគ្រាស (ឧទាហរណ៍ ការដាក់កំហិតលើរូបិយប័ណ្ណបរទេសបណ្តាលអោយមានការដាក់កំហិតលើការនាំចូល)។
- ☐ កំណត់ការនាំចេញ ក្នុងន័យនៃបរិមាណ និងតំលៃផលិតផលក្នុងស្រុក (ឧទាហរណ៍ តំរូវនៃការលក់ផលិតផលក្នុងស្រុកពាក់ព័ន្ធទៅនឹងការដាក់កំហិតលើការនាំចេញ)

កិច្ចព្រមព្រៀងចែងពីរយៈពេលអន្តរកាលសំរាប់លុបបំបាត់ TRIMS ដែលបានហាមឃាត់ ។ សំរាប់ប្រទេសជឿនលឿន រយៈពេលអន្តរកាលមាន២ឆ្នាំ ចាប់ពីឆ្នាំ ១៩៩៥ គឺចាប់ពីពេលដែលកិច្ចព្រមព្រៀងចូលជាធរមាន ។ ដូចនេះរយៈពេលនេះហួសកាលកំណត់ទៅហើយ ។ ប្រទេសកំពុងអភិវឌ្ឍន៍មានរយៈពេលអន្តរកាលឡើងដល់៥ឆ្នាំ (ឧទាហរណ៍ រហូតដល់ថ្ងៃទី ១ ខែមករា ឆ្នាំ ២០០០)

ឯប្រទេសក្រីក្រឡើងដល់ ៧ឆ្នាំ (រហូតដល់ថ្ងៃទី ១ ខែមករា ឆ្នាំ ២០០២)។ ក៏ប៉ុន្តែគួរកត់សំគាល់ថារយៈពេលអន្តរកាលនេះមានសំរាប់តែបទបញ្ញត្តិនៃ TRIMS ដែលគេបានហាមឃាត់ ហើយបានជូនដំណឹងថា ពេលណាកិច្ចព្រមព្រៀងអាចដំណើរការបាន។

ការពាក់ព័ន្ធផ្នែកពាណិជ្ជកម្ម

ចំពោះអាជីវករ ជាសំខាន់ត្រូវកត់សំគាល់ថា វិសាលភាពនៃកិច្ចព្រមព្រៀងមានកំរិត ។ កិច្ចព្រមព្រៀងបញ្ជាក់ថាមាន TRIMS ចំនួន ៥ ដែលមិនស្របទៅនឹងGATT ហើយផ្តល់រយៈពេលអន្តរកាលសំរាប់បំបាត់ចោលបទបញ្ញត្តិដែលមិនស្របនោះ។ កិច្ចព្រមព្រៀងមិនបានរារាំង មិនអោយប្រទេសនានាប្រើប្រាស់TRIMS ណាមួយយ៉ាងតិច ដែលមានរាយនាមនៅក្នុងវណ្ណ ៣១ទេ ។ ឧទាហរណ៍មិនមានការរារាំងមិនអោយប្រទេសនានាកំណត់ពន្ធលើតំរូវការនៃការនាំចេញជាល័ក្ខខ័ណ្ឌសំរាប់វិនិយោគឡើយ ។ មិនមានការរារាំងប្រទេសនានា មិនអោយទាមទារថា ការកាន់កាប់ភាគរយនៃភាគហ៊ុនណាមួយដោយវិនិយោគិនជាតិ ឬ វិនិយោគិនបរទេស ឬទាមទារថា ត្រូវនាំមកនូវបច្ចេកវិទ្យាទាន់សម័យបំផុត ឬ ត្រូវរៀបចំកំរិតជាក់លាក់ ឬ ប្រទេសនៃ R&D ក្នុងស្រុកទេ ។

បច្ចុប្បន្នប្រទេសកំពុងអភិវឌ្ឍន៍មួយចំនួន កំណត់អោយការវិនិយោគត្រូវប្រើប្រាស់វត្ថុធាតុដើមក្នុងស្រុក ។ ការលប់បំបាត់តំរូវការនេះអាចមានផលប៉ះពាល់ទៅលើឧស្សាហកម្មបន្ទាប់បន្សំ ដែលបានទទួលផលប្រយោជន៍ពីការការពារដែលគេផ្តល់អោយ ។ តែទោះជាយ៉ាងណាក៏ដោយ ប្រទេសទាំងនេះភាគច្រើនកំពុងពិនិត្យមើលឡើងវិញនូវតំរូវការដើម្បីរក្សាជាបន្តទៀតនូវវិធានការអាស្រ័យដោយគោលនយោបាយពាណិជ្ជកម្មបើកចំហ ដែលបច្ចុប្បន្នកំពុងអនុវត្តតាម និងដំណាក់កាលដែលគេប្រកាន់ឡើង ដើម្បីទាក់ទាញការវិនិយោគបរទេស ។ ឧទាហរណ៍ប្រទេសអាហ្សង់ទីន ប្រេស៊ីល ឥណ្ឌា និងម៉ិចស៊ិក បានធ្វើសេចក្តីសំរេចលុបចោលតំរូវការវិនិយោគដោយប្រើប្រាស់វត្ថុធាតុដើមក្នុងស្រុក មុនពេលចេញសេចក្តីសន្និដ្ឋានរបស់ឃ្យូរ៉ុយហ្គាយទៅទៀត។ ដូច្នេះកិច្ចព្រមព្រៀងបានដាក់អោយអនុវត្តឡើងវិញ តែនិន្នាការឆ្ពោះទៅរកការលប់បំបាត់ចោល TRIMS ដែលបានចាត់ទុកថាមានបទបញ្ញត្តិផ្ទុយពី GATT ។

វិសាលភាពមានកំណត់របស់កិច្ចព្រមព្រៀង TRIMS បានកំនត់អោយប្រទេសនានា ធ្វើការពិនិត្យឡើងវិញលើកិច្ចដំណើរការនៃកិច្ចព្រមព្រៀងក្នុងរយៈពេល ៥ឆ្នាំ ចាប់ពីកិច្ចព្រមព្រៀងចូលជាធរមាន (មុនថ្ងៃទី ១ ខែមករា ឆ្នាំ២០០០) ហើយការពិនិត្យមើលឡើងវិញត្រូវចាត់ទុកមានតំលៃទាក់ទាញបន្ថែម លើកិច្ចព្រមព្រៀងជាមួយបណ្តាបទបញ្ញត្តិដែលចែងពីការវិនិយោគ និងគោលនយោបាយប្រកួតប្រជែង ។

ដើម្បីអនុលោមទៅតាមសេចក្តីសំរេចដែលបានធ្វើឡើងនាសន្និសីទថ្នាក់រដ្ឋមន្ត្រីនាប្រទេសសិង្ហបុរី នៅក្នុងបរិបទនេះ សំខាន់ត្រូវកត់សំគាល់ថា ការពិភាក្សាលំអិតដែលបច្ចុប្បន្នកំពុងធ្វើឡើងនេះ គឺការពិភាក្សានៅក្នុង WTO អំពីទំនាក់ទំនងពាណិជ្ជកម្មជាមួយនឹងការវិនិយោគទុនជារឿងម្យ៉ាង និងម្យ៉ាងទៀតជាមួយនឹងគោលនយោបាយប្រកួតប្រជែង ជាពិសេសឥរិយាបទប្រឆាំងនឹងការប្រកួតប្រជែងរបស់សហគ្រាសពាណិជ្ជកម្ម (សូមមេត្តាអានជំពូក ២២ និង ២៣ ដែលនឹងមានចែងលំអិតពីបញ្ហានេះ) ។ លទ្ធផលនៃកិច្ចពិភាក្សានឹងដាក់សម្ពាធទៅលើស្ថានភាពរបស់បណ្តាប្រទេសនានាដែលបានចូលរួមនៅក្នុងកិច្ចពិភាក្សាស្តីពីតំលៃនៃការបំពេញបន្ថែមកិច្ចព្រមព្រៀងស្តីពី TRIMs តាមបណ្តាបទបញ្ញត្តិដែលទាក់ទងទៅនឹងការវិនិយោគ និងគោលនយោបាយប្រកួតប្រជែង ។

ជំពូក ១៨

កិច្ចព្រមព្រៀងស្តីពីវាយនភ័ណ្ឌ និងសំលៀកបំពាក់

សេចក្តីសង្ខេប

កិច្ចព្រមព្រៀងស្តីពីវាយនភ័ណ្ឌ និងសំលៀកបំពាក់ (ATC) មានបំណងជាមូលដ្ឋាន គឺធានាលប់ចោលការដាក់កំហិត ដែលបច្ចុប្បន្ន ប្រទេសជឿនលឿនមួយចំនួន កំពុងអនុវត្តទៅលើការនាំចូលផលិតផលវាយនភ័ណ្ឌ និងសំលៀកបំពាក់ ។ ដើម្បីបញ្ចប់ការដាក់កំហិត កិច្ចព្រមព្រៀងនេះបានកំណត់នូវនីតិវិធីសំរាប់ធ្វើសមាហរណកម្មទាំងស្រុង នូវពាណិជ្ជកម្មលើផលិតផល វាយនភ័ណ្ឌ និងសំលៀកបំពាក់ ទៅក្នុងប្រព័ន្ធ GATT ដោយតំរូវអោយប្រទេសនានាលប់ចោលការដាក់កំហិតលើបរិមាណជា ៤ ដំណាក់កាល ក្នុងរយៈពេល ១០ ឆ្នាំ ហើយត្រូវបញ្ចប់នាថ្ងៃទី ១ ខែ មករា ឆ្នាំ ២០០៥ ។ តែទោះជាយ៉ាងណាក៏ដោយ នៅមានភាព ដែលអាចបត់បែនបាន តាមនីតិវិធីសមាហរណកម្មនេះ ដើម្បីផ្តល់លទ្ធភាពអោយប្រទេសនានាលប់ចោលការដាក់កំហិត លើបរិមាណ ចេញក្នុងដំណាក់កាល ពីរដំបូង តែលើផលិតផលមួយចំនួនប៉ុណ្ណោះ ។ ដូច្នេះ យើងអាចរំពឹងថា ផលប៉ះពាល់ជាសំខាន់នៃកម្មវិធីសមាហរណកម្មនេះ កើតមានតែនៅពេលធ្វើសមាហរណកម្មដំណាក់កាលទីបីប៉ុណ្ណោះ (នាថ្ងៃទី ១ ខែ មករា ឆ្នាំ ២០០២) ហើយការលប់ចោល ទាំងស្រុងនូវការកំហិតលើបរិមាណនឹងធ្វើឡើងនៅដំណាក់កាលចុងក្រោយ គឺនៅពេលបញ្ចប់ដំណាក់កាលអន្តរកាល និងនៅពេល កិច្ចព្រមព្រៀងផុតកំណត់ ។

ឧស្សាហកម្មវាយនភ័ណ្ឌ និងកាត់ដេរសំលៀកបំពាក់ ជាឧស្សាហកម្មដ៏សំខាន់មួយរបស់បណ្តាប្រទេសកំពុងអភិវឌ្ឍន៍មួយចំនួនធំ។ ក៏ប៉ុន្តែការធ្វើពាណិជ្ជកម្មលើផលិតផលវាយនភ័ណ្ឌ និងសំលៀកបំពាក់នៅលើលោកនេះ ត្រូវស្ថិតនៅក្រោមចន្លោះនៃការដាក់កំហិតតាមកិច្ចព្រមព្រៀង ក្នុងរយៈពេលបីទស្សវត្សកន្លងមកនេះ ។ ផលិតផលមួយចំនួន ត្រូវគ្របដណ្តប់ដោយកូតាដែលអាចបង្កើនបានពីវាយនភ័ណ្ឌសំឡីកប្បាសតាមកិច្ចព្រមព្រៀងរយៈពេលយូរអង្វែង និងរយៈពេលខ្លីនៃទស្សវត្សឆ្នាំ ៦០ និងដើមទស្សវត្សឆ្នាំ ៧០ ឈានទៅរកផលិតផលវាយនភ័ណ្ឌដែលផលិតផលពីសំឡីធម្មជាតិ និងសិប្បនិមិត្ត តាមការពន្យាកិច្ចព្រមព្រៀងពហុភាគីស្តីពីសំឡីកប្បាស (MFA) សំរាប់រយៈពេលពីឆ្នាំ ១៩៧៤-១៩៩៤ ។

នៅចុងឆ្នាំ ១៩៩៤ នៅពេលបញ្ចប់កិច្ចព្រមព្រៀង MFA កិច្ចព្រមព្រៀងនេះមានមានសមាជិកចំនួន ៣៩ ប្រទេស ។ ក្នុងចំណោមនោះមានប្រទេសចំនួន ៨ ជាប្រទេសជឿនលឿន ហើយបានកំណត់ក្រៅផ្លូវការថា ជាប្រទេសនាំចូល ចំណែកប្រទេស ៣១ ទៀត ជាប្រទេសកំពុងអភិវឌ្ឍន៍ ត្រូវបានចាត់ទុកថាជាប្រទេសនាំចេញ ។ MFA អនុញ្ញាតិអោយប្រទេសនាំចេញ និង ប្រទេសនាំចូលចុះកិច្ចព្រមព្រៀងទ្វេភាគី ដោយតំរូវអោយប្រទេសនាំចេញដាក់កំហិតលើការនាំចូលនូវផលិតផលវាយនភ័ណ្ឌ និង សំលៀកបំពាក់មួយចំនួន ។ ក្នុងការចុះកិច្ចសន្យា លើកិច្ចព្រមព្រៀងទ្វេភាគី បណ្តាប្រទេសមួយចំនួនត្រូវតែគោរពតាមដាច់ខាត នូវវិធាន MFA របស់នេះ ÷

- ☐ ដើម្បីកំណត់ការខូចខាត ឬ ការគំរាមកំហែងធ្ងន់ធ្ងរដែលកើតមានពីកិច្ចព្រមព្រៀងនោះ ។
- ☐ ដើម្បីកំណត់នូវកំរិតនៃការដាក់កំហិត និង
- ☐ ដើម្បីដាក់បញ្ចូលបទបញ្ញត្តិទាំងនោះ ជាអត្រាកំណើនប្រចាំឆ្នាំ អនុវត្តបន្តទៀតនូវកូតាដែលមិនបានប្រើប្រាស់ពីឆ្នាំកន្លងមក និងផ្តល់ផ្នែកណាមួយនៃកូតាបច្ចុប្បន្ន សំរាប់ជាការប្រើប្រាស់ដល់ឆ្នាំបន្ទាប់ទៀត ។

បន្ទាប់ពីបានចរចាអំពីកិច្ចព្រមព្រៀងវាយនភ័ណ្ឌ និងសំលៀកបំពាក់នៅឃ្យូរ៉ូយហ្គាយមក កិច្ចព្រមព្រៀងនេះបានចាប់ដំណើរការនៅថ្ងៃទី ១ ខែ មករា ឆ្នាំ ១៩៩៥ ហើយប្រទេសនាំចូលមួយចំនួន (រួមមានសហរដ្ឋអាមេរិក កាណាដា សហគមន៍អឺរ៉ុប (ដែលមានសមាជិក ១៥ ប្រទេស និងប្រទេសណ័រវេស) មានកិច្ចព្រមព្រៀងដែលបានដាក់កំហិតសរុបចំនួន ៨១ ជាមួយបណ្តា ប្រទេសនានាជាសមាជិកនៃអង្គការ WTO ដែលក្នុងនោះប្រទេសនីមួយៗ មានជាងរាប់ពាន់កូតា ។ ក្រៅពីនេះ នៅមានកិច្ចព្រមព្រៀងមិនមែន MFA ចំនួន ២៩ ទៀត ឬ វិធានការជាឯកត្តោភាគីដែលកំណត់នូវការដាក់កំហិតលើបរិមាណលើការនាំចូលផលិតផលវាយនភ័ណ្ឌ ។

ការធ្វើសមាហរណកម្មពាណិជ្ជកម្មវាយនភ័ណ្ឌនៅក្នុងកិច្ចព្រមព្រៀងទូទៅអំពីពាណិជ្ជកម្ម និងពន្ធគយ

តាមទស្សនៈច្បាប់ដ៏តឹងរឹងបង្ហាញអោយឃើញថា ការរក្សាទុកនូវការដាក់កំហិតលើបរិមាណនេះ មិនស្របទៅតាមកិច្ចព្រមព្រៀង GATT ទេ ។ តែទោះជាយ៉ាងណាក៏ដោយ ក៏កិច្ចព្រមព្រៀងអំពីការរៀបចំពហុសសៃអំបោះ (ដែលបានចរចា ក្នុងក្របខ័ណ្ឌនៃគំរោង GATT) បានថែងពីការការពារតាមផ្លូវច្បាប់ ដោយការធ្វើបដិប្បញ្ញត្តិចំពោះការដាក់ទណ្ឌកម្មនៃកិច្ចព្រមព្រៀង GATT ដែរ ។ គោលបំណងសំខាន់នៃកិច្ចព្រមព្រៀងស្តីពីវាយនភ័ណ្ឌ និងសំលៀកបំពាក់ ដែលបន្តអនុវត្តដាក់កំហិតលើកូតាពី MFA គឺការធ្វើសមាហរណ៍កម្មពាណិជ្ជកម្មវាយនភ័ណ្ឌ និងសំលៀកបំពាក់ទៅក្នុង GATT និងការដាក់ទណ្ឌកម្ម ដោយតម្រូវអោយប្រទេសទាំងឡាយដែលបានដាក់កំហិតលើបរិមាណ ត្រូវលប់ចោលការដាក់កំហិតនេះក្នុងរយៈពេល ១០ឆ្នាំ ។ បន្ទាប់ពីផុតកំណត់រយៈពេល ១០ឆ្នាំ គឺចាប់ពីថ្ងៃទី ១ ខែ មករា ឆ្នាំ ២០០៥ ទៅប្រទេសជាសមាជិកមួយចំនួនមិនអាចដាក់កំហិតទៅលើបរិមាណនៃការនាំចូលផលិតផលវាយនភ័ណ្ឌបានទៀតទេ លុះត្រាតែអាចផ្តល់មូលហេតុបញ្ជាក់ត្រឹមត្រូវ ស្របតាមបទបញ្ញត្តិនៃមាត្រា ១៤ នៃ GATT ដូចដែលបានបកស្រាយដោយកិច្ចព្រមព្រៀងស្តីពីវិធានការការពាររបស់ WTO។ ម្យ៉ាងវិញទៀត ប្រទេសនាំចូលជាច្រើន អាចដាក់កំហិតបាន បន្ទាប់ពីមានការស៊ើបអង្កេត ដោយផ្តល់លទ្ធផលបញ្ជាក់ថា ការនាំចូលដែលកើនឡើងនោះ ពិតជាបង្កផលប៉ះពាល់ ឬ គំរាមកំហែងបង្កផលប៉ះពាល់ធ្ងន់ធ្ងរទៅលើឧស្សាហកម្មវាយនភ័ណ្ឌក្នុងស្រុក ។ ម្យ៉ាងវិញទៀត ការដាក់កំហិតនេះ ត្រូវអនុវត្តទៅលើការនាំចូលពីគ្រប់ប្រភពទាំងអស់ ដោយមិនរើសអើងលើការនាំចូលពីប្រទេសមួយ ឬ ពីរ ដូចករណីនៃការដាក់កំហិតតាម MFA និងដែលបច្ចុប្បន្នមានតាម ATC នោះទេ ។

វិធីសាស្រ្តនៃការធ្វើសមាហរណកម្ម

កិច្ចព្រមព្រៀងស្តីពីវាយនភ័ណ្ឌ និងសំលៀកបំពាក់ មាត្រា ១: ឧបសម្ព័ន្ធ

វិធីសាស្រ្តជាមូលដ្ឋានសំរាប់ធ្វើសមាហរណ៍កម្មពាណិជ្ជកម្មវាយនភ័ណ្ឌ និងសំលៀកបំពាក់ ទៅក្នុង GATT គឺជាតារាងនៃផលិតផលវាយនភ័ណ្ឌដែលរួមមាននៅក្នុងឧបសម្ព័ន្ធនៃ ATC ។ តារាងនេះមានវិសាលភាពគ្របដណ្តប់លើផលិតផលវាយនភ័ណ្ឌទាំងអស់ រួមមាន អំបោះ និងក្រណាត់ ផលិតផលផលិតពីវាយនភ័ណ្ឌ និងសំលៀកបំពាក់ ទោះជាស្ថិតនៅក្រោមការដាក់កំហិត ឬ អត់ក៏ដោយ ។ កិច្ចដំណើរការសមាហរណកម្មត្រូវបានអនុវត្តឡើងជាបួនដំណាក់កាល។ នៅដំណាក់កាលនីមួយៗ ផលិតផលដែលមានចំនួនឡើងដល់ភាគរយអប្បបរិមាណាមួយនៃបរិមាណនាំចូលរបស់ប្រទេស ក្នុងឆ្នាំ ១៩៩៦ ត្រូវបានគេដាក់បញ្ចូលនៅក្នុងកិច្ចដំណើរការសមាហរណកម្ម ដែលកំពុងត្រូវផ្លាស់ប្តូរចេញពីទស្សនៈនៃ ATC ឆ្ពោះទៅរកទស្សនៈនៃវិធានទូទៅរបស់ WTO ។ ចំនួនភាគរយទាំងនេះ គឺ ÷

(កិច្ចព្រមព្រៀងស្តីពីវាយនភ័ណ្ឌ និងសំលៀកបំពាក់ មាត្រា ២:៦ និង មាត្រា ២:៨)

- ☐ ១៦%នៃបរិមាណនាំចូលផលិតផលរបស់ប្រទេសលើតារាង នាកាលបរិច្ឆេទដែលកិច្ចព្រមព្រៀងនេះចូលជាធរមាន (ថ្ងៃទី ១ ខែមករា ១៩៩៥)
- ☐ ១៧% ទៀត នៅដំណាច់ឆ្នាំទី ៣ (ថ្ងៃទី ១ ខែមករា ១៩៩៨)
- ☐ ១៨% ទៀត នៅដំណាច់ឆ្នាំទី ៧ (ថ្ងៃទី ១ ខែមករា ២០០២)
- ☐ សមតុល្យ ដែលមានដល់ ៤៩% បានបញ្ចប់នៅដំណាច់ឆ្នាំទី ១០ (ថ្ងៃទី ១ ខែមករា ២០០៥)

ដើម្បីសំរេចថា តើផលិតផលមួយណា ដែលត្រូវដាក់បញ្ចូលទៅក្នុងដំណើរការសមាហរណកម្មនោះ ប្រទេសទាំងឡាយមិនមាន

កាតព្វកិច្ចកំណត់ខ្លួនឯងថា ផលិតផលណាដែលត្រូវស្ថិតនៅក្រោមការដាក់កំហិតឡើយ ។ ជាការពិតណាស់ បណ្តាប្រទេសនានាបានចាប់ផ្តើមពីផលិតផលដែលមិនសូវមានវេទយិតភាព និងរួមបញ្ចូលទាំងផលិតផលមួយចំនួនតូច ដែលមានកូតា ។ ល័ក្ខខ័ណ្ឌតែមួយគត់ដែលកិច្ចព្រមព្រៀងអាចកំណត់បាន គឺបញ្ជីសមាហរណកម្មត្រូវមានផលិតផលពីវិស័យចំនួនបួន គឺ tops និងអំបោះផលិតផលផលិតពីវាយនភ័ណ្ឌ និងសំលៀកបំពាក់ ។

បទពិសោធន៏នៃការអនុវត្តន៏កិច្ចដំណើរការសមាហរណកម្ម

ភាគរយនៃការនាំចូលផលិតផលមិនស្ថិតនៅក្រោមការដាក់កំហិតក្នុងឆ្នាំ ១៩៩០ របស់សហរដ្ឋអាមេរិក (ជាឆ្នាំមូលដ្ឋានដែលប្រើប្រាស់សំរាប់ធ្វើសមាហរណកម្ម) មានប្រហែលជា ៣៤% ឯសហគមន៏អឺរ៉ុបមានប្រហែល ៣៧% ។ សំរាប់ប្រទេសផ្សេងទៀតដែលរក្សាការដាក់កំហិត នោះចំនួនភាគរយមានខ្ពស់ជាង ។ ជាទូទៅ នៅកំរិតជាតិ គេអាចមានលទ្ធភាពគ្រប់គ្រងអោយប្រទេសទាំងនេះបំពេញតាមកាតព្វកិច្ចរបស់គេ ដើម្បីធ្វើសមាហរណកម្មផលិតផលនៅក្នុង ២ ដំណាក់ដំបូង ដោយមិនចាំបាច់លប់ចោលល័ក្ខខ័ណ្ឌនៃការដាក់កំហិតច្រើនឡើយ ។

តាមពិតទៅ អ្វីដែលបានរៀបរាប់ខាងលើកើតមាននៅក្នុងដំណាក់កាល ២ ដំបូង ។ ប្រទេសជាសមាជិកដែលជាប្រទេសត្រួតពិនិត្យសំខាន់ៗ មានបី គឺ សហរដ្ឋអាមេរិក សហគមន៏អឺរ៉ុប និងប្រទេសកាណាដា កន្លងមកមានលទ្ធភាពបំពេញការធ្វើសមាហរណកម្មតាមកំរិតភាគរយដែលត្រូវ (១៦% នៅដំណាក់កាលទី១ និង ១៧% នៅដំណាក់កាលទី២) ដោយការធ្វើសមាហរណកម្មផលិតផលដែលពាក់ព័ន្ធនឹងសមាមាត្រនៃការដាក់កំហិតលើកូតាតូចមួយ ។

ដូច្នេះ ជាទូទៅគេរំពឹងថា ផលប៉ះពាល់សំខាន់ៗ ពីកម្មវិធីសមាហរណ័កម្មដំបូង កើតមានឡើងតែនៅពេលធ្វើសមាហរណកម្មក្នុងដំណាក់កាលទីបី តែប៉ុណ្ណោះ (នាថ្ងៃទី ១ ខែ មករា ឆ្នាំ ២០០២) និងនៅពេលដែលការដាក់កំហិតត្រូវបានលប់ចោលទាំងស្រុងនាថ្ងៃទី ១ ខែ មករា ឆ្នាំ ២០០៥ ដែលជាពេលផុតកំណត់នៃកិច្ចដំណើរការអន្តរកាល និង ATC ។

ការជំរុញពង្រីកកូតា

កិច្ចព្រមព្រៀងស្តីពីវាយនភ័ណ្ឌ និងសំលៀកបំពាក់ មាត្រា ២:១៣ និង ២:១៤

ទោះជាយ៉ាងណាក៏ដោយ ក៏កិច្ចព្រមព្រៀងព្យាយាមបើកទីផ្សារអោយបានទូលាយ និងមានលក្ខណៈល្អប្រសើរឡើងសំរាប់ផលិតផលវាយនភ័ណ្ឌ និងសំលៀកបំពាក់ដែលបន្តស្ថិតនៅក្រោមការដាក់កំហិតក្នុងរយៈពេលអន្តរកាលនេះ ។ ទង្វើនេះអាចធ្វើបាន ដោយតំរូវអោយបង្កើនអត្រាកូតាប្រចាំឆ្នាំនៅដំណាក់កាលនីមួយៗ ក្នុងរយៈពេលអន្តរកាល ។ ដូច្នេះ ប្រសិនបើកំណើនអត្រាកូតាប្រចាំឆ្នាំមានថេរ ៣ ភាគរយក្នុងមួយឆ្នាំ (ឧទាហរណ៍ កូតាសំរាប់អាវយឺត) តាមកិច្ចព្រមព្រៀងទ្វេភាគី នោះការបង្កើនកូតានឹងមានលទ្ធផលដូចខាងក្រោម ÷

- ☐ ១៦% ក្នុងមួយឆ្នាំសំរាប់ឆ្នាំនីមួយៗ នៃរយៈពេល ៣ ឆ្នាំដំបូង (៣%x១.១៦=៣.៤៨%)
- ☐ -២៥% ក្នុងមួយឆ្នាំសំរាប់ឆ្នាំនីមួយៗ នៃរយៈពេល ៤ ឆ្នាំបន្ទាប់ (៣.៤៨%x១.២៥= ៤.៣៥%)
- ☐ -២៧% ក្នុងមួយឆ្នាំសំរាប់ឆ្នាំនីមួយៗ នៃរយៈពេល ៣ ឆ្នាំបន្ទាប់ (៤.៣៥%x១.២៦=៥.៥២%)

ធ្វើដូច្នេះ អត្រាកំណើននឹងកើនឡើងពី ៣% ទៅ ៥.៥២% ក្នុងរយៈពេល ៨ឆ្នាំ។ ប្រសិនបើបរិមាណកូតាមាន ១០០តោននៅពេលចាប់ផ្តើមរយៈពេលអន្តរកាល នោះបរិមាណនេះនឹងកើនឡើងច្រើនជាងពីរដង គឺប្រហែល២០៤តោននៅក្នុងរយៈពេល ១០ ឆ្នាំក្រោយ ។

កិច្ចព្រមព្រៀងស្តីពីវាយនភ័ណ្ឌនិងសំលៀកបំពាក់ មាត្រា ២:១៨

ATC បានចែងបន្ថែមទៀតថា បណ្តាប្រទេសផ្គត់ផ្គង់តូចតាច (ដូចជាប្រទេសដែលមានការដាក់កំហិតស្មើនឹង ១.២ភាគរយ ឬតិចជាងបរិមាណសរុបនៃការដាក់កំហិតរបស់ប្រទេសនាំចូល) និងប្រទេសក្រីក្រ ត្រូវទទួលបាននូវ " អត្ថប្រយោជន៏តាមអត្រានៃការកើនឡើងមួយដំណាក់កាល " ។

ការអនុវត្តន៍បទបញ្ញត្តិ

ប្រទេសដែលដាក់កំហិត ជាទូទៅបានគោរពទៅតាមបទបញ្ញត្តិស្តីពីកត្តាកំណើនជាក់ស្តែង ។ ក៏ប៉ុន្តែ ដរាបណាប្រទេសបានទទួលផលប្រយោជន៍ពីការអនុវត្តន៍អត្រាកំណើនដែលបានជំរុញ ត្រូវពឹងផ្អែកទៅលើអត្រាកំណើនដំបូង ដែលបានផ្តល់អោយតាមកិច្ចព្រមព្រៀងទ្វេភាគី ។ ក្នុងករណីភាគច្រើន អត្រាដំបូងនេះមានចំនួន ៦ ភាគរយ ។ ក្នុងករណីមួយចំនួនតូច អត្រានេះមាន ១ ភាគរយ ឬ ទាបជាងនេះផង ។ កូតាភាគច្រើនដែលបានទទួលពីការផ្តល់អោយតាមអត្រាកំណើនខ្ពស់ ភាគច្រើនមិនបានប្រើប្រាស់អោយបានពេញលេញទេ សំរាប់កូតាបែបនោះ ការអនុវត្តន៍អត្រាកំណើនដែលបានជំរុញ មិនបានផ្តល់លទ្ធផលជាអត្ថប្រយោជន៍ប្រកបដោយខ្លឹមសារ ចំពោះប្រទេសនាំចេញទេ ។

ម្យ៉ាងទៀត ប្រទេសកំពុងអភិវឌ្ឍន៍រំពឹងថា ការបង្កើនកូតា បានបំពេញបន្ថែមលើកិច្ចដំណើរការនៃការធ្វើសមាហរណកម្មផលិតផលវាយនភ័ណ្ឌទៅក្នុង GATT តាមរយៈការដកចេញនូវការដាក់កំហិតនេះ។ នៅក្នុងការត្រួតពិនិត្យឡើងវិញរបស់ពួកគេ ការអនុវត្តន៍អត្រាកើនឡើង និងមិនអាចសំរេចបាននូវសេរីភាវូបនីយកម្មដែលគេរំពឹងទុកបានទេ លើកលែងតែមានការចាត់វិធានការច្បាស់លាស់ ដើម្បីលប់ចោលការដាក់កំហិតទាំងនេះ ។

ការធ្វើសមាហរណកម្មនៃការដាក់កំហិតក្រៅពី MFA

កិច្ចព្រមព្រៀងស្តីពីវាយនភ័ណ្ឌ និងសំលៀកបំពាក់ មាត្រា ៣

ATC តំរូវផងដែរអោយប្រទេសដែលអនុវត្តការដាក់កំហិតលើបរិមាណខុសពី MFA ហើយដែលការដាក់កំហិតបែបនេះ មិនស្របតាមបទបញ្ញត្តិ GATT នោះ ត្រូវលប់ចោលការដាក់កំហិតនេះក្នុងរយៈពេល១០ឆ្នាំ ឬ ធ្វើយ៉ាងណាអោយស្របទៅតាមកិច្ចព្រមព្រៀង GATT ។ កម្មវិធីសំរាប់លប់ចោលបន្តិចម្តង ៗ នូវការដាក់កំហិតនេះ ត្រូវបានរៀបចំឡើងដោយប្រទេសនាំចេញ និង បានបង្ហាញជូនទៅ អង្គភាពតាមដានការងារវាយនភ័ណ្ឌ (TMB) ជាអង្គភាពមួយដែលបានបង្កើតឡើងក្រោមកិច្ចព្រមព្រៀង ដើម្បីត្រួតពិនិត្យមើលកិច្ចប្រតិបត្តិការលប់បំបាត់ការដាក់កំហិតនេះ ។

វិធានការការពារបណ្តោះអាសន្ន ឬ អន្តរកាល

កិច្ចព្រមព្រៀងស្តីពីវាយនភ័ណ្ឌ និងសំលៀកបំពាក់ មាត្រា ៦

គួរកត់សំគាល់ថា ទោះបីកិច្ចព្រមព្រៀងមានបំណងសម្រួលដល់ការលប់ចោលការដាក់កំហិតលើផលិតផលវាយនភ័ណ្ឌក៏ដោយ ក៏កិច្ចព្រមព្រៀងនេះ អនុញ្ញាតអោយប្រទេសនានា ចាត់វិធានការការពារនៅក្នុងរយៈពេលអន្តរកាល តាមវិធានតឹងតែងបំផុត ។ វិធានការការពារបណ្តោះអាសន្ននេះ អាចយកមកអនុវត្តបានតែលើផលិតផលវាយនភ័ណ្ឌ និងសំលៀកបំពាក់ ដែលមិនទាន់ជាកម្មវត្ថុនៃការកំណត់កូតា និងមិនទាន់បានបញ្ចូលទៅក្នុងកិច្ចព្រមព្រៀង GATT ហើយប្រសិនបើប្រទេសនាំចេញអាចកំណត់បានថា ÷

- ☐ ផលិតផលដែលកំពុងនាំចេញ មានបរិមាណកើនឡើង ដែលជាមូលហេតុបង្កការខូចខាតធ្ងន់ធ្ងរ ឬ ការគំរាមកំហែងជាក់ស្តែងទៅលើឧស្សាហកម្មក្នុងស្រុកដែលផលិតផលិតផលដូចគ្នា និង
- ☐ បណ្តាលអោយមូលហេតុផ្សារភ្ជាប់ទៅនឹងការខូចខាតធ្ងន់ធ្ងរចំពោះឧស្សាហកម្មក្នុងស្រុក ហើយការកើនឡើងយ៉ាងរហ័ស និងគួរអោយកត់សំគាល់នៅក្នុងការនាំចូលពីប្រទេសនាំចេញ ឬ ពីប្រទេសណាដែលការនាំចេញរបស់គេមានការត្រួតពិនិត្យ។

សមាជិកទាំងអស់នៃអង្គការ WTO មានសិទ្ធិប្រើប្រាស់វិធានការការពារបណ្តោះអាសន្ន មិនមែនសំរាប់តែប្រទេសដែលកន្លងមកបានអនុវត្តការដាក់កំហិតលើបរិមាណតាម MFA ទេ ប៉ុន្តែសំរាប់បណ្តាប្រទេសផ្សេងទៀត (រួមមានទាំងប្រទេសកំពុងអភិវឌ្ឍន៍ និងប្រទេសក្រីក្រ) ដែលស្ថិតក្រោមល័ក្ខខ័ណ្ឌយ៉ាងតឹងតែងដូចមានរៀបរាប់ខាងក្រោមនេះ ។

កិច្ចព្រមព្រៀងស្តីពីវាយនភ័ណ្ឌ និងសំលៀកបំពាក់ មាត្រា ៦:១

ទីមួយ ដើម្បីមានសិទ្ធិអនុវត្តវិធានការបែបនេះ ប្រទេសទាំងឡាយមានកាតព្វកិច្ចជូនដំណឹងទៅអង្គការ WTO ស្តីពីគោលបំណងរបស់ពួកគេ ដើម្បីសុំនូវសិទ្ធិប្រើប្រាស់បទបញ្ញត្តិទាំងនេះក្នុងរយៈពេលជាក់លាក់ ក្រោយពេលដែល ATC ដំណើរការ ។ អនុលោមទៅតាមបទបញ្ញត្តិទាំងនេះ ប្រទេសចំនួន ៥៥ បានជូនដំណឹងអំពីបំណងរបស់ពួកគេ ដើម្បីសុំសិទ្ធិអនុវត្តវិធានការ ឯប្រទេសចំនួន ៩ ទៀត បានជូនដំណឹងថា ពួកគេមិនចង់បន្តអនុវត្តសិទ្ធិនេះទេ ។

ទីពីរ ប្រទេសដែលបានជូនដំណឹងអំពីបំណងរបស់ពួកគេ ដើម្បីអនុវត្តសិទ្ធិ មានកាតព្វកិច្ចធ្វើសមាហរណកម្មពាណិជ្ជកម្មវាយនភ័ណ្ឌរបស់ពួកគេទៅក្នុងកិច្ចព្រមព្រៀង GATT ជាបួនដំណាក់កាល ដោយអនុលោមទៅតាមនីតិវិធី ដែលអនុវត្តបានទៅលើបណ្តាប្រទេសនានាដែលអនុវត្តការដាក់កំហិតតាម MFA ។

ទីបី ប្រទេសដែលស្នើសុំអនុវត្តវិធានការការពារ ត្រូវតំរូវអោយពិគ្រោះយោបល់ជាតំបូង ជាមួយប្រទេសនាំចេញ ឬ ប្រទេសពាក់ព័ន្ធផ្សេងទៀត ដើម្បីបង្ហាញពីស្ថានភាពនៃការខូចខាតយ៉ាងធ្ងន់ធ្ងរ ឬការគំរាមកំហែងជាក់ស្តែងដែលកើតមានពីការអនុវត្តន៏វិធានការ។

កិច្ចព្រមព្រៀងស្តីពីវាយនភ័ណ្ឌ និងសំលៀកបំពាក់ មាត្រា ៦:៨

ការពិគ្រោះយោបល់ អាចនាំមកនូវការព្រមព្រៀងថា ស្ថានភាពនោះមិនទាមទារអោយដាក់កំហិតលើផលិតផល ដែលកំពុងតែពិភាក្សា ក្នុងករណីដែលកំរិតនៃការដាក់កំហិត និងរយៈពេលនៃការដាក់កំហិតនោះ មានបញ្ជាក់ច្បាស់លាស់នៅក្នុង ATC។ ការដាក់កំហិតអាចអនុវត្តផងដែរ ដោយសមាជិកនៃបណ្តាប្រទេសនាំចេញ បើទោះជាការពិគ្រោះយោបល់មិនទទួលបានជោគជ័យក៏ដោយ ។ ប៉ុន្តែនៅក្នុងករណីនេះ គេត្រូវបញ្ជូនបញ្ហាដែលកើតមាននេះទៅអោយអង្គភាពតាមដានការងារវាយនភ័ណ្ឌ អោយធ្វើការត្រួតពិនិត្យជាបន្ទាន់ និងផ្តល់អនុសាសន៏សមស្រប ។ ជាងនេះទៅទៀត ដើម្បីធានាអោយការដាក់កំហិតដែលបានព្រមព្រៀងនៅក្នុងកិច្ចពិគ្រោះយោបល់ទ្វេភាគី ស្របទៅតាមបទបញ្ញត្តិនៃកិច្ចព្រមព្រៀង ATC នោះត្រូវតំរូវអោយអង្គភាពតាមដានការងារ វាយនភ័ណ្ឌជាអ្នកកំណត់ថាតើការដាក់កំហិតនោះ ស្របទៅតាម ATC ឬទេ ។

បទពិសោធន៍នៃការអនុវត្តន៍បទបញ្ញត្តិ ATC

ដូចបានគូសបញ្ជាក់ពីខាងលើរួចមកហើយថា វិធានការការពារបណ្តោះអាសន្ន (ឬ អន្តរកាល) ត្រូវបានអនុញ្ញាតអោយយកមកប្រើប្រាស់ក្នុងករណីតិចតួច ឬ តែក្នុងករណីលើកលែង នៅពេលដែលឧស្សាហកម្មផលិត ផលិតផលប្រភេទណាមួយ ទទួលរងនូវការខូចខាតធ្ងន់ធ្ងរ ឬ ការគំរាមកំហែងជាក់ស្តែង ដោយសារតែការនាំចូលកើនឡើងនោះ ។ បទបញ្ញត្តិចែងច្បាស់ថា គេអាចចាត់វិធានការបណ្តោះអាសន្នបាន ក្រោយពេលដែលប្រទេសនាំចូលអាចបញ្ជាក់ថា ការបង្កមូលហេតុនោះពាក់ព័ន្ធរវាងការនាំចូលដែលកើនឡើង ទៅនឹងការខូចខាតទៅលើឧស្សាហកម្ម ។ ចំពោះគោលបំណងនេះ កិច្ចព្រមព្រៀង ATC បានកំណត់នូវបំរែបំរួលផ្នែកសេដ្ឋកិច្ចដែលត្រូវត្រួតពិនិត្យ ដើម្បីបញ្ជាក់ថាតើ ពិតជាមានទំនាក់ទំនងដែលបង្កអោយមានមូលហេតុនោះមែនឬអត់ ។ កិច្ចព្រមព្រៀងបានលើកទៀតថា នៅពេលដែលស្ថានភាពឧស្សាហកម្មដែលបានអះអាងនោះ មិនបណ្តាលមកពីការកើនឡើងនៃការនាំចូលទេ ប៉ុន្តែបណ្តាលមកពីកត្តាដូចជា " បំលាស់ប្តូរបច្ចេកវិជ្ជា ឬ បំលាស់ប្តូរបរិមាណអ្នកប្រើប្រាស់ " នោះមិនមានប្រទេសណាមួយអាចអនុវត្តវិធានការការពារបានទេ ។

កិច្ចព្រមព្រៀងស្តីពីវាយនភ័ណ្ឌ និងសំលៀកបំពាក់ មាត្រា ៦:២

នៅពេលកិច្ចព្រមព្រៀងចូលជាធរមាន នោះបទបញ្ញត្តិទាំងនេះ ត្រូវបានយកមកប្រើប្រាស់ដោយប្រទេសចំនួនបី គឺសហរដ្ឋអាមេរិក ប្រេស៊ីល និងកូឡុំប៊ី ។ ក្នុងពេលអនុវត្តកិច្ចព្រមព្រៀងរយៈពេល ៦ ខែដំបូង (ពីខែ មករា ដល់ ខែ មិថុនា 1995) សហរដ្ឋអាមេរិក ជាចុងក្រោយបានអនុវត្តការការពារលើករណី ១៤ យ៉ាង ។ ការត្រួតពិនិត្យបានបង្ហាញថា ការអនុវត្តន៍វិធានការទាំងនេះភាគច្រើន មិនអនុលោមទៅតាមវិធាននៃកិច្ចព្រមព្រៀងទេ ។ រឿងក្តី ២ ដែលបានលើកយកមកដោះស្រាយតាមនីតិវិធីដោះស្រាយវិវាទ គណៈវិនិច្ឆ័យបានសង្កេតឃើញថា សហរដ្ឋអាមេរិកមិនបានត្រួតពិនិត្យរាល់កត្តាទាំងឡាយដែលត្រូវលើកយកមកពិចារណា ដើម្បីកំណត់ថាតើ ការនាំចូលដែលកើនឡើងនោះពិតជាបណ្តាលអោយមានផលប៉ះពាល់ដល់ផលិតករនៃផលិតផលណាមួយមែនឬទេ ។

ពីឆមាសទីពីរ នៃឆ្នាំ ១៩៩៥ មានការកាត់បន្ថយយ៉ាងច្រើនគួរអោយកត់សំគាល់ទៅលើឧប្រាស្រ័យចំពោះបទបញ្ញត្តិទាំងនេះដោយសហរដ្ឋអាមេរិក បានប្រើប្រាស់វិធានការការពារតែបួនលើកប៉ុណ្ណោះចាប់ពីពាក់កណ្តាលឆ្នាំ ១៩៩៥ ដល់១៩៩៨។ នេះប្រហែលជាបណ្តាលមកពីកត្តាពីរយ៉ាងដែលមានឥទ្ធិពលទៅវិញទៅមក ។ នៅក្នុងការស៊ើបអង្កេតអំពីរឿងក្តីទាំងនោះ អង្គភាពតាមដាន

ការងារវាយនភ័ណ្ឌបានសង្កត់ធ្ងន់ថា វិធានស្តីពីការប្រើប្រាស់វិធានការការពារទាំងនេះ គួរអនុវត្តអោយបានតឹងតែងបំផុត ។ ត្រូវយល់អោយច្បាស់ថា ប្រទេសនាំចេញដែលទទួលរងនូវផលប៉ះពាល់អាចប្រើប្រាស់នីតិវិធីដោះស្រាយវិវាទបាន លើកលែងតែវិធានការការពារនោះ ត្រូវបានយកមកអនុវត្តតាមលក្ខណៈត្រឹមត្រូវ និងយុត្តិធម៌ ។

វិធាននៃប្រភពដើមទំនិញ

ដើម្បីគ្រប់គ្រងការបែងចែកកូតារបស់ប្រទេស ឬ តំបន់បាន ជាការចាំបាច់ គឺត្រូវអនុម័តវិធាននៃប្រភពដើមទំនិញ សំរាប់កំណត់ថាតើកូតារបស់ប្រទេសមួយណា ដែលដំណើរការនាំចូលផលិតផលនៅក្នុងប្រទេសផ្សេងៗគ្នានោះ បែងចែកយ៉ាងដូចម្តេច ។ នៅសហរដ្ឋអាមេរិក មុនថ្ងៃទី មួយ ខែ មករា ឆ្នាំ១៩៩៦ ប្រភពដើមទំនិញត្រូវបានចាត់ទុកថាជាប្រទេសណាដែលធ្វើការផ្លាស់ប្តូទំរង់ផលិតផលច្រើនជាងគេ (ក្នុងករណីសំលៀកបំពាក់ គឺមួទៅជាកន្លែងដែលគេកាត់ក្រណាត់) ។ ចាប់ពីកាលបរិច្ឆេទនោះមក វិធាននៃប្រភពដើមទំនិញ បានចែងថា ប្រទេសណាដែលផលិតផលិតផលវាយនភ័ណ្ឌ ឬ សំលៀកបំពាក់ទាំងស្រុង ឬ ផលិត ឬ ផ្គុំ នឹងត្រូវចាត់ទុកជាប្រទេសប្រភពដើម ។ ទោះជាយ៉ាងណាក៏ដោយ ក៏ផលិតផលចំនួន ១៦ប្រភេទ ត្រូវស្ថិតនៅក្នុងការកំណត់ដោយវិធានដោយឡែក។ ដូច្នេះប្រភពដើមនៃវត្ថុដែលផលិតអំបោះ ខ្សែ strips, cordage, rope ឬ cables មិនមែនជាប្រទេសដែលផលិតទំនិញនោះទេ ប៉ុន្តែជាប្រទេសដែលផលិតអំបោះ ។ល។ ទៅវិញ ។ ម្យ៉ាងទៀត ចំពោះប្រភេទផលិតផលដ៏ទៃទៀតដែលមានរាយនាមក្នុងវណ្ឌ ៣២ ប្រភពដើមនៃផលិតផល គឺសំដៅលើប្រទេសដែលផលិតក្រណាត់ ។

ខណ្ឌ ៣២

សហរដ្ឋអាមេរិក: ក្រុមផលិតផលដែលស្ថិតនៅក្រោមវិធាននៃប្រភពដើមពិសេស

Articles of yarn, strip, twine, etc.
(HTS 5609)Labels, badges, emblems
(HTS 5807) Quilted products
(HTS 5811) Baby diapers
(HTS 6209.20.5040) Handkerchiefs
(HTS 6213) Shawls, scarves, etc.
(GTS 6214) Blankets and traveling
rugs (HTS 6301)

Household linen (HTS 6302) Curtains, etc.
(HTS 6303) Bedspreads and furnishings
(HTS 6304) Sacks and bags for packing
(HTS 6306) Dust cloths, mops, etc
(HTS 6307.10) Pillow shells, banners and
other items
(HTS 6307.90) Needlecraft sets
(HTS 6308)Pillows, cushions, etc
(HTS 9404.90)

វិធានថ្មីរបស់សហរដ្ឋអាមេរិក អាចបង្កផលប៉ះពាល់មិនល្អទៅលើការធ្វើពាណិជ្ជកម្មរបស់បណ្តាប្រទេសនាំចេញមួយចំនួន ជាពិសេសចំពោះផលិតផលដែលមានរាយនាមក្នុងវណ្ឌ ៣២ ។ ផលិតផលទាំងនេះភាគច្រើន មានដូចជាក្រណាត់ជ្រលក់ពណ៌ និងបោះពុម្ពផលិតផលភួយសំឡី កំរាលពូក កន្សែងដៃ កន្សែងរុំក ក្រណាត់ជូតធូលី និងប្រដាប់ជុសលាង ខ្នើយ និងស្រោមខ្នើយ គឺជាមុខទំនិញដែលត្រូវនៅក្រោមការដាក់កំហិតសំរាប់ប្រទេសមួយចំនួន ។ ប្រទេសកំពុងអភិវឌ្ឍន៍ខ្លះបាននាំចូលក្រណាត់មកជ្រលក់ពណ៌ និងបោះពុម្ពហើយបន្ទាប់មកនាំផលិតផលដែលបានកែច្នៃទាំងនេះ ចេញបន្តទៀត ។ តាមវិធានថ្មីនេះ ប្រភពដើមនៃទំនិញ នាំចេញទាំងនោះគឺជាប្រទេសដែលផលិតក្រណាត់នោះ ។ស្រដៀងគ្នាដែរ ប្រទេសជាច្រើននាំចូលក្រណាត់សំរាប់កែច្នៃអោយទៅជារបស់ប្រើប្រាស់ក្នុងគេហដ្ឋាន វាំងននបាំងបង្អួច ឬ សំរាប់យកទៅដេរប៉ាក់ ។ ជាថ្មីម្តងទៀត ប្រភពដើមនៃផលិតផលទាំងនេះ គឺជាប្រទេសដែលនាំចូលក្រណាត់ ។

អាចកើតមាននូវបញ្ហាលំបាកដ៏ទៃទៀតសំរាប់ប្រទេសនាំចេញ។ ជាឧទាហរណ៍ ប្រទេសមួយដែលផ្គត់ផ្គង់ក្រណាត់ នឹងជួបបញ្ហាលំបាកក្នុងការសំរេចសំរួលកូតាទំនិញដែលបានដឹកចេញដោយប្រទេសដ៏ទៃ ហើយដកឥណពន្ធដូចជាប្រទេសនៃប្រភពដើម ។ ការស្នើសុំទិដ្ឋាការពីប្រទេសប្រភពដើមទំនិញមួយ អាចជាបុព្វហេតុដែលបង្កអោយមានការលំបាកផ្នែករដ្ឋបាលច្រើនគួរអោយកត់សំគាល់សំរាប់ប្រទេស ឬ តំបន់នាំចេញ ។

បញ្ហាខ្លះក្នុងចំណោមបញ្ហាទាំងនេះ អាចដោះស្រាយបាន តាមរយៈការងារដែលអនុវត្តឡើងនៅក្នុងអង្គការពាណិជ្ជកម្មពិភពលោក ដោយសហការជាមួយអង្គការគយអន្តរជាតិ ក្រោមកិច្ចព្រមព្រៀងស្តីពីវិធាននៃប្រភពដើមទំនិញ វិធានស្របគ្នា ដែលបានអនុម័តឡើងសំរាប់ធ្វើការកំណត់ប្រភពដើមទំនិញ ។ បច្ចុប្បន្ននេះ មិនទាន់មានកិច្ចព្រមព្រៀងពហុភាគីដែលមានប្រសិទ្ធិភាពចងភ្ជាប់ណាមួយដែលបញ្ជាក់ច្បាស់ពីវិធានការដាក់លាក់សំរាប់កំណត់ប្រភពទំនិញឡើយ (សូមអានជំពូក១២) ។

ការបង្កើនសកម្មភាពប្រឆាំងនឹងការលក់បង្ខូចថ្លៃ

បញ្ហាចំបងមួយទៀត គឺការបង្កើនដំណោះស្រាយប្រឆាំងនឹងការលក់បង្ខូចថ្លៃ និងវិធានការប៉ះប៉ូវ ។ វណ្ឌ ៣៣ រាយនាមពីបណ្ដាប្រទេសដែលបច្ចុប្បន្នអនុវត្តការយកពន្ធប្រឆាំងនឹងការលក់បង្ខូចតំលៃ លើការនាំចូលផលិតផលវាយនភ័ណ្ឌ និងសំលៀកបំពាក់តិច ឬ ច្រើន និងប្រទេសដែលការនាំចេញរបស់គេទទួលរងនូវផលប៉ះពាល់ ។

នៅក្នុងប្រទេសខ្លះ ពន្ធបែបនេះបានត្រូវគេអនុវត្តន៍ទៅលើផលិតផលនាំចូល ដោយការដាក់កំហិតកូតា ទង្វើនេះផ្តល់នូវកិច្ចគាំពារទ្វេចំពោះទំនិញក្នុងស្រុក ។ ការស៊ើបអង្កេតជារឿយៗ ត្រូវបានធ្វើឡើងដោយគ្មានការបញ្ជាក់គ្រប់គ្រាន់ ការស៊ើបអង្កេតខ្លះត្រូវបានបញ្ឈប់យ៉ាងឆាប់ ដោយសារគ្មានភស្តុតាង ។ ទោះបីការស៊ើបអង្កេត បានបញ្ចប់ដោយមិនមានកំណត់អោយយកពន្ធប្រឆាំងនឹងការលក់បង្ខូចតំលៃក៏ដោយ ក៏ការស៊ើបអង្កេតបែបនេះបានបន្ទោកអន្ទោលអោយអ្នកនាំចូល ផ្លាស់ប្តូរប្រភពផ្គត់ផ្គង់ និងជាលទ្ធផលធ្វើអោយរំខានដល់ការធ្វើពាណិជ្ជកម្មរបស់ពួកគេ។ ដូច្នេះវាជាការសំខាន់ណាស់ ដែលអាជ្ញាធរស៊ើបអង្កេត ត្រូវត្រួតពិនិត្យយ៉ាងប្រុងប្រយ័ត្នលើសំណើរដែលស្នើឡើងដោយឧស្សាហកម្មណាមួយ ដើម្បីចាត់វិធានការប្រឆាំងនឹងការលក់បង្ខូចថ្លៃ និងធ្វើការទប់ស្កាត់ការស៊ើបអង្កេតជាតំបូង ជាពិសេស នៅពេលណាដែលទំនិញពាក់ព័ន្ធស្ថិតនៅក្រោមការដាក់កំហិតកូតា ។

វណ្ឌ ៣៣

ពន្ធប្រឆាំងនឹងការលក់បង្ខូចតំលៃ លើផលិតផលវាយនភ័ណ្ឌ និងសំលៀកបំពាក់

ប្រទេសជាសមាជិកដែលអនុវត្តពន្ធនេះ ÷

អាហ្សង់ទីន ប្រេស៊ីល កាណាដា សហគមន៍អ៊ឺរ៉ុប ជប៉ុន ម៉ិកស៊ិកកូ ញូសេឡែន ហ្វីលីពីន សាធារណៈរដ្ឋកូរ៉េ អាហ្វ្រិកខាងត្បូង ទួរគី និងសហរដ្ឋអាមេរិក ។

ប្រទេសជាសមាជិក ដែលទទួលរងនូវផលប៉ះពាល់ ÷

ប្រេស៊ីល ហុងកុង (ចិន) ឥណ្ឌា ឥណ្ឌូនេស៊ី ម៉ាឡេស៊ី ប៉ាគីស្ថាន ព័រទុយហ្គាល់ សាធារណៈរដ្ឋកូរ៉េ ថៃឡង់ ទួរគី និងសហរដ្ឋអាមេរិក ។

ការពាក់ព័ន្ធផ្នែកពាណិជ្ជកម្ម

ការត្រៀមខ្លួនតទល់នឹងការប្រកួតប្រជែងដែលកើនឡើង

ប្រទេសណាដែលនាំចេញផលិតផលវាយនភ័ណ្ឌទៅកាន់ប្រទេសជឿនលឿន ហើយជាប់កូតា ប្រាកដជាខកចិត្តដោយសារការលប់ចោលការដាក់កំហិតនេះមានដំណើរការយឺតនៅដំណាក់កាលពីរដំបូង តាមការកំណត់ដោយកិច្ចព្រមព្រៀងស្តីពីវាយនភ័ណ្ឌ និងសំលៀកបំពាក់ ។ ទោះបីយ៉ាងណាក៏ដោយ ក៏កិច្ចព្រមព្រៀងនេះ ទទួលស្គាល់ថា ការដាក់កំហិតដែលនៅ សេសសល់ផ្សេងទៀត នឹងត្រូវបានលប់ចោលនៅក្នុងដំណាក់កាលទី ៣ និង ទី៤ ហើយអ្នកនាំចេញត្រូវប្រឈមមុខជាមួយ ការប្រកួតប្រជែងដែលបានកើនឡើងយ៉ាងសំបើមក្នុងទីផ្សារអន្តរជាតិ។ ជាងនេះទៀតផលប្រយោជន៍ដែលបានមកពីការលប់ចោលការដាក់កំហិតនេះ មិនទំនងជាមានការបែងចែកស្មើភាព ក្នុងចំណោមបណ្តាប្រទេសនាំចេញទាំងនោះទេ ។

ប្រទេសនានា ដែលស្ថានភាពប្រកួតប្រជែងរបស់គេ បច្ចុប្បន្នស្ថិតនៅក្រោមការដាក់កំហិតកូតា ត្រូវកំណត់ថាតើការលប់ចោលការដាក់កំហិតទាំងនេះនឹងផ្តល់អត្ថប្រយោជន៍ពិតប្រាកដដល់ពួកគេដែរឬទេ ។ ប្រទេសទាំងឡាយដែលជាប្រទេសមានឧត្តមភាពប្រៀបធៀបខ្ពស់ ដោយការប្រើប្រាស់បច្ចេកវិទ្យាទាន់សម័យ អាចទទួលបានផលប្រយោជន៍យ៉ាងពេញលេញពីការលប់ចោលការដាក់កំហិតនេះ ។ ប្រទេសនាំចេញដ៏ទៃទៀត ជាពិសេសប្រទេសដែលគ្មានលទ្ធភាពប្រើប្រាស់កូតាអោយបានពេញលេញ ប្រហែលជាអាចទទួលបានផលប្រយោជន៍តិចតួចប៉ុណ្ណោះ លើកលែងតែពួកគេបានចាត់វិធានការជាបន្ទាន់ ដើម្បីជួយឧស្សាហ៍កម្មរបស់ពួកគេ អោយមានលក្ខណៈប្រកួតប្រជែងកាន់តែខ្លាំង ។ ប្រទេសដែលបច្ចុប្បន្នមិនទាន់ស្ថិតនៅក្រោមការដាក់កំហិតលើទីផ្សារនាំចូល ក៏ត្រូវតែត្រៀមខ្លួន ដើម្បីប្រឈមនឹងការប្រកួតប្រជែងដែលមានកាន់តែច្រើនឡើងៗ ពីប្រទេសដែលបច្ចុប្បន្នស្ថិតក្រោមការដាក់កំហិតលើការនាំចេញ។

ដូច្នេះ ឧស្សាហកម្មវាយនភ័ណ្ឌនៅក្នុងប្រទេសនាំចេញ ក្នុងរយៈពេលអន្តរកាលនេះ ត្រូវត្រៀមខ្លួន ដើម្បីប្រឈមនឹងការប្រកួតប្រជែងដែលកាន់តែកើនឡើង។ ប្រទេសទាំងនេះគួរធ្វើទំនើបកាវូបនីយកម្មបច្ចេកវិទ្យារបស់គេអោយមានលក្ខណៈសមរម្យ និងស្រាវជ្រាវទីផ្សារដើម្បីកំណត់ផលិតផលវាយនភ័ណ្ឌណាមួយ ដែលអាចប្រកួតប្រជែងយ៉ាងមានប្រសិទ្ធភាពនៅលើទីផ្សារអន្តរជាតិ លើមូលដ្ឋានតំលៃ និងគុណភាព។

តាមទំនៀមទំលាប់ សហគ្រាសជាច្រើន (ជាពិសេសនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ខ្លះ) បានប្រមូលផ្តុំនៅទីផ្សាររបស់បណ្តាប្រទេសជឿនលឿន ។ ដើម្បីអនុម័តកម្មវិធី និងយុទ្ធសាស្ត្រសំរាប់អភិវឌ្ឍន៍ការនាំចេញ ក្រោយពេលអនុម័ត ATC បណ្តាប្រទេសទាំងនេះក៏គួរពិចារណាទៅលើសក្តានុពលយ៉ាងធំ ដែលបច្ចុប្បន្នមានសំរាប់វិស័យពាណិជ្ជកម្មដែលកើនឡើងជាមួយប្រទេសកំពុងអភិវឌ្ឍន៍ដ៏ទៃទៀត ។ ប្រទេសទាំងនេះមួយចំនួនបានកាត់បន្ថយតំលៃពន្ធទំនិញដែលខ្ពស់ជាឯកតោភាគី តាមវគ្គប្រជុំនៅយូរ៉ូហ្គាយ ដែលអត្រាពន្ធបែបនេះ ត្រូវបានគេអនុវត្តន៍កន្លងមកទៅលើការនាំចូលផលិតផលវាយនភ័ណ្ឌ ។ ប្រទេសទាំងនេះបច្ចុប្បន្ន កំពុងកាត់បន្ថយការដាក់កំហិតលើបរិមាណ ជាដំណាក់កាលៗ តាមកិច្ចដំណើរការសមាហរណកម្មនៃ ATC។ តំរូវការផលិតផលវាយនភ័ណ្ឌនៅក្នុងប្រទេសទាំងនេះ នឹងមានការកើនឡើង ដោយសារការវិវត្តន៍ថែមទៀតនៅក្នុងការអភិវឌ្ឍន៍ផ្នែកសេដ្ឋកិច្ច និងដោយសារការកើនឡើងនូវប្រាក់ចំណូលរបស់គេម្នាក់ៗ ។

ជំពូក ១៥

កិច្ចព្រមព្រៀងស្តីពីកសិកម្ម

សេចក្តីសង្ខេប

កម្មវិធីកំណែទំរង់ ដែលបានអនុម័តក្រោមកិច្ចព្រមព្រៀងស្តីពីកសិកម្ម តាមការចរចានៅក្នុងកិច្ចប្រជុំឧរុយហ្គាយ ព្យាយាមធ្វើឱ្យពាណិជ្ជកម្មក្នុងវិស័យកសិកម្មស្ថិតនៅក្រោមបទបញ្ជាទាំងឡាយរបស់GATT ជាផ្នែកមួយ ដែលក្នុងនោះវិធានទាំងឡាយ របស់វិស័យនេះជានិច្ចកាលមិនត្រូវបានអនុវត្តពេញលេញដោយបណ្តាប្រទេសជាសមាជិកទាំងអស់ឡើយ ។

ក្រោមកម្មវិធីកំណែទំរង់ជាបន្ថែមទៅលើអត្រាពន្ធ ប្រទេសទាំងឡាយដែលអនុវត្តវិធានការផ្សេងទៀត ដូចជា ការដាក់កំហិតលើបរិមាណ និងបំរែបំរួលអាករផ្សេងៗ ត្រូវបានតំរូវឱ្យលុបចោលវិធានការទាំងនោះ ដោយបូកបន្ថែមនូវ អត្រាពន្ធដែលសមមូលទៅនឹងវិធានការលើអត្រាពន្ធដែលមានស្រាប់ ។ ប្រទេសទាំងនោះត្រូវបានតំរូវថែមទៀតឱ្យបន្ថយអត្រាពន្ធដែលអនុវត្ត ចំពោះការនាំចូលផលិតផលកសិកម្ម រួមទាំងអត្រាដែលបានមកពីការកំណត់អត្រាពន្ធផងដែរ ដោយយោងទៅលើភាគរយដែលបានព្រមព្រៀងគ្នា ។ ប្រទេសកំពុងអភិវឌ្ឍន៍ ទោះជាស្ថិតនៅក្នុងល័ក្ខខ័ណ្ឌនេះក្តី ត្រូវបានអនុញ្ញាតិឱ្យបន្ថយអត្រាពន្ធរបស់ខ្លួនមកនៅត្រឹមអត្រាភាគរយមួយដែលទាបជាងអត្រាដែលតំរូវលើប្រទេសជឿនលឿន និងនៅក្នុងរយៈពេលមួយវែងជាង ។ ចំណែកប្រទេសក្រីក្រ ត្រូវបានរួចផុតអំពីភាតព្វកិច្ចបន្ថយពន្ធនេះ ។

ប្រទេសទាំងអស់ ទាំងប្រទេសជឿនលឿន ប្រទេសកំពុងអភិវឌ្ឍន៍ និងប្រទេសក្រីក្រ ត្រូវតំរូវថែមទៀតឱ្យចងអត្រាពន្ធរបស់ខ្លួនកទល់នឹងការកើនឡើងក្នុងកំរិតដែលបង្ហាញក្នុងកាលវិភាគនៃការធ្វើសម្បទានរបស់ពួកគេ ។ ទោះជាយ៉ាងនេះក្តី ប្រទេសកំពុងអភិវឌ្ឍន៍ និងប្រទេសក្រីក្រ ទទួលបាននូវភាពដែលអាចបត់បែនបានក្នុងការចងភ្ជាប់អត្រាពន្ធគយដែលខ្ពស់បំផុតរបស់ខ្លួន(Ceiling binding) ត្រឹមអត្រាដែលខ្ពស់ជាងអត្រាអនុវត្តកន្លងមក និងអត្រាដែលបានបន្ថយរួចរបស់ពួកគេ ។

ក្រោមកម្មវិធីកំណែទំរង់ ប្រទេសទាំងឡាយដែលប្រើប្រាស់ឧបត្ថម្ភធន (Subsidies) យល់ព្រមបន្ថយតាមភាគរយដោយឡែកៗនៃឧបត្ថម្ភធនលើការនាំចេញ (Export subsidies) និងឧបត្ថម្ភធនសំរាប់គាំទ្រក្នុងស្រុក (Domestic subsidies) ដែលត្រូវបានគេចាត់ទុកថា ធ្វើឱ្យប៉ះពាល់ដល់ការធ្វើពាណិជ្ជកម្ម ។

កិច្ចព្រមព្រៀងបានចែងថា ការចរចាធ្វើសេរីភាវូបនីយកម្មថែមទៀតក្នុងវិស័យពាណិជ្ជកម្ម និងការកែលំអវិធានទាំងឡាយដែលបានអនុម័តក្រោមកម្មវិធីកំណែទំរង់នឹងត្រូវធ្វើឡើងមុនដំណាច់ឆ្នាំ ១៩៩៩ ។

និដ្ឋភាពទូទៅ

កិច្ចព្រមព្រៀងស្តីពីកសិកម្ម បុព្វកថា

កិច្ចព្រមព្រៀងស្តីពីកសិកម្ម បង្កើតឡើងនូវកម្មវិធីមួយសំរាប់ការកែទំរង់ជាលំដាប់លំដោយនូវវិស័យពាណិជ្ជកម្មក្នុងផ្នែកកសិកម្ម ។ កម្មវិធីមានគោលបំណងបង្កើតឡើងនូវ " ប្រព័ន្ធពាណិជ្ជកម្មកសិកម្ម ឆ្ពោះទៅរកទីផ្សារមួយដែលស្មើភាព និងស្មោះត្រង់ " ដោយតំរូវឱ្យប្រទេសទាំងឡាយអនុម័តនូវបទបញ្ញត្តិ ដែលគ្រប់គ្រងទាំង ÷

- ☐ ការប្រើប្រាស់នូវវិធានការតាមព្រំដែន ដើម្បីត្រួតពិនិត្យការនាំចូល ។

- ☐ ការប្រើប្រាស់ឧបត្ថម្ភធនលើការនាំចេញ និងឧបត្ថម្ភធនដទៃទៀត ដែលរដ្ឋាភិបាលធ្វើឡើង ដើម្បីគាំទ្រថ្លៃកសិផល និងធានានូវចំណូលសមស្របដល់កសិករ ។

កិច្ចព្រមព្រៀងស្តីពីកសិកម្ម បុព្វកថា

ដើម្បីធានាអោយកម្មវិធីកំណែទំរង់បែងចែកផលប្រយោជន៍ឱ្យស្មើភាពគ្នា ក្នុងចំណោមប្រទេសជាសមាជិកទាំងអស់ កិច្ចព្រមព្រៀងបានចែងថា ការសន្យាដែលប្រទេសទាំងអស់តំរូវឱ្យធ្វើ គឺត្រូវយកចិត្តទុកដាក់ដល់ ÷

- ☐ បញ្ហាដែលមិនពាក់ព័ន្ធដល់ពាណិជ្ជកម្ម រួមមានសន្តិសុខស្បៀងអាហារ ។
- ☐ តំរូវការការពារបរិស្ថាន ។
- ☐ តំរូវការផ្តល់ប្រព្រឹត្តិកម្មពិសេស និងដោយឡែកចំពោះប្រទេសកំពុងអភិវឌ្ឍន៍ និង
- ☐ លទ្ធភាពនៃឥទ្ធិពលជាអវិជ្ជមាន ដែលបណ្តាលមកពីការអនុវត្តន៍កម្មវិធីកំណែទំរង់ ទៅលើប្រទេសក្រីក្រ និងប្រទេសដែលនាំចូលស្បៀងសុទ្ធសាធ (Net food-Importing countries) ។

បទបញ្ញត្តិទាំងឡាយនៃកិច្ចព្រមព្រៀងអនុវត្តចំពោះផលិតផលនៅក្នុងជំពូក ១ ដល់ជំពូក ២៤ នៃប្រព័ន្ធមុខទំនិញរួម (Harmonized System) និងផលិតផលជាច់ដោយឡែកមួយចំនួនផ្សេងទៀត ។ ប្រព័ន្ធនេះមានវិសាលភាពផងដែរទៅ លើទាំងផលិតផលកសិកម្មបឋម និងផលិតផលកសិកម្មកែច្នៃ ។

សំរាប់ហេតុផលនៃការអនុវត្តន៍ ផលិតផលកសិកម្មជួនកាលត្រូវបានបែងចែកជា ២ ក្រុម គឺក្រុមផលិតផលត្រូពិក និងក្រុមដទៃទៀត ។ ទោះជាគ្មាននិយមន័យព្រមព្រៀងណាមួយអំពីផលិតផលត្រូពិកក្តី ក៏ភេសជ្ជៈទាំងឡាយ ដូចជា តែ កាហ្វេ និងកាកាវ, កប្បាស និងសរសៃរឹងដទៃទៀតដូចជា ក្រចៅ និងផ្លែ ផ្លែឈើ ដូចជា ចេក ស្វាយ និង ត្របែក និងផលិតផលដទៃទៀតដែលស្ទើរតែទាំងអស់ ផលិតនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ត្រូវបានចាត់ថា ជាផលិតផលត្រូពិក ។ នៅក្នុងអំឡុងឆ្នាំបន្ទាប់ពីការបង្កើត GATT ផលិតផលទាំងនេះ គឺជាកម្មវត្ថុនៃការកំណត់អត្រាពន្ធគយខ្ពស់ ពន្ធផ្ទៃក្នុងផ្សេងៗទៀត ស្ទើរតែនៅគ្រប់ប្រទេសជឿនលឿន។ ដោយសារផលិតផលទាំងអស់នេះ គឺជាផលិតផលដែលមានអត្ថប្រយោជន៍លើសលុប សំរាប់ការនាំចេញ របស់ប្រទេសកំពុងអភិវឌ្ឍន៍នេះសិទ្ធិជាអាទិភាពត្រូវបានផ្តល់ឱ្យនៅក្នុងការចរចាGATT កន្លងមក ដើម្បីដកចេញនូវរបាំងពាណិជ្ជកម្ម ចំពោះផលិតផលទាំងនេះ។ ជាលទ្ធផល សូម្បីតែមុនពេលមានកិច្ចប្រជុំយូរ៉ូហ្គាយ ផលិតផលមួយចំនួនធំនៃក្រុមផលិតផលទាំងនេះ ទាំងក្រោមរូបភាពបឋម និងកែច្នៃរួច ត្រូវបាននាំចូលទៅក្នុងទីផ្សារប្រទេសជឿនលឿន លើមូលដ្ឋានរួចពន្ធ និងមូលដ្ឋានអត្រាពន្ធទាបតាមអត្រាកំណត់ MFN ឬ តាមការព្រមព្រៀងអនុគ្រោះពន្ធដទៃទៀត ។

ប្រទេសជឿនលឿនស្ទើរតែទាំងអស់ ទោះជាយ៉ាងនេះក្តី នៅតែបន្តអនុវត្តការនាំចូលកសិផលដទៃទៀត ដូចជា ស្រូវសាឡី និងគ្រាប់ធញ្ញជាតិដទៃទៀត សាច់ និងផលិតផលសាច់ ដោយអត្រាពន្ធខ្ពស់ និងមានវិធានការដែលមិនមែនជាអត្រាពន្ធដទៃទៀត ដូចជាការដាក់កំហិតលើបរិមាណ ឆន្ទានុសិទ្ធិក្នុងការចេញអាជ្ញាប័ណ្ណ និងអាករប្រែប្រួលដទៃទៀត ។ គោលដៅជាមូលដ្ឋានរបស់រដ្ឋាភិបាលក្នុងការផ្តល់កិច្ចការពារដល់ផលិតផលទាំងនេះ (ដែលគេតែងតែស្គាល់ឃើញជាញឹកញាប់ថា ជាផលិតផលនៃតំបន់ដែលមានអាកាសធាតុល្មម) គឺដើម្បីធានាដល់ផលិតករនូវថ្លៃដែលខ្ពស់ជាងថ្លៃពិភពលោក និងដើម្បីធានាអោយពួកគេ ទទួលបាននូវចំណូលសមស្រប ។ គោលនយោបាយទាំងនេះ ក្រៅពីការកាត់បន្ថយកាលានុវត្តន៍ភាពពាណិជ្ជកម្មសំរាប់ការប្រកួតប្រជែងរបស់ផលិតករបរទេស ក៏បានបង្កើតជាបន្ទុកធ្ងន់ធ្ងរផងដែរ ដល់ប្រភពថវិការបស់រដ្ឋាភិបាល ។ ប្រការទាំងនេះ គឺមិនអាចចៀសវាងបានដោយសារតំលៃខ្ពស់របស់ផលិតកម្មលើសពីតំរូវការក្នុងស្រុក អាចនឹងបានត្រូវទូទាត់ចំពោះទីផ្សារអន្តរជាតិតាមរយៈឧបត្ថម្ភធនលើការនាំចេញ ។

ប្រទេសកំពុងអភិវឌ្ឍន៍ ក៏ការពារវិស័យកសិកម្មរបស់គេផងដែរ តាមរយៈការកំណត់អត្រាពន្ធគយខ្ពស់ និងការដាក់កំហិតលើការនាំចូល ។

វិធានការតាមព្រំដែន

ការកំណត់ពន្ធ

កិច្ចព្រមព្រៀងស្តីពីកសិកម្ម មាត្រា ៤ និងកំណត់ពន្យល់ ១

ចំណុចសំខាន់ៗ បំផុតនៃកិច្ចព្រមព្រៀងស្តីពីកសិកម្ម គឺវិធានថ្មីៗ ។ វិធានទាំងនេះតំរូវឱ្យប្រទេសទាំងឡាយដែលអនុវត្តវិធានការមិនមែនពន្ធគយ (ដូចជាការដាក់កំហិតលើបរិមាណ ឆន្ទានុសិទ្ធនៃការចេញអាជ្ញាប័ណ្ណ និងអាការប្រែប្រួលដទៃទៀត) ត្រូវលុបបំបាត់វិធានការទាំងនេះ ដោយគណនាអត្រាពន្ធសមមូល ហើយបន្ថែមអត្រាសមមូលនេះ ទៅលើអត្រាពន្ធដែលកំណត់រួចហើយ។ ជាលទ្ធផល ប្រទេសទាំងឡាយបានបង្កើតនូវអត្រាពន្ធថ្មី សំរាប់ផលិតផលទាំងអស់ (ស្ទើរតែទាំងអស់ គឺផលិតផលដែលនៅក្នុងអាកាសធាតុល្មម) ដែលពីមុននេះផលិតផលទាំងនេះត្រូវបានគេអនុវត្តវិធានការមិនមែនពន្ធគយ ។ អត្រាពន្ធដែលសមមូលទៅនឹងវិធានការ មិនមែនពន្ធគយ ត្រូវបានគណនាលើមូលដ្ឋានមធ្យមភាគនៃថ្លៃទីផ្សារពិភពលោក ចំពោះផលិតផលដែលជាកម្មវត្ថុនៃវិធានការមិនមែនពន្ធគយ និងថ្លៃផ្ទៃក្នុងរបស់វានៅក្នុងប្រទេសនាំចូល ។

កាតព្វកិច្ចចំពោះការដាក់កំហិតលើបរិមាណដែលផ្អែកលើពន្ធ (Tariff quantitative restriction) ទោះជាយ៉ាងនេះក្តី មិនត្រូវបានអនុវត្ត ចំពោះការដាក់កំហិតដែលប្រកាន់ទុកដោយបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ ក្នុងការសំរួលដល់ការលំបាកនៃជញ្ជីងទូទាត់តាមបទបញ្ញត្តិនៃ GATT ទេ ។

ការសន្យាបច្ចុប្បន្ន និងការសន្យាបើកច្រកទីផ្សារអប្បបរិមា

បណ្តាប្រទេសនាំចេញទាំងឡាយ នៅមានការទើសទាស់ចំពោះការនាំចូលផលិតផលមួយចំនួន ដែលត្រូវកំណត់ដោយការដាក់កំហិតលើបរិមាណ ឬ អាការប្រែប្រួលផ្សេងៗ ដែលជាគ្រោះថ្នាក់ដោយសារថាបែបបទនៃការកំណត់ពន្ធដោយខ្លួនឯង ពុំមានឥទ្ធិពលមួលទូលាយលេចធ្លោណាមួយទេ ។ ការប្រើប្រាស់ការសន្យាបច្ចុប្បន្ន និងការបើកច្រកអប្បបរិមាត្រូវបានអនុម័ត ដើម្បីបំពេញបន្ថែមចំពោះ បែបបទកំណត់ពន្ធ (សូមអានវណ្ណ ៣៤ ដែលមានរៀបរាប់លំអិតសេចក្តី) ។

ចណ្ណ ៣៤

ផលិតផលកសិកម្ម : ការសន្យាបច្ចុប្បន្ន និងការបើកច្រកទីផ្សារអប្បបរិមា

(កិច្ចព្រមព្រៀងកសិកម្ម មាត្រា ៥.២)

ការសន្យាបើកច្រកទីផ្សារបច្ចុប្បន្ន

ប្រទេសមួយចំនួនមានកិច្ចព្រមព្រៀងពិសេសសំរាប់ការនាំចូល សាច់ និងផលិតផលនៃតំបន់អាកាសធាតុល្មមសំខាន់ៗ ដទៃទៀតដែលមានព្រំដែនកូតាលើមូលដ្ឋានរួចពន្ធ ឬ មូលដ្ឋានអនុគ្រោះពន្ធ ។ ដើម្បីធានាមិនអោយការនាំចូលនេះ ទទួលរងនូវផលប៉ះពាល់ ដោយសារការអនុវត្តន៍អត្រាពន្ធខ្ពស់ជាងដែលជាលទ្ធផលនៃការកំណត់ពន្ធ ប្រទេសនាំចូលទាំងឡាយ បានផ្តល់នូវការសន្យាបើកច្រកទីផ្សារបច្ចុប្បន្ន ដោយបង្កើតនូវពន្ធកូតា (Tariff quota) ដើម្បីគ្រប់គ្រងការនាំចូលដែលកំពុងចូលមកក្នុងទីផ្សារតាមអត្រាពន្ធទាបជាង ។ ជាលទ្ធផលនៃការសន្យានេះ ការនាំចូលឱ្យដល់ត្រឹមកំរិតកំណត់កូតា ត្រូវបានអនុញ្ញាតិឱ្យធ្វើឡើងតាមអត្រាទាបជាងដែលកំពុងប្រើប្រាស់ ។ ចំណែកអត្រាខ្ពស់ជាង ដែលជាទាបានពីការកំណត់ពន្ធ ត្រូវបានអនុវត្តចំពោះការនាំចូលដែលលើសហួសពីព្រំដែនកូតាកំណត់ ។

ការសន្យាបើកច្រកទីផ្សារអប្បបរិមា

ចំពោះផលិតផលដែលនាំចូលតិចតួច ឬ គ្មាននាំចូលសោះ ក្នុងអំឡុងពេលអតីតកាល ដោយសារតែការកំណត់ពន្ធខ្ពស់ និងរបបពន្ធ ដែលមាននៅក្នុងពេលនេះ ប្រទេសទាំងនេះតំរូវឱ្យផ្តល់នូវការសន្យាផ្តល់ការអនុវត្តន៍ការបើកច្រកទីផ្សារអប្បបរិមាមួយ ។ ការសន្យាទាំងនោះបានផ្តល់ឱ្យនូវការបង្កើតពន្ធកូតាដែលស្មើទៅនឹង ៣០ ភាគរយ នៃការប្រើប្រាស់ក្នុងស្រុកលើមូលដ្ឋាន

អំឡុងឆ្នាំ ១៩៨៦-១៩៨៨ ហើយកើនឡើងដល់ ៥ ភាគរយ នូវដំណាច់ឆ្នាំ ២០០០ ចំពោះប្រទេសជឿនលឿន និង ២០០៤ ចំពោះប្រទេសកំពុងអភិវឌ្ឍន៍ ។ អត្រាពន្ធទាបជាង (ដែលកំណត់ ក្នុងកាលវិភាគជាតិ ប៉ុន្តែជាទូទៅ មិនឡើងដល់ព្រំខ័ណ្ឌកូតា ហើយទន្ទឹមគ្នានេះដែរអត្រាខ្ពស់ជាងដែលបានមកពីការកំណត់ពន្ធ ត្រូវបានអនុវត្តចំពោះការនាំចូលដែលលើសព្រំខ័ណ្ឌកំណត់) ។ ជាលទ្ធផលនៃការសន្យាបើកច្រកអប្បបរិមាទាំងនេះ ប្រទេសទាំងឡាយ នឹងត្រូវនាំចូលនូវបរិមាណសមរម្យនៃផលិតផល ត្រូវដាក់កំហិតដែលខ្លួនត្រូវការបំផុត ។ ផលិតផលទាំងឡាយដែលគ្របដណ្តប់ដោយការសន្យាបើកច្រកអប្បបរិមាទាំងនេះ រួមមាន សាច់ ផលិតផលទឹកដោះ និងបន្លែស្រស់មួយចំនួន ព្រមទាំងផ្លែឈើ ។

វិធានការការពារពិសេស

កិច្ចព្រមព្រៀងកសិកម្ម មាត្រា ៥

កិច្ចព្រមព្រៀងឆ្លើយតបទៅនឹងការព្រួយបារម្ភរបស់បណ្តាប្រទេសនាំចូលដែលថា ការលប់ចោលនូវការដាក់កំហិតលើបរិមាណ នឹងនាំទៅដល់ការកើនឡើងយ៉ាងគំហុកនៃការនាំចូល ទោះបីជាមានអត្រាពន្ធសមមូលក៏ដោយនោះ ហើយបានអនុញ្ញាតិឱ្យប្រទេសទាំងនោះ ដាក់ចេញនូវវិធានការការពារពិសេសលើផលិតផលដែលកំណត់ពន្ធរួចហើយ ។

បទបញ្ញត្តិស្តីពីការការពារពិសេសបានអនុញ្ញាតិឱ្យមានការកំណត់អត្រាពន្ធបន្ថែម ប្រសិនបើស្របទៅតាមលក្ខណៈវិនិច្ឆ័យមួយចំនួន ។ លក្ខណៈវិនិច្ឆ័យមួយដែលពាក់ព័ន្ធទាំងការកើនឡើងយ៉ាងឆាប់រហ័សនៃការនាំចូល (បរិមាណដែលជាគន្លឹះ) ឬ ក៏ផ្អែកលើមូលដ្ឋាននៃការដឹកជញ្ជូនមួយលើកៗ ការធ្លាក់ចុះថ្លៃនាំចូលនៅក្រោមថ្លៃគោល (ថ្លៃជាគន្លឹះ) នៅក្នុងករណីបរិមាណជាគន្លឹះ ពន្ធនាំចូលខ្ពស់ជាង ត្រូវបានអនុវត្តតែរហូតដល់ពេលចុងឆ្នាំដែលមានបញ្ហា ។ ចំពោះករណីថ្លៃជាគន្លឹះអត្រាពន្ធនាំចូលបន្ថែមត្រូវបានដាក់តែនៅលើទំនិញនៃជើងដឹកជញ្ជូនដែលពាក់ព័ន្ធប៉ុណ្ណោះ ។ គេអាចយកពន្ធនាំចូលបន្ថែម តែលើផលិតផលដែលបានកំណត់អត្រាពន្ធរួច ហើយត្រូវធ្វើឡើងតែក្នុងករណី ប្រសិនបើការត្រៀមបំរុងដើម្បីបង្កើតកិច្ចការពារត្រូវបានលើកឡើងទល់នឹងផលិតផលដែលមាននៅក្នុងតំរោងសម្បទានរបស់ប្រទេស ។

ការបន្ថយភាគរយនៃអត្រាពន្ធ

ប្រទេសទាំងឡាយបានព្រមព្រៀងកាត់បន្ថយពន្ធរបស់ខ្លួន នៅក្នុងកិច្ចប្រជុំ ឃ្យ៉ូរ៉ុយហ្គាយ (ទាំងអត្រាពន្ធថ្មីដែលកំណត់រួច និងពន្ធដទៃទៀត) ដោយកំណត់អត្រាជាក់លាក់ ។ ប្រទេសជឿនលឿន និងប្រទេសក្នុងដំណាក់កាលអន្តរកាល អនុវត្តការបន្ថយពន្ធដោយអត្រាមធ្យម ៣៦ ភាគរយ ហើយប្រទេសកំពុងអភិវឌ្ឍន៍បន្ថយត្រឹមអត្រា ២៤ ភាគរយ ។ ការបន្ថយនេះត្រូវបានធ្វើឡើងដោយប្រទេសជឿនលឿនក្នុងអំឡុងពេល ៦ ឆ្នាំ គិតចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ១៩៩៥ តទៅ ឯប្រទេសកំពុងអភិវឌ្ឍន៍ ក្នុងរយៈពេល ១០ ឆ្នាំ ។ ប្រទេសក្រីក្រ ទោះបីជាគេបានចងអត្រាពន្ធនៅអត្រាខ្ពស់បំផុតក្តី ក៏មិនបានតំរូវឱ្យបន្ថយអត្រាទាំងនោះដែរ។

វិធានចែងទៀតថា អត្រាពន្ធលើផលិតផលនីមួយៗចាំបាច់ត្រូវបញ្ចុះយ៉ាងហោចណាស់ ១៥% ភាគរយ ដោយប្រទេសជឿនលឿន និង១០ ភាគរយ ដោយប្រទេសកំពុងអភិវឌ្ឍន៍ ។

ការចងភ្ជាប់ពន្ធ

ចំណុចមួយក្នុងចំណុចជាច្រើននៃកម្មវិធីកំណែទំរង់គឺអត្រាពន្ធ (រួមទាំងអត្រាពន្ធដែលជាលទ្ធផលនៃការកំណត់ពន្ធផង) ដែលអនុវត្តចំពោះផលិតផលកសិកម្មត្រូវបានចងភ្ជាប់ដោយប្រទេសទាំងអស់ (ទាំងប្រទេសជឿនលឿន ប្រទេសកំពុងអភិវឌ្ឍន៍ ប្រទេសក្រីក្រ និងប្រទេសក្នុងដំណាក់កាលអន្តរកាល តទល់នឹងការកើនឡើងលើសពីកំរិតកំណត់ដែលបានបង្ហាញនៅក្នុងតំរោងសម្បទានរបស់ខ្លួន) ។ ប្រការនេះបន្ថែមទៅលើការលប់បំបាត់វិធានការមិនមែនពន្ធគយ តាមរយៈការកំណត់ពន្ធឡើងវិញ ត្រូវបានចាត់ទុកថាជាសមិទ្ធិផលដ៏ចំបងមួយនៃកម្មវិធីកំណែទំរង់ : មុនពេលអនុម័តកម្មវិធីនេះ មានតែអត្រាពន្ធមួយចំនួនតូចប៉ុណ្ណោះនៃប្រទេសជឿនលឿន និងប្រទេសកំពុងអភិវឌ្ឍន៍ត្រូវបានចងភ្ជាប់ ។

ភាពដែលអាចបត់បែនបានសំរាប់ប្រទេសកំពុងអភិវឌ្ឍន៍ : អត្រាពន្ធចងភ្ជាប់ខ្ពស់បំផុត

ប្រទេសកំពុងអភិវឌ្ឍន៍ និងប្រទេសក្រីក្រ ទទួលបាននូវភាពដែលអាចបត់បែនបាន ដើម្បីចងភ្ជាប់អត្រាពន្ធរបស់ខ្លួននៅនឹងអត្រាចងភ្ជាប់ដែលខ្ពស់បំផុត ដែលអាចខ្ពស់ជាងអត្រាដែលគេកំពុងអភិវឌ្ឍន៍ ឬ អត្រាដែលជាលទ្ធផលនៃការកាត់បន្ថយដែលបានព្រមព្រៀងនៅក្នុងការចរចា ។ ប្រទេសទាំងនេះមួយចំនួនបានទាញយកអត្ថប្រយោជន៍ពីភាពដែលអាចបត់បែនបាននេះ ហើយបានផ្តល់នូវអត្រាពន្ធចងភ្ជាប់ដែលខ្ពស់បំផុត ដោយមិនតម្លើងអត្រាពន្ធណាមួយ ដែលអនុវត្តចំពោះផលិតផលកសិកម្មលើសពីកំរិតព្រមព្រៀង (ដូចជា ៦០ ឬ ៨០ ភាគរយ) ។ អត្រាអនុវត្តនៅក្នុងប្រទេសទាំងនេះ គឺទាបជាងអត្រាពន្ធចងភ្ជាប់ខ្ពស់បំផុតរបស់គេ ។

ឧបត្ថម្ភធនសំរាប់ការនាំចេញ និងវិធានការគាំទ្ររបស់រដ្ឋាភិបាល

ក្រៅពីការការពារកំរិតខ្ពស់នានា ភាពប៉ះពាល់ដល់ពាណិជ្ជកម្មអន្តរជាតិក្នុងវិស័យផលិតផលកសិកម្ម កើតមានឡើងដោយការអនុវត្តន៍របបឧបត្ថម្ភធន ជាពិសេសនៅក្នុងប្រទេសជឿនលឿនមួយចំនួន ។ ទោះបីជាប៉ុន្មានឆ្នាំកន្លងទៅនេះ GATT មានលទ្ធភាពបង្កើតវិធានមួយចំនួន សំរាប់របបឧបត្ថម្ភធនចំពោះផលិតផលឧស្សាហកម្មក៏ដោយ តែGATT មិនបានពិចារណា (bring under discipline) មៅលើរបបឧបត្ថម្ភធនដែលផ្តល់ឱ្យដោយរដ្ឋាភិបាលចំពោះវិស័យកសិកម្មទេ ។ កិច្ចព្រមព្រៀងស្តីពីកសិកម្មរួមមានវិធានមួយចំនួនស្តីពីរបបឧបត្ថម្ភធនលើផលិតផលកសិកម្ម ។

ឧបត្ថម្ភធនសំរាប់ការនាំចេញ

ឧបត្ថម្ភធនសំរាប់ការនាំចេញ ត្រូវបានចាត់ទុកថាជាការប៉ះពាល់ធ្ងន់ធ្ងរដល់ពាណិជ្ជកម្មក្នុងចំណោមរបបឧបត្ថម្ភធនទាំងឡាយដែលផ្តល់ដោយរដ្ឋាភិបាល ។ របបឧបត្ថម្ភធននេះផ្តល់លទ្ធភាពឱ្យកសិករលក់ផលិតផលរបស់ខ្លួនទៅក្នុងទីផ្សារអន្តរជាតិ ។

វិធានអនុវត្តចំពោះផលិតផលឧស្សាហកម្ម

វិធានស្តីពីការប្រើប្រាស់របបឧបត្ថម្ភធនសំរាប់ការនាំចេញផលិតផលកសិកម្ម ខុសគ្នាពីរបបឧបត្ថម្ភធនដែលអនុវត្តចំពោះផលិតផលឧស្សាហកម្ម ។ តាំងពីដើមដំបូង វិធានរបស់GATT បានហាមឃាត់ប្រទេសជឿនលឿនមិនឱ្យប្រើប្រាស់របបឧបត្ថម្ភធន សំរាប់ការនាំចេញផលិតផលឧស្សាហកម្ម ។ ការសើរើកិច្ចព្រមព្រៀង SCM ឡើងវិញនៅក្នុងកិច្ចប្រជុំឃ្រុយហ្គាយ បានពង្រីកការហាមឃាត់នេះ ទៅដល់ផលិតផលឧស្សាហកម្មនៃប្រទេសកំពុងអភិវឌ្ឍន៍ផងដែរ ។ ប្រទេសកំពុងអភិវឌ្ឍន៍ទាំងនេះ មានដំណាក់កាលអន្តរកាលរហូតដល់ ៨ ឆ្នាំ (រហូតដល់ថ្ងៃទី ០១ មករា ឆ្នាំ ២០០៣) ដើម្បីបំពេញឱ្យបាននូវកាតព្វកិច្ចនេះ ។ ទោះជាយ៉ាងនេះក្តី ប្រទេសក្រីក្រ និងប្រទេសដែលមានផលចំណូលសំរាប់មនុស្សម្នាក់ៗ តិចជាង ១,០០០ ដុល្លា បច្ចុប្បន្ននេះ ត្រូវបានលើកលែងពីកាតព្វកិច្ចនេះ (សូមអានជំពូក ៨) ។

វិធានអនុវត្តចំពោះផលិតផលកសិកម្ម

កិច្ចព្រមព្រៀងស្តីពីកសិកម្ម មាត្រា ៩

ក្នុងវិស័យកសិកម្ម គេទទួលស្គាល់ថាប្រទេសមួយចំនួនពឹងផ្អែកលើការប្រើប្រាស់របបឧបត្ថម្ភធន ដើម្បីបំពេញអតិរេកនៃផលិតផលរបស់គេ ទៅក្នុងទីផ្សារអន្តរជាតិ ។ កិច្ចព្រមព្រៀងស្តីពីកសិកម្មតំរូវឱ្យប្រទេសទាំងនោះអនុវត្តការប្តេជ្ញាចិត្ត ដើម្បីកាត់បន្ថយការប្រើប្រាស់របបឧបត្ថម្ភធនរបស់គេ ។ មានការអនុញ្ញាតិអោយប្រទេសនោះប្រើប្រាស់របបឧបត្ថម្ភធន ចំនួន ៦ ប្រភេទដូចមានចែងក្នុងវណ្ណ ៣៥ ប្រសិនបើគេព្រមព្រៀងអនុវត្តការសន្យាបន្ថយទាំងបរិមាណនៃរបបឧបត្ថម្ភធន (ដែលបង្ហាញនៅក្នុងតារាងថវិការ) និងបរិមាណនៃការនាំចេញដែលទទួលបានរបបឧបត្ថម្ភធន ។

គួរកត់សំគាល់ផងដែរថា ប្រទេសដែលប្រើប្រាស់របបឧបត្ថម្ភធន បានធ្វើការសន្យាយ៉ាងធំធេងនៅក្នុងអំឡុងពេលចរចា ។ ការសន្យាទាំងនេះត្រូវបានធ្វើឡើងលើមូលដ្ឋានផលិតផលមួយ ទៅផលិតផលមួយ ក្នុងគំរោងសម្បទាន WTO របស់គេ ។

កិច្ចព្រមព្រៀងស្តីពីកសិកម្ម មាត្រា ១០

ប្រទេសទាំងនេះកំពុងស្ថិតនៅក្រោមកាតព្វកិច្ចមួយ ដែលពួកគេមិនអាចធ្វើឱ្យហួសពីកំរិតដែលបានសន្យារួច ដូចដែលបានបង្ហាញនៅក្នុងគំរោងរបស់ពួកគេទាំងផ្នែកថវិការ និងបរិមាណ ។ ប្រទេសទាំងនោះក៏មានកាតព្វកិច្ចមួយទៀតផងដែរ គឺពួកគេមិនអាចពង្រីកវិសាលភាពនៃផលិតផលដែលអាចទទួលនូវរបបឧបត្ថម្ភធនឱ្យលើសពីអ្វី ដែលមានចែងក្នុងគំរោងឧបត្ថម្ភធននោះទេ ។

តារាងលេខ ១ នៅក្នុងឧបសម្ព័ន្ធដែលភ្ជាប់និងជំពូកនេះមានចែងនូវការសន្យាចំពោះរបបឧបត្ថម្ភធនសំរាប់ការនាំចេញ ដែលធ្វើឡើងដោយប្រទេសទាំងនោះ ហើយនឹងផលិតផលដែលមានរបបឧបត្ថម្ភធននោះ ។

ប្រទេសទាំងឡាយណាដែលមិនផ្តល់ការសន្យាកាត់បន្ថយឧបត្ថម្ភ នឹងត្រូវហាមឃាត់មិនឱ្យប្រើប្រាស់របបឧបត្ថម្ភធសំរាប់ការនាំចេញផលិតផលកសិកម្មទេ ។ ទោះជាយ៉ាងនេះក្តី បទបញ្ញត្តិទាំងឡាយស្តីពីប្រព្រឹត្តិកម្មពិសេស និងប្រព្រឹត្តិកម្មដោយឡែក អនុញ្ញាតិឱ្យប្រទេសកំពុងអភិវឌ្ឍន៍ប្រើប្រាស់របប ២យ៉ាង ក្នុងចំណោមរបបឧបត្ថម្ភធនសំរាប់ការនាំចេញដូចមានចែងក្នុងវណ្ឌ ៣៥ ។ ប្រភេទរបបឧបត្ថម្ភធនសំរាប់ការនាំចេញទាំង ២ នោះគឺ ÷

- ☐ របបឧបត្ថម្ភធន ដើម្បីបន្ថយចំណាយនៃការស្វែងរកទីផ្សារនាំចេញផលិតផលកសិកម្ម រួមមានទាំងការបង្កើនគុណភាព និងចំណាយកែឆ្នៃផ្សេងទៀត ព្រមទាំងចំណាយលើការដឹកជញ្ជូនអន្តរជាតិ និងថ្លៃដឹកនាំផ្សេងៗ ។
- ☐ ថ្លៃដឹកជញ្ជូនក្នុងស្រុក និងថ្លៃដឹកនាំលើការដឹកជញ្ជូននាំចេញ តាមល័ក្ខខ័ណ្ឌដែលអំណោយផល ជាងជើងដឹកជញ្ជូនក្នុងស្រុក។

របបឧបត្ថម្ភធនក្នុងស្រុក

កិច្ចព្រមព្រៀងស្តីពីកសិកម្មមាត្រា ១ (ក) មាត្រា ៦

ចំពោះរបបឧបត្ថម្ភធនក្នុងស្រុក កំហិតជំពូកនៃកិច្ចព្រមព្រៀង គឺតំរូវឱ្យប្រទេសទាំងឡាយយល់ព្រមសន្យា បន្ថយរបបឧបត្ថម្ភធនដែលប៉ះពាល់ដល់ពាណិជ្ជកម្ម ។ ចំពោះគោលបំណងនេះ គេបានចែករបបឧបត្ថម្ភធនជា ៣ ប្រភេទគឺ បៃតង ខៀវ និងលឿង ។ របបឧបត្ថម្ភធនបៃតង និងខៀវ គឺជារបបឧបត្ថម្ភធនដែលទទួលបានការអនុញ្ញាត្តិ ហើយជារបបឧបត្ថម្ភធនដែលមិនអនុវត្តការសន្យាកាត់បន្ថយ ។ ចំណែករបបឧបត្ថម្ភធនពណ៌លឿង ជារបបឧបត្ថម្ភធនដែលគេត្រូវអនុវត្តការសន្យាកាត់បន្ថយ ។

របបឧបត្ថម្ភធនបៃតង

កិច្ចព្រមព្រៀងស្តីពីកសិកម្ម ឧបសម្ព័ន្ធ ២:១

របបឧបត្ថម្ភធនទាំងអស់ដែល " គ្មាន ឬ មានឥទ្ធិពលតិចតួចបំផុតដល់ពាណិជ្ជកម្ម ឬ លើផលិតកម្ម " និង " ពុំមានឥទ្ធិពលដល់ការឧបត្ថម្ភធនថ្លៃចំពោះផលិតករ " ត្រូវបានចាត់ទុកថាជារបបឧបត្ថម្ភធនពណ៌បៃតង ហើយត្រូវបានលើកលែងឱ្យរួចផុតពីការសន្យាកាត់បន្ថយ ។ កិច្ចព្រមព្រៀងពុំបានដាក់កំហិតដល់សិទ្ធិរបស់រដ្ឋាភិបាលក្នុងការផ្តល់របបឧបត្ថម្ភធន ដើម្បីកែលំអផលិតភាពផលិតកម្ម និងប្រសិទ្ធិភាពនៃផលិតកម្មកសិកម្មនោះទេ ។ វណ្ឌ ៣៦ រួមមានឧទាហរណ៍បង្ហាញអំពីការអនុវត្តន៍របបឧបត្ថម្ភធនបៃតង ។

វណ្ឌ ៣៥

របបឧបត្ថម្ភធនសំរាប់ការនាំចេញដែលជាកម្មវត្ថុនៃការសន្យាកាត់បន្ថយ

(កិច្ចព្រមព្រៀងស្តីពីកសិកម្មមាត្រា ៩-១)

កិច្ចព្រមព្រៀងស្តីពីកសិកម្ម បង្កើតបានជារបបឧបត្ថម្ភធនសំរាប់ការនាំចេញចំនួន ៦ ប្រភេទ ជាមូលដ្ឋានដែលចាំបាច់ត្រូវកាត់បន្ថយ ដោយបណ្តាប្រទេសជាសមាជិក ។ ប្រភេទទាំងនោះគឺ ÷

- ☐ *ការផ្តល់របបឧបត្ថម្ភធនផ្ទាល់ដោយរដ្ឋាភិបាល ដែលជាការពឹងផ្អែកទៅលើការនាំចេញ ។*

- ☐ *ការលក់នូវស្តុកផលិតផលកសិកម្ម ដែលមិនមែនពាណិជ្ជកម្ម (ជាកម្មសិទ្ធិសាធារណៈ) ដោយរដ្ឋាភិបាល តាមតំលៃទាបជាង បើប្រៀបធៀបនឹងតំលៃនៃផលិតផលដូចគ្នា ដែលគេលក់ឱ្យអ្នកទិញនៅក្នុងទីផ្សារក្នុងស្រុក ។*
- ☐ *ការទូទាត់ចំពោះការនាំចេញផលិតផលកសិកម្ម ដែលផ្តល់ផ្គង់ហិរញ្ញវត្ថុដោយសារចំណាត់ការរបស់រដ្ឋាភិបាល ទោះជាមាន ឬ គ្មានការគិតជាបន្ទុកទៅលើគណនីសាធារណៈត្រូវបានពាក់ព័ន្ធក្តី ដោយរួមមាន ទាំងការទូទាត់ដែលផ្គត់ផ្គង់ហិរញ្ញវត្ថុ ដោយចំណូលបានពីពន្ធដែលដាក់លើផលិតផលដែលពាក់ព័ន្ធ ឬ ដាក់លើផលិតផលកសិកម្មដែលបង្កើតបានជាផលិតផលនាំចេញនោះ ។*
- ☐ *ការផ្តល់របបឧបត្ថម្ភធន ដើម្បីបន្ថយចំណាយស្វែងរកទីផ្សារនាំចេញផលិតផលកសិកម្ម (ក្រៅអំពីសេវាជំរុញការនាំចេញ និងសេវាផ្តល់ការប្រឹក្សាដែលមានស្រាប់) រួមមានទាំងការចាត់ចែងការបង្កើនគុណភាព និងថ្លៃកែច្នៃដទៃទៀត ព្រមទាំងថ្លៃដឹកជញ្ជូនអន្តរជាតិ និងថ្លៃដឹកនាំផ្សេងៗ **
- ☐ *ការដឹកជញ្ជូនអន្តរជាតិ និងថ្លៃដឹកនាំផ្សេងៗ ចំពោះជើងនាំចេញនីមួយៗតាមលក្ខខ័ណ្ឌដែលអំណោយផលជាងជើងដឹកជញ្ជូនក្នុងស្រុក * និង*
- ☐ *របបឧបត្ថម្ភលើផលិតផលកសិកម្មដែលធ្វើឡើងផ្អែកលើការរួមបញ្ចូលផលិតផលទាំងនេះទៅក្នុងផលិតផលនាំចេញ។*

* *ប្រទេសកំពុងអភិវឌ្ឍន៍ មិនបានតំរូវឱ្យអនុវត្តការសន្យាកាត់បន្ថយ ដែលទាក់ទងដល់ការអនុវត្តន៍របបឧបត្ថម្ភធនសំរាប់ការនាំ ចេញទាំងនេះទេ (មាត្រា ៩-៤) ។*

របបឧបត្ថម្ភធនខៀវ

ជាបន្ថែមទៅលើការអនុវត្តន៍ដែលមានចែងក្នុងវគ្គ ៣៦ "ការទូទាត់ដោយផ្ទាល់ ក្រោមកម្មវិធីកំណត់ផលិតកម្ម" ក៏ត្រូវបានលើកលែងផងដែរពីកិច្ចសន្យាកាត់បន្ថយប្រសិនបើ ÷

- ☐ ការទូទាត់ទាំងនោះត្រូវធ្វើឡើងលើផ្ទៃក ឬ ទិន្នផលដែលបានកំណត់ ។
- ☐ ការទូទាត់ទាំងនោះត្រូវធ្វើលើមូលដ្ឋាន ៨៥ ភាគរយ ឬ តិចជាងនៃផលិតកម្ម ។
- ☐ ការទូទាត់ចំពោះការចិញ្ចឹមសត្វពាហនៈត្រូវធ្វើឡើងលើមូលដ្ឋានកំណត់ចំនួនរបស់សត្វទាំងនោះ ។

ការអនុវត្តន៍របបឧបត្ថម្ភធនទាំងនេះតែងតែធ្វើឡើងដោយយោងទៅដល់វិធានការដែលហៅថា វិធានការខៀវ ។

របបឧបត្ថម្ភធនលឿង

ការគាំទ្រក្នុងស្រុក

របបឧបត្ថម្ភធនលឿងគ្របដណ្តប់ជាចំបងលើរបបឧបត្ថម្ភធនគាំទ្រក្នុងស្រុក ដែលត្រូវបានចាត់ទុកថាមានផលប៉ះពាល់ដល់ពាណិជ្ជកម្ម ។ កិច្ចព្រមព្រៀងបានកំណត់នូវកំរិតខ្ពស់បំផុតមួយស្តីពីការគាំទ្រក្នុងស្រុកសរុប (ដែលគណនាជារង្វាស់កំណើននៃការគាំទ្រ. AMS) ដែលរដ្ឋាភិបាលអាចផ្តល់ឱ្យផលិតករក្នុងស្រុក ។ ជាបន្ថែមកិច្ចព្រមព្រៀងតំរូវថា AMS គួរបានត្រូវកាត់បន្ថយដោយភាគរយដែលបានព្រមព្រៀងគ្នា ។

ខណ្ឌ ៣៦

តារាងបង្ហាញនៃគោលនយោបាយឧបត្ថម្ភធនបៃតងដែលផ្តល់ឱ្យផលិតករ ហើយត្រូវបានលើកលែងពីការសន្យាកាត់បន្ថយ
(កិច្ចព្រមព្រៀងស្តីពីកសិកម្ម ឧបសម្ព័ន្ធ ២)

ខាងក្រោមនេះគឺជាឧទាហរណ៍មួយចំនួនក្នុងឧបសម្ព័ន្ធ ២ នៃកិច្ចព្រមព្រៀងស្តីពីកសិកម្ម ពាក់ព័ន្ធនឹងការអនុវត្តន៍របបឧបត្ថម្ភ ដែលបានត្រូវលើកលែងពីការសន្យាកាត់បន្ថយ ប្រសិនបើឆ្លើយតបទៅតាមលក្ខខណ្ឌពិសេសដែលចែងដោយកិច្ចព្រមព្រៀង÷

- ☐ *ការចំណាយរបស់រដ្ឋាភិបាលលើការស្រាវជ្រាវផ្នែកកសិកម្ម ការត្រួតពិនិត្យសំឡាប់សត្វល្អិត ការត្រួតពិនិត្យ និងការកំណត់គុណភាពនៃផលិតផលមួយចំនួន សេវាស្វែងរកទីផ្សារ និងការជំរុញផ្សព្វផ្សាយ ។*
- ☐ *ការចូលរួមខាងផ្នែកហិរញ្ញវត្ថុ ដោយរដ្ឋាភិបាលទៅក្នុងចំណូលធានារ៉ាប់រង និងកម្មវិធីសុវត្ថិភាពចំណូល ។*
- ☐ *ការទូទាត់ចំពោះគ្រោះមហន្តរាយធម្មជាតិ*
- ☐ *ជំនួយការក្នុងការកែតំរូវរចនាសម្ព័ន្ធ តាមរយៈ ÷*
  - *កម្មវិធីចូលនិវត្តន៍របស់ផលិតករ ដែលរៀបចំឡើង ដើម្បីសំរួលការចូលនិវត្តន៍របស់បុគ្គលដែលពាក់ព័ន្ធនឹងផលិតកម្មកសិកម្មដែលអាចលក់បាន ។*
  - *កម្មវិធីចូលនិវត្តន៍របស់ប្រភពធនធាន (Resource retirement Programmes) ដែលធ្វើឡើងដើម្បីដកហូតយកដី និងប្រភពធនធានដទៃទៀត រួមមាន សត្វពាហនៈពីផលិតកម្មកសិកម្ម ។*
  - *ជំនួយវិនិយោគដែលរៀបចំឡើង ដើម្បីជួយផ្នែកហិរញ្ញវត្ថុ ឬ ការកសាងឡើងវិញនូវរូបភាពប្រតិបត្តិការរបស់ផលិតករ ។*
- ☐ *ការទូទាត់ក្រោមកម្មវិធីបរិស្ថាន ។*
- ☐ *ការទូទាត់ក្រោមកម្មវិធីជំនួយការថ្នាក់តំបន់ ។*

AMS ត្រូវបានគណនាលើមូលដ្ឋានផលិតផលនីមួយៗ ដោយប្រើប្រាស់ភាពខុសគ្នារវាងថ្លៃគោលខាងក្រៅជាមធ្យម ចំពោះផលិតផលមួយ និងថ្លៃចាត់ចែងអនុវត្តរបស់វាដោយគុណនឹងបរិមាណផលិតផលដែលបានផលិត ។ ដើម្បីឈានឱ្យដល់ AMS របបឧបត្ថម្ភធនក្នុងស្រុកចំពោះផលិតផលមិនជាក់លាក់មួយ ត្រូវបានបន្ថែមទៅលើរបបឧបត្ថម្ភសរុប ដែលបានគណនាលើមូលដ្ឋានផលិតផលនិមួយៗ ។

របបឧបត្ថម្ភធនបៃតង និងទៀវ ដែលបានអធិប្បាយពីខាងលើត្រូវបានលើកលែងពីការបញ្ចូលទៅក្នុង AMS ។ ជាងនេះទៅទៀតនៅពេលផ្តល់ការគាំទ្រចំពោះផលិតផលណាមួយតិចជាង ៥០ ភាគរយ នោះការចំណាយលើការឧបត្ថម្ភធន ចំពោះផលិតផលនោះត្រូវបានដាត់ចេញពីការសន្យាកាត់បន្ថយ ។ ដូចគ្នានេះដែរ របបឧបត្ថមធនក្នុងស្រុកនៃផលិតផលមិនជាក់លាក់ណាមួយ ត្រូវបានដាត់ចេញពីការគណនា ប្រសិនបើវាមិនលើសពី ៥០ ភាគរយ នៃតំលៃផលិតកម្មកសិកម្ម ។ ចំពោះប្រទេសកំពុងអភិវឌ្ឍន៍កំរិតភាគរយខាង បំផុតនេះគឺ ១០ ភាគរយ ។

ប្រទេសកំពុងអភិវឌ្ឍន៍ បានទទួលការអនុញ្ញាតិថែមទៀត ដើម្បីលើកទឹកចិត្តដល់ការអភិវឌ្ឍវិស័យកសិកម្ម និងការអភិវឌ្ឍន៍ជនបទឱ្យរួចផុតពីការគណនា AMS ហើយនិងរួចផុតពីការសន្យាកាត់បន្ថយចំពោះប្រការដូចខាងក្រោម ÷

- ☐ ការឧបត្ថម្ភធនសំរាប់ការវិនិយោគដែលជាទូទៅមានចំពោះវិស័យកសិកម្ម ។
- ☐ របបឧបត្ថម្ភធនវត្ថុធាតុដើម ដែលជាទូទៅមានចំពោះផលិតករមានចំណូលទាប និងមានប្រភពធនធានខ្សត់ខ្សោយ ។
- ☐ របបឧបត្ថម្ភធន ដើម្បីលើកទឹកចិត្តការធ្វើពហុភាពងាកចេញពីដំណាំគ្រឿងញៀន Narcotic ។

ប្រទេសទាំងឡាយត្រូវបានគេតំរូវឱ្យកាត់បន្ថយការគណនា AMS លើមូលដ្ឋានខាងលើតាមភាគរយណាមួយ តារាងលេខ ២ នៅក្នុងឧបសម្ព័ន្ធបង្ហាញអំពីការកាត់បន្ថយដែលចាំបាច់ត្រូវធ្វើឡើងចំពោះរបបគាំទ្រក្នុងស្រុក ដោយបណ្តាប្រទេសដែលបានធ្វើកិច្ចសន្យាពាក់ព័ន្ធដល់ការកាត់បន្ថយនេះ ។ ប្រទេសជឿនលឿនបានព្រមព្រៀងបន្ថយ AMS ២០ ភាគរយ ក្នុងរយៈពេល ៦ ឆ្នាំ (គិតចាប់ពីថ្ងៃ ០១ មករា ឆ្នាំ ១៩៩៥) ពីកំរិតមធ្យមដែលគេឈានដល់ក្នុងរយៈពេលមូលដ្ឋាន ១៩៨៦-១៩៨៨ ។ ប្រទេសកំពុងអភិវឌ្ឍន៍ត្រូវបានគេតំរូវឱ្យបន្ថយ AMS ចំនួន ១៣-១/៣ ភាគរយក្នុងអំឡុងពេល ១០ ឆ្នាំ ។ ដោយសារតែការសន្យាទាំងនេះ បរិមាណសរុបនៃ AMS ផ្តល់ឱ្យដោយបណ្តាប្រទេស ដែលបានធ្វើកិច្ចសន្យាទាំងនោះ រំពឹងថានឹងធ្លាក់ចុះពី ១៩៧-៧២១ លានដុល្លារអាមេរិកក្នុងរយៈពេល ១៩៨៦-១៩៨៨មកនៅត្រឹម ១៦២-៤៩៧ លានដុល្លារអាមេរិក នៅចុងដំណាក់ការនៃការអនុវត្តន៍។ (សូមមើលតារាងលេខ ២ ក្នុងឧបសម្ព័ន្ធនៃជំពូកនេះ) ។

ប្រការសន្តិភាព (Peace clause)

តាមបទបញ្ញត្តិទាំងឡាយនៃកិច្ចព្រមព្រៀង SCM ការនាំចូលផលិតផលឧស្សាហកម្ម និងផលិតផលកសិកម្ម ដែលបានទទួលរបបឧបត្ថម្ភធន អាចត្រូវស្ថិតជាកម្មវត្ថុនៃការកំណត់វិធានការពន្ធប៉ះប៉ូវ ដែលធ្វើឡើងដោយប្រទេសនាំចូល ប្រសិនបើការនាំចូលទាំងនោះ បង្កនូវការខូចខាតដល់ឧស្សាហកម្មក្នុងស្រុក ដែលផលិតផលិតផលដូចគ្នានេះ ។ ជាបន្ថែម កិច្ចព្រមព្រៀងបានផ្តល់លទ្ធភាពអោយប្រទេសណាមួយ ដែលយល់ឃើញថាផលប្រយោជន៍របស់ខ្លួន ទទួលរងនូវផលប៉ះពាល់ ដោយការអនុវត្តន៍របបឧបត្ថម្ភធនរបស់ប្រទេសមួយទៀត ធ្វើការប្រកួតប្រជែងចំពោះការអនុវត្តន៍របបឧបត្ថម្ភ ដោយលើកយកបញ្ហានោះទៅដោះស្រាយតាមនីតិវិធីដោះស្រាយវិវាទរបស់អង្គការពាណិជ្ជកម្មពិភពលោក ។

កិច្ចព្រមព្រៀងស្តីពីកសិកម្ម មាត្រា ១៣

លក្ខណៈពិសេសមួយចំនួនក្នុងចំណោមលក្ខណៈពិសេសជាច្រើនរបស់កិច្ចព្រមព្រៀងស្តីពីកសិកម្មបានចែងអំពីប្រការសន្តិភាព ។ ប្រការនេះ ការពារគោលនយោបាយឧបត្ថម្ភធនក្នុងស្រុក និងប្រភេទឧបត្ថម្ភធនសំរាប់ការនាំចេញមួយចំនួនពីសកម្មភាពដោះស្រាយវិវាទដែលធ្វើឡើងដោយប្រទេសមួយទៀតនៅថ្នាក់ជាតិ និងថ្នាក់ពហុភាគី ។

ជាទូទៅកិច្ចព្រមព្រៀងចែងថាផលិតផល ដែលទទួលអត្ថប្រយោជន៍ពីរបបឧបត្ថម្ភធនបៃតង ដែលស្របទាំងស្រុងទៅនឹងបទបញ្ញត្តិរបស់វា អាចជាឧបត្ថម្ភធនដែលមិនអាចប្តឹងបាន ចំពោះគោលបំណងនៃចំណាត់ការវិធានការប៉ះប៉ូវ ក៏ដូចជាការប្រឈមនៅក្នុង WTO តាមរយៈការប្រើប្រាស់នីតិវិធីដោះស្រាយវិវាទ ។

វិធានការគាំទ្រក្នុងស្រុក និងរបបឧបត្ថម្ភធនសំរាប់ការនាំចេញផ្សេងទៀត ដែលស្របជាមួយនឹងបទបញ្ញត្តិទាំងឡាយនៃកិច្ចព្រមព្រៀង អាចក្លាយជាកម្មវត្ថុនៃវិធានការកំណត់ពន្ធប៉ះប៉ូវ ប៉ុន្តែដោយសារការដាក់កំហិតក្នុងការអនុវត្តន៍វិធានការនេះ បណ្តាប្រទេសជាសមាជិកអាចផ្តួចផ្តើមធ្វើការស្រាវជ្រាវសិន មុននឹងអនុវត្តវិធានការនេះ ។ បទបញ្ញត្តិស្តីពី " ការដាក់កំហិតសមស្រប" មិនអាចអនុវត្តបានទៅលើការគាំទ្រក្នុងស្រុក ឬ កម្មវិធីរបបឧបត្ថម្ភធនសំរាប់ការនាំចេញ ដែលលើសពីការសន្យាកាត់បន្ថយទេ រដ្ឋាភិបាលអាចស្រាវជ្រាវរករបបឧបត្ថម្ភធនទាំងនេះ ដើម្បីមានវិធានការប៉ះប៉ូវ ។

ប្រទេសដែលនាំចូលស្បៀងសុទ្ធសាធ

កិច្ចព្រមព្រៀងស្តីពីកសិកម្ម មាត្រា១៦ ។ សេចក្តីសំរេចចិត្ត របស់អង្គប្រជុំថ្នាក់រដ្ឋមន្ត្រី ស្តីពីវិធានការទាក់ទងដល់ផលប៉ះពាល់អវិជ្ជមានដែលអាចកើតមាននៅក្នុងកម្មវិធីកំណែទំរង់ចំពោះប្រទេសក្រីក្រ និងប្រទេសកំពុងអភិវឌ្ឍន៍ដែលជាប្រទេសនាំចូលស្បៀងសុទ្ធសាធ

មុននឹងធ្វើសេចក្តីសេចក្តីសន្និដ្ឋានទៅលើទិដ្ឋភាពរួមនៃបទបញ្ញត្តិទាំងឡាយរបស់កិច្ចព្រមព្រៀង ជាសំខាន់ត្រូវកត់សំគាល់ ពីការផ្តល់ប្រយោជន៍ពិសេសដល់ប្រទេសកំពុងអភិវឌ្ឍន៍ ដែលជាប្រទេសនាំចូលស្បៀងសុទ្ធសាធ ។

កិច្ចព្រមព្រៀងទទួលស្គាល់ទៀតថា ការអនុវត្តន៍ ការសន្យាធ្វើសេរីភាវូបនីយកម្ម (ជាពិសេសការកាត់បន្ថយរបបឧបត្ថម្ភធន) អាចផ្តល់ផលបញ្ច្រាស់តបវិញ លើភាពសំបូរបែបនៃស្បៀងអាហារជាមូលដ្ឋាន ដោយសារការកាត់បន្ថយផលិតកម្មអតិរេក ។ ប្រការនេះអាចជះផលអវិជ្ជមានមកលើប្រទេសក្រីក្រ និងប្រទេសកំពុងអភិវឌ្ឍន៍ដែលជាអ្នកនាំចូលស្បៀងសុទ្ធសាធ ។

ដើម្បីបំបាត់ផលអវិជ្ជមានទាំងនេះគេបានព្រមព្រៀងថា ÷

- ☐ គួរផ្តួចផ្តើមចាត់ការ ដើម្បីធានាអោយមានការបង្កើនសមាមាត្រជំនួយស្បៀងជាមូលដ្ឋាន សំរាប់ប្រទេសទាំងនេះអោយបានពេញលេញ ។
- ☐ គួរផ្តល់ជំនួយការបច្ចេកទេស និងហិរញ្ញវត្ថុដល់ប្រទេសទាំងនេះ ដើម្បីកែលំអរផលិតភាពកសិកម្ម និងហេដ្ឋារចនាសម្ព័ន្ធរបស់គេ ។
- ☐ គួរចាត់វិធានការសមស្រប ដើម្បីលើកទឹកចិត្តស្ថាប័នហិរញ្ញវត្ថុទាំងឡាយ (ដូចជាIMF ធនាគារពិភពលោក) ឱ្យគិតគូរដល់មូលបទ ដើម្បីបង្កើតនូវមធ្យោបាយថ្មីៗ ឬ លើកកំពស់មធ្យោបាយដែលមានស្រាប់ ដើម្បីផ្តល់ជំនួយការដល់ប្រទេសទាំងនេះ ដោយជួយដល់ពួកគេក្នុងការប្រឈមមុខនឹងការលំបាកផ្នែកហិរញ្ញប្បទានចំពោះការនាំចូលពាណិជ្ជកម្ម ដែលជាលទ្ធផលនៃវិធានការសេរីភាវូបនីយកម្ម ដែលបានប្រកាន់យកក្នុងជំនួបឧរ៉ូហ្គាយ ។

ការពាក់ព័ន្ធផ្នែកពាណិជ្ជកម្ម និងការចរចានាពេលអនាគត

ផ្តើមចេញពីចំណុចពាណិជ្ជកម្ម សមិទ្ធិផលដ៏ចំបងនៃកម្មវិធីកំណែទំរង់ គឺការផ្តើមអនុវត្តបទបញ្ជា GATT-WTO ចំពោះពាណិជ្ជកម្មក្នុងវិស័យនេះ ។

កិច្ចព្រមព្រៀងស្តីពីកសិកម្ម មាត្រា ១៨

កិច្ចព្រមព្រៀងស្តីពីកសិកម្មចែងថា ការចរចាដើម្បធ្វើសេរីភាវូបនីយកម្មថែមទៀត ចំពោះពាណិជ្ជកម្មក្នុងវិស័យនេះ និងដើម្បីកែលំអរវិធានទាំងឡាយរបស់វាគួរតែត្រូវចាប់ផ្តើមមុនដំណាច់ឆ្នាំ ១៩៩៩ ។ ដើម្បីរៀបចំកិច្ចចរចាទាំងនេះ គណៈកម្មាធិការកសិកម្មបានចាប់ផ្តើមរួចមកហើយនូវដំណើរការវិភាគ និងផ្លាស់ប្តូរព័ត៌មានគ្នា ។ ក្នុងការពិភាក្សាទាំងនេះ គេបានលើកឡើងនូវសំណើមួយចំនួនអំពីជំហានដែលត្រូវប្រកាន់យកក្នុងការចរចាដែលរួមមានដូចតទៅ ÷

- ☐ ការអនុវត្តន៍បន្តនូវដំណើរការសេរីភាវូបនីយកម្ម ។
- ☐ ស្វែងរកដំណោះស្រាយចំពោះបញ្ហាប្រឈមមុខរបស់សហគ្រាសនាំចេញ ដោយសារការប្រើប្រាស់ប្រព័ន្ធផ្សេងៗ ដោយប្រទេសទាំងឡាយក្នុងការចាត់ចែងពន្ធកូតា ដែលកំណត់ដោយការអនុវត្តន៍នូវការសន្យាបើកច្រកទីផ្សារអប្បបរិមា និងការបើកច្រកទីផ្សារក្នុងពេលបច្ចុប្បន្ន ។
- ☐ ទាញការអនុវត្តន៍របស់អង្គភាពពាណិជ្ជកម្មរដ្ឋ ដែលពាក់ព័ន្ធក្នុងមុខជំនួញកសិផលឱ្យមកស្ថិតនៅក្រោមវិធាន GATT និង
- ☐ ធានាថាវិធានទាំងឡាយដែលអនុវត្តចំពោះពាណិជ្ជកម្មក្នុងវិស័យកសិកម្ម ត្រូវទទួលស្គាល់ភាពចាំបាច់របស់ប្រទេសទាំងឡាយហើយត្រូវមានទិន្នផលក្នុងស្រុកគ្រប់គ្រាន់ ដើម្បីធានាដល់សុវត្ថិភាពស្បៀង ។

ឧបសម្ព័ន្ធ

តារាង ១ **ការកាត់បន្ថយឧបត្ថម្ភធនលើការនាំចេញតាមប្រទេស ដែលចូលរួម (គិតជាលានដុល្លារអាមេរិក)**

ប្រទេសចូលរួម	ឧបត្ថម្ភធនលើការនាំចេញ			សមាសភាពផលិតផល នៃឧបត្ថម្ភធនលើការនាំចេញ
	តំបូង	ចុងក្រោយ	បំរែបំរួល	
European Union	13 274	8 496	-36	Bovine meat (19%), wheat (17%), coarse grains (13%), butter (13%), other milk products (10%)
Austria	1 235	790	-36	Live animals (45%), wheat (14%), bovine meat (13%), cheese (12%)
United States	929	594	-36	Wheat (61%), skim milk powder (14%)
Poland	774	493	-36	Meat preparations (39%), fruits and vegetables (21%)
Mexico	748	553	-26	Sugar (76%), cereal preparations (21%)
Finland	708	453	-36	Butter (25%), coarse grains (22%), other milk products (13%)
Sweden	572	366	-36	Pigmeat (21%), wheat (21%), coarse grains (17%)
Canada	567	363	-36	Wheat (47%), coarse grains (18%)
Switzerland	487	312	-36	Other dairy products (65%)
Colombia	371	287	-23	Rice (32%), cotton (20%), fruits and vegetables (23%)
South Africa	319	204	-36	Fruits and vegetables (24%), cereal preparations (14%), wheat (13%), sugar (10%)
Hungary	312	200	-36	Poultry meat (30%), pigmeat (26%), wheat (11%), fruits and vegetables (19%)
Czech Republic	164	105	-36	Other milk products (38%), fruits and vegetables (10%)
Turkey	157	98	-37	Fruits and vegetables (36%), wheat (23%)
New Zealand	133	0	-100	Not available
Norway	112	72	-36	Cheese (54%), pigmeat (19%), butter (12%)
Australia	107	69	-36	Other milk products (32%), skim milk powder (27%), cheese (25%), butter (16%)
Brazil	96	73	-24	Sugar (56%), fruits and vegetables (30%)
Slovak Republic	76	49	-36	Other dairy products (19%), cereal preparations (13%), bovine meat (13%)
Israel	56	43	-24	Fruits and vegetables (59%), plants (22%), cotton (17%)
Indonesia	28	22	-24	Rice (100%)
Iceland	25	16	-36	Sheep meat (78%), other dairy products (22%)
Cyprus	19	14	-24	Fruits and vegetables (67%), alcohol (16%)
Uruguay	2	1	-23	Rice (83%), butter (12%)

ប្រភព: WTO

១ ការសន្យានេះបានគិតទៅជាដុល្លារអាមេរិក តាមអត្រាប្តូររូបិយប័ណ្ណជាមធ្យម សំរាប់ឆ្នាំ១៩៩០/១៩៩១ ។ ការសន្យាការកាត់បន្ថយ អនុវត្តទៅលើប្រទេសផលិតផលនីមួយៗ ដូចមានកំណត់ក្នុងតារាងនេះ ។

ប្រទេសដែលបានចូលរួម បានដាក់ចេញនូវឯកសារឧបសម្ព័ន្ធរបស់គេ ហើយមិនរក្សាទុកនូវឧបត្ថម្ភធនលើការនាំចេញ រួមមានប្រទេស: Algeria, Antigua and Barbuda, Argentina, Bahrain, Barbados, Belize, Bolivia, Brunei Darussalam, Cameroon, Chile, Congo, Costa Rica, Côte d'Ivoire, Cuba, Dominica, Dominican Republic, Egypt, El Savador, Fiji, Gabon, Grenada, Gambia, Ghana, Guatemala, Guyana, Honduras, Hong Kong, (China), India, Jamaica, Japan, Kenya, Republic of Korea, Kuwait, Macau, Malaysia, Malta, Maurtius, Morocco, Namibia, Nicaragua, Nigeria, Pakistan, Paraguay, Peru, Philippines, Saint Kitts ans Nevis, Saint Lucia, Saint Vincent and the Grenadines, Senegal, Singapore, Sri Lanka, Suriname, Swazilanand, Thailand, Trinidad and Tobago, Tunisia, Zambia and Zimbabwe . បណ្តាប្រទេសក្រីក្រត្រូវបានលើកលែងពីតម្រូវការអោយធ្វើការកាត់បន្ថយឧបត្ថម្ភធនលើការនាំចេញ ។

តារាង ២ ការកាត់បន្ថយការគាំទ្រចំពោះផលិតករកសិកម្ម ដែលចូលរួម (គិតជាលានដុល្លាអាមេរិក)

ប្រទេសចូលរួម	តំបូង	ចុងក្រោយ	ការកាត់បន្ថយ %
Total	197 721	162 497	18
European Union	92 390	76 903	17
Japan	35 472	28 378	20
United States	23 879	19 103	20
Mexico	9 669	8 387	13
Canada	4 650	3 720	20
Finland	4 186	3 349	20
Poland	4 160	3 329	20
Republic of Korea	4 086	3 543	13
Switzerland	3 769	3 016	20
Sweden	3 429	2 743	20
Austria	2 534	2 027	20
Norway	2 247	1 797	20
Venezuela	1 305	1 131	13
Brazil	1 053	912	13
Thailand	866	745	13
Czech Republic	717	574	20
Israel	654	569	13
New Zealand	210	268	20
Hungary	613	490	20
Australia	460	368	20
Slovak Republic	435	348	20
Colombia	398	345	13
Iceland	222	177	20
Cyprus	127	110	13
Morocco	93	81	13
Tunisia	76	66	13
Costa Rica	18	16	13
South Africa	3	2	20

ប្រភព: WTO

* ឧបត្ថម្ភធនដែលបានផ្តល់ក្នុងឆ្នាំ ១៩៨៦ ដល់ ១៩៨៨

ជំពូក ១៦

លទ្ធផលនៃការចរចាបើកទីផ្សារ

សេចក្តីសង្ខេប

ជំពូកមុនបាននិយាយរៀបរាប់អំពីលក្ខណៈពិសេសៗ នៃការពង្រឹងប្រព័ន្ធច្បាប់ ដែលកំពុងយកមកអនុវត្តបច្ចុប្បន្នតាមGATT ១៩៩៤ លើការធ្វើពាណិជ្ជកម្មលើទំនិញ ។ ប្រព័ន្ធនេះមានគោលបំណងសំខាន់មួយ គឺជួយបណ្តាប្រទេសនានា អោយជំរុញការអភិវឌ្ឍន៍ផ្នែកសេដ្ឋកិច្ចរបស់គេ តាមរយៈការបង្កើនពាណិជ្ជកម្ម ដោយការលប់ចោលពន្ធគយ និងរបាំងពាណិជ្ជកម្មផ្សេងៗទៀតចេញ ក្នុងពេលចរចាជាមួយបណ្តាប្រទេសជាសមាជិកនៃអង្គការនេះ ។

មានការចរចាកុម្មុលចំនួន ប្រាំពីរ ផង មុនពេលសម័យប្រជុំឃ្លូរ៉ុយហ្គាយ ហើយបណ្តាប្រទេសជឿនលឿនបានធ្វើការកាត់បន្ថយតារាងពន្ធគយដែលមានទៅលើផលិតផលឧស្សាហកម្ម យ៉ាងច្រើនគួរអោយកត់សំគាល់ ។ តែទោះជាយ៉ាងណាក៏ដោយ ដូចដែលជំពូកមុនបានកត់សំគាល់ថា បណ្តាប្រទេសជឿនលឿនធ្វើអោយមានការវិវត្តន៍តិចតួចប៉ុណ្ណោះ ក្នុងការលប់ចោលការដាក់កំហិតលើបរិមាណ និងវិធានការមិនជាប់ពន្ធគយផ្សេងទៀត ដែលមានទៅលើការនាំចូល ។ ឧទាហរណ៍ ក្នុងផ្នែកឧស្សាហកម្ម ការដាក់កំហិតលើបរិមាណដែលមានភាពរើសអើងរបស់បណ្តាប្រទេសជឿនលឿន ទៅលើការនាំចូលផលិតផលវាយនភ័ណ្ឌ និងសំលៀកបំពាក់ នៅមានអនុវត្តបន្តទៀត តាមកិច្ចព្រមព្រៀងពហុភាគីស្តីពីផលិតផលវាយនភ័ណ្ឌ ។ ការប្រជុំកុម្មុលមិនបានកំណត់អោយបាន ពុំធើកគាល់នយោបាយដែលគាំពារដល់វិស័យកសិកម្ម ដែលបណ្តាប្រទេសជឿនលឿនមួយចំនួនបានអនុវត្តតាម ហើយដែលគេស្ទើរតែបិទទីផ្សាររបស់គេ មិនអោយមានការនាំចូលប្រកបដោយភាពប្រកួតប្រជែង ។ ជាងនេះទៅទៀត គេមិនបានធ្វើការកែប្រែគោលនយោបាយរបស់គេ ស្តីអំពីការជួយប៉ះប៉ូវលើការនាំចេញផលិតផលកសិកម្ម ដែលជាហេតុធ្វើអោយមានផលប៉ះពាល់ដល់លក្ខខណ្ឌនៃការប្រកួតប្រជែងនៅក្នុងការធ្វើពាណិជ្ជកម្មអន្តរជាតិ ។

ការចរចាបើកទីផ្សារនៅក្នុងឃ្លូរ៉ុយហ្គាយ បានកែលំអស្ថានភាពយ៉ាងច្រើន។ លក្ខណៈពិសេសៗ នៃការចរចាឃ្លូរ៉ុយហ្គាយ មានរៀបរាប់សង្ខេបដូចតទៅ ÷

- ☐ *បណ្តាប្រទេសដែលកាត់បន្ថយតារាងពន្ធគយ បានសន្យាថានឹងកាត់បន្ថយពន្ធគយទៅលើផលិតផលឧស្សាហកម្មអោយបានច្រើន និងខ្ពស់ជាងតារាងពន្ធដែលបានកាត់បន្ថយក្នុងពេលប្រជុំកុម្មុលលើកមុននៅតូក្យូ ។*
- ☐ *ដោយការអនុម័តកិច្ចព្រមព្រៀងស្តីពីវាយនភ័ណ្ឌ និងសំលៀកបំពាក់ បណ្តាប្រទេសនានា យល់ព្រមលប់ចោលនូវការដាក់កំហិតលើបរិមាណដែលមានតាមកិច្ចព្រមព្រៀងពហុភាគីសរសៃអំបោះ (Multi-Fibre Arrangement) នៅក្នុងរយៈពេល ១០ ឆ្នាំ មានន័យថា មុនថ្ងៃទី ១ ខែ មករា ឆ្នាំ ២០០៥ ។*
- ☐ *កិច្ចព្រមព្រៀងស្តីពីកសិកម្ម បានបង្កើតអោយមានគំរោងការងារមួយសំរាប់ការធ្វើពាណិជ្ជកម្មលើផលិតផលកសិកម្មបន្តិចម្តងៗ តាមគោលការណ៍របស់GATT និងដើម្បីធ្វើសេរីភាវូបនីយកម្មពាណិជ្ជកម្មនៅក្នុងវិស័យនេះ ។*
- ☐ *បណ្តាប្រទេសកំពុងអភិវឌ្ឍន៍ និងបណ្តាប្រទេសដែលមានសេដ្ឋកិច្ចអន្តរកាល បានចូលរួមយ៉ាងសកម្មនៅក្នុងការចរចា ហើយបានកាត់បន្ថយអត្រាពន្ធរបស់គេទាំងទៅលើផលិតផលកសិកម្ម និងផលិតផលឧស្សាហកម្ម ។*

- *អត្រាពន្ធគយភាគច្រើនរបស់បណ្តាប្រទេសជឿនលឿន បាននឹងកំពុងតែមានប្រសិទ្ធិភាពកើនឡើងនៅក្នុងសេដ្ឋកិច្ចរបស់បណ្តាប្រទេសកំពុងអភិវឌ្ឍន៍ និងរបស់ប្រទេសដែលមានសេដ្ឋកិច្ចអន្តរកាល ហើយសមាមាត្រនៃអត្រាពន្ធគយ ដែលមានប្រសិទ្ធិភាពនោះបានកើនឡើងគួរអោយកត់សំគាល់ ។*

បន្ទាប់ពីបានបញ្ចប់កិច្ចប្រជុំនៅយូរ៉ុយហ្គាយ កិច្ចដំណើការសេរីភាវូបនីយកម្មបានដំណើរការឡើងថែមទៀត តាមរយៈការចរចាស្តីពីកិច្ចព្រមព្រៀងលើបច្ចេកវិទ្យាពត៌មាន ដែលចែងពីការលប់បំបាត់បន្តិចម្តងៗ នូវតារាងពន្ធគយលើផលិតផលបច្ចេកវិទ្យាពត៌មានជាង ៤០០ មុខ ។

ប្រព័ន្ធ GATT/WTO ដែលបានចូលជាធរមាន អស់រយៈពេល ៥០ឆ្នាំ កន្លងមកនេះ បានបង្ហាញអោយឃើញពីការកែលំអបន្តិចម្តងៗ នូវការបើកទីផ្សារនាំចូល តាមរយៈការដកចេញ ឬ លប់បំបាត់ដោយបណ្តាប្រទេសជាសមាជិក នូវរបាំងពាណិជ្ជកម្មនៅក្នុងពេលចរចាតុមូលពហុភាគីលើផ្នែកពាណិជ្ជកម្មទាំង ៨ លើកនេះ ។ ជំពូកនេះ ជាដំបូងនឹងរៀបរាប់ពីការវិវត្តន៍ ដែលកើតមានឡើងនៅក្នុងពេលប្រជុំតុមូលចុងក្រោយនេះ គឺការចរចាផ្នែកពាណិជ្ជកម្មនៅយូរ៉ុយហ្គាយ ។ ពេលនោះ គេបានផ្តល់ការយកចិត្តទុកដាក់ទៅលើការចរចាផ្នែកពាណិជ្ជកម្ម ដែលកើតមាននៅក្នុងវិស័យមួយចំនួននៃការធ្វើពាណិជ្ជកម្មទៅលើទំនិញ បន្ទាប់ពីបានបញ្ចប់កិច្ចចរចានៅយូរ៉ុយហ្គាយ មក ។ ជំពូកនេះនឹងធ្វើការសន្និដ្ឋានដោយគូសបញ្ជាក់ពីដំណាក់កាល ដែលអាជីវករអាចទទួលយកនូវបាននូវអត្ថប្រយោជន៍ពីវិធានការសេរីភាវូបនីយកម្មនេះ ។

ការចរចាពាណិជ្ជកម្មនៅយូរ៉ុយហ្គាយ

ផលិតផលឧស្សាហកម្ម

ការកាត់បន្ថយពន្ធគយ

ជាលទ្ធផលនៃការចរចាដែលធ្វើឡើងមុនកិច្ចប្រជុំយូរ៉ុយហ្គាយ បានបង្ហាញអោយឃើញថា កំរិតពន្ធគយជាមធ្យមក្នុងបណ្តាប្រទេសជឿនលឿន បានធ្លាក់ចុះប្រហែលពី ៤០ភាគរយ មកនៅ ១០ភាគរយ ។ កំរិតមធ្យមភាគនេះ ត្រូវបានកាត់បន្ថយបន្ថែមទៀតក្នុងកិច្ចប្រជុំយូរ៉ុយហ្គាយ មកនៅត្រឹម ៤០ភាគរយ ។ ប្រទេសដែលមានប្រព័ន្ធសេដ្ឋកិច្ចអន្តរកាល និងប្រទេសកំពុងអភិវឌ្ឍន៍ ក៏កាត់បន្ថយពន្ធគយរបស់ខ្លួនផងដែរ ប៉ុន្តែត្រឹមតែ ៣០ ភាគរយប៉ុណ្ណោះ។ មានតែប្រទេសក្រីក្រប៉ុណ្ណោះ ដែលមិនតំរូវអោយកាត់បន្ថយពន្ធគយរបស់ខ្លួនជាភាគរយ ប៉ុន្តែបានលើកទឹកចិត្តអោយផ្តល់សម្បទានតិចតួច ដោយតំរូវអោយកាត់បន្ថយពន្ធគយលើផលិតផលមួយចំនួន។ រាល់ការកាត់បន្ថយពន្ធគយទាំងនេះ លើកលែងតែប្រទេស ជឿនលឿនមួយចំនួនតូចប៉ុណ្ណោះ ត្រូវបានធ្វើឡើងជាប្រាំតំណាក់កាលស្មើៗគ្នា ដើម្បីឈានដល់អត្រាឯកភាពចុងក្រោយតាមកំរិតខ្សែចង្វាក់ពន្ធគយ ដែលត្រូវអនុវត្តនៅត្រឹមថ្ងៃទី១ ខែមករា ឆ្នាំ១៩៩៩។

ជាបន្ថែម បណ្តាប្រទេសជឿនលឿន និងប្រទេសកំពុងអភិវឌ្ឍន៍មួយចំនួន ក៏បានឯកភាពផងដែរនៅក្នុងកិច្ចប្រជុំយូរ៉ុយហ្គាយ ដើម្បីលុបបំបាត់ពន្ធគយទាំងអស់ អោយស្ថិតក្នុងផ្នែកជាក់លាក់ ដែលគេហៅថា zero-for-zero sectors ។ ផ្នែកនេះរួមមាន ឱសថ សំភារៈបរិក្ខា កសិកម្ម គ្រឿងសំណង់ ថ្នាំពេទ្យ គ្រឿងសង្ហារឹម ក្រដាស ដែកថែប និងគ្រឿងក្មេងលេង ។ ជាលទ្ធផលដែលទទួលបានមកពី សម្បទាននេះ និងសម្បទានផ្សេងៗទៀត សមាមាត្រនៃផលិតផលឧស្សាហកម្មដែលហូរចូលទៅក្នុងទីផ្សារប្រទេសជឿនលឿន តាមមូលដ្ឋានរូបពន្ធ MFN សង្ឃឹមថានឹងកើនឡើងទ្វេពី ២២ភាគរយ ទៅ ៤៤ភាគរយ ។ កំរិតមធ្យមភាគល្មៀងនៃពន្ធគយ ដែលអនុវត្តចំពោះផលិតផលឧស្សាហកម្មធ្លាក់ចុះពី ÷

- ៦.៣ភាគរយ មកនៅ ៣.៨ភាគរយ ក្នុងប្រទេសជឿនលឿន
- ១៥.៣ភាគរយ មកនៅ ១២.៣ភាគរយ ក្នុងប្រទេសកំពុងអភិវឌ្ឍន៍ និង
- ៨.៦ភាគរយ មកនៅ ៦ភាគរយ ក្នុងប្រទេសដែលមានប្រព័ន្ធសេដ្ឋកិច្ចអន្តរកាល ។

នៅពេលដែលដំណើរការកាត់បន្ថយពន្ធគយតាមតំណាក់កាលដែលបានឯកភាពក្នុងយូរ៉ុយហ្គាយបានបញ្ចប់ ។

អត្រាពន្ធគយដែលមានប្រសិទ្ធិភាពចងភ្ជាប់ ***(Binding of tariff)***

ទិដ្ឋភាពនៃការចរចាដ៏សំខាន់មួយផ្សេងទៀតគឺ ដំណើរការដែលបានធ្វើឡើងក្នុងការចងភ្ជាប់ពន្ធគយ ។ ជាការពិតណាស់ រាល់ការនាំចូលផលិតផលទៅកាន់ប្រទេសជឿនលឿន ទាំងផលិតផលឧស្សាហកម្ម និងកសិកម្ម ឥឡូវនេះស្ថិតក្រោមអត្រា: សមាមាត្រសំរាប់ប្រទេសកំពុងអភិវឌ្ឍន៍ និងប្រទេសប្រព័ន្ធសេដ្ឋកិច្ចអន្តរកាល គឺ ៧៣ភាគរយ និង ៩៨ភាគរយ។ អត្ថប្រយោជន៍ដ៏ចំបងមួយនៃអត្ថប្រយោជន៍ជាច្រើនក្នុងការចងសម្ព័ន្ធនេះ គឺសុវត្ថិភាពនៃការបើកច្រកទីផ្សារបរទេស។ សហគ្រាសនានា អាចរៀបចំគំរោងការអភិវឌ្ឍន៍ពាណិជ្ជកម្មរបស់ខ្លួន ដោយមិនព្រួយបារម្ភពីពន្ធដែលកំពុងតែកើនឡើង ឬ លែងព្រួយពីការបើកច្រកចូលទីផ្សារដែលបាននិងកំពុងតែដាក់កំហិតដោយការកំរិតលើបរិមាណ ។

លប់ចោលការដាក់កំហិតលើបរិមាណ

សារៈសំខាន់ដូចគ្នាដែលកើតចេញពីចំណុចនៃការបង្កើតឱកាសពាណិជ្ជកម្ម គឺបទបញ្ញត្តិដែលធ្វើអោយលែងមានការដាក់កំហិតលើបរិមាណ ចំពោះផលិតផលឧស្សាហកម្ម ។ ដូចបានគូសបញ្ជាក់ក្នុងជំពូកទី ១៤ រួចមកហើយ កិច្ចព្រមព្រៀងស្តីពីវាយនភ័ណ្ឌ និងសំលៀកបំពាក់ កំណត់នូវដំណាក់កាលបួន សំរាប់លុបបំបាត់ការដាក់កំហិតលើវាយនភ័ណ្ឌ និងសំលៀកបំពាក់ នៅត្រឹមថ្ងៃទី១ ខែមករា ឆ្នាំ២០០៥ ។ កិច្ចព្រមព្រៀងស្តីពីវិធានការការពារ តំរូវអោយប្រទេសទាំងឡាយគ្រប់គ្រងការនាំចេញ និងអនុវត្តវិធានការទាំងឡាយ ដើម្បីលុបបំបាត់ការដាក់កំហិតនេះ នៅត្រឹមថ្ងៃទី១ ខែមករា ឆ្នាំ២០០០ ។

ផលិតផលកសិកម្ម

វិស័យកសិកម្ម ដូចមានចែងក្នុងជំពូកទី ១៥ មានការវិវត្តន៍គួរអោយកត់សំគាល់ ដើម្បីធានាដល់សេរីភាវូបនីយកម្មពាណិជ្ជកម្មដោយ÷

- ☐ ការលុបបំបាត់វិធានការមិនមែនពន្ធគយ តាមរយៈការយកពន្ធគយ
- ☐ ការចងអត្រាពន្ធគយ តទល់នឹងការកើនឡើងថែមទៀត
- ☐ ការកាត់បន្ថយការកំណត់ពន្ធគយអោយនៅត្រឹម ៣៦ភាគរយ ក្នុងប្រទេសជឿនលឿន និង ២៤ភាគរយ ក្នុងប្រទេសកំពុងអភិវឌ្ឍន៍
- ☐ ការបើកច្រកទីផ្សារបច្ចុប្បន្ន និងការសន្យាបើកច្រកទីផ្សារអប្បបរមា
- ☐ ការសន្យាកាត់បន្ថយតាមភាគរយនូវតំលៃ និងកំរិតនៃការឧបត្ថម្ភសំរាប់នាំចេញ
- ☐ សន្យាកាត់បន្ថយតាមភាគរយសំរាប់ជំនួយឧបត្ថម្ភក្នុងស្រុក តាមវិធានការនៃការជួយឧបត្ថម្ភទូទៅ ។

ការចរចារក្រោយកិច្ចប្រជុំកុម្មូលនៅយូរ៉ុយហ្គាយ

ការចរចាក្នុងវិស័យពីរទាក់ទិនដល់ការធ្វើពាណិជ្ជកម្ម ទំនិញបានកើតមានឡើងតាំងពីក្រោយកិច្ចប្រជុំកុម្មូលនៅយូរ៉ុយហ្គាយមកម្លេះ។ ក្រោមសេចក្តីប្រកាសអន្តរក្រសួង ស្តីពីការធ្វើពាណិជ្ជកម្មផលិតផលពត៌មានវិទ្យា (ដែលគេស្គាល់ថា ជាកិច្ចព្រមព្រៀងពត៌មានវិទ្យា "ITA") ដែលបានអនុម័តនៅឯសន្និសីទថ្នាក់រដ្ឋមន្ត្រីនៅប្រទេសសិង្ហបុរី (Singapore Ministerial Conference) ប្រទេសដែលជាសមាជិករបស់អង្គការជាច្រើន បានឯកភាពកាប់បន្ថយពន្ធគយអោយនៅត្រឹមសូន្យភាគរយ លើផលិតផលនេះ ដូចជា កុំព្យូទ័រ សំភារៈបរិក្ខាទូរគមនាគមន៍ semiconductor, semiconductor manufacturing equipment គ្រឿងទន់ និងបរិធានដែលមានលក្ខណៈវិទ្យាសាស្ត្រ ។ ខែមេសា ឆ្នាំ១៩៩៩ ITA មានសិក្ខាកាមចំនួន ៣១ប្រទេស (មានវិសាលភាពគ្របដណ្តប់លើសមាជិក និងរដ្ឋចំនួន ៤៦ ឬ ដែនដី ក្នុងដំណើរការនៃការចូលជាសមាជិកអង្គការ WTO) ។ ប្រទេសដែលជាសមាជិកដែលមានវត្តមាន បានគិតគូរពិចារណាលើលទ្ធភាពនៃការពង្រីកវិសាលភាពផលិតផលពត៌មានវិទ្យា ។

បណ្តាប្រទេសដែលពាក់ព័ន្ធក្នុងការធ្វើពាណិជ្ជកម្មផលិតផលឱសថ ក៏បានឯកភាពគ្នាផងដែរ ដាក់បន្ថែមផលិតផលចំនួន ៤៥០មុខ ចូលទៅក្នុងបញ្ជីផលិតផលនៃកិច្ចប្រជុំតុមូលនៅយូរ៉ុយហ្គាយ ដោយសំរេចដកពន្ធគយ zero-for-zero ចេញ ។

វាមានសារៈសំខាន់ណាស់ ទោះបីជាប្រទេសមួយចំនួនបានចរចាលុបបំបាត់ពន្ធគយលើផលិតផលពត៌មានវិទ្យា និងឱសថក៏ដោយ ក៏នៅតែធ្វើសម្បទានតាមមូលដ្ឋាន MFN ដល់ប្រទេសទាំងអស់ ។

ការវាយតំលៃលើផលប្រយោជន៍ ដែលបានមកពីការធ្វើសេរីភាវូបនីយកម្មនៅយូរ៉ុយហ្គាយ

តាមទស្សនៈរបស់សហគ្រាសពាណិជ្ជកម្ម ដែលធ្វើសេចក្តីសំរេចលើយុទ្ធសាស្ត្រទីផ្សារ ជាកត្តាសំខាន់ គេត្រូវដឹងពីផលចំណេញ-ជាប្រាក់ចំណូល និងពាណិជ្ជកម្ម - ដែលបានមកពីវិធានសេរីភាវូបនីយកម្ម ។

WTO អង្គការអន្តរជាតិ និងវិទ្យាស្ថានស្រាវជ្រាវ បានធ្វើការសិក្សាលើម៉ាក្រូសេដ្ឋកិច្ច ដើម្បីវាយតំលៃពីផលប៉ះពាល់ដល់ពាណិជ្ជកម្មពិភពលោក និងប្រាក់ចំណូលពិភពលោក ដែលកើតឡើងដោយការអនុវត្តន៍ការសន្យារបស់កិច្ចប្រជុំតុមូលនៅយូរ៉ុយហ្គាយ ។

ការទទួលបានប្រាក់ចំណូល និងពាណិជ្ជកម្មៈ ការប៉ាន់ស្មាន និងតថភាព

ការប៉ាន់ស្មាន

និយាយជាទូទៅ ការសិក្សានេះបានប៉ាន់ស្មានថា ប្រសិនបើមានការអនុវត្តន៍អោយបានពេញលេញ នូវវិធានការសេរីភាវូបនីយកម្មដែលរដ្ឋទាំងអស់បានឯកភាព នោះនឹងធ្វើអោយប្រាក់ចំណូលពិភពលោកកើនឡើង ១ភាគរយ ក្នុងមួយឆ្នាំ ឬ មានតំលៃជាប្រាក់ចន្លោះពី ២០០កោដិ ដុល្លា ទៅ ៥០០កោដិ ដុល្លា ជារៀងរាល់ឆ្នាំ ។ កំរិតពាណិជ្ជកម្មពិភពលោក នឹងកើនឡើង ៦ ភាគរយ ទៅ ២០ ភាគរយរៀងរាល់ឆ្នាំ ដោយផ្អែកលើការសន្និដ្ឋាន ដែលការសិក្សានេះបានធ្វើឡើង ។ អត្រាកំណើននេះ នឹងកើនឡើងជាប្រចាំឆ្នាំគឺ ៤ ភាគរយ នៅក្នុងផ្នែកពាណិជ្ជកម្មពិភពលោក ហើយដែលរំពឹងថានឹងកើតមានឡើង ទោះបីមិនមានការអនុវត្តន៍លទ្ធផលនៃយូរ៉ុយហ្គាយក៏ដោយ ។

មានការរំពឹងថា ផលចំណេញច្រើនជាងមួយភាគបីនឹងបានមកពីការលប់ចេញនូវការដាក់កំហិតលើបរិមាណនៃការនាំចូលផលិតផលវាយនភ័ណ្ឌ និងសំលៀកបំពាក់ ហើយមួយភាគបីទៀត បានមកពីរបបសេរីភាវូបនីយកម្មលើផលិតផលឧស្សាហកម្មផ្សេងៗទៀត។ ផលិតផលកសិកម្ម រំពឹងថានឹងមានចំណែកពី ១០ ទៅ ៣០ ភាគរយ ។

ក៏ប៉ុន្តែ បណ្តាប្រទេសទាំងអស់មិនអាចទទួលបាននូវផលចំណេញទាំងនេះអោយបានស្មើៗគ្នានោះទេ ។ បណ្តាប្រទេសដែលរំពឹងថាបានទទួលផលប្រយោជន៍ច្រើនជាងគេ គឺបណ្តាប្រទេសជឿនលឿន បណ្តាប្រទេសកំពុងអភិវឌ្ឍន៍ដែលឈានដល់ដំណាក់កាលអភិវឌ្ឍន៍ខ្ពស់ និងបណ្តាប្រទេសដែលការនាំចេញផលិតផលវាយនភ័ណ្ឌរបស់គេស្ថិតនៅក្រោមការដាក់កំហិត ។ បណ្តាប្រទេសនៅអាហ្វ្រិក និងបណ្តាប្រទេសក្រីក្រ អាចទទួលបានផលប្រយោជន៍មានកំណត់បំផុតពីវិធានការសេរីភាវូបនីយកម្មនេះ ។

តថភាព

បច្ចុប្បន្ន ការវិភាគភាគច្រើន ប៉ាន់ស្មានថា ការទទួលបានប្រាក់ចំណូល និងផលប្រយោជន៍ពាណិជ្ជកម្ម អាចមានតិចជាងអ្វីដែលបានរំពឹងទុក ។ បណ្តាបញ្ហាដែលបានកំណត់ដោយវិធីសាស្ត្រនៃការវាយតំលៃ និងដោយកត្តាមួយចំនួន ដែលជាក់ស្តែងមិនអាចវាយតំលៃបានដោយងាយស្រួលនោះ គឺជាមូលហេតុមួយ ។ មូលហេតុដែលមានសារៈសំខាន់មួយទៀត គឺបរាជ័យនៃការសន្និដ្ឋានជាមូលដ្ឋានចំនួនពីរ ពីដំណើរការជាក់ស្តែង ។

ទីមួយ ក្នុងការវាយតំលៃ អ្នកវិភាគបានសន្និដ្ឋានថា បណ្តាប្រទេសនានាបានបំពេញការសន្យារបស់គេបានយ៉ាងពេញលេញ ដូចជាមិនមែនក្នុងន័យនៃសេចក្តីថ្លែងការណ៍ទេ ប៉ុន្តែក្នុងស្មារតីដែលគេបានធ្វើការសន្យានោះ ។ ការសន្និដ្ឋាននេះ មិនមែនកើតឡើងពីកត្តាជាក់

ស្តែងទេ តែបានងាកទៅរកការបំពេញការសន្យាកន្លងមកច្រើនគួរអោយកត់សំគាល់នៅក្នុងកត្តាពីរ គឺវាយនភ័ណ្ឌ និងផលិតផលកសិកម្ម ដែលក្នុងនោះគេរំពឹងថានឹងបានទទួលផលប្រយោជន៍ច្រើនពីវិធានការសេរីភាវូបនីយកម្មនេះ ។

ទាក់ទងទៅនឹងផលិតផលវាយនភ័ណ្ឌ ដូចដែលមានលើកឡើងនៅក្នុងជំពូក ១៤ បណ្តាប្រទេសជឿនលឿន ដែលនៅរក្សាការដាក់កំហិតលើបរិមាណ មានលទ្ធភាពអនុវត្តដំណាក់កាលពីរដំបូង ដោយមិនចាំបាច់ធ្វើការកាត់បន្ថយការដាក់កំហិតលើការនាំចូលជាធំដុំនោះឡើយ ។ គេធ្វើដូច្នេះ ដោយទាញយកអត្ថប្រយោជន៍ពីលទ្ធភាពដែលអាចបត់បែនបាន ហើយដែលមានតាមបទបញ្ញត្តិដែលពាក់ព័ន្ធទៅនឹងកិច្ចព្រមព្រៀងស្តីពីវាយនភណ្ឌ័ និងសំលៀកបំពាក់ ។ ជាលទ្ធផល មានការបង្ហាញអោយឃើញច្បាស់ថា ការដាក់កំហិតលើបរិមាណធំដុំនេះ អាចដកចេញបានតែនៅក្នុងដំណាក់កាលចុងក្រោយតែប៉ុណ្ណោះ ឬ នៅថ្ងៃ (ទី ១ ខែ មករា ឆ្នាំ ២០០៥) ដែលកិច្ចព្រមព្រៀងត្រូវបញ្ចប់ ។ យើងនៅតែមានភាពជឿជាក់ពីការកើនឡើងយ៉ាងច្រើននៃផ្នែកពាណិជ្ជកម្មវាយនភ័ណ្ឌនៅក្នុងរយៈពេលអន្តរកាលយ៉ាងយូរបំផុត ១០ ឆ្នាំ ។

ក្នុងវិស័យកសិកម្ម ប្រទេសកំពុងអភិវឌ្ឍន៍ (និងជាពិសេសប្រទេសក្រីក្រ) បានទទួលផលប្រយោជន៍ពីការនាំចេញ ផលិតផលផ្លែឈើនៃតំបន់ត្រូពិក ទៅកាន់ទីផ្សាររបស់បណ្តាប្រទេសជឿនលឿន ដោយមិនមានបង់ពន្ធ ឬ មានជាប់ពន្ធទាបតាម MFN ឬ តាមមូលដ្ឋានដែលផ្តល់ភាពអនុគ្រោះ មុនពេលចាប់ផ្តើមយូរ៉ុយហ្គាយទៅទៀត ។ បន្ទាប់មក ការកាត់បន្ថយបន្ថែមអាចមានឥទ្ធិពលទៅលើការធ្វើពាណិជ្ជកម្មនៃផលិតផលទាំងនេះ ។ ចំពោះ ផលិតផលកសិកម្មនៃតំបន់ដែលមានសីតុណ្ហភាពល្មម ដូចជា ស្រូវសំឡី និងម្សៅ ឥឡូវហាក់ដូចជាបង្ហាញអោយឃើញថា ពេលខ្លះ ការគណនាតារាងពន្ធគយមានតំលៃស្មើ ឬ ពេលខ្លះមានការវាយតំលៃលើសពីការកើតមាននូវវិធានការដែលមិនគិតពន្ធគយ (ជារឿយៗ បញ្ហានេះសំដៅទៅលើ "dirty tariffication) ។ លទ្ធផលបង្ហាញអោយឃើញថា សំរាប់ផលិតផលមួយចំនួន កំរិតនៃការគាំពារដែលបានផ្តល់អោយ ដោយអត្រាពន្ធគយថ្មី បន្ទាប់ពីកាត់បន្ថយ ត្រូវបានធ្វើឡើង អាចចាត់ទុកថាមានលក្ខណៈខ្ពស់ជាងច្រើនពីកំរិតនៃការគាំពារ ដែលមានកន្លងមក ។

អ្នកវិភាគបានធ្វើសេចក្តីសន្និដ្ឋានទីពីរថា សេដ្ឋកិច្ចពិភពលោកនឹងបន្តកើនឡើងគ្រប់ជំហាន និងមិនអាចមានការថយចុះណាមួយនៅក្នុងកំណើនសេដ្ឋកិច្ច និងពាណិជ្ជកម្មឡើយ ។ ក្តីរំពឹងនេះ ត្រូវទទួលបរាជ័យដោយសារវិបត្តិសេដ្ឋកិច្ចហិរញ្ញវត្ថុនៅអាស៊ីដែលបានចាប់ផ្តើមឡើងក្នុងពាក់កណ្តាលឆ្នាំ ១៩៩៧ ដោយសារសេដ្ឋកិច្ចអន់ថយរបស់ជប៉ុន និងដោយសារបរាជ័យផ្នែកសេដ្ឋកិច្ចរបស់រុស្ស៊ី ដែលទើបចាប់ផ្តើមសារជាថ្មីនាឆ្នាំ ១៩៩៨ ។ បច្ចុប្បន្នមានការយល់ច្បាស់ថា ដោយមានការកាត់បន្ថយជាបន្តបន្ទាប់នូវកំណើនសេដ្ឋកិច្ច ធ្វើអោយមានការថយចុះជារួមនៃតំលៃពាណិជ្ជកម្មពិភពលោក សំរាប់រយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ និងអាចយូរជាងនេះ ដោយសារកង្វះខាតតំរូវការនៅទីផ្សារអាស៊ី និងមានការថយចុះជារួមនៃតំលៃប្រេង និងតំលៃទំនិញផ្សេងៗទៀត។

ការពាក់ព័ន្ធផ្នែកពាណិជ្ជកម្ម

ផលប៉ះពាល់ផ្សេងៗ ទៅលើការនាំចេញពីបណ្តាប្រទេសនានា

ដូច្នេះ យើងយល់ច្បាស់ថា ផលចំណេញ និងប្រាក់ចំណូលដែលទទួលបានមកពីពាណិជ្ជកម្ម អាចមានតិចជាអ្វីដែលបានប៉ាន់ស្មាននៅក្នុងការសិក្សាផ្នែកម៉ាក្រូសេដ្ឋកិច្ច ហើយផលចំណេញខ្លះត្រូវបានទុកជាមោឃៈ ដោយសារតែសេដ្ឋកិច្ចពិភពលោកបានធ្លាក់ចុះនាពេលថ្មីៗនេះ ។ ក្រៅពីនេះ ការសន្យាទៅលើផលិតផលមួយចំនួន យ៉ាងហោចណាស់អាចទទួលរងនូវផលប៉ះពាល់ផ្សេងៗដែលមានទៅលើពាណិជ្ជកម្មនាំចេញរបស់ប្រទេសនីមួយៗ ។ ដូច្នេះបណ្តាប្រទេសជឿនលឿន ដែលបើកទីផ្សារប្រកបដោយភាពអនុគ្រោះ សំរាប់ទីផ្សារនាំចូលដ៏ជឿនលឿនបំផុតរបស់គេ អាចមើលឃើញថា កំរិតនៃភាពអនុគ្រោះទៅលើផលិតផលនាំចេញរបស់គេត្រូវបានកាត់បន្ថយ ដោយសារតែមានការកាត់បន្ថយនៅក្នុងអត្រាពន្ធ MFN ។ លទ្ធភាពទទួលរងនូវផលប៉ះពាល់ អាស្រ័យថាតើការបើកទីផ្សារដោយភាពអនុគ្រោះនោះមានន័យយ៉ាងណានៅក្នុងល័ក្ខខ័ណ្ឌពាណិជ្ជកម្ម ដោយពិចារណាទៅលើកត្តា ដូចជាតំលៃ និងគុណភាពផលិតផល ។ សំរាប់ផលិតផលវាយនភ័ណ្ឌ នៅពេលដែលមានការដាក់កំហិតដោយបរេ លើមូលដ្ឋានរើសអើង ផលប៉ះពាល់នៃការដកការដាក់កំហិតនេះអាចមានលក្ខណៈប្រែប្រួលខុសៗគ្នា សំរាប់ប្រទេសផ្គត់ផ្គង់ផ្សេងៗដែរ។ វណ្ឌ ៣៧ ពិនិត្យមើលលើផលប៉ះពាល់នៃការលុបចោលការដាក់កំហិត MFA ទៅលើផលិតផលវាយនភ័ណ្ឌ ។

ត្រូវធ្វើការសិក្សានៅកំរិត មីក្រូ (ផលិតផល ឬ កំរិតវិស័យផលិតផល) ដើម្បីបញ្ជាក់អោយបានច្បាស់ពីផលប៉ះពាល់នៃការសន្យាអនុវត្តរបស់យូរ៉ុយហ្គាយទៅលើផលិតផលផ្សេងៗ ។ ការសិក្សាទាំងនេះ ត្រូវបានភ្ជាប់បន្ថែមដោយការស្រាវជ្រាវ និងការវិភាគពីតំរូវការជាសក្តានុពលនៅក្នុងទីផ្សារសេរីភាវូបនីយកម្ម ។ ការវិភាគពីតំរូវការនេះ អាចផ្តល់លទ្ធភាពអោយសហគ្រាស រៀបចំយុទ្ធសាស្ត្រដើម្បីទាញយកអត្ថប្រយោជន៍ពីការលានុវត្តន៍ភាពថ្មី និងនៅពេលចាំបាច់ ត្រូវសំរបទៅតាមស្ថានភាពប្រកួតប្រជែង ដោយសារស្ថានភាពនេះផ្លាស់ប្តូរទៅតាមការអនុវត្តន៍បន្តិចម្តងៗ ចំពោះការសន្យានៅយូរ៉ុយហ្គាយ ។

ការស្រាវជ្រាវបែបនោះ អាចធ្វើលើសពីធនធានហិរញ្ញវត្ថុ និងបច្ចេកទេសរបស់សហគ្រាសនីមួយៗ ជាពិសេស SMEs ។ ក្នុងករណីបែបនេះ ការផ្តួចផ្តើមគំនិតធ្វើការសិក្សាស្រាវជ្រាវ អាចចាប់ផ្តើមឡើងដោយវិទ្យាស្ថានជាតិស្រាវជ្រាវពាណិជ្ជកម្មបរទេស ឬ ដោយសមាគមឧស្សាហកម្ម ឬ សភាពាណិជ្ជកម្ម ។ ដើម្បីនឹងធ្វើដូច្នេះ គេត្រូវការជំនួយហិរញ្ញវត្ថុពីរដ្ឋាភិបាលរបស់គេ ។ អង្គការអន្តរជាតិ អាចធ្វើការសិក្សាស្រាវជ្រាវនេះបានទៅលើផលិតផលដែលបានជ្រើសរើសមួយចំនួន ឬ ជួយដល់ស្ថាប័ន និងសមាគមពាក់ព័ន្ធនៅបណ្តាប្រទេសផ្សេងៗ អោយធ្វើការសិក្សានេះ ។

ខណ្ឌ ៣៧

ឥទ្ធិពលនៃការលប់ចោលការដាក់កំហិត MFA ទៅលើផលិតផលវាយនភ័ណ្ឌ បើប្រៀបធៀបជាមួយអត្រាផលិតផលតាមន្តសាលផ្សេងទៀត

អត្រាពន្ធគយទៅលើការនាំចូលផលិតផលវាយនភ័ណ្ឌ នឹងបន្តកើនឡើង ទោះបីជាមានការអនុវត្តន៍ពេញលេញនូវការកាត់បន្ថយពន្ធដែលបានព្រមព្រៀងគ្នាក្នុងពេល យូរ៉ុយហ្គាយ ក៏ដោយ ។ ដូច្នេះផលប្រយោជន៍ជាសំខាន់ដែលទទួលបានពីពាណិជ្ជកម្ម រំពឹងថានឹងបានមកពីការលប់ចោលការដាក់កំហិតទៅលើបរិមាណ នៅក្នុងប្រទេសជឿនលឿនមួយចំនួន។ ការដាក់កំហិតទៅលើការនាំចូល ធ្វើអោយតំលៃនាំចូលកើនឡើង ដោយសារការផ្គត់ផ្គង់មានមិនគ្រប់គ្រាន់ទៅតាមតំរូវការ។ ដូច្នេះការដាក់កំហិតលើការនាំចូលហាក់ដូចជាការដាក់ទណ្ឌកម្មចំពោះអ្នកប្រើប្រាស់ ដែលត្រូវទិញទំនិញក្នុងតំលៃមួយដែលខ្ពស់ជាងមុន ។ ថាតើអ្នកនាំចូល ឬ អ្នកនាំចេញបានទទួលផលប្រយោជន៍ពីការឡើងថ្លៃ ឬ យ៉ាងណានោះ គឺអាស្រ័យទៅលើប្រព័ន្ធផ្តល់អាជ្ញាប័ណ្ណ ដែលគ្រប់គ្រងដំណើរការនាំចេញ ឬ នាំចូលនោះ ។ ប្រសិនបើជាការនាំចូលចុងក្រោយនោះអ្នកនាំចូលមានលទ្ធភាពបំពេញបាននូវផ្នែកដែលខុសគ្នារវាងតំលៃនាំចូលធម្មតា និងតំលៃលក់ដុំនៅក្នុងប្រទេសនាំចូល។ ម្យ៉ាងទៀត ប្រសិនបើប្រទេសនាំចេញជាអ្នកចេញអាជ្ញាប័ណ្ណ នោះអ្នកនាំចេញអាចរៀបចំអោយសមស្រប ទៅនឹងបុព្វលាភដោយការគិតបន្ថែមតំលៃនាំចេញអោយបានខ្ពស់ជាង ។ តាមកិច្ចព្រមព្រៀងស្តីពីផលិតផលវាយនភ័ណ្ឌ និងសំលៀកបំពាក់ អាជ្ញាប័ណ្ណដែលតំរូវសំរាប់គ្រប់គ្រងលើការដាក់កំហិតនឹងត្រូវចេញ ដោយប្រទេសនាំចេញ ។ នៅពេលលប់ចោលការដាក់កំហិតកូតា នោះប្រទេសនាំចេញមិនមានលទ្ធភាពទាមទារបុព្វលាភទេ ហើយត្រូវតែគិតថ្លៃនាំចេញអោយបានថោកជាង។ ការថយចុះតំលៃក្នុងមួយឯកត្តាសំរាប់នាំចេញ រំពឹងថានឹងត្រូវបានទូទាត់ដោយការបង្កើនបរិមាណនាំចេញ ក្រោយពេលលប់ចោលការដាក់កំហិត ។ ក៏ប៉ុន្តែ កំណើនពាណិជ្ជកម្មជាក់ស្តែង អាស្រ័យទៅលើការប្រែប្រួលនៃតំរូវការ (ដូចជាថាតើ តំរូវការកើនឡើងដោយមានតំលៃធ្លាក់ចុះ) ។ តំរូវការលើផលិតផលវាយនភ័ណ្ឌ នៅក្នុងទីផ្សារមានកំណត់ ភាគច្រើន ជាទូទៅត្រូវបានសន្និដ្ឋានថាមានការប្រែប្រួល ។ ប៉ុន្តែនៅកំរិតសហគ្រាស បញ្ហាជាសំខាន់ថាតើ វាមានភាពប្រែប្រួល សំរាប់ប្រភេទផលិតផលវាយនភ័ណ្ឌប្រភេទណាមួយឬទេ ដូចជា អាវយឺត និងសំលៀកបំពាក់កុមារ ដែលសហគ្រាសកំពុងធ្វើការនាំចេញ និងថាតើមានការលប់ចោលការដាក់កំហិតទៅលើផលិតផលប្រភេទណា ។ ប្រសិនបើមិនមានភាពច្បាស់លាស់ទេ សហគ្រាសអាចមិនទទួលបាននូវផលប្រយោជន៍ពីការលប់ចោលការដាក់កំហិតនោះឡើយ ហើយអាចមានការខាតបង់ទៅវិញផង លើកលែងតែមានលទ្ធភាពបំបែកផលិតកម្ម និងការនាំចេញរបស់គេទៅក្នុងខ្សែសង្វាក់ផលិតកម្មណាដែលតំរូវការមានការប្រែប្រួលនោះ ។ ការលប់ចោលការដាក់កំហិត នឹងធ្វើអោយមានការប្រកួតប្រជែង ដែលកើនឡើងក្នុងចំណោមបណ្តាប្រទេសផ្គត់ផ្គង់នៅក្នុងទីផ្សារមានកំរិត ។ ដោយសារការដាក់កំហិតតាម ATC អាចអនុវត្តបានតាមមូលដ្ឋាននៃការរើសអើង ដូច្នេះផលប៉ះពាល់នៃការ

ប្រកួតប្រជែង បែបនោះ ទៅលើបណ្ដាប្រទេសផ្គត់ផ្គង់ផ្សេងៗ អាចមានលក្ខណៈខុសគ្នា ។ ឧទាហរណ៍ ក្រុមហ៊ុននាំចេញនៅក្នុងប្រទេស ក ដែលការនាំចេញអាវយឺត និងសំលៀកបំពាក់ក្មេងរបស់គេស្ថិតក្រោមការដាក់កំហិត អាចរៀបចំយុទ្ធសាស្ត្រដើម្បីទាញយកអត្ថប្រយោជន៍ពីការលប់ចោល ការដាក់កំហិតនោះ ។ ម៉្យាងទៀត អ្នកផ្គត់ផ្គង់នៅក្នុងបណ្ដាប្រទេសផ្សេងទៀតដែលការនាំចេញផលិតផលវាយនភណ្ឌ របស់គេមិនមានការដាក់កំហិតនោះ ត្រូវត្រៀមខ្លួនដើម្បីប្រឈមនឹងការប្រកួតប្រជែងជាមួយអ្នកផ្គត់ផ្គង់នៅក្នុងប្រទេស ក ។ (សូមមេត្តាអាន ជំពូក ១៤ ស្ដីពីកិច្ចព្រមព្រៀងវាយនភ័ណ្ឌ និងសំលៀកបំពាក់)។

ម៉ាជីនូបនីយកម្ម (Marginalization) របស់បណ្ដាប្រទេសជឿនលឿន និងបណ្ដាប្រទេសកំពុងអភិវឌ្ឍន៍

ដូចដែលមានគូសបញ្ជាក់ពីខាងលើរួចមកហើយថា តាមការសិក្សាផ្នែកម៉ាក្រូសេដ្ឋកិច្ច រំពឹងថា បណ្ដាប្រទេសកំពុងអភិវឌ្ឍន៍ និងបណ្ដាប្រទេសក្រីក្រភាគច្រើន នឹងទទួលបានផលប្រយោជន៍តិចតួចបំផុតពីវិធានការសេរីភាវូបនីយកម្ម ដែលបានធ្វើឡើងក្នុងកិច្ចប្រជុំយូរ៉ុយហ្គាយ ។ ការថយចុះតំលៃទំនិញ និងការលំបាកដែលកើតមានឡើងនៅក្នុងការអនុវត្តន៍កិច្ចព្រមព្រៀងទាំងនេះ បានធ្វើអោយមានម៉ាជីនូបនីយកម្មបន្ថែមទៀត របស់បណ្ដាប្រទេសទាំងនេះ នៅក្នុងពាណិជ្ជកម្មអន្តរជាតិ ។

ដើម្បីការពាររាល់ការបំផ្លិចបំផ្លាញណាមួយបន្ថែមទៀតដល់សភាពការណ៍នេះ ប្រទេសជឿនលឿនមួយចំនួនបានពង្រីកវិសាលភាពនៃប្រព័ន្ធអនុគ្រោះទូទៅរបស់គេ ដោយអនុលោមទៅតាមសេចក្ដីសំរេច ដែលបានធ្វើឡើងនាសម័យប្រជុំកំពូលស្ដីពីការផ្ដួចផ្ដើមគំនិតធ្វើសមាហរណកម្ម សំរាប់ការអភិវឌ្ឍន៍របស់បណ្ដាប្រទេសក្រីក្រ តាមទស្សនៈអនុញ្ញាតិអោយមានការនាំចូលផលិតផលទាំងអស់នៃផលប្រយោជន៍នាំចេញ ទៅកាន់បណ្ដាប្រទេសទាំងនោះ ដោយមិនមានបង់ពន្ធ ។ប្រទេសកំពុងអភិវឌ្ឍន៍មួយចំនួនតូច ក៏បានសំរេចអនុម័តប្រព័ន្ធនោះផងដែរ លើផលិតផលដែលបានជ្រើសរើសនាំចូល ពីបណ្ដាប្រទេសក្រីក្រទាំងនោះតាមមូលដ្ឋានផ្ដល់ភាពអនុគ្រោះ ហើយខណៈនេះសំណើសុំប្រើប្រាស់ប្រព័ន្ធនោះ កំពុងស្ថិតនៅក្នុងការពិចារណា នៅក្នុងប្រទេសមួយចំនួន ។ បំណាត់ការទាំងនេះត្រូវបានអនុវត្តបំពេញបន្ថែមដោយជំនួយការបច្ចេកទេសដែលបានធ្វើសមាហរណកម្មរបស់អង្គការ WTO, UNCTAD, ITC និងអង្គការអន្តរជាតិផ្សេងទៀត ទៅដល់បណ្ដាប្រទេសទាំងនេះនៅកំរិតសហគ្រាស ដោយមានកម្មវត្ថុច្បាស់លាស់ក្នុងការកសាងសមត្ថភាពជាតិ ដើម្បីផលិតកម្ម និងការផ្គត់ផ្គង់ ។

សក្ដានុពលសំរាប់ពាណិជ្ជកម្មនាំចេញ ជាមួយបណ្ដាប្រទេសកំពុងអភិវឌ្ឍន៍

នៅក្នុងបរិបទនេះ ជាចាំបាច់ត្រូវចងចាំពីទិដ្ឋភាពជាសំខាន់នៃយូរ៉ុយហ្គាយ ។ ជំនួបនេះក៏ជំរុញបន្ថែមទៀតដល់កិច្ចដំណើរការសេរីភាវូបនីយកម្ម ទាំងនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ និងប្រទេសដែលមានសេដ្ឋកិច្ចអន្តរកាល ។ ការចាប់ផ្ដើមកិច្ចប្រជុំយូរ៉ុយហ្គាយហាក់ដូចជាមានភាពស្របគ្នាជាមួយបំលាស់ប្ដូរនៃគោលនយោបាយបើកចំហ និងពាណិជ្ជកម្មសេរី សូម្បីតែនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ដែលមកដល់ពេលនោះ នៅអនុវត្តតាមគោលនយោបាយពាណិជ្ជកម្មមានកំណត់នៅឡើយ ។ ក្នុងពេលជាមួយគ្នានោះដែរ សេដ្ឋកិច្ចអន្តរកាល បានប្រកាន់យកនូវដំណាក់កាលផ្ដួចផ្ដើម ឈានទៅរកកំណែទំរង់ទីផ្សារ ឯកជនភាវូបនីយកម្ម សេដ្ឋកិច្ចបត់ទិស និងគោលនយោបាយពាណិជ្ជកម្ម ។ ក្រុមប្រទេសទាំងពីរ បានរួមបញ្ចូលគ្នានៅយូរ៉ុយហ្គាយ លើការកាត់បន្ថយអត្រាពន្ធគយដំបូងរបស់គេ ដោយការចងភ្ជាប់កាតព្វកិច្ចតាមអត្រាដែលបានបញ្ចុះ ឬ ដោយកំណត់អត្រាចងភ្ជាប់កាតព្វកិច្ចដែលខ្ពស់បំផុត។ អត្រាទាំងនេះ ហាក់ដូចជារំពឹងថានឹងមានការថយចុះបន្ថែមទៀត ក្នុងករណីខ្លះមានទាបជាងអត្រាបញ្ចុះដែលបានព្រមព្រៀងគ្នានៅយូរ៉ុយហ្គាយទៅទៀត ។ ទាំងនេះស្តែងចេញមកពីវិធានការសេរីភាវូបនីយកម្មបន្ថែម ដែលប្រទេសមួយចំនួនកំពុងប្រកាន់យក ឬ ស្នើសុំប្រកាន់យកតាមមូលដ្ឋានឯកត្តោភាគី ដោយអនុលោមទៅតាមគោលនយោបាយរបស់គេស្ដីពីការជំរុញកំណើនដែលមានបត់ទិសទៅរកការនាំចេញ ។

ក្នុងករណីជាក់លាក់ខ្លះ ការកាត់បន្ថយអត្រាពន្ធគយតាមមូលដ្ឋាន MFN អាចធ្វើអោយមានការថយចុះនៅក្នុងចំនួនខុសគ្នាដែលមានភាពអនុគ្រោះលើផលិតផល ដែលគ្របដណ្តប់ដោយកិច្ចព្រមព្រៀងផ្តល់ភាពអនុគ្រោះពាណិជ្ជកម្មក្នុងតំបន់ [៦៩] ឬ តាមកិច្ចព្រមព្រៀងអន្តរតំបន់ ក្នុងចំណោមបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ [៧០]។ តែទោះជាយ៉ាងណាក៏ដោយ អត្រាពន្ធគយតាម MFN របស់បណ្តាប្រទេសកំពុងអភិវឌ្ឍន៍ភាគច្រើន ដែលបានចូលរួមនៅក្នុងប្រព័ន្ធអនុគ្រោះនោះនឹងបន្តកើនខ្ពស់ ទោះបីមានការកាត់បន្ថយក្តីដោយសារចំនួនខុសគ្នាដែលបានទទួលភាពអនុគ្រោះ មានភាពតូចតាចក៏ដោយ ក៏មានផលប្រយោជន៍ពាណិជ្ជកម្មគួរអោយកត់សំគាល់ដែរ ។

ប៉ុន្តែអ្វីដែលមានសារៈសំខាន់ជាងការកាត់បន្ថយអត្រាពន្ធគយនោះ គឺដំណាក់កាលដែលបណ្តាប្រទេសកំពុងអភិវឌ្ឍន៍បានប្រកាន់យកក្នុងការធ្វើសេរីភាវូបនីយកម្ម វិធានការមិនជាប់ពន្ធរបស់គេ ។ វិធានការទាំងនេះ នឹងកាត់បន្ថយ ឬ លប់ចោលការកំណត់កូតាលើការនាំចូលនេះ និងតំរូវការស្នើសុំអាជ្ញាប័ណ្ណ និងកំណត់ពីការបែងចែកដោយសេរីនៃរូបិយវត្ថុបរទេសទៅលើពាណិជ្ជកម្មនាំចូល។ កន្លងមកការដាក់កំហិតមិនមែនពន្ធគយបានរាំងដល់ការអភិវឌ្ឍន៍ពាណិជ្ជកម្មផលិតផល ដែលផលិតផលនោះទទួលបាននូវការផ្លាស់ប្តូរសម្បទានអនុគ្រោះ តាមកិច្ចព្រមព្រៀងអនុគ្រោះអន្តរតំបន់ ឬ តំបន់ ។ សេរីភាវូបនីយកម្មនៃរបបនាំចូល អាចផ្តល់នូវការជំរុញថ្មីមួយ ដើម្បីពង្រីកពាណិជ្ជកម្មនេះតាមល័ក្ខខ័ណ្ឌអនុគ្រោះ និង MFN ។

តាមទំនៀមទំលាប់ សហគ្រាសជាច្រើន (ជាពិសេស សហគ្រាសនៅក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍន៍) បានផ្តោតអារម្មណ៍ទៅលើទីផ្សារនៅក្នុងបណ្តាប្រទេសជឿនលឿន ។ កាលានុវត្តន៍ភាពទីផ្សារថ្មី ដែលបានបង្កើតឡើងដោយវិធានការសេរីភាវូបនីយកម្មនៅក្នុងប្រទេសក្រីក្រ និងប្រទេសអន្តរកាល (បានប្រកាន់ឡើងជាឯកតោភាគី ឬ តាមកម្មវិធីកែតំរូវលើរចនាសម្ព័ន្ធ ដែលគាំទ្រដោយ IMF និង WB) បច្ចុប្បន្ន ត្រូវជំរុញលើកទឹកចិត្តស្មើគ្នាចំពោះសហគ្រាសនៅក្នុងបណ្តាប្រទេសទាំងនេះ បើមិនដូច្នោះទេនោះគឺគ្មានសារៈប្រយោជន៍អ្វីជាសំខាន់ដល់ការអភិវឌ្ឍន៍ផ្នែកពាណិជ្ជកម្មក្នុងចំណោមប្រទេសទាំងនោះដែរ ។

---

៦៩ ដូចជាទីផ្សាររួមសំរាប់បណ្តាប្រទេសអាហ្វ្រិកខាងកើត និងខាងត្បូង (COMESA) និងសហគមន៍សេដ្ឋកិច្ចរបស់រដ្ឋអាហ្វ្រិកខាងលិច (ECOWAS) នៅអាហ្វ្រិក សមាគមន៍ប្រជាជាតិអាស៊ីអាគ្នេយ៍ (ASEAN) នៅអាស៊ី និងសមាគមអាមេរិកឡាទីន នៅអាមេរិកឡាទីន (ALADI) ។

៧០ ដូចជាប្រព័ន្ធអនុគ្រោះពាណិជ្ជកម្មពិភពលោក (GSTP) ។

ផ្នែកទីបី

វិធានអន្តរជាតិស្តីពីការធ្វើពាណិជ្ជកម្ម
ផ្នែកសេវាកម្ម

ជំពូក ១៧

កិច្ចព្រមព្រៀងទូទៅ ស្តីអំពីពាណិជ្ជកម្មលើសេវាកម្ម

សេចក្តីសង្ខេប

ពាណិជ្ជកម្មលើសេវាកម្ម មានការកើនឡើងយ៉ាងខ្លាំង ដែលបច្ចុប្បន្ន ពាណិជ្ជកម្មក្នុងផ្នែកនេះស្រូបយក ២០ ភាគរយ នៃពាណិជ្ជកម្មអន្តរជាតិ ។ កិច្ចព្រមព្រៀងទូទៅស្តីអំពីសេវាកម្ម (GATS) ដែលបានលើកយកទៅចរចា នៅក្នុងកិច្ចប្រជុំ Uruguay Round បានអនុវត្តន៍នូវវិធានជា មូលដ្ឋាននានា ដូចគ្នា សំរាប់ការធ្វើពាណិជ្ជកម្មលើទំនិញដែរ ។ ទោះបី យ៉ាងណាក៏ដោយ វិធានជាមូលដ្ឋានទាំងអស់នោះត្រូវបានកែប្រែអោយសមស្រប ដើម្បីពិចារណាទៅលើភាពខុសគ្នា រវាងការធ្វើពាណិជ្ជកម្មលើទំនិញ និង ពាណិជ្ជកម្មលើសេវាកម្ម ព្រមទាំងរបៀបផ្គត់ផ្គង់សេវាកម្មទាំងបួនប្រភេទ ដែលមាននៅក្នុងការធ្វើពាណិជ្ជកម្មលើសេវាកម្មជាអន្តរជាតិ ។

កិច្ចព្រមព្រៀងទូទៅស្តីអំពីសេវាកម្ម (GATS) រួមមាន ÷

- ☐ ប្រព័ន្ធនៃវិធានជាទូទៅ និង លក្ខណៈតំរូវនានា
- ☐ ឧបសម្ព័ន្ធដែលយោងទៅដល់លក្ខខ័ណ្ឌពិសេសទាំងឡាយ ដែលពាក់ព័ន្ធទៅនឹងវិស័យនីមួយ ៗ និង
- ☐ ការសន្យាក្នុងការធ្វើសេរីភាវូបនីយកម្ម ផ្នែកសេវាសកម្មនានា ដែលមានចែងនៅ ក្នុងបញ្ជីសន្យារបស់ប្រទេសជាសមាជិក

ប្រព័ន្ធនៃវិធានការជាទូទៅ តំរូវអោយប្រទេសជាសមាជិក មិនត្រូវធ្វើការរើសអើង រវាងផលិតផលសេវាកម្ម ព្រមទាំងអ្នកផ្តល់សេវាកម្មនៃប្រទេសផ្សេងៗ ដោយអនុវត្តតាមគោលការណ៍ MFN នោះទេ ។ ទោះបីយ៉ាងណាក៏ដោយ គោលការណ៍នេះអនុញ្ញាតអោយប្រទេសជាសមាជិកមួយចំនួន រក្សាទុករយៈពេលអន្តរកាលមួយ ដែលមានរយៈពេល ១០ឆ្នាំ ដើម្បីកែតំរូវប្រព័ន្ធច្បាប់គ្រប់គ្រងវិស័យសេវាកម្មណា ដែលមិនទាន់ស្របជាមួយនិងគោលការណ៍នេះ ។ តាមគោលការណ៍ប្រព្រឹត្តកម្មជាតិ (National Treatment) ដែលជាគោលការណ៍សំខាន់ នោះតំរូវអោយប្រទេសជា សមាជិកទទួលស្គាល់សេវាកម្មដែលផ្តល់ដោយជនបរទេស ដូចគ្នានឹងសេវាកម្មដែលផ្តល់ដោយជនក្នុងស្រុក ។ ទោះបីប្រព័ន្ធច្បាប់នេះ មិនតំរូវអោយប្រទេសជាសមាជិកចងនូវកាតព្វកិច្ចរបស់ខ្លួនក្តី ប៉ុន្តែវាតំរូវអោយប្រទេសនោះ បង្ហាញនៅក្នុងតារាងសម្បទានរបស់ខ្លួននូវវិស័យសេវាកម្មទាំងឡាយ ដែលល័ក្ខខ័ណ្ឌនានា ស្ថិតក្រោមប្រព្រឹត្តកម្មជាតិ (National Treatment) នឹងត្រូវបានពង្រីកបន្ថែម ។

ក្នុងចំណោមបទបញ្ញត្តិសំខាន់ផ្សេងៗទៀត ដែលមានចែងនៅក្នុងប្រព័ន្ធវិធានជាទូទៅគឺ ÷

- ☐ តំរូវអោយប្រទេសជាសមាជិកធានាអោយបាននូវតំលាភាពនៃប្រព័ន្ធច្បាប់ក្នុងស្រុកដែលអនុវត្តចំពោះឧស្សាហកម្ម សេវាកម្ម និងសកម្មភាពនានា ។
- ☐ សំដៅធានាអោយមានការចូលរួមអោយកាន់តែច្រើនថែមទៀត ពីសំណាក់ប្រទេសកំពុងអភិវឌ្ឍន៍ ក្នុងការធ្វើពាណិជ្ជកម្មលើសេវាកម្ម ។

កិច្ចព្រមព្រៀងទូទៅស្តីអំពីសេវាកម្ម (GATS) រំពឹងថាត្រូវលើកមកចរចាបន្តទៀត នៅឯអង្គការពាណិជ្ជកម្មពិភពលោក ដើម្បីពង្រីកសេរីភាវូបនីយកម្មនៃការធ្វើពាណិជ្ជកម្មលើសេវាកម្មជាក់លាក់។ ជាបន្ថែមវានឹងបង្កើតអោយមានការចរចាថ្មីមួយទៀត សំរាប់ការធ្វើសេរីភាវូបនីយកម្ម ពាណិជ្ជកម្មនៃសេវាកម្មគ្រប់ផ្នែកទាំងអស់ ដែលនឹងចាប់ផ្តើមក្នុងឆ្នាំ ២០០០ ។

ពាក្យសេវាកម្ម គ្របដណ្ដប់ទៅលើសកម្មភាពសេដ្ឋកិច្ចមួយចំនួនធំ ។ លេខាធិការដ្ឋានអង្គការពាណិជ្ជកម្មពិភពលោក បានធ្វើការបែងចែកសកម្មភាព ទាំងនោះ ជា១២ ផ្នែកដូចខាងក្រោម :

- ☐ សេវាកម្មអាជីវកម្ម (រួមទាំងសេវាកម្មមុខរបរវិជ្ជាជីវៈ និងសេវាកម្មកុំព្យូទ័រ)
- ☐ សេវាកម្មទូរគមនាគមន៍
- ☐ សេវាកម្មសំណង់ និងវិស្វកម្ម
- ☐ សេវាកម្មចែកចាយទំនិញ
- ☐ សេវាកម្មសិក្សាធិការ
- ☐ សេវាកម្មបរិស្ថាន
- ☐ សេវាកម្មហិរញ្ញវត្ថុ (ធានារ៉ាប់រង និងធនាគារ)
- ☐ សេវាកម្មសុខាភិបាល
- ☐ សេវាកម្មទេសចរណ៍ និងការធ្វើដំណើរកំសាន្ត
- ☐ សេវាកម្មវប្បធម៌ និងកីឡា
- ☐ សេវាកម្មដឹកជញ្ជូន
- ☐ សេវាកម្មផ្សេងៗទៀត ក្រៅពីសេវាកម្មខាងលើ

សេវាកម្មទាំង១២ផ្នែកនេះ ត្រូវបានបំបែកជាផ្នែកតូចៗ ចំនួន ១៥៥ ផ្សេងទៀត ដែលមានរាយនៅក្នុង ឧបសម្ព័ន្ធ មួយ នៃជំពូកនេះ ។

របៀបផ្ដល់សេវាកម្មពាណិជ្ជកម្ម

ភាពខុសគ្នារវាងពាណិជ្ជកម្មលើទំនិញ និងពាណិជ្ជកម្មលើសេវាកម្ម

តើសេវាកម្ម និងទំនិញខុសគ្នាយ៉ាងដូចម្ដេច ? លក្ខណៈសម្បត្តិសំខាន់មួយរបស់សេវាកម្មគឺ សេវាកម្មមានលក្ខណៈអរូបិយ និង មិនអាចមើលឃើញ ដែលផ្ទុយមកវិញគេអាចមើលឃើញនិងមានលក្ខណៈរូបិយនូវវត្ថុនានាដែលជាទំនិញ។ ក្រៅពីនេះសេវាកម្ម ខុសពីទំនិញត្រង់ថា សេវាកម្មមិនអាចស្តុកទុកបានទេ [៧១] ។ សេដ្ឋកិច្ចវិទូ បានអះអាងបញ្ជាក់យ៉ាងច្បាស់ពីភាពខុសគ្នាទាំងនេះថា " អ្វីៗដែលគេអាចលក់បាននៅក្នុងពាណិជ្ជកម្ម ហើយវត្ថុនោះ មិនដែលធ្លាក់ត្រូវជើងរបស់អ្នក " នោះគឺជាសេវាកម្ម [៧២] ។

របៀបបួនយ៉ាងក្នុងការផ្ដល់សេវាកម្មនៃអាជីវកម្មអន្តរជាតិ

លក្ខណៈខុសគ្នារវាងទំនិញ និងសេវាកម្ម បណ្ដាលអោយមានរបៀបផ្ដល់សេវាកម្មផ្សេងៗ នៅក្នុងអាជីវកម្មសេវាកម្មអន្តរជាតិ ។ នៅពេលដែលការធ្វើពាណិជ្ជកម្មលើទំនិញជាអន្តរជាតិមានទំនាក់ទំនងទៅនឹងលក្ខណៈជាក់ស្ដែងនៃចរន្តទំនិញពីប្រទេសមួយទៅ ប្រទេសមួយទៀត នោះមានតែអាជីវកម្ម សេវាកម្មជាទំលាប់ខ្លះតែប៉ុណ្ណោះ ដែលពាក់ព័ន្ធដោយចៀស មិនរួចពីការផ្ដត់ផ្គង់សេវាកម្ម

---

៧១ ការពិពណ៌នាខាងលើមិនមានកំណត់ទេ ។ សេវាកម្មខ្លះ អាចមើលឃើញ (ឧទាហរណ៍ ដូចជារបាយការណ៍របស់ទីប្រឹក្សាជា (diskette)។ សេវាកម្មខ្លះអាចរក្សាទុកបាន (ឧទាហរណ៍ ប្រព័ន្ធឆ្លើយតាមទូរស័ព្ទ) ។

៧២ ដូមមានបញ្ជាក់នៅក្នុង : ....

ក្នុងលក្ខណៈឆ្លងព្រំដែន ។ ឧទាហរណ៍ជាក់ស្តែង នៃការផ្តល់សេវាកម្មឆ្លងដែន គឺជាសេវាកម្មខ្លះ ដែលអាចបញ្ជូនតាមរយៈមធ្យោបាយទូរគមនាគមន៍ ប៉ុណ្ណោះ (ឧទាហរណ៍ ការបង្វែរសាច់ប្រាក់តាមរយៈធនាគារ) ឬ សេវាកម្មដែលមានលក្ខណៈជាទំនិញ (ឧទាហរណ៍ របាយការណ៍ ពិគ្រោះយោបល់ជាលក្ខណៈបច្ចេកទេស ឬ ទិន្នន័យជា Software) ។

នៅក្នុងអាជីវកម្មសេវាកម្ម ដែលមានលក្ខណៈធំដុំ ពេលវេលានិងទីកន្លែងប្រើប្រាស់សេវាកម្មនោះ មិនអាចបែងចែកដាច់ពីគ្នាបានទេ ហើយតំរូវអោយមានការនៅជិតគ្នារវាងអ្នកផ្តល់សេវាកម្ម និងអ្នកប្រើប្រាស់ ។ ភាពនៅជិតគ្នាបែបនេះ កើតមានបានតាមរយៈការចូលទៅរកស៊ីរបស់ក្រុមហ៊ុនបរទេស នៅក្នុងប្រទេសនាំចូលសេវាកម្ម (ឧទាហរណ៍ ការបង្កើតជាសាខា ឬក្រុមហ៊ុនតំណាង) ឬ ការចូលទៅផ្តល់សេវាកម្មជាបណ្តោះអាសន្នរបស់រូបវន្តបុគ្គល (ឧទាហរណ៍ អ្នកច្បាប់ ឬ ស្ថាបត្យករចូលទៅផ្តល់សេវាកម្មក្នុងប្រទេសមួយទៀត) ។ លក្ខណៈធម្មជាតិនៃអាជីវកម្មសេវាកម្មមួយចំនួនទៀត តំរូវអោយអ្នកប្រើប្រាស់សេវាកម្មធ្វើដំណើរទៅកាន់ប្រទេសដែលសេវាកម្មបែបនោះអាចរកបាន (ឧទាហរណ៍ ភ្ញៀវទេសចរ ទៅទស្សនាប្រទេសដែលគេចង់ទៅ ឬ និស្សិតដែលទៅបន្តការសិក្សានៅប្រទេសក្រៅ ។

ការបង្ហាញទាំងអស់ខាងលើនេះធ្វើអោយយើងមើលឃើញភាពខុសគ្នារវាងពាណិជ្ជកម្មលើសេវាកម្មអន្តរជាតិ និងការធ្វើពាណិជ្ជកម្មលើទំនិញដែលតំរូវអោយមានការដឹកជញ្ជូនឆ្លងកាត់ព្រំដែន រីឯសេវាកម្មត្រូវបានផ្តល់ជាអន្តរជាតិទៅតាមរបៀបបួនយ៉ាងដូចខាងក្រោម ÷

- ☐ ការផ្តល់សេវាកម្មឆ្លងដែន គឺជាចលនារបស់ផលិតផលសេវាកម្ម
- ☐ ចលនារបស់អ្នកប្រើប្រាស់សេវាកម្មទៅកាន់ប្រទេសនាំចូល
- ☐ ការបង្កើតក្រុមហ៊ុនរកស៊ីនៅក្នុងប្រទេសដែលផ្គត់ផ្គង់សេវាកម្ម
- ☐ ការចូលទៅផ្តល់សេវាកម្មជាបណ្តោះអាសន្ននៅក្នុងប្រទេសមួយ ដោយរូបវន្តបុគ្គលបរទេស

ដោយសារការខ្វះខាតស្ថិតិ ធ្វើអោយយើងមានការពិបាកក្នុងការវាយតំលៃអោយបានត្រឹមត្រូវ អំពីបរិមាណសរុបនៃការធ្វើពាណិជ្ជកម្មលើសេវាកម្ម តាមរយៈរបៀបផ្តល់សេវាកម្មទាំងពីរចុងក្រោយនេះ ដែលអាចមានទំហំធំជាងច្រើនដង បើប្រៀបធៀបទៅនិងបរិមាណពាណិជ្ជកម្ម តាមរយៈរបៀប ផ្តល់សេវាកម្មទាំងពីរខាងដើម ។ ប៉ុន្តែ ដោយសារការប្រែប្រួលយ៉ាងឆាប់រហ័សនៃបច្ចេកវិទ្យាទូរគមនាគមន៍ និងការអភិវឌ្ឍន៍ពាណិជ្ជកម្មអេឡិចត្រូនិច បានធ្វើអោយក្រុមហ៊ុនសេវាកម្មនានា អាចផ្តល់សេវាកម្មឆ្លងដែន ដោយពុំចាំបាច់ចូលទៅបើកក្រុមហ៊ុនពាណិជ្ជកម្មនៅក្នុងប្រទេសនាំចូលសេវាកម្មទេ ។

ការការពារវិស័យសេវាកម្ម

ភាពខុសគ្នាជាសំខាន់មួយទៀតរវាងទំនិញ និងសេវាកម្ម គឺផ្អែកទៅលើវិធីការពារ ដែលធ្វើឡើងដោយរដ្ឋាភិបាលចំពោះឧស្សាហកម្មក្នុងស្រុក ។ ឧស្សាហកម្មផលិតទំនិញ ជាធម្មតាត្រូវបានការពារដោយរបាំងពន្ធគយ ឬវិធានការតាមព្រំដែនផ្សេងទៀតដូចជាការដាក់កំហិតលើបរិមាណនាំចូល ជាដើម ។ ដូចបានកត់សំគាល់ក្នុងជំពូក ២ រួចមកហើយថា វិធាន GATT តំរូវអោយប្រទេសនានាផ្តល់ការការពារឧស្សាហកម្មក្នុងស្រុក ដោយប្រើប្រាស់របាំងពន្ធគយ និងតំរូវអោយប្រទេសទាំងនោះ ឈប់ប្រើប្រាស់ការការពារតាមរយៈការដាក់កំហិតលើបរិមាណនាំចូល និងវិធានការស្រដៀងគ្នាផ្សេងទៀត ។ ដោយសារលក្ខណៈធម្មជាតិអរូបិយរបស់សេវាកម្ម ហើយអាជីវកម្មសេវាកម្មជាច្រើនទៀត មិនជាប់ទាក់ទងទៅនឹងចលនា ឆ្លងកាត់ព្រំដែន ធ្វើអោយការការពារឧស្សាហកម្មសេវាកម្ម មិនអាចធ្វើឡើងបានតាមរយៈវិធានការនានាដែលអនុវត្តនៅតាមព្រំដែនបានទេ ។ ឧស្សាហកម្មសេវាកម្ម ភាគច្រើនត្រូវបានការពារដោយច្បាប់ក្នុងស្រុក ដែលគ្រប់គ្រងលើវិស័យវិនិយោគពីបរទេស និងការចូលរួមរបស់អ្នកផ្តល់ សេវាកម្មបរទេសនៅក្នុងឧស្សាហកម្មក្នុងស្រុក ។ ច្បាប់ក្នុងស្រុកទាំងនេះអាចចែងអំពីការហាមឃាត់អ្នកផ្តល់សេវាកម្មបរទេស (ឧទាហរណ៍ ធនាគារ ឬ ក្រុមហ៊ុនធានារ៉ាប់រង) ពីការធ្វើវិនិយោគ ឬ បង្កើតសាខាក្រុមហ៊ុន ដែលចាំបាច់សំរាប់ការផ្តល់សេវាកម្ម ។ ច្បាប់ក្នុងស្រុកនានាអាចត្រូវបាន ប្រើប្រាស់ក្នុងលក្ខណៈរើសអើង ចំពោះរូបវន្តបុគ្គលដែលផ្តល់សេវាកម្មតាមរបៀបផ្តល់សិទ្ធិតិចជាងអ្នកផ្តល់សេវាកម្មបរទេស (មិនអនុវត្តគោលការណ៍ប្រព្រឹត្តកម្មជាតិ) ។ ច្បាប់នេះក៏អាចផ្តល់សិទ្ធិខុសគ្នាផងដែរ ចំពោះអ្នកផ្តល់សេវាកម្មមកពីប្រទេសផ្សេងៗ (មិនអាចអនុវត្តបាននូវ គោលការណ៍ MFN) ។

ការកើនឡើងនៃសារៈសំខាន់នៃការធ្វើពាណិជ្ជកម្មលើសេវាកម្មជាអន្តរជាតិ

ការនាំចេញសេវាកម្មនាពេលបច្ចុប្បន្ន មានតំលៃប្រមាណ មួយពាន់លានដុល្លាអាមេរិក ឬស្មើនិង ២០ ភាគរយ នៃការនាំចេញរបស់ពិភពលោកទាំងមូល ។ ទោះបីសមាមាត្រនៃការនាំចេញសេវាកម្មសរុប ពីប្រទេសកំពុងអភិវឌ្ឍន៍ មានបរិមាណតិចតួចនៅឡើយក៏ដោយ ក៏ប៉ុន្តែប្រទេសកំពុង អភិវឌ្ឍន៍ខ្លះ ស្ថិតនៅក្នុងចំណោមប្រទេសនាំចេញសេវាកម្មនាំមុខក្នុងពិភពលោកទាំង ២៥ ដែរ ។ ការនាំចេញនៃពាណិជ្ជកម្មលើសេវាកម្ម កំពុងមាន កំណើនយ៉ាងសំខាន់ មិនត្រឹមតែនៅក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ជឿនលឿនប៉ុណ្ណោះទេ ប៉ុន្តែមាននៅក្នុងប្រទេសដែលមានប្រាក់ចំណូលទាប និងប្រទេសក្រីក្រផងដែរ ។

ប្រទេសកំពុងអភិវឌ្ឍន៍ភាគច្រើនបច្ចុប្បន្ន កំពុងពឹងផ្អែកស្ទើតែទាំងស្រុងទៅលើការនាំចូលសេវាកម្ម ។ ការនាំចូលសេវាកម្ម មានកំណើនដោយសារ តែការកើនឡើងនៃផលិតភាពផលិតកម្ម របស់ឧស្សាហកម្ម ដែលបច្ចុប្បន្ន នេះមានទំនាក់ទំនងយ៉ាងជិតស្និទជាមួយនិងសេវាកម្មហិរញ្ញវត្ថុកុំព្យូទ័រ និង ពត៌មាន ដែលងាយរកបាន ជាមួយនិងថ្លៃសមស្រប ។ សហគ្រាសនានា កំពុងសំលឹងរកទីផ្សារនៅបរទេស ដែលតំរូវអោយគេត្រូវចាយវាយប្រាក់ ច្រើនជាងមុន ក្នុងការសិក្សាស្រាវជ្រាវអំពីទីផ្សារ និងការអភិវឌ្ឍន៍ការផ្សាយពាណិជ្ជកម្ម និងការគាំទ្របន្ទាប់ពីការលក់ជាដើម ។

ការរីកចំរើនយ៉ាងឆាប់រហ័ស នៃបច្ចេកវិទ្យាក្នុងវិស័យទូរគមនាគមន៍ ធ្វើអោយអ្នកផ្តល់សេវាកម្ម មានលទ្ធភាពក្នុងការគ្រប់គ្រងទីផ្សារក្នុងស្រុក និង អាជីវកម្មជាអន្តរជាតិ ។ ធនាគារនិងក្រុមហ៊ុនធានារ៉ាប់រងអាចធ្វើអាជីវកម្មបានឆាប់រហ័សជាងមុន និងប្រកបដោយប្រសិទ្ធិភាព ពីព្រោះតែការបង្កើត អោយមានម៉ាស៊ីនហ្វាក់ ការបញ្ជូនសារតាមអេឡិចត្រូនិច និង ឧបករណ៍ផ្សេងៗទៀត ។ ស្ថាបត្យករ អាចផ្តល់ស្នាដៃស្ថាបត្យកម្មរបស់ខ្លួន និង ត្រួតពិនិត្យការដ្ឋានពីរយៈចំងាយរាប់ពាន់ម៉ាយ ដោយមានជំនួយពីបច្ចេកវិទ្យាពត៌មានទំនើបៗ ។ ដូចគ្នានេះដែរ វិស្វករអាចផ្តល់យោបល់ទៅអោយ អតិថិជនរបស់ខ្លួន នៅក្នុងប្រទេសឆ្ងាយពីគ្នាដោយមានជំនួយពីការបញ្ជូនគំរូប្លង់តាមរយៈកំព្យូទ័រ ។ ដូច្នេះ ការធ្វើពាណិជ្ជកម្មលើសេវាកម្មអន្តរជាតិ ត្រូវតែពង្រីកអោយបានឆាប់រហ័សហើយតាមទស្សនៈខ្លះយល់ថា ការធ្វើពាណិជ្ជកម្មលើសេវាកម្ម អាចមានទំហំធំជាងការធ្វើពាណិជ្ជកម្មលើទំនិញ ក្នុងរយៈពេល១០ឆ្នាំខាងមុខ ។

កិច្ចព្រមព្រៀងទូទៅស្តីអំពីពាណិជ្ជកម្មលើសេវាកម្ម

មុនពេលចរចាឧរូហ្គាយ ពាណិជ្ជកម្មលើសេវាកម្ម ពុំស្ថិតនៅក្រោមគោលការណ៍ណាមួយនៅកំរិតអន្តរជាតិទេ ។ កិច្ចព្រមព្រៀងទូទៅស្តីអំពីសេវាកម្ម (GATS) ដែលបានលើកយកទៅចរចានៅឯកិច្ចចរចាឧរូហ្គាយ គឺជាជំហានដំបូងក្នុងការធ្វើអោយពាណិជ្ជកម្មបែបនេះស្ថិតក្រោម វិធានច្បាប់អន្តរជាតិជាបណ្តើរៗ ។

គោលបំណង

GATS បុព្វកថា

GATS មានគោលបំណងស្រដៀងគ្នាទៅនឹងគោលបំណងរបស់កិច្ចព្រមព្រៀងទូទៅស្តីអំពីពន្ធគយ និងពាណិជ្ជកម្ម (GATT)។ គោលបំណងនោះ គឺសំដៅ " ជំរុញកំណើនសេដ្ឋកិច្ចរបស់ដៃគូពាណិជ្ជកម្មទាំងឡាយ និងធ្វើការអភិវឌ្ឍន៍ប្រទេសកំពុងអភិវឌ្ឍន៍" តាមរយៈការពង្រីកពាណិជ្ជកម្មលើសេវាកម្ម ។ ដើម្បីសំរេចបានគោលដៅនេះ គេបានយកវិធាននានារបស់ GATT មកអនុវត្តនៅក្នុងការធ្វើពាណិជ្ជកម្មលើសេវាកម្ម ដោយធ្វើការកែសំរួលខ្លះៗចំនុចខ្លះៗ ដែលចាំបាច់ ដើម្បីអោយស្របជាមួយលក្ខណៈពិសេសនៃសេវាកម្ម ។

រចនាសម្ព័ន្ធ

កិច្ចព្រមព្រៀងទូទៅស្តីអំពីសេវាកម្ម (GATS) រួមមាន ÷

- ☐ ប្រព័ន្ធនៃវិធានជាទូទៅ ដែលកំណត់អំពីលក្ខណៈទូទៅ គោលការណ៍ និងវិធាននានា ដែលអនុវត្តសំរាប់ស្ទង់មើលការជះឥទ្ធិពលដល់ការធ្វើពាណិជ្ជកម្មលើសេវាកម្ម ។

- ☐ ឧបសម្ព័ន្ធ នៃកិច្ចព្រមព្រៀង ដែលបង្កើតអោយមានគោលការណ៍ និងវិធាននានា សំរាប់វិស័យសេវាកម្មជាក់លាក់ និងសំរាប់បំពេញបន្ថែមដល់កិច្ចព្រមព្រៀង ។
- ☐ ការសន្យាក្នុងការធ្វើសេរីភាវូបនីយកម្ម ពាណិជ្ជកម្មលើសេវាកម្ម និងលើសេវាកម្មរងដែលមានចែងនៅក្នុងបញ្ជីសន្យារបស់ប្រទេសជាសមាជិក ។

ក្របខ័ណ្ឌនៃកិច្ចព្រមព្រៀង

ទំហំនិងកាតព្វកិច្ចសំខាន់ៗ

កិច្ចព្រមព្រៀង GATS អនុវត្តចំពោះវិធានការនានារបស់រដ្ឋាភិបាល ដែលមានឥទ្ធិពលចំពោះការផ្តល់សេវាកម្ម នៅលើមូលដ្ឋានពាណិជ្ជកម្ម ។ ដូច្នេះ GATS គ្របដណ្តប់ទាំងសហគ្រាសឯកជន និងសហគ្រាសរដ្ឋ ដែលគ្រប់គ្រងដោយរដ្ឋាភិបាលប្រសិនបើសហគ្រាសនោះផ្តល់សេវាកម្មលើមូលដ្ឋានពាណិជ្ជកម្ម ។ សេវាកម្មដែលផ្តល់ដោយក្រសួងស្ថាប័ន និងភ្នាក់ងារផ្សេងៗរបស់រដ្ឋក្នុងក្របខ័ណ្ឌមិនមែនពាណិជ្ជកម្ម មិនស្ថិតនៅក្រោមកិច្ចព្រមព្រៀងនេះទេ ។ ក៏ប៉ុន្តែ កិច្ចព្រមព្រៀងនេះបានចែងថា ការចរចាជាពហុភាគីគួរត្រូវបានធ្វើឡើង ដើម្បីយកការទិញរបស់រដ្ឋទៅដាក់នៅ ក្រោមវិធានច្បាប់អន្តរជាតិ ដោយពិចារណាទៅលើបទបញ្ញត្តិនានានៅក្នុងកិច្ចព្រមព្រៀងស្តីអំពីលទ្ធកម្មសាធារណៈរបស់រដ្ឋាភិបាល ដូចមានចែងនៅក្នុងជំពូក ១៨ ។

GATS មាត្រា ១.៣

ពាក្យថា " សេវាកម្ម " គ្របដណ្តប់គ្រប់សកម្មភាពសេវាទាំងអស់ នៃវិស័យសេវាកម្ម[២៣] រួមមាន ផលិតកម្ម ការបែងចែក ការស្រាវជ្រាវទីផ្សារ ការលក់ និង ការផ្តល់សេវា ដោយផ្អែកទៅ លើរបៀបទាំងបួន នៃការផ្តល់សេវាកម្ម ដូចដែលបានបញ្ជាក់រួចហើយក្នុងជំពូកនេះ ។

GATS ផ្នែក II

កាតព្វកិច្ចនានា ដែលកំណត់ដោយក្របខ័ណ្ឌនៃកិច្ចព្រមព្រៀងអាចចែកជាពីរផ្នែកសំខាន់:

- ☐ កាតព្វកិច្ចទូទៅ ដែលអនុវត្តចំពោះទៅលើវិស័យសេវាកម្មទាំងអស់ ។
- ☐ កាតព្វកិច្ចជាលក្ខខ័ណ្ឌ ដែលអនុវត្តបានចំពោះវិស័យសេវាកម្ម ដែលជាប់សន្យានៅក្នុងតារាងសន្យារបស់ជាតិ

កាតព្វកិច្ចទូទៅ

ក្នុងចំណោមកាតព្វកិច្ចទូទៅសំខាន់ៗ ដែលកំណត់ដោយក្របខ័ណ្ឌនៃកិច្ចព្រមព្រៀងទាក់ទងទៅនឹងចំនុចខាងក្រោម ÷

GATS មាត្រា៣

- ☐ តំលាភាពនៃច្បាប់ក្នុងស្រុក ។

GATS មាត្រា៤

- ☐ ការទទួលស្គាល់ទៅវិញទៅមក នៃលក្ខណៈសម្បត្តិដែលបានតំរូវសំរាប់ផ្គត់ផ្គង់សេវាកម្ម ។

GATS មាត្រា៨&៩

- ☐ វិធាននានាដែលគ្រប់គ្រង ចំពោះការផ្តល់សេវាកម្មផ្តាច់មុខ និងការអនុវត្តន៍ក្នុងអាជីវកម្ម ដែលមិនបើកចំហអោយមានការប្រកួតប្រជែង ។

GATS មាត្រា២

- ☐ ការពង្រីកការអនុវត្តគោលការណ៍ MFN ។

GATS មាត្រា៤

- ☐ វិធានការណ៍ដែលត្រូវអនុវត្តដើម្បីធ្វើសេរីភាវូបនីយកម្មពាណិជ្ជកម្ម រួមទាំងការធានាអោយមានការចូលរួមយ៉ាងផុសផុលពីបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ ។

[២៣] អនុលោមទៅតាមឧបសម្ព័ន្ធស្តីពីការដឹកជញ្ជូនតាមអាកាស ការធ្វើចរាចរ និងសិទ្ធិពាក់ព័ន្ធផ្សេងទៀត ដែលមិនស្ថិតនៅក្រោមការគ្រប់គ្រងរបស់ GATS ។

GATS មាត្រា ៣.៤ ***តំលាភាព: ការបង្កើតអោយមានមជ្ឈមណ្ឌលទំនាក់ទំនងការងារសេវាកម្ម***

អ្នកផ្គត់ផ្គង់សេវាបរទេស ជារឿយ ៗ ជួបប្រទះការលំបាក ក្នុងការរកស៊ីជាមួយសហគ្រាសនៅក្រៅប្រទេស ដោយសារច្បាប់ទំលាប់នានាដែល អនុវត្តនៅទីនោះ ។ កង្វះតំលាភាពនៃច្បាប់នៅក្នុងប្រទេសនោះបានបង្កើតអោយមានបញ្ហាកាន់តែច្រើនថែមទៀត ចំពោះផ្នែកសេវាកម្ម ដោយសារការអនុវត្តច្បាប់ទំលាប់នានា ដើម្បីផ្តល់ការការពារផលិតករ ក្នុងស្រុកពីការប្រជែងពីក្រៅប្រទេស ។ ហេតុនេះហើយ កិច្ចព្រមព្រៀងនេះ តំរូវអោយប្រទេសជាសមាជិក បង្កើតនូវមជ្ឈមណ្ឌលទំនាក់ទំនង

GATS មាត្រា ៤ ការងារសេវាកម្មមួយ ឬ ច្រើន ដែលតាមរយៈមជ្ឈមណ្ឌលនេះ ប្រទេសជាសមាជិក អាចទទួលបាននូវពត៌មានផ្សេងៗ អំពីច្បាប់ទំលាប់នានា ដែលមានឥទ្ធិពលចំពោះផ្នែកសេវាកម្មទាំងឡាយដែលពាក់ព័ន្ធ ។ ក្រៅពីនេះ ដើម្បីជួយដល់អ្នកផ្គត់ផ្គង់សេវាកម្មនៅក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ កិច្ចព្រមព្រៀងបានអំពាវនាវដល់បណ្តាប្រទេសជឿនលឿន ជាសមាជិកទាំងឡាយ អោយបង្កើតឡើងនូវមជ្ឈមណ្ឌលទំនាក់ទំនងការងារសេវាកម្មផងដែរ ។ ដើម្បីទទួលបានពត៌មានចាំបាច់ពីមជ្ឈមណ្ឌលនេះ សហគ្រាសសេវាកម្មនានា ត្រូវតែបញ្ជូនសំណើរបស់ខ្លួន តាមរយៈរដ្ឋាភិបាល ដើម្បីស្នើសុំនូវពត៌មានពីមជ្ឈមណ្ឌលទំនាក់ទំនងការងារសេវាកម្ម ។ បញ្ជីមជ្ឈមណ្ឌលទំនាក់ទំនងការងារសេវាកម្ម មានភ្ជាប់នៅក្នុងឧបសម្ព័ន្ធ ២ នៃជំពូកនេះ ។

ការបង្កើតមជ្ឈមណ្ឌលទំនាក់ទំនងការងារសេវាកម្ម សំដៅបង្កើនល្បឿននៃការផ្តល់ពត៌មានក្នុងកិច្ចអាជីវកម្ម ។ ជាពិសេសកិច្ចព្រមព្រៀងតំរូវអោយ មជ្ឈមណ្ឌលទំនាក់ទំនងការងារសេវាកម្ម ផ្តល់នូវពត៌មាននានា ជូនដល់អ្នកផ្តល់សេវាកម្មតាមសំណើរបស់គេនៅក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ ÷

- ☐ លទ្ធភាពនៃការរកបាននូវបច្ចេកវិទ្យាសេវាកម្ម
- ☐ ទិដ្ឋភាពបច្ចេកទេស និងពាណិជ្ជកម្ម នៃការផ្គត់ផ្គង់សេវាកម្ម
- ☐ ការចុះបញ្ជី ការទទួលស្គាល់ និងការទទួលសិទ្ធិប្រកបមុខរបរ

GATS មាត្រា ៧ **ការទទួលស្គាល់ទៅវិញទៅមក នៃសមត្ថភាពក្នុងការផ្តល់សេវាកម្ម**

ក្រុមហ៊ុន ឬបុគ្គល ដែលប្រកបមុខរបរជាអ្នកផ្តល់សេវាកម្ម ត្រូវតែមានលិខិតអនុញ្ញាត ឬអាជ្ញាប័ណ្ណ ឬ លិខិតផ្តល់សិទ្ធិផ្សេងៗទៀតដែលអនុញ្ញាត អោយគេអាចប្រកបមុខរបរណាមួយបាន ។ អ្នកផ្តល់សេវាកម្ម បរទេសជារឿយៗ ជួបប្រទះការលំបាកក្នុងការទទួលបាននូវលិខិតអនុញ្ញាតិទាំងនោះ ដោយសារតែភាពខុសគ្នានៃលក្ខណ:តំរូវរបស់ច្បាប់ទៅលើគុណភាពនៃការបណ្តុះបណ្តាលនិងបទពិសោធន៍ការងារ ។ ដើម្បីដោះស្រាយនូវការលំបាកនេះ កិច្ចព្រមព្រៀងបានជំរុញអោយប្រទេសជាសមាជិកចុះកិច្ចសន្យាទ្វេភាគី និង ពហុភាគីលើការទទួលស្គាល់ទៅវិញទៅមកនូវលក្ខណ:ដែលតំរូវសំរាប់ ស្នើសុំលិខិតអនុញ្ញាតិនោះ ។ កិច្ចព្រមព្រៀងបានចែងបន្ថែមទៀតថា ប្រពន្ធ័នៃការទទួលស្គាល់ទៅវិញទៅមកនេះ ត្រូវបើកទូលាយសំរាប់អោយបណ្តាប្រទេសផ្សេងទៀតសុំចូលជាសមាជិក ប្រសិនបើប្រទេសទាំងនោះអាចបង្ហាញអោយឃើញថា ស្តង់ដារ និងតំរូវការក្នុងស្រុករបស់គេមានលក្ខណ:ដែលអាចប្រៀបធៀបបានទៅនឹងសង្គដាររបស់ប្រពន្ធ័ខាងលើនេះ ។

GATS មាត្រា ៧ ***វិធាននានាដែលគ្រប់គ្រង ចំពោះការផ្តល់សេវាកម្មផ្តាច់មុខ និងការអនុវត្តន៍ក្នុងអាជីវកម្ម ដែលមិនបើកចំហអោយមានការប្រកួតប្រជែង***

ឧស្សាហកម្មសេវាកម្ម ជារឿយ ៗ អនុវត្តសិទ្ធិអំណាចផ្តល់សេវាកម្មផ្តាច់មុខនៅក្នុងទីផ្សារក្នុងស្រុក សិទ្ធិផ្តាច់មុខក្នុងការផ្តល់សេវាកម្មនេះ ពេលខ្លះ រដ្ឋាភិបាលជាអ្នកផ្តល់ទៅអោយអ្នកផ្តល់សេវាកម្មមួយចំនួនតូចប៉ុណ្ណោះ ។ ក្នុងករណីណាក៏ដោយ ប្រទេសជាសមាជិកទាំងអស់មានកាតព្វកិច្ច ធានាមិនអោយអ្នកផ្តល់សេវាកម្មប្រើប្រាស់ដោយរំលោភនូវសិទ្ធិផ្តាច់មុខ ឬម៉ូណូប៉ូលរបស់គេ ឬ ធ្វើសកម្មភាពណាមួយដែលមិនស្របទៅនឹងកាតព្វកិច្ចជាទូទៅ ឬ កាតព្វកិច្ចជាក់លាក់ណាមួយតាមកិច្ចព្រមព្រៀងនេះឡើយ។

GATS មាត្រា៩ និង ១៩ — កិច្ចព្រមព្រៀងបានទទួលស្គាល់ទៀតថា អ្នកផ្តល់សេវាកម្មអាចប្រើប្រាស់ការអនុវត្តន៍ជាក់ស្តែងណាមួយដែលអាចរាំងរាំងដល់ការប្រកួតប្រជែង និងអាចជាការដាក់កំហិតលើការធ្វើពាណិជ្ជកម្ម ។ នៅពេលណាបញ្ហានៃលក្ខណៈបែបនេះកើតមាន បណ្តាប្រទេសជាសមាជិកដែលទទួលរងនូវផលប៉ះពាល់ មានសិទ្ធស្នើអោយប្រទេសជាសមាជិកណាដែលអ្នកផ្តល់សេវាកម្មស្ថិតនៅធ្វើការពិគ្រោះយោបល់ដើម្បីលប់ចោលការអនុវត្តន៍បែបនោះ ។

កាតព្វកិច្ចផ្សេងទៀតនៃក្របខណ្ឌនៃកិច្ចព្រមព្រៀង

ដូចបានគូសបញ្ជាក់រួចមកហើយថា ក្រៅពីកាតព្វកិច្ចទូទៅដែលបានកំណត់ខាងដើម[២៤] កិច្ចព្រមព្រៀងបានកំណត់នូវកាតព្វកិច្ចតាមលក្ខខណ្ឌមួយចំនួនទៀត ដើម្បីធានាការអនុវត្តន៍ការសន្យារបស់ប្រទេសនីមួយៗ ។ ទាក់ទងទៅនឹងវិស័យនេះ ការសន្យាអនុវត្តន៍ដែលបានប្រកាន់ឡើង រួមមានកាតព្វកិច្ចដូចតទៅ ÷

- GATS មាត្រា ៦.១ — ☐ ដើម្បីធានាអោយមានការគ្រប់គ្រងលើរាល់ការអនុវត្តន៍លិខិតបទដ្ឋានក្នុងស្រុកជាទូទៅណាមួយដែលបង្កផលប៉ះពាល់ដល់ពាណិជ្ជកម្មលើសេវាកម្ម តាមវិធីសមស្រប និងប្រកបដោយសត្យានុម័ត ។
- GATS មាត្រា ៦.២ — ☐ ដើម្បីរក្សា ឬ រៀបចំសាលាជំរះក្តី ឬ នីតិវិធីដែលកំណត់ពីការត្រួតពិនិត្យឡើងវិញលើសេចក្តីសំរេចរដ្ឋបាល ដែលប៉ះពាល់ដល់ពាណិជ្ជកម្មលើសេវាកម្ម ។
- GATS មាត្រា ៦.៣ — ☐ ដើម្បីចេញជូនអ្នកផ្តល់សេវាកម្មបរទេស នូវលិខិតអនុញ្ញាតិដែលបានតំរូវសំរាប់បែងចែកសេវាកម្មក្នុងរយៈពេលមួយសមស្រប ។
- GATS មាត្រា ៩ និង ១២ — ☐ មិនត្រូវអនុវត្តការដាក់កំហិតទៅលើការផ្ទេរ និងការទូទាត់ប្រាក់ទៅបរទេសទេ លើកលែងតែពេលដែលប្រទេសនោះ ស្ថិតនៅក្នុងស្ថានភាពលំបាកក្នុងការទូទាត់ជញ្ជីងតុល្យភាព ។

បទបញ្ញត្តិផ្សេងៗទៀត

វណ្ណ ៣៨ និងសង្ខេបពីបទបញ្ញត្តិផ្សេងៗទៀត ។

ឧបសម្ព័ន្ធនៃកិច្ចព្រមព្រៀង

នៅពេលកិច្ចប្រជុំ Uruguay ធ្វើសេចក្តីសន្និដ្ឋាន គេគិតថាប្រហែលជាមិនអាចបញ្ចប់ការចរចាអំពីសេរីភាវូបនីយកម្មពាណិជ្ជកម្មទៅលើវិស័យមួយចំនួនបានទេ ។ ដូច្នេះ ក៏មានការសំរេចថា ត្រូវរៀបចំជាឧបសម្ព័ន្ធបន្ថែមទៅលើក្របខណ្ឌកិច្ចព្រមព្រៀង ហើយដែលឧបសម្ព័ន្ធនោះនឹងកំណត់វិធាន បន្ថែមស្តីពីយថាប្រភេទតាមវិស័យ និងថែងពីគោលការណ៍ណែនាំបន្តសំរាប់ចរចា ធ្វើសេរីភាវូបនីយកម្មបន្ថែម ។ ដោយអនុលោមទៅតាមគោលការណ៍ណែនាំនេះ ការចរចាត្រូវបានធ្វើឡើងបន្ទាប់ ពីសម័យប្រជុំបានធ្វើការសន្និដ្ឋាន ដើម្បីកែលំអការសន្យាអនុវត្តលើអ្វីដែលពាក់ព័ន្ធទៅនឹងរូបវន្តបុគ្គល និងនៅក្នុងវិស័យដូចជា សេវាកម្មហិរញ្ញវត្ថុ និងទូរគមនាគមន៍ ។

---

[២៤] កាតព្វកិច្ចដែលវិធានស្តីពីការផ្តល់សេវាកម្មផ្តាច់មុខ (GATS មាត្រា៨) និងស្តីពីការបង្កើនការចូលរួម របស់បណ្តាប្រទេសកំពុងអភិវឌ្ឍន៍ (GATS មាត្រា៤) បានកំណត់ អាចលើកយកមកពិចារណា ដោយចាត់ទុកថា ជាកាតព្វកិច្ចតាមល័ក្ខខ័ណ្ឌ ទោះបីកាតព្វកិច្ចទាំងនោះ ត្រូវបានរាយនាមតាមផ្នែក ២ នៃ GATS ក៏ដោយ (កាតព្វកិច្ច និងគោលការណ៍) ។

ខណ្ឌ ៣៨

បទបញ្ញត្តិផ្សេងៗទៀតរបស់ GATS

បទបញ្ញត្តិផ្សេងៗទៀត ដែលមានចែងក្នុងក្របខ័ណ្ឌកិច្ចព្រមព្រៀងទូទៅស្តីពីសេវាកម្ម អាចចែកចេញជាពីរក្រុមសំខាន់ៗ។ ក្នុងបទបញ្ញត្តិក្រុមទីមួយ គ្របដណ្តប់លើវិស័យដែលកិច្ចព្រមព្រៀងចែងថា ត្រូវធ្វើការចរចា ។ បទបញ្ញត្តិក្រុមទីពីរ ផ្តល់នូវការលើកលែងមិនអនុវត្តវិធានទូទៅ ។

បទបញ្ញត្តិស្តីពីការចរចាក្នុងពេលអនាគត

កិច្ចព្រមព្រៀងបានចែងថា ប្រទេសជាសមាជិកត្រូវបន្តចរចាថែមទៀត លើវិស័យសេវាកម្ម ដើម្បីបង្កើតច្បាប់នានា ដែលគ្រប់គ្រងលើការប្រើប្រាស់ មធ្យោបាយឧបត្ថម្ភធន និងការអនុវត្តវិធានការការពារនានា ចំពោះពាណិជ្ជកម្មលើសេវាកម្ម ។

បទបញ្ញត្តិស្តីពីអញ្ញត្រកម្ម

សមាហរណកម្មសេដ្ឋកិច្ច : *កិច្ចព្រមព្រៀងអនុញ្ញាតិអោយប្រទេសជាសមាជិក ចូលជាសមាជិកតំបន់សេដ្ឋកិច្ចសេរី ដើម្បីធ្វើសេរីភាវូបនីយកម្មក្នុងចំណោមប្រទេស ដែលមានចំនួនសមាជិកកំណត់ ប្រសិនបើកិច្ចព្រមព្រៀងតាមតំបន់នោះមានចែងពីវិស័យសេវាកម្ម ហើយប្រទេសទាំងនោះបាន បំពេញទៅតាមលក្ខខ័ណ្ឌដែលបានកំណត់ ។*

ការដាក់កំហិតលើតុល្យភាពនៃការទូទាត់ : *ប្រទេសជាសមាជិក ត្រូវបានអនុញ្ញាតិអោយដាក់កំហិតលើការបង្វែរសាច់ប្រាក់ទូទាត់ ទោះបីក្នុងវិស័យសេវាកម្ម ដែលគេបានធ្វើការសន្យាហើយក៏ដោយ នៅពេលដែលសមាជិកនោះជួបប្រទះ បញ្ហាលំបាកក្នុងការរក្សាលំនឹងជញ្ជីងទូទាត់ ។*

សមាហរណកម្មទីផ្សារពលកម្ម : *កិច្ចព្រមព្រៀងពុំបានហាមឃាត់ប្រទេសសមាជិកណាមួយ មិនអោយធ្វើសមាហរណកម្មទាំងស្រុង នូវទីផ្សារពលកម្មរបស់ខ្លួន ទៅក្នុងប្រទេសមួយទៀត ដោយមិនគិតដល់សញ្ជាតិ នៃប្រជាជនរបស់ប្រទេសទាំងពីរក្នុងការទទួលបានសិទ្ធិធ្វើការនោះទេ ។*

អញ្ញត្រកម្មទូទៅ និងអញ្ញត្រកម្មដោយហេតុផលសន្តិសុខ: *ដូចគ្នានឹងការធ្វើពាណិជ្ជកម្មលើទំនិញដែរ កិច្ចព្រមព្រៀងនេះមិនបានហាមឃាត់ ប្រទេសជាសមាជិកមិនអោយអនុវត្តនូវវិធានការណ៍នានា ដែលគេយល់ថាជាការចាំបាច់ក្នុងការការពារសណ្តាប់ធ្នាប់សាធារណៈ ជីវិតមនុស្ស សត្វ និងរុក្ខជាតិ ឬសន្តិសុខ ចាំបាច់របស់ខ្លួនទេ។*

វិធានស្តីពីសេរីភាវូបនីយកម្មសេវាកម្ម

GATS មាត្រា ១៩:១ — GATS ចែងថា ការចរចាដើម្បីសំរេចបាននូវកំរិតសេរីភាវូបនីយកម្មខ្ពស់ .... ត្រូវធ្វើឡើង ....តាមមូលដ្ឋានផ្តល់អត្ថប្រយោជន៍ទៅវិញទៅមក " និងមានបំណង " ធានាតុល្យភាពនៃសិទ្ធិ និងកាតព្វកិច្ចជារួមអោយមានដូចគ្នា " ក្នុងចំណោមប្រទេសដែលបានចូលរួមទាំងអស់ ។

គោលការណ៍ដែលគ្រប់គ្រងលើការចូលរួមរបស់បណ្តាប្រទេសកំពុងអភិវឌ្ឍន៍

GATS មាត្រា ៤ និង ១៩ — ដើម្បីកំណត់ពីលក្ខណៈ និងវិសាលភាពនៃការសន្យាអនុវត្តដែលប្រទេសនានាបានទទួលយក វិធានបានចែងពីការពិចារណាទៅលើ:

☐ កត្តាសក្យានុម័តរបស់ជាតិ ។

GATS មាត្រា ១៩:២ — ☐ កំរិតនៃការអភិវឌ្ឍន៍របស់ប្រទេសនីមួយៗ ក្នុងវិស័យជារួម និងក្នុងវិស័យនីមួយៗ ។

GATS មាត្រា ១៩:២ ជាចុងក្រោយ វិធានបានចែងថា គួរព្រមព្រៀងផ្តល់ “ភាពដែលអាចបត់បែនសមស្រប” ដល់បណ្តាប្រទេសកំពុងអភិវឌ្ឍន៍ដែលបានចូលរួមនៅក្នុងការចរចា ដើម្បីអោយប្រទេសទាំងនោះមានលទ្ធភាពបំពេញការសន្យាអនុវត្តដោយ ÷

- ☐ បើកចំហវិស័យមួយចំនួនតូច
- ☐ ធ្វើសេរីភាវូបនីយកម្មការងារអាជីវកម្មមួយចំនួន
- ☐ ផ្សារភ្ជាប់លក្ខខណ្ឌនៃការបើកទីផ្សារ ជាកត្តាចាំបាច់សំរាប់សំរេចអោយបាននូវកម្មវត្ថុនៃការអភិវឌ្ឍន៍ ។ លក្ខខណ្ឌទាំងនេះអាចរួមមានការដាក់ពន្ធទៅលើអ្នកផ្គត់ផ្គង់បរទេស ដែលមានបំណងវិនិយោគនៅក្នុងឧស្សាហកម្មសេវាកម្ម ដូចជាការបង្កើតសាខា (ឬ ប្រភេទសាខាពាណិជ្ជកម្មផ្សេងទៀត) នៅក្នុងប្រទេស ការបង្កើតក្រុមហ៊ុនចំរុះ ឬ ផ្តល់មធ្យោបាយអោយក្រុមហ៊ុនក្នុងស្រុកទទួលបាននូវបច្ចេកវិទ្យា ពត៌មាន និងប្រភពចែកចាយទំនិញ ។

GATS មាត្រា ៤.៣ នៅក្នុងការចរចា វិធានបានតំរូវបន្ថែមទៀតថា គួរពិចារណាទៅលើ “ការលំបាក” របស់បណ្តាប្រទេសក្រីក្រ ក្នុងការទទួលយក “ការសន្យាអនុវត្ត ជាក់លាក់ដែលបានចរចាររួច ទាក់ទងទៅនឹងស្ថានភាពសេដ្ឋកិច្ចពិសេស ព្រមទាំងតំរូវការនៃការអភិវឌ្ឍន៍ តំរូវការពាណិជ្ជកម្ម និងតំរូវការហិរញ្ញវត្ថុរបស់គេ ។

ក្រៅពីបទបញ្ញត្តិពិសេសសំរាប់បណ្តាប្រទេសកំពុងអភិវឌ្ឍន៍ នៅមានការអនុវត្តន៍ផងដែរនូវគោលការណ៍ និងវិធានដែលគ្រប់គ្រងការធ្វើពាណិជ្ជកម្ម លើទំនិញ ដោយមានការកែតំរូវខ្លះ ជាការផ្លាស់ប្តូរជាមួយនឹងការធ្វើសម្បទានក្នុងពាណិជ្ជកម្មលើសេវាកម្ម ។ គោលការណ៍ទាំងនេះរួមមាន ÷

- ☐ គោលការណ៍ស្តីពីភាពអនុគ្រោះបំផុតផ្នែកពាណិជ្ជកម្ម (MFN)
- ☐ គោលការណ៍ប្រព្រឹត្តកម្មជាតិ និង
- ☐ វិធានដែលគ្រប់គ្រងលើប្រសិទ្ធិភាពចងភ្ជាប់នៃសម្បទានដែលបានចរចារួច

បណ្ណាល័យ
គ.ជ.អ.ម

ប្រព្រឹត្តកម្ម MFN

ក្នុងពាណិជ្ជកម្មលើទំនិញ គោលការណ៍MFN តំរូវថា បើប្រទេសណាមួយផ្តល់ “អត្ថប្រយោជន៍ភាពអនុគ្រោះ ឬ អាទិភាព” ទៅអោយប្រទេសមួយទៀត (ឧទាហរណ៍ ដោយកាត់បន្ថយអត្រាពន្ធគយ ឬ ដោយអនុវត្តវិធាន និងបែបបទសំរាប់ការនាំចូល និងនាំចេញ) នោះប្រទេសនោះត្រូវផ្តល់ លក្ខខណ្ឌដូចគ្នានេះដែរទៅអោយប្រទេសផ្សេងៗទៀត ។ កាតព្វកិច្ចនេះមានវិសាលភាពទៅលើប្រព្រឹត្ត MFN ដោយគ្មានល័ក្ខខ័ណ្ឌ ។

GATS មាត្រា ២:១ ឧបសម្ព័ន្ធនៃមាត្រា ២ ស្តីពីអញ្ញាត្រកម្ម

GATS ក៏កំណត់កាតព្វកិច្ចផងដែរទៅលើបណ្តាប្រទេសនានា ដើម្បីអនុវត្តគោលការណ៍ MFN អោយស្របទៅតាមកាតព្វកិច្ចរបស់បណ្តាប្រទេសផ្សេងទៀត ពាក់ព័ន្ធទៅនឹងវិធានការដែលគ្របដណ្តប់ដោយកិច្ចព្រមព្រៀងនេះនូវ “ប្រព្រឹត្តកម្មដែលមិនផ្តល់ភាពអនុគ្រោះតិចជាងអ្វីដែលបានព្រមព្រៀងគ្នាផ្តល់អោយអ្នកផ្គត់ផ្គង់សេវាកម្មនៃបណ្តាប្រទេសផ្សេងទៀតឡើយ” ។ កាតព្វកិច្ចដែលមានវិសាលភាពទៅលើប្រព្រឹត្តកម្មបែបនេះ អនុវត្តទៅលើច្បាប់ de jure និងតាមហេតុការណ៍ពិត de facto។ តែទោះជាយ៉ាងណា ក៏ដោយ GATS ទទួលស្គាល់ថា មិនមែនប្រទេសទាំងអស់សុទ្ធតែមានលទ្ធភាពទទួលយកកាតព្វកិច្ចបែបនេះ

GATS មាត្រា ២:២

បានភ្លាមនោះទេ ។ ដូច្នេះកិច្ចព្រមព្រៀងបានអនុញ្ញាតិអោយប្រទេសនានារក្សាទុកនូវវិធានការណា ដែលមិនស្របទៅតាមវិធាននេះបានក្នុងរយៈពេលអតិបរិមា ១០ ឆ្នាំ និងប្រសិនបើគេចង់ ។

ឧបសម្ព័ន្ធនៃមាត្រា ២ ស្តីពីអញ្ញាត្រកម្ម

វណ្ណ ៣៩ នឹងពន្យល់ពីមូលហេតុនៃការផ្តល់អញ្ញាត្រកម្មមួយចំនួនដល់បណ្តាប្រទេសទាំងនេះ ។ អញ្ញាត្រកម្ម គឺជាការលើកលែងបណ្តោះអាសន្ន ហើយតំរូវការក្នុងការរក្សាទុកអញ្ញាត្រកម្មនេះ នឹងត្រូវបានត្រួតពិនិត្យមើលជាប្រចាំក្នុងរយៈពេល ៥ ឆ្នាំម្តង ហើយអញ្ញាត្រកម្មទាំងនេះនឹងត្រូវលុបបំបាត់ចោលក្នុងរយៈពេល ១០ ឆ្នាំក្រោយ (មុនថ្ងៃទី ១ ខែ មករា ឆ្នាំ ២០០៥)។

គោលការណ៍ប្រព្រឹត្តកម្មជាតិ

គោលការណ៍នេះមានលក្ខណៈប្រហាក់ប្រហែលនឹងគោលការណ៍ប្រព្រឹត្តកម្ម GATS ដែរ ។ វិធានស្ដីពីប្រព្រឹត្តកម្មជាតិ GATT បានហាមឃាត់ បណ្ដាប្រទេសជាសមាជិកពីការកំណត់ពន្ធក្នុងស្រុកខ្ពស់ជាង ឬ ពីការអនុវត្តន៍បទបញ្ជាក្នុងស្រុកដែលមានលក្ខណៈតឹងរឹងទៅលើ ផលិតផលនាំចូលជាងការអនុវត្តន៍ទៅលើផលិតផលក្នុងស្រុកប្រហាក់ប្រហែលគ្នាផ្សេងទៀត ក្រោយពេលដែលផលិតផលនាំចូលនោះបានចូលមកដល់ក្នុងប្រទេសហើយ បានបង់ពន្ធ និងបង់ថ្លៃឈ្នួលផ្សេងៗទៀតរួចនៅព្រំដែនហើយ ។ ជាក់ស្ដែង វិធាននេះមានបំណងធ្វើយ៉ាងណា កុំអោយផលិតផលដែលផលិតក្នុងស្រុក បានទទួលកិច្ចគាំពារខ្ពស់ជាងដោយសារតែការកំណត់ពន្ធគយនោះ ។

GATS មាត្រា ១៧ ចាប់តាំងពីពេលដែលបណ្ដាប្រទេសមួយចំនួនឈប់កំណត់ពន្ធគយលើការនាំចូលសេវាកម្ម ការដាក់អោយអនុវត្តន៍គោលការណ៍ប្រព្រឹត្តកម្មជាតិដែលតំរូវ អោយប្រទេសនានាអនុវត្តបទបញ្ជាក្នុងស្រុកទៅលើអ្នកផ្គត់ផ្គង់បរទេស និងអ្នកផ្គត់ផ្គង់ក្នុងស្រុកស្មើគ្នាមកបានធ្វើអោយឧស្សាហកម្មសេវាកម្មក្នុងស្រុក ត្រូវបាត់បង់ការគាំពារទាំងស្រុងរបស់គេមួយរំពេច ។ ក្នុងករណីដែល វិធាន GATS ចែងថា ការពង្រីកគោលការណ៍ប្រព្រឹត្តកម្មជាតិ ដោយប្រទេសនានា អាចធ្វើឡើងដោយផ្អែកលើលទ្ធផលនៃការចរចា នោះក្នុងពេលចរចា គេអាចគូសបញ្ជាក់ពីវិស័យ ឬ វិស័យបន្ទាប់បន្សំផ្សេងណាមួយ និងលក្ខខ័ណ្ឌណាមួយ ដែលគេត្រៀមខ្លួនជាស្រេចដើម្បីពង្រីកប្រព្រឹត្តបែបនោះ ទៅលើអ្នកផ្គត់ផ្គង់ និងសេវាកម្មបរទេសបាន ។

ខណ្ឌ ៣៩

GATS អញ្ញត្រកម្មចំពោះវិធាន MFN

គោលបំណងមួយរបស់បណ្ដាប្រទេសជាសមាជិក ក្នុងការធ្វើអញ្ញត្រកម្មមិនអនុវត្តគោលការណ៍ MFN គឺដើម្បីរក្សាទុកការអនុគ្រោះផ្នែកពាណិជ្ជកម្ម លើវិស័យសេវាកម្មណាមួយ ដែលគេបានផ្ដល់ទៅអោយប្រទេសណាមួយក្រោមកិច្ចព្រមព្រៀងក្នុងតំបន់ ឬ កិច្ចព្រមព្រៀងផ្សេងទៀត ។ ដូច្នេះ បណ្ដាប្រទេសអឺរ៉ុបខាងជើង បានលើកលែងមិនអនុវត្តកាតព្វកិច្ចក្រោមគោលការណ៍ MFN ដើម្បីជំរុញកិច្ចសហប្រតិបត្តិការណ៍រវាងក្រុមប្រទេសទាំងនេះ ។ វិធានការណ៍ទាំងនេះរួមមាន ការធានា និងការផ្ដល់ប្រាក់កម្ចីទៅអោយបណ្ដាគំរោងវិនិយោគរបស់ក្រុមប្រទេសអឺរ៉ុបខាងជើង ព្រមទាំងផ្ដល់នូវជំនួយហិរញ្ញវត្ថុដល់ក្រុមហ៊ុន ដែលមានប្រភពពីក្រុមប្រទេសអឺរ៉ុបខាងជើង ដើម្បីប្រើប្រាស់បច្ចេកវិទ្យាបរិដ្ឋានផងដែរ។ សហភាពអឺរ៉ុបដោយអនុវត្តអញ្ញត្រកម្មគោលការណ៍ MFN បានផ្ដល់ការធានាមួយថា ផលប្រយោជន៍ដែលជាលទ្ធផលនៃកិច្ចព្រមព្រៀងពិសេស ដែលប្រទេសជាសមាជិកនៃសហភាពអឺរ៉ុបទទួលបានពីប្រទេសមួយក្រុម និងមិនត្រូវផ្ដល់ជាស្វ័យប្រវត្តិទៅដល់ប្រទេសណាមួយទេ(*)។ កិច្ចព្រមព្រៀងពិសេសអនុញ្ញាតិ អោយ ប្រទេសជាសមាជិកផ្ដល់សិទ្ធិធ្វើការបណ្ដោះអាសន្នអោយដល់ពលរដ្ឋ ពីបណ្ដាប្រទេស ក្នុងក្រុមនេះ លើមូលដ្ឋានកិច្ចសន្យារវាងក្រុមហ៊ុនមួយនៅក្នុងរដ្ឋនៃសហភាពអឺរ៉ុប ជាអ្នកផ្ដល់សេវាកម្ម ដូចជា: សំណង់ សណ្ឋាគារ និងអាហារដ្ឋានជាដើម ។

ប្រទេសខ្លះដែលបើកទូលាយរបបនាំចូលបានលើកលែងមិនអនុវត្តគោលការណ៍ MFN ក្នុងវិស័យសេវាកម្មហិរញ្ញវត្ថុ និងដឹកជញ្ជូនផ្លូវសមុទ្រ ។ គោលបំណងនៃការធ្វើបែបនេះ គឺរក្សាទុកការមានប្រៀបជាង ក្នុងការចរចាដើម្បីធ្វើសេរីភាវូបនីយកម្មជាមួយប្រទេសដែលមានការត្បិតត្បៀតក្នុងការធ្វើសេរីភាវូបនីយកម្ម ។ ក្នុងវិស័យសេវាកម្មហិរញ្ញវត្ថុ ប្រទេសមួយចំនួនខាងលើបានដកចេញនូវការលើកលែងនេះក្នុងការចរចា ក្រោយពេលបញ្ចប់ កិច្ចចរចាUruguay ។

វាជាការចាំបាច់ក្នុងការកត់សំគាល់ថា ប្រទេសជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក ត្រូវបានស្នើរអោយអនុវត្តសិទ្ធិរបស់ខ្លួនដើម្បីទទួលយកការ លើកលែងមិនអនុវត្តគោលការណ៍ MFN នៅមុនពេល GATT ចូលជាធរមាន ។ ប៉ុន្តែចំពោះវិស័យសេវាកម្ម ដែលត្រូវបន្តការចរចាបន្ទាប់ពីការបញ្ចប់ការចរចានៅ Uruguay (ដូចជា សេវាកម្មហិរញ្ញវត្ថុ និងទូរគមនាគមន៍) ប្រទេសជាសមាជិកអាច ទាមទារការមិនអនុវត្តគោលការណ៍ MFN នៅក្នុងរយៈពេលដែលការចរចាមិនទាន់បញ្ចប់ ។

* *បណ្ដាប្រទេសនៅអឺរ៉ុបខាងត្បូង ខាងកើត និងកណ្ដាល (រួមមាន ស្វ៊ីស អ៊ូបេគីស្ថង់ ហុងគ្រី និង បណ្ដាប្រទេសក្នុងតំបន់ មេឌីទែរ៉ាណេ) ។*

ប្រភេទ និងលក្ខណៈនៃការសន្យាអនុវត្ត

ក្នុងពាណិជ្ជកម្មលើសេវាកម្ម មិនមានការអនុវត្តន៍ពន្ធគយ និងពន្ធសារពើភណ្ឌទៅលើផលិតផលសេវាកម្ម ឬ អ្នកផ្តល់សេវាកម្ម ដែលបានចូលមកក្នុងទឹកដីនៃប្រទេសមួយទៀតទេ ។ ការការពារចំពោះឧស្សាហកម្មក្នុងស្រុក ត្រូវបានផ្តល់អោយតាមរយៈបទបញ្ញាក្នុងស្រុក ។ ដូច្នេះ ប្រទេសណាដែលមានបំណងធ្វើសេរីភាវូបនីយកម្ម ត្រូវធ្វើការសំរេចថាតើគួររក្សាទុកវិធានការណាខ្លះ ហើយត្រូវតែប្រែ ឬ លប់ចោលវិធានការណា ដើម្បីអោយស្របទៅតាមវិធាន GATS ។ វិធានការដែលត្រូវធ្វើការសំរេចនោះ គឺវិធានណាដែលបង្កផលប៉ះពាល់ដល់ផលិតផលសេវាកម្ម ឬ អ្នកផ្តល់សេវាកម្ម ដែលចូលមកកាន់ទីផ្សាររបស់ខ្លួន និងវិធានការណាដែលបង្កផលប៉ះពាល់ដល់សកម្មភាពមុនពេលរៀបចំបង្កើត (post-establishment activities) អ្នកផ្តល់សេវាកម្មបរទេស។ វិធានការទាំងនោះ រួមមានដូចតទៅ ÷

- ☐ វិធានការដែលដាក់កំហិតទៅលើការបើកទីផ្សារផលិតផល និងអ្នកផ្តល់សេវាកម្មបរទេស និង
- ☐ វិធានការដែលរើសអើងរវាងផលិតផល និងអ្នកផ្តល់សេវាកម្មបរទេស ជាមួយផលិតផលនិង អ្នកផ្តល់សេវាកម្មក្នុងស្រុក។

ទាក់ទងទៅនឹងវិធានការបើកទីផ្សារ បើប្រទេសមួយបានចូលរួមនៅក្នុងការសន្យាដែលបានចរចារួច មិនមានបំណងលប់ចោលល័ក្ខខ័ណ្ឌទាំងស្រុងទេនោះ កិច្ចព្រមព្រៀងអាចចែងថា ការសន្យាលប់ចោលរបស់ប្រទេសនោះ ត្រូវស្ថិតនៅក្រោមលក្ខខណ្ឌមួយចំនួន ។ ទំរង់នៃ ល័ក្ខខ័ណ្ឌទាំងនោះ មានរាយនាម នៅក្នុងមាត្រា ១៦ (សូមអានវណ្ឌ ៤០) ។ មិនអាចដាក់លក្ខខណ្ឌណាផ្សេងទៀតបានទេ។

ម៉្យាងទៀត នៅពេលដែលការសន្យារបស់ប្រទេសមួយមានវិសាលភាពទៅលើប្រព្រឹត្តកម្មជាតិនោះ ប្រទេសនោះ អាចមានលទ្ធភាពបន្តអនុវត្តការរើសអើងរវាងអ្នកផ្តល់សេវាកម្មបរទេស ជាមួយនឹងអ្នកផ្តល់សេវាកម្មក្នុងស្រុក ឬ រវាងផលិតផលសេវាកម្មបរទេស និងផលិតផលសេវាកម្មក្នុងស្រុកបាន (ឧទាហរណ៍ អត្រាពន្ធខ្ពស់ជាងលើប្រាក់ចំណេញដែលប្រមូល បានដោយក្រុមហ៊ុនធានារ៉ាប់រងបរទេស)។

ខណ្ឌ ៤០

លក្ខខ័ណ្ឌនានា ដែលប្រទេសជាសមាជិកមួយអាចអនុវត្តន៍បាននៅពេលធ្វើការសន្យាបើកទីផ្សារ

(កិច្ចព្រមព្រៀងទូទៅស្តីអំពីសេវាកម្ម, មាត្រាXVI)

- ☐ *កំណត់ចំនួនក្រុមហ៊ុនផ្តល់សេវាកម្ម (ដូចជា : ចំនួនធនាគារ រឺក្រុមហ៊ុនធានារ៉ាប់រងបរទេស អាចអនុញ្ញាត អោយបើកបានដោយកំណត់ចំនួនផ្នែក រឺសាខាច្បាស់លាស់ ។*
- ☐ *កំណត់បរិមាណតំលៃសរុបនៃសេវាកម្មដែលផ្គត់ផ្គង់ រឺកំណត់ធនធានសរុបដែលអនុញ្ញាត (ដូចជា : អនុញ្ញាតអោយក្រុមហ៊ុនបរទេសផ្តល់ការធានារ៉ាប់រងឡើងវិញក្នុងទឹកប្រាក់តែ ១០% ប៉ុណ្ណោះ)។*
- ☐ *កំណត់ចំនួនអ្នកផ្គត់ផ្គង់សេវាកម្មសរុប រឺកំណត់បរិមាណនៃផលិតផលសេវាកម្មដែលផលិត បាន។*
- ☐ *កំណត់បរិមាណរូបវន្តបុគ្គល ដែលត្រូវជួលអោយធ្វើការក្នុងវិស័យសេវាកម្មណាមួយ ឬ ដែលអ្នកផ្តល់ សេវាកម្មអាចជួល (ដូចជា : ច្បាប់ កំណត់ថា សមាជិកក្រុមប្រឹក្សាភិបាលភាគច្រើន ត្រូវតែជាពលរដ្ឋ ក្នុងស្រុក)*
- ☐ *អនុវត្តវិធានការដែលតំរូវអោយមាននីតិវិធីជាផ្លូវច្បាប់ (ដូចជា : ក្នុងវិស័យធានាគារ រឺ ធានារ៉ាប់រង សាខាក្រុមហ៊ុនបែបនេះត្រូវបង្កើត ជាសាជីវកម្មរួមគ្នា) ។*
- ☐ *កំណត់បរិមាណភាគហ៊ុន រឺទ្រព្យសម្បត្តិរបស់ជនបរទេសក្នុងការចូលរួមរកស៊ី (ដូចជា : ភាគហ៊ុនបរទេស មិនត្រូវអោយលើស ៤៩% នៃភាគហ៊ុនសរុប)*

លក្ខណៈនៃកាតព្វកិច្ចដែលការសន្យាបានកំណត់

ការសន្យា ដែលប្រកាន់យកដោយប្រទេសមួយ ត្រូវបានកត់ត្រាទុកនៅឧបសម្ពន្ធ័ស្តីពីការសន្យាអនុវត្តរបស់ GATS ។ ឧបសម្ព័ន្ធនីមួយៗ ត្រូវបានបែងចែកជា ពីរផ្នែក: គឺមួយតាម Horizontal commitment និងមួយទៀតតាមវិស័យ ។ Horizontal commitment អនុវត្តទៅ លើវិស័យសេវាកម្មទាំងអស់ ឯការសន្យាតាមវិស័យ អនុវត្តទៅលើវិស័យ ឬ អនុវិស័យសេវាកម្មជាក់លាក់ ។

ការចុះបញ្ជីនៅក្នុងឧបសម្ពន្ធ័នេះបង្ហាញអោយឃើញពីវិសាលភាពនៃការសន្យា ដែលប្រទេសមួយបានឯកភាពផ្តល់អោយ ។ ការសន្យាមានរាយនាម ដោយឡែកៗ សំរាប់របៀបផ្គត់ផ្គង់នីមួយៗ នៃរបៀបផ្គត់ផ្គង់ទាំងបួន ប្រភេទនៃការធ្វើពាណិជ្ជកម្មលើសេវាកម្មអន្តរជាតិ។ លក្ខណៈនៃការសន្យា ដែលអាចប្រកាន់យកតាមរបៀបផ្គត់ផ្គង់នីមួយៗ មានបង្ហាញជូននៅក្នុងវណ្ឌ៤១ ។

> ខណ្ឌ ៤១
>
> *លក្ខណៈនៃការសន្យាដែលអាចប្រកាន់យកតាមរបៀបផ្គត់ផ្គង់ទាំង ៤ យ៉ាង នៃការធ្វើពាណិជ្ជកម្មលើសេវាកម្មអន្តរជាតិ ។*
>
> ☐ *ការសន្យាបើកចំហទាំងស្រុង ។ "None" "គ្មានការរឹតត្បិត" : មានន័យថាប្រទេសជាសមាជិកមិនស្វែងរកការដាក់កំហិត រឹត្បិតផ្សេងៗ ក្នុងការបើកច្រកទីផ្សារ ដោយប្រើប្រាស់វិធានការនានា ដែលផ្ទុយនឹងមាត្រា XVI រឺ XVII នៃកិច្ចព្រមព្រៀងទេ ។*
>
> ☐ *ការបើកទីផ្សារដោយមានកំរិតកំណត់ ។ ប្រទេសជាសមាជិក កំណត់យ៉ាងល់អិតអំពី វិធានការនានាដែលផ្ទុយទៅនឹងវិធាន ច្បាប់នៃការបើកទីផ្សារ រឺប្រព្រឹត្តធម្មជាតិ ដែលខ្លួនរក្សាទុក ហើយសន្យាមិនអនុវត្តនូវវិធានការផ្សេងៗទៀតដែលផ្ទុយនឹងវិធានច្បាប់ ។*
>
> ☐ *គ្មានការសន្យាបើកទីផ្សារ : "Unbound" បញ្ជាក់ថាប្រទេសជាសមាជិកមួយរក្សាសិទ្ធិរបស់ខ្លួន ក្នុងការរក្សាទុក រឺ ប្រើប្រាស់នូវវិធានការ ផ្សេងៗ ដែលផ្ទុយទៅនឹងវិធានច្បាប់គ្រប់គ្រង លើការបើកច្រកទីផ្សាររឺប្រព្រឹត្តកម្មជាតិ ។*
>
> ☐ *គ្មានការសន្យាចំពោះលទ្ធិលទ្ធភាពសិក្សាផ្នែកបច្ចេកទេស : ប្រទេសជាសមាជិកបង្ហាញថា ផ្នែកសេវាកម្មដែលលើកឡើងនេះ ជាពិសេសរបៀប ផ្គត់ផ្គង់ណាមួយនោះ មិនអាចយកមកអនុវត្តបាន (ដូចជា: ការផ្តល់សេវាកម្មកាត់សក់ឆ្លងដែន)។*

ការសន្យាធ្វើសេរីភាវូបនីយកម្មតាម GATS

ជំពូកដែលរៀបរាប់ជារួមពីការសន្យាធ្វើសេរីភាវូបនីយកម្ម ដែលបានអនុវត្តឡើងនៅក្នុងពេល និង ក្រោយពេលកិច្ចប្រជុំនៅUruguay Round មាននៅក្នុងជំពូកស្តីពីវិស័យសេវាកម្ម ។ ដូចបានបញ្ជាក់ពីខាងដើមរួចមកហើយ ថា GATS បានចែងពីកិច្ចដំណើរការចរចាបន្តនៅក្នុងអង្គការពាណិជ្ជកម្មពិភពលោក ដើម្បីធ្វើសេរីភាវូបនីយកម្មលើពាណិជ្ជកម្មសេវាកម្ម ។ ដោយអនុលោមទៅតាមបទបញ្ញត្តិទាំងនេះ ការចរចាដើម្បីកែលំអការសន្យាធ្វើសេរីភាវូបនីយកម្មដែលបានប្រកាន់យកនៅក្នុងកិច្ចប្រជុំ Uruguay បានធ្វើឡើងទៅលើវិស័យមួយចំនួន ។

ឯកសារនៃការសន្យា

ការសន្យាធ្វើសេរីភាវូបនីយកម្ម ដែលបានប្រកាន់ឡើងដោយបណ្តាប្រទេសនានា មានរៀបរាប់នៅក្នុងឯកសារនៃការសន្យា

អនុវត្ត ។ វិសាលភាព និងល័ក្ខខ័ណ្ឌដែលគោលការណ៍គ្រឹះរបស់ GATS បានអនុវត្តតាម និងទៅលើ (ដូចជាការបើកទីផ្សារ ប្រព្រឹត្តកម្មជាតិ និងប្រព្រឹត្តកម្មMFN) វិស័យសេវាកម្មនីមួយៗ នៅក្នុងប្រទេសណាមួយ អាចវាយតំលៃបាន ដោយយោងទៅលើ ឯកសាររបស់ប្រទេសនោះ ទៅលើលក្ខណៈសម្បត្តិនៃរបបគ្រប់គ្រង ដែលមានជាធរមាន និងលក្ខណៈនៃការកំណត់ ប្រសិនបើមាន សំរាប់គ្រប់គ្រងការសន្យាអនុវត្តនោះ ។

ឯកសារ មានលក្ខណៈស្មុគស្មាញ ដោយសារឯកសារនោះ គ្របដណ្ដប់ទៅលើវិស័យចំនួន ១២ និងអនុវិស័យចំនួន ១៥ ។ សំរាប់អនុវិស័យនីមួយ ៗ ការសន្យាអនុវត្តមានចែងបន្តទៀត ដោយអនុលោមទៅតាមរបៀបផ្គត់ផ្គង់ បួនយ៉ាងនៃការធ្វើពាណិជ្ជកម្មសេវាកម្ម ។

ដូចបានបញ្ជាក់ពីខាងដើមថា ការសន្យាអនុវត្តតាមរបៀបផ្គត់ផ្គង់នីមួយៗ អាចជាការសន្យាបែប horizontal (ដែលគ្របដណ្ដប់លើសេវាកម្មគ្រប់ ប្រភេទ) ឬ ជាការសន្យាជាក់លាក់លើវិស័យ ឬ សកម្មភាពដែលលើកឡើងណាមួយ ។

វណ្ឌ៤២ បង្ហាញពីឧទាហរណ៍នៃឯកសារស្ដីពីការសន្យាបែប horizontal និង ការសន្យាជាក់លាក់ ។ នៅពេលដែលមិនមានការកំណត់ទៅលើរបៀបផ្គត់ផ្គង់ណាមួយ (ដូចជាការ ការសន្យាបើកចំហរទាំងស្រុង "None" "គ្មានការរឹតត្បិត" នៅក្នុងឯកសារ) ប្រទេសដែលចូលរួមនៅក្នុងការសន្យា ដែលមានប្រសិទ្ធិភាពចងភ្ជាប់ មិនអាចចាត់វិធានការថ្មីណាមួយ ដើម្បីដាក់កំហិតលើការបើកទីផ្សារ ឬ ដាក់កំហិតលើកិច្ចដំណើរការសេវាកម្មបានទេ ។ នៅពេលដែល មានការដាក់កំហិតទៅលើរបៀបផ្គត់ផ្គង់ណាមួយ (ដូចជា ការបង្កើតក្រុមហ៊ុន នាំអោយមានលក្ខខណ្ឌសំរាប់ដំណើរការសេវាកម្ម) នោះ ប្រទេសមានកាតព្វកិច្ច មិនត្រូវអនុវត្តការដាក់កំហិតណាមួយថែមទៀត ទៅលើការបើកទីផ្សារអោយអ្នកផ្ដល់សេវាកម្មបរទេសបានទេ ។ តែទោះជាយ៉ាងណាក៏ដោយ នៅពេលដែលគ្មានការសន្យាបើកទីផ្សារ "Unbound" តាមការសន្យាបែប horizontal ឬ ការសន្យាជាក់លាក់ណាមួយ យ៉ាងហោចណាស់នៅដំណាក់កាលនោះ ប្រទេសនោះ ត្រូវបង្ហាញថា ប្រទេសមានសិទ្ធិសេរីភាពក្នុងការកែប្រែបទបញ្ជារបស់គេ និងអាចមានលទ្ធភាព ផ្លាស់ប្ដូរល័ក្ខខណ្ឌនៃការបើកទីផ្សារអោយអ្នកផ្ដល់សេវាកម្មបរទេស ។

ការសន្យាបែប horizontal

ការកំណត់ស្ទើរតែទាំងអស់ តាមការសន្យាបែប horizontal ដែលបានប្រកាន់យកក្នុងពេលចរចា ត្រូវអនុវត្តទៅលើសេវាកម្មដែលចាំបាច់តំរូវអោយ មានវត្តមានក្រុមហ៊ុនពាណិជ្ជកម្មនៅក្នុងប្រទេសនាំចូល និង ទៅលើចលនារបស់រូបវន្តបុគ្គល ។

និយាយជារួម ប្រទេសជឿនលឿនមិនមានចែងពី ការកំណត់បែប horizontal ទៅលើការបង្កើតក្រុមហ៊ុនពាណិជ្ជកម្ម ដោយអ្នកផ្គត់ផ្គង់បរទេសទេ។ ការបង្កើតសាខាក្រុមហ៊ុន ឬ បុត្រសម្ព័ន្ធក្រុមហ៊ុនដោយអ្នកផ្គត់ផ្គង់សេវាកម្មបរទេស ដើម្បីដំណើរការសេវាកម្ម ឬ ដើម្បីធ្វើការវិនិយោគនៅក្នុង ឧស្សាហកម្មសេវាកម្មក្នុងស្រុក និងបន្តអនុញ្ញាតិអោយដំណើរការតាមច្បាប់ និង បទបញ្ជាដែលមានជាធរមាន ។ តាមវិធាន បទបញ្ជាទាំងនេះ ចែងពីការផ្ដល់លិខិតអនុញ្ញាតិដោយឈរលើលក្ខខណ្ឌសេរី ។

ក៏ប៉ុន្តែ នៅក្នុងឯកសារនៃកិច្ចប្រជុំនៅUruguay ភាគច្រើន ការសន្យាបែប horizontal ដែលពាក់ព័ន្ធទៅនឹងចលនារបស់រូបវន្តបុគ្គល ត្រូវបាន ដាក់កំហិតយ៉ាងច្រើនទៅលើ:

- ☐ ការផ្ទេររវាងក្រុមហ៊ុន (intra-company transfer) ដែលគ្របដណ្ដប់ទៅលើបុគ្គលិកសំខាន់ ៗ ដូចជា ប្រធានគ្រប់គ្រង និងបុគ្គលិកបច្ចេកទេស ដែលមានទំនាក់ទំនង
- ☐ ភ្ញៀវអាជីវករដែលជាភ្ញៀវមកទស្សនារយៈពេលខ្លី មិនបានធ្វើការពេញលេញនៅក្នុងប្រទេសជាម្ចាស់ ។

ខណ្ឌ ៤២:

ទំរង់ និងឧទាហរណ៍នៃឧសម្ព័ន្ធស្តីពីការសន្យាជាទូទៅតាមបែប horizontal និងតាមវិស័យជាក់លាក់

ការសន្យា	របៀបផ្គត់ផ្គង់	ល័ក្ខខ័ណ្ឌលើការបើកទីផ្សារ	ល័ក្ខខ័ណ្ឌ រឺលក្ខណ:តំរូវលើប្រព្រឹត្តកម្មជាតិ
ការសន្យាទូទៅ (ការសន្យាលើគ្រប់ផ្នែកសេវាកម្ម)	ការផ្គត់ផ្គង់ឆ្លងដែន	បើកចំហរ	បើកចំហរ, លើកលែងតែវិធានការយកពន្ធដែលធ្វើអោយមានការផ្តល់សិទ្ធិខុសគ្នានៃសេវាស្រាវជ្រាវ និងអភិវឌ្ឍន៍
	ការប្រើប្រាស់សេវាកម្មនៅក្រៅប្រទេស	បើកចំហរ	មិនបើកទីផ្សារចំពោះនយោបាយគាំពារដែលមានចែងក្នុងច្បាប់អនុញ្ញាត្តិអោយក្រុមហ៊ុនបរទេសមានភាគហ៊ុនតែ២៥% ចំពោះវិនិយោគថ្មីដែលមានទុនលើសពី
	ក្រុមហ៊ុនពាណិជ្ជកម្ម	អនុញ្ញាត្តិអោយក្រុមហ៊ុនបរទេសមានភាគហ៊ុន៤៩%	មិនបើកទីផ្សារការពារ ការលើកចំពោះនយោបាយគាំទឹកចិត្តផ្នែកពន្ធដារ
	ចលនាកំលាំងពលកម្ម	មិនបើកទីផ្សារ លើកលែងតែកិច្ចសហប្រតិបត្តិការផ្លាស់ប្តូរនាយកប្រតិបត្តិ រឺនាយកជាន់ខ្ពស់ អ្នកជំនាញក្នុងរយ:ពេលមួយឆ្នាំអ្នកជំនាញដោយផ្អែកលើបំរែបំរួលសេដ្ឋកិច្ចដែលចាំបាច់ត្រូវស្នាក់នៅធ្វើការច្រើនជាងមួយឆ្នាំ ។ ចំពោះអ្នកផ្តល់សេវាកម្មកំលាំងពលកម្មត្រូវបានអនុញ្ញាត្តិអោយស្នាក់នៅត្រឹមរយ:ពេល បីខែ	មិនបើកទីផ្សារ លើកលែងតែរូបវន្តបុគ្គលដូចបានបញ្ជាក់ក្នុងផ្នែកទីផ្សារ
ផ្នែកសេវាកម្មជាក់លាក់	ផ្គត់ផ្គង់ឆ្លងព្រំដែន	តំរូវអោយបើកក្រុមហ៊ុនតំណាង	មិនបើកទីផ្សារ
សេវាកម្មស្ថាបត្យកម្ម	ការប្រើប្រាស់សេវានៅក្រៅប្រទេស	បើកទីផ្សារ	បើកចំហរ
	ក្រុមហ៊ុនចូលមករកស៊ីតាមរយ:	២៥%នៃអ្នកគ្រប់គ្រង់ជាន់ខ្ពស់ជាជនក្នុងស្រុក ។	មិនបើកទីផ្សារ
	ចលនាកំលាំងពលកម្ម	មិនបើកទីផ្សារ លើកលែងតែដូចមានចែង នៅក្នុងតារាងនៃការសន្យាទូទៅ	មិនបើកទីផ្សារ,លើកលែងតែដូចមាន ចែងនៅក្នុងតារាងនៃចែងនៅក្នុងតារាងនៃការសន្យាទូទៅ

-ស្រាវជ្រាវ និងលក់ដូរ - វិនិយោគផ្ទាល់ពីបរទេស

សំណើដ៏សំខាន់មួយរបស់បណ្តាប្រទេសកំពុងអភិវឌ្ឍន៍គឺស្នើសុំអោយ បណ្តាប្រទេសជាសមាជិកនានា ត្រូវទទួលយកនូវការសន្យាអនុវត្តយ៉ាងពិត ប្រាកដ និងមានប្រសិទ្ធិភាពចងភ្ជាប់ដោយស្របច្បាប់ ដើម្បីអនុញ្ញាតិអោយអ្នកប្រកបវិជ្ជាជីវៈឯកជនណាមួយ ធ្វើការនៅក្រៅប្រទេសបាន ដោយមិនតំរូវអោយបង្កើតក្រុមហ៊ុន ឬ បង្កើតក្រុមហ៊ុនពាណិជ្ជកម្មក្នុងទំរង់ណាមួយផ្សេងទៀត ។ នៅក្នុងការចរចានាសម័យប្រជុំនៅ Uruguay គេបានបំពេញទៅតាមសំណើនេះ តែលើករណីមួយចំនួនតូចប៉ុណ្ណោះ។ ឯលទ្ធផលនៃការចរចាបន្ថែមទៀតដែលបានធ្វើឡើងក្រោយពេលចេញសេចក្តីសន្និដ្ឋាន នៃសម័យប្រជុំនោះគឺ ប្រទេសចំនួន ៦ បានធ្វើការកែលំអការសន្យារបស់គេ ។ សហគមន៍អឺរ៉ុប និងបណ្តាប្រទេសជាសមាជិករបស់គេ បានធានាថានឹងកែប្រែកាលានុវត្តន៍ភាពរបស់គេសំរាប់អ្នកប្រកបវិជ្ជាជីវៈបរទេស អោយបំពេញការងារជាបណ្តោះអាសន្ននៅក្នុងប្រទេសជាសមាជិកចំនួន ១៤ ទៀត ដោយមិនចាំបាច់បង្កើតក្រុមហ៊ុនពាណិជ្ជកម្មនៅទីនោះ (លើកលែងតែប្រទេស Portugal ចេញ) ។ ការសន្យាបន្ថែមទៀតរបស់ Switzerland និង Norway មានលក្ខណៈប្រហាក់ប្រហែលគ្នា ប៉ុន្តែខុសគ្នាត្រង់វិសាលភាព ។ ប្រទេសអូស្ត្រាលី បានអនុវត្តភាពដែលអាចបត់ បែនបានខ្លះទៅលើសំណើជាធរមានរបស់គេចំពោះភ្ញៀវដែលជាអាជីវករ ។ ប្រទេសឥណ្ឌា បានកែលំអការសន្យាខ្លះរបស់គេដែលមានពីមុន ។

ប្រទេសកំពុងអភិវឌ្ឍន៍មួយចំនួន បានកំណត់លក្ខខណ្ឌ ដែលតំរូវអោយអ្នកផ្តល់សេវាកម្មបរទេស បង្កើតកិច្ចព្រមព្រៀងចំរុះជាមួយឧស្សាហកម្ម សេវាកម្មក្នុងស្រុក ។ លក្ខខណ្ឌទាំងនេះ បានដាក់កំហិតបន្ថែមទៀតសំរាប់ករណីមួយចំនួន ដើម្បីអោយអ្នកផ្តល់សេវាកម្មបរទេសអាចកាន់កាប់ភាគហ៊ុនទ្រព្យសកម្មបានខ្លះ ។ ប្រទេសទាំងនេះ មួយចំនួនបានទាញយកអត្ថប្រយោជន៍ពីបទបញ្ញត្តិនៃកិច្ចព្រមព្រៀង ស្តីពីការបង្កើនការចូលរួមរបស់ បណ្តាប្រទេសកំពុងអភិវឌ្ឍន៍ និងបានកំណត់នូវការអនុញ្ញាត្តិជាក់ស្តែងក្នុងការបង្កើតក្រុមហ៊ុនពាណិជ្ជកម្មរបស់បរទេសដោយផ្អែកលើលក្ខណៈសម្បត្តិ ចាំបាច់នៃសេដ្ឋកិច្ច ដើម្បីពង្រឹងសមត្ថភាពសេវាកម្មក្នុងស្រុក និងការត្រៀមជាស្រេចរបស់អ្នកផ្តល់សេវាកម្មបរទេស ក្នុងការនាំមកនូវបច្ចេកវិទ្យាទាន់សម័យ (សូមអាន វណ្ឌ ៤៣ ដែលមានបញ្ជាក់លំអិត) ។

ខណ្ឌ ៤៣

លក្ខណៈនៃការកំណត់ដែលដាក់ដោយប្រទេសកំពុងអភិវឌ្ឍន៍នៅក្នុងតារាងនៃការសន្យាបែប (horizontal) ទូទៅដែលអនុញ្ញាត្តិអោយមាន ការបង្កើតក្រុមហ៊ុនរកស៊ីរបស់ជនបរទេស

ប្រទេសកំពុងអភិវឌ្ឍន៍មួយចំនួនបានទាញយកអត្ថប្រយោជន៍ពីបទបញ្ញត្តិដែលស្តីពីការចូលរួមរបស់ប្រទេសកំពុងអភិវឌ្ឍន៍ក្នុងកិច្ចព្រមព្រៀង និងបានកំណត់នូវការអនុញ្ញាត្តិជាក់ស្តែងក្នុងការបង្កើតក្រុមហ៊ុនពាណិជ្ជកម្មរបស់បរទេសដោយផ្អែកលើលក្ខណៈសម្បត្តិចាំបាច់នៃសេដ្ឋកិច្ច ដើម្បីពង្រឹងសមត្ថភាពសេវាកម្មក្នុងស្រុក ។ ការដាក់លក្ខ័ណ្ឌ ដើម្បីគោលដៅនេះរួមមាន ÷

☐ ការអនុញ្ញាតអោយក្រុមហ៊ុនបរទេសចុះបញ្ជីអាជីវកម្ម ត្រូវផ្អែកលើការរកស៊ីចំរុះហ៊ុន

☐ *អ្នកផ្តល់សេវាកម្មបរទេស នឹងត្រូវបានអនុញ្ញាត្តិអោយមានភាគហ៊ុនតិចជាងភាគហ៊ុនភាគច្រើនរបស់ក្រុមហ៊ុនចំរុះ។*

☐ *ចំនួនជាក់លាក់នៃសមាជិកក្រុមប្រឹក្សាភិបាល គឺជាជនក្នុងស្រុក ។*

☐ *អ្នកផ្តល់សេវាកម្មបរទេស ត្រូវប្រើប្រាស់បច្ចេកវិទ្យាជឿនលឿន សមស្រប និងមានបទពិសោធន៍ក្នុងការគ្រប់គ្រង ។*

☐ *ក្រុមហ៊ុនបរទេសត្រូវបណ្តុះបណ្តាល និងផ្ទេរបច្ចេកវិទ្យាទៅអោយអ្នកម៉ៅការបន្តក្នុងស្រុក*

☐ *ក្រុមហ៊ុនទាំងនេះត្រូវផ្តល់របាយការណ៍ត្រឹមត្រូវអោយបានគ្រប់គ្រាន់ និងចាប់ហ៉េសអំពីប្រតិបត្តិការរបស់ខ្លួនរួមមានទាំងខ្លឹមសារបច្ចេកវិទ្យា គណនេយ្យ សេដ្ឋកិច្ច និង រដ្ឋបាលផងដែរ ។*

ការសន្យាតាមវិស័យ (Sectoral Commitments)

ការសន្យាដែលប្រទេសនានា បានធ្វើឡើងនៅក្នុងឯកសារតាមវិស័យរបស់គេ ជាការបន្ថែមទៅលើការសន្យាតាមបែប Horizontal។ ក្នុងខណៈពេលដែលប្រទេសជឿនលឿនមួយចំនួន បានដាក់បញ្ចូលសេវាកម្មគ្រប់វិស័យទៅក្នុងឯកសារសន្យារបស់គេ ប្រទេសកំពុងអភិវឌ្ឍន៍ដែលអនុវត្តភាព អាចបត់បែនបានក្នុងកិរិតមួយ ហើយមានវិសាលភាពទៅលើវិស័យមួយចំនួនជាក់លាក់នោះ ក៏លើកយកមកពិចារណាទៅលើកត្តាដូចជា ដំណាក់កាលនៃការអភិវឌ្ឍន៍របស់គេផងដែរ ។

ប្រភេទនៃការកំណត់ដែលមានចែងនៅក្នុងឯកសារសន្យាតាមវិស័យ ទាក់ទងទៅនឹងលក្ខណៈសម្បត្តិនៃសកម្មភាពសេវាកម្ម និងពីរបៀបផ្គត់ផ្គង់នៃការផ្តល់សេវាកម្មនោះ ។ វាក្យខណ្ឌ ដែលនឹងពន្យល់ជាបន្តពីលក្ខណៈ និងខ្លឹមសារនៃការសន្យាដែលបានប្រកាន់ឡើង និងកំហិតដែលបានដាក់ទៅលើវិស័យចំនួន ៦ ក្នុងកិច្ចប្រជុំ និងក្រោយកិច្ចប្រជុំ Uruguay មាន ÷

- ☐ សេវាកម្មហិរញ្ញវត្ថុ
- ☐ សេវាកម្មទូរគមនាគមន៍
- ☐ សេវាកម្មមុខរបរវិជ្ជាជីវៈ
- ☐ សេវាកម្មសាងសង់ និង វិស្វកម្មពាក់ព័ន្ធ
- ☐ សេវាកម្មសង្គម និង សេវាកម្មដែលពាក់ព័ន្ធនឹងសុខាភិបាល
- ☐ សេវាកម្មពិគ្រោះយោបល់លើការគ្រប់គ្រង

សេវាកម្មវិស័យទាំងនេះ បានកំណត់ឡើង ដើម្បីជាគោលបំណងនៃមគ្គុទេសក៏នេះ ក្នុងចំណោមវិស័យ ដែលប្រទេសកំពុងអភិវឌ្ឍន៍កំពុងពិចារណា ថាមានសក្តានុពលសំរាប់អភិវឌ្ឍន៍ពាណិជ្ជកម្មនាំចេញ ឬ សំរាប់ជាផលប្រយោជន៍ពីការធ្វើសេរីភាវូបនីយកម្មលើការនាំចូល ។

សេវាកម្មហិរញ្ញវត្ថុ

សេវាកម្មហិរញ្ញវត្ថុ មានពីរប្រភេទធំៗ គឺ : សេវាកម្មធានារ៉ាប់រង និងសេវាកម្មធនាគារ ដែលសេវាកម្មទាំងពីរប្រភេទនេះគ្របដណ្តប់លើសកម្មភាព មួយចំនួនធំ ។ សេវាកម្មធានារ៉ាប់រង រួមមានទាំងការធានារ៉ាប់រងលើជីវិត និងការធានារ៉ាប់រងក្រៅជីវិត (non life insurance) ការធានារ៉ាប់រងអន្តរភារី និងការធានារ៉ាប់រងបន្ទាប់បន្សំ ។ សេវាកម្មធនាគារ រួមមានសេវាកម្មតាមទំនៀមទំលាប់ ដូចជាការទទួលយកប្រាក់បញ្ញើរ ការអោយខ្ចីប្រាក់កម្ចីគ្រប់ប្រភេទ សេវាកម្មផ្ញើប្រាក់ និងទូទាត់ប្រាក់ ។ សេវាកម្មនេះ ក៏គ្រប់ដណ្តប់ផងដែរទៅលើពាណិជ្ជកម្មនៃការផ្លាស់ប្តូរប្រាក់ ឧបករណ៍ហិរញ្ញវត្ថុនិស្សន្ទ ប្រាតិភោគដែលមានការធានាទីភ្នាក់ងាររូបិយវត្ថុ ការគ្រប់គ្រងទ្រព្យសកម្ម សេវាកម្មដោះស្រាយ និងផាត់ទាត់ ការចែកចាយ និងផ្ទេរពត៌មានផ្នែកហិរញ្ញវត្ថុ និងសេវាកម្មហិរញ្ញវត្ថុបន្ទាប់បន្សំផ្សេង ១ ទៀត ។

ការចរចាលើវិស័យនេះបានធ្វើជាបន្តទៀត ក្រោយពេលបញ្ចប់កិច្ចប្រជុំនៅ Uruguay ដោយសារគេថា ការវិវត្តន៍ដែលសំរេចបានក្នុងពេលប្រជុំនោះ មិនសមស្របតាមបំណងរបស់គេទេ ។ ការចរចាជាថ្មី បានធ្វើឡើងជាពីរដំណាក់កាល ហើយបានបញ្ចប់ទៅនៅខែធ្នូ ឆ្នាំ ១៩៩៧ ។

ចាប់ពីពាក់កណ្តាលទសវត្សន៍ ៨០ មក បណ្តាប្រទេសភាគច្រើន បានធ្វើការវិវត្តន៍ច្រើនគួរអោយកត់សំគាល់នៅក្នុងវិស័យនេះ ដោយការលប់បំបាត់ចោលរបាំងផ្សេងៗ ឬ លប់ចោលការដាក់កំហិតលើបរិមាណ ការបង្កើតសាខា ឬ ក្រុមហ៊ុនពាណិជ្ជកម្មផ្សេងៗ ដោយស្ថាប័នបរទេស ឬ កិច្ចប្រតិបត្តិការអាជីវកម្មរបស់គេ ។ បណ្តាប្រទេសជឿនលឿនបានចាត់វិធានការសេរីភាវូបនីយកម្មតាមកិច្ចព្រមព្រៀងដែលបានសំរេចកន្លងមក ក្រោមការឧបត្ថម្ភរបស់អង្គការសំរាប់កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងការអភិវឌ្ឍន៍ (OECD) ។ ប្រទេសកំពុងអភិវឌ្ឍន៍មួយចំនួនធំ ដែលកន្លងមកបានអនុវត្តតាមគោលនយោបាយការពារខ្ពស់ ក៏បានចាប់ផ្តើម

ជាឯកច្ឆន្ទនូវដំណើរការសេរីភាវូបនីយកម្មផងដែរ តាមរយៈការកាត់បន្ថយបន្តិចម្តងៗ នូវការហាមឃាត់ ឬ ការដាក់កំហិតយ៉ាងតឹងតែងទៅលើប្រភេទអាជីវកម្មផ្សេងៗ ដែលធនាគារបរទេសអាចដំណើរការបាន ។

ការចរចាមុនកិច្ចប្រជុំ Uruguay បានផ្តល់សមិទ្ធិផលបន្ថែមទៀត ក្នុងវិធានការសេរីភាវូបនីយកម្ម ដែលបានប្រកាន់យកពីមុនមកនៅក្នុងអនុវិស័យ ធានារ៉ាប់រង និង បញ្ចូលទៅក្នុងការសន្យាដែលមានប្រសិទ្ធិភាពចងភ្ជាប់នៃវិធានការដែលបានប្រកាន់យករួចមកហើយ។ ការសន្យាអនុវត្តទាំងនេះ ពាក់ព័ន្ធទៅនឹងវត្តមានក្រុមហ៊ុនពាណិជ្ជកម្មរបស់អ្នកផ្តល់សេវាកម្មបរទេស (សាខា បុត្តសម្ព័ន្ធ ភ្នាក់ងារ ការិយាល័យតំណាង) និងលប់បំបាត់ចោល ឬ បន្ធូរបន្ថយលើការដាក់កំណត់ចំពោះ ÷

- ☐ កម្មសិទ្ធិភាពរបស់ជនបរទេសក្នុងស្ថាប័នហិរញ្ញវត្ថុក្នុងស្រុក ។
- ☐ កំណែទំរង់គតិយុត្តនៃវត្តមានរបស់ក្រុមហ៊ុនពាណិជ្ជកម្ម ។
- ☐ ការពង្រីកកិច្ចដំណើរការដែលមានស្រាប់ ។

ប្រទេសកំពុងអភិវឌ្ឍន៍មួយចំនួន ខិតខំធានាអោយ សេវាកម្មធានារ៉ាប់រង និង ឧស្សាហកម្មធនាគារ ស្ថិតនៅក្រោមការប្រកួតប្រជែងពីបរទេសបន្តិចម្តងៗ ដោយការកំណត់លើការដាក់ភាគទុនរបស់បរទេស (មិនអោយលើសពី ៤៩ ភាគរយ) និងដាក់កំហិតទៅលើចំនួនអ្នកផ្តល់សេវាកម្មបរទេស (ចំនួន សាខាដែលត្រូវបង្កើត មិនអោយលើសពី ១៥ ក្នុងរយៈពេលកំណត់) ។

GATS ឧបសម្ព័ន្ធស្តីពីសេវាកម្មហិរញ្ញវត្ថុ មាត្រា ២០

ជាសំខាន់ត្រូវកត់សំគាល់នៅក្នុងបរិបទនេះថា GATS ទទួលស្គាល់ថា រដ្ឋាភិបាលអាចយល់ឃើញថា កិច្ចព្រមព្រៀងនេះមានភាពចាំបាច់ក្នុងការអនុវត្តការគ្រប់គ្រងតាមច្បាប់គួរអោយកត់សំគាល់ ទៅលើសកម្មភាពធនាគារ ក្រុមហ៊ុនធានារ៉ាប់រង និងគ្រឹះស្ថានហិរញ្ញវត្ថុផ្សេងៗទៀត ។ ដូច្នេះ ឧបសម្ពន្ធ័នៃកិច្ចព្រមព្រៀងនេះស្តីអំពីសេវាកម្មហិរញ្ញវត្ថុ បានចែងថា ការសន្យាធ្វើសេរីភាវូបនីយកម្ម ដែលបានប្រកាន់យកមិនអាចរារាំងមិនអោយប្រទេសមួយចំនួន ចាត់វិធានការលើមូលហេតុប្រុងប្រយ័ត្នណាមួយ រួមមានទាំងការការពារវិនិយោគិន អ្នកផ្ញើប្រាក់អ្នកអនុវត្តគោលនយោបាយ... ឬ ដើម្បីធានាដល់ភាពសុចរិត និងស្ថេរភាពនៃប្រព័ន្ធហិរញ្ញវត្ថុនោះបានទេ ។ ទោះបីជាឧបសម្ព័ន្ធមិនមានចែងលំអិតថា អ្វីជាវិធានការប្រុងប្រយ័ត្នក៏ដោយ ក៏តំរូវការនៃការចេញអាជ្ញាប័ណ្ណ ហាក់ដូចជាមានបំណងធានាដល់ភាពសុចរិតផ្នែកហិរញ្ញវត្ថុ និងសមត្ថកិច្ចអាជីកម្ម ហើយតំរូវការមូលធនអប្បបរិមា និងតំរូវការគណនេយ្យកម្មទៀងទាត់ ក៏អាចទុកថាជាវិធានប្រុងប្រយត្ន័បានដែរ ។ វិធានការទាំងនេះ មិនចាំបាច់ត្រូវមានភាពរើសអើងទេ ប៉ុន្តែអាចអនុវត្តបានដោយរើសអើងប្រសិនបើមានការធានាតាមកាលៈទេសៈ ។

ទូរគមនាគមន៍

សេវាកម្មទូរគមនាគមន៍ ដើរតួពីរយ៉ាងនៅក្នុងសេដ្ឋកិច្ចរបស់ប្រទេស ៖ ទីមួយ វាផ្តល់នូវហេដ្ឋារចនាសម្ពន្ធ័ប្រាស្រ័យទាក់ទង និងទីពីរ ដើរតួជាខ្សែរយៈសំរាប់ធ្វើពាណិជ្ជកម្មផងដែរ ។ កន្លងមក ដោយសារសេវាកម្មទូរគមនាគមន៍មានសារៈសំខាន់ផ្នែកអភិវឌ្ឍន៍ហេដ្ឋារចនាសម្ពន្ធ័ មានសារៈសំខាន់ ជាយុទ្ធសាស្ត្រ និងនយោបាយទៅលើប្រទេសមួយចំនួន ទើបឧស្សាហកម្មនេះត្រូវបានអភិវឌ្ឍន៍ក្រោមភាពផ្តាច់មុខរបស់រដ្ឋ ។ តែទោះជាយ៉ាងណាក៏ដោយ ក៏បំលាស់ប្តូរផ្នែកបច្ចេកវិទ្យា និងបច្ចេកវិទ្យាពត៌មាននៅក្នុងទូរគមនាគមន៍នេះ បានបង្កើតលទ្ធភាពអោយសហគ្រាសពាណិជ្ជកម្ម ផ្តល់ជូននូវ ផលិតផលសេវាកម្ម និងទំនិញនៅទីផ្សារអន្តរជាតិតាមតំលៃដែលមានលក្ខណៈប្រកួតប្រជែងបាន ដោយសារការមានសេវាកម្មទាក់ទងទាន់សម័យ និងថោកជាង ។ ការទទួលស្គាល់ថាវិស័យបច្ចេកវិទ្យាដែលមានភាពជឿនលឿន និងកែលំអភាពប្រកួតប្រជែងបានបន្តិចម្តងៗ នោះបានដឹកនាំទៅរកការធ្វើឯកជនភាវូបនីយកម្មនៃភាពម៉ូណូប៉ូលីរបស់រដ្ឋ និងការលប់ចោលការដាក់កំហិតលើការបើកទីផ្សារអោយអ្នកផ្តល់សេវាកម្មបរទេស និងផលិតផលរបស់គេ ។

សេវាកម្មទូរគមនាគមន៍មានពីរប្រភេទធំ ៗ គឺសេវាកម្មទូរគមនាគមន៍ជាមូលដ្ឋាន និងសេវាកម្មដែលមានតំលៃបន្ថែម ។

សេវាកម្មទូរគមនាគមន៍ជាមូលដ្ឋាន គ្របដណ្តប់ទៅលើ " សេវាកម្មបញ្ជូន (ដឹកជញ្ជូន) ទូរគមនាគមន៍ណាមួយ" ។ សេវាកម្មបែបនេះរួមមានការបញ្ជូនសំលេង (voice telephony) ការបញ្ជូនទិន្នន័យ តេឡិច តេលេក្រាម ទូរសារ សេវាកម្មសុីគ្វី ដែលជួលឯកជន

(ដូចជា សមត្ថភាពនៃការលក់ ឬ ជួលសេវាបញ្ជូនសារ) និង សេវាកម្មបណ្តាញប្រព័ន្ធការងារ (ដូចជា ហេដ្ឋារចនាសម្ព័ន្ធទូរគមនាគមន៍ដែលអនុញ្ញាតិអោយមានសេវាកម្ម ទូរគមនាគមន៍រវាង និងក្នុងចំណោមចំណុចគោលដៅនៃប្រព័ន្ធការងារដែលបានកំណត់) ។

សេវាកម្មដែលមានតំលៃបន្ថែម គឺជាសេវាកម្មណាដែលតាមរយៈសេវាកម្មនោះ អ្នកផ្តល់សេវាកម្មបន្ថែមតំលៃទៅលើអតិថិជនដោយការកែលំអទំរង់ ឬ ខ្លឹមសារ ឬ ដោយការផ្តល់កន្លែងរក្សាទុក និងការដកស្រង់ពត៌មាន ។ សេវាកម្មបែបនេះ រួមមានការបញ្ជូនពត៌មានតាមសារ សារជាសំលេង ការបញ្ជូនពត៌មានតាមបណ្តាញ និងការដកស្រង់ទិន្នន័យតាមសារ ការផ្លាស់ប្តូរទិន្នន័យអេឡិចត្រូនិក សេវាកម្មទូរសារដែលមានតំលៃបន្ថែម/ដែលបានកែលំអ រួមមានទាំងការរក្សាទុក និងការបញ្ជូនបន្ត ការរក្សាទុក និងការដកស្រង់យកសារ ការផ្លាស់ប្តូរក្រម និងពិធីសារ និងពត៌មានតាមបណ្តាញ ទូរសព្ទ និង/ឬ ការបញ្ជូនទិន្នន័យ (រួមមានទាំងកិច្ចដំណើរការអាជីវកម្មផង) ។

ការចរចានៅក្នុងវិស័យនេះ បានបន្តធ្វើទៀត ក្រោយកិច្ចប្រជុំនៅ Uruguay ដោយសារក្នុងសម័យប្រជុំនោះ មានការសំរេចតិចតួចប៉ុណ្ណោះទៅលើ ការធ្វើសេរីភាវូបនីយកម្មលើសេវាកម្មទូរគមនាគមន៍ជាមូលដ្ឋាន ។ ការចរចាជាថ្មី បានបញ្ចប់សព្វគ្រប់នៅក្នុងខែ កុម្ភៈ ឆ្នាំ ១៩៩៧ ។ ការចរចានេះ មានបំណងជាបឋម គឺការធ្វើសេរីភាវូបនីយកម្មក្នុងសេវាកម្មទូរគមនាគមន៍ជាមូលដ្ឋាន ទោះបីមានប្រទេសមួយចំនួនតូចបានកែលំអរការសន្យារបស់គេ ដែលបានធ្វើក្នុងកិច្ចប្រជុំយូរ៉ុយហ្គាយ លើសេវាកម្មតំលៃបន្ថែមក៏ដោយ ។

ការសន្យាដែលបានធ្វើ បានគ្របដណ្តប់ទៅលើសេវាកម្មទូរគមនាគមន៍ជាមូលដ្ឋានទាំងអស់ ។ លើសេវាកម្មទូរសព្ទជាសំលេង បណ្តាប្រទេសនានាបាន ប្តេជ្ញាសន្យាដោយខ្លួនឯង ថានឹងអនុញ្ញាតិអោយមានការប្រកួតប្រជែងពីអ្នកផ្តល់សេវាកម្មបរទេសទៅលើការផ្តល់សេវាកម្មទូរសព្ទក្នុងស្រុក លើសេវាកម្មទូរសព្ទចំងាយឆ្ងាយ និងសេវាកម្មទូរសព្ទអន្តរជាតិ ។ ក៏ប៉ុន្តែការផ្តល់សំណើលើសេវាកម្មទូរសព្ទតាមសំលេងជាសាធារណៈជាង ៤០ ភាគរយ របស់រដ្ឋាភិបាលបានបង្ហាញថា សំណើទាំងនេះត្រូវអនុវត្តមុនកាលបរិច្ឆេទដែលបានកំណត់នៅក្នុងឯកសារឧបសម្ព័ន្ធរបស់គេ ។ វិស័យសេវាកម្មផ្សេងទៀត ដែលគេបានសន្យារួចមកហើយ ដើម្បីអនុញ្ញាតិអោយមានការប្រកួតប្រជែងពីបរទេសនោះ រួមមាន កិច្ចប្រតិបត្តិការទូរសព្ទចល័ត/សែលុយឡា សេវាកម្មស៊ីត្លីជួល (ដូចជាទិន្នន័យទូរសព្ទចល័ត និងការ paging) និងសេវាកម្មផ្កាយរណបចល័ត ។

ដោយសាររចនាសម្ព័ន្ធនៃឧស្សាហកម្មនេះ ទិដ្ឋភាពដ៏សំខាន់នៃការចរចាទៅលើវិស័យទូរគមនាគមន៍ គឺការទទួលស្គាល់ថាក្រោយពេលធ្វើសេរីភាវូបនីយកម្ម និងឯកជនភាវូបនីយកម្មហើយ ការគ្រប់គ្រងផ្តាច់មុខរបស់ក្រុមហ៊ុនឯកជនដែលផ្តល់សម្បទានទូរគមនាគមន៍ជាមូលដ្ឋានអាចមានលទ្ធភាពអនុវត្តនោះ មិនអាចដឹកនាំទៅរកការប្រើប្រាស់ប្រកបដោយប្រសិទ្ធិភាព និងចំណាយទាបចំពោះអ្នកប្រើប្រាស់សេវាកម្មនេះបានទេ ។

ដូច្នេះ ជាសំខាន់ បណ្តាប្រទេសនានាដែលប្រកាន់យកនូវវិធានការសេរីភាវូបនីយកម្ម ត្រូវរៀបចំប្រព័ន្ធគ្រប់គ្រង ដើម្បីធានាអោយអ្នកប្រើប្រាស់មានលទ្ធភាពទទួលបាននូវសម្បទាទូរគមនាគមន៍ជាមូលដ្ឋានតាមលក្ខខណ្ឌប្រកបដោយយុត្តិធម៌ ។ ការទទួលស្គាល់នេះបានបង្ហាញអោយឃើញនៅក្នុងការអនុម័ត "ឯកសារជាអាទិភាព" ដែលកំណត់នូវគោលការណ៍ និងវិធានដែលត្រូវអនុវត្តតាម ដើម្បីធានាមិនអោយក្រុមហ៊ុនដែលមានស្រាប់នោះ អនុវត្តវិធានការប្រឆាំងនឹងការប្រកួតប្រជែង រាំងមិនអោយក្រុមហ៊ុនថ្មីចូលមកក្នុងទីផ្សារ ហើយគិតថ្លៃឈ្នួលខ្ពស់ពីអតិថិជន ជាងថ្លៃឈ្នួលដែលបានកំណត់ ។ គោលការណ៍ និងវិធានទាំងនេះ អនុវត្តទៅលើ៖

- ☐ ការបង្កើតអាជ្ញាធរគ្រប់គ្រងឯករាជ្យ
- ☐ ការអនុម័តវិធានការការពារភាពប្រកួតប្រជែង
- ☐ វិធានការ ដើម្បីធានាដល់ការតភ្ជាប់ទៅវិញទៅមក
- ☐ ការផ្តល់អាជ្ញាប័ណ្ណប្រកបដោយតំលាភាព និងមិនរើសអើង
- ☐ កាតព្វកិច្ចផ្តល់សេវាកម្មជាសាកល

សេវាកម្មមុខរបរវិជ្ជាជីវៈ: សេវាកម្មគណនេយ្យកិច្ច

សេវាកម្មមុខរបរវិជ្ជាជីវៈ គ្របដណ្តប់ទៅលើសេវាកម្មមួយចំនួនធំ ដូចជាសេវាកម្មច្បាប់ ស្ថាបត្យកម្ម ពេទ្យ និងគណនេយ្យកិច្ច។ ការចរចាមុនកិច្ចប្រជុំ Uruguay លើវិស័យនេះ បានផ្តោតអារម្មណ៍ជាសំខាន់ទៅលើសេវាកម្មគណនេយ្យកិច្ច ។

គណនេយ្យកិច្ច មានសារៈសំខាន់ទៅលើផលិតកម្មទំនិញជារូបវន្ត និងទំនិញជាសេវាកម្ម។ សកម្មភាពមួយចំនួនធំ ដែលបំពេញដោយក្រុមហ៊ុន គណនេយ្យកិច្ច មានភាពទូលំទូលាយ និងកំពុងមានការរីកលូតលាស់ ។ នេះដោយសារកត្តាថា ជំនាញដែលបានអភិវឌ្ឍន៍ដោយជំនាញគណនេយ្យកិច្ច ដើម្បីផលិត ដំណើរការវិភាគ និងធ្វើសវនកម្មលើព័ត៌មានហិរញ្ញវត្ថុ អាចយកមកប្រើប្រាស់បានសំរាប់គោលបំណងផ្សេងទៀត ។ ជាលទ្ធផល និងក្រៅពីតួនាទីតាមទំនៀមទំលាប់របស់គេ ក្នុងការអនុវត្តន៍តំរូវការប្រុងប្រយត្ន័ និង វិធានការគ្រប់គ្រងហិរញ្ញវត្ថុ ក្រុមហ៊ុនទាំងនេះ កំពុងបង្កើនការផ្តល់សេវាកម្មសំរាប់ការវិនិយោគ និងពន្ធដារ សេវាកម្មសវនកម្មថ្មីៗ និងការពិគ្រោះយោបល់លើការគ្រប់គ្រងផ្សេងៗទៀត ។

តំរូវការលើសេវាកម្មគណនេយ្យកិច្ច មានចរន្តមកពីតំរូវការចាំបាច់តាមច្បាប់ជាតិស្តីពីក្រុមហ៊ុន និង អតិថិជនដែលស្វែងរកយោបល់លើបញ្ហាផ្សេង ៗ ។ សេវាកម្មបែបនេះភាគច្រើនធ្វើឡើងសំរាប់ផ្តល់ជូនសហគ្រាស ទោះបីមានបុគ្គលជារូបវន្តប្រើប្រាស់សេវាកម្មគណនេយ្យកិច្ចនេះក៏ដោយ ។

សេវាកម្មមុខរបរវិជ្ជាជីវៈ ដែលរួមមានទាំងគណនេយ្យកិច្ចផងនោះ ត្រូវបានគ្រប់គ្រងដោយវិធីផ្សេងៗ របស់ប្រទេសនីមួយ ៗ (និងពេលខ្លះសូម្បីតែ នៅក្នុងប្រទេសជាច្រើនក៏ដោយ) ។ បទបញ្ញាគ្រប់គ្រង គ្របដណ្តប់ទៅលើទាំងអ្នកផ្តល់សេវាកម្ម និងសេវាកម្មខ្លួនឯងតែម្តង ។ ភាពខុសគ្នា នៅក្នុងវិធានការគ្រប់គ្រងលើលក្ខណៈសម្បត្តិវិជ្ជាជីវៈ ស្តង់ដារបច្ចេកទេស និងការផ្តល់អាជ្ញាប័ណ្ណក្នុងចំណោមប្រទេសទាំងនោះ ធ្វើអោយមានការលំបាកដល់អ្នកប្រកបវិជ្ជាជីវៈក្នុងការផ្តល់សេវាកម្មរបស់គេពីប្រទេសមួយទៅប្រទេសមួយ ។ ការពិចារណាទាំងនេះ បណ្តាលអោយមានសេចក្តីសំរេច ថ្នាក់រដ្ឋមន្ត្រីស្តីពី សេវាកម្មមុខរបរវិជ្ជាជីវៈ (ដែលបានអនុម័តដោយក្រុមប្រឹក្សានៃអង្គការ WTO សំរាប់ពាណិជ្ជកម្មលើសេវាកម្ម ក្នុងខែមិនា ឆ្នាំ ១៩៩៥) សំរាប់ការចាប់ផ្តើមការងារស្តីពីការរៀបរាប់ពីគោលការណ៍ពាណិជ្ជកម្មលើ សេវាកម្មមុខរបរវិជ្ជាជីវៈ ។ គោលការណ៍ទាំងនេះ អាចដាក់បន្ថែម ទៅលើការសន្យាជាក់លាក់ដែលប្រកាន់យកដោយបណ្តាប្រទេសនានានៅក្នុងកិច្ចប្រជុំរ៉ូយហ្គាយ និងដើម្បីធានាថា វិធានការគ្រប់គ្រង ដែលអនុម័តដោយបណ្តាប្រទេសនានានោះ បង្កើតជារបាំងមិនចាំបាច់ដល់ការផ្តល់សេវាកម្មមុខរបរវិជ្ជាជីវៈ ។

កិច្ចការនេះ កើតមានដោយសារការអនុម័តគោលការណ៍ស្តីពីបទបញ្ញាគ្រប់គ្រងក្នុងស្រុកទៅលើវិស័យគណនេយ្យកិច្ច ឆ្នាំ ១៩៩៨ ដោយក្រុមប្រឹក្សាពាណិជ្ជកម្មលើសេវាកម្ម ។ គោលការណ៍ រួមមានវិធាននៅក្នុងវិស័យដូចតទៅ ÷

- ☐ តំលាភាព : បណ្តាប្រទេសជាសមាជិកត្រូវផ្តល់ជាសាធារណៈនូវឈ្មោះ និងអាស័យដ្ឋានរបស់អាជ្ញាធរមានសមត្ថកិច្ច ដែលទទួលខុសត្រូវ លើការរៀបចំបង្កើតបទបញ្ញា គ្រប់គ្រងគណនេយ្យកិច្ច និងការចេញអាជ្ញាប័ណ្ណដល់ក្រុមហ៊ុន ឬអ្នកប្រកបវិជ្ជាជីវៈទាំងនោះ ដោយផ្ទាល់ ឬ តាមរយៈមជ្ឈមណ្ឌលទាក់ទងណាមួយដែលខ្លួនបានបង្កើត ។
- ☐ តំរូវការ និងនីតិវិធីនៃការចេញអាជ្ញាប័ណ្ណ ។ តំរូវការចេញអាជ្ញាប័ណ្ណ (ដូចជាតំរូវការសំខាន់ ៗ ក្រៅពីតំរូវការស្តីពីលក្ខណៈសម្បត្តិ ដែលត្រូវបំពេញ ដើម្បីសុំ ឬបន្តលិខិតអនុញ្ញាតិដំណើរការ) និង " នីតិវិធីចេញអាជ្ញាប័ណ្ណ (ដូចជានីតិវិធីដែលត្រូវអនុវត្តតាមដើម្បីដាក់ និងអនុម័តពាក្យ ស្នើសុំលិខិតអនុញ្ញាតិដំណើរការ)" ត្រូវរៀបចំកំណត់ជាមុន និងផ្សព្វផ្សាយចែកចាយជាសាធារណៈ ។ ជាងនេះទៅទៀត " នីតិវិធីនៃការចេញអាជ្ញាប័ណ្ណ មិនត្រូវបង្កើតអោយទៅជាការដាក់កំហិតលើការផ្តល់សេវាកម្មទេ " ។
- ☐ តំរូវការលក្ខណៈសម្បត្តិ ។ បណ្តាប្រទេសជាសមាជិកត្រូវធានាអោយ អាជ្ញាធរមានសមត្ថកិច្ចរបស់ខ្លួនពិចារណាទៅលើលក្ខណៈសម្បត្តិដែលបាន តំរូវនៅក្នុងទឹកដីនៃបណ្តាប្រទេសជាសមាជិកផ្សេងទៀត ដោយឈរលើមូលដ្ឋានសមមូលនៃការអប់រំសិក្សា បទពិសោធ និង/ឬ តំរូវការប្រលងត្រួតពិនិត្យផ្សេងៗទៀត ។

- ☐ ស្តង់ដារបច្ចេកទេស ។ បណ្តាប្រទេសជាសមាជិក ត្រូវធានាអោយមានការរៀបចំអនុម័ត និងអនុវត្តវិធានការដែលពាក់ព័ន្ធទៅនឹងស្តង់ដារបច្ចេកទេស ដើម្បីបំពេញតែកម្មវត្ថុស្របច្បាប់តែប៉ុណ្ណោះ ។

គោលការណ៍ មានប្រសិទ្ធិភាពចងភ្ជាប់ទៅលើបណ្តាប្រទេសជាសមាជិកទាំងអស់ ដែលបានសន្យានៅក្នុងវិស័យគណនេយ្យកិច្ច ប៉ុន្តែមិនអាចចូលជា ធរមានបានភ្លាមទេ ។ បណ្តាប្រទេសជាសមាជិកនៃអង្គការ WTO និងបន្តធ្វើការងាររបស់គេលើបញ្ហាក្នុងស្រុក តាមរូបភាពជាក្រុមការងារស្តីពី សេវាកម្មមុខរបរវិជ្ជាជីវៈ (WPPS) ។ WPPS មានបំណងរៀបចំគោលការណ៍ទូទៅសំរាប់សេវាកម្មមុខរបរវិជ្ជាជីវៈ ហើយក្នុងពេលនោះ គេក៏រក្សាទុកលទ្ធភាពរៀបចំគោលការណ៍សំរាប់វិស័យបន្ថែមទៀតដែរ ។

មុនពេលបញ្ចប់ការចរចាលើសេវាកម្ម ដែលនឹងចាប់ផ្តើមខែ មករា ឆ្នាំ ២០០០ខាងមុខនេះ គោលការណ៍ទាំងឡាយដែលបានរៀបចំឡើងដោយ WPPS នឹងត្រូវដាក់បញ្ចូលទៅក្នុង GATS ហើយពេលនេះគោលការណ៍នោះ នឹងចូលជាធរមានមានប្រសិទ្ធិភាពស្របច្បាប់ ។ គោលការណ៍ស្តីពី វិស័យគណនេយ្យកិច្ច រួមមាន " stand-still provision " មានប្រសិទ្ធិភាពភ្លាម ហើយតាមគោលការណ៍នេះ បណ្តាប្រទេសទាំងអស់ដែលជាសមាជិក WTO រួមមានទាំងបណ្តាប្រទេសដែលមិនបានសន្យាចំពោះ GATS នៅក្នុងវិស័យគណនេយ្យកិច្ចផង បានព្រមព្រៀងថានឹងមិនចាត់ វិធានការណាដែលមិនស្របទៅតាមគោលការណ៍គណនេយ្យកិច្ចនេះទេ ដរាបណាគោលការណ៍នោះស្របទៅតាមច្បាប់ក្នុងស្រុករបស់គេដែរ ។

សេវាកម្មសាងសង់ និងវិស្វកម្មពាក់ព័ន្ធ

វិស័យនេះ គ្របដណ្តប់ទៅលើ ÷

- ☐ ការងារសាងសង់អគារទូទៅ
- ☐ ការងារសាងសង់សំរាប់វិស្វកម្មស៊ីវិល
- ☐ ការងារតំឡើង និងផ្គុំនឹង
- ☐ ការបញ្ចប់ការងារសាងសង់អគារ និងការងារផ្សេងៗទៀត

ប្រទេសចំនួន ៤៨ មានឧបសម្ព័ន្ធស្តីពីការសន្យាកំរិតជាតិនៅក្នុងវិស័យនេះ ។

ពាណិជ្ជកម្មនៅក្នុងវិស័យនេះ មិនអាចធ្វើបានតាមរយៈចលនាឆ្លងដែន ឬតាមចលនារបស់អតិថិជននៅបរទេសទេ ។ ក៏ប៉ុន្តែមានតំរូវការអោយអ្នកផ្តល់សេវាកម្មវិស្វកម្មសំណង់ បង្កើតការិយាល័យនៅក្នុងប្រទេស ដែលត្រូវផ្តល់សេវាកម្មនោះ ។ ភាពប្រកួតប្រជែងរបស់ក្រុមហ៊ុនសំណង់វិស្វកម្មភាគច្រើន នៅក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ ទាក់ទងនឹងការងារនៅក្រៅប្រទេស ត្រូវពឹងផ្អែកជាសំខាន់ទៅលើកត្តាថាតើ ប្រទេសខាងក្រៅនោះ អនុញ្ញាតិអោយអ្នកបច្ចេកទេស ដូចជា អ្នកចាក់គ្រឹះ និងអ្នកតបំពង់ទឹក ឬ ភ្លើង និងកម្មករផ្សេងៗទៀត ស្នាក់នៅប្រទេសនោះ ក្នុងរយៈពេលបណ្តោះអាសន្នបានទេ ។

ទាក់ទងទៅនឹងសិទ្ធិក្នុងការបង្កើតក្រុមហ៊ុនពាណិជ្ជកម្ម ដើម្បីបំពេញការងារសាងសង់វិស្វកម្ម ប្រទេសជឿនលឿនទាំងអស់ និងប្រទេសកំពុងអភិវឌ្ឍន៍ មួយចំនួនធំ បានបង្ហាញអោយឃើញនៅក្នុងឯកសារការងាររបស់គេថា គេមិនមានដាក់កំហិតទេ ។ ម៉្យាងទៀតគេនឹងអនុវត្តទៅលើបណ្តាក្រុមហ៊ុនបរទេសនូវវិធាន ដែលអាចអនុវត្តបានទៅលើអ្នកផ្គត់ផ្គង់ក្នុងស្រុកដែរ ស្តីពីការបង្កើតក្រុមហ៊ុនសំរាប់បំពេញការងារទាំងនេះ ។ តែទោះជាយ៉ាងណាក៏ដោយ ប្រទេសកំពុងអភិវឌ្ឍន៍មួយចំនួនតូច បានបង្ហាញថា អ្នកផ្តល់សេវាកម្មបរទេសដែលមានបំណងរកស៊ីក្នុងការងារសាងសង់ ត្រូវតែបង្កើតក្រុមហ៊ុនចំរុះ ជាមួយក្រុមហ៊ុនក្នុងស្រុកដែលផ្តល់សេវាកម្មដូចគ្នានេះដែរ ។

បណ្តាប្រទេសដែលតំរូវអោយអ្នកផ្តល់សេវាកម្មបរទេស ត្រូវបង្កើតក្រុមហ៊ុនចំរុះ ឬ កិច្ចប្រតិបត្តិការប្រភេទផ្សេងៗ ដែលពាក់ព័ន្ធជាមួយអ្នកផ្តល់សេវាកម្ម ក្នុងស្រុកនោះ រួមមានប្រទេស ឥណ្ឌា ម៉ាឡេស៊ី ម៉ារ៉ុក ប៉ាគីស្ថាន ថៃ និងទួរគី ។

ទាក់ទងទៅនឹងការធ្វើសកម្មភាពរបស់រូបវន្តបុគ្គល បណ្តាប្រទេសទាំងអស់បានបញ្ជាក់ថា របៀបផ្តល់សេវាកម្មបែបនេះ មិនមានប្រសិទ្ធិភាពចងភ្ជាប់ទេ ។ ម្យ៉ាងទៀត បណ្តាប្រទេសនានាមិនបានធ្វើការសន្យា ដើម្បីអនុញ្ញាតិអោយបុគ្គលក្រោមថ្នាក់គ្រប់គ្រងចូលមកធ្វើការក្នុងប្រទេស តាមកិច្ចសន្យាបណ្តោះអាសន្ន នៅក្នុងឧស្សាហកម្មសាងសង់បានឡើយ ។

សេវាកម្មសង្គម និងសេវាកម្មដែលពាក់ព័ន្ធនឹងសុខាភិបាល

មានប្រទេសតែមួយចំនួនតូចប៉ុណ្ណោះ ដែលបានធ្វើការសន្យាទៅលើវិស័យនេះ ។ នេះដោយសារថា ក្នុងបណ្តាប្រទេសជាច្រើន សេវាកម្មបែបនេះ មិនមែនផ្តល់អោយដោយក្រុមហ៊ុនឯកជនមួយទេ តែផ្តល់អោយផងដែរដោយរដ្ឋាភិបាល ឬ មន្ទីរពេទ្យសាធារណៈ ។ វិស័យនេះគ្របដណ្តប់ទៅលើ ÷

- ☐ សេវាកម្មមន្ទីរពេទ្យ
- ☐ សេវាកម្មសុខាភិបាលសំរាប់មនុស្សជាតិ និង
- ☐ សេវាកម្មសង្គម

ទាក់ទងទៅនឹងសិទ្ធិរបស់ជនបរទេសក្នុងការបង្កើតមន្ទីរពេទ្យ ទាំងសហគមន៍អឺរ៉ុប និង ទាំងសហរដ្ឋអាមេរិកបានបង្ហាញថា សំណើនេះត្រូវនៅក្រោម ការដាក់កំហិតផ្នែកបរិមាណដោយឈរលើតំរូវការ ដោយត្រូវពិចារណាទៅលើកត្តាដូចជា ចំនួនគ្រែសំរាកតាមចំនួនប្រជាជននៅក្នុងតំបន់នីមួយៗ ។ ប្រទេសកំពុងអភិវឌ្ឍន៍ខ្លះ បានបញ្ជាក់ច្បាស់ថា ការបង្កើតមន្ទីរពេទ្យដោយមានការចូលរួមពីជនបរទេស អាចធ្វើឡើងបាន ដោយឈរលើគោលការណ៍ បង្កើតក្រុមហ៊ុនចំរុះ ដោយមានការចូលរួមចំណែកភាគហ៊ុនរបស់ប្រជាជនក្នុងស្រុក ។

ក៏ប៉ុន្តែ ប្រទេសភាគច្រើនបានបញ្ជាក់ថា សកម្មភាពរបស់រូបវន្តបុគ្គល ក្នុងការផ្តល់សេវាកម្មបែបនេះ មិនមានប្រសិទ្ធិភាពចងភ្ជាប់ទេ ។ នេះមានន័យថា គេនៅបន្តអនុវត្តបទបញ្ញាដែលមានជាធរមានរបស់គេដដែល ហើយដែលបទបញ្ញានោះជាទូទៅមិនទទួលស្គាល់ជាក់ស្តែងសមមូល និងលក្ខណៈសម្បត្តិផ្សេងៗ ទៀត ដែលទទួលបាននៅក្នុងប្រទេសផ្សេងទៀតឡើយ ដូច្នេះគេមិនអនុញ្ញាតិអោយជនបរទេស ដែលមានលក្ខណៈសម្បត្តិបែបនោះ ធ្វើការនៅក្នុងមន្ទីរពេទ្យ ជាវេជ្ជបណ្ឌិត គិលានុបដ្ឋាយិកា ឬ ឆ្មប ឬ ដើម្បីផ្តល់សេវាកម្មសុខាភិបាល ឬ សេវាកម្មសង្គមណាមួយទេ ។

សេវាកម្មពិគ្រោះយោបល់លើការគ្រប់គ្រង

សេវាកម្មពិគ្រោះយោបល់លើការគ្រប់គ្រង គ្របដណ្តប់លើសកម្មភាពមួយចំនួនធំ ដូចជាសេវាកម្មពិគ្រោះយោបល់ទូទៅ ហិរញ្ញវត្ថុ ផលិតកម្ម ការស្វែងរកទីផ្សារ និងសេវាកម្មពិគ្រោះយោបល់លើធនធានមនុស្ស ។

អាចមានលទ្ធភាពចែងថា សេវាកម្មបែបនេះអាចធ្វើឆ្លងដែនបាន តាមរយៈសម្បទាទាក់ទង ។ តែទោះជាយ៉ាងណាក៏ដោយ ដើម្បីអោយការផ្តល់សេវា កម្មនេះមានប្រសិទ្ធិភាពខ្ពស់ ការបង្កើតក្រុមហ៊ុននៅក្នុងប្រទេសដែលត្រូវផ្តល់សេវាកម្មនោះ គឺជាកត្តាសំខាន់ ។ ក្នុងចំណោមប្រទេសចំនួន ៤៥ ដែល បានដាក់បញ្ចូលសេវាកម្មពិគ្រោះយោបល់លើការគ្រប់គ្រង ទៅក្នុងឯកសារសន្យារបស់គេនោះ មានប្រទេសមួយចំនួនធំ បានចងភ្ជាប់កាតព្វកិច្ចនៃការ ផ្តល់សេវាកម្មបែបនេះ ដោយគ្មានកំណត់តាមមូលដ្ឋានឆ្លងដែន ឬ បានតំរូវអោយបង្កើតក្រុមហ៊ុនពាណិជ្ជកម្ម ។ ក៏ប៉ុន្តែ ប្រទេសកំពុងអភិវឌ្ឍន៍មួយ ចំនួនមិនបានចងភ្ជាប់ការផ្តល់សេវាកម្មតាមមូលដ្ឋានឆ្លងដែនទេ ហើយបានបញ្ជាក់ថា ការបង្កើតសាខាក្រុមហ៊ុន ឬ ការិយាល័យអាចធ្វើបាន ដរាបណាបានបង្កើតក្រុមហ៊ុនចំរុះជាមួយក្រុមហ៊ុនពិគ្រោះយោបល់ក្នុងស្រុក ។ មិនមានប្រទេសណាមួយ យល់ព្រមចងភ្ជាប់កាតព្វកិច្ចផ្តល់សេវាកម្មនេះ តាមរយៈសកម្មភាពរបស់រូបវន្តបុគ្គលទេ ។ មានន័យថា បទបញ្ញាដែលមានជាធរមាន បានហាមឃាត់អ្នកផ្តល់សេវាកម្មបរទេសពីការផ្តល់សេវាកម្ម លើកលែងតែអ្នកផ្តល់សេវាកម្មបរទេសនោះបានបង្កើតក្រុមហ៊ុនពាណិជ្ជកម្មនៅក្នុងប្រទេសដែលត្រូវផ្តល់សេវាកម្មនោះ ។

ការពាក់ព័ន្ធផ្នែកពាណិជ្ជកម្ម

ការវាយតំលៃលើផលប្រយោជន៍

ប្រទេសនានាបានប្រកាន់យកវិធានការដំបូង សំដៅធ្វើសេរីភាវូបនីយកម្មពាណិជ្ជកម្មអន្តរជាតិលើសេវាកម្ម នៅក្នុងកិច្ចប្រជុំយូរ៉ុយហ្គាយ និងក្នុងការចរចាដែលបានធ្វើក្រោយកិច្ចប្រជុំនោះ ។ ក៏ប៉ុន្តែ ពាណិជ្ជកម្មលើសេវាកម្ម មានលក្ខណៈខុសពីពាណិជ្ជកម្មលើទំនិញ ដោយសារគេមិនមានលទ្ធភាព កំណត់បរិមាណលើឥទ្ធិពលពាណិជ្ជកម្មជាសក្តានុពលនៃការធ្វើសេរីភាវូបនីយកម្មតាមមូលហេតុពីរយ៉ាង ។ មិនមានអ្វីសមមូល្យទៅនឹងពន្ធគយនៅ ក្នុងវិស័យសេវាកម្ម ។ នៅពេលដែលមានការផ្តល់កិច្ចគាំពារ តាមរយៈបទបញ្ញាក្នុងស្រុក ដែលរើសអើងចំពោះអ្នកផ្តល់សេវាកម្មបរទេស នោះឥទ្ធិពលនៃវិធានការ ឬ ការលប់ចោលវិធាននោះ មិនអាចកំណត់បានជាបរិមាណបានទេ ។

ក៏ប៉ុន្តែ ជាទូទៅគេជឿជាក់ថា ប្រទេសភាគច្រើនដែលបានធ្វើការចរចា បានព្យាយាមសំរបសំរួលវិធានការសេរីភាវូបនីយកម្មកន្លងមករបស់គេ ដោយការសន្យាថាមិនដកចេញ ឬ កែប្រែវិធានការនោះឡើយ ។ អត្ថប្រយោជន៍ចំពោះមុខសំរាប់សហគ្រាសនាំចេញសេវាកម្ម បានមកពីការធានាបើកទីផ្សារបរទេស តាមការសន្យាដែលបានចែង ។

ផលប្រយោជន៍សំរាប់ឧស្សាហកម្មសេវាកម្មនៅក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍន៍

សំរាប់ឧស្សាហកម្មសេវាកម្មនៅក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ អត្ថប្រយោជន៍ជាចំបងនៃវិធានការសេរីភាវូបនីយកម្មដែលបានប្រកាន់ឡើង ដោយបណ្តាប្រទេសទាំងនេះ ទោះបីជាដោយឯកតោភាគី ឬ ក្នុងបរិបទនៃកិច្ចប្រជុំយូរ៉ុយហ្គាយ ក៏ដោយ ក៏រំពឹងថានឹងបានមកពីផលចំណេញខ្ពស់ពីការប្រកួតប្រជែងដែលកើនឡើងនៅទីផ្សារក្នុងស្រុករបស់គេ ។ ការបើកអោយអ្នកផ្តល់សេវាកម្មបរទេស ចូលមកក្នុងវិស័យសេវាកម្ម ដូចជា សេវាកម្មទូរគមនាគមន៍ ធនាគារ និងការធានារ៉ាប់រង នឹងជំរុញអោយឧស្សាហកម្មក្នុងស្រុកក្នុងប្រទេសដែលមានការការពារខ្ពស់ កែលំអស្ថានភាពប្រកួតប្រជែងរបស់គេ តាមរយៈការប្រើប្រាស់របៀបផ្តល់សេវាកម្មប្រកបដោយប្រសិទ្ធិភាពខ្ពស់ ។ លទ្ធផលដែលឧស្សាហកម្មសេវាកម្ម ដំណើរការបានល្អ មិនត្រឹមតែផ្តល់ផលប្រយោជន៍ជូនសាធារណៈជនទេ ប៉ុន្តែផ្តល់ផងដែរទៅអោយសហគ្រាសកាមន្តសាលកម្មនៅក្នុងពាណិជ្ជកម្មនាំ ចេញរបស់គេ ។ លទ្ធភាពរបស់សហគ្រាសនោះ ក្នុងការប្រកួតប្រជែងនៅទីផ្សារបរទេស ពឹងពាក់ជាសំខាន់ថាតើពួកគេ អាចទទួលបានសេវាកម្ម ប្រាស្រ័យទាក់ទង ធនាគារ និងការធានារ៉ាប់រង យ៉ាងមានប្រសិទ្ធិភាពយ៉ាងណា ។

កាលានុវត្តន៍ភាពថ្មី សំរាប់សហការជាមួយអ្នកផ្តល់សេវាកម្មបរទេស

ការសន្យាដែលប្រកាន់ឡើងដោយរដ្ឋាភិបាល ក៏ផ្តល់អោយឧស្សាហកម្មសេវាកម្មនៅក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍន៍នូវកាលានុវត្តន៍ថ្មី ដើម្បីសហការជាមួយឧស្សាហកម្មសេវាកម្មបរទេស និងទទួលបានផលប្រយោជន៍ពីបច្ចេកវិទ្យារបស់អ្នកផ្តល់សេវាកម្មបរទេសនោះផងដែរ ។ ក្នុងកិច្ចព្រមព្រៀង សហការចរចា ឧស្សាហកម្មអាចប្រើប្រាស់ជាអនុភាពនៃការតថ្លៃ លើការដាក់កំហិត ដោយរដ្ឋាភិបាលនៅក្នុងឯកសារសន្យារបស់គេ ។ ដូច្នេះ ក្នុងនោះ ឯកសារនៃការសន្យាបានបញ្ជាក់ថា ការអនុញ្ញាតិអាចផ្តល់អោយបាន ប្រសិនបើអ្នកផ្តល់សេវាកម្មបរទេស យល់ព្រមនាំមកនូវបច្ចេកវិទ្យាទំនើប និងយល់ព្រមបណ្តុះបណ្តាលនិយោជិកក្នុងស្រុក ដែលគេជួលមកប្រើក្នុងសេវាកម្មរបស់គេ ។

ផលប្រយោជន៍នៃមជ្ឈមណ្ឌលទាក់ទង

ភាពខ្វះខាតមួយដ៏សំខាន់ក្នុងចំណោមភាពខ្វះខាតជាច្រើន ដែលឧស្សាហកម្មសេវាកម្មនៅក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ជួបប្រទះក្នុងពេលចរចាលើ កិច្ចព្រមព្រៀងសហការ គឺកង្វះខាតនូវការយល់ដឹងពីទីផ្សារពាណិជ្ជកម្ម និង បច្ចេកទេសនៃសេវាកម្ម និង បច្ចេកវិទ្យាដែលគេចង់បាន ។ ដូច្នេះ GATS បានចែងពីការបង្កើតមជ្ឈមណ្ឌលពត៌មាន ដោយបណ្តាប្រទេសជឿនលឿន ហើយពីមជ្ឈមណ្ឌលនោះ យើងអាចទទួលបាននូវពត៌មានស្តីពីឧស្សាហកម្មសេវាកម្ម ដែលពាក់ព័ន្ធនៅក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍន៍។

កាលានុវត្តន៍ភាពនៃការនាំចេញថ្មី

ចំណែកការនាំចេញវិញ គេចាត់ទុកថា បណ្តាប្រទេសកំពុងអភិវឌ្ឍន៍មានឧត្តមភាពប្រៀបធៀបនៅក្នុងវិស័យសេវាកម្ម ព្រោះមានកំលាំងពលកម្មច្រើន ឬ តំរូវអោយមានបុគ្គលិកបំរើការដែលមានជំនាញខ្ពស់ ។ វិស័យ ឬ អនុវិស័យ ដែលអាចផ្តល់លទ្ធភាពអោយប្រទេសទាំងនេះអភិវឌ្ឍន៍ពាណិជ្ជកម្មបាន មានរាយនាមដូចខាងក្រោម និងដោយពិចារណាទៅលើកត្តាពីរខាងលើ ÷

- ☐ សេវាកម្មអាជីវកម្ម រួមមានសេវាកម្មពិគ្រោះយោបល់លើការគ្រប់គ្រង សេវាកម្មកុំព្យូទ័រ សេវាកម្មមុខវិជ្ជាជីវៈ និង សេវាកម្មភតិសន្យា ។
- ☐ សេវាកម្មសាងសង់ និងវិស្វកម្ម
- ☐ សេវាកម្មសិក្សាអប់រំ
- ☐ សេវាកម្មបរិស្ថាន
- ☐ សេវាកម្មសុខាភិបាល
- ☐ សេវាកម្មទេសចរណ៍ និងការធ្វើដំណើរ និង
- ☐ សេវាកម្មកីឡា វប្បធម៌ និងការកំសាន្ត

កន្លងមក មានប្រទេសកំពុងអភិវឌ្ឍន៍ខ្លះ បានក្លាយជាអ្នកនាំចូល ឬ អ្នកនាំចេញសេវាកម្ម ហើយដែលសេវាកម្មទាំងនោះអាចផ្តល់អោយបានតាមរយៈ សកម្មភាពរបស់រូបវន្តបុគ្គលដែលមានជំនាញបច្ចេកទេសស្របតាមលក្ខណៈសម្បត្តិ ។ សេវាកម្មទាំងនេះរួមមានសេវាកម្មសុខាភិបាល (គិលានុបដ្ឋាយិកា) និងកុំព្យូទ័រ (software) ។

ការតភ្ជាប់ការសន្យាជាមួយច្បាប់ក្នុងស្រុក

ការរៀបរាប់ខាងលើនៅក្នុងជំពូកនេះស្តីពីការសន្យានៅក្នុងវិស័យមួយចំនួន បានផ្តល់នូវគំនិតដ៏ទូលំទូលាយអំពីលក្ខណៈ និងខ្លឹមសារនៃការសន្យា ដែលប្រទេសនានាបានប្រកាន់យកពាក់ព័ន្ធនឹងសេវាកម្ម ។ ក៏ប៉ុន្តែ ការសន្យាពាក់ព័ន្ធ តែទៅនឹងទិដ្ឋភាពនៃច្បាប់ក្នុងស្រុកមួយចំនួនប៉ុណ្ណោះ។ ដើម្បី វាយតំលៃពីឥទ្ធិពលនៃផលប្រយោជន៍ នោះជាចាំបាច់ត្រូវពិនិត្យមើលការសន្យាទាំងអស់នោះធៀបជាមួយសាវតាពេញលេញនៃច្បាប់ និង វិធានក្នុងស្រុកដែលអនុវត្តបានទៅលើវិស័យសេវាកម្មនៅក្នុងប្រទេស ដែលធ្វើការសន្យានោះ ។ ក្នុងករណីខ្លះ ការសន្យាគ្រាន់តែជាការបញ្ជាក់អះអាងឡើងវិញ ឬ ចងភ្ជាប់ការអនុវត្តន៍កន្លងមក ឧទាហរណ៍ការផ្តល់ការអនុញ្ញាតិអោយបង្កើតសាខា ឬ បុត្តសម្ព័ន្ធក្រុមហ៊ុនប៉ុណ្ណោះ ។ ក្នុងករណីផ្សេងទៀត អាចជាការទទួលយកកាតព្វកិច្ចថ្មី។

ចំពោះអ្នកផ្តល់សេវាកម្ម ដែលចាប់អារម្មណ៍ក្នុងការរៀបចំពាណិជ្ជកម្ម ពត៌មានដែលមាននៅក្នុងឯកសារសន្យារបស់ជាតិ នឹងអាចមានតំលៃអនុវត្តបាន ប្រសិនបើគេមានពត៌មានទាំងអស់ពាក់ព័ន្ធស្តីពីច្បាប់ វិធាន បទបញ្ជា និងការអនុវត្តន៍ជាក់ស្តែងក្នុងស្រុកសំរាប់ជាការគាំទ្រចំពោះការសន្យានោះ ។ ដើម្បីជួយអោយសេវាកម្ម និង ឧស្សាហកម្មផ្សេងទៀត ទទួលបាននូវពត៌មានទាំងនោះ GATS តំរូវអោយបណ្តាប្រទេសជាសមាជិកទាំងអស់បង្កើតមជ្ឈមណ្ឌលផ្តល់ពត៌មានមួយ ។ មជ្ឈមណ្ឌលនេះ អាចផ្តល់ពត៌មានស្តីពីច្បាប់ និងបទបញ្ជាដែលអាចអនុវត្តបានទៅលើវិស័យសេវាកម្ម ។

កាលានុវត្តន៍ភាពដែលកើនឡើងសំរាប់រូបវន្តបុគ្គលដែលផ្តល់សេវាកម្ម

ក្នុងវិស័យខ្លះ ឧត្តមភាពប្រៀបធៀបរបស់ប្រទេសមួយចំនួន ជាពិសេសវិស័យដែលផ្តល់អត្ថប្រយោជន៍ច្រើន កើតចេញពីការដែលមានប្រជាជនមានជំនាញបច្ចេកទេសខ្ពស់ ។ សេវាកម្មដែលត្រូវការជំនាញច្រើន អាចផ្តល់ជូនបានតាមរយៈសកម្មភាពបណ្តោះអាសន្នរបស់រូបវន្តបុគ្គល ទៅអោយបណ្តាប្រទេសណាដែលសេវាកម្មនោះត្រូវផ្តល់ទៅអោយ ។ ការសន្យា horizontal ដែលប្រទេសនានាបានប្រកាន់យកនាពេលថ្មីៗ នេះដែលដាក់បញ្ចូលការចរចាស្តីពីចលនាសកម្មភាពរបស់

រូបវន្តបុគ្គលផងនោះ បានចែងពីការលានុវត្តន៍ភាពថ្មីសំរាប់អោយបុគ្គលដែលមានជំនាញបច្ចេកទេស និងជំនាញវិជ្ជាជីវៈ ផ្តល់សេវាកម្មបែបនោះ ដោយមិនចាំបាច់បង្កើតការិយាល័យ ឬ ក្រុមហ៊ុនពាណិជ្ជកម្មតាមទំរង់ណាមួយឡើយ ។

សារៈសំខាន់នៃការអនុម័តបុគ្គលិកលក្ខណៈតាមផ្លូវច្បាប់

ជាសំខាន់ ត្រូវកត់សំគាល់ថា នៅក្នុងការសន្យាបែប horizointal និងតាមវិស័យ ប្រទេសមួយចំនួនបានបង្ហាញពីការអនុវត្តន៍ល័ក្ខខណ្ឌបច្ចុប្បន្ន នៅពេលណាដែលមានការអនុញ្ញាតិអោយក្រុមហ៊ុនរបស់គេ ប្រើប្រាស់សេវាកម្មអ្នកបច្ចេកទេស និងអ្នកជំនាញបរទេសក្នុងរយៈពេលបណ្តោះអាសន្ន។ នៅពេលដែលការសន្យានេះ លើកចំហសំរាប់តែការលានុវត្តន៍ភាពមានកំណត់ នោះការយល់ដឹងពីល័ក្ខខ័ណ្ឌដែលអនុវត្តត្រូវផ្តល់លទ្ធភាពអោយក្រុមហ៊ុនបរទេសទាញយកអត្ថប្រយោជន៍ពេញលេញពីល័ក្ខខ័ណ្ឌនោះ ។ ការសន្យានោះជារឿយៗ បានបង្ហាញពីការអនុញ្ញាតិ ដែលបានផ្តល់អោយ ប្រសិនបើក្រុមហ៊ុនក្នុងស្រុក បានចុះកិច្ចសន្យាជាមួយសហគ្រាសអាជីវកម្មបរទេសដែលបានបង្កើតឡើង ដើម្បីទទួលបាននូវសេវាកម្មពីអ្នកជំនាញទាំងនោះ ។ ដូច្នេះ ជាកត្តាសមស្របសំរាប់អោយបុគ្គលដែលចាប់អារម្មណ៍ផ្តល់សេវាកម្មបែបនោះ រៀបចំខ្លួនចូលជាមួយក្រុមហ៊ុន ឬ ជាដៃគូ ជាជាងធ្វើសកម្មភាព ជារូបវន្តបុគ្គល ឬ បង្កើតជាក្រុមដែលមិនមានភាពច្បាស់លាស់ ។

ការលានុវត្តន៍ភាពសំរាប់ពង្រីកពាណិជ្ជកម្ម ក្នុងចំណោមបណ្តាប្រទេសកំពុងអភិវឌ្ឍន៍

ចុងក្រោយ ការសន្យាដែលប្រកាន់ឡើង ដោយបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ បានបើកចំហទៅរកការលានុវត្តន៍ភាពថ្មីសំរាប់ពង្រីកពាណិជ្ជកម្មសេវាកម្ម South-South តាមរយៈការបង្កើតក្រុមហ៊ុនចំរុះ និងកិច្ចព្រមព្រៀងសហការផ្សេងៗ ទៀតជាពិសេសកិច្ចព្រមព្រៀងតាមតំបន់ ។ ក្រៅពីការជំរុញពាណិជ្ជកម្មលើសេវាកម្ម South-South សមាគម (consortia) តាមតំបន់ក៏មានសក្តានុពល ក្នុងការប្រកួតប្រជែងជាមួយបណ្តាប្រទេសឧស្សាហកម្មផ្សេងទៀត ក្នុងការចងភ្ជាប់កិច្ចសន្យាសេវាកម្មរបស់គេដែរ ។ Consortia អាចផ្តល់ជូននូវជំនាញ និងបទពិសោធគួរអោយចាប់អារម្មណ៍ មួយចំនួនធំទៀត ដើម្បីកែលំអរូបភាព និងគូសបញ្ជាក់ពីសមត្ថភាពរបស់គេ ជាពិសេសដែលទាក់ទងទៅនឹងការងារនៅក្នុងតំបន់របស់គេ ។

ឧបសម្ព័ន្ធ ១

ការធ្វើចំណាត់ថ្នាក់វិស័យសេវាកម្មរបស់អង្គការពាណិជ្ជកម្មពិភពលោក

ផ្នែកសេវាកម្ម/ផ្នែកសេវាកម្មរង	ចំណាត់ថ្នាក់ផ្នែក .B.
A.. សេវាកម្ម ជំនួញ	
a. សេវាកម្ម មុខរបរ	
b. សេវាកម្ម ផ្នែកច្បាប់	៨៦១
c. សេវាកម្ម គណនេយ្យ,សវនកម្ម និងការចុះបញ្ជីសៀវភៅធំ	៨៦២
c. សេវាកម្ម ពន្ធអាករ	៨៦៣
d. សេវាកម្ម ស្ថាបត្យកម្ម	៨៦៧១
e. សេវាកម្ម វិស្វកម្ម	៨៦៧២
f. សេវាកម្ម បង្គុំវិស្វកម្ម	៨៦៧
g. សេវាកម្ម នគរូបនីយកម្ម និងស្ថាបត្យកម្មបំព្រួញ	៨៦៧
h. សេវាកម្ម វេជ្ជសាស្ត្រ និងទន្តសាស្ត្រ	៩៣១២
i. សេវាកម្ម បសុសត្វ	៩៣
j. សេវា ដែលផ្តល់ដោយឆ្មប, គិលានុបដ្ឋាការ/ ការិនី, អ្នកធ្វើសរសៃ និងមន្ត្រីវេជ្ជសាស្ត្រ ដ៏ទៃទៀត	៩៣១៩១
k. សេវាកម្ម ផ្សេងទៀត	
B. កំព្យូទ័រ និង សេវាដែលទាក់ទង	
a. សេវាពិគ្រោះយោបល់ ទាក់ទងទៅនឹងការតំលើងកំព្យូទ័រ	៨៤១
b. សេវាប្រើប្រាស់ Software	៨៤២
c. សេវារៀបចំទិន្នន័យ	៨៤៣
d. សេវាទិន្នន័យ	៨៤៤
e. សេវាផ្សេងៗទៀត	៨៤៥៨៤៩
C. សេវាស្រាវជ្រាវ និងអភិវឌ្ឍន៍	
a. សេវាស្រាវជ្រាវ និងអភិវឌ្ឍន៍ វិទ្យាសាស្ត្រធម្មជាតិ	៨៥១
b. សេវាស្រាវជ្រាវ និងអភិវឌ្ឍន៍វិទ្យាសាស្ត្រសង្គម និងមនុស្ស	៨៥២
c. សេវាស្រាវជ្រាវ និងអភិវឌ្ឍន៍ ការបណ្តុះបណ្តាល	៨៥៣
D. សេវាកម្ម អចលនទ្រព្យ	
a. សេវាទាក់ទង និងសិទ្ធិកាន់កាប់ រឺ ជួលទ្រព្យសម្បត្តិ	៨២១
b. លើមូលដ្ឋានថ្លៃ ឬ កិច្ចសន្យា	៨២២
E. សេវាកម្ម សេវាកម្មជួលដោយគ្មានអ្នកបើកបរ	
a. សេវាកម្មទាក់ទង និងនាវា	៨៣១០៣

b.	សេវាកម្មទាក់ទង និងយន្តហោះ	៨៣១០៤
c.	សេវាកម្មទាក់ទង និងឧបករណ៍ដឹកជញ្ជូនផ្សេងៗទៀត	៨៣១០១៖៨៣១០២៖៨៣១០៥
d.	សេវាកម្មទាក់ទង និងគ្រឿងម៉ាស៊ីន និងឧបករណ៍ផ្សេងៗ	៨៣១០៦ - ៨៣១០៩
e.	សេវាកម្ម ផ្សេងៗទៀត	៨៣២
F.	សេវាកម្មជំនួញផ្សេងៗទៀត	
a.	សេវាកម្មផ្សាយពាណិជ្ជកម្ម	៨៧១
b.	សេវាកម្មស្រាវជ្រាវទីផ្សារ និងការស្ទង់មតិសាធារណៈ	៨៦៤
c.	សេវាកម្មផ្តល់យោបល់លើការគ្រប់គ្រង	៨៦៥
d.	សេវាកម្មទាក់ទង និងការផ្តល់យោបល់លើការគ្រប់គ្រង	៨៦៦
e.	សេវាកម្មពិសោធន៍បច្ចេកទេស និងវិភាគ	៨៦៧៦
f.	សេវាកម្មឧបត្ថម្ភហេតុចំពោះកសិករ ការបរបាញ់ និងរុក្ខកម្ម	៨៨១
g.	សេវាកម្មឧបត្ថម្ភហេតុចំពោះការនេសាទ	៨៨២
h.	សេវាកម្មឧបត្ថម្ភហេតុចំពោះការយករ៉ែ	៨៨៣˙ ៥១១៥
i.	សេវាកម្មឧបត្ថម្ភហេតុចំពោះផលិតកម្ម	៨៨៤៨៨៥ Except for ៨៨៤៤២)
j.	សេវាកម្មឧបត្ថម្ភហេតុ ចំពោះការចែកចាយថាមពល	៨៨៧
k.	សេវាកម្ម ផ្គត់ផ្គង់និងផ្តល់បុគ្គលិក	៨៧២
l.	ស៊ើបអង្កេត និងសន្តិសុខ	៨៧៣
m.	សេវាកម្ម ទាក់ទងនិង ការពិគ្រោះយោបល់ផ្នែកបច្ចេកទេស និងវិទ្យាសាស្ត្រ	៨៦៧៥
n.	ថែរក្សា និងជួសជុលឧបករណ៍ (ដោយមិនរាប់បញ្ចូល នាវាសមុទ្រ យន្តហោះ រឺ ឧបករណ៍ដឹក ជញ្ជូនផ្សេងទៀត)	៦៣៣៨៨៦១៨៨៦៦
o.	សេវាកម្ម សំអាតអាគារ	៨៧៤
p.	សេវាកម្ម រូបថត	៨៧៥
q.	សេវាកម្ម វេចខ្ចប់	៨៧៦
r.	សេវាកម្ម បោះពុម្ព និងបោះផ្សាយ	៨៨៤៤២
s.	សេវាកម្ម សន្និបាត	៨៧៩០៩ [*]
t.	សេវាកម្ម ផ្សេងៗទៀត	៨៧៩០

២. សេវាកម្មគមនាគមន៍

A.	សេវាកម្ម ប្រៃសណីយ៍	៧៥១១
B.	សេវាកម្មកញ្ចប់បញ្ញើរ	៧៥១២
C.	សេវាកម្មទូរគមនាគមន៍	
a.	សេវា ទូរស័ព្ទមានសំលេង	៧៥២១
b.	សេវាបញ្ជូនទិន្នន័យ Pocket-switched	៧៥២៣[**]
c.	សេវា បញ្ជូនទិន្នន័យ Circuit-switched	៧៥២៣[**]
d.	សេវា Telex	៧៥២៣[**]
e.	សេវា Telegraph	៧៥២២
f.	សេវា ហ្វាក់ (Facsimile)	៧៥២១[**] ˙ ៧៥២៩[**]
g.	សេវា ជួល Circuit ឯកជន	៧៥២២[**] ˙ ៧៥២៣[**]
h.	សេវា បញ្ជូនសារអេឡិចត្រូនិច Electronic Mail	៧៥២៣[**]
i.	សេវា បញ្ជូនសារជាសំលេង Voice Mail	៧៥២៣[**]

	j.	ពត៌មាន On-line និងការទទួលយកទិន្នន័យ	៧៥២៣**
	k.	ការប្តូរគ្នា នៃទិន្នន័យអេឡិចត្រូនិច	៧៥២៣**
	l.	សេវាកម្ម បង្កើនតំលៃបន្ថែមតាមហ្វាក់ រួមទាំងការស្តុកទុក និងបញ្ជូនបន្ត ការស្តុកទុក និងទាញយកមកប្រើ	៧៥២៣**
	m.	ក្រម និង Protocol នៃការសន្ទនា	n-a
	n.	ពត៌មាន On-line និង ឬ ការរៀបចំទិន្នន័យ (រួមមានលំដាប់នៃការរៀបចំ)	៨៤៣**
	o.	សេវាកម្មផ្សេងៗ	
D.		សេវាកម្ម សោតទស្សន៍	
	a.	សេវាកម្មរូបភាព ជាខ្សែភាពយន្ត និងផលិតកម្មកាសែតនិងការចែកចាយលក់	៩៦១១
	b.	សេវាកម្មបញ្ចាំងភាពយន្ត	៩៦១២
	c.	សេវាកម្ម វិទ្យុ និងទូរទស្សន៍	៩៦១៣
	d.	សេវាកម្ម ផ្សាយតាមវិទ្យុ និងទូរទស្សន៍	៧៥២៤
	e.	សេវាកម្ម ថតសំលេង	n-a
	f.	សេវាកម្ម ផ្សេងៗទៀត	
E.		ផ្សេងៗ	

៣.		**សំណង់ និងសេវាកម្មទាក់ទងនឹងវិស្វកម្ម**	
	A.	ការងារសំណង់ទូទៅ សំរាប់អាគារ	៥១២
	B.	ការងារសំណង់ទូទៅ សំរាប់វិស្វកម្មស៊ីវិល	៥១៣
	C.	ការងាររៀប និងផ្គុំ	៥១៤+៥១៦
	D.	ការបញ្ចប់ការសាងសង់អាគារ និងសំអាត	៥១៧
	E.	សេវាកម្មផ្សេងទៀត	៥១១+៥១៥+៥១៨
៤.		**សេវាកម្ម បែងចែកទំនិញ**	
	A.	សេវាកម្ម ភ្នាក់ងារកំរៃជើងសារ	៦១២
	B.	សេវា លក់ដុំ	៦២២
	C.	សេវាកម្ម លក់រាយ	៣១+៦៣២+៦១១១+៦១១៣+៦១២១
	D.	ការផ្តល់សិទ្ធិ	៨៩២៩
	E.	សេវាកម្មផ្សេងទៀត	
៥.		**សេវាកម្មសិក្សាអប់រំ**	
	A.	សេវា អប់រំបឋមសិក្សា	៩២១
	B.	សេវា អប់រំមធ្យមសិក្សាទី១	៩២២
	C.	សេវា អប់រំមធ្យមសិក្សាទី២	៩២៣
	D.	សេវា អប់រំវ័យជំទង់	៩២៤
	E.	សេវា អប់រំផ្សេងទៀត	៩២៩
៦.		**សេវាកម្មបរិស្ថាន**	
	A.	សេវាកម្ម លូទឹកស្អុយ	៩៤០១
	B.	សេវាកម្ម កាកសំណល់	៩៤០២
	C.	អនាម័យ និង សេវាកម្មប្រហាក់ប្រហែល	៩៤០៣
	D.	សេវាកម្ម ផ្សេងៗទៀត	

៧. សេវាកម្ម ហិរញ្ញវត្ថុ

A. សេវាកម្ម ធានារ៉ាប់រង និងសេវាកម្មពាក់ព័ន្ធ ៨១២**

a. សេវាកម្ម ធានារ៉ាប់រងជីវិត គ្រោះថ្នាក់ និងសុខភាព ៨១២១

b. សេវាកម្ម ធានារ៉ាប់រងក្រៅ ការធានារ៉ាប់រងជីវិត ៨១២៩

c. ការផ្ដល់ធានារ៉ាប់រងឡើងវិញ និង Retrocession ៨១២៩៩

d. សេវាកម្ម ជំនួយចំពោះធានារ៉ាប់រង (រួមមាន សេវាកំរៃជើងសារ និងភ្នាក់ងារ) ៨១៤០

B. ធនាគារ និងសេវាកម្ម ហិរញ្ញវត្ថុផ្សេងទៀត (ក្រៅពីធានារ៉ាប់រង)

a. ការទទួលប្រាក់បញ្ញើ និងមូលនិធិពីសាធារណៈ ៨១១១៥ - ៨១១១៩

b. ការអោយខ្ចីគ្រប់ប្រភេទ រួមមាន ឥណទានអ្នកប្រើប្រាស់ ឥណទានបញ្ចាំ និងហិរញ្ញវត្ថុនៃការ ធ្វើពាណិជ្ជកម្ម ៨១៣

c. ការអោយខ្ចីហិរញ្ញវត្ថុ ៨១១២

d. សេវាបង់ប្រាក់ និងផ្ញើប្រាក់ ៨១៣៣៩**

e. ធានា និងសន្យា ៨១១៩៩**

f. ធ្វើពាណិជ្ជកម្មសំរាប់ខ្លួនឯងគណនីយ្យផ្ទាល់ខ្លួន ឬ សំរាប់ខ្លួនឯងគណនីយ្យអតិថិជន ទាំងការប្ដូរប្រាក់ in an-over-the Counter Market ក្ដី

- ឧបករណ៍សាច់ប្រាក់ផ្សេងទៀត (មូលទានប្បប័ត្រ វិក័យប័ត្រ វិញ្ញាបនប័ត្រតំកល់ប្រាក់ ជាដើម) ៨១៣៣៩**
- ប្រាក់បរទេស ៨១៣៣៣
- ផលិតផលផ្សេងទៀត រួមទាំង តែមិនកំណត់ត្រឹមអនាគត និងជំរើស ៨១៣៣៩**
- ឧបករណ៍អត្រាប្ដូរប្រាក់ និងអត្រាការប្រាក់ រួមមាន Swap និង Forward rate agreement ៨១៣៣៩**
- ប័ណ្ណភាគហ៊ុន ដែលអាចផ្ទេរបាន ៨១៣២១*
- ឧបករណ៍ផ្សេងទៀត ដែលអាចចរចាបាន និងទ្រព្យសម្បត្តិជាហិរញ្ញវត្ថុ រួមទាំងដុំមាស រឺប្រាក់ ៨១៣៣៩**

g. ចូលរួមក្នុងការបោះផ្សាយ មូលប្បទានប័ត្រ គ្រប់ប្រភេទ រួមទាំង ការបញ្ចុះតំលៃ និងផ្ដល់ទៅអោយភ្នាក់ងារ (ទោះបីជាផ្នែករដ្ឋ ឬ ឯកជន) ព្រមទាំងផ្ដល់សេវានានា ទាក់ទងទៅនឹង ស្ថានភាពដូចនេះ ៨១៣២

h. លក់ ទិញរូបិយប័ណ្ណ យកកំរៃជើងសា ៨១៣៣៩**

i. ចាត់ចែងលើទ្រព្យសម្បត្តិ ដូចជា សាច់ប្រាក់ ឬការគ្រប់គ្រង ប័ណ្ណភាគហ៊ុនគ្រប់គ្រងការវិនិយោគគ្រប់ប្រភេទ គ្រប់គ្រងមូលនិធិចាស់ជរា ឥណទានសំរាប់ចិញ្ចឹមក្មេង និងសេវាគ្រប់គ្រងផ្សេងទៀត ៨១១៩* ៨១៣២៣*

j. សេវាកម្មដោះស្រាយ និងបញ្ជប់ទ្រព្យជាហិរញ្ញវត្ថុ រួមទាំង ប័ណ្ណភាគហ៊ុន ផលិតផលផ្សេងៗ និងឧបករណ៍ដែលអាចចរចាបានផ្សេងទៀត ៨១៣៣៩** or ៨១៣១៩**

l. សេវាផ្ដល់យោបល់ និងសេវាហិរញ្ញវត្ថុជាជំនួយផ្សេងទៀត លើគ្រប់សកម្មភាពទាំងអស់ ដែលមានចែងក្នុងប្រការ ១៨ នៃ MTN.TNC/W/៥០ រួមទាំងឥណទានយោង និងការវិភាគ វិនិយោគ និងការស្រាវជ្រាវ Porfoler និងឱវាទ អំពីការទទួលបាន និងការកែទំរង់រចនាសម្ព័ន្ធ និងយុទ្ធសាស្ត្រ ៨១៣១ or ៨១៣៣

- l. ផ្តល់និងបញ្ជូនពត៌មានហិរញ្ញវត្ថុ និងទិន្នន័យហិរញ្ញវត្ថុ ព្រមទាំង Software ពាក់ពន្ធ័ពីអ្នកផ្តល់ សេវាហិរញ្ញវត្ថុដទៃទៀត — ៨១៣១
- C. សេវាកម្ម ហិរញ្ញវត្ថុផ្សេងទៀត

៨. សេវាកម្មទាក់ទងនឹងសុខាភិបាល និងសេវាសង្គម (ក្រៅពីសេវាកម្ម ដែលបញ្ជាក់ក្នុងចំនុច 1.A.a.j.)

- A. សេវាកម្ម មន្ទីរពេទ្យ — ៩៣១១
- B. សេវាកម្ម សុខភាពមនុស្សផ្សេងទៀត — ៩៣១៩ ក្រៅពី ៩៣១៩១
- C. សេវាកម្មសង្គម — ៩៣៣
- D. សេវាកម្មផ្សេងទៀត

៩. សេវាកម្ម ទេសចរណ៍ និងសេវាទាក់ទង និងដំណើរកំសាន្ត

- A. សណ្ឋាគារ ភោជនីយដ្ឋាន (រួមទាំងអាហារដ្ឋាន) — ៦៤១-៦៤៣
- B. ភ្នាក់ងារស្នាក់ការទេសចរណ៍ — ៧៤៧១
- C. សេវាកម្មមគ្គុទ្ទេស ទេសចរណ៍ — ៧៤៧២
- D. សេវាកម្មផ្សេងទៀត

១០. សេវាកម្មសំរាប់ ការកំសាន្ត វប្បធម៌ និងកីឡា (ក្រៅពី សេវាកម្ម សោតទស្សន៍)

- A. សេវាកម្មកំសាន្ត (ដូចជា សិល្បៈ ការប្រគុំបទភ្លេង និងហ៊ែសកម្ម) — ៩៦១៩
- B. សេវាកម្ម ភ្នាក់ងារពត៌មាន — ៩៦២
- C. បណ្ណាល័យ ប័ណ្ណសារដ្ឋាន សារៈមន្ទីរ និងសេវាវប្បធម៌ ដទៃទៀត — ៩៦៣
- D. កីឡា និងសេវាកំសាន្ត ផ្សេងទៀត — ៩៦៤
- E. សេវាកម្ម ផ្សេងទៀត

១១. សេវាកម្ម ដឹកជញ្ជូន

- A. សេវាកម្ម ដឹកជញ្ជូន ផ្លូវសមុទ្រ
  - a. ការដឹកជញ្ជូនអ្នកដំណើរ — ៧២១១
  - b. ការដឹកជញ្ជូនទំនិញ — ៧២១២
  - c. ការជួលនាវា ព្រមទាំងអ្នកបើកបរ — ៧២១៣
  - d. ការថែទាំ និងជួសជុលនាវា — ៨៨៦៨**
  - e. សេវា រុញនិងសណ្តោង — ៧២១៤
  - f. សេវាគាំទ្រផ្សេងៗ ចំពោះការដឹកជញ្ជូនផ្លូវសមុទ្រ — ៧៤៥**
- B. ការដឹកជញ្ជូន ផ្លូវទន្លេ
  - a. ការដឹកជញ្ជូន អ្នកដំណើរ — ៧២២១
  - b. ការដឹកជញ្ជូនទំនិញ — ៧២២២
  - c. ការជួលនាវាព្រមទាំងអ្នកបើកបរ — ៧២២៣
  - d. ការថែទាំ និងជួលនាវា — ៨៨៦៨**
  - e. សេវារុញ និងសណ្តោង — ៧២២៤
  - f. សេវាគាំទ្រផ្សេងៗ ចំពោះការដឹកជញ្ជូនផ្លូវទន្លេ — ៧៤៥**
- C. សេវាកម្ម ដឹកជញ្ជូនតាមផ្លូវអាកាស
  - a. ការដឹកជញ្ជូនអ្នកដំណើរ — ៧៣១
  - b. ការដឹកជញ្ជូនទំនិញ — ៧៣២
  - c. ការជួលយន្តហោះ ព្រមទាំងអ្នកបើកបរ — ៧៣៤

	d.	ការថែទាំ និងជួសជុលយន្តហោះ	៨៨៦៨**
	e.	សេវាគាំទ្រផ្សេងៗ ចំពោះការដឹកជញ្ជូនតាមអាកាស	៧៤៦**
D.		សេវាដឹកជញ្ជូនក្នុងអវកាស	៧៣៣
E.		សេវាកម្ម ដឹកជញ្ជូនតាមផ្លូវដែក	
	a.	ការដឹកជញ្ជូនអ្នកដំណើរ	៧១១១
	b.	ការដឹកជញ្ជូនទំនិញ	៧១១២
	c.	សេវាកម្ម រុញ និងសណ្តោង	៧១១៣
	d.	ការថែទាំ និងជួសជុលសម្ភារៈដឹកជញ្ជូនតាមផ្លូវដែក	៨៨៦៨**
	e.	សេវាគាំទ្រផ្សេងៗចំពោះ ការដឹកជញ្ជូនតាមផ្លូវដែក	៧៤៣
F.		សេវាកម្ម ដឹកជញ្ជូនតាមផ្លូវគោក	
	a.	ការដឹកជញ្ជូនអ្នកដំណើរ	៧១២១ ៧១២២
	b.	ការដឹកជញ្ជូនទំនិញ	៧១២៣
	c.	ការជួលជុលរថយន្តពាណិជ្ជកម្ម រួមទាំងអ្នកបើកបរ	៧១២៤
	d.	ការថែទាំ និងជួសជុលឧបករណ៍ដឹកជញ្ជូនផ្លូវគោក	៦១១២ ៨៨៦៧
	e.	សេវាគាំទ្រផ្សេងៗ ចំពោះការដឹកជញ្ជូនផ្លូវគោក	៧៤៤
G.		ការដឹកជញ្ជូនតាមបំពង់បង្ហូរ	
	k.	ការដឹកជញ្ជូនប្រេងចំហេះ	៧១៣១
	k.	ការដឹកជញ្ជូនទំនិញផ្សេងទៀត	៧១៣៩
H.		សេវាកម្ម ជំនួយចំពោះរបៀបដឹកជញ្ជូនគ្រប់ប្រភេទ	
	a.	សេវារៀបចំ (Cargo) ទំនិញ	៧៤១
	b.	សេវាកម្ម ស្តុកទំនិញ និងឃ្លាំង	៧៤២
	c.	សេវាកម្ម ភ្នាក់ងារដឹកជញ្ជូន	៧៤៨
	d.	សេវាកម្ម ផ្សេងទៀត	៧៤៩
I.		សេវាកម្ម ដឹកជញ្ជូនផ្សេងទៀត	

១២. សេវាកម្ម ផ្សេងទៀត ដែលមិនបានរាប់បញ្ចូល ៩៥៩៧៩៨៩៩

កំណត់សំគាល់ :

- សញ្ញា (*) បញ្ជាក់ថា សេវាកម្មជាក់លាក់នេះ គឺជាធាតុមួយនៃ CPC ដែលមានលំដាប់ លេខរួមសញ្ញា (**) បញ្ជាក់ថា សេវាកម្មនេះ ស្របតែទៅនឹង ផ្នែកមួយ នៃសកម្មភាពទាំងអស់ របស់ CPC (ឧបករណ៍ Voice Mail គឺស្របតែទៅនឹងភាគី CPC ៧៥២៣)។

ឧបសម្ព័ន្ធ ២

មជ្ឈមណ្ឌលជំនាក់ជំនងការងារសេវាកម្ម កិច្ចព្រមព្រៀងទូទៅស្ដីអំពីសេវាកម្ម

AUSTRALIA
The Director
Services Trade Section
Trade Negotiations and Organisations Division
Department of Foreign Affairs and Trade
Parkes ACT 2600
Tel: +(61 6) 261 3156
Fax: +(61 6) 261 3514

BAHRAIN
Directorate of Foreign Trade Relations
Ministry of Commerce
P.O. Box 5479
Manama
Tel: (+973) 531 063
Fax: (+973) 536 145

BRAZIL
Ministério das Ralações Exteriores
Bloco H, Anexo I, Sala 508
70 170-900 Brasília DF
Tel: +(55 61) 211 6374, +(55 61) 211 6375, +(55 61) 211 6376, +(5561) 211 6377
Fax: +(55 61) 223 7362

BRUNEI DARUSSALAM*
International Relations and Trade and Development Division
Ministry of Industry and Primary Resources
Bandar Seri Begawan 1220
Tel: (+673 2) 382 822, (+673 2) 382 850
Fax: (+673 2) 382 846, (+673 2) 383 811

CANADA*
Services Trade Policy Division
Department of Foreign Affairs and International Trade
125 Sussex Drive
Ottawa, Ontario
K1A OG2
Tel: +(1 613) 944 2046
Fax: +(1 613) 944 0058

CHILE
Departamento de Servicios e Inversiones
Dirección General de Relaciones Económicas Internacionales
Avenida Libertador Bernardo O'Higgins 1325
2° piso
Santiago
Tel: +(56 2) 696 0043
Fax: +(56 2) 696 0639

COLOMBIA
Ministerio de Comercio Exterior
Dirección de Negociaciones
Calle 28, Número 13 A 15, Piso 6
Santafé de Bogotá, D.C.
Tel: +(571) 336 2495
Fax: +(571) 336 2482

CUBA
Ministerio de Justicia
Calle O No. 216 entre 23 y 25, Vedado
Código Postal 10400
La Habana
Tel: +(53 7) 324 536, +(53 7) 322 931
Fax: +(53 7) 333 088

CZECH REPUBLIC*
Ministry of Industry and Trade
Department of International Trade Organizations
Politických vezn 20
Praha 1
Tel: +(420 2) 2406 2569
Fax: +(420 2) 2422 1560

DOMINICAN REPUBLIC
Secretariado Técnico de la Presidencia
Ave. México, esq. Dr. Delgado (Palacio Nacional)
Santo Domingo
Tel: +(809) 685 7701, +(809) 682 5430
Fax: +(809) 686 7040

EGYPT
The Department of International Economic Organizations
Trade Representation Department (TAMSEEL)
Ministry of Trade and Supply
Cairo
Tel: (+20 2) 346 8830, 347 1890
Fax: (+20 2) 344 4398, 345 1840

ECUADOR
Subsecretaría Económica
Ministerio de Relaciones Exteriores
Avenida 10-de-Agosto y Carrión

a/ Unless otherwise stated, the addresses given are enquiry points. An asterisk (*) indicates that the address given is both an enquiry and a contact point.

Quito
Tel: +(593 2) 561 032
Fax: +(593 2) 569 805

EL SALVADOR
Ministerio de Economía
Dirección de Política Comercial
Edificio C-2, Tercera Planta Centro de Gobierno
Plan Maestro
Calle Guadalupe y Alameda Juan Pablo II
San Salvador, C.A.
Tel/Fax: +(503) 221 4771

EUROPEAN COMMUNITIES*

EUROPEAN COMMISSION*
DGI - External Relations
Services and External Dimension of the Union
Unit I/M/1
Rue de la Loi 200
1049 Brussels, Belgium
Tel: +(32 2) 296 5649
Fax: + (32 2) 299 2435

AUSTRIA*
Federal Ministry for Economic Affairs
Directorate II/11a
Stubenring 1
1011 Vienna
Tel: +(43 1) 711 00 (ext. 6915/5516)
Fax: +(43 1) 718 0508, +(43 1) 715 9651
Telex: 111145 regeb a

BELGIUM*
Ministère des affaires économiques
Administration des relations économiques
Rue du Cornet 43
1040 Bruxelles
Tel: +(32 2) 206 5811
Fax: +(32 2) 230 0050

DENMARK*
Ministry of Foreign Affairs
The North Group N.4
Asiatisk Plads 2
1448 Copenhagen K
Tel: +(45) 3392 0000
Fax: +(45) 3392 0433

FINLAND*
Ministry for Foreign Affairs
Department for External Economic Relations
Unit for International Economic Organisations
P.O. Box 176
00161 Helsinki
Tel: +(358 9) 1341 5531
Fax: +(358 9) 1341 5599

FRANCE*
Ministère de l'économie et des finances
Direction des relations économiques extérieures
Sous Direction des affaires multilatérales
Bureau des échanges internationaux de services
139 rue de Bercy
75772 Paris Cedex 12
Tel: +(33 1) 5318 8252
Fax: +(33 1) 5318 9655

GERMANY*
Federal Office for Foreign Trade Information - BFAI
Scharnhorststr. 36
10115 Berlin
Tel: +(49 30) 2014 5200
Fax: +(49 30) 2014 5204

GREECE*
Ministry of National Economy
General Secretariat for International Economic Relations
General Directorate for External Economic and Commercial Relations
Directorate for External Trade Policy
1 Kornarou Street
10563 Athens
Tel: +(30 1) 328 6308
Fax: +(30 1) 328 6179

IRELAND*
Department of Tourism and Trade
WTO Section
Kildare Street
Dublin 2
Tel: +(353 1) 662 1444
Fax: +(353 1) 676 6154

ITALY*
Ministero degli Affari Esteri
Dirizione Generale degli Affari Economici
Piazzale della Farnesina 1
000194 Rome
Tel: +(39 6) 3691 3874
Fax: +(39 6) 3691 5280
E-mail: Econ.Quinto@agora.stm.it

LUXEMBOURG*
Ministère des affaires étrangères
Direction des relations économiques internationales et de la coopération
2911 Luxembourg
Tel: +(352) 478 2355
Fax: +(352) 22 2048

NETHERLANDS*
Ministry of Economic Affairs
Directorate-General for Foreign Economic Relations
Trade and Investment Policy Department (ALP: B227)
P.O. Box 20101
2500 EC Den Haag
Tel: +(31 70) 379 6331, +(31 70) 379 6250
Fax: +(31 70) 379 7221
E-mail: M.F.T.RiemslagBaas@MinEZ.nl

PORTUGAL
Enquiry point:
Ministry of Foreign Affairs
General Directorate for Community Affairs
R Cova da Moura 1
1300 Lisbon
Tel: +(351 1) 395 4588, +(351 1) 395 4589
Fax: +(351 1) 395 4540

Contact point:
Ministry of Economy
ICEP - Investment, Trade and Tourism of Portugal
Av. 5 de Outubro 101
1050 Lisbon
Tel: +(351 1) 793 0103
Fax: +(351 1) 795 2329

SPAIN*
Ministerio de Economía y Hacienda
Secretaria de Estado de Comercio, Turismo y de la Pequeña y Mediana Empresa
Dirección General de Comercio Exterior
Subdirección General de Comercio Internacional de Servicios
Paseo de la Castellana 162, 5a Planta
28046 Madrid
Tel: +(34 1) 349 3781
Fax: +(34 1) 349 5226

SWEDEN*
Kommerskollegium (National Board of Trade)
First Division
Första Utrikeshandelsbyrån
Box 6803
S-113 86 Stockholm
Tel: +(46 8) 690 4800
Fax: +(46 8) 306 759

UNITED KINGDOM*
Department of Trade and Industry
Trade Policy and Europe Directorate 2
Room 347
Kingsgate House
66-74 Victoria Street
London SW1E 6SW
Tel: +(44 171) 215 4248
Fax: +(44 171) 215 4252

GHANA
The Director (Multilaterals)
Ministry of Trade and Industry
P.O. Box M.47
Accra
Tel: +(233 21) 667 382
Fax: +(233 21) 662 428
E-mail: moti@ighmail.com

GUATEMALA
Ministerio de Economía
Dirección de Negociaciones Comerciales Internacionales
8a Av. 10-43 Zona 1
3° Piso
Guatemala C.A.
Tel: (502) 238 3331 ext. 3301
Fax: (502) 238 3331 3xt. 3375

HAITI
Directeur du commerce extérieur
Ministère du commerce et de l'industrie
Champ-de-Mars
Port-au-Prince (W.I.)
Tél: (509) 228 167
Fax: (509) 238 402, 235 950

HONG KONG
The Assistant Director General
Multilateral Division
Trade Department
Hong Kong Government
Trade Department Tower
Nathan Road 700
Kowloon
Fax: +(852) 2789 2491

HONDURAS
Secretaria de Economía y Comercio
Dirección General de Política Comercial
Edificio Salamé 3° piso
Calle Peatonal
Tegucigalpa
Tel: +(504) 226 055, +(504) 221 819
Fax: +(504) 381 336

HUNGARY
Ministry of Industry and Trade
Department of International Organisations and Tariff Policy
Honvéd. u. 13-15
1880 - Budapest
Tel/Fax: +(36 1) 331 2167

ICELAND
Ministry for Foreign Affairs
External Trade Department
Raudararstig 25
150 - Reykjavík
Tel: +(354) 560 9930
Fax: +(354) 562 4878

INDIA
Trade Policy Division
Ministry of Commerce
Udyog Bhawan
New Delhi 110011
Tel: +(91 11) 301 3691, +(91 11) 301 6461
Fax: +(91 11) 301 4418, +(91 11) 301 3583

ISRAEL*
Ministry of Finance
The International Division
P.O. Box 13195
Jerusalem 91131
Tel: +(972 2) 670 5296
Fax: +(972 2) 651 3207

Ministry of Industry and Trade
Foreign Trade Administration
30 Agrron Street
Jerusalem 94190
Tel: +(972 2) 622 0289
Fax: +(972 2) 624 3005

JAMAICA
The Director
International Trade and Negotiations Division
Planning Institute of Jamaica
8 Ocean Boulevard
Kingston Mall
Tel: (1876) 967 3690-2
Fax: (1876) 967 4871, (1876) 967 3688

JAPAN
Ministry of Foreign Affairs
Services Trade Division
Kasumigaseki 2-2-1, Chiyoda-ku
Tokyo
Tel: +(81 3) 3580 3311 ext. 2751 or 2752
Fax: +(81 3) 3592 6296

Ministry of Foreign Affairs
Services Trade Division
Kasumigaseki 2-2-1
Chiyoda-ku
Tokyo
Tel: +(81 3) 3580 3311 ext. 2751 or 2752
Fax: +(81 3) 3592 6296

KENYA*

Services:
Department of External Trade
P.O Box 43137
Nairobi
Tel: +(254 2) 333 555
Fax: +(254 2) 226 036

Movement of natural persons:
(a) Ministry of Labour & Manpower Development
Social Security House
P.O. Box 40326
Nairobi
Tel: +(254 2) 729 700, +(254 2) 729 800
Fax: +(254 2) 726 497

(b) Immigration Department
Office of the President
Nyayo House
P.O. Box 90284
Nairobi
Tel: +(254 2) 333 551
Fax: +(254 2) 220 731

Air transport services:
Ministry of Transport & Communication
P.O. Box 52692
Nairobi
Tel: +(254 2) 729 200
Fax: +(254 2) 726 362

Financial services:
Ministry of Finance
Treasury Building
P.O. Box 30007
Nairobi
Tel: +(254 2) 338 111
Fax: +(254 2) 330 426

LIECHTENSTEIN
Office for Foreign Affairs
Heiligkreuz 14
9490 Vaduz
Tel: +(41 75) 236 6057
Fax: +(41 75) 236 6059

MADAGASCAR
Ministère chargé du commerce
B.P. 454
Antananarivo 101
Tel: +(261 2) 261 40, +(261 2) 207 58
Fax: +(261 2) 264 26, +(261 2) 312 80

MALDIVES
Ministry of Trade and Industries
Government of Maldives
Ghaazee Building
Ameeru Ahmed Magu
Male 20-05
Tel: (960) 323 668, (960) 325 205
Fax: (960) 323 840
E-mail: trademin@dhivehnet.net.mv

MEXICO
Secretaría de Comercio y Fomento Industrial
Dirección General de Negociaciones de Servicios y Coordinación con Europa
(Ministry of Trade and Industrial Development Directorate General for Negotiations on Services and Coordination with Europe)
Alfonso Reyes 30, Colonia Condesa
06140 Mexico DF
Tel: + (52 5) 729 9140, + (52 5) 729 9141
Fax: + (52 5) 729 9381

MOROCCO
Ministère du commerce extérieur
Boulevard Moulay Youssef
10000 Rabat
Tel: + (212 7) 751 532
Fax: + (212 7) 735 023

NEW ZEALAND
The Trade Negotiations Division
Ministry of Foreign Affairs and Trade
Private Bag 18-901
Wellington
Tel: +(64 4) 494 8500
Fax: +(64 4) 472 9596

NORWAY
Royal Ministry of Foreign Affairs
Department of External Economic Affairs
Section IV (Services, investment)
PO Box 8114 Dep
0032 - Oslo
Tel: +(47) 2224 3907, +(47) 2224 3921, +(47) 2224 3600
Fax: +(47) 2224 3600

PAKISTAN
Assistant Chief
ITO Wing
Ministry of Commerce
State Life Building No 5, 7th Floor
Blue Area
Islamabad

PANAMA
Ministerio de Comercio e Industrias
Viceministerio de Comercio Exterior
Dirección Nacional de Servicios al Comercio Exterior
Apartado postal 552359
Paitilla
Tel: +(507) 236 0122, 236 0347
Fax: +(507) 236 0495
E-mail: secomex@mici.gob.pa

PARAGUAY*
Ministerio de Industria y Comercio
Subsecretaría de Estado de Comercio
Avenida España 323 c/EE.UU
Asunción
Tel/Fax: +(59 521) 227 140
E-mail: sscemic@oka.net.py

PERU
Dirección de Relaciones Económicas Internacionales
Ministerio de Relaciones Exteriores
Jirón Lampa No. 535
Lima
Fax: +(51 1) 426 0128

PHILIPPINES
National Economic Development Authority (NEDA)
NEDA sa Pasig
Amber Avenue, Pasay City
1600 Metro Manila

POLAND*
Ministry of Economy
Trade and Services Department
GATS Enquiry Point
Plac Trzech Krzyzy 3/5
00-507 Warsaw
Tel: (48 22) 693 5148, (48 22) 621 8828
Fax: (48 22) 693 5096

QATAR
Department of Commerce
Ministry of Finance, Economy and Commerce
P.O. Box
22355 Doha
Tel: (0974) 432 103
Fax: (0974) 431 412

REPUBLIC OF KOREA*
World Trade Organization Team
Ministry of Foreign Affairs and Trade
Government Complex Sejongro
Seoul
Tel: +(82 2) 720 2188, +(82 2) 739 9142
Fax: +(82 2) 738 9726
E-mail: wto@mofat.go kr

ROMANIA
Directorate for Multilateral Relations
Ministry of Industry and Commerce
17, Apolodor Street
Bucharest 7000
Tel: (401) 411 1190, 410 2186
Fax: (410) 411 2342

SINGAPORE
Singapore Trade Development Board
230 Victoria Street # 09-00
Bugis Junction Office Tower
Singapore 188024
Tel: +(65) 337 6628
Fax: +(65) 337 6898

SLOVAK REPUBLIC*
Ministry of Economy
Trade Policy Division
Department of International Organizations
Mierová 19
82715 - Bratislava
Tel: +(42 7) 574 2515
Fax: +(42 7) 574 3579

SLOVENIA
Ministry of Economic Relations and Development
State Secretary for Trade Policy
Kotnikova 5
1000 Ljubljana
Tel: +(386 61) 178 3542
Fax: +(386 61) 178 3611

SOUTH AFRICA
The Director
Foreign Trade Relations
Department of Trade and Industry
Private Bag X84
Pretoria 0001
Tel: +(2712) 310 9413, +(2712) 310 9380
Fax: +(2712) 320 7905

SRI LANKA
Director of Commerce
Department of Commerce
4th Floor, Rakshana Mandiraya
Vauxall Street 21
Colombo 2
Tel: +(94 1) 329 733, +(94 1) 430 068
Fax: +(94 1) 430 233
Telex: 21908 Commerce

SURINAME
Mrs. M. Tilborg
Ministry of Finance/Economic Affairs Department
Section of International Economic Affairs
Gravenstraat
Paramaribo
Tel: (597) 471 069, (597) 475 614
Fax: (597) 476 314, (597) 476 309

SWITZERLAND*
Federal Office for Foreign Economics Affairs
3003 Berne
Tel: +(41 31) 324 0867
Fax: +(41 31) 324 0967

THAILAND*
Division of Trade in Services
Department of Business Economics
Ministry of Commerce
Ratchadamnoen Klang Road
Bangkok 10200
Tel: +(66 2) 282 6171, +(66 2) 282 6172,
+(66 2) 282 6173, +(66 2) 282 6174,
+(66 2) 282 6175, +(66 2) 282 6176,
+(66 2) 282 6177, +(66 2) 282 6178,
+(66 2) 282 6179
Fax: +(66 2) 629 1792, +(66 2) 280 0775,
+(66 2) 280 0826
Telex: 84361 DEPBUSE TH

TRINIDAD AND TOBAGO
Mr Bernard Sylvester
Ministry of Trade and Industry
Level 12, Riverside Plaza
Besson Street
Port of Spain
Tel: (868) 627 0057, (868) 627 1913
Fax: (868) 627 8488
E-mail: mini@trinidad.net

TURKEY
The Under-Secretariat of Treasury
General Directorate of Banking and Exchange
Inönü Bulvari
06510 Emek-Ankara
Fax: +(312) 212 8775

UGANDA
(a) National enquiry point
The Ministry of Trade and Industry
Directorate of Foreign Trade
Farmers House, Parliament Avenue
P.O. Box 7103
Kampala
Tel: (256 41) 254 091 / 2, (256 41) 230 933
Fax: (256 41) 252 578

(b) Sectoral enquiry points
Labour
The Ministry of Labour and Social Services
17/19 Hannington Road
Crested Towers Building

P.O. Box 5261
Kampala
Tel: (256 41) 258 334

Financial and banking services
The Bank of Uganda
Research Department
P.O. Box 7120
Kampala
Tel: (256 41) 259 866
Fax: (256 41) 230 878

Transport services
The Ministry of Transport and Communications
Airport Road
P.O. Box 10
Entebbe
Tel: (256 42) 201 01 / 9
Fax: (256 42) 201 35

Tourism
The Uganda Tourist Board
IPS Building, Parliament Avenue
P.O. Box 7211
Kampala
Tel: (256 41) 342 196 / 7
Fax: (256 41) 342 188

Telecommunications
The Uganda Post & Telecommunications Corporation
P.O. Box 7171
Kampala
Tel: (256 41) 256 151
Fax: (256 41) 345 505
E-mail: uptccp@imul.com

Energy
The Ministry of Natural Resources
Amber House
29/53 Kampala Road
P.O. Box 7172
Kampala
Tel: (256 41) 230 243, (256 41) 254 732

Insurance
The National Insurance Corporation
NIC Building
Pilkinton Road
P.O. Box 7134
Kampala
Tel: (256 41) 258 001/ 3
Fax: (256 41) 259 925

UNITED ARAB EMIRATES
WTO Division
Ministry of Economy and Commerce
P.O. Box 901
Abu Dhabi
Tel: (+971 2) 265 000
Fax: (+971 2) 260 000
E-mail: economy@emirates.net.ae

UNITED STATES OF AMERICA*
Chair, Trade Policy Sub-Committee on Services
Office of the United States Trade Representative
Washington, D.C. 20508
Tel: +(1 202) 395 7271
Fax: +(1 202) 395 3891

URUGUAY*
Ministerio de Relaciones Exteriores
Dirrección General para Asuntos Económicos Internacionales
Colonia 1206
Montevideo
Tel: +(598 2) 920 618
Fax: +(598 2) 917 413

VENEZUELA
Instituto de Comercio Exterior
Dirección General de Negociaciones Comerciales
Internacionales
Dirección para Asuntos de la OMC
División sobre Comercio de Servicios
Avenida Libertador
Centro Comercial "Los Cedros", Piso 5
Caracas 1050
Tel: +(58 2) 731 1676, +(58 2) 731 1955,
+(58 2) 761 0419, +(58 2) 761 6555
Fax: +(58 2) 762 2961

ZAMBIA
The Chief Economist
(Commerce & Trade)
Ministry of Commerce
Trade and Industry
P.O. Box 31968
Lusaka
Tel: +(260) 122 1475, 122 6673
Fax: +(260) 122 3273
E-mail: comtrade@zamnet.zm

ផ្នែកទីបួន

លទ្ធកម្មសាធារណៈ
និងការធ្វើពាណិជ្ជកម្មរបស់រដ្ឋ

ជំពូក ១៨

លទ្ធកម្មសាធារណៈរបស់រដ្ឋាភិបាល

សេចក្តីសង្ខេប

វិធានរបស់GATT បានលើកលែងជាពិសេសនូវការទិញទាំងឡាយរបស់រដ្ឋាភិបាល និងទីភ្នាក់ងារដែលគ្រប់គ្រងដោយរដ្ឋាភិបាល ចេញពីវិធានប្រព្រឹត្តកម្មជាតិ ។ ទីភ្នាក់ងាររដ្ឋាភិបាលដែលនាំចូលសំភារៈតាមតម្រូវការរបស់ខ្លួន មិនមានកាតព្វកិច្ចតាមប្រព្រឹត្តកម្ម MFN ចំពោះអ្នកផ្គត់ផ្គង់ផលិតផលក្រៅប្រទេសទេ ប៉ុន្តែមានតែកាតព្វកិច្ចផ្តល់នូវប្រព្រឹត្តកម្មសមស្រប និងស្មើភាពចំពោះអ្នកផ្គត់ផ្គង់នោះតែប៉ុណ្ណោះ ។ បទបញ្ញត្តិនេះ អនុញ្ញាតឲ្យភ្នាក់ងារទិញ ទិញផលិតផលតាមតម្រូវការរបស់ខ្លួន ពីផលិតករក្នុងស្រុក ទោះជាផលិតករក្រៅប្រទេស អាចស្នើលក់ផលិតផលដែលមានគុណភាពប្រហាក់ប្រហែលតាមតំលៃទាបជាងក៏ដោយ ។

កិច្ចព្រមព្រៀងស្តីពីលទ្ធកម្មសាធារណៈរបស់រដ្ឋាភិបាល ដែលបានកែប្រែយ៉ាងច្រើននៅអ៊ុយរូហ្គាយ តម្រូវអោយ ប្រទេសដែលជាសមាជិកព្រមព្រៀងលើប្រព្រឹត្តកម្មជាតិ និងMFN ជាមួយរដ្ឋាភិបាលដែលជាអ្នកទិញ ។ កាតព្វកិច្ចពង្រីកប្រព្រឹត្តកម្មនោះ ធ្វើឡើងចំពោះការទិញទាំងឡាយណាដែលធ្វើឡើងដោយ ទីភ្នាក់ងារទាំងអស់របស់រដ្ឋាភិបាលដូចមានរាយឈ្មោះ ដោយប្រទេសជាសមាជិកក្នុងឧបសម្ព័ន្ធនៃកិច្ចព្រមព្រៀងនេះ។ ឧបសម្ព័ន្ធនេះ គឺជាផ្នែកមួយនៃកិច្ចព្រមព្រៀង ។ កិច្ចព្រមព្រៀងតម្រូវឱ្យបណ្តាទីភ្នាក់ងារដែលមានរាយឈ្មោះ ផ្តល់សំណើទិញ ដែលក្នុងនោះ ផលិតករបរទេសអាចមានកាលានុវត្តន៍សមស្រប និងស្មើភាពគ្នា ក្នុងការចូលរួមផ្តល់សំណើ ។

ប៉ុន្តែ កិច្ចព្រមព្រៀងថ្មីស្តីពីលទ្ធកម្មសាធារណៈរបស់រដ្ឋាភិបាល គឺជាកិច្ចព្រមព្រៀងពហុភាគី និងខុសពីកិច្ចព្រមព្រៀង Multilateral ដូចមានបញ្ជាក់ក្នុងជំពូកមុនៗ នៃមគ្គុទេសក៍នេះ ហើយបណ្តាប្រទេសដែលជាសមាជិកអង្គការWTO មិនមានកាតព្វកិច្ច ដែលត្រូវចូលរួមនោះទេ ។ សមាជិកបច្ចុប្បន្ននៃកិច្ចព្រមព្រៀងនេះ នាពេលថ្មីៗនេះ ភាគច្រើនគឺជាប្រទេសជឿនលឿន។ កន្លងមកមានតែប្រទេសកំពុងអភិវឌ្ឍន៍ ចំនួនបីប៉ុណ្ណោះ រួមមាន - ហុង កុង (ចិន) សាធារណរដ្ឋកូរ៉េ និងសិង្ហបុរី - ដែលបានចូលជាសមាជិក។ បណ្តាប្រទេសកំពុងអភិវឌ្ឍន៍ដែលមិនមែនជាសមាជិកកិច្ចព្រមព្រៀងនេះ មិនជាប់កាតព្វកិច្ចត្រូវពង្រីកប្រព្រឹត្តកម្មជាតិ និង MFN ចំពោះផលិតផល និងអ្នកផ្គត់ផ្គង់បរទេសទេ ។

គួរកត់សំគាល់ដែរថា ដើម្បីនឹងត្រៀមខ្លួនអោយប្រទេសកំពុងអភិវឌ្ឍន៍ចូលជាសមាជិកនៃកិច្ចព្រមព្រៀងនេះ បច្ចុប្បន្នគេកំពុងបំពេញមានការងារថ្មីៗ ដើម្បីរៀបចំកិច្ចព្រមព្រៀងបណ្តោះអាសន្នមួយស្តីពីតម្លាភាពលើលទ្ធកម្មសាធារណៈរបស់រដ្ឋាភិបាល ។ កិច្ចព្រមព្រៀងនេះ អាចជាកិច្ចព្រមព្រៀងពហុភាគី ហើយមិនមានកំណត់កាតព្វកិច្ចទៅលើបណ្តាប្រទេសដែលជាសមាជិក ដើម្បីពង្រីក MFN និងប្រព្រឹត្តកម្មជាតិទេ ។ កិច្ចព្រមព្រៀងនេះ គ្រាន់តែអនុវត្តបទបញ្ញត្តិតាមនីតិវិធី ដែលដឹកនាំទៅរកការកែលំអតម្លាភាពអោយកាន់តែប្រសើរឡើងនៅក្នុងវិធី ដែលភ្នាក់ងារទិញរបស់រដ្ឋាភិបាលបានអនុម័តយល់ព្រម ដើម្បីទិញទំនិញលទ្ធកម្ម (សូមអានជំពូក ១១)។

នៅស្ទើតែគ្រប់ប្រទេសទាំងអស់ រដ្ឋាភិបាល និងភ្នាក់ងារដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់រដ្ឋាភិបាល គឺជាអ្នកទិញទំនិញ និងសេវាកម្មដ៏សំខាន់មួយ ។ ជារឿយៗ ការទិញមានតំលៃស្មើនឹង ១០% ទៅ ១៥% នៃផលិតផលជាតិសរុបទាំងអស់របស់ប្រទេស។ ពាណិជ្ជកម្មអន្តរជាតិនៅក្នុងការទិញផលិតផល និងសេវាកម្មរបស់រដ្ឋាភិបាល មានការកើនឡើងជាប្រចាំ ហើយបច្ចុប្បន្នមានតំលៃដល់រាប់ពាន់កោដដុល្លារ ក្នុងមួយឆ្នាំៗ ។

សាមគារនៃការវិវត្តន៍វិធាន

វិធានអន្តរជាតិដែលគ្រប់គ្រងការធ្វើពាណិជ្ជកម្មនេះ កំពុងមានការវិវត្តន៍ទៅមុខ ។ នៅពេលចរចា GATT ឆ្នាំ ១៩៤៧ ប្រទេសស្ទើរតែទាំងអស់ បានទាមទារអោយនាយកដ្ឋាន និងភ្នាក់ងាររដ្ឋាភិបាលរបស់ប្រទេសគេ ព្រមព្រៀងទិញតាមតំលៃអនុគ្រោះចំពោះផលិតករក្នុងស្រុក និងទិញផលិតផលបរទេស តែក្នុងករណីដែលតំលៃក្នុងស្រុកខ្ពស់ជាង (ពី១០%ទៅ១៥%) តំលៃផលិតផលនាំចូល ។ បន្ថែមពីលើនោះ នៅពេលនាំចូលទំនិញ ជារឿយៗភ្នាក់ងារទិញ មានភាតព្វកិច្ចទិញពីអ្នកផ្គត់ផ្គង់ក្នុងប្រទេសណា ដែលរដ្ឋាភិបាលមានទំនាក់ទំនងពាណិជ្ជកម្ម ឬ នយោបាយជាមួយ។

ដូចបានបញ្ជាក់រួចមកហើយថា ការផ្តល់តំលៃអនុគ្រោះ មិនមានលក្ខណៈស្របទៅតាមគោលការណ៍ប្រព្រឹត្តិកម្មជាតិទេ ព្រោះគោលការណ៍មិនអនុញ្ញាតផ្តល់ភាពអនុគ្រោះចំពោះផលិតផលនាំចូលតិចជាងផលិតផលក្នុងស្រុកឡើយ ។ ម៉្យាងទៀត ការកំណត់អោយភ្នាក់ងារទិញ ទទួលបានការនាំចូលតែពីប្រទេសមួយចំនួនដែលបានកំណត់នោះ ក៏មិនស្របទៅតាមគោលការណ៍មិនរើសអើងដែលមានចែងនៅក្នុងវិធានរបស់ MFNដែរ ។

GATT ១៩៩៤ មាត្រា ៣: ៨ (ក)
GATT ១៩៩៤ មាត្រា ១៧:២

ចំពោះប្រទេសដែលមិនបានត្រៀមខ្លួនចំពោះបំលាស់ប្តូរការអនុវត្តន៍នេះទេ វិធាន GATT បានចែងជាពិសេសអញ្ញត្រកម្មមិនរាប់បញ្ចូលនូវទំរង់លទ្ធកម្មលើទំនិញប្រើប្រាស់ផ្ទាល់ខ្លួន ដោយភ្នាក់ងាររដ្ឋាភិបាល ហើយមិនបានអនុវត្តវិធានប្រព្រឹត្តកម្មជាតិ ទៅលើការលក់បែបពាណិជ្ជកម្មដែរ ។ វិធានក៏មិនតំរូវអោយប្រទេស ពង្រីកប្រព្រឹត្តិកម្ម MFN ចំពោះផលិផលនាំចូលដោយភ្នាក់ងាររដ្ឋាភិបាល ដើម្បីប្រើប្រាស់ខ្លួនឯងដែរ ។ គ្រាន់តែមានការស្នើសុំអោយប្រទេសទាំងនោះ អនុវត្តប្រព្រឹត្តកម្មដោយស្មើភាព និងយុត្តិធម៌ប៉ុណ្ណោះចំពោះអ្នកផ្គត់ផ្គង់ ។

កិច្ចព្រមព្រៀងស្តីពីលទ្ធកម្មសាធារណៈរបស់រដ្ឋាភិបាល

គោលនយោបាយដែលតំរូវអោយភ្នាក់ងារទិញរបស់រដ្ឋាភិបាល ទិញផលិតផលក្នុងស្រុក គឺជាការបង្កើនចំណាយរបស់រដ្ឋាភិបាល និងបន្ថែមបន្ទុកដល់អ្នកបង់ពន្ធ ទោះបីជាទំនិញបរទេសអាចទិញបានក្នុងតំលៃថោកជាងក៏ដោយ ។ ការពិចារណាទាំងនេះ បានដឹកនាំប្រទេសដែលជាសមាជិករបស់ GATT ឈានទៅរកការចរចានៅតូក្យូ (Tokyo) ដើម្បីកិច្ចព្រមព្រៀង ស្តីពីលទ្ធកម្មសាធារណៈរបស់រដ្ឋាភិបាល។ កិច្ចព្រមព្រៀងដែលអនុវត្តចំពោះតែទំនិញ ត្រូវបានកែប្រែយ៉ាងច្រើន និងយ៉ាងទូលំទូលាយ ដើម្បីគ្របដណ្តប់ទៅលើការទិញដោយសេវាកម្មរដ្ឋាភិបាល ក្នុងពេលចរចាស្របគ្នា នៅឧរុយហ្គាយ ។

គោលបំណង

កិច្ចព្រមព្រៀងស្តីពី លទ្ធកម្មសាធារណៈ របស់រដ្ឋាភិបាល បុព្វកថា

កិច្ចព្រមព្រៀងស្តីពីលទ្ធកម្មសាធារណៈរបស់រដ្ឋាភិបាល មានគោលបំណងសំខាន់បំផុត គឺតំរូវអោយរដ្ឋាភិបាលធ្វើការពិចារណាទៅលើតំលៃពាណិជ្ជកម្ម នៅពេលធ្វើលទ្ធកម្មទំនិញ និងសេវាកម្មសំរាប់ប្រើប្រាស់ផ្ទាល់ខ្លួន ដោយមិនមានការរើសអើង រវាងការផ្គត់ផ្គង់ពីបរទេស និងការផ្គត់ផ្គង់ក្នុងស្រុក និងដើម្បីប្រើប្រាស់ប្រាក់ចំណូលពន្ធ និងមូលនិធិសាធារណៈដ៏ទៃទៀតអោយមានប្រសិទ្ធិភាពខ្ពស់។ ក៏ប៉ុន្តែ កិច្ចព្រមព្រៀង plurilateral និងកិច្ចព្រមព្រៀងពហុភាគី មិនដូចគ្នាទេ ដូចដែលពិភាក្សាពីខាងដើមរួចមកហើយ ព្រោះកិច្ចព្រមព្រៀង plurilateral មិនមានកំណត់ភាតព្វកិច្ចអោយបណ្តាប្រទេសជាសមាជិក WTO ត្រូវតែទទួលយកនោះទេ។ សមាជិកនៃកិច្ចព្រមព្រៀងនេះ ភាគច្រើនជាប្រទេសជឿនលឿន ឯប្រទេសកំពុងអភិវឌ្ឍន៍ មានចំនួនតែ បី ប៉ុណ្ណោះគឺ- ហុងកុង (ចិន) សាធារណៈរដ្ឋកូរ៉េ និងសាំងហ្គាពួរ - នៅក្នុងបញ្ជីឈ្មោះ ។

វិសាលភាព

កិច្ចព្រមព្រៀងស្តីពី លទ្ធកម្មសាធារណៈ របស់រដ្ឋាភិបាល មាត្រា១ និងឧបសម្ព័ន្ធ ១

ភាតព្វកិច្ចដែលកិច្ចព្រមព្រៀងបានកំណត់ អនុវត្តបានទៅលើតែការទិញដែលធ្វើឡើងដោយអង្គភាពលទ្ធកម្មសាធារណៈ ដែលមានរាយនាមនៅក្នុងបញ្ជីរបស់ប្រទេសនីមួយៗ ដែលមានភ្ជាប់ជាឧបសម្ព័ន្ធ ។ ឧបសម្ព័ន្ធទាំងនេះ ត្រូវដាក់បញ្ចូលជាផ្នែកមួយនៃកិច្ចព្រមព្រៀង ។ អង្គភាពដែលមានរាយនាមរួមមាន ÷

- ☐ ក្រសួង នាយកដ្ឋាន និងការិយាល័យកណ្ដាលរបស់រដ្ឋាភិបាលផ្សេងទៀត
- ☐ អនុអង្គការកណ្ដាល ដូចជាអង្គភាពក្រុង សាជីវកម្ម និងអង្គភាពមូលដ្ឋានផ្សេងៗទៀត
- ☐ ក្នុងករណីជារដ្ឋសហព័ន្ធ នាយកដ្ឋាន និងភ្នាក់ងាររដ្ឋាភិបាលនៅកំរិតខេត្ត និងរដ្ឋ
- ☐ សេវាកម្មសាធារណៈដែលផ្គត់ផ្គង់អគ្គិសនី និងទឹកស្អាត អង្គភាពគ្រប់គ្រងអាកាសយានដ្ឋាន កំពង់ផែ និងដឹកជញ្ជូនក្នុងក្រុង។

មានការលើកចំហអោយបណ្ដាប្រទេសជាសមាជិកបញ្ជាក់អោយច្បាស់នៅក្នុងឧបសម្ព័ន្ធស្ដីពីផលិតផល និងសេវាកម្មដែលគ្របដណ្ដប់ដោយកិច្ចព្រមព្រៀង។ ចំពោះទំនិញវិញ ប្រទេសជាសមាជិកបានបញ្ជាក់យ៉ាងទូលំទូលាយថា កិច្ចព្រមព្រៀងនឹងអនុវត្តទៅលើរាល់ការទិញទាំងអស់ ដោយអង្គភាពដែលបានចុះបញ្ជី ។ មានអញ្ញត្រកម្មតែមួយគត់ គឺការទិញរបស់នាយកដ្ឋានការពារជាតិតាមតំរូវការការពារប្រទេស ប៉ុន្តែការទិញរបស់នាយកដ្ឋានការពារជាតិ ក្នុងគោលបំណងមិនការពារជាតិ ក៏ស្ថិតនៅក្រោមកិច្ចព្រមព្រៀងនេះដែរ ។

ដូច្នេះ កិច្ចព្រមព្រៀងនេះ អនុវត្តទៅលើកិច្ចសន្យាស្ទើរតែទាំងអស់ ដែលផ្ដល់អោយដោយភ្នាក់ងាររដ្ឋាភិបាលពាក់ព័ន្ធលើលទ្ធកម្មទំនិញ ហើយដែលការចាប់ផ្ដើមបានធ្វើឡើងពាក់ព័ន្ធនឹងការទិញសេវាកម្មតែប៉ុណ្ណោះ ។ ប្រទេសជាសមាជិកទាំងអស់ បានដាក់បញ្ចូលសេវាកម្មសាងសង់ ទៅក្នុងវិសាលភាពនៃកិច្ចព្រមព្រៀងនេះដែរ ។ ដូចនេះ វិស័យសេវាកម្មដែលរដ្ឋាភិបាលបានចំណាយធនធានមួយភាគធំនៃថវិការបស់ខ្លួននោះ ក៏ស្ថិតនៅក្រោមគោលការណ៍នៃកិច្ចព្រមព្រៀងនេះដែរ។ ចំពោះសេវាកម្មផ្សេងទៀត វិធាននៃកិច្ចព្រមព្រៀងអនុវត្តទៅលើតែសេវាកម្មណា ដែលមានបញ្ជាក់នៅក្នុងឧបសម្ព័ន្ធរបស់ប្រទេសដែលជាសមាជិកនីមួយៗ តែប៉ុណ្ណោះ។ សេវាកម្មក្នុងចំណោមនោះមាន ÷

- ☐ សេវាកម្មពិគ្រោះយោបល់លើការគ្រប់គ្រង និងសេវាកម្មពាក់ព័ន្ធ
- ☐ សេវាកម្មស្រាវជ្រាវទីផ្សារ
- ☐ កុំព្យូទ័រ និងសេវាកម្មពាក់ព័ន្ធ
- ☐ សេវាកម្មគណនី និងសវនកម្ម
- ☐ សេវាកម្មផ្សាយពាណិជ្ជកម្ម
- ☐ សេវាកម្មសំអាតអាគារ និង
- ☐ ការបោះពុម្ព និងផ្សព្វផ្សាយ ។

បទបញ្ញត្តិសំខាន់ៗ

កិច្ចព្រមព្រៀងស្ដីពីលទ្ធកម្មសាធារណៈរដ្ឋាភិបាល មាត្រា៣

កាតព្វកិច្ចដ៏សំខាន់បំផុតដែលកិច្ចព្រមព្រៀងបានកំណត់ គឺការតំរូវអោយអង្គភាពទិញពង្រីកវិសាលភាព ចំពោះផលិតផលនាំចូល សេវាកម្ម អ្នកផ្គត់ផ្គង់ជាតិ និងប្រព្រឹត្តិកម្ម MFN ។ ទីមួយបង្អាក់ពួកគេ មិនអោយផ្ដល់ថ្លៃអនុគ្រោះ ឬ ភាពអនុគ្រោះផ្សេងៗ ចំពោះអ្នកផ្គត់ផ្គង់ក្នុងស្រុក និងទីពីរ មិនអនុញ្ញាតិអោយមានការរើសអើងចំពោះប្រទេសដែលផ្គត់ផ្គង់ខាងក្រៅ ។

បទបញ្ញត្តិដំណើរការផ្សេងៗ

កិច្ចព្រមព្រៀងស្ដីពីលទ្ធកម្មសាធារណៈរដ្ឋាភិបាល ពីមាត្រា ៧ ដល់ ១៦

ដើម្បីធានាអោយមានការអនុវត្តន៍កាតព្វកិច្ចសំខាន់ៗ ទាំងនេះ និងដើម្បីផ្ដល់កាលានុវត្តន៍ភាពត្រឹមត្រូវ និងយុត្តិធម៌ចំពោះអ្នកផ្គត់ផ្គង់ក្នុងស្រុក និងបរទេសដែលពាក់ព័ន្ធ កិច្ចព្រមព្រៀងបានកំណត់នូវវិធានស្ដីពីនីតិវិធីមួយចំនួន ។ ជាពិសេស កិច្ចព្រមព្រៀងតំរូវអោយអង្គភាពទិញខាងលើ threshold limits ដើម្បីបញ្ជាក់ពី ÷

- ☐ ការទិញដែលអាចធ្វើបាន ដោយការស្នើអោយដេញថ្លៃ ។
- ☐ ការធានាអោយអ្នកផ្គត់ផ្គង់បរទេស ទទួលបាននូវកាលានុវត្តន៍ភាពស្មើភាព និងយុត្តិធម៌ ដើម្បីចូលរួមក្នុងដំណើរការដេញថ្លៃ និង

- ☐ ផ្ដល់កិច្ចសន្យាអោយអ្នកដេញថ្លៃណា ដែលបានកំណត់មកថា មានសមត្ថភាពពេញលេញក្នុងការអនុវត្តន៍កិច្ចសន្យានោះ ហើយបញ្ជាក់ថាការដេញថ្លៃរបស់នរណាដែលទាបជាងគេ ឬ ក្នុងន័យនៃការវាយតំលៃលក្ខណៈវិនិច្ឆ័យដែលមានចែងក្នុងលិខិតជូនដំណឹង ដែលបានកំណត់ថាមានអត្ថប្រយោជន៍បំផុត ៗ

វណ្ឌ ៤៤ ពន្យល់ពីវិធីផ្សេងៗ ដែលអាចយកមកប្រើប្រាស់បាន នៅក្នុងការអញ្ជើញអោយដេញថ្លៃ និងលក្ខខណ្ឌ សំរាប់ប្រើប្រាស់របស់គេ ។

ខណ្ឌ ៤៤

វិធានស្ដីពីនីតិវិធីក្នុងការដេញថ្លៃរបស់រដ្ឋាភិបាល តំរូវអោយអង្គភាពទិញរបស់រដ្ឋាភិបាល ត្រូវទិញផលិតផលតាមរយៈការដេញថ្លៃ ដើម្បីផ្ដល់កាលានុវត្តន៍ភាពពាណិជ្ជកម្មស្មើភាព និងយុត្តិធម៌ទៅអោយ អ្នកផ្គត់ផ្គង់ក្នុងស្រុក និងបរទេស និងដើម្បីធានាដល់ប្រសិទ្ធិភាពនៃលទ្ធកម្ម ។ អង្គភាពទាំងនេះមានជំរើសមួយ ក្នុងចំណោមជំរើសទាំងបីដូចតទៅ ÷

- ☐ *បើកដាក់អោយដេញថ្លៃ ដើម្បីអោយអ្នកផ្គត់ផ្គង់ណាដែលចាប់អារម្មណ៍ អាចដាក់សំណើរដេញថ្លៃបាន*
- ☐ *នីតិវិធីនៃការជ្រើសរើសអ្នកដេញថ្លៃ ដើម្បីអញ្ជើញអ្នកផ្គត់ផ្គង់ណា ដែលធ្លាប់បានបញ្ជាក់ថា ជាអ្នកមានគុណសម្បត្តិចាំបាច់ប៉ុណ្ណោះ អោយមកចូលរួមដេញថ្លៃ និង*
- ☐ *នីតិវិធីនៃការដេញថ្លៃដែលបានកំណត់ ដែលតាមនីតិវិធីនេះ និងតាមកាលៈទេសៈពិសេសជាក់ស្ដែង ការទិញត្រូវបានធ្វើឡើង តាមរយៈការចរចារដោយផ្ទាល់ ជាមួយអ្នកផ្គត់ផ្គង់ដែលបានកំណត់ ។ តាមនីតិវិធីនៃការជ្រើសរើសអ្នកដេញថ្លៃជាទូទៅសហគ្រាសតែងតែរក្សាបញ្ជីឈ្មោះអ្នកផ្គត់ផ្គង់ដែលសមស្រប ។ កិច្ចព្រមព្រៀងបានចែងថា ក្នុងចំណោមអ្នកផ្គត់ផ្គង់ដែលមានលក្ខណៈសមស្របនេះ អង្គភាពទិញ ÷*
- ☐ *មិនត្រូវធ្វើការរើសអើងរវាងអ្នកផ្គត់ផ្គង់ក្នុងស្រុក និងបរទេសឡើយ*
- ☐ *គួរដាក់តែលក្ខខណ្ឌណាដែលទាក់ទងទៅនឹងគុណសម្បត្តិបច្ចេកទេស ការធានាហិរញ្ញវត្ថុ និងការកំណត់សមត្ថភាពពាណិជ្ជកម្ម របស់អ្នកផ្គត់ផ្គង់ប៉ុណ្ណោះ ដោយសារលក្ខខ័ណ្ឌទាំងនេះ ជាលក្ខខណ្ឌចាំបាច់ក្នុងការធានាសមត្ថកិច្ចរបស់ក្រុមហ៊ុន ដើម្បីបំពេញកិច្ចសន្យា និង*
- ☐ *គួរតែអនុញ្ញាតអោយអ្នកផ្គត់ផ្គង់ ស្នើសុំការកំណត់គុណសម្បត្តិនៅពេលណាមួយ ។ កិច្ចព្រមព្រៀងបានចែងថា នីតិវិធីនៃការដេញថ្លៃដែលបានកំណត់ គួរប្រើក្នុងស្ថានភាពពិសេស ដូចជា ÷*
- ☐ *ពេលដែលមិនបានទទួលសំណើរណាមួយ ឆ្លើយតបទៅនឹងការបើកអោយដេញថ្លៃ និងការដេញថ្លៃដែលបានជ្រើសរើស*
- ☐ *នៅពេលដាក់ដេញថ្លៃ ដោយមានការរួមគំនិត*
- ☐ *នៅពេលដែលតំរូវអោយអ្នកផ្គត់ផ្គង់ណាម្នាក់ បន្ថែមនូវនិស្សន៍ណាមួយលើសំណើរដេញថ្លៃឈ្នះរបស់គេនោះ ។ ជាងនេះទៀត ដើម្បីធានាអោយមានតំលាភាពគ្រប់គ្រាន់ក្នុងការអញ្ជើញអោយដេញថ្លៃ កិច្ចព្រមព្រៀងបានតំរូវអោយប្រទេសជាសមាជិកជូនដំណឹងទៅ WTO អំពីបញ្ជីនៃការផ្សព្វផ្សាយស្ដីពីការអញ្ជើញអោយដាក់ដេញថ្លៃនោះ ។*

ការពិនិត្យពិច័យជាសាធារណៈ និងដោយឈ្មួញចំពោះសេចក្ដីសំរេច

កិច្ចព្រមព្រៀងស្ដីពីលទ្ធកម្មសាធារណៈរបស់រដ្ឋាភិបាល មាត្រា ១៨

នៅក្នុងផ្នែកលទ្ធកម្មសាធារណៈរបស់រដ្ឋាភិបាល ជាទូទៅយើងតែងតែឮពីការប្ដឹងតវ៉ា អំពីកិច្ចសន្យាដែលពាក់ព័ន្ធនឹងចំនួនទឹកប្រាក់យ៉ាងច្រើន ហើយដែលបានប្រគល់ទៅអោយអ្នកដេញថ្លៃមួយដែលមានទំនាក់ទំនងនយោបាយត្រឹមត្រូវជាមួយរដ្ឋាភិបាល ។ ជារឿយៗគេឮពាក្យចោទប្រកាន់ថា មានការប្រគល់កិច្ចសន្យាទៅអោយក្រុមហ៊ុនក្នុងស្រុក ឬ បរទេសដែលលបអោយប្រាក់លួចលាក់ទៅអោយអ្នកដែលទទួលខុសត្រូវក្នុងការធ្វើសេចក្ដីសំរេច ។ កិច្ចព្រមព្រៀង បានប្រមើលមើលទៅលើការគ្រប់គ្រងសកម្មភាពមិនត្រឹមត្រូវនោះ ដោយអនុញ្ញាតិអោយមានការពិនិត្យពិច័យជាសាធារណៈ ទៅលើការធ្វើសេចក្ដីសំរេចផ្ដល់កិច្ចសន្យា ។ ដូច្នេះ កិច្ចព្រមព្រៀងតំរូវអោយនាយកដ្ឋានទិញធ្វើការបោះពុម្ពផ្សាយពី ÷

- ☐ សេចក្ដីជូនដំណឹងមុនពេលចេញសេចក្ដីសំរេច ដោយបញ្ជាក់ពីលក្ខណៈ និងបរិមាណ នៃផលិតផល ឬ សេវាកម្មដែលមានចែងនៅក្នុងកិច្ចសន្យា
- ☐ ឈ្មោះនិងអាសយដ្ឋាន របស់អ្នកឈ្នះលើការដេញថ្លៃនោះ
- ☐ តំលៃនៃការដេញថ្លៃដែលឈ្នះ និង
- ☐ សំណើដែលទាបបំផុត និងខ្ពស់បំផុត ហើយដែលត្រូវលើកមកពិចារណាដើម្បីផ្ដល់កិច្ចសន្យា

ថែមពីលើនេះទៀត ប្រសិនបើអ្នកដេញថ្លៃដែលបរាជ័យម្នាក់ស្នើរសុំ នោះអង្គភាពទិញ ត្រូវធ្វើការផ្ដល់ហេតុផលរបស់គេ ពីមូលហេតុដែលគេជ្រើសរើស ឬ បដិសេធសំណើរបស់ខ្លួន ។

នីតិវិធីតវ៉ា

កិច្ចព្រមព្រៀងស្ដីពីលទ្ធកម្មសាធារណៈរបស់រដ្ឋាភិបាល មាត្រា ២០

កិច្ចព្រមព្រៀងក៏បានអំពាវនាវអោយប្រទេសជាសមាជិកទាំងអស់ បង្កើតអង្គភាពត្រួតពិនិត្យឯករាជ្យមួយ នៅកំរិតជាតិ ដើម្បីទទួលពាក្យបណ្ដឹង ឬ ការតវ៉ា និងសំណើកែប្រែពីអ្នកផ្គត់ផ្គង់ក្នុងស្រុក និងបរទេស សបតនឹងអង្គភាពទិញណាមួយដែលគេគិតថា បានទទួលកិច្ចសន្យាដោយមិនស្របទៅតាមវិធាននៃកិច្ចព្រមព្រៀងស្ដីពីការផ្ដល់កិច្ចសន្យានោះ ។ នីតិវិធីសំរាប់ការស៊ើបអង្កេតចំពោះបណ្ដឹងតវ៉ា មានចែងពី ÷

- ☐ វិធានបណ្ដោះអាសន្ន ដើម្បីកែតំរូវកំហុសឆ្គងក្នុងការបំពានវិធាននៃកិច្ចព្រមព្រៀង រួមទាំងវិធានក្នុងការផ្អាកដំណើរការលទ្ធកម្មនោះផង ឬ
- ☐ ការបង់ប្រាក់សំណងទៅអ្នកធ្វើសំណើរទាមទារ ដែលអាចកំណត់ត្រឹមចំណាយនៃការរៀបចំការដេញថ្លៃ និងការទាមទារនោះ។

បន្ថែមពីលើនេះទៀត នៅពេលរដ្ឋាភិបាលនៃប្រទេសមួយដែលអ្នកផ្គត់ផ្គង់បរទេសនៅស្ថិតនៅ មិនពេញចិត្តចំពោះដំណោះស្រាយនៃការអនុវត្តន៍តាមវិធាននៃកិច្ចព្រមព្រៀងស្ដីពីការផ្ដល់កិច្ចសន្យាទេនោះ រដ្ឋាភិបាលនៃប្រទេសនោះអាចអនុវត្តនីតិវិធីនៃការដោះស្រាយវិវាទរបស់អង្គការពាណិជ្ជកម្មពិភពលោកបាន ។

បទបញ្ញត្តិពិសេសសំរាប់ប្រទេសកំពុងអភិវឌ្ឍន៍

កិច្ចព្រមព្រៀងស្ដីពីលទ្ធកម្មសាធារណៈរបស់រដ្ឋាភិបាល មាត្រា ៥

ដូចគេបានកត់សំគាល់ពីខាងដើមរួចមកហើយថា មានតែប្រទេសកំពុងអភិវឌ្ឍន៍ចំនួនប៉ុន្មានប៉ុណ្ណោះ មកទល់ពេលនេះ ដែលបានចូលជាសមាជិកនៃកិច្ចព្រមព្រៀងនេះ ។ ហេតុផលដែលធ្វើអោយប្រទេសកំពុងអភិវឌ្ឍន៍ មានការស្ទាក់ស្ទើរក្នុងការចូលរួមក្នុងកិច្ចព្រមព្រៀងនេះ ជាទូទៅអាចបណ្ដាលមកពីការគិតថា នៅពេលដែលគេចូលជាសមាជិក ពួកគេចាំបាច់ត្រូវផ្លាស់ប្ដូរគោលនយោបាយរបស់គេ។ គោលនយោបាយបច្ចុប្បន្ននេះ តំរូវអោយភ្នាក់ងារទិញរបស់គេ ធ្វើការទិញផលិតផលក្នុងស្រុក ដោយផ្ដល់ភាពអនុគ្រោះចំពោះផលិតករក្នុងស្រុក នៅពេលណាដែលអាចធ្វើបាន ហើយនៅពេលដែលពួកគេបានទទួលការអនុញ្ញាតិនោះ គេនឹងអញ្ជើញអោយអ្នកផ្គត់ផ្គង់បរទេសអោយចូលរួមផ្ដល់សំណើរ និងដើម្បីផ្ដល់កំរៃអនុគ្រោះដល់ផលិតផលក្នុងស្រុក។ ជាងនេះទៀត ដើម្បីជំរុញ

ការអភិវឌ្ឍន៍សហគ្រាសធុនតូច និងមធ្យម វិធានក្នុងស្រុកជារឿយៗ កំណត់កាតព្វកិច្ចអោយភ្នាក់ងារទិញរបស់ពួកគេធ្វើការជ្រើសរើសផលិតផលរបស់សហគ្រាសធុនតូច និងមធ្យម ជាងផលិតផលរបស់ក្រុមហ៊ុនធំៗ ។

កិច្ចព្រមព្រៀងស្តីពីលទ្ធកម្មសាធារណៈរបស់រដ្ឋាភិបាល មាត្រា ៥:៥

ទោះបីយ៉ាងណា កិច្ចព្រមព្រៀងបានចែងពីប្រព្រឹត្តកម្មពិសេស និងដោយឡែក ។ កិច្ចព្រមព្រៀងនេះ បានអនុញ្ញាតិអោយប្រទេសកំពុងអភិវឌ្ឍន៍ធ្វើការចរចារ សុំចូលជាសមាជិក ដោយមិនតំរូវអោយប្រទេសទាំងនោះត្រូវបំពេញកាតព្វកិច្ចទាំងឡាយ អោយស្របកិច្ចព្រមព្រៀង នៅពេលចូលជាសមាជិកនោះភ្លាមទេ ។ ឧទាហរណ៍ គេអាចចែងថា គោលការណ៍នៃកិច្ចព្រមព្រៀងត្រូវអនុវត្តទៅលើតែភ្នាក់ងារទិញមួយចំនួនប៉ុណ្ណោះ ។ ជាងនេះទៀត គេអាចធ្វើការចរចារ "ដើម្បីលើកលែងចេញពីវិធានការស្តីពីប្រព្រឹត្តកម្មជាតិ" នូវផលិតផល ឬ សេវាកម្មមួយចំនួន ដែលគេអាចបន្តតំលៃអនុគ្រោះទៅលើផលិតករក្នុងស្រុក តាមរយៈការទិញពីពួកគេទោះបីជាអ្នកផ្គត់ផ្គង់បរទេសបានដាក់តំលៃទាបជាងក៏ដោយ។

កិច្ចព្រមព្រៀងស្តីពីលទ្ធកម្មសាធារណៈរបស់រដ្ឋាភិបាល មាត្រា ៥:១២-១៣

កិច្ចព្រមព្រៀងមានបទបញ្ញត្តិជាក់លាក់ស្តីពីប្រព្រឹត្តកម្មពិសេស ដែលត្រូវព្រមព្រៀងគ្នា សំរាប់បណ្តាប្រទេសក្រីក្រ ចំពោះផលិតផល ឬ សេវាកម្មដែលមានប្រភពមកពីប្រទេសទាំងនេះ ។ កិច្ចព្រមព្រៀង បានដាក់កាតព្វកិច្ចអោយប្រទេសជឿនលឿន ផ្តល់ជំនួយការតាមសំណើរ ដល់អ្នកដេញថ្លៃជាសក្តានុពល នៅក្នុងបណ្តាប្រទេសទាំងនេះ ដើម្បីដាក់ដេញថ្លៃ និងដោយអនុលោមទៅតាមបទបញ្ជា និងស្តង់ដារបច្ចេកទេស និងបទដ្ឋាន ចំពោះផលិតផល ឬ សេវាកម្ម ដែលស្ថិតនៅក្រោមលទ្ធកម្មណាមួយ ។

កិច្ចព្រមព្រៀងស្តីពីលទ្ធកម្មសាធារណៈរបស់រដ្ឋាភិបាល មាត្រា ៥:១១

ជាងនេះទៀត ដើម្បីផ្តល់លទ្ធភាពអោយអ្នកផ្គត់ផ្គង់ក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ដែលបានក្លាយជាសមាជិករបស់កិច្ចព្រមព្រៀង ទទួលបានផលប្រយោជន៍យ៉ាងពេញលេញពីការបើកទីផ្សារលទ្ធកម្មសាធារណៈរបស់រដ្ឋាភិបាល ប្រទេសអភិវឌ្ឍន៍នីមួយៗ ត្រូវបានតំរូវអោយបង្កើតមជ្ឈមណ្ឌលពត៌មាន ដែលអាចផ្តល់ពត៌មានស្តីពី ÷

- ☐ ច្បាប់ បទបញ្ជា និងកិច្ចប្រតិបត្តិដែលពាក់ព័ន្ធទៅនឹងលទ្ធកម្មសាធារណៈរបស់រដ្ឋាភិបាល
- ☐ អាសយដ្ឋានរបស់អង្គភាព ដែលគ្របដណ្តប់ដោយកិច្ចព្រមព្រៀង
- ☐ លក្ខណៈ និងបរិមាណផលិតផល ឬ សេវាកម្មដែលទទួលបាន រួមមានទាំងពត៌មានស្តីពីសំណើរនាពេលអនាគត

តាមទស្សនៈគតិយុត្ត មានតែបណ្តាប្រទេសជាសមាជិកនៃកិច្ចព្រមព្រៀងប៉ុណ្ណោះ ដែលអាចធ្វើសំណើសុំអោយផ្តល់ពត៌មានទាំងនោះបាន ។ ក៏ប៉ុន្តែ នៅក្នុងការអនុវត្តន៍ជាក់ស្តែង មជ្ឈមណ្ឌលពត៌មានសុខចិត្តផ្តល់ពត៌មានទៅអោយបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ដែលជាសមាជិក WTO បើមិនទាំងអស់ ក៏ស្ទើរតែទាំងអស់ដែរ ទោះបីប្រទេសទាំងនោះមិនចូលជាសមាជិកនៃកិច្ចព្រមព្រៀងនោះក៏ដោយ ។ តាមពេលវេលាសមស្របណាមួយ កិច្ចព្រមព្រៀងបានប្រមើលមើលបន្ថែមទៀត ពីការបង្កើតមជ្ឈមណ្ឌលពត៌មានអន្តរជាតិមួយ នាពេលអនាគត ។ មជ្ឈមណ្ឌលពត៌មាននោះនឹងផ្តល់ពត៌មាន និងជំនួយការជូនដល់អ្នកផ្គត់ផ្គង់ដែលពាក់ព័ន្ធនៅក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ ហើយឱកាសក្នុងការរៀបចំមជ្ឈមណ្ឌលពត៌មាននេះ ពឹងពាក់ជាសំខាន់ ថាតើបណ្តាប្រទេសកំពុងអភិវឌ្ឍន៍មួយចំនួន នឹងចូលជាសមាជិកនៃកិច្ចព្រមព្រៀងនេះ ដោយរបៀបណា ។

ការពិភាក្សាកែលំអកិច្ចព្រមព្រៀង

កិច្ចព្រមព្រៀងស្តីពីលទ្ធកម្មសាធារណៈរបស់រដ្ឋាភិបាល មាត្រា ២៤:៧

កិច្ចព្រមព្រៀងអំពាវនាវអោយបណ្តាប្រទេសជាសមាជិក ធ្វើការចរចាបន្ថែមទៀត នៅក្នុងរយៈពេល ៣ឆ្នាំ ចាប់ពីថ្ងៃដែលកិច្ចព្រមព្រៀងនេះចូលជាធរមាន (ថ្ងៃទី ១ ខែ មករា ឆ្នាំ ១៩៩៦) និងបន្ទាប់មក ធ្វើការចរចាជាប្រចាំ ដើម្បីកែលំអកិច្ចព្រមព្រៀង។ យោងទៅតាមបទបញ្ញត្តិទាំងនេះ នៅក្នុងខែ កុម្ភៈ ឆ្នាំ ១៩៩៧ គណៈកម្មាធិការលទ្ធកម្មសាធារណៈរបស់រដ្ឋាភិបាល បានផ្តួចផ្តើមគំនិតធ្វើការចរចា ដែលពិភាក្សាលើចំណុចខាងក្រោម ÷

- ☐ ការសំរួល និងការកែលំអកិច្ចព្រមព្រៀង រួមមានទាំងការកែតំរូវនូវអត្ថប្រយោជន៍ផ្នែកបច្ចេកវិទ្យាពត៌មានផង ប្រសិនបើសមស្រប ។

- ☐ លុបបំបាត់វិធានរើសអើង និងការអនុវត្តន៍ណា ដែលធ្វើអោយប៉ះពាល់ដល់លទ្ធកម្ម ដែលមានលក្ខណៈបើកចំហ
- ☐ ការពង្រីកវិសាលភាពនៃផលិតផលក្នុងកិច្ចព្រមព្រៀង និង
- ☐ ការបង្កើនសមាជិកភាពនៃកិច្ចព្រមព្រៀង

ប្រទេសដែលបានចូលរួម មានបំណងបញ្ចប់ការចរចា យ៉ាងហោចណាស់ ទៅលើចំណុចទីមួយ (ការសំរួល និងការកែលំអកិច្ចព្រមព្រៀង) ក្នុងឆ្នាំ ១៩៩៩ មុនកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីលើកទី ៣ ។

កិច្ចព្រមព្រៀងបណ្ដោះអាសន្នស្ដីពីលទ្ធកម្មសាធារណៈរបស់រដ្ឋាភិបាល

ដូចបានបញ្ជាក់រួចមកហើយថា មានប្រទេសកំពុងអភិវឌ្ឍតែប៉ុណ្ណោះ ដែលបានក្លាយជាសមាជិកនៃកិច្ចព្រមព្រៀងនេះ។ ហេតុផលមួយ ដែលបណ្ដាលអោយប្រទេសកំពុងអភិវឌ្ឍន៍គិតក្នុងចិត្តថា ការដាក់កំហិតចំពោះគោលការណ៍ប្រព្រឹត្តិកម្មជាតិ និងគោលការណ៍ MFN របស់កិច្ចព្រមព្រៀងនេះ នឹងតំរូវអោយគេត្រូវបំបាត់ចោលនូវការអនុវត្តន៍ជាក់ស្ដែងរបស់គេដែលមាននាពេលបច្ចុប្បន្ន ហើយដែលតាមការអនុវត្តន៍ជាក់ស្ដែងនេះ អ្នកផ្គត់ផ្គង់ក្នុងស្រុក នឹងទទួលបាននូវផលប្រយោជន៍ពីតំលៃអនុគ្រោះនេះ ។ ដើម្បីជំរុញលើកទឹកចិត្តអោយប្រទេសកំពុងអភិវឌ្ឍន៍ត្រៀមខ្លួន ក្នុងការចូលជាសមាជិកនៃកិច្ចព្រមព្រៀងនេះ សន្និសិទថ្នាក់រដ្ឋមន្ត្រី នៅសិង្ហបុរី បានសំរេចបង្កើតក្រុមការងារស្ដីពីតម្លាភាពក្នុងលទ្ធកម្មសាធារណៈរបស់រដ្ឋាភិបាល ដើម្បីពិនិត្យមើលលើការសំរេចនៃការចរចានៅក្នុងកិច្ចព្រមព្រៀងបណ្ដោះអាសន្នស្ដីពីតម្លាភាពនៅក្នុងលទ្ធកម្មសាធារណៈរបស់រដ្ឋាភិបាល ។ កិច្ចព្រមព្រៀងបណ្ដោះអាសន្នស្ដីពីលទ្ធកម្មសាធារណៈរបស់រដ្ឋាភិបាល គឺជាកិច្ចព្រមព្រៀង ដែលមានប្រសិទ្ធិភាពចងភ្ជាប់កាតព្វកិច្ចទៅលើបណ្ដាប្រទេសជាសមាជិកទាំងអស់ ហើយដែលខុសគ្នាពីកិច្ចព្រមព្រៀងស្ដីពីលទ្ធកម្មសាធារណៈរបស់រដ្ឋាភិបាល ។ ក៏ប៉ុន្តែ កិច្ចព្រមព្រៀងនេះ មិនបានកំណត់កាតព្វកិច្ចធំដុំទៅលើការពង្រីកវិសាលភាពនៃប្រព្រឹត្តកម្ម MFN និងប្រព្រឹត្តកម្មជាតិទេ ប៉ុន្តែកិច្ចព្រមព្រៀងនេះនឹងកំណត់ពីបទបញ្ញត្តិតាមនីតិវិធីដើម្បីធ្វើអោយមានតំលាភាពច្រើន នៅក្នុងវិធីដែលភ្នាក់ងារទិញរបស់រដ្ឋាភិបាលបានប្រើប្រាស់ក្នុងលទ្ធកម្មទំនិញ ។ ជំពូក ២៤ បានបង្ហាញ ពីទស្សនៈនៃការជជែកពិភាក្សាក្រុមការងារនាពេលថ្មីៗនេះ ។

ការចរស្ដីពីលទ្ធកម្មសាធារណៈរបស់រដ្ឋាភិបាលតាមបទបញ្ញត្តិនៃ GATS

កិច្ចព្រមព្រៀងស្ដីពីលទ្ធកម្មសាធារណៈរបស់រដ្ឋាភិបាល មាត្រា ១៣:២

មាត្រា១៣: ២ នៃ GATS បានអំពាវនាវអោយមានការចរចាពហុភាគីលើលទ្ធកម្មសាធារណៈរបស់រដ្ឋាភិបាល ក្នុងវិស័យសេវាកម្ម ក្នុងរយៈពេល ២ ឆ្នាំ ចាប់ពីថ្ងៃដែលកិច្ចព្រមព្រៀង WTO បានចូលជាធរមាន ។ ដោយអនុលោមទៅតាមបទបញ្ញាតិនេះ ក្រុមប្រឹក្សាពាណិជ្ជកម្មលើសេវាកម្ម បានបង្កើតក្រុមការងារស្ដីពីវិធាន GATS ដើម្បីរៀបចំការងារសំរាប់ចរចានៅក្នុងវិស័យលទ្ធកម្មសាធារណៈរបស់រដ្ឋាភិបាល ។ (ក្រុមការងារ ត្រូវទទួលខុសត្រូវលើការរៀបចំវិធានស្ដីពីវិធានការការពារបន្ទាន់ និងវិធានការឧបត្ថម្ភធន) ។

ការពាក់ព័ន្ធផ្នែកពាណិជ្ជកម្ម

ចំនួនផលិតផលដែលភ្នាក់ងាររដ្ឋាភិបាលបានទិញ នៅក្នុងប្រទេសជឿនលឿន អាចផ្ដល់អោយដោយសហគ្រាសក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ។ បញ្ជីរាយនាមនៃផលិតផលទាំងនោះ មាននៅក្នុងវណ្ឌ ៤៥ ។

បច្ចុប្បន្ន អ្នកផ្គត់ផ្គង់នៃប្រទេសកំពុងអភិវឌ្ឍន៍ មិនមានលទ្ធភាពដេញថ្លៃ ដោយសារគេមិនបានទទួលព័ត៌មានស្ដីពីការដេញថ្លៃរបស់ភ្នាក់ងារទិញ នៅក្នុងប្រទេសជឿនលឿន ។ ការប្រើប្រាស់ប្រពន្ធ័អេឡិចត្រូនិចដោយភ្នាក់ងារទិញ ដើម្បីដេញថ្លៃ នឹងមានផ្ដល់ជូនតាមប្រពន្ធ័អ៊ីនធឺណែត ។ សកម្មភាពនេះ បានកែលំអយ៉ាងច្រើននូវមធ្យោបាយលើកទឹកចិត្តរបស់សហគ្រាសពាណិជ្ជកម្ម

ជាពិសេសនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ដែលមានលទ្ធភាពអភិវឌ្ឍន៍បរិក្ខារ និងមធ្យោបាយអ៊ិនធ័រណែត ឆ្ពោះទៅរកទីផ្សារលទ្ធកម្មសាធារណៈរបស់រដ្ឋាភិបាលនៅក្នុងប្រទេសផ្សេងទៀត ។ មានសក្ដានុពលយ៉ាងច្រើនផងដែរ សំរាប់ការអភិវឌ្ឍន៍ពាណិជ្ជកម្មតាមតំបន់ នៅក្នុងវិស័យលទ្ធកម្ម ក្នុងចំណោមប្រទេសកំពុងអភិវឌ្ឍន៍ ។

ខណ្ឌ ៤៥

ផលិតផលដែលភ្នាក់ងាររដ្ឋាភិបាលបានទិញ ហើយដែលផលិតផលបែបនេះ អាចផ្គត់ផ្គង់បានដោយសហគ្រាសនៅក្នុងបណ្ដាប្រទេសកំពុងអភិវឌ្ឍន៍

ភាយនកំណ្ដុ និងសំលៀកបំពាក់
ស្បែកជើង
គ្រឿងម៉ាស៊ីនសំរាប់ការិយាល័យ និងបរិក្ខាដំណើរការទិន្នន័យ
គ្រឿងសង្ហារិមការិយាល័យ
បរិក្ខារទូរគមនាគមន៍
ឱសថ
សម្ភារៈពេទ្យ
ម្ហូបអាហារ និងផលិតផលម្ហូបអាហារ
អនាម័យ កំដៅ និងអគ្គិសនី
ទោចក្រយានយន្ត
គ្រឿងយន្តអគ្គិសនី
ក្រដាស ម៉ាស៊ីនបោះពុម្ព និងផលិតផលរោងពុម្ព
កៅស៊ូ និងផលិតផលផ្លាស្ទិច
សំភារៈ និងបរិក្ខាសំរាប់សំអាត

ជំពូក ១៩

ពាណិជ្ជកម្មរដ្ឋ

សេចក្តីសង្ខេប

វិធានរបស់ GATT បានកំណត់នូវកាតព្វកិច្ច ពីរសំខាន់ៗ ចំពោះប្រទេសជាសមាជិក ទាក់ទងដល់សហគ្រាសពាណិជ្ជកម្មរដ្ឋ ។ ទី១ គេតំរូវឱ្យសហគ្រាសទាំងនេះធ្វើសកម្មភាពជំនាញរបស់ខ្លួន ផ្អែកលើមូលដ្ឋាននៃការគិតគូរខាងពាណិជ្ជកម្ម ។ ទី២ ដើម្បីធានាឱ្យមានតម្លាភាពចំពោះផលិតផលនាំចូល និងនាំចេញដោយសហគ្រាសទាំងនោះ គេតំរូវឱ្យប្រទេសជាសមាជិកជូនដំណឹងដល់លេខាធិការដ្ឋាន WTO អំពីសកម្មភាពរបស់សហគ្រាសទាំងនោះ ។

ការយល់ដឹងអំពីការបកស្រាយ មាត្រាទី១៧ របស់ GATT ឆ្នាំ ១៩៩៤ §១

ទោះបីជាមាននិន្នាការកាន់តែកើនឡើងសំដៅទៅរកការធ្វើឯកជនភាវូបនីយកម្មក្តី ក៏ប្រទេសទាំងឡាយ កំពុងកាត់បន្ថយការពឹងផ្អែករបស់ខ្លួនទៅលើការធ្វើពាណិជ្ជកម្មរដ្ឋ តែពាណិជ្ជកម្មរដ្ឋនោះ កំពុងតែបន្តដើរតួយ៉ាងសំខាន់ យ៉ាងហោចណាស់នៅក្នុងប្រទេសមួយចំនួនក្នុងវិស័យនាំចេញ នាំចូលនូវមុខទំនិញខ្លះ ជាពិសេសម្ហូបអាហារ និងផលិតផលម្ហូបអាហារ ព្រមទាំងមុខទំនិញមួយចំនួនទៀត ដែលធ្វើពាណិជ្ជកម្មក្នុងទំហំធំ ។ សហគ្រាសពាណិជ្ជកម្មរដ្ឋត្រូវបានកំណត់និយមន័យយ៉ាងទូលាយដូចខាងក្រោម ។

> សហគ្រាសរដ្ឋាភិបាល និងមិនមែនរដ្ឋាភិបាល រួមមាន ក្រុមប្រឹក្សាភិបាលទីផ្សារដែលមានសិទ្ធិពិសេស ឬ សិទ្ធិផ្តាច់មុខ ឬ អភ័យឯកសិទ្ធិ រួមទាំងអំណាចតាមលក្ខន្តិកៈ ឬ តាមធម្មនុញ្ញក្នុងការអនុវត្តន៍ ដែលតាមរយៈសកម្មភាពនោះ ពួកគេមានឥទ្ធិពល ឆ្លងតាមការទិញ ឬ លក់ទៅលើកំរិត ឬ ទិសដៅនៃការនាំចេញ ឬ នាំចូល ។

ពាណិជ្ជកម្មរដ្ឋ ចាំបាច់ត្រូវតែញែកឱ្យដាច់ពីការធ្វើលទ្ធកម្មសាធារណៈរបស់រដ្ឋាភិបាលដែលបានពិភាក្សារួចមកហើយក្នុងជំពូកខាងលើ (ជំពូក ១៨) ។ នៅក្រោមលទ្ធកម្មសាធារណៈរបស់រដ្ឋាភិបាល ផលិតផលដែលផលិតក្នុងស្រុក ឬ ផលិតផលនាំចូល ត្រូវបានទិញដោយភ្នាក់ងាររដ្ឋាភិបាលសំរាប់ការប្រើប្រាស់ផ្ទាល់ ឬ ការប្រើប្រាស់ទូទៅ ឬ សំរាប់ផលិតកម្មនៃទំនិញ ឬ សេវាកម្មដើម្បីលក់ ។ ក្នុងករណីនៃពាណិជ្ជកម្មរដ្ឋ ការនាំចូលត្រូវបានធ្វើឡើងជាលើម ដើម្បីលក់នៅទីផ្សារក្នុងស្រុក ហើយផលិតផលក្នុងស្រុកបានទិញដើម្បីលក់នៅទីផ្សារក្នុងស្រុកផង និងដើម្បីនាំចេញទៅទីផ្សារបរទេសផង ។

ភាតព្វកិច្ចសំខាន់ៗ

ដើម្បីដំណើរការអាជីវកម្មអោយស្របទៅតាមតំលៃតបស្នងផ្នែកពាណិជ្ជកម្ម

GATT ១៩៩៤ មាត្រា ១៧:១

កាតព្វកិច្ចសំខាន់ដែល GATT កំណត់ទៅលើសហគ្រាសពាណិជ្ជកម្មរដ្ឋ គឺត្រូវអោយសហគ្រាសពាណិជ្ជកម្មរដ្ឋ ធ្វើសកម្មភាពអោយស្របទៅតាមគោលការណ៍ទូទៅនៃប្រព្រឹត្តិកម្មដែលមិនរើសអើង ។ ជាក់ស្តែង កិច្ចព្រមព្រៀងចែងថា កាតព្វកិច្ចនេះអាចសំរេចបានដោយកំណត់អោយ ÷

- ☐ រាល់ការទិញ ឬ លក់អាចធ្វើបាន ដោយអនុលោមទៅតាមតំលៃតបស្នងផ្នែកពាណិជ្ជកម្ម រួមមានតំលៃគុណភាព លទ្ធភាពដែលមាន និងលទ្ធភាពស្វែងរកទីផ្សារបាន ការដឹកជញ្ជូន និងល័ក្ខខ័ណ្ឌនៃការទិញ ឬ លក់ផ្សេងៗទៀត ។

- ☐ ដោយការផ្តល់កាលានុវត្តន៍ភាពគ្រប់គ្រាន់ទៅអោយសហគ្រាសនៅក្នុងបណ្តាប្រទេសផ្សេងៗទៀត " ដើម្បីធ្វើការប្រកួតប្រជែងចូលរួមនៅក្នុងការទិញ និងលក់នោះ " ។

តំលាភាព

កាតព្វកិច្ចសំខាន់ផ្សេងទៀតនៃកិច្ចព្រមព្រៀងនេះ គឺតំលាភាព ។ កាតព្វកិច្ចដែល GATT បានកំណត់ក្នុងការជូនដំណឹងនេះ ត្រូវបានពង្រឹងថែមទៀត ដោយការអនុម័តការយោគយល់មួយស្តីពីការបកស្រាយនូវមាត្រាទី ១៧ នៃ កិច្ចព្រមព្រៀង GATT ឆ្នាំ១៩៩៤ (អំពីពាណិជ្ជកម្មរដ្ឋ) នៅឯកិច្ចប្រជុំ URUGUAY។ ការយោគយល់នេះ តំរូវឱ្យប្រទេសជាសមាជិកធ្វើសេចក្តីជូនដំណឹងដល់ក្រុមប្រឹក្សាពាណិជ្ជកម្មលើទំនិញអំពី ÷

- ☐ សហគ្រាសរដ្ឋដែលពាក់ព័ន្ធក្នុងវិស័យពាណិជ្ជកម្មក្រៅប្រទេស ។
- ☐ ផលិតផលដែលសហគ្រាសនោះនាំចេញ ឬ នាំចូល និង
- ☐ ពត៌មានផ្សេងទៀត (ដែលផ្តល់ជាចំឡើយចំពោះសំនួរ) ដែលអាចផ្តល់លទ្ធភាពអោយមានការវាយតំលៃច្បាស់លាស់អំពីបែបផែនដែលសហគ្រាសទាំងនោះធ្វើសកម្មភាពពាណិជ្ជកម្មរបស់ខ្លួន ។

ការយល់ដឹងពី មាត្រា ១៧ វាក្យខ័ណ្ឌ ៤

មាត្រានេះក៏លើកចំហអោយប្រទេសមួយ ធ្វើការជូនដំណឹងតបវិញចំពោះក្រុមប្រឹក្សាពាណិជ្ជកម្មលើទំនិញ នៅពេលដែលប្រទេសនោះយល់ឃើញថា សហគ្រាសពាណិជ្ជកម្មរដ្ឋមួយ នៅប្រទេសមួយទៀត មិនទាន់បានបំពេញកាតព្វកិច្ចជូនដំណឹងរបស់ខ្លួន ដែលទាក់ទងដល់សកម្មភាពពាណិជ្ជកម្មរដ្ឋនៅឡើយ ។

ការយល់ដឹងពី មាត្រា ១៧ វាក្យខ័ណ្ឌ ៥

ការទទួលខុសត្រូវក្នុងការពិនិត្យឡើងវិញនូវសេចក្តីជូនដំណឹង និងសេចក្តីជូនដំណឹងតបវិញ ដែលធ្វើឡើងដោយប្រទេសជាសមាជិក គឺជាភារៈរបស់ក្រុមការងារអំពីសហគ្រាសពាណិជ្ជកម្មរដ្ឋ ដែលបានបង្កើតឡើងយោងតាមប្រការទាំងឡាយនៃការយោគយល់គ្នា។ ក្នុងឆ្នាំ ១៩៩៧ និង ១៩៩៨ ក្រុមការងារបានពិនិត្យឡើងវិញ នូវសំណួរស្ទាបស្ទង់អំពីពាណិជ្ជកម្មរដ្ឋ ដែលត្រូវបានប្រើប្រាស់ដោយប្រទេសជាសមាជិក ដើម្បីបំពេញកាតព្វកិច្ចនៃការជូនដំណឹងរបស់គេ ហើយបានធ្វើឱ្យមានការរីកចំរើនគួរឱ្យកត់សំគាល់ ក្នុងការបង្កើតនូវបញ្ជីមួយ បង្ហាញពីសកម្មភាពរបស់សហគ្រាសពាណិជ្ជកម្មរដ្ឋ និងប្រភេទនៃទំនាក់ទំនង ដែលកើតឡើងរវាងសហគ្រាសទាំងនេះ និងរដ្ឋាភិបាលរបស់ខ្លួន ។ សំនួរស្ទាបស្ទង់ដែលបានកែប្រែឡើងវិញ ត្រូវបានអនុម័តដោយក្រុមប្រឹក្សាពាណិជ្ជកម្មលើទំនិញ ហើយនឹងផ្តល់នូវមូលដ្ឋានមួយសំរាប់ការផ្តល់ពត៌មានដល់ប្រទេសជាសមាជិក អំពីការអនុវត្តន៍ពាណិជ្ជកម្មរបស់រដ្ឋខ្លួន ។

ការពាក់ព័ន្ធផ្នែកពាណិជ្ជកម្ម

ពត៌មានស្តីពីផលិតផលនាំចូល និងនាំចេញ ដោយអង្គការពាណិជ្ជកម្មរដ្ឋ និងស្តីពីការអនុវត្តន៍ដែលសហគ្រាសទាំងនោះបានធ្វើក្នុងការទិញ ត្រូវបានរំពឹងថានឹងអាចជួយអោយសហគ្រាសពាណិជ្ជកម្មឯកជនចូលរួមផ្លាស់ប្តូរពាណិជ្ជកម្មជាមួយនឹងអង្គការទាំងនោះបាន ។

ផ្នែកទីប្រាំ

ពាណិជ្ជកម្មពាក់ព័ន្ធ នឹងច្បាប់សិទ្ធិបញ្ញា

ជំពូក ២០

កិច្ចព្រមព្រៀងស្តីអំពីទិដ្ឋភាពពាណិជ្ជកម្មដែលទាក់ទងនឹងកម្មសិទ្ធិបញ្ញា

សេចក្តីសង្ខេប

ការអភិវឌ្ឍន៍ពាណិជ្ជកម្មអន្តរជាតិ អាចទទួលរងនូវផលប៉ះពាល់បញ្ច្រាសមកវិញ ប្រសិនបើស្តង់ដារដែលអនុម័តដោយប្រទេសទាំងឡាយក្នុងការការពារកម្មសិទ្ធិបញ្ញា មានភាពខុសគ្នាពីប្រទេសមួយទៅប្រទេសមួយ ។ ជាងនេះទៅទៀត ភាពអសកម្ម ឬ អប្រសិទ្ធិភាពនៃការពង្រឹងកម្មសិទ្ធិនេះ អាចនឹងលើកទឹកចិត្តដល់ការធ្វើពាណិជ្ជកម្មទំនិញក្លែងក្លាយ និងទំនិញថតចំលងពុំស្របច្បាប់ ដែលធ្វើឲ្យប៉ះពាល់ដល់ផលប្រយោជន៍ពាណិជ្ជកម្មស្របច្បាប់ របស់ផលិតករដែលមានសិទ្ធិ ឬ បានទទួលសិទ្ធិទាំងអស់នេះ ។ កិច្ចព្រមព្រៀងស្តីអំពីទិដ្ឋភាពពាណិជ្ជកម្មដែលទាក់ទងនឹងកម្មសិទ្ធិបញ្ញា ដែលបានចរចានៅក្នុងកិច្ចប្រជុំឧរុយហ្គាយ បានដាក់ចេញនូវស្តង់ដារអប្បបរមាសំរាប់ការការពារកម្មសិទ្ធិបញ្ញា ក៏ដូចជាដាក់ចេញនូវនីតិវិធី និងដំណោះស្រាយសំរាប់ពង្រឹងសិទ្ធិនេះផងដែរ។ កិច្ចព្រមព្រៀងនេះ បង្កើតនូវយន្តការមួយសំរាប់ពិគ្រោះយោបល់ និងត្រួតពិនិត្យនៅថ្នាក់អន្តរជាតិ ដើម្បីធានាភាពស្របគ្នាទៅនឹងស្តង់ដារដែលត្រូវអនុវត្តដោយបណ្តាប្រទេសដែលជាសមាជិកនៅថ្នាក់ជាតិ ។

រចនាសម្ព័ន្ធនៃកិច្ចព្រមព្រៀង ត្រូវបានកសាងឡើងលើមូលដ្ឋានអនុសញ្ញាអន្តរជាតិពាក់ព័ន្ធនឹងកម្មសិទ្ធិបញ្ញា ដែលមានជាធរមាន។ បទបញ្ញត្តិទាំងឡាយរបស់កិច្ចព្រមព្រៀងនេះ ត្រូវអនុវត្តចំពោះកម្មសិទ្ធិបញ្ញា ដូចតទៅ ÷

- ☐ ***ប្រកាសនីយបត្រតក្កកម្ម***
- ☐ ***សិទ្ធិចំលង និងសិទ្ធិពាក់ព័ន្ធ***
- ☐ ***ពាណិជ្ជសញ្ញា***
- ☐ ***គំនូរឧស្សាហកម្ម***
- ☐ ***គំនូសបំព្រាង សៀគ្វីប្រមូលផ្តុំ***
- ☐ ***ពត៌មានសម្ងាត់ និង***
- ☐ ***ការចង្អុលបង្ហាញលក្ខណៈភូមិសាស្ត្រ***

ដើម្បីធានាថា ម្ចាស់កម្មសិទ្ធិបញ្ញាមិនបានបំពានក្នុងការប្រើប្រាស់សិទ្ធិផ្តាច់មុខរបស់ខ្លួន ។ សិទ្ធិទាំងនេះ ត្រូវស្ថិតជាកម្មវត្ថុនៃព្រំខណ្ឌកំណត់ និងការលើកលែងមួយចំនួន ។ ប្រការទាំងនេះសំដៅធានានូវតុល្យភាពរវាងផលប្រយោជន៍ស្របច្បាប់របស់ម្ចាស់កម្មសិទ្ធិ និងអ្នកប្រើប្រាស់កម្មសិទ្ធិបញ្ញា ។

កិច្ចព្រមព្រៀងក៏បានដាក់ចេញផងដែរ នូវនីតិវិធីសំរាប់ការពិគ្រោះយោបល់រវាងរដ្ឋាភិបាល នៅពេលដែលភាគីម្ខាងមានហេតុផលនឹងជឿជាក់ថា ការអនុវត្តន៍អាជ្ញាប័ណ្ណ ឬ លក្ខខណ្ឌរបស់សហគ្រាសមួយនៃប្រទេសជាសមាជិកមួយទៀត បានរំលោភលើកិច្ចព្រមព្រៀង ឬ មានផលប៉ះពាល់ជាអវិជ្ជមានចំពោះការប្រកួតប្រជែង ។

កិច្ចព្រមព្រៀងបានផ្តល់នូវរយៈពេលអន្តរកាលចំនួន ៥ ឆ្នាំ (គឺរហូតដល់ថ្ងៃទី ១ ខែ មករា ឆ្នាំ ២០០០) សំរាប់ប្រទេសកំពុងអភិវឌ្ឍន៏ ដើម្បីធ្វើឱ្យច្បាប់កម្មសិទ្ធិបញ្ញារបស់ប្រទេសទាំងនោះ ដំណើរការស្របទៅនឹងបទបញ្ញត្តិទាំងឡាយនៃកិច្ចព្រមព្រៀង។ ចំពោះប្រទេសក្រីក្រ រយៈពេលអន្តរកាលកំណត់ត្រឹម ១១ ឆ្នាំ (គឺរហូតដល់ថ្ងៃទី ១ ខែ មករា ឆ្នាំ ២០០៦) ។

បច្ចុប្បន្ន កំពុងមានការពិនិត្យឡើងវិញលើបទបញ្ញត្តិទាំងឡាយនៃកិច្ចព្រមព្រៀងស្តីអំពីការច្នៃប្រឌិតលើផលដំណាំ និងពូជដាផ្សេងៗ ដើម្បីឱ្យសមស្របនឹងបញ្ញត្តិនានាដែលពាក់ព័ន្ធ ។ កិច្ចព្រមព្រៀងក៏បានចែងផងដែរ ពីការពិនិត្យឡើងវិញលើបទបញ្ញត្តិទាំងអស់នៃកិច្ចព្រមព្រៀងនេះ ក្រោយរយៈពេល ៥ ឆ្នាំ ដូចជានៅក្នុងឆ្នាំ ២០០០ ជាដើម ។

កម្មសិទ្ធិបញ្ញា និងការពាក់ព័ន្ធរបស់កម្មសិទ្ធិនេះ ចំពោះពាណិជ្ជកម្មអន្តរជាតិ

កម្មវត្ថុនៃកម្មសិទ្ធិបញ្ញា គឺការបង្កើតឡើងដោយគំនិតមនុស្ស បញ្ញាញាណរបស់មនុស្ស ហេតុនេះហើយទើបគេសន្មត ហៅថាជា "កម្មសិទ្ធិបញ្ញា" ។

កម្មសិទ្ធិទាំងនេះរួមមាន សិទ្ធិចំលង ប្រកាសនីយប័ត្រតក្កកម្ម និងគំនូរឧស្សាហកម្ម ។ សិទ្ធិចំលងទាក់ទងដល់សិទ្ធិរបស់អ្នកបង្កើតស្នាដៃអក្សរសាស្ត្រ វិទ្យាសាស្ត្រ និងស្នាដៃសិល្បៈ ។ ប្រកាសនីយប័ត្រតក្កកម្ម ផ្តល់សិទ្ធិផ្តាច់មុខដល់អ្នកច្នៃប្រឌិត ប៉ុន្តែទោះជាយ៉ាងនេះក្តី ការច្នៃប្រឌិតទាំងឡាយណា ដែលអាចទទួលនូវសិទ្ធិប្រកាសនីយប័ត្រតក្កកម្មបាន លុះត្រាតែការច្នៃប្រឌិតទាំងនោះជាការច្នៃប្រឌិតថ្មី មិនជាក់ស្តែងពេក និងអាចយកទៅប្រើប្រាស់ក្នុងវិស័យឧស្សាហកម្មបាន ។ គំនូរឧស្សាហកម្មគឺជាការច្នៃប្រឌិតមានលក្ខណៈសិល្បៈដើម ឬថ្មី ដែលកំណត់នូវរូបរាងខាងក្រៅរបស់ផលិតផលឧស្សាហកម្ម ។ សិទ្ធិទាំង ៣ នេះ ត្រូវបានផ្តល់ឱ្យសំរាប់រយៈពេលកំណត់មួយ ។

កម្មសិទ្ធិបញ្ញាក៏រួមបញ្ចូលផងដែរនូវពាណិជ្ជសញ្ញា សេវាសញ្ញា និងលក្ខណៈបង្ហាញប្រភពដើម (ឬហៅថា ការចង្អុលបង្ហាញលក្ខណៈភូមិសាស្ត្រ) ។ ក្នុងករណីនៃកម្មសិទ្ធិទាំងនេះ ទិដ្ឋភាពនៃការបង្កើតថ្មីរបស់បញ្ញា ទោះជាមានអត្ថិភាពក្តី ក៏ប៉ុន្តែពុំសូវលេចធ្លោទេ ។ ទោះជាយ៉ាងនេះក៏ដោយ ការការពារត្រូវបានគេផ្តល់ឱ្យចំពោះពាណិជ្ជសញ្ញា និងសញ្ញាដទៃទៀត ដើម្បីឱ្យផលិតករអាចញែកដាច់ផលិតផល ឬ សេវារបស់គេ ពីផលិតផល ឬ សេវាកម្មរបស់អ្នកដទៃទៀត ។ ពាណិជ្ជសញ្ញា ក៏ជួយឱ្យផលិតករអាចកសាងបាននូវ ទំនុកចិត្តរបស់អ្នកប្រើប្រាស់ ។ ពាណិជ្ជសញ្ញា ក៏ជួយផងដែរ ដល់អ្នកប្រើប្រាស់ ក្នុងការផ្តល់នូវជំរើសលើមូលដ្ឋានពត៌មាន ដែលផ្តល់ឱ្យដោយផលិតករ ស្តីពីគុណភាពផលិតផលរបស់ខ្លួន ។

ការពាក់ព័ន្ធនៃកម្មសិទ្ធិបញ្ញាចំពោះពាណិជ្ជកម្ម

ការប្រើប្រាស់ទាំងឡាយណានៃកម្មសិទ្ធិបញ្ញាដែលពុំបានទទួលការអនុញ្ញាតនឹងបង្កើតបានជាការបំពានសិទ្ធិរបស់កម្មសិទ្ធិករ ។ រហូតមកទល់នឹងប្រហែលជា ២ ទសវត្សកន្លងទៅនេះ ការបំពានរបៀបនេះ បានបង្កើតជាផលប៉ះពាល់យ៉ាងធំធេងដល់វិស័យពាណិជ្ជកម្មក្នុងស្រុក ។ ជាងនេះទៅទៀត បញ្ហាទាំងឡាយដែលការបំពាននេះបានបង្កើតឡើង ត្រូវបានចាត់ទុកថាជាបញ្ហាចំបងនៅកំរិតជាតិ ដែលក្រៅអំពីការប៉ះពាល់ដល់ផលប្រយោជន៏របស់ម្ចាស់កម្មសិទ្ធិ ក៏បានរាំងស្ទះដល់ការរីកចំរើនផ្នែកវិទ្យាសាស្ត្រ និងជីវភាពវប្បធម៌ផងដែរ ។

នៅក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ ទោះជាមានការយល់ដឹងកាន់តែកើនឡើងអំពីស្តង់ដារទាំងឡាយ ដែលអនុម័តដោយប្រទេសជាច្រើនក្នុងការការពារកម្មសិទ្ធិបញ្ញា ក៏ដូចជាប្រសិទ្ធិភាពនៃការការពារដែលប្រទេសទាំងនោះបានធ្វើឡើងថា មានផលប៉ះពាល់ដល់ការអភិវឌ្ឍន៏ពាណិជ្ជកម្មអន្តរជាតិ ។ នៅមានហេតុផលជាច្រើនទៀតសំរាប់លើកឡើងនូវប្រការនេះ ដែលគួរកត់កត់សំគាល់ជាពិសេសទៅលើហេតុផល ៣ យ៉ាង ។

ហេតុផលទី ១ គឺ សកម្មភាពសេដ្ឋកិច្ចនៅក្នុងប្រទេសជឿនលឿនជាច្រើន កំពុងតែវិវត្តន៏ទៅជាសកម្មភាពស្រាវជ្រាវ និងជំរុញបច្ចេកវិទ្យា ។ ជាលទ្ធផល ផលិតផលនាំចេញរបស់ប្រទេសទាំងនោះ ទាំងផលិតផលប្រពៃណី (ដូចជា ជាតិគីមី ជី និង

ផលិតផលឱសថ) និងផលិតផលថ្មី (ដូចជាឧបករណ៍ទូរគមនាគមន៍ កុំព្យូទ័រ និងថាសទន់របស់កុំព្យូទ័រជាដើម) បច្ចុប្បន្ននេះមានរួមបញ្ចូលបច្ចេកវិទ្យា និងការច្នៃប្រឌិតជាច្រើន ដែលជាកម្មវត្ថុរបស់កម្មសិទ្ធិបញ្ញា ។ កម្មន្តសាលករ បានយកចិត្តទុកដាក់ដើម្បីធានាអោយមានការគោរពការពារកម្មសិទ្ធិបញ្ញាទាំងនេះបានយ៉ាងពេញលេញ ទោះជានៅទីណាដែលគេលក់ផលិតផលរបស់គេក៏ដោយ ដែលហេតុនេះហើយធ្វើឱ្យពួកគេអាចទទួលបានមកវិញនូវចំណាយសំរាប់ការស្រាវជ្រាវ និងការអភិវឌ្ឍន៍របស់ពួកគេ។

ហេតុផលទី ២ គឺការដកចេញនូវការដាក់កំហិតចំពោះការវិនិយោគបរទេស ដែលធ្វើឡើងដោយប្រទេសកំពុងអភិវឌ្ឍន៍មួយចំនួនធំ បានផ្តល់នូវកាលានុវត្តន៍ថ្មីៗ ដែលកំពុងលេចឡើងសំរាប់ការផលិតនៅក្នុងប្រទេសទាំងនោះ នូវផលិតផលដែលបានចុះប្រកាសនីយប័ត្រតក្កកម្មរួចហើយ តាមអាជ្ញាប័ណ្ណ តាមរយៈអាជីវកម្មរួម ។ គោលបំណងនៃឧស្សាហកម្ម ក្នុងបណ្តាប្រទេសឧស្សាហកម្មជឿនលឿន គឺធ្វើការរៀបចំរបៀបនេះ និងធ្វើឱ្យបច្ចេកវិទ្យារបស់គេមានភាពសំបូរបែប តែទោះជាយ៉ាងនេះក្តី គេចាំបាច់ត្រូវពឹងទៅលើប្រព័ន្ធការពារកម្មសិទ្ធិបញ្ញា ដែលអាចនឹងទៅមុខបានដល់កំរិតណានៅក្នុងប្រទេសជាម្ចាស់ផ្ទះដែលត្រូវផ្តល់ឱ្យគេនូវការធានាថាកម្មសិទ្ធិរបស់ពួកគេលើផ្នែកបច្ចេកវិទ្យា នឹងត្រូវបានការពារពេញលេញ ហើយនឹងមិនត្រូវបំពានដោយដៃគូក្នុងស្រុកដែលនឹងប្រើប្រាស់បច្ចេកវិទ្យានេះ ក្នុងវិស័យវិស្វកម្ម ដែលមានទិសដៅបញ្ច្រាសមកវិញ ។

ហេតុផលទី ៣ គឺ ការកែលំអរបច្ចេកវិទ្យាចំពោះផលិតផល ដែលត្រូវចូលទៅក្នុងទីផ្សារអន្តរជាតិ ដែលចាំបាច់ត្រូវមានបច្ចេកវិទ្យាជឿនលឿន ដែលអាចនឹងត្រូវបានគេផលិតឡើងវិញ និងត្រាប់តាមយ៉ាងងាយៗប្រកបដោយតំលៃថោក ។ នៅក្នុងបណ្តាប្រទេសដែលមិនទាន់បានពង្រឹងច្បាប់ស្តីពីកម្មសិទ្ធិបញ្ញាអោយបានតឹងរ៉ឹងនៅឡើយ គេសង្កេតឃើញមានលទ្ធផលដូចបង្ហាញជូនក្នុងវណ្ឌ ៤៦ នូវការកើនឡើងនៃផលិតកម្មទំនិញក្លែងក្លាយ និងទំនិញថតចំលងពុំស្របច្បាប់ ដែលពុំគ្រាន់តែដើម្បីលក់នៅទីផ្សារក្នុងស្រុកប៉ុណ្ណោះទេ ថែមទាំងដើម្បីនាំចេញផងដែរ ។

ខណ្ឌ ៤៦

ពាណិជ្ជកម្មទំនិញក្លែងក្លាយ និងទំនិញថតចំលងពុំស្របច្បាប់

ការប៉ាន់ប្រមាណនូវចំណូល ដែលបាត់បង់ដោយផ្នែកឧស្សាហកម្មដោយសារទំនិញក្លែងក្លាយ និងទំនិញថតចំលងពុំស្របច្បាប់ ព្រមទាំងការបំពានកម្មសិទ្ធិបញ្ញាផ្សេងៗទៀត មានភាពខុសគ្នាយ៉ាងខ្លាំង ប៉ុន្តែជាក់ស្តែងគឺ ការខាតបង់ទាំងនោះមានតំលៃធំធេងគួរឱ្យកត់សំគាល់ ។

ទំនិញដែលចាត់ទុកថាជាទំនិញក្លែងក្លាយ គឺនៅពេលដែលទំនិញទាំងនោះ ត្រូវបានគេដាក់លក់ក្រោមពាណិជ្ជសញ្ញាល្បីឈ្មោះ ដែលអ្នកលក់ពុំបានទទួលសិទ្ធិប្រើប្រាស់ពាណិជ្ជសញ្ញានោះទេ ។ ទំនិញទាំងនេះ ជាទូទៅ គឺជាផលិតផលដែលប្រើប្រាស់ពលកម្មច្រើន ហើយដោយសារតែកេរ្តិ៍ឈ្មោះនៃម៉ាករបស់វា ធ្វើឱ្យគេអាចលក់ក្នុងតំលៃខ្ពស់បាន ។ ទំនិញទាំងនោះរួមមាន សំលៀកបំពាក់ ស្បែកជើង នាឡិកាដៃ គ្រឿងសំអាង ទំនិញធ្វើពីស្បែក និងទំនិញប្រើប្រាស់ក្នុងផ្ទះ ព្រមទាំងសំភារៈកីឡា។

ទំនិញថតចំលងពុំស្របច្បាប់ គឺទំនិញទាំងឡាយណាដែលបំពានសិទ្ធិចំលង និងសិទ្ធិពាក់ព័ន្ធ ។ អ្នកបោះពុម្ពផ្សាយសៀវភៅ ផលិតករ ថតថាស ថតភាពយន្ត ថតខ្សែអាត់ កាសែត ជាបឿយៗ គឺជាជនរងគ្រោះនៃការរំលោភសិទ្ធិចំលង និងសិទ្ធិពាក់ព័ន្ធ ។ ការរីកចំរើននៃបច្ចេកវិទ្យាបានសំរួលយ៉ាងច្រើនដល់សិល្បៈនៃការថតចំលង ។ ឧស្សាហកម្មកម្មវិធីកុំព្យូទ័រគឺជាអ្នករងគ្រោះមុនគេ ដោយសារល្បឿនដែលកម្មសិទ្ធិបញ្ញាអាចបានត្រូវគេថតចំលងពុំស្របច្បាប់ ហើយចែកចាយក្នុងកំរិតអន្តរជាតិ ។

អនុសញ្ញារបស់អង្គការកម្មសិទ្ធិបញ្ញាអន្តរជាតិស្តីអំពីកម្មសិទ្ធិបញ្ញា

កិច្ចប្រឹងប្រែងបង្កើតប្រពន្ធ័ច្បាប់ ដើម្បីផ្តល់នូវការការពារអោយបានសមស្រប ចំពោះកម្មសិទ្ធិបញ្ញាក្នុងកំរិតអន្តរជាតិ ត្រូវបានធ្វើឡើងអស់រយៈពេលជាងមួយសតវត្សមកហើយ ដែលផ្នែកសំខាន់នៃកិច្ចការនេះ ប្រព្រឹត្តិទៅក្រោមការដឹកនាំរបស់អង្គការកម្មសិទ្ធិបញ្ញាអន្តរជាតិ (WIPO) និងបណ្តាអង្គការដែលជាបុព្វាធិការរបស់អង្គការនេះ។ ជាលទ្ធផល មានការអនុម័តអនុសញ្ញាមួយចំនួនដែលកំនត់កាតព្វកិច្ចជាអន្តរជាតិ ក្នុងការការពារសិទ្ធិរបស់ម្ចាស់កម្មសិទ្ធបញ្ញា ។ វណ្ឌ ៤៧ នឹងរៀបជាលំដាប់នូវអនុសញ្ញាទាំងនេះព្រមទាំងបង្ហាញនូវវិសាលភាព និងវិស័យចំបង ដែលកិច្ចព្រមព្រៀងទាំងនោះត្រូវយកមកអនុវត្ត ។

ប្រវត្តិនៃការចរចាក្នុងកិច្ចប្រជុំយូរ៉ូហ្គាយស្តីពីកម្មសិទ្ធិបញ្ញា

មានសំណូមពរជាច្រើន ដែលបានលើកឡើងស្នើសុំអោយមានការចាត់សកម្មភាពណាមួយតាមកិច្ចព្រមព្រៀង GATT ដើម្បីគ្រប់គ្រងការធ្វើពាណិជ្ជកម្មទំនិញក្លែងក្លាយ និងទំនិញថតចំលងខុសច្បាប់ ហើយសំណូមពរនេះ ត្រូវបានលើកឡើងដោយបណ្តាប្រទេសជឿនលឿនមួយចំនួនតាំងពីការចាប់ផ្តើមកិច្ចចរចានៅក្នុងកិច្ចប្រជុំទីក្រុងតូក្យូម្លេះ ។ នៅពេលចាប់ផ្តើមកិច្ចប្រជុំយូរ៉ូហ្គាយ ប្រទេសទាំងនេះបានស្នើថា កិច្ចចរចាមិនគួរពិភាក្សាត្រឹមតែការធ្វើពាណិជ្ជកម្មទំនិញក្លែងក្លាយ និងទំនិញថតចំលងខុសច្បាប់ប៉ុណ្ណោះទេ ប៉ុន្តែត្រូវកំណត់ស្តង់ដារអប្បបរមានៃការការពារសិទ្ធិទាំងនោះ សំរាប់អោយបណ្តាប្រទេសជាសមាជិកធ្វើការអនុមតិផងដែរ។ នៅពេលដែលប្រទេសកំពុងអភិវឌ្ឍន៍ ជាទូទៅពុំមានជំទាស់អ្វីទៅនឹងវិធានការចំពោះទំនិញក្លែងក្លាយ ប្រទេសទាំងនោះក៏ផ្តើមជំទាស់ចំពោះការពិភាក្សាស្តីពីស្តង់ដារអប្បបរមាផងដែរ ។ ប្រទេសទាំងនោះយល់ឃើញថា ការចរចាបែបនេះនឹងតំរូវអោយពួកគេចាំបាច់ត្រូវផ្លាស់ប្តូរគោលនយោបាយនៃប្រទេសរបស់ខ្លួន ។ ដើម្បីអោយមានការអភិវឌ្ឍន៍ និងដោយហេតុផលសង្គម គោលនយោបាយទាំងនេះបានផាត់ចេញនូវផលិតផលមួយចំនួន ពីការផ្តល់ប្រកាសសនីយបត្រ័តក្កកម្ម ឬ ផ្តល់នៅរយៈពេលការពារតិចជាង ២០ឆ្នាំ ចំពោះការការពារប្រកាសសនីយបត្រ័តក្កកម្ម ដែលជាទូទៅត្រូវបានផ្តល់អោយដោយប្រទេសជឿនលឿនក្នុងរយៈពេលនេះ ចំពោះការច្នៃប្រឌិតទាំងឡាយណាដែលទាក់ទងទៅនឹងផលិតផល ដូចជា ផលិតផលឱសថ គីមី ជី ថ្នាំសំលាប់សត្វល្អិត និងថ្នាំការពារពីសត្វល្អិតបង្កើតជំងឺផ្សេងៗ ។ ប្រទេសទាំងនោះក៏មានការភ័យខ្លាចផងដែរថា ការអនុម័តនូវស្តង់ដារអប្បបរមានឹងនាំមកនូវការបង្កើនប្រាក់ចំណាយ សួយសារអាករ (Royalty Payment) សំរាប់ការប្រើបច្ចេកវិទ្យាដែលបានចុះប្រកាសសនីយបត្រ័តក្កកម្មរួចហើយក្រោមរូបភាព អាជ្ញាបណ្ណ័ ហើយនឹងនាំអោយមានការបង្កើនថ្លៃខ្ពស់ចំពោះផលិតផល ដែលផលិតដោយបច្ចេកវិទ្យាទាំងនោះ។

ទោះជាយ៉ាងនេះក្តី ទស្សនៈទាំងនេះមិនអាចនៅថិតថេរបានទេ ហើយដោយសារមានសម្ពាធពីប្រទេសជឿនលឿនទាំងឡាយនោះទើបមានការចរចា ដែលប្រមូលផ្តុំក្នុងវិសាលភាពធំមួយស្តីពីការបង្កើតនូវស្តង់ដារទាំងឡាយជាចំបង និងឯកភាពគ្នា ដោយផ្តល់នូវការការពារកម្មសិទ្ធិបញ្ញាក្នុងកំរិតខ្ពស់ជាងនេះ ។ គេគួរធ្វើការកត់សំគាល់សំខាន់មួយក្នុងបរិបទនេះ ដែលឥរិយាបទរបស់ប្រទេសកំពុងអភិវឌ្ឍន៍ និងប្រទេសជឿនលឿនបានប្រែប្រួលក្នុងខណៈដែលកិច្ចចរចាកំពុងឈានទៅមុខ ។ នេះជាលទ្ធភាពមួយដែលធ្វើអោយប្រទេសទាំងនោះអាចឈានទៅដល់ការព្រមព្រៀងគ្នាអំពីកិច្ចព្រមព្រៀង (TRIPS) នៅក្នុងកិច្ចព្រមព្រៀងនេះបានកំណត់នូវស្តង់ដារអប្បបរមាសំរាប់ការពារគ្រប់ជំពូកកម្មសិទ្ធិបញ្ញាសំខាន់ៗទាំងអស់ ។

ខណ្ឌ ៤៧

កម្មសិទ្ធិបញ្ញា: ឧបករណ៍សំរាប់ការពារ កម្មវត្ថុនៃការការពារ វិស័យនៃការអនុវត្តន៍ និងការពាក់ពន្ធ័ទៅនឹងអង្គការកម្មសិទ្ធិបញ្ញាអន្តរជាតិ និងកិច្ចព្រមព្រៀងអន្តរជាតិដទៃទៀត

ប្រភេទនៃកម្មសិទ្ធិបញ្ញា		កម្មវត្ថុនៃការការពារ	វិស័យសំខាន់ៗនៃការអនុវត្តន៍	កិច្ចព្រមព្រៀងអន្តរជាតិសំខាន់ៗ
ប្រភេទនៃឧបករណ៍សំរាប់ការពារ				
កម្មសិទ្ធិឧស្សាហកម្ម	ប្រកាសនីយប័ត្រតក្កកម្ម	ថ្មី មិនអាចយល់បានដោយមនុស្សធម្មតា មានជំហាន	ឧស្សាហកម្មផលិត	អនុសញ្ញាទីក្រុងប៉ារីស សន្ធិសញ្ញាសហប្រតិបត្តិការ

		ថ្លៃប្រឌិត ដែលអាចអនុវត្តបានលើផ្នែកឧស្សាហកម្ម		ប្រកាសនីយប័ត្រតក្កកម្ម សន្ធិសញ្ញា ទីក្រុងប៊ុយដាប៉េស្ត
	គំរូដែលមានអត្ថប្រយោជន៍	គំរូដែលអាចយកទៅប្រើការបាន	ឧស្សាហកម្មផលិត	អនុសញ្ញាទីក្រុងប៉ារីស
	គំនូសបំព្រាងឧស្សាហកម្ម	គំនូសបំព្រាងដែលមានលក្ខណៈជាការតុបតែងលំអ	សំលៀកបំពាក់ រថយន្ត និងគ្រឿងអេឡិចត្រូនិច ។ ល ។	កិច្ចព្រមព្រៀងទីក្រុងឡាអេ អនុសញ្ញាទីក្រុងប៉ារីស កិច្ចព្រមព្រៀងទីក្រុងឡូកាណូ
	ពាណិជ្ជសញ្ញា	សញ្ញា ឬ និមិត្តសញ្ញាសំរាប់សំគាល់អោយឃើញលក្ខណៈខុសគ្នានៃទំនិញនិងសេវាកម្ម របស់សហគ្រាសមួយទៅនឹងសហគ្រាសមួយទៀត	គ្រប់ផ្នែកឧស្សាហកម្ម	អនុសញ្ញាទីក្រុងប៉ារីស កិច្ចព្រមព្រៀងទីក្រុងម៉ាឌ្រីត (ការចុះបញ្ជីជាអន្តរជាតិ) កិច្ចព្រមព្រៀងទីក្រុងនីស ពិធីសារទីក្រុងម៉ាឌ្រីត (មិនទាន់ចូលជាធរមាន) សន្ធិសញ្ញាអំពីច្បាប់ពាណិជ្ជសញ្ញា (មិនទាន់ចូលជាធរមាន)
	ការចង្អុលបង្ហាញលក្ខណៈភូមិសាស្ត្រ	ការចង្អុលបង្ហាញទីកន្លែងដែលជាប្រភពរបស់ទំនិញដើម្បីសំគាល់គុណភាព ឬលក្ខណៈសម្បត្តិដទៃទៀតដែលពាក់ព័ន្ធនឹងតំបន់នោះ	កសិកម្ម និងឧស្សាហកម្មចំណីអាហារជាពិសេសផ្នែកដែលទាក់ទងដល់ស្រា និងគ្រឿងមេរយ៉ៃផ្សេងៗ	កិច្ចព្រមព្រៀងទីក្រុងលីសបិន កិច្ចព្រមព្រៀងទីក្រុងម៉ាឌ្រីត អំពីការចង្អុលបង្ហាញដោយ (ក្លែងបន្លំ)
កម្មសិទ្ធិអក្សរសាស្ត្រ និងសិល្បៈ	សិទ្ធិចម្លង និងសិទ្ធិពាក់ពន្ធ័	ស្នាដៃដើមរបស់អ្នកនិពន្ធ និងការចូលរួមដែលពាក់ព័ន្ធពីសំណាក់អ្នកសំដែង ផលិតករថតសំលេង និងបណ្តាអង្គភាពផ្សព្វផ្សាយស្នាដៃ	ការបោះពុម្ព ការកំសាន្ត (សំលេង រូប និងរូបភាពដែលមានចលនា ផ្នែកទន់នៃកុំព្យូទ័រ និងការផ្សព្វផ្សាយ)	អនុសញ្ញាទីក្រុងប៊ឺន អនុសញ្ញា ទីក្រុងរ៉ូម អនុសញ្ញាក្រុងហ្សឺណែវ អនុសញ្ញាទីក្រុងប្រ៊ុយសែល អនុសញ្ញាសិទ្ធិចំលងសកល
ការការពារសិទ្ធិតាមប្រព័ន្ធផ្សេងៗ	សិទ្ធិរបស់អ្នកបង្កាត់ពូជ	ពូជថ្មី មានស្ថេរភាព មានលក្ខណៈតែមួយ និងដាច់ដោយឡែកពីគេ	កសិកម្មនិងឧស្សាហកម្មចំណីអាហារ	សហភាពសំរាប់ការការពារពូជថ្មីៗនៃដំណាំ (UPOV)
	សៀគ្វីបំព្រួញ	គំនូសបំព្រាងដើម	ឧស្សាហកម្មមីក្រូអេឡិចត្រូនិច	សន្ធិសញ្ញាទីក្រុងវ៉ាស៊ីនតោន (មិនទាន់ចូលជាធរមាន)
ការសម្ងាត់ផ្នែកពាណិជ្ជកម្ម		ពត៌មានសម្ងាត់ផ្នែកអាជីវកម្ម	គ្រប់ផ្នែកឧស្សាហកម្ម	

ប្រភព: កាឡូសប្រាហ្គា " ទិដ្ឋភាពពាណិជ្ជកម្មដែលពាក់ព័ន្ធនឹងកម្មសិទ្ធិបញ្ញា : កិច្ចព្រមព្រៀងយូរ៉ុយហ្គាយ និងការពាក់ព័ន្ធរបស់កិច្ចព្រមព្រៀងនេះដល់សេដ្ឋកិច្ច "(ឯកសារសន្និសីទរបស់ធនាគារពិភពលោកថ្ងៃទី ២៦-២៧ មករា ឆ្នាំ ១៩៩៥) ។

កំណត់សំគាល់: លើកលែងតែ UPOV ចេញ សន្ធិសញ្ញាទាំងអស់ដែលបានបង្ហាញជូនខាងលើ សុទ្ធតែត្រូវគ្រប់គ្រងអនុវត្តដោយ WIPO។ សន្ធិសញ្ញាទីក្រុងវ៉ាស៊ីនតោនមិនទាន់ចូលជាធរមាននៅឡើយ ប៉ុន្តែត្រូវបានចរចាក្រោមអធិបតីភាពរបស់ WIPO ផងដែរ ។ អនុសញ្ញាទីក្រុងរ៉ូម ត្រូវបានគ្រប់គ្រងអនុវត្តរួមគ្នាដោយ WIPO, ILO និង UNESCO។ អនុសញ្ញាសិទ្ធិចំលងសកល ត្រូវបានអនុវត្តដោយ UNESCO ។

កិច្ចព្រមព្រៀងស្តីពីទិដ្ឋភាពពាណិជ្ជកម្មដែលពាក់ព័ន្ធនឹងកម្មសិទ្ធិបញ្ញា

របនាសម្ព័ន្ធ

កិច្ចព្រមព្រៀង TRIPS ត្រូវបានកសាងឡើងលើមូលដ្ឋានអនុសញ្ញាអន្តរជាតិសំខាន់ៗស្តីពីកម្មសិទ្ធិបញ្ញា ដោយរួមបញ្ចូល (យោងដល់) ស្ទើរគ្រប់បទបញ្ញត្តិទាំងអស់របស់អនុសញ្ញាទាំងនោះ ។ បទបញ្ញត្តិទាំងនេះ បានចែងឱ្យប្រទេសទាំងឡាយដែលអាចអនុវត្តតាមអនុសញ្ញាទាំងនោះ នូវការធានា ការការពារ ដែលមានកំរិតខ្ពស់ជាងការការពារ ដែលតំរូវដោយកិច្ចព្រមព្រៀង TRIPS ហើយពុំមានបទបញ្ញត្តិណាមួយនៃអនុសញ្ញាទាំងនោះត្រូវបានគេបកស្រាយផ្ទុយពីបទបញ្ញត្តិទាំងឡាយនៃកិច្ចព្រមព្រៀងនេះឡើយ ។

ប្រការសំខាន់ៗនៃកិច្ចព្រមព្រៀងនេះ ត្រូវបានបែងចែកជា ៥ ក្រុមដូចតទៅ ÷

- ☐ គោលការណ៍ជាមូលដ្ឋាន និងកាតព្វកិច្ចជាទូទៅ
- ☐ ស្តង់ដារអប្បបរិមានៃការការពារ ដែលមានវិសាលភាពលើ ÷
  - កម្មវត្ថុនៃការការពារ
  - សិទ្ធិដែលត្រូវទទួលបាន
  - ការលើកលែងដែលត្រូវបានអនុញ្ញាតចំពោះសិទ្ធិទាំងនេះ និង
  - រយៈពេលអប្បបរមានៃការការពារ
- ☐ វិធានការប្រឆាំងតបនឹងការអនុវត្តន៍ការប្រកួតប្រជែងក្នុងការផ្តល់អាជ្ញាប័ណ្ណដែលជាប់កិច្ចសន្យា
- ☐ បែបបទក្នុងស្រុក និងដំណោះស្រាយចំពោះការពង្រឹងការការពារកម្មសិទ្ធិបញ្ញា
- ☐ ការចាត់ចែងក្នុងដំណាក់កាលអន្តរកាលចំពោះការអនុវត្តន៍បញ្ញត្តិច្បាប់នៅថ្នាក់ជាតិ

គោលការណ៍ជាមូលដ្ឋាន និងកាតព្វកិច្ចជាទូទៅ

កិច្ចព្រមព្រៀង TRIPS មាត្រា៣ និង៤

កិច្ចព្រមព្រៀង TRIPS មាត្រា៣ កំណត់សំគាល់

កិច្ចព្រមព្រៀងបានប្រកាសឡើងវិញនូវគោលការណ៍ជាមូលដ្ឋានអំពីប្រព្រឹត្តិកម្មជាតិ ដែលមានចែងនៅក្នុងអនុសញ្ញាទាំងឡាយនៃកម្មសិទ្ធិបញ្ញា ។ ជាពិសេស កិច្ចព្រមព្រៀងបានបញ្ជាក់ថា ចំពោះប្រការដែលទាក់ទងដល់ "ភាពដែលអាចមាន និងការទទួលបាន, ចំណុចដែលត្រូវការពារ ការថែរក្សាសិទ្ធិ និងការការពារ " កម្មសិទ្ធិបញ្ញាចំពោះជនបរទេស ដែលនឹងមិនត្រូវទទួលបាននូវភាពអនុគ្រោះតិចជាងការការពារ ដែលប្រព្រឹត្តិចំពោះជនជាម្ចាស់ស្រុកឡើយ ។ ជាបន្ថែម ប្រទេសទាំងនោះត្រូវបានតំរូវឱ្យផ្តល់នូវប្រព្រឹត្តិកម្ម MFN ចំពោះជនបរទេសដោយមិនត្រូវធ្វើការរើសអើងអ្វីឡើយក្នុងចំណោមពួកគេ ។

ស្តង់ដារអប្បបរមា រួមបញ្ចូលទាំងរយៈពេលនៃការការពារ

កិច្ចព្រមព្រៀងបានកំណត់មូលដ្ឋានថ្មី ដោយផ្តល់និយមន័យចំពោះធាតុសំខាន់ៗ នៃការការពារសិទ្ធិដែលទទួលបាន និងរយៈពេលអប្បបរមាសំរាប់ការការពារកម្មសិទ្ធិបញ្ញានិមួយៗដូចតទៅ ÷

- ☐ ប្រកាសនីយប័ត្រតក្កកម្ម
- ☐ សិទ្ធិថតចំលង និងសិទ្ធិពាក់ព័ន្ធ
- ☐ ពាណិជ្ជសញ្ញា
- ☐ គំនូសឧស្សាហកម្ម

- ☐ គំនូសបំព្រាង និងសៀគ្វីបំព្រួញ
- ☐ ពត៌មានដែលត្រូវបិទបាំង និងសំងាត់ពាណិជ្ជកម្ម
- ☐ ការចង្អុលបង្ហាញលក្ខណៈភូមិសាស្ត្រ រួមទាំងការបង្ហាញពីប្រភពដើមទំនិញផង

កិច្ចព្រមព្រៀង TRIPS ជំពូក៨ (មាត្រា ៤០)

កិច្ចព្រមព្រៀងក៏មានផ្នែកមួយផងដែរស្តីពីការត្រួតពិនិត្យប្រឆាំងតបនឹងការប្រកួតប្រជែងក្នុងការផ្តល់អាជ្ញាប័ណ្ណដែលជាប់កិច្ចសន្យា

ប្រកាសនីយប័ត្រតក្កកម្ម

កិច្ចព្រមព្រៀង TRIPS មាត្រា ២៧

និយមន័យ និងវិសាលភាព, ប្រកាសនីយប័ត្រតក្កកម្មផ្តល់នូវកម្មសិទ្ធិចំពោះការឆ្នៃប្រឌិតទាំងឡាយ[៧៥]។ កិច្ចព្រមព្រៀងបានចែងថា ការឆ្នៃប្រឌិតមួយ ចាំបាច់ត្រូវចុះបញ្ជីក្រោមប្រកាសនីយប័ត្រតក្កកម្មមួយ ដោយការឆ្នៃប្រឌិតនោះត្រូវជា ÷

បណ្ណាល័យ
គ.ជ.អ.ប

- ☐ ការឆ្នៃប្រឌិតដែលថ្មី
- ☐ ដែលពាក់ព័ន្ធនឹងជំហានឆ្នៃប្រឌិត
- ☐ ជាការឆ្នៃប្រឌិតដែលអាចប្រើប្រាស់ក្នុងវិស័យឧស្សាហកម្ម

កិច្ចព្រមព្រៀងក៏បានចែងបន្ថែមទៀតថា ប្រទេសទាំងឡាយត្រូវផ្តល់ប្រកាសនីយប័ត្រតក្កកម្មចំពោះការឆ្នៃប្រឌិតទាំងអស់ លើគ្រប់វិស័យបច្ចេកវិទ្យាទាំង ÷

- ☐ ផលិតផល និង
- ☐ ដំណើរការផលិត ដែលរួមមានដំណាក់កាលប្រើប្រាស់ក្នុងការផលិតផលិតផលទាំងនោះ

ជាងនេះទៅទៀត ប្រកាសនីយប័ត្រតក្កកម្ម ត្រូវតែបានផ្តល់ឱ្យដោយពុំមានការរើសអើងចំពោះទីកន្លែងនៃការឆ្នៃប្រឌិត និងចំពោះប្រការដែលថាតើផលិតផលទាំងនេះត្រូវបាននាំចូល ឬ ក៏ផលិតនៅក្នុងប្រទេស ។ មានតែផលិតផល ឬ ដំណើរការផលិតកម្មមួយចំនួនប៉ុណ្ណោះ ដែលប្រទេសទាំងឡាយត្រូវបានអនុញ្ញាតឱ្យជាត់ចេញពីការផ្តល់ប្រកាសនីយប័ត្រតក្កកម្ម ÷

- ☐ ដំណាក់កាលធ្វើរោគវិនិច្ឆ័យ របៀបវះកាត់ និងព្យាបាល ចំពោះមនុស្ស ឬ សត្វ
- ☐ ការឆ្នៃប្រឌិតដែលពាក់ព័ន្ធនឹងដំណាំ ឬ សត្វពាហនៈ ក្រៅអំពីមីក្រូសរីរាង្គ
- ☐ ដំណាក់កាលជីវវិទ្យាសំខាន់ៗ សំរាប់ផលិតកម្មដំណាំ និងសត្វពាហនៈ ក្រៅអំពីដំណាក់កាលដែលមិនមែនជីវវិទ្យា និងដំណាក់កាលមីក្រូជីវសាស្ត្រ ។

ទោះជាយ៉ាងនេះក្តី នៅពេលដែលប្រទេសមួយដកចេញនូវការឆ្នៃប្រឌិតដែលពាក់ព័ន្ធនឹងដំណាំ និងសត្វពាហនៈ ព្រមទាំងពូជដំណាំផ្សេងៗ ចេញពីការផ្តល់ប្រកាសនីយប័ត្រតក្កកម្ម នោះការឆ្នៃប្រឌិតទាំងនេះត្រូវបានគេរំពឹងថានឹងត្រូវបានការពារតាមប្រព័ន្ធផ្សេងទៀត (sui generis) ដែលមានប្រសិទ្ធិភាព ។ (ភាសាឡាតាំង ស៊ុងនេរិស មានន័យថា "តាមរបៀបផ្ទាល់ដោយឡែក ") ។ ជាទូទៅប្រការនេះត្រូវបានគេចាត់ទុកថា បានប្រើប្រាស់សំដៅលើកទឹកចិត្តប្រទេសទាំងឡាយឱ្យប្រើប្រព័ន្ធ ស៊ុងនេរិស ដែលផ្តល់ឱ្យដោយអនុសញ្ញា UPOV[៧៦] ស្តីពីការការពារ ពូជដំណាំថ្មី (ដូចមានអធិប្បាយក្នុងវណ្ណ ៤៨) ។

---

[៧៥] " ការឆ្នៃប្រឌិត " អាចត្រូវបានកំណត់ថា ជាគំនិតបង្កើត ដែលជាក់ស្តែង អនុញ្ញាតអោយមានដំណោះស្រាយបញ្ហាណាមួយ នៅក្នុងវិស័យបច្ចេកវិទ្យា ។

[៧៦] សហគមន៍អន្តរជាតិការពារពូជដំណាំថ្មី

ខណ្ឌ ៤៨

អនុសញ្ញាស្តីពីការការពារពូជដំណាំថ្មី

កម្មវត្ថុនៃអនុសញ្ញា UPOV គឺសំដៅធានាថា រដ្ឋជាសមាជិកទាំងអស់ត្រូវទទួលស្គាល់សមិទ្ធផលនៃអ្នកបង្កាត់ពូជដំណាំផ្សេងៗ ដោយរៀបចំផ្តល់ឱ្យពួកគេនូវកម្មសិទ្ធិផ្តាច់មុខ លើមូលដ្ឋានឯកភាពមួយដែលកំណត់ដោយគោលការណ៍ច្បាស់លាស់ ។ ដើម្បីអាចទទួលសិទ្ធិសំរាប់ការការពារ ពូជដំណាំថ្មីចាំបាច់ត្រូវតែ ÷

- ☐ *ខុសប្លែកអំពីពូជដែលមានស្រាប់ ត្រូវគេទទួលស្គាល់រួចមកហើយ*
- ☐ *ត្រូវមានលក្ខណៈដាច់ដោយឡែកគ្រប់គ្រាន់*
- ☐ *មានស្ថិរភាព និង*
- ☐ *ថ្មីក្នុងន័យដែលថា ពូជដំណាំទាំងនេះមិនទាន់ត្រូវបានយកមកធ្វើពាណិជ្ជកម្មនៅឡើយ*

ដូចកម្មសិទ្ធិបញ្ញាដទៃទៀតដែរ សិទ្ធិរបស់អ្នកបង្កាត់ពូជដំណាំត្រូវបានផ្តល់ឱ្យសំរាប់រយៈពេលកំណត់មួយ ដែលនៅចុងបញ្ចប់នៃរយៈពេលកំណត់នេះ សិទ្ធិនោះត្រូវបានផ្ទេរបន្តទៅឱ្យសាធារណៈជន ។ ការអនុញ្ញាតពីអ្នកគ្រប់គ្រង សិទ្ធិមិនចាំបាច់ត្រូវឱ្យមានទេ ក្នុងករណីដែលប្រើប្រាស់ពូជដំណាំដែលត្រូវការពារក្នុងការស្រាវជ្រាវ ដោយរួមបញ្ចូលទាំងការប្រើប្រាស់វាក្នុងការបង្កាត់ពូជថ្មីទៀតផង ។

កំណត់សំគាល់ : អនុសញ្ញានេះ ត្រូវបានគ្រប់គ្រងអនុវត្តដោយសហភាពអន្តរជាតិ សំរាប់ការការពារពូជដំណាំថ្មី (UPOV)។ ច្បាប់កែប្រែអនុសញ្ញានេះ បានចូលជាធរមាននៅថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ១៩៩៨ ។

កិច្ចព្រមព្រៀង TRIPS មាត្រា ២៧:៣(ខ)

ក្នុងការពិនិត្យសើរើឡើងវិញមួយនាឆ្នាំ ១៩៩៩ កិច្ចព្រមព្រៀងបានផ្តល់នូវជំរើសដើម្បីដកចេញពីការផ្តល់ប្រកាសនីយប័ត្រតក្កកម្ម ចំពោះការច្នៃប្រឌិតមួយចំនួនលើដំណាំ និងសត្វពាហនៈ ។ ការងារដែលពាក់ព័ន្ធទៅនឹងដំណើរការពិនិត្យឡើងវិញនេះ ត្រូវបានផ្តួចផ្តើមគំនិតដោយក្រុមប្រឹក្សាការងារកម្មសិទ្ធិបញ្ញា (Council for TRIPS) ។

កិច្ចព្រមព្រៀង TRIPS មាត្រា ២៨

សិទ្ធិរបស់អ្នកកាន់កាប់ប្រកាសនីយប័ត្រតក្កកម្ម : ប្រកាសនីយប័ត្រតក្កកម្មបានផ្តល់ឱ្យអ្នកកាន់កាប់នូវសិទ្ធិផ្តាច់មុខ ដែលសិទ្ធិទាំងនេះអនុញ្ញាតឱ្យគេ ការពារមិនឱ្យអ្នកដទៃប្រើប្រាស់ការច្នៃប្រឌិត ដែលបានការពារដោយប្រកាសនីយប័ត្រតក្កកម្មរបស់ខ្លួន ។ ផលិតករទាំងឡាយណា ដែលមានបំណងចង់ប្រើប្រាស់ការច្នៃប្រឌិត ដែលចុះប្រកាសនីយប័ត្រតក្កកម្មរួចហើយ ចាំបាច់ត្រូវសុំអាជ្ញាប័ណ្ណ ឬ ការអនុញ្ញាតពីម្ចាស់កាន់កាប់ប្រកាសនីយប័ត្រតក្កកម្ម ដែលជាធម្មតាតំរូវឱ្យអ្នកស្នើសុំនោះចាំបាច់ត្រូវបង់សោហ៊ុយទំនុកចិត្ត (ឬពន្ធសួរសោអាករ) (Royalty)។

កិច្ចព្រមព្រៀងបានបញ្ជាក់ច្បាស់នូវសិទ្ធិផ្តាច់មុខទាំងឡាយរបស់ម្ចាស់ប្រកាសនីយប័ត្រតក្កកម្ម ។ ជាពិសេស កិច្ចព្រមព្រៀងបានបញ្ជាក់ថែមទៀតថា នៅពេលដែលកម្មវត្ថុដែលត្រូវការពារដោយប្រកាសនីយប័ត្រតក្កកម្មជាផលិតផលមួយ នោះជនទី ៣ អាចបង្កើត លក់ ឬ នាំចូលនូវផលិតផលនោះ ប្រសិនបើមានការយល់ព្រមពីម្ចាស់ប្រកាសនីយប័ត្រតក្កកម្ម ។ នៅពេលដែលដំណើរការផលិតកម្មមួយ ត្រូវបានគេចុះប្រកាសនីយប័ត្រតក្កកម្ម នោះជនទី ៣ មិនអាចប្រើប្រាស់ដំណើរការផលិតកម្មនោះ ដោយគ្មានការយល់ព្រមពីម្ចាស់ប្រកាសនីយប័ត្រតក្កកម្មបានឡើយ ហើយគេក៏ពុំអាចលក់ ឬ នាំចូលផលិតផលដែលផលិតបានដោយផ្ទាល់ពីដំណើរការផលិតកម្មនោះ ដោយគ្មានការយល់ព្រមពីម្ចាស់ប្រកាសនីយប័ត្រតក្កកម្មដែរ ។

ជាងនេះទៅទៀត កិច្ចព្រមព្រៀងបានចែងថា នៅក្នុងការកាត់ក្តីរដ្ឋប្បវេណីចំពោះបទល្មើសរំលោភលើប្រកាសនីយប័ត្រតក្កកម្ម ដែលការពារដំណើរការផលិតកម្ម ផលិតផលដែលបំពានសិទ្ធិនឹងត្រូវបានចាត់ទុកថា បានផលិតដោយប្រើប្រាស់ដំណើរការផលិតកម្ម

ដែលចុះប្រកាសនីយប័ត្រតក្កកម្មរួច ប្រសិនបើផលិតផលនោះដូចគ្នាទៅនឹងផលិតផលដែលផលិតបានតាមរយៈដំណើរការផលិតកម្មដែលបានចុះប្រកាសនីយប័ត្រតក្កកម្មរួចហើយនោះ ។ ក្នុងករណីបៀបនេះ ដោយសារមានការលំបាកចំពោះម្ចាស់ប្រកាសនីយប័ត្រតក្កកម្ម ក្នុងការប្រមូលភស្តុតាងដើម្បីបង្ហាញថា ដំណើរការផលិតកម្មរបស់ខ្លួនត្រូវបានគេយកមកប្រើប្រាស់ នោះបន្ទុកនៃការប្រមូលសក្ខីកម្មត្រូវធ្លាក់ទៅលើចុងចោទ ដោយចុងចោទនោះចាំបាច់ត្រូវបង្ហាញថាផលិតផលដែលផលិតរួច បានប្រើប្រាស់ដំណើរការផលិតកម្មខុសប្លែកពីដំណើរការផលិតកម្មដែលបានចុះប្រកាសនីយប័ត្រតក្កកម្មរួច ។

កិច្ចព្រមព្រៀង TRIPS មាត្រា ៣១

អាជ្ញាប័ណ្ណចាប់បង្ខំ : តើនឹងមានបញ្ហាអ្វីកើតឡើង ប្រសិនបើម្ចាស់ប្រកាសនីយប័ត្រតក្កកម្មម្នាក់ បដិសេធមិនព្រមផ្តល់អាជ្ញាប័ណ្ណសំរាប់ប្រើប្រាស់ការច្នៃប្រឌិតដែលចុះប្រកាសនីយប័ត្រតក្កកម្មរួច ដោយទាមទារដាក់លក្ខខណ្ឌដែលពុំសមស្រប ? ច្បាប់នៃប្រទេសជាច្រើនបានចែងថា នៅពេលដែលផលិតផលដែលចុះប្រកាសនីយប័ត្រតក្កកម្មរួច ហើយពុំមាន ឬ មានដែរ តែលក់ក្នុងតំលៃខ្ពស់ហួសប្រមាណ រដ្ឋាភិបាលអាចនឹងធ្វើការអនុញ្ញាតដោយផ្អែកលើហេតុផលនៃផលប្រយោជន៍សាធារណៈ ផ្តល់សិទ្ធិដល់ផលិតករដែលមានបំណងផលិតផលិតផលនោះ ឱ្យប្រើប្រាស់ប្រកាសនីយប័ត្រតក្កកម្ម ដោយបង់សោហ៊ុយទៅឱ្យម្ចាស់ប្រកាសនីយប័ត្រតក្កកម្មក្នុងរូបភាពជាសួយសារអាករដែលសមស្រប ។ ទោះជាយ៉ាងនេះក្តី កិច្ចព្រមព្រៀងបានដាក់ចេញនូវលក្ខខណ្ឌតឹងរ៉ឹងចំពោះការផ្តល់អាជ្ញាប័ណ្ណបៀបនេះ ដើម្បីធានាថាអាជ្ញាប័ណ្ណចាប់បង្ខំ ត្រូវបានផ្តល់ឱ្យតែក្នុងករណីពិសេស និងលើមូលដ្ឋានជាក់លាក់មួយ។ ជាពិសេសកិច្ចព្រមព្រៀងចែងថា អាជ្ញាប័ណ្ណចាប់បង្ខំ អាចនឹងត្រូវផ្តល់ជូនតែក្នុងករណីដែលផលិតករដែលមានបំណងចង់ប្រើប្រាស់ប្រកាសនីយប័ត្រតក្កកម្មត្រូវទទួលបរាជ័យ ក្នុងការខំប្រឹងប្រែងស្នើសុំការអនុញ្ញាតពីម្ចាស់ប្រកាសនីយប័ត្រតក្កកម្មតាមលក្ខខណ្ឌ និងប្រការសមហេតុផលនានារួចហើយ ។ វណ្ណ ៤៩ នឹងរៀបរាប់នូវលក្ខខណ្ឌមួយចំនួនដែលចាំបាច់ត្រូវតែបំពេញឱ្យបានមុនពេលដែលរដ្ឋាភិបាលអាចចូលធ្វើអន្តរាគមន៍ និងផ្តល់អាជ្ញាប័ណ្ណឱ្យផលិតករមួយរូបអាចប្រើប្រាស់បច្ចេកវិទ្យា ដែលចុះប្រកាសនីយប័ត្រតក្កកម្មរួចហើយ ។

កិច្ចព្រមព្រៀង TRIPS មាត្រា ២៩

ការបើកចំហរពត៌មាន : ទោះបីជាម្ចាស់ប្រកាសនីយប័ត្រតក្កកម្មមានសិទ្ធិផ្តាច់មុខលើការច្នៃប្រឌិតរបស់ខ្លួនក្តី ក៏គេមិនអាចបិទបាំងពត៌មានបច្ចេកទេសអំពីការច្នៃប្រឌិតទាំងនេះបានឡើយ ។ បញ្ញត្តិច្បាប់នៃប្រទេសស្ទើរតែទាំងអស់ តំរូវឱ្យអ្នកស្នើសុំចុះប្រកាសនីយប័ត្រតក្កកម្ម ចាំបាច់ត្រូវបើកចំហរពត៌មានទាំងនេះ ស្តីពីផលិតផល ឬ ដំណើរការផលិតកម្ម ដែលត្រូវការពារដោយប្រកាសនីយប័ត្រតក្កកម្ម ដើម្បីឱ្យបុគ្គលដែលមានសមត្ថភាពខាងបច្ចេកទេសអាចប្រើប្រាស់បច្ចេកវិទ្យាទាំងនោះបាន សំរាប់ស្រាវជ្រាវបន្ត ឬ សំរាប់ការអនុវត្តន៍ខាងឧស្សាហកម្ម បន្ទាប់ពីរយៈពេលការពារដោយប្រកាសនីយប័ត្រតក្កកម្ម ត្រូវបានផុតរលត់ទៅ ។ បុគ្គលដែលមានការចាប់អារម្មណ៍ណាម្នាក់ អាចស្នើសុំពត៌មានទាំងនេះបាន ពីការិយាល័យប្រកាសនីយប័ត្រតក្កកម្មបន្ទាប់ពីបុគ្គលនោះបានបង់កំរៃចាំបាច់នានារួចហើយ ។

ចណ្ណ ៤៩

លក្ខខណ្ឌដែលចែងនៅក្នុងកិច្ចព្រមព្រៀង TRIPS សំរាប់ការផ្តល់អាជ្ញាប័ណ្ណចាប់បង្ខំចំពោះប្រកាសនីយប័ត្រតក្កកម្ម (កិច្ចព្រមព្រៀង TRIPS មាត្រា ៣១)

តាមគោលការណ៍ជាទូទៅ អាជ្ញាប័ណ្ណចាប់បង្ខំមួយសំរាប់ការប្រើប្រាស់ប្រកាសនីយប័ត្រតក្កកម្មបច្ចេកវិទ្យា អាចបានត្រូវផ្តល់ឱ្យដោយរដ្ឋាភិបាលនៃប្រទេសមួយ ដែលប្រកាសនីយប័ត្រតក្កកម្មនោះត្រូវបានចុះបញ្ជី ប្រសិនបើអ្នកដែលមានបំណងប្រើប្រាស់ (អាចជារដ្ឋាភិបាលខ្លួនឯង ឬ ក្រុមហ៊ុនមួយ ឬ បុគ្គលឯកជនណាម្នាក់) បានព្យាយាមដោយពុំទទួលជោគជ័យក្នុងការស្នើសុំអាជ្ញាប័ណ្ណ ពីម្ចាស់ប្រកាសនីយប័ត្រតក្កកម្ម តាមរយៈលក្ខខណ្ឌពាណិជ្ជកម្មដ៏សមស្របនានា ។ ក្នុងករណីប្រជាជាតិជួបនឹងគ្រោះអាសន្ន កាលៈទេសៈបន្ទាន់ចាំបាច់ផ្សេងទៀត និងក្នុងករណីដែលការយកទៅប្រើប្រាស់ជាសាធារណៈពុំមានលក្ខណៈពាណិជ្ជកម្ម នោះលក្ខខណ្ឌខាងលើពុំចាំបាច់ត្រូវបំពេញទេ ។ ទោះជាយ៉ាងនេះក្តី ម្ចាស់ប្រកាសនីយប័ត្រតក្កកម្មចាំបាច់ត្រូវបានគេផ្តល់ដំណឹងជាមុនអំពីការប្រើប្រាស់នេះ ។

ការផ្ដល់អាជ្ញាប័ណ្ណចាប់បង្ខំត្រូវតែស្ថិតជាកម្មវត្ថុនៃល័ក្ខខ័ណ្ឌទាំងឡាយដូចខាងក្រោម ÷

- ☐ *អាជ្ញាប័ណ្ណនេះនឹងត្រូវផ្ដល់ឱ្យចំពោះតែការផ្គត់ផ្គង់ណា ដែលធ្វើឡើងលើសលប់ចំពោះទីផ្សារក្នុងស្រុក ។*
- ☐ *អាជ្ញាប័ណ្ណចាំបាច់ត្រូវបញ្ចប់ភ្លាម ប្រសិនបើ និងនៅពេលដែលកាលៈទេសៈ ដែលនាំទៅដល់ការផ្ដល់អាជ្ញាប័ណ្ណនេះ លែងមានអាទិភាពទៀតហើយ*
- ☐ *ក្នុងករណីនៃបច្ចេកវិទ្យា Semi-Conductor អាជ្ញាប័ណ្ណនេះនឹងត្រូវប្រើសំរាប់តែការប្រើប្រាស់ជាសាធារណៈ មិនមានលក្ខណៈពាណិជ្ជកម្ម ឬ សំរាប់ជាដំណោះស្រាយក្នុងការអនុវត្តនីតិវិធានប្រឆាំងតបនឹងការប្រកួតប្រជែង ។*
- ☐ *ការផ្ដល់អាជ្ញាប័ណ្ណនេះនឹងត្រូវស្ថិតក្នុងលក្ខណៈដែលមិនមែនជាការប្រើប្រាស់ផ្ដាច់មុខ ។*
- ☐ *ម្ចាស់ប្រកាសនីយប័ត្រតក្កកម្មនឹងទទួលបាននូវកំរៃលើកទឹកចិត្តសមស្រប ដោយផ្អែកទៅលើការគិតគូរតំលៃសេដ្ឋកិច្ចនៃអាជ្ញាប័ណ្ណ ។*
- ☐ *ម្ចាស់ប្រកាសនីយប័ត្រតក្កកម្មមានសិទ្ធិប្ដឹងឧទ្ធរណ៍ប្រឆាំងតវ៉ានឹងសេចក្ដីសំរេចផ្ដល់អាជ្ញាប័ណ្ណចាប់បង្ខំ ឬ សេចក្ដីសំរេចទាំងឡាយណាដែលទាក់ទងដល់ការផ្ដល់កំរៃលើកទឹកចិត្ត ។*

បទបញ្ញត្តិស្ដីពីការផ្សព្វផ្សាយពត៌មានដល់សាធារណជន បានធ្វើឱ្យមានតុល្យភាពដល់គោលដៅពីរ របស់រដ្ឋាភិបាលក្នុងការផ្ដល់សិទ្ធិប្រកាសនីយប័ត្រតក្កកម្ម ។ តាមរយៈការផ្ដល់សិទ្ធិផ្ដាច់មុខ រដ្ឋាភិបាលផ្ដល់ឱ្យអ្នកច្នៃប្រឌិតនូវការលើកទឹកចិត្តចំពោះការស្រាវជ្រាវ និងរង្វាន់ចំពោះការងារច្នៃប្រឌិតរបស់ពួកគេ ។ សិទ្ធិផ្ដាច់មុខទាំងនេះ ក៏ផ្ដល់លទ្ធភាពផងដែរ ដល់ផលិតករក្នុងការស្រង់យកមកវិញ និងទទួលផលចំណេញពីការធ្វើវិនិយោគលើការស្រាវជ្រាវ និងការអភិវឌ្ឍន៍របស់គេ ។ ព្រមពេលជាមួយគ្នានេះដែរ តាមរយៈការទាមទារឱ្យអ្នកច្នៃប្រឌិតបើកចំហរពត៌មានជាសាធារណៈ អំពីការច្នៃប្រឌិតរបស់ខ្លួន រដ្ឋាភិបាលស្វែងរកការធានាថា ការច្នៃប្រឌិតទាំងនេះ នឹងត្រូវបានប្រើប្រាស់សំរាប់ប្រយោជន៍របស់សហគមន៏ និងសំរាប់ការស្រាវជ្រាវ និងអភិវឌ្ឍន៍បច្ចេកវិទ្យាក្នុងថ្ងៃអនាគត។ នៅពេលដែលពត៌មានទាំងនេះពុំអាចបានត្រូវប្រើប្រាស់ដោយអ្នកដទៃក្នុងគោលដៅពាណិជ្ជកម្ម រហូតទាល់តែផុតកំណត់អាជ្ញាយុកាល វាបានត្រូវបើកចំហរចំពោះសកលវិទ្យាល័យណាមួយ ចំពោះអង្គការស្រាវជ្រាវ ឬ អង្គការអាជីវកម្ម ដើម្បីប្រើប្រាស់វាសំរាប់ការសិក្សាស្រាវជ្រាវបន្ត ។ គេថែមទាំងអាចស្នើសុំចុះប្រកាសនីយប័ត្រតក្កកម្មទី ២ លើមូលដ្ឋាននៃការច្នៃប្រឌិត ដែលបានចុះប្រកាសនីយប័ត្រតក្កកម្មពីមុនរួចមកហើយ ។ កិច្ចព្រមព្រៀងបានបញ្ជាក់ច្បាស់នូវប្រការនេះ ដោយចែងថា បញ្ញត្តិច្បាប់នៃប្រទេសជាសមាជិក "ចាំបាច់ត្រូវតំរូវឱ្យអ្នកដាក់ពាក្យស្នើសុំប្រកាសនីយប័ត្រតក្កកម្មបើកចំហរការច្នៃប្រឌិតរបស់ខ្លួន តាមរបៀបដែល គ្រប់គ្រាន់ច្បាស់លាស់ និងពេញលេញ សំរាប់ការច្នៃប្រឌិតដែលត្រូវអនុវត្តដោយបុគ្គលដែលមានជំនាញក្នុងវិស័យនោះ" ។

សិទ្ធិចំលង និងសិទ្ធិពាក់ព័ន្ធ

កិច្ចព្រមព្រៀង TRIPS មាត្រា ៩:១៤

កម្មវត្ថុនៃការការពារសិទ្ធិចំលងរួមមាន ស្នាដៃក្នុងវិស័យអក្សរសាស្ត្រ វិទ្យាសាស្ត្រ និងសិល្បៈ ទោះជាតាមរបៀប ឬ ទំរង់នៃការសំដែងចេញរបៀបណាក៏ដោយ ។ ទោះជាយ៉ាងនេះក្ដី ចំពោះស្នាដៃមួយ ដែលអាចទទួលបាននូវការការពារសិទ្ធិចំលងស្នាដៃនោះ ចាំបាច់ត្រូវតែជាស្នាដៃដើម ។ គំនិតដែលសំដែងចេញក្នុងស្នាដៃ មិនចាំបាច់ជាគំនិតថ្មីទេ ប៉ុន្តែទំរង់របស់វាដែលជាទំរង់អក្សរសាស្ត្រ សិល្បៈ ឬ វិទ្យាសាស្ត្រ ត្រូវសំដែងចេញជាលក្ខណៈជាស្នាដៃដើមរបស់អ្នកនិពន្ធ ។

សិទ្ធិដែលរួមមាននៅក្នុងសិទ្ធិចំលង : ម្ចាស់នៃសិទ្ធិចំលងនៅក្នុងស្នាដៃមួយដែលត្រូវបានការពារ មានសិទ្ធិមិនឱ្យអ្នកដទៃប្រើប្រាស់ស្នាដៃនោះដោយគ្មានការអនុញ្ញាត ។ ហេតុនេះហើយ សិទ្ធិរបស់ម្ចាស់សិទ្ធិចំលងតែងត្រូវបានពណ៌នាថា ជាសិទ្ធិផ្ដាច់មុខ ក្នុងការអនុញ្ញាតឱ្យអ្នកដទៃប្រើប្រាស់ស្នាដៃដែលត្រូវបានការពារ ។ ការស្នើសុំអនុញ្ញាតពីម្ចាស់សិទ្ធិចំលង ជាធម្មតាតែងតែទាមទារឱ្យធ្វើឡើងនៅក្នុងស្ថានភាពដូចខាងក្រោម ÷

- ☐ សិទ្ធិក្នុងការផលិតឡើងវិញ : ដោយការថតចំលង និងការផលិតឡើងវិញនូវស្នាដៃ
- ☐ សិទ្ធិក្នុងការសំដែង : ដោយការសំដែងស្នាដៃជាសាធារណៈ (ដូចជាល្ខោន ឬ ការប្រគុំតូរ្យតន្ត្រី)
- ☐ សិទ្ធិក្នុងការថតស្នាដៃ : ដោយការថតសំលេងនៃស្នាដៃមួយ (ដូចជា ការថតថាស ឬ ការថតសំលេងក្នុងភាសាបច្ចេកទេសនៃច្បាប់របស់សិទ្ធិចំលង)
- ☐ សិទ្ធិក្នុងការថតរូបភាពដែលមានចលនា : ដោយការថតរូបភាពដែលមានចលនា (ជាទូទៅហៅថា ស្នាដៃភាពយន្តតាមភាសាបច្ចេកទេស)
- ☐ សិទ្ធិក្នុងការផ្សាយ : ដោយការផ្សព្វផ្សាយស្នាដៃ តាមរយៈវិទ្យុ ឬ ទូរទស្សន៍
- ☐ សិទ្ធិក្នុងការបកប្រែ និងគ្រាប់តាម : ដោយការបកប្រែ និងគ្រាប់តាមស្នាដៃមួយ

ជាបន្ថែមទៅលើសិទ្ធិផ្ដាច់មុខទាំងនេះ ដែលមានលក្ខណៈសេដ្ឋកិច្ច ច្បាប់នៃសិទ្ធិចំលងបានផ្ដល់ឱ្យអ្នកនិពន្ធនៃស្នាដៃដើមនូវសិទ្ធិខាងសីលធម៌ផងដែរ ។ សិទ្ធិទាំងនេះផ្ដល់លទ្ធភាពឱ្យអ្នកនិពន្ធ សូម្បីតែក្រោយពីគេបានផ្ទេរសិទ្ធិសេដ្ឋកិច្ចរបស់ខ្លួនទៅឱ្យអ្នកដទៃរួចហើយក្ដី អាចទាមទារសិទ្ធិជាអ្នកនិពន្ធស្នាដៃ ហើយប្រឆាំងជំទាស់បាន ចំពោះរាល់សកម្មភាពដែលធ្វើឱ្យប៉ះពាល់ ឬ ខូចតំលៃចំពោះស្នាដៃ ដែលសកម្មភាពនោះអាចធ្វើឱ្យអ្នកដទៃ ធ្វើបុរេវិនិច្ឆ័យខុសចំពោះកេរ្ដិ៍ឈ្មោះ ឬ កិត្តិយសរបស់អ្នកនិពន្ធ ។

សិទ្ធិពាក់ព័ន្ធ : ស្នាដៃអក្សរសាស្ត្រ និងសិល្បៈ ត្រូវបានបង្កើតឡើង ដើម្បីផ្សព្វផ្សាយក្នុងចំណោមសាធារណជន ។ ប្រការនេះជានិច្ចជាកាល មិនអាចធ្វើឡើងដោយអ្នកនិពន្ធខ្លួនឯងដោយផ្ទាល់ទេ គេតែងតែត្រូវការឱ្យមានអន្តរការី ដែលជាអ្នកប្រើប្រាស់វិជ្ជាជីវៈជំនាញរបស់ខ្លួនក្នុងការធ្វើឱ្យស្នាដៃមានទំរង់សមស្រប សំរាប់បង្ហាញ ដើម្បីឱ្យស្នាដៃនោះអាចជ្រាបចូលបានយ៉ាងទូលំទូលាយទៅក្នុងស្រទាប់មហាជន ។

ជាបន្ថែមទៅលើការការពារសិទ្ធិរបស់អ្នកនិពន្ធស្នាដៃ គេចាំបាច់ត្រូវតែការពារសិទ្ធិរបស់ ÷

- ☐ អ្នកសំដែងស្នាដៃ ក្នុងទំនាក់ទំនងទៅនឹងការសំដែងរបស់គេ
- ☐ អ្នកផលិតថាសចំរៀង ក្នុងទំនាក់ទំនងទៅនឹងការថតថាសរបស់ពួកគេ និងអង្គភាពផ្សព្វផ្សាយក្នុង
- ☐ ទំនាក់ទំនងទៅនឹងកម្មវិធី ទូរទស្សន៍ និងវិទ្យុរបស់ពួកគេ ។

សិទ្ធិដែលទាក់ទងនឹងអ្នកសំដែងស្នាដៃ ផលិតករថតថាស និងអ្នកផ្សព្វផ្សាយ តែងត្រូវបានហៅថា ជាសិទ្ធិពាក់ព័ន្ធ ពីព្រោះសិទ្ធិទាំងនោះត្រូវបានអភិវឌ្ឍន៍ ស្របពេលជាមួយនឹងសិទ្ធិចំលង ហើយការអនុវត្តន៍សិទ្ធិទាំងនេះតែងតែពាក់ព័ន្ធទៅនឹងការអនុវត្តន៍សិទ្ធិចំលង។ ច្បាប់អំពីសិទ្ធិចំលង តែងតែមានចែងផងដែរអំពីសិទ្ធិពាក់ព័ន្ធ ។

បទបញ្ញត្តិទាំងឡាយនៃកិច្ចព្រមព្រៀង TRIPS : បញ្ញត្តិសំខាន់ៗស្ដីពីសិទ្ធិចំលង និងសិទ្ធិពាក់ព័ន្ធ មានចែងនៅក្នុងអនុសញ្ញាទីក្រុងប៊ែន។ កិច្ចព្រមព្រៀង TRIPS បានចែងបំភ្លឺ និងបន្ថែមទៅលើបញ្ញត្តិទាំងឡាយរបស់អនុសញ្ញានោះចំពោះ ÷

- ☐ កម្មវិធីកុំព្យូទ័រ និងសំណុំទិន្នន័យ (Database)
- ☐ សិទ្ធិក្នុងការជួលកម្មវិធីកុំព្យូទ័រ ការថតសំលេង និងភាពយន្ត
- ☐ សិទ្ធិរបស់អ្នកសំដែង និងផលិតករថតថាស និង
- ☐ សិទ្ធិរបស់អង្គភាពផ្សព្វផ្សាយ

វគ្គ ៥០ និងសង្ខេបនូវបញ្ញត្តិទាំងឡាយរបស់កិច្ចព្រមព្រៀងនេះ ។

ប្រអប់ ៥០

បទបញ្ញត្តិទាំងឡាយនៃសិទ្ធិចម្លងនៅក្នុងកិច្ចព្រមព្រៀង TRIPS

កម្មវិធីកុំព្យូទ័រ *(មាត្រា ១០) កិច្ចព្រមព្រៀងចែងថា កម្មវិធីកុំព្យូទ័រនឹងបានត្រូវចាត់ទុកថាជាស្នាដៃអក្សរសាស្ត្រ ហើយត្រូវការពារតាមច្បាប់ចម្លងរបស់ជាតិនីមួយៗ ។*

សិទ្ធិក្នុងការជួល *(មាត្រា ១១) កិច្ចព្រមព្រៀងតម្រូវឱ្យប្រទេសទាំងឡាយផ្តល់ឱ្យអ្នកនិពន្ធកម្មវិធីកុំព្យូទ័រ អ្នកថតសំលេង និងអ្នកថតភាពយន្តនូវ " សិទ្ធិក្នុងការអនុញ្ញាត ឬ ហាមឃាត់ រាល់ការជួលដែលមានលក្ខណៈពាណិជ្ជកម្ម" នៃស្នាដៃដែលការពារដោយសិទ្ធិចំលងរបស់គេ ។ ប្រទេសជាសមាជិកមួយ " នឹងត្រូវបានរំពឹងថាមិនអនុវត្តកាតព្វកិច្ចនេះ ចំពោះស្នាដៃភាពយន្ត លើកលែងតែក្នុងករណីដែលការជួលនេះនាំទៅដល់ការរីកសាយភាយនៃការចំលងស្នាដៃ..... ដែលការរីកសាយភាយនេះធ្វើឱ្យប៉ះពាល់ដល់សិទ្ធិផ្តាច់មុខក្នុងការផលិតឡើងវិញ ដែលត្រូវផ្តល់ឱ្យ..... ដល់អ្នកនិពន្ធ" ។*

ការការពារសិទ្ធិអ្នកសំដែង សិទ្ធិអ្នកផលិតថាស (ការថតសំលេង) និងសិទ្ធិរបស់អង្គភាពផ្សព្វផ្សាយ

សិទ្ធិអ្នកសំដែង (មាត្រាទី ១៤) កិច្ចព្រមព្រៀងចែងថា អ្នកសំដែងត្រូវមានសិទ្ធិ " ដែលទាក់ទងដល់ការថតការសំដែងរបស់គេជាថាស " ដើម្បីការពារការផលិតឡើងវិញនូវការថតនោះ ។ ពួកគេក៏ត្រូវមានសិទ្ធិផងដែរ ក្នុងការការពារ "ការផ្សព្វផ្សាយ ដែលធ្វើឡើងដោយមធ្យោបាយជាលកសំលេង និងការផ្សព្វផ្សាយជាសាធារណៈ ដោយបន្តផ្ទាល់នូវការសំដែងរបស់ពួកគេ " ដោយគ្មានការអនុញ្ញាត ។

អ្នកផលិត ។ អ្នកផលិតថាសត្រូវមានសិទ្ធិអនុញ្ញាត ឬ ហាមឃាត់ការថតចំលងឡើងវិញ ដោយផ្ទាល់ ឬ ដោយប្រយោលនូវថាសចំរៀងរបស់ពួកគេ ។

អង្គភាពផ្សព្វផ្សាយ ។ អង្គភាពទាំងនេះមានសិទ្ធិហាមឃាត់សកម្មភាពមួយចំនួនដូចខាងក្រោម ដោយមិនអនុញ្ញាតឱ្យបុគ្គលដទៃធ្វើសកម្មភាពទាំងនេះដោយគ្មានការអនុញ្ញាតពីពួកគេ ÷

- ☐ *ការសំដែងឡើងវិញ*
- ☐ *ការផលិតឡើងវិញនូវការសំដែង*
- ☐ *ការផ្សាយឡើងវិញដោយមធ្យោបាយរលកសំលេង ឬ តាមរយៈការផ្សព្វផ្សាយលើទូរទស្សន៍នូវការផ្សព្វផ្សាយរបស់ពួកគេ ។*

សូមពិនិត្យមើលវគ្គ ៥២ អំពីបទបញ្ញត្តិទាំងឡាយ ទាក់ទងដល់រយៈពេលនៃការការពារសិទ្ធិទាំងនេះ ។

ពាណិជ្ជសញ្ញា

កិច្ចព្រមព្រៀង TRIPS
មាត្រា ១៥-២១

ពាណិជ្ជសញ្ញា គឺជាសញ្ញាមួយសំរាប់សំគាល់ភាពខុសគ្នានៃទំនិញ ឬ សេវារបស់សហគ្រាសពាណិជ្ជកម្ម ឬ ឧស្សាហកម្មមួយពីទំនិញ ឬ សេវាកម្មរបស់សហគ្រាសដទៃទៀត ។ សញ្ញានេះអាចរួមមាន ពាក្យ អក្សរ ឈ្មោះ លេខ ធាតុផ្សំជារូបភាព និងការផ្គួបផ្សំនូវពណ៌ជាច្រើន ដែលមានលក្ខណៈដាច់ដោយឡែកមួយ ឬ ច្រើន ។ សញ្ញានេះ អាចរួមមានលក្ខណៈណាមួយនៃធាតុទាំងឡាយដែលបានបង្ហាញជូនពីខាងលើ ។ ដោយសារគោលបំណងជាមូលដ្ឋាននៃពាណិជ្ជសញ្ញា គឺសំដៅបែងចែកនូវលក្ខណៈខុសគ្នានោះ ច្បាប់នៃប្រទេសជាច្រើនចែងថា ម៉ាកទាំងឡាយណាដែលត្រូវបានការពារ ចាំបាច់ត្រូវមានលក្ខណៈដាច់ដោយឡែករបស់ខ្លួន ។

គោលបំណងបំរើដោយពាណិជ្ជសញ្ញា ពាណិជ្ជសញ្ញាត្រូវបានប្រើប្រាស់បំរើឱ្យគោលបំណងពីរយ៉ាង ។ វាជួយឱ្យម្ចាស់ពាណិជ្ជសញ្ញាលក់ និងជំរុញការលក់ផលិតផលរបស់គេតាមរយៈការបង្កើតឱ្យមានភាពជឿជាក់ទៅលើផ្លាកសញ្ញាមួយ ។ វាក៏បំរើដល់អ្នកប្រើប្រាស់តាមរយៈការជួយពួកគេក្នុងការជ្រើសរើសពីក្នុងចំណោមលទ្ធភាពនៃជំរើសជាច្រើន និងតាមរយៈការលើកទឹកចិត្តឱ្យម្ចាស់ពាណិជ្ជសញ្ញារក្សា ឬ កែលំអរគុណភាពផលិតផលរបស់ខ្លួន ដែលដាក់លក់ក្រោមពាណិជ្ជសញ្ញានោះ ។

ទោះបីជានៅក្នុងប្រទេសខ្លះ និងនៅក្នុងស្ថានភាពខ្លះ សិទ្ធិអំពីការធ្វើអាជីវកម្មផ្តាច់មុខរបស់ពាណិជ្ជសញ្ញាមួយ អាចត្រូវទទួលបានតាមរយៈការប្រើប្រាស់ពាណិជ្ជសញ្ញានោះយ៉ាងទូលំទូលាយក្នុងវិស័យពាណិជ្ជកម្ម និងដោយគ្មានការចុះបញ្ជីក្តី ក៏ប៉ុន្តែជាទូទៅ គេចាំបាច់ទាមទារឱ្យមានការការពារប្រកបដោយប្រសិទ្ធិភាពនូវពាណិជ្ជសញ្ញាមួយ តាមរយៈការចុះបញ្ជីនៅនឹងការិយាល័យរដ្ឋាភិបាលមួយ (ជាធម្មតាគឺការិយាល័យដែលផ្តល់ប្រកាសនីយប័ត្រតក្កកម្ម) ។ អ្នកដាក់ពាក្យសុំទាំងឡាយណា ដែលមានបំណងចុះបញ្ជីពាណិជ្ជសញ្ញា ត្រូវគេទាមទារឱ្យបញ្ជាក់នូវសារជាតិនៃទំនិញដែលពាក់ម៉ាកនឹងត្រូវចុះបញ្ជី ។ ហេតុផលដែលបង្កើតឱ្យមាន វិធាននេះគឺសំដៅឱ្យអ្នកចុះបញ្ជីពាណិជ្ជសញ្ញាអាចប្រើប្រាស់សញ្ញារបស់ខ្លួន សំរាប់តែទំនិញដែលបានបញ្ជាក់ជូនតែប៉ុណ្ណោះ ។ ទោះជាយ៉ាងនេះក្តី ក្នុងការអនុវត្តន៍ជាក់ស្តែង ការការពារការប្រើប្រាស់ពាណិជ្ជសញ្ញាសំរាប់ទំនិញ ឬ សេវាកម្មដទៃទៀត ក៏ត្រូវធ្វើឡើងដោយគួបផ្សំលើភាពដូចគ្នា ដែលអ្នកប្រើប្រាស់អាចភាន់ច្រឡំទៅនឹងពាណិជ្ជសញ្ញាដែលបានចុះបញ្ជីរួចហើយ ។ ប្រការនេះត្រូវបានគេសាកល្បងលើមូលដ្ឋាននៃភាពដូចគ្នារបស់ទំនិញ ឬនៅលើកិត្តិសព្ទរបស់ម៉ាកមួយ ។

វិធានអន្តរជាតិស្តីពីការប្រើប្រាស់ពាណិជ្ជសញ្ញា ។ វិធានច្បាប់អន្តរជាតិស្តីពីពាណិជ្ជសញ្ញា ត្រូវបានចែងនៅក្នុងអនុសញ្ញាទីក្រុងប៉ារីស ។ កិច្ចព្រមព្រៀង TRIPS បំពេញបន្ថែមឱ្យវិធានទាំងនេះលើផ្នែកដូចតទៅ ÷

- ☐ និយមន័យនៃពាណិជ្ជសញ្ញា ។
- ☐ សិទ្ធិផ្តាច់មុខរបស់ម្ចាស់ពាណិជ្ជសញ្ញា
- ☐ ការហាមឃាត់នូវការដាក់កំហិតលក្ខខ័ណ្ឌជាតំរូវការពិសេសចំពោះការប្រើប្រាស់ពាណិជ្ជសញ្ញា ។
- ☐ ការផ្តល់អាជ្ញាប័ណ្ណ និងការផ្ទេរសិទ្ធិរបស់ពាណិជ្ជសញ្ញា ។
- ☐ ការលុបចោលពាណិជ្ជសញ្ញា ។

កិច្ចព្រមព្រៀង TRIPS មាត្រា ១៥

និយមន័យនៃពាណិជ្ជសញ្ញា : កិច្ចព្រមព្រៀងចែងថា សញ្ញា ឬ បង្គុំនៃសញ្ញា ដែលអាចបែងចែកលក្ខណៈសំគាល់របស់ទំនិញ ឬ សេវាកម្មនៃសហគ្រាសមួយ ពីទំនិញ និងសេវាកម្មនៃសហគ្រាសមួយទៀត អាចបានត្រូវចុះបញ្ជីជាពាណិជ្ជសញ្ញា ។ សញ្ញាទាំងនេះរួមមាន ឈ្មោះ អក្សរ លេខ សមាសធាតុជារូបភាព ឬ ការគួបផ្សំនៃពណ៌ ។ ប្រទេសមួយអាចចែងថា ម៉ាកមួយដែលបានប្រើប្រាស់ក្នុងរយៈពេលមួយជាបង្គួរ អាចទទួលឱ្យចុះបញ្ជីបាន ។

កិច្ចព្រមព្រៀង TRIPS មាត្រា ១៦

សិទ្ធិផ្តាច់មុខ : ម្ចាស់ពាណិជ្ជសញ្ញាដែលចុះបញ្ជីរួច មានសិទ្ធិផ្តាច់មុខក្នុងការការពារភាគីទី ៣ មិនឱ្យប្រើប្រាស់សញ្ញាដែលមានលក្ខណៈដូច ឬ ប្រហាក់ប្រហែលនឹងពាណិជ្ជសញ្ញាដែលចុះបញ្ជីរួចរបស់ខ្លួនទៅលើទំនិញ ឬ សេវាកម្ម ដែលមានលក្ខណៈដូច ឬ ប្រហាក់ប្រហែល ដែលជាហេតុបង្កឱ្យមានការភ័ន្តច្រឡំ ។ នៅពេលពាណិជ្ជសញ្ញាដូចគ្នាមួយ ត្រូវបានប្រើប្រាស់លើទំនិញ និងសេវាដែលដូចគ្នា នោះនឹងបង្កើតអោយមានការភាន់ច្រឡំ" ។

កិច្ចព្រមព្រៀង TRIPS មាត្រា ២០

លក្ខខ័ណ្ឌជាតំរូវការពិសេស : កិច្ចព្រមព្រៀងបានដាស់តឿនកុំឱ្យប្រទេសទាំងអស់ធ្វើការដាក់កំហិតចំពោះការប្រើប្រាស់ពាណិជ្ជសញ្ញានូវលក្ខខ័ណ្ឌជាតំរូវការពិសេស ដែលជាឧទាហរណ៍ អាចនឹងកំណត់នូវសមត្ថភាពក្នុងការ" បែងចែកលក្ខណៈទំនិញ ឬ សេវាកម្ម របស់សហគ្រាសមួយពីទំនិញ ឬ សេវាកម្មនៃសហគ្រាសមួយទៀត " ។ កិច្ចព្រមព្រៀងក៏បានតំរូវឱ្យប្រទេសទាំងឡាយបន្តការអនុវត្តន៍ការអនុញ្ញាតប្រើប្រាស់ពាណិជ្ជសញ្ញាបរទេស ប្រសិនបើពាណិជ្ជសញ្ញាទាំងនេះ បានត្រូវគួបផ្សំជាមួយពាណិជ្ជសញ្ញាមួយទៀត ដែលជាពាណិជ្ជសញ្ញាមួយមានលក្ខណៈប្រភពដើមជាតិ ។

កិច្ចព្រមព្រៀង TRIPS មាត្រា ២១

ការផ្តល់អាជ្ញាប័ណ្ណ និងការផ្ទេរសិទ្ធិរបស់ពាណិជ្ជសញ្ញា : កិច្ចព្រមព្រៀងទុកឱ្យប្រទេសជាសមាជិកមានសេរីភាពក្នុងការកំណត់ "លក្ខខ័ណ្ឌស្តីពីការផ្តល់អាជ្ញាប័ណ្ណ និងការផ្ទេរសិទ្ធិរបស់ពាណិជ្ជសញ្ញា" ។ ទោះជាយ៉ាងនេះក្តី កិច្ចព្រមព្រៀងចែងថា មិនត្រូវបង្ខំអោយម្ចាស់សិទ្ធិ ផ្តល់អាជ្ញាប័ណ្ណចំពោះការប្រើប្រាស់ពាណិជ្ជសញ្ញាទេ ។ ជាងនេះទៅទៀត ម្ចាស់សិទ្ធិ " ត្រូវមានសិទ្ធិផ្ទេរសិទ្ធិនៃពាណិជ្ជសញ្ញាមួយដោយចាំបាច់ ឬ ពុំចាំបាច់ផ្ទេរអាជីវកម្មទាំងមូល ដែលប្រើប្រាស់ពាណិជ្ជសញ្ញានោះទេ " ។

កិច្ចព្រមព្រៀង TRIPS មាត្រា ១៩

ការលុបចោលពាណិជ្ជសញ្ញា : ការការពារដែលផ្តល់ចំពោះម្ចាស់នៃម៉ាកដែលចុះបញ្ជីចមួយ ធ្វើឡើងផ្អែកលើមូលដ្ឋាននៃការសន្មត់ថា គាត់នឹងប្រើប្រាស់សញ្ញានោះក្នុងការធ្វើពាណិជ្ជកម្ម ។ ច្បាប់នៃប្រទេសជាច្រើន មានចែងសំរាប់ការលុបម៉ាក ប្រសិនបើម៉ាកនោះមិនបានត្រូវប្រើប្រាស់ក្នុងរយៈពេលណាមួយ ។ ច្បាប់នៃប្រទេសជាច្រើន ក៏បានចែងផងដែរ សំរាប់ការលុបម៉ាកដែលមិនបានប្រើប្រាស់ ប្រសិនបើចំនួននៃម៉ាកដែលស្នើសុំចុះបញ្ជី ត្រូវបានកើនឡើងជារៀងរាល់ឆ្នាំ ក្នុងអត្រាមួយគួរឱ្យកត់សំគាល់ ។ តាមពិត ការកើនឡើងយ៉ាងឆាប់រហ័សនូវចំនួនម៉ាក និងការកើនឡើងនៃការប្រើម៉ាកទាំងនោះក្នុងពាណិជ្ជកម្ម បាននាំទៅដល់ការផុតរលត់ពិតប្រាកដនៃនិមិត្តសញ្ញា ឬ ពាណិជ្ជសញ្ញាសំរាប់ទទួលយក និងប្រើប្រាស់ដោយអ្នកដាក់ពាក្យសុំថ្មីៗ ។ ទេពកោសល្យរបស់មនុស្សជាតិក្នុងការបង្កើតសញ្ញាថ្មីៗ ដោយគួបផ្សំអក្សរ លេខ ឬ រូបភាពប្រព្រឹត្តិទៅដោយគ្មានព្រំខ័ណ្ឌកំណត់ទេ ។

កិច្ចព្រមព្រៀង TRIPS បានដាក់ចេញនូវការណែនាំមួយចំនួន ដែលអង្គភាពចុះបញ្ជីទាំងឡាយ ត្រូវអនុវត្តតាមក្នុងការលុបពាណិជ្ជសញ្ញា ដោយមូលហេតុនៃការពុំបានប្រើប្រាស់វា ។ កិច្ចព្រមព្រៀងចែងថា ពាណិជ្ជសញ្ញាដែលចុះបញ្ជីរួច អាចលុបចោលបាន " បើគ្រាន់តែពុំបានប្រើប្រាស់ជាប់ជាបន្តយ៉ាងហោចណាស់ក្នុងរយៈពេល ៣ ឆ្នាំ " ។ ក្នុងការសំរេចលុបពាណិជ្ជសញ្ញា ការផ្តល់ទំងន់នៃសេចក្តីសំរេច គួរត្រូវធ្វើឡើងដោយគិតគូរដល់កាលៈទេសៈ ដែលហួសពីការគ្រប់គ្រងរបស់ម្ចាស់ពាណិជ្ជសញ្ញាបរទេស ដូចជាការដាក់កំហិតលើការនាំចូល ដែលធ្វើឡើងដោយរដ្ឋាភិបាល ចំពោះការនាំចូលទំនិញដែលប្រើពាណិជ្ជសញ្ញានោះ ។ ជាងនេះទៀត ការប្រើប្រាស់ ឧទាហរណ៍ ដោយអ្នកទទួលអាជ្ញាប័ណ្ណ គួរបានត្រូវទទួលស្គាល់ថាជាការប្រើប្រាស់ដោយម្ចាស់ម៉ាកខ្លួនឯងដែរ ។

គំនូសឧស្សាហកម្ម

កិច្ចព្រមព្រៀង TRIPS មាត្រា ២៥-២៦

ពុំមែនគ្រប់ប្រទេសទាំងអស់ទេ ដែលបច្ចុប្បន្ននេះធ្វើការការពារគំនូសឧស្សាហកម្ម ដែលជាគំនូសសំគាល់លក្ខណៈលំអរបស់ផលិតផលរួមមាន រូបរាង ខ្សែបន្ទាត់ គំនូសលំអរ និងពណ៌ ។ គំនូសឧស្សាហកម្មត្រូវបានការពារ ជាពិសេសក្នុងវិស័យវត្ថុប្រើប្រាស់. ជាឧទាហរណ៍ ដូចជា ផលិតផលវាយនភ័ណ្ឌ ស្បែក ផលិតផលស្បែក និងរថយន្តជាដើម ។

កិច្ចព្រមព្រៀង TRIPS មាត្រា ២៥

កិច្ចព្រមព្រៀង TRIPS បានដាក់ចេញនូវភាតព្វកិច្ចមួយ ចំពោះប្រទេសជាសមាជិកក្នុងការការពារគំនូសឧស្សាហកម្ម ដោយតំរូវអោយគំនូសនោះ ចាំបាច់ត្រូវ ÷

☐ ថ្មី ឬ

☐ មានលក្ខណៈដើម

កិច្ចព្រមព្រៀង TRIPS មាត្រា ២៥

គំនូសបំព្រាងនេះចាំបាច់ត្រូវជាគំនូសបំព្រាងថ្មី ឬ មានលក្ខណៈដើម ដើម្បីបំពេញបាននូវលក្ខណៈវិនិច្ឆ័យសំរាប់ទទួលការការពារ[៣៧] ។ ម្ចាស់របស់គំនូសបំព្រាងដែលបានទទួលការការពារ មានសិទ្ធិផ្តាច់មុខក្នុងការប្រើប្រាស់គំនូសនេះ ហើយអាចរាំងមិនឱ្យភាគីទី ៣ ដែលមិនបានទទួលការយល់ព្រមពីខ្លួនមិនឱ្យ " ផលិតលក់ ឬ នាំចូល ទំនិញដែលរចនាតាមគំនូសបំព្រាង ទោះជាមានលក្ខណៈចំលង ឬ ក៏ជារូបចំលងផ្ទាល់តែម្តងនៃគំនូសបំព្រាងក៏ដោយ " ។

កិច្ចព្រមព្រៀងមានបទបញ្ញត្តិពិសេសមួយ ដែលយកចិត្តទុកដាក់ផងដែរ ចំពោះវដ្តជីវិតនៃជីវិតរបស់ផលិតផល និងចំនួនដែលចេះតែកើនឡើងនៃការបង្កើតរចនាបទថ្មីៗក្នុងផ្នែកវាយនភ័ណ្ឌ ។ ប្រការនោះបានចែងថា ទោះជា " ក្នុងតំលៃណាក៏ដោយ ការពិនិត្យ

---

[៣៧] ក្នុងការចរចានាកិច្ចប្រជុំឧរូហ្គាយ មានប្រទេសខ្លះបានស្នើអោយមានការផ្តល់កម្មសិទ្ធិបញ្ញាតែលើគំនូសឧស្សាហកម្មណាដែលមានលក្ខណៈថ្មី និងប្រភពដើម " ។ ក៏ប៉ុន្តែ ការអនុវត្តន៍គោលការណ៍នេះ មិនបានទទួលការគាំទ្រពីប្រទេសភាគច្រើន ដោយប្រទេសទាំងនោះចាត់ទុកថា ការអនុវត្តន៍គោលការណ៍បែបនេះ នឹងធ្វើអោយគេមានការលំបាកក្នុងការការពារគំនូសឧស្សាហកម្ម ។

កិច្ចព្រមព្រៀង TRIPS មាត្រា ២២-២៤

ឬការផ្សព្វផ្សាយអំពីការចុះបញ្ជី " មិនត្រូវធ្វើឡើងដោយមិនសមស្របប៉ះពាល់ដល់កាលានុវត្តន៍ភាព ដែលត្រូវផ្តល់ឱ្យចំពោះការសុំកិច្ចការពារចំពោះកម្មសិទ្ធិបញ្ញានេះឡើយ " ។

ការចង្អុលបង្ហាញលក្ខណៈភូមិសាស្ត្រ

កិច្ចព្រមព្រៀង TRIPS មាត្រា ២២

ការចង្អុលបង្ហាញលក្ខណៈភូមិសាស្ត្រ មានគោលបំណងជូនដំណឹងដល់អ្នកប្រើប្រាស់ថា ទំនិញមួយមានគុណភាព កេរ្តិ៍ឈ្មោះ ឬលក្ខណៈសម្បត្តិដទៃទៀតដែល "ពាក់ព័ន្ធយ៉ាងពិសេសទៅនឹងលក្ខណៈភូមិសាស្ត្ររបស់វា" ។ កិច្ចព្រមព្រៀងចែងថា ប្រទេសជាសមាជិកគួរបង្កើតឡើងនូវ " មធ្យោបាយស្របច្បាប់មួយ" ដើម្បីការពារ " ការប្រើប្រាស់ ទោះជាតាមវិធីណាក៏ដោយក្នុងការកំណត់ ឬ បង្ហាញ ដែលបញ្ជាក់ប្រាប់ ឬ អាចធ្វើសេចក្តីសន្និដ្ឋានថា ទំនិញមួយមានប្រភពនៅក្នុងតំបន់ភូមិសាស្ត្រណាមួយដែលមិនមែនជាទីតាំងពិតប្រាកដនៃប្រភពដើមទំនិញ ហើយដែលការកំណត់បង្ហាញ ឬ សន្និដ្ឋាននោះ នាំឱ្យសាធារណជនមានការភ័ន្តច្រឡំចំពោះលក្ខណៈភូមិសាស្ត្រដើមនៃទំនិញ " ។

ឧទាហរណ៍សាមញ្ញបំផុត ថាតើការចង្អុលបង្ហាញលក្ខណៈភូមិសាស្ត្រ អាចធ្វើឱ្យសាធារណជនភ័ន្តច្រឡំបែបណានោះ ? គឺការប្រើឈ្មោះថា " សាំប៉ាញ " (Champagne) ដែលមិនមែនជាពាណិជ្ជសញ្ញាមួយទេ ប៉ុន្តែជាឈ្មោះតំបន់មួយនៅក្នុងប្រទេសបារាំង ។ ជាគោលការណ៍ គេមិនអនុញ្ញាតឱ្យហៅឈ្មោះស្រាដែលផលិតនៅទីកន្លែងផ្សេង (ឧទាហរណ៍ នៅប្រទេស អាល្លឺម៉ង់ ឬ សហរដ្ឋអាមេរិក) ថាសាំប៉ាញទេ ទោះបីជាប្រទេសដែលផលិតទំនិញនោះ ចាត់ទុកថាផលិតផលស្រារបស់ខ្លួនថា អាចប្រៀបធៀបបានទៅនឹងស្រាសាំប៉ាញរបស់បារាំងក៏ដោយ ។

ដោយសារកិច្ចព្រមព្រៀងនេះមិនបានកំណត់នូវវិធីសាស្ត្រ អំពីរបៀបការពារលក្ខណៈចង្អុលបង្ហាញខាងភូមិសាស្ត្រនោះ ទើបមានការខុសប្លែកគ្នាយ៉ាងខ្លាំងអំពីវិធីដែលច្បាប់កំណត់ចំពោះការការពារនេះ ។ នៅពេលដែលប្រទេសខ្លះមានច្បាប់ការពារការចង្អុលបង្ហាញលក្ខណៈភូមិសាស្ត្រពិសេសដោយឡែករបស់ខ្លួនក្តី ប្រទេសដទៃទៀតប្រើប្រាស់ច្បាប់ពាណិជ្ជសញ្ញា ច្បាប់ការពារអ្នកប្រើប្រាស់ ច្បាប់ទីផ្សារ (ម៉ាខែតធីង) ប្រព័ន្ធច្បាប់ធម្មតា ឬ ការគួបផ្សំនៃច្បាប់ទាំងនេះ ដើម្បីការពារការចង្អុលបង្ហាញលក្ខណៈភូមិសាស្ត្រនេះ ។

កិច្ចព្រមព្រៀង TRIPS មាត្រា ២៥-២៦

ផលិតផលមួយចំនួនដែលច្បាប់ទាំងនេះអនុវត្តទៅលើ នៅក្នុងប្រទេសជឿនលឿន ភាគច្រើនជាផលិតផលស្រា និងមេរ៉ៃយ ។ ទោះជាយ៉ាងនេះក្តី ក៏មានការលើកលែងមួយចំនួនផងដែរ ។ ឧទាហរណ៍ ច្បាប់របស់សហរដ្ឋអាមេរិក ការពារការអនុវត្តន៍ការចង្អុលបង្ហាញលក្ខណៈភូមិសាស្ត្រ (Idaho) ចំពោះដំឡូង និងមើមខ្ទឹមបារាំង ហើយការពារមិនឱ្យប្រើពាក្យថា " Real California Cheese" ចំពោះផលិតផល Cheese ដែលមិនផលិតក្នុងតំបន់នេះ ។

កិច្ចព្រមព្រៀងក៏មានបទបញ្ញត្តិពិសេសមួយចំនួនសំដៅទទួលយកការគោរពយ៉ាងតឹងរ៉ឹង ដែលធ្វើឡើងដោយប្រទេសខ្លះ ក្នុងការចង្អុលបង្ហាញលក្ខណៈភូមិសាស្ត្រលើមុខទំនិញស្រា និងមេរ៉ៃយ ។ ជាពិសេសកិច្ចព្រមព្រៀងចែងថា ភាគីពាក់ព័ន្ធត្រូវអនុម័តមធ្យោបាយស្របច្បាប់ ដើម្បីការពារមិនឱ្យមានការប្រើប្រាស់មិនត្រឹមត្រូវនូវការចង្អុលបង្ហាញលក្ខណៈភូមិសាស្ត្រចំពោះផលិតផលដែលមិនមានប្រភពពីទីកន្លែង ដែលការចង្អុលបង្ហាញលក្ខណៈភូមិសាស្ត្រសំដៅដល់ ។ បទបញ្ញត្តិនេះក៏ត្រូវអនុវត្តផងដែរ សូម្បីតែសាធារណៈជនមិនត្រូវបានគេធ្វើឱ្យភ័ន្តច្រឡំក៏ដោយ ។

ប្រភេទកម្មសិទ្ធិបញ្ញាដទៃទៀត

បទបញ្ញត្តិទាំងឡាយនៃកិច្ចព្រមព្រៀងស្តីអំពី ការរចនាសៀគ្វីព្រួញ និងពត៌មានសំងាត់ ត្រូវបានធ្វើការកត់សំគាល់សង្ខេប នៅក្នុងវគ្គ ៥១ ។

ខណ្ឌ ៥១

កម្មសិទ្ធិបញ្ញាដទៃទៀត

(កិច្ចព្រមព្រៀង TRIPS មាត្រា ៣៥-៣៩)

ការរចនាសៀគ្វីបំព្រួញ (មាត្រា ៣៥-៣៨) ។ លើកលែងតែមានការចែងដោយឡែកផ្សេងទៀត កិច្ចព្រមព្រៀងតម្រូវឱ្យប្រទេសទាំងឡាយត្រូវការពារការរចនាសៀគ្វីបំព្រួញ ដោយយោងតាមសន្ធិសញ្ញាស្តីពីកម្មសិទ្ធិបញ្ញាទាក់ទងនឹងសៀគ្វីបំព្រួញដែលអនុម័តនៅទីក្រុងវ៉ាស៊ីនតោន ក្នុងឆ្នាំ ១៩៨៩ ។ បទបញ្ញត្តិបន្ថែមមួយចំនួនបានចែងថា ក្នុងចំណោមវត្ថុដែលនាំចូល ឬដាក់លក់ដែលប្រើប្រាស់បច្ចេកទេសសៀគ្វីបំព្រួញ ដែលពុំមានការអនុញ្ញាតពីម្ចាស់កម្មសិទ្ធិត្រូវចាត់ទុកថាខុសច្បាប់ ។ ទោះជាយ៉ាងនេះក្តី នៅពេលដែលបុគ្គលនោះ ពុំបានដឹងថាខ្លួនបានផលិត ឬ លក់ទំនិញ ដែលប្រើប្រាស់សៀគ្វីបំព្រួញដោយខុសច្បាប់ទេ នោះអំពើដែលប្រព្រឹត្តិដោយមិនដឹងខ្លួននេះ មិនអាចចាត់ទុកជាការខុសច្បាប់ឡើយ ។ "ជនដែលរំលោភបំពានដោយស្មោះត្រង់" អាចលក់ ឬ ក៏ចែកចាយសន្និធិទំនិញរបស់ខ្លួនមុនពេលដែលគេដឹងថា ការប្រើប្រាស់សៀគ្វីបំព្រួញរបៀបនេះគឺជាការខុសច្បាប់ ។ ទោះជាយ៉ាងនេះក្តី ពួកគេនឹងត្រូវជាប់បន្ទុកបង់ថ្លៃឱ្យដល់ម្ចាស់កម្មសិទ្ធិនូវសំណងសួយសារអាករ (Royalty) យ៉ាងសមស្រប ។ ប្រការមួយទៀតនៃកិច្ចព្រមព្រៀង បានហាមឃាត់មិនឱ្យមានការចេញអាជ្ញាប័ណ្ណដោយបង្ខំចំពោះសិទ្ធិដែលបានការពាររួចហើយ លើកលែងតែក្នុងករណីនៃការប្រើប្រាស់ជាសាធារណៈ មិនមានលក្ខណៈជាពាណិជ្ជកម្ម ឬ ប្រើប្រាស់សំរាប់ដំណោះស្រាយផ្សេងៗ ដែលកំណត់ដោយអង្គតុលាការ ឬ ស្ថាប័នរដ្ឋបាលនានាសំដៅបង្កើតជាការទប់ទល់នឹងអំពើប្រកួតប្រជែងណាមួយ ។

ពត៌មានសំងាត់ (មាត្រាទី ៣៩) ។ កិច្ចព្រមព្រៀង TRIPS មានចែងនូវបទបញ្ញត្តិទាំងឡាយដែលអនុវត្តជាសាធារណៈលើកទី ១ ក្នុងប្រព័ន្ធច្បាប់អន្តរជាតិ ដែលតម្រូវឱ្យមានការការពារពត៌មានសំងាត់ កិច្ចការសំងាត់ខាងពាណិជ្ជកម្ម ឬ បច្ចេកទេសពិសេស (Know-how) ណាមួយ ។ ការការពារនេះ អនុវត្តចំពោះពត៌មានដែលជាពត៌មានសំងាត់ ហើយមានតំលៃពាណិជ្ជកម្មដោយសារភាពសំងាត់របស់វា និងមានហេតុផលសមរម្យក្នុងការរក្សាទុកជាការសំងាត់ ។ កិច្ចព្រមព្រៀងមិនទាមទារឱ្យចាត់ទុកពត៌មានសំងាត់ទាំងនោះជាទ្រព្យសម្បត្តិទេ ប៉ុន្តែបានចែងថា បុគ្គលម្នាក់មានសិទ្ធិស្របច្បាប់ក្នុងការត្រួតពិនិត្យពត៌មាននេះ មានលទ្ធភាពហាមឃាត់ មិនឱ្យអ្នកដទៃបើកកាយពត៌មានរបស់ខ្លួន ឬ មិនអោយអ្នកដទៃប្រើប្រាស់ពត៌មាននេះ ដោយគ្មានការអនុញ្ញាតក្នុងទំរង់ដែលផ្ទុយទៅនឹងសកម្មភាពពាណិជ្ជកម្មស្មោះត្រង់ ។ ជាងនេះទៅទៀត កិច្ចព្រមព្រៀង មានបទបញ្ញត្តិមួយចំនួនអំពីទិន្នន័យសំងាត់ដែលគេប្រើប្រាស់ ក្នុងការសាកល្បង និងទិន្នន័យដទៃទៀត ដែលទិន្នន័យទាំងនេះតម្រូវឱ្យដាក់ជូនទៅរដ្ឋាភិបាល "ជាល័ក្ខខ័ណ្ឌក្នុងការអនុម័តចំពោះការប្រើប្រាស់ក្នុងវិស័យទីផ្សារឱសថសាស្ត្រ (Marketing of Pharmaceutical products) ឬ វិស័យគីមីសាស្ត្រកសិកម្ម" ។ ប្រទេសជាសមាជិកទាំងអស់ចាំបាច់ត្រូវការពារទិន្នន័យទាំងនេះ ប្រឆាំងទល់នឹងការប្រើប្រាស់ដោយមិនស្មោះត្រង់ក្នុងវិស័យពាណិជ្ជកម្ម ។

រយៈពេលនៃការការពារកម្មសិទ្ធិបញ្ញា

ការការពារកម្មសិទ្ធិបញ្ញាទាំងឡាយ (ក្រៅពីពាណិជ្ជសញ្ញា ការចង្អុលបង្ហាញលក្ខណៈភូមិសាស្ត្រ និងពត៌មានសំងាត់) ត្រូវបានកំណត់ក្នុងរយៈពេលមួយ ។ ថ្វីៗនេះរយៈពេលអប្បបរិមានៃការការពារ ខុសគ្នាពីប្រទេសមួយទៅប្រទេសមួយ ។ កិច្ចព្រមព្រៀងបានបង្កើតនូវកំរិតរយៈពេលអប្បបរមាសំរាប់ការការពារកម្មសិទ្ធិបញ្ញាក្នុងផ្នែកផ្សេងៗគ្នា ។ រយៈពេលទាំងនេះ នឹងត្រូវបង្ហាញជូនក្នុងវណ្ណ ៥២ ។

ខណ្ឌ ៥២

រយៈពេលការពារអប្បបរមាចំពោះកម្មសិទ្ធិបញ្ញា

(កិច្ចព្រមព្រៀង TRIPS មាត្រាផ្សេងៗ)

ប្រកាសនីយបត្រតក្កកម្ម : *២០ ឆ្នាំចាប់ពីកាលបរិច្ឆេទដាក់ពាក្យសុំប្រកាសនីយបត្រតក្កកម្ម (មាត្រា ៣៣)*

សិទ្ធិចំលង : *ការពារមួយជីវិតរបស់អ្នកនិពន្ធ បូកបន្ថែម ៥០ ឆ្នាំ ក្រោយពីមរណភាព*

ចំពោះស្នាដៃភាពយន្ត : *ការពារ ៥០ ឆ្នាំ ក្រោយពីស្នាដៃត្រូវបានបញ្ចាំងជាសាធារណៈ ឬ បើសិនជាមិនបានបញ្ចាំងទេ គឺក្រោយពីកាលបរិច្ឆេទនៃការបង្កើតស្នាដៃនេះ ។*

ស្នាដៃរូបថត ឬស្នាដៃនៃសិល្បៈអនុវត្ត : ការពារ ២៥ ឆ្នាំ ក្រោយកាលបរិច្ឆេទបង្កើតស្នាដៃ

អ្នកសំដែង និងផលិតករថាស : *ការពារ ៥០ ឆ្នាំ ចាប់ពីដំណាច់ឆ្នាំប្រក្រតិទិន ដែលការថតថាសត្រូវធ្វើឡើង ឬ ការសំដែងបានកើតឡើង (មាត្រា ១៤.៥) ។*

ការផ្សព្វផ្សាយ : *ការពារ ២០ ឆ្នាំ ចាប់ពីដំណាច់ឆ្នាំប្រក្រតិទិន ដែលការផ្សព្វផ្សាយនោះបានធ្វើឡើង (មាត្រា ១៤.៥) ។*

ពាណិជ្ជសញ្ញា : *ការពារ ០៧ ឆ្នាំ ចាប់ពីកាលបរិច្ឆេទចុះបញ្ជីលើកដំបូង និងចាប់ពីរៀងរាល់កាលបរិច្ឆេទនៃការចុះបញ្ជីឡើងវិញ ។ ការចុះបញ្ជីអាចធ្វើការចុះបញ្ជីឡើងវិញបានដោយគ្មានកំណត់ (មាត្រា ១៨) ។*

គំនូសឧស្សាហកម្ម : *ការពារយ៉ាងហោចណាស់ ១០ ឆ្នាំ (មាត្រា ២៦.៣)*

ការរចនាសៀគ្វីបំព្រួញ: *ការពារ ១០ ឆ្នាំ ចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជី ។ ប្រសិនបើពុំតំរូវឱ្យមានចុះបញ្ជីទេ ត្រូវការពារ ១០ ឆ្នាំ ចាប់ពីកាលបរិច្ឆេទនៃការធ្វើអាជីវកម្មលើកដំបូង (មាត្រា ៣៨.២ និង ៣) ។*

ម្ចាស់កម្មសិទ្ធិបញ្ញាដែលបាត់បង់សិទ្ធិរបស់ខ្លួន នៅពេលរយៈពេលការពាររបស់ខ្លួនផុតកំណត់ ចាប់ពីពេលនោះមក ប្រកាសនីយបត្រតក្កកម្ម សិទ្ធិចំលង គំនូសឧស្សាហកម្ម និងកម្មសិទ្ធិបញ្ញាដទៃទៀត អាចបានត្រូវអនុញ្ញាតិឱ្យធ្វើអាជីវកម្ម ដោយបុគ្គលណាមួយក្នុងចំណោមសាធារណជន ដោយពុំចាំបាច់សុំការអនុញ្ញាតពីម្ចាស់កម្មសិទ្ធិឡើយ ។

ការអនុវត្តន៍ដែលមានកំណត់ព្រំដែន

ដើម្បីធានាការកែលំអរ និងការបង្កើនឡើងនូវការការពារកម្មសិទ្ធិបញ្ញាមិនឱ្យមានផលប៉ះពាល់ដល់ការផ្ទេរបច្ចេកវិទ្យាក្នុងបែបបទពាណិជ្ជកម្មសមស្រប កិច្ចព្រមព្រៀងចែងថា ប្រទេសទាំងឡាយអាចអនុម័តវិធានការណ៍សមស្របរួមទាំងការតាក់តែងបញ្ញត្តិច្បាប់ផងដែរ ដើម្បីការពារម្ចាស់កម្មសិទ្ធិបញ្ញាពី ÷

- ☐ ការរំលោភបំពានក្នុងការអនុវត្តន៍សិទ្ធិរបស់ខ្លួន
- ☐ ការប្រកាន់យកការអនុវត្តន៍ដែលរារាំងដោយមិនសមស្របចំពោះពាណិជ្ជកម្ម ឬ មានផលប៉ះពាល់ធ្ងន់ធ្ងរ ដល់ការផ្ទេរបច្ចេកវិទ្យា

បញ្ញត្តិអំពីការពង្រឹងការការពារសិទ្ធិ

លក្ខណៈវិនិច្ឆ័យមួយនៃកិច្ចព្រមព្រៀង TRIPS ដែលធ្វើឱ្យកិច្ចព្រមព្រៀងនេះខុសប្លែកពីអនុសញ្ញាទាំងឡាយ របស់អង្គការកម្មសិទ្ធិបញ្ញាអន្តរជាតិ (WIPO) គឺការសង្កត់ធ្ងន់ដែលកិច្ចព្រមព្រៀងនេះធ្វើឡើងចំពោះការពង្រឹងការការពារសិទ្ធិ ដែលត្រូវអនុវត្តដោយប្រទេសជាសមាជិក ឱ្យមានបទដ្ឋាន និងច្បាប់របស់ខ្លួនផ្ទាល់ ។ នៅចុងបញ្ចប់របស់កិច្ចព្រមព្រៀង គេបានចែងអំពីយន្តការតាមរយៈស្ថាប័ន បែបបទ និងដំណោះស្រាយ ដែលប្រទេសទាំងឡាយត្រូវអនុម័តយកដូចតទៅ ÷

កិច្ចព្រមព្រៀង TRIPS មាត្រា ៤២-៦១

- ☐ ត្រូវអនុញ្ញាតឱ្យម្ចាស់កម្មសិទ្ធិបញ្ញាទទួលបាននូវសំណងជំងឺចិត្តទៅតាមច្បាប់រដ្ឋប្បវេណី ។
- ☐ ត្រូវមានការអនុវត្តតាមផ្លូវតុលាការ ចំពោះអ្នកក្លែងបន្លំទំនិញ និងបំពានសិទ្ធិចំលងតាមច្បាប់ព្រហ្មទណ្ឌ ។
- ☐ បង្កើតឱ្យមានវិធានការបំរុងទប់ស្កាត់ការក្លែងបន្លំ និង
- ☐ ការពារកុំឱ្យមានការដោះលែងដោយអាជ្ញាធរគយចំពោះទំនិញក្លែងក្លាយ ទំនិញបំពានសិទ្ធិចំលង និងទំនិញបំពានកម្មសិទ្ធិបញ្ញាដទៃទៀត ។

សំណងរដ្ឋប្បវេណី

កិច្ចព្រមព្រៀងចែងថា តុលាការថ្នាក់ជាតិ ត្រូវមានលទ្ធភាព " បញ្ជាជាបន្ទាន់ និងអនុវត្តនូវវិធានការបណ្តោះអាសន្នប្រកបដោយប្រសិទ្ធិភាព" ដើម្បីរក្សាភស្តុតាងដែលពាក់ព័ន្ធលើការរំលោភបំពានកម្មសិទ្ធិបញ្ញា និងការពារកុំឱ្យការរំលោភបំពាននោះកើតឡើង ដូចជា ការពារកុំឱ្យមានការនាំចូលទំនិញ ដែលបំពានសិទ្ធិមកក្នុងចរន្តពាណិជ្ជកម្ម ក្នុងដែនយុត្តាធិការរបស់ខ្លួន ។ នៅពេលដែលការកើតមាននូវការរំលោភបំពានកម្មសិទ្ធិបញ្ញា តុលាការត្រូវមានអំណាចបញ្ជាឱ្យអ្នករំលោភបំពានសងការខូចខាតជាជំងឺចិត្តដល់ម្ចាស់សិទ្ធិ ។ ជាងនេះទៅទៀត ដើម្បីរាំងឱ្យមានប្រសិទ្ធិភាពលើការរំលោភបំពាន តុលាការត្រូវមានសិទ្ធិចេញបញ្ជា បំផ្លាញចោលទំនិញដែលរំលោភបំពានសិទ្ធិកុំឱ្យចូលមកក្នុងចរន្តពាណិជ្ជកម្ម ។

កិច្ចព្រមព្រៀង TRIPS មាត្រា ៦១

បណ្តឹងព្រហ្មទណ្ឌ

ជាបន្ថែម កិច្ចព្រមព្រៀងបានតំរូវឱ្យប្រទេសទាំងអស់ពិនិត្យមើលថា ប្រសិនបើ "មានការរំលោភបំពានដោយចេតនាក្នុងការក្លែងក្លាយពាណិជ្ជសញ្ញា ឬ សិទ្ធិចំលង ជាលក្ខណៈពាណិជ្ជកម្ម " ជនរំលោភបំពានត្រូវកាត់ទោសតាមច្បាប់ព្រហ្មទណ្ឌ និងត្រូវដាក់ពន្ធនាគារ ឬ ពិន័យ យោលទៅតាមករិតជាក់ស្តែងដែលមានប្រសិទ្ធិភាពធ្វើឱ្យរាងចាល ។

កិច្ចព្រមព្រៀង TRIPS មាត្រា ៥០

វិធានការបណ្តោះអាសន្ន

ដោយសារមានដំណើរការទាំងក្នុងបណ្តឹងរដ្ឋប្បវេណី និងបណ្តឹងព្រហ្មទណ្ឌផង ដូច្នេះនីតិវិធីតាមផ្លូវច្បាប់ ទាមទារនូវរយៈពេលមួយយូរបង្គួរ កិច្ចព្រមព្រៀងចែងថា អង្គតុលាការត្រូវមានអំណាចចេញដីការប្រញាប់ និងវិធានការបណ្តោះអាសន្នប្រកបដោយប្រសិទ្ធិភាព ។ វិធានការទាំងនោះត្រូវប្រកាន់យក ដើម្បី ÷

- ☐ ការពារកុំឱ្យការរំលោភបំពានកើតឡើង ។
- ☐ ការពារកុំឱ្យទំនិញរំលោភបំពានចូលក្នុងចរន្តពាណិជ្ជកម្មបាន ។

កិច្ចព្រមព្រៀង TRIPS មាត្រា ៥១

ការការពារកុំឱ្យអាជ្ញាធរគយដោះលែងទំនិញរំលោភបំពាន

ប្រទេសជាសមាជិកត្រូវបានគេតំរូវឱ្យប្រកាន់យកនូវបែបបទ ដែលតាមបែបបទនោះម្ចាស់កម្មសិទ្ធិបញ្ញា ដែលមានហេតុផលគ្រប់គ្រាន់ក្នុងការសង្ស័យថា ÷

- ទំនិញក្លែងក្លាយ ដែលរំលោភបំពានពាណិជ្ជសញ្ញារបស់គេ ឬ

- ទំនិញបំពានសិទ្ធិចំលង

នឹងបានត្រូវគេនាំចូល ហើយអាចសំណូមពរឱ្យអាជ្ញាធរគយកុំឱ្យដោះលែងទំនិញទាំងនោះ ។ ប្រទេសទាំងនោះ មានជំរើសក្នុងការជ្រើសរើសយកបែបបទព្យួរការអនុញ្ញាតដោះលែងទំនិញ ដែលធ្វើឡើងដោយអាជ្ញាធរគយ ចំពោះទំនិញដែលបំពានប្រកាសនីយប័ត្រតក្កកម្ម និងកម្មសិទ្ធិបញ្ញាដទៃទៀត ។

កិច្ចព្រមព្រៀង TRIPS មាត្រា ៦៥-៦៦

ដំណាក់កាលអន្តរកាល

បញ្ញត្តិច្បាប់ជាតិនៃប្រទេសមួយចំនួន ជាពិសេសប្រទេសកំពុងអភិវឌ្ឍន៍ និងប្រទេសក្រីក្រ បច្ចុប្បន្ននេះពុំទាន់សមស្របទៅនឹងបទបញ្ញត្តិទាំងឡាយនៃកិច្ចព្រមព្រៀង TRIPS ដែលបានអធិប្បាយពីខាងលើទេ ។ ឧទាហរណ៍ ក្នុងផ្នែកប្រកាសនីយប័ត្រតក្កកម្ម ដែលកិច្ចព្រមព្រៀងតំរូវថា ត្រូវផ្តល់ប្រកាសនីយប័ត្រនេះទៅឱ្យរាល់ការបង្កើតថ្មី ក្នុងគ្រប់វិស័យបច្ចេកវិទ្យា តែប្រទេសខ្លះមិនផ្តល់ប្រកាសនីយប័ត្រនេះទៅឱ្យវត្ថុគីមី ចំណីអាហារ និងផលិតផលនៃចំណីអាហារទេ ។ ក្នុងប្រទេសខ្លះ រយៈពេលដែលប្រកាសនីយប័ត្រតក្កកម្មត្រូវផ្តល់ឱ្យចំពោះការបង្កើតថ្មីដែលទាក់ទងដល់ ជី ថ្នាំសំលាប់សត្វល្អិត និងផលិតផលឱសថ នៅខ្លីជាងការកំណត់ ២០ ឆ្នាំ ដែលចែងក្នុងកិច្ចព្រមព្រៀងនេះផងដែរ ។ ជាងនេះទៅទៀត ចំពោះផលិតផលឱសថ ប្រទេសខ្លះផ្តល់ការការពារចំពោះតែដំណើរការផលិតកម្ម ប៉ុន្តែមិនការពារផលិតផលទេ ។ ក្នុងវិស័យសិទ្ធិចំលង មានប្រទេសជាច្រើនពុំចាត់ទុកកម្មវិធីកុំព្យូទ័រទៅក្នុងការការពាររបស់ខ្លួនឡើយ ។ ប្រទេសមួយចំនួនទៀតពុំផ្តល់ការការពារ ចំពោះគំនូសបំព្រាងឧស្សាហកម្មទេ ។

ដើម្បីឱ្យឧស្សាហកម្ម និងពាណិជ្ជកម្មក្នុងប្រទេសទាំងនេះ រៀបចំខ្លួនបានសមរម្យ សំរាប់ការផ្លាស់ប្តូរ ដែលតំរូវដោយកិច្ចព្រមព្រៀង TRIPS ប្រទេសជាសមាជិកបានផ្តល់នូវពេលវេលាអន្តរកាលមួយ ដើម្បីឱ្យប្រទេសទាំងនោះរៀបចំច្បាប់ និងបទបញ្ញត្តិរបស់ខ្លួនឱ្យសមស្របនឹងបទបញ្ញត្តិទាំងឡាយនៃកិច្ចព្រមព្រៀង ÷

- ☐ ចំពោះប្រទេសជឿនលឿន : ចំនួន ០១ ឆ្នាំ គឺរហូតដល់ថ្ងៃ ០១ មករា ឆ្នាំ ១៩៩៦ ។ រយៈពេលនេះបានផុតកំណត់ទៅហើយ ។
- ☐ ប្រទេសកំពុងអភិវឌ្ឍន៍ : ចំនួន ០៥ ឆ្នាំ គឺរហូតដល់ថ្ងៃទី ០១ មករា ឆ្នាំ ២០០០ ។
- ☐ ប្រទេសសេដ្ឋកិច្ចអន្តរកាល : ចំនួន ០៥ ឆ្នាំ គឺរហូតដល់ថ្ងៃ ០១ មករា ឆ្នាំ ២០០០ ប្រសិនបើប្រទេសទាំងនោះមានបញ្ហាក្នុងការកែទំរង់ច្បាប់កម្មសិទ្ធិបញ្ញារបស់ខ្លួន ។
- ☐ ប្រទេសក្រីក្រ : ចំនួន ១១ ឆ្នាំ គឺរហូតដល់ថ្ងៃ ០១ មករា ឆ្នាំ ២០០៦ ។

ភាតព្វកិច្ច " ប្រអប់សំបុត្រ "

កិច្ចព្រមព្រៀង TRIPS មាត្រា ៦៥.៤

ជាបន្ថែមទៅនឹងកាតព្វកិច្ចខាងលើ ប្រទេសកំពុងអភិវឌ្ឍន៍ ដែលបច្ចុប្បន្ននេះផ្តល់ការការពារប្រកាសនីយប័ត្រតក្កកម្មដល់ដំណើរការផលិតកម្ម តែមិនផ្តល់ការការពារចំពោះផលិតផលក្នុងវិស័យបច្ចេកវិទ្យាណាមួយនោះ ។ ឧទាហរណ៍ វិស័យឱសថ និងគីមីកសិកម្ម អាចពន្យារហូតដល់ថ្ងៃ ០១ មករា ឆ្នាំ ២០០៥ ចំពោះការអនុវត្តកាតព្វកិច្ចរបស់ខ្លួនក្នុងការការពារផលិតផល ។

កិច្ចព្រមព្រៀង TRIPS មាត្រា ៧០.៨

ភាពដែលអាចបត់បែនបាននេះ អាចអនុវត្តចំពោះប្រទេសកំពុងអភិវឌ្ឍន៍ លុះត្រាណាតែប្រទេសទាំងនេះបំពេញបានល័ក្ខខ័ណ្ឌសំខាន់មួយ ។ ប្រទេសដែលពាក់ព័ន្ធត្រូវបង្កើតយន្តការមួយ (ហៅថាកាតព្វកិច្ចប្រអប់សំបុត្រ) ចាប់ពីកាលបរិច្ឆេទដែលកិច្ចព្រមព្រៀងនេះចូលជាធរមាន (គឺថ្ងៃ ០១ មករា ឆ្នាំ ១៩៩៥) ដើម្បីទទួលពាក្យស្នើសុំប្រកាសនីយប័ត្រតក្កកម្មពីអ្នកវិនិយោគក្នុងស្រុក និងបរទេស ។ ពាក្យសុំទាំងនេះ មិនចាំបាច់ត្រូវពិនិត្យលើល័ក្ខខ័ណ្ឌចុះប្រកាសនីយប័ត្រតក្កកម្មទេ រហូតដល់ប្រទេសនោះចាប់ផ្តើមអនុវត្តការការពារប្រកាសនីយប័ត្រតក្កកម្មលើផលិតផលក្នុងវិស័យឱសថ និងគីមីកសិកម្ម គឺរហូតដល់ដំណាច់ពេល ១០ ឆ្នាំ នៃដំណាក់កាលអន្តរកាល (ថ្ងៃ ០១ មករា ២០០៥) ។

ទោះជាយ៉ាងនេះក្តី ផលិតផលឱសថ និងផលិតផលគីមីកសិកម្មថ្មីទាំងឡាយអាចនឹងត្រូវលក់បានលុះត្រាតែ ក្រោយពេលក្រុមហ៊ុនផលិតផលិតផលទាំងនោះ បានទទួលការអនុញ្ញាតពីអាជ្ញាធរ ដែលចេញបែបបទឱ្យដាក់លក់នៅលើទីផ្សារនូវផលិតផលទាំងនេះ។ ការអនុញ្ញាតនេះ ជាទូទៅ ផ្តល់ឱ្យក្រោយពីអាជ្ញាធរទាំងនោះព្រមព្រៀងចំពោះទំនិញ លើមូលដ្ឋានដែលផ្អែកលើលទ្ធផលនៃការពិសោធន៍ធ្វើឡើងដោយក្រុមហ៊ុនតាមសំណើរបស់អាជ្ញាធរ ដែលលទ្ធផលនោះបង្ហាញថា ផលិតផលទាំងនេះនឹងមិនមានផលប៉ះពាល់អ្វីគ្រោះថ្នាក់ដល់សុខភាពមនុស្ស សត្វ ផលដំណាំ និងបរិស្ថាន ។ កិច្ចព្រមព្រៀងចែងទៀតថា ប្រសិនបើអាជ្ញាធរផ្តល់ការអនុញ្ញាតឱ្យដាក់លក់ដល់ផលិតករដែលបានដាក់ពាក្យស្នើសុំប្រកាសនីយប័ត្រតក្កកម្មចំពោះផលិតផលឱសថ ឬ គីមីកសិកម្ម តាមរបៀបប្រអប់សំបុត្រនេះ គេត្រូវផ្តល់ឱ្យផលិតករទាំងនោះនូវសិទ្ធិផ្តាច់មុខ ដើម្បីធ្វើអាជីវកម្មផលិតផលរបស់ខ្លួន ក្នុងរយៈពេល ០៥ ឆ្នាំ ឬ រហូតដល់ប្រកាសនីយប័ត្រតក្កកម្មត្រូវគេផ្តល់ឱ្យ ដោយជ្រើសរើសរយៈពេលណាដែលខ្លីជាង ។

បទបញ្ញត្តិដែលនៅទ្រឹង (ទុកនៅដដែល)

កិច្ចព្រមព្រៀង TRIPS មាត្រា ៦៥.៥

ក្នុងអំឡុងពេលអន្តរកាល ប្រទេសជាសមាជិកមិនបានតំរូវឱ្យប្រកាន់យកវិធានការ ដែលនាំមកនូវលទ្ធផលដល់ ការការពារកម្មសិទ្ធិបញ្ញា ដែលមានកំរិតទាបជាងអ្វីដែលមានស្រាប់នៅក្នុងដែនដីរបស់ខ្លួនឡើយ ។ ប្រការនេះ ត្រូវគេសំអាងដល់ថាជាបទញ្ញត្តិដែលនៅទ្រឹង ឬ ប្រការ " ដែលមិនធាក់ថយក្រោយ " ។ ប្រទេសទាំងអស់ ដែលស្ថិតក្រោមកាតព្វកិច្ចនេះត្រូវអនុវត្តប្រព្រឹត្តិកម្មជាតិ និងប្រព្រឹត្តិកម្ម MFN ចាប់ពីថ្ងៃ ០១ មករា ឆ្នាំ ១៩៩៦ ។

ការពាក់ព័ន្ធផ្នែកពាណិជ្ជកម្ម

ក្នុងទ្រង់ទ្រាយធំ កិច្ចព្រមព្រៀង TRIPS នឹងមានឥទ្ធិពលជាលក្ខណៈស៊ីសង្វាក់មួយចំពោះបទដ្ឋាននៃការការពារកម្មសិទ្ធិ ទូទាំងពិភពលោក ។ ដោយមានការលើកលែងចំពោះកាតព្វកិច្ចដែលទាក់ទងដល់ផលិតផលឱសថ និងគីមីកសិកម្ម ការធ្វើឱ្យស៊ីសង្វាក់គ្នានេះអាចនឹងត្រូវរំពឹងថាអនុវត្តបានក្នុងឆ្នាំ ២០០០ នៅពេលដែលដំណាក់ការអន្តរកាលនៃការអនុវត្តន៍កិច្ចព្រមព្រៀង ដែលត្រូវធ្វើដោយប្រទេសកំពុងអភិវឌ្ឍន៍ និងប្រទេសសេដ្ឋកិច្ចអន្តរកាលត្រូវបានបញ្ចប់ ។ ការសង្កត់ធ្ងន់ចំពោះកិច្ចព្រមព្រៀង គឺធ្វើឡើងលើផ្នែកពង្រឹងការការពារ ដែលហុចលទ្ធផលឱ្យជាការអនុវត្តន៍តឹងរ៉ឹងជាងក្នុងកំរិតជាតិ ចំពោះការការពារកម្មសិទ្ធិបញ្ញា ទាំងនៅទីផ្សារក្នុងស្រុក និងនៅឯព្រំដែន ។

ការប្រឈមមុខ

ចំពោះអាជីវករនៃប្រទេសកំពុងអភិវឌ្ឍន៍ និងប្រទេសសេដ្ឋកិច្ចអន្តរកាល កិច្ចព្រមព្រៀងផ្តល់ទាំងការប្រឈមមុខ និងគុណសម្បត្តិ។ ការប្រឈមមុខកើតឡើងពីកត្តា ៣ ដែលយើងនឹងពិភាក្សាខាងក្រោម ។

កាតព្វកិច្ចចំពោះការប្តូរប្រព័ន្ធកម្មសិទ្ធិបញ្ញា

ទីមួយ កិច្ចព្រមព្រៀងតំរូវឱ្យមានការផ្លាស់ប្តូរជាចំបងនៃរបបកម្មសិទ្ធបញ្ញារបស់ប្រទេសកំពុងអភិវឌ្ឍន៍មួយចំនួន ។ ការកែតំរូវនេះទាមទារឱ្យធ្វើឡើងចំពោះប្រទេសមួយចំនួនធំ ដែលផ្តល់កិច្ចការពារប្រកាសនីយប័ត្រតក្កកម្មតិចជាង ២០ ឆ្នាំ ដែលបានចែងក្នុងកិច្ចព្រមព្រៀង ឬ ប្រទេសដែលមានការលើកលែងចំពោះរយៈពេល ២០ ឆ្នាំ ឬ ផ្តល់កិច្ចការពាររយៈពេលណាមួយផ្សេងទៀត។ កម្មវិធីកុំព្យូទ័រ ត្រូវតែការពារក្រោមសិទ្ធិចំលងថាជាស្នាដៃអក្សរសាស្ត្រ ។ ប្រទេសកំពុងអភិវឌ្ឍន៍មួយចំនួនធំ (និងប្រទេសជឿនលឿន ២ ទៀត) មិនមានការការពារចំពោះកម្មវិធីកុំព្យូទ័រទេ មកទល់នឹងខែ មេសា ឆ្នាំ ១៩៩៤ ហើយប្រទេសមួយចំនួនតូច ផ្តល់ការការពារតាមវិធានច្បាប់ផ្សេងៗ ក្រៅពីច្បាប់សិទ្ធិចំលង ។

ក្រៅពីការលំបាកទាំងនេះ គេរំពឹងថា ប្រទេសកំពុងអភិវឌ្ឍន៍មួយចំនួនធំនឹងកែតំរូវច្បាប់របស់ខ្លួនឱ្យស្របតាមបទបញ្ញត្តិទាំងឡាយនៃកិច្ចព្រមព្រៀង នាថ្ងៃទី ០១ មករា ឆ្នាំ ២០០០ នៅពេលដែលដំណាក់ការអន្តរកាលដែលផ្តល់ចំពោះពួកគេត្រូវបានបញ្ចប់។

ទោះជាយ៉ាងនេះក្ដី ពួកគេនៅមានពេលរហូតដល់ថ្ងៃ ០១ មករា ឆ្នាំ ២០០៥ ដើម្បីអនុវត្តបទបញ្ញត្តិទាំងឡាយ ស្ដីពីការការពារប្រកាសនីយប័ត្រតក្កកម្ម លើផលិតផលឱសថ និងគីមីកសិកម្ម ។ ប្រទេសកំពុងអភិវឌ្ឍន៍ជាច្រើន បច្ចុប្បន្ននេះបានបង្កើតនូវយន្តការប្រអប់សំបុត្រ ដើម្បីទទួលពាក្យសុំប្រកាសនីយប័ត្រតក្កកម្មចំពោះផលិតផលទាំងនេះ តាមការតម្រូវរបស់កិច្ចព្រមព្រៀង ។

ជាការចាំបាច់បំផុតចំពោះសហគមន៍អាជីវកម្ម ដែលត្រូវប្រុងប្រៀបខ្លួនចំពោះការផ្លាស់ប្ដូរទាំងនេះ ។

ការលំបាកក្នុងការប្រើប្រាស់បច្ចេកទេសវិស្វកម្មដែលបន្សល់ទុកវិញ

ទីពីរ ការការពារខ្លាំងពេកនឹងបង្កការលំបាកចំពោះអាជីវកម្មនៃប្រទេសកំពុងអភិវឌ្ឍន៍ ក្នុងការប្រើប្រាស់បច្ចេកទេសវិស្វកម្ម ដែលបន្សល់ទុកវិញ និងមធ្យោបាយដទៃទៀត ដែលបច្ចេកវិទ្យាអភិវឌ្ឍន៍ដោយក្រុមហ៊ុនបរទេស ហើយបច្ចេកវិទ្យានោះ ត្រូវការពារសិទ្ធិដោយប្រកាសនីយប័ត្រតក្កកម្ម ។ ក្នុងអតីតកាល វិស្វកម្មដែលបន្សល់ទុកវិញនេះ ជាប្រភពធនធានសំខាន់នៃបច្ចេកវិទ្យា ជាពិសេសសំរាប់សហគ្រាសតូច និងមធ្យម ។ ដោយការអនុវត្តកិច្ចព្រមព្រៀង ក្រុមហ៊ុនដែលបានចុះបញ្ជីការពារប្រកាសនីយប័ត្រតក្កកម្ម អាចរំពឹងទុកថានឹងកាន់តែទទួលសិទ្ធិស្ទួចស្ទើងថែមទៀតក្នុងការធានាថា បច្ចេកវិទ្យាដែលចុះបញ្ជីការពារប្រកាសនីយប័ត្រតក្កកម្មរបស់គេ នឹងមិនត្រូវបានប្រើប្រាស់ ដោយមិនបង់សួយសារអាករ (Royalty)។

បញ្ហាពាក់ព័ន្ធនឹងចំណេះដឹងជាប្រពៃណី

ទីបី ប៉ុន្មានឆ្នាំថ្មីៗនេះ មានលេចឡើងនូវបាតុភូតរីកចំរើនក្នុងការស្រាវជ្រាវវិស័យជីវបច្ចេកទេស និងវិស្វកម្ម ហ្សែនតំណពូជ។ ក្នុងករណីខ្លះ ការបង្កើតថ្មី ធ្វើឡើងដោយផ្អែកលើប្រភពហ្សេនេទិចដែលមានស្រាប់ តែក្នុងតំបន់ត្រូពិក ជាពិសេសក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ។

ក្រុមអ្នកបរិស្ថានខ្លះ បានតវ៉ាថា ទោះបីជាក្រុមហ៊ុនដែលស្រាវជ្រាវប្រភពហ្សេនេទិចទាំងនោះ បានប្រើប្រាស់ចំណេះដឹងប្រពៃណីរបស់ជនជាតិភាគតិច ឬសហគមន៍ក្នុងស្រុក ក៏សហគមន៍ទាំងនោះមិនដែលបានទទួលប្រយោជន៍អ្វីពីប្រកាសនីយប័ត្រតក្កកម្មដែលជាលទ្ធផលនៃការបង្កើតថ្មីទាំងនោះឡើយ ។ រាប់សតវត្សរ៍មកហើយ ផ្នែកនៃដំណាំមួយចំនួន (ដូចជា ឫស មើម ស្លឹក ផ្កា និងផ្លែ) បានត្រូវប្រើប្រាស់ក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ដើម្បីបន្ថយការឈឺចាប់ និងព្យាបាលជំងឺឆ្លង ព្រមទាំងអាការៈចុកចាប់ដទៃទៀត។ ផ្នែកនៃដំណាំទាំងនោះក៏ត្រូវប្រើផងដែរ ជាថ្នាំកំចាត់សត្វល្អិត និងថ្នាំស្ងាវបុរាណ ។ ចំណេះដឹងប្រពៃណីទាំងនេះ ត្រូវបានប្រើប្រាស់ក្នុងវិធីផ្សេងៗ ទោះជាមិនបានត្រូវកត់ត្រាជាសៀវភៅ ឬ ឯកសារក៏ដោយ ក៏ជាផ្នែកមួយនៃមរតកសហគមន៍ ។ ចំណេះដឹងនេះមានលទ្ធភាពផ្ដល់ចំណីអាហារពីផលដំណាំ ក៏ដូចជាមានគុណភាពទ្រទ្រង់ជីវិត ដែលបានផ្ទេរពីមាត់មួយទៅមាត់មួយ និង ពីជំនាន់មួយទៅជំនាន់មួយទៀត ។

បញ្ហានៃការទទួលស្គាល់ និងការផ្ដល់នូវរង្វាន់ចំពោះការចូលរួមរបស់ជនជាតិភាគតិច និងសហគមន៍ក្នុងស្រុក ដែលចំណេះដឹងប្រពៃណីរបស់គេត្រូវបានប្រើប្រាស់ ហើយចុះបញ្ជីប្រកាសនីយប័ត្រតក្កកម្មថាជាការបង្កើតថ្មី ត្រូវបានគេលើកមកពិភាក្សាក្នុងកំរិតអន្តរជាតិ ។ អង្គការស្បៀងអាហារ និងកសិកម្ម នៃអង្គការសហប្រជាជាតិ (FAO) បានបង្កើតនូវទស្សនៈមួយអំពីសិទ្ធិកសិករ ដែលចែងអំពី " សិទ្ធិពីអតីតកាល បច្ចុប្បន្ន និង អនាគត ដែលបានពីការរួមចំណែករបស់កសិករក្នុងការថែរក្សា កែលំអរ និងបង្កើតជាដំណាំនៃប្រភពហ្សេនេទិច "។ អនុសញ្ញាស្ដីពីពហុភាពនៃជីវសាស្ត្របានលើកឡើងនូវសំណួរ ថាតើប្រទេសដែលមានប្រភពហ្សេនេទិច អាចចូលរួមបែបណាក្នុងសកម្មភាពស្រាវជ្រាវបច្ចេកវិទ្យាជីវសាស្ត្រ ហើយរួមចំណែកចែករំលែកតាមការព្រមព្រៀងទៅវិញទៅមកនូវផ្លែផ្កានៃការស្រាវជ្រាវនេះ ។

គុណសម្បត្តិ

ការប្រឈមមុខ ដែលជាកត្តា និងការអភិវឌ្ឍន៍ ដែលបានអធិប្បាយពីខាងលើចំពោះសហគមន៍អាជីវកម្ម ត្រូវបានថ្លឹងថ្លែងទល់នឹងឥទ្ធិពលវិជ្ជមាន ដែលច្បាប់កម្មសិទ្ធិបញ្ញាបានផ្ដល់ឱ្យ ÷

☐ ការលើកទឹកចិត្ត ការបង្កើតថ្មី និងការច្នៃប្រឌិត

- ☐ ការផ្ទេរបច្ចេកវិទ្យា ក្នុងល័ក្ខខ័ណ្ឌពាណិជ្ជកម្ម ចំពោះសហគ្រាសអាជីវកម្មនៃប្រទេសកំពុងអភិវឌ្ឍន៍
- ☐ ការការពារអ្នកប្រើប្រាស់តាមរយៈការត្រួតពិនិត្យពាណិជ្ជកម្មទំនិញក្លែងក្លាយ
- ☐ ឥទ្ធិពលចំពោះពាណិជ្ជកម្មនាំចេញ និងនាំចូល

ទិដ្ឋភាពទាំងនេះត្រូវបានគេទទួលយកក្នុងកិរិតលំអិតជាងនៅក្នុងកថាខ័ណ្ឌដែលនឹងរៀបរាប់នៅខាងក្រោម ។

ការលើកទឹកចិត្ត ការបង្កើតថ្មី និងស្នាដៃច្នៃប្រឌិត

ការការពារកម្មសិទ្ធិបញ្ញាឱ្យកាន់តែមានប្រសិទ្ធិភាពឡើង ចំពោះសិទ្ធិចំលង ប្រកាសនីយប័ត្រតក្កកម្ម និងគំនូសឧស្សាហកម្ម នឹងផ្តល់រង្វាន់ដល់ស្នាដៃ ដែលប្រើប្រាស់បញ្ញាញាណ ហើយលើកទឹកចិត្តការបង្កើតថ្មី និងស្នាដៃច្នៃប្រឌិតក្នុងប្រទេសកំពុងអភិវឌ្ឍន៍។ ដូចបានកត់សំគាល់រួចមកហើយ ច្បាប់ស្តីពីប្រកាសនីយប័ត្រតក្កកម្ម ត្រូវស្វែងរកតុល្យភាព រវាងសេចក្តីត្រូវការក្នុងការការពារសិទ្ធិរបស់ម្ចាស់កម្មសិទ្ធិប្រកាសនីយប័ត្រតក្កកម្ម និងតំរូវការរបស់ឧស្សាហកម្ម និងសង្គមជាតិទាំងមូល ដែលត្រូវទទួលផលពីចំណេះដឹងថ្មីដែលត្រូវកែលំអរទាំងនេះ ។ កិច្ចព្រមព្រៀង អំពាវនាវប្រទេសជាសមាជិកទាំងអស់ អនុវត្តយ៉ាងតឹងរ៉ឹងចំពោះបទបញ្ញត្តិទាំងឡាយដែលតំរូវឱ្យអ្នកដាក់ពាក្យសុំប្រកាសនីយប័ត្រតក្កកម្ម ត្រូវបើកចំហរពត៌មានបច្ចេកទេស ដែលអាចឱ្យបុគ្គលមានសមត្ថភាពខាងបច្ចេកទេស បង្កើតឡើងវិញនូវការច្នៃប្រឌិតនោះ ។ ការបើកចំហរនូវពត៌មាន ត្រូវធ្វើចំពោះផ្នែកឧស្សាហកម្ម ជាពិសេសក្នុងកំរិតខ្ពស់ជាង នៅក្នុងប្រទេសដទៃទៀត ដែលមានបុគ្គលមានសមត្ថភាពបច្ចេកទេសគ្រប់គ្រាន់ ឱ្យប្រើប្រាស់វា ដើម្បីស្រាវជ្រាវបន្ថែម និងអភិវឌ្ឍន៍ដំណើរការផលិតកម្ម ឬ ផលិតផល ដែលផ្សេងអំពីផលិតផលបានចុះប្រកាសនីយប័ត្រតក្កកម្មរួច ។ ឃ្លាសដំរុញនៃដំណើរការច្នៃប្រឌិតនេះ នឹងផ្តល់ប្រយោជន៍យ៉ាងប្រាកដដល់ប្រទេសនោះទាំងមូល [២៧]។

ការផ្ទេរបច្ចេកវិទ្យាក្នុងល័ក្ខខ័ណ្ឌពាណិជ្ជកម្ម

ការបង្កើនការការពារកម្មសិទ្ធិបញ្ញា នឹងសំរួលយ៉ាងខ្លាំងដល់ការប្រឹងប្រែងរបស់ក្រុមហ៊ុន នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ឱ្យឈានចូលទៅធ្វើអាជីវកម្មរួមគ្នា និងសហប្រតិបត្តិការដទៃទៀត ក្នុងការផ្ទេរបច្ចេកវិទ្យាក្នុងល័ក្ខខ័ណ្ឌពាណិជ្ជកម្ម ។ មានភស្តុតាងកាន់តែច្រើនឡើងដែលបង្ហាញថា ការការពារកម្មសិទ្ធិបញ្ញាក្នុងប្រទេសជាម្ចាស់ផ្ទះ ជាកត្តាសំខាន់ក្នុងការសំរេចចិត្តរបស់ក្រុមហ៊ុននៃប្រទេសជឿនលឿនក្នុងការមកធ្វើវិនិយោគនៅប្រទេសកំពុងអភិវឌ្ឍន៍ [២៨]។ ប្រការនេះដើរតួនាទីចំបងក្នុងការសំរេចធ្វើវិនិយោគលើឧស្សាហកម្មគីមី និងឱសថ ជាពិសេសក្រុមហ៊ុនដែលផលិតទំនិញ មានភាពងាយស្រួលក្នុងការត្រាប់តាម (ឧទាហរណ៍ ទំនិញអេឡិចត្រូនិច និងកុំព្យូទ័រ) ។

ការបង្កើនការការពារកម្មសិទ្ធិបញ្ញា នឹងលើកទឹកចិត្តដៃគូបរទេសក្នុងការធ្វើអាជីវកម្មរួមឱ្យធ្វើការស្រាវជ្រាវ និងអភិវឌ្ឍន៍ថែមទៀតនៅក្នុងប្រទេសម្ចាស់ផ្ទះ ដែលជាប្រទេសកំពុងអភិវឌ្ឍន៍ ។ បច្ចុប្បន្ននេះ ការងារស្រាវជ្រាវភាគច្រើនត្រូវធ្វើនៅក្នុងប្រទេសជឿនលឿនរួចជាម្ចាស់ស្នាដៃ ។ ការអភិវឌ្ឍន៍របៀបនេះ នឹងនាំឱ្យដៃគូជាម្ចាស់ផ្ទះ មានឥទ្ធិពលខ្លាំងឡើងទាំងអត្ថន័យ និងអាទិភាពក្នុងស្នាដៃស្រាវជ្រាវ ។

ហេតុនេះហើយ ជាតុល្យភាព គេអាចវែកញែកបានថា ក្នុងរយៈពេលវែង និងមធ្យម ការការពារកម្មសិទ្ធិបញ្ញា ដូចមានចែងក្នុងកិច្ចព្រមព្រៀងនឹងផ្តល់ផលវិជ្ជមាន ចំពោះកំណើននៃដំណើរការច្នៃប្រឌិតក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ។ ទោះជាយ៉ាងណា ក្នុងរយៈពេលខ្លី ការសិក្សាជាច្រើនបង្ហាញថា ការកែលំអរការការពារនឹងជំរុញឧស្សាហកម្មក្នុងផ្នែកខ្លះដូចជា ផ្នែកឱសថ និងគីមី ឱ្យបង់ថ្លៃខ្ពស់ជាងមុន ក្នុងការទទួលបានបច្ចេកវិទ្យាដែលចុះប្រកាសនីយប័ត្រតក្កកម្មរួច ។ [២៩]

---

[២៧] លទ្ធផលនៃកិច្ចប្រជុំអ៊ុយរូហ្គាយៈ ការវាយតំលៃដំបូង (ការបោះពុម្ពផ្សាយរបស់អង្គការសហប្រជាជាតិ ឡេខលក់លេខ (E.94.II.D.28) p.p ១៩៦-២០៣

[២៨] Carlos Braga "កិច្ចព្រមព្រៀង TRIPS: កិច្ចប្រជុំអ៊ុយរូហ្គាយ និងចំណងទាក់ទងសេដ្ឋកិច្ចរបស់ខ្លួន" (ឯកសារធនាគារពិភពលោក ថ្ងៃទី ២៦-២៧ ខែមករា ឆ្នាំ១៩៩៥) ។

[២៩] លទ្ធផលនៃកិច្ចប្រជុំអ៊ុយរូហ្គាយ pp ១៩៦-២០៣ ។

ឥទ្ធិពលចំពោះពាណិជ្ជកម្មទំនិញក្លែងក្លាយ

កិច្ចព្រមព្រៀងក៏សង្កត់ធ្ងន់ចំពោះបទបញ្ញត្តិនៃការពង្រឹងការការពារ ដែលរំពឹងផងដែរថានឹងជួយឱ្យ មានការត្រួតពិនិត្យបាននូវផលិតកម្មទំនិញក្លែងក្លាយ និងទំនិញរំលោភសិទ្ធិចំលង ។ ក្នុងឆ្នាំបន្តបន្ទាប់ខាងមុខ យន្តការពិគ្រោះយោបល់ និងដោះស្រាយវិវាទរបស់អង្គការពាណិជ្ជកម្មពិភពលោក នឹងបង្កើនសំពាធចំពោះប្រទេសដែលមានផលិតកម្មទំនិញក្លែងក្លាយធំៗទាំងនេះ ឱ្យពង្រឹងកែលំអរការការពារច្បាប់ពាណិជ្ជសញ្ញា និងច្បាប់សិទ្ធិចំលង ។ ក្នុងផលប្រយោជន៍រយៈពេលវែងរបស់ឧស្សាហកម្មក្នុងស្រុក និងអ្នកប្រើប្រាស់ផងដែរ គេត្រូវសម្លឹងឃើញថា ច្បាប់នេះចាំបាច់ត្រូវតែពង្រឹង ។

ការកើតឡើងនូវការផលិតក្លែងក្លាយ ជាញឹកញាប់ចំណុះឱ្យប្រការដែលថា សហគ្រាសតូចៗមិនទាន់យល់ច្បាស់អំពីផលវិបាកផ្លូវច្បាប់ ដែលត្រូវទទួលពីការប្រើប្រាស់ពាណិជ្ជសញ្ញា ដោយគ្មានការអនុញ្ញាតពីម្ចាស់សិទ្ធិ ។ មានភស្តុតាងខ្លះបង្ហាញថា អ្នកផលិតទំនិញក្លែងក្លាយ និងទំនិញបំពានសិទ្ធិចំលង តែងអាចងាកទៅរកសកម្មភាពស្របច្បាប់បាន កាលណាបរិស្ថានច្បាប់ផ្លាស់ប្តូរ ។ [៣៩]

ការផលិតទំនិញក្លែងក្លាយផ្តល់ផលប៉ះពាល់ខ្លាំងក្លាផងដែរ ដល់ផលប្រយោជន៍នាំចេញរបស់ផលិករនាំចេញក្នុងស្រុកតូចតាច ដែលផលិតក្រោមអាជ្ញាប័ណ្ណសំរាប់ផលិតករនៅឯបរទេស ។ ប៉ុន្មានឆ្នាំថ្មីៗនេះ ផលិតករមួយចំនួន បានធ្វើពាណិជ្ជកម្មផលិតផលិតផលរបស់ខ្លួនក្រោមផ្លាកសញ្ញា ដែលផលិតផលនេះ ឬ ផ្នែករបស់វា ត្រូវបានផលិតដោយសហគ្រាសតូច និងមធ្យម ក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ដើម្បីទាញយកផលប្រយោជន៍ថ្លៃផលិតកម្មទាប ។ ផលិតករទាំងនេះមានចេតនាជាងគេ ដូចដែលបានបង្ហាញនៅក្នុងវណ្ណ ៥៣ ដើម្បីចូលទៅរួមដៃធ្វើអាជីវកម្ម នៅក្នុងប្រទេសដែលមានការការពារកម្មសិទ្ធិបញ្ញាប្រកបដោយប្រសិទ្ធិភាព ។

ការទាក់ទងចំពោះពាណិជ្ជកម្មនីហរណ៍-អាហរណ៍

សហគ្រាសអាជីវកម្មត្រូវចងចាំបទបញ្ញត្តិទាំងឡាយនៃកិច្ចព្រមព្រៀង TRIPS ដើម្បីរៀបចំផែនការយុទ្ធសាស្ត្រ លក់ទំនិញរបស់ខ្លួនក្នុងទីផ្សារបរទេស ។ ជាពិសេស ប្រការទាំងនេះចាំបាច់សំរាប់ពួកគេក្នុងការពិនិត្យមើលថាតើ ដំណើរការផលិតកម្មដែលគេប្រើប្រាស់ដើម្បីផលិតទំនិញ ឬ ធាតុផ្សំវត្ថុធាតុដើមរបស់ទំនិញ មានភ្ជាប់ទៅនឹងការការពារប្រកាសនីយបត្រតក្កកម្ម ឬ ការការពារកម្មសិទ្ធបញ្ញាផ្សេងទៀត នៅក្នុងទីផ្សារដែលគេប៉ុរងនាំទំនិញចេញទៅលក់ឬទេ ដូចគ្នាដែរ នៅពេលដែលផលិតផលដាក់លក់ក្នុងទីផ្សារបរទេស ពាក់ផ្លាកពាណិជ្ជសញ្ញាមួយ គេចាំបាច់ត្រូវធានាថា ម៉ាកប្រហាក់ប្រហែលគ្នា ឬ ដូចគ្នានេះមិនត្រូវបានប្រើ ឬ បានចុះបញ្ជីក្នុងទីផ្សារនោះទេ ។ ប្រសិនបើពាណិជ្ជសញ្ញារបស់គេ ត្រូវចាត់ទុកថាធ្វើឱ្យភាន់ច្រឡំទៅនឹងពាណិជ្ជសញ្ញាដទៃ សហគ្រាសនាំចេញច្បាស់ជាអាចត្រូវទទួលរងនូវការប្តឹងផ្តល់ តាមផ្លូវច្បាប់អំពីការរំលោភបំពានកម្មសិទ្ធិបញ្ញា ។

ការពិចារណាទាំងនេះគួរត្រូវចងចាំទុកដោយសហគ្រាសដែលបញ្ជាទិញទំនិញនាំចូលផងដែរ ។ វាចាំបាច់ណាស់ ជាពិសេសចំពោះផលិតផល ដែលគេច្រើនក្លែងបន្លំ ឬ បំពានសិទ្ធិ ហើយអ្នកនាំចូល ដើម្បីកំចាត់បាននូវការព្រួយបារម្ភទាំងនេះគោងពិនិត្យលទ្ធភាពថា នៅពេលអ្នកផ្គត់ផ្គង់បរទេសអះអាងថា ទំនិញដែលត្រូវនាំចូលផលិតក្រោមអាជ្ញាប័ណ្ណមួយ គេចាំបាច់ត្រូវមានការអនុញ្ញាតឱ្យធ្វើដូច្នេះ ។ បើពុំនោះទេ អ្នកនាំចូលនឹងត្រូវប្រឈមនឹងគ្រោះថ្នាក់ ដែលកើតពីការប្តឹងទារសំណងការខូចខាតរបស់ម្ចាស់ពាណិជ្ជសញ្ញា និងលទ្ធភាពនៃការរឹបអូសទំនិញនាំចូលដោយអាជ្ញាធរគយ នៅពេលទំនិញទៅដល់គោលដៅ ។

ប្រអប់ ៥៣

សារៈសំខាន់នៃការពង្រឹងការការពារកម្មសិទ្ធិបញ្ញា ចំពោះផលិតកម្មក្រោមអាជ្ញាប័ណ្ណ :
ការនិទានអំពីការប្រុងប្រយ័ត្នបង្ការទុកជាមុន

អ្នកនាំចូលកំរាលព្រំដ៏ធំមួយក្នុងប្រទេសជឿនលឿន (ប្រទេស ក) បាននាំចូលព្រំពីផលិតករតូចៗជាច្រើននៃប្រទេសក្រីក្រ (ប្រទេស ខ) ដែលមានប្រពៃណីស្នាដៃសិល្បៈរបៀបនេះជាយូរលង់មកហើយ ។ ការរចនាម៉ូតលំអរ និងការកំណត់គោលដៅសិល្បៈ ត្រូវផ្តល់ឱ្យដោយអ្នកនាំចូល ។ ដើម្បីការពារការប្រើប្រាស់រចនាបទនេះ ដោយផលិតករដទៃទៀត សហគ្រាសដែលនាំចូលបានចុះបញ្ជី គំនូសឧស្សាហកម្ម ជាកម្មសិទ្ធិបញ្ញា ទាំងក្នុងប្រទេសរបស់ខ្លួន និងនៅក្នុងប្រទេសផលិតកម្ម ។ ក្រោយពីបានចំណាយប្រាក់មួយចំនួនធំលើការផ្សាយពាណិជ្ជកម្ម និងផ្សាយដំណឹងក្នុងរយៈពេល ២-៣ ឆ្នាំ សហគ្រាសនាំចូលអាចពង្រីកទីផ្សារសំរាប់កំរាលព្រំ ដែលផលិតតាមការរចនារបស់ខ្លួន ។

ប្រការនេះនាំឱ្យផលិតករតូចតាចដទៃទៀត ក្នុងប្រទេស ខ នាំគ្នាផលិតកំរាលព្រំ ដែលមានរចនាបទដូចគ្នា ដើម្បីនាំចេញទៅកាន់ប្រទេស ក ដែរ ។ អ្នកនាំចូលក្នុងប្រទេស ក ព្យាយាមប្តឹងទៅអាជ្ញាធរកម្មសិទ្ធិបញ្ញា ក្នុងប្រទេស ខ ឱ្យបញ្ឈប់ផលិតកម្ម និងការនាំចេញដោយសហគ្រាសទាំងនេះ ដោយសំអាងលើសិទ្ធិផ្តាច់មុខរបស់ខ្លួនក្នុងការប្រើប្រាស់គំនូសឧស្សាហកម្មដែលចុះបញ្ជីការពារួច ។ ទោះជាយ៉ាងនេះក្តី ដោយសារមានការយឺតយ៉ាវក្នុងការការពារកម្មសិទ្ធិបញ្ញាក្នុងប្រទេស ខ នាំឱ្យអាជ្ញាធរក្នុងប្រទេស ខ មិនមានចាត់សកម្មភាពអ្វីសោះ ។ ពេលនោះ អ្នកនាំចូលបានសំរេចចិត្តបញ្ឈប់ទំនាក់ទំនងពាណិជ្ជកម្មនេះ ហើយផ្ទេរផលិតកម្មរបស់ខ្លួន ទៅកាន់ប្រទេសមួយទៀត ដែលមានកេរ្តិ៍ឈ្មោះក្នុងការពង្រឹងច្បាប់កម្មសិទ្ធិបញ្ញា ។

សេចក្តីសន្និដ្ឋាន

ជាការសរុបសេចក្តី ប្រសិនបើចង់ទាញប្រយោជន៍នៃភាពទន់ខ្សោយក្នុងពាណិជ្ជកម្ម ដែលទាក់ទងនឹងវិស័យកម្មសិទ្ធិបញ្ញាត្រូវចៀសវាងបាន វាជាប្រការចាំបាច់បំផុតចំពោះសហគ្រាសអាជីវកម្មទាំងអស់ ដែលពាក់ព័ន្ធនឹងពាណិជ្ជកម្មក្រៅប្រទេស ត្រូវអនុវត្តមិនត្រឹមតែបន្សាំខ្លួនទៅនឹងប្រព័ន្ធដែលបង្កើតឡើងដោយសារកិច្ចព្រមព្រៀងនេះទេ តែត្រូវយល់ឱ្យបានសព្វជ្រុងជ្រោយអំពីកាតព្វកិច្ច ដែលកិច្ចព្រមព្រៀងបានកំណត់ និងសិទ្ធិដែលផ្តល់ឱ្យដោយកិច្ចព្រមព្រៀងនេះ ។ សហគ្រាសទាំងនោះត្រូវធ្វើការសិក្សាតាមរយៈសមាគមរបស់ខ្លួននូវបញ្ហាជាក់ស្តែងអំពីការលក់ក្នុងទីផ្សារបរទេស និងបញ្ហាដែលកើតចេញពីការអនុវត្តន៍កិច្ចព្រមព្រៀង TRIPS។ សហគ្រាសទាំងនេះត្រូវជំរាបប្រាប់រដ្ឋាភិបាលអំពីការរកឃើញនៅក្នុងការសិក្សារបស់ខ្លួន ដែលអាចឱ្យតំណាងរដ្ឋាភិបាលធ្វើការចរចានៅក្នុងអំឡុងពេលពិនិត្យឡើងវិញ ប្រការទាំងឡាយ ដែលជាលទ្ធភាពមួយផ្តល់ឱ្យដោយកិច្ចព្រមព្រៀងនេះ ដើម្បីធ្វើការកែតំរូវប្រការទាំងនោះ ឱ្យឆ្លើយតបនឹងកង្វល់របស់សហគមន៍អាជីវកម្ម ។

ផ្នែកទីប្រាំមួយ

ប្រធានបទបន្ថែមនៅលើកម្មវិធីការងារ សំរាប់សិក្សា និងវិភាគរបស់ អង្គការពាណិជ្ជកម្មពិភពលោក

បណ្ណាល័យ
គ.ជ.អ.ប

ឧបសម្ព័ន្ធ ២១

ពាណិជ្ជកម្ម និងបរិស្ថាន

ការទិចត្ថន៍និន្នាការសកល

ក្នុងអំឡុងពេលពីរទសវត្សចុងក្រោយនេះ ការពាក់ព័ន្ធរវាងពាណិជ្ជកម្ម និងបរិស្ថានកាន់តែក្លាយទៅជាបញ្ហាមួយយ៉ាងសំខាន់ជាលំដាប់នៅក្នុងទំនាក់ទំនងពាណិជ្ជកម្មអន្តរជាតិ ។ ការយល់ដឹងច្រើនឡើងៗ អំពីតំរូវការការពារបរិស្ថាន និងការជំរុញការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាពនូវធនធានដែលមាន បាននាំអោយមានការកើនឡើងនូវវិធានការនយោបាយបរិស្ថានជាច្រើន ។ វិធានការទាំងនោះជាទូទៅត្រូវបានអនុវត្តឡើងដោយរដ្ឋាភិបាល តាមរយៈឧបករណ៍ជាបទបញ្ញត្តិ ឬសេដ្ឋកិច្ច ។ ក្នុងករណីមួយចំនួនគេបានប្រើប្រាស់ ឧបករណ៍ទាំងពីរប្រភេទនោះ ÷

វិធានការបទប្បញ្ញត្តិសំខាន់ៗ ដែលគេក៏ស្គាល់ថាជា " វិធានការបញ្ជារ និងត្រួតពិនិត្យ " មានដូចតទៅ ÷

- ☐ ស្តង់ដារផលិតផលដែលទាមទារអោយផលិតផលមួយដែលលក់នៅក្នុងទីផ្សារជាក់លាក់ណាមួយ ត្រូវគោរពតាមស្តង់ដារនោះ។
- ☐ បទប្បញ្ញត្តិនៅលើវិធីដំណើរការ និងផលិត(PPM) ព្រមទាំងស្តង់ដារនៅលើការបំពុលបរិស្ថាន
- ☐ ការហាមឃាត់លើការនាំចូល និងនាំចេញនូវផលិតផលដែលមានគ្រោះថ្នាក់ ឬអន្តរាយដល់សុខភាព
- ☐ ការដាក់កំហិតលើការនាំចូល និងនាំចេញ សំដៅថែរក្សានិងអភិវឌ្ឍន៍ប្រកបដោយនិរន្តភាពនូវធនធានធម្មជាតិ និង
- ☐ តំរូវការលើការវេចខ្ចប់ និងសរសេរផ្លាកទំនិញ ។

វិធានការណ៏សេដ្ឋកិច្ចរួមមាន ពន្ធលើផលិតផលដែលមានគ្រោះថ្នាក់ ឬអន្តរាយដល់សុខភាព អាករលើការបញ្ចេញជាតិពុល ឬវិធានការផ្សេងៗ ដែលផ្អែកទៅលើថ្លៃ និងការឧបត្ថម្ភធនចំពោះផ្នែកបរិស្ថាន ។

ជាទ្រឹស្តី បើប្រៀបទៅនឹងវិធានការណ៏ច្បាប់ វិធានការណ៏សេដ្ឋកិច្ច យ៉ាងហោចណាស់ ក៏ផ្តល់នូវឧត្តមភាពមួយចំនួនដែរ : ប្រសិទ្ធិភាពខ្ពស់ក្នុងចំណាយ ការលើកទឹកចិត្តជាអចិន្ត្រៃយ៍អោយកាត់បន្ថយការបំពុលបរិស្ថាន និងប្រភពចំណូលសំរាប់រដ្ឋាភិបាល ។ ប៉ុន្តែជាក់ស្តែង សំរាប់មូលហេតុសេដ្ឋកិច្ច និងរដ្ឋបាល រដ្ឋាភិបាលអាចយល់ថា បទប្បញ្ញត្តិ និងការត្រួតពិនិត្យដោយ ផ្ទាល់មានលក្ខណៈសមស្រប និងមានប្រសិទ្ធិភាពជាង នៅក្នុងស្ថានភាពមួយចំនួន ។ ឧទាហរណ៍ វិធានការជាបទប្បញ្ញត្តិអាចត្រូវយកមកអនុវត្តនៅទីណាដែលជាក់ច្បាស់ថា ការបញ្ចេញនូវធាតុពុលណាមួយ ឬការប្រើប្រាស់ផលិតផល ឬ របស់គ្រោះថ្នាក់ ត្រូវតែហាមឃាត់ជាដាច់ខាត។ នៅក្នុងកាលៈទេសៈខ្លះទៀត វិធានការគ្រប់គ្រង អាចយកមកប្រើបន្ថែម នៅលើវិធានការសេដ្ឋកិច្ច ដើម្បីពង្រឹងការអនុវត្តន៍ ។

ការជ្រើសរើសនូវវិធានការរបស់ប្រទេសមួយ ជាវិធានការច្បាប់ ឬសេដ្ឋកិច្ច អាស្រ័យទៅលើភាពខ្លាំងនិង ភាពខ្សោយនៃ រចនាសម្ព័ន្ធនយោបាយ និង រដ្ឋបាលរបស់គេ ហើយត្រូវកំណត់ទៅតាមករណីនីមួយៗ។ ការជ្រើសរើសនេះត្រូវយកចិត្តទុកដាក់ លើកត្តាទាំងឡាយដូចជា ប្រសិទ្ធិភាពនៃវិធានការណ៏ ចំពោះបរិស្ថាន ប្រសិទ្ធិភាពសេដ្ឋកិច្ច ការចំណាយ និង លទ្ធភាពអាចអនុវត្ត របស់រដ្ឋបាលភាពជាម្ចាស់ និងការយល់ព្រមពីសាធារណៈជន ។ វិធានការណ៏នយោបាយបរិស្ថានរបស់រដ្ឋាភិបាល អាចមានឥទ្ធិពលដល់ផ្នែកពាណិជ្ជកម្មជាច្រើនសណ្ឋាន ។ នៅក្នុងនោះ មានចំណុចបី ដែលគួរកត់សំគាល់ ។

ទីមួយ : ការបារម្ភថា ស្តង់ដាបរិស្ថានអាចកែប្រែលក្ខខ័ណ្ឌប្រកួតប្រជែង ។ ផលិតករនៅក្នុងប្រទេសដែលមានស្តង់ដារបរិស្ថានតឹងរឹង មានការព្រួយបារម្ភអំពីឥទ្ធិពលនៃស្តង់ដារនោះទៅលើចំណាយ និងសមត្ថភាពរបស់គេ ក្នុងការប្រកួតប្រជែងនៅក្នុងទីផ្សារពិភពលោក។

ទីពីរ : ផលិតករនៅក្នុងប្រទេសដែលមានស្តង់ដារពុំសូវតឹងតែង (ជាឧទាហរណ៍ប្រទេសកំពុងអភិវឌ្ឍន៍ និង ប្រទេសដែលមានសេដ្ឋកិច្ចក្នុងអន្តរកាល) ភ័យព្រួយថា ផលិតផលរបស់ខ្លួនអាចរងនូវវិធានការពាណិជ្ជកម្ម ដោយហេតុថា ផលិតផលនេះបានធ្វើឡើងដោយឧស្សាហកម្ម ដែលពុំគោរពតាមស្តង់ដារបំពុលបរិស្ថានខ្ពស់ ឬស្តង់ដារបញ្ចេញ គ្រឿងបំពុលរបស់ប្រទេសជាអ្នកនាំចូល ។

ទីបី : មានការបារម្ភច្រើនឡើងៗ របស់សាធារណជន ពីបញ្ហារួមជាសកល (ឧទាហរណ៍ ការបំផ្លាញស្រទាប់អូសូន និងបំរែបំរួលបរិយាកាស) ពីប្រភេទប្លែកៗគ្នា និងការប្រើប្រាស់នូវពពួកសត្វ ។ ចំពោះនយោបាយពាណិជ្ជកម្ម ការនេះ បានលើកឡើងនូវសំនួរមួយយ៉ាងសំខាន់ថា តើកិច្ចព្រមព្រៀងបរិស្ថានជាអន្តរជាតិ ដែលពាក់ព័ន្ធនឹងបញ្ហាបរិស្ថានជាសកល គួរតែមានចែងនូវបទបញ្ញត្តិមួយចំនួន ទាមទារសមាជិកទាំងឡាយ អោយដាក់ដែនកំណត់ជាមួយអ្នកពុំមែនជាគូភាគីរបស់ខ្លួន ដើម្បីបង្ខំគេអោយចូលរួមនៅក្នុងកិច្ចព្រមព្រៀងនោះដែរឬទេ ?

បទបញ្ញត្តិរបស់អង្គការពាណិជ្ជកម្មពិភពលោក (WTO)

កិច្ចព្រមព្រៀងបង្កើតអង្គការពាណិជ្ជកម្មពិភពលោកបានលើកឡើងនូវ " បញ្ហាទាក់ទង នឹងផ្នែកពាណិជ្ជកម្ម នៃគោលនយោបាយបរិស្ថាន " យ៉ាងច្បាស់នៅក្នុងអាណត្តិរបស់ WTO ។ បុព្វកថានៃកិច្ចព្រមព្រៀងចែងថា គោលដៅនៃកិច្ចព្រមព្រៀងសំដៅ "លើកស្ទួយកំរិតជីវភាព និងធានាភាពមានការងារធ្វើយ៉ាងពេញលេញ "តាមរយៈ " ការពង្រីកផលិតកម្ម និងពាណិជ្ជកម្មលើទំនិញ និងសេវាកម្ម " និងត្រូវសំរេចបានដោយប្រើប្រាស់យ៉ាងល្អនូវធនធានរបស់ពិភពលោក សមស្របទៅតាមគោលដៅនៃការអភិវឌ្ឍន៍ប្រកបដោយសេរីភាព សំដៅការពារ និងរក្សាបរិស្ថាន..... តាមវិធីមួយដែលសមស្របតាមតំរូវការនិងការបារម្ភ នៅគ្រប់ថ្នាក់ទាំងអស់នៃការអភិវឌ្ឍន៍សេដ្ឋកិច្ច " ។

បទបញ្ញត្តិសំខាន់ ៗ សំរាប់ប្រតិបត្តិការពាក់ពន្ធ័នឹងវិធានការពាណិជ្ជកម្មរបស់រដ្ឋាភិបាលចំពោះមូលហេតុបរិស្ថាន មានចែងនៅក្នុង GATT ១៩៩៤ ។ ប៉ុន្តែ GATT ពុំមានអធិប្បាយអ្វីដោយផ្ទាល់អំពីបញ្ហាបរិស្ថានឡើយ ជាបឋមគឺ ដោយសារក្នុងពេលចរចាជាដំបូង អំពីអត្ថបទ GATT គេនៅមិនទាន់ស្គាល់ពីផលប៉ះពាល់ទាំងឡាយនៃការខូចខាតបរិស្ថាន និងធម្មជាតិ ដែលបណ្តាលមកពីការបំពុលបរិស្ថាន ឬការធ្វើអាជីវកម្មហួសហេតុ លើធនធានធម្មជាតិនៅឡើយទេ ។

ករណីលើកលែងជាទូទៅដែលមានចែងនៅក្នុងមាត្រា XX នៃ GATT ១៩៩៤ អាចអោយបណ្តាប្រទេស យកមកអនុវត្តបាន ដើម្បីរៀបចំវិធានការសេដ្ឋកិច្ច សំដៅសំរេចបាននូវគោលដៅបរិស្ថាន ប្រសិនបើគេគោរពបាននូវលក្ខខ័ណ្ឌដែលបានកំណត់ ។ មាត្រានោះអនុញ្ញាតិអោយបណ្តាប្រទេសធ្វើការហាមឃាត់ ឬ ដាក់កំហិតទៀតៗ ដែលពុំទាន់អនុញ្ញាតិអោយនៅក្នុងបទបញ្ញត្តិនៃ GATT ១៩៩៩ ឬប្រសិនបើវិធានការនោះ ÷

- ☐ មានការចាំបាច់ត្រូវការពារជីវិត និងសុខភាពមនុស្ស សត្វ និងរុក្ខជាតិ (មាត្រា XX(a) និង
- ☐ មានពាក់ពន្ធ័ទៅនឹងការគាំពារធនធានធម្មជាតិដែលហោចទៅៗ ប្រសិនបើវិធាននោះត្រូវបានអនុវត្តឡើង គួបផ្សំជាមួយការដាក់ដែនកំណត់ទៅលើផលិតកម្មនិងការប្រើប្រាស់ក្នុងស្រុក (មាត្រា XX(g) ។

នៅក្នុងទំនាស់មួយថ្មីៗ នេះ ដែលបានលើកឡើងចំពោះមុខ WTO (អំពីការនាំចូលនូវបង្គារ (shrimp) និងផលិតផលព្រៃនព្រមទាំងឥទ្ធិពលរបស់វាទៅលើអណ្តើកសមុទ្រ) ក្រុមឧទ្ធរណ៍បានចេញបទប្បញ្ញត្តិថា ពាក្យ " ធនធានធម្មជាតិដែលហោចទៅ ៗ " សំរាប់ GATT មាត្រាទី XX (g) ត្រូវមានន័យមិនតែចំពោះ ធនធានធម្មជាតិជា "រ៉ែ" ឬ " គ្មានជីវិត " ប៉ុណ្ណោះទេ គឺត្រូវរួមបញ្ចូលទាំងធនធានធម្មជាតិដែល " អាចបង្កើតជាថ្មីបាន " និងដែល " មានជីវិត " ដូចជាអណ្តើកសមុទ្រផង ។

ដូច្នេះវិធានការដាក់កំហិតលើពាណិជ្ជកម្មទាំងឡាយ ដែលធ្វើឡើងសមស្របទៅតាមប្រការនៃមាត្រាទី XX ត្រូវតែបំពេញនូវលក្ខខ័ណ្ឌដូចតទៅ ÷

- ☐ វិធានការនេះពុំមែនជាមធ្យោបាយសំរាប់ធ្វើការរើសអើង ដោយពុំសមហេតុផលចំពោះ ទីណាដែលមានលក្ខខ័ណ្ឌដូចគ្នានេះ (គោលការណ៍ស្តីពីការមិនរើសអើងរបស់ GATT) ។
- ☐ វិធានការនោះពុំមែនជាការដាក់កំហិតក្លែងក្លាយចំពោះពាណិជ្ជកម្មឡើយ ។

ក្រៅពីបទបញ្ញត្តិរបស់ GATT ១៩៩៤ នៅមានបទបញ្ញត្តិមួយចំនួនទៀតរបស់កិច្ចព្រមព្រៀងខ្លះៗ ដែលទាក់ទងនឹង WTO ដែលមានសារៈសំខាន់ចំពោះទំនាក់ទំនងរវាងពាណិជ្ជកម្ម និងបរិស្ថាន។ ក្នុងនោះរួមមាន បទបញ្ញត្តិស្តីពីស្តង់ដារនៅក្នុងកិច្ចព្រមព្រៀង SPS និង TBT ព្រមទាំងបទបញ្ញត្តិស្តីពីឧបត្ថម្ភធន នៅក្នុងកិច្ចព្រមព្រៀង SCM និងកសិកម្ម ។

បញ្ហាឆាក់ឆងនិងពាណិជ្ជកម្ម

ភារៈកិច្ចទទួលខុសត្រូវលើការងារ WTO ផ្នែកពាណិជ្ជកម្ម និងបរិស្ថានត្រូវបានប្រគល់អោយទៅ គណៈកម្មាធិការអចិន្ត្រៃយ៍ផ្នែកពាណិជ្ជកម្ម និងបរិស្ថាន (CTE) ។ ដូច្នេះការពិភាក្សាអំពីផលប៉ះពាល់ទៅលើពាណិជ្ជកម្មនៃវិធានការរបស់ រដ្ឋាភិបាលក្នុងគោលដៅបរិស្ថាន ត្រូវធ្វើឡើងនៅក្នុងគណៈកម្មាធិការនោះ ហើយក៏មានធ្វើឡើងនៅក្នុងគណៈកម្មាធិការដែល បង្កើតឡើងក្រោមកិច្ចព្រមព្រៀង WTO នីមួយៗ ដែលបានរៀបរាប់ពីខាងលើដែរ ។

ជំពូកបន្ត និងពិពណ៌នាអំពីបញ្ហាពាណិជ្ជកម្ម ដែលនឹងបកស្រាយនៅក្នុងក្របខ័ណ្ឌនៃបទបញ្ញត្តិទាំងឡាយរបស់ច្បាប់ WTO។ បញ្ហា ពិភាក្សាមានរាយដូចខាងក្រោម ÷

- ☐ វិធានការបរិស្ថានដែលមានឥទ្ធិពលសំខាន់ៗ ទៅលើពាណិជ្ជកម្ម និងបទបញ្ញត្តិនៃច្បាប់ WTO
  - ការប្រើប្រាស់នូវវិធីដំណើរការ និងផលិតនៅក្នុងបញ្ញត្តិបរិស្ថាន
  - បទបញ្ញត្តិលើការវេចខ្ចប់
  - ការដាក់ស្លាកសញ្ញាបរិស្ថាន
  - ពន្ធលើការប្រើប្រាស់ ឬពន្ធផ្សេងៗ ដែលបង្កើតឡើងក្នុងគោលដៅបរិស្ថាន ។
- ☐ បទបញ្ញត្តិពាណិជ្ជកម្មទាំងឡាយ នៅក្នុងកិច្ចព្រមព្រៀងពហុភាគីផ្នែកបរិស្ថាន
- ☐ គុណប្រយោជន៍ដល់បរិស្ថាន នៃសេរីភាវូបនីយកម្មពាណិជ្ជកម្ម

វិធានការបរិស្ថានដែលមានឥទ្ធិពលសំខាន់ៗទៅលើពាណិជ្ជកម្ម និងបទបញ្ញត្តិនៃច្បាប់ WTO

ការប្រើប្រាស់នូវវិធីដំណើរការ និងផលិតនៅក្នុងបទបញ្ញត្តិបរិស្ថាន

ជាទូទៅស្តង់ដារអាចត្រូវបែងចែកជាពីរប្រភេទ: ស្តង់ដារផលិតផល និងវិធីដំណើរការនិងផលិត (PPH)។ ស្តង់ដារផលិតផលកំណត់នូវចំណុចពិសេសចំពោះលក្ខណៈផលិតផល (ដូចជាសមិទ្ធិផលសុវត្ថិភាពនៃផលិតផល) ព្រមទាំងបទបញ្ញត្តិ លើការវេចខ្ចប់ និងសរសេរស្លាកទំនិញ ។ អ្វីទាំងនេះចាំបាច់ ត្រូវប្រើការក្នុងដំណាក់កាលផលិតកម្ម ពោលគឺមុនពេលដែលទំនិញ ត្រូវបានដាក់លក់នៅលើទីផ្សារ ។

ភាពសមហេតុផលមានតែមួយគឺ ប្រទេសនីមួយៗ គួរមានសិទ្ធិអធិបតេយ្យភាព ក្នុងការទាមទារអោយផលិតផលនាំចូល ត្រូវតែគោរពនូវស្តង់ដារផលិតផល ដែលបានអនុវត្តឡើង ចំពោះទំនិញផលិតនៅក្នុងស្រុក ក្នុងគោលបំណងការពារបរិស្ថាន ឬ សុខភាព និងសុវត្ថិភាពរបស់ប្រជាជន ឬ ជីវិតរបស់សត្វគេ ។ កិច្ចព្រមព្រៀង SPS និង TBT តំរូវឱ្យបណ្តាប្រទេសប្រើប្រាស់ស្តង់ដារអន្តរជាតិ ក្នុងការរៀបចំធ្វើស្តង់ដារប្រភេទនោះ ។ នៅទីណាដែលស្តង់ដារអន្តរជាតិអវត្តមាន ឬ ចាត់ទុកថាពុំសមស្រប បណ្តាប្រទេសត្រូវធានាថាស្តង់ដារមិនត្រូវធ្វើឡើង ឬ អនុវត្តនៅក្នុងផ្លូវណាមួយដែលបង្កើតជារបាំងមិនចាំបាច់ចំពោះពាណិជ្ជកម្មឡើយ ។

វិធាននៅក្នុងកិច្ចព្រមព្រៀង SPS និង TBT ពុំអនុញ្ញាតិអោយបណ្តាប្រទេសហាមឃាត់ ឬ ដាក់កំហិតលើការនាំចូល ដោយមូលហេតុថា ទំនិញនាំចូលនោះពុំបានផលិតសមស្របទៅតាមស្តង់ដារ PPM ដែលបានអនុវត្តចំពោះឧស្សាហកម្មក្នុងស្រុកឡើយ។ កិច្ចព្រមព្រៀង TBT មានអញ្ញត្រកម្មតែមួយគត់ចំពោះវិធាននោះ : ប្រទេសមួយអាចធ្វើហាមឃាត់ការនាំចូលនូវផលិតផលមួយនៅពេលណាដែល PPM ដែលបានប្រើនោះ មានផលប៉ះពាល់ទៅលើលក្ខណៈ ឬ គុណភាពរបស់ផលិតផល ។

ក៏ប៉ុន្តែប្រទេសនាំចូលមិនអាចហាមឃាត់ដល់ការនាំចូល ដោយគ្រាន់តែផលិតផលនោះ ត្រូវបានផលិតឡើងនៅក្នុងរោងចក្រមួយដែលពុំសមស្របតាមស្តង់ដារជាតិ ស្តីពីការបំពុលទឹក ឬ ខ្យល់តែម្យ៉ាងនោះ ឬ ក៏ដោយសារផលិតផលនោះ ពុំបានផលិតឡើងតាមវិធីផលិតរបស់ប្រទេសនោះឡើយ ។ ការទាមទារបែបនេះ មានន័យដូចគ្នានឹងការតំរូវអោយប្រទេសជាអ្នកនាំចេញអនុវត្តនូវ PPM របស់ប្រទេសនាំចូល ដែលប្រទេសនាំចេញ គ្មានបំណង នឹងចង់ប្រើប្រាស់ឡើយ ដោយមូលហេតុល័ក្ខខ័ណ្ឌបរិស្ថាន និងអេកូឡូស៊ីរបស់ខ្លួន ។

ថ្វីបើមានច្បាប់ WTO ហើយក្តី ក៏នៅមានការជំរុញពីអ្នកគាំទ្របរិស្ថាន ទាមទារអោយរដ្ឋាភិបាលបង្កើតច្បាប់ ដែលមានឥទ្ធិពលទៅលើផ្នែកពាណិជ្ជកម្ម ពីព្រោះការនាំចូលត្រូវបានហាមឃាត់ ដោយសារតែផលិតផលពុំបានផលិតឡើងតាមវិធីផលិតដែលកំណត់ដោយច្បាប់នោះឡើយ ។ វិធីបែបនេះ រួមមានដូចតទៅ ÷

- ☐ ការអនុវត្តន៍ការគ្រប់គ្រងធនធានព្រៃឈើ
- ☐ បទដ្ឋានក្នុងការចាប់ត្រី
- ☐ វិធីបំប៉នសត្វអោយធំ ឬ បង្កើនសមត្ថភាពផ្តល់ទឹកដោះរបស់សត្វគោ និង
- ☐ វិធីសម្លាប់សត្វ

ឧទាហរណ៍ នៅក្នុងប្រទេសហូឡង់ គេបានអនុញ្ញាត្តិអោយនាំចូលឈើនិងផលិតផល តែនៅពេលណាដែលការនាំចូលនោះមានភ្ជាប់ជាមួយនូវវិញ្ញាបនប័ត្ររបស់អាជ្ញាធរមានសមត្ថកិច្ចបញ្ជាក់ថា វត្ថុធាតុដើមជាឈើនោះត្រូវបានយកមក ពីក្នុងព្រៃដែលមានការគ្រប់គ្រងប្រកបដោយនិរន្តភាព ។ សហគមន៍អឺរ៉ុប បានហាមឃាត់ការនាំចូលរោមសត្វ ដែលបានមកពីការចាប់សត្វបាន ដោយដាក់អន្ទាក់វាយជាប់ជើង ។ សហរដ្ឋអាមេរិក មានច្បាប់ដាក់កំហិតលើការនាំចូលត្រី Tuna ពីប្រទេសណាដែលពុំបានទាមទារអោយអ្នកនេសាទរបស់ខ្លួន ខិតខំរាំងមិនអោយមានការសម្លាប់ត្រី Dolphins ដោយមិនចាំបាច់នៅក្នុងពេលធ្វើនេសាទ ដែលនេះជាកាតព្វកិច្ចមួយសំរាប់អ្នកនេសាទនៃសហរដ្ឋអាមេរិក ។ ដ៏ដូចគ្នាដែរ សហរដ្ឋអាមេរិក ធ្វើការហាមឃាត់ នូវការនាំចូលក្រោនពីបណ្តាប្រទេសដែលពុំគោរពតាមស្តង់ដារជាតិ សំដៅរាំងនូវការប្រមូលអណ្តើកសមុទ្រ ក្នុងខណៈធ្វើការអូសថ្នងចាប់ក្រោន ។

ស្តង់ដារដែលបានប្រើសំរាប់កំណត់នូវវិធានការពាណិជ្ជកម្មទាំងនោះ ជាទូទៅគឺពុំបាន ផ្អែកទៅលើគោលការណ៍ វិទ្យាសាស្ត្រទេ ប៉ុន្តែ វាឆ្លុះបញ្ចាំងនូវតំលៃដែលគេចង់បាននៅក្នុងប្រទេសអ្នកនាំចូល ។ នៅក្នុងកាលៈទេសៈខ្លះ ដូចជានៅក្នុងករណីស្នើអោយមានការដាក់កំហិតលើការនាំចូលឈើពីតំបន់ត្រូពិច ស្តង់ដារអាចនឹងមានមូលដ្ឋានមួយផ្នែក ផ្អែកលើមតិវិទ្យាសាស្ត្រ ហើយមួយផ្នែកទៀតផ្អែកលើតំលៃនិយមរបស់ប្រទេសអ្នកនាំចូល ។ វិធានការបែបនេះ មានន័យថាជាការកំណត់ នូវតំលៃមួយសំរាប់ប្រទេស អ្នកនាំចេញដោយប្រទេសអ្នកនាំចូល ។

វិធានការរបស់សហរដ្ឋអាមេរិកហាមឃាត់នូវការនាំចូល Tuna និងព្រោនត្រូវលើកឡើងចំពោះមុខ GATT/WTO នៅក្នុងក្របខ័ណ្ឌនៃនីតិវិធីដោះស្រាយវិវាទ ដោយបណ្តាប្រទេសដែលយល់ថា ពាណិជ្ជកម្មនាំចេញរបស់ខ្លួនបានទទួលរងនូវផលប៉ះពាល់អវិជ្ជមាន ។ នៅក្នុងករណីទាំងពីរនេះ លទ្ធផលនៃការវិនិច្ឆ័យបានប្រឆាំងនឹងសហរដ្ឋអាមេរិក ។ ក្រុមអ្នកច្បាប់ និងឧទ្ធរណ៍មានមតិថា វិធានការទាំងនោះពុំសមស្របឡើយ ផ្អែកតាមករណីលើកលែងជាទូទៅ ដែលបានអនុញ្ញាតក្នុងមាត្រា២០ ដោយវិធានការ នោះបានអនុវត្តដោយមានការរើសអើង ហើយមានលក្ខណៈជារបាំងមិនសមស្របចំពោះពាណិជ្ជកម្ម ។ ពួកគេបានស្នើបន្ថែមថា ដោយវិធានការនោះមានន័យជាការអនុវត្តន៍នូវស្តង់ដារ PPH របស់ប្រទេសមួយទៅលើប្រទេសដទៃក្រៅពីដែនដីរបស់ខ្លួន បណ្តាប្រទេសនាំចូល ដែលនឹកគិតដល់វិធានការទាំងឡាយនោះ គួរពិនិត្យរកលទ្ធភាពធ្វើការចរចាជាកិច្ចព្រមព្រៀងសហប្រតិបត្តិការ អន្តរជាតិ ក្នុងចំណោមបណ្តាប្រទេសនាំចូល និងនាំចេញ ដែលពាក់ព័ន្ធទាំងអស់ទៅវិញ ដើម្បីធានាអោយវិធានការនោះសមស្របទៅ តាមបទបញ្ញត្តិនៃមាត្រា២០ ។

ប៉ុន្តែ ការលំបាកដែលអាចកើតមានពីការចចារធ្វើកិច្ចព្រមព្រៀងសហប្រតិបត្តិការអន្តរជាតិ មានមិនតិចជាងអប្បបរមាទេ ។ ការចចារនោះទាមទារពេលវេលាច្រើន ហើយពួកអ្នកបរិស្ថាននិយម ដែលទាមទារអោយមានសកម្មភាពភ្លាមៗ អាចនឹងមិនយល់ព្រមអោយរដ្ឋាភិបាលខ្លួនពន្យាពេលធ្វើសកម្មភាពរហូតដល់មានការព្រមព្រៀង ជាឯកច្ឆ័ននៅថ្នាក់អន្តរជាតិឡើយ ។ លើសពីនេះទៀត ការចចារនោះច្រើនតែមានលក្ខណៈស្មុគស្មាញ ដោយក្នុងករណីជាច្រើន PPM ដែលស្នើឡើងនោះ ពុំបានផ្អែកទៅលើមតិវិទ្យាសាស្ត្រ តែគឺទៅលើតំលៃដែលបណ្តាប្រទេសខ្លះ ឬ ក្រុមប្រទេសមួយចំនួន ចាត់ទុកជាមានសារៈសំខាន់ ។ តំលៃដែលអាចមានសារៈសំខាន់ចំពោះសង្គមអ្នកមានធូធារ ពុំចាំបាច់នឹងទទួលការគាំទ្រដូចគ្នាពីសំណាក់សង្គម ដែលមានប្រាក់ចំណូលតិច និងដែលមានអាទិភាពដោយឡែកឡើយ។

តំរូវការលើការវេចខ្ចប់

គោលដៅនៃបទបញ្ញត្តិលើការវេចខ្ចប់

កញ្ចប់ ឬ ការវេចខ្ចប់ អាចអោយនិយមន័យជាសម្ភារៈ ឬអ្វីដែលប្រើសំរាប់ការពារ ឬដាក់របស់ ឬ ផលិតផលណាមួយ ។

គោលដៅបរិស្ថានសំខាន់ដែលនាំអោយមានបទបញ្ញត្តិថ្មីលើការវេចខ្ចប់ គឺសំដៅកាត់បន្ថយបរិមាណសម្ភារៈវេចខ្ចប់ នៅក្នុងកាកសំណល់ ជាពិសេសសម្ភារៈវេចខ្ចប់ ដែលត្រូវកំទេចចោលតាមរយៈការដុតរំលាយ ឬកប់ក្នុងដី ។ គេបានប៉ាន់ស្មាន ថាពី ២៥% ទៅ ៣០% នៃទម្ងន់កាកសំណល់របស់គ្រួសារសាមញ្ញមួយនៃបណ្តាប្រទេសអឺរ៉ុប គឺជាប្រភេទសម្ភារៈខ្ចប់វេច ។ ភាគច្រើនប្រទេសនោះអត់មានទីកន្លែងសំរាប់កប់សំរាម ដូច្នេះបទបញ្ញត្តិថ្មី មានគោលដៅជំរុញផលិតករក្នុងស្រុក អ្នកនាំចូល និងក្រុមហ៊ុនបរទេសអោយកាត់បន្ថយកាកសំណល់ជាសម្ភារៈវេចខ្ចប់ ដែលត្រូវកំទេចចោលជាដើម តាមរយៈការស្នើសុំអោយ គេប្រើប្រាស់សម្ភារៈវេចខ្ចប់ជាច្រើនលើក និងធ្វើការច្នៃឡើងវិញនូវសំភារៈដែលមិនអាចប្រើបានច្រើនដង ។ ទន្ទឹមនោះបទប្បញ្ញត្តិ លើការវេចខ្ចប់អាចនឹងត្រូវបានធ្វើឡើង ដើម្បីកាត់បន្ថយប្រពលភាពធនធាននៃសម្ភារៈវេចខ្ចប់ (ពោលគឺតាមរយៈការមិនជំរុញ អោយប្រើប្រាស់សម្ភារៈដែលធ្វើឡើងដោយប្រើថាមពលទឹក ខ្យល់អាកាសយ៉ាងច្រើន) ឬតាមការត្រួតពិនិត្យលើហានិភ័យ ដែលមាននៅជាមួយនឹងកញ្ចប់ប្រភេទណាមួយនោះ ។

ប្រភេទនៃបញ្ញត្តិ

វិធានការនយោបាយរបស់រដ្ឋាភិបាល សំដៅសំរេចបាននូវគោលដៅខាងលើអាច និងរួមបញ្ចូលនូវឧបករណ៍បញ្ជា និងត្រួតពិនិត្យ (ដូចជាការហាមឃាត់ទាំងស្រុង ឬការទាមទារអោយមានការប្រមូលវិញ ឬធ្វើការកែច្នៃ) ឬក៏ជាឧបករណ៍សេដ្ឋកិច្ច ដែលជាបឋមសំដៅបង្កើតការទទួលខុសត្រូវដោយខ្លួនឯងផ្ទាល់ ទៅលើផលប៉ះពាល់ទៅក្រៅនៃផលិតកម្មសម្ភារៈ វេចខ្ចប់ លើការប្រើប្រាស់ ឬបោះចោល និងសំដៅបង្កឥទ្ធិពលលើអាកប្បកិរិយាអ្នកប្រើប្រាស់ តាមយន្តការថ្លៃ ។ វណ្ឌ ៥៤ បង្ហាញនូវលក្ខណៈសំខាន់ៗនៃវិធានការដែលប្រើ ក្នុងខណៈដែលបទបញ្ញត្តិមួយចំនួនត្រូវបានអនុវត្តដូចៗគ្នា ក្នុងទូទាំងផ្ទៃប្រទេស នៅក្នុងក្របខ័ណ្ឌច្បាប់របស់ជាតិ តែក៏ពុំមានជារឿងប្លែកដែរ រាប់អង្គភាពខេត្ត ឬ មូលដ្ឋាន គេបានបង្កើតនូវយន្តការសងប្រាក់បញ្ញើវិញ ឬគំរោងអ្វីផ្សេងទៀត សំរាប់ការប្រមូលសំរាមជាសម្ភារៈវេចខ្ចប់ នៅទីណាដែលគេយល់ថា យន្តការនោះមានសារសំខាន់ចំពោះការបំបាត់បានយ៉ាងមានប្រសិទ្ធិភាពនូវសំរាមជាសម្ភារៈវេចខ្ចប់ ។

ផ្លូវការផ្នែកពាណិជ្ជកម្ម នៃបទបញ្ញត្តិលើការវេចខ្ចប់

ទោះបីជាបទបញ្ញត្តិលើការវេចខ្ចប់ ត្រូវបានអនុវត្តដោយគ្មានការរើសអើងរវាងផលិតផលក្នុងស្រុក និងផលិតផលនាំចូលក្តី ក៏បទបញ្ញត្តិនេះអាចនឹងបង្កជាបញ្ហាពិសេស ឬ ការលំបាកចំពោះបរទេសជាអ្នកផ្គត់ផ្គង់ដែរ ជាពិសេសចំពោះស្ថានភាពដូចទៅ ÷

ធណ្ឌ ៥៨

ឧទាហរណ៍ នៃបទបញ្ញត្តិលើការវេចខ្ចប់ ដែលបានបង្កើតឡើងសំរាប់មូលហេតុបរិស្ថាន

វិធានការជាបទបញ្ញត្តិ

ក្នុងនោះរួមមានវិធានការហាមឃាត់នូវការប្រើប្រាស់ ÷

- ☐ *សម្ភារៈវេចខ្ចប់ដែលមានសារធាតុ សំណ បារ៉ត Cadmium*
- ☐ *ធុងដែលពុំអាចប្រើ ឬកែច្នៃជាថ្មីបាន និង*
- ☐ *សម្ភារៈវេចខ្ចប់ដែលពុំមាន ឬ មានសារធាតុដែលអាចកែច្នៃប្រើជាថ្មីបាន ក្នុងសមាមាត្រមួយដែលទាបជាងការកំណត់ ។*

ប្រព័ន្ធសងប្រាក់បញ្ញើអោយវិញ (DRS) : បណ្តាប្រទេសមួយចំនួនបានបង្កើតនូវប្រព័ន្ធសងប្រាក់បញ្ញើអោយវិញជាកាតព្វកិច្ចចំពោះកំប៉ុងស្រាបៀរ និងភេសជ្ជៈ ។ ប្រទេសខ្លះទៀតបានពង្រីកប្រព័ន្ធនេះអោយគ្របដណ្តប់ទៅលើកំប៉ុងដាក់ម្សៅសាប៊ូ និងថ្នាំពណ៌ ។ ដោយអ្នកប្រើប្រាស់អាចទារយកប្រាក់បញ្ញើបានវិញ តែនៅពេលណាដែលខ្លួនបានប្រគល់កំប៉ុងនោះអោយវិញ ហើយប្រព័ន្ធនោះបានបង្កើតនូវការលើកទឹកចិត្តដល់ពួកគេអោយធ្វើដូច្នេះ ។

ច្បាប់កែច្នៃឡើងវិញ ឬ ប្រើប្រាស់ឡើងវិញ ជាកាតព្វកិច្ច : ដើម្បីសំរួលនូវការកែច្នៃប្រើឡើងវិញនូវសំរាមជាសម្ភារៈវេចខ្ចប់ ច្បាប់របស់ប្រទេសខ្លះៗ បានទាមទារអោយបណ្តាគ្រួសារទាំងឡាយធ្វើការបែងចែកផ្សេងៗគ្នា នូវសំរាមតាមលក្ខណៈវេចខ្ចប់នៃប្រភេទនិមួយៗ (ឧទាហរណ៍កំប៉ុង ជ័រ និងក្រដាស) សំរាប់ធ្វើការប្រមូលដាច់ដោយឡែកពីគ្នា ។

ឧបករណ៍សេដ្ឋកិច្ច ពន្ធលើវត្ថុធាតុដើម :

ពន្ធនេះអាចត្រូវបានយកនៅលើវត្ថុធាតុដើម ប្រើសំរាប់ផលិតកម្មសម្ភារៈវេចខ្ចប់ ។ គោលបំណងនៃពន្ធបែបនេះគឺសំដៅកាត់បន្ថយការប្រើប្រាស់វត្ថុធាតុដើម ជាគុណប្រយោជន៍ដល់ការប្រើវត្ថុធាតុបានពីការកែច្នៃឡើងវិញ ។

កំរៃលើផលិតផល : នេះជាប្រាក់ដែលយកលើសម្ភារៈវេចខ្ចប់ ។ កំរៃនេះ ត្រូវបានប្រើសំរាប់ជំរុញការប្រើប្រាស់សម្ភារៈវេចខ្ចប់ ដែលមានលក្ខណៈមិនប្រឆាំងនឹងបរិស្ថាន ។ ឧទាហរណ៍ សម្ភារៈវេចខ្ចប់ដែលផលិតឡើង អំពីសារធាតុកែច្នៃប្រើឡើងវិញទាំងស្រុង អាចនឹងរងការលើកលែងពន្ធ ក្នុងខណៈដែលខ្លះទៀតធ្វើពីសារធាតុកែច្នៃប្រើឡើងវិញ តែមួយភាគណានោះ ត្រូវរងនូវការបង់កំរៃមួយទាបបន្តិច ។ឯកំរៃខ្ពស់ត្រូវបង់ទៅលើសំបកកញ្ចប់ណាដែលមិនអាចកែច្នៃប្រើឡើងវិញ ឬ មិនអាចប្រើជាថ្មីម្តងទៀតបាន ។

កិច្ចព្រមព្រៀងសហប្រតិបត្តិការ

ជាបន្ថែមលើនេះ រោងចក្រឧស្សាហកម្មអាចយល់ព្រមគោរពតាមច្បាប់ណែនាំលើមូលដ្ឋានស្ម័គ្រចិត្ត ដែលកើតឡើងពីការចរចាគ្នា នៅក្នុងសមាគមវិស័យឯកជន ក្នុងគោលបំណងកាត់បន្ថយការបង្កើតសំរាមជាសម្ភារៈវេចខ្ចប់ថ្មីៗ និងបង្កើតឡើងនូវការប្រើប្រាស់សម្ភារៈវេចខ្ចប់ដែលប្រើម្តងទៀតបាន ឬ ដែលអាចកែច្នៃប្រើឡើងវិញបាន ។

ប្រភព និងទិសដៅនៃការហូរចូល FDI ទៅកាន់ប្រទេសកំពុងអភិវឌ្ឍន៍

ប្រភព

ការវិនិយោគនៅក្នុងតំបន់ជាច្រើននៃប្រទេសកំពុងអភិវឌ្ឍន៍ បានធ្វើឡើងជាលំហមដោយប្រទេស/តំបន់ជឿនលឿន ចំនួនបី ។ សហគមន៍អឺរ៉ុប គឺជាប្រភពនៃការវិនិយោគច្រើនបំផុតនៅអាហ្វ្រិក អឺរ៉ុប និងជប៉ុននៅអាស៊ី ហើយសហរដ្ឋអាមេរិក នៅអាមេរិកឡាទីន។

ប្រទេសកំពុងអភិវឌ្ឍន៍ខ្លះៗ (ដូចជា ចិន ឥណ្ឌា សាធារណរដ្ឋកូរ៉េ សិង្ហបុរី នៅអាស៊ី ហើយអាហ្សង់ទីន ប្រេស៊ីល និងស៊ីលី នៅអាមេរិកឡាទីន) ក៏បានក្លាយទៅជាប្រភព FDI ដែរនាឆ្នាំថ្មីៗនេះ ជាពិសេសសំរាប់ប្រទេសកំពុងអភិវឌ្ឍន៍ នៅក្នុងតំបន់រៀងៗខ្លួន ។

ទិសដៅ

ការហូរចូល FDI មានទិសដៅជាលំហមឆ្ពោះទៅកាន់ប្រទេសកំពុងអភិវឌ្ឍន៍មួយចំនួន ។ ឧទាហរណ៍ (ពិនិត្យលើរយៈពេលបួនឆ្នាំពី១៩៩៣ ដល់ ១៩៩៧ ក្នុងចំណោមលំហូរ FDI សរុបទៅកាន់ប្រទេសកំពុងអភិវឌ្ឍន៍ មានមួយភាគធំទៅកាន់ប្រទេសចិន ។ ប្រទេសដែលទទួលជាបន្ទាប់ៗ គឺ ម៉ិកស៊ិក សិង្ហបុរី ប្រេស៊ីល ម៉ាឡេស៊ី និងឥណ្ឌូនេស៊ី ។ ជារួមប្រទេសកំពុងអភិវឌ្ឍន៍ចំនួន២០ (ដែលជាទូទៅ ជាប្រទេសមានការរីកចំរើនជាងគេ ក្នុងចំណោមប្រទេសកំពុងអភិវឌ្ឍន៍ទាំងអស់ ទទួលបានប្រមាណ ៩០% នៃលំហូរ FDI សរុប ទៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ។ ប្រទេសកំពុងអភិវឌ្ឍន៍ និងប្រទេសក្រីក្រដទៃទៀត បានទទួលត្រឹម ១០% នៃ ចំនួនសរុបប៉ុណ្ណោះ ។ ប្រទេសក្រីក្រទាំង ៤៨ បានទទួលត្រឹម ១.៤% នៃលំហូរសរុប ទៅក្នុងពិភពនៃប្រទេសកំពុងអភិវឌ្ឍន៍ប៉ុណ្ណោះ ។

ទំរង់នៃ FDI

ការវិនិយោគផ្ទាល់ពីបរទេស ជាទូទៅមានទ្រង់ទ្រាយពីរៈ វាលបៃតង ឬ ការវិនិយោគនៅក្នុងផ្នែកផលិតកម្មថ្មីៗ ការរួមបញ្ចូលគ្នា និងការស្រូបទិញយក (Mergers & acquisitions (M & As)) ។

M & As ឆ្លងព្រំប្រទល់កើតមានកាន់តែកើនឡើងៗនាឆ្នាំថ្មីៗនេះ ។ វាមានចំណែកប្រមាណពាក់កណ្តាលនៃលំហូរ FDI សរុបនៅឆ្នាំ១៩៩៧ ថ្វីត្បិតតែ M & As ភាគច្រើនត្រូវបានកើតឡើងក្នុងចំណោមក្រុមហ៊ុននៅសហរដ្ឋអាមេរិក និងអឺរ៉ុប តែសភាពនេះក៏ត្រូវបានកត់សំគាល់នៅក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ និងក្នុងប្រទេសដែលមានសេដ្ឋកិច្ចអន្តរកាលខ្លះៗដែរ ជាពិសេសនៅទីណាដែលសហគ្រាសរដ្ឋស្ថិតនៅក្រោមឯកជនភាវូបនីយកម្ម ។

ផលប៉ះពាល់ជាគុណប្រយោជន៍នៃ FDI ចំពោះប្រទេសជាម្ចាស់ផ្ទះ ៈ ការផ្ទេរនូវបច្ចេកវិទ្យា

ក្នុងចំណោមមូលហេតុ ដែលនាំអោយមានការប្រែប្រួលនូវឥរិយាបទរបស់ប្រទេសកំពុងអភិវឌ្ឍន៍ និងប្រទេសដែលមានសេដ្ឋកិច្ចអន្តរកាលជាច្រើន ចំពោះបញ្ហា FDI គឺការមានជំនឿថា FDI ជាទុយោយ៉ាងសំខាន់សំរាប់ផ្ទេរបច្ចេកវិទ្យា ដោយសារបច្ចេកវិទ្យាត្រូវបានកំណត់យ៉ាងទូលាយថា ពុំមែនរួមបញ្ចូលតែដំណើរការវិទ្យាសាស្ត្រប៉ុណ្ណោះទេ គឺថែមទាំងបញ្ចូលនូវជំនាញ ក្នុងការចាត់ចែងគ្រប់គ្រង និងម៉ាឃីតទីងទៀតផង ។

ជាញឹកញាប់ FDI ច្រើនតែមានការពាក់ព័ន្ធទៅនឹងគុណប្រយោជន៍បន្ទាប់បន្សំទៀត តាមរយៈការហូរចូលនូវបច្ចេកវិទ្យា ចំពោះក្រុមហ៊ុននៅក្នុងប្រទេសជាម្ចាស់ផ្ទះ ។ ការហូរចូលអាចកើតឡើងដោយស្ម័គ្រចិត្ត ដូចជាការផ្តល់អាជ្ញាប័ណ្ណបច្ចេកវិទ្យាមួយ ដោយក្រុមហ៊ុនបុត្តសម្ព័ន្ធទៅកាន់ក្រុមហ៊ុនក្នុងស្រុក ឬ អាចមានទ្រង់ទ្រាយជាការហូរហៀរនូវបច្ចេកវិទ្យា ដែលកើតឡើងនៅពេលណាដែលសកម្មភាពរបស់ក្រុមហ៊ុនពហុជាតិ បានទទួលនូវផលប្រយោជន៍ សំរាប់ភ្នាក់ងារសេដ្ឋកិច្ចក្នុងស្រុកលើសពីអ្វីដែលខ្លួនបានគ្រោងទុក។

FDI ក៏អាចបង្កើតឥទ្ធិពលនៃការពង្រឹងប្រសិទ្ធិភាព ដោយពុំបានគ្រោងទុកជាមុនផ្សេងៗ ទៀតដែរដូចជា នៅពេលណាដែលមានការជំរុញអោយអ្នកប្រកួតប្រជែងក្នុងស្រុកត្រូវលើកកំពស់សមត្ថភាពបច្ចេកវិទ្យារបស់ខ្លួន ដោយសារការគាបសង្កត់ពីការប្រកួតប្រជែង

ដោយពិចារណាទៅលើការអភិវឌ្ឍន៍ទាំងនេះ ក៏ដូចជាទៅលើតួនាទីសំខាន់នៃការវិនិយោគផ្ទាល់ពីបរទេស នាពេលបច្ចុប្បន្ន នៅក្នុងសេដ្ឋកិច្ចពិភពលោក ដែលកាន់តែមានលក្ខណៈជាសកល នៅឆ្នាំ ១៩៩៦ នៅក្នុងសន្និសិទថ្នាក់រដ្ឋមន្ត្រី នាប្រទេសសិង្ហបុរី គេបានបង្កើតក្រុមការងារមួយ សំរាប់ដោះស្រាយបញ្ហាទំនាក់ទំនងរវាងពាណិជ្ជកម្ម និងការវិនិយោគ ។ ភារកិច្ចរបស់ក្រុមនោះ គឺសិក្សាលើទំនាក់ទំនងរវាងពាណិជ្ជកម្ម និងវិនិយោគ ដោយគេយល់ថា ក្រុមការងារត្រូវតែបង្កើតដោយពុំបាច់វិនិច្ឆ័យជាមុនលើបញ្ហាថាតើ គួរបង្កើតគោលការណ៍ពហុភាគីលើផ្នែកវិនិយោគ នៅក្នុងក្របខ័ណ្ឌរបស់ WTO ឬ ក៏អត់ ។ សេចក្តីប្រកាសថ្នាក់រដ្ឋមន្ត្រីនៅសិង្ហបុរី បានចែងថា សេចក្តីសំរេចណាមួយ ស្តីពីការចាប់ផ្តើមចរចាគោលការណ៍វិនិយោគនៅក្នុង WTO ចាំបាច់ត្រូវមានមតិជាឯកច្ឆ័ន្ទសិន ។ ដូច្នេះ ការងាររបស់ក្រុមនោះ គឺមានបំណងជាដំណើរការសិក្សាអប់រំ ពុំមែនជាការចរចាឡើយ ។

ការវិនិយោគផ្ទាល់ពីបរទេស (FDI) : សារៈសំខាន់ និងផលប៉ះពាល់ កិច្ចព្រមព្រៀងជាធរមាន និងបទបញ្ញត្តិរបស់ WTO

ការកើនឡើងនូវសារៈសំខាន់នៃ FDI

ការវិនិយោគផ្ទាល់ពីបរទេស (FDI) គឺជាកំលាំងចលករយ៉ាងសំខាន់នៅក្នុងសកលភាវូបនីយកម្ម ដែលជាលក្ខណៈកត់សំគាល់ពីសេដ្ឋកិច្ចពិភពលោកសម័យទំនើប ។ លំហូរច្រើនឡើងនៃ FDI គួបផ្សំជាមួយកំណើននៃការវិនិយោគភាគហ៊ុនជាមូលប័ត្រ របស់បរទេស បានគូសបញ្ជាក់នូវតួនាទីសំខាន់ឡើងៗនៃសាជីវកម្មអន្តរជាតិ (TNCS) នៅក្នុងសេដ្ឋកិច្ចនៃបណ្តាប្រទេសជឿនលឿន ក៏ដូចជាប្រទេសកំពុងអភិវឌ្ឍន៍ ។ សេរីភាវូបនីយកម្មនៃរបប FDI ជាពិសេសនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ និងប្រទេសអន្តរកាលដែលកន្លងមកធ្លាប់បានដាក់កំហិតលើលំហូរ FDI ព្រមទាំងវិធានការ ដែលគេបានប្រកាន់យកដើម្បីជំរុញ FDI បានធ្វើអោយចរន្ត FDI កើនឡើងទ្វេជាពីរនាទសវត្ស កន្លងទៅ ហើយចរន្ត FDI ដែលហូរចូលទៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ បានកើតឡើងមួយជាប្រាំ (សូមមើលតារាង ខាងក្រោម) ។

ការហូរចូលនៃការវិនិយោគផ្ទាល់ពីបរទេស ឆ្នាំ ១៩៨៦-១៩៨៧

(ជាកោដិដុល្លារអាមេរិក)

សេដ្ឋកិច្ច	១៩៨៦-១៩៩១ (ជាមធ្យមប្រចាំឆ្នាំ)	១៩៩២	១៩៩៣	១៩៩៤	១៩៩៥	១៩៩៦	១៩៩៧
ពិភពលោក	159.3	175.9	217.6	24	3331.1	337.6	401
ប្រទេសជឿនលឿន	129.6	120.3	138.9	141.5	211.5	195.4	233
ប្រទេសកំពុងអភិវឌ្ឍន៍	29.1	51.1	72.5	95.6	105.5	129.8	149
អាហ្វ្រិក	2.9	3.1	3.6	5.7	5.1	4.8	4.7
អាមេរិកឡាទីន	9.5	17.6	17.2	28.7	31.9	43.8	56.1
អាស៊ី	16.4	29..6	51.2	60.7	67.3	80	86.9
អឺរ៉ុបកណ្តាលនិងខាងកើត	0.65	4.4	6.1	5.9	14.2	12.3	18.4
បណ្តាប្រទេសក្រីក្រ	0.8	1.5	1.7	0.8	1	1.9	1.8

ប្រភព: UNCTAD របាយការណ៍ស្តីពីការវិនិយោគក្នុងពិភពលោក ១៩៩៨ និន្នាការ និងការកំណត់ (ការបោះពុម្ពផ្សាយរបស់អង្គការសហប្រជាជាតិ) ។

ជំពូក ២២

ពាណិជ្ជកម្ម និងការវិនិយោគ

សាវតា : ការពិភាក្សារនៅក្នុង GATT/WTO អំពីពាណិជ្ជកម្ម និងការវិនិយោគ

កិច្ចព្រមព្រៀងទូទៅ ស្តីពីពន្ធគយ និងពាណិជ្ជកម្ម(GATT) កើតមានឡើងប្រមាណ ៥០ ឆ្នាំមុន ។ ជាសំខាន់ គួរចងចាំថា កិច្ចព្រមព្រៀងនោះ ត្រូវបានចរចាដោយឈរលើមូលដ្ឋាននៃបទបញ្ញត្តិពាណិជ្ជកម្មរបស់កតិកសញ្ញា ហាវ៉ាណា ដែលមានជំពូកស្តីពីការវិនិយោគផ្ទាល់បរទេស និងការដាក់កំហិតលើពាណិជ្ជកម្ម ។ ប៉ុន្តែបទបញ្ញត្តិទាំងនោះ ពុំមានដាក់បញ្ចូលទៅក្នុង GATT ឡើយ ។ កតិកសញ្ញាហាវ៉ាណា មិនអាចយកមកអនុវត្តបាន ដោយសារសហរដ្ឋអាមេរិកមិនបានផ្តល់សច្ចាប័នលើកតិកាសញ្ញានោះ ។

សំនួរស្តីពីការបញ្ចូលទៅក្នុងអត្ថបទនៃបទបញ្ញត្តិស្តីពីការវិនិយោគរបស់ GATT ត្រូវបានលើកឡើងជាបន្តបន្ទាប់ ក្រោយពេលដែល GATT ចូលជាធរមាន ។ នៅក្នុងការពិនិត្យកិច្ចព្រមព្រៀងនេះឡើងវិញនាឆ្នាំ ១៩៩៥ ការអនុម័តលើសេចក្តីសំរេចមួយស្តីពីការវិនិយោគអន្តរជាតិសំរាប់ការអភិវឌ្ឍន៍សេដ្ឋកិច្ច ដែលទទួលស្គាល់ពីតំរូវការនៃការវិនិយោគពីបរទេស ដើម្បីបង្កើនចរន្តដើមទុនទៅក្នុងប្រទេស ជាពិសេសទៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ បានជួយសំរួលដល់ការសំរេចនូវគោលដៅនៃកិច្ចព្រមព្រៀងទូទៅ។ បទប្បញ្ញត្តិបានណែនាំថា ប្រទេសដែលមានលទ្ធភាពផ្តល់ដើមទុនសំរាប់វិនិយោគអន្តរជាតិ និងប្រទេសដែលមានបំណងទទួលនូវដើមទុននោះ គួរតែខំប្រឹងប្រែងអោយអស់ពីសមត្ថភាព ដើម្បីបង្កើតល័ក្ខខ័ណ្ឌ ដែលអំណោយផលដល់លំហូរនៃដើមទុនអន្តរជាតិ ។ ក្នុងនេះ រួមមានការផ្តល់នូវការធានាចំពោះការវិនិយោគដែលមានស្រាប់ និងការវិនិយោគនាពេលអនាគត ជៀសវាងការយកពន្ធត្រួតគ្នា និង ការសំរួលដល់ការបង្វែរប្រាក់ចំណេញ ដែលបានមកពីការវិនិយោគបរទេសនោះ ។ កិច្ចព្រមព្រៀងបានជំរុញប្រទេសជាសមាជិក GATT អោយចូលរួមទៅក្នុងការពិភាក្សា ដែលនឹងនាំអោយមានការអនុម័តនូវកិច្ចព្រមព្រៀងទ្វេភាគី និងពហុភាគីស្តីពីបញ្ហានោះ។

នៅក្នុងឆ្នាំជាបន្តបន្ទាប់មក GATT បានពង្រីកវិសាលភាពនៃវិធានរបស់ខ្លួន ដែលពីមុនជាវិធានការណ៍អនុវត្ត ដោយរដ្ឋាភិបាលនៅតាមព្រំប្រទេស រហូតដល់វិធានការណ៍នយោបាយផ្ទៃក្នុង ។ ទោះជាវិធានថ្មីៗ ជាច្រើនដែលបានអនុម័តនៅទស្សវត្ស ទី៧០ ក្នុងអំឡុងការចរចាតុមូលនៅតូក្យូលើវិស័យផ្សេងៗ ដូចជាឧបត្ថម្ភធន លក្ខណៈបច្ចេកទេស និងលទ្ធកម្មសាធារណៈ មានគោលដៅជាបឋម គឺលុបបំបាត់នូវរបាំងពាណិជ្ជកម្មក្តី ក៏វិធានខ្លះៗក្នុងនោះមានសារៈសំខាន់ៗ ចំពោះលក្ខណៈប្រកួតប្រជែងដែលវិនិយោគបរទេសត្រូវប្រឈមមុខដែរ ។ ឧទាហរណ៍ ដូចដែលបានពន្យល់លំអិតនាពេលក្រោយទៀតក្នុងជំពូកនេះ វិធានដែលបានបង្កើតឡើងនៅលើផ្នែកឧបត្ថម្ភធន ត្រូវបានអនុវត្ត ចំពោះករណីលើកទឹកចិត្តខ្លះៗ ដែលរដ្ឋាភិបាលបានផ្តល់ជូន សំរាប់ទាក់ទាញវិនិយោគបរទេស។

ការអភិវឌ្ឍន៍សំខាន់មួយទៀតនៅក្នុងការងាររបស់GATT គឺការវិវត្តន៍ជាបន្តបន្ទាប់នូវវិធានអន្តរជាតិ សំរាប់គ្រប់គ្រងក្រុមហ៊ុនបរទេស ។ ជាដំបូងវិធាន GATT បានកំណត់នូវកាតព្វកិច្ចចំពោះរដ្ឋាភិបាល តែចំពោះទំនិញបរទេសប៉ុណ្ណោះ ។ វិធាននោះពុំបានគិតគូរទៅដល់ជនបរទេសឡើយ ទោះជាឯកត្តជន ឬ នីតិបុគ្គល ដែលមានប្រតិបត្តិការ នៅក្នុងទឹកដីរបស់ខ្លួនក្តី ហើយបញ្ហានេះគឺជាចំណុចស្នូលនៃគោលនយោបាយវិនិយោគ ។ កិច្ចព្រមព្រៀងទូទៅស្តីពីពាណិជ្ជកម្មលើសេវាកម្ម ព្រមទាំងកិច្ចព្រមព្រៀងស្តីពីទិដ្ឋភាពពាណិជ្ជកម្មទាក់ទងនឹងកម្មសិទ្ធិបញ្ញា ដែលបានធ្វើឡើងនៅក្នុងកិច្ចប្រជុំនៅយូរ៉ុយហ្គាយ បានកំណត់នូវកាតព្វកិច្ចចំពោះរដ្ឋាភិបាលក្នុងការគ្រប់គ្រងជនជាតិ ឬ ក្រុមហ៊ុនបរទេសនៅក្នុងទឹកដីរបស់ខ្លួន ។ ក្រៅពីនេះ កិច្ចព្រមព្រៀងស្តីពីវិធានការពាណិជ្ជកម្មទាក់ទងនឹងការវិនិយោគ ដែលបានចរចានៅលើតុមូលនៅយូរ៉ុយហ្គាយដែរនោះ បានទាមទារមិនអោយរដ្ឋាភិបាលដាក់ល័ក្ខខ័ណ្ឌចំពោះវិនិយោគិន ដូចជាតំរូវការអោយប្រើប្រាស់វត្ថុធាតុដើមក្នុងស្រុក ដែលមិនស្របទៅនឹងបទបញ្ញត្តិរបស់ GATT ។

ឧបសម្ព័ន្ធ

គោលការណ៍អ្នកបង្កគ្រឿងបំពុលត្រូវបង់កំរៃ និងអ្នកប្រើប្រាស់បង់កំរៃ

ផ្អែកលើគោលការណ៍អ្នកបង្កគ្រឿងបំពុល ត្រូវបង់កំរៃ (PPP) អ្នកបង្កគ្រឿងបំពុលត្រូវបានបង្ខំអោយទទួលបន្ទុកលើចំណាយដែលបង្ករឡើងដោយអាជ្ញាធរសាធារណៈ ក្នុងសកម្មភាពកាត់បន្ថយគ្រឿងបំពុល និងការរាំងមិនអោយមានគ្រឿងពុល ព្រមទាំងក្នុងការថែរក្សាបរិស្ថាន អោយស្ថិតក្នុងស្ថានភាពទទួលយកបាន ។ គោលការណ៍ នេះបានបន្ថែមទៅលើគោលការណ៍អ្នកប្រើប្រាស់ត្រូវបង់កំរៃ (UPP) ហើយបានបង្កើតឡើង ជាបន្ទាប់មក ដោយOECD ។ ក្នុងខណៈដែល PPP គិតគូរទៅលើគ្រឿងបំពុលបរិស្ថាន UPPបានគិតគូរអំពីការកំណត់ថ្លៃចំពោះធនធានធម្មជាតិដែលកាន់តែខ្សត់ទៅៗ ក្នុងនោះបានចែងថា ធនធានធម្មជាតិត្រូវឆ្លុះបញ្ចាំងនូវចំណាយគ្រប់ស្រទាប់ទាំងអស់ ពាក់ព័ន្ធនឹងការប្រើប្រាស់វា រួមទាំងចំណាយនៃឥទ្ធិពលពីខាងក្រៅពាក់ព័ន្ធនឹងការធ្វើអាជីវកម្មយកការបំផ្លែង និងការប្រើប្រាស់ធនធានគួបផ្សំ និងចំណាយប៉ាន់ស្មានសំរាប់ការប្រើប្រាស់នាអនាគតផងដែរ ។

វិចារណកម្មសេដ្ឋកិច្ចដែលជាមូលដ្ឋាននៃគោលការណ៍ទាំងពីរនោះគឺ នៅពេលណាដែលចំណាយបរិស្ថានត្រូវបានគិតបញ្ចូលទាំងស្រុង ហើយដូចនេះនឹងត្រូវឆ្លុះបញ្ចាំងទៅក្នុងថ្លៃ នៅពេលនោះ គេអាចរំពឹងថា យន្តការទីផ្សារនឹងជួយជំរុញអោយបង្កើតឡើងនូវបច្ចេកទេសសំរាប់កាត់បន្ថយគ្រឿងបំពុល និងសំរាប់ថែរក្សានូវធនធាន ដែលកាន់តែខ្សត់ទៅៗ នៅក្នុងតំលៃមួយដែលសមស្របទៅនឹងការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព និងដើម្បីជួយការពារ រារាំង នូវការរំខានផ្សេងៗ នៅក្នុងការធ្វើការបែងចែកនូវវិនិយោគ និងក្នុងការធ្វើពាណិជ្ជកម្ម ។ ដូច្នេះការអនុវត្តន៍នូវគោលការណ៍ទាំងពីរ ដោយគ្រប់បណ្តាប្រទេសទាំងអស់អាចនឹងជួយសំរួលដល់ការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាពនូវធនធានរបស់ពិភពលោក ។

ជាក់ស្តែងការគិតបញ្ចូលនូវចំណាយទាំងឡាយតាមគោលការណ៍ទាំងពីរនោះ អាចនឹងធ្វើទៅបានតាមរយៈវិធានការបញ្ជូន និងត្រួតពិនិត្យ (ចាប់ពីស្តង់ដារដំណើរការ និងផលិតផលរហូតដល់បទប្បញ្ញត្តិនិមួយៗ និងការហាមឃាត់) ព្រមទាំងតាមរយៈ ឧបករណ៍សេដ្ឋកិច្ចនានា (រៀបចំអោយមាននូវកំរៃ លើគ្រឿង បំពុលបរិស្ថានជា ច្រើនប្រភេទផ្សេងៗ) ។

ចំពោះប្រទេសកំពុងអភិវឌ្ឍន៍ ពាណិជ្ជកម្ម គឺជាឧបករណ៍សំខាន់ជាងគេ ដើម្បីធានានូវធនធានចាំបាច់សំរាប់ការការពារបរិស្ថាន។ ការសន្យានយោបាយធ្វើឡើងនៅក្នុងសន្និសិទ្ធិសហប្រជាជាតិអំពីបរិស្ថាន និងការអភិវឌ្ឍន៍(UNCED) អំពីការផ្តល់នូវហិរញ្ញវត្ថុ និងបច្ចេកវិទ្យាយ៉ាងច្រើន ចំពោះប្រទេសកំពុងអភិវឌ្ឍន៍ ដើម្បីជួយបំពេញតំរូវការរបស់គេ ក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ច និងការពារបរិស្ថាន ពុំបានកើតឡើងជាក់ស្តែងដូចសន្យាឡើយ ។ ជាលទ្ធផលសេរីភាវូបនីយកម្មពាណិជ្ជកម្ម បានផ្តល់ផលប្រយោជន៍ដល់ផលិតផលដែលអាចនាំចេញបានចំពោះប្រទេសកំពុងអភិវឌ្ឍន៍ ហើយបានក្លាយជាការទាមទារចាំបាច់សំរាប់ ជួយពួកគេអោយសំរេចបាននូវការអភិវឌ្ឍន៍ប្រកបដោយនិរន្តភាព ។ ទន្ទឹមនោះ ដើម្បីដោះស្រាយបញ្ហាបរិស្ថាន ជាសកល ចំពោះមុខ (ឧទាហរណ៍ បំរែបំរួលបរិយាកាស) ការធ្វើសេរីភាវូបនីយកម្មពាណិជ្ជកម្មនូវទំនិញ និងសេវា មានលក្ខណៈបរិស្ថាន អាចនឹងចូលរួមចំណែកបានយ៉ាងសំខាន់ ។

ការងារអនាគត

CTE និងបន្តអនុវត្តការងារស្រាវជ្រាវអំពីបញ្ហានេះ និងបញ្ហាពាក់ព័ន្ធឯទៀតៗ ។ ការសំរេចថា តើគួរអោយមានការចរចាសំដៅអភិវឌ្ឍន៍នូវវិធានការថ្មីៗ នៅក្នុងបញ្ហានេះឬទេ នឹងត្រូវធ្វើឡើងនៅក្នុងសិទ្ធិថ្នាក់រដ្ឋមន្ត្រី លើកទីបី ដែលនឹងប្រព្រឹត្តទៅនាខែវិច្ឆិកា ឆ្នាំ ១៩៩៩ ។

ឯកសារយោង:

ពាណិជ្ជកម្ម និងបរិស្ថាន ។ (WTO ឯកសារសាវតាដែលបានដាក់ជូនក្នុងសម័យប្រជុំស្តីពីពាណិជ្ជកម្ម និងបរិស្ថាន នៅ Cairo ១៩៩៨)

បទបញ្ញត្តិនោះបានចោទជាសំនួរពីរធំៗ ។ ទីមួយ តើបទបញ្ញត្តិពាណិជ្ជកម្មដែលទាមទារអោយសមាជិក ហាមឃាត់ ឬដាក់កំហិតពាណិជ្ជកម្មខ្លួនជាមួយប្រទេសមិនមែនជាភាគីនៃកិច្ចព្រមព្រៀងបរិស្ថាន ពិតជាចាំបាច់ និងគួរត្រូវធ្វើឬទេ ផ្អែកលើគោលជំហរសេដ្ឋកិច្ច ។ សំនួរទីពីរគឺ តើបទបញ្ញត្តិដែលអនុវត្តចំពោះការនាំចូល ឬនាំចេញពីប្រទេសមិនមែនភាគី លើមូលដ្ឋាននៃការរើសអើងសមស្របទៅនឹងកាតព្វកិច្ចនៅក្រោមគោលការណ៍ទូទៅនៃច្បាប់អន្តរជាតិ និងជាពិសេសនៃច្បាប់របស់ GATT ឬទេ ? ។

បញ្ហាទាំងនេះត្រូវបានលើកយកមកពិភាក្សានៅក្នុងអង្គការពាក់ព័ន្ធជាមួយបរិស្ថានផ្សេងៗ ដូចជា UNEP និងគណៈកម្មាធិការពាណិជ្ជកម្ម និងបរិស្ថានរបស់ WTO (CTE) ។ ប៉ុន្តែ CTE បានធ្វើការកត់សំគាល់ នៅក្នុងរបាយការណ៍ ឆ្នាំ ១៩៩៦ របស់គេថា វិធាន WTO បានបើកនូវវិសាលភាពយ៉ាងទូលាយ ចំពោះវិធានការទាំងនោះ ហើយមកទល់ពេលនេះ ពុំមានកិច្ចព្រមព្រៀងណាមួយ ក្នុងចំណោមប្រទេសជាសមាជិក ធ្វើការកែប្រែបទបញ្ញត្តិ WTO ដែលពាក់ព័ន្ធឡើយ ។

គុណប្រយោជន៍បរិស្ថាននៃការធ្វើសេរីភាវូបនីយកម្មពាណិជ្ជកម្ម

បញ្ហាមួយក្នុងចំណោមបញ្ហាដ៏ទូលំទូលាយ និងសំខាន់ៗទាំងឡាយដែលទទួលនូវការយកចិត្តទុកដាក់ ពីសំណាក់ LTE គឺជាទំនាក់ទំនងរវាងសេរីភាវូបនីយកម្មពាណិជ្ជកម្ម និងការការពារបរិស្ថាន ព្រមទាំងការអភិវឌ្ឍន៍ប្រកបដោយនិរន្តភាព ។ ដើម្បីផ្តល់ជាមូលដ្ឋានសំរាប់ការពិភាក្សាលើបញ្ហានេះ លេខាធិការដ្ឋាន WTO បានរៀបចំជាឯកសារណែនាំមួយគ្របដណ្តប់លើវិស័យមួយចំនួន (កសិកម្ម ថាមពល នេសាទ ព្រៃឈើ លោហៈពុំមានសារធាតុដែក វាយនភ័ណ្ឌ និងសំលៀកបំពាក់ ស្បែក និងសេវាកម្មបរិស្ថាន) បកស្រាយពីការដាក់កំហិត និងការរំខានចំពោះពាណិជ្ជកម្មសំខាន់ៗ នៅក្នុងវិស័យនីមួយៗ ព្រមទាំងគុណប្រយោជន៍បរិស្ថានដែលកើតឡើង ពីការលប់ចោលនូវអ្វីទាំងនោះ ។

ឯកសារកត់សំគាល់ថា ជាទូទៅសេរីភាវូបនីយកម្មពាណិជ្ជកម្មពុំមែនជាមូលហេតុចំបងចំពោះភាពខូចខាតបរិស្ថាននោះទេ ហើយលិខិតុបករណ៍ពាណិជ្ជកម្មក៏ពុំមែនជានយោបាយដ៏វិសេសវិសាលផុតគេ ក្នុងការដោះស្រាយបញ្ហាបរិស្ថានដែរ ។ ផ្នែកយ៉ាងសំខាន់បំផុតនៃទំនាក់ទំនងរវាងសេរីភាវូបនីយកម្មពាណិជ្ជកម្ម និងបរិស្ថានត្រូវបានឆ្លុះបញ្ចាំងនៅក្នុងឥទ្ធិពលមិនផ្ទាល់របស់វា ទៅលើកំរិត និងបែបផែននៃផលិតកម្ម និងការប្រើប្រាស់ ។ ដូច្នេះផលប្រយោជន៍បរិស្ថាននៃការលប់ចោលនូវរបាំង និងគ្រឿងអន្តរាយដល់ពាណិជ្ជកម្ម ក៏ទំនងមានលក្ខណៈមិនផ្ទាល់ ហើយជាទូទៅ ក៏មិនអាចធ្វើការកត់សំគាល់បានភ្លាមៗដែរ។

គោលគំនិតជាមូលដ្ឋាននៃឯកសាររបស់លេខាធិការដ្ឋានគឺ នៅក្នុងសេដ្ឋកិច្ចទីផ្សារដែលមានដំណើរការល្អ ថ្លៃគឺជាអ្នកកត់ត្រានូវភាពខ្សត់នៃធនធាន និងនូវចំណូលចិត្តរបស់អ្នកប្រើប្រាស់ ពោលគួនាទីមួយរបស់ វាគឺធ្វើការបែងចែកធនធានយ៉ាងមានប្រសិទ្ធិភាព។ ប៉ុន្តែសុខុមាលភាពសង្គមអាចនឹងថយចុះ ប្រសិនបើថ្លៃទីផ្សារពុំគិតគូរទៅដល់ឥទ្ធិពលនៃសកម្មភាពបំផ្លាញបរិស្ថាន ហើយដូចនេះកំបញ្ជូននូវសញ្ញាមិនត្រឹមត្រូវ អំពីការប្រើប្រាស់យ៉ាងល្អនូវធនធានបរិស្ថាន ។ ការបែងចែកមិនបានល្អនៃធនធាន នាំអោយមានការអន់ថយដល់ប្រសិទ្ធិភាពនៃការគ្រប់គ្រងបរិស្ថាន ។ ថ្លៃដែលរងការរំខាន បានលាក់បាំងនូវភាពសម្បូរណ៍នៃធនធាន បរិស្ថានដែលពុំសូវបានយកមកប្រើប្រាស់រួមចំណែកធ្វើអោយអន្តរាយអស់នូវធនធានឯទៀត ដែលរងការប្រើប្រាស់ហួសហេតុ បង្កនូវបញ្ហាបរិស្ថានថ្មីៗ និងបង្កើតនូវការប្រើប្រាស់ហួសហេតុ នូវអ្វីដែលបំផ្លាញបរិស្ថាន ។

ប៉ុន្តែឯកសារណែនាំនោះបានចង្អុលបង្ហាញនូវទំនាក់ទំនងជាវិជ្ជមានរវាងការលប់បំបាត់នូវរបាំង និងការរំខានចំពោះពាណិជ្ជកម្ម និងគុណភាពប្រសើរឡើងនៃបរិស្ថាន ។ ទំនាក់ទំនងបែបនេះ នាំអោយមានលទ្ធភាព ដូចតទៅ ÷

- ☐ ការប្រើប្រាស់ប្រកបដោយប្រសិទ្ធិភាពជាងមុន នូវកត្តាផលិតកម្មផ្សេងៗ តាមរយៈការពង្រឹងការប្រកួតប្រជែង ។
- ☐ ការកាត់បន្ថយភាពក្រីក្រតាមរយៈការពង្រីកពាណិជ្ជកម្ម និងជំរុញអោយមានអត្រាប្រកបដោយនិរន្តភាពមួយនូវការធ្វើអាជីវកម្មធនធានធម្មជាតិ ។
- ☐ ការកើនឡើងនូវបរិមាណទំនិញ និងសេវាកម្មពាក់ព័ន្ធនឹងបរិស្ថាន តាមរយៈសេរីភាវូបនីយកម្មទីផ្សារ និង
- ☐ ភាពប្រសើរឡើងនៃលក្ខខ័ណ្ឌសំរាប់ធ្វើសហប្រតិបត្តិការអន្តរជាតិ តាមរយៈដំណើរការការចចាជាពហុភាគីជាបន្តបន្ទាប់

ភារកិច្ចរបស់គេតំរូវអោយស្រាវជ្រាវលើករណីនោះ ដោយផ្អែកលើច្បាប់ជាធរមាន -គណៈវិនិច្ឆ័យ- ជាមួយការប្រកាន់ថា វិធានការរបស់សហរដ្ឋអាមេរិកសមស្របជាមួយនឹង GATT ក៏បានស្នើឡើងថា ក្រុម GATT ទទួលបន្ទុកវិធានការបរិស្ថាន និងពាណិជ្ជកម្មអន្តរជាតិ គួរវិភាគអំពីការបញ្ចូលគោលការណ៍ អ្នកបង្ករគ្រឿងបំពុលត្រូវបង់ប្រាក់ទៅក្នុងច្បាប់របស់ GATT និងអំពីភាពចាំបាច់នៃការកែប្រែទៅលើវិធានរបស់ GATT ពាក់ព័ន្ធទៅនឹងការកែតំរូវលើពន្ធឆ្លងព្រំប្រទល់ ។ ឧបសម្ព័ន្ធនៃជំពូកនេះ បានពិពណ៌នាអំពីលក្ខណៈសំខាន់ៗនៃគោលការណ៍នោះ ។

បទបញ្ញត្តិពាណិជ្ជកម្មផ្សេងៗនៅក្នុងកិច្ចព្រមព្រៀងបរិស្ថានពហុភាគី

នៅក្នុងផ្នែកបរិស្ថានមានកិច្ចព្រមព្រៀង និងលិខិតុបករណ៍អន្តរជាតិប្រមាណជាង ១៤០ ។ ក្នុងនេះកិច្ចព្រមព្រៀងបរិស្ថាន ពហុភាគីចំនួន ២០ ដែលមានបទបញ្ញត្តិស្តីពីពាណិជ្ជកម្ម ។ កិច្ចព្រមព្រៀងទាំងនោះអាចប្រមូលផ្តុំជាបីប្រភេទ ។

- ☐ កិច្ចព្រមព្រៀងលើការត្រួតពិនិត្យការបំពុលឆ្លងព្រំប្រទល់ ឬសំរាប់ការពារសម្បត្តិរួមជាសកល ។ ឧទាហរណ៍នៃកិច្ចព្រមព្រៀងនោះមានដូចជាអនុសញ្ញាវេនៃ ដើម្បីការពារស្រទាប់អូសូន និងអនុសាសន៍របស់វានៅម៉ុងរេអាល់ លើសារធាតុដែលធ្វើអោយអន្តរាយដល់ស្រទាប់អូសូន ព្រមទាំងកិច្ចព្រមព្រៀងអំពីបំរែបំរួលបរិយាកាស ។
- ☐ កិច្ចព្រមព្រៀង ដើម្បីការពារសត្វដែលជិតដាច់ពូជ បក្សីធ្វើអន្តោប្រវេស្ត ព្រមទាំងសត្វត្រីសត្វ សមុទ្រឯទៀតៗ ។ ឧទាហរណ៍មានអនុសញ្ញាអំពីពាណិជ្ជកម្មអន្តរជាតិ នៃប្រភេទសត្វដែលជិតដាច់ពូជ និងរុក្ខជាតិតាមតំបន់(CITES) និងអនុសញ្ញាអន្តរជាតិសំរាប់គ្រប់គ្រងការនេសាទត្រីបាឡែន ។ ក្នុងចំណោមបទបញ្ញត្តិទាំងឡាយនៃកិច្ចព្រមព្រៀងនោះ ក៏មានវិធានការណែនាំអំពីវិធីសំរាប់ចាប់ ឬសម្លាប់សត្វព្រៃ ឬ ត្រីដែរ ។
- ☐ កិច្ចព្រមព្រៀងពីការត្រួតពិនិត្យផលិតកម្ម និងពាណិជ្ជកម្មនៃផលិតផល និងសារធាតុប្រកបដោយគ្រោះថ្នាក់ ។ ឧទាហរណ៍ដូចជាអនុសញ្ញាបាហ្សែល ស្តីពីការត្រួតពិនិត្យលើសកម្មភាពឆ្លងព្រំប្រទល់នៃកាកសំណល់ប្រកបដោយគ្រោះថ្នាក់ និងការបោះចោលនូវកាកសំណល់នោះ និងវិធានណែនាំរបស់ឡុងដុង ចំពោះការដោះដូរនូវពត៌មានអំពីសារធាតុគីមីនៅក្នុងពាណិជ្ជកម្មអន្តរជាតិ ។

និយាយជាទូទៅ កាតព្វកិច្ចនៅក្នុងកិច្ចព្រមព្រៀងនោះ ចំពោះបណ្តាប្រទេសដែលចូលរួម ក្នុងគោលបំណងត្រួតពិនិត្យ ពាណិជ្ជកម្មមានបែបផែនជាការហាមឃាត់ការនាំចូល និងនាំចេញ ។

ផ្អែកទៅលើច្បាប់របស់ GATT ការដាក់កំហិតទៅលើពាណិជ្ជកម្មជាមួយប្រទេសដទៃទៀត ដែលជាសមាជិកនៃ MEA គឺពុំមែនជាបញ្ហាអ្វីទេ ដោយអ្នកចូលរួមក្នុង MEA ទាំងអស់បានព្រមព្រៀង លើការដាក់កំហិតរួចទៅហើយ ។ ប្រទេសជាសមាជិកនីមួយៗអាចមានលទ្ធភាពបញ្ជាក់លើការដាក់កំហិតថា ជាការចាំបាច់ទៅតាមមាត្រា២០ ដើម្បីការពារសុខភាព ឬការពារនូវធនធានក្នុងបូរណភាពទឹកដីរបស់ខ្លួន ។

ប៉ុន្តែវាជាករណីមួយផ្សេងទៀតទៅវិញ នៅពេលណាដែល MEA ដាក់ការហាមឃាត់លើពាណិជ្ជកម្ម ជាមួយបណ្តាប្រទេសដែលពុំមែនជាភាគីនៃកិច្ចព្រមព្រៀងដែរនោះ ។ ឧទាហរណ៍ដែលច្រើនលើកឡើង នៅក្នុងបរិបទនេះ គឺអនុស្សារណៈ ម៉ុងរ៉េអាល់។ ឯកសារនោះអំពាវនាវអោយបណ្តាប្រទេសជាភាគី លុបបំបាត់ចោលនូវផលិតកម្ម និងការប្រើប្រាស់នូវសារធាតុដែលធ្វើអោយអន្តរាយដល់ស្រទាប់អូសូន (ឈ្មោះក្នុងបញ្ជីជា " សារធាតុត្រូវត្រួតពិនិត្យ") យ៉ាងយូរ ត្រឹមឆ្នាំ ២០០០ ។ ចំណែកឯពាណិជ្ជកម្មជាមួយភាគីវិញអនុស្សារណៈបានអនុញ្ញាត្តិអោយប្រទេសនីមួយៗ សំរេចដោយផ្ទាល់ថាតើគេត្រូវដាក់កំហិតលើការនាំចេញនាំចូលរបស់គេទៅលើសារធាតុនោះ ដោយរបៀបណា ដោយផ្អែកលើការសន្យារួមរបស់គេ ក្នុងការបំបាត់នូវផលិតកម្ម និងការប្រើប្រាស់នូវសារធាតុនោះតាមពេលដែលកំណត់ ។ ប៉ុន្តែភាគី នៃអនុស្សរណៈ មានកាតព្វកិច្ចត្រូវហាមឃាត់ពាណិជ្ជកម្ម ជាមួយអ្នកមិនមែនភាគីនៅលើសារធាតុណា ដែលធ្វើអោយអន្តរាយដល់ស្រទាប់អូសូនដោយភ្លាមៗ នៅក្រោយពេលដែលអនុស្សរណៈ ចាប់ផ្តើមមានសុពលភាព ។ បទបញ្ញត្តិដូចគ្នានេះ ទាមទារអោយភាគីទាំងឡាយអនុវត្តវិធានការដាក់កំហិតលើពាណិជ្ជកម្ម ចំពោះអ្នកមិនមែនជាភាគីច្រើនជាង ចំពោះភាគីត្រូវបានបញ្ចូលតំលៃទៅក្នុងអនុសញ្ញា បាហ្សែល និងក្នុង CITES ។

ប្រអប់ ៥៦

ពន្ធដែលបានបង្កើតក្នុងគោលដៅសំរេចបាននូវគោលដៅបរិស្ថាន

កំរៃលើផលិតផល

កំរៃនេះត្រូវបានអនុវត្តលើផលិតផលដែលមានលក្ខណៈបំពុលបរិស្ថាន ឬដោយសារធាតុខ្លះរបស់វាបង្កជាបញ្ហា នៅពេលបោះចោល ក្រោយប្រើប្រាស់រួច ។ ក្នុងចំណោមផលិតផលនោះមានធាតុគីមីពុល សាប៊ូមានជាតិហ្វូសហ្វាត ថ្មពិលមានជាតិដែកខ្ពស់ និងសំបកវេចខ្ចប់ ដែលមិនអាចផ្តល់ត្រឡប់ទៅវិញបាន ។ កំរៃបែបនោះក៏អាចនឹងត្រូវយកក្នុងអត្រាមួយបាន ដើម្បីជំរុញអោយមានការប្រើប្រាស់នូវផលិតផលពុំសូវមានគ្រឿងបំពុល ដូចជាប្រេង ដែលគ្មានជាតិសំណ ។

កំរៃលើការបញ្ចេញគ្រឿងបំពុលបរិស្ថាន

កំរៃនេះត្រូវបានអនុវត្តលើគ្រឿងបំពុលចំពោះខ្យល់ ទឹក ឬ ដី ឬ នៅលើការបង្កើតនូវសម្លេង ។ គេអាចយកកំរៃនេះនៅពេលប្រើប្រាស់ (ក្នុងករណីនេះគឺវាមានសភាពដូចជាកំរៃលើផលិផល ហើយនឹងមានឥទ្ធិពលដូចគ្នាលើពាណិជ្ជកម្ម) ឬកំរៃនេះអាចមានទំរង់ជាកំរៃប្រើប្រាស់សេវា ដើម្បីគ្របដណ្តប់លើចំណាយកិច្ចការសាធារណៈ ចំពោះទឹកសំអុយ និងកាកសំណល់ ។

កំរៃរដ្ឋបាល

ជាទូទៅកំរៃត្រូវបានអនុវត្តរួមគ្នាជាមួយ និងឧបករណ៍ជាបទបញ្ញត្តិ ដើម្បីគ្របដណ្តប់លើចំណាយនៃសេវាកម្មរបស់រដ្ឋាភិបាល ហើយអាចមានរូបភាពជាអាជ្ញាប័ណ្ណ ការចុះបញ្ជីឈ្មោះ ការធ្វើតេស្ត ឬ កំរៃត្រួតពិនិត្យ ។

> ...វិធានអំពីការកែតំរូវលើពន្ធនៃកិច្ចព្រមព្រៀងទូទៅបានធ្វើការបែងចែករវាងពន្ធលើផលិតផល (ពន្ធផ្ទាល់) និងពន្ធដែលពុំយកលើផលិតផលដោយផ្ទាល់ (ពន្ធប្រយោល) ។ តែពុំបានបែងចែករវាងពន្ធដែលមានគោលដៅនយោបាយខុសៗគ្នានោះទេ ។ ទោះបីជាពន្ធលើផលលក់នៃផលិតផលមួយ ត្រូវបានយកដោយមូលហេតុប្រាក់ចំណូលជាទូទៅ ឬ ដើម្បីអោយមានការប្រើប្រាស់ប្រកបដោយវិចារណញ្ញាណ នូវធនធានបរិស្ថានក្តី គឺពុំមែនជាកត្តាសំខាន់សំរាប់ការកំណត់នូវសុពលភាពនៃពន្ធសំរាប់កែតំរូវលើពន្ធឆ្លងព្រំប្រទល់ឡើយ ។

ដោយឡែកចំពោះការអះអាងថា យោងទៅលើគោលដៅអ្នកបង្កគ្រឿងបំពុលត្រូវបង់កំរៃ ហើយដូចនោះ គឺមានតែផលិតកម្មក្នុងស្រុកប៉ុណ្ណោះ ដែលត្រូវបង់ពន្ធ គណៈវិនិច្ឆ័យបានធ្វើការសង្កេតថា គោលការណ៍នោះ-ថ្វីត្បិតតែត្រូវបានទទួលស្គាល់ពីសំណាក់ប្រទេស OECD នៅលើមូលដ្ឋានស្ម័គ្រចិត្តក្តី- តែវាពុំមែនជាផ្នែកនៃច្បាប់របស់GATT ឡើយ ។ ជាពិសេសគេបានលើកឡើងថា

> " វិធាននៃកិច្ចព្រមព្រៀងទូទៅ ស្តីពីការកែតំរូវលើពន្ធឆ្លងព្រំប្រទល់ " បានផ្តល់ដល់សមាជិករបស់ GATT នូវលទ្ធភាពអនុវត្តតាមវិធានអ្នកបង្កគ្រឿងបំពុលត្រូវបង់កំរៃ ប៉ុន្តែវិធាននោះពុំបានដាក់កំហិតអោយត្រូវតែធ្វើដូច្នោះដោយខានមិនបាននោះឡើយ " ។

ប៉ុន្តែ គណៈវិនិច្ឆ័យធ្វើការសង្កេតថា ប្រសិនបើប្រទេសសមាជិកGATT ណាមួយ មានបំណងយកពន្ធលើផលរបរនៃផលិតផលក្នុងស្រុក (ដោយសារផលិតកម្មវាធ្វើអោយមានការបំពុលបរិស្ថានក្នុងស្រុក) ហើយកំណត់យកពន្ធមួយទាបជាង ឬក៏មិនយកពន្ធនោះតែម្តងនៅលើទំនិញនាំចូល (ពីព្រោះការប្រើប្រាស់វា បណ្តាលអោយមានបញ្ហាតែបន្តិចបន្តួច) ជាគោលការណ៍ គេអាចធ្វើដូច្នេះដោយសេរីបាន ។

របាយការណ៍របស់គណៈវិនិច្ឆ័យហាក់ដូចជាស្នើឡើងថា គេចាត់ទុកថាជាការមិនសមស្រប ដែលពន្ធយកនៅក្នុងគោលដៅធ្វើហិរញ្ញប្បទានកម្មវិធីបរិស្ថានក្នុងស្រុកនៃប្រទេសនាំចូលតែឯកឯង ត្រូវបានយកនៅលើផលិតផលនាំចូលដែរនោះ ។ ប៉ុន្តែដោយ

គំរោងស្លាកសញ្ញាឯកជន (មិនមែនរដ្ឋាភិបាល)

- ☐ *ប្រព័ន្ធវិញ្ញាបនប័ត្រវិទ្យាសាស្ត្រ ដែលពីមុនមានឈ្មោះថា កាកបាទបៃតង : សហរដ្ឋអាមេរិក*
- ☐ *ត្រាបៃតង : សហរដ្ឋអាមេរិក*
- ☐ *ជំរើសបរិស្ថានល្អ : ស៊ុយអែដ គំនិតផ្តួចផ្តើមជាឯកជនពីរនៅអាឡឺម៉ង់ មួយសំរាប់វាយនភ័ណ្ឌ និងមួយទៀតសំរាប់ឈើតំបន់ត្រូពិក គឺជាលក្ខណៈវិនិច្ឆ័យ ដែលបានបង្កើតឡើងសំរាប់ធ្វើស្លាកសញ្ញាដល់ផលិតផលទាំងនោះ ។*

បទបញ្ញត្តិរបស់ GATT ស្តីអំពីស្លាកសញ្ញាបរិស្ថាន

បទបញ្ញត្តិសំខាន់ៗ នៃច្បាប់របស់GATT អនុវត្តចំពោះស្លាកសញ្ញាបរិស្ថានមានចែងក្នុងកិច្ចព្រមព្រៀង TBT ។

ពន្ធលើការប្រើប្រាស់ និងពន្ធផ្សេងៗទៀតលើការប្រើប្រាស់

កំរៃលើផលិតផល កំរៃលើការបញ្ចេញនូវគ្រឿងបំពុលបរិស្ថាន និងកំរៃរដ្ឋបាល ត្រូវបានយកមកប្រើកាន់តែច្រើនឡើងសំដៅសំរេចបាននូវគោលដៅបរិស្ថាន ។ វណ្ឌ ៥៦ លើកឡើងនូវគោលបំណងបរិស្ថានខ្លះៗ ដែលនាំអោយមានការបង្កើតឡើងនូវពន្ធបែបនោះ ។

***វិធានរបស់* GATT**

វិធានរបស់GATT អនុញ្ញាត្តិអោយបណ្តាប្រទេសបង្កើតពន្ធផ្ទៃក្នុងទៅលើផលិតផលនាំចូល (ជាបន្ថែមលើពន្ធគយ) ដែលនឹងត្រូវបង់ដូចជាពន្ធលើផលិតផលក្នុងស្រុកដែរ ។ ដើម្បីធានាថា ពន្ធនោះ ពុំក្លាយទៅជាការការពារកំរិតខ្ពស់ ដល់ផលិតកម្មក្នុងស្រុក មាត្រា៣.២ របស់ GATT បានសង្កត់ទៅលើវិធានការប្រព្រឹត្តិកម្មជាតិ ចំពោះការបង្កើតពន្ធជារផ្ទៃក្នុង និងបានចែងថា ផលិតផលនាំចូល និងមិនត្រូវក្លាយជាកម្មវត្ថុ "ដោយផ្ទាល់ ឬ ដោយប្រយោល ជាកំរៃផ្ទៃក្នុង ឬ កំរៃផ្សេងៗណាមួយអោយលើសពីកំរិតពន្ធ ឬកំរៃដែលបានអនុវត្ត... ចំពោះផលិតផលក្នុងស្រុកឡើយ " ។ ដូច្នេះកំរៃលើផលិតផល និងកំរៃរដ្ឋបាល នឹងសមស្របតាមវិធានរបស់ GATT នៅពេលណាដែលកំរៃនោះ ពុំត្រូវបានដាក់នៅលើផលិតផលនាំចូលក្នុងអត្រាមួយខ្ពស់ជាងអត្រាអនុវត្តចំពោះផលិតផលមានពន្ធក្នុងស្រុកទេ ។

ការប្រើប្រាស់ប្រាក់ចំណូល ដែលបានមកពីការអនុវត្តន៍ពន្ធផ្ទៃក្នុងលើការនាំចូល

តើគេអាចបង្កើតពន្ធផ្ទៃក្នុងលើផលិតផលមានគ្រឿងបំពុល ទាំងចំពោះផលិតផលក្នុងស្រុក និងនាំចូល ដើម្បីប្រមូលចំណូល សំរាប់ធ្វើហិរញ្ញប្បទានចំពោះកម្មវិធីបរិស្ថាន ជាគុណប្រយោជន៍ក្នុងស្រុករបស់គេតែប៉ុណ្ណោះបានឬទេ ? បញ្ហានេះត្រូវ បានគេពិចារណានៅឆ្នាំ ១៩៨៧ ក្នុងការពិភាក្សាដោះស្រាយវិវាទរបស់ GATT នៅលើមូលដ្ឋាននៃការតវ៉ារបស់សហគមន៍អឺរ៉ុប កាណាដា និង ម៉ិចស៊ិក ពាក់ព័ន្ធនឹងច្បាប់វិសោធនកម្មមូលនិធិពិសេស ច្បាប់ផ្តល់ការអនុញ្ញត្តិជាថ្មីរបស់សហរដ្ឋអាមេរិក។ ច្បាប់នេះ អនុញ្ញាត្តិអោយមានពន្ធលើធាតុគីមី ដែលនាំចូល និងដែលផលិតក្នុងស្រុក ដែលគេប្រើសំរាប់ផលិតនូវមូលបត្រ ដើម្បីធ្វើហិរញ្ញប្បទាន ចំពោះកម្មវិធីមូលនិធិ ពិសេសសំរាប់សំអាតកាកសំណល់ដ៏មានគ្រោះថ្នាក់ ដែលជាលទ្ធផលនៃផលិតកម្មឧស្សាហកម្មនៅក្នុងប្រទេស ។ សហរដ្ឋអាមេរិកអះអាងថា វិធានការនោះសមស្របទៅតាមមាត្រា៣ របស់ GATT ដែលអនុញ្ញាត្តិអោយ បណ្តាប្រទេសធ្វើការកែតំរូវលើពន្ធឆ្លងព្រំប្រទល់ តាមរយៈការយកពន្ធផ្ទៃក្នុងលើទំនិញនាំចូល ផ្អែកលើការគោរពតាមយ៉ាងតឹងរ៉ឹងនូវវិធានប្រព្រឹត្តិកម្មជាតិ។ សហគមន៍អឺរ៉ុបវិញ បានអះអាងថា គេពុំគួរយកពន្ធទៅលើទំនិញនាំចូលឡើយ ។

គណៈវិនិច្ឆ័យបានសំរេចថា ពន្ធនោះសមស្របទៅតាមគោលការណ៍ប្រព្រឹត្តិកម្មជាតិនៃមាត្រា៣ ពិតមែនហើយ ដូចនេះអាចយកមកប្រើសំរាប់ធ្វើការកែតំរូវលើពន្ធឆ្លងព្រំប្រទល់បាន ។ ចំពោះចំនុចដែលបានលើកឡើងដោយសហគមន៍អឺរ៉ុប គណៈវិនិច្ឆ័យបានធ្វើការកត់សំគាល់ដូចតទៅ ÷

កម្មវិធីស្លាកសញ្ញាធម្មជាតិ មានគោលដៅការពារបរិស្ថាន តាមរយៈការបង្កើតនូវការយល់ដឹងរបស់អ្នកប្រើប្រាស់ អំពីឥទ្ធិពលនៃផលិតផលចំពោះបរិស្ថាន ហើយដូចនេះនឹងធ្វើអោយមានការកែប្រែនូវឥរិយាបទក្នុងការទិញ ព្រមទាំង និងបំរែបំរួលលើលក្ខណៈរបស់ផលិតផលជាគុណប្រយោជន៍ ដល់ការប្រើប្រាស់សម្ភារៈ និងបច្ចេកវិទ្យាដែលកាន់តែប្រសើរចំពោះបរិស្ថាន ។ នៅក្នុងកម្មវិធីនេះស្លាកសញ្ញាត្រូវបានចាត់ទុកថា ជាវិធានការណ៍តាមលំអានទីផ្សារ ដែលមិនបង្កអោយមាននូវការទាមទារ ឬ ដាក់ដែនកំណត់ជាផ្លូវច្បាប់ណាមួយឡើយ ។

ឥទ្ធិពលពាណិជ្ជកម្មនៃប្រព័ន្ធស្លាកសញ្ញាធម្មជាតិ

វណ្ឌ ៥៥ មានតារាងមួយ ដែលបង្ហាញអំពីប្រព័ន្ធស្លាកសញ្ញាធម្មជាតិ ទាំងសំរាប់ប្រទេសជឿនលឿន និងប្រទេសកំពុងអភិវឌ្ឍន៍។ គេអាចឃើញបានថា ប្រព័ន្ធស្លាកសញ្ញាធម្មជាតិជាច្រើន ត្រូវបានឧបត្ថម្ភគាំទ្រដោយរដ្ឋាភិបាល ។ ដោយហេតុថា ផលិតផលដែលគេបង្កើតស្លាកសញ្ញាអោយនោះ ជាទូទៅមានចំនួនតិច ដូច្នេះគេក៏ពុំសូវមានភស្តុតាងច្រើន អំពីផលប៉ះពាល់ជាអវិជ្ជមានរបស់វាទៅលើវិស័យពាណិជ្ជកម្មដែរ ។ ប៉ុន្តែមានការអះអាងថា កម្មវិធីស្លាកសញ្ញានេះ អាចនាំអោយបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ទទួលរងនូវគុណវិបត្តិប្រកួតប្រជែង នៅពេលដែលគំរោងមួយចំនួន ដែលបច្ចុប្បន្នកំពុងស្ថិតនៅក្នុងការរៀបចំនៅឡើយ បានចាប់ផ្តើមដំណើរការ។ ការបំភ័យនេះ ត្រូវបានបំភ្លឺឡើងដោយកត្តាថា អ្នកផ្គត់ផ្គង់បរទេស ពុំមានលទ្ធភាពចូលរួមក្នុងការចរចា អំពីការជ្រើសរើសផលិតផល និងលក្ខណៈវិនិច្ឆ័យនៃស្លាកសញ្ញាធម្មជាតិឡើយ ។

ការលំបាកចំពោះផលិតករបរទេស ជាពិសេសនៃប្រទេសកំពុងអភិវឌ្ឍន៍ អាចនឹងមានកាន់តែច្រើន ប្រសិនបើលក្ខណៈវិនិច្ឆ័យ (ពិសេសដែលទាក់ទងនឹង PPMs) ត្រូវរងឥទ្ធិពលពីសំណាក់ឧស្សាហកម្មក្នុងស្រុក និងពីតំលៃបរិស្ថាន របស់ក្រុមជនទាំងឡាយនៅក្នុងប្រទេសដែលអនុវត្តប្រព័ន្ធនោះ ។ លើសពីនេះទៀត ផលិតករទាំងនោះ ស្ទើរតែគ្មានលទ្ធភាពទទួលបាននូវសិទ្ធិប្រើប្រាស់ស្លាកសញ្ញាធម្មជាតិផង-ប្រសិនបើ លក្ខណៈវិនិច្ឆ័យរវាងប្រទេសនិមួយៗមានការខុសគ្នា ។

វណ្ឌ ៥៥

តារាងបង្ហាញពីប្រព័ន្ធស្លាកសញ្ញាធម្មជាតិ

ប្រព័ន្ធស្លាកសញ្ញាគាំទ្រដោយរដ្ឋាភិបាល

☐ *ប្រទេសជឿនលឿន*

- *ទេវតាខៀវ : អាឡឺម៉ង់*
- *សញ្ញាធម្មជាតិ : ជប៉ុន*
- *ជំរើសបរិស្ថាន : កាណាដា*
- *បរិស្ថាន NF : បារាំង*
- *ក្ងានស : ប្រទេសនៅក្នុងតំបន់ណរឌីក*
- *ស្លាកសញ្ញាសហគមន៍អឺរ៉ុបប្រទេសអូស្ត្រាលី, អូទ្រីស ,ហូឡង់ និងណូវែលហ្សេឡង់ ក៏ចាប់ផ្តើមមានកម្មវិធីស្លាកសញ្ញាធម្មជាតិដែរ*

☐ *ប្រទេសកំពុងអភិវឌ្ឍន៍*

- *ឡូកូ ធម្មជាតិ : សាធារណៈរដ្ឋកូរ៉េ*
- *សញ្ញាធម្មជាតិ : ឥណ្ឌា*
- *ផ្លាកសញ្ញាបៃតង : សាំងហ្គាពួរ*

ការប្រឹងប្រែងបង្កើតប្រព័ន្ធស្លាកសញ្ញាធម្មជាតិ នៅក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ខ្លះៗ កំពុងស្ថិតក្នុងដំណាក់កាលផ្សេងៗនៃការអភិវឌ្ឍន៍ ។

គុណភាពបរិស្ថានណាមួយ ។ នៅក្នុងករណីខ្លះ ដើម្បីធានានូវភាពពិតប្រាកដនៃអំណះអំណាងខាងបរិស្ថាន ចំពោះមុខអ្នកប្រើប្រាស់ អំណះអំណាងនោះ អាចនឹងត្រូវទទួលនូវសេចក្ដីបញ្ជាក់អំពីទីពិសោធន៍ស្រាវជ្រាវ និងភ្នាក់ងារត្រួតពិនិត្យឯករាជ្យទៀតផង ។

ស្លាកសញ្ញាបរិស្ថានប្រភេទនេះ ចាំបាច់ត្រូវតែបែងចែកអោយដាច់ស្រលះ ពីស្លាកសញ្ញាដែលស្ថិតនៅក្នុងប្រភេទទីពីរ ដែលការប្រើប្រាស់វា ត្រូវបានអនុញ្ញាត្តិដោយអង្គការនានា ដោយរដ្ឋាភិបាល ឬ អង្គភាពឯករាជ្យជាឯកជន ដោយហេតុថា ផលិតករ ឬ អ្នកផ្គត់ផ្គង់ដែលបានដាក់ពាក្យសុំ បានគោរពតាមនូវលក្ខណៈវិនិច្ឆ័យ និងល័ក្ខខ័ណ្ឌទាំងឡាយ ដែលអង្គភាពនោះបានកំណត់ឡើង ចំពោះការផ្ដល់នូវស្លាកសញ្ញា ។ ស្លាកសញ្ញានៅក្នុងប្រភេទទីពីរ នេះជាទូទៅ មានឈ្មោះថា " ស្លាកសញ្ញាធម្មជាតិ " ។

ប្រព័ន្ធស្លាកសញ្ញាធម្មជាតិ

លក្ខណៈដ៏សំខាន់មួយនៃប្រព័ន្ធស្លាកសញ្ញាធម្មជាតិ គឺលក្ខណៈវិនិច្ឆ័យដែលប្រើសំរាប់ការផ្ដល់នូវសិទ្ធិអោយប្រើនូវផ្លាកសញ្ញានោះ ត្រូវបានរៀបចំឡើងដោយអង្គភាពស្លាកសញ្ញាធម្មជាតិ ។ លក្ខណៈវិនិច្ឆ័យទាំងនោះ ត្រូវបានកំណត់ស្ទើរតែជានិច្ចជាកាលទៅលើមូលដ្ឋាននៃការវិភាគវដ្តជីវិត គឺជាដំណើរការមួយដែលគេហៅថា វិធីសាស្ត្រតាំងពីកើតរហូតដល់ស្លាប់ ។ តាមវិធីសាស្ត្រនោះគេបានធ្វើការវាយតំលៃ ពីផលប៉ះពាល់របស់ផលិតផលមួយ នៅគ្រប់ដំណាក់កាលទាំងអស់នៃវដ្តជីវិតរបស់វា ។ ដំណាក់កាលទាំងនោះរួមមាន ពេលមុនផលិតកម្ម (ពោលពេលដំណើរការវត្ថុធាតុដើម) ផលិត បែងចែក (រួមទាំងវេចខ្ចប់) ប្រើប្រាស់ ឬ ហូបចុក និងពេលបោះចោលក្រោយពេលប្រើ ។

វិធីសាស្ត្រវិភាគវដ្តជីវិតមានការប្រែប្រួលពីប្រព័ន្ធមួយទៅប្រព័ន្ធមួយ ។ នៅក្នុងប្រព័ន្ធខ្លះ ការវិភាគលំអិតនូវផលប៉ះពាល់ដល់បរិស្ថាននៃផលិតផលមួយ ត្រូវបានធ្វើឡើងផ្អែកលើទិន្នន័យនៃធាតុចូល និងផលដែលបានមកចំពោះធាតុនីមួយៗ របស់ផលិតផល នៅគ្រប់ដំណាក់កាលនៃវដ្តជីវិតរបស់វា ។ ប្រពន្ធ័ខ្លះទៀត វិភាគផលប៉ះពាល់ដល់បរិស្ថាន ដោយពាក់ពន្ធ័តែទៅនឹងតំណាក់កាលណាមួយ នៅក្នុងវដ្តជីវិតរបស់ផលិតផលតែប៉ុណ្ណោះ ។ លក្ខណៈវិនិច្ឆ័យដែលធ្វើឡើងដោយអ្នកជំនាញការបច្ចេកទេស ផ្អែកលើការវិភាគវដ្តជីវិត ត្រូវបានអនុញ្ញាត្តិដោយគណៈកម្មាធិការត្រួតពិនិត្យ ដែលមានសមាជិកពីតំណាងឧស្សាហកម្មដែលពាក់ពន្ធ័ ក្រុមបរិស្ថាន អ្នកប្រើប្រាស់ និងក្រុមផ្សេងៗទៀត ព្រមទាំងរដ្ឋាភិបាល ។ ក្នុងករណីភាគច្រើន ថ្វីត្បិតតែផលប៉ះពាល់ដល់បរិស្ថាននៃផលិតផលមួយនៅគ្រប់តំណាក់កាលនៃផលិតកម្ម ត្រូវបានលើកយកមកគិតគូរក្ដី ក៏លក្ខណៈវិនិច្ឆ័យសំរេចចុងក្រោយ អាចនឹងផ្អែកតែទៅលើលក្ខណៈបរិស្ថានតែមួយ ឬ ពីរប៉ុណ្ណោះ (ឧទាហរណ៍ការប្រើប្រាស់ថាមពល លទ្ធភាពអាចកែច្នៃប្រើឡើងវិញបាន) ។

កំរិតនៃការចូលរួមរបស់រដ្ឋាភិបាលនៅក្នុងការធ្វើការសំរេចិត្ត ទាំងចំពោះការជ្រើសរើសផលិតផល និងទាំងចំពោះលក្ខណៈវិនិច្ឆ័យដែលប្រើសំរាប់ផ្ដល់អោយនូវស្លាកសញ្ញា មានការប្រែប្រួលពីប្រទេសមួយទៅប្រទេសមួយ ។ យ៉ាងហោចណាស់ ជាដំបូងអង្គភាពស្លាកសញ្ញាធម្មជាតិត្រូវពឹងផ្អែកទៅលើការគាំទ្រហិរញ្ញវត្ថុពីរដ្ឋាភិបាល ដែលជាពិសេស គឺដោយសារការងារស្រាវជ្រាវ និងបច្ចេកទេសសំរាប់រៀបចំលក្ខណៈវិនិច្ឆ័យ ដោយផ្អែកលើវិធីសាស្ត្រតាំងពីកើតរហូតដល់ស្លាប់ ទាមទារនូវការចាយវាយខ្ពស់។

បទបញ្ញត្តិលើការបង្កើតនូវអង្គភាពស្លាកសញ្ញាធម្មជាតិឯករាជ្យទាំងឡាយ ច្រើនតែទាមទារអោយគណៈកម្មាការត្រួតពិនិត្យ ដាក់ជូននូវសេចក្ដីសំរេចចិត្តរបស់ខ្លួន ចំពោះរដ្ឋាភិបាល ដើម្បីសុំការអនុម័ត ។ ប៉ុន្តែក្នុងករណីជាច្រើន រដ្ឋាភិបាលច្រើនតែមិនគ្រប់សង្កត់ទៅលើគណៈកម្មាការត្រួតពិនិត្យទេ ។ ឧទាហរណ៍ ចំពោះស្លាកសញ្ញាប្រទេស អូទ្រីស និងស្កង់ឌីណាវី សេចក្ដីស្នើឡើងរបស់គណៈកម្មាការត្រួតពិនិត្យ ភាគច្រើនតែងទទួលបាននូវការយល់ព្រម ។ ចំពោះស្លាកសញ្ញាទេវតាខៀវរបស់អាឡឺម៉ង់ គណៈកម្មាការត្រួតពិនិត្យ មានសិទ្ធិអំណាចដាច់ខាត ក្នុងការកំណត់នូវប្រភេទ និងលក្ខណៈវិនិច្ឆ័យរបស់ផលិតផល ។ ផ្ទុយទៅវិញ រដ្ឋាភិបាលបារាំងអាចកែប្រែយ៉ាងច្រើននូវលក្ខណៈវិនិច្ឆ័យផលិតផលដែលបានស្នើឡើង ដោយអង្គភាពរៀបចំស្តង់ដារ (The Association française de normalisation ឬ AFNOR) ។ នៅប្រទេសឥណ្ឌា តំណាងនៃបណ្ដាក្រសួងដូចជាបរិស្ថាន និងឧស្សាហកម្ម គឺជាសមាជិកនៃគណៈកម្មាធិការដឹកនាំមួយ ដែលមានភារៈជ្រើសរើសផលិតផល និងកំណត់នូវលក្ខណៈវិនិច្ឆ័យ។

ជារួម ការចូលរួមរបស់រដ្ឋាភិបាលនៅក្នុងកម្មវិធីស្លាកសញ្ញា ត្រូវបានទទួលនូវការស្វាគមន៍ ពីព្រោះរដ្ឋាភិបាលមានលទ្ធភាពប្រសើរជាងក្នុងការធានាអោយលក្ខណៈវិនិច្ឆ័យដែលបានកំណត់នោះ មានមូលដ្ឋានផ្អែកលើការពិចារណា អំពីគោលដៅត្រឹមត្រូវ ហើយបានឆ្លុះបញ្ចាំងនូវការថ្លឹងថ្លែងមតិរបស់ឧស្សាហកម្ម ក្រុមបរិស្ថាន និងក្រុមផ្សេងៗទៀតផង ។

- ☐ នៅទីណាដែលបទបញ្ញត្តិលើការវេចខ្ចប់មានភាពស្មុគស្មាញ ពីប្រទេសមួយទៅប្រទេសមួយ អ្នកផ្គត់ផ្គង់បរទេសអាចត្រូវអស់ចំណាយខ្ពស់ ដើម្បីធានាថាការនាំចេញរបស់ខ្លួន ស្របទៅតាមបទបញ្ញត្តិផ្សេងៗពីគ្នានោះ ។

- ☐ តំរូវការលើការវេចខ្ចប់ភាគច្រើនត្រូវបានធ្វើឡើង នៅលើមូលដ្ឋានសម្ភារៈវេចខ្ចប់ដែលប្រើប្រាស់ជាទូទៅ នៅក្នុងប្រទេសនាំចូល និងទៅលើលទ្ធភាពគ្រប់គ្រងសំរាម ឬ អាទិភាពដែលមាន ។ បទបញ្ញត្តិនោះអាចរាំងមិនអោយអ្នកផ្គត់ផ្គង់បរទេស បន្តប្រើប្រាស់សម្ភារៈវេចខ្ចប់របស់ប្រទេសផ្ទាល់ខ្លួនបាន ។

- ☐ អ្នកផ្គត់ផ្គង់បរទេស ជាពិសេសក្នុងប្រទេសកំពុងអភិវឌ្ឍន៍ អាចជួបការលំបាក ក្នុងការគោរពច្បាប់របស់ប្រទេសនាំចូល ដែលបានកំណត់នូវកាតព្វកិច្ចផ្សេងៗ ពាក់ព័ន្ធនឹងការប្រមូលយកវិញ និងប្រើប្រាស់ឡើងវិញ ការកែច្នៃប្រើឡើងវិញ ឬកំទេចជាស្ថាពរ នូវសំរាមជាសម្ភារៈវេចខ្ចប់ ប្រសិនបើ ÷
  - ពួកគេមើលឃើញថា ចំណាយកើតឡើងពីការចូលរួមក្នុងកម្មវិធីជាកាតព្វកិច្ច (សោហ៊ុយ សមាជិកភាព និងវិភាគទាន ឬក៏ចំណាយសំរាប់ធ្វើអោយការវេចខ្ចប់របស់ខ្លួនសមស្របទៅតាមកម្មវិធី) មានកំរិតខ្ពស់ បើធៀបទៅនឹងផលលក់ សរុបរបស់គេនៅក្នុងទីផ្សារនាំចូល និងប្រសិនបើ
  - កម្មវិធីនេះពុំសំពេញតាមតំរូវការចំពោះសម្ភារៈវេចខ្ចប់ដែលពួកគេប្រើ ។ ឧបករណ៍ កម្មវិធីនោះ អាចនឹងគិតគូរទៅដល់ការប្រមូលនូវគ្រឿងប្លាស្ទិក ក្រដាសជ្រួញៗ ឬ ផ្ទាំងក្រដាសរឹង ប៉ុន្តែពុំគិតគូរដល់ការប្រមូលយកនូវសម្ភារៈវេចខ្ចប់ជាឈើ ក្រចៅ ឬ សម្ភារៈផ្សេងៗទៀតដែល ប្រើប្រាស់ជាទូទៅ នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ឡើយ។

គេអាចកាត់បន្ថយនូវការលំបាកខ្លះៗ តាមរយៈការធ្វើអោយស៊ីសង្វាក់គ្នានូវតំរូវការលើការវេចខ្ចប់ និងបោះចោលជាអន្តរជាតិ ។ ប៉ុន្តែក៏នៅមានមន្ទិលដែរថា តើការធ្វើអោយស៊ីគ្នាសង្វាក់ជាអន្តរជាតិនោះ អាចធ្វើទៅបានឬទេ ហើយបើអាចទៅបាន តើគេពិតជាមានបំណងចង់ធ្វើដូច្នេះឬ ពីព្រោះតែវាមានភាពខុសៗគ្នាយ៉ាងខ្លាំងនៅ ក្នុងការផ្គត់ផ្គង់សម្ភារៈវេចខ្ចប់ លទ្ធភាពបោះចោលសំរាម និងរសនិយមរបស់ឧស្សាហកម្ម និងអ្នកប្រើប្រាស់នៅក្នុងប្រទេសនីមួយៗ ។

បទបញ្ញត្តិច្បាប់

កិច្ចព្រមព្រៀង TBT មានចែងនូវបទបញ្ញត្តិជាក់លាក់មួយចំនួនអំពីការវេចខ្ចប់ ។ ដូចបានកត់សំគាល់ពីមុនមកហើយថា កិច្ចព្រមព្រៀងនោះត្រូវបានអនុវត្តជាបឋម ចំពោះបទបញ្ញត្តិបច្ចេកទេស ដែលកំណត់នូវលក្ខណៈនៃផលិតផល ។ កិច្ចព្រមព្រៀងបញ្ជាក់ថានៅក្នុងលក្ខណៈនោះរួមត្រូវមាន " តំរូវការលើការវេចខ្ចប់... ឬលើស្លាកទំនិញ ហើយត្រូវអនុវត្តចំពោះផលិតផល វិធីដំណើរការ ឬ វិធីផលិត " ។

ការដាក់ស្លាកសញ្ញាបរិស្ថាន

ប្រភេទនៃស្លាកសញ្ញាបរិស្ថាន

ក្នុងឆ្នាំថ្មីៗនេះ គេឃើញមានការកើនឡើងយ៉ាងច្រើននូវការប្រើប្រាស់ស្លាកសញ្ញាបរិស្ថាន នៅលើផលិតផល ឬ កញ្ចប់របស់វា ដើម្បីសំរេចឡើងនូវនិមិត្តរូប ឬលក្ខណៈបរិស្ថាន ។ ស្លាកសញ្ញាទាំងនោះភាគច្រើន ធ្វើឡើងដោយការស្ម័គ្រចិត្ត ពីព្រោះសេចក្តីសំរេចចិត្តប្រើប្រាស់សញ្ញា ធ្វើឡើងដោយផលិតករ ឬពាណិជ្ជករ ដែលលក់ផលិតផលនោះ ក្រោមឈ្មោះពាណិជ្ជកម្មរបស់ខ្លួន។ ប៉ុន្តែនៅក្នុងករណីខ្លះ ការដាក់ស្លាកសញ្ញា អាចនឹងត្រូវបង្ខំដោយបទបញ្ញត្តិកាតព្វកិច្ច ។ បទបញ្ញត្តិបែបនោះមានបំណងដាស់តឿនអ្នកប្រើប្រាស់ ឱ្យប្រឆាំងនឹងគុណភាពប្រកបដោយគ្រោះថ្នាក់ ដល់បរិស្ថាននៃផលិតផល ឧទាហរណ៍នៅលើសារធាតុ Chlorofluo rocarlon (CFC) ។

ស្លាកសញ្ញាបរិស្ថានដោយស្ម័គ្រចិត្ត ត្រូវបានគេប្រើប្រាស់ជាបច្ចេកទេសលក់ដូរ ដើម្បីជំរុញការលក់ផលិតផល នៅលើមូលដ្ឋាននៃនិមិត្តរូបបរិស្ថានរបស់វា ។ ស្លាកនោះអាចត្រូវបានគេចែកចេញជាពីរប្រភេទធំៗ ។ នៅក្នុងប្រភេទទីមួយ រួមមានស្លាកសញ្ញាបរិស្ថានសំរាប់ម៉ាឃីតទីង ដែលសំដែងអោយឃើញនូវការអះអាងរបស់ផលិតករ ឬ ពាណិជ្ជករថា ផលិតផលនោះ មានលក្ខណៈ ឬ

ពីសំណាក់សាខាក្រុមហ៊ុនបុត្តសម្ព័ន្ធក្នុងស្រុករបស់ TNC ។ ឧទាហរណ៍ នៅសហរដ្ឋអាមេរិក នៅពេលដែលផលិតកររថយន្តរបស់ជប៉ុន ឈានចូលទៅក្នុងទីផ្សារក្នុងស្រុក តាមរយៈ FDI បានធ្វើអោយផលិតករយានយន្តក្នុងស្រុកធំៗ (ដែលជាក្រុមហ៊ុនពហុជាតិ) ត្រូវខិតខំលើកកំពស់ផលិតផលរបស់ខ្លួន និងបង្កើននូវប្រសិទ្ធិភាពរោងចក្រផលិតកម្មក្នុងស្រុក ។ ទាំងអស់នេះជាផលប្រយោជន៍ចំពោះអ្នកប្រើប្រាស់ទាំងអស់ នៅក្នុងសហរដ្ឋអាមេរិក ទោះបីគេទិញយានយន្តជប៉ុន ឬអាមេរិកកាំងក្តី ។ មានភស្តុតាងគួរអោយកត់សំគាល់ថា គុណប្រយោជន៍ប្រហាក់ប្រហែលគ្នានេះ កើតមានឡើងចំពោះប្រទេសកំពុងអភិវឌ្ឍន៍ដែរ ។ ឧទាហរណ៍ពីសាធារណរដ្ឋកូរ៉េ បានចូលរួមចំណែកក្នុងការអភិវឌ្ឍន៍ឧស្សាហកម្មនាំចេញវាយនភ័ណ្ឌនៅក្នុងស្រុកនៃប្រទេសបង់ក្លាដេស្ស ។

ក្នុងករណីជាច្រើន FDI អាចនឹងនាំមកនូវការហូរចូលនូវចំណេះដឹង ច្រើនជាងវិធីដទៃទៀតសំរាប់បំរើដល់ទីផ្សារ ។ ក្នុងខណៈដែលមានការនាំចូលផលិតផលបច្ចេកវិទ្យាខ្ពស់ នោះការទិញ ឬ ការផ្តល់អាជ្ញាប័ណ្ណបច្ចេកវិទ្យាបរទេស គឺជាបណ្តាញយ៉ាងសំខាន់សំរាប់បញ្ជូលបច្ចេកវិទ្យាជាអន្តរជាតិ ហើយ FDI បានផ្តល់នូវវិសាលភាពកាន់តែធំ ដើម្បីបញ្ចូលអោយបានច្រើននូវបច្ចេកវិទ្យា ។ ឧទាហរណ៍ បច្ចេកវិទ្យា និងផលិតភាពរបស់ក្រុមហ៊ុន ក្នុងស្រុកអាចនឹងកើនឡើង នៅពេលណាក្រុមហ៊ុនបរទេសបានចូលទៅក្នុងទីផ្សារ និងបង្ហាញនូវបច្ចេកវិទ្យាថ្មីៗ ព្រមទាំងវិធីថ្មីៗនៃការចាត់ចែង និងបែងចែក បានផ្តល់នូវជំនួយបច្ចេកទេស ចំពោះអ្នកផ្គត់ផ្គង់ជាជនក្នុងស្រុក និងអ្នកប្រើប្រាស់ ហើយផ្តល់ការបណ្តុះបណ្តាលដល់អ្នកធ្វើការ និងអ្នកចាត់ការដែលនឹងអាចត្រូវបានជ្រើសរើសអោយធ្វើការក្នុងក្រុមហ៊ុនក្នុងស្រុក នៅពេលក្រោយទៀត ។ បុត្រសម្ព័ន្ធនៅបរទេស អាចធ្វើការស្រាវជ្រាវ និងអភិវឌ្ឍន៍សកម្មភាពដោយខ្លួនឯង សំដៅសំរបតាមការរៀបចំថ្មី ៗ របស់ក្រុមហ៊ុនជាមេបាដែរ ទៅតាមល័ក្ខខ័ណ្ឌក្នុងស្រុក ។ ជាក់ស្តែង FDI បាននាំអោយមានទំនាក់ទំនងបុគ្គលកាន់តែច្រើនឡើងៗ ជាមួយជនបរទេស និងបើកចំហរទៅរកផ្លូវថ្មីៗ ក្នុងការធ្វើអ្វីផ្សេងៗច្រើនជាងដែល ផ្នែកពាណិជ្ជកម្មអាចធ្វើបានទៅទៀត។

FDI និងសកម្មភាពប្រឆាំងនឹងការប្រកួតប្រជែង

ជាទូទៅ FDI តាមរយៈការបង្កើតនូវភាពពុំសូវមានលំនឹងនៃទីផ្សារ (ពោលគឺភាពដែលអាចបត់បែនបាននៃការចូល និងចាកចេញរបស់ក្រុមហ៊ុន) នាំអោយកើនឡើងនូវការប្រកួតប្រជែង ។ តែនៅក្នុងស្ថានភាពខ្លះ អ្នកប្រើប្រាស់ និងអ្នកហូបចុក នៅក្នុងប្រទេសជាម្ចាស់ផ្ទះ អាចនឹងពុំទទួលផលប្រយោជន៍ពីវិនិយោគបែបនេះ តាមរយៈថ្លៃទាបជាងមុន និងគុណភាពទំនិញ និងសេវាកម្មប្រសើរជាមុនឡើយ ប្រសិនបើ TNC ដែលធ្វើវិនិយោគនៅក្នុងប្រទេសនោះ មានលទ្ធភាពកំណត់ថ្លៃផ្តាច់មុខតាមរយៈការកាន់កាប់នូវជំហរមួយដ៏ធំលើសលប់ (សូមអានជំពូក ២៣ ផងដែរ)។

FDI និងវិនិយោគប្រកបដោយសមធម៌លើផលប័ត្ររបស់បរទេស

FDI ពាក់ព័ន្ធនឹងសេចក្តីសំរេចធ្វើវិនិយោគនៅក្នុងប្រទេសមួយទៀត តាមរយៈការបង្កើតសាខាក្រុមហ៊ុនសម្ព័ន្ធ ឬ ចំរុះ ។ ឆ្នាំកន្លងទៅថ្មីៗនេះ ក៏បានបង្ហាញនូវការកើនឡើងនូវលំហូរមូលនិធិ សំរាប់វិនិយោគប្រកបដាយសមធម៌ លើផលប័ត្របរទេសដែរ (FPEI) ។ តាមរយៈការចូលរួមទៅក្នុងដើមទុនរបស់ក្រុមហ៊ុន ទាំង FDI និងទាំង FPEI អាចពង្រឹងការអភិវឌ្ឍន៍វិស័យសហគ្រាសនៃប្រទេសជាម្ចាស់ផ្ទះបាន ។ ប៉ុន្តែក៏មានភាពខុសគ្នាដែរ រវាងកត្តាជំរុញការវិនិយោគទាំងពីរប្រភេទ និងផលប៉ះពាល់រយៈពេលខ្លី និងវែង ដែលការវិនិយោគទាំងនោះ អាចមានទៅលើសេដ្ឋកិច្ចរបស់ប្រទេសជាម្ចាស់ផ្ទះ ។

ជាគោលការណ៍ FPEI ខុសគ្នាពី FDI ដោយកំរិតនៃការត្រួតពិនិត្យលើការគ្រប់គ្រង ដែលវិនិយោគិនបរទេសអនុវត្ត នៅលើការវិនិយោគរបស់ខ្លួន ។ វិនិយោគមួយត្រូវបានចាត់ទុកថាជា FDI នៅពេលណាវាពាក់ព័ន្ធ នឹងភាគហ៊ុនដើមទុន១០% ឬលើសពីនេះ[៣២] នៃភាគហ៊ុនដើមរបស់សហគ្រាសអាជីវកម្ម ឬមានកំរិតសមាមាត្រសមស្របមួយ ចំពោះសហគ្រាសមិនមែនសាជីវកម្ម។

[៣២] ក្បួនដញ្ញើងទូទាត់សំរាប់ IMF បានចែងថា FDI ជាវិនិយោគ ដែលឆ្លុះបញ្ចាំងនូវគោលបំណងនៃអង្គភាពដែលមាននិវាសនដ្ឋាននៅក្នុងសេដ្ឋកិច្ចមួយសំដៅចង់បានភាគហ៊ុនយូរអង្វែងនៅក្នុងសហគ្រាសមួយ នៅក្នុងសេដ្ឋកិច្ចមួយទៀត ហើយភាគហ៊ុនយូរអង្វែងនោះ មានន័យថាជាអត្ថិភាពនៃទំនាក់ទំនងរវាងវិនិយោគផ្ទាល់ និងសហគ្រាសព្រមទាំងឥទ្ធិពល ក្នុងកំរិតគួរអោយកត់សំគាល់មួយ នៃវិនិយោគទៅលើការគ្រប់គ្រងសហគ្រាសនោះ ។ ពាក្យថាភាគហ៊ុនយូរអង្វែង ត្រូវបានទទួលនិយមន័យពី IMF ដោយពុំសំដៅ លើរយៈវេលាណាមួយឡើយ ហើយលក្ខណៈវិនិច្ឆ័យសំខាន់ ដែលបានកំណត់ គឺកំរិតនៃកម្មសិទ្ធិនៅលើសហគ្រាស។ កំរិតប្រមាណ ១០% ឬលើសពីនេះនៅលើកម្មសិទ្ធិ ភាគច្រើនត្រូវបានចាត់ទុកថា បានឆ្លុះបញ្ចាំងនូវភាពមានភាគហ៊ុនយូរអង្វែងហើយ ។

ជាធម្មតាវិនិយោគិនលើលប័ត្ររយៈពេលខ្លី ផ្តល់នូវដើមទុនហិរញ្ញវត្ថុ តាមរយៈការទិញនូវភាគហ៊ុនរបស់ក្រុមហ៊ុន ដោយពុំមានពាក់ព័ន្ធទៅក្នុងការគ្រប់គ្រងក្រុមហ៊ុនឡើយ ។ ប្រភេទនៃវិនិយោគិនក៏ខុសៗគ្នាដែរ ។ ក្នុងខណៈដែលវិនិយោគ FDI ជាក្រុមហ៊ុនកេទទួលទាននៅក្នុងផលិតកម្មទំនិញ និងសេវាកម្ម វិនិយោគិនលើផលប័ត្រភាគច្រើន គឺជាស្ថាប័នហិរញ្ញវត្ថុ វិនិយោគិន ជាស្ថាប័ន (ដូចជាមូលនិធិសោធន៍និវត្តន៍ ក្រុមហ៊ុនធានារ៉ាប់រង ឬ ក្រុមហ៊ុនវិនិយោគ) ឬ ក៏ជាបុគ្គលដែលមានការយកចិត្តទុកដាក់ជាបឋមលើចំណូលហិរញ្ញវត្ថុពីការវិនិយោគរបស់ខ្លួន ។

ភាពខុសគ្នានេះបញ្ជាក់នូវភាពផ្សេងគ្នានៃកត្តាជំរុញអោយធ្វើ FDI ឬ FPEI ។ ក្នុងការធ្វើ FDI ពួក TNCs មានការយកចិត្តទុកដាក់ទៅលើការធានាថា ធាតុផ្សំដែលគេត្រូវការ ឬផលិតសំរេចដែលគេផលិតបាន នឹងត្រូវបានផលិតដោយវិធីយ៉ាងមានប្រសិទ្ធិភាព និងអស់ចំណាយតិច ។ ដូច្នេះការសំរេចចិត្តរបស់គេភាគច្រើន ត្រូវរងឥទ្ធិពល នៃលទ្ធផលរយៈពេលវែង ដែលការវិនិយោគមួយអាចនឹងមានទៅលើការប្រកួតប្រជែង របស់អាជីវកម្មទាំងមូល ព្រមទាំងលើចំណូលអំពីដើមទុនដែលបានវិនិយោគ និងបច្ចេកវិទ្យាដែលបានផ្តល់ ។ ចំណែកកត្តាជំរុញសំខាន់ចំពោះវិនិយោគ ធ្វើឡើងដោយវិនិយោគិនលើផលប័ត្រ គឺការចូលរួមចំណែករបស់គេ នៅក្នុងប្រាក់ចំណូលក្នុងស្រុក តាមរយៈប្រាក់ចំណេញលើដើមទុន ឬ ភាគលាភ ។ ការយកចិត្តទុកដាក់របស់គេលើទ្រព្យសម្បត្តិរយៈកាលវែងរបស់សហគ្រាស គឺមានកំរិតប៉ុណ្ណោះ ។

ដូច្នេះលំហូរ FPEI មានទំនោរមិននឹងនរ ។ វិនិយោគិនសាកល្បងនឹងជំរះវិនិយោគខ្លួន តាមរយៈការលក់នូវភាគហ៊ុនខ្លួននៅក្នុងទីផ្សារទីពីរ ប្រសិនបើផលចំណេញមានការថយចុះ ឬថ្លៃភាគហ៊ុនធ្លាក់ចុះ ។ ចំណែក TNCs វិញមានទំនោរពិចារណាវែងឆ្ងាយទៅលើការវិនិយោគរបស់ខ្លួន ។ ទោះបីជានៅក្នុងស្ថានភាពមានវិបត្តិក្តី ពួកគេអាចមានការស្ទើរស្ទាក់ ក្នុងការលក់ជំរុះភាគហ៊ុនរបស់គេនៅក្នុងក្រុមហ៊ុនសម្ព័ន្ធ នៅពេលណាដែលចំណាយថេរខ្ពស់ ហើយផលិតកម្មរបស់ក្រុមហ៊ុនសម្ព័ន្ធមានការពាក់ព័ន្ធ នឹងផលិតកម្មអន្តរជាតិ។

ជាក់ស្តែងភាពខុសគ្នានៃកំរិតមិននឹងនរវាង FPEI និង FDI អាចនឹងមិនធ្ងន់ធ្ងរដូចពិពណ៌នាពីខាងលើ ហើយត្រូវអាស្រ័យទៅលើយន្តការ ដែលប្រើសំរាប់ជាបណ្តាញបញ្ជូនវិនិយោគលើមូលប័ត្រ ។ មូលនិធិជាមូលប័ត្រភាគច្រើនត្រូវបានទទួលការវិនិយោគពីសំណាក់ក្រុមហ៊ុនវិនិយោគផ្សេងៗ ដើមទុនដែលផ្តល់ដើមទុនដល់ក្រុមហ៊ុនថ្មីៗ នៅតំណាក់កាលចាប់ផ្តើមដំបូង ។ ជាញឹកញាប់គេចូលរួមក្នុងការគ្រប់គ្រងក្រុមហ៊ុនដោយផ្ទាល់ ឬ ដោយប្រយោលតាមរយៈការផ្តល់នូវសេវាណែនាំ ។ ថ្វីត្បិតតែកត្តាសំខាន់ជំរុញអោយមានផលចំណេញពីដើមទុនក្តី ក៏វិនិយោគិនដើមទុន ច្រើនតែរង់ចាំយូរឆ្នាំដែរមុននឹងលក់នូវភាគហ៊ុនខ្លួន ។

វិធានការរបស់រដ្ឋាភិបាលក្នុងការជំរុញការវិនិយោគ

ការបន្ធូរបន្ថយនូវរបបគ្រប់គ្រងតាមបញ្ញត្តិច្បាប់

ក្នុងរយៈពីរទសវត្សចុងក្រោយនេះ យើងអាចមើលឃើញពីការធ្វើសេរីភាវូបនីយកម្មយ៉ាងដុះដាលខាងផ្នែកច្បាប់ និងការគ្រប់គ្រងទៅលើការវិនិយោគបរទេស ជាពិសេសនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ និងប្រទេសដែលមានសេដ្ឋកិច្ចអន្តរកាល ។ ក្នុងករណីជាច្រើនការធ្វើសេរីភាវូបនីយកម្មវិនិយោគបរទេសនេះ គឺជាផ្នែកមួយនៃកំណែទំរង់ទៅរកសេដ្ឋកិច្ចទីផ្សារនៃនយោបាយសេដ្ឋកិច្ចពាក់ព័ន្ធ នឹងសេរីភាវូបនីយកម្មពាណិជ្ជកម្ម ការលប់ចោលនូវបទបញ្ញត្តិ និងការធ្វើឯកជនភាវូបនីយកម្ម។ វិធានការអនុវត្តរួមមាន ÷

- ☐ ការសំរួលនូវតំរូវការត្រួតពិនិត្យជ្រើសរើស ចំពោះការអនុម័តលើ FDI ដែលហូរចូលមក
- ☐ ការបើកចំហរឧស្សាហកម្មចំពោះវិនិយោគបរទេស
- ☐ ការកាត់បន្ថយអោយដល់កំរិតអប្បបរិមានូវការដាក់កំហិតលើការចូលរួមភាគហ៊ុនរបស់បរទេស
- ☐ ការជំរុញអោយវិនិយោគិនបរទេស យកចិត្តទុកដាក់លើដំណើរការឯកជនភាវូបនីយកម្ម និងលើការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ (ជាផ្នែកពីរ ដែលទាមទារដើមទុនច្រើន និងការវិនិយោគលើបច្ចេកវិទ្យា)

ការផ្តល់ការលើកទឹកចិត្តវិនិយោគ

ក្រៅពីនេះ ប្រទេសស្ទើរតែទាំងអស់បានផ្តល់នូវការលើកទឹកចិត្ត ដើម្បីទាក់ទាញការវិនិយោគ ។ ការលើកទឹកចិត្ត អាចផ្តល់ជូនក្នុងលំនាំបីប្រភេទដូចតទៅ ÷

- ☐ ការលើកទឹកចិត្តផ្នែកហិរញ្ញវត្ថុ រួមមានការផ្តល់នូវមូលនិធិដោយផ្ទាល់ ចំពោះវិនិយោគិនបរទេស ដោយរដ្ឋាភិបាលជាម្ចាស់ផ្ទះ ឧទាហរណ៍ ក្រោមរូបភាពជាអំណោយវិនិយោគ និងឥណទានឧបត្ថម្ភធន ។
- ☐ ការលើកទឹកចិត្តផ្នែកសារពើពន្ធ សំដៅកាត់បន្ថយបន្ទុកពន្ធជាជារួមចំពោះវិនិយោគិនបរទេស ។ ក្នុងប្រភេទនៃការលើកទឹកចិត្តបែបនេះមានដូចជា រយៈពេលលើកលែងពន្ធលើប្រាក់ចំណេញ និងការលើកលែងពន្ធនាំចូលលើវត្ថុដើម វត្ថុធាតុពាក់កណ្តាលសំរេច និងទំនិញមូលធន ។
- ☐ ការលើកទឹកចិត្តដោយប្រយោល សំដៅពង្រឹងលទ្ធភាពទាញយកចំណេញពីវិនិយោគិន ដោយវិធីប្រយោលផ្សេងៗ ។ ឧទាហរណ៍ : រដ្ឋាភិបាលអាចផ្តល់ដីធ្លី និងហេដ្ឋារចនាសម្ព័ន្ធណាមួយ អោយគេក្នុងតំលៃទាបជាងថ្លៃពាណិជ្ជកម្ម ។ ឬគេអាចផ្តល់ដល់ក្រុមហ៊ុនបរទេសនូវជំហរទីផ្សារ ពិសេសក្រោមរូបភាព ជាការទទួលបានដោយភាពអនុគ្រោះក្នុងការធ្វើកិច្ចសន្យាជាមួយរដ្ឋាភិបាល ជំហរផ្តាច់មុខ ការបិទទីផ្សារមិនអោយមានការចូលផ្សេងៗទៀត ការការពារចំពោះការប្រកួតប្រជែងពីការនាំចូល ឬ ប្រព្រឹត្តកម្មគ្រប់គ្រងពិសេសឯទៀតៗ ។

ការដាក់លក្ខខ័ណ្ឌលើការអនុវត្តន៍

ប្រទេសមួយចំនួន ជាពិសេសកំពុងអភិវឌ្ឍន៍ បានដាក់ល័ក្ខខ័ណ្ឌលើការអនុវត្តន៍ ដើម្បីធានាអោយការវិនិយោគទាំងឡាយ ដំណើរការស្របតាមគោលដៅ និងអាទិភាពជាតិរបស់ខ្លួន ។ ជារួមល័ក្ខខ័ណ្ឌនោះ ទាមទារវិនិយោគិនបរទេសអោយ ÷

- ☐ ផលិតនូវវត្ថុធាតុដែលប្រើនៅក្នុងផលិតផលសំរេច តាមចំនួនភាគរយណាមួយនោះ នៅក្នុងប្រទេសជាម្ចាស់ផ្ទះ (តំរូវការប្រើប្រាស់វត្ថុធាតុដើមក្នុងស្រុក) ។
- ☐ នាំចេញនូវទំនិញ និងសេវាកម្មក្នុងកំរិតណាមួយ នឹង
- ☐ សំរេចបាននូវការស្រាវជ្រាវ និងអភិវឌ្ឍន៍នៅក្នុងប្រទេស តាមកំរិតណាមួយ ។

លិខិតុបករណ៍វិនិយោគទ្វេភាគី តាមតំបន់ និងពហុភាគី

សិទ្ធិសញ្ញាវិនិយោគទ្វេភាគី

បំណងរបស់រដ្ឋាភិបាលក្នុងការសំរួលលំហូរ FDI ក៏បានឆ្លុះបញ្ចាំងនៅក្នុងការកើនឡើងដ៏ខ្លាំង នៃសិទ្ធិសញ្ញាវិនិយោគទ្វេភាគីសំរាប់ការពារ និងជំរុញការវិនិយោគក្នុងអំឡុងទសវត្សទី ៩០ ដែរ ។ មកដល់ត្រឹមថ្ងៃ ១ មករា ១៩៩៧ មានសិទ្ធិសញ្ញាបែបនេះចំនួន ១៣៣០ ពាក់ព័ន្ធនឹងប្រទេសចំនួន ១២០ ធៀបទៅនឹងសិទ្ធិសញ្ញាចំនួន ៤៤០ នៅដើមទសវត្សន៍ ។

សិទ្ធិសញ្ញាប្រមាណ៦២% ជាសន្ធិសញ្ញាដែលបានធ្វើឡើងរវាងប្រទេសជឿនលឿន និងប្រទេសកំពុងអភិវឌ្ឍន៍ ។ ប្រទេសជឿនលឿនដែលសកម្មនៅក្នុងការចរចាលើសិទ្ធិសញ្ញានោះ ជាមួយប្រទេសកំពុងអភិវឌ្ឍន៍ រួមមាន ប្រទេសបារាំង អាល្លឺម៉ង់ ហូឡង់ អង់គ្លេស និងសហរដ្ឋអាមេរិក ។ សិទ្ធិសញ្ញានោះសង្កត់ធ្ងន់ទៅលើការការពារផលប្រយោជន៍របស់ក្រុមហ៊ុនវិនិយោគ ពីការធ្វើជាតូបនីយកម្ម ការតបស្នងចំពោះកំហាតដែលកើតមានដោយទំនាស់ប្រដាប់អាវុធ ឬ ការគ្មានសណ្តាប់ធ្នាប់ផ្ទៃក្នុង និងការផ្ទេរនូវប្រាក់ទូទាត់ផ្សេងៗ។ ជាទូទៅ និយមន័យនៃការវិនិយោគដែលប្រើ ច្រើនគ្របដណ្តប់ទាំង FDI និងទាំងការវិនិយោគភាគហ៊ុនជាមូលប័ត្ររបស់បរទេស។ សិទ្ធិសញ្ញាខ្លះ អនុញ្ញាត្តិអោយមានការពង្រីកនូវប្រព្រឹត្តកម្មជាតិ ។ បទបញ្ញាតិបែបនោះ ទាមទារភាគីទាំងឡាយមិនត្រូវផ្តល់នូវការអនុគ្រោះ ចំពោះវិនិយោគិនបរទេសតិចជាងអ្វី ដែលផ្តល់ចំពោះវិនិយោគិនក្នុងស្រុកទេ ហើយអាចអនុវត្តបាន តែក្រោយ

ពេលគេបានបង្កើតរោងចក្រផលិតកម្មក្នុងស្រុក ឬ បង្កើតក្រុមហ៊ុនពាណិជ្ជកម្មក្នុងប្រទេសជាម្ចាស់ផ្ទះ។ មានកិច្ចព្រមព្រៀងតែមួយចំនួនតូចប៉ុណ្ណោះ ដែលអនុញ្ញាត្តិអោយពង្រីកប្រព្រឹត្តកម្មជាតិ នៅពេលវិនិយោគទើបចូលមកដល់ ។

ប្រទេសកំពុងអភិវឌ្ឍន៍ កំពុងចាប់ផ្តើមបង្កើតសិទ្ធិសញ្ញាវិនិយោគទ្វេភាគីជាមួយគ្នាទៅវិញទៅមកដែរ ។ នៅឆ្នាំ ១៩៩៧ មានសន្ធិសញ្ញាប្រភេទនេះចំនួន ១១% បានធ្វើឡើងរវាងប្រទេសកំពុងអភិវឌ្ឍន៍ ។ ប្រទេសដែលសកម្មក្នុងការអនុម័តសិទ្ធិសញ្ញានេះជាបឋម គឺជាមួយប្រទេសកំពុងអភិវឌ្ឍន៍ឯទៀត នៅក្នុងតំបន់របស់ខ្លួនមាន អាល់ហ្សេរី ស៊ីលី ចិន និងសាធារណរដ្ឋកូរ៉េ។ ការអភិវឌ្ឍន៍នេះឆ្លុះបញ្ចាំង នូវការកើតឡើងនូវក្រុមហ៊ុនពីប្រទេសកំពុងអភិវឌ្ឍន៍ ដែលជាវិនិយោគិន មានទិសដៅទៅខាងក្រៅប្រទេស ។

កិច្ចព្រមព្រៀងតំបន់សំរាប់ដោះស្រាយបញ្ហាវិនិយោគ

ជាបន្ថែមទៅលើសិទ្ធិសញ្ញាទ្វេភាគីទាំងនោះ គេបានរៀបចំកិច្ចព្រមព្រៀងជំរុញការវិនិយោគបរទេសថែមទៀត នៅលើមូលដ្ឋានតំបន់ ក្នុងក្របខ័ណ្ឌនៃកិច្ចព្រមព្រៀងសហប្រតិបត្តិការក្នុងតំបន់ ។ កិច្ចព្រមព្រៀងតំបន់ រួមមានបទបញ្ញត្តិដែលចែងពីប្រព្រឹត្តកម្មដោយមិនរើសអើងចំពោះវិនិយោគិនបរទេស និងបានដាក់បញ្ចូលនៅក្នុងសិទ្ធិសញ្ញាក្រុងរ៉ូម ដែលបង្កើតសហគមន៍សេដ្ឋកិច្ចអឺរ៉ុប កិច្ចព្រមព្រៀងអំពីតំបន់សេដ្ឋកិច្ចអឺរ៉ុប និងកិច្ចព្រមព្រៀងបង្កើត ASEAN MERCOSUR និង NAFTA ។ ក្នុងនោះកិច្ចព្រមព្រៀងភាគច្រើន បានអនុញ្ញាត្តិអោយមានការពង្រីកនូវប្រព្រឹត្តកម្មជាតិ ចំពោះវិនិយោគបរទេសទាំងក្នុងដំណាក់កាលមុនពេលចូល និងក្រោយពេលចូលមក ។

កិច្ចព្រមព្រៀងពហុភាគីស្តីពីវិនិយោគ

ថ្វីត្បិតតែកន្លងមកមានការខិតខំជាច្រើនហើយក្តី ក្នុងការបង្កើតវិធានការច្បាស់ជាពហុភាគី ដែលចងក្រងនូវវិធានសំខាន់ៗ និងយ៉ាងលំអិតអំពីការវិនិយោគបរទេស តែគ្មានការខិតខំណាមួយទទួលបានជោគជ័យឡើយ ។ ថ្មីៗនេះមានការចរចាក្នុងចំណោមបណ្តាប្រទេស OECD អំពីការបង្កើតនូវកិច្ចព្រមព្រៀងពហុភាគីយ៉ាងទូលំទូលាយមួយស្តីពីការវិនិយោគ ។ ថ្វីត្បិតតែការចរចានោះត្រូវបានធ្វើឡើង ក្នុងចំណោមប្រទេសសមាជិក OECD ក្តី ក៏ពួកគេបានប្រកាសថា កិច្ចព្រមព្រៀងដែលនឹងធ្វើឡើង នឹងបើកចំហរអោយមានការចូលរួមពីសំណាក់ប្រទេសដ៏ទៃទៀតដែរ ។ ពង្រាងនៃកិច្ចព្រមព្រៀងមានគោលដៅកំណត់នូវកាតព្វកិច្ច ចំពោះប្រទេសជាសមាជិក អោយពង្រីកនូវការមិនរើសអើងចំពោះវិនិយោគិនបរទេស និងក្នុងស្រុក ទាំងនៅដំណាក់កាលមុន និងក្រោយការបង្កើត ដោយអនុវត្តន៍នូវគោលការណ៍ប្រព្រឹត្តកម្មជាតិ អោយលប់បំបាត់នូវការដាក់លក្ខខ័ណ្ឌលើលក្ខណៈផលិតផល និងដាក់វិន័យក្នុងការប្រើប្រាស់ការលើកទឹកចិត្តវិនិយោគតាមរយៈការអនុវត្តន៍គោលការណ៍ជាមូលដ្ឋានបី MFN ប្រព្រឹត្តកម្មជាតិ និងតម្លាភាព ។

ប៉ុន្តែការចរចាបានបញ្ចប់ទៅដោយមិនសំរេចបាននូវការឯកភាពណាមួយ នៅក្នុងពង្រាងអត្ថបទនៃកិច្ចព្រមព្រៀងឡើយ ដោយសារតែការមានមតិខុសៗ គ្នាជាខ្លាំង ក្នុងចំណោមប្រទេសចូលរួម ពីការរួមបញ្ចូលនូវបទប្បញ្ញត្តិពិសេសស្តីពីពលករ បរិស្ថាន និងវប្បធម៌ ។

វណ្ឌ ៥៧ បង្ហាញនូវវិធានការណ៍វិនិយោគជាពហុភាគីខ្លះៗ ដែលមានសុពលភាព នាពេលបច្ចុប្បន្ន។ ក្នុងនោះ វិធានការដែលកំណត់កាតព្វកិច្ចតាមផ្លូវច្បាប់មានលក្ខណៈតូចតាច និងពុំមានបង្កើតជាបទដ្ឋានសំខាន់ៗអ្វីទេ ក្នុងខណៈដែលវិធានការដែលមានកំណត់បទដ្ឋានសំខាន់ៗពុំមានលក្ខណៈជាកាតព្វកិច្ចជាផ្លូវច្បាប់ឡើយ ។

ខណ្ឌ ៥៧

លិខិតុបករណ៍ស្តីពីការវិនិយោគបរទេសជាពហុភាគីដែលមានជាធរមាន

នៅក្នុងក្រុមធនាគារពិភពលោក គេមានដាក់បញ្ចូលនូវលិខិតុបករណ៍ពហុភាគីពីរ ដែលមានលក្ខណៈជាច្បាប់ និងពាក់ព័ន្ធជាពិសេស ទៅនឹងការវិនិយោគបរទេស ។ មួយគឺសិទ្ធិសញ្ញាស្តីពីការដោះស្រាយវិវាទនៃការវិនិយោគរវាងរដ្ឋ

និងជនជាតិនៃរដ្ឋដទៃទៀត ដែលបានធ្វើឡើងនៅឆ្នាំ ១៩៦៥ និងចូលជាធរមាននៅខែកញ្ញា ឆ្នាំ១៩៦៦ ។ សិទ្ធិសញ្ញាបាន កំណត់នូវមធ្យោបាយសំរាប់ដោះស្រាយវិវាទ រវាងវិនិយោគិន និងរដ្ឋ តាមរយៈការផ្សះផ្សារ និងមជ្ឈត្តវិនិច្ឆ័យនៅក្នុង មជ្ឈមណ្ឌលអន្តរជាតិសំរាប់ដោះស្រាយវិវាទនៃការវិនិយោគ (ICSID) ។ កិច្ចព្រមព្រៀងដទៃទៀត ដែលបានធ្វើឡើង នៅក្រោមការឧបត្ថម្ភរបស់ក្រុមធនាគារពិភពលោក គឺកតិកាសញ្ញាបង្កើតភ្នាក់ងារធានាការវិនិយោគជាពហុភាគី ដែលធ្វើឡើង នៅឆ្នាំ១៩៨៥ និងចូលជាធរមាន នៅខែមេសា១៩៨៨ ។ ផ្អែកទៅលើជំនឿថា លំហូរវិនិយោគបរទេសទៅកាន់ប្រទេសកំពុង អភិវឌ្ឍន៍ អាចនឹងស្រួល និងជំរុញទៅមុខបាន ដោយការកាត់បន្ថយនូវសេចក្តីបារម្ភពាក់ព័ន្ធនឹងហានិភ័យ ពុំមែនពាណិជ្ជកម្ម ភ្នាក់ងារធានាវិនិយោគជាពហុភាគីមានគោលដៅចំបង គឺផ្តល់នូវយន្តការ ធានារ៉ាប់រងវិនិយោគពហុភាគីជាបន្ថែមលើយន្តការ ធានារ៉ាប់រងវិនិយោគរបស់ជាតិ តំបន់ និងឯកជន ។ កតិកាសញ្ញានោះ ក៏បានចែងពីតួនាទីរបស់ភ្នាក់ងារ ចំពោះបញ្ហា ស្តង់ដារសំខាន់ៗ សំរាប់អនុវត្តលើការវិនិយោគដែរ ។ តាមមាត្រា ១២ (d) នៃកតិកាសញ្ញាចែងថា នៅក្នុងការធានាចំពោះការ វិនិយោគណាមួយ ភ្នាក់ងារនេះត្រូវមានការពេញចិត្តផ្ទាល់ លើបញ្ហាមួយចំនួនដូចជា "លក្ខខណ្ឌវិនិយោគក្នុងប្រទេសជាម្ចាស់ផ្ទះ រួមទាំងលទ្ធភាពលើការគ្រប់គ្រងដោយត្រឹមត្រូវ និងស្មើភាព ព្រមទាំងការការពារដោយច្បាប់ចំពោះវិនិយោគ" ។ មាត្រា ២៣ នៃកតិកាសញ្ញាមានចែងពីការជំរុញវិនិយោគ និងបានបញ្ជាក់ថា បន្ថែមនៅលើសកម្មភាពស្រាវជ្រាវ និងជំនួយបច្ចេកទេស ភ្នាក់ងារនោះត្រូវមានភារៈជួយសំរួលការអនុម័តកិច្ចព្រមព្រៀង ក្នុងចំណោមសមាជិកនៃកតិកាសញ្ញាស្តីពីការជំរុញ និងការពារ វិនិយោគបរទេសផងដែរ ។

ធម្មនិយាមពហុភាគីសំខាន់ៗ សំរាប់គ្រប់គ្រងការវិនិយោគពីបរទេស មានចែងនៅក្នុងវិធានណែនាំ ដែលពុំមែនជាកាតព្វកិច្ច ចងភ្ជាប់ស្តីអំពី ការគ្រប់គ្រងការវិនិយោគផ្ទាល់ពីបរទេស បង្កើតឡើងនៅក្នុងក្រុមធនាគារពិភពលោក បន្ទាប់ពីមានសំណើរនៅថ្ងៃ ០៦ មេសា ឆ្នាំ១៩៩១ ពីសំណាក់គណៈកម្មាធិការអភិវឌ្ឍន៍ IMF និងធនាគារពិភពលោក អោយមានការរៀបចំនូវបណ្តុំគោលការណ៍ មួយស្តីអំពីក្របខ័ណ្ឌច្បាប់ទូទៅ ដែលកត់ត្រានូវគោលការណ៍ច្បាប់សំខាន់ៗសំដៅជំរុញការវិនិយោគផ្ទាល់ពីបរទេស ។ វិធាន ណែនាំនោះត្រូវបានគណៈកម្មាធិការអភិវឌ្ឍន៍ យកធ្វើជាកម្មវត្ថុ ទាក់ទាញការយកចិត្តទុកដាក់ពីសំណាក់ក្រុមធនាគារពិភពលោក កាលពីខែកញ្ញា ១៩៩២ ដោយចាត់ទុកថាជា "សូចនាករសំខាន់ក្នុងការអនុញ្ញាត្តិ និងគ្រប់គ្រងវិនិយោគឯកជនរបស់បរទេស នៅក្នុងទឹកដីរបស់ខ្លួន ដោយពុំមានប៉ះពាល់ទៅដល់វិធានជាកាតព្វកិច្ចនៃច្បាប់អន្តរជាតិ" ។ វិធានណែនាំ នោះមានលក្ខណៈ សម្បត្តិពីរខុសគ្នា អំពីការងារដែលផ្តើមឡើងនៅឆ្នាំ១៩៧៧ នៅក្នុងអង្គការសហប្រជាជាតិ អំពីច្បាប់អនុវត្តន៍សំរាប់សាជីវកម្ម អន្តរជាតិ ។ ទីមួយ វិធាននេះគ្រប់ដណ្តប់តែនៅលើគោលការណ៍ទូទៅ ដើម្បីណែនាំឥរិយាបថរបស់រដ្ឋាភិបាលចំពោះមុខ វិនិយោគិនបរទេស តែពុំបានរួមបញ្ចូលនូវវិធាននៃសកម្មភាពល្អ ចំពោះវិនិយោគបរទេសឡើយ ។ ទីពីរ វាពុំមានគោលបំណង តំណាងអោយបទដ្ឋាននៃច្បាប់អន្តរជាតិធម្មតា ដែលអនុវត្តចំពោះវិនិយោគបរទេសនោះទេ ប៉ុន្តែគឺសំដៅកំណត់ជាទូទៅនូវស្តង់ដា ដែលគេទទួលស្គាល់ជាអន្តរជាតិ ដើម្បីជួយជំរុញការវិនិយោគពីបរទេស ។ ផ្នែកទាំងប្រាំនៃវិធានណែនាំបានចែងពីវិសាលភាព នៃការអនុវត្តន៍ការអនុញ្ញាត្តិចំពោះវិនិយោគបរទេស ស្តង់ដារសំរាប់គ្រប់គ្រងលើការវិនិយោគពីបរទេស ការដកហូតកម្មសិទ្ធិ និងការកែប្រែជា ឯកតោភាគី ឬការបញ្ចប់កិច្ចសន្យា ព្រមទាំងការដោះស្រាយវិវាទ ។ គេគួរលើកឡើងផងដែរនូវលិខិតុបករណ៍ វិនិយោគ ពហុភាគីដទៃទៀត ដែលមានវិសាលភាពខុសគ្នាៗ ប៉ុន្តែនៅតែមានសារៈសំខាន់ច្រើនដែរនៅក្នុងបរិបទនេះ ។ សេចក្តីសំរេច របស់មហាសន្និបាតនៃអង្គការសហប្រជាជាតិ ដែលបានអនុម័តនៅក្នុងទសវត្សទី៦០ និង៧០ រួមមានបទបញ្ញត្តិ ស្តីពីការវិនិយោគពីបរទេស ដែលបញ្ជាក់ជាពិសេសនូវសិទ្ធិមួយចំនួនរបស់រដ្ឋជាម្ចាស់ផ្ទះ ។ បញ្ហាពាក់ព័ន្ធនឹងសង្គមកិច្ច ត្រូវបានដោះស្រាយដោយ សេចក្តីប្រកាសត្រីភាគី ILO (មិនមែនជាកាតព្វកិច្ច) អំពីគោលការណ៍ពាក់ព័ន្ធនឹងសហគ្រាស ពហុជាតិ និងនយោបាយសង្គមកិច្ច ដែលបានអនុម័តនៅ ឆ្នាំ១៩៧៧ ហើយមានសុពលភាពនៅឆ្នាំ ១៩៧៨ ។ សេចក្តីប្រកាសនោះ មានចែងនូវគោលការណ៍ដែលសមស្រប សំរាប់រដ្ឋាភិបាល ពលករ និងនិយោជិកនៃអង្គការនានារបស់ ប្រទេសជាម្ចាស់ផ្ទះ និងជាភ្ញៀវ និងចំពោះសហគ្រាសពហុជាតិ ។

ប្រភព: WTO របាយការណ៍ប្រចាំឆ្នាំ ១៩៩៦, ច្បាប់ទី១ ប្រធានបទពិសេស: ពាណិជ្ជកម្ម និងវិនិយោគផ្ទាល់បរទេស។

បទបញ្ញត្តិរបស់ WTO

ដូចបានកត់សំគាល់ពីមុនរួចមកហើយថា បទប្បញ្ញត្តិមួយចំនួនរបស់ច្បាប់ WTO ទាក់ទងទៅនឹងបញ្ហាវិនិយោគទាក់ទងនឹងពាណិជ្ជកម្ម ។ បញ្ហានោះមួយចំនួនមានពិពណ៌នាដូចខាងក្រោម ÷

កិច្ចព្រមព្រៀងស្តីពីវិធានការប៉ះប៉ូវ និងឧបត្ថម្ភធន

កិច្ចព្រមព្រៀងស្តីពីSCM បានអោយនិយមន័យលើពាក្យ "ឧបត្ថម្ភធន" និងកំណត់នូវគោលការណ៍ស្តីពីការផ្តល់ឧបត្ថម្ភធន ។ នៅក្នុង ចំណោមការលើកទឹកចិត្តទាំង ៣ ប្រភេទដែលបានរៀបរាប់កន្លងមក គឺការលើកទឹកចិត្តជាសារពើពន្ធ ជាហិរញ្ញវត្ថុ និងការលើកទឹកចិត្ត ដោយប្រយោល គឺជាវិធានការតែប៉ុន្មានប៉ុណ្ណោះ ដែលពាក់ព័ន្ធនឹងឧបត្ថម្ភធន ដូចដែលមាននិយមន័យតាមកិច្ចព្រមព្រៀងស្តីពី SCM ។ ពោលគឺវាមានពាក់ព័ន្ធនឹងវិភាគទានហិរញ្ញវត្ថុរបស់រដ្ឋាភិបាល ឬអង្គភាពសាធារណៈ និងការផ្តល់នូវផលប្រយោជន៍ផងដែរ ។

កិច្ចព្រមព្រៀងស្តីពីវិធានការវិនិយោគទាក់ទងនឹងពាណិជ្ជកម្ម

កិច្ចព្រមព្រៀង TRIMS ហាមឃាត់បណ្តាប្រទេស មិនអោយប្រើប្រាស់វិធានការវិនិយោគទាក់ទងនឹងពាណិជ្ជកម្មចំនួន ៥ ប្រភេទ (ដូចជាការទាមទារអោយប្រើប្រាស់វត្ថុធាតុដើមក្នុងស្រុក) ដែលត្រូវបានចាត់ទុកថា មិនសមស្របនឹងបទបញ្ញត្តិឆ្នាំ ១៩៩៤ របស់ GATT ស្តីពីប្រព្រឹត្តកម្មជាតិ (មាត្រាIII) និងវិធានការដែលហាមឃាត់នូវការប្រើប្រាស់ ការដាក់កំហិតលើបរិមាណ (មាត្រា១១)។

ប្រទេសទាំងឡាយណា ដែលមានវិធានការវិនិយោគទាក់ទងនឹងពាណិជ្ជកម្ម ដែលពុំសមស្របទៅនឹងបទប្បញ្ញត្តិនៃកិច្ចព្រមព្រៀង ត្រូវមានកាតព្វកិច្ចផ្តល់ព័ត៌មានជាជំណឹងក្នុងរវាង ៩០ ថ្ងៃ បន្ទាប់ពីកិច្ចព្រមព្រៀងចូលជាធរមាន ។ ដើម្បីអនុវត្តវិធានការផ្តល់ព័ត៌មាននេះ គេបានផ្តល់រយៈពេលអន្តរកាល សំរាប់ប្រទេសកំពុងអភិវឌ្ឍន៍ចំនួន ៥ ឆ្នាំ (ពោលគឺទៅទល់នឹងថ្ងៃ ០១ មករា ២០០០) ដើម្បីអោយលុបបំបាត់នូវវិធានការនោះវិញ ។ នៅក្នុងគោលដៅនេះ ប្រទេសក្រីក្រទទួលបាននូវរយៈពេលអន្តរកាលចំនួន ៧ ឆ្នាំ (ពោល គឺទៅទល់នឹងថ្ងៃ ១ មករា ២០០២) ។

ដោយវិសាលភាពនៃខ្លឹមសាររបស់កិច្ចព្រមព្រៀងស្តីពី TRIMS នៅមានកំរិត នាំអោយបណ្តាប្រទេសនានា ព្រមព្រៀងគ្នាថា គួរតែត្រួតពិនិត្យឡើងវិញលើប្រតិបត្តិការរបស់គេ ក្នុងអំឡុងប្រាំឆ្នាំម្តង ។ កិច្ចព្រមព្រៀងបានចែងថា ក្នុងការពិនិត្យឡើងវិញបែបនោះ ក៏ត្រូវមានការពិចារណាលើការរៀបចំបន្ថែមទៅលើបទបញ្ញត្តិរបស់វានូវបញ្ញត្តិស្តីពីការវិនិយោគ និងគោលនយោបាយប្រកួតប្រជែងផងដែរ (សូមអានជំពូក ១៣) ។

កិច្ចព្រមព្រៀងទូទៅស្តីពីពាណិជ្ជកម្មលើសេវាកម្ម

បទបញ្ញត្តិសំខាន់ៗ ផ្សេងទៀតស្តីពីការវិនិយោគមានចែងនៅក្នុង GATS ។ កិច្ចព្រមព្រៀងទទួលស្គាល់ពីលក្ខណៈខុសគ្នានៃការធ្វើពាណិជ្ជកម្មអន្តរជាតិលើទំនិញឆ្លងព្រំប្រទល់ ។ ពាណិជ្ជកម្មលើសេវាកម្មធ្វើឡើងតាមរយៈវិធី ៣ យ៉ាង ។ វិធីទីមួយគឺការបង្កើតនូវវត្តមានក្រុមហ៊ុនពាណិជ្ជកម្មនៅក្នុងប្រទេស ដែលនឹងត្រូវផ្តល់នូវសេវាកម្ម។GATS បានចែងជាបន្តទៀតថា បណ្តាប្រទេសអាច ព្រមព្រៀង តាមការចរចាលើផ្នែកពាណិជ្ជកម្ម ដើម្បីផ្តល់នូវសន្យាអនុញ្ញាតិអោយអ្នកផ្គត់ផ្គង់បរទេស នូវជំរើសខ្លះៗ ស្តីពីការបង្កើត ក្រុមហ៊ុនពាណិជ្ជកម្មបាន (ឧទាហរណ៍តាមរយៈការបង្កើតនូវក្រុមហ៊ុនបុត្តសម្ព័ន្ធ ឬសាខា) ។ នៅក្នុងការធ្វើការសន្យាបែបនោះ ប្រទេសមួយ អាចមានលទ្ធភាពអនុវត្តនូវល័ក្ខខ័ណ្ឌខ្លះៗ ដើម្បីដាក់កំហិតលើការបើកទីផ្សារ ឬ ការពង្រីកនូវប្រព្រឹត្តកម្មជាតិចំពោះអ្នកផ្គត់ផ្គង់បរទេស (ឧទាហរណ៍ ការដាក់កំហិតលើការចូលរួមភាគហ៊ុនរបស់បរទេស) ។

មានភាពខុសគ្នាជាមូលដ្ឋានមួយ ក្នុងកំហិតជិតនៃការផ្តល់សិទ្ធិចំពោះវិនិយោគិនបរទេស នៅក្នុងកិច្ចព្រមព្រៀងតំបន់ និងពហុភាគី និងវិធីសាស្ត្រដែលបានអនុម័តនៅក្នុងGATS ។ កិច្ចព្រមព្រៀងតំបន់ និងពហុភាគី គិតគូរទៅដល់អ្វីដែលគេហៅថា វិធីសាស្ត្រពីលើចុះមកក្រោម ឬ "បញ្ជីអវិជ្ជមាន" ។ មានការរំពឹងថា បណ្តាប្រទេសនានា នឹងយល់ព្រមបើកចំហរនូវវិស័យឧស្សាហកម្មទាំងអស់ចំពោះ FDI ទោះផលិតផលទំនិញ ឬ សេវាកម្មក្តី ដោយមានការលើកលែងតែមួយចំនួនមានកំណត់ប៉ុណ្ណោះ ។ រីឯ

GATS វិញ បានអនុវត្តនូវវិធីសាស្ត្រ " ពីក្រោមឡើងលើ ឬ "បញ្ជីវិជ្ជមាន" ។ មានការអនុញ្ញាតិអោយបណ្តាប្រទេសធ្វើសេរីភាវូបនីយកម្ម ដោយសន្សឹមៗ ហើយអោយកំណត់នៅក្នុងពេលចចារលើផ្នែកពាណិជ្ជកម្ម នូវផ្នែកសេវាកម្មណាដែលគេមានបំណងផ្តល់ចំពោះអ្នកផ្គត់ផ្គង់បរទេសនូវសិទ្ធិក្នុងការបង្កើតក្រុមហ៊ុនពាណិជ្ជកម្ម និងធ្វើវិនិយោគ ។

កិច្ចព្រមព្រៀងស្តីពីទិដ្ឋភាពពាណិជ្ជកម្ម ដែលទាក់ទងនឹងកម្មសិទ្ធិបញ្ញា

ថ្វីត្បិតតែកិច្ចព្រមព្រៀងTRIPS ពុំបានលើកឡើងដោយផ្ទាល់នូវបញ្ហាវិនិយោគបរទេសក្តី ក៏ប៉ុន្តែបទបញ្ញត្តិនៃកិច្ចព្រមព្រៀងនេះមានចែងពីស្តង់ដារអប្បរមាសំរាប់ការពារកម្មសិទ្ធិបញ្ញា នីតិវិធីនៃការអនុវត្តន៍ក្នុងប្រទេស និងដំណោះស្រាយអន្តរជាតិ មានការពាក់ព័ន្ធទៅនឹងបរិយាកាសគតិយុត្តដែលមានឥទ្ធិពលទៅលើការវិនិយោគបរទេស (និយមន័យនៃពាក្យ " វិនិយោគ" នៅក្នុងកិច្ចព្រមព្រៀងអន្តររដ្ឋាភិបាលជាច្រើន រួមបញ្ចូលយ៉ាងជាក់ច្បាស់ នូវកម្មសិទ្ធិបញ្ញា) (សូមអានជំពូក ២០) ។

ការពិពណ៌នាអំពីបញ្ហា និងចំណុចសំខាន់ៗ ដែលបានលើកឡើងនៅក្នុងការពិភាក្សា ក្នុងក្រុមការងារ WTO

បញ្ហាចំបងដែលបានលើកឡើង

ផ្អែកពីពត៌មានជាមូលដ្ឋាន ដែលបានផ្តល់ជូននៅក្នុងផ្នែកកន្លងមកអំពីនិន្នាការនៃ FDI និងអំពីកិច្ចព្រមព្រៀងវិនិយោគទ្វេភាគី និងពហុភាគី ផ្នែកនេះនឹងពណ៌នាអំពីចំណុចចំបងៗ និងមតិខុសគ្នាផ្សេងៗ ដែលបានលើកឡើងនៅក្នុងក្រុមការងារពីបញ្ហាទំនាក់ទំនងរវាងពាណិជ្ជកម្មនិងវិនិយោគ[៣៣] ។ មូលដ្ឋានសំរាប់ពិភាក្សានៅក្នុងក្រុមការងារ គឺការបញ្ជូនមកនូវគណៈប្រតិភូ ព្រមទាំងឯកសារវិភាគរៀបចំឡើងដោយអគ្គលេខាធិការដ្ឋាន WTO, UNCTAD និង OECD ។ ដើម្បីផ្តល់នូវរចនាសម្ព័ន្ធមួយសំរាប់ការពិភាក្សា ក្រុមការងារបានរៀបចំជាកម្មវិធីការងារមួយ នាអំឡុងពេលប្រជុំលើកទីមួយនៅខែមិថុនា១៩៩៧ ក្រោមរូបភាពជា "បញ្ជីត្រួតពិនិត្យពីបញ្ហាដែលបានស្នើសិក្សា" ។ បញ្ជីត្រួតពិនិត្យ នោះមានប្រធានបទធំៗបួន ÷

- ☐ ផលប៉ះពាល់ដល់ទំនាក់ទំនងរវាងពាណិជ្ជកម្ម និងការវិនិយោគចំពោះការអភិវឌ្ឍន៍ និងកំណើនសេដ្ឋកិច្ច ។
- ☐ ទំនាក់ទំនងសេដ្ឋកិច្ចរវាងពាណិជ្ជកម្ម និងវិនិយោគ
- ☐ ការពិនិត្យស្ថានភាព និងវិភាគលើកិច្ចព្រមព្រៀង វិនិយោគអន្តរជាតិ ដែលកំពុងមានអត្ថិភាព និង
- ☐ សំនួរមួយចំនួនដែលមានសារៈសំខាន់សំរាប់ធ្វើការវិនិច្ឆ័យលើឧត្តមភាពនៃលទ្ធភាពបង្ករការផ្តួចផ្តើមមួយ នៅក្នុង WTO ដើម្បីបង្កើតនូវវិធានពហុភាគីលើបញ្ហាវិនិយោគ ។

វាក្យខ័ណ្ឌជាបន្តទៀត មានគោលដៅផ្តល់នូវការសង្ខេបជារួមទៅលើចំណុច និងទស្សនៈដែលបានលើកឡើង នៅក្នុងការពិភាក្សាលើប្រធានបទនីមួយៗ ។ ជាសំខាន់គេត្រូវកត់សំគាល់ថា សេចក្តីសង្ខេប ពុំមានលក្ខណៈគ្រប់ជ្រុងជ្រោយទេ ហើយក៏មិនឆ្លុះបញ្ចាំងទាំងស្រុងនូវចំណុចគោល ឬ មតិមិនស្របគ្នា ដែលគណៈប្រតិភូនានាលើក ឡើងក្នុងមតិរបស់ខ្លួនដែរ ។

ផលប៉ះពាល់នៃទំនាក់ទំនងរវាងពាណិជ្ជកម្ម និងការវិនិយោគ ចំពោះការអភិវឌ្ឍន៍និងកំណើនសេដ្ឋកិច្ច

ក្រុមការងារនោះបានធ្វើការកត់សំគាល់ថា បទពិសោធន៍របស់ប្រទេសមួយចំនួនបានបង្ហាញថា FDI បាននាំមកអោយបណ្តាប្រទេសជាម្ចាស់ផ្ទះនូវទ្រព្យសកម្មរូបិយ និងអរូបីមួយសំណុំ ។ គុណប្រយោជន៍អរូបិយ រួមមានកំណែលំអបច្ចេកវិទ្យាជំនាញក្នុងការគ្រប់គ្រង និងការអភិវឌ្ឍន៍ធនធានមនុស្ស ។ FDI ក៏បានជួយដល់ឧស្សាហកម្មក្នុងស្រុក ដើម្បីបង្កើនប្រសិទ្ធិភាពរបស់គេតាមរយៈការសំរប

---

[៣៣] ក្រុមការងារត្រូវបានបង្កើតឡើង យោងតាមសេចក្តីប្រកាសថ្នាក់ រដ្ឋមន្ត្រីនៅសិង្ហបុរី នាខែធ្នូ ឆ្នាំ ១៩៩៦ ។

ទៅតាម ការប្រកួតប្រជែងដែរ ។ គុណប្រយោជន៍អរូបីនេះ ត្រូវបានចាត់ទុកថាមានសារៈសំខាន់ច្រើនជាងការចូលរួមចំណែករបស់ FDI ទៅក្នុងវិនិយោគដើមទុន ចំណូល ពន្ធដារ និងជញ្ជីងទូទាត់ទៅទៀត។

ប៉ុន្តែមានគណៈប្រតិភូខ្លះទៀតលើកឡើងថា ក្នុងខណៈដែល FDI ដើរតួនាទីវិជ្ជមានយ៉ាងសំខាន់ក្នុងការផ្ទេរទ្រព្យសកម្មអរូបីទៅកាន់ប្រទេសកំពុងអភិវឌ្ឍន៍នោះ ក៏នៅមានពេលខ្លះប្រទេសនោះ ត្រូវប្រឈមមុខនឹងឥទ្ធិពលជាអវិជ្ជមាននៃការវិនិយោគដែរ ។ ឧទាហរណ៍នៃឥទ្ធិពលនៃអវិជ្ជមានបែបនោះមានៈ ការដាក់កំហិតទៅលើសកម្មភាពនៃក្រុមហ៊ុនសម្ព័ន្ធបរទេស ដោយក្រុមហ៊ុនមេបានៅក្នុងក្របខ័ណ្ឌនៃកិច្ចព្រមព្រៀងផ្ទេរបច្ចេកវិទ្យា ហានិភ័យដែលប្រទេសត្រូវប្រឈមចំពោះការក្លាយទៅជាទីកន្លែងសំរាប់ធ្វើប្រតិបត្តិការតំឡើងអ្វីសាមញ្ញៗ អស្ថេរភាពជញ្ជីងពាណិជ្ជកម្ម និងជញ្ជីងទូទាត់ដោយមូលហេតុFDI ដូចដែលបានបង្ហាញតាមរយៈបទពិសោធន៍ថ្មីៗនៃប្រទេសមួយចំនួននៅអាស៊ីអគ្នេយ៍ ការអនុវត្តន៍នូវឥទ្ធិពលនយោបាយមិនសមស្របនៃក្រុមហ៊ុនបរទេស ឥទ្ធិពលអវិជ្ជមាននៃក្រុមហ៊ុនសម្ព័ន្ធទៅលើលទ្ធភាពហិរញ្ញប្បទានដែលមាននៅក្នុងប្រទេស ព្រមទាំងការប្រកួតប្រជែងនៅក្នុងទីផ្សារក្នុងស្រុក រួមទាំងសហគ្រាសធុនតូច និងមធ្យមផង ។

ទំនាក់ទំនងសេដ្ឋកិច្ចរវាងពាណិជ្ជកម្ម និងការវិនិយោគ

កំរិតនៃទំនាក់ទំនងរវាងពាណិជ្ជកម្ម និងវិនិយោគ

នៅក្នុងការពិភាក្សាអំពីបញ្ហានេះ ក្រុមការងារធ្វើការកត់សំគាល់ថា ការស្រាវជ្រាវលើមូលដ្ឋានធ្វើការសង្កេតស្តីអំពីទំនាក់ទំនងរវាងពាណិជ្ជកម្មបរទេស និងលំហូរវិនិយោគបានអោយឃើញថា រវាងលំហូរចេញនៃការវិនិយោគ និងការនាំចេញរបស់ប្រទេសខ្លួនផ្ទាល់មានទំនាក់ទំនងវិជ្ជមានជារួមមួយ ។ ហើយការពិត ក៏មានទំនាក់ទំនងរវាងលំហូរចូលនៃការវិនិយោគ និងការនាំចេញរបស់ប្រទេសជាម្ចាស់ផ្ទះដែរ ។ ដូចការសិក្សាបានបង្ហាញឥទ្ធិពលពាណិជ្ជកម្មមានលក្ខណៈវិជ្ជមានទាំងចំពោះប្រទេសខ្លួនផ្ទាល់ និងប្រទេសជាម្ចាស់ផ្ទះ។ ក្នុងករណីប្រទេសជាម្ចាស់ផ្ទះ ឥទ្ធិពលចំពោះពាណិជ្ជកម្មមានកំរិតកាន់តែច្បាស់លាស់ចំពោះប្រទេសណាដែលមានគោលនយោបាយពាណិជ្ជកម្ម បើកចំហរ និងសេរី ក្នុងគោលបំណងជំរុញដំណើរសេដ្ឋកិច្ចមួយនាំមុខ ដោយការនាំចេញជាងប្រទេសដែលនៅពឹងផ្អែកលើគោលនយោបាយជំនួសអោយការនាំចូល ដើម្បីជំរុញកំណើនសេដ្ឋកិច្ច ។

ប៉ុន្តែមតិក៏លើកឡើងដែរថា គឺពុំមែនជាការត្រឹមត្រូវទេ ក្នុងការផ្តោតការយកចិត្តទុកដាក់ហួសហេតុទៅលើភាពបំពេញអោយគ្នាទៅវិញទៅមករវាងពាណិជ្ជកម្ម និង FDI ហើយក៏ជាការចាំបាច់ដែរ ដែលត្រូវពិនិត្យទៅលើឥទ្ធិពលនៃការវិនិយោគបែបនោះទៅលើប្រសិទ្ធិភាព ភាពមានការងារធ្វើ និងការអភិវឌ្ឍន៍សេដ្ឋកិច្ច ។ លើសពីនេះទៀត គេបានចង្អុលបង្ហាញថា នៅមានការចាំបាច់នឹងបំពេញបន្ថែមទៅលើការសិក្សា ដែលមានលក្ខណៈទូទៅនោះ ដោយការវិភាគលំអិតជាងនេះទៀត អំពីទំនាក់ទំនងរវាងពាណិជ្ជកម្ម និងការវិនិយោគនៅក្នុងវិស័យឧស្សាហកម្ម និងសេវាកម្មសំខាន់ៗ ។

ផលប៉ះពាល់នៃគោលនយោបាយវិនិយោគ និងវិធានការលើផ្នែកពាណិជ្ជកម្ម

ចំពោះបញ្ហានេះ ក្រុមការងារបានពិភាក្សាអំពីផលប៉ះពាល់ដែលអាចមាន ដែលនយោបាយវិនិយោគ ជាពិសេស អ្វីដែលពាក់ព័ន្ធនឹងការលើកទឹកចិត្តវិនិយោគ និងតំរូវការអនុវត្ត ដែលអាចមានទៅលើពាណិជ្ជកម្ម និងការវិនិយោគ ។

អំពីការលើកទឹកចិត្តផ្នែកវិនិយោគ គេបានលើកឡើងថា ការសិក្សាដោយអង្គការអន្តរជាតិបានបង្ហាញថា ការលើកទឹកចិត្ត ពុំមែនជាកត្តាកំណត់ក្នុងការសំរេចចិត្តលើបញ្ហាទីកន្លែង ចំពោះសាជីវកម្មអន្តរជាតិឡើយ ។ នៅក្នុងទសវត្សចុងក្រោយនេះ ប្រភេទនៃការលើកទឹកចិត្តមានច្រើន ហើយស្មុគស្មាញ ទៀតផង ។ ទង្វើនេះនាំអោយកើតមានឡើងនូវការប្រកួតប្រជែងយ៉ាងខ្លាំងរវាងបណ្តាប្រទេស ដើម្បីទាក់ទាញ FDI ។ ការផ្តល់ការលើកទឹកចិត្ត ដោយពុំមានការរើសអើង អាចនឹងធ្វើអោយមានការរំខានដល់លំហូរវិនិយោគជាគុណប្រយោជន៍ ដល់បណ្តាប្រទេសដែលមានលទ្ធភាពធ្វើហិរញ្ញប្បទានលើកទឹកចិត្ត ប៉ុន្តែចំពោះរយៈកាលយូរអង្វែងការលើកទឹកចិត្តមានន័យថា ជាការខាតបង់ចំពោះគ្រប់ប្រទេសដែលពាក់ព័ន្ធ នៅក្នុងការប្រកួតប្រជែងបែបនោះទៅវិញផង ហើយនៅទីបញ្ចប់ នឹងនាំអោយកើតមាននូវការផ្ទេរធនធាន អោយវិនិយោគបរទេស ។ លើសពីនេះទៀត ការលើកទឹកចិត្តអាចរំខានដល់លំហូរពាណិជ្ជកម្មអន្តរជាតិ តាមរយៈការនិយមចូលចិត្តដោយសិប្បនិម្មិតនូវការរៀបចំផលិតកម្ម នៅក្នុងប្រទេសណាមួយនោះជាជាង

ប្រទេសឯទៀត ដែលពុំមានលទ្ធភាពផ្តល់នូវការលើកទឹកចិត្ត ជាពិសេសនៅពេលដែលផលិតកម្ម មានគោលដៅដើម្បីការនាំចេញ។ ការសិក្សាដោយសង្កេតបានបង្ហាញថា ការលើកទឹកចិត្តអាចរំខានដល់រចនាសម្ព័ន្ធផលិតកម្មនៅក្នុងប្រទេសជាម្ចាស់ផ្ទះ តាមរយៈការនិយមចូលចិត្តធ្វើផលិតកម្មនៅក្នុងវិស័យណាមួយនោះ ។ បន្ថែមលើនេះទៀត ការលើកទឹកចិត្តវិនិយោគ តែងផ្សារភ្ជាប់នឹងចំណាយរដ្ឋបាលខ្ពស់ មានការពិបាកក្នុងការគ្រប់គ្រង ហើយជាញឹកញាប់ត្រូវបានផ្តល់ អោយដោយពុំមានតម្លាភាព ។

ប៉ុន្តែគណៈប្រតិភូខ្លះបានចង្អុលបង្ហាញថា ទោះបីជាមានមតិជំទាស់មួយចំនួននៅក្នុងឯកសាររបស់អ្នកសិក្សាជាន់ខ្ពស់ថ្មីៗក្តី ក៏ការលើកទឹកចិត្តវិនិយោគ នឹងនៅតែជាឧបករណ៍នយោបាយ យ៉ាងមានប្រយោជន៍នៅក្នុងការអនុវត្តន៍យុទ្ធសាស្ត្រអភិវឌ្ឍន៍ដែរ ។ មតិជំទាស់ដែលថា ការលើកទឹកចិត្ត គឺគ្មានអ្វីក្រៅពីការផ្ទេរនូវប្រាក់ចំណូលពីប្រទេសទៅអោយក្រុមហ៊ុន និងថា ដរាបណាការប្រកួតប្រជែងក្នុងចំណោមប្រទេសជាម្ចាស់ផ្ទះកាន់តែស្វិតស្វាញ ដរាបនោះ ចំណែកនៃប្រាក់ចំណេញដែលអាចមាន និងដែលបានផ្ទេរទៅអោយសហគ្រាសពហុជាតិ នឹងរឹតតែធំ ពុំបានផ្តល់នូវការទទួលស្គាល់នូវការពិតថា គោលបំណងនៃការលើកទឹកចិត្ត គឺពុំមែនដើម្បីគាំទ្រដល់សហគ្រាស ដែលគ្មានលទ្ធភាពរស់ដោយខ្លួនឯងបាននោះឡើយ ។ ផ្ទុយទៅវិញ វាមានគោលបំណងទាក់ទាញនូវវិនិយោគដែលបង្កើតនូវកំណើនសេដ្ឋកិច្ច ប្រាក់ចំណូល និងការងារ ។

អំពីល័ក្ខខ័ណ្ឌក្នុងការអនុវត្តន៍ : មានការអះអាងថា ការដាក់ល័ក្ខខ័ណ្ឌនេះ ធ្វើអោយសហគ្រាសបាត់បង់នូវភាពដែលអាចបត់បែនចាំបាច់ ដើម្បីសម្របខ្លួនទៅតាមកាលៈទេសៈសេដ្ឋកិច្ចដែលប្រែប្រួល ។ ការដាក់លក្ខខ័ណ្ឌពីផលិតផល និងឧបករណ៍វិនិយោគបង្កើតនូវការរាំងមិនតែចំពោះទីផ្សារអន្តរជាតិប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងចំពោះទីផ្សារ ក្នុងស្រុកនៃប្រទេសជាម្ចាស់ផ្ទះទៀតផងនៅពេលណាដែលការប្រកួតប្រជែងរវាងវិនិយោគិនទទួលនូវការរាំង ដោយសារតែវិនិយោគដែលធ្វើនៅពេលផ្សេងៗគ្នា នោះគឺជាកម្មវត្ថុនៃតំរូវការអនុវត្តន៍ និងការលើកទឹកចិត្តផ្សេងៗពីគ្នា ។

ប៉ុន្តែមានចំណុចមួយលើកឡើងថា ក្នុងខណៈដែលតំរូវការនៃការផលិតផលពាក់ពន្ធ័ទៅនឹងពាណិជ្ជកម្ម-ដូចជា វិធានការប្រើប្រាស់វត្ថុធាតុដើមក្នុងស្រុក ដូចដែលបានបង្ហាញរួចមកហើយថា ពុំមានឥទ្ធិពលវិជ្ជមានទេ នោះតំរូវការលើការផលិត ពាក់ពន្ធ័ទៅនឹងការផ្ទេរបច្ចេកវិទ្យា ការជំរុញការស្រាវជ្រាវ និងអភិវឌ្ឍន៍ និងជំរុញនូវការចងសម្ព័ន្ធភាពរវាងក្រុមហ៊ុនបរទេសនិងក្រុមហ៊ុនក្នុងស្រុក ជាទូទៅបានបង្ហាញថា ជាទង្វើមានឥទ្ធិពលទៅវិញ ។ ប្រសិនបើមានការអនុវត្តន៍ត្រឹមត្រូវ ពុំប្រឆាំងនឹងទីផ្សារតំរូវការលើការផលិតនៅក្នុងទំនាក់ទំនងជាមួយការផ្ទេរនូវបច្ចេកវិទ្យា ការស្រាវជ្រាវ និងអភិវឌ្ឍន៍ ក៏អាចនឹងត្រូវបានចាត់ទុកថា បានចូលរួមដោយប្រយោលទៅក្នុងការសំរេចបាននូវគោលដៅនៃនយោបាយប្រកួតប្រជែង ដោយសារកត្តានេះជួយសំរួលដល់បណ្តាក្រុមហ៊ុនអោយឈានទៅចាប់យកបច្ចេកវិទ្យាបាន (រួមទាំង ក្រុមហ៊ុនធុនតូច និងមធ្យម) និងបង្កើតនូវភាពសម្បូរបែបនៃសេដ្ឋកិច្ច ។

អំពីទំនាក់ទំនងរវាងវិនិយោគបរទេស និងនយោបាយប្រកួតប្រជែង : ចំណុចដែលលើកឡើងគឺរបប FDI មួយដែលលើកចំហរនិងសេរីបានបង្កើតនូវសេចក្តីសង្ឃឹម សំរាប់អោយមានការចូលមកថ្មីៗទៀត ហើយដូចនេះ ក៏សំរាប់ការប្រកួតប្រជែងនៅលើទីផ្សារ។ តាមរយៈការសំរួលអោយមានអ្នកប្រកួតប្រជែងថ្មី វិធានវិនិយោគសេរី ក៏បានរារាំងនូវការកើតឡើងនូវក្រុមហ៊ុនផ្តាច់មុខក្នុងស្រុក បំបាត់នូវការខ្វះខាត ក្នុងការបែងចែកបំរើក្នុងស្រុក និងកាត់បន្ថយនូវលទ្ធភាពកើតមាននូវក្រុមហ៊ុន Cartels និងក្រុមហ៊ុនផ្តាច់មុខផងដែរ ។

ប៉ុន្តែគេបានទទួលស្គាល់ដែរថា ក្រុមហ៊ុនបរទេសដែលមានកំរិតប្រកួតប្រជែងខ្ពស់អាចដណ្តើមយកនូវជំហរចំបងនៅលើទីផ្សារក្នុងស្រុក តាមរយៈការបណ្តេញចេញនូវអ្នកប្រកួតប្រជែងក្នុងស្រុកចេញ ហើយបានប្រើប្រាស់ជំហរនេះខុស ។ ដូច្នេះការអនុវត្តន៍ច្បាប់ប្រកួតប្រជែង ព្រមទាំងគោលនយោបាយ សំដៅរួមបញ្ចូលគ្នានូវក្រុមហ៊ុន ការទិញយក និងការធ្វើជាក្រុមហ៊ុនចំរុះ គឺជាទិដ្ឋភាពដ៏មានសារៈសំខាន់នៃទំនាក់ទំនងរវាងវិនិយោគ និងគោលនយោបាយប្រកួតប្រជែង ។

ប៉ុន្តែក៏មានមតិលើកឡើងបញ្ជាក់ដែរថា ទោះបីជាការប្រកួតប្រជែងជាទូទៅ នាំអោយមានប្រសិទ្ធិភាពសេដ្ឋកិច្ចខ្ពស់ជាងមុន ហើយដូច្នេះក៏មាននូវកំណើន និងការអភិវឌ្ឍន៍សេដ្ឋកិច្ចក្តី ក៏ប្រទេសកំពុងអភិវឌ្ឍន៍ខ្លះអាចមានមូលហេតុ ប្រុងប្រយ័ត្នក្នុងការយកប្រសិទ្ធិភាពមកធ្វើជាគោលដៅចំពោះមុខដែរ ។ ការនេះកើតឡើងពីការចាំបាច់ត្រូវគិតគូរទៅដល់បញ្ហាគោលដៅប្រកួតប្រជែង រួមទាំងគោលដៅអភិវឌ្ឍន៍ និងជំរុញសហគ្រាសធុនតូច និងមធ្យម។

ការពិនិត្យលើស្ថានភាព និងវិភាគលើកិច្ចព្រមព្រៀងទ្វេភាគីក្នុងកំរិតតំបន់ និងអន្តរជាតិ

គេបានអធិប្បាយថា អនុសញ្ញាវិនិយោគទ្វេភាគីមានឧត្តមភាពសំខាន់ ដោយសារអនុសញ្ញានេះស្របទៅតាមកាលទេសៈជាក់ស្តែង របស់គូរភាគីដែលពាក់ព័ន្ធ និងអាចដោះស្រាយការព្រួយបារម្ភជាក់ស្តែង ដូចជាបញ្ហាអភិវឌ្ឍន៍ជាដើម ។ មិនតែប៉ុណ្ណោះ អនុសញ្ញានេះ អាចត្រូវបានអនុម័តយ៉ាងឆាប់រហ័សជាជាងកិច្ចព្រមព្រៀងកំរិតតំបន់ ឬពហុភាគី ហើយអាចកែលំអទំនាក់ទំនងសេដ្ឋកិច្ច និងការទូត ជាទ្វេភាគីផង ។ ដូចជាអនុសញ្ញាវិនិយោគទ្វេភាគីដែរ កិច្ចព្រមព្រៀងតំបន់ស្តីពីការវិនិយោគមានលក្ខណៈអាចបត់បែនបាន ខាងនយោបាយ ជាជាងកិច្ចព្រមព្រៀងពហុភាគី ដោយសារអនុសញ្ញានេះពាក់ព័ន្ធនឹងចំនួនអ្នកចូលរួមតិច ហើយនឹងអាចសម្រប ទៅតាមភាពជាក់ស្តែង ដើម្បីដោះស្រាយនូវក្តីបារម្ភរបស់ប្រទេសនីមួយៗ ។

ប៉ុន្តែគណៈប្រតិភូខ្លះមានគំនិតថា អនុសញ្ញាវិនិយោគទ្វេភាគី ពុំមានបទពិសោធណាដែលអាចបង្ហាញថា អនុសញ្ញានេះគឺជាកត្តាកំណត់ យ៉ាងសំខាន់ ដែលមានឥទ្ធិពលលើសេចក្តីសំរេចចិត្តអំពីវិនិយោគឡើយ ។ ដូច្នេះគឺពុំមានភស្តុតាងគ្រប់គ្រាន់ បង្ហាញថា ក្របខ័ណ្ឌ ពហុភាគីផ្អែកលើអនុសញ្ញាបែបនេះ នឹងមានផលប៉ះពាល់សំខាន់ៗ ទៅលើលំហូរវិនិយោគដែរ ។ គេបានបញ្ជាក់ទៀតថា ជាទូទៅតាម ការសង្កេតមានភស្តុតាងតិចតួចប៉ុណ្ណោះ ដែលបង្ហាញថាការសំរេចចិត្តអំពីទីកន្លែង គឺអាស្រ័យទៅលើអត្ថិភាពនៃកិច្ចព្រមព្រៀងវិនិយោគ។

មតិផ្សេងទៀតពោលថា គ្មានមូលហេតុអ្វីត្រូវរំពឹងថា រវាងអត្ថិភាពនៃអនុសញ្ញាទ្វេភាគី និងទំហំនៃលំហូរ វិនិយោគមានទំនាក់ទំនង នឹងគ្នាជាស្វ័យប្រវត្តិឡើយ ពីព្រោះអនុសញ្ញានេះត្រូវបានធ្វើឡើង ដោយរដ្ឋាភិបាល ពុំមែនដោយភាគីឯកជនឡើយ ។ តាមការប៉ាន់ស្មាន រដ្ឋាភិបាលធ្វើការចរចាលើអនុសញ្ញាបែបនេះ ដោយមានមូលហេតុជាច្រើន ហើយក៏អាចមានដែរនូវស្ថានភាពដែលថា រដ្ឋាភិបាល ធ្វើការចរចាលើអនុសញ្ញានេះ ដោយសារផលប្រយោជន៍យូរអង្វែងទៅមុខ ដោយមិនគិតដល់លទ្ធផលរយៈពេលខ្លីឡើយ ។

មានមតិលើកឡើងជាបន្តទៀតថា ការបង្កើតនូវសំណុំមួយយ៉ាងធំនៃវិធានពហុភាគីទាំងឡាយ ដែលមានភាពសមស្របគ្នា និងដែល ចងភ្ជាប់កាតព្វកិច្ចគ្រប់សមាជិកនៃ WTO ទាំងអស់នឹងអនុញ្ញាត្តិអោយមាន នូវបរិយាកាសមួយដ៏ស្ថេរ មានតម្លាភាព និងស៊ីសង្វាក់ គ្នាសំរាប់បណ្តាសហគ្រាសដែលប្រតិបត្តិការនៅក្នុងទីផ្សារ ទោះបីជារចនាសម្ព័ន្ធកម្មសិទ្ធិ ឬទីកន្លែងនៃការបង្កើតក្រុមហ៊ុនរបស់គេ យ៉ាងណា ឬ នៅទីណាក៏ដោយ ។ ការអនុវត្តន៍ជាសកលនូវគោលការណ៍វិនិយោគដូចៗគ្នា យ៉ាងទូលំទូលាយ នឹងអាចលប់បំបាត់ចោល នូវភាពស្មុគស្មាញដល់វិនិយោគិន ដែលកើតមានឡើងពីក្របខ័ណ្ឌកិច្ចព្រមព្រៀងវិនិយោគទ្វេភាគី និងតំបន់ ហើយដូចនេះ នឹងជួយ សំរួលដល់ការអនុវត្តន៍ទៀតផង ។ ការអនុម័តនូវវិធានពហុភាគីបែបនេះ នឹងផ្តល់នូវឧត្តមភាព ជាបន្ថែមទៅលើកិច្ចព្រមព្រៀង ទ្វេភាគីដូចតទៅ ÷

- ☐ ក្នុងខណៈដែលការចរចារលើកិច្ចព្រមព្រៀងវិនិយោគទ្វេភាគី ជាពិសេសកិច្ចព្រមព្រៀងរវាងប្រទេសជឿនលឿន និងប្រទេស កំពុងអភិវឌ្ឍន៍អាចនឹងទទួលរងនូវផលប៉ះពាល់ ពីទំនាក់ទំនងអំណាចនយោបាយ និងសេដ្ឋកិច្ចដែលពុំស្មើភាពគ្នារវាង ប្រទេសដែលពាក់ព័ន្ធនោះ ហានិភ័យនេះនឹងត្រូវថយចុះនៅក្នុងការចរចាជាពហុភាគី ។
- ☐ វិធីសាស្រ្តជាពហុភាគី អាចអនុញ្ញាត្តិអោយបណ្តាប្រទេសធ្វើសេរីភាវូបនីយកម្មយ៉ាងសកម្មបាន ។
- ☐ កិច្ចព្រមព្រៀងពហុភាគី អាចដោះស្រាយបញ្ហាមិនស៊ីសង្វាក់គ្នារវាងកិច្ចព្រមព្រៀងវិនិយោគទ្វេភាគីទាំងឡាយ ។ លើសពី នេះទៀត កិច្ចព្រមព្រៀងពហុភាគីអំពីការវិនិយោគ ដែលចរចារនៅក្នុង WTO នឹងធានានូវភាពស៊ីសង្វាក់គ្នានៃវិធាន វិនិយោគពហុភាគីជាមួយនឹង GATS កិច្ចព្រមព្រៀង TRIMS និងបទប្បញ្ញត្តិ WTO ដទៃទៀត ។
- ☐ កិច្ចព្រមព្រៀងពហុភាគី ក៏ផ្តល់នូវវិសាលភាពធំជាង សំរាប់សម្របសម្រួលវិធាននានា ហើយដោយហេតុថា បំរែបំរួលនៃ វិធានចាំបាច់ ត្រូវមានការយល់ព្រមពីភាគីទាំងអស់នោះ វានឹងនាំអោយមាននូវភាពងាយគិតស្មានទុកបានមុន ជាច្រើនទៅ លើវិធាននោះ ។

សំនួរសំខាន់ៗដើម្បីពិចារណាទៅលើឧត្តមភាពនៃគំនិតផ្តួចផ្តើមដែលអាចមាននៅក្នុង WTO ដើម្បីបង្កើតសំណុំវិធានពហុភាគីមួយអំពីវិនិយោគ

ក្នុងចំណោមសំនួរពិភាក្សានៅក្នុងក្រុមការងារលើបញ្ហាឧត្តមភាពនៃការអនុម័តសំនុំវិធានពហុភាគីមួយស្តីពីវិនិយោគនៅក្នុង WTO អំពីបញ្ហាដែលបានលើកឡើង អំពីនិយមន័យនៃវិនិយោគ និងផលប៉ះពាល់ទៅលើការអភិវឌ្ឍន៍នៃវិធានពហុភាគីដែលអាចមានទៅលើកាវិនិយោគ ត្រូវបានធ្វើការកត់សំគាល់ ដោយសង្ខេបដូចខាងក្រោម ។

និយមន័យនៃវិនិយោគ

នៅក្នុងការពិភាក្សាអំពីនិយមន័យនៃពាក្យថា "វិនិយោគ" នៅក្នុងកិច្ចព្រមព្រៀងអន្តរជាតិមួយស្តីពីការវិនិយោគ គណៈប្រតិភូមួយចំនួនចូលចិត្តនិយមន័យ ដែលផ្អែកលើមូលដ្ឋានទ្រព្យសកម្ម ទាំងសំរាប់វិនិយោគផ្ទាល់ និងវិនិយោគលើមូលប័ត្រ ។ គេបានស្នើថា បញ្ហាដែលអាចកើតមានឡើង ពីការគិតបញ្ចូលនូវការវិនិយោគលើមូលប័ត្រទៅក្នុង និយមន័យនៃការវិនិយោគនៅក្នុងកិច្ចព្រមព្រៀងមួយ ពុំចាំបាច់មានន័យថាគ្រប់កាតព្វកិច្ច ទាំងអស់នៃកិច្ចព្រមព្រៀង នឹងត្រូវអនុវត្តចំពោះការវិនិយោគបែបនោះឡើយ ។

គណៈប្រតិភូមួយចំនួនមានមតិថា ត្រូវបង្កើតក្រុមការងារ ដោយមានការយល់ច្បាស់ថា ការងារនោះនឹងគ្របដណ្តប់ត្រឹម FDI ប៉ុណ្ណោះ ។ ការរួមបញ្ចូលនូវវិនិយោគលើមូលប័ត្រ នៅក្នុងនិយមន័យ អាចនឹងមានផលប៉ះពាល់នយោបាយខ្លះៗ ដែលទាមទារនូវការសិក្សាជាបន្តទៀត រួមទាំងមូលហេតុ និងទិសដៅនៃភាពនឹងនរនៃលំហូរនៃការវិនិយោគលើមូលប័ត្រ ព្រមទាំងផលប៉ះពាល់របស់វាទៅលើសេដ្ឋកិច្ចនៃប្រទេសជាម្ចាស់ផ្ទះផងដែរ ។

ផលប៉ះពាល់ទៅលើការអភិវឌ្ឍន៍នៃវិធានពហុភាគីដែលអាចកើតមានទៅលើវិនិយោគ

ប្រធានបទដែលគេចូលចិត្តពិភាក្សាមួយទៀតនៅក្នុងក្រុមការងារគឺ ថាតើទំហំនៃការអភិវឌ្ឍន៍ឆ្លុះបញ្ចាំងយ៉ាងណាទៅលើសំនុំវិធានវិនិយោគជាពហុភាគីណាមួយនោះ ?

គេបានព្រមព្រៀងថា ក្នុងការព្រាងធាតុនិមួយៗ នៃសំនុំវិធានពហុភាគី នោះមានវិធីមួយសំរាប់ធានាដល់ការធ្វើដូច្នេះ គឺត្រូវយកចិត្តទុកដាក់ខ្ពស់បំផុតទៅលើបញ្ហាប៉ះពាល់ទៅលើការអភិវឌ្ឍន៍ ។

គណៈប្រតិភូខ្លះមានការស្រពិចស្រពិលថា តើការតំរង់ទិសទៅរកការអភិវឌ្ឍន៍នៃកិច្ចព្រមព្រៀងពហុភាគីមួយ អាចនឹងត្រូវបានធានាដោយគ្រាន់តែធ្វើការបូកបញ្ចូលនូវទំហំនៃការអភិវឌ្ឍន៍ទៅលើធាតុនិមួយៗ របស់វាបានដែរឬទេ ? គេក៏ត្រូវតែពិនិត្យទៅលើរចនាសម្ពន្ធ័ និងរូបភាពនៃឯកសារដែលស្នើរឡើងនេះដែរ រួមទាំងគោលដៅណែនាំ ដែលជាអ្នកកំណត់នូវខ្លឹមសាររបស់ឯកសានោះផង។ ជាបន្ថែម ចាំបាច់គេត្រូវតែដោះស្រាយនូវបញ្ហាមូលដ្ឋានមួយទៀតដែរថា តើសញ្ញាណដំបូងបំផុតនៃក្របខ័ណ្ឌ ពហុភាគីចំពោះការវិនិយោគជាក់ស្តែង វាសមស្របទៅនឹងតំរូវការគាំពារនូវលទ្ធភាពរបស់រដ្ឋាភិបាល ក្នុងការអនុវត្តន៍យុទ្ធសាស្ត្រអភិវឌ្ឍន៍ដែលសមស្របទៅនឹងបញ្ហាពិសេសៗនៃប្រទេសនិមួយៗឬទេ ?

មតិមួយបានលើកឡើងថា គេត្រូវតែទទួលស្គាល់ថាការអភិវឌ្ឍន៍ពឹងផ្អែកយ៉ាងខ្លាំងទៅលើការវិនិយោគ ។ នៅពេលដែលមិនមានគោលការណ៍អន្តរជាតិសំរាប់ជំរុញអោយការវិនិយោគហូរចូលទេ នោះបណ្តាប្រទេស នឹងជួបប្រទះនូវការលំបាកក្នុងការសំរេចបាននូវគោលដៅអភិវឌ្ឍន៍របស់ខ្លួន ។

ឯកសារយោង:

UNCTAD របាយការណ៍ស្តីពីការវិនិយោគពិភពលោក ឆ្នាំ ១៩៩៨ ទិន្នាការ និងការកំណត់ (ការបោះពុម្ពផ្សាយរបស់អង្គការសហប្រជាជាតិ)

របាយការណ៍ប្រចាំឆ្នាំ របស់អង្គការពាណិជ្ជកម្មពិភពលោក ឆ្នាំ ១៩៩៦ ច្បាប់ចេញផ្សាយលេខ ១ ស្តីពីប្រធានបទពិសេស: ពាណិជ្ជកម្ម និងការវិនិយោគផ្ទាល់ពីបរទេស ។

របាយការណ៍ប្រចាំឆ្នាំ របស់អង្គការពាណិជ្ជកម្មពិភពលោក ឆ្នាំ ១៩៩៨ ច្បាប់ចេញផ្សាយលេខ ១ ស្តីពីប្រធានបទពិសេស: សកលភាវូបនីយកម្ម និងពាណិជ្ជកម្ម ។

ជំពូក ២៣

ពាណិជ្ជកម្ម និងគោលនយោបាយប្រកួតប្រជែង

ប្រធានបទស្តីពីអន្តរកម្មរវាងពាណិជ្ជកម្ម និងគោលនយោបាយប្រកួតប្រជែងត្រូវបានបូកបញ្ចូលទៅក្នុងកម្មវិធីការងាររបស់ WTO តាមសេចក្តីសំរេចដែលធ្វើឡើងនៅឆ្នាំ ១៩៩៦ នៅក្នុងសន្និសិទ្ធថ្នាក់រដ្ឋមន្ត្រីនៅទីក្រុងសឹង្ហបូរី ។ មានការរំពឹងថា ក្រុមការងារដែលបានបង្កើតឡើងនឹងធ្វើការសិក្សាស្រាវជ្រាវលើ "បញ្ហាលើកឡើងដោយសមាជិកដែលពាក់ព័ន្ធទៅនឹងទំនាក់ទំនងរវាងពាណិជ្ជកម្ម និងគោលនយោបាយប្រកួតប្រជែង រួមទាំងការអនុវត្តន៍ប្រឆាំងនឹងការប្រកួតប្រជែង " និងដើម្បីកំណត់នូវផ្នែកទាំងឡាយណាដែលសក្តិសមនឹងយកចិត្តទុកដាក់ជាបន្ថែមទៀត នៅក្នុងក្របខ័ណ្ឌរបស់ WTO [៣៤] ។ នៅក្នុងការវិភាគ គេរំពឹងថា ក្រុមការងារនឹងធ្វើការពិចារណាបន្ថែមទៀតពីបទបញ្ញត្តិនៃកិច្ចព្រមព្រៀងស្តីពីវិធានការវិនិយោគដែលពាក់ព័ន្ធនឹងពាណិជ្ជកម្ម បទបញ្ញត្តិនៅក្នុងច្បាប់របស់ WTO ស្តីពីការវិនិយោគ និងគោលនយោបាយប្រកួតប្រជែង ព្រមទាំងការពិភាក្សា នៅក្នុងក្រុមការងារស្តីពីពាណិជ្ជកម្ម និងការវិនិយោគ ។

បញ្ហាគោលនយោបាយប្រកួតប្រជែងនៅក្នុងពាណិជ្ជកម្មអន្តរជាតិ

ការកំណត់និយមន័យនៃគោលនយោបាយប្រកួតប្រជែង

ពាក្យ " គោលនយោបាយប្រកួតប្រជែង " ត្រូវបានប្រើប្រាស់ជាច្រើនសេបនៅក្នុងប្រទេសផ្សេងៗ និងនៅក្នុងបរិបទខុសៗគ្នាទៀត។ ក្នុងន័យទូលាយបំផុត ពាក្យនេះរួមបញ្ចូលនូវរាល់គោលនយោបាយទាំងអស់ ដែលមានសារៈសំខាន់ ចំពោះការប្រកួតប្រជែងនៅក្នុងទីផ្សាររួម ទាំងគោលនយោបាយពាណិជ្ជកម្ម គោលនយោបាយគ្រប់គ្រង និងគោលនយោបាយអនុម័ត ដោយរដ្ឋាភិបាលទប់ទល់នឹងគោលនយោបាយប្រឆាំងនឹងការប្រកួតប្រជែងរបស់សហគ្រាស ទោះជាឯកជន ឬ សាធារណៈក្តី ។ នៅក្នុងន័យចង្អៀត ពាក្យនេះត្រូវបានប្រើ ដើម្បីគ្របដណ្តប់លើអ្វីមួយ ដែលបានលើកឡើងចុងក្រោយនេះ ពោលគឺច្បាប់ ឬ គោលនយោបាយសំរាប់គ្រប់គ្រងលើឥរិយាបទប្រឆាំងនឹងការប្រកួតប្រជែងរបស់សហគ្រាស ។

មូលហេតុនៃការបញ្ចូលនូវពាណិជ្ជកម្ម និងការប្រកួតប្រជែងនៅក្នុងកម្មវិធីការងាររបស់ WTO

សេចក្តីបារម្ភអំពីលទ្ធភាពកើតមាននូវផលប៉ះពាល់ជាអវិជ្ជមាននៃការអនុវត្តន៍ពាណិជ្ជកិច្ច ដោយប្រឆាំងនឹងការប្រកួតប្រជែង (ជាញឹកញាប់គេអោយឈ្មោះថា ការអនុវត្តន៍ពាណិជ្ជកម្មដោយមានការដាក់កំហិត) ត្រូវបានលើកឡើងតាំងពី ៥០ ឆ្នាំកន្លងទៅម្ល៉េះ នៅពេលដែល GATT ត្រូវបានបង្កើតឡើង ។ សេចក្តីព្រាងនៃកតិការសញ្ញា ហាវ៉ាណា នៅឆ្នាំ១៩៤៧ មានចែងជាបន្ថែមទៅលើបទបញ្ញត្តិស្តីពីគោលនយោបាយពាណិជ្ជកម្ម បទបញ្ញត្តិស្តីអំពីការអនុវត្តន៍ពាណិជ្ជកិច្ច ដោយមានការដាក់កំហិត និងការបង្កើតអង្គការពាណិជ្ជកម្មអន្តរជាតិ ។ កតិការសញ្ញាហាវ៉ាណា ពុំអាចយកមកអនុវត្តន៍បាន ដោយសារតែសភាសហរដ្ឋអាមេរិក ពុំបានផ្តល់សច្ចាប័ន ។ ថ្វីត្បិតតែបទបញ្ញត្តិស្តីពីគោលនយោបាយពាណិជ្ជកម្ម របស់កតិការសញ្ញានេះ ត្រូវបានគេយកមកប្រើសំរាប់បង្កើត GATT ក្តី ការខំប្រឹងប្រែងបញ្ចូលបទបញ្ញត្តិស្តីពីគោលនយោបាយប្រកួតប្រជែង បែរជាពុំបានសំរេច ដោយសារតែមានមតិ

---

[៣៤] សេចក្តីប្រកាសថ្នាក់រដ្ឋមន្ត្រីនៅសិង្ហកាពួរ ២០

ផ្ទុយច្រើន ក្នុងចំណោមបណ្តាប្រទេសដែលចូលរួមចរចាលើតំរូវការក្នុងការដាក់បញ្ចូលនេះ ។ តាំងពីនោះមក ប្រទេសខ្លះបានស្នើឱ្យប្រើវិធានអន្តរជាតិនៅក្នុងផ្នែកនេះ នៅក្នុងការពិភាក្សា GATT ប៉ុន្តែសំណើរនោះពុំត្រូវបានគេអនុវត្តន៍តាមទាំងស្រុងឡើយ។

ការយកចិត្តទុកដាក់ច្រើនឡើងៗនៅក្នុងបណ្តាឆ្នាំថ្មីៗនេះ នៅក្នុងការពិភាក្សាស្តីពីគោលនយោបាយប្រកួតប្រជែង គឺអាចបណ្តាលមកពីកត្តាជាច្រើន ។ ក្នុងនោះមានចំណុចដូចតទៅ ÷

- ☐ មានអារម្មណ៍យល់ឃើញកាន់តែច្រើនឡើងថា នៅពេលលប់ចោលរបាំងរបស់រដ្ឋាភិបាល តាមរយៈការចរចាស្តីអំពីពាណិជ្ជកម្មប្រកបដោយជោគជ័យ នោះការដាក់កំហិតលើពាណិជ្ជកម្ម និងការរារាំងទាំងឡាយដែលបណ្តាលមកពីការអនុវត្តន៍របស់សហគ្រាសអាចនឹងកើនឡើងជាខ្លាំងទៅវិញផង ។

- ☐ ភ្ជាប់ជាមួយនេះគឺ ការកើនឡើងនូវសមាហរណកម្មសេដ្ឋកិច្ចពិភពលោក ដែលមិនត្រឹមតែតាមរយៈសេរីភាវូបនីយកម្មពាណិជ្ជកម្មប៉ុណ្ណោះទេ ប៉ុន្តែក៏តាមរយៈការរីកដុះដាលយ៉ាងខ្លាំងនៃការវិនិយោគផ្ទាល់ពីបរទេសផងដែរ (FDI) ។ ដូច្នេះការអនុវត្តន៍ប្រឆាំងនឹងការប្រកួតប្រជែងរបស់សហគ្រាស ទាមទារនូវវិសាលភាពឆ្លងព្រំប្រទល់កាន់តែធំដែលនឹងមានផលប៉ះពាល់ដល់ប្រទេសមួយចំនួន ហើយក្នុងករណីខ្លះ ដល់ពិភពលោកទាំងមូលទៀតផង ។

- ☐ ឥទ្ធិពលមួយទៀត គឺកំណើននៃវិធានអន្តរជាតិក្នុងកិរិតទ្វេភាគី តំបន់ និងពហុភាគីដែលការពារនូវផលប្រយោជន៍របស់ក្រុមហ៊ុនបរទេសដែលដំណើរការនៅលើទឹកដីនៃប្រទេសមួយ ។ ឧទាហរណ៍ នៅក្នុង WTO ជាលទ្ធផលនៃកិច្ចប្រជុំកុម្មូលនៅយូរ៉ូយហ្គាយ បច្ចុប្បន្ន បង្កើតអោយមានវិធានពាណិជ្ជកម្មអន្តរជាតិជាច្រើន មាននៅក្នុងវិស័យសេវាកម្ម និងកម្មសិទ្ធិបញ្ញា ហើយក្រុមការងារក៏កំពុងសិក្សាអំពីទំនាក់ទំនងរវាងពាណិជ្ជកម្មនិងការវិនិយោគដែរ ។ ប្រទេសខ្លះមានអារម្មណ៍ថា វិធានអន្តរជាតិបែបនេះ គួរតែផ្សារភ្ជាប់ទៅដោយសហប្រតិបត្តិការអន្តរជាតិយ៉ាងមុតមាំមួយ ដើម្បីត្រួតពិនិត្យលើសកម្មភាពពាណិជ្ជកិច្ចប្រឆាំងនឹងការប្រកួតប្រជែងរបស់ក្រុមហ៊ុនណានោះ ។

- ☐ ទីបញ្ចប់នៅមានការរីកចំរើនដ៏សំខាន់មួយទៀត គឺការមានមតិស្របគ្នាច្រើនឡើងៗ ពោលគឺពុំសូវមានភាពខុសគ្នា ដូចពីមុនរវាងតំបន់ខាងជើង និងខាងត្បូង ព្រមទាំងខាងកើត និងខាងលិចថា ច្បាប់ប្រកួតប្រជែងជាទូទៅ គឺជាមធ្យោបាយគតិយុត្តិមួយយ៉ាងសមស្របសំរាប់ទប់ទល់នឹងសកម្មភាពប្រឆាំងនឹងការប្រកួតប្រជែងរបស់សហគ្រាស ទោះបីជាកិច្ចព្រមព្រៀងលើបញ្ហាលំអិតទាំងឡាយទាមទានូវពេលវេលាយូរតទៅទៀតក្តី ។

ទ្រង់ទ្រាយនៃសកម្មភាពពាណិជ្ជកិច្ចប្រឆាំងនឹងការប្រកួតប្រជែង

សកម្មភាពពាណិជ្ជកិច្ចដែលអាចមានឥទ្ធិពលប្រឆាំងនឹងការប្រកួតប្រជែង ហើយមានផលប៉ះពាល់ទៅលើពាណិជ្ជកម្មអន្តរជាតិមានបួនប្រភេទធំៗ ដូចតទៅ ÷

- ☐ ការដាក់ដែនកំណត់តាមរយៈបណ្តោយ (កិច្ចព្រមព្រៀងរវាងក្រុមហ៊ុនដែលប្រកួតប្រជែងគ្នាក្នុងការផលិតនូវផលិតផលដូចគ្នា ឬ ប្រហាក់ប្រហែល ដើម្បីរារាំងនូវការប្រកួតប្រជែង) ។

- ☐ ការដាក់ដែនកំណត់តាមរយៈទទឹង (កិច្ចព្រមព្រៀងប្រឆាំងនឹងការប្រកួតប្រជែង រវាងបណ្តាក្រុមហ៊ុននៅតាមខ្សែសង្វាក់ផលិតកម្ម និងការបែងចែក) ។

- ☐ ការប្រើប្រាស់ខុសនូវជំហរដែលលេចលើសគេរបស់ខ្លួន

- ☐ ការរួមបញ្ចូលគ្នានូវក្រុមហ៊ុន

ការដាក់ដែនកំណត់តាមរយៈបណ្តោយ

កិច្ចព្រមព្រៀងដាក់ដែនកំណត់តាមរយៈបណ្តោយអាចមានទ្រង់ទ្រាយបីយ៉ាង ÷

- ☐ ក្រុមហ៊ុនកាតែលនាំចូល (cartel) និងកិច្ចព្រមព្រៀងដែលពាក់ព័ន្ធ
- ☐ ក្រុមហ៊ុនកាតែលខាងនាំចេញ និងកិច្ចព្រមព្រៀងដែលពាក់ព័ន្ធ
- ☐ ក្រុមហ៊ុនកាតែលអន្តរជាតិ ។

ក្រុមហ៊ុនកាតែលនាំចូល និងកិច្ចព្រមព្រៀងដែលពាក់ព័ន្ធ

ក្រុមហ៊ុនកាតែលនាំចូលបង្កើតឡើងដោយអ្នកនាំចូល ឬអ្នកទិញក្នុងស្រុក ព្រមទាំងវិធានការប្រហាក់ប្រហែលនេះ (ដូចជាការធ្វើវិទ្ធង្សនា ឬ ការប្រឆាំងជំទាស់ជាសមូហភាពនឹងអ្នកប្រកួតប្រជែងបរទេស) គឺសុទ្ធតែជាកម្មវត្ថុនៃសេចក្តីបារម្ភ បើពិនិត្យលើទិដ្ឋភាពនៃការបើកទីផ្សារ ។ បញ្ហាពាក់ព័ន្ធ មានការហាមឃាត់នូវការប្រកួតប្រជែងពីបរទេស ឬ លក្ខខណ្ឌនៃការរើសអើងសមាជិកភាពនៅក្នុងសមាគមន៍ពាណិជ្ជកម្ម ព្រមទាំងជាពិសេស ការប្រើផ្តាច់មុខនូវស្តង់ដារកំណត់ដោយសមាគមន៍នោះ ។ ការតែល "ប្រភេទខ្លាំង" ដូចជាកំណត់ថ្លៃ ការដាក់កំហិតលើបរិមាណផលិតកម្ម ការបែងចែកទីផ្សារ និងអតិថិជន ជាទូទៅត្រូវបានហាមឃាត់ទាំងស្រុងនៅក្នុងច្បាប់ប្រកួតប្រជែង ទោះបីជាក់ស្តែងគឺកិច្ចជាការពុំតឹងរ៉ឹងណាស់ណាក្តី (នៅក្នុងលក្ខខណ្ឌច្បាប់ខ្លះ គេអាចអនុញ្ញាតិអោយបាន ប្រសិនបើអ្នកនាំចូលត្រូវប្រឈមមុខជាមួយអ្នកផ្គត់ផ្គង់បរទេស ដែលមានជំហរលើសលប់ ហើយការប្រកួតប្រជែងនៅលើទីផ្សារ ក្នុងស្រុកពុំស្ថិតនៅក្រោមការដាក់កំហិតប៉ុន្មាន) ។ កិច្ចព្រមព្រៀងសហប្រតិបត្តិការផ្សេងទៀត រវាងអ្នកប្រកួតប្រជែង ដូចជានៅក្នុងការកំណត់ស្តង់ដារ និងការធ្វើការទិញនូវអ្វីរួមគ្នា ជាញឹកញាប់គឺជាកម្មវត្ថុ នៃការវិភាគវិធាននៃមូលហេតុ ។

កាតែលនាំចេញ និងកិច្ចព្រមព្រៀងដែលពាក់ព័ន្ធ

កាតែលនាំចេញអាចបែងចែកចេញជាពីរក្រុម ។ កាតែលនាំចេញ "សុទ្ធសាធ" តំរង់សេចក្តីប្រឹងប្រែងរបស់ខ្លួន តែចំពោះទីផ្សារបរទេសប៉ុណ្ណោះ ។ កាតែលនាំចេញ "ចំរុះ" រាំងនូវការប្រកួតប្រជែង ទាំងនៅលើទីផ្សារក្នុងស្រុក របស់ប្រទេសនាំចេញផង ហើយក៏នៅទីផ្សារបរទេសផងដែរ ។

ការតែលនាំចេញ "សុទ្ធសាធ" ត្រូវបានចាត់ទុកថា ដូចជាស្ថិតនៅក្រៅវិសាលភាពនៃច្បាប់ប្រកួតប្រជែង របស់បណ្តាប្រទេសជាច្រើនដោយមូលហេតុពីរ ។ ទីមួយ កាតែលនេះ ត្រូវបានចាត់ទុកថា ស្ថិតនៅក្រៅអំណាចច្បាប់នៃច្បាប់ប្រកួតប្រជែងក្នុងស្រុក ហើយម្យ៉ាងទៀត ត្រូវបានគេលើកលែងដោយផ្ទាល់ពីការអនុវត្តន៍របស់ច្បាប់ ។ ចំណែកកាតែលនាំចេញចំរុះវិញ ជាទូទៅចាំបាច់ត្រូវរងនូវលក្ខខណ្ឌដូចគ្នា ឬ ក៏ការហាមឃាត់តែម្តង ដូចជាកាតែលឯទៀតៗ ដែលមានឥទ្ធិពលតែទៅលើទីផ្សារក្នុងស្រុកដែរ ទោះបីជាមានប្រទេសខ្លះផ្តល់នូវការលើកលែងពិសេសសំរាប់កាតែលបែបនេះ នៅទីណាដែលលក្ខណក្នុងស្រុក ឬ ឥទ្ធិពលក្នុងស្រុកមានលក្ខណៈជាឧបករណ៍ជំនួយចំពោះការដាក់កំហិតនៅលើពាណិជ្ជកម្មនាំចេញក្តី ។

កាតែលអន្តរជាតិ

កាតែល និងទីផ្សារអន្តរជាតិ ដែលមានកិច្ចព្រមព្រៀងរវាងបណ្តាសហគ្រាសនៅក្នុងប្រទេសពីរ ឬ ច្រើនជាទូទៅ ត្រូវបានគេចាត់ទុកថាមានលក្ខណៈដូច និងការកំណត់ថ្លៃជារយៈបណ្តោយ ព្រមទាំងកិច្ចព្រមព្រៀងសំងាត់ដ៏ទៃទៀត នៅក្នុងប្រទេសណាមួយតែឯង ។ ក្នុងករណីទាំងពីរ ការប្រកួតប្រជែងក៏មានការកើតថ្លៃក៏កើនឡើង ផលិតកម្មក៏មានដែនកំណត់ ហើយទីផ្សារត្រូវបានបែងចែកជាគុណប្រយោជន៍ឯកជនរបស់ក្រុមហ៊ុន ។ ក្នុងគីរីតដែលឥទ្ធិពលរបស់វានៅក្នុងសមត្ថកិច្ច ច្បាប់មួយមានលក្ខណៈដូចគ្នា និងឥទ្ធិពលនៃកាតែលជាតិ ការអនុវត្តន៍នូវច្បាប់ប្រកួតប្រជែងជាធរមាន នោះនឹងពុំសូវមានប្រសិទ្ធិភាពប៉ុន្មានឡើយ ក្នុងការដោះស្រាយបញ្ហា។ ឧទាហរណ៍នៅទសវត្ស ទី៤០ និង៥០ អាជ្ញាធរប្រឆាំងត្រឹស (trust) នៅសហរដ្ឋអាមេរិកបានធ្វើការកាត់ទោសចំពោះករណីកាតែលមួយចំនួនធំពាក់ព័ន្ធនឹងទីផ្សារអន្តរជាតិ សំរាប់ផលិតផលដើម និងទំនិញផលិតរួច ។ ករណីនោះពាក់ពន្ធ័នឹងការកំណត់ថ្លៃ និងការបែងចែកទីផ្សារក្នុងស្រុក ដោយផ្ទាល់ក្នុងចំណោមបណ្តាសហគ្រាសដែល វានឹងអាចកើតមាននូវការប្រកួតប្រជែងនឹងគ្នា ប្រសិនបើគ្មានទង្វើបែបនេះទេនោះ ។ ហើយការនេះរឹតតែធ្ងន់ធ្ងរទៅទៀតតាមរយៈការហាមឃាត់ប្រឆាំង នឹងការនាំចូល និងនាំចេញដោយក្រុមហ៊ុនដែលចូលរួមជាមួយ ។ ក្នុងករណីនេះជាច្រើន កាតែលត្រូវបានបង្កើតឡើង ដោយការផ្តល់អាជ្ញាប័ណ្ណ

ប្រកាសនីយប័ត្រតក្កកម្មអោយគ្នាទៅវិញទៅមក ។ នៅក្នុងទសវត្សទី ៩០ ក៏មាននៅការកាត់ទោសថ្មីទៀតជាច្រើន លើបញ្ហាកាតែលកំណត់ថ្លៃ ជាអន្តរជាតិ ក្នុងចំណោមផលិតករនៃផលិតផល ដូចជា លីស៊ីន អាស៊ីដស៊ីទ្រិក និងក្រដាសហ្វាក់ ។

ប្រភេទសំខាន់មួយទៀតនៃកិច្ចព្រមព្រៀងតាមរយៈបណ្តោយ ដែលបង្កនូវការព្រួយបារម្ភច្រើន អំពីបញ្ហាផលប៉ះពាល់របស់វា ចំពោះការអនុវត្តន៍នូវអំណាចទីផ្សារនៅក្នុងទីផ្សារអន្តរជាតិ គឺកិច្ចព្រមព្រៀង កិច្ចសហប្រតិបត្តិការ សំរាប់ការស្រាវជ្រាវនិងអភិវឌ្ឍន៍ (R&D) ជាពិសេសនៅទីណា ដែលពង្រាងគំរោងបញ្ញត្តិច្បាប់សំរាប់សហប្រតិបត្តិការលើ R&D បានធ្វើអោយកិច្ចព្រមព្រៀងនោះងាយរងនូវឥទ្ធិពលនៃការប្រើប្រាស់ជាយុត្តិសាស្រ្ត ។ សមត្ថកិច្ចច្បាប់ភាគច្រើន ដែលមានលក្ខណៈទំនើប បានបង្កើតនូវទ្រង់ទ្រាយមួយចំនួននៃបទបញ្ញត្តិពិសេសសំរាប់សហប្រតិបត្តិការអន្តរក្រុមហ៊ុន (ក្រុមហ៊ុនចំរុះ ឬ Consortia) នៅក្នុងកម្មវិធី R&D ព្រោះបើពុំដូច្នេះទេ R&D នឹងមិនអាចធ្វើទៅបានឡើយ ។ ប៉ុន្តែគេបានកត់សំគាល់ថា បទបញ្ញត្តិសំរាប់កិច្ចព្រមព្រៀងបែបនេះពុំមានរូបរាងជាការលើកលែងទាំងស្រុងពីច្បាប់ប្រកួតប្រជែងឡើយ ពីព្រោះការប្រកួតប្រជែងក៏មានតួនាទីសំខាន់ដែរ នៅក្នុងការផ្តល់ការលើកទឹកចិត្ត ចំពោះទង្វើអ្វីដែលថ្មីៗ ទាន់ពេលវេលាព្រមទាំងការបង្កើននូវបច្ចេកវិទ្យាថ្មីផង ។

កិច្ចព្រមព្រៀងដាក់កំហិតទីផ្សារតាមរយៈទទឹង

កិច្ចព្រមព្រៀងដាក់កំហិតទីផ្សារតាមរយៈទទឹង អាចបណ្តាលអោយមានការបារម្ភខាងផ្នែកពាណិជ្ជកម្មនៅទីណា ដែលរាំងក្រុមហ៊ុនបរទេស មិនអោយមានលទ្ធភាពចូលរួមក្នុងបណ្តាញបែងចែក ដែលគ្រប់គ្រងដោយអ្នកផ្គត់ផ្គង់ក្នុងស្រុក ។ ការអនុវត្តន៍ដែលធ្លាប់ប្រើរួមមាន ÷

- ☐ ការទាមទារធ្វើសកម្មភាពតែឯង ដែលរាំងចំពោះអ្នកបែងចែកទាំងឡាយពីការលក់ផលិតផល ។
- ☐ ការលក់ដោយមានចំណងល័ក្ខខ័ណ្ឌ ដែលធ្វើអោយអ្នកទិញផលិតផលនៃម៉ាកណាមួយ ត្រូវជាប់ល័ក្ខខ័ណ្ឌទិញផលិតផលមួយទៀតនៃម៉ាកដដែល ។
- ☐ ការចុះថ្លៃចំពោះភក្តីភាព ឬ ចុះថ្លៃលក់ ដែលផ្តល់នូវការលើកទឹកចិត្តជាហិរញ្ញវត្ថុ សំដៅមិនអោយធ្វើការបែងចែកនូវផលិតផលរបស់គូប្រកួតប្រជែង ។
- ☐ ទឹកដីដាច់ដោយឡែក ដែលរាំងមិនអោយអ្នកបែងចែក លក់ផលិតផលនៅក្រៅតំបន់ភូមិសាស្រ្តណាមួយ ។

ការប្រើប្រាស់ខុសនូវជំហរលេចលើសគេរបស់ខ្លួន

ចំណាត់ថ្នាក់សកម្មភាពពាណិជ្ជកិច្ចដែលមានការដាក់កំហិតជាការដាក់កំហិត រយៈបណ្តោយ និងទទឹងត្រូវបានធ្វើឡើងតាមភាពសមហេតុផលនៃសេដ្ឋកិច្ច ។ ប៉ុន្តែច្បាប់ប្រកួតប្រជែងជាច្រើនក៏បានបែងចែក រវាងកិច្ចព្រមព្រៀងក្នុងចំណោមក្រុមហ៊ុន និងការប្រើប្រាស់ខុសនូវជំហរលេចលើសគេ ឬ ទង្វើផ្តាច់មុខដែរ ។ ពាក្យខាងក្រោយនេះមាន និយមន័យថា ជាសកម្មភាព ធ្វើឡើងដោយក្រុមហ៊ុនមានជំហរលេចលើសគេ សំដៅរក្សាពង្រឹង ឬ ធ្វើអាជីវកម្មទាញយកផលពីជំហរលេចលើសគេនោះ នៅក្នុងទីផ្សារមួយ ។ សកម្មភាពដែលស្ថិតនៅក្រោមនិយមន័យនេះរួមមាន ÷

- ☐ អំណាចធ្វើអាជីវកម្មផ្តាច់មុខ
- ☐ ការផ្តាច់ចេញពីទីផ្សារតាមរយៈសមាហរណ៍កម្មរយៈទទឹង
- ☐ ការលក់ដោយមានចំណងល័ក្ខខ័ណ្ឌ
- ☐ ការត្រួតពិនិត្យលើឧបករណ៍ដែលខ្សត់ និង Input ឬ បណ្តាញបែងចែកសំខាន់ៗ
- ☐ ការទាញយកប្រយោជន៍តាមរយៈថ្លៃ - និងមិនតាមរយៈថ្លៃ
- ☐ ការរើសអើងដោយប្រើថ្លៃជាឧបករណ៍

- ☐ កិច្ចព្រមព្រៀងជាកិច្ចសន្យាផ្តាច់មុខ

- ☐ នៅក្នុងក្របខ័ណ្ឌសមត្ថកិច្ចច្បាប់ខ្លះ គឺមានន័យទ្រង់ទ្រាយសាមញ្ញចាប់តាំងពីការយកថ្លៃ ខ្ពស់ជាងថ្លៃ ប្រកួតប្រជែង ឬ ការអនុវត្តន៍នូវការប្រើប្រាស់ខុសដើម្បីទាញយកផលប្រយោជន៍តាមប្រភេទផ្សេងៗទៀត ។

ការរួមបញ្ចូលក្រុមហ៊ុន

គេអាចបែងចែករវាងប្រភេទនៃការរួមបញ្ចូលក្រុមហ៊ុនជាបីយ៉ាងសំខាន់ៗ គឺការរួមបញ្ចូលតាមរយៈខ្សែបណ្តោយ តាមរយៈខ្សែទទឹង និងការធ្វើជា (Conglomerate) ក្រុមហ៊ុនពហុផលិតផល ។

ការចូលរួមគ្នាតាមរយៈខ្សែបណ្តោយ គឺជាការបញ្ចូលគ្នានូវក្រុមហ៊ុនពីរ ឬ ច្រើនដែលស្ថិតនៅក្នុងខ្សែអាជីវកម្មតែមួយ និងនៅក្នុងទីផ្សារក្នុងភូមិសាស្ត្រតែមួយ ហើយដែលមាននិន្នាការជំរុញថ្លៃអោយឡើងខ្ពស់ គឺដូចជាកាតែលដែរ។ ប៉ុន្តែការសំរេចចិត្តអំពីគោលនយោបាយប្រកួតប្រជែង ចំពោះការរួមបញ្ចូលតាមរយៈខ្សែបណ្តោយនេះ មានលក្ខណៈស្មុគស្មាញ ពីព្រោះក្រុមហ៊ុនដែលកើតពីការបញ្ចូលគ្នានោះ អនុញ្ញាតិអោយអតីតអ្នកប្រកួតប្រជែងខ្លួនធ្វើសមាហរណកម្ម នៅក្នុងផលិតកម្មរបស់ខ្លួន ដូច្នេះការនេះអាចមានផលប៉ះពាល់ទៅលើចំណាយផលិតកម្ម ។ ប្រសិនបើក្រុមហ៊ុន កើតពីការបញ្ចូលគ្នានេះ កាត់បន្ថយនូវចំណាយអថេរនោះ ជាក់ស្តែងវាអាចនាំអោយថ្លៃទីផ្សារចុះទាបជាងថ្លៃ នៅមុនពេលកើតមានការរួមបញ្ចូគ្នានេះ ហើយដូចនោះ ការរួមបញ្ចូលគ្នានេះអាចមានអ្នកចង់ធ្វើបើពិនិត្យលើមូលដ្ឋានសង្គម ។

ការរួមចូលគ្នាតាមរយៈខ្សែទទឹង ពាក់ព័ន្ធនឹងក្រុមហ៊ុន ដែលស្ថិតនៅក្នុងដំណាក់កាលផ្សេងៗគ្នា នៃផលិតកម្មនិងធ្វើម៉ាឃីតទីងនៅក្នុងឧស្សាហកម្មតែមួយ ។ ប្រភេទនៃការរួមបញ្ចូលគ្នានេះ ជាញឹកញាប់ ត្រូវបានធ្វើឡើងដើម្បីសំរេចបាននូវប្រសិទ្ធិភាពតាមរយៈការកាត់បន្ថយចំណាយប្រតិបត្តិការ និងចំណាយឯទៀតៗ ដោយវិធីធ្វើអោយទៅជារបស់ផ្ទៃក្នុងនូវតំណាក់កាលផ្សេងៗគ្នានៃផលិតកម្ម និងការបែងចែក តែគេក៏អាចប្រើវាដើម្បីផ្តាច់ចេញនូវធនធានជាវត្ថុធាតុបញ្ចូលក្នុងផលិតកម្ម (Inputs) ឬបណ្តាញបែងចែកពីគូប្រកួតប្រជែងដែរ ។ ការរួមបញ្ចូលគ្នាជាក្រុមហ៊ុនពហុផលិតផល (Conglomerate) គឺការធ្វើសមាហរណកម្មនៃក្រុមហ៊ុន ដែលមានប្រតិបត្តិការក្នុងខ្សែពាណិជ្ជកិច្ចដែលពុំមានពាក់ព័ន្ធគ្នាសោះ ។ ការរួមបញ្ចូលគ្នាបែបនេះ ជាធម្មតាពុំបានបង្កើតអោយមានក្តីបារម្ភទេ បើពិនិត្យលើមូលដ្ឋាននយោបាយប្រកួតប្រជែង ពីព្រោះជាទូទៅ វាពុំបានបង្កើននូវកំរិតនៃអំណាចទីផ្សារ ដែលនឹងអាចធ្វើទៅបានដោយក្រុមហ៊ុនធម្មតានៅក្នុងទីផ្សារផលិតផលនោះឡើយ ។

ធាតុផ្សំសំខាន់ៗនៃច្បាប់ប្រកួតប្រជែង

មុននឹងបែរទៅរកការពិពណ៌នាអំពីចំណុចដែលលើកឡើងនៅក្នុងការពិភាក្សាក្នុងក្រុមការងារ អំពីបញ្ហាកើតឡើងពីសវិយាបទពាណិជ្ជកម្មប្រឆាំងនឹងការប្រកួតប្រជែង ជាការល្អគេគួរធ្វើការកត់សំគាល់ ដោយសង្ខេបអំពីលក្ខណៈសំខាន់ៗនៃច្បាប់ជាតិស្តីពីការប្រកួតប្រជែង ដែលមានគោលដៅគ្រប់គ្រងលើសវិយាបទទាំងនោះ ។

គោលដៅចំបង នៃច្បាប់ជាតិស្តីពីការប្រកួតប្រជែងនៅក្នុងបណ្តាប្រទេសដែលមានច្បាប់នេះ គឺសំដៅរក្សា និងជំរុញនូវការប្រកួតប្រជែងអោយក្លាយជាមធ្យោបាយមួយ ដើម្បីធានានូវការបែងចែកធនធាននៅក្នុងសេដ្ឋកិច្ច ដោយមានប្រសិទ្ធិភាព ដែលនឹងនាំអោយមានជំរើសគុណភាពល្អបំផុត ថ្លៃថោកបំផុត និងការផ្គត់ផ្គង់សមស្របដល់អតិថិជន ។ ជាបន្ថែមលើការជំរុញនូវប្រសិទ្ធិភាព ច្បាប់ប្រកួតប្រជែងជាច្រើន មានគោលដៅផ្សេងៗទៀត ដូចជាត្រួតពិនិត្យលើការប្រមូលផ្តុំនូវអំណាចសេដ្ឋកិច្ច ជំរុញលទ្ធភាពប្រកួតប្រជែងនៃឧស្សាហកម្មក្នុងស្រុកជំរុញការផ្ទេរនូវអ្វីថ្មីៗ ឧបត្ថម្ភធនចំពោះសហគ្រាសធុនតូច និងមធ្យមព្រមទាំងជំរុញសមាហរណកម្មតំបន់។ជួនកាលគោលដៅជាបន្ថែមនេះមួយ ចំនួនក៏មានទំនាស់ជាមួយ នឹងគោលដៅដែលចង់បានប្រសិទ្ធិភាពដែរ ។

ច្បាប់ប្រកួតប្រជែងភាគច្រើន ដោះស្រាយសវិយាបទសហគ្រាសតាមរយៈការហាមឃាត់នូវសកម្មភាពពាណិជ្ជកិច្ចប្រឆាំងនឹងការប្រកួតប្រជែង ក្នុងរូបភាពជាកិច្ចព្រមព្រៀងខ្សែរយៈបណ្តោយ រាំងមិនអោយមានការប្រកួតប្រជែង ការទិញយក និងប្រើប្រាស់ខុសនូវជំហរលេចលើសគេ ក៏ដូចជាកិច្ចព្រមព្រៀងខ្សែរយៈទទឹងសំខាន់ៗ លើបណ្តាញបែងចែកដែលមានការដាក់កំហិត ។ ជាបន្ថែមលើនេះ ការកើនឡើងនូវច្បាប់ប្រកួតប្រជែង បានដោះស្រាយនូវបញ្ហាកែប្រែរចនាសម្ព័ន្ធទីផ្សារតាមរយៈការត្រួតពិនិត្យលើការរួម

បញ្ចូលគ្នានូវក្រុមហ៊ុនការទិញយកក៏ដូចជាក្រុមហ៊ុនចំរុះ សំដៅរាំងនូវការបង្កើតក្រុមហ៊ុន ដែលមានជំហរលេចលើសគេ ក្រុមហ៊ុនផ្តាច់មុខ ឬ ក៏ក្រុមហ៊ុន Oligopolies ។ នៅក្នុងច្បាប់ខ្លះទៀត អាជ្ញាធរក៏បានបង្គាប់អោយបំបែកចេញនូវក្រុមហ៊ុនផ្តាច់មុខ ដើម្បីកែប្រែរចនាសម្ព័ន្ធទីផ្សារ ។

តែច្បាប់នោះក៏មានករណីលើកលែងពីការអនុវត្តន៍បទបញ្ញត្តិរបស់វាដែរ ។ ក្នុងនោះមានបញ្ហាពលកម្ម ឧស្សាហកម្មដែលរងនូវការគ្រប់គ្រង (ឧទាហរណ៍ដូចជា ទូរគមនាគមន៍ ការពារជាតិ កសិកម្ម) សហគ្រាសធុនតូច និងមធ្យម ព្រមទាំងកិច្ចព្រមព្រៀងសហប្រតិបត្តិការខ្លះៗរួមទាំងក្រុមហ៊ុនចំរុះលើ R&D ។

ប៉ុន្តែមានប្រទេសមួយចំនួនបានពិនិត្យឡើងវិញលើភាពត្រឹមត្រូវ និងសុពលភាពនៃករណីលើកលែងជាទូទៅបែបនេះដែរ ។ ពោលគឺគេកាន់តែផ្តោតអារម្មណ៍ច្រើនឡើងៗ ទៅលើការអនុវត្តន៍ច្បាប់ប្រកួតប្រជែង ចំពោះគ្រប់អាជីវកម្មទាំងអស់ ។ ដូច្នេះ នេះគឺជាការងាររបស់អាជ្ញាធរទទួលបន្ទុកលើការប្រកួតប្រជែង ឬ តុលាការ ក្នុងការវិនិច្ឆ័យលើសកម្មភាពពាណិជ្ជកិច្ចព្រមទាំងផ្តោតការយកចិត្តទុកដាក់ទៅលើសកម្មភាពណាដែលមានការជឿជាក់ខ្ពស់ថានឹងមានឥទ្ធិពលប្រឆាំងនឹងការប្រកួតប្រជែង និងមានករណីលើកលែងយ៉ាងសមហេតុផល តែតិចតួចបំផុតដោយផ្អែកលើមូលដ្ឋានប្រសិទ្ធិភាព ។

សង្ខេបរួមលើបញ្ហាសំខាន់ៗ នៅក្នុងការពិភាក្សាក្នុងក្រុមការងារ WTO[៣៥]

បញ្ហាសំខាន់ៗនៃការពិភាក្សា

ចំណុចសំខាន់នៃការពិភាក្សានៅក្នុងក្រុមការងារ WTO ស្តីពីទំនាក់ទំនងរវាងពាណិជ្ជកម្ម និងគោលនយោបាយប្រកួតប្រជែង គឺម្យ៉ាងជាទំនាក់ទំនងរវាងគោលនយោបាយពាណិជ្ជកម្ម និងការអភិវឌ្ឍន៍ ហើយម្យ៉ាងទៀត គឺរវាងគោលនយោបាយពាណិជ្ជកម្ម និងគោលនយោបាយប្រកួតប្រជែង ។ ចំណុចតទៅនេះនឹងរំលេចឡើងនូវការពិភាក្សារបស់ក្រុមការងារ ដែលក្នុងនោះមានប្រធានបទសំខាន់ៗដូចតទៅ ÷

- ☐ ទំនាក់ទំនងនៃពាណិជ្ជកម្ម និងគោលនយោបាយប្រកួតប្រជែងចំពោះការអភិវឌ្ឍន៍ និងកំណើនសេដ្ឋកិច្ច
- ☐ ផលប៉ះពាល់នៃសកម្មភាពប្រឆាំងនឹងការប្រកួតប្រជែងរបស់សហគ្រាស និងសហគមន៍ទាំងឡាយ នៅលើពាណិជ្ជកម្មអន្តរជាតិ
- ☐ ក្រុមហ៊ុនផ្តាច់មុខរបស់រដ្ឋ និងបទបញ្ញត្តិផ្សេងៗ
- ☐ ទំនាក់ទំនងរវាងការវិនិយោគ និងគោលនយោបាយប្រកួតប្រជែង
- ☐ ទំនាក់ទំនងរវាងទិដ្ឋភាពពាណិជ្ជកម្ម ដែលទាក់ទងនឹងកម្មសិទ្ធិបញ្ញា និងគោលនយោបាយប្រកួតប្រជែង
- ☐ ផលប៉ះពាល់នៃគោលនយោបាយពាណិជ្ជកម្មទៅលើការប្រកួតប្រជែង ។

[៣៥] កំនិតនេះត្រូវបានដកស្រង់ចេញពីរបាយការណ៍របស់ក្រុមការងារ ស្តីពីសកម្មភាពរបស់ខ្លួន ក្នុងឆ្នាំ ១៩៩៧-១៩៩៨ ។ ពត៌មានពិស្តារ អ្នកអានគួរតែពិភាក្សាលើរបាយការណ៍ដោយខ្លួនឯង [" របាយការណ៍ឆ្នាំ ១៩៩៨ របស់ក្រុមការងារស្តីពីអន្តរទំនាក់ទំនងរវាងពាណិជ្ជកម្ម និងគោលនយោបាយប្រកួតប្រជែង ដែលបានដាក់ជូនទៅអគ្គក្រុមប្រឹក្សា" (WTO, WT/WGTCP/2, ៨ ធ្នូ ១៩៩៨] ។

ទំនាក់ទំនងនៃពាណិជ្ជកម្ម និងគោលនយោបាយប្រកួតប្រជែងចំពោះការអភិវឌ្ឍន៍ និងកំណើនសេដ្ឋកិច្ច

ក្រុមការងារបានយកចិត្តទុកដាក់ ជាពិសេសទៅលើការវិភាគទំនាក់ទំនងនៃពាណិជ្ជកម្ម និងគោលនយោបាយប្រកួតប្រជែងចំពោះការអភិវឌ្ឍន៍ ។ នៅក្នុងបរិបទនេះ គេបានចង្អុលបង្ហាញថា នៅក្នុងបណ្តាប្រទេសមួយចំនួន ច្បាប់ និងគោលនយោបាយប្រកួតប្រជែងត្រូវបានអនុវត្ត ឬពង្រីកជារូមពុំមែនឯកោរទ្បើយ ប៉ុន្តែគឺជាធាតុផ្សំនៃកញ្ចប់មួយនៃគោលនយោបាយកែទំរង់ដែលពាក់ព័ន្ធ សំដៅជំរុញការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមកិច្ច ។ លក្ខណៈសំខាន់នៃកំណែទំរង់នេះ គឺការពឹងពាក់ជាសំខាន់ទៅលើកំលាំងទីផ្សារដែលជាយន្តការនៃការអភិវឌ្ឍន៍ និងកំណែតំរូវ ព្រមទាំងទៅលើការបង្កើតនូវក្របខ័ណ្ឌមួយដែលមានគោលដៅធានាថា កំលាំងបែបនេះនឹងមានដំណើរការ ដើម្បីផលប្រយោជន៍សាធារណៈ ជាពិសេសតាមរយៈការជំរុញ ឬរក្សានូវការប្រកួតប្រជែងនៅក្នុងទីផ្សារ ។ កំណែទំរង់ដែលពាក់ពន្ធ័រួមមានវិធានការបើកចំហរទីផ្សារ (រួមទាំងសេរីភាវូបនីយកម្មនៃពាណិជ្ជកម្ម និងរបបវិនិយោគបរទេស) ឯកជនភាវូបនីយកម្ម និងកំណែទំរង់បទបញ្ញត្តិ ចំពោះផ្នែកពិសេសៗ ឬការលប់បំបាត់នូវបទប្បញ្ញត្តិ ។ ធាតុផ្សំផ្សេងៗទៀតនៃកញ្ចប់នេះ ត្រូវបានគេគិតទុកថានឹងមានដំណើរការដោយការជួយពង្រឹងគ្នាទៅវិញទៅមក ។

ចំណុចពាក់ព័ន្ធមួយលើកឡើងនៅក្នុងការពិភាក្សា គឺសារៈសំខាន់នៃគោលនយោបាយប្រកួតប្រជែងក្នុងលក្ខណៈជាឧបករណ៍មួយសំរាប់អភិវឌ្ឍន៍នៅក្នុងបរិស្ថានសេដ្ឋកិច្ចសកលនាបច្ចុប្បន្ននេះ ប្រៀបធៀបទៅនឹងយុគសម័យមុន ។ មតិដែលបានលើកឡើង គឺខណៈដែលនៅពេលអតីតកាលបណ្តាប្រទេសអាចសង្ឃឹមនឹងសំរេចបាននូវការអភិវឌ្ឍន៍ តាមរយៈឧបករណ៍ និងវិធីសាស្ត្រផ្សេងទៀត (ប្រហែលជាដោយការធ្វើអន្តរាគមន៍ច្រើន) វិធីសាស្ត្របែបនេះរបែរជាមិនអាចប្រើប្រាស់បានទៀត ពីព្រោះតែកំរិតនៃការកកើតឡើងនូវសេរីភាវូបនីយកម្មពាណិជ្ជកម្ម និងសកលភាវូបនីយកម្មនៃសកម្មភាពជំនួញ ព្រមទាំងកំរិតកើនឡើងនៃសារៈសំខាន់នៃការវិនិយោគផ្ទាល់ពីបរទេសថា ជាម៉ាស៊ីននៃកំណើនសេដ្ឋកិច្ចនៅក្នុងបរិស្ថានសេដ្ឋកិច្ចបច្ចុប្បន្ន ។ ជាលទ្ធផលនៃការអភិវឌ្ឍន៍នេះ សកម្មភាពប្រឆាំង នឹងការប្រកួតប្រជែងរបស់សហគ្រាស ក៏មានវិសាលភាពកើនឡើងៗ ជាអន្តរជាតិ ហើយទំនងជាមានភាពធ្ងន់ធ្ងរជាងពេលមុនៗ។ ហេតុដូច្នេះហើយ យោងតាមមតិខាងលើនេះ គេចាំបាច់ត្រូវមានគោលនយោបាយប្រកួតប្រជែងមួយយ៉ាងសកម្ម ដើម្បីឆ្លើយតបយ៉ាងសមស្របទៅនឹងសេចក្តីបារម្ភ និងដើម្បីបង្កើតនូវបរិយាកាសអំណោយផលមួយ ចំពោះវិនិយោគ និងកំណើនសេដ្ឋកិច្ច។

ក្នុងខណៈដែលមតិអំពីតួនាទីរបស់ការប្រកួតប្រជែងនៅក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ច ត្រូវបានទទួលការគាំទ្រជាទូទៅពីសំណាក់ក្រុមការងារ ក៏មានមតិមួយទៀតលើកឡើងដែរថា ទោះជាមានច្បាប់ប្រកួតប្រជែងដ៏ទូលំទូលាយណាមួយហើយក្តី ក៏ច្បាប់នោះពុំប្រាកដជាធានាបាននូវកំរិតប្រកួតប្រជែងមួយ ដែលគេចង់បានដែរ ។ ការនេះឆ្លុះបញ្ចាំងអោយឃើញនូវការពិចារណាជាច្រើន ។

ក្នុងចំណោមសមាជិក WTO ទាំង ១១៤ គឺមានប្រទេសតែប្រមាណ ៧០ ទៅ ៨០ ប៉ុណ្ណោះ ដែលមានច្បាប់ប្រកួតប្រជែង។ ទោះបីជានៅក្នុងប្រទេសដែលមានច្បាប់នេះហើយក្តី ក៏ក្នុងករណីខ្លះ ការអនុវត្តន៍នៅមានការខ្វះខាតដែរ ដោយកង្វះធនធានហិរញ្ញវត្ថុ និងបុគ្គលដែលមានបទពិសោធន៍អំពីច្បាប់ប្រកួតប្រជែង ។ ដោយសារតែច្បាប់នោះមានលក្ខណៈស្មុគស្មាញ ទើបការអនុមត័ច្បាប់បែបនេះ នាពេលបច្ចុប្បន្ន ទាមទារនូវពេលវេលាជាច្រើន ។

លើសពីនេះទៅទៀត ប្រសិនបើច្បាប់ប្រកួតប្រជែងនេះ ត្រូវបំពេញអោយបាននូវគោលដៅជំរុញកំណើនសេដ្ឋកិច្ច តាមរយៈការធ្វើអោយប្រសើរឡើងនូវប្រសិទ្ធិភាពសេដ្ឋកិច្ច និងធ្វើអោយទីផ្សារមានលក្ខណៈប្រកួតប្រជែង សមាជិកជាច្រើនជឿជាក់ថា គេក៏ត្រូវតែគិតគូរទៅដល់លក្ខណៈពិសេសនៃបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ដែរ ដូចជា កំរិតប្រាក់ចំណូលទាប បែងចែកពុំបានត្រឹមត្រូវនូវទ្រព្យធន ការសិក្សាអប់រំមានកំរិតទាប និងកង្វះពត៌មាន ។ ប្រការទាំងនោះ អាចនឹងទាមទារអោយគេប្រើនូវវិធីសាស្ត្រដែលអាចបត់បែនបានច្រើនជាង ហើយនឹងត្រូវការនូវអន្តរាគមន៍ខ្លះៗទៅលើទីផ្សារ ។ ឧទាហរណ៍ ច្បាប់ប្រកួតប្រជែងរបស់ប្រទេសជឿនលឿនជាច្រើនបានចែងពីប្រព្រឹត្តិកម្មពិសេសចំពោះឧស្សាហកម្មទំហំតូច និងមធ្យម ។ នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ភាពចាំបាច់ក្នុងការអនុវត្តន៍ប្រព្រឹត្តិកម្មពិសេស ចំពោះឧស្សាហកម្មប្រភេទនោះ តាមរយៈការផ្តល់អោយគេនូវការលើកទឹកចិត្តខាងពន្ធដារ និងអ្វីផ្សេងទៀត ព្រមទាំងការបើកច្រកចូល ទៅកាន់ហិរញ្ញប្បទានដែលមានល័ក្ខខ័ណ្ឌអនុគ្រោះអាចនឹងមានកំរិតកាន់តែធំឡើង ។ រដ្ឋាភិបាល នៃប្រទេសទាំងនេះអាចនឹងមើលឃើញថា គេចាំបាច់ត្រូវដើរតួនាទីសកម្មជាងប្រទេសឯទៀតនៅក្នុងទីផ្សារ ដើម្បីការពារនូវសុវត្ថិភាពជាតិ (តាមរយៈការរក្សាសមត្ថភាពផលិតកម្ម នៅក្នុងឧស្សាហកម្ម ដែលគេចាត់ទុកថាមានសារៈសំខាន់) ការពារសិទ្ធិពលករ និងរក្សាការពារវប្បធម៌ជាតិ (តាមរយៈការគ្រប់គ្រងលើវប្បធម៌) ។

ផលប៉ះពាល់នៃសកម្មភាពប្រឆាំងនឹងការប្រកួតប្រជែងរបស់សហគ្រាស និងក្រុមសម្ព័ន្ធរបស់គេទៅលើពាណិជ្ជកម្មអន្តរជាតិ

ការពិភាក្សាអំពីផលប៉ះពាល់នៃសកម្មភាពប្រឆាំងនឹងការប្រកួតប្រជែងរបស់សហគ្រាសទៅលើពាណិជ្ជកម្មអន្តរជាតិ បានផ្តោតជាទូទៅលើប្រធានបទបីប្រភេទ ÷

- ☐ សកម្មភាពប៉ះពាល់ទៅលើការបើកច្រកទីផ្សារសំរាប់ទំនិញនាំចូល
- ☐ សកម្មភាពប៉ះពាល់ទៅលើទីផ្សារអន្តរជាតិ នៅទីណាដែលប្រទេសផ្សេងៗនានា ទទួលរងនូវផលប៉ះពាល់តាមបែបដូចគ្នា និង
- ☐ សកម្មភាពដែលមានផលប៉ះពាល់ខុសៗគ្នាទៅលើទីផ្សារជាតិនៃបណ្តាប្រទេសនីមួយៗ ។

សកម្មភាពប៉ះពាល់ទៅលើការបើកទីផ្សារសំរាប់ទំនិញនាំចូល

ឧទាហរណ៍ពិសេស នៃសកម្មភាពដែលមានផលប៉ះពាល់ទៅលើការបើកច្រកទីផ្សារសំរាប់នាំចូល និងដែលបានលើកឡើងដោយសមាជិកនៅក្នុងការពិភាក្សារួមមានករណីជាក់ស្តែងនៃ ÷

- ☐ ការតែលក្នុងស្រុក ខាងផ្នែកនាំចូល
- ☐ ការតែលអន្តរជាតិ ដែលបែងចែកទីផ្សារជាតិ ក្នុងចំណោមក្រុមហ៊ុនចូលរួមនានា
- ☐ ភាពរាំងស្ទះដែលពុំសមស្របនានា ចំពោះការនាំចូលនូវទំនិញដូចគ្នា
- ☐ ការត្រួតពិនិត្យគ្រប់គ្រងលើការនាំចូលនូវឧបករណ៍ ឬមធ្យោបាយសំខាន់ៗ
- ☐ ការប្រើប្រាស់ខុសនូវជំហរលេចលើសគេ និងការដាក់កំហិតតាមខ្សែរយៈទទឹងទៅលើទីផ្សារដែលផ្តាច់ទីផ្សារ ពីគូរប្រកួតប្រជែង សកម្មភាពកំណត់ស្តង់ដារជាឯកជន និងសកម្មភាពប្រឆាំងនឹងការប្រកួរប្រជែងផ្សេងៗទៀតដែលពាក់ព័ន្ធទៅនឹងក្រុមសម្ព័ន្ធឧស្សាហកម្ម ។

ចំណុចដែលបានលើកឡើងគឺ សកម្មភាពប្រឆាំងនឹងការប្រកួតប្រជែងប្រភេទទាំងនេះ អាចមានឥទ្ធិពលកាត់បន្ថយ និងលប់បំបាត់នូវផលប្រយោជន៍ជាយថាហេតុពីសេរីភាវូបនីយកម្មពាណិជ្ជកម្ម ។ ជាការបកស្រាយនូវចំណុចនេះ គេបានផ្តល់ពត៌មានចំពោះក្រុមការងារអំពីការសិក្សាលើករណីវិស័យមួយចំនួន ដែលគេបានដកចេញនូវរបាំងពាណិជ្ជកម្ម ដែលធ្លាប់មានជាទម្លាប់នោះ ។ សេចក្តីសន្និដ្ឋានជាមូលដ្ឋាននៃការសិក្សានេះគឺថា ជាទូទៅ នៅពេលដែលប្រទេសមួយអនុវត្តនូវសេរីភាវូបនីយកម្មយ៉ាងច្រើនហើយនោះនោះ គេក៏មានសេចក្តីរំពឹងដែរថា ថ្លៃក្នុងស្រុកនឹងមានទំនោរទោរទៅរកកំរិតសមមូលនឹងថ្លៃនាំចូល ។ ក៏ប៉ុន្តែ ការសិក្សាលើករណីក៏បានចង្អុលបង្ហាញដែរនូវស្ថានភាពជាច្រើន ដែលពុំមានលក្ខណៈឆ្លើយតបដូចខាងលើ ដោយសារតែសកម្មភាពប្រឆាំងនឹងការប្រកួតប្រជែងរបស់សហគ្រាស ។ កត្តាដែលមានទំនោរជួយសំរួល ឬគាំទ្រនូវសកម្មភាពប្រឆាំងនឹងការប្រកួតប្រជែងបែបនេះរួមមានកំរិតប្រមូលផ្តុំរបស់ទីផ្សារខ្ពស់ តំរូវការរបស់អ្នកប្រើប្រាស់ដែលពុំសូវប្រែប្រួល (ឆ្លុះបញ្ចាំងនូវកង្វះខាតទំនិញដែលអាចជំនួសបាន) វត្តមាននូវរូបជាស្រេចនៃការតែល និងការគ្រប់គ្រងដោយសហគ្រាស ដែលលេចលើសគេនៅលើឧបករណ៍មធ្យោបាយក្រខ្សត់ ដែលចាំបាច់នាំអោយមានការនាំចូល ។

សកម្មភាពដែលមានឥទ្ធិពលទៅលើទីផ្សារអន្តរជាតិ នៅពេលដែលប្រទេសផ្សេងៗទទួលរងនូវផលប៉ះពាល់តាមបែបដូចគ្នាច្រើន

ឧទាហរណ៍ញឹកញាប់ជាងគេនៃសកម្មភាពប្រឆាំងនឹងការប្រកួតប្រជែងនៅក្នុងបរិបទនេះ គឺបញ្ហាការតែលអន្តរជាតិ ដែលមានឥទ្ធិពលទៅលើថ្លៃ និងផលិតផលនៅលើទីផ្សានានានៃប្រទេសផ្សេងៗ ។ ករណីជាច្រើន ដែលក្នុងនោះ អាជ្ញាធរទទួលបន្ទុកខាងប្រកួតប្រជែងក្នុងប្រទេសនានា បានរកឃើញនូវការតែលបែបនេះ ត្រូវបានលើកឡើង នៅចំពោះមុខក្រុមការងារ ។ ការតែលដែលមាន

ប្រតិបត្តិការនៅក្នុងវិស័យសេវាកម្មខ្លះៗ ដូចជានាវា សមុទ្រអន្តរជាតិ ឬសេវាកម្មហិរញ្ញវត្ថុ ត្រូវបានសមាជិកមួយចំនួននិយាយថា ជាកាតែលដែលប្រកបគ្រោះថ្នាក់ ជាពិសេសចំពោះពាណិជ្ជកម្ម ពីព្រោះវាមិនត្រឹមតែដាក់កំហិត ចំពោះពាណិជ្ជកម្មក្នុងក្របខ័ណ្ឌសេវាកម្មចំពោះមុខនោះប៉ុណ្ណោះទេ ប៉ុន្តែក៏បានបង្កើនថ្លៃសេវាកម្មនោះ ចំពោះអ្នកនាំចេញដែរ ហើយបានបង្កើននូវការរំខានក្នុងកិតមួយផ្សេងទៀតផង ។

ក៏ប៉ុន្តែមានចំណុចលើកឡើងថា ទោះបីជាមានការកាត់ទោសជាទូទៅចំពោះកាតែល ឬ មានកិច្ចព្រមព្រៀងរបៀបនេះក្តី ក៏ជាញឹកញាប់គេអាចនឹងយល់ស្របអោយមានដែរ នូវវិធីសាស្រ្តទន់ភ្លន់មួយលើការអនុវត្តន៍ច្បាប់ប្រកួតប្រជែងចំពោះប្រភេទខ្លះនៃសកម្មភាពអន្តរក្រុមហ៊ុន ។ សកម្មភាពទាំងនោះរួមមាន ទីមួយ កិច្ចព្រមព្រៀងខ្សែរយៈបណ្តោយ ដែលមិនដូចទម្លាប់ធម្មតា ដូចជាក្រុមសម្ព័ន្ធភាពយុទ្ធសាស្រ្ត ក្រុមហ៊ុនចំរុះ និងសមាគមន៍បណ្តោះអាសន្នផ្នែក R&D ដែលពុំចាំបាច់ និងមានឥទ្ធិពលដូចគ្នានឹងឥទ្ធិពលនៃកិច្ចព្រមព្រៀងជាប្រពៃណី ដូចជា ការរួមបញ្ចូលគ្នានៃក្រុមហ៊ុន និងកាតែល ហើយដែលមាននិន្នាការពិតជាក់លាក់ និងទីពីរ គឺកិច្ចព្រមព្រៀងដែលពាក់ពន្ធ័នឹងក្រុមហ៊ុនធុនតូច និងមធ្យម ។

សកម្មភាពដែលមានផលប៉ះពាល់ផ្សេងៗគ្នាទៅលើទីផ្សារអន្តរជាតិ

ឧទាហរណ៍មួយដែលលើកឡើងជាទូទៅ អំពីសកម្មភាពប្រឆាំងនឹងការប្រកួតប្រជែង នៅក្នុងបរិបទនេះ គឺកាតែលនាំចេញ ។ គេបាននិយាយថា ជនរងគ្រោះនៃកាតែលនាំចេញ ជាញឹកញាប់រួមមាន ប្រទេសកំពុងអភិវឌ្ឍន៍ ដែលនាំចូលនូវគ្រឿងម៉ាស៊ីន ឬផលិតផលប្រើប្រាស់ ។ លើសពីនេះទៀត គេបានស្នើឡើងថា ទំហំនៃកាតែលបែបនេះ ព្រមទាំងឥទ្ធិពលខូចខាតរបស់វាទៅលើពាណិជ្ជកម្មអន្តរជាតិ និងការអភិវឌ្ឍន៍ អាចនឹងមានក៏វិតធំជាងពីការធ្លាប់យល់ដឹង ពីព្រោះប្រទេសជាច្រើនពុំបានជំនះ អោយមានការចុះបញ្ជី នូវកាតែលបែបនោះទេ គឺពួកគេសុខចិត្តសម្លឹងមើលកាតែលនោះដោយបិទភ្នែកទៅវិញ ។ បញ្ហានៃការរួមបញ្ចូលគ្នានូវក្រុមហ៊ុនដែលត្រូវទទួលនូវការវិនិច្ឆ័យថា គួរបដិសេធន៍ ឬក៏មានប្រយោជន៍នៅក្នុងទីផ្សារមួយ ប៉ុន្តែស៊ែរជាមានន័យផ្សេងវិញ នៅលើទីផ្សារមួយទៀត ក៏ត្រូវបានគេលើកមកពិភាក្សាដែរ ។ ចំណុចដែលលើកឡើង គឺការកើតមាននូវករណីបែបនោះអាចនឹងពុំសូវមានញឹកញាប់ឡើយ ចំពោះប្រទេសណាដែលអនុវត្តស្តង់ដារសុខុមាលភាពអ្នកប្រើប្រាស់ ជាជាងស្តង់ដារសុខមាលភាពសរុប សំរាប់ធ្វើការវិនិច្ឆ័យក្រុមហ៊ុនរួមបញ្ចូលគ្នានោះ ។ មូលហេតុគឺ នៅក្នុងវិធីសាស្រ្តខាងក្រោយនេះ ក្រុមហ៊ុនរួមបញ្ចូលគ្នាដែលទទួលបាននូវប្រសិទ្ធិភាពខ្ពស់ នៅក្នុងទីផ្សារក្នុងស្រុកអាចនឹងទទួលនូវការទទួលស្គាល់ ទោះបីជាក្រុមហ៊ុននោះ មានបង្កឥទ្ធិពលប្រឆាំងនឹងការប្រកួតប្រជែងច្រើនក្តី រួមទាំងឥទ្ធិពលដែលនឹងអាចកើតមាននៅក្នុងទីផ្សារបរទេសផងដែរ ។

កត្តាសំរួលដល់សកម្មភាពប្រឆាំងនឹងការប្រកួតប្រជែង ដែលមានផលប៉ះពាល់ទៅលើពាណិជ្ជកម្ម

ក្រុមការងារបានធ្វើការពិភាក្សាជាច្រើនអំពីកត្តានានា រួមទាំងនយោបាយ និងវិធានការរបស់រដ្ឋាភិបាល ដែលអាចជួយសំរួលដល់សកម្មភាពប្រឆាំងនឹងការប្រកួតប្រជែងរបស់សហគ្រាស ហើយដូចនោះ ក៏ធ្វើអោយខូចខាតដល់ផលប្រយោជន៍ ដែលអាចទទួលបានពីសេរីភាវូបនីយកម្ម ។ កត្តាដែលលើកឡើងនៅក្នុងបរិបទនេះរួមមាន ÷

- ☐ អត្ថិភាព ឬការពុំមានអត្ថិភាពនៃច្បាប់ និងគោលនយោបាយប្រកួតប្រជែងមួយដែលមានការរៀបចំល្អ
- ☐ ការលើកលែងជាផ្លូវច្បាប់ ឬ របបបទបញ្ញត្តិការពារ ដែលគ្របដណ្តប់លើសកម្មភាពដែលមានបញ្ហានោះ
- ☐ កំហុសកើតឡើងពីការពុំបានអនុវត្តអោយបានសមស្របនូវច្បាប់ និងគោលនយោបាយដែលមានការពាក់ព័ន្ធទៅនឹងសកម្មភាពប្រឆាំងនឹងការប្រកួតប្រជែង
- ☐ អត្ថិភាពនៃនយោបាយឯទៀតៗរបស់រដ្ឋាភិបាលដែលគាំទ្រដោយផ្ទាល់ ឬ ដោយប្រយោល ឬ ជំរុញនូវសកម្មភាពប្រឆាំងនឹងការប្រកួតប្រជែង និង
- ☐ ការខ្វះខាតនូវវិធានដ៏មានប្រសិទ្ធិភាពសំរាប់គ្រប់គ្រងច្រកចូលទៅកាន់ឧបករណ៍ / មធ្យោបាយសំខាន់ៗ នៅក្នុងបរិបទនៃការលប់បំបាត់នូវបទបញ្ញត្តិ ។

លើសពីនេះទៀត គេបានធ្វើការកត់សំគាល់ថា បញ្ហាលុបបំបាត់សកម្មភាពប្រឆាំងនឹងការប្រកួតប្រជែងរបស់សហគ្រាសអាចនឹងកាន់តែជួបការលំបាក ជាពិសេសនៅក្នុងករណីដែលអតីតសហគ្រាសរដ្ឋដែលធ្លាប់មានអំណាចគ្រប់គ្រងខ្លួនឯងផ្ទាល់ ត្រូវឯងនូវការធ្វើឯកជនភាវូបនីយកម្ម ដោយពុំមានវិធានការដាក់ចុះសំរាប់កំណត់នូវអំណាចទីផ្សាររបស់គេផងនោះ ។

ក្រុមហ៊ុនផ្ដាច់មុខរបស់រដ្ឋ និងបទបញ្ញត្តិ

ក្រុមហ៊ុនផ្ដាច់មុខរបស់រដ្ឋ និងអភ័យឯកសិទ្ធិ

នៅក្នុងការពិភាក្សានៅលើប្រធានបទនេះ មានមតិជាច្រើនអំពីបញ្ហាខូចខាតដែលក្រុមហ៊ុនផ្ដាច់មុខរបស់រដ្ឋ និងអភ័យឯកសិទ្ធិអាចធ្វើឡើងទាំងចំពោះការប្រកួតប្រជែង និងការបើកច្រកទៅកាន់ទីផ្សារ។ គេបានកត់សំគាល់ថា WTO ក៏បានទទួលស្គាល់ដែរថា នៅក្នុងកិច្ចប្រតិបត្តិរបស់គេ សហគ្រាសដែលមានអភ័យឯកសិទ្ធិបែបនេះ អាចបង្កនូវឧបសគ្គយ៉ាងធ្ងន់ធ្ងរចំពោះពាណិជ្ជកម្ម ។ ឥទ្ធិពលនោះអាចនឹងកើតឡើង នៅក្នុងទីផ្សារណា ដែលគេអនុវត្តន៍នូវអភ័យឯកសិទ្ធិទាំងទីផ្សារ ក្នុងសង្វាក់ផលិតកម្មខាងលើ និងខាងក្រោមផងដែរ ។ ឧទាហរណ៍ជាពិសេស ត្រូវបានលើកឡើងអំពីផលប៉ះពាល់ ដែលអ្នកទិញ និងអ្នកលក់ផ្ដាច់មុខអាចធ្វើឡើង ដើម្បីរារាំងដល់ការប្រកួតប្រជែងនឹងពាណិជ្ជកម្ម រួមទាំងតាមរយៈកង្វះខាតនូវតម្លាភាព និងការបំរើជាឧបករណ៍សំរាប់អនុវត្តគោលនយោបាយពាណិជ្ជកម្មជាតិ ។ ជាលទ្ធផលវាអាចមានឥទ្ធិពលដាក់កំហិតលើការនាំចូល និងបង្កើតនូវការរំខានដល់ទីផ្សារ។ សមាជិកខ្លះ បានលើកឡើងពីតួនាទីជាវិជ្ជមានរបស់ក្រុមហ៊ុនផ្ដាច់មុខរបស់រដ្ឋ និងអភ័យឯកសិទ្ធិដែរ ជាពិសេស គឺប្រទេសកំពុងអភិវឌ្ឍន៍ដែលនៅទីនោះ កំលាំងទីផ្សារជួនកាលកំពុងស្ថិតក្នុងបឋមវ័យនៅឡើយ ។

គោលនយោបាយដាក់បញ្ញត្តិ

គណៈប្រតិភូខ្លះបានបកស្រាយនូវបទពិសោធន៍ប្រទេសជាតិខ្លួន ជាមួយក្រុមការងារអំពីបញ្ហាអនិយតកម្ម ព្រមទាំងផលប្រយោជន៍ទទួលបានពីទង្វើនោះ ។ គេនិយាយថា បទពិសោធន៍បានបង្ហាញថា ការប្ដេជ្ញាចិត្តបង្កើតទីផ្សារប្រកួតប្រជែងជាជាងកំហិតជិតនិយកតកម្ម ដែលជាឧបករណ៍ទីមួយនៃអភិបាលកិច្ច និងមានគុណប្រយោជន៍សំខាន់ចំពោះការប្រកួតប្រជែងពាណិជ្ជកម្ម និងសុខុមាលភាពអ្នកប្រើប្រាស់ ព្រមទាំងបង្កើតនូវប្រសិទ្ធិភាព និងជំរុញនូវការបង្កើតអ្វីថ្មីៗ ពោលគឺពុំមែនវិធីសាស្ត្រគ្រប់គ្រងនោះឡើយ ។ លទ្ធផលដែលបានមក ជាការកាត់បន្ថយថ្លៃប្រើប្រាស់ នៅក្នុងករណីជាច្រើនមានកំរិតហួសពីសេចក្ដីរំពឹងទៅទៀត ។ គេបានសង្កត់ធ្ងន់ទៅលើសារៈសំខាន់នៃច្បាប់ និងគោលនយោបាយប្រកួតប្រជែងយ៉ាងម៉ឺងម៉ាត់ ដែលជាធាតុផ្សំបន្ថែមពីលើកំណែទំរង់បទបញ្ញត្តិសំដៅធ្វើសេរីភាវូបនីយកម្មទីផ្សារ ដើម្បីរាំងនូវការបន្ត ឬ ការកើតឡើងថ្មីៗនូវសកម្មភាពប្រឆាំងនឹងការប្រកួតប្រជែងនៅក្នុងទីផ្សារ ដែលគេបានលុបបំបាត់នូវការគ្រប់គ្រងរួច ។ គេបានផ្ដល់ពត៌មានចំពោះក្រុមការងារអំពីលទ្ធផលការងាររបស់ OECD ដែលបានបង្ហាញថា មានភស្តុតាងជាច្រើនបញ្ជាក់អំពីលទ្ធភាពនៃកំណែទំរង់និយតកម្ម ដែលបានធ្វើឡើងដោយត្រឹមត្រូវ និងមានការយល់ច្បាស់ពីទំនាក់ទំនងគោលនយោបាយ ថាអាចនឹងកែលំអលទ្ធផលសេដ្ឋកិច្ចបានយ៉ាងច្រើន ទោះតាមផ្នែកក្ដី និងទូទាំងប្រទេសក្ដី ព្រមទាំងជាមួយគ្នានោះក៏អាចពង្រឹងសមត្ថភាពរបស់រដ្ឋាភិបាល ក្នុងការការពារផលប្រយោជន៍សាធារណៈសំខាន់ៗដូចជាការការពារបរិស្ថាន និងអ្នកប្រើប្រាស់ផងដែរ ។ ក្រុមការងារក៏បានទទួលពត៌មានដែរ អំពីការសិក្សានាពេលថ្មីៗ ដែលបានលើកឡើងចំពោះមុខក្រុមអន្តររដ្ឋាភិបាលរបស់ UNCTAC នៃអ្នកជំនាញការច្បាប់ និងគោលនយោបាយប្រកួតប្រជែង ដែលជាអ្នកធ្វើការស្រាវជ្រាវរកភស្តុតាងតាមរយៈការងារសង្កេតអំពីផលប្រយោជន៍នៃការអនុវត្តន៍ច្បាប់ប្រកួតប្រជែងចំពោះការអភិវឌ្ឍន៍ ។ ភស្តុតាងដែលសង្ខេបឡើងនៅក្នុងការសិក្សាបានចង្អុលបញ្ជាក់ថា ការប្រើប្រាស់ថ្លៃទីផ្សារសេរីជំនួសថ្លៃកំណត់ដោយរដ្ឋាភិបាល អាចផ្ដល់នូវផលចំណេញសំខាន់ៗ ចំពោះប្រសិទ្ធិភាព និងសុខុមាលភាពអ្នកប្រើប្រាស់ ។

ទំនាក់ទំនងរវាងការវិនិយោគ និងគោលនយោបាយប្រកួតប្រជែង

នៅក្នុងការពិភាក្សានៅក្នុងក្រុមការងារ ចំណុចដែលបានលើកឡើងគឺ របប FDI សេរីមួយ អាចបង្កើនការប្រកួតប្រជែងនៅក្នុងទីផ្សារ ។ គោលនយោបាយប្រកួតប្រជែងដែលមានដំណើរការល្អ ក៏អាចជួយលុបបំបាត់នូវឧបសគ្គចំពោះលំហូរនៃ FDI ដោយសារឥរិយាបថរបស់អ្នកទទួលខុសត្រូវបច្ចុប្បន្ន ហើយក៏ចូលរួមចំណែកក្នុងការផ្ដល់នូវក្របខ័ណ្ឌច្បាប់ដ៏មានលក្ខណៈទាក់ទាញមួយចំពោះ វិនិយោគិនបរទេសដែរ ។ នៅក្នុងបរិបទនោះ គេបានបញ្ជាក់ថា ជាពិសេសនៅក្នុងប្រទេសជឿនលឿន និងប្រទេសដែលមាន

សេដ្ឋកិច្ចអន្តរកាល សេរីភាវូបនីយកម្មនៃ FDI ជាញឹកញាប់អាចក្លាយជាផ្នែកមួយនៃកញ្ចប់គោលនយោបាយដ៏ទូលំទូលាយមួយ ដែលគ្របដណ្តប់ផ្នែកនានា ដូចជា សេរីភាវូបនីយកម្មពាណិជ្ជកម្ម កំណែទំរង់ការគ្រប់គ្រងតាមបទបញ្ញត្តិ និងឯកជនភាវូនីយកម្ម ក៏ដូចជាគោលនយោបាយប្រកួតប្រជែង ។ គេបានបង្ហាញដែរថា គោលនយោបាយ និងច្បាប់ប្រកួតប្រជែងដ៏ត្រឹមត្រូវ អាចរួមចំណែក ផ្តល់នូវបរិស្ថានទាក់ទាញមួយចំពោះ FDI តាមរយៈការផ្តល់នូវក្របខ័ណ្ឌច្បាប់ស្ថិតស្ថេរ និងមានតម្លាភាព ដូចជាប្រភេទដែល វិនិយោគិនបរទេសជាច្រើនធ្លាប់ស្គាល់ស្រាប់ និងតាមរយៈការផ្តល់ជាសញ្ញាអំពីការប្តេជ្ញាចិត្តរបស់គេចំពោះ ការបង្កើតស្ថាប័ន និង យន្តការទីផ្សារ ។

នៅក្នុងការពិចារណាអំពីទំនាក់ទំនងរវាងការវិនិយោគ និងគោលនយោបាយប្រកួតប្រជែង គេក៏បានពិភាក្សា អំពីភាពមិនស៊ីគ្នា ឬ ប្រឆាំងគ្នាដែលមានកើតឡើងរវាងគោលនយោបាយទាំងពីរនោះដែរ ។ គេបានស្នើថា ការគ្រប់គ្រងហួសហេតុនៅលើការវិនិយោគ ឧទាហរណ៍តាមរយៈបទបញ្ញត្តិគ្រប់គ្រង ធ្វើការរើសសំរាំង ឬ តំរូវការផលិត អាចបង្ករការខូចខាតទាំងចំពោះការវិនិយោគ និងការប្រកួតប្រជែង ។ មតិនោះបានបញ្ជាក់ថា វិធានការបែបនោះមិនត្រឹមតែអាចធ្វើអោយមានការរួញរាដល់លំហូរដ៏មានប្រយោជន៍ នៃដើមទុន និងបច្ចេកវិទ្យាដែលគេរំពឹងថានឹងជួយជំរុញដល់ការប្រកួតប្រជែងនៅក្នុងទីផ្សារក្នុងស្រុកប៉ុណ្ណោះទេ ប៉ុន្តែជាញឹកញាប់ ច្រើនក្លាយទៅជាឧបករណ៍នៃគោលនយោបាយមិនត្រឹមត្រូវ ឬ អាចប្រឆាំងនឹងផលិតភាពទៀត នៅពេលណាដែលវាពាក់ព័ន្ធ នឹងគោលនយោបាយប្រកួតប្រជែង ។ ប៉ុន្តែមានខ្លះក៏កត់សំគាល់ថា ការអនុវត្តន៏នូវដំណើរការជ្រើសរើសសំរាំងការវិនិយោគ ពុំមែន ជាទំរង់មួយនៃការដាក់បទបញ្ញត្តិគ្រប់គ្រងហួសហេតុនោះទេ ប៉ុន្តែជាក់ស្តែង គឺជាបែបបទដែលប្រើសំរាប់អនុវត្តការសំរាំងនោះទេវិញ (សេរីជាង ធៀបនឹងរឹតត្បិតជាង) ហើយក៏ជាកត្តាកំណត់ថា តើវាជាបទបញ្ញត្តិគ្រប់គ្រងហួសហេតុ ឬយ៉ាងណា ។ មានចំណុច លើកឡើងដែរថា គោលនយោបាយប្រកួតប្រជែងដែលពុំអនុវត្តតាមវិធីដែលមានតំលាភាព ស្ថេរ អព្យាក្រឹត្យ និងមិនរើសអើង (ចំពោះប្រទេសជាតិ) ទេនោះ អាចនឹងក្លាយទៅជាការរាំងស្ទះ ចំពោះលំហូរចូលនៃការវិនិយោគ ។

ចំណុចលើកឡើងគឺ ទំនាក់ទំនងរវាងពាណិជ្ជកម្ម ការវិនិយោគ និងការប្រកួតប្រជែងត្រូវបានគេទទួលស្គាល់ជាស្រេចនៅក្នុង លិខិតុបករណ៍មួយចំនួនរបស់ WTO ដូចជាកិច្ចព្រមព្រៀង GATS, TRIM, និង TRIPS ។ ឧទាហរណ៍ក៏បានលើកឡើង ចំពោះកិច្ចព្រមព្រៀងតាមតំបន់ ដែលមានភស្តុតាងបញ្ជាក់អំពីវត្តមាននៃទំនាក់ទំនងដូចគ្នានោះ ។ មានមតិលើកឡើងថា ក្រៅពីការ ផ្តល់នូវក្របខ័ណ្ឌចំពោះសហប្រតិបត្តិការ និងនីតិវិធីចរចា ព្រមទាំងការត្រួសត្រាយផ្លូវសំរាប់ការបង្កើតនូវវិធានលំអិតជាច្រើនទៀត លិខិតុបករណ៍របស់ WTO បច្ចុប្បន្នពុំមានលទ្ធភាពរាំងនូវសកម្មភាពពាណិជ្ជកម្មដែលមានការដាក់កំហិត ឬរាំងនូវការប្រើប្រាស់ ខុសនូវបទបញ្ញត្តិនានា នៅក្នុងបរិបទគោលនយោបាយប្រកួតប្រជែងឡើយ ។ ដូច្នេះបញ្ហា ចំពោះមុខ គឺត្រូវលប់ចេញនូវវិធាន WTO បច្ចុប្បន្នដែលពុំសមស្រប នឹងត្រូវបង្កើននូវឥទ្ធិពលរួមរវាងគោលនយោបាយវិនិយោគ និងការប្រកួតប្រជែងតាមវិធីមួយ ដែលមានលក្ខណៈជាប្រព័ន្ធច្រើនជាងមុន ។

ទំនាក់ទំនងរវាងទិដ្ឋភាពពាណិជ្ជកម្មដែលទាក់ទងនឹងកម្មសិទ្ធិបញ្ញា និងគោលនយោបាយប្រកួតប្រជែង

ទំនាក់ទំនងរវាងកម្មសិទ្ធិបញ្ញា និងគោលនយោបាយប្រកួតប្រជែង បានបង្កើតឡើងនូវបញ្ហាដ៏ស្មុគស្មាញ ។ គោលបំណងនៃសិទ្ធិ កម្មសិទ្ធផ្តាច់មុខផ្តល់អោយដោយរបបកម្មសិទ្ធិបញ្ញា គឺការផ្តល់នូវកំរៃសមស្រប ចំពោះទ្រព្យសម្បត្តិ ដែលជាលទ្ធផលនៃការងារ ខាងបញ្ញា ។ ចំណែកគោលបំណងនៃច្បាប់ប្រកួតប្រជែងវិញ គឺដើម្បីធានាថាសិទ្ធិផ្តាច់ មុខរបស់អ្នកកាន់កាប់សិទ្ធិនឹងមិនត្រូវយក មកប្រើប្រាស់ ដើម្បីអោយពួកគេទទួលនូវកំរៃដ៏ខ្ពស់យ៉ាងមិនសមស្របបានឡើយ ហើយទីផ្សារនៃកម្មសិទ្ធិនោះក៏ត្រូវតែមានលក្ខណៈ សមស្រប និងយុត្តិធម៌ ។

នៅក្នុងបរិបទនេះក្រុមការងារបានកត់សំគាល់ នូវបំលាស់ប្តូរឥរិយាបថរបស់អាជ្ញាធរប្រកួតប្រជែងខ្លះ អំពីបញ្ហាអំណាចទីផ្សារនៃ ម្ចាស់កម្មសិទ្ធិបញ្ញា ។ ពោលគឺមានការកាត់បន្ថយនូវនិន្នាការរបស់តុលាការ និងអាជ្ញាធរទទួលបន្ទុកលើការប្រកួតប្រជែងក្នុងការ សន្និដ្ឋានថា កម្មសិទ្ធិខាងបញ្ញា ដូចជាប្រកាសនីយបត្រ័កក្កកម្មជាដើម គឺសុទ្ធតែផ្តល់ដល់ម្ចាស់ប្រកាសនីយបត្រ័កក្កកម្ម នូវអំណាច ទីផ្សារ ។ បច្ចុប្បន្នកាន់តែមានការព្រមព្រៀង ធ្វើការស្រាវជ្រាវលើបញ្ហានេះច្រើនឡើងៗ លើករណីនីមួយៗ និងការទទួលស្គាល់-ជាឧទាហរណ៍ថា-ក្នុងចំណោមប្រកាសនីយបត្រ័កក្កកម្មរាប់ពាន់ ដែលបានផ្តល់អោយក្នុងមួយឆ្នាំៗ គឺមានតែមួយភាគតូចប៉ុណ្ណោះទេ ដែលផ្តល់នូវអំណាចទីផ្សារធំដុំ ។

លើសពីនេះទៅទៀត នៅក្នុងការអនុវត្តន៍ច្បាប់ប្រកួតប្រជែង ចំពោះបញ្ហាកម្មសិទ្ធិបញ្ញា បច្ចុប្បន្ន ក៏មានការទទួលស្គាល់ច្រើនឡើងដែរ អំពីផលប្រយោជន៍ខាងប្រសិទ្ធិភាព បានមកពីការផ្តល់អាជ្ញាប័ណ្ណ នៃសិទ្ធិលើកម្មសិទ្ធិបញ្ញាជាបន្ថែមទៅលើឥទ្ធិពលនៃការប្រឆាំងនឹងការប្រកួតប្រជែង ដែលកិច្ចព្រមព្រៀងអោយអាជ្ញាប័ណ្ណ អាចបង្កើតឡើងនៅក្នុងករណីខ្លះ ។ អាជ្ញាធរជាតិទទួលបន្ទុកលើការប្រកួតប្រជែងរបស់ប្រទេសមួយចំនួន បានចេញនូវសេចក្តីណែនាំលើការផ្តល់អាជ្ញាប័ណ្ណ ដែលគេចាត់ទុកថាអាចយល់ស្របបាន និងករណីដទៃទៀតដែលទាមទារអោយគេធ្វើការពិនិត្យស្រាវជ្រាវសិន ។ នៅទីណាដែលការផ្តល់អាជ្ញាប័ណ្ណចាំបាច់ត្រូវថ្លឹងកាត់ការត្រួតពិនិត្យ ការនេះជាទូទៅត្រូវបានធ្វើឡើងតាមករណីដោយឡែកៗ ស្របតាមស្តង់ដារ "វិធាននៃមូលហេតុ" ដែលតាមរយៈនោះ ផលប្រយោជន៍បានមកពីការគាំទ្រនូវការប្រកួតប្រជែង ត្រូវបានថ្លឹងថ្លែងជាមួយនឹងឥទ្ធិពលដែលកើតពីការប្រឆាំងនឹងការប្រកួតប្រជែង ។

ផលប៉ះពាល់នៃគោលនយោបាយពាណិជ្ជកម្មទៅលើការប្រកួតប្រជែង

នៅក្នុងប្រធានបទនេះ ក្រុមការងារមានគោលបំណងកំណត់នូវទិដ្ឋភាពនៃគោលនយោបាយពាណិជ្ជកម្ម និងបទបញ្ញត្តិ នៅក្នុងច្បាប់ WTO ដែលមានផលប៉ះពាល់ទៅលើការប្រកួតប្រជែង ។ គណៈប្រតិភូខ្លះ បានលើកឡើងនៅក្នុងបរិបទនេះនូវភាពខុសគ្នានៃវិធីសាស្រ្តសំរាប់ដោះស្រាយបញ្ហាកំណត់ថ្លៃកេងប្រវ័ញ្ច នៅក្នុងក្របខ័ណ្ឌច្បាប់ប្រកួតប្រជែង និងការប្រឆាំងនឹងការលក់បង្ខូចថ្លៃ។ "ការកំណត់ថ្លៃកេងប្រវ័ញ្ច" អាចមាននិយមន័យជាការអនុវត្តន៍របស់សហគ្រាស សំដៅដណ្តើមទីផ្សារផ្តាច់មុខ តាមរយៈការបណ្តេញចេញនូវអ្នកប្រកួតប្រជែងពីអាជីវកម្ម ដោយវិធីលក់ក្នុងតំលៃក្រោមចំណាយផលិតកម្ម ដែលនៅទីបំផុត ពួកគេអាចនឹងបង្កើនថ្លៃនោះអោយខ្ពស់ជាងកំរិតជំនាញវិញ ។ នៅក្នុងច្បាប់ប្រកួតប្រជែង ការតវ៉ាអំពីឥរិយាបទ ប្រឆាំងនឹងការប្រកួតប្រជែងអាចនឹងធ្វើឡើងបានតែនៅទីណាដែលបំណងកេងប្រវ័ញ្ច នៃផលិតផលផ្តាច់មុខកើតមានឡើងប៉ុណ្ណោះ ។ ចំណែកតាមច្បាប់ ប្រឆាំងនឹងការបង្ខូចថ្លៃវិញ ពន្ធប្រឆាំងនឹងការបង្ខូចថ្លៃ អាចនឹងត្រូវបានទារយកនៅលើផលិតផលនាំចូល ដែលជាប់ចោទ ថាបានលក់ បង្ខូចថ្លៃ ដោយពុំចាំបាច់ទាមទារអោយឧស្សាហកម្មដែលតវ៉ានោះ បង្ហាញនូវបំណងកេងប្រវ័ញ្ចនៃសហគ្រាសនាំចេញនោះឡើយ ។ ប៉ុន្តែគណៈប្រតិភូខ្លះទៀតមានអារម្មណ៍ថា គោលដៅនៃច្បាប់ស្តីពីការប្រឆាំងនឹងការបង្ខូចថ្លៃ និងការប្រកួតប្រជែង គឺមានលក្ខណៈ ខុសគ្នាទាំងស្រុង ហើយវានឹងនាំអោយគេយល់ខុសក្នុងការប្រៀបធៀបច្បាប់នោះ ឬ ក៏ចាត់ទុកថា ការប្រឆាំងនឹងការលក់បង្ខូចថ្លៃ អាចនឹងទទួលផលប្រយោជន៍ពីការបញ្ចូលនូវគោលការណ៍នយោបាយប្រកួតប្រជែងរួមជាមួយផង ។

កិច្ចព្រមព្រៀងទ្វេភាគី តំបន់ និងអន្តរជាតិ ដែលពាក់ព័ន្ធនឹងបញ្ហាគោលនយោបាយប្រកួតប្រជែង

ជាមួយនឹងការធ្វើឯកជនភាវូបនីយកម្ម និងលំហូរវិនិយោគទូទាំងពិភពលោក ករណីជាច្រើនដែលបានលើកឡើងនៅក្រោមច្បាប់ប្រកួតប្រជែង គឺមានពាក់ព័ន្ធនឹងការស្រាវជ្រាវអង្កេតទៅលើសកម្មភាពប្រឆាំងនឹងការប្រកួតប្រជែងនៅក្នុងប្រទេសផ្សេងៗ ។ ទង្វើនេះនាំអោយកើតមាននូវការអភិវឌ្ឍន៍កិច្ចព្រមព្រៀងសហប្រតិបត្តិការទ្វេភាគី តំបន់ និងអន្តរជាតិ ដែលមានគោលដៅជំរុញសហប្រតិបត្តិការ និងធ្វើអោយស៊ីសង្វាក់គ្នានូវវិធីសាស្រ្តអនុវត្តច្បាប់ប្រកួតប្រជែង ។ កិច្ចព្រមព្រៀងតាមតំបន់មួយចំនួន មានចែងនូវបទបញ្ញត្តិ ស្តីពីកិច្ចព្រមព្រៀងសហប្រតិបត្តិការសំរាប់អនុវត្តច្បាប់ ប្រកួតប្រជែង (សូមអានវណ្ឌ ៥៨ សំរាប់ខ្លឹមសារលំអិត)។

> ខណ្ឌ ៥៨
>
> ***កិច្ចព្រមព្រៀងតំបន់ : បទបញ្ញត្តិស្តីពីសហប្រតិបត្តិការអនុវត្តន៍ចំពោះករណីប្រឆាំងនឹងការលក់បង្ខូចថ្លៃ*** *សហប្រតិបត្តិការក្នុងការអនុវត្តន៍ច្បាប់ប្រកួតប្រជែង*
>
> *កិច្ចព្រមព្រៀងអំពីតំបន់សេដ្ឋកិច្ចអឺរ៉ុប (EEA) បានបង្កើតនូវវិធានប្រកួតប្រជែងសំរាប់អនុវត្តនៅក្នុង EEA ដែលស្របទៅតាមមាត្រាទី ៨៥ (ការហាមឃាត់ជាទូទៅចំពោះសកម្មភាពប្រឆាំងនឹងការប្រកួតប្រជែង) មាត្រា ៨៦ (ការប្រើប្រាស់ខុសនូវជំហរលេចលើសគេ) និងមាត្រា ៩០ (ការអនុវត្តន៍ជាសាធារណៈ)នៃសិទ្ធិសញ្ញារបស់ EC ព្រមទាំងស្របទៅតាមនិតិបញ្ញត្តិ បន្ទាប់បន្សំសំខាន់ៗខ្លះទៀត ។ របបសំរាប់ត្រួតពិនិត្យការរួមបញ្ចូលក្រុមហ៊ុននៅក្នុងសិទ្ធិសញ្ញា*

នេះក៏ត្រូវបានយកមកអនុវត្តក្នុងកិច្ចព្រមព្រៀងនៃ EEA ដែរ ។

បណ្តារដ្ឋនៃ EFTA ដែលជាភាគីសន្យានៃកិច្ចព្រមព្រៀង EEA បានបង្កើតនូវប្រព័ន្ធស្ថាប័នដាច់ដោយឡែកមួយ សំរាប់គ្រប់គ្រងនូវបទបញ្ញត្តិទាំងនេះ ។ កិច្ចព្រមព្រៀង EEA ក៏មានចែងនូវបទបញ្ញត្តិ ស្តីពីការទទួលខុសត្រូវចំពោះករណីនានារវាងអាជ្ញាធរ EFTA និងគណៈកម្មការ EC នៅក្នុងផ្នែកប្រកួតប្រជែងដែរ ។

កិច្ចព្រមព្រៀងសហប្រតិបត្តិការជាច្រើនទៀត ត្រូវបានបង្កើតឡើង រវាងភ្នាក់ងារទទួលបន្ទុកផ្នែកប្រកួតប្រជែងនៃបណ្តាប្រទេសដែលបង្កើត MERCOSUR ដែលបានបង្កើតនីតិវិធីសំរាប់ពិភាក្សាទៅវិញទៅមក និងជំនួយបច្ចេកទេសទៅវិញទៅមកផងដែរ ។ គេបានប្រឹងប្រែងបង្កើតឡើងនូវទំនាក់ទំនងជិតស្និទ្ធ ជាពិសេស រវាងភ្នាក់ងារទទួលបន្ទុកផ្នែកប្រកួតប្រជែងរបស់ប្រទេសអាហ្សង់ទីន និងប្រេស៊ីល ។ ទង្វើនេះនាំអោយមានផលប៉ះពាល់ជាវិជ្ជមាន ចំពោះការធ្វើអោយឯកភាពគ្នានូវស្តង់ដារ ប្រើដោយភ្នាក់ងារទាំងពីរ ។

នៅក្នុង NAFTA ក្រុមការងារផ្នែកប្រកួតប្រជែង បានទទួលភារកិច្ចសិក្សាអំពីទំនាក់ទំនង រវាងគោលនយោបាយប្រកួតប្រជែង និងពាណិជ្ជកម្មនៅក្នុងបរិបទតំបន់ពាណិជ្ជកម្មសេរីបង្កើតឡើងដោយ NAFTA ។ មកទល់បច្ចុប្បន្ន បញ្ហាដែលក្រុមការងារបានសិក្សានៅលើមូលដ្ឋាននៃការប្រៀបធៀប រួមមានការដាក់កំហិតតាមរយៈខ្សែបណ្តោយកាតែលនាំចេញ ការត្រួតពិនិត្យលើការរួមបញ្ចូលគ្នានូវក្រុមហ៊ុន ការប្រើប្រាស់ខុសនូវភាពលេចលើសគេ ប្រព្រឹត្តកម្មជាតិ និងសិទ្ធិឯកជនក្នុងការធ្វើសកម្មភាព ។ ថ្មីៗនេះ ក្រុមការងារបានបង្វែរទៅធ្វើការសិក្សាលើករណីប្រកួតប្រជែងដែលមានវិសាលភាពឆ្លងព្រំប្រទល់ឧទាហរណ៍សកម្មភាពផ្តាច់មុខដែលរាំងនូវការបើកច្រកទីផ្សារ ។

ការអនុវត្តប្រឆាំងនឹងការលក់បង្ខូចថ្លៃ

វិធានប្រកួតប្រជែងនៅក្នុងកិច្ចព្រមព្រៀងទំនាក់ទំនងសេដ្ឋកិច្ចដ៏ជិតស្និទ្ធ រវាងអូស្ត្រាលី និងណូវែលហ្សេឡង់ ជាដើមបានគិតគូរទៅដល់ការមិនអនុវត្តនូវវិធានការប្រឆាំងនឹងការលក់បង្ខូចថ្លៃ ចំពោះពាណិជ្ជកម្មទ្វេភាគីរបស់គេ ។ ការតវ៉ាទាំងអស់ពាក់ព័ន្ធនឹងការលក់តាមថ្លៃទាបជាងចំណាយផលិតកម្ម ត្រូវបានដោះស្រាយតាមច្បាប់ប្រកួតប្រជែងនៃប្រទេសទាំងពីរ ។

នៅក្នុងករណី MERCOSUR វិញ អនុស្សរណៈសំរាប់ប្រឆាំងនឹងការប្រកួតប្រជែង បានអំពាវនាវអោយប្រទេសជាសមាជិកធ្វើការពិភាក្សាចាប់តាំងពីដើមឆ្នាំ ២០០០ ទៅ អំពីបញ្ហាថា តើគេគួរដោះស្រាយការតវ៉ាប្រឆាំងនឹងការលក់បង្ខូចថ្លៃ ចំពោះការនាំចូលពីប្រទេសជាសមាជិកដោយរបៀបណា ។

ក្នុងចំណោមកិច្ចព្រមព្រៀងសហប្រតិបត្តិការសំខាន់ៗ នៅកំរិតអន្តរជាតិមាន ÷

- ☐ សំណុំគោលការណ៍និងវិធានស្មើភាព ដែលយល់ព្រមជាពហុភាគីរបស់ UNCTAD សំរាប់ធ្វើការត្រួតពិនិត្យសកម្មភាពពាណិជ្ជកម្មដាក់កំហិតដែលអនុម័តនៅឆ្នាំ ១៨៩០ និង
- ☐ អនុសាសន៍របស់ OECD ពាក់ព័ន្ធនឹងសហប្រតិបត្តិការរវាងប្រទេសជាសមាជិកស្តីពីសកម្មភាពប្រឆាំងនឹងការប្រកួតប្រជែងដែលមានផលប៉ះពាល់ដល់ពាណិជ្ជកម្មអន្តរជាតិ និងបានកែលំអឡើងនៅឆ្នាំ ១៩៩៥ ។

កិច្ចព្រមព្រៀងទាំងអស់នេះ គ្រាន់តែជាអនុសាសន៍ប៉ុណ្ណោះ ហើយក៏មិនចងភ្ជាប់ជាផ្លូវច្បាប់ដែរ ។ ក្នុងករណី UNCTAD ការអនុវត្តន៍នូវសំណុំខាងលើ ត្រូវបានជំរុញតាមរយៈកិច្ចប្រជុំប្រចាំឆ្នាំជាអចិន្ត្រៃយ៍ នៃក្រុមជំនាញការព្រមទាំងសកម្មភាពដែលពាក់ព័ន្ធផ្សេងៗរបស់លេខាធិការដ្ឋាន ។ ចំណែកអនុសាសន៍របស់ OECD វិញ បានលើកទឹកចិត្តបណ្តាប្រទេសអោយបង្កើតកិច្ចព្រមព្រៀង រវាងអាជ្ញាធរផ្នែកប្រកួតប្រជែងនៃប្រទេសនានា ។ មធ្យោបាយបង្កើតឡើង ដោយប្រទេសជាសមាជិកសំរាប់ជំរុញសហប្រតិបត្តិការរួមមាន ÷

- ☐ ការផ្តល់នូវដំណឹងជាមុនអំពីពេលវេលាអនុវត្តនិង កម្មវិធីសំរាប់ធ្វើសេចក្តីសំរេចចិត្ត លើករណីប្រឆាំងនឹងការប្រកួតប្រជែង
- ☐ ការដោះដូរនូវពត៌មានជាហេតុការណ៍ជាក់ស្តែង និងការវិភាគ ដែលអាស្រ័យទៅនឹងច្បាប់ប្រទេសជាតិ ស្តីពីការគ្រប់គ្រងពត៌មានសម្ងាត់ និង
- ☐ ការពិភាក្សា ឬ ចរចាដោយមានការសំរបសំរួលគ្នា ស្តីអំពីដំណោះស្រាយនៅក្នុងស្ថានភាពដែលផលប្រយោជន៍របស់ប្រទេសលើសពីមួយអាចរងនូវផលប៉ះពាល់ ។

បញ្ហាពាក់ពន្ធ័និងការអភិវឌ្ឍន៍កិច្ចសហប្រតិបត្តិការកំរិតអន្តរជាតិ រវាងអាជ្ញាធរផ្នែកប្រកួតប្រជែង ផ្អែកលើមូលដ្ឋានទូទៅនេះ ក្រុមការងារបានពិចារណាអំពីផលប្រយោជន៍ទាំងឡាយជាសក្តានុពល និងអំពីអ្វីដែលអាចប្រឆាំង នឹងការពង្រឹងសហប្រតិបត្តិការអន្តរជាតិ លើគោលនយោបាយ និងច្បាប់ប្រកួតប្រជែង ដើម្បីប្រយុទ្ធតទល់នឹងឥទ្ធិពលនៃសកម្មភាពប្រឆាំងនឹងការប្រកួតប្រជែងរបស់សហគ្រាស និងក្រុមសម្ព័ន្ធទៅលើពាណិជ្ជកម្មអន្តរជាតិ ។

គេបានទទួលស្គាល់ថា សហប្រតិបត្តិការបានកើតមានរួចស្រេចនៅលើកំរិតផ្សេងៗមួយចំនួន និងក៏ជាកត្តាយ៉ាងសំខាន់សំរាប់ធ្វើការកាត់ក្តីលើកិច្ចព្រមព្រៀងមួយចំនួន ដែលបានពិភាក្សានៅក្នុងក្រុមការងារ ។ លើសពីនេះទៅទៀត ដើម្បីអោយមានតំលៃពិតៗ កិច្ចសហប្រតិបត្តិការ ត្រូវតែអភិវឌ្ឍន៍ទៅទៀត ក្នុងពេលជាបន្ត ហើយត្រូវតែបង្កើតឡើង ដោយផ្អែកលើផលប្រយោជន៍ទៅវិញទៅមក ទំនុកចិត្ត និងគោលដៅរួម ។ ទោះជាដូច្នេះក្តី ក៏មានមតិលើកឡើងថា ចាំបាច់ត្រូវមានការពង្រីកនូវវិធីសាស្ត្រសហប្រតិបត្តិការ រួមទាំងលទ្ធភាពធ្វើឡើងលើកំរិតពហុភាគីផងដែរ ។ ជាពិសេស គេបាននិយាយថា ចាំបាច់ត្រូវតែធ្វើការដោះស្រាយបញ្ហាកង្វះខាត ឬ គម្លាតក្នុងដំណោះស្រាយរបស់សហគមន៍អន្តរជាតិ ចំពោះប្រភេទទាំងបី នៃសកម្មភាពប្រឆាំងនិងការប្រកួតប្រជែងរបស់សហគ្រាស និងក្រុមសម្ព័ន្ធដែលបានពិភាក្សានៅក្នុងក្រុមការងារពោលគឺ ÷

- ☐ សកម្មភាពមានផលប៉ះពាល់ទៅលើការបើកច្រកចូលទីផ្សារសំរាប់ការនាំចូល
- ☐ សកម្មភាពមានផលប៉ះពាល់ទៅលើការបើកច្រកចូលទីផ្សារអន្តរជាតិ នៅទីណាដែលប្រទេសផ្សេងៗគ្នារងនូវផលប៉ះពាល់ប្រហាក់ប្រហែលគ្នាព្រមទាំង
- ☐ សកម្មភាពដែលមានផលប៉ះពាល់ខុសៗគ្នាទៅលើទីផ្សារក្នុងប្រទេសរបស់ប្រទេសផ្សេងៗ ។

ចំពោះប្រភេទទីមួយ គម្លាតអាចនឹងកើតមានឡើងដោយមូលហេតុដូចតទៅ: អវត្តមាននៃច្បាប់ ការលើកលែងដោយច្បាប់ ឬរបបទបញ្ញត្តិការពារដែលគ្របដណ្តប់លើសកម្មភាពដែលមានបញ្ហា ឬ ករណីពុំអនុវត្តន៍បានល្អនូវច្បាប់ដែលត្រូវអនុវត្ត ។

ចំពោះប្រភេទបញ្ហាទីពីរ គឺថាតើគេត្រូវពង្រឹងសហប្រតិបត្តិការរកដំណោះស្រាយសមស្របចំពោះសកម្មភាពបែបនោះ ដោយរបៀបណា ក្នុងខណៈដែលគេត្រូវកាត់បន្ថយអោយដល់កំរិតអប្បរមា នូវវិវាទនានានៃអំណាចច្បាប់ផងនោះ ។ ចំពោះប្រភេទទីបីសំនួរចោទសួរ គឺ តើគេត្រូវការនូវកិច្ចព្រមព្រៀងសហប្រតិបត្តិការអន្តរជាតិថ្មីៗទៀតឬទេ ដើម្បីជួយដោះស្រាយសកម្មភាពទាំងនោះអោយបានប្រសើរឡើង ។

ក្រៅពីនេះត្រូវធ្វើសំណើដូចខាងក្រោម ចំពោះសកម្មភាពប្រឆាំងនឹងការប្រកួតប្រជែងសំខាន់ៗ ដោយផ្អែកលើកំរិតនៃមតិឯកភាពដែលហាក់ដូចជាមានរួចស្រេចចំពោះសកម្មភាពនីមួយៗ និងលើសារសំខាន់យ៉ាងច្បាស់របស់សំណើរនោះចំពោះពាណិជ្ជកម្មអន្តរជាតិ ។

ទីមួយ ចំពោះការតែលដែលមានលក្ខណៈរឹងមាំខ្លាំង គេនិយាយថានៅទីណាដែលមានមតិឯកភាពជាអន្តរជាតិយ៉ាងខ្លាំង នៅទីនោះក៏មានទស្សនវិស័យល្អសំរាប់ធ្វើការប្រឹងប្រែងអនុវត្តរួមគ្នានៅក្នុងផ្នែកនេះដែរ ។

ទីពីរ ចំពោះកាតែលនាំចេញ ការពិតគេត្រូវមានការពិចារណាអំពីមធ្យោបាយសំរាប់ពង្រឹងការអនុវត្តន៍ច្បាប់ ប្រកួតប្រជែងនៅក្នុងផ្នែកនេះ ។

ទីបីចំពោះកិច្ចព្រមព្រៀងខ្សែរយៈទទឹង គេបានទទួលស្គាល់ជាទូទៅថា ការថ្លឹងថ្លែងរវាងឥទ្ធិពលនៃការគាំទ្រ និងការប្រឆាំងនឹងការប្រកួតប្រជែង គឺជាទង្វើសមស្របនៅក្នុងផ្នែកនេះ ។ គឺជាការមួយមានប្រយោជន៍ ប្រសិនបើក្រុមការងារ អាចកំណត់ធ្វើជាតារាងបង្ហាញមួយ អំពីកត្តាទាំងឡាយដែលអាជ្ញាធរអនុវត្ត អាចគិតគូរពិចារណានៅពេលធ្វើការថ្លឹងថ្លែងចាំបាច់ ចំពោះករណីពិសេសៗនោះ។

ទីបួន នៅក្នុងផ្នែកប្រើប្រាស់ខុសនូវជំហរលេចលើសគេ ក្រុមការងារអាចនឹងធ្វើជាតារាងមួយ បង្ហាញពីសកម្មភាពប្រើប្រាស់ខុសទាំងនោះដែលអាចមានឥទ្ធិពលដល់ការរុញច្រានចេញពីទីផ្សារ ព្រមទាំងរៀបចំសំណុំនៃលក្ខណៈវិនិច្ឆ័យមួយ ដើម្បីប្រើសំរាប់កំណត់នូវជំហរលេចលើសគេនៅក្នុងទីផ្សារ ។

ទីប្រាំ ចំពោះការរួមបញ្ចូលគ្នានៃក្រុមហ៊ុន ក្រុមការងារអាចពិនិត្យលើវិសាលភាពនៃភាពដូចគ្នា នៅក្នុងល័ក្ខខ័ណ្ឌនីតិវិធីព្រមទាំងលើលទ្ធភាពអាចធ្វើបាននូវការពង្រឹងសហប្រតិបត្តិការអន្តរភ្នាក់ងារសំដៅដោះស្រាយ សេចក្តីបារម្ភលើបញ្ហាអំណាចច្បាប់ខុសៗគ្នាដោយអស់ចំណាយតិចជាអប្បរមា ។

ក៏ប៉ុន្តែ ក៏មានមតិផ្ទុយគ្នាដែរ នៅក្នុងក្រុមការងារ ចំពោះបំណងចង់បាន និងលទ្ធភាពអនុវត្តបាននៃសំណើរទាំងនោះ ។ ជាការឆ្លើយតបចំពោះសំណើរដែលបានលើកឡើង អំពីប្រភេទសកម្មភាពសំខាន់ៗទាំងបី ដែលបានពិភាក្សាមកនោះ មតិមួយចំនួនទៀតបានលើកឡើងដូចតទៅ ÷

ចំពោះប្រភេទសកម្មភាពទីមួយ នៅក្នុងករណីភាគច្រើន ច្បាប់ក្នុងស្រុកស្តីពីការប្រកួតប្រជែង គួរតែមានលក្ខណៈសមស្របសំរាប់ដោះស្រាយហើយ ។ ពោលគឺប្រទេសទាំងអស់គួរតែមាន និងអនុវត្តនូវច្បាប់ប្រកួតប្រជែង មួយដ៏មានលក្ខណៈត្រឹមត្រូវ។ ចំពោះប្រភេទសកម្មភាពទីពីរ គឺជាការច្បាស់លាស់ ហើយថា កិច្ចសហប្រតិបត្តិការ អន្តរភ្នាក់ងារអាចមានប្រយោជន៍ ក្នុងការដោះស្រាយសកម្មភាពដូចជា កាតែលអន្តរជាតិជាដើម ។ នៅក្នុងតំណាក់កាលសមស្របមួយ គឺជាការមួយមានប្រយោជន៍ ប្រសិនបើភ្នាក់ងារទាំងឡាយ អាចធ្វើសហប្រតិបត្តិការស៊ីជំរៅថែមទៀត រហូតដល់មានការដោះដូរនូវពត៌មានសម្ងាត់ រវាងភ្នាក់ងារទៅវិញទៅមក ។ ក៏ប៉ុន្តែដំណើរការកសាងទំនុកចិត្តទៅវិញទៅមក និងក្នុងករណីខ្លះ ការកសាងស្ថាប័នា គឺជាការចាំបាច់ ប្រសិនបើចង់អោយសំរេចនូវអ្វីដូចដែលបានលើកឡើងនោះ ។ ចំពោះប្រភេទទីបីវិញ អ្វីដែលសមរម្យអាចនឹងសង្ឃឹមបាន គឺបណ្តាប្រទេសដែលមានផលប្រយោជន៍ដូចគ្នា នៅក្នុងករណីពិសេសខ្លះ គួរតែពិភាក្សាគ្នាទៅវិញទៅមក ។ ដោយមានមូលហេតុជាច្រើន រួមទាំងការមាននូវឥទ្ធិពលផ្សេងគ្នា នៅក្នុងទីផ្សារជាតិនីមួយៗ ក៏ដូចជាស្តង់ដារច្បាប់ខុសគ្នាៗជាដើម គឺជាការចាំបាច់មិនអាចចៀសវាងបាន ដែលមានម្តងម្កាល សមត្ថកិច្ចច្បាប់ផ្សេងៗគ្នា អាចទាញសេចក្តីសន្និដ្ឋានខុសៗគ្នា ទៅលើភាពទទួលនូវយកបាននូវកិច្ចព្រមព្រៀង និងប្រតិបត្តិការពិសេសនានា ។

ចំណុចយកចិត្តទុកដាក់នៅលើការងារអនាគតរបស់ក្រុមការងារ

មានការរំពឹងថា ក្រុមការងារនឹងបន្តការពិភាក្សាលើបញ្ហានេះ និងបញ្ហាផ្សេងទៀត ដែលបានលើកឡើងដោយប្រទេសជាសមាជិកក្នុងអំឡុងពេលពិភាក្សាដែលគេគ្រោងធ្វើឡើងនៅឆ្នាំ ១៩៩៩ ។ ដើម្បីធ្វើការងារនោះ អគ្គទីស្នាក់ការបានស្នើសុំអោយផ្តោតលើចំណុចដូចតទៅ ÷

- ☐ វិធីសាស្ត្រសំរាប់ជំរុញសហប្រតិបត្តិការ ស្តីពីសកម្មភាពប្រឆាំងនឹងការប្រកួតប្រជែង រវាងប្រទេសជាសមាជិក រួមទាំងនៅក្នុងផ្នែកសហប្រតិបត្តិការសេដ្ឋកិច្ច ។
- ☐ ចំណុចសំខាន់ៗនៃគោលការមូលដ្ឋានរបស់ WTO ស្តីពីប្រព្រឹត្តកម្មជាតិ តម្លាភាព និងការអនុវត្តន៍នូវករណីអនុគ្រោះជាពិសេសចំពោះគោលនយោបាយប្រកួតប្រជែង និងការអនុវត្តន៍ក្នុងទិសដៅ បញ្ច្រាស់ទៅវិញព្រមទាំង
- ☐ ការរួមចំណែកនៃគោលនយោបាយប្រកួតប្រជែង សំដៅសំរេចបាននូវគោលដៅWTO រួមមានការជំរុញនូវពាណិជ្ជកម្មអន្តរជាតិ ។

ឯកសារយោង

UNCTAD របាយការណ៍ស្តីពីការវិនិយោគពិភពលោក ឆ្នាំ ១៩៩៨ ទិន្នាការ និងការកំណត់ (ការបោះពុម្ពផ្សាយរបស់អង្គការសហប្រជាជាតិ)

របាយការណ៍ប្រចាំឆ្នាំ របស់អង្គការពាណិជ្ជកម្មពិភពលោក ឆ្នាំ ១៩៩៧ ច្បាប់ចេញផ្សាយលេខ ១ ស្តីពីប្រធានបទពិសេស : ពាណិជ្ជកម្ម និងគោលនយោបាយប្រកួតប្រជែង ។

របាយការណ៍ប្រចាំឆ្នាំ របស់អង្គការពាណិជ្ជកម្មពិភពលោក ឆ្នាំ ១៩៩៨ ។

របាយការណ៍ប្រចាំឆ្នាំ របស់អង្គការពាណិជ្ជកម្មពិភពលោក ឆ្នាំ ១៩៩៨ របស់ក្រុមការងារស្តីពីអន្តរកម្មរវាងពាណិជ្ជកម្ម និងគោលនយោបាយប្រកួតប្រជែងជូនចំពោះអគ្គក្រុមប្រឹក្សា ។

ជំពូក ២៨

តម្លាភាពនៅក្នុងលទ្ធកម្មសាធារណៈរបស់រដ្ឋាភិបាល

ដូចបានធ្វើការកត់សំគាល់នៅក្នុងជំពូក១៨ កិច្ចព្រមព្រៀងអំពីលទ្ធកម្មសាធារណៈរបស់រដ្ឋាភិបាល ដែលបានចរចានៅក្នុងកិច្ចប្រជុំកុម្មូលនៅយូរ៉ូយហ្គាយ គឺជាកិច្ចព្រមព្រៀងពហុភាគី ។ និយាយម្យ៉ាងទៀតគឺខុសពីកិច្ចព្រមព្រៀងសហព័ន្ធឯទៀតៗ ដែលចងភ្ជាប់កាតព្វកិច្ចចំពោះសមាជិក WTO ទាំងអស់ កិច្ចព្រមព្រៀងនោះចងភ្ជាប់តែប្រទេសណាដែលបានចូលជាសមាជិកតែប៉ុណ្ណោះ ។

ក្នុងខណៈដែលបណ្តាប្រទេសជឿនលឿនភាគច្រើនសុទ្ធតែជាសមាជិក ក៏មានប្រទេស/តំបន់កំពុងអភិវឌ្ឍន៍ចំនួនបី ដែលមានកំរិតជឿនលឿនខ្ពស់ជាងគេ បានចូលរួមជាសមាជិកដែរ ។ ប្រទេសទាំងនោះគឺ ប្រទេសហុងកុង (ចិន) សាធារណៈរដ្ឋកូរ៉េ និងសឹង្ហបុរី។ ដូច្នេះប្រទេសកំពុងអភិវឌ្ឍន៍ និងប្រទេសដែលមានសេដ្ឋកិច្ចអន្តរកាលជាច្រើន ពុំត្រូវបានចងភ្ជាប់ដោយកាតព្វកិច្ចជាខ្លឹមសារ និងនីតិវិធីដាក់ចុះដោយកិច្ចព្រមព្រៀងទេ ប៉ុន្តែគឺចងភ្ជាប់ដោយ GATT ឆ្នាំ ១៩៩៤ ទៅវិញ ។

GATT ពុំបានគិតបញ្ចូលនូវ " លទ្ធកម្មសាធារណៈរបស់រដ្ឋាភិបាល ចំពោះទំនិញសំរាប់ការប្រើប្រាស់ផ្ទាល់ និងពុំសំរាប់ការលក់ដូរ " ក្នុងការអនុវត្តនីតិវិធាន MFN និងប្រព្រឹត្តិកម្មជាតិឡើយ ។ ប៉ុន្តែវាបានចែងថា ក្នុងខណៈដែលបណ្តាប្រទេសពុំត្រូវបានរំពឹងថានឹងគោរពទាំងស្រុងនូវគោលការណ៍ MFN ប៉ុន្តែគេគួរតែផ្តល់ដល់អ្នកផ្គត់ផ្គង់ពីប្រទេសផ្សេងៗនូវ " ការអនុវត្តមួយដែលសមស្រប និងយុត្តិធម៌ " នៅពេលធ្វើការទិញអ្វីពីប្រទេសទាំងនោះ ។

ដើម្បីបញ្ចូលការអនុវត្តន៍របស់ប្រទេសទាំងអស់ទៅក្រោមវិធានអន្តរជាតិមួយ សន្និសីទថ្នាក់រដ្ឋមន្ត្រីនៅ សឹង្ហបុរី បានសំរេចជាលទ្ធផលនៃគំនិតផ្តួចផ្តើមដោយសហរដ្ឋអាមេរិក និងសមាគមន៍អឺរ៉ុប ក្នុងការបង្កើត WTO នូវក្រុមការងារមួយស្តីអំពីតម្លាភាពនៅក្នុងលទ្ធកម្មសាធារណៈរបស់រដ្ឋាភិបាល " ដើម្បីសិក្សាអំពីតម្លាភាពនៅក្នុងសកម្មភាពលទ្ធកម្មសាធារណៈ ... អភិវឌ្ឍន៍សមាសធាតុផ្សេងៗ សំរាប់បញ្ចូលទៅក្នុងកិច្ចព្រមព្រៀងសមស្របណាមួយ " ។ សមាជិកភាពនៃកិច្ចព្រមព្រៀងបែបនោះ គឺជាកាតព្វកិច្ចចំពោះគ្រប់សមាជិក WTO ទាំងអស់ ។ ប៉ុន្តែភ្នាក់ងារជាអ្នកទិញ ពុំត្រូវបានទាមទារអោយទទួលយក កាតព្វកិច្ចជាខ្លឹមសារអោយផ្តល់ MFN និងប្រព្រឹត្តកម្មជាតិ ដែលកំណត់ដោយកិច្ចព្រមព្រៀង ស្តីពីលទ្ធកម្មសាធារណៈរបស់រដ្ឋាភិបាលឡើយ ។ ផ្អែកលើមតិនៃអ្នកគាំទ្រសំណើនោះ ឧត្តមភាពចំបងនៃកិច្ចព្រមព្រៀងបែបនេះ គឺការធ្វើអោយប្រសើរឡើងនូវតម្លាភាពនៅក្នុងលទ្ធកម្មសាធារណៈរបស់រដ្ឋាភិបាល ។

ជំពូកនេះត្រូវបានបែងចែកជាពីរផ្នែក ។ ផ្នែកទីមួយ ផ្តល់នូវការពិពណ៌នាត្រួសៗអំពីបទប្បញ្ញត្តិសំខាន់ៗ នៃកិច្ចព្រមព្រៀងស្តីពីលទ្ធកម្មសាធារណៈរបស់រដ្ឋាភិបាល និងបកស្រាយនូវមូលហេតុនៃការរុញរារបស់ប្រទេសកំពុងអភិវឌ្ឍន៍ ក្នុងការចូលរួមជាសមាជិកនៃកិច្ចព្រមព្រៀងនោះ ។ ផ្នែកទីពីរ ផ្តោតទៅលើការពិភាក្សា ដែលធ្វើឡើងនៅក្នុងក្រុមការងារក្នុងចន្លោះឆ្នាំ ១៩៩៧-១៩៩៨។

កិច្ចព្រមព្រៀងស្តីពីលទ្ធកម្មសាធារណៈរបស់រដ្ឋាភិបាល

វិសាលភាព និងកាតព្វកិច្ច

កិច្ចព្រមព្រៀងនេះ អនុវត្តចំពោះពាណិជ្ជកម្មលើទំនិញ និងលើសេវាកម្ម ។ ប៉ុន្តែវិសាលភាពរបស់វាបានកំណត់តែចំពោះលទ្ធកម្មទំនិញ និងសេវាកម្មតែប៉ុណ្ណោះ ហើយចំពោះអង្គភាពផ្គង់ផ្គង់ ប្រទេសជាសមាជិកនីមួយៗ បានកំណត់នៅក្នុងកម្មវិធីនៃឧបសម្ព័ន្ធនៅក្នុងបរិសិទ្ធ ១ នៃកិច្ចព្រមព្រៀង ។ ឧបសម្ព័ន្ធ គឺជាផ្នែកផ្សេងមួយនៃកិច្ចព្រមព្រៀង ។

កាតព្វកិច្ចដែលកំណត់ឡើងក្នុងកិច្ចព្រមព្រៀង អាចនឹងបែងចែកជាទូទៅជា ពីរប្រភេទ : ខ្លឹមសារ និងនីតិវិធី ។

កិច្ចព្រមព្រៀងស្តីពីលទ្ធកម្មសាធារណៈរបស់រដ្ឋាភិបាល មាត្រា១-៤

ចំពោះកាតព្វកិច្ចជាខ្លឹមសារសំខាន់ៗ មានកាតព្វកិច្ចដែលទាមទារអោយភ្នាក់ងារជាអ្នកទិញអនុវត្តនូវ MFN និងប្រព្រឹត្តកម្មជាតិ ចំពោះកិច្ចសន្យាទំនិញ និងសេវាកម្មក្នុងកំរិតខ្ពស់ជាងកំរិតដែលបានកំណត់នៅក្នុងឧបសម្ព័ន្ធពី ១ ដល់៣ នៃបរិសិទ្ធ១ នៃកិច្ចព្រមព្រៀង ។ តាមរយៈការទាមទារអោយភ្នាក់ងារជាអ្នកទិញផ្តល់នូវប្រព្រឹត្តកម្មជាតិ ចំពោះអ្នកផ្គត់ផ្គង់បរទេស កិច្ចព្រមព្រៀងនោះបានរាំងគេមិនអោយផ្តល់ដល់អ្នកផ្គត់ផ្គង់ក្នុងស្រុកនូវការអនុគ្រោះជាថ្លៃ ឬ ជាអ្វីផ្សេងទៀតឡើយ ។

កិច្ចព្រមព្រៀងស្តីពីលទ្ធកម្មសាធារណៈរបស់រដ្ឋាភិបាល មាត្រា៨-១៦

កាតព្វកិច្ចជានីតិវិធី មានគោលដៅធានាដូចតទៅ ÷

- ☐ នីតិវិធីនៃការដេញថ្លៃ (ដោយបើកចំហរ ដោយជ្រើសរើស និងដាក់កំហិត) ត្រូវតែមានលក្ខណៈចំហរ និងមានសមត្ថភាពព្រមទាំងផ្តល់លទ្ធភាពដល់អ្នកផ្គត់ផ្គង់បរទេស ដែលមានបំណងទាំងអស់អោយចូលរួមផង ។

កិច្ចព្រមព្រៀងស្តីពីលទ្ធកម្មសាធារណៈ មាត្រា១៨ និងលទ្ធកម្មសាធារណៈរបស់រដ្ឋាភិបាល មាត្រា២០

- ☐ ការមានតំលាភាព មុនពេលផ្តល់ពត៌មាន ។
- ☐ នីតិវិធីតតាំងដែលផ្តល់នូវដំណោះស្រាយក៏ត្រូវតែមានដែរ ចំពោះអ្នកផ្គត់ផ្គង់បរទេស ឬ ក្នុងស្រុក ដែលពុំមានជ័យជំនះព្រមទាំងចំពោះអ្នកផ្គត់ផ្គង់បរទេស ដែលបានចាត់ទុកថា កិច្ចសន្យាបានត្រូវផ្តល់ឲ្យអ្នកឈ្នះ ដោយល្មើសពីកិច្ចព្រមព្រៀងក្តី។

មូលហេតុដែលធ្វើអោយប្រទេសកំពុងអភិវឌ្ឍន៍មានការរុញរា ក្នុងការចូលជាសមាជិកនៃកិច្ចព្រមព្រៀង

គេកត់សំគាល់ឃើញ មានមូលហេតុបី ក្នុងចំណោមមូលហេតុជាច្រើន ដែលធ្វើអោយប្រទេសកំពុងអភិវឌ្ឍន៍មានការរុញរាក្នុងការចូលជាសមាជិកនៃកិច្ចព្រមព្រៀងនេះ ÷

ទីមួយ នៅក្នុងគំនិតគេ ការចូលជាសមាជិកភាពនៃកិច្ចព្រមព្រៀង នឹងធ្វើអោយគេទទួលបានផលចំណេញពីការនាំចេញតិចតួចប៉ុណ្ណោះ ។ ផលចំណេញមួយផ្នែកធំត្រូវបានទៅលើកម្មន្តសាលកម្ម និងឧស្សាហកម្មសេវាកម្មរបស់ប្រទេសជឿនលឿនដែលមានលទ្ធភាពទាញយកឧត្តមភាព ពីការកែលំអការបើកទីផ្សាររបស់ប្រទេសកំពុងអភិវឌ្ឍន៍ដែលស្ថិតនៅក្រោមកិច្ចព្រមព្រៀង ។

ទីពីរ ប្រទេសកំពុងអភិវឌ្ឍន៍មានលទ្ធភាពអភិវឌ្ឍន៍ពាណិជ្ជកម្មតំបន់រវាងគ្នា នឹងគ្នានៅក្នុងវិស័យលទ្ធកម្មសាធារណៈរបស់រដ្ឋាភិបាលនេះ ។ ប៉ុន្តែចំពោះការអភិវឌ្ឍន៍នូវពាណិជ្ជកម្មនេះ គេពុំចាំបាច់ចូលជាសមាជិកនៃកិច្ចព្រមព្រៀងទេ ពីព្រោះវិធានការសេរីភាវូបនីយកម្មធ្វើឡើងបាន ត្រឹមកំរិតតំបន់តែម្តង ។

ទីបី ចំពោះប្រទេសកំពុងអភិវឌ្ឍន៍ភាគច្រើន ការទទួលបានផលចំណេញប្រកបដោយប្រសិទ្ធិភាព ចំពោះភ្នាក់ងារផ្គត់ផ្គង់ អំពីការអនុវត្តន៍កិច្ចព្រមព្រៀងអាចនឹងពុំមានលក្ខណៈធំដុំដោយមូលហេតុដូចតទៅ ÷

- ☐ ការទិញទំនិញតាមរយៈការដេញថ្លៃបានធ្វើឡើងយ៉ាងទូលាយជាទូទៅ
- ☐ ក្នុងប្រទេសមានចំណូលទាប និងបណ្តាប្រទេសក្រីក្រ ដែលការចាយវាយរបស់រដ្ឋាភិបាលមួយភាគធំ ត្រូវធ្វើហិរញ្ញប្បទានដោយស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ និងប្រទេសម្ចាស់ជំនួយ ដូច្នេះការទិញត្រូវធ្វើឡើងស្របទៅ តាមការណែនាំរបស់ធនាគារពិភពលោក ដែលក្នុងទិដ្ឋភាពជាច្រើន គឺដូចគ្នាទៅនឹងបទបញ្ញត្តិនៃកិច្ចព្រមព្រៀងស្តីពីលទ្ធកម្មសាធារណៈរបស់រដ្ឋាភិបាល។ លើសពីនេះទៅទៀត កិច្ចព្រមព្រៀងពុំត្រូវបានអនុវត្តទៅ លើការផ្សារភ្ជាប់ការទិញទំនិញ ពីប្រទេសអ្នកផ្តល់ជំនួយទេ ។ ចំណែកនៃជំនួយមានចំណងនៅក្នុងជំនួយទ្វេភាគីសរុបជាទូទៅមានទំហំធំ ។

ក្រៅពីនេះ ក្នុងខណៈដែលសមាជិកភាពនៅក្នុងកិច្ចព្រមព្រៀងពុំប្រាកដជា នឹងនាំមកនូវតំលៃនាំចេញខ្ពស់ជាងមុន ឬ ផលចំណេញលើប្រសិទ្ធភាពប្រសើរជាងមុន ទន្ទឹមនឹងនោះកិច្ចព្រមព្រៀងបានកំណត់កាតព្វកិច្ចឱ្យប្រទេសកំពុងអភិវឌ្ឍន៍ លុបចោលនូវគោលនយោបាយដែលទាមទាឱ្យភ្នាក់ងារជាអ្នកទិញ ផ្តល់នូវការអនុគ្រោះលើថ្លៃចំពោះអ្នកផ្គត់ផ្គង់ក្នុងស្រុកផងដែរ ។ គោលនយោបាយបែបនេះមានគោលដៅក្នុងចំណោមគោលដៅផ្សេងៗ ជំរុញនូវការអភិវឌ្ឍន៍ឧស្សាហកម្មធុនតូច និងតំបន់ដែលពុំសូវរីកចំរើន ។

ក្រុមការងារស្តីពីតម្លាភាពនៅក្នុងលទ្ធកម្មសាធារណៈរបស់រដ្ឋាភិបាល

នៅឆ្នាំ១៩៩៧-១៩៩៨ ក្រុមការងារបានកំណត់នូវសមាសធាតុសំខាន់ ៗ ដែលអាចមានរបស់កិច្ចព្រមព្រៀងស្តីពីតម្លាភាពនៅក្នុងលទ្ធកម្មសាធារណៈរបស់រដ្ឋាភិបាល ។ ជាបន្ថែមទៅលើបទបញ្ញត្តិសំខាន់ៗ នៃកិច្ចព្រមព្រៀងស្តីពីលទ្ធកម្មសាធារណៈ ក្រុមការងារបានយកចិត្តទុកដាក់ ទៅលើ ការណែនាំរបស់ធនាគារពិភពលោក អំពីលទ្ធកម្មសាធារណៈរបស់រដ្ឋាភិបាល ច្បាប់គំរូរបស់ UNCITRAC ស្តីពីការផ្គត់ផ្គង់ នូវទំនិញ សំណង់ និងសេវាកម្មព្រមទាំងច្បាប់ជាតិនានា ។

សមាសធាតុសំខាន់ៗ ដែលអាចមានក្នុងកិច្ចព្រមព្រៀង ស្តីពីតម្លាភាពនៅក្នុងលទ្ធកម្មសាធារណៈរបស់រដ្ឋាភិបាល

នៅក្នុងផ្នែកនេះគេមានបំណងបង្ហាញនូវចំណុចសំខាន់ៗ ដែលបានកើតឡើងនៅក្នុងកិច្ចពិភាក្សារបស់ក្រុមការងារនៅឆ្នាំ១៩៩៧-១៩៩៨ ស្តីពីធាតុផ្សំសំខាន់ៗ ដែលអាចមានក្នុងកិច្ចព្រមព្រៀង ដើម្បីធានានូវតម្លាភាពមុន និងក្រោយពេលផ្តល់កិច្ចសន្យាផ្គត់ផ្គង់។

គេចាំបាច់ត្រូវតែគូសបញ្ជាក់ថា រូបភាពជារួមដែលបង្ហាញនៅក្នុងផ្នែកនេះ គឺពុំបានចូលលំអិតទៅក្នុងមតិផ្សេងៗ ជាច្រើនដែលបានលើកអំពីចំណាប់ធ្វើការបញ្ចូលនូវធាតុផ្សំណាមួយ ព្រមទាំងពីវិសាលភាពនៃខ្លឹមសាររបស់វាឡើយ ។

សមាសធាតុសំរាប់ធានានូវតម្លាភាពមុនពេលផ្តល់កិច្ចសន្យាមួយ

វិសាលភាព និងដែនកំណត់

ដែនកំណត់នៃអង្គភាព : អង្គភាពគ្រប់ជាន់ថ្នាក់របស់រដ្ឋាភិបាល រួមទាំងថ្នាក់ក្រោមមជ្ឈឹម និងសហគ្រាសជាកម្មសិទ្ធ ឬ ស្ថិតក្រោមឥទ្ធិពលរបស់រដ្ឋាភិបាល គួរត្រូវបានកំណត់ដោយកិច្ចព្រមព្រៀង ប្រកបដោយតំលាភាពមួយ ។

ដែនកំណត់នៃផលិតផល : វិសាលភាពនៃកិច្ចព្រមព្រៀងដ៏មានតម្លាភាពមួយអាចពង្រីកទៅដល់ទំនិញ និងសេវាកម្មទាំងអស់ និងចំពោះគ្រប់ការគួបផ្សំគ្នានូវទំនិញ និងសេវាផងដែរ ។

ដែនកំណត់នៃតំលៃ : ជាគោលការណ៍ ដែនកំណត់នៃកិច្ចព្រមព្រៀងដ៏មានតម្លាភាពមួយ មិនគួរគ្របដណ្តប់តែចំពោះកិច្ចសន្យានានាដែលមានកំរិតខ្ពស់ជាងកំរិតកំណត់ណាមួយនោះទេ ប៉ុន្តែមាត្រាខ្លះ គួរតែត្រូវបានអនុវត្តដោយភាពអាចបត់បែនបាន ចំពោះកិច្ចសន្យាដែលតូចៗជាង ។

ដែនកំណត់នៃប្រតិបត្តិការណ៍ : ការទិញយកតាមរយៈវិធីជាកិច្ចសន្យា រួមមានជាឧទាហរណ៍ កិច្ចព្រមព្រៀងជួល គួរតែត្រូវបានគ្របដណ្តប់ដែរ ។

វិធីធ្វើលទ្ធកម្ម

រាល់បទបញ្ញត្តិអំពីវិធីធ្វើលទ្ធកម្ម គួរតែមានលក្ខណៈអាចបត់បែនបានសមស្រប ដើម្បីសំរបទៅនឹងវិធីលទ្ធកម្មផ្សេងៗ ដែលបានប្រើក្នុងប្រទេសនិមួយៗ ហើយគួរតែអនុញ្ញាតអោយមាននូវលទ្ធភាពប្រើប្រាស់វិធី ដែលផ្អែកលើការដេញថ្លៃផងដែរ ។ វិធីដែលប្រទេសជាសមាជិកបានប្រើប្រាស់ ចំពោះកិច្ចព្រមព្រៀងស្តីពីលទ្ធកម្មរដ្ឋ ជាធម្មតា ផ្អែកលើការដេញថ្លៃសំរាប់កិច្ចសន្យា ដែលមានតំលៃខ្ពស់ (ចំហរ ដោយជ្រើសរើស មានព្រំដែន) ពួកគេក៏បានប្រើប្រាស់នូវរបៀបផ្សេងៗទៀតដែរ (ឧទាហរណ៍ : ប័ណ្ណទិញ, ព្រឹត្តបត្រស្នើបង្ហាញម៉ូតអេឡិចត្រូនិច) សំរាប់កិច្ចសន្យាតំលៃទាប ។

យោងតាមទស្សនមួយស្តីពីវិធីលទ្ធកម្មចំបង ការដេញថ្លៃជាអន្តរជាតិ ឬ បើកចំហដោយគ្មានដាក់កំហិតលើចំនួននៃអ្នកដេញថ្លៃជាយថាភាព គឺជាវិធីប្រកបដោយតម្លាភាពបំផុត ។ នីតិវិធីជ្រើសរើសគឺត្រឹមត្រូវល្អ នៅពេលណាដែលគេមិនអាចធ្វើបាន ឬក៏ជាការគ្មានប្រសិទ្ធភាព និងធ្វើការពិចារណា ឬ វាយតំលៃទៅលើចំនួនដ៏ច្រើននៃអ្នកដេញថ្លៃជាយថាភាព ក្នុងល័ក្ខខ័ណ្ឌដែលអ្នកផ្គត់ផ្គង់សំខាន់ៗ ជាយថាហេតុត្រូវបានផ្តល់អោយនូវឱកាសដូចគ្នា ក្នុងការទទួលបានព័តមានស្តីពីលទ្ធកម្ម និងស្វែងរកការអញ្ជើញមកដេញថ្លៃ ។

ទស្សនៈមួយទៀតថា គួរចាត់ទុកការដេញថ្លៃដោយជ្រើសរើស និងដោយចំហ ថាមានតម្លាភាព ស្មើគ្នា ប្រសិនបើការដេញថ្លៃដោយជ្រើសរើស ត្រូវបានធ្វើឡើងស្របតាមគោលការណ៍ដ៏សមរម្យ ។ ការដេញថ្លៃ ជាចំហមិនសុទ្ធតែជារបៀបមួយដែលមានប្រសិទ្ធភាពអស់ចំណាយទាបបំផុតនោះទេ ជាពិសេសសំរាប់លទ្ធកម្ម ដែលមានលក្ខណៈស្មុកស្មាញ ។

ចំពោះវិធីលទ្ធកម្មសំខាន់ទីបី គឺការដេញថ្លៃដោយកំណត់ (ឧទាហរណ៍ជាបុគ្គលប្រភពតែមួយគត់ ប្រភពដាច់ដោយឡែក ឬការដេញថ្លៃផ្ទាល់) ត្រូវបានអោយយោបល់ ដោយហេតុថាមិនមានការផ្សព្វផ្សាយពត៌មាន និងលក្ខន្តិកៈនៃការជ្រើសរើសជាសាធារណៈ វិធីនេះគួរត្រូវតែយកមកប្រើនៅក្នុងកាលៈទេសៈដែលពិសេស ឬ សមហេតុផលប៉ុណ្ណោះ ។ លិខិតុបករណ៍អន្តរជាតិ និងការអនុវត្តន៍ជាលក្ខណៈជាតិ បានទទួលស្គាល់នូវកាលៈទេសៈ និងល័ក្ខខ័ណ្ឌសំរាប់ឱ្យមានការប្រើប្រាស់ការដេញថ្លៃមានកំណត់ ។

សេចក្តីសំរេចលើលក្ខណៈសម្បត្តិរបស់អ្នកផ្គត់ផ្គង់

ប្រព័ន្ធនៃការកំណត់លក្ខណៈសម្បត្តិ និងការចុះបញ្ជីមានតួនាទីដ៏សំខាន់ក្នុងដំណើរការលទ្ធកម្ម កាលណាប្រព័ន្ធនោះមានតម្លាភាពពេញលេញ ។ គោលការណ៍សំខាន់នៃតម្លាភាពចំពោះបញ្ហានេះគឺថា សេចក្តីសំរេចលើការចុះបញ្ជី និងលក្ខណៈសម្បត្តិរបស់អ្នកផ្គត់ផ្គង់ ត្រូវធ្វើឡើង ដោយឈរលើមូលដ្ឋាននៃលក្ខន្តិកៈ ដែលត្រូវបានបញ្ជាក់តាំងពីដំបូងក្នុងកិច្ចដំណើរការនេះ ហើយដែលបានផ្តល់ដំណឹងគ្រប់គ្រាន់ជាមុនទៅកាន់អ្នកផ្គត់ផ្គង់ ។ ត្រូវធ្វើការផ្សព្វផ្សាយរាល់ការផ្លាស់ប្តូរល័ក្ខខ័ណ្ឌស្តីពីលក្ខណៈសម្បត្តិ អោយអ្នកផ្គត់ផ្គង់ដែលពាក់ព័ន្ធទាំងអស់បានដឹង ។

ការបោះពុម្ពផ្សាយនូវច្បាប់ និងនីតិវិធី

ការបោះពុម្ពផ្សាយនូវច្បាប់ជាតិ មិនត្រឹមតែជាផែនទីផ្លូវដ៏ច្បាស់មួយសំរាប់អ្នកផ្គត់ផ្គង់ប៉ុណ្ណោះទេ ប៉ុន្តែអាចជាវិធីត្រួតពិនិត្យមួយលើការបំពានច្បាប់ក្នុងរបបលទ្ធកម្មសាធារណៈ ។ កត្តាដែលមាននីតិវិធីច្បាស់លាស់ អាចកាត់បន្ថយចំណាយនៃវដ្តរបស់លទ្ធកម្មសាធារណៈបាន ។

ប្រកាសស្តីពីការអញ្ជើញចូលរួមដេញថ្លៃ

គួរតែមានពត៌មានគ្រប់គ្រាន់ស្តីពីប្រកាសអញ្ជើញចូលរួមដេញថ្លៃ ក្នុងកាលានុវត្តន៍ភាពលទ្ធកម្មសាធារណៈ ដើម្បីអោយអ្នកផ្គត់ផ្គង់ជាយថាហេតុ អាចវាយតំលៃផលប្រយោជន៍របស់គេក្នុងការចូលរួមនៅក្នុងនីតិវិធីលទ្ធកម្មសាធារណៈ ដែលបានស្នើរឡើង ហើយដើម្បីស្វែងរកឯកសារដេញថ្លៃ ។ ការអនុវត្តន៍ជាលក្ខណៈជាតិ អំពីពត៌មានលំអិត ដែលត្រូវដាក់បញ្ចូលក្នុងប្រកាសដេញថ្លៃដំបូង និងក្នុងឯកសារបន្ទាប់មកសំរាប់ការដេញថ្លៃ មានភាពខុសគ្នាជាច្រើន ហើយអាចនិងមិនសំខាន់អ្វីទេក្នុងការតំរូវអោយមានពត៌មានជាអប្បរមាច្បាស់លាស់អំពីមាតិកាពិសេសរបស់វា ឬក៏ដើម្បីស្វែងរកភាពសុក្រឹត្យទៅលើចំណុចនេះ ។ គឺជាការគ្រប់គ្រាន់ហើយសំរាប់កិច្ចព្រមព្រៀងដ៏មានតម្លាភាពមួយដោយគ្រាន់តែបង្កើតនូវធាតុផ្សេងៗ នៅក្នុងទំរង់នៃគោលការណ៍ជាទូទៅ ។

ពត៌មានស្តីពីកាលានុវត្តន៍ភាពដេញថ្លៃ

មានបញ្ហាពីរ ស្តីពីពត៌មានពិស្តានៃកាលានុវត្តន៍ភាពដេញថ្លៃគឺ : កន្លែងដែលអាចរកពត៌មានបាន និងខ្លឹមសារពត៌មាន។

ការផ្សព្វផ្សាយ: ចំណុចដូចខាងក្រោមនេះ ទាក់ទងនឹងកន្លែងដែលអ្នកផ្គត់ផ្គង់ជាយថាភាព អាចស្វែងរកពត៌មានបាន÷

- ☐ គួរផ្សព្វផ្សាយ និងផ្តល់ជូនភាគីដែលពាក់ព័ន្ធទាំងអស់ អំពីកាលានុវត្តន៍ភាពនៃលទ្ធកម្មសាធារណៈ និងល័ក្ខខ័ណ្ឌនីតិវិធីដែលពាក់ព័ន្ធ តាមរយៈប្រភពងាយមួយ ។
- ☐ គួរផ្សព្វផ្សាយតាមរយៈបណ្តាញផ្សព្វផ្សាយអេឡិចត្រូនិច និងសារពត៌មាន នូវពត៌មានស្តីពីកាលានុវត្តន៍ភាពនៃការដេញថ្លៃ។ បណ្តាញផ្សាយដែលបោះពុម្ពអាចជារាជកិច្ច ឬ ជាកាសែតជាតិមួយដែលចរាចរយ៉ាងទូលំទូលាយ ។
- ☐ ការផ្សព្វផ្សាយតាមប្រព័ន្ធអេឡិចត្រូនិច ត្រូវប្រើនៅទីណាដែលអាចធ្វើបាន ដោយគិតផងដែរអំពីកំរិតនៃការអភិវឌ្ឍន៍របស់បណ្តាប្រទេសជាសមាជិក WTO នីមួយៗ ។ ត្រូវផ្សព្វផ្សាយអោយដឹងពីអាស័យដ្ឋាន Internet របស់បណ្តាញផ្សព្វផ្សាយ

អេឡិចត្រូនិច ។ ដោយការផ្សព្វផ្សាយជាអេឡិចត្រូនិចមានផលប្រយោជន៍យ៉ាងសំខាន់ គិតជាពេលវេលា និងតំលៃ ដូច្នេះ ការប្រើប្រាស់ការផ្សព្វផ្សាយបែបនេះ នឹងកើនឡើងនៅឆ្នាំខាងមុខ ។

មាតិកាពត៌មាន : ដោយការអនុវត្តន៍ថ្នាក់ជាតិ មានលក្ខណៈខុសៗគ្នា ដូច្នេះពត៌មានស្តីពីកាលានុវត្តន៍ភាពលទ្ធកម្មសាធារណៈ នៅក្នុងប្រកាសអញ្ជើញដេញថ្លៃ និងប្រកាសអំពីឯកសារដេញថ្លៃ គួរមានលក្ខណៈគ្រប់គ្រាន់ ដើម្បីអនុញ្ញាតអោយអ្នកផ្គត់ផ្គង់ជាយថាភាព មានលទ្ធភាពវាយតំលៃលើផលប្រយោជន៍របស់ពួកគេក្នុងការចូលរួមក្នុងលក្ខណៈ សាធារណៈ ឬ ប្រព័ន្ធនៃលក្ខណៈសម្បត្តិ ដែលបានស្នើឡើង និងដែលបានអនុញ្ញាតអោយគេត្រៀមខ្លួនសំរាប់ការដេញថ្លៃ ឬ ធ្វើសំណើសំរាប់លក្ខណៈសម្បត្តិអោយបាន សមស្រប។ សមាជិកគួរមានលទ្ធភាពសំរេចថាតើ ពត៌មានស្តីពីកាលានុវត្តន៍ភាពលទ្ធកម្ម សាធារណៈ គួរផ្សព្វផ្សាយទាំងស្រុងដោយ ប្រើសេចក្តីប្រកាសដេញថ្លៃ ឬ ក៏ថា តើចំនួនដ៏ច្រើននៃពត៌មាន គួរដាក់បញ្ចូលទៅក្នុងទំរង់ឯកសារដេញថ្លៃទាំងអស់ ឬ គួរធ្វើអោយគេអាចរកបានដោយមធ្យោបាយផ្សេងៗទៀត ។

ពត៌មានស្តីពីភាពអនុគ្រោះចំពោះអ្នកផ្គត់ផ្គង់ក្នុងស្រុក : តម្លាភាពនៃការអនុគ្រោះ ឬ តំរូវការរើសអើងដទៃទៀត អាចអនុញ្ញាត អោយអ្នកដេញថ្លៃបរទេសជាយថាភាព ធ្វើការសំរេចបានថា តើពួកគេមានប្រយោជន៍ក្នុងការចូលរួមក្នុងដំណើរការលទ្ធកម្មសាធារណៈ ពិសេសនេះទេ ទោះបីជាមានគោលនយោបាយជាតិរើសអើងក៏ដោយ ។ អ្នកមានបំណងផ្គត់ផ្គង់អាចធ្វើការបែងចែករវាងកាលានុវត្តន៍ ភាពលទ្ធកម្មសាធារណៈ ដែលអនុវត្តចំពោះអ្នកផ្គត់ផ្គង់ក្នុងស្រុក និងកាលានុវត្តន៍ភាពដែលបើកចំហ ការប្រកួតប្រជែងជាអន្តជាតិបាន លុះត្រាតែពួកគេដឹងជាមុនពីពត៌មានស្តីពីគោលនយោបាយរើសអើងទាំងនោះ ។

ការផ្តល់ពត៌មានស្តីពីភាពអនុគ្រោះលើតំលៃ ឬល័ក្ខខ័ណ្ឌលើលក្ខណៈសម្បត្តិ ដែលអំណោយផលដល់អ្នកផ្គត់ផ្គង់ក្នុងស្រុក អាចផ្តល់ លទ្ធភាពអោយអ្នកផ្គត់ផ្គង់ ថ្លឹងថ្លែងនូវផលប្រយោជន៍របស់គេ និងវាយតំលៃលើកាលានុវត្តន៍ភាពពិតប្រាកដរបស់គេក្នុងការទទួល បានកិច្ចសន្យា ។

ភាសា: ល័ក្ខខ័ណ្ឌលើភាសាសំរាប់ការបោះពុម្ពផ្សាយប្រកាសអញ្ជើញដេញថ្លៃគួរត្រូវបានកំណត់ យកតែជាភាសាជាតិផ្លូវការ មួយ ។ ការបកប្រែជាភាសាក្នុង WTO អាចក្លាយជាបញ្ហាដ៏លំបាក ។

ការកំណត់ពេលវេលា

មានសំណូមពរមួយ ស្តីពីការកំណត់ពេលវេលាជាអប្បរមា សំរាប់អោយអ្នកផ្គត់ផ្គង់ជាយថាហេតុ បំពេញនូវល័ក្ខខ័ណ្ឌនានា នៅរាល់ដំណាក់កាលផ្សេងៗនៃកិច្ចដំណើរការលទ្ធកម្មសាធារណៈ ជាជាងការបង្កើតនូវរយៈពេលអប្បរមាមួយ ចំពោះកិច្ច ព្រមព្រៀងដ៏មានតម្លាភាព ហើយបណ្តាប្រទេសនេះ អាចព្រមព្រៀងគ្នាលើគោលការណ៍ជាទូទៅមួយ ដូចក្នុងច្បាប់គំរូរបស់ UNCITRAL ឬ ក្នុង មាត្រា១១ នៃកិច្ចព្រមព្រៀងស្តីពីលទ្ធកម្មសាធារណៈរបស់រដ្ឋាភិបាល ។

ធាតុនានាសំរាប់ធានានូវតម្លាភាពបន្ទាប់ពីផ្តល់កិច្ចសន្យាលទ្ធកម្មសាធារណៈរបស់រដ្ឋាភិបាល

តម្លាភាពនៃសេចក្តីសំរេចលើការផ្តល់កិច្ចសន្យា

ដើម្បីអោយមានតម្លាភាពក្នុងការសំរេចលើការផ្តល់កិច្ចសន្យាលទ្ធកម្មសាធារណៈ ជាសំខាន់ គឺការសំរេចនោះ ត្រូវធ្វើឡើងយ៉ាងម្មត់ចត់ ផ្អែកលើមូលដ្ឋាននៃលក្ខន្តិកៈវាយតំលៃ (ដោយរួមមានលក្ខន្តិកៈ លើលក្ខណៈសម្បត្តិបច្ចេកទេស) ដោយបានកំណត់ជាមុន ក្នុងឯកសារដេញថ្លៃ និងឈរលើមូលដ្ឋានពត៌មាន ដែលបានផ្តល់អោយអំពីរបៀបអនុវត្តលក្ខន្តិកៈ ។ លើសពីនេះទៀត ដើម្បីធានាថា សេចក្តីសំរេចត្រូវបានយកមកប្រើប្រាស់តាមរបៀបនេះមែន លក្ខន្តិកៈនេះត្រូវតែកំណត់យ៉ាងណា ដើម្បីធានាថា វាអាចត្រូវបានអនុវត្ត យ៉ាងចំគោលដៅ ។

ដោយហេតុថា មិនមានការចាំបាច់ទាមទារអោយមានការបើកចំហរជាសាធារណៈនូវការដេញថ្លៃ ដើម្បីធានានូវតម្លាភាពទេនោះ អង្គភាពលទ្ធកម្មសាធារណៈគួរតែមាននីតិវិធី ដើម្បីធានាកុំអោយមានភាពគ្មានលំអៀងនៃកិច្ចដំណើរការលទ្ធកម្មសាធារណៈប្រព្រឹត្តទៅ ដោយលំអៀង ។

ពត៌មានជាបន្ទាប់មកដែលត្រូវផ្ញើជូនអ្នកដេញថ្លៃដែលចាញ់

ចំណុចខាងក្រោមនេះ ត្រូវបានរៀបចំឡើង ដើម្បីគោលបំណងនិងដំណើរការផ្ញើពត៌មានជាបន្ទាប់មកទៀត ÷

- ☐ ប្រភេទនៃពត៌មាននេះ ត្រូវបានផ្តល់ជូនអ្នកដេញថ្លៃដែលចាញ់ ដើម្បីបញ្ជាក់ប្រាប់ពួកគេថា សំណើដេញថ្លៃរបស់គេ ត្រូវបានវាយតំលៃដោយសមធម៌យោងតាមល័ក្ខខ័ណ្ឌ និងលក្ខន្តិកៈ ដែលកំណត់ក្នុងឯកសារដេញថ្លៃ ហើយមានការអនុវត្តន៍ដោយគោរពទៅតាមវិធាន និងការអនុវត្តន៍ ដែលបានកំណត់ទាំងឡាយ
- ☐ មធ្យោបាយសំរាប់ផ្តល់ពត៌មាននេះ គឺជាជំរើសរបស់សមាជិកម្នាក់ៗ ប៉ុន្តែត្រូវតែធ្វើយ៉ាងណាអោយភាគីពាក់ព័ន្ធបានដឹង ។ នៅក្នុងទំនាក់ទំនងនេះ ទស្សនៈមួយបានបង្ហាញថា វាជាការប្រើប្រាស់ពេលវេលា និងបន្ទុកយ៉ាងធ្ងន់ក្នុងការផ្តល់ពត៌មានដល់អ្នកដេញថ្លៃ ដែលចាញ់ម្នាក់ៗពីលទ្ធផលនៃការដេញថ្លៃរបស់គេ ។

នីតិវិធីត្រួតពិនិត្យក្នុងប្រទេស

ការកំណត់នូវវិធានគឺមិនទាន់គ្រប់គ្រាន់ ដើម្បីទទួលបាននូវតម្លាភាពក្នុងលទ្ធកម្មសាធារណៈរបស់រដ្ឋាភិបាលទេ ។ ពោលគឺត្រូវតែមានយន្តការត្រួតពិនិត្យក្នុងប្រទេសមួយ ដើម្បីបង្កើតអោយមានការទទួលខុសត្រូវនៅក្នុងកិច្ចដំណើរការនេះ និងដើម្បីធានាអោយអ្នករាល់គ្នាគោរពទៅតាមវិធាន ដែលទាក់ទងក្នុងកិច្ចដំណើរការលទ្ធកម្មសាធារណៈនោះ ។ ការមានយន្តការមួយសំរាប់ត្រួតពិនិត្យនូវកិច្ចដំណើរការលទ្ធកម្មសាធារណៈ គឺជាគន្លឹះដ៏សំខាន់មួយនៃតម្លាភាព ។ យន្តការសំរាប់ត្រួតពិនិត្យបណ្តឹងពីអ្នកផ្គត់ផ្គង់ ឬ ប្រព័ន្ធសំរាប់តវ៉ាក្នុងការដេញថ្លៃ នឹងធានាអោយមានកិច្ចដំណើរការដ៏ត្រឹមត្រូវ ព្រមទាំងការទទួលខុសត្រូវជាសាធារណៈ នៅក្នុងកិច្ចដំណើរការលទ្ធកម្មសាធារណៈ និងបង្កើតនូវតម្លាភាពនៃកិច្ចដំណើរការនេះផង ។ វត្តមាននៃយន្តការត្រួតពិនិត្យអាចធ្វើអោយអាជ្ញាធរលទ្ធកម្មសាធារណៈកាន់តែយល់ដឹងពីតំរូវការចាំបាច់ ដើម្បីធានាថា នីតិវិធីដែលត្រូវបានប្រើក្នុងលទ្ធកម្មសាធាណៈណាមួយនេះ មានភាពសមស្របជាមួយច្បាប់ និងបទបញ្ញត្តិដែលត្រូវអនុវត្ត ។

យន្តការនៃការប្តឹងតវ៉ា ឬត្រួតពិនិត្យនោះត្រូវផ្អែកតាមនីតិវិធីនៃកិច្ចព្រមព្រៀង WTO ឧទាហរណ៍ កិច្ចព្រមព្រៀងស្តីពីការប្រឆាំងការអនុវត្តន៍គោលនយោបាយបញ្ចុះតំលៃទំនិញ ការវាយតំលៃពន្ធគយ ការត្រួតពិនិត្យមុនពេលដឹកជញ្ជូន និង TRIPS ។

ទស្សនៈម្យ៉ាងទៀតគឺថា បញ្ហាត្រួតពិនិត្យ ហាក់ដូចជាខ្ពស់ផុតពីបញ្ហាតម្លាភាពហើយដូច្នេះវាក៏មិនអាចស្ថិតក្នុងអាណត្តិនៃក្រុមការងារដែរ (Working Group) ។ មិនទាន់ដល់ពេលពិភាក្សាសំនួរនេះទេ ។ លើសពីនេះទៀតបទបញ្ញត្តិស្តីពី ការត្រួតពិនិត្យកិច្ចព្រមព្រៀងដ៏មានតម្លាភាពមួយអាចនាំមកនូវការកើនឡើងនូវបញ្ហាប្រឈមមុខមិនសមស្រប ការកើនឡើងនូវចំណាយ និងការពន្យាពេលក្នុងការផ្តល់អោយនូវកិច្ចសន្យា ។

លើសពីនេះទៀត នីតិវិធីក្នុងស្រុករបស់បណ្តាប្រទេសមួយចំនួន បានអនុញ្ញាត្តិអោយមានការត្រួតពិនិត្យឡើងវិញមួយ ដើម្បីបញ្ជាក់ថាតើលទ្ធកម្មសាធារណៈ ធ្វើឡើងដោយស្របទៅនឹងច្បាប់ឬទេ ។ ដោយហេតុថា នីតិវិធីនោះអាចមានវិសាលភាពធំជាងកាតព្វកិច្ចទាំងឡាយ កិច្ចព្រមព្រៀងប្រកបដោយតម្លាភាពមួយ ដូច្នេះគេប្រហែលជាមិនចាំបាច់កំណត់ព្រំដែននៃការអនុវត្តន៍នីតិវិធីត្រួតពិនិត្យឡើងវិញ ចំពោះតែកាតព្វកិច្ចតម្លាភាពជាក់លាក់ណាមួយក្នុងកិច្ចព្រមព្រៀង WTO ស្តីពីតម្លាភាពទេ ។

ការអនុវត្តន៍នីតិវិធីដោះស្រាយវិវាទក្នុង WTO

ចំពោះដំណោះស្រាយវិវាទរវាងបណ្តារដ្ឋាភិបាលនានា ទស្សនៈជាទូទៅ គឺថាវាមិនទាន់ដល់ពេលពិចារណាពីភាពអាចប្រតិបត្តិបាននូវបទបញ្ញត្តិអំពីដំណោះស្រាយជំលោះ នៅមុនពេលដែលធាតុនានានៃកិច្ចព្រមព្រៀងស្តីពីតម្លាភាពមួយ ត្រូវបានកំណត់យ៉ាងច្បាស់លាស់ទេ ។ លើសពីនេះបេសកកម្មរបស់ក្រុមការងារ គឺពិភាក្សាពីបណ្តាធាតុនៃកិច្ចព្រមព្រៀងស្តីពីតម្លាភាពដ៏សមស្របមួយ ដែលអាចមានទំរង់ជាកិច្ចព្រមព្រៀងចងភ្ជាប់កាតព្វកិច្ច ឬ ជាក្រុមមួយដែលជំរុញបណ្តាប្រទេសទាំងឡាយ អោយប្រឹងប្រែង ដើម្បីគោរពតាមការណែនាំរបស់ក្រុមនោះ ។ មានតែកិច្ចព្រមព្រៀងចងភ្ជាប់ជាកាតព្វកិច្ចទេ ដែលអាចជាកម្មវត្ថុនៃនីតិវិធីដោះស្រាយវិវាទរបស់ WTO ។

កិច្ចសហប្រតិបត្តិការបច្ចេកទេស និងប្រព្រឹត្តិកម្មពិសេស និងដោយឡែក ចំពោះប្រទេសកំពុងអភិវឌ្ឍន៍

កិច្ចសហប្រតិបត្តិការបច្ចេកទេស មានសារៈសំខាន់ក្នុងការធានានូវការអនុវត្តន៍ប្រកបដោយជ័យជំនះ នូវកិច្ចព្រមព្រៀងនាពេលអនាគតមួយស្តីពីតម្លាភាព ។ វាក៏អាចជួយដល់បណ្តាសមាជិកក្នុងការអភិវឌ្ឍន៍ នូវរបបលទ្ធកម្មសាធារណៈក្នុងប្រទេស និងក្នុងការចាប់យកនូវជំហានអនុវត្ត ដើម្បីពង្រឹងតម្លាភាពនៃនយោបាយ និងការអនុវត្តន៍លទ្ធកម្មសាធារណៈ ។ អនុសាសន៍ជាពិសេសស្តីពីប្រភេទនៃការជួយឧបត្ថម្ភ ដែលបានផ្តល់អោយមានបញ្ចូលក្នុងបញ្ជីវណ្ណ ៥៩ ។

កិច្ចការកំពុងធ្វើ

ក្រុមការងារកំពុងបន្តកិច្ចការអភិវឌ្ឍន៍នូវធាតុនានា សំរាប់បញ្ចូលទៅក្នុងកិច្ចព្រមព្រៀងមួយ ស្តីពីតម្លាភាពក្នុងលទ្ធកម្មសាធារណៈរបស់រដ្ឋាភិបាល គេបានរៀបចំកំរោងប្រជុំ ៣ លើកសំរាប់ឆ្នាំ ១៩៩៩ ។ សេចក្តីសំរេចថា គួររៀបចំកិច្ចព្រមព្រៀងបន្តរទៀត ដើម្បីចងភ្ជាប់ជាកាតព្វកិច្ច ទាំងស្រុង ឬ គួររៀបចំជាក្រុមមួយ ដើម្បីទាមទារអោយសមាជិកប្រឹងប្រែងអនុវត្តកិច្ចព្រមព្រៀងនោះ នឹងរំពឹងថា លើកមកធ្វើជារបៀបវារៈ ទៅឯសន្និសិទថ្នាក់រដ្ឋមន្ត្រីលើកទី៣ ដែលធ្វើនៅខែវិច្ឆិកា ១៩៩៩ ។

ខណ្ឌ ៥៩

ប្រភេទនៃការឧបត្ថម្ភដែលអាចផ្តល់ដល់ប្រទេសកំពុងអភិវឌ្ឍន៍ នៅក្រោមកិច្ចព្រមព្រៀងស្តីពីតម្លាភាពក្នុងលទ្ធកម្មសាធារណៈរបស់រដ្ឋ

ការអភិវឌ្ឍន៍នៃនីតិវិធីនិងបញ្ញត្តិច្បាប់ជាតិ

- □ *ការវិភាគ និងការណែនាំលើជំរើសនយោបាយ និងរដ្ឋបាល*
- □ *ការកាត់តែងនូវនីតិវិធីសំរាប់ផ្សព្វផ្សាយ*
- □ *ការស្តាបនា និងប្រតិបត្តិនូវប្រព័ន្ធកាំក្នុងការដេញថ្លៃ*
- □ *ជំណាក់កាលអនុវត្តន៍ ដើម្បីជំរុញអោយលទ្ធកម្មសាធារណៈមានភាពអំណោយផលចំពោះអតិថិជន ដូចជាការអភិវឌ្ឍន៍នូវឯកសារ ស្តង់ដារសំរាប់សេចក្តីប្រកាសដេញថ្លៃ និងឯកសារដេញថ្លៃដែលត្រូវបំពេញ ក៏ដូចជាការអភិវឌ្ឍន៍នូវវាក្យស័ព្ទលទ្ធកម្មសាធារណៈរួមមួយ*

ការបណ្តុះបណ្តាល

- □ *ការបង្ហាត់បង្រៀនអ្នកទាំងឡាយដែលមានតួនាទីជាអ្នកប្រតិបត្តិករជាអ្នកប្រើប្រាស់ ឬអនុវត្តនូវបទបញ្ញត្តិនីតិវិធី និង ឬ ការអនុវត្តថ្មីៗ ។*
- □ *ការបណ្តុះបណ្តាលតុលាការ*
- □ *ការបណ្តុះបណ្តាលដល់គ្រូបង្ហាត់ ដើម្បីអោយពួកគេអាចរៀបចំកម្មវិធីបណ្តុះបណ្តាល ជាឧទាហរណ៍នៅតាមសាលាជំនួញ ឬវិទ្យាស្ថាន រដ្ឋបាលសាធារណៈក្នុងប្រទេសដែលទទួលជំនួយឧបត្ថម្ភនោះ*
- □ *បណ្តុះបណ្តាលអ្នកទិញ និងអ្នកផ្គត់ផ្គង់*
- □ *ការផ្លាស់ប្តូរបុគ្គលិក*

ការកសាងស្ថាប័ន

- □ *កិច្ចសហប្រតិបត្តិការរដ្ឋបាល ដើម្បីពង្រឹងការកសាងស្ថាប័ន និងបំលាស់ប្តូរពត៌មាន*

មធ្យោបាយដែលអ្នកផ្គត់ផ្គង់អាចទទួលយកបាននូវពត៌មាន

- ☐ *ការពិភាក្សាសិក្ខាសាលា និងការផលិតនូវសៀវភៅណែនាំដល់អ្នកប្រើប្រាស់ ដោយរួមមានការអភិវឌ្ឍន៍ទំព័រអ៊ីនធឺណេត ម៉ាស៊ីន សំរាប់ស្រាវជ្រាវកឃ្លាំងទិន្នន័យ សំដៅផ្តល់ពត៌មានស្តីពីការអនុវត្តសំរាប់ធ្វើពាណិជ្ជកម្មជាមួយរដ្ឋាភិបាលក្នុងនិងក្រៅប្រទេស ហើយដើម្បីជួយសំរួលលទ្ធភាពទទួលបាននូវពត៌មានទាំងនោះ ។ ជំនួយទាំងនោះអាចផ្តល់ជាប្រយោជន៍ដល់សហគ្រាសធុនមធ្យម ឬតូចដោយការបង្កើតនូវជំនឿទុកចិត្ត និងប្រសិទ្ធិភាពរបស់គេក្នុងការចូលទៅរកទីផ្សារសាធារណៈក្នុងស្រុក និងក្រៅស្រុក ។ ការប្រើប្រាស់នូវបច្ចេកវិជ្ជាពត៌មានសាស្រ្ត ។*
- ☐ *ការអភិវឌ្ឍន៍នូវឧបករណ៍បច្ចេកវិជ្ជាពត៌មានុសាស្រ្ត សំរាប់ផ្សព្វផ្សាយពត៌មានស្តីពីលទ្ធភាព និងអនុវត្តធ្វើលទ្ធកម្ម ព្រមទាំងការបង្កើតនូវការដេញថ្លៃតាមប្រព័ន្ធអេឡិចត្រូនិចទាំងស្រុង ក៏ដូចជាដើម្បីសំរួលដល់ការប្រមូលនូវទិន្នន័យ និងស្ថិតិសេដ្ឋកិច្ចសំខាន់ៗដែរ ។*
- ☐ *ការផ្តល់នូវការិយាល័យបច្ចេកវិទ្យាពត៌មានសាស្រ្ត និងឧបករណ៍ដទៃទៀត ដែលចាំបាច់សំរាប់ការអនុវត្តន៍ និងប្រតិបត្តិនូវបទបញ្ញត្តិច្បាប់ នីតិវិធី និងការអនុវត្តន៍នានា ។*

ជំពូក ២៥

ការសំរួលផ្នែកពាណិជ្ជកម្ម

ការសំរួលផ្នែកពាណិជ្ជកម្ម គឺជាប្រធានបទថ្មីដែលបានបូកបន្ថែមទៅក្នុងកម្មវិធីការងារ WTO នៅក្នុងសន្និសិទ្ធថ្នាក់រដ្ឋមន្ត្រីនៅសិង្ហបុរី ឆ្នាំ១៩៩៦ ។ សេចក្តីប្រកាសថ្នាក់រដ្ឋមន្ត្រីនៃសន្និសិទ្ធនោះបានណែនាំអោយក្រុមប្រឹក្សាផ្នែកពាណិជ្ជកម្មលើទំនិញ ធ្វើការស្រាវជ្រាវ និងវិភាគនៅក្នុងវិស័យនេះ ។ កឋាខ័ណ្ឌសំខាន់ចំពោះសេចក្តីប្រកាសនោះបានចែងដូចតទៅ ÷

> បណ្តារដ្ឋមន្ត្រីណែនាំដល់ក្រុមប្រឹក្សាផ្នែកពាណិជ្ជកម្មលើទំនិញអោយធ្វើការស្រាវជ្រាវ និងវិភាគដោយផ្អែកលើការងារសំខាន់ៗរបស់អង្គការអន្តរជាតិនានា ស្តីពីលើការសំរួលនូវនីតិវិធីពាណិជ្ជកម្ម ដើម្បីវាយតំលៃវិសាលភាព សំរាប់វិធានរបស់ WTO នៅក្នុងវិស័យនេះ ។

ការពិភាក្សានៅក្នុងជំពូកនេះត្រូវបានរៀបចំដូចតទៅ ÷

- ☐ អង្គការអន្តរជាតិ និងអង្គការរដ្ឋាភិបាលតាមតំបន់ព្រមទាំងអង្គការដទៃទៀត ដែលបានកំពុងធ្វើការនៅក្នុងវិស័យនេះ កន្លងមកដល់បច្ចុប្បន្ន និងដែលកំពុងដំណើរការនៅក្នុងអង្គការសំខាន់ៗ ។
- ☐ ទស្សនៈអំពីការសំរួលចំពោះពាណិជ្ជកម្ម និងបទបញ្ញត្តិនៃកិច្ចព្រមព្រៀង WTO ដែលមានគោលដៅជាពិសេស គឺជំរុញការសំរួល ផ្នែកពាណិជ្ជកម្ម ។
- ☐ មូលហេតុសំខាន់ចំពោះសំណើរឱ្យមានការចូលរួមរបស់ WTO នៅក្នុងការងារជួយសំរួលផ្នែកពាណិជ្ជកម្ម ហើយប្រធានបទផ្នែកនេះ បានស្នើអោយមានការបញ្ចូលទៅក្នុងកម្មវិធីការងារ ។
- ☐ ការពិភាក្សាបច្ចុប្បន្ននៅក្នុង WTO ។

ការងាររបស់អង្គការអន្តរជាតិដទៃទៀតក្រៅពី WTO

ការទទួលស្គាល់ថា វិធីធ្វើជំនួញ និងនីតិវិធីរដ្ឋាភិបាលសំរាប់ការទូទាត់ទំនិញ ដែលធ្វើពាណិជ្ជកម្មជាអន្តរជាតិ អាចនាំអោយមានការយឺតយ៉ាវ និងអស់ចំណាយខ្ពស់ បានជំរុញអោយអង្គការមួយចំនួនអនុម័តនូវអនុសញ្ញា និងលិខិតុបករណ៍គតិយុត្តិឯទៀត ដែលមានចែងអំពីវិធានអនុសាសន៍ ឬស្តង់ដារនានា ដើម្បីសំរួលដល់ពាណិជ្ជកម្ម ។ វណ្ណ ៦០ បានរាយនាមអង្គការអន្តរជាតិជាអន្តររដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាលជាច្រើន ដែលបច្ចុប្បន្នកំពុងធ្វើការងារសំរួលផ្នែកពាណិជ្ជកម្ម ។ អង្គការភាគច្រើនដែលបានរាយនាមនៅក្នុងវណ្ណនោះ បានធ្វើការងារ នៅក្នុងប្រធានបទមួយចំណែកតូច ក្នុងការកិច្ចរបស់ខ្លួន ។

ច្បាប់របស់ WTO ស្តីពីការសំរួលផ្នែកពាណិជ្ជកម្ម

និយមន័យនៃការសំរួលផ្នែកពាណិជ្ជកម្ម

គ្មាននិយមន័យឯកភាពណាមួយចំពោះ "ការសំរួលផ្នែកពាណិជ្ជកម្មទេ" ហើយពាក្យនេះក៏ត្រូវបានប្រើប្រាស់ នៅក្នុងអង្គការផ្សេងៗ

ដោយសំដៅលើសកម្មភាពប្លែកៗគ្នាដែរ ។ ក្នុងន័យទូលាយជាងគេ ពាក្យនេះត្រូវបានប្រើ ដើម្បីបញ្ជូលនូវការងាររបស់ UNCTAD សំដៅជំរុញបណ្តាប្រទេសអោយបង្កើតនូវ "ចំណុចពាណិជ្ជកម្មជាតិ "ដែលប្រមូលជាក្រុម-ជារូបវន្តឬជាអេឡិចត្រូនិក-នូវភ្នាក់ងារទាំងឡាយ ដែលចូលរួមក្នុងប្រតិបត្តិការពាណិជ្ជកម្មក្រៅប្រទេស ដែលនាំអោយគេអាចផ្តល់នូវសេវាកម្មចាំបាច់សំរាប់បញ្ចប់នូវប្រតិបត្តិការនេះយ៉ាងរហ័សនិងយ៉ាងមានប្រសិទ្ធិភាព ។ ប៉ុន្តែនៅក្នុងន័យចង្អៀត ពាក្យនេះត្រូវបានប្រើដោយ សំដៅលើការងារកែលំអលើតំរូវការឯកសារ និងនីតិវិធីកំណត់ដោយបណ្តាប្រទេស ដើម្បីធានានូវការគោរពតាមវិធានដែលអនុវត្តចំពោះទំនិញនៅពេលធ្វើការនាំចេញ នាំចូល និងឆ្លងកាត់ ។ វិធានទាំងនោះរួមមាន ÷

ខណ្ឌ ៦០

បណ្តាអង្គការដែលធ្វើការងារសំរួលផ្នែកពាណិជ្ជកម្មអង្គការអន្តររដ្ឋាភិបាលអន្តរជាតិ ÷

អង្គការអាកាសចរស៊ីវិលអន្តរជាតិ (ICAO)
មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF)
អង្គការដែនសមុទ្រអន្តរជាតិ(IMO)
មជ្ឈមណ្ឌលពាណិជ្ជកម្មអន្តរជាតិ (UNCTAD/WTO (ITC)
អង្គការសំរាប់សហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍន៍ (OECD)
សន្និសិទ្ធិអង្គការសហប្រជាជាតិអំពីពាណិជ្ជកម្ម និងអភិវឌ្ឍន៍(UNCTAD)
គណៈកម្មការសេដ្ឋកិច្ចរបស់អង្គការសហប្រជាជាតិសំរាប់អឺរ៉ុប(ECE)
គណកម្មការរបស់អង្គការសហប្រជាជាតិស្តីពីច្បាប់ពាណិជ្ជកម្មអន្តរជាតិ (UNCITRAL)
គណៈកម្មការប្រជាជាតិសំរាប់អាស៊ី និងប៉ាស៊ីហ្វិក(ESCAP)
អង្គការគយពិភពលោក (WCO)
ធនាគារពិភពលោក (WB)

អង្គការក្រៅរដ្ឋាភិបាលអន្តរជាតិ ÷

☐ *សភាពាណិជ្ជកម្មអន្តរជាតិ(ICC)*
សភាដឹកជញ្ជូនផ្លូវទឹកអន្តរជាតិ (ICS)
សមាគមដឹកជញ្ជូនផ្លូវទឹកអន្តរជាតិ (IATA)
អង្គការអន្តរជាតិសំរាប់ស្តង់ដាររូបនីយកម្ម (ISO)
សមាគមដឹកជញ្ជូនផ្លូវគោកអន្តរជាតិ(IRU)
សហព័ន្ធអន្តរជាតិនៃសមាគមអ្នកដឹកជញ្ជូនទំនិញ (FIATA)

អង្គការតំបន់ តំបន់ពាណិជ្ជកម្ម និងសមាគមន៍គយ ÷

វេទិកាសហប្រតិបត្តិការសេដ្ឋកិច្ច អាស៊ី ប៉ាស៊ីហ្វិក(APEC)
សហគមអឺរ៉ុប(EU)
កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាមេរិកខាងជើង(NAFTA)

☐ វិធានត្រួតពិនិត្យរបស់ភ្នាក់ងារគយ ដើម្បីធានាការគោរពច្បាប់ និងបទបញ្ញត្តិគយ ។

- ☐ បទបញ្ញត្តិបច្ចេកទេស ដើម្បីធានាថាទំនិញមានលក្ខណៈស្របតាមស្តង់ដារ ជាកាតព្វកិច្ចដែលបានកំណត់ នៅក្នុងច្បាប់ និងបទបញ្ញត្តិជាតិ ។
- ☐ ការត្រួតពិនិត្យជំងឺសត្វ ចំពោះសត្វ និងផលិតផលពីសត្វ ដើម្បីការពារជីវិតសត្វ និងមនុស្សពីជំងឺបេស្ដ៏ ឬ និងជំងឺឯទៀត ដែលអាចមាន ។
- ☐ ការត្រួតពិនិត្យភូតគាមអនាម័យ ចំពោះរុក្ខជាតិ និងផលិតផលពីរុក្ខជាតិ ដើម្បីរារាំងនូវការចូលមក ឬការរាលដាលនូវជំងឺបេស្ដ៏ ។
- ☐ ការត្រួតពិនិត្យលើគុណភាព (ក្រៅពីអ្វីដែលបានកើតពីខាងលើ) ដើម្បីធានាថា ទំនិញបានឆ្លើយតប ទៅនឹងស្តង់ដារអប្បបរមារបស់ជាតិ និងអន្តរជាតិ ដែលបានកំណត់នៅក្នុងច្បាប់និងបទបញ្ញត្តិសំខាន់ៗទាំងឡាយ។

កិច្ចព្រមព្រៀងរបស់ WTO : បទបញ្ញត្តិស្តីពីការសំរួលផ្នែកពាណិជ្ជកម្ម

នៅក្នុងផ្នែកខ្លះនៃនិយមន័យតាមន័យចង្អៀត កិច្ចព្រមព្រៀង WTO ចែងនូវបទបញ្ញត្តិ ដែលជួយសំរួលដល់ការធ្វើពាណិជ្ជកម្ម ដូចដែលបានឃើញនៅក្នុងវណ្ឌ ៦១ ។

ខណ្ឌ ៦១

បទបញ្ញត្តិ WTO ដើម្បីសំរួលដល់ពាណិជ្ជកម្ម

ផ្នែកពាក់ព័ន្ធ	***កិច្ចព្រមព្រៀង WTO***
វិធានការត្រួតពិនិត្យគយ	☐ *កិច្ចព្រមព្រៀងស្តីពីការវាយតំលៃរបស់គយ ។ មានចែងនូវវិធានរបស់ភ្នាក់ងារគយកំណត់នូវតំលៃទំនិញនាំចូលសំដោយកពន្ធគយលើតម្លៃបន្ថែម (មើលជំពូក៣) ។* ☐ *កិច្ចព្រមព្រៀងស្តីពីវិធាននៃប្រភពដើមទំនិញ ។ កិច្ចព្រមព្រៀងនេះត្រូវបានធ្វើនៅក្នុង WTO ដោយផ្អែកនៅលើការងារ ដែលកំពុងធ្វើឡើងដោយ WCO ដើម្បីអោយស៊ីសង្វាក់គ្នានូវវិធាននៃប្រភពដើមទំនិញ ។ កិច្ចព្រមព្រៀងនេះ នឹងមានចែងអំពីវិធានសំរាប់កំណត់នូវប្រភពទំនិញ ដែលនាំចូលលើមូលដ្ឋាន FMN ក្នុងគោលបំណងដូចជា ការអនុវត្តន៍នូវវិធានការណ៍សុវត្ថិភាព ឬ ការយកពន្ធប្រឆាំងនឹងការលក់បង្ខូចថ្លៃ (សូមអានជំពូក១២) ។* ☐ *កិច្ចព្រមព្រៀងស្តីពីការត្រួតពិនិត្យមុនពេលដឹកជញ្ជូន ។ កិច្ចព្រមព្រៀងនេះកំណត់វិធានអំពីការប្រតិបត្តិ ដែលធ្វើឡើងដោយក្រុមហ៊ុន PSI បន្ទាប់ពីបានពិនិត្យ បញ្ជាក់រួចមុនពេលធ្វើការនាំចូលទៅក្នុងប្រទេសមួយក្នុងការកំណត់នូវតំលៃសំរាប់គោលដៅពន្ធគយ (មើលជំពូក ៤)។* ☐ *កិច្ចព្រមព្រៀងអំពីនីតិវិធីផ្តល់អាជ្ញាប័ណ្ណនាំចូល ។ កិច្ចព្រមព្រៀងនេះមានចែងពីវិធានលើការចេញអាជ្ញាប័ណ្ណនាំចូល ចំពោះផលិតផលដែលត្រូវអនុវត្តន៍ប្រព័ន្ធផ្តល់អាជ្ញាប័ណ្ណ (មើលជំពូក ៦) ។*
ការគោរពតាមបទបញ្ញត្តិបច្ចេកទេសអនាម័យ និងភូតគាមអនាម័យ	*កិច្ចព្រមព្រៀងអំពីរបាំងបច្ចេកទេសចំពោះពាណិជ្ជកម្ម និងអំពីការអនុវត្តនៃវិធានការអនាម័យ និងភូតគាមអនាម័យបានកំណត់នូវគោលការណ៍ និងវិធានការ ដើម្បីធានាថា វិធាន និងនីតិវិធីថ្នាក់ជាតិ ចំពោះវិស័យដែលមាននៅក្នុងកិច្ចព្រមព្រៀងនេះ ពុំមែនជារបាំងពាណិជ្ជកម្មឡើយ (មើលជំពូក៥)។*

ជាបន្ថែមលើនេះ GATT ឆ្នាំ ១៩៩៤ ក៏មានបទបញ្ញត្តិ សំដៅសំរួលដល់ពាណិជ្ជកម្មដែរ តាមរយៈការបន្ថែមនូវតម្លាភាពទៅលើវិធាន និងបទបញ្ញត្តិថ្នាក់ជាតិ និងតាមរយៈការធានាមិនអោយវិធាន និងបទបញ្ញត្តិនោះ ក្លាយជារបាំងពាណិជ្ជកម្ម ។

- ☐ មាត្រា៥: សេរីភាពក្នុងការឆ្លងកាត់ ។
- ☐ មាត្រា៨: សោហ៊ុយ និងបែបបទដែលពាក់ព័ន្ធ នឹងការនាំចូល និងនាំចេញ ។
- ☐ មាត្រា១០: ការបោះពុម្ពផ្សាយ និងការគ្រប់គ្រងលើបទបញ្ញត្តិពាណិជ្ជកម្ម ។

សំណើសុំអោយមានការចូលរួមរបស់ WTO នៅក្នុងការសំរួលផ្នែកពាណិជ្ជកម្ម

មូលហេតុនៃសំណើ

ចាំបាច់ត្រូវកត់សំគាល់ថា គោលដៅសំខាន់របស់បទបញ្ញត្តិ WTO ដែលបានលើកឡើងពីខាងលើ គឺការលុបបំបាត់ចោលនូវរបាំងមិនមែនពន្ធគយ ដែលជាលទ្ធផលនៃវិធានអនុវត្តដោយបណ្តាប្រទេស នៅតាមព្រំប្រទល់ ចំពោះទំនិញនាំចេញ និងនាំចូល។

ក្នុងឆ្នាំកន្លងមកអង្គការអន្តរជាតិនានា បានបង្កើតនូវសេចក្តីណែនាំចំពោះបណ្តាប្រទេស ក្នុងការកំណត់នូវនីតិវិធី ទៅតាមកិតអនុវត្តដែលពាក់ព័ន្ធ ឧទាហរណ៍ការទូទាត់ជំរះរបស់គយនូវទំនិញ នាំចេញ និងនាំចូល ។ នៅក្នុងដំណើរការនោះ អង្គការក៏បានទទួលនូវបទពិសោធន៍ជាច្រើន អំពីការសំរួលផ្នែកពាណិជ្ជកម្ម ។ សំណើសុំអោយមានការពាក់ព័ន្ធរបស់ WTO មានជាបន្ថែមលើនេះនូវមូលហេតុធំៗបី ។

ការកែលំអការអនុវត្តន៍វិធាន

ទីមួយគឺ ភាពខុសប្លែកគ្នារវាងច្បាប់ និងការអនុវត្តន៍នូវកាតព្វកិច្ចនានា នៅក្នុងក្របខ័ណ្ឌ WTO និងច្បាប់ ព្រមទាំងការអនុវត្តន៍របស់បណ្តាអង្គការដទៃទៀត ។

វិធានទាំងអស់នៃកិច្ចព្រមព្រៀង គឺសុទ្ធតែចងភ្ជាប់ដោយច្បាប់ ចំពោះប្រទេសជាសមាជិកនិមួយៗ។ ផ្ទុយទៅវិញ មានតែលិខិតុបករណ៍ច្បាប់មួយចំនួនតូចរបស់អង្គការដូចជា CEC និង WCO ដែលជាកាតព្វកិច្ចចងភ្ជាប់ ។ ភាគច្រើន វាមានរូបរាងជាសេចក្តីណែនាំឧទាហរណ៍ដូចជា គន្លឹះកំណត់ចំពោះ ឯកសារពាណិជ្ជកម្មនៃអង្គការសហប្រជាជាតិ ស្តង់ដារ EDIFACT របស់អង្គការសហប្រជាជាតិ (ការផ្លោះប្តូរទិន្នន័យអេឡិចត្រូនិក សំរាប់ការគ្រប់គ្រងពាណិជ្ជកម្ម និងដឹកជញ្ជូន) សំរាប់ការបញ្ជូនទិន្នន័យតាមកុំព្យូទ័រ និងស្តង់ដារ ISO ជាដើម ។ វាក៏អាចមានទំរង់ជាគំរូ ឬជាអនុសាសន៍ ចំពោះនិតិវិធី ឬការអនុវត្តន៍ដែរ (ឧទាហរណ៍ ឧបសម្ព័ន្ធ ចំពោះអនុសញ្ញាជាតិស្តីពីការសំរួល និងធ្វើអោយស៊ីសង្វាក់គ្នានូវនីតិវិធីគយ ដែលមានឈ្មោះថា អនុសញ្ញាក្យូតូ) ។

សេចក្តីណែនាំ ឬ អនុសាសន៍សំរាប់ការអនុវត្តន៍នេះពុំមែនជាកាតព្វកិច្ចចងភ្ជាប់ទេ គឺគ្រាន់តែជាការអំពាវនាវអោយបណ្តាប្រទេសប្រឹងប្រែងគោរពតាមប៉ុណ្ណោះ ។ ភាគច្រើនគឺពុំមានការទាមទារអោយរដ្ឋាភិបាលទទួលស្គាល់ជាផ្លូវការ ឬផ្តល់សច្ចាប័នឡើយ ។

ឯការអនុវត្តនីវិញ ទោះបីជាក្នុងករណីលិខិតុករណ៍មួយចំនួនតូចដែលមានលក្ខណៈចងភ្ជាប់ក្តី ឧទាហរណ៍ អត្ថបទបឋមរបស់អនុសញ្ញាក្យូតូមិនមែនឧបសម្ព័ន្ធទេ-ក៏មានភាពខុសប្លែកគ្នាយ៉ាងច្រើន ពីអ្វីដែលបានកំណត់ដោយឧបករណ៍ច្បាប់របស់ WTO ដែរ ។

ភាពខុសគ្នានេះ កើតឡើងពីធម្មជាតិនៃពិន័យដែលកើតមាននៅពេលមានការខុសឆ្គង ។ ប្រទេសដែលផលប្រយោជន៍ខ្លួនត្រូវទទួលនូវផលប៉ះពាល់ជាអវិជ្ជមាន បណ្តាមកពីភាពខុសឆ្គងរបស់ប្រទេសណាមួយទៀត ក្នុងការគោរពតាមនីតិវិធី WTO អាចនឹងទាមទារនូវ

នីតិវិធីដោះស្រាយវិវាទ ។ ការខុសឆ្គងក្នុងការអនុវត្តន៍សេចក្តីសំរេចរបស់ អាជ្ញាធរដោះស្រាយវិវាទ អាចនាំអោយមានការដាក់ចុះនូវវិធានការតទល់ជាការសងសឹក ពីសំណាក់ប្រទេសដែលមានការអន់ចិត្ត ។ វិធានការតទល់នោះអាចមានរូបរាងជាកំណើនពន្ធគយលើការនាំចូលពីប្រទេសខុសឆ្គងនោះ ឬ ការអោយសងជំងឺចិត្តជាដើម ។

ចំពោះលិខិតុបករណ៍របស់អង្គការដ៏ទៀត គឺគ្មានពិន័យបែបនេះទេ ។ ខណៈដែលលិខិតុបករណ៍ខ្លះមាន បទបញ្ញត្តិសំរាប់ ធ្វើការតវ៉ាចំពោះភាពមិនគោរពតាម ចំពោះមុខគណៈកម្មការគ្រប់គ្រង និងសំរាប់ការដោះស្រាយវិវាទក្តី លិខិតុបករណ៍នោះមានចែងពីគោលការណ៍ដែលជាការគៀបសង្កត់លើផ្លូវគំនិត និងជាការរិះគន់ប៉ុណ្ណោះ ប្រសិនបើការគៀបសង្កត់លើគំនិតត្រូវបរាជ័យ ។

តាមរយៈការអនុម័តវិធាននៅក្នុងផ្នែកនេះខ្លះៗនៅក្នុង WTO ឬតាមរយៈការបញ្ចូលលិខិតុបករណ៍ មួយចំនួនដែលបានចរចានៅក្នុងអង្គការដ៏ទៃទៀតទៅក្នុងក្របខ័ណ្ឌនៃច្បាប់ WTO ពួកអ្នកគាំទ្រនូវសំណើរសង្ឃឹមថា នឹងអាចធ្វើអោយវិធានទាំងឡាយបានអនុវត្តបានច្រើនជាងមុន ។ វិធានទាំងនោះ ជាទូទៅច្រើនតែមានលក្ខណៈចងភ្ជាប់ ហើយក៏មាននូវការគំរាមដាក់ពិន័យពាណិជ្ជកម្មដែរ ក្នុងករណីដែលមានការមិនគោរពតាម ។

នៅក្នុងបរិបទនេះ ជាការសំខាន់ត្រូវកត់សំគាល់ថា ក្នុងខណៈដែរកិច្ចព្រមព្រៀង WTO កំណត់នូវកាតព្វកិច្ចចងភ្ជាប់ចំពោះសមាជិកក៏នៅក្នុងករណីមួយចំនួនតូចវាត្រឹមតែជាការទាមទារអោយសមាជិកខិតខំយ៉ាងអស់សមត្ថភាព ដើម្បីអនុវត្តនូវបទបញ្ញត្តិខ្លះៗប៉ុណ្ណោះ។ ឧទាហរណ៍បទបញ្ញត្តិភាគច្រើនស្តីពីប្រព្រឹត្តកម្មពិសេស និងដោយឡែកនៃប្រទេសកំពុងអភិវឌ្ឍន៍បានដាក់ចុះនូវកាតព្វកិច្ចខិតខំខ្ពស់បំផុតចំពោះប្រទេសជឿនលឿន ។

ធ្វើអោយប្រសើរឡើងនូវការស៊ីគ្នាខាងនយោបាយ ក្នុងការគោរពនូវវិធាន

មូលហេតុទីពីរ ក្នុងការស្នើអោយ WTO បង្កើតនូវវិធាននៅក្នុងប្រធានបទថ្មីៗ គឺស្ថិតនៅក្នុងក្របខ័ណ្ឌនៃសេដ្ឋកិច្ចនយោបាយ។ ពួកអ្នកគាំទ្រជឿថា ដោយសារសារៈសំខាន់ក្នុងការចងភ្ជាប់ទៅនឹងប្រព័ន្ធច្បាប់របស់ WTO នៅក្នុងសេដ្ឋកិច្ចពិភពលោកជាសកលបណ្តាប្រទេសកាន់តែមានបំណងអនុវត្តនូវស្តង់ដារ ឬ អនុសាសន៍របស់អង្គការដទៃទៀត ប្រសិនបើ បានបញ្ចូលទៅក្នុងក្របខ័ណ្ឌនៃប្រព័ន្ធ WTO ។

ការនេះអាចធ្វើបានដោយវិធីពីរយ៉ាង ។ ទីមួយ គឺត្រូវដាក់នូវកាតព្វកិច្ចចងភ្ជាប់ ដែលចំពោះផ្នែកណាមួយនោះ បណ្តាប្រទេសនឹងគោរពតាមវិធានដែលបង្កើតឡើងដោយអង្គការអន្តរជាតិដទៃ ។ ឧទាហរណ៍ កិច្ចព្រមព្រៀងពី TBT និង SPS បានចែងថា ស្តង់ដារអនុម័តដោយ ISO គណៈកម្មការ Codex Alimentaieus អនុសញ្ញាអន្តរជាតិការពាររុក្ខជាតិ និងការិយាល័យអន្តរជាតិនៃ Epizootics ត្រូវតែបានចាត់ទុកថា ជាស្តង់ដារអន្តរជាតិ ហើយត្រូវកំណត់ជាកាតព្វកិច្ចចងភ្ជាប់ សំរាប់ប្រទេសអោយប្រើប្រាស់វាជាមូលដ្ឋាន សំរាប់បទបញ្ញត្តិចាំបាច់របស់ខ្លួន លើកលែងតែក្នុងករណីណាដែលពួកគេមានមូលហេតុត្រឹមត្រូវសំរាប់ងាកចេញពីនោះ នៅក្នុងករណីលើកលែងពិសេសដែលអនុញ្ញាត្តិដោយកិច្ចព្រមព្រៀង ។

ភាពចាំបាច់នៃការអនុម័តស្តង់ដារអន្តរជាតិ ទៅលើការបញ្ជូនទិន្នន័យអេឡិកត្រូនិក

មូលហេតុទីបី ចំពោះការស្នើអោយមានការចូលរួមជាមុនរបស់ WTO ទៅក្នុងការសំរួលផ្នែកពាណិជ្ជកម្មកើតឡើង ពីការលូតលាស់នៃបច្ចេកវិទ្យាក្នុងការបញ្ជូននូវទិន្នន័យតាមរយៈបណ្តាញអេឡិចត្រូនិក ដែលធ្វើអោយវាកាន់តែមានភាពចាំបាច់ សំរាប់អោយប្រទេសទាំងអស់អោយអនុម័តនូវស្តង់ដារអន្តរជាតិ ។ ឧទាហរណ៍ ការអភិវឌ្ឍន៍នូវស្តង់ដារ UN/CEC EDIFACT សំរាប់ការបញ្ជូនទិន្នន័យ បង្កើតឡើងដោយសារការលំបាកក្នុងការប្រើស្តង់ដារបញ្ជូន ទិន្នន័យខុសគ្នារវាងសហរដ្ឋអាមេរិក និងសហគមន៍អ៊ឺរ៉ុប។ ប្រទេសដែលពុំបានជំរុញអោយមានការបញ្ជូនតាមប្រព័ន្ធអេឡិចត្រូនិកនូវទិន្នន័យ ដែលទាមទារដោយបណ្តាធនាគារអ្នកនាំចូលប្រតិបត្តិការជំនួញឯទៀត និងភ្នាក់ងារគយផងដែរ នឹងកាន់តែជួបនូវផលវិបាកច្រើនឡើង នៅក្នុងទីផ្សារអន្តរជាតិ ។ ការចូលរួមរបស់ WTO នឹងជំរុញ ជាបន្តទៀតនូវការងារថ្នាក់បច្ចេកទេស ដើម្បីអភិវឌ្ឍន៍ស្តង់ដារបញ្ជូនទិន្នន័យ និងដើម្បីធានាថា ស្តង់ដារនោះត្រូវបានអនុវត្តនៅគ្រប់ប្រទេសទាំងអស់ ។

ផ្នែកដែលស្នើអោយបញ្ចូលទៅក្នុងកម្មវិធីការងាររបស់ WTO ស្តីពីការសំរួលផ្នែកពាណិជ្ជកម្ម

ប្រធានបទពិសេសៗ ដែលត្រូវបញ្ចូលទៅក្នុងកម្មវិធីការងាររបស់ WTO ស្តីពីការសំរួលផ្នែកពាណិជ្ជកម្ម នៅពុំទាន់បានកំណត់នៅឡើយទេ ហើយសំនួរថាតើ WTO គួរដើរតួនាទីដោយផ្ទាល់នៅ ក្នុងផ្នែកនោះក៏ពុំទាន់សំរេចនៅឡើយដែរ ។ ប៉ុន្តែសេចក្តីថ្លែងការរបស់បណ្តាប្រទេសមួយចំនួន បានបង្ហាញនូវសញ្ញាខ្លះៗ អំពីលទ្ធភាពនៃតួនាទី របស់ WTO ។ ជាទូទៅ គេនិយាយថាជាការប្រសើរគួរតែអនុម័ត នូវវិធានជាភាតព្វកិច្ចចងភ្ជាប់នៅក្នុងផ្នែកដូចខាងក្រោម ÷

- ☐ ការអនុម័តនូវវិធានជាបន្ត ឬគ្មានឈប់ឈរ សំរាប់ការទូទាត់ពិនិត្យលើឯកសារ ទំនិញតាមរយៈមធ្យោបាយអេឡិចត្រូនិច។
- ☐ ការអនុម័តនូវស្តង់ដារ ឯកភាពជាភាតព្វកិច្ចចងភ្ជាប់ សំរាប់ការបញ្ជូនពត៌មាន តាមមធ្យោបាយអេឡិកត្រូនិក ដោយការប្រើប្រាស់នូវស្តង់ដារ បង្កើតឡើងដោយ UN/ECE ISO និង UNCTAD ។
- ☐ ការអនុម័តនូវប្រព័ន្ធផ្នែកលើសវនកម្ម សំរាប់ការត្រួតពិនិត្យរបស់ភ្នាក់ងារគយ ។ នៅក្នុងប្រព័ន្ធនេះការបញ្ជូនទំនិញពុំត្រូវបានត្រួតពិនិត្យដោយឡែកៗទេ ។ គេប្រើនូវការវិនិច្ឆ័យលើហានិភ័យ និងនីតិវិធីគ្រប់គ្រង ហើយអនុញ្ញាត្តិអោយពាណិជ្ជករដែលមានការអនុញ្ញាត្តិធ្វើការបញ្ជាក់អំពីប្រភព និងបញ្ជូនទំនិញឆ្លងកាត់ភ្នាក់ងារគយ ។
- ☐ ការសំរួល និងធ្វើស្តង់ដារូបនីយកម្មនៃឯកសារ ដែលប្រើនៅក្នុងនីតិវិធីនាំចេញ និងនាំចូល ។
- ☐ ការអនុម័ត-ជាផ្នែកមួយនៃប្រព័ន្ធច្បាប់ WTO នូវស្តង់ដារដែលបានកែលំអរួចព្រមទាំងអនុសាសន៍ ដែលអាចបានព្រមព្រៀងនៅក្នុងក្របខ័ណ្ឌអនុសញ្ញាក្យូតូរបស់ WCO និងអនុសញ្ញាអ៊ីស្តង់ប៊ូល ។
- ☐ ការអនុម័តនូវសេចក្តីណែនាំនានា ដើម្បីប្រឆាំងនឹងអំពើពុករលួយពាក់ព័ន្ធនឹងភ្នាក់ងារគយព្រមទាំងអំពើអសកម្មដទៃទៀតទៅលើមូលដ្ឋាននៃសេចក្តីប្រកាស ARUSHA របស់ WCO ។

ការងារកំពុងធ្វើ

កិច្ចប្រជុំពន្យល់ក្រៅផ្លូវការ និងការវិភាគស្រាវជ្រាវរបស់បណ្តាប្រទេសជាសមាជិកដែលពាក់ព័ន្ធ បច្ចុប្បន្នកំពុងធ្វើឡើងនៅក្រោមការដឹកនាំរបស់ក្រុមប្រឹក្សាផ្នែកពាណិជ្ជកម្មទំនិញ ។ ការពិភាក្សានៃកិច្ចប្រជុំនោះ បានផ្តោតទៅលើ ÷

- ☐ នីតិវិធីនាំចេញ និងនាំចូលនិងការទាមទារទាំងឡាយ (រួមទាំងបញ្ហាគយ និងបញ្ហាឆ្លងព្រំដែនឯទៀត) ។
- ☐ ចលនាបញ្ជូនជាក់ស្តែងនូវទំនិញ (ដឹកជញ្ជូន និងត្រង់ស៊ីត) ក៏ដូចជាការទូទាត់ប្រាក់ធានារ៉ាប់រង និងល័ក្ខខ័ណ្ឌ ហិរញ្ញវត្ថុដទៃទៀតដែលមានផលប៉ះពាល់ទៅលើចលនាឆ្លងព្រំប្រទល់នៃទំនិញ ។
- ☐ ឧបករណ៍អេឡិចត្រូនិច និងសារៈសំខាន់របស់វា ក្នុងការសំរួលពាណិជ្ជកម្មអន្តរជាតិ ។
- ☐ សហប្រតិបត្តិការបច្ចេកទេស និងការអភិវឌ្ឍន៍ដែលពាក់ព័ន្ធនឹងការសំរួលដល់នីតិវិធីពាណិជ្ជកម្ម និង
- ☐ ទំនាក់ទំនងរវាងកិច្ចព្រមព្រៀង WTO និងការជួយសំរួល ។

សេចក្តីសំរេចអំពីរបៀបធ្វើការងារបន្តទៀត ត្រូវបានរំពឹងថានឹងធ្វើនៅក្នុងសន្និសិទ្ធិថ្នាក់រដ្ឋមន្ត្រីលើកទីបី ឆ្នាំ១៩៩៩ ដោយផ្អែកលើអនុសាសន៍របស់ក្រុមប្រឹក្សាផ្នែកពាណិជ្ជកម្មទំនិញ ដែលនឹងត្រូវគិតគូ អំពីលទ្ធផលនៃការពិភាក្សាក្រៅផ្លូវការផងដែរ ។

ជំពូក ២៦

ពាណិជ្ជកម្មអេឡិចត្រូនិក

តើអ្វីទៅជាពាណិជ្ជកម្មអេឡិចត្រូនិក

និយមន័យដែលគេទទួលស្គាល់ជាទូទៅចំពោះ " ពាណិជ្ជកម្មអេឡិចត្រូនិក " នៅពុំទាន់មាននៅឡើយទេ ។ ប៉ុន្តែជាទូទៅ គេប្រើពាក្យនេះដោយសំដៅលើ " ការបែងចែកម៉ាឃីតទីង ការលក់ ឬ ការដឹកជញ្ជូនទំនិញ ឬ សេវាកម្មដោយមធ្យោបាយអេឡិចត្រូនិក នាអំឡុងទសវត្សចុងក្រោយនេះ គឺបណ្តាលមកពីការប្រើប្រាស់ច្រើនឡើងនូវអ៊ីនធើណេត សំរាប់គោលដៅពាណិជ្ជកម្ម ។

ប្រតិបត្តិការពាណិជ្ជកម្មមួយអាចបែងចែកជាបីដំណាក់កាលធំៗ ÷

☐ ដំណាក់កាលផ្សាយពាណិជ្ជកម្ម និងស្វែងរក

☐ ដំណាក់កាលបញ្ជារទិញ និងទូទាត់ប្រាក់

☐ ដំណាក់កាលបញ្ជូនទំនិញ

ដំណាក់កាលនិមួយៗ ឬទាំងអស់នេះ អាចធ្វើឡើងតាមរយៈអ៊ីនធឺណេត (ឬជាមធ្យោបាយអេឡិចត្រូនិកឯទៀតដូចជា ហ្វាក់ ឬ ទូរស័ព្ទ) ហើយទង្វើទាំងនេះ អាចស្ថិតនៅក្រោមទស្សនៈពាណិជ្ជកម្មអេឡិចត្រូនិក ។ មធ្យោបាយអេឡិចត្រូនិក ត្រូវបានប្រើប្រាស់កាន់តែច្រើនយ៉ាងសម្បើម ដោយក្រុមហ៊ុនជំនួញនានា ដើម្បីផ្សាយពាណិជ្ជកម្ម និងលក់ទាំងទំនិញនិងសេវាទូទាំងពិភពលោក ។ ជាការពិតផលិតផលទាំងអស់សុទ្ធតែអាចដាក់លក់នៅលើមូលដ្ឋាននៃព័តមានតាមអ៊ីនធឺណេត ។ ព័តមានអំពីថ្លៃ គុណភាព ល័ក្ខខ័ណ្ឌ ដឹកជញ្ជូន និងទូទាត់ បានធ្វើអោយក្រុមហ៊ុនកម្មន្តសាល អ្នកលក់រាយ ឬ អ្នកប្រើប្រាស់នៅប្រទេសឆ្ងាយៗ អាចធ្វើការបញ្ជារទិញពីអ្នកផ្គត់ផ្គង់ណា ដែលមានលក្ខណៈប្រកួតប្រជែងជាងគេ ។ ទំនិញជាក់ស្តែង ក៏នឹងត្រូវបានបញ្ជូនមក តាមមធ្យោបាយដឹកជញ្ជូនដទៃទៀត ។

ការបញ្ជូនប្រភេទទំនិញជាក់លាក់ណាមួយ ដោយអេឡិចត្រូនិក ក៏កាន់តែអាចអនុវត្តទៅបានច្រើនឡើងៗដែរ ។ ជាក់ស្តែងផលិតផលណាមួយ ដែលអាចមានទំរង់ជាតួលេខ ក៏អាចបញ្ជូនទៅអោយបានតាមវិធីនេះដែរ ។ ប្រភេទនៃផលិតផលជាយថាភាពនោះមានច្រើនៈ សេវាកម្មហិរញ្ញវត្ថុ និងធានារ៉ាប់រង ផលិតផលសោតទស្សន៍ (ហ្វីល ល្បែង និងភ្លេង) សេវាកម្មធ្វើដំណើរ (សំបុត្រ យន្តហោះ កក់សណ្ឋាគារ) សេវាកម្មសារព័តមាន (សេវាបណ្តាញអេឡិចត្រូនិក និងការបើកឃ្លាំងទិន្នន័យ) សេវាទូគមនាគមន៍ និងសេវាកម្មបច្ចេកវិទ្យាពត៌មានសាស្ត្រ និង Software ។ បញ្ជីនេះពុំទាន់ចប់ទេ ហើយផលិតផលជាបន្ថែមទៀត ក៏ទំនងជាមានលក្ខណៈសមស្រប សំរាប់ពាណិជ្ជកម្មតាមអេឡិចត្រូនិកនាពេលអនាគតដែរ ។ បច្ចុប្បន្ន Software របស់កុំព្យូទ័រ គឺជាផលិតផលនាំមុខ ដែលបានលក់តាមអ៊ីនធឺណេត ។

ផលប្រយោជន៍នៃពាណិជ្ជកម្មអេឡិចត្រូនិក

ពាណិជ្ជកម្មអេឡិចត្រូនិកផ្តល់ដល់អ្នកប្រើប្រាស់ និងសហគ្រាសជំនួញនូវព័តមានអំពីការមាននៅទូទាំងពិភពលោក នូវផលិតផល ឬសេវា ថ្លៃ និងល័ក្ខខ័ណ្ឌនៃការលក់ ដែលអនុញ្ញាតិអោយពួកគេទទួលបាននូវការផ្គត់ផ្គង់ក្នុងល័ក្ខខ័ណ្ឌមួយដ៏ល្អបំផុត ។

វាក៏បានផ្តល់ដល់អ្នកផ្គត់ផ្គង់នូវសេវាម៉ាឃីតទីងតាមអេឡិចត្រូនិក និងអនុញ្ញាតិអោយពួកគេ ធ្វើជំនួញដោយពុំចាំបាច់បើកទីតាំង ឬ ក៏ជួលភ្នាក់ងារនៅបរទេស ។ " ហាងទំនិញ " និងចំណុចទំនាក់ទំនងនៅក្នុងអ៊ីនធឺណេត បានបំបាត់ចោលនូវភាពឃីតឃ៉ាវមួយចំនួន នៅក្នុងការផ្គត់ផ្គង់ទំនិញ តាមរយៈការជួយសំរួលដល់ការធ្វើទំនាក់ទំនង ។ ភាពមានប្រើប្រាស់ និងល្បឿននៃការផ្គត់ផ្គង់ ក៏អាច អនុញ្ញាតិអោយឧស្សាហកម្ម អ្នកលក់ដុំ និងរាយ អោយកាត់បន្ថយនូវកិរិតសន្និធិ និងស្តុករបស់ខ្លួនបានដែរ ។ ការនេះជួយដល់ក្រុមហ៊ុន ជាពិសេសក្រុមហ៊ុនធុនតូច និងមធ្យម អោយកាត់បន្ថយចំណាយបាន ។

ប្រអប់ ៦២

ឧបករណ៍សំខាន់ៗនៃពាណិជ្ជកម្មអេឡិចត្រូនិច

ពាណិជ្ជកម្មអេឡិចត្រូនិចមានឧបករណ៍សំខាន់ៗចំនួន ៦ : ទូរស័ព្ទ ហ្វាក់ ទូរទស្សន៍ ប្រព័ន្ធទូទាត់ និងផ្ទេរប្រាក់តាមអេឡិចត្រូនិច ការផ្លោះប្តូរទិន្នន័យ និងអ៊ីនធឺណេត ។ ខណៈដែលពាក្យ " ពាណិជ្ជកម្មអេឡិចត្រូនិច " នៅក្នុងការពិភាក្សាជាច្រើនសំដៅតែទៅលើ អ៊ីនធឺណេត ព្រមទាំងពាណិជ្ជកម្មផ្អែកលើបណ្តាញដទៃទៀត ជាទូទៅទូរស័ព្ទ ហ្វាក់ និងទូរទស្សន៍ ត្រូវបានប្រើប្រាស់ជាគ្រឿងផ្សព្វផ្សាយ សំរាប់ប្រតិបត្តិការជំនួញ ពិសេសនៅក្នុងប្រទេសឧស្សាហកម្ម ។ ឧទាហរណ៍ ការបញ្ជាទិញជាទូទៅត្រូវបានធ្វើឡើងតាមទូរស័ព្ទ ហើយបង់ប្រាក់តាមប័ណ្ណឥណទាន ។ ដូច្នេះការកើតឡើងនូវឧបករណ៍ដូចជាអ៊ីនធឺណេត ពុំមានន័យថា ជាការរកឃើញពាណិជ្ជកម្មអេឡិចត្រូនិចឡើយ ។

ប៉ុន្តែអ៊ីនធឺណេតពិតជាបានបើកផ្លូវថ្មីជាច្រើនទៀត : ជាមួយនឹងអ៊ីនធឺណេត ធាតុភាគច្រើនប្រតិបត្តិការជំនួញ អាចនឹងធ្វើឡើងនៅលើមូលដ្ឋាននៃអន្តរកម្មគ្មានឈប់ឈរ ជាមួយបុគ្គលម្នាក់ ឬ ច្រើន ដោយគ្មានទើសទាស់នឹងពេលវេលា ឬទំហំបន្ទប់ នៅក្នុងបរិវេណនៃគ្រឿងផ្សព្វផ្សាយពាក៏មានជាច្រើនប្រភេទដូចជា សំលេង រូបភាព និងការបញ្ជូនអត្ថបទ ព្រមទាំងដោយអស់ចំណាយទាបគួរសមផង (និងនៅតែចុះទៅទៀត) ។ ការនេះនាំអោយអ៊ីនធឺណេត អាចប្រើប្រាស់បានច្រើនយ៉ាងជាងបណ្តាឧបករណ៍ពាណិជ្ជកម្មអេឡិចត្រូនិចឯទៀតៗ ។ ឧបករណ៍ទាំងនេះជាទូទៅចាំបាច់ត្រូវប្រើគួបផ្សំជាមួយគ្នាវិញទៅមក ឬ ក៏ជាមួយឧបករណ៍បុរាណដ៏ជាងនេះ ដូចជាការទិញ តាមសំបុត្រ ឬចុះទិញផ្ទាល់ ដើម្បីអាចនឹងបញ្ចប់ប្រតិបត្តិការទិញដូរបាន ។ ដូច្នេះអ៊ីនធឺណេត បានកាត់បន្ថយរាំងចំពោះទំនាក់ទំនង និងពាណិជ្ជកម្មបានយ៉ាងច្រើនជាងមធ្យោបាយតាមប្រព័ន្ធអេឡិចត្រូនិច ដែលបានបង្កើតរួចជាមុន និងតាមមធ្យោបាយជាបុរាណដ៏ទៅទៀត ។

ប្រភព : WTO ពាណិជ្ជកម្មអេឡិចត្រូនិច និងតួនាទីរបស់ WTO (១៩៩៨)

ពាណិជ្ជកម្មអន្តរជាតិផ្អែកលើអ៊ីនធឺណេត

សហរដ្ឋអាមេរិកជាប្រទេសដែលមានពាណិជ្ជកម្ម ធ្វើឡើងតាមរយៈអ៊ីនធឺណេតជាច្រើន ។ ការលក់តាម អ៊ីនធឺណេត ត្រូវបានរំពឹងថា និងមានចំនួនពី២០០ពាន់ - ៣០០ពាន់ លានដុល្លានៅឆ្នាំ ២០០១ ដែលបណ្តាលជាបឋមមកពីផ្សារក្នុងស្រុក ។ ចំនួននេះស្មើនឹង ២% - ៣% នៃការលក់ក្នុងប្រទេសសរុប ។ ការប្រើប្រាស់នូវមធ្យោបាយអេឡិចត្រូនិក ក្នុងការលក់ផលិតផល និងសេវាក៏កំពុងមានការកើនឡើងដែរ នៅក្នុងប្រទេសអឺរ៉ុប ទោះបីជាវានៅមានទំហំតូចជាងពាណិជ្ជកម្មនៅក្នុងសហរដ្ឋអាមេរិកក្តី ។ ការប៉ាន់ស្មានដ៏សុក្រិតទៅលើពាណិជ្ជកម្មអន្តរជាតិ ផ្អែកនៅលើអ៊ីនធឺណេត នៅពុំទាន់មាននៅឡើយ ។ ប៉ុន្តែការប៉ាន់ស្មានប្រហាក់ប្រហែលបង្ហាញថា វាអាចមានទំហំពី ៤០ពាន់-៦០ពាន់ លានដុល្លាអាមេរិក នៅ ឆ្នាំ២០០១ ។

ពាណិជ្ជកម្មតាមអ៊ីនធឺណេត និងប្រទេសកំពុងអភិវឌ្ឍន៍

ជាទូទៅ ប្រទេសកំពុងអភិវឌ្ឍន៍ឃ្លាតឆ្ងាយពីប្រទេសជឿនលឿនជាច្រើន នៅក្នុងការមានបច្ចេកទេសចាំបាច់ សំរាប់ដំណើរការពាណិជ្ជកម្មតាមអេឡិកត្រូនិក ។ ម៉្យាងការនេះអាចបណ្តាលមកពីការអភិវឌ្ឍន៍ពុំសមស្រប នៃហេដ្ឋារចនាសម្ព័ន្ធទូរគមនាគមន៍របស់គេ ព្រមទាំងតំលៃក្នុងការប្រើប្រាស់អ៊ីនធឺណេត ។ ជាបន្ថែមលើតំលៃរបស់សំភារៈកុំព្យូទ័រជាមូលដ្ឋាន ចំណាយក្នុងការប្រើប្រាស់អ៊ីនធឺណេតក៏ពឹងផ្អែកលើកត្តាជាច្រើន រួមទាំងចំណាយបណ្តាញតភ្ជាប់ និងសំភារៈដទៃទៀត ហើយក៏នៅមានប្រាក់ខែរបស់អ្នកដំណើការតិចតួចដែរ ។

សោហ៊ុយអ៊ីនធឺណេតនៅប្រទេសកំពុងអភិវឌ្ឍន៍ អាចមានកំរិតខ្ពស់ជាងនៅប្រទេសជឿនលឿន ។ ដូច្នេះចំណាយមធ្យមសំរាប់ជាវការហៅតភ្ជាប់អ៊ីនធឺណេតនៅអាហ្វ្រិកត្រូវបាន ITU លើកឡើងថាមានចំនួន៧៥ ដុល្លាអាមេរិក ក្នុងមួយខែធៀបទៅនឹង ១០ដុល្លានៅអាមេរិក និង១៥ដុល្លានៅអង់គ្លេស ។ បើគិតពីចំណូលជាមធ្យមនៅអាហ្វ្រិកផង[៣] សោហ៊ុយជាវនេះ ស្ទើតែត្រូវហាមឃាត់ និងគ្មានជនធម្មតាណាអាចប្រើបានឡើយ ។ លើសពីនេះទៀតចំណាយក្នុងការហៅទូរសព្ទ័ក្នុងស្រុក និងចំងាយវែង ដែលផ្តល់នូវការបើកច្រកទៅកាន់អ៊ីនធឺណេតក៏អាចមានកំរិតខ្ពស់ខ្លាំងដែរនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ។

ជំនាញជាច្រើនរបស់មនុស្សដែលចាំបាច់សំរាប់ពាណិជ្ជកម្មអេឡិចត្រូនិក គឺមានលក្ខណៈខុសគ្នា ពីជំនាញដែលចាំបាច់សំរាប់ពាណិជ្ជកម្មតាមទ្រង់ទ្រាយផ្សេង។ ដរាបណាមានដំណាក់ការជាច្រើននៃការដោះដូរពាណិជ្ជកម្ម ត្រូវបានធ្វើឡើងដោយអេឡិចត្រូនិក ដរាបនោះជំនាញកាន់តែឯកទេស និងកាន់តែចាំបាច់ ។ ចំណេះដឹងពីកុំព្យូទ័រជាមូលដ្ឋាន និងចំណេះដឹង ពីអ៊ីធឺណេតគឺជាការចាំបាច់ ទោះបី គេគ្រាន់តែរាវរកផលិតផលណាមួយ នៅក្នុងបណ្តាញក៏ដោយ ។ ជំនាញខាងភាសាយ៉ាងទូលំទូលាយ ក៏អាចជាការចាំបាច់ដើម្បីបើកទំព័រអ៊ីនធឺណេតបរទេស ។ ប្រសិនបើផលិតផលមួយត្រូវធ្វើពាណិជ្ជកម្មតាមអ៊ីនធឺណេត ជំនាញក្នុងការរៀបចំគំរោងទំព័រអ៊ីនធឺណេត និងចាំបាច់ត្រូវតែមាន ហើយប្រសិនបើមានការទទួលយកការបង់ប្រាក់តាមអេឡិចត្រូនិកនោះ នោះគេក៏ត្រូវការនូវជនដែលមានជំនាញក្នុងការផ្ទេរប្រាក់តាមអេឡិកត្រូនិកដែរ ។ ខណៈដែលប្រទេសកំពុងអភិវឌ្ឍន៍ខ្លះមានការជឿនលឿន ក្នុងការអភិវឌ្ឍន៍សមត្ថភាពធនធានមនុស្ស ក៏ពួកគេភាគច្រើននៅពុំទាន់មានកម្លាំងពលកម្មដែលមានជំនាញទូលំទូលាយក្នុងផ្នែកនេះដែរ ។

ការលំបាក និងបញ្ហា

ផលប៉ះពាល់នៃពាណិជ្ជកម្មអេឡិចត្រូនិកទៅលើចំណូលថវិកា

ផលិតផលជាក់ស្តែង ដែលបានបញ្ជាទិញពីប្រទេសដទៃតាមអេឡិកត្រូនិក ត្រូវបានបញ្ជូនទៅតាមផ្លូវអាកាស ផ្លូវដែកទឹក និងសមុទ្រ ។ ពន្ធគយនៅលើទូរសព្ទ័នោះ ត្រូវប្រមូលនៅតាមព្រំដែន ដូចគ្នានឹងពន្ធគយ ដែលប្រមូលលើផលិតផលបញ្ជាទិញដោយមធ្យោបាយមិនមែនអេឡិកត្រូនិកដែរ ។

ប៉ុន្តែផលិតផលដូចជាសៀវភៅ ហ្វីល និងភ្លេង អាចនឹងធ្វើអោយទៅជាតួលេខហើយ បញ្ជូនដោយផ្ទាល់ទៅអ្នកប្រើប្រាស់តែម្តង ។ ការនេះអាចនាំអោយកើតមានស្ថានភាពមិនធម្មតា នៅពេលដែលពាណិជ្ជកម្មតាមអ៊ីនធឺណេតរីកចំរើន ។ សៀវភៅមួយ ឬ ម៉ាស៊ីនថតចម្លង CD មួយអាចនឹងត្រូវបង់ពន្ធគយនៅពេលឆ្លងកាត់ព្រំប្រទល់ តែការប្រែក្លាយវាអោយទៅជាតួលេខហើយបញ្ជូនផ្ទាល់ទៅកាន់អ្នកប្រើប្រាស់តាមអ៊ីនធឺណេត និងធ្វើអោយរួចពីពន្ធគយនេះ ។ ហើយក៏ជាការពិបាកដែរ ក្នុងការប្រមូលពន្ធលើអ៊ីនធឺណេត (ឧទាហរណ៍ពន្ធ លើតំលៃបន្ថែម ឬ លើផលលក់) នៅលើផលិតផលនោះ ។

ការការពារនូវសិទ្ធិកម្មសិទ្ធិបញ្ញា

ពាណិជ្ជករតាមអ៊ីនធឺណេតដែលកាន់តែកើនឡើង អាចបង្ករការលំបាកដល់ការអនុវត្តន៍កម្មសិទ្ធិបញ្ញា ។ ស្លាកសញ្ញាពាណិជ្ជកម្ម ប្រហាក់ប្រហែលគ្នាអាចនឹងកើតមានឡើងនៅលើទឹកដីទីទៃពីគ្នានៅក្នុងពិភពលោកដ៏គ្មានព្រំដែននៃពាណិជ្ជកម្មអេឡិចត្រូនិច ហើយក៏អាចនាំអោយមានទំនាស់ ។ បញ្ហាដែលពាក់ព័ន្ធមួយ គឺការបែងចែកនូវឈ្មោះនៃដែនកំណត់

និងការដោះស្រាយវិវាទ កើតឡើងពីការប្រើប្រាស់នូវឈ្មោះនៃដែនកំណត់ដូចគ្នា ឬ ប្រហាក់ប្រហែលគ្នា ។ នៅក្នុងគំនិតផ្តួចផ្តើមមួយ WIPO ត្រូវបានស្នើអោយធ្វើអនុសាសន៍ សំរាប់ដោះស្រាយបញ្ហាស្លាកសញ្ញាពាណិជ្ជកម្ម និងវិវាទលើឈ្មោះនៃដែនកំណត់ ព្រមទាំងធ្វើរបាយការណ៍ពីរបកគំហើញរបស់ខ្លួន ទៅកាន់នាយកដ្ឋានពាណិជ្ជកម្មរបស់សហរដ្ឋនៅឆ្នាំ ១៩៩៩ ផង ។

បញ្ហាច្បាប់ផ្សេងទៀត

ទំនាក់ទំនងពាណិជ្ជកម្ម និងជំនួញតាមរយៈមធ្យោបាយអេឡិចត្រូនិក នាំអោយកើតមានឡើងនូវសំនួរមួយចំនួន ដែលពាក់ព័ន្ធនឹងផ្នែកគតិយុត្តិ ។ ក្នុងនោះមាន : តើអ្វីទៅជាប្រភពនៃផលិតផលជួញដូរតាមអេឡិចត្រូនិច? នៅពេលណាដែលផលិតផលដែលបានបញ្ជូនដោយអេឡិចត្រូនិច គឺជាផលិតផល " ក្នុងស្រុក " និងពេលណា ជាផលិតផល "នាំចូល" ? តើពាណិជ្ជករដែលជាអ្នកប្រើមធ្យោបាយទំនាក់ទំនងអេឡិចត្រូនិចត្រូវធ្វើយ៉ាងណា នៅក្នុងស្ថានភាពមួយដែលច្បាប់ជាតិ ឬ អនុសញ្ញាអន្តរជាតិ ដែលអនុវត្តចំពោះប្រតិបត្តិការពាណិជ្ជកម្មអន្តរជាតិ ទាមទារអោយមាននូវកិច្ចព្រមព្រៀងជា " លាយលក្ខណ៍អក្សរ" ឯកសារ "ដើម" ឬ ហត្ថលេខា "គំរូ" ? តើភាពពិតនៃពត៌មាន និងត្រូវធានាបានដោយវិធីណា ដើម្បីអោយបណ្តាភាគីអាចដឹងដោយប្រាកដប្រជាបាននូវអត្តសញ្ញាណរបស់អ្នកផ្ញើនូវពត៌មានអេឡិចត្រូនិច ឬក៏អនុញ្ញាតិអោយគេបញ្ជាក់បានថា ពត៌មានអេឡិចត្រូនិច នេះពុំមានការកែប្រែឡើយ នៅពេលធ្វើការបញ្ជូន ? ភាពមិនប្រាកដប្រជាអំពីការអនុវត្តន៍ និងលទ្ធភាពនូវការសើរើឡើងវិញនូវកិច្ចសន្យាដែលបានធ្វើឡើងតាមអេឡិចត្រូនិច អាចបង្កើតជាឧបសគ្គចំពោះការអភិវឌ្ឍន៍ពាណិជ្ជកម្មអេឡិចត្រូនិចឆ្លងព្រំប្រទល់ ។ ការប្រើប្រាស់នូវមធ្យោបាយ ទំនាក់ទំនងអេឡិចត្រូនិច ឧទាហរណ៍ ក្នុងការរៀបចំ និងសំរេចនូវកិច្ចសន្យាមួយ និងក្នុងការបញ្ជូនផលិតផលមិនត្រឹមតែទាមទារនូវដំណោះស្រាយ បច្ចេកទេស គឺថែមទាំងនូវក្របខ័ណ្ឌច្បាប់ ដ៏សមស្របមួយផងដែរ ។

គំនិតផ្តួចផ្តើមថ្នាក់អន្តរជាតិមួយចំនួនត្រូវបានធ្វើឡើង ដើម្បីជួយដល់រដ្ឋាភិបាលក្នុងការដោះស្រាយនូវកង្វះខាតក្នុងច្បាប់សំរាប់អនុវត្ត ។ ឧទាហរណ៍ UNCITRAL ដែលជាអង្គភាពរបស់អង្គការសហប្រជាជាតិទទួលបន្ទុកជំរុញការធ្វើអោយស៊ីសង្វាក់គ្នា ព្រមទាំងឯកភាពនៅក្នុងច្បាប់ពាណិជ្ជកម្មអន្តរជាតិ បានអនុវត្តការងារ ដែលនាំទៅដល់ការអនុម័តច្បាប់គំរូស្តីពីពាណិជ្ជកម្មអេឡិចត្រូនិចនៅឆ្នាំ១៩៩៦ ។ ច្បាប់គំរូនេះបានបង្កើតនូវវិធាន និងបទដ្ឋានសំរាប់សុពលភាព និងការទទួលស្គាល់កិច្ចសន្យាដែលបង្កើតឡើងតាមរយៈមធ្យោបាយអេឡិចត្រូនិច ដាក់ចុះនូវវិធានក្បួយធន សំរាប់ការបង្កើតកិច្ចសន្យា និងការអនុវត្តន៍ ឱ្យនិយមន័យចំពោះចរិកលក្ខណៈរបស់ឯកសារសរសេរដោយអេឡិចត្រូនិច ដែលមានសុពលភាព ព្រមទាំងឯកសារដើម ផ្តល់ការអនុញ្ញាតិដល់ការទទួលយកនូវហត្ថលេខាអេឡិចត្រូនិច សំរាប់គោលដៅច្បាប់ និងពាណិជ្ជកម្ម ព្រមទាំងធ្វើការគាំទ្រដល់ ការដាក់ជូននូវភស្តុតាងដោយកុំព្យូទ័រ នៅក្នុងតុលាការនៅក្នុងដំណើរការក្តី ។ បណ្តារដ្ឋនានាអាចប្រើច្បាប់គំរូ ដើម្បីអនុម័តបទប្បញ្ញត្តិ ដែលនិងជួយលប់បំបាត់ឧបសគ្គផ្លូវច្បាប់ ព្រមទាំងភាពមិនប្រាកដប្រជាដែលកើតឡើង ពីពាណិជ្ជកម្មអេឡិចត្រូនិច ។ ទាំងសហរដ្ឋអាមេរិក និង ទាំង OECD បានជំរុញនូវការអភិវឌ្ឍន៍អនុសញ្ញាអន្តរជាតិ ស្តីពីប្រតិបត្តិការអេឡិចត្រូនិចផ្អែកលើច្បាប់គំរូ ។ អនុសញ្ញានោះនិងមានគោលដៅពី : លុបបំបាត់ចោលនូវរបាំងច្បាប់ផ្អែកលើក្រដាសស្នាមចំពោះប្រតិបត្តិការអេឡិចត្រូនិច និងផ្តល់នូវវិធីសាស្ត្រដ៏មានប្រសិទ្ធិភាពមួយ សំរាប់បញ្ជាក់នូវភាពពិត ។ គំនិតផ្តួចផ្តើមខ្លះ ទៀតក៏ត្រូវបានធ្វើឡើងដោយបណ្តាប្រទេសនីមួយៗ សហគមន៍អឺរ៉ុប និងអង្គការអន្តរជាតិដែរ ដើម្បីដោះស្រាយបញ្ហាច្បាប់ ដែលកើតឡើងពីពាណិជ្ជកម្មអេឡិចត្រូនិច ។ ក្នុងនោះរួមមានការផ្លោះប្តូរតាមកិច្ចសន្យា និងកិច្ចព្រមព្រៀងនៃភាគីជំនួញដែលមានបញ្ហាពាក់ព័ន្ធ និង EDI (ការផ្លោះប្តូរទិន្នន័យតាមអេឡិចត្រូនិច) EDI គឺជាប្រព័ន្ធគ្រប់គ្រងលើបញ្ជាដែលមាននិយមន័យថា ជាសំណុំនិយមន័យនៃទិន្នន័យដែលអនុញ្ញាតិ ដល់ទំរង់ជំនួញនានាអោយធ្វើការផ្តើមប្តូរបានតាមអេឡិចត្រូនិច ។ វាបានកើតមានឡើងចាប់តាំងពីពេលមានកុំព្យូទ័រ ប៉ុន្តែដោយសារវាមានលក្ខណៈស្មុគស្មាញ និងអស់ចំណាយអនុវត្តន៍ខ្ពស់ ហើយជាទូទៅ ទាមទារនូវបណ្តាញតំលៃបន្ថែម (VANS) ដែលផលិតនិងលក់ដោយក្រុមហ៊ុនតែមួយទៀតនោះ ដូចនេះវាក៏ពុំដែលទទួលការនិយមប៉ុន្មានឡើយ លើកលែងតែចំពោះក្រុមហ៊ុនធំៗ ដែលមានដៃគូរផ្គត់ផ្គង់យូរអង្វែង និងតំលៃខ្ពស់ៗ ។ ប៉ុន្តែបច្ចុប្បន្នក៏មានក្រុមហ៊ុន Software ជាច្រើនដែរ ដែលប្រាថ្នាបញ្ជូន EDI ឆ្លងតាមអ៊ីនធឺណេត ដែលនឹងអាចធ្វើអោយក្រុមហ៊ុនជំនួញតូចៗជាងនេះមានលទ្ធភាពប្រើប្រាស់បាន ហើយក៏និងជួយសន្សំសំចៃចំពោះក្រុមហ៊ុនធំៗដែរ។ ប៉ុន្តែដើម្បីអោយអ្វីទាំងនេះ អាចធ្វើទៅបាននៅលើ ថ្នាក់អន្តរជាតិ គេត្រូវតែមានស្តង់ដារសកលមួយ សំរាប់ការផ្ញើបញ្ជូននូវពត៌មាន

EDI តាមអ៊ីនធឺណេត ។ អង្គភាពថ្នាក់ជាតិ ផ្នែកសម្រួលពាណិជ្ជកម្មជាច្រើន ក៏ដូចជាអង្គការតំបន់និងអន្តរជាតិដែរ បាននឹងកំពុងធ្វើការងារនៅលើបញ្ហានេះ ។

ជាទីបញ្ចប់ ស្ទើរតែគ្រប់ប្រទេសទាំងអស់ ទាំងប្រទេសជឿនលឿន និងប្រទេសកំពុងអភិវឌ្ឍន៍ មានការព្រួយបារម្ភ អំពីខ្លឹមសារនៃអ៊ីនធឺណេត ។ នេះគឺបញ្ហាធម្មតា ពីព្រោះអ៊ីនធឺណេត មានផ្ទុកនូវប្រភពពត៌មានដែលគេត្រូវការ និងមិនត្រូវការជាច្រើន គឺមាននូវមតិផ្សេងៗគ្នាជាច្រើនអំពីបញ្ហាថាតើអ្វីខ្លះអាចជាហានិភ័យចំពោះឧត្តមគតិសាធារណជន សុវត្ថិភាព ឬ ប្រភេទដទៃទៀតនៃសំភារៈដែលមិនត្រឹមត្រូវ ។ ចំពោះភ្នាក់ងារប៉ូលិសវិញខ្លឹមសារទាំងអស់ ដែលមាននៅក្នុងអ៊ីនធឺណេត គឺស្ទើរតែពុំអាចទទួលយកបាន ។ ប៉ុន្តែ ក៏មាននូវលទ្ធភាពសំរាប់រាំងនូវច្រកចូលទៅកាន់ខ្លឹមសារដែលមិនត្រូវការនោះដែរ ។ តាមរយៈ Software ចំរាញ់យកមួយៗ ដែលបានបញ្ចូលក្នុងកុំព្យូទ័រ ឬនៅលើកំរិតជាទូទៅគឺតាមរយៈអ្នកផ្តល់សេវា អ៊ីនធឺណេតតែម្តង ។

កម្មវិធីការងាររបស់ WTO

ការប្រើប្រាស់ច្រើនឡើងៗ នូវអ៊ីនធឺណេត និងមធ្យោបាយអេឡិចត្រូនិចដទៃទៀតនៅ ក្នុងពាណិជ្ជកម្មលើទំនិញ និងសេវាកម្មអន្តរជាតិបានធ្វើអោយសមាជិក WTO នៅក្នុងសន្និសីទថ្នាក់រដ្ឋមន្ត្រី នៅហ្សឺណែវ (ធ្វើនៅ ខែឧសភា ១៩៩៨) អនុម័តនូវ "សេចក្តីប្រកាសស្តីពីពាណិជ្ជកម្មអេឡិចត្រូនិច" ដែលបានណែនាំដល់ទីស្តីការកណ្តាល អោយបង្កើតនូវកម្មវិធីការងារយ៉ាងទូលំទូលាយមួយ ដើម្បីពិនិត្យនូវបញ្ហាពាក់ព័ន្ធនិងពាណិជ្ជកម្ម ទាំងអស់ដែលទាក់ទងនឹងពាណិជ្ជកម្មអេឡិចត្រូនិចជាសកល។ សមស្របទៅតាមអាណត្តិនេះការងារត្រូវតពិនិត្យទៅលើបញ្ហាថា តើមានការកែសំរួលណា ឬ ការធ្វើអោយប្រសើរឡើងណាមួយ ចំពោះវិធានស្តីពីពាណិជ្ជកម្មលើទំនិញ និងសេវាកម្ម និងពីផ្នែកកម្មសិទ្ធិបញ្ញាជាការចាំបាច់ឬទេនោះ កំពុងតែអនុវត្តន៍ឡើងនៅក្នុងវេទិការសំខាន់ៗរបស់ WTO ។ ជាបន្ថែមលើនេះអគ្គក្រុមប្រឹក្សាបានស្នើដល់គណៈកម្មាការពាណិជ្ជកម្ម និងអភិវឌ្ឍន៍ អោយពិនិត្យលើបញ្ហាដូចជាឥទ្ធិពលនៃពាណិជ្ជកម្មអេឡិចត្រូនិចទៅលើពាណិជ្ជកម្មនៃប្រទេសកំពុងអភិវឌ្ឍន៍ និងជាពិសេសទៅលើសហគ្រាសធុនតូច និងមធ្យមនៅក្នុងប្រទេសទាំងនោះ ព្រមទាំងលើមធ្យោបាយសំរាប់ អោយពួកគេទទួលនូវផលប្រយោជន៍អតិបរិមាជាដើម ។ អគ្គក្រុមប្រឹក្សាត្រូវបានរំពឹងថា នឹងធ្វើជូននូវរបាយការណ៍ការងាររបស់ខ្លួនរួមនឹងអនុសាសន៍សកម្មភាព ចំពោះកិច្ចប្រជុំលើកទី ៣ នៃសន្និសីទថ្នាក់រដ្ឋមន្ត្រី ដែលនិងធ្វើឡើងនៅខែវិច្ឆិកា ឆ្នាំ ១៩៩៩ ។

ពន្ធគយនៅលើប្រតិបត្តិការអេឡិចត្រូនិច

នៅក្នុងសេចក្តីប្រកាសដដែលនោះ បណ្តាសមាជិកបានយល់ព្រមបន្ត (រហូតដល់សន្និសីទថ្នាក់រដ្ឋមន្ត្រី) នូវការអនុវត្តន៍បច្ចុប្បន្នដែលភាគច្រើននៃពួកគេមិនយកពន្ធគយលើការបញ្ជូនតាមអេឡិចត្រូនិក (ផលិតផលដែលមានលក្ខណៈជាតួរលេខ) ។ សេចក្តីសំរេចអំពីករណី ថាតើសេចក្តីប្រកាសនោះ គួរតែត្រូវបានពង្រីក និងធ្វើអោយទៅជាកាតព្វកិច្ចចងភ្ជាប់ និងត្រូវធ្វើឡើងនៅក្នុងសន្និសីទថ្នាក់រដ្ឋមន្ត្រី លើកទី៣ ដោយផ្អែកទៅលើលទ្ធផលជឿនលឿននៃកម្មវិធីការងាររបស់អគ្គមីប្រឹក្សា ។

សរុបមក

តំលៃនៃពាណិជ្ជកម្មអេឡិចត្រូនិចពោល គឺលក្ខណៈសំខាន់ច្រើនឡើងៗ នៃពាណិជ្ជកម្មអន្តរជាតិ ត្រូវបានរំពឹងថា នឹងមានការកើនឡើងយ៉ាងសម្បើមនៅក្នុងសតវត្សខាងមុខ ។ ដើម្បីចូលរួមនៅក្នុងពាណិជ្ជកម្មនេះ បណ្តាប្រទេសចាំបាច់ត្រូវកសាងសមត្ថភាពរបស់ខ្លួន ក្នុងការធ្វើពាណិជ្ជកម្មបែបនេះជាកិច្ចការអាទិភាពមួយ ។ ប៉ុន្តែការលំបាកក្នុងការធ្វើដូច្នេះ ពុំគួរត្រូវមើលស្រាលឡើយ ។ បណ្តាប្រទេសចាំបាច់ ត្រូវវិនិយោគទាំងនៅលើហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងមនុស្ស ។ នៅលើការអប់រំ និងបណ្តុះបណ្តាលឯកទេស ព្រមទាំងផ្តល់នូវក្របខ័ណ្ឌច្បាប់សមស្រប សំរាប់អនុវត្តន៍ពាណិជ្ជកម្មដោយអេឡិចត្រូនិកផងដែរ ។

មជ្ឈមណ្ឌលពាណិជ្ជកម្មអន្តរជាតិ

UNCTAD

អង្គការពាណិជ្ជកម្មអន្តរជាតិ

មជ្ឈមណ្ឌលពាណិជ្ជកម្មអន្តរជាតិ UNCTAD/WTO (ITC) គឺជាស្ថាប័នការកណ្តាលនៅក្នុងប្រព័ន្ធអង្គការសហប្រជាជាតិ ទទួលបន្ទុកសហប្រតិបត្តិការបច្ចេកទេសជាមួយបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ ដើម្បីជំរុញវិស័យពាណិជ្ជកម្ម ។ ITC ត្រូវបានបង្កើតឡើង ដោយកិច្ចព្រមព្រៀងទូទៅស្តីពីពន្ធគយ និងពាណិជ្ជកម្ម (GATT) ក្នុងឆ្នាំ ១៩៦៤ ហើយចាប់ពីឆ្នាំ១៩៦៨ មក អង្គការនេះបានដំណើរការរួមគ្នាតាម GATT (បច្ចុប្បន្នជាអង្គការពាណិជ្ជកម្មពិភពលោក ឬហៅកាត់ថា WTO) និងជាមួយអង្គការសហប្រជាជាតិ ហើយអង្គការសហប្រជាជាតិ ដំណើរការតាមរយៈសន្និសីទអង្គការសហប្រជាជាតិស្តីពីពាណិជ្ជកម្ម និងការអភិវឌ្ឍន៍ (UNCTAD) ។ ក្នុងនាមជាទីភ្នាក់ងារប្រតិបត្តិរបស់កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) មជ្ឈមណ្ឌលពាណិជ្ជកម្មអន្តរជាតិ (ITC) មានភារកិច្ចទទួលខុសត្រូវដោយផ្ទាល់លើការអនុវត្តន៍គំរោងទាំងឡាយណាដែលបានទទួលមូលនិធិពី UNDP នៅក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ និងប្រទេសដែលមានសេដ្ឋកិច្ចអន្តរកាលទាក់ទងទៅនឹងការជំរុញវិស័យពាណិជ្ជកម្ម ។

ITC ធ្វើការជាមួយបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ និងប្រទេសដែលមានសេដ្ឋកិច្ចអន្តរកាល ដើម្បីរៀបចំកម្មវិធីជំរុញវិស័យពាណិជ្ជកម្ម សំរាប់ពង្រីក និងកែលំអកិច្ចដំណើរការនាំចេញ និងនាំចូលរបស់ប្រទេសទាំងនោះ។ កម្មវិធីនេះ គ្របដណ្តប់ទៅលើវិស័យចំនួន ៦ មាន ÷

- ការអភិវឌ្ឍន៍ទីផ្សារ និងផលិតផល : ផ្តល់ការគាំទ្រលើការស្វែងរកទីផ្សារនាំចេញដោយផ្ទាល់ជូនដល់សហគមន៍ធុរកិច្ច តាមរយៈការផ្តល់ដំបូន្មានស្តីពីការអភិវឌ្ឍន៍ផលិតផល ការផលិតផលិតផលអោយស្របទៅតាមប្រទេសនីមួយ ៗ និងការស្វែងរកទីផ្សារអន្តរជាតិសំរាប់ទំនិញ កាមន្តសាលកម្ម និងសេវាកម្ម ។
- ការអភិវឌ្ឍន៍សេវាកម្មដែលគាំទ្រវិស័យពាណិជ្ជកម្ម: ការបង្កើត និងការពង្រីកសេវាកម្មដែលគាំទ្រដល់ពាណិជ្ជកម្មអន្តរជាតិ សំរាប់សហគមន៍ធុរកិច្ច ដែលបានផ្តល់អោយដោយស្ថាប័នសាធារណៈ និងឯកជននៅកំរិតជាតិ និងតំបន់ ។
- ពត៏មានពាណិជ្ជកម្ម: រៀបចំបង្កើតសេវាកម្មផ្តល់ពត៏មានស្តីពីពាណិជ្ជកម្មជាតិប្រកបដោយនិរន្តភាព និងការចែកចាយពត៏មាន ស្តីពីផលិតផល សេវាកម្ម ទីផ្សារ និងមុខងារជូនទៅបណ្តាសហគ្រាស និងអង្គការពាណិជ្ជកម្ម ។
- ការអភិវឌ្ឍន៍ធនធានមនុស្ស: ការពង្រឹងសមត្ថភាពស្ថាប័នជាតិ ដើម្បីបណ្តុះបណ្តាលជំនាញពាណិជ្ជកម្មអន្តរជាតិ និងរៀបចំការបណ្តុះបណ្តាលដោយផ្ទាល់ សំរាប់សហគ្រាសនានា ដែលធ្វើការនាំចេញ និងនាំចូល ។
- ការគ្រប់គ្រងការទិញ និងការផ្គត់ផ្គង់ជាអន្តរជាតិ: ប្រើប្រាស់ប្រព័ន្ធនាំចូល និងការអនុវត្តន៍ជាក់ស្តែងប្រកបដោយប្រសិទ្ធិភាព នៅក្នុងអង្គភាពពាណិជ្ជកម្មសាធារណៈ និងក្នុងសហគ្រាសនានា ដោយការពង្រឹងសេវាកម្មផ្តល់យោបល់ ដែលផ្តល់អោយដោយអង្គភាពទិញរបស់ជាតិ ទាំងសាធារណៈ និងឯកជន ។
- ការរៀបចំកម្មវិធីជំរុញវិស័យពាណិជ្ជកម្ម និងការវាយតំលៃលើគំរូវការ : ទស្សនាទានស្តីពីកម្មវិធីជំរុញវិស័យពាណិជ្ជកម្ម នៅកំរិតជាតិ និងតំបន់អាចដំណើរការបានប្រកបដោយប្រសិទ្ធិភាព អាស្រ័យទៅលើការវិភាគពីសក្តានុពល និងការដាក់កំហិតលើការផ្គត់ផ្គង់ និងការបញ្ជាក់ពីអត្តសញ្ញាណកម្ម ដែលទាក់ទងទៅនឹងតំរូវការសហប្រតិបត្តិការបច្ចេកទេស ។

ក្រៅពីគំរោងសហប្រតិបត្តិការបច្ចេកទេសជាក់លាក់ដែលអនុវត្តជាមួយបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ និងបណ្តាប្រទេសដែលមានសេដ្ឋកិច្ចអន្តរកាល ឬ ជាមួយក្រុមនៃបណ្តាប្រទេសទាំងនេះ ហើយ ITC នៅផ្តល់សេវាកម្មពីបញ្ជាការដ្ឋានរបស់គេដែលស្ថិតនៅ ទីក្រុង ហ្សឺណែវ ដែលប្រទេសទាំងឡាយអាចទទួលបានសេវាកម្មបែបនោះគ្រប់ៗគ្នា ។ សេវាកម្មទាំងនេះ រួមមានទាំងការបោះពុម្ពផ្សាយស្តីពីការជំរុញវិស័យពាណិជ្ជកម្ម ការជំរុញការនាំចេញ ការស្វែងរកទីផ្សារអន្តរជាតិ ការទិញជាអន្តរជាតិ ការគ្រប់គ្រងលើការផ្គត់ផ្គង់ និងការបណ្តុះបណ្តាលពាណិជ្ជកម្មអន្តរជាតិ ព្រមទាំងពត៏មានអន្តរជាតិ និងសេវាកម្មស្ថិតិពាណិជ្ជកម្មផ្សេងៗទៀតផង។

គោលការណ៍ណែនាំស្តីពីគោលនយោបាយដ៏ទូលំទូលាយសំរាប់ការងារសហប្រតិបត្តិការបច្ចេកទេសរបស់ ITC ត្រូវបានកំណត់ដោយអង្គភាពគ្រប់គ្រងរបស់អង្គភាពមេនៃ ITC ។ ក្រុមទីប្រឹក្សាពិគ្រោះយោបល់រួមទទួលបន្ទុកមជ្ឈមណ្ឌលពាណិជ្ជកម្មអន្តរជាតិ UNCTAD/WTO (JAG) ជាអ្នកធ្វើអនុសាសន៍ស្តីពីកម្មវិធីការងារនាពេលអនាគតរបស់ ITC ជូនទៅអង្គភាពទាំងនេះតាមរយៈសម័យប្រជុំប្រចាំឆ្នាំរបស់អន្តររដ្ឋាភិបាល។

ITC ត្រូវបានដឹកនាំដោយនាយកប្រតិបត្តិមួយរូប ។ មានបុគ្គលិកជាច្រើនរយនាក់បំពេញការងារនៅបញ្ជាការដ្ឋានរបស់ ITC និងនៅតាមការដ្ឋាននានា ។ ក្រៅពីនោះ នៅមានទីប្រឹក្សាពិគ្រោះយោបល់មួយចំនួនទៀត ដែលត្រូវបានតែងតាំងអោយទៅធ្វើការតាមគំរោងនៅក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ និងបណ្តាប្រទេសដែលមានសេដ្ឋកិច្ចអន្តរកាល ។

ពត៏មានបន្ថែម សូមទាក់ទងទៅ :

មជ្ឈមណ្ឌលពាណិជ្ជកម្មអន្តរជាតិ UNCTAD/ WTO

Palais des Nations
1211 Geneva 10
Switzerland

Tel: (41-22) 730-01 11
Fax: (41-22) 733 44 39
E-mail: itcreg@intracen.org

Website: http://www.intracen.org

លេខាធិការដ្ឋាននៃសហព័ន្ធរដ្ឋស្វយ័ត

លេខាធិការដ្ឋាននៃសហព័ន្ធរដ្ឋស្វយ័ត គឺជាអង្គការអន្តរជាតិចំបងរបស់សហព័ន្ធរដ្ឋស្វយ័ត ។ លេខាធិការដ្ឋាននេះ ត្រូវបានបង្កើតឡើង នៅក្នុងឆ្នាំ ១៩៦៥ ហើយបង្កើតទៅជាមជ្ឈមណ្ឌលសេវាកម្មស៊ីវិលផ្ទាល់របស់សហព័ន្ធរដ្ឋស្វយ័ត ដែលមានមូលដ្ឋាននៅទីក្រុង ឡុងដ៍ ហើយចាប់ផ្តើមដំណើរការប្រកបដោយប្រសិទ្ធិភាពនូវអាទិភាពរបស់រដ្ឋាភិបាលជាសមាជិកទាំង ៥៤ របស់គេ ។

លេខាធិការដ្ឋាន បំពេញការងារឆ្ពោះទៅរកការបង្កើនតំលៃជាមូលដ្ឋានរបស់សហព័ន្ធរដ្ឋស្វយ័ត រួមមានអភិបាលកិច្ចល្អ និងប្រជាធិបតេយ្យ ការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមប្រកបដោយនិរន្តភាព នីតិរដ្ឋ សិទ្ធិមនុស្ស និងសមភាពផ្នែកយេនឌ័រ ។ តួនាទីជាចំបងរបស់លេខាធិការដ្ឋាន រួមមានការជំរុញអោយមានការពិគ្រោះយោបល់អោយបានច្រើន និងការផ្លាស់ប្តូរយោបល់ទាំងនោះ ក្នុងចំណោមបណ្តាប្រទេសជាសមាជិក ការរៀបចំ និងការចែកចាយពត៌មានស្តីពីបញ្ហាពាក់ព័ន្ធ ជាពិសេសនៅក្នុងការងារអន្តរជាតិ និងសេដ្ឋកិច្ច ជំរុញការអភិវឌ្ឍន៍របស់បណ្តាប្រទេសជាសមាជិក ធ្វើសកម្មភាពជាស្នាក់ការកណ្តាល សំរាប់ស្ថាប័នជំនាញរបស់សហព័ន្ធរដ្ឋស្វយ័ត និងរៀបចំ ព្រមទាំងផ្តល់សេវាកម្មចំពោះរាល់សម័យប្រជុំអន្តររដ្ឋាភិបាល ។

សមាជិកទាំង ៥០ របស់សហព័ន្ធរដ្ឋស្វយ័ត គឺជាបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ ហើយមូលនិធិរបស់សហព័ន្ធរដ្ឋស្វយ័ត សំរាប់សហប្រតិបត្តិការបច្ចេកទេស (CFTC) គឺជាមធ្យោបាយគោលរបស់សហព័ន្ធរដ្ឋស្វយ័ត ហើយដែលតាមមធ្យោបាយនេះ សហព័ន្ធ រដ្ឋស្វយ័តជំរុញអោយមានការអភិវឌ្ឍន៍ផ្នែកសេដ្ឋកិច្ច និងសង្គមនៅក្នុងបណ្តាប្រទេសទាំងនោះ ។ មូលនិធិត្រូវបានគ្រប់គ្រងដោយលេខាធិការដ្ឋានសហព័ន្ធរដ្ឋស្វយ័ត ហើយមូលនិធិនេះ គឺជាសាខានៃការអភិវឌ្ឍន៍របស់សហព័ន្ធរដ្ឋស្វយ័ត ។ CFTC ដំណើរការតាមគោលការណ៍ជួយគ្នាទៅវិញទៅមក ដោយមានជំនួយវិភាគទានផ្នែកហិរញ្ញវត្ថុ និងជំនាញពីរដ្ឋាភិបាលតាមមូលដ្ឋានស្ម័គ្រចិត្ត និងទទួលបាននូវជំនួយការបច្ចេកទេសតាមតំរូវការ ។

នៅក្នុងគំរោងដំណើរការរបស់ CFTC លេខាធិការដ្ឋាននៃសហព័ន្ធរដ្ឋស្វយ័តកន្លងមក បានជួយដល់បណ្តាប្រទេសជាសមាជិករបស់គេបានយ៉ាងច្រើន ក្នុងការអនុវត្តន៍កម្មវិធីកំណែទំរង់សេដ្ឋកិច្ច ។ ផ្នែកអភិវឌ្ឍន៍ឧស្សាហកម្ម និងនាំចេញ (EIDD) បានផ្តល់សេវាកម្មជំនួយការបច្ចេកទេសទៅអោយបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ដែលជាសមាជិក ដើម្បីរៀបចំ និងពង្រឹងរចនាសម្ព័ន្ធជំរុញការនាំចេញសមស្រប រៀបចំអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធចាំបាច់ ពង្រីកមូលដ្ឋាននាំចេញ កែលំអស្តង់ដារគុណភាព និងពង្រីកការបើកច្រកទីផ្សារសំរាប់ផលិតផលរបស់គេ ។ ជំនួយការដែលផ្តល់អោយបណ្តាប្រទេសទាំងនោះ ដើម្បីស្វែងយល់ និងទទួលបានផលចំណេញ ពីកិច្ចព្រមព្រៀងពាណិជ្ជកម្មអន្តរជាតិថ្មីៗ គឺជាសមាសធាតុគន្លឹះនៃការងារដែលអនុវត្តដោយ EIDD ។

ទាក់ទងនឹងបញ្ហានេះ EIDD បានផ្តល់ជូននូវកម្មវិធីជំនួយការបច្ចេកទេស ដែលបានរៀបចំឡើងជាពិសេស សំរាប់ជួយអោយបណ្តាប្រទេសកំពុងអភិវឌ្ឍន៍មានលទ្ធភាពរៀបចំ និងចូលរួមបាននៅក្នុងប្រព័ន្ធពាណិជ្ជកម្មពហុភាគី ។ រដ្ឋជាសមាជិកមួយចំនួននៅក្នុងសហព័ន្ធរដ្ឋស្វយ័ត បានទទួលផលចំណេញពីជំនួយការបច្ចេកទេសនៅក្នុងសម័យប្រជុំសុំចូលជាសមាជិកនៃអង្គការ WTO ។ សមាសធាតុសំខាន់មួយនៃកម្មវិធីនេះ គឺយោបល់បច្ចេកទេសដែលបានផ្តល់ជូនទៅតំណាងទាំងឡាយនៃបណ្តាប្រទេសកំពុងអភិវឌ្ឍន៍នៃសហព័ន្ធរដ្ឋស្វយ័តនៅ WTO តាមរយៈទីប្រឹក្សាដែលធ្វើការនៅ ហ្សឺណែវ ។ EIDD ស្វែងរកការគាំទ្របន្ថែមទៀត ចំពោះវិស័យពាណិជ្ជកម្ម និងទិសដៅនៃការអភិវឌ្ឍន៍ឧស្សាហកម្មរបស់រដ្ឋជាសមាជិក តាមរយៈការផ្តួចផ្តើមគំនិត Combinet ជាបណ្តាញការងារអេឡិចត្រូនិក ដែលផ្សារភ្ជាប់ធុរកិច្ចទៅនឹងអង្គការទាក់ទងផ្នែកពាណិជ្ជកម្ម តាមរយៈសហព័ន្ធរដ្ឋស្វយ័ត ។

សូមមេត្តាទាក់ទង:

ផ្នែកអភិវឌ្ឍន៍ឧស្សាហកម្ម និងនាំចេញ (EIDD)
លេខាធិការដ្ឋាននៃសហព័ន្ធរដ្ឋស្វយ័ត
East Wing, Marlborough House
Pall Mall
London SW1Y 5HX
Telephone: (44) 020 7747 6300
Fax: (44) 020 7747 6307
Web Site: http://www.thecommonwealth.org